بيان معاني القرآن الكريم باللغة الخميرية

សេចក្តីពន្យល់អត្ថន័យនៃ
គម្ពីរអាល់ក្រូអាន
ជាភាសាខ្មែរ

សមាគមបម្រើមាតិការអ៊ីស្លាមពហុភាសា

موسوعة القرآن الكريم
QuranEnc.com



សេចក្តីពន្យល់អត្ថន័យនៃ

គម្ពីរអាល់ក្ងរអាន

ជាភាសាខ្មែរ

សមាគមបម្រើមាតិកាអ៊ីស្លាមពហុភាសា



ⓒ جمعية خدمة المحتوى الإسلامي باللغات، ١٤٤٦هـ

جمعية خدمة المحتوى الإسلامي باللغات

بيان معاني القرآن الكريم : خميرية (بدون نص)./ جمعية خدمة المحتوى الإسلامي باللغات؛ جمعية خدمة المحتوى الإسلامي باللغات ط١.. - الرياض، ١٤٤٦هـ

(٧٧٣ص) ؛ .. سم

رقم الإيداع : ٢٥٩٢/ ١٤٤٦

ردمك : ٩-١٢-٨٤٧٤-٦٠٣-٩٧٨

الطبعة الأولى ١٤٤٧ هـ

للتحقق من التحديثات

27/01/2026 (V1.0.4)

للتواصل: info@quranenc.com

نحو توفير تفاسير وتراجم موثوقة لمعاني القرآن بلغات العالم

جمعية الربوة

المحتوى الإسلامي

សេចក្តីផ្តើម

តើគម្ពីរគួរអានជាអ្វី?

គម្ពីរគួរអាន គឺជាបន្ទូលរបស់អល់ឡោះជាព្រះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់ និងជាព្រះជាម្ចាស់ដែលបានបង្កើតពួកគេ។ ទ្រង់បានបញ្ចុះវាទៅកាន់ព្យាការី និងជាអ្នកនាំសារចុងក្រោយបង្អស់ មូហាំម៉ាត់ (សូមសន្តិភាពកើតមានដល់លោក) ដើម្បីបញ្ជាក់ដល់មនុស្សលោកពីគោលបំណងនៃការបង្កើតពួកគេ និងដើម្បីចង្អុលបង្ហាញពួកគេទៅកាន់អ្វីដែលនាំមកនូវសុភមង្គលដល់ពួកគេទាំងក្នុងលោកិយ និងបរលោកខាងមុខ ក៏ដូចជាដើម្បីសង្គ្រោះមនុស្សលោកពីភាពអពមង្គលដ៏អស់កល្បជានិច្ចក្រោយពេលស្លាប់។ វាគឺជាព្រះគម្ពីរចុងក្រោយបង្អស់របស់ព្រះជាម្ចាស់ដែលត្រូវបានបញ្ចុះមកដើម្បីធ្វើការបញ្ជាក់ទៅលើព្រះគម្ពីរទាំងនោះ និងនិរាករណ៍ចោលនូវច្បាប់បញ្ញត្តិដែលមានចែងក្នុងព្រះគម្ពីរមុនៗទាំងនោះផងដែរ។

គម្ពីរគួរអាន គឺជាសញ្ញាភស្តុតាង និងជាអច្ឆរិយភាពដ៏អមតៈ។ វាគឺជាភស្តុតាងនៃភាពជាព្យាការីនៃអ្នកនាំសាររបស់អល់ឡោះ មូហាំម៉ាត់ (សូមសន្តិភាពកើតមានដល់លោក)។ អល់ឡោះជាម្ចាស់ទ្រង់បានប្រកាសឲ្យពួកជិន និងមនុស្សលោកប្រកួតប្រជែងនឹងគម្ពីរគួរអានដោយនាំមកនូវគម្ពីរមួយដែលដូចនឹងគម្ពីរគួរអាននេះ ឬសូម្បីតែមួយជំពូកដែលដូចវា។ ក៏ប៉ុន្តែពួកគេអសមត្ថភាពក្នុងការធ្វើដូច្នោះ។

គម្ពីរគួរអានគ្មានការកែប្រែ ឬផ្លាស់ប្តូរនោះឡើយចាប់ពីវាត្រូវបានបញ្ចុះមកតាំងពីជាង ១៤០០ឆ្នាំមុន ហើយវានៅតែត្រូវបានថែរក្សាជាភាសាអារ៉ាប់ ដែលជាភាសាដើមដែលគេបញ្ចុះគម្ពីរនេះមក ខណៈដែលអល់ឡោះជាម្ចាស់ទ្រង់បានធានាថែរក្សាគម្ពីរនេះ រហូតដល់អវសានៃផែនដី។

គម្ពីរគួរអាន គឺជាប្រភពមូលដ្ឋាននៃសាសនាឥស្លាម និងជាធម្មនុញ្ញដែលរៀបចំសណ្តាប់ធ្នាប់ និងវិនិច្ឆ័យទៅលើការរស់នៅរបស់មនុស្សនៅគ្រប់សម័យកាល និងគ្រប់ទីកន្លែង។ គម្ពីរគួរអានអំពាវនាវមនុស្សទៅកាន់ការគោរពសក្ការៈចំពោះព្រះអាទិទេពជាអម្ចាស់ដែលជាអ្នកបង្កើតតែមួយអង្គគត់។ វាបញ្ជាក់នូវអ្វីដែលមនុស្សលោកត្រូវការដើម្បីស្គាល់ព្រះជាម្ចាស់ និងសាសនារបស់ខ្លួន ព្រមទាំងបញ្ជាក់ពីការចាប់ផ្តើមនៃការបង្កើតចក្រវាល ដំណាក់កាលនៃការបង្កើតមនុស្ស ប្រាប់ពីរឿងរ៉ាវអាថ៌កំបាំងទាំងក្នុងអតីតកាល និងអនាគតកាល និងមានការរៀបរាប់ប្រាប់ពីប្រវត្តិរឿងរ៉ាវរបស់ បណ្តាព្យាការីជំនាន់មុនៗ ថាតើទ្រង់បានសង្គ្រោះពួកគាត់ និងបំផ្លាញសត្រូវរបស់

ពួកគាត់យ៉ាងដូចម្តេច។ នៅក្នុងគម្ពីរគួរអានផងដែរ គឺផ្តុកទៅដោយមូលដ្ឋានគ្រឹះនៃការគោរពសក្ការៈ ការទំនាក់ទំនង និងការអំពាវនាវទៅកាន់សីលធម៌ដែលគេកោតសរសើរ ព្រមទាំងព្រមានពីភាពអសីលធម៌ដែលគួរឲ្យស្អប់ខ្ពើម ក៏ដូចជាកន្លែងដែលត្រូវវិលត្រឡប់ទៅកាន់នាថ្ងៃបរលោក អាចជាឋានសួគ៌ដែលជាលំនៅឋានសម្រាប់អ្នកមានជំនឿ ឬអាចជាឋាននរកដែលជាលំនៅឋានសម្រាប់ពួកដែលបំពាន គ្មានជំនឿ។

ដោយឃើញពីសារៈសំខាន់នៃគម្ពីរដ៏ឧត្តុង្គឧត្តមនេះដែលអល់ឡោះបានបញ្ចុះជាភាសាអារ៉ាប់ ហើយទ្រង់បានបង្គាប់ប្រើឲ្យធ្វើការផ្សព្វផ្សាយទៅកាន់មនុស្សលោក យើងខ្ញុំមានក្តីសោមនស្សរីករាយសូមផ្តល់ជូនលោកអ្នកអាននូវគម្ពីរគួរអានដែលត្រូវបានប្រែសម្រួលជាខេមរភាសាដើម្បីជួយសម្រួលដល់ការយល់ពីអត្ថន័យរបស់វា និងដើម្បីសម្រេចបាននូវការផ្សព្វផ្សាយគម្ពីរនេះ។ ក្រុមការងារបានខិតខំប្រឹងប្រែងក្នុងការឈ្វេងយល់ និងបកប្រែអត្ថន័យរបស់វា ទោះជាបានដឹងច្បាស់ប្រាកដរួចទៅហើយក៏ ដោយថា ទោះបីជាខិតខំធ្វើការប្រែសម្រួលយ៉ាងលម្អិតធ្ងិតធ្ងង់យ៉ាងក៏ដោយ ក៏ភាពខ្វះចន្លោះនៅតែមានក្នុងការឈានទៅដល់អត្ថន័យដើមពិតប្រាកដដែលមាននៅក្នុងគម្ពីរគួរអានដ៏អច្ឆរិយៈនេះដែលលើសពីសមត្ថភាពរបស់មនុស្សឈានដល់។ ជនណាដែលមានបំណងចង់ដឹងបន្ថែមពីធាតុពិតដែលបាននាំមកដោយគម្ពីរគួរអាន យើងខ្ញុំសូមណែនាំឲ្យរួបគេសិក្សាភាសាអារ៉ាប់ដែលជាភាសាដើមដែលគេបញ្ចុះវាមក។

សព្វវចនាធិប្បាយគម្ពីរអាល់គួរអានុលការីម

លោកអ្នកអាចចូលទៅកាន់អត្ថន័យនៃគម្ពីរគួរអានជាខេមរភាសាដោយស្មែន ជាមួយនឹងកាមេរ៉ាទូរសព្ទ។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយចំពោះការផ្តល់យោបល់ និងការរិះគន់ក្នុងន័យស្ថាបនារបស់អស់លោកអ្នកដើម្បីអភិវឌ្ឍការបកប្រែតាមរយៈ "បង្អួចកំណត់ចំណាំ" ដែលមាននៅពីមុខវាក្យខណ្ឌនីមួយៗនៅលើគេហទំព័រ សព្វវចនាធិប្បាយគម្ពីរ
អាល់គួរអានុលការីម៖

(**www.quranenc.com**)

ប្រសិនបើលោកអ្នកមានបំណងទាក់ទងមកកាន់យើងខ្ញុំ
លោកអ្នកអាចផ្ញើអ៊ីមែលមកកាន់យើងខ្ញុំតាមរយៈ៖

info@quranenc.com

ជំពូក អាល់ហ្វាធីហះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

2. សេចក្តីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

3. ទ្រង់(ជាព្រះជាម្ចាស់)មហាសប្បុរស មហាអាណិតស្រលាញ់។

4. ជាស្តេចគ្រប់គ្រងនាថ្ងៃបរលោក។

5. ចំពោះទ្រង់(តែមួយគត់)យើងខ្ញុំគោរពសក្ការៈ ហើយចំពោះទ្រង់(តែមួយគត់)យើងខ្ញុំសុំជំនួយ។

6. សូមទ្រង់មេត្តាចង្អុលបង្ហាញយើងខ្ញុំទៅកាន់មាគ៌ាដ៏ត្រឹមត្រូវផង។

7. គឺមាគ៌ារបស់បណ្តាអ្នកដែលទ្រង់បានប្រទាននូវឧបការគុណដល់ពួកគេ ពុំមែនជា(មាគ៌ា)ពួកដែលត្រូវគេខឹងសម្បាចំពោះពួកគេ ហើយក៏ពុំមែនជា(មាគ៌ា)ពួកដែលវង្វេងនោះដែរ។

ជំពូក អាល់ហ្គាក៏អ៉ះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម។

2. នេះគឺជាគម្ពីរ(គួរអាន)ដែលគ្មានការមន្ទិលសង្ស័យឡើយនៅក្នុងវា ជាការចង្អុលបង្ហាញដល់បណ្តាអ្នកដែលកោតខ្លាច(ចំពោះអល់ឡោះ)។

3. គឺបណ្តាអ្នកដែលមានជំនឿនឹងប្រការអាថ៌កំបាំង ហើយពួកគេប្រតិបត្តិសឡាត ហើយមួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេ គឺពួកគេធ្វើការបរិច្ចាគ។

4. ហើយនិងបណ្តាអ្នកដែលមានជំនឿនឹងអ្វីដែលគេបញ្ចុះមកឱ្យកាន់អ្នក(ព្យាការីមូហាំម៉ាត់) ហើយនិងអ្វីដែលគេបញ្ចុះទៅឲ្យ(បណ្តាព្យាការី)មុនអ្នក។ ហើយពួកគេក៏មានជំនឿយ៉ាងមុតមាំនឹងថ្ងៃបរលោកផងដែរ។

5. អ្នកទាំងនោះហើយដែលស្ថិតនៅលើការចង្អុលបង្ហាញពីព្រះជាម្ចាស់របស់ពួកគេ ហើយអ្នកទាំងនោះហើយគឺជាអ្នកដែលទទួលជោគជ័យ។

6. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿនោះ ទោះបីជាអ្នក(ព្យាការីមូហាំម៉ាត់)ដាស់តឿនព្រមានពួកគេ ឬមិនដាស់តឿនព្រមានពួកគេក៏ដោយ ក៏ពួកគេនៅតែគ្មានជំនឿដដែល។

7. (ដោយសារតែ)អល់ឡោះជាម្ចាស់បានបោះត្រាភ្ជិតលើដួងចិត្តរបស់ពួកគេ និងទៅលើការស្តាប់ឮរបស់ពួកគេ ថែមទាំងបានដាក់របាំងទៅលើការមើលឃើញរបស់ពួកគេ(មិនឲ្យមើលឃើញការពិត)។ ហើយពួកគេនឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត(នៅថ្ងៃបរលោក)។

8. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលនិយាយថា៖ ពួកយើងមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោក ខណៈដែល(ជាតុពិត)ពួកគេពុំមែនជាអ្នកដែលមានជំនឿឡើយ។

9. (ពួកគេគិតស្មានថា) ពួកគេកំពុងតែបោកប្រាស់អល់ឡោះ និងបណ្តាអ្នកដែលមានជំនឿ ខណៈដែល(ជាក់ស្តែង) ពួកគេកំពុងតែបោកប្រាស់ខ្លួនឯងតែប៉ុណ្ណោះ។ ក៏ប៉ុន្តែពួកគេមិនដឹងខ្លួនឡើយ។

10. នៅក្នុងចិត្តពួកគេមានជំងឺ(មន្ទិលសង្ស័យ) ហើយអល់ឡោះបានបន្ថែមនូវជំងឺនោះដល់ពួកគេថែមទៀត។ ហើយសម្រាប់ពួកគេនឹងទទួលទណ្ឌកម្មយ៉ាងឈឺចាប់បំផុតដោយសារតែអ្វីដែលពួកគេបានបដិសេធ។

11. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេ(ពួកពុតត្បុត)ថា៖ ចូរពួកអ្នកកុំឱ្យបង្កវិនាសកម្មនៅលើផែនដី ពួកគេបានតបថា៖ តាមពិត ពួកយើងគ្រាន់តែជាអ្នកសម្របសម្រួលប៉ុណ្ណោះ។

12. តើពុំមែនទេឬ តាមពិតពួកគេគឺជាពួកដែលបង្កវិនាសកម្មទៅវិញទេ ក៏ប៉ុន្តែពួកគេមិនបានដឹងខ្លួនឡើយ។

13. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកមានជំនឿដូចអ្វីដែលមនុស្សលោក(បណ្តាអ្នកមានជំនឿ)បានជឿ ពួកគេបែរជានិយាយថា៖ តើឱ្យពួកយើងមានជំនឿដូចអ្នកដែលខ្សោយបញ្ញាបានជឿយ៉ាងដូចម្តេច? តើពុំមែនទេឬ តាមពិតពួកគេទៅវិញទេដែលជាអ្នកខ្សោយបញ្ញានោះ ក៏ប៉ុន្តែពួកគេមិនបានដឹងឡើយ។

14. ហើយនៅពេលដែលពួកគេបានជួបនឹងបណ្តាអ្នកមានជំនឿ ពួកគេនិយាយថា៖ ពួកយើងបានជឿ(ដូចពួកអ្នក)ដែរ។ តែនៅពេលដែលពួកគេបានចាកចេញ(ពីអ្នកមានជំនឿ)ទៅជួបនឹងមេដឹកនាំរបស់ខ្លួនវិញ ពួកគេបាននិយាយ(ទៅកាន់មេដឹកនាំរបស់ខ្លួន)ថា៖ ពិតប្រាកដណាស់ ពួកយើងនៅជាមួយពួកអ្នក។ តាមពិត ពួកយើងគ្រាន់តែចំអកឡកឡឺយ(ចំពោះអ្នកមានជំនឿ)ប៉ុណ្ណោះ។

15. អល់ឡោះជាម្ចាស់ទ្រង់ចំអកឡកឡឺយចំពោះពួកគេវិញ ហើយទ្រង់បណ្តោយពួកគេឲ្យស្ថិតក្នុងភាពវង្វេងរបស់ពួកគេដោយពួកគេមានភាពស្រពិចស្រពិល(ជារឿងហូត)។

16. ពួកទាំងនោះហើយជាពួកដែលយកការចង្អុលបង្ហាញប្តូរយកភាពវង្វេង។ ជាការពិតណាស់ ការធ្វើជំនួញរបស់ពួកគេបែបនេះគឺគ្មានផលចំណេញអ្វីឡើយ ហើយពួកគេក៏ពុំមែនជាពួកដែលទទួលបានការចង្អុលបង្ហាញ(ទៅកាន់ការពិត)នោះដែរ។

17. ការប្រៀបធៀបសម្រាប់ពួកគេ(ពួកពុតត្បុត)គឺប្រៀបដូចអ្នកដែលបង្កាត់ភ្លើង(ដើម្បីបំភ្លឺ)។ នៅពេលដែលភ្លើងឆេះបំភ្លឺនូវអ្វីដែលនៅជុំវិញពួកគេ អល់ឡោះក៏បានឲ្យពន្លឺ(ភ្លើង)របស់ពួកគេនោះរលត់បាត់ទៅវិញ ហើយទុកឱ្យពួកគេស្ថិតក្នុងភាពងងឹតសូន្យសុងដោយពួកគេមិនអាចមើលឃើញឡើយ។

18. (ពួកគេ)ថ្លង់ គរ ខ្វាក់ ហេតុដូច្នេះ ពួកគេមិនអាចវិលត្រឡប់(ចេញពីភាពវង្វេង)បានឡើយ។

19. ឬប្រៀបដូចជាភ្លៀងដែលធ្លាក់ពីលើមេឃដែលគ្របដណ្តប់ដោយភាពងងឹត ផ្គរន្ទះ និងផ្លេកបន្ទោរ។ ពួកគេក៏យកម្រាមដៃញ៉ាំកត្រចៀករបស់ពួកគេដើម្បីការពារពីសំឡេងន្ទះដោយភ័យខ្លាចសេចក្តីស្លាប់។ ហើយអល់ឡោះដឹងជ្រួតជ្រាបបំផុតចំពោះពួកដែលប្រឆាំង។

20. ផ្លេកបន្ទោរស្ទើតែនឹងឆាបឆក់ក្រសែភ្នែករបស់ពួកគេ។ រាល់ពេលដែលផ្លេកបន្ទោរបានជះពន្លឺដល់ពួកគេ ពួកគេបានបន្តដំណើរទៅមុខ។ តែនៅពេលដែលគ្មានពន្លឺ ពួកគេនៅឈរទ្រឹង(ដោយពួកគេមិនអាចបន្តដំណើរទៅមុខបានឡើយ)។ ហើយប្រសិនបើអល់ឡោះមានចេតនា ទ្រង់ប្រាកដជានឹងដកយកការស្តាប់ឮ និងការមើលឃើញរបស់ពួកគេជាមិនខាន។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានសមត្ថភាពលើអ្វីៗទាំងអស់។

21. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកគោរពសក្ការៈចំពោះព្រះជាម្ចាស់របស់ពួកអ្នក ជាអ្នកដែលបានបង្កើតពួកអ្នកនិងមនុស្សជំនាន់មុនពួកអ្នក។ សង្ឃឹមថា ពួកអ្នកនឹងកោតខ្លាច(ចំពោះអល់ឡោះ)។

22. ទ្រង់ជាអ្នកដែលធ្វើឲ្យផែនដីមានសណ្ឋានលាតសន្ធឹងសម្រាប់ពួកអ្នក និងបានបង្កើតមេឃជាសំណង់មួយ(នៅពីលើផែនដី)។ ហើយទ្រង់បានបញ្ចុះពីលើមេឃនូវទឹកភ្លៀង ដោយតាមរយៈទឹកភ្លៀងនេះ ទ្រង់បានបណ្តុះនូវផលានុផលជាច្រើនជាលាភសក្ការៈសម្រាប់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកុំយកអ្នកផ្សេងមកគោរពសក្ការៈរួមជាមួយនឹងអល់ឡោះឲ្យសោះ ខណៈដែលពួកអ្នកបានដឹងហើយនោះ។

23. ប្រសិនបើពួកអ្នកនៅមានមន្ទិលសង្ស័យចំពោះអ្វី(គម្ពីរគួរអាន)ដែលយើងបានបញ្ជូនមកឱ្យខ្ញុំបម្រើរបស់យើង(ព្យាការីមូហាំម៉ាត់)នោះ ចូរពួកអ្នកនាំមកនូវដំពូកមួយដែលដូចនឹងវា(គម្ពីរគួរអាន)ហើយចូរពួកអ្នកហៅសាក្សីរបស់ពួកអ្នកក្រៅពីអល់ឡោះ(ដែលមានសមត្ថភាពឲ្យមកជួយពួកអ្នកចុះ)ប្រសិនបើពួកអ្នកគឺជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកអះអាង)មែននោះ។

24. តែប្រសិនបើពួកអ្នកមិនអាចធ្វើវាបាន(ក្នុងពេលនេះ)ហើយក៏នឹងមិនអាចធ្វើវាបាន(នៅពេលខាងមុខ)នោះ ដូច្នេះ ចូរពួកអ្នកខ្លាចភ្លើងនរកដែលវត្ថុសម្រាប់បង្កាត់វានោះ គឺមនុស្ស និងដុំថ្មដែលគេត្រៀមទុកសម្រាប់ពួកដែលគ្មានជំនឿ។

25. ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលថា៖ ពិតណាស់ ពួកគេនឹងទទួលបានឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ រាល់ពេលដែលពួកគេត្រូវបានគេផ្តល់លាភសក្ការៈជាផ្លែឈើអំពីវាដល់ពួកគេ ពួកគេបាននិយាយថា៖ នេះគឺដូចជាអ្វីដែលគេផ្តាប់បានប្រទានជាលាភសក្ការៈដល់ពួកយើងកាលពីមុន(ក្នុងលោកិយ)ដែរ។ ហើយពួកគេត្រូវបានគេផ្តល់ឱ្យនូវផ្លែឈើដែលស្រដៀងគ្នា(នឹងផ្លែឈើនៅក្នុងលោកិយ តែមានរសជាតិខុសគ្នា)។ ហើយនៅក្នុងឋានសួគ៌នោះ ពួកគេមានភរិយាដ៏ស្អាតស្អំជាច្រើន ហើយពួកគេស្ថិតនៅក្នុងឋានសួគ៌នោះជាអមតៈ។

26. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនខ្មាសអៀនក្នុងការលើកជាឧទាហរណ៍អំពីសត្វមូស ឬអ្វីដែលធំជាងនេះឬតូចជាងនេះនោះឡើយ។ ចំពោះបណ្តាអ្នកដែលមានជំនឿ ពួកគេដឹងថា ពិតណាស់ វាគឺជាការពិតមកពីព្រះជាម្ចាស់របស់ពួកគេ។រីឯពួកដែលគ្មានជំនឿវិញ ពួកគេនឹងនិយាយថា៖ តើអល់ឡោះចង់បានអ្វីពីឧទាហរណ៍នេះ។ តាមរយៈឧទាហរណ៍នេះ ទ្រង់បានធ្វើឲ្យមនុស្សជាច្រើនវង្វេង ហើយតាមរយៈឧទាហរណ៍នេះផងដែរ ទ្រង់ក៏បានធ្វើឲ្យមនុស្សជាច្រើនទទួលបានការចង្អុលបង្ហាញផងដែរ។ ហើយទ្រង់មិនធ្វើឱ្យនរណាម្នាក់វង្វេងតាមរយៈវា ក្រៅពីពួកដែលប្រព្រឹត្តល្មើស(ចំពោះទ្រង់)នោះឡើយ។

27. ពួកដែលក្បត់នឹងកិច្ចសន្យារបស់អល់ឡោះបន្ទាប់ពីពួកគេបានយល់ព្រមទទួលយកកិច្ចសន្យានោះ ហើយពួកគេកាត់ផ្តាច់នូវអ្វី(ចំណងសាច់សាលោហិត)ដែលអល់ឡោះបានបញ្ជាពួកគេឱ្យផ្សារភ្ជាប់វា ព្រមទាំងបានបង្កវិនាសកម្មនៅលើផែនដីនោះ ពួកទាំងនោះហើយ គឺជាពួកដែលខាតបង់។

28. តើពួកអ្នកប្រឆាំងនឹងអល់ឡោះយ៉ាងដូចម្តេច ខណៈដែលពួកអ្នកមិនទាន់មានវត្តមានសោះ ហើយទ្រង់បានបង្កើតពួកអ្នកឱ្យមានជីវិត។ ក្រោយមក ទ្រង់ឱ្យពួកអ្នកស្លាប់ទៅវិញ បន្ទាប់មក ទ្រង់បានធ្វើឱ្យពួកអ្នករស់ឡើងវិញ(នៅថ្ងៃបរលោក)។ បន្ទាប់មកទៀត ពួកអ្នកនឹងត្រូវគេបញ្ជូនត្រឡប់ទៅកាន់ទ្រង់វិញ។

29. ទ្រង់គឺជាអ្នកដែលបានបង្កើតអ្វីៗទាំងអស់នៅលើផែនដីនេះសម្រាប់ពួកអ្នក។ បន្ទាប់មក ទ្រង់ឆ្ពោះទៅកាន់មេឃ រួចទ្រង់បានបង្កើតមេឃប្រាំពីរជាន់(នៅបន្តបន្ទាប់ពីលើគ្នា)។ ហើយទ្រង់មហាដឹងបំផុតនូវគ្រប់អ្វីៗទាំងអស់។

30. ហើយ(ចូរអ្នករំឭកដល់មនុស្សលោក)នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ពិតប្រាកដណាស់ យើងនឹងបង្កើតនូវអ្នកគ្រប់គ្រងនៅលើផែនដីនេះ។ ពួកគេបានសួរថា៖ តើទ្រង់នឹងបង្កើតនៅលើផែនដីនូវអ្នកដែលនឹងបង្កវិនាសកម្ម និងបង្ហូរឈាមគ្នាលើវា(ផែនដី)ឬ ខណៈដែលពួកយើងវិញជាអ្នកដែលលើកតម្កើងដោយការកោតសរសើរ និងបញ្ជាក់ពីភាពបរិសុទ្ធរបស់ទ្រង់នោះ? ទ្រង់បានតបវិញថា៖ ពិតប្រាកដណាស់ យើងដឹងបំផុតនូវអ្វីដែលពួកអ្នកមិនដឹង។

31. ហើយទ្រង់បានបង្រៀនព្យាការីអាហ្សាំនូវឈ្មោះអ្វីៗគ្រប់យ៉ាងទាំងអស់។ ក្រោយមក ទ្រង់បានបង្ហាញអ្វីៗទាំងនោះទៅកាន់ ម៉ាឡាអ៊ីកាត់ រួចទ្រង់បានមានបន្ទូលថា៖ ចូរពួកអ្នកប្រាប់យើងនូវឈ្មោះអ្វីៗទាំងអស់នេះមក ប្រសិនបើពួកអ្នកជាអ្នកត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកអះអាង)មែននោះ។

32. ពួកគេបានឆ្លើយថា៖ ទ្រង់មហាស្អាតស្អំ! ពួកយើងគ្មានចំណេះដឹងអ្វីឡើយ លើកលែងតែអ្វីដែលទ្រង់បានបង្រៀនពួកយើងប៉ុណ្ណោះ។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកដែលមហាដឹង មហាគតិបណ្ឌិតបំផុត។

33. ទ្រង់បានមានបន្ទូលថា៖ ឱអាហ្សាំ! ចូរអ្នកប្រាប់ពួកគេ(ម៉ាឡាអ៊ីកាត់)នូវឈ្មោះអ្វីៗទាំងអស់នោះចុះ។ ហើយនៅពេលដែលគាត់បានប្រាប់ពួកគេនូវឈ្មោះទាំងនេះរួចមក ទ្រង់បានមានបន្ទូល(ទៅកាន់ម៉ាឡាអ៊ីកាត់)ថា៖ តើយើងមិនបានប្រាប់ពួកអ្នកទេឬថា ពិតប្រាកដណាស់ យើងដឹងបំផុតនូវប្រការអោចំកំបាំងនៃមេឃជាច្រើនជាន់និងផែនដី ហើយយើងដឹងផងដែរនូវអ្វីៗដែលពួកអ្នកលាតត្រដាង និងអ្វីៗដែលពួកអ្នកបានលាក់បាំងនោះ?

34. ហើយ(ចូរអ្នកវិឬកដល់មនុស្សលោក)នៅពេលដែលយើងមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ចូរពួកអ្នកស៊ូជោត(ក្រាបគោរព)ទៅចំពោះអាហ្សាំ។ ពេលនោះ ពួកគេក៏បានស៊ូជោតទាំងអស់គ្នា លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលបានបដិសេធ និងមានអំនួត។ ហេតុនេះ វាក៏ស្ថិតក្នុងចំណោមពួកដែលប្រឆាំង(នឹងអល់ឡោះជាម្ចាស់)។

35. ហើយយើង(អល់ឡោះ)បានមានបន្ទូលថា៖ ឱអាហ្សាំ! ចូរអ្នក និងភរិយារបស់អ្នក(ហាវ៉ា)រស់នៅក្នុងឋានសួគ៌នេះចុះ ហើយចូរអ្នកទាំងពីរទទួលទានចុះនូវអ្វីដែលមាននៅក្នុងវា(ឋានសួគ៌)តាមក្តីប្រាថ្នារបស់អ្នកទាំងពីរ។ តែអ្នកទាំងពីរមិនត្រូវទៅជិតដើមឈើមួយដើមនេះ(ជាដាច់ខាត)។ បើមិនដូច្នោះទេ អ្នកទាំងពីរនឹងស្ថិតក្នុងចំណោមពួកដែលបំពានជាមិនខាន។

36. ហើយស្មែតននៅតែបន្តញុះញង់ពួកគេទាំងពីរ រហូតធ្វើឱ្យពួកគេទាំងពីរត្រូវបានគេបណ្តេញចេញពី(ឋានសួគ៌)កន្លែងដែលពួកគេធ្លាប់រស់នៅ។ ហើយយើងបានមានបន្ទូល(ទៅកាន់ពួកគេទាំងពីរ និងស្មែតន)ថា៖ ចូរពួកអ្នកចុះចេញ(ទៅរស់នៅលើផែនដី)ក្នុងភាពជាសត្រូវនឹងគ្នាចុះ។ ហើយផែនដី គឺជាកន្លែងស្នាក់អាស្រ័យរបស់ពួកអ្នក និង(ជាកន្លែង)សោយសុខរហូតដល់អវសានៃជីវិត។

37. បន្ទាប់មក ព្យាការីអាហ្សាំបានទទួលយកនូវពាក្យណែនាំពីព្រះជាម្ចាស់របស់គាត់ ហើយទ្រង់ក៏បានទទួលយកការសារភាពកំហុសរបស់គាត់។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកទទួលយកការសារភាពកំហុស ជាអ្នកអាណិតស្រលាញ់បំផុត។

38. យើងបានមានបន្ទូលថា៖ ចូរពួកអ្នកចុះចេញពីវា(ឋានសួគ៌)ទាំងអស់គ្នាចុះ។ ហើយប្រសិនបើមានការចង្អុលបង្ហាញអំពីយើងបានមកដល់ពួកអ្នក ដូចនេះ ជនណាហើយដែលបានដើរតាមការចង្អុលបង្ហាញនោះ ពួកគេគ្មានការភ័យខ្លាចអ្វីឡើយ ហើយពួកគេក៏គ្មានការព្រួយបារម្ភអ្វីនោះដែរ។

39. រីឯពួកដែលប្រឆាំង និងបានបដិសេធនឹងបណ្តាវាក្យខណ្ឌរបស់យើងនោះ ពួកគេគឺជាពួកឋាននរក ដោយពួកគេស្ថិតនៅក្នុងវាជាអមត:។

40. ឱអម្បូរអ៊ីស្រាអែល! ចូរពួកអ្នកនឹកឃើញនូវឧបការគុណដែលយើងបានប្រោសប្រទានដល់ពួកអ្នក ហើយចូរពួកអ្នកប្រកាន់ខ្ជាប់នូវកិច្ចសន្យារបស់យើង(ដែលបានដាក់ទៅលើពួកអ្នក) នោះយើងនឹងបំពេញតាមកិច្ចសន្យារបស់ពួកអ្នកវិញ។ ហើយចំពោះយើង(តែមួយគត់)ដែលពួកអ្នកត្រូវកោតខ្លាច។

41. ហើយចូរពួកអ្នកមានជំនឿចំពោះអ្វី(គម្ពីរគួរអាន)ដែលយើងបានបញ្ចុះវាដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃគម្ពីរដែលមាននៅជាមួយពួកអ្នក ហើយពួកអ្នកមិនត្រូវក្លាយខ្លួនជាក្រុមដែលប្រឆាំងនឹងវាមុនគេនោះឡើយ ហើយក៏មិនត្រូវយកបណ្តាវាក្យខណ្ឌរបស់យើងប្តូរនឹងតម្លៃបន្តិចបន្តួចនោះដែរ។ ហើយចំពោះយើង(តែមួយគត់)ដែលពួកអ្នកត្រូវកោតខ្លាច។

42. ហើយចូរពួកអ្នកកុំលាយឡំប្រការពិតជាមួយនឹងប្រការមិនពិតឱ្យសោះ។ ហើយពួកអ្នកមិនត្រូវលាក់បាំងការពិតឡើយ ខណៈដែលពួកអ្នកបានដឹង(អំពីវា)ហើយនោះ។

43. ហើយចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយចូរពួកអ្នកសឡាត(រួមគ្នា)ជាមួយនឹងបណ្តាអ្នកដែលសឡាតទាំងឡាយ។

44. តើពួកអ្នកប្រើមនុស្សឲ្យធ្វើអំពើល្អ ហើយពួកអ្នកបែរជាភ្លេចខ្លួនឯងទៅវិញ ខណៈដែលពួកអ្នកកំពុងតែសូត្រគម្ពីរ(តាវ៉ាត)បែបនេះឬ? តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

45. ហើយចូរពួកអ្នកសុំជំនួយ(ពីអល់ឡោះ)តាមរយៈការអត់ធ្មត់ និងការប្រតិបត្តិសឡាត។ ហើយពិតប្រាកដណាស់ សឡាតពិតជាមានការលំបាកជាខ្លាំង លើកលែងតែចំពោះបណ្តាអ្នកដែលខ្ជិនលំទោនប៉ុណ្ណោះ។

46. គឺបណ្តាអ្នកដែលជឿថា ពិតប្រាកដណាស់ ពួកគេនឹងជួបព្រះជាម្ចាស់របស់ពួកគេវិញ(នៅថ្ងៃបរលោក)ហើយពិតប្រាកដណាស់ ពួកគេនឹងត្រូវវិលត្រឡប់ទៅកាន់ទ្រង់វិញ។

47. ឱអម្បូរអ៊ីស្រាអែល! ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើងដែលបានប្រោសប្រទានដល់ពួកអ្នក ហើយពិតប្រាកដណាស់ យើងបានលើកតម្កើងពួកអ្នកឱ្យល្អប្រសើរជាងគេលើលោកនេះ(នៅសម័យកាលនោះ)។

48. ហើយចូរពួកអ្នកខ្លាចថ្ងៃមួយ(ថ្ងៃបរលោក)ដែលបុគ្គលម្នាក់ៗមិនអាចជួយអ្វីដល់គ្នាបាន ហើយគេក៏មិនទទួលយកការអន្តរាគមន៍ និងមិនទទួលយកការលោះពីនរណាម្នាក់ឡើយ ហើយពួកគេក៏មិនត្រូវបានគេជួយនោះដែរ(នៅក្នុងថ្ងៃនោះ)។

49. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)ខណៈដែលយើងបានសង្គ្រោះពួកអ្នកឱ្យរួចផុតពីបក្សពួកហ្វៀរអោន(ផារ៉ាអុង)ដែលពួកគេបានឱ្យពួកអ្នកភ្លក់នូវទារុណកម្មយ៉ាងព្រៃផ្សៃបំផុតដោយពួកគេសម្លាប់កូនប្រុសហើយទុកជីវិតកូនស្រីរបស់ពួកអ្នក(ដើម្បីទុកធ្វើជាទាសករ)។ ហើយនៅក្នុងរឿងនោះ គឺជាការសាកល្បងយ៉ាងធំធេងពីព្រះជាម្ចាស់របស់ពួកអ្នក។

50. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)ខណៈដែលយើងបានញែកសមុទ្រសម្រាប់ពួកអ្នក ដោយយើងបានសង្គ្រោះពួកអ្នក និងបានពន្លិចបក្សពួកហ្វៀរអោន ខណៈដែលពួកអ្នកមើលឃើញ(ផ្ទាល់នឹងភ្នែក)។

51. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)នៅពេលដែលយើងបានសន្យា(កំណត់ពេល)ជាមួយព្យាការីមូសារយៈពេលសែសិបយប់។ ក្រោយមក ពួកអ្នកបែរជាយករូបសំណាកកូនគោ(មកគោរពសក្ការៈ)បន្ទាប់ពីគាត់(អវត្តមាន)ខណៈដែលពួកអ្នកគឺជាពួកដែលបំពាន។

52. ក្រោយមក យើងបានអធ្យាស្រ័យឱ្យពួកអ្នកបន្ទាប់ពីនោះ។ សង្ឃឹមថា ពួកអ្នកនឹងដឹងគុណ(ចំពោះយើង)។

53. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)ខណៈដែលយើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត)និងជាការវិនិច្ឆ័យ(រវាងខុសនិងត្រូវ)។ សង្ឃឹមថាពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញ។

54. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)នៅពេលដែលព្យាការីមូសាបានពោលទៅកាន់ក្រុមរបស់គាត់ថាៈ ឱក្រុមរបស់ខ្ញុំ! ពួកអ្នកពិតជាបានបំពានលើខ្លួនឯងដោយយករូបសំណាក់កូនគោ(មកគោរពសក្ការៈ)។ ហេតុនេះ ចូរពួកអ្នកសារភាពកំហុសទៅកាន់ព្រះជាម្ចាស់ដែលបង្កើតពួកអ្នកដោយពួកអ្នកត្រូវសម្លាប់ខ្លួនឯង(សម្លាប់គ្នាទៅវិញទៅមក)។ នោះជាការប្រសើរសម្រាប់ពួកអ្នកនៅចំពោះមុខព្រះជាម្ចាស់របស់ពួកអ្នក ហើយទ្រង់នឹងទទួលយកការសារភាពកំហុសរបស់ពួកអ្នក។ ជាការពិតណាស់ ទ្រង់ជាអ្នកដែលទទួលយកការសារភាពកំហុស មហាអាណិតស្រលាញ់បំផុត។

55. ហើយ(ចូរពួកអ្នកនឹកឃើញ)នៅពេលដែលពួកអ្នកបាននិយាយថាៈ ឱមូសា! ពួកយើងនឹងមិនជឿលើអ្នកជាដាច់ខាតលុះត្រាតែពួកយើងបានឃើញអល់ឡោះផ្ទាល់នឹងភ្នែក។ ពេលនោះ រន្ទះបានឆក់យកជីវិតពួកអ្នកភ្លាមៗ ខណៈដែលពួកអ្នកមើលឃើញ(ផ្ទាល់នឹងភ្នែក)។

56. ក្រោយមក យើងបានប្រោសពួកអ្នកឱ្យរស់ឡើងវិញបន្ទាប់ពីការស្លាប់របស់ពួកអ្នក សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

57. ហើយយើងបានបញ្ជូនពពកឱ្យបាំងជាម្លប់ដល់ពួកអ្នកហើយយើងបានបញ្ចុះមកឱ្យពួកអ្នកនូវអាល់ម៉ាន់(កេសជ្ជៈដែលមានរសជាតិផ្អែមដូចទឹកឃ្មុំ) និងអាស់សាល់វ៉ា(បក្សីមួយប្រភេទដែលស្រដៀងនឹងសត្វក្រួច)។ (យើងបានមានបន្ទូលទៅកាន់ពួកអ្នកថាៈ) ចូរពួកអ្នកបរិភោគចំណីអាហារល្អៗដែលយើងបានប្រទានឱ្យពួកអ្នកចុះ។ ហើយពួកគេមិនបានបំពានលើយើង(ធ្វើឱ្យយើងខាតបង់)អ្វីឡើយ។ ក៏ប៉ុន្តែ ពួកគេទៅវិញទេដែលបំពានលើខ្លួនឯង។

58. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)នៅពេលដែលយើងមានបន្ទូលថាៈ ចូរពួកអ្នកចូលក្នុងស្រុកភូមិនេះ(ក្រុងយេរូសាឡឹម) ហើយចូរពួកអ្នកបរិភោគនូវអ្វីៗដែលមាននៅទីនោះដោយក្តីរីករាយតាមតែពួកអ្នកត្រូវការចុះ។ ហើយចូរពួកអ្នកចូលតាមទ្វារដោយឱនលំទោន និងបួងសួងសុំការអភ័យទោស(ពីយើង) នោះយើងនឹងអភ័យទោសដល់ពួកអ្នកចំពោះកំហុសឆ្គងរបស់ពួកអ្នក។ ហើយយើងនឹងបន្ថែម(ផលបុណ្យ)ដល់បណ្តាអ្នកដែលសាងអំពើល្អ។

59. តែពួកដែលបំពានវិញបែរជាផ្លាស់ប្តូរពាក្យពេចន៍ខុសពីពាក្យពេចន៍ដែលគេបាននិយាយទៅកាន់ពួកគេ។ ដូចនេះ យើងក៏បានបញ្ចុះទណ្ឌកម្មពីលើមេឃទៅលើពួកដែលបំពានដោយសារតែអ្វីដែលពួកគេបានប្រព្រឹត្តល្មើស។

60. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)ខណៈដែលព្យាការីមូសាបានសុំទ្រង់ឱ្យប្រទានទឹកដល់ក្រុមរបស់គាត់។ ពេលនោះ យើងបានមានបន្ទូលថាៈ ចូរអ្នកវាយដុំថ្មនឹងដំបងរបស់អ្នកចុះ។ ខណៈនោះ វាក៏បាញ់ទឹកចេញជាដប់ពីរន្ទ(ទៅតាមចំនួនកុលសម្ព័ន្ធរបស់ពួកគេ)។ ពិតណាស់ រាល់ក្រុមនីមួយៗ គឺដឹងនូវកន្លែងដែលខ្លួនត្រូវផឹក។ (យើងបានមានបន្ទូលទៅកាន់ពួកគេថា)ៈ ចូរពួកអ្នកបរិភោគ និងផឹកអំពីលាភសក្ការៈរបស់អល់ឡោះចុះ ហើយចូរពួកអ្នកកុំបំពាននៅលើផែនដីដោយការបង្កវិនាសកម្មឱ្យសោះ។

61. ហើយ(ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើង)ខណៈដែលពួកអ្នកបាននិយាយទៅកាន់ព្យាការីមូសាថាៈ ឱមូសា! ពួកយើងពិតជាមិនអាចអត់ទ្រាំលើ(ការបរិភោគ)ចំណីអាហារតែមួយមុខ(ដដែលៗ)បែបនេះបានឡើយ។ ហេតុនេះ ចូរអ្នកបួងសួងសុំពីព្រះជាម្ចាស់របស់អ្នកឱ្យទ្រង់បញ្ចេញឱ្យពួកយើងនូវអ្វីដែលគេបណ្តុះចេញពីដី ដូចជាដី ត្រសក់ ខ្ទឹមស សណ្តែក និងខ្ទឹមក្រហមជាដើម។ គាត់បានតបថាៈ តើពួកអ្នកសុំប្តូររបស់ដែលល្អយករបស់ដែលអន់ជាងឬ? ចូរពួកអ្នកចាកចេញទៅរស់នៅទីក្រុងណាមួយផ្សេងចុះ នោះពួកអ្នកនឹងទទួលបាននូវអ្វីដែលពួកអ្នកបានស្នើសុំជាមិនខាន។ (ដោយសារតែការប្រឆាំងរបស់ពួកគេជាបន្តបន្ទាប់)ពួកគេបានទទួលរងនូវភាពអាប់ឱនភាពក្រខ្សត់ ហើយពួកគេបានវិលត្រឡប់មកវិញដោយការខឹងសម្បាពីអល់ឡោះជាម្ចាស់។ នោះក៏ដោយសារតែពួកគេបានប្រឆាំងនឹងបណ្តាកសិ្តតាងរបស់ទ្រង់ ព្រមទាំងបានសម្លាប់ព្យាការីជាច្រើនដោយបំពាន។ ទាំងនោះគឺដោយសារតែពួកគេបានប្រព្រឹត្តល្មើស ព្រមទាំងបានបំពាន(លើព្រំដែនរបស់ទ្រង់)។

62. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ (នៃប្រជាជាតិរបស់ព្យាការីមូហាំម៉ាត់) និង (ប្រជាជាតិមុនៗដូចជា) ពួកយូដា និងពួកគ្រីស្ទាន ហើយនិងពួកសពីអ៊ីន (ជាអ្នកដែលដើរតាមបណ្តាព្យាការីមួយចំនួន) ជនណាហើយដែលមានជំនឿលើអល់ឡោះនិងថ្ងៃបរលោក ហើយនិងបានសាងទង្វើកុសលនោះ សម្រាប់ពួកគេនឹងទទួលបានផលបុណ្យពីព្រះជាម្ចាស់របស់ពួកគេ។ ហើយចំពោះពួកគេ គឺគ្មានការភ័យខ្លាចអ្វីឡើយ ហើយក៏គ្មានការព្រួយបារម្ភអ្វីនោះដែរ។

63. ហើយ (ចូរពួកអ្នកនឹកឃើញ) នៅពេលដែលយើងបានដាក់កិច្ចសន្យាទៅលើពួកអ្នក ហើយយើងបានលើកភ្នំ "តួរ" ដាក់ពីលើពួកអ្នក។ (យើងបានបញ្ជាថា៖) ចូរពួកអ្នកទទួលយកឱ្យប្រាកដប្រជា (អនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួន) នូវអ្វី (គម្ពីរតោរ៉ាត) ដែលយើងបានផ្តល់ឲ្យពួកអ្នក ហើយពួកអ្នកត្រូវចងចាំនូវអ្វីដែលមាននៅក្នុងវា សង្ឃឹមថា ពួកអ្នកនឹងកោតខ្លាច។

64. ក្រោយមក ពួកអ្នកបែរជាងាកចេញបន្ទាប់ពីនោះទៅវិញ។ ហើយប្រសិនបើគ្មានការប្រោសប្រទានពីអល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់ទេនោះ ពួកអ្នកប្រាកដជានឹងស្ថិតក្នុងចំណោមពួកដែលខាតបង់ជាមិនខាន។

65. ហើយជាការពិតណាស់ពួកអ្នក (អម្ប្រាអ៊ីស្រាអែល) បានដឹងពីរឿងរ៉ាវពួកដែលបំពានក្នុងចំណោមពួកអ្នក (ដោយការល្មើសនឹងបម្រាមចេញទៅនេសាទ) នៅថ្ងៃសៅរ៍។ ពេលនោះ យើងបានមានបន្ទូលទៅកាន់ពួកគេថា ចូរពួកឯងក្លាយទៅជាសត្វស្វាដ៏ថោកទាបចុះ។

66. ដូច្នេះ យើងបានទុករឿងរ៉ាវនេះ ជាមេរៀនមួយដើម្បីព្រមានដល់អ្នកជំនាន់នោះ និងអ្នកជំនាន់ក្រោយ ហើយក៏ជាការប្រៀនប្រដៅ (ក្រើនរំឭក) មួយសម្រាប់បណ្តាអ្នកដែលកោតខ្លាចផងដែរ។

67. ហើយ (ចូរពួកអ្នកចងចាំនូវរឿងរ៉ាវបុព្វបុរសរបស់ពួកអ្នក) នៅពេលដែលព្យាការីមូសាបាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់បានប្រើពួកអ្នកឲ្យសំឡះគោញីមួយក្បាល។ ពួកគេបានតបថា៖ តើអ្នកយកពួកយើងធ្វើជាការលេងសើចឬ? គាត់បានឆ្លើយតបវិញថា៖ ខ្ញុំសុំពីអល់ឡោះឲ្យបញ្ចៀសខ្ញុំកុំឱ្យស្ថិតក្នុងចំណោមពួកដែលល្ងង់ខ្លៅ។

68. ពួកគេបាននិយាយថា៖ សូមអ្នកសុំពីព្រះជាម្ចាស់របស់អ្នកឱ្យទ្រង់បញ្ជាក់ប្រាប់ពួកយើងពីលក្ខណៈរបស់គោញីនោះផង។ គាត់បានប្រាប់ពួកគេថា៖ ពិតប្រាកដណាស់ ទ្រង់បានមានបន្ទូលថា៖ គោញីនោះមិនចាស់ពេក ហើយក៏មិនក្មេងពេក ពោលគឺស្ថិតនៅក្នុងវ័យកណ្តាល។ ដូច្នេះ ចូរពួកអ្នកអនុវត្តតាមអ្វីដែលគេបានបញ្ជាពួកអ្នកចុះ។

69. ពួកគេបាននិយាយទៀតថា៖ សូមអ្នកសុំពីព្រះជាម្ចាស់របស់អ្នកឱ្យបញ្ជាក់ប្រាប់ពួកយើងផងពីពណ៌សម្បុររបស់គោញីនោះ។ គាត់បានប្រាប់ពួកគេថា៖ ពិតប្រាកដណាស់ ទ្រង់បានមានបន្ទូលថា៖ គោញីនោះមានពណ៌លឿងចាស់ដែលធ្វើឱ្យអ្នកទាំងឡាយដែលបានឃើញពេញចិត្ត។

70. ពួកគេបាននិយាយទៀតថា៖ សូមអ្នកសុំពីព្រះជាម្ចាស់របស់អ្នកឱ្យបញ្ជាក់ប្រាប់ពួកយើងបន្ថែមទៀតពីលក្ខណៈរបស់គោញីនោះ ព្រោះលក្ខណៈរបស់គោញីដែលបានរៀបរាប់ គឺធ្វើឲ្យពួកយើងមិនមានភាពច្បាស់លាស់នោះទេ។ ហើយពិតប្រាកដណាស់ ប្រសិនបើអល់ឡោះមានចេតនា នោះពួកយើងនឹងទទួលបានការចង្អុលបង្ហាញ (អាចរកគោញីនោះឃើញ) ជាមិនខាន។

71. គាត់បានប្រាប់ពួកគេថា៖ ពិតប្រាកដណាស់ ទ្រង់បានមានបន្ទូលថា៖ ការពិតគោញីនោះ គេមិនដែលយកទៅប្រើប្រាស់ភ្ជួររាស់ដី និងមិនដែលដឹកទឹកស្រោចស្រពដំណាំនោះទេ ព្រមទាំងមានលក្ខណៈពេញលេញ ហើយក៏គ្មានពណ៌ចម្រុះ (ក្រៅពីពណ៌លឿង) នោះដែរ។ (ខណៈនោះ) ពួកគេក៏បាននិយាយថា៖ ឥឡូវនេះ អ្នកបានផ្តល់នូវការពិត (លក្ខណៈពេញលេញរបស់គោញី) នោះហើយ។ ពេលនោះ ពួកគេក៏សំឡះគោញីនោះ ខណៈដែលពួកគេស្ទើរតែមិនអាចធ្វើបាន។

72. ហើយ(ចូរពួកអ្នកនឹកឃើញ)នៅពេលដែលពួកអ្នកបានសម្លាប់មនុស្សម្នាក់រួចពួកអ្នកបានទម្លាក់កំហុសឱ្យអ្នកដទៃក្នុងរឿងនោះ។ តែអល់ឡោះជាអ្នកលាតត្រដាងនូវអ្វីដែលពួកអ្នកបានលាក់បាំង(ពីអំពើឃាតកម្មនោះ)។

73. ពេលនោះ យើងបានមានបន្ទូលថា៖ ចូរពួកអ្នកយកផ្នែកណាមួយនៃគោញីនោះវាយទៅលើសាកសពនោះទៅ(នោះអល់ឡោះជាម្ចាស់នឹងធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញដើម្បីប្រាប់ពីឃាតករពិត)។ ក៏ដូចគ្នាដែរ អល់ឡោះនឹងធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញ(នៅថ្ងៃបរលោក)ហើយទ្រង់បង្ហាញឱ្យពួកអ្នកបានឃើញនូវសញ្ញាកស្តែងរបស់ទ្រង់ សង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

74. ក្រោយមក ដួងចិត្តរបស់ពួកអ្នកនៅតែរឹងរូសដដែលក្រោយពីហេតុការណ៍នោះ ដែលវាប្រៀបដូចជាដុំថ្ម ឬរឹងជាងដុំថ្មទៅទៀត។ ជាការពិតណាស់ ផ្នាំងថ្មខ្លះ អាចផុសទឹកចេញ ក្លាយជាទន្លេជាច្រើន។ មានផ្នាំងថ្មខ្លះ អាចប្រេះបែកធ្វើឱ្យទឹកហូរចេញក្រៅ ហើយមានផ្នាំងថ្មខ្លះទៀតធ្លាក់ពីលើភ្នំដោយសារតែការខ្លាចអល់ឡោះ។ ហើយអល់ឡោះមិនព្រងើយកន្តើយនូវអ្វីដែលពួកអ្នកកំពុងតែប្រព្រឹត្តនោះឡើយ។

75. តើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)នៅតែប្រាថ្នាចង់ឱ្យពួកគេ(ពួកយូដា)មានជំនឿចំពោះ(សាសនា)ពួកអ្នកទៀតឬ ខណៈដែលមួយក្រុមក្នុងចំណោមពួកគេបានស្តាប់ឮនូវបន្ទូលរបស់អល់ឡោះ ក្រោយមកពួកគេបានកែប្រែវា បន្ទាប់ពីពួកគេបានយល់ដឹងអំពីវា ខណៈដែលពួកគេក៏បានដឹងយ៉ាងច្បាស់(ពីបទល្មើសនៃការកែប្រែបន្ទូលអល់ឡោះ)ហើយនោះ។

76. ហើយនៅពេលដែលពួកគេបានជួបបណ្តាអ្នកមានជំនឿ ពួកគេនិយាយថា៖ ពួកយើងមានជំនឿហើយ។ តែនៅពេលដែលពួកគេនៅជាមួយក្រុមរបស់ពួកគេវិញ ពួកគេនិយាយថា៖ តើពួកអ្នកនិយាយប្រាប់ពួកគេ(អ្នកមានជំនឿ)នូវអ្វីដែលអល់ឡោះបានបើកបង្ហាញប្រាប់ពួកអ្នកដើម្បីឱ្យពួកគេយកជាអំណះអំណាងប្រឆាំងនឹងពួកអ្នកនៅចំពោះមុខព្រះជាម្ចាស់របស់ពួកអ្នកឬ? តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

77. តើពួកគេមិនដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងនូវអ្វីៗដែលពួកគេលាក់បាំង និងអ្វីៗដែលពួកគេលាតត្រដាងនោះ។

78. ហើយក្នុងចំណោមពួកគេ មានក្រុមមួយដែលមិនមានចំណេះដឹងអ្វីពីគម្ពីរ(តាវ៉ាត)នោះទេក្រៅតែពីចេះសូត្រប៉ុណ្ណោះ ហើយពួកគេគ្មានអ្វីក្រៅតែពីការស្មាននោះឡើយ។

79. ដូចនេះ ភាពវិនាសអន្តរាយ គឺសម្រាប់ពួកដែលបានសរសេរគម្ពីរដោយដៃពួកគេផ្ទាល់ រួចនិយាយ(បោកប្រាស់)ថា៖ (គម្ពីរ)នេះ គឺមកពីអល់ឡោះ ដើម្បីប្តូរវាជាមួយនឹងកម្រៃបន្តិចបន្តួច។ ដូចនេះ ភាពវិនាសអន្តរាយគឺសម្រាប់ពួកគេដោយសារតែអ្វីដែលពួកគេបានសរសេរដោយផ្ទាល់ដៃពួកគេ ហើយភាពវិនាសអន្តរាយក៏កើតមានចំពោះពួកគេផងដែរ ដោយសារតែកម្រៃដែលពួកគេទទួលបាន។

80. ហើយពួកគេបាននិយាយថា៖ ភ្លើងនរកនឹងមិនប៉ះពាល់ពួកយើងជាដាច់ខាត លើកលែងតែប៉ុន្មានថ្ងៃ(ដ៏ខ្លី)ដែលត្រូវបានគេកំណត់ប៉ុណ្ណោះ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកបានទទួលការសន្យានេះពីអល់ឡោះឬយ៉ាងណា? (ប្រសិនបើអល់ឡោះពិតជាបានសន្យាបែបនេះមែននោះ) ពិតប្រាកដណាស់ អល់ឡោះនឹងមិនក្បត់ការសន្យារបស់ទ្រង់ឡើយ។ ឬមួយក៏ពួកអ្នកចេះតែនិយាយប្រឌិតកុហកទៅលើអល់ឡោះនូវអ្វីដែលពួកអ្នកមិនបានដឹង?

81. តាមពិត ជនណាហើយដែលបានប្រព្រឹត្តអំពើអាក្រក់ ហើយបាបកម្មរបស់គេបានហ៊ុមព័ទ្ធជុំវិញខ្លួនគេនោះ ពិតប្រាកដណាស់ ពួកគេគឺជាពួកឋាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

82. រីឯបណ្ដាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលវិញនោះ ពួកគេគឺជាអ្នកឋានសួគ៌ ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

83. ហើយចូរពួកអ្នកនឹកឃើញពីកិច្ចសន្យាដែលយើងបានដាក់វាទៅលើអម្បូរអ៊ីស្រាអែលថាៈ ពួកអ្នកមិនត្រូវគោរពសក្ការៈ(ចំពោះអ្វីផ្សេង)ឡើយ លើកលែងតែចំពោះអល់ឡោះជាម្ចាស់តែមួយគត់ ហើយត្រូវធ្វើល្អចំពោះមាតាបិតា ញាតិសន្តាន ក្មេងកំព្រា និងអ្នកក្រីក្រ ហើយត្រូវនិយាយទៅកាន់មនុស្សលោកនូវពាក្យសម្ដីដែលល្អ និងត្រូវប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់។ ក្រោយមក ពួកអ្នកបែរជាងាកចេញទៅវិញ លើកលែងតែមួយចំនួនតូចក្នុងចំណោមពួកអ្នកប៉ុណ្ណោះ ខណៈដែលពួកអ្នកជាអ្នកដែលបដិសេធ។

84. ហើយចូរពួកអ្នក(ឱអម្បូរអ៊ីស្រាអែលនឹកឃើញ)ខណៈដែលយើងបានដាក់កិច្ចសន្យាលើពួកអ្នកថាៈ ពួកអ្នកមិនត្រូវបង្ហូរឈាមគ្នា និងមិនត្រូវបណ្ដេញគ្នាឯងចេញពីលំនៅឋានរបស់ពួកអ្នកនោះឡើយ។ បន្ទាប់មក ពួកអ្នកបានយល់ព្រម(ឯកភាពតាមកិច្ចសន្យានោះ) ខណៈដែលពួកអ្នកក៏បានធ្វើជាសាក្សីផងដែរ។

85. ក្រោយមក ពួកអ្នកបែរជាកាប់សម្លាប់គ្នាទៅវិញទៅមក និងបានបណ្ដេញក្រុមមួយក្នុងចំណោមពួកអ្នកចេញពីលំនៅឋានរបស់ពួកគេដោយទៅពឹងសត្រូវមកបង្កការជិះជាន់ធ្វើបាប និងរំលោភបំពានគ្នាឯងទៅវិញ ។ ហើយប្រសិនបើមានគ្នាឯងត្រូវគេចាប់ជាឈ្លើយសឹក(ក្នុងដៃសត្រូវ)បានមកកាន់ពួកអ្នក ពួកអ្នកលោះពួកគេ(ឱ្យរួចផុតពីឈ្លើយសឹក) ខណៈដែលការបណ្ដេញពួកគេ(ចេញពីលំនៅឋាន) គឺត្រូវបានហាមឃាត់ចំពោះពួកអ្នក។ តើពួកអ្នកមានជំនឿនឹងប្រការមួយចំនួនដែលមាននៅក្នុងគម្ពីរ(តាវ៉ឹត) ហើយបដិសេធចំពោះប្រការមួយចំនួនទៀតឬ? ហើយការតបស្នងចំពោះអ្នកដែលធ្វើដូច្នោះក្នុងចំណោមពួកអ្នក គឺគ្មានអ្វីក្រៅពីភាពអាប់ឱននៅក្នុងជីវិតលោកិយនោះឡើយ។ ហើយនៅថ្ងៃបរលោករូបគេនឹងត្រូវគេនាំត្រលប់ទៅកាន់ទណ្ឌកម្មយ៉ាងខ្លោចផ្សាបំផុត។ ហើយអល់ឡោះមិនព្រងើយកន្តើយចំពោះអ្វីដែលពួកអ្នកកំពុងតែប្រព្រឹត្តនោះឡើយ។

86. ពួកទាំងនោះហើយ គឺជាពួកដែលប្ដូរយកជីវិតនៅលោកិយនឹងថ្ងៃបរលោក។ ដូចនេះ គេនឹងមិនបន្ធូរបន្ថយទណ្ឌកម្មចំពោះពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេជួយនោះដែរ។

87. ហើយជាការពិតណាស់ យើងបានប្រទានឲ្យព្យាការីមូសានូវគម្ពីរ(តាវ៉ឹត) ហើយយើងបានបញ្ជូនអ្នកនាំសារជាច្រើនបន្ទាប់ពីគេ។ ហើយយើងបានប្រទានឲ្យព្យាការីអ៊ីសា កូនប្រុសរបស់ ម៉ារយ៉ាំ(យេស៊ូគ្រីស្ដបុត្ររបស់នាងម៉ារី)នូវសញ្ញាភស្ដុតាងជាច្រើន ហើយយើងបានពង្រឹងរូបគេតាមរយៈដ៏ព្រឹល។ តើគ្រប់ពេលដែលអ្នកនាំសារបានមកដល់ពួកអ្នក(ឱអម្បូរអ៊ីស្រាអែល)ដោយនាំមកឲ្យពួកអ្នកនូវអ្វីដែលមិនស្របនឹងចំណង់តណ្ហារបស់ពួកអ្នក ពួកអ្នកនាំគ្នាក្រអឺតក្រទម(មិនទទួលយក)ឬ? អ្នកខ្លះក្នុងចំណោមពួកគេ ពួកអ្នកបានបដិសេធ ហើយអ្នកខ្លះទៀត គឺពួកអ្នកបានសម្លាប់។

88. ហើយពួកគេបាននិយាយថាៈ ដួងចិត្តរបស់ពួកយើងត្រូវបានគេបិទជិត។ ផ្ទុយទៅវិញ ពួកគេត្រូវបានអល់ឡោះដាក់បណ្ដាសាដោយសារតែការប្រឆាំងរបស់ពួកគេ។ ពិតណាស់ អ្វីដែលពួកគេជឿនោះ គឺតិចតួចបំផុត។

89. ហើយនៅពេលដែលគម្ពីរមួយមកពីអល់ឡោះ(គម្ពីរគួរអាន)បានមកដល់ពួកគេដែលបញ្ជាក់នូវអ្វី(គម្ពីរតាវ៉ឹត និងគម្ពីរអ៊ីនជីល)ដែលមាននៅជាមួយពួកគេ ខណៈដែលពីមុនមក ពួកគេតែងនិយាយថា ពួកគេនឹងទទួលបានជ័យជម្នះលើពួកគ្មានជំនឿ(នៅពេលដែលព្យាការីចុងក្រោយបានមកដល់ពួកគេ)។ តែនៅពេលដែលអ្វីដែលពួកគេបានស្គាល់(គម្ពីរគួរអាន និងព្យាការីមូហាំម៉ាត់)បានមកដល់ពួកគេ ពួកគេបែរជាប្រឆាំងនឹងវាទៅវិញ។ ដូច្នេះ បណ្ដាសារបស់អល់ឡោះគឺធ្លាក់ទៅលើពួកដែលប្រឆាំង។

90. អាក្រក់បំផុតអ្វីដែលពួកគេបានប្តូរនឹងខ្លួនរបស់ពួកគេដោយពួកគេបានប្រឆាំងចំពោះអ្វីដែលអល់ឡោះបានបញ្ចុះដោយការច្រណែនឈ្នានីស ដោយសារតែទ្រង់បានផ្តល់នូវការប្រោសប្រទានរបស់ទ្រង់(ភាពជាព្យាការីនិងការបញ្ចុះគម្ពីរគួរអាន)ឲ្យជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)។ ដូចនេះ ពួកគេទទួលនូវការខឹងសម្បាទ្វេដង។ ហើយសម្រាប់ពួកដែលប្រឆាំងនឹងទទួលនូវទណ្ឌកម្មយ៉ាងអាម៉ាស់បំផុត។

91. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេ(ពួកយូដា)ថា៖ ចូរពួកអ្នកមានជំនឿចំពោះអ្វីដែលអល់ឡោះបានបញ្ចុះមក(ឲ្យព្យាការីមូហាំម៉ាត់) ពួកគេបែរជានិយាយថា៖ ពួកយើងមានជំនឿចំពោះតែអ្វីដែលគេបានបញ្ចុះមកឱ្យ(បណ្តាព្យាការី)ពួកយើងប៉ុណ្ណោះ។ ហើយពួកគេបានប្រឆាំងនឹងអ្វីដែលមកក្រោយពីនោះ ដ្បិតថាវា(គម្ពីរគួរអាន)គឺជាការពិតដែលបញ្ជាក់នូវអ្វីដែលមាននៅជាមួយពួកគេ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបទៅកាន់ពួកគេថា៖ ចុះហេតុអ្វីបានកាលពីមុនពួកអ្នកសម្លាប់បណ្តាព្យាការីរបស់អល់ឡោះបែបនេះ ប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿ(ចំពោះអ្វីដែលបានបញ្ចុះមកឲ្យពួកអ្នក)មែននោះ?

92. ហើយជាការពិតណាស់ ព្យាការីមូសាបានមកដល់ពួកអ្នកដោយនាំមកនូវសញ្ញាកស្តែងជាច្រើន(ដែលបញ្ជាក់ពីសច្ចភាពរបស់គាត់)។ ក្រោយមក ពួកអ្នកបែរជាយកកូបសំណាកកូនគោមកគោរពសក្ការៈក្រោយពីគាត់(អវត្តមានពីពួកអ្នក)ទៅវិញ ខណៈដែលពួកអ្នក គឺជាពួកដែលបំពាន។

93. ហើយ(ចូរពួកអ្នកនឹកឃើញឡើងវិញ)ខណៈដែលយើងបានដាក់កិច្ចសន្យាលើពួកអ្នក ហើយយើងបានលើកភ្នំតួរដាក់ពីលើពួកអ្នក។ (យើងបានមានបន្ទូលថា)៖ ចូរពួកអ្នកទទួលយក(ប្រកាន់ខ្ជាប់)ចុះនូវអ្វី(គម្ពីរតោរ៉ាត)ដែលយើងបានផ្តល់ឱ្យពួកអ្នកដោយមឺងម៉ាត់ ហើយចូរពួកអ្នកស្តាប់តាម។ ពួកគេបានតបថា៖ ពួកយើងបានឮហើយ តែពួកយើងមិនអនុវត្តតាមឡើយ។ ព្រោះតែភាពគ្មានជំនឿរបស់ពួកគេ ទើបធ្វើឱ្យ(ការគោរពសក្ការៈចំពោះ)រូបសំណាកកូនគោ នៅតែជក់ជាប់ក្នុងដួងចិត្តរបស់ពួកគេ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ពិតជាអាក្រក់បំផុតជំនឿដែលបានប្រើពួកអ្នក(ឱ្យប្រឆាំងនឹងអល់ឡោះ)បែបនេះ ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។

94. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ប្រសិនបើឋានសួគ៌នៅថ្ងៃបរលោកគឺសម្រាប់តែពួកអ្នក(ពួកយូដា)ដោយគ្មានអ្នកណាផ្សេងក្រៅពីពួកអ្នកអាចចូលបានមែននោះ ចូរពួកអ្នកប្រាថ្នាចង់ស្លាប់ទៅមើល៍ ប្រសិនបើពួកអ្នកគឺជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកអះអាង)មែននោះ។

95. ពួកគេនឹងមិនប្រាថ្នាចង់ស្លាប់ជាដាច់ខាតដោយសារតែអ្វី(បាបកម្ម)ដែលពួកគេបានប្រព្រឹត្តដោយដៃពួកគេផ្ទាល់។ ហើយអល់ឡោះដឹងបំផុតចំពោះពួកដែលបំពាន។

96. ហើយអ្នក(ឱព្យាការីមូហាំម៉ាត់)ពិតជានឹងឃើញថា ពួកគេជាមនុស្សដែលយកចិត្តទុកដាក់បំផុតក្នុងជីវិតរស់នៅរបស់ពួកគេនិងជាមនុស្សដែលលោភលន់ជាងពួកមុស្លីគីន(ពួកពហុទេពនិយម)ទៅទៀត។ ពួកគេម្នាក់ៗពេញចិត្តចង់បានអាយុវែងរហូតដល់មួយពាន់ឆ្នាំ។ ប៉ុន្តែទោះបីជាអាយុរបស់គេវែងយ៉ាងណាក៏ដោយ ក៏គេមិនអាចគេចផុតពីទណ្ឌកម្មរបស់អល់ឡោះបានដែរ។ ហើយអល់ឡោះឃើញបំផុតចំពោះអ្វីដែលពួកគេបានសាង។

97. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ជនណាដែលចាត់ទុកម៉ាឡាអ៊ីកាត់ជីព្រីលជាសត្រូវនោះ តាមពិត គាត់គ្រាន់តែជាអ្នកនាំយកគម្ពីរគួរអានចុះមកក្នុងដួងចិត្តរបស់អ្នក ដោយមានការអនុញ្ញាតពីអល់ឡោះដើម្បីបញ្ជាក់ទៅលើអ្វី(គម្ពីរទាំងឡាយ)ដែលមាននៅជាមួយគេ ព្រមទាំងជាការចង្អុលបង្ហាញ និងជាការផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿប៉ុណ្ណោះ។

98. ជនណាហើយដែលបានចាត់ទុកអល់ឡោះ បណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្តាអ្នកនាំសាររបស់ទ្រង់ ម៉ាឡាអ៊ីកាត់ជីព្រីល និងម៉ាឡាអ៊ីកាត់មីកាអែលជាសត្រូវនោះ ពិតប្រាកដណាស់ អល់ឡោះ គឺជាសត្រូវនឹងពួកដែលប្រឆាំង។

99. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនឱ្យអ្នក(ឱព្យាការីមូហាំម៉ាត់)នូវសញ្ញាភស្តុតាងយ៉ាងច្បាស់លាស់ជាច្រើន។ ហើយគ្មានអ្នកណាដែលប្រឆាំងនឹងសញ្ញាភស្តុតាងដ៏ច្បាស់លាស់ទាំងនោះឡើយ លើកលែងតែពួកដែលប្រព្រឹត្តល្មើសប៉ុណ្ណោះ។

100. ជាការពិតណាស់ រាល់ពេលដែលគេដាក់កិច្ចសន្យាណាមួយទៅលើពួកគេ(ពួកយូដា) ក្រុមមួយក្នុងចំណោមពួកគេបែរជានាំគ្នាបដិសេធនឹងវាទៅវិញ។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

101. ហើយនៅពេលដែលអ្នកនាំសារម្នាក់(ព្យាការីមូហាំម៉ាត់)មកពីអល់ឡោះបានមកដល់ពួកគេដើម្បីបញ្ជាក់នូវអ្វីដែលមាននៅជាមួយពួកគេនោះ ស្រាប់តែក្រុមមួយក្នុងចំណោមពួកដែលគេផ្តល់គម្ពីរឱ្យ(ពួកអះលីគីតាប)បែរជាបានបដិសេធដោយបោះគម្ពីររបស់អល់ឡោះ(គម្ពីរតោរ៉ាត)ទៅខាងក្រោយខ្នងរបស់ពួកគេទៅវិញ ហាក់ដូចជាពួកគេមិនដឹងអ្វីសោះឡើយ។

102. ហើយពួកគេបែរជាបានធ្វើតាមពាក្យកុហករបស់ស្មែតន(ដែលចោទប្រកាន់)ទៅលើរជ្ជកាលរបស់ព្យាការីស៊ូឡៃម៉ានទៅវិញ។ ហើយព្យាការីស៊ូឡៃម៉ានមិនបានប្រឆាំង(នឹងអល់ឡោះ)ទេ ក៏ប៉ុន្តែពួកស្មែតនទេដែលបានប្រឆាំងនោះ ដោយពួកវាបានបង្រៀនមន្តអាគមដល់មនុស្សលោក ហើយនិងអ្វីដែលគេបញ្ជូនទៅចំពោះម៉ាឡាអ៊ីកាត់ទាំងពីរគឺ ម៉ាឡាអ៊ីកាត់ហារូត និងម៉ារូត ដែលនៅទីក្រុងបាប៊ីឡូន។ ហើយម៉ាឡាអីកាត់ទាំងពីរនេះមិនបានបង្រៀនមន្តអាគមដល់នរណាម្នាក់នោះទេ លុះត្រាតែគេទាំងពីរបានព្រមានថាៈ តាមពិត ពួកយើងគ្រាន់តែជាអ្នកសាកល្បងចំពោះមនុស្សលោកប៉ុណ្ណោះ។ ហេតុនេះ ចូរពួកអ្នកកុំប្រឆាំង(នឹងអល់ឡោះតាមរយៈការរៀនមន្តអាគមនេះ)ឱ្យសោះ។ ពេលនោះ ពួកគេក៏បានរៀនមន្តអាគមនោះពីអ្នកទាំងពីរនូវអ្វីដែលធ្វើឱ្យប្តីប្រពន្ធបែកបាក់គ្នា។ ប៉ុន្តែអ្នកដែលចេះមន្តអាគមទាំងនោះមិនអាចធ្វើឱ្យនរណាម្នាក់មានគ្រោះថ្នាក់បានឡើយ លើកលែងតែមានការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ។ ហើយពួកគេក៏បានរៀននូវអ្វីដែលផ្តល់នូវគ្រោះថ្នាក់ដល់ពួកគេ និងគ្មានបានផលប្រយោជន៍ដល់អ្វីពួកគេទាល់តែសោះ។ ជាការពិតណាស់ ពួកគេ(ពួកយូដាទាំងនោះ)ពិតជាបានដឹងហើយថា ជនណាហើយដែលបានប្តូរយកមន្តអាគមនឹងគម្ពីររបស់អល់ឡោះនោះ រូបគេនឹងមិនទទួលបានចំណែកអ្វីឡើយនៅថ្ងៃបរលោក។ វាជាអំពើដ៏អាក្រក់បំផុតដែលពួកគេយកខ្លួនរបស់គេប្តូរយកមន្តអាគមបែបនេះ ប្រសិនបើពួកគេបានដឹង។

103. ហើយប្រសិនបើពួកគេមានជំនឿ ហើយនិងកោតខ្លាច(អល់ឡោះ)នោះ ផលបុណ្យដែលមាននៅឯអល់ឡោះ គឺល្អប្រសើរបំផុត ប្រសិនបើពួកគេបានដឹង។

104. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំប្រើពាក្យថា "រ៉ាអ៊ីណា" តែពួកអ្នកត្រូវប្រើពាក្យ "អ៊ុនហ្សុរណា"វិញ ហើយចូរពួកអ្នកស្តាប់តាម។ ហើយសម្រាប់ពួកដែលប្រឆាំងនោះ ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

105. ពួកដែលប្រឆាំងក្នុងចំណោមពួកអះលីគីតាប និងពួកមុស្លីគីន គឺពួកគេមិនពេញចិត្តចំពោះប្រការល្អដែលព្រះជាម្ចាស់របស់ពួកអ្នកបានបញ្ជូនមកឱ្យពួកអ្នកឡើយ។ ហើយអល់ឡោះជាអ្នកកំណត់ក្តីករុណារបស់ទ្រង់ចំពោះតែជនណាដែលទ្រង់មានចេតនាប៉ុណ្ណោះ។ ហើយអល់ឡោះជាម្ចាស់គឺមាននូវការប្រោសប្រទានដ៏ធំធេងបំផុត។

106. វាក្យខណ្ឌ(អាយ៉ាត់)ណាមួយដែលយើងបានផ្លាស់ប្តូរ ឬក៏ធ្វើឱ្យភ្លេចវានោះ គឺយើងបានជំនួសមកវិញនូវអ្វីដែលល្អជាង ឬប្រហាក់ប្រហែលនឹងវាក្យខណ្ឌនោះ។ តើអ្នក(ឱព្យាការីមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

107. តើអ្នក(ឱព្យាការីមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់នោះ? ហើយសម្រាប់ពួកអ្នក គឺគ្មានអ្នកគាំពារ និងអ្នកជួយក្រៅពីអល់ឡោះឡើយ។

108. តើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ចង់សួរដេញដោលអ្នកនាំសាររបស់ពួកអ្នក(ព្យាការីមូហាំម៉ាត់) ដូចដែលគេបានសួរព្យាការីមូសាកាលពីមុននោះឬ? ហើយជនណាដែលបានយកសេចក្តីជំនឿប្តូរយកភាពគ្មានជំនឿនោះ ពិតប្រាកដណាស់ រូបគេពិតជាបានវង្វេងចេញពីមាគ៌ាដ៏ត្រឹមត្រូវជាមិនខាន។

109. ភាគច្រើននៃពួកអះលីគីតាបមានបំណងចង់ត្រលប់ពួកអ្នកទៅរកភាពគ្មានជំនឿវិញបន្ទាប់ពីពួកអ្នកមានជំនឿរួចដោយសារតែការប្រឆាំង និងការច្រណែនឈ្នានីសដែលមាននៅក្នុងខ្លួនរបស់ពួកគេ ក្រោយពីការពិតបានបញ្ជាក់យ៉ាងច្បាស់ដល់ពួកគេហើយនោះ។ ហេតុនេះ ចូរពួកអ្នកអភ័យទោស និងអធ្យាស្រ័យ(ដល់ពួកគេ)រហូតដល់អល់ឡោះនាំមកនូវបទបញ្ជារបស់ទ្រង់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

110. ហើយចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់។ ហើយអ្វីក៏ដោយដែលពួកអ្នកបានសាងវាសម្រាប់ខ្លួនឯងនៃប្រការល្អនោះ ពួកអ្នកនឹងទទួលបានវាពីអល់ឡោះ(នៅថ្ងៃបរលោក)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាឃើញបំផុតនូវអ្វីដែលពួកអ្នកបានប្រព្រឹត្ត។

111. ហើយពួកគេ(យូដា និងគ្រឹស្ទាន)បាននិយាយថា៖ គ្មានអ្នកណាអាចចូលឋានសួគ៌ជាដាច់ខាត លើកលែងតែអ្នកដែលកាន់សាសនាយូដា ឬកាន់តាមសាសនាគ្រឹស្តប៉ុណ្ណោះ។ ទាំងនេះគ្រាន់តែជាការស្រមើស្រមៃរបស់ពួកគេប៉ុណ្ណោះ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកបង្ហាញភស្តុតាងរបស់ពួកអ្នកមក ប្រសិនបើពួកអ្នកជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកបានអះអាង)មែននោះ។

112. តាមពិត(អ្នកដែលអាចចូលបានឋានសួគ៌)នោះ គឺរាល់អ្នកដែលប្រគល់ខ្លួនរបស់គេដោយស្មោះសចំពោះអល់ឡោះ និងជាមនុស្សល្អ ដោយរូបគេនឹងទទួលបានផលបុណ្យពីព្រះជាម្ចាស់របស់គេ។ ហើយពួកគេគ្មានការភ័យខ្លាច ហើយក៏គ្មានទុក្ខព្រួយអ្វីនោះដែរ។

113. ពួកយូដាបាននិយាយថា៖ ពួកគ្រឹស្ទានពុំស្ថិតនៅលើ(សាសនាដែលត្រឹមត្រូវ)អ្វីនោះទេ ហើយពួកគ្រឹស្ទានវិញក៏បាននិយាយដែរថា៖ ពួកយូដាក៏ពុំស្ថិតនៅលើ(សាសនាដែលត្រឹមត្រូវ)អ្វីនោះដែរ ខណៈដែលពួកគេ(ទាំងពីរក្រុម)សូត្រគម្ពីរ(របស់ពួកគេរៀងៗខ្លួន)។ ក៏ដូចគ្នាដែរ ពួក(មុស្លីគីន)ដែលមិនបានយល់ដឹងអ្វីសោះនោះ ក៏បាននិយាយដូចពាក្យសម្តីរបស់ពួកគេដែរ។ ហេតុនេះ អល់ឡោះជាម្ចាស់ទ្រង់នឹងកាត់ក្តីរវាងពួកគេនៅថ្ងៃបរលោកចំពោះអ្វីដែលពួកគេបានខ្វែងគំនិតគ្នា។

114. ហើយគ្មានជនណាម្នាក់ដែលជាអ្នកបំពានខ្លាំងជាងអ្នកដែលបានរារាំងអ្នកដទៃមិនឱ្យរំឭកព្រះនាមអល់ឡោះនៅក្នុងម៉ាស្ជិតរបស់ទ្រង់ ហើយថែមទាំងព្យាយាមបំផ្លិចបំផ្លាញវានោះឡើយ។ ពួកទាំងនោះ ពួកគេមិនហ៊ានចូលម៉ាស្ជិតនោះទេ លើកលែងតែក្នុងលក្ខណៈភ័យខ្លាចប៉ុណ្ណោះ។ ពួកគេនឹងទទួលបានភាពអាម៉ាស់នៅក្នុងលោកិយនេះ ហើយនៅថ្ងៃបរលោកពួកគេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

115. ហើយទិសខាងកើតនិងទិសខាងលិច គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហេតុនេះ ទោះបីជាពួកអ្នកតម្រង់ទៅរកទិសណាក៏ដោយ ក៏ពួកអ្នកបានតម្រង់ទៅកាន់អល់ឡោះដែរ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់វិសេសវិសាលមហាដឹងបំផុត។

116. ហើយពួកគេ(ពួកយូដា ពួកណាសរ៉ានី និងពួកមុស្លីគីន)បាននិយាយថា៖ អល់ឡោះជាម្ចាស់ទ្រង់មានបុត្រ។ ទ្រង់មហាស្អាតស្អំបំផុត(អំពីរឿងនេះ)។ ផ្ទុយទៅវិញ អ្វីៗដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ រាល់អ្វីៗទាំងអស់ គឺឱនលំទោនទៅចំពោះទ្រង់។

117. អល់ឡោះជាអ្នកបង្កើតមេឃជាច្រើនជាន់និងផែនដីដោយគ្មានគំរូពីមុនឡើយ។ ហើយនៅពេលដែលទ្រង់មានចេតនាចង់សម្រេចកិច្ចការអ្វីមួយ ទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" នោះវានឹងកើតឡើងភ្លាម។

118. ហើយពួកដែលគ្មានចំណេះដឹង(ក្នុងចំណោមពួកអះលីគីតាប និងពួកមុស្លីគីន)បាននិយាយថា៖ ហេតុអ្វីបានជាអល់ឡោះមិនមានបន្ទូលមកកាន់ពួកយើងដោយផ្ទាល់ ឬផ្តល់ជាសញ្ញាកស្តុតាងណាមួយឲ្យពួកយើងតែម្តងទៅ? ក៏ដូចគ្នាដែរ អ្នកជំនាន់មុនៗពួកគេក៏បាននិយាយដូចសម្តីរបស់ពួកគេនេះដែរ ព្រោះដួងចិត្តរបស់ពួកគេ គឺស្រដៀងៗគ្នា។ ពិតប្រាកដណាស់ យើង(អល់ឡោះ)ពិតជាបានបញ្ជាក់យ៉ាងច្បាស់នូវកស្តុតាងជាច្រើនសម្រាប់ក្រុមដែលមានជំនឿជឿជាក់យ៉ាងពិតប្រាកដ។

119. ជាការពិតណាស់ យើងបានបញ្ជូនអ្នក(ព្យាការីមូហាំម៉ាត់)មកយ៉ាងពិតប្រាកដដើម្បីផ្តល់ដំណឹងរីករាយ និងដាស់តឿនព្រមាន។ ហើយអ្នកនឹងមិនត្រូវបានគេសួរអំពីពួកនរកដើហ៊ឹមឡើយ។

120. ហើយពួកយូដា និងពួកគ្រីស្ទាននឹងមិនពេញចិត្តចំពោះអ្នក(ព្យាការីមូហាំម៉ាត់)ជាដាច់ខាត លុះត្រាតែអ្នកដើរតាមសាសនាពួកគេ។ ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ ការចង្អុលបង្ហាញរបស់អល់ឡោះ ទើបជាការចង្អុលបង្ហាញដ៏ត្រឹមត្រូវ។ ហើយប្រសិនបើអ្នកដើរតាមចំណង់តណ្ហារបស់ពួកគេ ក្រោយពីចំណេះដឹងបានមកដល់អ្នកហើយនោះ ពិតប្រាកដណាស់ អ្នកពិតជាគ្មានអ្នកគាំពារ និងអ្នកជួយមកពីអល់ឡោះឡើយ។

121. អ្នកដែលយើង(អល់ឡោះ)បានប្រទានគម្ពីរទៅឱ្យពួកគេដោយពួកគេបានសូត្រវានូវការសូត្រយ៉ាងត្រឹមត្រូវនោះ អ្នកទាំងនោះហើយគឺជាអ្នកដែលមានជំនឿចំពោះវា។ ហើយជនណាដែលប្រឆាំងចំពោះវា ពិតណាស់ពួកទាំងនោះគឺជាពួកដែលខាតបង់។

122. ឱអម្បូរអ៊ីស្រាអែល! ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់យើងដែលយើងបានប្រោសប្រទានដល់ពួកអ្នក ហើយពិតប្រាកដណាស់ យើងបានលើកតម្កើងពួកអ្នកឱ្យល្អប្រសើរជាងគេលើលោកនេះ(នៅសម័យកាលនោះ)។

123. ហើយចូរពួកអ្នកខ្លាចថ្ងៃមួយ(ថ្ងៃបរលោក)ដែលបុគ្គលម្នាក់មិនអាចជួយអ្វីដល់គ្នាបាន ហើយគេមិនទទួលយកការលោះពីនរណាម្នាក់នោះទេ ហើយការអន្តរាគមន៍គ្មានផ្តល់ជាប្រយោជន៍ដល់នរណាម្នាក់ឡើយ ហើយពួកគេក៏មិនត្រូវបានគេជួយនោះដែរ។

124. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលអល់ឡោះបានសាកល្បងព្យាការីអ៊ីព្រហ៊ីមនូវពាក្យពេចន៍(បទបញ្ជានិងក្បួនច្បាប់)ជាច្រើន ហើយគាត់ក៏បានអនុវត្តវាយ៉ាងពេញលេញ។ ទ្រង់បានមានបន្ទូលថា៖ ពិតប្រាកដណាស់ យើងនឹងចាត់តាំងអ្នកធ្វើជាមេដឹកនាំសម្រាប់មនុស្សលោក។ គាត់បានតបវិញថា៖ សូមទ្រង់មេត្តាយកពីក្នុងចំណោមពូជអម្បូររបស់ខ្ញុំ(ធ្វើជាមេដឹកនាំ)ផង។ ទ្រង់បានមានបន្ទូលថា៖ ការសន្យារបស់យើង គឺមិនកើតមានចំពោះពួកដែលបំពានឡើយ។

125. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលយើងបានបង្កើតពៃទុលឡោះ ជាទីជ្រកកោនសម្រាប់មនុស្សលោក និងជាកន្លែងដែលមានសុខសន្តិភាព។ (ទ្រង់បានមានបន្ទូលថា៖) ចូរពួកអ្នកយកម៉ាកមអ៊ីព្រហ៊ីមធ្វើជាកន្លែងសឡាត(ថ្វាយបង្គំ)ចុះ។ ហើយយើងបានផ្តែផ្តាំទៅចំពោះព្យាការីអ៊ីព្រហ៊ីម និងព្យាការីអ៊ីស្មាឯលឱ្យសម្អាតពៃទុលឡោះអំពីភាពកខ្វក់សម្រាប់អ្នកតវ៉ាហ្វ(ដើរប្រទក្សិណ) អ្នកអៀកទីកាហ្វ និងអ្នកសឡាតទាំងឡាយ។

126. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលព្យាការីអ៊ីព្រហ៊ីមបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមទ្រង់ធ្វើឱ្យទីកដី(ម៉ាក្កះ)នេះជាទីកដ៏ដែលមានសុខសន្តិភាព ហើយសូមទ្រង់មេត្តាប្រទានលាភសក្ការៈដល់អ្នកដែលនៅទីនេះនូវផែលានុផលគ្រប់ប្រភេទចំពោះជនណាដែលមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោកក្នុងចំណោមពួកគេផងចុះ។ ទ្រង់បានមានបន្ទូលថា៖ ហើយចំពោះជនណាដែលប្រឆាំងនោះ យើងនឹងផ្តល់ឱ្យគេនូវការសោយសុខមួយរយៈពេលខ្លី(នៅក្នុងលោកិយ)។ បន្ទាប់មកនៅថ្ងៃបរលោក គេនឹងចាប់ទាញពួកគេទាំងបង្ខំទៅកាន់ទណ្ឌកម្មភ្លើងនរក ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

127. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្យាការីអ៊ីព្រហ៊ីម និងព្យាការីអ៊ីស្មាឯលបានតម្លើងគ្រឹះកាក់ហ្គះ។ (គាត់ទាំងពីរបានបួងសួងថា៖) បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាទទួលយក(ទង្វើកុសល)អំពីយើងខ្ញុំផង។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

128. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាធ្វើឱ្យយើងទាំងពីរក្លាយជាអ្នកប្រគល់ខ្លួន(ជាជនមូស្លីម)ហើយសូមទ្រង់មេត្តាបង្កើតឱ្យមានក្នុងចំណោមពូជពង្សរបស់ពួកយើងនូវប្រជាជាតិដែលប្រគល់ខ្លួន(ជាជនមូស្លីម)ចំពោះទ្រង់ផង។ ហើយសូមទ្រង់មេត្តាផ្តល់ឱ្យពួកយើងបានយល់ដឹងពីរបៀបនៃការគោរពសក្ការៈចំពោះទ្រង់ និងទទួលយកនូវការសោរភាពកំហុសរបស់ពួកយើងផង។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកដែលទទួលយកនូវការសោរភាពកំហុស មហាអាណិតស្រលាញ់បំផុត។

129. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាតែងតាំងទៅកាន់ពួកគេនូវអ្នកនាំសារម្នាក់ដែលចេញអំពីពួកគេផង ដើម្បីឱ្យគេ(អ្នកនាំសារ)សូត្រនូវបណ្តាវាក្យខណ្ឌរបស់ទ្រង់ឱ្យពួកគេស្តាប់ ហើយបង្រៀននូវគម្ពីរ(គួរអាន)និងគតិបណ្ឌិត(ស៊ុណ្ណៈ)ដល់ពួកគេ ព្រមទាំងជម្រះសម្អាតពួកគេ(ពីប្រការស្ទើរែកនិងអំពើបាប)ផងចុះ។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

130. ហើយគ្មានជនណាដែលមិនពេញចិត្តសាសនារបស់ព្យាការីអ៊ីព្រហ៊ីមឡើយ លើកលែងតែអ្នកដែលល្ងង់ខ្លៅខ្លួនឯងប៉ុណ្ណោះ។ ពិតប្រាកដណាស់ យើងបានជ្រើសរើសគេនៅក្នុងលោកិយនេះ(ជាអ្នកនាំសារ និងជាអ្នកជំនិតរបស់យើង)។ ហើយពិតណាស់នៅថ្ងៃបរលោក រូបគេគឺស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

131. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្រះជាម្ចាស់របស់គាត់បានមានបន្ទូលទៅកាន់គាត់ថា៖ ចូរអ្នកប្រគល់ខ្លួន(ក្លាយជាអ្នកមូស្លីម)។ គាត់បានតបថា៖ ខ្ញុំសូមប្រគល់ខ្លួន(ក្លាយជាអ្នកមូស្លីម)ចំពោះព្រះជាម្ចាស់នៃពិភពទាំងអស់។

132. ហើយព្យាការីអ៊ីព្រហ៊ីមបានផ្តាំផ្ញើទៅចំពោះកូនចៅរបស់គាត់នឹងពាក្យពេចន៍ទាំងនេះ ហើយព្យាការីយ៉ាក់កូបក៏ដូចគ្នាដែរ។ (គាត់ទាំងពីរផ្តែផ្តាំថា៖) ឱកូនៗរបស់យើង! ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានជ្រើសរើសសាសនា(អ៊ីស្លាម)សម្រាប់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកុំទាន់ស្លាប់ លើកលែងតែពួកអ្នកស្ថិតក្នុងភាពជាអ្នកមូស្លីម។

133. ឬមួយពួកអ្នកមានវត្តមាន នៅពេលដែលព្យាការីយ៉ាក់កូបហៀបនឹងស្លាប់ខណៈដែលគាត់បានសួរទៅកាន់កូនចៅរបស់គាត់ថា៖ តើពួកអ្នកនឹងគោរពសក្ការៈអ្វីបន្ទាប់ពីយើង(ស្លាប់)ទៅ? ពួកគេបានឆ្លើយតបថា៖ គឺពួកយើងគោរពសក្ការៈចំពោះ(អល់ឡោះ)ព្រះជាម្ចាស់របស់អ្នក និងជាព្រះជាម្ចាស់របស់ដូនជីតាអ្នក ព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្មាឯល និងព្យាការីអ៊ីស្ហាក (ដែលទ្រង់)គឺជាព្រះជាម្ចាស់តែមួយគត់។ ហើយពួកយើងជាអ្នកប្រគល់ខ្លួនចំពោះទ្រង់(កាន់សាសនាអ៊ីស្លាម)។

134. ពួកគេទាំងនោះ គឺជាប្រជាជាតិដែលបានកន្លងផុតទៅហើយ។ ពួកគេទទួលបាននូវអ្វីដែលពួកគេបានសាង ហើយពួកអ្នកក៏នឹងទទួលបាននូវអ្វីដែលពួកអ្នកបានសាង(ដូចគ្នា)។ ហើយគេនឹងមិនសួរពួកអ្នកពីអ្វីដែលពួកគេបានសាងនោះឡើយ។

135. ហើយពួកគេ(ពួកយូដា និងពួកគ្រីស្ទាន)បាននិយាយថា៖ ចូរពួកអ្នកកាន់តាមសាសនាយូដា ឬសាសនាគ្រីស្ត នោះពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបថា៖ ផ្ទុយទៅវិញ ពួកយើងគឺកាន់តាមសាសនារបស់ព្យាការីអ៊ីព្រហ៊ីម(សាសនាអ៊ីស្លាម)ដ៏ស្អាតស្អំ ហើយគាត់ពុំស្ថិតក្នុងចំណោមពួកដែលធ្វើស្ទើរែក(ពហុទេពនិយម)នឹងអល់ឡោះឡើយ។

136. ចូរពួកអ្នកថា៖ ពួកយើងមានជំនឿចំពោះអល់ឡោះ និងអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះមកឱ្យពួកយើង ហើយនិងអ្វីដែលគេបានបញ្ចុះទៅឱ្យព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្មាឯល ព្យាការីអ៊ីស្ហាក ព្យាការីយ៉ាក់កូប និងកូនចៅរបស់ព្យាការីយ៉ាក់កូប(ដែលជាព្យាការី) ហើយនិងអ្វីដែលគេបានប្រទានឱ្យព្យាការីមូសា និងព្យាការីអ៊ីសា ព្រមទាំងអ្វី(គម្ពីរទាំងអស់)ដែលគេបានប្រទានឱ្យបណ្តាព្យាការីទាំងឡាយមកពីព្រះជាម្ចាស់របស់ពួកគេ។ ពួកយើងមិនបែងចែករវាងនរណាម្នាក់ក្នុងចំណោមពួកគេឡើយ ហើយចំពោះអល់ឡោះ(តែមួយគត់)ដែលពួកយើងប្រគល់ខ្លួន។

137. ដូច្នេះ ប្រសិនបើពួកគេមានជំនឿដូចអ្វីដែលពួកអ្នក(បណ្តាអ្នកមានជំនឿ)បានជឿនោះ ពួកគេពិតជានឹងទទួលបានការចង្អុលបង្ហាញ។ តែប្រសិនបើពួកគេងាកចេញ ពិតណាស់ ពួកគេនឹងស្ថិតនៅក្នុងការបែកបាក់គ្នាជាមិនខាន។ ពិតប្រាកដណាស់ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាម្ចាស់ការពារអ្នកពីពួកគេ។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

138. ចូរពួកអ្នកប្រកាន់ខ្ជាប់នឹងសាសនារបស់អល់ឡោះ។ តើមានសាសនាណាដែលល្អជាងសាសនារបស់អល់ឡោះទៀតនោះ? ហើយ(ចូរពួកអ្នកពោលចុះថា៖)ពួកយើងជាអ្នកដែលគោរពសក្ការៈទៅចំពោះទ្រង់(តែមួយគត់)។

139. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ តើពួកអ្នក(ពួកអះលីគីតាប)កំពុងតែប្រកែកជាមួយពួកយើងក្នុងរឿងរបស់អល់ឡោះឬ ខណៈដែលទ្រង់ គឺជាព្រះជាម្ចាស់របស់ពួកយើង ហើយក៏ជាព្រះជាម្ចាស់របស់ពួកអ្នកផងដែរនោះ? សម្រាប់ពួកយើង គឺទង្វើរបស់ពួកយើង ហើយសម្រាប់ពួកអ្នក គឺទង្វើរបស់ពួកអ្នក(ដូចគ្នា)។ ហើយពួកយើង គឺជាអ្នកដែលគោរពសក្ការៈដ៏ស្មោះសចំពោះទ្រង់។

140. ឬក៏ពួកអ្នកនិយាយថា៖ ជាការពិតណាស់ ព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្មាអ៊ីល ព្យាការីអ៊ីស្ហាក ព្យាការីយ៉ាក់កូប និងកូនចៅរបស់ព្យាការីយ៉ាក់កូបនោះ ពួកគេស្ថិតនៅលើសាសនាយូដា ឬក៏សាសនាគ្រឹស្តឬ? ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបវិញថា៖ តើពួកអ្នកដឹងច្បាស់ជាង ឬមួយអល់ឡោះជាម្ចាស់ដឹងច្បាស់ជាង? ហើយគ្មាននរណាម្នាក់ជាអ្នកបំពានខ្លាំងជាងអ្នកដែលលាក់បាំងការពិតមកពីអល់ឡោះដែលមាននៅជាមួយគេឡើយ។ ហើយអល់ឡោះជាម្ចាស់ទ្រង់មិនព្រងើយកន្តើយចំពោះអ្វីដែលពួកអ្នកបានសាងនោះឡើយ។

141. ពួកគេទាំងនោះ គឺជាប្រជាជាតិដែលបានកន្លងផុតទៅហើយ។ ពួកគេទទួលបាននូវអ្វីដែលពួកគេបានសាង ហើយពួកអ្នកក៏នឹងទទួលបាននូវអ្វីដែលពួកអ្នកបានសាង(ដូចគ្នា)។ ហើយគេនឹងមិនសួរពួកអ្នកពីអ្វីដែលពួកគេបានសាងនោះឡើយ។

142. ពួកដែលខ្សោយបញ្ញាក្នុងចំណោមមនុស្សលោក(ពួកយូដា និងពួកពុតត្បុត)នឹងនិយាយថា៖ តើអ្វីទៅដែលធ្វើឱ្យពួកគេងាកបែរចេញពីទិសគិបឡាត់(ពៃទុលមឹក្តទីស)របស់ពួកគេដែលពួកគេធ្លាប់តម្រង់ទៅកាន់(កាលពីមុន)? ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបវិញថា៖ ទិសខាងកើត និងទិសខាងលិច គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ទ្រង់ចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនាទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

143. ក៏ដូចគ្នាដែរ យើងបានបង្កើតពួកអ្នកជាប្រជាជាតិមួយដែលឈរនៅកណ្តាលដើម្បីឲ្យពួកអ្នកធ្វើជាសាក្សីចំពោះមនុស្សលោក និងដើម្បីឱ្យអ្នកនាំសារ(មូហាំម៉ាត់)ធ្វើជាសាក្សីលើពួកអ្នកវិញផងដែរ។ ហើយយើងមិនបានធ្វើការបង្វែរទិសគិបឡាត់ដែលអ្នកធ្លាប់បានតម្រង់ទៅកាន់នោះឡើយ លើកលែងតែដើម្បីយើងដឹងថា តើអ្នកណាដែលដើរតាមអ្នកនាំសារពីក្នុងចំណោមអ្នកដែលងាកចេញ(ប្រឆាំង)ប៉ុណ្ណោះ។ ហើយជាការពិតណាស់ ការបង្វែរទិសគិបឡាត់ជាកិច្ចការដ៏ធំធេងបំផុត លើកលែងតែជនណាដែលអល់ឡោះទ្រង់បានចង្អុលបង្ហាញប៉ុណ្ណោះ។ ហើយអល់ឡោះមិនធ្វើឲ្យសេចក្តីជំនឿរបស់ពួកអ្នក(ចំពោះទ្រង់)ក្លាយជាឥតប្រយោជន៍នោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាសប្បុរសមហាអាណិតស្រឡាញ់បំផុតចំពោះមនុស្សលោក។

144. ពិតប្រាកដណាស់ យើង(អល់ឡោះ)ពិតជាបានឃើញអ្នក(ឱព្យាការីមូហាំម៉ាត់)បែរមុខរបស់អ្នកសម្លឹងមើលទៅលើមេឃ(រង់ចាំវាហ៊ី)។ ដូចនេះ យើងពិតជានឹងបង្វែរអ្នកទៅកាន់ទិសគិបឡាត់មួយដែលអ្នកពេញចិត្ត។ ដូច្នេះ ចូរអ្នកបែរមុខរបស់អ្នកតម្រង់ទៅកាន់ទិសម៉ាស្ជិតអាល់ហារ៉ែមចុះ។ ហើយទោះបីជាពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ស្ថិតនៅទីកន្លែងណាក៏ដោយ ចូរពួកអ្នកតម្រង់មុខរបស់ពួកអ្នកទៅកាន់ទិសនោះចុះ(នៅពេលប្រតិបត្តិសឡាត)។ ហើយជាការពិតណាស់ បណ្តាអ្នកដែលត្រូវបានគេផ្តល់គម្ពីរឱ្យ(ពួកយូដានិងពួកគ្រឹស្ទាន) ពួកគេដឹងយ៉ាងច្បាស់ថា ពិតប្រាកដណាស់វា(ការផ្លាស់ប្តូរទិសគិបឡាត់) គឺជាការពិតមកពីព្រះជាម្ចាស់របស់ពួកគេ។ ហើយអល់ឡោះមិនព្រងើយកន្តើយចំពោះអ្វីដែលពួកគេកំពុងតែប្រព្រឹត្តឡើយ។

145. ហើយបើទោះបីជាអ្នក(ឱព្យាការីមូហាំម៉ាត់)នាំមកឱ្យពួកដែលត្រូវបានគេផ្តល់គម្ពីរឱ្យនូវរាល់ភស្តុតាងនានាក៏ដោយ ក៏ពួកគេនៅតែមិន(បែរតែម្រង់)តាមទិសគិបឡាត់របស់អ្នក(ទិសពៃទុលឡោះអាល់ហារ៉ែម)ដដែល ហើយអ្នកក៏ពុំមែនជាអ្នកដែលបែរ(តម្រង់)តាមទិសគិបឡាត់របស់ពួកគេ(ទិសពៃទុលមឹកទីស)ដូចគ្នាដែរ។ ហើយប្រសិនបើអ្នកដើរតាមចំណង់តណ្ហារបស់ពួកគេ ក្រោយពីចំណេះដឹង(ដ៏ត្រឹមត្រូវ)បានមកដល់អ្នកហើយនោះ ពិតប្រាកដណាស់ នៅខណៈនោះ រូបអ្នកពិតជាស្ថិតក្នុងចំណោមពួកដែលបំពានជាមិនខាន។

146. ពួកដែលយើងបានប្រទានគម្ពីរឱ្យពួកគេ(ពួកអ្នកប្រាជ្ញនៃពួកយូដានិងពួកគ្រីស្ទាន) ពួកគេបានស្គាល់វា(ភាពជាព្យាការីរបស់ព្យាការីមូហាំម៉ាត់) ប្រៀបដូចជាពួកគេស្គាល់កូនចៅរបស់ពួកគេដូច្នោះដែរ។ ហើយពិតប្រាកដណាស់ ក្រុមមួយក្នុងចំណោមពួកគេបានលាក់បាំងការពិត ខណៈដែលពួកគេបានដឹងហើយនោះ។

147. នេះជាការពិតមកពីព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ហេតុនេះ ចូរអ្នកកុំស្ថិតក្នុងចំណោមពួកដែលមានការមន្ទិលសង្ស័យឱ្យសោះ។

148. ហើយរាល់ប្រជាជាតិនីមួយៗ គឺមានទិស(គិបឡាត់)ដែលពួកគេតម្រង់ទៅកាន់។ ហេតុនេះ ចូរពួកអ្នកប្រជែងគ្នាធ្វើអំពើល្អ។ ទោះបីជាពួកអ្នកស្ថិតនៅទីកន្លែងណាក៏ដោយ ក៏អល់ឡោះជាម្ចាស់នឹងនាំពួកអ្នកត្រឡប់មកវិញទាំងអស់គ្នា(នៅថ្ងៃបរលោក)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

149. ហើយទោះបីជាអ្នក(ឱព្យាការីមូហាំម៉ាត់)ចេញពីទីកន្លែងណាក៏ដោយ ចូរអ្នកតម្រង់មុខរបស់អ្នកទៅកាន់ទិសម៉ាស្ជិតអាល់ហារ៉ែមចុះ(ប្រសិនបើអ្នកចង់ប្រតិបត្តិសឡាត)។ ពិតណាស់វាជាសេចក្តីពិតមកពីព្រះជាម្ចាស់របស់អ្នក។ ហើយអល់ឡោះជាម្ចាស់មិនព្រងើយកន្តើយចំពោះអ្វីដែលពួកអ្នកកំពុងប្រព្រឹត្តនោះឡើយ។

150. ហើយទោះបីជាអ្នកចេញពីទីកន្លែងណាក៏ដោយ ចូរអ្នកតម្រង់មុខរបស់អ្នកទៅកាន់ទិសម៉ាស្ជិតអាល់ហារ៉ែមចុះ(នៅពេលអ្នកចង់ប្រតិបត្តិសឡាត)។ ហើយទោះបីជាពួកអ្នកស្ថិតនៅទីកន្លែងណាក៏ដោយ ចូរពួកអ្នកតម្រង់មុខរបស់ពួកអ្នកទៅកាន់ទិស(ម៉ាស្ជិតអាល់ហារ៉ែម)ចុះ(នៅពេលដែលពួកអ្នកចង់ប្រតិបត្តិសឡាត) ដើម្បីកុំឱ្យមនុស្សលោកមានលេសប្រឆាំងនឹងពួកអ្នក លើកលែងតែពួកដែលបំពានក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហេតុនេះ ចូរពួកអ្នកកុំខ្លាចពួកគេឱ្យសោះ តែពួកអ្នកត្រូវខ្លាចយើងវិញ ដើម្បីយើងនឹងបំពេញនូវឧបការគុណរបស់យើងដល់ពួកអ្នក ហើយសង្ឃឹមថាពួកអ្នកទទួលបានការចង្អុលបង្ហាញ។

151. ក៏ដូចគ្នាដែរ យើងបានបញ្ជូនអ្នកនាំសារម្នាក់(គឺព្យាការីមូហាំម៉ាត់)ពីក្នុងចំណោមពួកអ្នកទៅកាន់ពួកអ្នក ដើម្បីឱ្យគាត់សូត្របណ្តាវាក្យខណ្ឌរបស់យើងឱ្យពួកអ្នកស្តាប់ និងជម្រះសម្អាតពួកអ្នក ហើយនិងបង្រៀនគម្ពីរ(គួរអាន) និងគតិបណ្ឌិត(ស៊ីណ្ណៈ)ដល់ពួកអ្នក ព្រមទាំងបង្រៀនពួកអ្នកនូវអ្វីដែលពួកអ្នកមិនធ្លាប់បានដឹង។

152. ដូច្នេះ ចូរពួកអ្នករំឭកមកចំពោះយើង នោះយើងពិតជានឹងនឹកឃើញដល់ពួកអ្នកវិញ។ ហើយចូរពួកអ្នកដឹងគុណមកចំពោះយើង ហើយមិនត្រូវរមិលគុណឡើយ។

153. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកសុំជំនួយ(ពីអល់ឡោះ)ដោយការអត់ធ្មត់ និងការប្រតិបត្តិសឡាត។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្ថិតនៅជាមួយបណ្តាអ្នកដែលអត់ធ្មត់។

154. ហើយពួកអ្នកមិនត្រូវនិយាយចំពោះអ្នកដែលត្រូវបានគេសម្លាប់(ពលីជីវិត)ក្នុងមាគ៌ារបស់អល់ឡោះនោះថា៖ ពួកគេបានស្លាប់(ដូចអ្នកដទៃបានស្លាប់)នោះឡើយ។ ផ្ទុយទៅវិញ ពួកគេនៅមានជីវិត(នៅឯព្រះជាម្ចាស់របស់ពួកគេ) ប៉ុន្តែពួកអ្នកមិនមានអារម្មណ៍ដឹងឡើយ។

155. ហើយយើងពិតជានឹងសាកល្បងពួកអ្នកដោយប្រការផ្សេងៗដូចជា ការភ័យខ្លាច គ្រោះអត់ឃ្លាន កង្វះខាតទ្រព្យសម្បត្តិ បាត់បង់ជីវិត និងកង្វះខាតផលានុផលជាដើម។ ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានភាពអត់ធ្មត់(លើការសោកល្បងទាំងនោះ)ចុះ។

156. គឺបណ្តាអ្នកដែលនៅពេលណាពួកគេជួបប្រទះគ្រោះថ្នាក់ណាមួយ ពួកគេនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងជាកម្មសិទ្ធិរបស់អល់ឡោះ ហើយពិតប្រាកដណាស់ ពួកយើងនឹងវិលត្រលប់ទៅកាន់ទ្រង់វិញ។

157. អ្នកទាំងនោះហើយជាអ្នកដែលទទួលបាននូវការកោតសរសើរ និងក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់ពួកគេ។ ហើយអ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

158. ជាការពិតណាស់ ភ្នំសហ្វា និងភ្នំម៉ារ៉ៈ គឺជាអត្តសញ្ញាណមួយក្នុងចំណោមអត្តសញ្ញាណនានារបស់អល់ឡោះជាម្ចាស់។ ដូចនេះ ជនណាដែលមានបំណងទៅកាន់ពៃទុលឡោះដើម្បីធ្វើធម្មយាត្រាហាជ្ជ ឬអ៊ុមអ៊ោះនោះ គឺគ្មានទោសពៃអ៊ីឡើយលើរូបគេក្នុងការដែលគេសាអ៊ី(ដើរទៅមក)រវាងភ្នំទាំងពីរនេះ។ ជនណាដែលបានធ្វើប្រការល្អដោយស្ម័គ្រចិត្តនោះ ពិតណាស់អល់ឡោះជាម្ចាស់ គឺជាអ្នកថ្លែងអំណរគុណ និងមហាដឹងបំផុត។

159. ជាការពិតណាស់ ពួកដែលបានលាក់បាំងនូវអ្វីដែលយើងបានបញ្ចុះមកនៃសញ្ញាកស្តុតាង និងការចង្អុលបង្ហាញ ក្រោយពីយើងបានបញ្ជាក់វាដល់មនុស្សលោកនៅក្នុងគម្ពីរ(របស់ពួកគេ)ហើយនោះ ពួកទាំងនោះហើយជាពួកដែលត្រូវបានអល់ឡោះដាក់បណ្តាសា។ ហើយបណ្តាអ្នកដែលដាក់បណ្តាសាទាំងឡាយ(ម៉ាឡាអ៊ីកាត់ ព្យាការី និងមនុស្សលោក)ក៏បានដាក់បណ្តាសាពួកគេផងដែរ។

160. លើកលែងតែបណ្តាអ្នកដែលបានសារភាពកំហុស ហើយបានកែលម្អ(ទង្វើរបស់ពួកគេ) ព្រមទាំងបានបញ្ជាក់(អំពីការលាក់បាំងរបស់ពួកគេ)ប៉ុណ្ណោះ។ ពិតណាស់ អ្នកទាំងនោះ គឺយើង(អល់ឡោះ)នឹងទទួលយកការសារភាពកំហុសរបស់ពួកគេ ហើយយើងគឺជាអ្នកដែលទទួលយកការសារភាពកំហុស ជាអ្នកអាណិតស្រលាញ់បំផុត។

161. ជាការពិតណាស់ ពួកដែលគ្មានជំនឿ ហើយពួកគេបានស្លាប់ក្នុងភាពជាអ្នកគ្មានជំនឿនោះ ពួកទាំងនោះហើយជាពួកដែលត្រូវបានអល់ឡោះ ម៉ាឡាអ៊ីកាត់ និងមនុស្សលោកទាំងអស់ដាក់បណ្តាសាចំពោះពួកគេ។

162. ពួកគេនឹងស្ថិតនៅជាក្នុងវាជានិច្ច។ ទណ្ឌកម្មនឹងមិនត្រូវបានគេបន្ធូរបន្ថយចំពោះពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេលនោះដែរ។

163. ហើយព្រះជាម្ចាស់របស់ពួកអ្នកដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដនោះ គឺមានតែមួយអង្គគត់។ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមហាសប្បុរស មហាអាណិតស្រលាញ់នោះឡើយ។

164. ពិតប្រាកដណាស់ នៅក្នុងការបង្កើតមេឃជាច្រើនជាន់និងផែនដី ការផ្លាស់ប្តូរវេនគ្នារវាងពេលយប់និងពេលថ្ងៃ សំពៅដែលធ្វើដំណើរនៅលើផ្ទៃសមុទ្រដែលផ្តល់ជាប្រយោជន៍ដល់មនុស្សលោក ទឹកភ្លៀងដែលអល់ឡោះបានបញ្ចុះពីលើមេឃដែលតាមរយៈទឹកភ្លៀងនេះ ទ្រង់ធ្វើឲ្យដីរស់ឡើងវិញ(មានជីជាតិ)បន្ទាប់ពីវាបានស្លាប់(គ្មានជីជាតិ) ហើយទ្រង់បានពង្រាយសត្វគ្រប់ប្រភេទនៅលើផែនដី ការផ្លាស់ប្តូរ(ទិស)ខ្យល់ ហើយនិងពពកដែលរសាត់អណ្តែតនៅរវាងមេឃនិងផែនដីទាំងនោះគឺជាភស្តុតាងយ៉ាងច្បាស់លាស់សម្រាប់ក្រុមដែលចេះគិតពិចារណា។

165. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលយកអ្វីផ្សេងពីអល់ឡោះធ្វើជាព្រះជាម្ចាស់ ដោយពួកគេស្រឡាញ់ពួកវាប្រៀបដូចជាស្រឡាញ់អល់ឡោះដែរ។ ចំណែកឯបណ្តាអ្នកមានជំនឿវិញ ពួកគេស្រឡាញ់អល់ឡោះខ្លាំងបំផុត(លើសអ្វីៗទាំងអស់)។ ហើយប្រសិនបើពួកបំពានបានដឹង(ពីស្ថានភាពរបស់ពួកគេ) ខណៈដែលពួកគេបានឃើញទណ្ឌកម្ម(ផ្ទាល់នឹងភ្នែកនៅថ្ងៃបរលោក)នោះ (ពួកគេនឹងដឹងថា) ភាពខ្លាំងក្លាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហើយពិតប្រាកដណាស់ ទ្រង់ជាអ្នកដាក់ទណ្ឌកម្មយ៉ាងខ្លាំងក្លាបំផុត។

166. (នោះគឺ)នៅពេលដែលពួក(មេដឹកនាំ)ដែលត្រូវបានគេដើរតាម គឺពួកគេបានយកឫចខ្លួនពីពួក(ទន់ខ្សោយ)ដែលបានដើរតាម(ពួកគេ) ខណៈដែលពួកគេបានឃើញទណ្ឌកម្ម(ផ្ទាល់នឹងភ្នែក)។ ហើយរាល់បុព្វហេតុទាំងឡាយត្រូវបានកាត់ផ្តាច់ពីពួកគេ។

167. ហើយពួក(ទន់ខ្សោយ)ដែលដើរតាម(មេដឹកនាំទាំងនោះ)បាននិយាយថា៖ ប្រសិនបើពួកយើងមានឱកាសត្រលប់ទៅកាន់លោកិយវិញ ពួកយើងប្រាកដជានឹងយកឫចខ្លួនពីពួកគេដូចដែលពួកគេបានយកឫចខ្លួនពីពួកយើង(នៅពេលនេះ)ដែរ មិនខាន។ ដូច្នោះដែរ ទ្រង់បង្ហាញឱ្យពួកគេឃើញនូវទង្វើរបស់ពួកគេដើម្បីឱ្យពួកគេមានវិប្បដិសារី ហើយពួកគេមិនអាចចេញពីឋាននរកបានជាដាច់ខាត។

168. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកបរិភោគអំពីអ្វីដែលត្រូវបានអនុញ្ញាត(ហាឡាល់) និងល្អៗដែលមាននៅលើផែនដី ហើយចូរពួកអ្នកកុំដើរតាមមាគ៌ាទាំងឡាយរបស់ស៊ែតនឱ្យសោះ។ ពិតប្រាកដណាស់ វាគឺជាសត្រូវយ៉ាងច្បាស់លាស់ចំពោះពួកអ្នក។

169. តាមពិតវាប្រើពួកអ្នកឱ្យប្រព្រឹត្តិអំពើអាក្រក់ និងបាបកម្ម និងឲ្យពួកអ្នកនិយាយបំផ្លើសទៅលើអល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹង។

170. ហើយនៅពេលមានគេនិយាយទៅកាន់ពួកគេ(ពួកគ្មានជំនឿទាំងនោះ)ថា៖ ចូរពួកអ្នកដើរតាមអ្វីដែលអល់ឡោះបានបញ្ជូនមក ពួកគេតបវិញថា៖ ផ្ទុយទៅវិញ ពួកយើងដើរតាមតែអ្វីដែលយើងមានមកពីដូនតារបស់ពួកយើងប៉ុណ្ណោះ។ តើសូម្បីតែដូនតារបស់ពួកគេមិនមានការយល់ដឹង ហើយក៏មិនទទួលបានការចង្អុលបង្ហាញអ្វីសោះ(ក៏ពួកគេដើរតាមដែរឬ)?

171. ហើយការប្រៀបធៀបពួកគ្មានជំនឿ(ទាំងនោះ)គឺប្រៀបដូចជាអ្នកគង្វាលសត្វ(ដែលស្រែកហៅសត្វរបស់ខ្លួន)ដែលវាមិនយល់អ្វីបានត្រឹមតែឮសំឡេងហៅរបស់ម្ចាស់វាប៉ុណ្ណោះ។ (ពួកគេ)ថ្លង់ គ ខ្វាក់ ហេតុនេះ ពួកគេមិនយល់អ្វីឡើយ។

172. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកបរិភោគពីចំណីអាហារល្អៗដែលយើង(អល់ឡោះ)បានប្រទានជាលាភសក្ការៈដល់ពួកអ្នក។ ហើយចូរពួកអ្នកដឹងគុណចំពោះអល់ឡោះ ប្រសិនបើពួកអ្នកពិតជាគោរពសក្ការៈចំពោះទ្រង់(តែមួយគត់)មែននោះ។

173. តាមពិត ទ្រង់បានដាក់បម្រាមទៅលើពួកអ្នកមិនឱ្យទទួលទានសត្វស្លាប់(ដែលពុំបានសំឡេះត្រឹមត្រូវតាមច្បាប់អ៊ីស្លាម) ឈាម សាច់ជ្រូក ហើយនិងអ្វីដែលគេសំឡេះ(ជាតង្វាយ)សម្រាប់អ្នកផ្សេងក្រៅពីអល់ឡោះ។ តែប្រសិនបើជនណាត្រូវបានគេបង្ខំ(ឱ្យទទួលទានអាហារទាំងនេះ) ដោយគេពុំមែនជាអ្នកដែលបំពាន ហើយក៏ពុំមែនជាអ្នករំលងព្រំដែន(នៃតម្រូវការចាំបាច់របស់ខ្លួន)ដែរនោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះរូបគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោសមហាអាណិតស្រលាញ់បំផុត។

174. ពិតប្រាកដណាស់ ពួកដែលលាក់បាំងអំពីគម្ពីរដែលអល់ឡោះបានបញ្ជូនមក ហើយពួកគេបានប្តូរវាជាមួយនឹងកម្រៃបន្តិចបន្តួច ពួកទាំងនោះ អ្វីដែលពួកគេទទួលទានចូលទៅក្នុងពោះរបស់ពួកគេ គឺគ្មានអ្វីក្រៅពីភ្លើងនោះឡើយ។ ហើយអល់ឡោះនឹងមិនមានបន្ទូលទៅកាន់ពួកគេឡើយនៅថ្ងៃបរលោក ហើយទ្រង់ក៏មិនជម្រះសម្អាតពួកគេនោះដែរ ហើយពួកគេនឹងត្រូវទទួលទណ្ឌកម្មដ៏ឈឺចាប់បំផុត។

175. ពួកទាំងនោះហើយ ជាពួកដែលយកការចង្អុលបង្ហាញប្តូរយកភាពវង្វេង និងយកការអភ័យទោស(ពីអល់ឡោះ)ប្តូរយកទណ្ឌកម្ម។ ពិតណាស់ ពួកគេពិតជាអាចអត់ទ្រាំពី(ទណ្ឌកម្ម)ភ្លើងនរកបានមែន(ឬយ៉ាងណា)!

176. នោះគឺដោយសារតែអល់ឡោះជាម្ចាស់បានបញ្ចុះនូវគម្ពីរយ៉ាងពិតប្រាកដ។ ជាការពិតណាស់ ពួកដែលបានខ្វែងគំនិតគ្នាចំពោះគម្ពីរនោះ ពួកគេពិតជាធ្លាក់ក្នុងការបែកបាក់ និងឃ្លាតឆ្ងាយ(ពីការពិត)ជាមិនខាន។

177. មិនទាន់ចាត់ទុកថាជាអំពើល្អឡើយ ការដែលពួកអ្នកគ្រាន់តែតម្រង់មុខរបស់ពួកអ្នកទៅកាន់ទិសខាងកើត ឬទិសខាងលិចនោះ ក៏ប៉ុន្តែ(ចាត់ទុកថាជា)អំពើល្អនោះ គឺជនណាដែលមានជំនឿលើអល់ឡោះនិងថ្ងៃបរលោក បណ្តាម៉ាឡាអ៊ីកាត់ បណ្តាគម្ពីរ និងបណ្តាព្យាការីទាំងឡាយ ហើយបានបរិច្ចាគទ្រព្យសម្បត្តិដែលគេស្រឡាញ់ចង់បានទៅឲ្យសាច់ញាតិ ក្មេងកំព្រា អ្នកក្រីក្រ អ្នកដំណើរដាច់ស្បៀង និងអ្នកសុំទាន ព្រមទាំង(ចំណាយវា)ក្នុងការដោះលែងទាសករ និងដោះលែងចំណាប់ខ្មាំង ហើយគេបានប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយនិងអ្នកទាំងឡាយដែលបំពេញនូវកិច្ចសន្យារបស់ខ្លួន នៅពេលណាដែលពួកគេបានសន្យា ព្រមទាំងបណ្តាអ្នកដែលមានភាពអត់ធ្មត់ទៅលើភាពក្រីក្រ ភាពលំបាកវេទនា និងនៅក្នុងសមរភូមិដែលមានភាពតានតឹង។ អ្នកទាំងនោះហើយគឺជាអ្នកដែលមានការជឿជាក់យ៉ាងពិតប្រាកដ ហើយអ្នកទាំងនោះហើយ គឺជាអ្នកដែលកោតខ្លាច(អល់ឡោះ)។

178. ឱបណ្តាអ្នកដែលមានជំនឿ! គេបានដាក់កាតព្វកិច្ចលើពួកអ្នកឲ្យមានសមភាពក្នុងការនិច្ឆ័យទោសក្នុងរឿងឃាតកម្ម ដោយអ្នកដែលមានសិទ្ធិសេរីភាព(ត្រូវសម្លាប់)ដោយអ្នកមានសិទ្ធិសេរីភាព ទាសករ(ត្រូវសម្លាប់)ដោយទាសករ ហើយស្ត្រី(ត្រូវសម្លាប់)ដោយស្ត្រី។ តែប្រសិនបើអាណាព្យាបាលជនរងគ្រោះបានអនុគ្រោះ(ឲ្យឃាតករ)ដោយការសងជំងឺចិត្តនោះ គឺត្រូវទាំសំណងឱ្យបានសមរម្យ ហើយ(ឃាតករ)ក៏ត្រូវផ្តល់សំណងឱ្យបានសមរម្យ(តាមការទាមទារ)ដូចគ្នាដែរ។ នោះគឺជាការបន្ធូរបន្ថយពីព្រះជាម្ចាស់របស់ពួកអ្នក និងជាក្តីមេត្តាករុណា(អំពីទ្រង់ចំពោះពួកអ្នក)។ ដូចនេះ ជនណាដែលបានបំពានបន្ទាប់ពីនោះ ពិតប្រាកដណាស់ គេនឹងទទួលទណ្ឌកម្មយ៉ាងខ្លោចផ្សាបំផុត។

179. ហើយនៅក្នុងការកំណត់សមភាពក្នុងការនិច្ឆ័យទោសដែលទ្រង់បានដាក់បញ្ញត្តិសម្រាប់ពួកអ្នកនោះ គឺដើម្បីឲ្យជីវិតរស់នៅរបស់ពួកអ្នកប្រកបទៅដោយសុខសន្តិភាព ឱបញ្ញាជនទាំងឡាយ សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច។

180. គេបានដាក់កាតព្វកិច្ចលើពួកអ្នក នៅពេលដែលសេចក្តីស្លាប់ជិតមកដល់នរណាម្នាក់ក្នុងចំណោមពួកអ្នក ប្រសិនបើគេបានបន្សល់ទុកទ្រព្យសម្បត្តិច្រើននោះ គឺត្រូវធ្វើបណ្តាំមរតកសម្រាប់មាតាបិតា និងញាតិសណ្តានដោយល្អប្រសើរ(តាមច្បាប់កំណត់)។ (ការអនុវត្តបែបនេះ) គឺជាកាតព្វកិច្ចដ៏ម៉ឺងម៉ាត់ទៅលើបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះជាម្ចាស់)។

181. ហេតុនេះ ជនណាហើយដែលបានផ្លាស់ប្តូរវា បន្ទាប់ពីគេបានដឹងអំពីវាហើយនោះ ជាការពិតណាស់ បាបកម្មនឹងធ្លាក់ទៅលើអ្នកដែលផ្លាស់ប្តូរ(កែប្រែ)បណ្តាំនោះ។ ពិតប្រាកដណាស់ អល់ឡោះមហាឮ មហាដឹងបំផុត។

182. តែចំពោះជនណាដែលបារម្ភខ្លាចអ្នកធ្វើបណ្តាំមរតកមានភាពលម្អៀង ឬមានបាបកម្ម(ភាពខុសឆ្គងនៅក្នុងពាក្យបណ្តាំ)រួចគេផ្សះផ្សារវាងពួកគេ(ភាគីទំនាស់ទាំងពីរ)នោះ គឺគ្មានទោសពៃរ៍អ្វីចំពោះគេឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រឡាញ់។

183. ឱបណ្តាអ្នកដែលមានជំនឿ! គេបានដាក់កាតព្វកិច្ចលើពួកអ្នកឱ្យកាន់អំណត់បួស ដូចដែលគេបានដាក់កាតព្វកិច្ច(បួសនេះ)ទៅលើអ្នកជំនាន់មុនពួកអ្នកដែរ សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច(អល់ឡោះ)។

184. (ការបួសដែលជាកាតព្វកិច្ចនោះ) គឺក្នុងបណ្តាថ្ងៃដែលគេបានកំណត់។ ដូចនេះក្នុងចំណោមពួកអ្នក ជនណាដែលមានជំងឺ ឬជាអ្នកធ្វើដំណើរ (គេអាចផ្អាកបួសបាន) តែត្រូវបួសសងវិញនៅបណ្តាថ្ងៃផ្សេង (តាមចំនួនថ្ងៃដែលគេបានផ្អាកបួស)។ ហើយចំពោះអ្នកដែលគ្មានលទ្ធភាពបួស គឺត្រូវទទួលការផាកពិន័យដោយត្រូវផ្តល់អាហារដល់ជនក្រីក្រ (តាមចំនួនថ្ងៃដែលគេមិនបានបួស)។ ហើយជនណាដែលធ្វើប្រការល្អដោយស្ម័គ្រចិត្ត វាគឺជាការប្រសើរសម្រាប់រូបគេ។ តែប្រសិនបើពួកអ្នកបួស វាជាការប្រសើរសម្រាប់ពួកអ្នកជាង ប្រសិនបើពួកអ្នកបានដឹង។

185. ខែរ៉ម៉ាហ្វន គឺជាខែដែលគេ(អល់ឡោះ)បានបញ្ចុះគម្ពីរគួរអានដើម្បីជាការចង្អុលបង្ហាញដល់មនុស្សលោក ព្រមទាំងបញ្ជាក់ច្បាស់នូវការចង្អុលបង្ហាញ និងការវែកញែក(រវាងខុសនិងត្រូវ)។ ដូច្នេះ ជនណាដែលមានវត្តមាននៅក្នុងខែនេះ ចូរឲ្យគេបួស(ជាចាំបាច់)។ ហើយជនណាដែលមានជំងឺ ឬជាអ្នកធ្វើដំណើរ (គេអាចផ្អាកបួសបាន) តែត្រូវបួសសងវិញនៅបណ្តាថ្ងៃផ្សេង(តាមចំនួនថ្ងៃដែលគេបានផ្អាកបួស)។ អល់ឡោះជាម្ចាស់ចង់ឲ្យពួកអ្នកមានភាពងាយស្រួល ហើយទ្រង់មិនចង់ឲ្យពួកអ្នកលំបាកឡើយ។ ហើយចូរពួកអ្នកបង្រ្គប់ចំនួនថ្ងៃ(នៃការបួសខែរ៉ម៉ាហ្វន) ហើយចូរពួកអ្នកលើកតម្កើងអល់ឡោះ(តឹកពៀរនៅថ្ងៃរ៉យ៉ា)ទៅលើអ្វីដែលទ្រង់បានចង្អុលបង្ហាញដល់ពួកអ្នក សង្ឃឹមថាពួកអ្នកចេះថ្លែងអំណរគុណ។

186. ហើយនៅពេលដែលបណ្តាខ្ញុំបម្រើរបស់យើងបានសួរអ្នក(ឱព្យាការីមូហាំម៉ាត់)អំពីយើង ពិតប្រាកដណាស់ យើងស្ថិតនៅជិតបង្កើយពួកគេ។ យើងឆ្លើយតបចំពោះអ្នកដែលធ្វើការបួងសួងនៅពេលណាដែលគេបួងសួងមកកាន់យើង។ ហេតុនេះ ចូរឱ្យពួកគេស្តាប់បង្គាប់យើង និងមានជំនឿចំពោះយើង សង្ឃឹមថាពួកគេនឹងទទួលបានការចង្អុលបង្ហាញ។

187. គេបានអនុញ្ញាតឲ្យពួកអ្នកអាចរួមដំណេកជាមួយនឹងភរិយារបស់ពួកអ្នកក្នុងពេលរាត្រីនៃការបួស។ ពួកនាងគឺជាសម្លៀកបំពាក់សម្រាប់ពួកអ្នក ហើយពួកអ្នកក៏ជាសម្លៀកបំពាក់សម្រាប់ពួកនាងវិញដែរ។ អល់ឡោះបានដឹងថា ពួកអ្នកបានក្បត់នឹងខ្លួនឯង(ដោយធ្វើប្រការដែលទ្រង់បានហាមឃាត់)។ ហេតុនេះ ទ្រង់បានទទួលយកការសោរភាពកំហុសរបស់ពួកអ្នក និងបានអធ្យាស្រ័យដល់ពួកអ្នក។ ដូច្នេះ ចាប់ពីពេលនេះទៅ ចូរពួកអ្នករួមដំណេកជាមួយពួកនាង ហើយស្វែងរកអ្វី(កូនចៅ)ដែលទ្រង់បានកំណត់សម្រាប់ពួកអ្នក។ ហើយចូរពួកអ្នកបរិភោគនិងផឹក រហូតដល់ពន្លឺពណ៌សនៃហ្វាជើរ(សេតារុណ)ដាច់ចេញពីផ្ទៃពណ៌ខ្មៅនៃស្បែរាត្រីបានបង្ហាញច្បាស់ចំពោះពួកអ្នក។ បន្ទាប់មក ចូរពួកអ្នកបំពេញនូវការបួសរហូតដល់យប់(ថ្ងៃលិច)។ ហើយពួកអ្នកមិនត្រូវរួមដំណេកជាមួយពួកនាង ខណៈពេលដែលពួកអ្នកកំពុងអៀកទីកាហ្វនៅក្នុងម៉ាស្ជិតឡើយ។ ទាំងនោះគឺជាព្រំដែនរបស់អល់ឡោះ។ ហេតុនេះ ចូរពួកអ្នកកុំទៅក្បែរវាឱ្យសោះ។ ក៏ដូចគ្នាដែរ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជាក់នូវបណ្តាវាក្យខណ្ឌរបស់ទ្រង់ដល់មនុស្សលោក សង្ឃឹមថាពួកគេនឹងកោតខ្លាច(ចំពោះទ្រង់)។

188. ហើយចូរពួកអ្នកកុំយកទ្រព្យសម្បត្តិគ្នាទៅវិញទៅមកដោយមិនត្រឹមត្រូវ(ខុសច្បាប់)ឲ្យសោះ និងមិនត្រូវនាំរឿងនោះប្តឹងដល់តុលាការ ដើម្បីពួកអ្នកបានស៊ីទ្រព្យសម្បត្តិរបស់មនុស្សមួយក្រុមដោយខុសច្បាប់នោះឡើយ ទាំងដែលពួកអ្នកដឹង(ថាអល់ឡោះបានហាមឃាត់អំពីរឿងនេះ)ហើយនោះ។

189. ពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីខ្នើតខែ។ ចូរអ្នកតបថា៖ វាជាការកំណត់ពេលវេលាជាច្រើនសម្រាប់មនុស្ស និង(ជាការកំណត់ពេលវេលា)សម្រាប់ធ្វើហាជ្ជី។ ហើយពុំមែនជាទង្វើល្អឡើយដែលពួកអ្នកចូលលំនៅឋានតាមផ្លូវក្រោយនោះ។ ក៏ប៉ុន្តែទង្វើល្អ(ពិតប្រាកដ) គឺអ្នកដែលកោតខ្លាចអល់ឡោះជាម្ចាស់ទៅវិញទេ។ ហើយចូរពួកអ្នកចូលលំនៅឋានតាមបណ្តាទ្វាររបស់វា(ទ្វារខាងមុខ)ចុះ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

190. ហើយចូរពួកអ្នក(អ្នកមានជំនឿ)ប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះជាមួយពួកដែលបង្កសង្គ្រាមនឹងពួកអ្នក ហើយចូរពួកអ្នកកុំបំពានព្រំដែនរបស់អល់ឡោះ(នៅពេលប្រយុទ្ធជាមួយពួកគេ)ឲ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនស្រឡាញ់ពួកដែលបំពានព្រំដែន(របស់ទ្រង់)ឡើយ។

191. ហើយចូរពួកអ្នកសម្លាប់ពួកគេ(ពួកប្រឆាំង)ចុះនៅពេលដែលពួកអ្នកបានជួបពួកគេ ហើយចូរពួកអ្នកបណ្តេញពួកគេ ឱ្យចាកចេញពីទីកន្លែងដែលពួកគេធ្លាប់បានបណ្តេញពួកអ្នក(ក្រុងម៉ាក្កៈ)វិញចុះ។ ហើយភាពវឹកវរ គឺធ្ងន់ធ្ងរជាង ការកាប់សម្លាប់គ្នាទៅទៀត។ ហើយចូរពួកអ្នកកុំ(ផ្តើម)ប្រយុទ្ធជាមួយពួកគេនៅឯម៉ាស្ជិតអាល់ហារ៉ែមឱ្យសោះ លុះត្រាតែ ពួកគេ(ផ្តើម)ប្រយុទ្ធជាមួយនឹងពួកអ្នកនៅទីនោះមុន។ ហើយប្រសិនបើពួកគេ(ផ្តើម)ប្រយុទ្ធនឹងពួកអ្នក ចូរប្រយុទ្ធ (តបត)នឹងពួកគេវិញចុះ។ ក៏ដូចគ្នាដែរ វាគឺជាការតបស្នងចំពោះពួកដែលប្រឆាំង។

192. តែប្រសិនបើពួកគេបានបញ្ឈប់(ការប្រយុទ្ធជាមួយពួកអ្នក)ហើយនោះ (ចូរពួកអ្នកបញ្ឈប់ការប្រយុទ្ធចុះ)។ ពិតប្រាកដ ណាស់ អល់ឡោះទ្រង់មហាអភ័យទោស មហាអាណិតស្រឡាញ់។

193. ហើយចូរពួកអ្នកប្រយុទ្ធនឹងពួកគេរហូតដល់គ្មានភាពវឹកវរ(អំពើស្តីរិក និងភាពគ្មានជំនឿ)តទៅទៀត ហើយសាសនារបស់ អល់ឡោះបានក្លាយជាសាសនាដ៏លេចធ្លោឡើង។ តែប្រសិនបើពួកគេបានបញ្ឈប់(ការប្រយុទ្ធ)ហើយនោះ (ចូរពួកបញ្ឈប់ ការប្រយុទ្ធចុះ) ព្រោះគ្មានភាពជាសត្រូវនោះទេ លើកលែងតែចំពោះពួកដែលបំពានប៉ុណ្ណោះ។

194. ខែបម្រាមគឺជំនួសដោយខែបម្រាម ហើយប្រការបម្រាមទាំងឡាយ គឺត្រូវកំណត់ច្បាប់វិនិច្ឆ័យទោស(ទៅលើពួកដែល បំពាន)ឱ្យដូចគ្នា។ ដូច្នេះ ជនណាហើយដែលបានបំពានលើពួកអ្នក ចូរពួកអ្នកតបតទៅពួកគេវិញឱ្យដូចអ្វីដែលពួកគេបាន ធ្វើដាក់ពួកអ្នក។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ និងត្រូវដឹងថា ពិតប្រាកដណាស់ អល់ឡោះទ្រង់នៅជាមួយ បណ្តាអ្នកដែលកោតខ្លាច។

195. ហើយចូរពួកអ្នកចំណាយ(ទ្រព្យសម្បត្តិ)ក្នុងមាគ៌ាអល់ឡោះ ហើយមិនត្រូវបណ្តោយខ្លួនពួកអ្នកឱ្យធ្លាក់ទៅក្នុងភាព វិនាសអន្តរាយនោះឡើយ និងចូរពួកអ្នកប្រព្រឹត្តអំពើល្អចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រឡាញ់បណ្តា អ្នកដែលប្រព្រឹត្តអំពើល្អ។

196. ហើយចូរពួកអ្នកបំពេញនូវកាតព្វកិច្ចហាជ្ជី និងអ៊ុមរ៉ោះសម្រាប់អល់ឡោះ។ តែប្រសិនបើពួកអ្នកត្រូវបានគេរារាំង(មិនឱ្យ បំពេញហាជ្ជីឬអ៊ុមរ៉ោះបាន) គឺតម្រូវលើពួកអ្នកត្រូវសំឡះសត្វជំនួនណាមួយដែលងាយនឹងរកបាន។ ហើយចូរពួកអ្នកកុំ ទាន់កោរសក់(ឬកាត់សក់)របស់ពួកអ្នក លុះត្រាតែសត្វជំនួនទាំងនោះបានទៅដល់កន្លែង(សំឡះ)របស់វាសិន។ ហើយ ប្រសិនបើនរណាម្នាក់ក្នុងចំណោមពួកអ្នកមានជំងឺ ឬមានបញ្ហាស្បែកក្បាល គឺត្រូវបង់ផាកពិន័យដោយត្រូវបួស(ចំនួនបីថ្ងៃ) ឬបរិច្ចាគទាន(ផ្តល់អាហារដល់អ្នកក្រីក្រនៅទឹកដីម៉ាក្កៈចំនួនប្រាំមួយនាក់) ឬសំឡះសត្វ(ពពែមួយក្បាលចែកជូនអ្នកក្រ ដែលរស់នៅទីនោះ)។ ហើយប្រសិនបើពួកអ្នកមានសុវត្ថិភាព ដូចនេះជនណាដែលធ្វើអ៊ុមរ៉ោះភ្ជាប់ជាមួយនឹងហាជ្ជី(ហាជ្ជី តាម៉ាត់តួក) គឺត្រូវសំឡះសត្វជំនួនណាមួយដែលគេងាយរកបាន។ តែប្រសិនបើគេគ្មានលទ្ធភាព(សំឡះសត្វ)ទេនោះ គឺ ត្រូវបួសចំនួនបីថ្ងៃក្នុងពេលធ្វើហាជ្ជី និងប្រាំពីរថ្ងៃទៀតនៅពេលដែលពួកអ្នកវិលត្រលប់ទៅ(កាន់គ្រួសារ)វិញ។ នោះគឺគ្រប់ ចំនួនដប់ថ្ងៃពេញ។ វាគឺសម្រាប់អ្នកដែលមិនមែនជាអ្នករស់នៅក្នុងតំបន់ម៉ាស្ជិតអាល់ហារ៉ែម។ ហើយចូរពួកអ្នកកោតខ្លាច អល់ឡោះ និងត្រូវដឹងថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

197. (ពេលវេលានៃ)ការធ្វើធម្មយាត្រាហាជ្ជី គឺស្ថិតក្នុងបណ្តាខែដែលត្រូវបានគេដឹងយ៉ាងច្បាស់ ។ ដូចនេះ ចំពោះអ្នកដែល មានកាតព្វកិច្ចធ្វើហាជ្ជីនៅអំឡុងខែទាំងនេះ (ក្រោយពេលកាន់តំណមអៀហរ៉ែមរួចហើយ) គឺមិនត្រូវរួមដំណេក មិនត្រូវ ប្រព្រឹត្តអំពើល្មើស(ចំពោះអល់ឡោះ) ហើយក៏មិនត្រូវឈ្លោះប្រកែកគ្នាក្នុងអំឡុងពេលនៃការធ្វើហាជ្ជីនោះដែរ។ ហើយ អំពើល្អណាក៏ដោយដែលពួកអ្នកបានសាងនោះ គឺអល់ឡោះទ្រង់ពិតជាជ្រាបដឹងអំពីវា។ ហើយចូរពួកអ្នកត្រៀមស្បៀង។ ជាការពិតណាស់ ស្បៀងដែលប្រសើរបំផុតនោះ គឺការកោតខ្លាចអល់ឡោះ។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចមកចំពោះយើង ឱបញ្ញាជនទាំងឡាយ។

198. គ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នក ដោយគ្រាន់តែពួកអ្នកស្វែងរកការប្រោសប្រទាន(លាភសក្ការៈ)ពីព្រះជាម្ចាស់របស់ពួកអ្នក(ក្នុងអំឡុងពេលធ្វើហាជ្ជីនោះ)។ ហើយនៅពេលដែលពួកអ្នកបានបំពេញកិច្ចការ(ហាជ្ជី)នៅឯតំបន់អារ៉ហ្វៈរួចរាល់ហើយនោះ ចូរពួកអ្នករំឭកចំពោះអល់ឡោះនៅឯម៉ាស្អារិលហារ៉ម(ដែលស្ថិតនៅទឹកដីមុហ្ស្ទាលីហ្វៈ)ចុះ។ ហើយចូរពួកអ្នករំឭកចំពោះទ្រង់ដូចដែលទ្រង់បានចង្អុលបង្ហាញដល់ពួកអ្នក ខណៈដែលកាលពីមុន ពួកអ្នកស្ថិតក្នុងចំណោមពួកដែលវង្វេង។

199. បន្ទាប់មក ចូរពួកអ្នកចាកចេញ(ពីអារ៉ហ្វៈ)វិញដូចដែលមនុស្សលោកទាំងឡាយបានចាកចេញ ហើយចូរពួកអ្នកសុំការអភ័យទោសពីអល់ឡោះចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

200. ហើយនៅពេលដែលពួកអ្នកបានបំពេញកិច្ចការហាជ្ជីរបស់ពួកអ្នកចប់សព្វគ្រប់ហើយ ចូរពួកអ្នករំឭកទៅចំពោះអល់ឡោះជាម្ចាស់(ឲ្យបានច្រើន)ដូចដែលពួកអ្នករំឭកដល់ជីដូនជីតារបស់ពួកអ្នក ឬរំឭកឱ្យច្រើនជាងនេះ។ ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលបួងសួងថា៖ ឱព្រះជាម្ចាស់របស់យើងខ្ញុំ! សូមទ្រង់មេត្តាប្រទានដល់យើងខ្ញុំនូវប្រការល្អក្នុងលោកិយផងចុះ។ ដូចនេះ សម្រាប់រូបគេគ្មានទទួលបានផលអ្វីឡើយនៅថ្ងៃបរលោក។

201. ហើយក្នុងចំណោមពួកគេផងដែរ គឺមានអ្នកដែលបួងសួងថា៖ ឱព្រះជាម្ចាស់របស់យើងខ្ញុំ! សូមទ្រង់មេត្តាប្រទានដល់យើងខ្ញុំនូវប្រការល្អក្នុងលោកិយ និងប្រការល្អនៅថ្ងៃបរលោក ព្រមទាំងការពាររយើងខ្ញុំពីទណ្ឌកម្មនៃភ្លើងនរកផង។

202. អ្នកទាំងនោះហើយ គឺជាអ្នកដែលនឹងទទួលបានចំណែកអំពីអ្វីដែលពួកគេបានសាង(ក្នុងលោកិយ)។ ហើយអល់ឡោះទ្រង់ជាអ្នកជំនុំជម្រះ(ចំពោះទង្វើទាំងឡាយ)យ៉ាងឆាប់រហ័សបំផុត។

203. ហើយចូរពួកអ្នករំឭកទៅចំពោះអល់ឡោះក្នុងបណ្តាថ្ងៃដែលត្រូវបានកំណត់ ។ ដូច្នេះ ជនណាដែលមានការប្រញាប់(ចង់ចាកចេញពីតំបន់មីណា)ក្នុងថ្ងៃទីពីរ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេ ហើយជនណាដែលចង់ពន្យារពេល(ដោយបន្តស្នាក់នៅរហូតដល់ថ្ងៃទីបី) ក៏គ្មានទោសពៃរ៍អ្វីចំពោះគេដែរសម្រាប់អ្នកដែលកោតខ្លាច(អល់ឡោះ)។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ និងត្រូវដឹងថា ជាការពិតណាស់ ពួកអ្នកនឹងត្រូវគេប្រមូលផ្តុំទៅកាន់ទ្រង់វិញ(នៅថ្ងៃបរលោក)។

204. ហើយក្នុងចំណោមមនុស្សលោក គឺមានពួក(ពុតត្បុត)ដែលពាក្យសម្តីរបស់គេធ្វើឱ្យអ្នក(ឱព្យាការីមូហាំម៉ាត់)មានការចាប់អារម្មណ៍ចំពោះឆាកជីវិតលោកិយនេះ ហើយគេយកអល់ឡោះជាម្ចាស់ធ្វើជាសាក្សីចំពោះអ្វីដែលមាននៅក្នុងដួងចិត្តរបស់គេ ខណៈដែលរូបគេ គឺជាអ្នកដែលបង្កវឿងឈ្លោះប្រកែកបំផុត។

205. ហើយនៅពេលដែលគេបានចាកចេញ(ពីអ្នក) គឺគេព្យាយាមនៅលើផែនដីនេះក្នុងគោលបំណងបង្កវិនាសកម្មនៅលើវា ហើយបំផ្លិចបំផ្លាញកសិផល និងសត្វពាហនៈនានា។ ហើយអល់ឡោះទ្រង់មិនស្រលាញ់អំពើវិនាសកម្មឡើយ។

206. ហើយនៅពេលដែលមានគេនិយាយទៅកាន់ជននោះថា៖ ចូរអ្នកកោតខ្លាចអល់ឡោះ បែរជាភាពក្អេងក្អាងបានអូសទាញរូបគេឲ្យប្រព្រឹត្តអំពើបាបកម្មទៅវិញ។ ដូចនេះ នរកដើហាន់ណាំ គឺគ្រប់គ្រាន់ហើយសម្រាប់រូបគេ ហើយវាជាកន្លែងស្នាក់នៅដ៏អាក្រក់បំផុត។

207. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលបានលក់ខ្លួនឯងស្វែងរកការពេញចិត្តពីអល់ឡោះ។ ហើយអល់ឡោះជាអ្នកដែលមានក្តីមេត្តាករុណាបំផុតចំពោះបណ្តាខ្ញុំបម្រើ(របស់ទ្រង់)។

208. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកចូលកាន់សាសនាអ៊ីស្លាមឱ្យបានពេញលេញ(ពិតប្រាកដ) ហើយចូរពួកអ្នកកុំដើរតាមមាគ៌ាទាំងឡាយរបស់ស្មៃតនឱ្យសោះ។ ពិតប្រាកដណាស់វាជាសត្រូវរបស់ពួកអ្នកយ៉ាងច្បាស់លាស់បំផុត។

209. តែប្រសិនបើពួកអ្នកងាកចេញបន្ទាប់ពីបណ្តាកស្តុតាងយ៉ាងច្បាស់លាស់បានមកដល់ពួកអ្នកហើយនោះ ដូច្នេះពួកអ្នកត្រូវដឹងថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

210. ពួកគេមិនរង់ចាំអ្វីក្រៅតែពីការយាងរបស់អល់ឡោះមកដល់ពួកគេតាមម្លប់នៃពពក(ដើម្បីកាត់សេចក្តីរវាងពួកគេ) ហើយនិងការមកដល់របស់បណ្តាម៉ាឡាអ៊ីកាត់នោះឡើយ។ នៅពេលនោះ ការកាត់សេចក្តី(របស់អល់ឡោះ)បានចប់សព្វគ្រប់។ ហើយកិច្ចការទាំងឡាយ គឺត្រូវវិលត្រឡប់ទៅកាន់អល់ឡោះ(តែមួយគត់)។

211. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)សួរទៅកាន់អម្បូរអ៊ីស្រាអែលថា៖ តើមានសញ្ញាកស្តុតាងដ៏ច្បាស់លាស់ប៉ុន្មានហើយដែលយើងបានប្រទានដល់ពួកគេ? ជនណាហើយដែលផ្លាស់ប្តូរឧបការគុណរបស់អល់ឡោះ(ជាមួយនឹងការប្រឆាំងនិងការបដិសេធ) ក្រោយពីសញ្ញាកស្តុតាងបានមកដល់រូបគេហើយនោះ ពិតណាស់ អល់ឡោះជាម្ចាស់គឺជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

212. គេបានលម្អជីវិតរស់នៅក្នុងលោកិយសម្រាប់ពួកដែលគ្មានជំនឿ ហើយពួកគេតែងតែសើចចំអកឱ្យបណ្តាអ្នកដែលមានជំនឿ។ ចំពោះបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)នៅថ្ងៃបរលោក ពួកគេខ្ពង់ខ្ពស់ជាងពួកគ្មានជំនឿទាំងនោះ។ ហើយអល់ឡោះទ្រង់ប្រទានលាភសក្ការៈឱ្យជនណាដែលទ្រង់មានចេតនាដោយមិនអាចគណនាបានឡើយ។

213. ដើមឡើយ មនុស្សលោកជាប្រជាជាតិតែមួយ(ស្ថិតនៅលើសាសនាអ៊ីស្លាម)។ (លុះដល់ពេលស្មៃតនធ្វើឱ្យពួកគេវង្វេង) ពេលនោះ អល់ឡោះក៏បានចាត់បញ្ជូននូវបណ្តាព្យាការីជាច្រើន ដើម្បីធ្វើជាអ្នកផ្តល់ដំណឹងរីករាយ(ដល់បណ្តាអ្នកមានជំនឿ) និងជាអ្នកដាស់តឿនព្រមាន(ដល់ពួកគ្មានជំនឿ) ហើយទ្រង់បានបញ្ចុះមកជាមួយពួកគេនូវគម្ពីរដ៏ពិតប្រាកដ ដើម្បីឱ្យគេវិនិច្ឆ័យរវាងមនុស្សលោកចំពោះអ្វីដែលពួកគេបានខ្វែងគំនិតគ្នានៅក្នុងវា។ ហើយគ្មានការខ្វែងគំនិតគ្នានៅក្នុងវា(គម្ពីរតាវ៉ត)ឡើយ លើកលែងតែអ្នកដែលគេបានផ្តល់គម្ពីរឱ្យប៉ុណ្ណោះ ក្រោយពីកស្តុតាងជាច្រើនបានមកដល់ពួកគេ ដោយសារតែភាពឈ្នានីសរវាងពួកគេ។ ពិតណាស់ អល់ឡោះដាម្ចាស់នឹងប្រទានការចង្អុលបង្ហាញនូវការពិតដល់បណ្តាអ្នកមានជំនឿចំពោះអ្វីដែលពួកគេបានខ្វែងគំនិតគ្នានៅក្នុងវាដោយការអនុញ្ញាតរបស់ទ្រង់។ ហើយអល់ឡោះជាម្ចាស់ទ្រង់ចង្អុលបង្ហាញជនណាដែលទ្រង់មានចេតនាទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

214. ឬមួយពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)គិតស្មានថា ពួកអ្នកអាចចូលឋានសួគ៌បានទាំងដែលមិនទាន់បានមកដល់ពួកអ្នក(នូវការសាកល្បងណាមួយ) ដូចអ្វីដែលបានកើតឡើងចំពោះអ្នកជំនាន់មុនពួកអ្នកឬ? ពួកគេ(អ្នកមានជំនឿជំនាន់មុន)បានជួបប្រទះនូវគ្រោះទុរភិក្ស ជំងឺ និងការភ័យញាប់ញ័ររហូតសូម្បីតែអ្នកនាំសារនិងបណ្តាអ្នកមានជំនឿដែលនៅជាមួយគាត់ក៏បាននិយាយដែរថា៖ តើពេលណាទៅទើបជំនួយរបស់អល់ឡោះមកដល់នោះ? តើពុំមែនទេឬ ជាការពិតណាស់ជំនួយរបស់អល់ឡោះ គឺនៅជិតបំផុត។

215. ពួកគេ(មិត្តភក្តិរបស់អ្នក)នឹងសួរអ្នក(ព្យាការីមូហាំម៉ាត់)ថា៖ តើពួកគេត្រូវបរិច្ចាគទៅលើអ្វី? ចូរអ្នកតបថា៖ អ្វីដែលពួកអ្នកបានបរិច្ចាគអំពីប្រការល្អនោះ គឺត្រូវផ្តល់ជូនទៅឪពុកម្តាយ ញាតិសណ្តាន ក្មេងកំព្រា ជនក្រីក្រ និងអ្នកដំណើរដាច់ស្បៀង។ ហើយអ្វីដែលពួកអ្នកបានសាងអំពីប្រការល្អនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតចំពោះវា។

216. គេបានដាក់កាតព្វកិច្ចលើពួកអ្នកឱ្យធ្វើសង្គ្រាមប្រយុទ្ធ(ក្នុងមាគ៌ាអល់ឡោះ) ខណៈដែលពួកអ្នកមិនពេញចិត្តនោះឡើយ។ តែជួនកាលប្រការអ្វីមួយដែលពួកអ្នកមិនពេញចិត្តវាជាប្រការល្អសម្រាប់ពួកអ្នក ហើយជួនកាលទៀតប្រការអ្វីមួយដែលពួកអ្នកពេញចិត្តនោះ វាជាប្រការអាក្រក់សម្រាប់ពួកអ្នកទៅវិញទេ។ ហើយអល់ឡោះមហាដឹងបំផុត តែពួកអ្នកមិនដឹងឡើយ។

217. មនុស្សលោកនឹងសួរអ្នក(ឱព្យាការីមូហាំម៉ាត់)អំពី(ច្បាប់)ការធ្វើសង្គ្រាមក្នុងខែបម្រាម ។ ចូរអ្នកតបថា៖ ការធ្វើសង្គ្រាមនៅក្នុងខែទាំងនោះ គឺជារឿងធំធេងបំផុត។ តែការរារាំងមនុស្សលោកពីមាគ៌ាអល់ឡោះ ការប្រឆាំងនឹងទ្រង់ ការរារាំងបណ្តាអ្នកមានជំនឿពីម៉ាស្ជិតអាល់ហារ៉ម និងការបណ្តេញអ្នកដែលរស់នៅទីនោះ(ដោយបង្ខំ)ចេញអំពីវា គឺជារឿងធំធេងបំផុតចំពោះអល់ឡោះ(ជាងការធ្វើសង្គ្រាមនៅក្នុងបណ្តាខែបម្រាមទៅទៀត)។ ហើយការបង្កភាពវឹកវរ(អំពើស្ទុះកែ) វាជារឿងធំធេងជាងការកាប់សម្លាប់ទៅទៀត។ ហើយពួកគេ(ពួកមុស្លីគីន)នៅតែបន្តធ្វើសង្គ្រាមប្រយុទ្ធនឹងពួកអ្នក រហូតទាល់តែពួកគេអាចបង្វែរពួកអ្នកឱ្យចេញពីសាសនារបស់ពួកអ្នក បើសិនជាពួកគេមានលទ្ធភាពធ្វើដូច្នោះ។ ហើយជនណាមួយក្នុងចំណោមពួកអ្នកដែលបានចេញពីសាសនារបស់ខ្លួន(សាសនាអ៊ីស្លាម)វិញ ហើយរូបគេបានស្លាប់ទាំងដែលគេជាអ្នកគ្មានជំនឿនោះ ពិតប្រាកដណាស់ ពួកទាំងនោះ អំពើល្អទាំងឡាយរបស់ពួកគេត្រូវរលាយសាបសូន្យទាំងអស់ ទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយពួកទាំងនោះ គឺជាពួកហាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

218. ជាការពិតណាស់ បណ្តាអ្នកដែលមានជំនឿ និងបណ្តាអ្នកដែលចំណាកស្រុក ហើយពួកគេបានតស៊ូ(ប្រយុទ្ធ)ក្នុងមាគ៌ារបស់អល់ឡោះនោះ អ្នកទាំងនោះហើយដែលពួកគេមានសង្ឃឹមចំពោះក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

219. ពួកគេនឹងសួរអ្នក(ព្យាការីមូហាំម៉ាត់)អំពីស្រា និងល្បែងស៊ីសង។ ចូរអ្នកតបថា៖ វាទាំងពីរនេះ គឺផ្តល់នូវគ្រោះថ្នាក់យ៉ាងធំធេង តែក៏មានផលប្រយោជន៍(តិចតួច)ដល់មនុស្សខ្លះដែរ។ ប៉ុន្តែគ្រោះថ្នាក់របស់វាទាំងពីរ គឺធំធេងជាងផលប្រយោជន៍ដែលទទួលបានអំពីវា។ ហើយពួកគេនឹងសួរអ្នកផងដែរអំពីអ្វីទៅដែលពួកគេត្រូវបរិច្ចាគ? ចូរអ្នកតបថា៖ គឺអ្វីដែលលើសពីតម្រូវការ(របស់ពួកអ្នក)។ ក៏ដូចគ្នាដែរ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជាក់នូវបណ្តាច្បាប់បញ្ញត្តិ(របស់ទ្រង់)ដល់ពួកអ្នកសង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

220. ទាំងក្នុងលោកិយនិងថ្ងៃបរលោក។ ហើយពួកគេនឹងសួរអ្នកអំពីក្មេងកំព្រា។ ចូរអ្នកតបថា៖ ការថែរក្សាទ្រព្យសម្បត្តិរបស់ពួកគេឲ្យបានល្អនោះ គឺជាការប្រសើរបំផុត(ទាំងសម្រាប់ពួកអ្នក និងសម្រាប់ក្មេងកំព្រា)។ តែប្រសិនបើពួកអ្នករស់នៅលាយឡំជាមួយពួកគេនោះ ពិតណាស់ពួកគេ គឺជាបងប្អូនរបស់ពួកអ្នក។ ហើយអល់ឡោះដឹងបំផុតចំពោះអ្នកដែលបំពាននិងអ្នកដែលធ្វើបានល្អ(ក្នុងការគ្រប់គ្រងក្មេងកំព្រា)។ ហើយប្រសិនបើអល់ឡោះមានចេតនាទ្រង់ប្រាកដជានឹងធ្វើឱ្យពួកអ្នកលំបាកជាមិនខាន។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

221. ហើយចូរពួកអ្នកកុំរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្ត្រីដែលធ្វើស្ទុះកែ(ពហុទេពនិយម)ឱ្យសោះ លុះត្រាតែពួកនាងមានជំនឿ(ចំពោះអល់ឡោះតែមួយគត់)។ ពិតប្រាកដណាស់ ទាសីដែលមានជំនឿនោះ គឺប្រសើរជាងស្ត្រីដែលធ្វើស្ទុះកែទៅទៀត បើទោះបីជានាងធ្វើឱ្យពួកអ្នកចាប់អារម្មណ៍ក៏ដោយ។ ហើយចូរពួកអ្នកកុំរៀបអាពាហ៍ពិពាហ៍ស្ត្រីមូស្លីមឱ្យទៅបុរសដែលធ្វើស្ទុះកែឱ្យសោះ។ ហើយទាសាដែលមានជំនឿ គឺប្រសើរជាងបុរសដែលធ្វើស្ទុះកែទៅទៀត ទោះបីជាគេធ្វើឱ្យពួកអ្នកចាប់អារម្មណ៍ក៏ដោយ។ ពួកទាំងនោះ គឺអំពាវនាវ(ពួកអ្នក)ទៅកាន់ហាននរក តែអល់ឡោះជាម្ចាស់ទ្រង់អំពាវនាវទៅកាន់ឋានសួគ៌ និងការអភ័យទោសដោយការអនុញ្ញាតពីទ្រង់។ ហើយទ្រង់បានបកស្រាយបញ្ជាក់នូវបណ្តាវាក្យខណ្ឌទាំងឡាយរបស់ទ្រង់ដល់មនុស្សលោក សង្ឃឹមថាពួកគេនឹងយកវាជាមេរៀន។

222. ហើយពួកគេនឹងសួរអ្នកអំពីឈាមរដូវ។ ចូរអ្នកតបថា៖ វាគឺជាភាពកខ្វក់មួយ។ ហេតុនេះ ចូរពួកអ្នកចៀសវាងការរួមដំណេកជាមួយភរិយានៅពេលនាងមករដូវ ហើយចូរពួកអ្នកកុំទៅក្បែរពួកនាង(រួមដំណេក) រហូតទាល់តែពួកនាងជ្រះស្អាត(ពីឈាមរដូវ និងបានងូតទឹកសម្អាតកាយរួច)។ នៅពេលណាដែលពួកនាងជ្រះស្អាតហើយនោះ ពួកអ្នកអាចរួមដំណេកជាមួយពួកនាងនៅត្រង់កន្លែងដែលគេបានអនុញ្ញាតដល់ពួកអ្នក(តាមទ្វារមាស)។ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បណ្តាអ្នកដែលសារភាពកំហុស និងបណ្តាអ្នកដែលជ្រះស្អាត។

223. ភរិយារបស់ពួកអ្នក គឺជាថ្នាលសម្រាប់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកមករកថ្នាលរបស់ពួកអ្នក(ពោលគឺទ្វារមាស)តាមដែលពួកអ្នកពេញចិត្តចុះ។ ហើយចូរពួកអ្នកសាងអំពើល្អសម្រាប់ខ្លួនឯង។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ និងត្រូវដឹងថា ជាការពិតណាស់ ពួកអ្នកនឹងជួបទ្រង់(នៅថ្ងៃបរលោក)ជាមិនខាន។ ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ។

224. ចូរពួកអ្នកកុំយកការស្បថស្បែនឹងអល់ឡោះជាលេសដែលរារាំង(ពួកអ្នក)ពីការធ្វើអំពើល្អ ការគោរពកោតខ្លាច និងការផ្សះផ្សារវាងមនុស្សលោកឱ្យសោះ។ ហើយអល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

225. អល់ឡោះជាម្ចាស់មិនយកទោសពៃរ៍ពួកអ្នកចំពោះពាក្យសម្បថដែលពួកអ្នកស្បថដោយអចេតនានោះឡើយ ប៉ុន្តែទ្រង់យកទោសពៃរ៍ពួកអ្នកចំពោះអ្វីដែលកើតឡើងពីចិត្តរបស់ពួកអ្នក(មានចេតនា)។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាទន់ភ្លន់បំផុត។

226. ចំពោះអ្នកដែលស្បថថាមិនរួមមេត្រីជាមួយនឹងភរិយារបស់ខ្លួន គឺត្រូវរង់ចាំមិនឱ្យលើសរយៈពេលបួនខែឡើយ។ តែប្រសិនបើពួកគេត្រឡប់ទៅរួមមេត្រីជាមួយភរិយារបស់ពួកគេវិញ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

227. ហើយប្រសិនបើពួកគេមានបំណងចង់លែងលះ(ដោយបន្តមិនរួមមេត្រី និងមិនវិលត្រលប់ទៅរកពួកនាងវិញនោះ)ពិតប្រាកដណាស់ អល់ឡោះមហាឮ មហាជ្រាបដឹងបំផុត។

228. ហើយស្ត្រីដែលត្រូវបានស្វាមីលែងលះ ពួកនាងត្រូវរង់ចាំរហូតដល់ខ្លួនពួកនាងជ្រះស្អាតពីឈាមដូវចំនួនបីដងសិន(ទើបអាចរៀបការបាន)។ ហើយគេមិនអនុញ្ញាតឱ្យពួកនាងលាក់បាំងនូវអ្វីដែលអល់ឡោះបានបង្កើតនៅក្នុងស្បូនរបស់ពួកនាង(មានផ្ទៃពោះ)នោះឡើយ ប្រសិនបើពួកនាងជាអ្នកមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោកមែននោះ។ ហើយស្វាមីរបស់ពួកនាង ពួកគេមានសិទ្ធិវិលត្រលប់មករួមរស់ជាមួយនឹងពួកនាងវិញក្នុងពេលដែលពួកនាងស្ថិតក្នុងអំឡុងពេលនោះ(រង់ចាំអ៊ិទហ្ទះ)ប្រសិនបើពួកគេមានបំណងចង់សម្រុះសម្រួល(វិលត្រឡប់មកជានានឹងគ្នាវិញ)។ ហើយចំពោះភរិយាវិញ ពួកនាងក៏មានសិទ្ធិដូចសិទ្ធិស្វាមីមានលើពួកនាងដោយសមរម្យដែរ។ តែសម្រាប់ស្វាមី គឺមានឋានៈខ្ពស់ជាងភរិយា(ក្នុងការដឹកនាំ និងបញ្ហាលែងលះគ្នា)។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

229. ការលែងលះ(ដែលប្តីមានសិទ្ធិអាចវិលត្រលប់ទៅរួមរស់នឹងប្រពន្ធវិញ)គឺមានចំនួនពីរដង។ (ក្រោយពីការលែងលះចំនួនពីរដងរួច) ពួកគេទាំងពីរអាចរួមរស់ជាមួយគ្នាដោយសមរម្យ ឬអាចលែងលះគ្នា(ឲ្យដាច់ស្រេច)ដោយល្អប្រពៃ។ ហើយគេមិនអនុញ្ញាតឱ្យពួកអ្នកយកអ្វី(ខាន់ស្លា)ដែលពួកអ្នកបានប្រគល់ជូនពួកនាង(ភរិយា)វិញនោះទេ លើកលែងតែពួកគេទាំងពីរបារម្ភខ្លាចមិនអាចអនុវត្តបាននូវច្បាប់បញ្ញត្តិរបស់អល់ឡោះប៉ុណ្ណោះ។ ដូចនេះ ប្រសិនបើពួកគេទាំងពីរបារម្ភខ្លាចមិនអាចអនុវត្តបាននូវច្បាប់បញ្ញត្តិរបស់អល់ឡោះនោះ គឺគ្មានទោសពៃរ៍អ្វីឡើយទៅលើពួកគេទាំងពីរ ចំពោះអ្វី(ប្រគល់ខាន់ស្លាជូនប្តី)ដែលនាងយកវាជាថ្នូរនឹងការសុំលែងលះរបស់នាងវិញ។ ទាំងនោះ គឺជាច្បាប់បញ្ញត្តិរបស់អល់ឡោះ។ ហេតុនេះ ចូរពួកអ្នកកុំបំពានចំពោះវាឱ្យសោះ។ ហើយជនណាដែលបានបំពានលើច្បាប់បញ្ញត្តិរបស់អល់ឡោះនោះ ជាការពិតណាស់ ពួកទាំងនោះហើយ គឺជាពួកដែលបំពាន។

230. ប្រសិនបើស្វាមីបានលែងលះនាង(ជាលើកទីបី)ហើយនោះ គឺមិនអនុញ្ញាតឱ្យគេត្រឡប់ទៅរួមរស់ជាមួយនាងបន្ទាប់ពីនោះឡើយ លុះត្រាតែនាងបានរៀបការជាមួយបុរសផ្សេងសិន។ ហើយប្រសិនបើប្តីក្រោយរបស់នាងបានលែងលះនាង(ឬបាត់បង់ជីវិត) គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេទាំងពីរ(ប្រពន្ធនិងប្តីដើម)ក្នុងការវិលត្រលប់មករួមរស់នឹងគ្នាវិញ ប្រសិនបើគេទាំងពីរគិតថា ពួកគេទាំងពីរអាចអនុវត្តនូវច្បាប់បញ្ញត្តិរបស់អល់ឡោះបាន។ បណ្តាច្បាប់បញ្ញត្តិរបស់អល់ឡោះទាំងនោះហើយ ដែលទ្រង់បានបកស្រាយបញ្ជាក់វាដល់ក្រុមដែលចេះដឹង។

231. បើកាលណាពួកអ្នកបានលែងលះភរិយារបស់ពួកអ្នក ហើយពួកនាងជិតផុតកំណត់អ៊ិទហ្ទះ(រយៈពេលរង់ចាំ)របស់ពួកនាង ហើយនោះ គឺពួកអ្នកអាចរួលត្រលប់មករួមរស់ជាមួយនឹងពួកនាងវិញដោយសមរម្យ ឬក៏លែងលះពួកនាង(បណ្តោយឱ្យផុតអ៊ិទហ្ទះ)ដោយល្អប្រពៃ។ ហើយពួកអ្នកមិនត្រូវរួលត្រលប់ទៅរួមរស់ជាមួយនឹងពួកនាងវិញក្នុងគោលបំណងអាក្រក់ដើម្បីបំពានលើពួកនាងនោះឡើយ។ ជនណាដែលធ្វើបែបនេះ ជាការពិតណាស់ គេពិតជាបានបំពានលើខ្លួនឯង។ ហើយចូរពួកអ្នកកុំយកវាក្យខណ្ឌរបស់អល់ឡោះមកធ្វើជាការលេងសើចឱ្យសោះ។ ហើយចូរពួកអ្នកនឹកឃើញនូវឱបការគុណរបស់អល់ឡោះដែលទ្រង់បានប្រទានឱ្យពួកអ្នក ហើយនិងអ្វីដែលទ្រង់បានបញ្ចុះមកឱ្យពួកអ្នកនៃគម្ពីរ(គួរអាន) និងស៊ុណ្ណះ(មាគ៌ារបស់ព្យាការីមូហាំម៉ាត់)ដើម្បីទ្រង់រំឭកពួកអ្នកតាមរយៈវា។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ និងត្រូវដឹងថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

232. ហើយបើកាលណាពួកអ្នកបានលែងលះភរិយារបស់ពួកអ្នក(តិចជាងបីដង) ហើយបានផុតកំណត់រយៈពេលរង់ចាំ(អ៊ិទហ្ទះ)របស់នាងហើយនោះ ចូរពួកអ្នក(អាណាព្យាបាល)កុំរារាំងពួកនាងមិនឱ្យរៀបការជាមួយស្វាមីរបស់ពួកនាងវិញឲ្យសោះ ប្រសិនបើពួកគេទាំងពីរពេញចិត្តនឹងរួមរស់ជាមួយគ្នាវិញដោយល្អប្រសើរ។ នោះគឺជាការដាស់រំឭកដល់អ្នកដែលមានជំនឿនឹងអល់ឡោះនិងថ្ងៃបរលោក។ ទាំងនោះជាប្រការដែលល្អប្រសើរ និងស្អាតស្អំបំផុតសម្រាប់ពួកអ្នក។ ហើយអល់ឡោះទ្រង់ជ្រាបដឹងបំផុត ខណៈដែលពួកអ្នកមិនដឹងឡើយ។

233. ហើយមាតាទាំងឡាយគប្បីបំបៅកូនៗរបស់ខ្លួនរយៈពេលពីរឆ្នាំពេញសម្រាប់ជនណាដែលមានបំណងចង់បំពេញឱ្យគ្រប់នូវការបំបៅ(កូនរបស់ខ្លួន)។ ហើយចាំបាច់លើឪពុកទាក រួវផ្គត់ផ្គង់ជីវភាព និងសម្លៀកបំពាក់ដល់ពួកនាង(ទៅតាមលទ្ធភាព)ដោយសមរម្យ។ អល់ឡោះមិនដាក់បន្ទុកលើនរណាម្នាក់ឱ្យហួសពីលទ្ធភាពរបស់គេឡើយ។ ហើយចំពោះឪពុកម្តាយមិនត្រូវបានអនុញ្ញាតឱ្យយកកូនរបស់ខ្លួនធ្វើជាមធ្យោបាយដើម្បីធ្វើឱ្យប៉ះពាល់ដល់ភាគីម្ខាងទៀតឡើយ។ ហើយចំពោះអ្នកដែលទទួលមរតកទាក(អាណាព្យាបាល) គឺត្រូវទទួលបន្ទុកបំពេញភាតព្វកិច្ចដូចឪពុកទាកនោះផងដែរ។ ប្រសិនបើគេទាំងពីរ(ឪពុកម្តាយ)ចង់ផ្តាច់ដោះកូន(មុនគ្រប់រយៈពេលពីរឆ្នាំ) ហើយគេទាំងពីរបានពិភាក្សាព្រមព្រៀងគ្នានោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេទាំងពីរ(ក្នុងការធ្វើដូច្នោះ)។ ហើយប្រសិនបើពួកអ្នកចង់ស្វែងរកអ្នកបំបៅ(ម៉ែដោះ)ឱ្យកូនៗរបស់ពួកអ្នក ក៏គ្មានទោសពៃរ៍អ្វីឡើយទៅលើពួកអ្នក ប្រសិនបើពួកអ្នកប្រគល់ឲ្យពួកគេនូវអ្វីដែលពួកអ្នកបាននាំមក(ជាថ្លៃឈ្នួល)ដោយសមរម្យ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ និងត្រូវដឹងថា ជាការពិតណាស់ អល់ឡោះទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

234. អ្នកដែលបានស្លាប់ក្នុងចំណោមពួកអ្នក ហើយគេបានបន្សល់ទុកនូវភរិយា គឺចាំបាច់លើពួកនាងត្រូវរង់ចាំអ៊ិទហ្ទះរយៈពេលបួនខែដប់ថ្ងៃសិន។ ប្រសិនបើផុតរយៈពេលកំណត់របស់ពួកនាងហើយនោះ គឺគ្មានទោសពៃរ៍អ្វីឡើយលើពួកអ្នក(អាណាព្យាបាល)ចំពោះអ្វីដែលពួកនាងបានធ្វើសម្រាប់ខ្លួនពួកនាង(តុបតែងរាងកាយ)ដោយសមរម្យនោះ។ ហើយអល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

235. ហើយក៏គ្មានទោសពៃរ៍អ្វីដែរលើពួកអ្នកចំពោះអ្វីដែលពួកអ្នកបានបង្ហាញចេញ(ពីបំណង)នៃការស្តីដណ្តឹងស្ត្រី(ដែលស្ថិតនៅក្នុងរយៈពេលរង់ចាំអ៊ិទហ្ទះ) ឬក៏ពួកអ្នកលាក់ទុកក្នុងចិត្តរបស់ពួកអ្នកនោះ។ អល់ឡោះទ្រង់ដឹងថា ពួកអ្នកនឹងនឹកគិតដល់ពួកនាង ក៏ប៉ុន្តែពួកអ្នកមិនត្រូវសន្យាស្ងាត់ៗ(ថានឹងរៀបការ)ជាមួយពួកនាងឡើយ លើកលែងតែពួកអ្នកនិយាយនូវពាក្យសម្តីដែលសមរម្យប៉ុណ្ណោះ។ ហើយចូរពួកអ្នកកុំរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្ត្រីដែលស្ថិតនៅក្នុងរយៈពេលរង់ចាំអ៊ិទហ្ទះឱ្យសោះ លុះត្រាតែផុតរយៈពេលកំណត់សិន។ ហើយចូរពួកអ្នកដឹងថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតចំពោះអ្វីដែលមាននៅក្នុងខ្លួនពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចទ្រង់ ហើយត្រូវដឹងចុះថា ជាការពិតណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាទន់ភ្លន់បំផុត។

236. គ្មានទោសពៃរ៍អ្វីឡើយទៅលើពួកអ្នក ប្រសិនបើពួកអ្នកលែងលះភរិយារបស់ពួកអ្នក ដរាបណាពួកអ្នកមិនទាន់បានផ្សំដំណេកជាមួយពួកនាង ឬមិនទាន់ដាក់កំណត់ខាន់ស្លាជូនពួកនាងទេនោះ ប៉ុន្តែពួកអ្នកត្រូវផ្តល់ឱ្យពួកនាងនូវអ្វីមួយដែលធ្វើឱ្យពួកនាងរីករាយទៅតាមលទ្ធភាពដោយសមរម្យ ទោះបីគេជាអ្នកមានជីវភាពធូធារ ឬជាអ្នកមានជីវភាពខ្វះខាតក៏ដោយ។ នេះគឺជាកាតព្វកិច្ចលើបណ្តាអ្នកដែលសាងអំពើល្អ។

237. ហើយប្រសិនបើពួកអ្នកលែងលះភរិយារបស់ពួកអ្នកមុននឹងពួកអ្នកផ្សំដំណេកជាមួយពួកនាង តែពួកអ្នកបានកំណត់នូវខាន់ស្លាជូនពួកនាងហើយនោះ គឺពួកអ្នកត្រូវផ្តល់ឱ្យពួកនាងពាក់កណ្តាលនៃខាន់ស្លាដែលពួកអ្នកបានកំណត់ លើកលែងតែពួកនាងអធ្យាស្រ័យ(ដោយមិនយកខាន់ស្លា) ឬមួយពួកគេ(ប្តី)អធ្យាស្រ័យដោយ(សុខចិត្ត)លះបង់ខាន់ស្លា(ដែលបានកំណត់)នោះឱ្យពួកនាងទាំងអស់។ ហើយការអធ្យាស្រ័យរបស់ពួកអ្នកចំពោះគ្នាទៅវិញទៅមក គឺធ្វើឱ្យពួកអ្នកកាន់តែខិតជិតទៅរកការកោតខ្លាចអល់ឡោះ។ ហើយចូរពួកអ្នកកុំភ្លេចនូវអំពើសប្បុរសដែលពួកអ្នកធ្លាប់បានធ្វើចំពោះគ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អល់ឡោះដាម្ចាស់ទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

238. ចូរពួកអ្នកថែរក្សាការសឡាត(ទាំងប្រាំពេល)ជាពិសេសសឡាតមួយដែលស្ថិតនៅកណ្តាលគេ(សឡាតអាសើរ)។ ហើយចូរពួកអ្នកឈរសឡាតចំពោះអល់ឡោះដោយការគោរពតាមប្រកបដោយភាពនឹងនរ។

239. ហើយប្រសិនបើពួកអ្នកមានការបារម្ភខ្លាច(សត្រូវឬអ្វីផ្សេងទៀត) ចូរពួកអ្នកសឡាតដោយដើរ ឬជិះលើយានជំនិះ។ នៅពេលដែលពួកអ្នកមានសុវត្ថិភាពវិញហើយនោះ ចូរពួកអ្នករំឭកចំពោះអល់ឡោះដូចអ្វីដែលទ្រង់បានបង្រៀនដល់ពួកអ្នកនូវអ្វីដែលពួកអ្នកមិនធ្លាប់ដឹងពីមុន។

240. អ្នកដែលបានស្លាប់ក្នុងចំណោមពួកអ្នក(ស្វាមី) ហើយបានបន្សល់ទុកនូវភរិយា ចាំបាច់លើពួកគេត្រូវធ្វើបណ្តាំសម្រាប់ភរិយារបស់ខ្លួននូវការផ្តត់ផ្គង់ចំពោះលំនៅឋាននិងជីវភាពរយៈពេលមួយឆ្នាំពេញ ដោយមិនត្រូវបណ្តេញពួកនាងឱ្យចេញពីលំនៅឋាន(ដោយបង្ខំ)នោះឡើយ។ តែប្រសិនបើពួកនាងចាកចេញពីលំនៅឋាន(ដោយខ្លួនឯង)គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នក(និងពួកនាង)នូវអ្វីដែលពួកនាងបានធ្វើសម្រាប់ខ្លួនពួកនាង(នៃការតុបតែងកាយ)ដោយសមរម្យនោះ។ ហើយអល់ឡោះដាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

241. ហើយសម្រាប់ស្ត្រី(ជាភរិយា)ដែលត្រូវគេលែងលះនោះ គឺទទួលបាននូវការផ្តត់ផ្គង់ជីវភាពដោយសមរម្យ។ វាជាកាតព្វកិច្ចលើបណ្តាអ្នកដែលកោតខ្លាចអល់ឡោះ។

242. ក៏ដូចគ្នាដែរ អល់ឡោះដាម្ចាស់ទ្រង់បកស្រាយបញ្ជាក់ដល់ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)នូវបណ្តាវាក្យខណ្ឌជាច្រើនរបស់ទ្រង់ សង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

243. តើអ្នក(ព្យាការីមូហាំម៉ាត់)មិនទាន់ទទួលបានដំណឹងអំពីរឿងរ៉ាវរបស់ពួកដែលបានចាកចេញពីលំនៅឋានរបស់ពួកគេ ខណៈដែលពួកគេមានគ្នាច្រើនរាប់ពាន់នាក់ដោយការភ័យខ្លាចពីសេចក្តីស្លាប់ទេឬ? ពេលនោះ អល់ឡោះដាម្ចាស់ក៏បានមានបន្ទូលទៅកាន់ពួកគេថា៖ ចូរពួកអ្នកស្លាប់ចុះ។ ក្រោយមក ទ្រង់ក៏បានប្រោសពួកគេឱ្យរស់ឡើងវិញ។ ពិតប្រាកដណាស់ អល់ឡោះដាអ្នកដែលមានការប្រោសប្រទានបំផុតចំពោះមនុស្សលោក។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនដឹងគុណឡើយ។

244. ហើយចូរពួកអ្នកប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះ និងត្រូវដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាឮ មហាដឹងបំផុត។

245. ជនណាហើយដែលបានឱ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ល្អប្រពៃនោះ ទ្រង់នឹងបង្កើន(តបស្នង)ដល់គេវិញនូវការបង្កើនមួយដ៏ច្រើនលើសលប់ទ្វេដង។ ហើយអល់ឡោះទ្រង់ត្បិតត្បៀត និងបើកទូលាយ។ ហើយពួកអ្នកនឹងត្រូវគេនាំត្រលប់ទៅកាន់ទ្រង់(នៅថ្ងៃបរលោក)។

246. តើអ្នក(ឱព្យាការីមូហាំម៉ាត់)មិនទាន់ទទួលបានដំណឹងស្តីពីរឿងរ៉ាវរបស់ពួកមេដឹកនាំក្នុងចំណោមអម្បូរអ៊ីស្រាអែលក្រោយសម័យកាលព្យាការីមូសាទេឬ? ខណៈដែលពួកគេបាននិយាយទៅកាន់ព្យាការីរបស់ពួកគេថា៖ ចូរអ្នកតែងតាំងឱ្យពួកយើងនូវមហាក្សត្រមួយអង្គដើម្បីពួកយើងនឹងប្រយុទ្ធតស៊ូក្នុងមាគ៌ារបស់អល់ឡោះ។ គាត់បានតបថា៖ តើពួកអ្នកបានគិតទេថា ប្រសិនបើអល់ឡោះដាក់កាតព្វកិច្ចសង្គ្រាមលើពួកអ្នក រួចមកពួកអ្នកបែរជាមិនចូលរួមប្រយុទ្ធវិញនោះ? ពួកគេបានឆ្លើយថា៖ តើមានអ្វីដែលរារាំងពួកយើងមិនឱ្យធ្វើសង្គ្រាមប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះនោះ ខណៈដែលគេ(សត្រូវ)បានបណ្តេញពួកយើងចេញពីលំនៅឋានរបស់ពួកយើង និងកូនចៅរបស់ពួកយើងនោះ។ ប៉ុន្តែនៅពេលដែលគេ(អល់ឡោះ)បានដាក់កាតព្វកិច្ចលើពួកគេឱ្យធ្វើសង្គ្រាម ពួកគេបែរជាងាកចេញទៅវិញ លើកលែងតែមួយចំនួនតូចក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហើយអល់ឡោះជាម្ចាស់មហាដឹងបំផុតចំពោះពួកដែលបំពាន។

247. ហើយព្យាការីរបស់ពួកគេបាននិយាយទៅកាន់ពួកគេថា៖ ជាការពិតណាស់ អល់ឡោះទ្រង់បានតែងតាំង តលូត ឱ្យធ្វើជាមហាក្សត្រគ្រប់គ្រងលើពួកអ្នក។ ពួកគេ(ពួកមេដឹកនាំ)បានតបវិញថា៖ តើឱ្យគេធ្វើជាមហាក្សត្រគ្រប់គ្រងលើពួកយើងយ៉ាងដូចម្តេចទៅ ខណៈដែលពួកយើងសក្តិសមធ្វើជាស្តេចជាងរូបគេ ហើយគេក៏ពុំមែនជាអ្នកដែលមានទ្រព្យសម្បត្តិសុកសម្ភផងនោះ? គាត់បានតបថា៖ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានជ្រើសតាំងរូបគេឱ្យគ្រប់គ្រងលើពួកអ្នក ហើយទ្រង់បានបន្ថែមនូវចំណេះដឹងដ៏ទូលំទូលាយ និងកម្លាំងកាយដ៏ខ្លាំងក្លាដល់រូបគេ។ អល់ឡោះទ្រង់ប្រទានអំណាចរបស់ទ្រង់ដល់ជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាវិសេសវិសាល មហាដឹងបំផុត។

248. ហើយព្យាការីរបស់ពួកគេបាននិយាយទៅកាន់ពួកគេទៀតថា៖ ជាការពិតណាស់ និមិត្តសញ្ញានៃភាពជាមហាក្សត្ររបស់គេនោះ គឺទ្រង់នឹងត្រឡប់ហឹបមកឱ្យពួកអ្នកវិញ ដែលនៅក្នុងហឹបនោះ គឺមានភាពនឹងនរពីព្រះជាម្ចាស់របស់ពួកអ្នក និងកេរដំណែលមួយចំនួនដែលក្រុមគ្រួសាររបស់ព្យាការីមូសា និងក្រុមគ្រួសាររបស់ព្យាការីហារូនបានបន្សល់ទុក ដែលម៉ាឡាអ៊ីកាត់ជាអ្នកនាំហឹបនោះមក។ ពិតប្រាកដណាស់នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។

249. ហើយនៅពេលដែលតលូតបានដឹកនាំទាហានចាកចេញពីមាតុភូមិ(របស់ពួកគេ)គាត់បាននិយាយ(ទៅកាន់ពួកគេ)ថា៖ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានយកទន្លេមួយមកសាកល្បងពួកអ្នក។ ដូចនេះ ជនណាដែលបានផឹកទឹកទន្លេគឺគេមិនមែនស្ថិតក្នុងចំណោមក្រុមរបស់ខ្ញុំឡើយ។ តែជនណាដែលមិនបានផឹកទឹកទន្លេនោះ គឺគេស្ថិតនៅក្នុងក្រុមរបស់ខ្ញុំ លើកលែងតែអ្នកដែល(ត្រូវបង្ខំចិត្ត)ផឹកទឹកមួយកំបង់ដៃប៉ុណ្ណោះ(គឺគ្មានបញ្ហាអ្វីឡើយ)។ ពេលនោះ ពួកគេបានផឹកទឹកទន្លេនោះទាំងអស់គ្នា លើកលែងតែមួយចំនួនតូចក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហើយនៅពេលដែលគាត់(តលូត)និងអ្នករួមដំណើរជាមួយគាត់ដែលជាអ្នកមានជំនឿបានឆ្លងផុតទន្លេនោះ ពួកគេ(មួយចំនួន)បាននិយាយថា៖ ថ្ងៃនេះពួកយើងគ្មានលទ្ធភាពប្រយុទ្ធនឹងជើលូត និងទាហានរបស់គេទេ។ នៅពេលនោះ បណ្តាអ្នកដែលជឿជាក់ក្នុងចិត្តថា ពួកគេនឹងបានជួបអល់ឡោះ(នៅថ្ងៃបរលោក)បាននិយាយថា៖ តើមានប៉ុន្មានដងហើយដែលក្រុម(អ្នកមានជំនឿ)មានគ្នាតិចបានយកឈ្នះក្រុម(ពួកគ្មានជំនឿ)ដែលមានគ្នាច្រើនដោយការអនុញ្ញាតពីអល់ឡោះជាម្ចាស់នោះ? ហើយអល់ឡោះទ្រង់ស្ថិតនៅជាមួយបណ្តាអ្នកដែលអត់ធ្មត់។

250. ហើយនៅពេលដែលពួកគេបានចេញទៅប្រឈមមុខជាមួយជើលូត និងទាហានរបស់គេ ពួកគេបានបួងសួងថា៖ បពិត្រអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាស្រោចស្រពនូវភាពអត់ធ្មត់មកលើពួកយើង ហើយសូមទ្រង់មេត្តាពង្រឹងជំហររបស់ពួកយើង និងសូមទ្រង់មេត្តាជួយពួកយើងឱ្យយកឈ្នះលើក្រុមដែលគ្មានជំនឿផងចុះ។

251. ពេលនោះពួកគេបានធ្វើឱ្យសត្រូវរបស់ពួកគេទទួលបរាជ័យដោយការអនុញ្ញាតពីអល់ឡោះ ហើយព្យាការីហ្គារូទក៏បានសម្លាប់ដើលូត។ ហើយអល់ឡោះបានប្រទានន្ូវអំណាចជាស្តេចផែនដីនិងគតិបណ្ឌិត(ភាពជាព្យាការី) ព្រមទាំងបានបង្រៀនដល់គាត់នូវអ្វីដែលទ្រង់មានចេតនា។ ហើយប្រសិនបើអល់ឡោះមិនទប់ទល់នឹងមនុស្សមួយចំនួន(ដែលបង្កវិនាសកម្ម)ដោយមនុស្សមួយចំនួនទៀតទេនោះ ច្បាស់ជាផែនដីនឹងត្រូវវិនាសអន្តរាយជាមិនខាន។ ក៏ប៉ុន្តែ អល់ឡោះជាម្ចាស់ទ្រង់មានក្តីសប្បុរសចំពោះពិភពទាំងអស់។

252. ទាំងនោះគឺជាបណ្តាវាក្យខណ្ឌរបស់អល់ឡោះជាម្ចាស់ដែលយើងបានសូត្រវាឱ្យអ្នក(ព្យាការីមូហាំម៉ាត់)ស្តាប់។ ហើយជាការពិតណាស់ រូបអ្នកគឺពិតជាស្ថិតក្នុងចំណោមអ្នកនាំសារម្នាក់(របស់អល់ឡោះ)។

253. បណ្តាអ្នកនាំសារទាំងនោះ យើងបានលើកតម្កើងពួកគេមួយចំនួនឱ្យមានភាពប្រសើរជាងគ្នា។ ក្នុងចំណោមពួកគេ មានអ្នកខ្លះ អល់ឡោះមានបន្ទូលទៅកាន់គេផ្ទាល់។ ហើយទ្រង់បានលើកតម្កើងអ្នកមួយចំនួនក្នុងចំណោមពួកគេឱ្យមានឋានៈខ្ពង់ខ្ពស់(ជាងអ្នកនាំសារផ្សេងទៀត)។ ហើយយើងបានប្រទានឱ្យអ៊ីសាកូនរបស់ម៉ារយ៉ាំ(យេស៊ូគ្រីស្ត) នូវអច្ឆរិយភាពជាច្រើនដ៏ច្បាស់លាស់ ហើយយើងបានពង្រឹងរូបគេតាមរយៈម៉ាឡាអ៊ីកាត់ដ៏ព្រឹល។ ហើយប្រសិនបើអល់ឡោះមានចេតនានោះអ្នកជំនាន់ក្រោយពួកគេនឹងមិនកាប់សម្លាប់គ្នាឡើយ បន្ទាប់ពីភស្តុតាងនានាដ៏ច្បាស់លាស់បានមកដល់ពួកគេហើយនោះ។ ក៏ប៉ុន្តែពួកគេបានខ្វែងគំនិតគ្នា។ ដូច្នេះ មួយចំនួននៃពួកគេ បានជឿ(ចំពោះអល់ឡោះ) ហើយមួយចំនួនទៀតនៃពួកគេ គឺគ្មានជំនឿ(ចំពោះទ្រង់)។ ហើយប្រសិនបើអល់ឡោះមានចេតនា ប្រាកដជាពួកគេនឹងមិនកាប់សម្លាប់គ្នាឡើយ។ ក៏ប៉ុន្តែ អល់ឡោះទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។

254. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកបរិច្ចាគមួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកអ្នកមុននឹងថ្ងៃមួយ(ថ្ងៃបរលោក)បានមកដល់ដែលគ្មានឡើយការលក់ដូរ គ្មានទេមិត្តភាព ហើយក៏គ្មានដៃរកាជួយអន្តរាគមន៍នោះ។ ហើយពួកគ្មានជំនឿ ពួកគេគឺជាពួកដែលបំពាន។

255. អល់ឡោះគឺជាព្រះជាម្ចាស់តែមួយគត់ ដែលគ្មានព្រះជាម្ចាស់ណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមានជីវិតអមតៈ ជាអ្នកគ្រប់គ្រងនោះឡើយ។ ទ្រង់ឥតងងុយគេង ហើយឥតសម្រាន្តឡើយ។ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ គ្មានបុគ្គលណាម្នាក់ហ៊ានធ្វើអន្តរាគមន៍នៅចំពោះមុខទ្រង់ឡើយ លើកលែងតែដោយមានការអនុញ្ញាតពីទ្រង់ប៉ុណ្ណោះ។ ទ្រង់ដឹងនូវអ្វីដែលបានកន្លងផុត និងអ្វីដែលនឹងកើតឡើង។ ហើយពួកគេមិនដឹងអ្វីមួយក្នុងចំណោមការដឹងរបស់ទ្រង់ឡើយ លើកលែងតែអ្វីដែលទ្រង់មានចេតនា(ឱ្យគេដឹង)ប៉ុណ្ណោះ។ ហើយគួរស៊ើយ(កន្លែងដាក់ព្រះបាទ)របស់ទ្រង់ទូលំទូលាយគ្រប់ដណ្តប់លើមេឃជាច្រើនជាន់ និងផែនដី។ ការថែរក្សាវាទាំងពីរ(មេឃនិងផែនដី)មិនមានភាពលំបាកចំពោះទ្រង់ឡើយ។ ហើយទ្រង់មហាខ្ពង់ខ្ពស់ មហាធំធេង។

256. គ្មានការបង្ខិតបង្ខំឡើយនៅក្នុងសាសនា(អ៊ីស្លាម)។ ពិតប្រាកដណាស់ ការពិតបានបង្ហាញច្បាស់ពីប្រការមិនពិត(ភាពវង្វេង)។ ហេតុនេះ ជនណាហើយដែលបដិសេធចំពោះអ្វីដែលគេគោរពសក្ការៈផ្សេងពីអល់ឡោះ ហើយគេមានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់នោះ ពិតប្រាកដណាស់ គេពិតជាបានប្រកាន់ខ្ជាប់នូវខ្សែដ៏រឹងមាំ(សាសនាអ៊ីស្លាម)ដោយមិនងាយនឹងដាច់ឡើយ។ ហើយអល់ឡោះមហាឮ មហាដឹងបំផុត។

257. អល់ឡោះជាអ្នកគាំពារបណ្តាអ្នកមានជំនឿ ដោយបញ្ចោញពួកគេពីភាពងងឹត(នៃភាពគ្មានជំនឿនិងភាពល្ងង់ខ្លៅ)ទៅកាន់ពន្លឺ(នៃសេចក្តីជំនឿនិងចំណេះដឹង)។ រីឯពួកគ្មានជំនឿវិញ អ្នកគាំពាររបស់ពួកគេ គឺតហ្ឃូត (ព្រះនានានិងរូបបដិមាទាំងឡាយ) ដោយពួកវាបញ្ចោញពួកគេអំពីពន្លឺទៅកាន់ភាពងងឹតសូន្យសុង។ ពួកទាំងនោះហើយ គឺជាពួកឋាននរកដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

258. តើអ្នកមិនបានឃើញទេឬ(ឱព្យាការីមូហាំម៉ាត់) អំពីជនម្នាក់ដែលអល់ឡោះបានប្រទានឱ្យគេនូវអំណាចជាស្តេចផែនដី បានជជែកដេញដោលនឹងព្យាការីអ៊ីព្រហ៊ីមអំពីព្រះជាម្ចាស់របស់គាត់នោះ ? ពេលនោះ ព្យាការីអ៊ីព្រហ៊ីមបាននិយាយថា៖ ព្រះជាម្ចាស់របស់ខ្ញុំ គឺជាអ្នកប្រទានជីវិត និងជាអ្នកដកហូតជីវិត។ ជននោះបានតបវិញថា៖ យើងក៏ជាអ្នកប្រទានជីវិត និងដកហូតយកជីវិតដែរ។ ពេលនោះ ព្យាការីអ៊ីព្រហ៊ីមក៏បានតបទៅកាន់គេវិញថា៖ ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកដែលធ្វើឱ្យព្រះអាទិត្យរះចេញពីទិសខាងកើត។ ដូចនេះ ចូរអ្នកឱ្យព្រះអាទិត្យរះចេញពីទិសខាងលិចមកវិញម្តងមើល៍។ ពេលនោះ ជនដែលប្រឆាំងនោះក៏បានទាល់តម្រិះ។ ហើយអល់ឡោះមិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

259. ឬប្រៀបដូចជាអ្នកដែលបានឆ្លងកាត់ភូមិមួយដែលត្រូវបានបំផ្លាញខ្ទេចខ្ទីអស់(ទាំងមនុស្ស ទាំងលំនៅឋាន)។ ជននោះបានសួរថា៖ តើអល់ឡោះធ្វើឲ្យអ្នកភូមិនេះរស់ឡើងវិញយ៉ាងដូចម្តេចក្រោយពីពួកគេបានស្លាប់ហើយនោះ ? ពេលនោះ អល់ឡោះក៏បានធ្វើឱ្យជននោះស្លាប់រយៈពេលមួយរយឆ្នាំ។ ក្រោយមក ទ្រង់បានប្រោសគេឱ្យរស់ឡើងវិញ។ ទ្រង់បានសួរថា៖ តើអ្នកស្នាក់នៅទីនេះរយៈពេលប៉ុន្មានហើយ ? គេបានឆ្លើយថា៖ ខ្ញុំនៅទីនេះរយៈពេលមួយថ្ងៃ ឬតិចជាងមួយថ្ងៃ។ ទ្រង់ក៏បានតបវិញថា៖ ផ្ទុយទៅវិញ អ្នកនៅទីនេះរយៈពេលមួយរយឆ្នាំហើយ។ ចូរអ្នកមើលទៅកាន់ម្ហូបអាហារ និងកេសដ្ឋៈរបស់អ្នក តើវាឥតមានប្រែប្រួលទេឬ ? ហើយចូរអ្នកមើលទៅកាន់សត្វលារបស់អ្នក។ (យើងធ្វើដូច្នេះ)គឺដើម្បីយើងយកអ្នកធ្វើជាភស្តុតាងសម្រាប់មនុស្សលោក។ ហើយចូរអ្នកមើលទៅឆ្អឹងទាំងនោះ តើយើងផ្គុំវាចូលគ្នា បន្ទាប់មក ស្រោបវាដោយសាច់វិញយ៉ាងដូចម្តេច ? នៅពេលដែលការពិតបានបញ្ជាក់យ៉ាងច្បាស់ដល់គេបែបនេះ គេក៏និយាយថា៖ (ពេលនេះ)ខ្ញុំដឹងហើយថា ពិតប្រាកដណាស់ អល់ឡោះទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

260. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្យាការីអ៊ីព្រហ៊ីមបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាបង្ហាញឱ្យខ្ញុំបានឃើញផង ថាតើទ្រង់ប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញដោយរបៀបណា ? ទ្រង់បានមានបន្ទូលថា៖ តើអ្នកមិនទាន់ជឿ(លើរឿងនេះ)ទេឬ ? គាត់ឆ្លើយថា៖ មិនដូច្នោះឡើយ ប៉ុន្តែ គឺដើម្បីឱ្យចិត្តរបស់ខ្ញុំកាន់តែមានភាពនឹងនរ(ជឿជាក់)ថែមទៀតប៉ុណ្ណោះ។ ទ្រង់ក៏បានមានបន្ទូលថា៖ ដូច្នេះ ចូរអ្នកយកសត្វបក្សីចំនួនបួនក្បាល ហើយចិញ្រ្ចាំវាបញ្ចូលគ្នា រួចមកចូរអ្នកយកបំណែកនីមួយៗអំពីសាច់នោះទៅដាក់តាមភ្នំនីមួយៗ(ផ្សេងៗគ្នា)។ បន្ទាប់មក ចូរអ្នកស្រែកហៅពួកវាចុះ នោះពួកវានឹងហើរមកកាន់អ្នកវិញជាមិនខាន។ ហើយចូរអ្នក(ឱអ៊ីព្រហ៊ីម)ដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

261. ការប្រៀបធៀបបណ្តាអ្នកដែលបានបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេក្នុងមាគ៌ារបស់អល់ឡោះ ប្រៀបដូចជាគ្រាប់ធញ្ញជាតិមួយគ្រាប់ដែលបានដុះចេញជាប្រាំពីរកួរ ហើយនៅក្នុងកួរនីមួយៗមានចំនួនមួយរយគ្រាប់។ អល់ឡោះទ្រង់បង្កើន (ផលបុណ្យ)ទ្វេដងចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាវិសេសវិសាល មហាដឹងបំផុត។

262. បណ្តាអ្នកដែលបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេក្នុងមាគ៌ារបស់អល់ឡោះ ក្រោយមក ពួកគេមិនបាននាំមកជាមួយអ្វីដែលពួកគេបានបរិច្ចាគនូវការរំលើកគុណ និងការបញ្ឈឺចិត្ត(ដល់អ្នកទទួល)ទេនោះ ពួកគេនឹងទទួលបានផលបុណ្យពីព្រះជាម្ចាស់របស់ពួកគេ។ ហើយពួកគេគ្មានការភ័យខ្លាចនោះឡើយ ហើយពួកគេក៏គ្មានការព្រួយបារម្ភអ្វីនោះដែរ។

263. ពាក្យសម្តីដែលល្អ ហើយនិងការចេះអភ័យទោស(ដល់អ្នកដទៃ) គឺប្រសើរជាងការបរិច្ចាគដែលភ្ជាប់ជាមួយនូវការបញ្ឈឺចិត្ត។ ហើយអល់ឡោះមហាមានលើសលប់ មហាទន់ភ្លន់បំផុត។

264. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំបំផ្លាញផលបុណ្យនៃការបរិច្ចាគរបស់ពួកអ្នកដោយការរំលើកគុណ និងការបញ្ឈឺចិត្ត(ដល់អ្នកទទួល)ឱ្យសោះ ប្រៀបដូចជាអ្នកដែលបរិច្ចាគទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីបង្ហាញឱ្យមនុស្សបានឃើញ ខណៈដែលគេមិនមានជំនឿលើអល់ឡោះ និងថ្ងៃបរលោកសោះឡើយ។ ការប្រៀបធៀបរូបគេ គឺប្រៀបដូចជាថ្មរលោងមួយដុំដែលមានធូលីដីជាប់ពីលើ រួចភ្លៀងបានធ្លាក់យ៉ាងខ្លាំងមកលើដុំថ្មនោះ ធ្វើឱ្យថ្មនោះរលោងវិញដោយគ្មានអ្វីនៅជាប់លើវាសោះ។ ពួកគេមិនទទួលបានផលបុណ្យពីអ្វីដែលពួកគេបានសាងបន្តិចណាឡើយ។ ហើយអល់ឡោះមិនចង្អុលបង្ហាញដល់ក្រុមដែលគ្មានជំនឿឡើយ។

265. ហើយការប្រៀបធៀបបណ្តាអ្នកដែលបានបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះ និងមានភាពនឹងនរចំពោះខ្លួនពួកគេផ្ទាល់ គឺប្រៀបដូចជាចម្ការមួយនៅតំបន់ខ្ពង់រាបដែលបានស្រោចស្រពដោយទឹកភ្លៀងយ៉ាងច្រើន។ ពេលនោះ វាក៏ផ្តល់នូវផលានុផលទ្វេដង។ តែប្រសិនបើគ្មានភ្លៀងធ្លាក់ខ្លាំងទេនោះ (សូម្បីតែភ្លៀងតិចតួច) ក៏គ្រប់គ្រាន់ដែរ។ ហើយអល់ឡោះទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

266. តើជនណាក្នុងចំណោមពួកអ្នកពេញចិត្តចង់បានចម្ការល្មើ និងចម្ការទំពាំងបាយជូរដែលមានទន្លេហូរកាត់ពីក្រោមវា ដោយនៅក្នុងចម្ការនោះ ពោរពេញដោយផលានុផលល្អៗជាច្រើនប្រភេទ។ លុះដល់ពេលដែលជននោះមានវ័យចាស់ជរា ព្រមទាំងមានកូនចៅតូចៗទន់ខ្សោយជាច្រើន ស្រាប់តែចម្ការនោះត្រូវទទួលរងនូវព្យុះភ្លើងបក់បោកឆេះខ្ទេចខ្ទីអស់។ (តើមានអ្នកចង់បានបែបនេះដែរឬទេ?) ក៏ដូចគ្នាដែរ អល់ឡោះជាម្ចាស់ទ្រង់បញ្ជាក់ប្រាប់ដល់ពួកអ្នកនូវបណ្តាកស្តុតាងជាច្រើនសង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

267. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកបរិច្ចាគទ្រព្យសម្បត្តិល្អៗមួយចំនួនដែលពួកអ្នករកបាន និងមួយចំណែកនៃភោគផលដែលយើងបានបញ្ចេញពីដីសម្រាប់ពួកអ្នក។ ហើយពួកអ្នកមិនត្រូវជ្រើសរើសអ្វីដែលអាក្រក់អំពីទ្រព្យសម្បត្តិដើម្បីបរិច្ចាគឡើយ ខណៈដែលពួកអ្នកខ្លួនឯងក៏មិនពេញចិត្តនឹងទទួលយកវានោះដែរ លើកលែងតែទទួលយកវាទាំងបិទភ្នែក(មិនពេញចិត្ត)ប៉ុណ្ណោះ។ ហើយចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះមហាមានលើសលប់ ជាអ្នកដែលត្រូវគេកោតសរសើរបំផុត។

268. ស្លែតនបំភ័យពួកអ្នកពីភាពក្រីក្រ និងប្រើពួកអ្នកឱ្យប្រព្រឹត្តអំពើអាក្រក់។ តែអល់ឡោះវិញ ទ្រង់សន្យានឹងពួកអ្នកនូវការអភ័យទោស និងក្តីសប្បុរសអំពីទ្រង់។ ហើយអល់ឡោះមហាវិសេសវិសាល មហាដឹងបំផុត។

269. ទ្រង់ប្រទាននូវគតិបណ្ឌិតដល់ជនណាដែលទ្រង់មានចេតនា។ ហើយជនណាដែលត្រូវបានគេប្រទានឱ្យនូវគតិបណ្ឌិតនោះ ជននោះប្រាកដជាត្រូវបានគេប្រទានឱ្យនូវប្រការល្អដ៏ច្រើនលើសលប់។ ហើយគ្មានអ្នកដែលនឹកឃើញ(ពីរឿងនេះ)ឡើយ លើកលែងតែបញ្ញាជនប៉ុណ្ណោះ។

270. ហើយអ្វីក៏ដោយដែលពួកអ្នកបានបរិច្ចាគ ឬពួកអ្នកបានសច្ចា(ណាហ្ស៊ែរ)នៃការសច្ចាណាមួយនោះ ពិតណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតអំពីវា។ ហើយសម្រាប់ពួកដែលបំពាន គឺគ្មានអ្នកដែលជួយ(ពួកគេ)នោះឡើយ។

271. ប្រសិនបើពួកអ្នកលាតត្រដាងការបរិច្ចាគ(របស់ពួកអ្នក)វាគឺជាការបរិច្ចាគទានមួយដ៏ល្អ។ តែប្រសិនបើពួកអ្នកលាក់បាំងហើយផ្តល់វាដល់ជនក្រីក្រ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក(ជាងការលាតត្រដាងឱ្យគេឃើញ) ហើយគេនឹងជម្រះចោលនូវបាបកម្មរបស់ពួកអ្នកចេញអំពីពួកអ្នក។ ហើយអល់ឡោះមហាដឹងនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

272. ពុំមែនជាកាតព្វកិច្ចរបស់អ្នកនោះទេ(ឱព្យាការីមូហាំម៉ាត់)ក្នុងការផ្តល់ការចង្អុលបង្ហាញដល់ពួកគេនោះ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទៅវិញទេដែលទ្រង់ប្រទានការចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអ្វីដែលពួកអ្នកបានបរិច្ចាគអំពីប្រការល្អនោះ គឺសម្រាប់ខ្លួនពួកអ្នក។ ពួកអ្នកមិនត្រូវបរិច្ចាគឡើយ លើកលែងតែដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ហើយអ្វីដែលពួកអ្នកបរិច្ចាគអំពីប្រការល្អនោះ គេនឹងតបស្នងដល់ពួកអ្នកវិញ ហើយពួកអ្នកមិនត្រូវបានគេបំពានឡើយ។

273. (ចូរពួកអ្នកបរិច្ចាគទាន)ដល់ជនក្រីក្រដែលពួកគេជាប់រវល់តស៊ូក្នុងមាគ៌ារបស់អល់ឡោះមិនអាចឱ្យពួកគេធ្វើដំណើរស្វែងរកលាភសក្ការៈនៅលើផែនដីបាន ធ្វើឱ្យអ្នកដែលមិនដឹង(ពីស្ថានភាពរបស់ពួកគេ)នឹកស្មានថា ពួកគេគឺជាអ្នកមានដោយសារតែពួកគេមិនបានសុំទានអ្នកដទៃ។ អ្នកអាចស្គាល់ពួកគេបានតាមរយៈសញ្ញាសម្គាល់របស់ពួកគេដោយពួកគេមិនសុំពីមនុស្សលោកដដែលៗនោះទេ។ ហើយអ្វីដែលពួកអ្នកបរិច្ចាគអំពីប្រការល្អនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតអំពីវា។

274. បណ្តាអ្នកដែលបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេទាំងពេលយប់និងពេលថ្ងៃ ទាំងដោយលាក់កំបាំង និងទាំងបើកចំហនោះ ពួកគេពិតជានឹងទទួលបានផលបុណ្យពីព្រះជាម្ចាស់របស់ពួកគេ(នៅថ្ងៃបរលោក) ហើយពួកគេគ្មានការភ័យខ្លាចនោះឡើយ ហើយក៏មិនមានការព្រួយបារម្ភនោះដែរ។

275. ពួកដែលស៊ីការប្រាក់(និងមានទំនាក់ទំនងនឹងការប្រាក់)នោះ ពួកគេមិនអាចក្រោកឈរបានឡើយ(នៅថ្ងៃបរលោក)លើកលែងតែគេក្រោកឈរដូចអ្នកដែលស្លេតន(អារក្សសាតាំង)ចូលដៃលធ្វើឱ្យគេលីលាដូច្នោះដែរ។ នោះគឺដោយសារតែពួកគេនិយាយថា៖ តាមពិត ការលក់ដូរ គឺដូចទៅនឹងការស៊ីការប្រាក់ដែរ។ ប៉ុន្តែអល់ឡោះទ្រង់បានអនុញ្ញាតចំពោះការលក់ដូរ ហើយបានហាមឃាត់ចំពោះការប្រាក់។ ដូច្នេះ ជនណាដែលការទូន្មានពីព្រះជាម្ចាស់របស់គេបានមកដល់គេ ហើយគេបានបញ្ឈប់(ការស៊ីការប្រាក់)ដូច្នេះ អ្វីដែលមានពីមុននៃការស៊ីការប្រាក់នោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេ ហើយកិច្ចការរបស់គេ គឺត្រឡប់ទៅរកអល់ឡោះ។ រីឯជនណាដែលបានត្រឡប់ទៅ(ស៊ីការប្រាក់)វិញ ពិតប្រាកដណាស់ ពួកទាំងនោះ គឺជាពួកឋាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

276. អល់ឡោះដកយកពរជ័យចំពោះការប្រាក់ ហើយទ្រង់បង្កើនផលបុណ្យចំពោះទ្រព្យបរិច្ចាគនានា។ ហើយអល់ឡោះទ្រង់មិនស្រលាញ់រាល់ពួកប្រឆាំងដែលសាងបាបកម្មឡើយ។

277. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ហើយបានប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ពិតប្រាកដណាស់ ពួកគេនឹងទទួលបានផលបុណ្យពីព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេក៏គ្មានការភ័យខ្លាច និងគ្មានការព្រួយបារម្ភនោះដែរ។

278. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះ ហើយចូរបោះបង់នូវអ្វីដែលនៅសេសសល់អំពីការប្រាក់(ដែលគេនៅជំពាក់ពួកអ្នក)ប្រសិនបើពួកអ្នកជាអ្នកមានជំនឿពិតប្រាកដមែននោះ។

279. តែប្រសិនបើពួកអ្នកមិនធ្វើ(ដូច្នោះ)ទេនោះ ពួកអ្នកត្រូវដឹងថា នឹងមានសង្គ្រាមពីអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់(មកលើពួកអ្នក)ជាមិនខាន។ តែប្រសិនបើពួកអ្នកសារភាពកំហុស(បោះបង់ការប្រាក់)សម្រាប់ពួកអ្នក គឺទទួលបានប្រាក់ដើមរបស់ពួកអ្នកវិញ។ (ការធ្វើដូច្នេះ)ពួកអ្នកមិនបំពានលើគេ ហើយគេក៏មិនបំពានលើពួកអ្នកដែរ។

280. ហើយប្រសិនបើពួកគេគ្មានលទ្ធភាពសងទេនោះ ចូរពួកអ្នកពន្យារពេលដល់ពួកគេ រហូតដល់ពួកគេមានលទ្ធភាព។ តែប្រសិនបើពួកអ្នកបរិច្ចាគ(ដល់ពួកគេ)វាគឺល្អប្រសើរបំផុតសម្រាប់ពួកអ្នកប្រសិនបើពួកអ្នកបានដឹង(ពីផលបុណ្យរបស់វា)។

281. ហើយចូរពួកអ្នកខ្លាចថ្ងៃមួយដែលគេនឹងនាំពួកអ្នកត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់វិញ។ បន្ទាប់មក គេនឹងតបស្នងដល់បុគ្គលគ្រប់រូបនូវអ្វីដែលរូបគេបានប្រព្រឹត្ត ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

282. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលពួកអ្នកខ្វីបុលគ្នាទៅវិញទៅមករហូតដល់ពេលកំណត់ណាមួយនោះ ចូរពួកអ្នកកត់ត្រាបំណុលនោះ។ ចូរឱ្យអ្នកកត់ត្រានោះ កត់ត្រាដោយយុត្តិធម៌រវាងពួកអ្នក។ ហើយអ្នកកត់ត្រាមិនត្រូវបដិសេធនូវការកត់ត្រា(បំណុល)ដូចអ្វីដែលអល់ឡោះបានបង្រៀនដល់គេឡើយ។ ដូច្នេះ ចូរឱ្យគេកត់ត្រា ហើយចូរឱ្យអ្នកខ្វីបញ្ជាក់ប្រាប់ពីបំណុលដែលបានខ្វី និងចូរឱ្យអ្នកខ្វីកោតខ្លាចព្រះជាម្ចាស់របស់គេ។ ហើយគេមិនត្រូវគៃបំបាត់អ្វីមួយពីបំណុលឡើយ។ តែប្រសិនបើអ្នកខ្វីនោះជាមនុស្សដែលខ្សោយបញ្ញា ឬជាមនុស្សទន់ខ្សោយ ឬអសមត្ថភាពក្នុងការបញ្ជាក់ប្រាប់ ចូរឱ្យអាណាព្យាបាលរបស់គេជាអ្នកបញ្ជាក់ប្រាប់ដោយយុត្តិធម៌(ដល់អ្នកកត់ត្រា)។ ហើយចូរពួកអ្នកស្វែងរកសាក្សីជាបុរសពីរនាក់ក្នុងចំណោមពួកអ្នក។ តែបើគ្មានបុរសពីរនាក់ទេនោះ គឺត្រូវយកបុរសម្នាក់ និងស្ត្រីពីរនាក់ក្នុងចំណោមអ្នកដែលពួកអ្នកទទួលស្គាល់ឲ្យធ្វើជាសាក្សី។ ប្រសិនបើម្នាក់ក្នុងចំណោមគេទាំងពីរភ្លេច គឺមានម្នាក់ទៀតជួយរំឭក។ ហើយសាក្សីទាំងឡាយមិនត្រូវបដិសេធនៅពេលដែលគេសុំ(ឲ្យខ្លួនធ្វើជាសាក្សី)នោះឡើយ។ ចូរពួកអ្នកកុំធុញទ្រាន់ក្នុងការកត់ត្រាបំណុលដែលមានកំណត់ពេលជាក់លាក់ ទោះតិចឬច្រើនក៏ដោយ។ ការធ្វើបែបនេះ គឺយុត្តិធម៌បំផុតចំពោះអល់ឡោះ និងជាជំនួយដ៏សំខាន់ក្នុងការធ្វើសាក្សី ហើយជាកត្តាដែលនាំឱ្យពួកអ្នកចៀសផុតពីការមន្ទិលសង្ស័យផងដែរ លើកលែងតែពួកអ្នកលក់របស់បរឱ្យគ្នាទៅវិញទៅមក ដោយការប្រគល់របស់ និងប្រគល់ប្រាក់ភ្លាមៗប៉ុណ្ណោះ គឺគ្មានទោសពៃរ៍អ្វីឡើយទៅលើពួកអ្នកចំពោះការដែលពួកអ្នកមិនកត់ត្រាវាទេនោះ។ ចូរពួកអ្នកធ្វើសាក្សីនៅពេលដែលពួកអ្នកលក់ដូរឲ្យគ្នាទៅវិញទៅមក។ ហើយគេមិនត្រូវបង្កការលំបាកដល់អ្នកកត់ត្រា និងសាក្សីឡើយ។ តែប្រសិនបើពួកអ្នកធ្វើដូច្នោះ ពិតប្រាកដណាស់ វាគឺជាអំពើល្មើសមកពីពួកអ្នក។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ អល់ឡោះទ្រង់បង្រៀនពួកអ្នក ហើយអល់ឡោះមហាដឹងបំផុតនូវគ្រប់អ្វីៗទាំងអស់។

283. តែប្រសិនបើពួកអ្នកស្ថិតនៅក្នុងការធ្វើដំណើរ ហើយពួកអ្នកគ្មានអ្នកកត់ត្រា(កិច្ចសន្យាបំណុលឱ្យពួកអ្នក)ទេនោះ គ្រប់គ្រាន់ហើយចំពោះភាគីដែលជាអ្នកខ្វីដាក់បញ្ចាំទ្រព្យអ្វីមួយដល់ម្ចាស់បំណុល។ តែបើពួកអ្នកទុកចិត្តគ្នាទៅវិញទៅមក ចូរឲ្យអ្នកដែលគេទុកចិត្តបំពេញនូវទំនុកចិត្ត(សងបំណុលដល់គេវិញ)។ ហើយចូរឱ្យគេកោតខ្លាចអល់ឡោះដែលជាព្រះជាម្ចាស់របស់គេ។ ហើយពួកអ្នកមិនត្រូវលាក់បាំងការធ្វើសាក្សីឡើយ។ ជនណាហើយដែលលាក់បាំងវានោះ ពិតណាស់ដួងចិត្តរបស់គេ គឺជាដួងចិត្តរបស់មនុស្សមានបាប។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

284. អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយទោះបីជាពួកអ្នកលាតត្រដាងអ្វីដែលមាននៅក្នុងចិត្តរបស់ពួកអ្នក ឬពួកអ្នកលាក់បាំងវាក៏ដោយ ក៏អល់ឡោះជាម្ចាស់នឹងជំនុំជម្រះពួកអ្នកចំពោះទង្វើនោះដែរ។ បន្ទាប់ពីនោះ ទ្រង់នឹងអភ័យទោសចំពោះជនណាដែលទ្រង់មានចេតនា ហើយដាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាម្ចាស់មានអានុភាពលើអ្វីៗទាំងអស់។

285. អ្នកនាំសារ(មូហាំម៉ាត់)មានជំនឿលើរាល់អ្វីទាំងអស់ដែលគេបានបញ្ចុះមកឱ្យគាត់ពីព្រះជាម្ចាស់របស់គាត់ ហើយបណ្តាអ្នកមានជំនឿទាំងអស់ក៏មានជំនឿដូចគ្នាដែរ។ ពួកគេទាំងអស់មានជំនឿលើអល់ឡោះ បណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្តាគម្ពីររបស់ទ្រង់ និងបណ្តាអ្នកនាំសារទាំងឡាយរបស់ទ្រង់។ (ពួកគេនិយាយថា៖) ពួកយើងមិនបែងចែកនរណាម្នាក់ក្នុងចំណោមអ្នកនាំសាររបស់ទ្រង់(ដោយជឿអ្នកខ្លះ ហើយបដិសេធអ្នកខ្លះទៀត)ឡើយ។ ហើយពួកគេបាននិយាយទៀតថា៖ ពួកយើងបានឮ និងបានប្រតិបត្តិតាមហើយ។ សូមទ្រង់មេត្តាអភ័យទោសឱ្យពួកយើងផងចុះ ឱព្រះជាម្ចាស់របស់ពួកយើង! ហើយកន្លែងវិលត្រឡប់(របស់ពួកយើង)គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

286. អល់ឡោះជាម្ចាស់ទ្រង់មិនដាក់បន្ទុកលើនរណាម្នាក់ហួសពីលទ្ធភាពរបស់គេឡើយ។ ជនណាដែលបានសាងអំពើល្អ គឺទទួលបានផលបុណ្យនៃទង្វើនោះ ហើយជនណាដែលបានសាងអំពើអាក្រក់ គឺនឹងទទួលបានផលអាក្រក់នៃបាបកម្មនោះ។ (ពួកគេបានបួងសួងថា៖) ឱព្រះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំយកទោសពៃរ៍ពួកយើងនូវអ្វីដែលពួកយើងបានភ្លេចភ្លាំង ឬប្រព្រឹត្តខុសឆ្គង។ ឱព្រះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំដាក់កាតព្វកិច្ចធ្ងន់ធ្ងរពេកមកលើពួកយើងដូចដែលទ្រង់បានដាក់ទៅលើពួកអ្នកជំនាន់មុនពួកយើង។ ឱព្រះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំដាក់បន្ទុកលើពួកយើងនូវអ្វីដែលពួកយើងគ្មានលទ្ធភាពនឹងធ្វើវា ហើយសូមទ្រង់មេត្តាអធ្យាស្រ័យ និងអភ័យទោស ព្រមទាំងអាណិតស្រឡាញ់ដល់ពួកយើងផង។ ទ្រង់គឺជាអ្នកគាំពាររបស់ពួកយើង។ ហេតុនេះ សូមទ្រង់មេត្តាជួយពួកយើងឱ្យកឈ្នះលើក្រុមដែលគ្មានជំនឿផងចុះ។

ជំពូក អាលីអ៊ុមរ៉ន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម។

2. អល់ឡោះគឺជាព្រះជាម្ចាស់តែមួយគត់ ដែលគ្មានព្រះជាម្ចាស់ណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមានជីវិតអមតៈ ដែលជាអ្នកគ្រប់គ្រងនោះឡើយ។

3. ទ្រង់បានបញ្ចុះគម្ពីរ(គួរអាន)ទៅកាន់អ្នក(ឱព្យាការីមូហាំម៉ាត់)យ៉ាងពិតប្រាកដ ដើម្បីបញ្ជាក់ចំពោះអ្វី(គម្ពីរទាំងឡាយ)ដែលមានពីមុនគម្ពីរនេះ។ ហើយទ្រង់បានបញ្ចុះគម្ពីរតាវ៉ត និងគម្ពីរអ៊ិញជីល

4. កាលពីមុន ដើម្បីជាការចង្អុលបង្ហាញដល់មនុស្សលោក ហើយទ្រង់បានបញ្ចុះនូវការវិនិច្ឆ័យ (រវាងប្រការពិត និងប្រការដែលមិនពិត)។ ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងបណ្តាកស្តុតាងរបស់អល់ឡោះនោះ សម្រាប់ពួកគេនឹងទទួលទណ្ឌកម្មយ៉ាងខ្លោចផ្សាបំផុត។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ ជាអ្នកមានអំណាចផ្តន្ទាទោសបំផុត។

5. ជាការពិតណាស់ គ្មានអ្វីមួយដែលនៅលើផែនដី ឬក៏នៅលើមេឃអាចលាក់បាំងពីអល់ឡោះជាម្ចាស់បានឡើយ។

6. ទ្រង់គឺជាអ្នកដែលបានបង្កើតរូបរាងពួកអ្នកនៅក្នុងផ្ទៃម្តាយទៅតាមអ្វីដែលទ្រង់មានចេតនា។ គ្មានព្រះជាម្ចាស់ណាផ្សេងដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមហាខ្លាំងពូកែ មហាគតិបណ្ឌិតនោះឡើយ។

7. ទ្រង់គឺជាអ្នកដែលបានបញ្ចុះគម្ពីរគួរអានមកកាន់អ្នក(ព្យាការីមូហាំម៉ាត់)ដែលក្នុងនោះ មានវាក្យខណ្ឌមួយចំនួនមានភាពច្បាស់លាស់ ដែលវាគឺជាមូលដ្ឋានគ្រឹះនៃគម្ពីរ ហើយមានវាក្យខណ្ឌខ្លះទៀត គឺជាវាក្យខណ្ឌមានភាពមិនច្បាស់លាស់(មានអត្ថន័យច្រើន)។ រីឯអ្នកដែលនៅក្នុងចិត្តរបស់ពួកគេមានភាពលម្អៀង(ចេញពីការពិត)នោះ ពួកគេប្រកាន់យកនូវវាក្យខណ្ឌដែលមានភាពមិនច្បាស់លាស់ទៅវិញក្នុងគោលបំណងបង្កឲ្យមានភាពវឹកវរ(បំផុសនូវភាពមន្ទិលសង្ស័យ) និងដើម្បីឱ្យពួកគេអាចបកស្រាយវាក្យខណ្ឌទាំងនោះទៅតាមទំនើងចិត្តរបស់ពួកគេ។ ហើយគ្មាននរណាដឹងពីអត្ថន័យពិតរបស់វា(វាក្យខណ្ឌដែលមិនច្បាស់លាស់ទាំងនោះ)ក្រៅពីអល់ឡោះឡើយ។ ហើយបណ្តាអ្នកដែលមានចំណេះដឹងជ្រៅជ្រះ(ក្នុងសាសនា)ពួកគេនិយាយថា៖ ពួកយើងមានជំនឿចំពោះវា(គម្ពីរគួរអាន)ពីព្រោះវាទាំងមូល គឺមកពីព្រះជាម្ចាស់របស់ពួកយើង។ តាមពិត អ្នកដែលទទួលយកការក្រើនរំឭកនោះ គឺមានតែបញ្ញាជនទាំងឡាយប៉ុណ្ណោះ។

8. ឱព្រះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំបង្វែរដួងចិត្តរបស់ពួកយើង(ពីសេចក្តីពិត)ក្រោយពីទ្រង់បានចង្អុលបង្ហាញដល់ពួកយើងហើយនោះ ហើយសូមទ្រង់មេត្តាប្រទានដល់ពួកយើងនូវក្តីមេត្តាករុណាអំពីទ្រង់ផងចុះ។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកផ្តល់នូវការប្រោសប្រទានដ៏លើសលប់បំផុត។

9. ឱព្រះជាម្ចាស់របស់ពួកយើង! ពិតប្រាកដណាស់ ទ្រង់ជាអ្នកប្រមូលផ្តុំមនុស្សលោកទាំងអស់នៅថ្ងៃមួយដែលគ្មានការសង្ស័យឡើយចំពោះវា(គឺថ្ងៃបរលោក)។ ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនធ្វើខុសពីការសន្យារបស់ទ្រង់ឡើយ។

10. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ទ្រព្យសម្បត្តិរបស់ពួកគេ និងកូនចៅរបស់ពួកគេ ពិតជាមិនអាចជួយការពារពួកគេ ពី(ទណ្ឌកម្ម)អល់ឡោះបន្តិចណាឡើយ។ ហើយពួកទាំងនោះ ពួកគេគឺជាវត្ថុសម្រាប់បង្កាត់ភ្លើងនរក(នៅថ្ងៃបរលោក)។

11. គឺដូចជាទម្លាប់របស់ពូជពង្សហ្វៀរអោន និងពួកជំនាន់មុនពួកគេដែរ ពួកគេបានបដិសេធនឹងបណ្តាវាក្យខណ្ឌរបស់យើង។ ដូច្នេះ អល់ឡោះបានដាក់ទណ្ឌកម្មពួកគេដោយសារតែបាបកម្មរបស់ពួកគេ។ ហើយអល់ឡោះជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

12. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ពួកគ្មានជំនឿថា៖ គេ(អ្នកមានជំនឿ)នឹងយកឈ្នះទៅលើពួកអ្នក ហើយ គេ(អល់ឡោះ)នឹងប្រមូលផ្តុំពួកអ្នកទៅកាន់នរកដើហាន់ណាំ ហើយវាជាកន្លែងដ៏អាក្រក់បំផុត។

13. ជាការពិតណាស់ នៅក្នុងរឿងកងទ័ពពីរក្រុមដែលបានជួបប្រយុទ្ធគ្នា(នៅក្នុងសមរភូមិហ្គាទើរ) គឺជាកស្តុតាងមួយសម្រាប់ ពួកអ្នក(ពួកយូដា)។ មួយក្រុម(ក្រុមអ្នកមានជំនឿ) គឺគេប្រយុទ្ធតស៊ូក្នុងមាគ៌ារបស់អល់ឡោះ ហើយមួយក្រុមផ្សេងទៀត គឺជាពួកប្រឆាំង។ ពួកគ្មានជំនឿបានមើលឃើញពួកគេមានចំនួនច្រើនជាងខ្លួនទ្វេដងផ្ទាល់នឹងភ្នែក។ ហើយអល់ឡោះទ្រង់ ពង្រឹងដោយជំនួយរបស់ទ្រង់ចំពោះជនណាដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាមេរៀនមួយ សម្រាប់បណ្តាអ្នកដែលមានការឈ្វេងយល់។

14. គេបានលម្អសម្រាប់មនុស្សលោក(ជាការសាកល្បងពួកគេ)នូវការស្រលាញ់ភាពត្រអាល(ក្នុងលោកិយ) ដូចជា ស្ត្រី កូនចៅ និងទ្រព្យសម្បត្តិច្រើនលើសលប់ ដូចជា មាស ប្រាក់ សេះបង្វឹក សត្វពាហនៈ និងចម្ការដំណាំ។ ទាំងនោះគឺជាការ ត្រេកត្រអាលនៃជីវិតលោកិយ។ ហើយអល់ឡោះទ្រង់មានកន្លែងវិលត្រឡប់ដ៏ល្អប្រពៃបំផុត(ឋានសួគ៌)។

15. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើចង់ឱ្យខ្ញុំប្រាប់ពួកអ្នកនូវអ្វីដែលល្អប្រសើរជាងប្រការទាំងនោះដែរឬទេ? សម្រាប់បណ្តាអ្នកដែលកោតខ្លាចនោះ នៅឯព្រះជាម្ចាស់របស់ពួកគេ គឺមានឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោម វា។ ពួកគេស្ថិតនៅទីនោះជាអមត: និងទទួលបានភរិយាដ៏ស្អាតស្អំជាច្រើន ព្រមទាំងទទួលបានការពេញចិត្តពីអល់ឡោះ ជាម្ចាស់ថែមទៀត។ ហើយអល់ឡោះមហាឃើញបំផុតចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

16. គឺបណ្តាអ្នកដែលបួងសួងថា៖ ឱព្រះជាម្ចាស់របស់ពួកយើង! ពិតប្រាកដណាស់ ពួកយើងពិតជាមានជំនឿ(លើទ្រង់) ហើយ។ ដូចនេះ សូមទ្រង់មេត្តាអភ័យទោសឱ្យពួកយើងចំពោះបាបកម្មទាំងឡាយរបស់ពួកយើង និងបញ្ចៀសពួកយើង ពីទណ្ឌកម្មនៃភ្លើងនរកផងចុះ។

17. (អ្នកទាំងនោះដែរ) គឺបណ្តាអ្នកដែលអត់ធ្មត់ អ្នកសច្ចៈ អ្នកដែលគោរពប្រតិបត្តិ អ្នកដែលបរិច្ចាគ និងបណ្តាអ្នកដែលសុំ ការអភ័យទោស(ពីអល់ឡោះ)នៅមុនពេលទៀបភ្លឺ។

18. អល់ឡោះជាម្ចាស់ទ្រង់បានអះអាងថា៖ ពិតប្រាកដណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ក្រៅពីទ្រង់ឡើយ ហើយបណ្តាម៉ាឡាអ៊ីកាត់ និងអ្នកមានចំណេះដឹងទាំងឡាយ ក៏បានអះអាងយ៉ាងដូច្នោះដែរ ដោយទ្រង់ ឈរលើភាពយុត្តិធម៌ត្រឹមត្រូវ។ គ្មានទេព្រះជាម្ចាស់ដែលគេត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមហាខ្លាំងពូកែ មហាគតិបណ្ឌិតឡើយ។

19. ពិតប្រាកដណាស់ សាសនារបស់អល់ឡោះ គឺសាសនាអ៊ីស្លាម។ ហើយពួកដែលគេផ្តល់គម្ពីរឱ្យមិនបានខ្វែងគំនិត គ្នា(នៅក្នុងសាសនារបស់ពួកគេ)នោះឡើយ លើកលែងតែបន្ទាប់ពីចំណេះដឹងបានមកដល់ពួកគេ ដោយសារតែការ ច្រណែនឈ្នានីសរវាងពួកគេប៉ុណ្ណោះ។ ហើយជនណាដែលប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់អល់ឡោះនោះ ពិតប្រាកដ ណាស់ អល់ឡោះទ្រង់ជាអ្នកជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

20. ដូច្នេះ ប្រសិនបើពួកគេជជែកដេញដោលនឹងអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ចូរអ្នកតបថា៖ ខ្ញុំ ហើយនិងបណ្ដាអ្នកដែលដើរតាមខ្ញុំបានប្រគល់ខ្លួនទៅចំពោះអល់ឡោះជាម្ចាស់ហើយ។ ហើយចូរអ្នកពោលទៅកាន់ពួកដែលគេបានផ្ដល់គម្ពីរឱ្យ(យូដា និងគ្រឹស្ដាន) និងពួកអនក្ខរជន(ពួកមុស្លីគីន)ថា៖ តើពួកអ្នកព្រមប្រគល់ខ្លួន(ចូលសាសនាអ៊ីស្លាម)ដែរឬទេ? ប្រសិនបើពួកគេព្រមប្រគល់ខ្លួន នោះពួកគេពិតជាទទួលបានការចង្អុលបង្ហាញ។ តែប្រសិនបើពួកគេបែរចេញវិញនោះ គឺកាតព្វកិច្ចលើអ្នកគ្រាន់តែផ្សព្វផ្សាយប៉ុណ្ណោះ។ ហើយអល់ឡោះមហាឃើញបំផុតចំពោះខ្ញុំបម្រើរបស់ទ្រង់។

21. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងបណ្ដាវាក្យខណ្ឌរបស់អល់ឡោះ និងបានសម្លាប់បណ្ដាព្យាការីជាច្រើនដោយអយុត្តិធម៌ ព្រមទាំងបានសម្លាប់បណ្ដាអ្នកដែលប្រើមនុស្សឱ្យប្រកាន់នូវភាពយុត្តិធម៌នោះ ចូរអ្នកប្រាប់ពួកគេពីទណ្ឌកម្មដ៏សែនឈឺចាប់បំផុតចុះ។

22. ពួកទាំងនោះហើយជាពួកដែលអំពើកុសលទាំងឡាយរបស់ពួកគេបានរលាយសាបសូន្យ ទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក ហើយពួកគេក៏គ្មានអ្នកជួយនោះដែរ។

23. តើអ្នក(ឱព្យាការីមូហាំម៉ាត់)ពុំបានឃើញទេឬអំពីពួក(យូដា)ដែលគេបានផ្ដល់ឱ្យពួកគេនូវចំណេះដឹងពីគម្ពីរ(តាវ៉ាត) ដោយពួកគេត្រូវបានគេអំពាវនាវឱ្យត្រឡប់ទៅកាន់គម្ពីររបស់អល់ឡោះដើម្បីកាត់សេចក្ដីរវាងពួកគេ។ ក្រោយមក ស្រាប់តែក្រុមមួយក្នុងចំណោមពួកគេបែរជាងាកចេញទៅវិញ ខណៈដែលពួកគេជាពួកដែលបដិសេធ។

24. នោះគឺដោយសារតែពួកគេបានអះអាងថា៖ ជាការពិតណាស់ ភ្លើងនរកនឹងមិនប៉ះពាល់(ឆាបឆេះ)ពួកគេឡើយ លើកលែងតែក្នុងរយៈពេលប៉ុន្មានថ្ងៃ(ដ៏ខ្លី)ដែលត្រូវបានកំណត់ប៉ុណ្ណោះ។ ហើយអ្វីដែលពួកគេបានប្រឌិតឡើងនោះគឺបានបោកប្រាស់ពួកគេចំពោះសាសនារបស់ពួកគេទៅវិញទេ។

25. តើ(ស្ថានភាពរបស់ពួកគេ)យ៉ាងណាទៅវិញ នៅពេលដែលយើងប្រមូលផ្ដុំពួកគេនៅក្នុងថ្ងៃមួយដែលគ្មានការសង្ស័យឡើយចំពោះវា(ថ្ងៃបរលោក)។ ហើយគេផ្ដល់ឱ្យបុគ្គលគ្រប់រូបនូវអ្វីដែលបុគ្គលនោះបានប្រព្រឹត្ត ខណៈដែលពួកគេមិនត្រូវបានគេបំពានឡើយ។

26. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱអល់ឡោះជាម្ចាស់! ទ្រង់ជាអ្នកដែលគ្រប់គ្រងអំណាចទាំងអស់។ ទ្រង់ប្រទានអំណាចចំពោះជនណាដែលទ្រង់មានចេតនា ហើយទ្រង់ដកហូតអំណាចពីជនណាដែលទ្រង់មានចេតនា។ ទ្រង់ប្រទានកិត្តិយសចំពោះជនណាដែលទ្រង់មានចេតនា និងធ្វើឱ្យអាប់ឱនកិត្តិយសចំពោះជនណាដែលទ្រង់មានចេតនា។ ប្រការល្អទាំងឡាយ គឺស្ថិតនៅក្នុងកណ្ដាប់ដៃទ្រង់។ ពិតប្រាកដណាស់ ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

27. ទ្រង់បញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ ហើយបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយទ្រង់បញ្ចេញរបស់មានជីវិតពីរបស់ស្លាប់(បញ្ចេញអ្នកមានជំនឿពីអ្នកគ្មានជំនឿ ហើយបញ្ចេញជំណាំពីគ្រាប់ធញ្ញជាតិ) ហើយទ្រង់បញ្ចេញរបស់ស្លាប់ពីរបស់មានជីវិត (បញ្ចេញអ្នកគ្មានជំនឿពីអ្នកមានជំនឿ និងបញ្ចេញពងមាន់ពីមេមាន់) ហើយទ្រង់ប្រទានលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនាដោយគ្មានកំណត់ឡើយ។

28. បណ្ដាអ្នកមានជំនឿមិនត្រូវយកពួកគ្មានជំនឿធ្វើជាអ្នកគាំពារក្រៅពីអ្នកមានជំនឿនោះឡើយ។ ជនណាហើយដែលធ្វើដូច្នោះ ពិតប្រាកដណាស់ រូបគេបានកាត់ផ្ដាច់ពីអល់ឡោះ ហើយអល់ឡោះក៏បានកាត់ផ្ដាច់ពីគេវិញដែរ លើកលែងតែអ្នកដែលបារម្ភខ្លាចពួកគេ(ធ្វើបាប)ប៉ុណ្ណោះ។ ហើយអល់ឡោះព្រមានពួកអ្នកនូវទណ្ឌកម្មរបស់ទ្រង់។ ហើយកន្លែងវិលត្រឡប់(នៅថ្ងៃបរលោក)គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

29. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ទោះបីពួកអ្នកលាក់បាំងនូវអ្វីដែលមានក្នុងចិត្តរបស់ពួកអ្នក ឬលាតត្រដាងវាក៏ដោយ ក៏អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតអំពីវាដែរ។ ហើយទ្រង់ដឹងនូវអ្វីដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីដែលមាននៅលើផែនដី។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

30. នៅថ្ងៃដែលបុគ្គលគ្រប់រូបនឹងបានឃើញនូវអំពើល្អដែលខ្លួនបានប្រព្រឹត្តត្រូវបានគេនាំមក(ដោយគ្មានបាត់បង់បន្តិចណាឡើយ) ហើយនិងអ្វីដែលខ្លួនបានប្រព្រឹត្តនៃអំពើអាក្រក់ គឺរូបគេប្រាថ្នាចង់ឱ្យអំពើអាក្រក់របស់គេនិងខ្លួនគេឃ្លាតឆ្ងាយពីគ្នាបំផុត។ ហើយអល់ឡោះព្រមានពួកអ្នកនូវទណ្ឌកម្មរបស់ទ្រង់។ ហើយអល់ឡោះទ្រង់អាណិតស្រលាញ់បំផុតចំពោះខ្ញុំបម្រើទាំងឡាយ។

31. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើពួកអ្នកស្រលាញ់អល់ឡោះ(ពិតមែននោះ) ចូរពួកអ្នកប្រតិបត្តិតាមខ្ញុំ នោះអល់ឡោះនឹងស្រឡាញ់ពួកអ្នក ហើយទ្រង់នឹងអភ័យទោសឱ្យពួកអ្នកនូវបាបកម្មទាំងឡាយរបស់ពួកអ្នក។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

32. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសារ(របស់ទ្រង់)។ តែប្រសិនបើពួកអ្នកងាកចេញ ពិតប្រាកដណាស់ អល់ឡោះមិនស្រលាញ់ពួកដែលប្រឆាំងឡើយ។

33. ពិតប្រាកដណាស់ អល់ឡោះទ្រង់បានជ្រើសរើសព្យាការីអាដាំ ព្យាការីនួហ និងពូជពង្សព្យាការីអ៊ីព្រហ៊ីម ហើយនិងពូជពង្សអ៊ុមរ៉ានឲ្យល្អប្រសើរលើសមនុស្សទាំងឡាយ(នៅក្នុងសម័យកាលរបស់ពួកគេ)។

34. (ពួកគេ)ជាពូជពង្សខ្សែស្រឡាយរវាងគ្នានឹងគ្នា។ ហើយអល់ឡោះមហាឮ មហាដឹងបំផុត។

35. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹកឃើញ នៅពេលដែលភរិយារបស់អ៊ុមរ៉ានបានបួងសួងថា៖ ឱព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសូមសច្ចាចំពោះទ្រង់នូវអ្វី(កូន)ដែលមាននៅក្នុងផ្ទៃរបស់ខ្ញុំឲ្យធ្វើជាអ្នកបម្រើដ៏ស្មោះស្ម័គ្រចំពោះទ្រង់។ ដូចនេះសូមទ្រង់មេត្តាទទួលយក(ការបួងសួង)ពីខ្ញុំផង។ ពិតប្រាកដណាស់ ទ្រង់ជាម្ចាស់មហាឮ មហាដឹងបំផុត។

36. ហើយនៅពេលដែលនាងបានសម្រាលកូនរួច នាងបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសម្រាលបានកូនស្រីម្នាក់។ ហើយអល់ឡោះដឹងបំផុតចំពោះកូនដែលនាងបានសម្រាលនោះ។ ហើយកូនប្រុស គឺមិនដូចកូនស្រីឡើយ។ (នាងបានបន្តថា៖)ពិតប្រាកដណាស់ ខ្ញុំបានដាក់ឈ្មោះឱ្យនាងថា ម៉ារយ៉ាំ(ម៉ារី)។ ហើយជាការពិតណាស់ ខ្ញុំសូមឱ្យទ្រង់បញ្ជៀសរូបនាង និងពូជពង្សរបស់នាងអំពីស្មៃតនដែលត្រូវបានគេដាក់បណ្តាសាផងចុះ។

37. ពេលនោះ ព្រះជាម្ចាស់របស់នាងក៏បានទទួលយកការសច្ចារបស់នាងនូវការទទួលយកមួយដ៏ល្អប្រសើរ ហើយទ្រង់បានបណ្តុះបណ្តាលនាងនូវការបណ្តុះបណ្តាលមួយដ៏ល្អប្រពៃ ព្រមទាំងបានឱ្យព្យាការីហ្សាការីយ៉ាជាអ្នកមើលថែនាង។ រាល់ពេលដែលព្យាការីហ្សាការីយ៉ាចូលទៅ(ជួបនាង)នៅឯកន្លែងគោរពសក្ការៈរបស់នាង គាត់តែងប្រទះឃើញមានចំណីអាហារនៅជាមួយនាង។ គាត់ក៏សួរថា៖ ឱម៉ារយ៉ាំ! តើអ្នកបានអាហារទាំងនេះមកពីណា? នាងបានឆ្លើយថា៖ វាគឺមកពីអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ប្រទានលាភសក្ការៈចំពោះជនណាដែលទ្រង់មានចេតនាដោយគ្មានការកំណត់ឡើយ។

38. នៅខណៈនោះ ព្យាការីហ្សាការីយ៉ាក៏បានបួងសួងទៅកាន់ព្រះជាម្ចាស់របស់គាត់។ គាត់បានបួងសួងថា៖ ឱព្រះជាម្ចាស់! សូមទ្រង់មេត្តាប្រទានឱ្យខ្ញុំនូវកូនប្រុសដ៏ល្អម្នាក់ផងចុះ។ ពិតប្រាកដណាស់ ទ្រង់មហាឮបំផុតនូវការបួងសួងសុំ។

39. នៅពេលនោះ ម៉ាឡាអ៊ីកាត់ក៏បានហៅគាត់ ខណៈដែលគាត់កំពុងឈរសេឡាតនៅកន្លែងគោរពសក្ការៈ(របស់គាត់)ថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ផ្តល់ដំណឹងរីករាយដល់អ្នកនូវ(កូនប្រុសម្នាក់ឈ្មោះ)យ៉ះយ៉ា ជាអ្នកបញ្ជាក់នូវបន្ទូលពិតមកពីអល់ឡោះ(ក្នុងការបង្កើតព្យាការីអ៊ីសា) ជាមេដឹកនាំ ជាអ្នកដែលផ្តាច់ខ្លួនពីកិលេសតណ្ហាផ្សេងៗ និងជាព្យាការីម្នាក់ក្នុងចំណោមអ្នកដែលល្អត្រឹមត្រូវទាំងឡាយ។

40. គាត់បានតបថា៖ ឱព្រះជាម្ចាស់! តើឱ្យខ្ញុំមានកូនយ៉ាងដូចម្តេច ខណៈដែលខ្ញុំមានវ័យចំណាស់ ហើយប្រពន្ធរបស់ខ្ញុំក៏ជាស្ត្រីអារ(ដែលមិនអាចមានកូន)ទៀតនោះ? ទ្រង់បានមានបន្ទូលថា៖ គឺដូច្នោះឯង អល់ឡោះទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។

41. គាត់បានបន្តថា៖ ឱព្រះជាម្ចាស់! សូមទ្រង់មេត្តាផ្តល់ឱ្យខ្ញុំនូវសញ្ញាបញ្ជាក់មួយផង។ ទ្រង់មានបន្ទូលថា៖ សញ្ញារបស់អ្នកគឺអ្នកមិនអាចនិយាយស្តីជាមួយមនុស្សបានឡើយចំនួនបីថ្ងៃ លើកលែងតែធ្វើសញ្ញា(កាយវិការ)ប៉ុណ្ណោះ។ ហើយចូរអ្នកបង្កើននូវការរំឭកទៅចំពោះព្រះជាម្ចាស់របស់អ្នកឱ្យបានច្រើន និងសូត្រតម៉ាលើកតម្កើងទ្រង់ទាំងពេលល្ងាច ទាំងពេលព្រឹក។

42. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹកឃើញ ខណៈដែលម៉ាឡាអ៊ីកាត់បាននិយាយ(ទៅកាន់ម៉ារយ៉ាំ)ថា៖ ឱម៉ារយ៉ាំ! ជាការពិតណាស់ អល់ឡោះជាម្ចាស់បានជ្រើសរើសអ្នក និងបានជម្រះសម្អាតអ្នក ហើយទ្រង់បានជ្រើសរើសអ្នកឱ្យមានភាពល្អប្រសើរលើសស្ត្រីផ្សេងៗនៅលើលោកនេះ(ក្នុងជំនាន់អ្នក)។

43. ឱម៉ារយ៉ាំ! ចូរអ្នកឈរសេឡាតចំពោះព្រះជាម្ចាស់របស់អ្នកឱ្យបានយូរ ហើយចូរអ្នកក្រាបស៊ូជោត និងឱនរុកជាមួយនឹងបណ្តាអ្នកដែលឱនរុកទាំងឡាយ។

44. នោះគឺស្ថិតក្នុងចំណោមដំណឹងអាថ៌កំបាំងដែលយើងផ្តល់វាជាវ៉ាហ៊ីទៅកាន់អ្នក(ឱព្យាការីមូហាំម៉ាត់)។ ហើយអ្នកមិនបានស្ថិតនៅជាមួយពួកគេឡើយ នៅពេលដែលពួកគេបានបោះស្លាបប៉ាកការបស់ពួកគេ(ដើម្បីជ្រើសរើស)ថាតើនរណាម្នាក់នៃពួកគេជាអ្នកមើលថែម៉ារយ៉ាំ ហើយអ្នកក៏មិនបានស្ថិតនៅជាមួយពួកគេនោះដែរ ខណៈដែលពួកគេឈ្លោះប្រកែកគ្នានោះ។

45. (ចូរអ្នកនឹកឃើញ) នៅពេលដែលម៉ាឡាអ៊ីកាត់បានពោលថា៖ ឱម៉ារយ៉ាំ! ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានផ្តល់ដំណឹងរីករាយដល់អ្នកនូវ(កូនប្រុសម្នាក់)ឈ្មោះ អាល់ម៉ាសៀហ អ៊ីសាកូនម៉ារយ៉ាំ(យេស៊ូគ្រីស្ត)ដែលជាបន្ទូលមកពីទ្រង់ ជាអ្នកដែលមានឋានៈដ៏ខ្ពង់ខ្ពស់ទាំងក្នុងលោកិយនិងថ្ងៃបរលោក និងជាអ្នកជំនិតម្នាក់ក្នុងចំណោមអ្នកជំនិតទាំងឡាយ(របស់អល់ឡោះ)។

46. ហើយគាត់អាចនិយាយទៅកាន់មនុស្សលោកតាំងពីនៅ(ជាទារក)ក្នុងអង្រឹង និងនៅពេលដែលគាត់ធំពេញវ័យ ហើយគាត់ក៏ស្ថិតក្នុងចំណោមអ្នកសាងកុសលទាំងឡាយផងដែរ។

47. នាងបាននិយាយ(ទាំងភ្ញាក់ផ្អើល)ថា៖ ឱព្រះជាម្ចាស់! តើខ្ញុំនឹងមានកូនយ៉ាងដូចម្តេច ខណៈដែលគ្មានបុរសណាមកប៉ះពាល់ខ្ញុំផងនោះ? ម៉ាឡាអ៊ីកាត់បានតបថា៖ គឺដូច្នោះឯង។ អល់ឡោះជាម្ចាស់ទ្រង់បង្កើតនូវអ្វីដែលទ្រង់មានចេតនា។ នៅពេលដែលទ្រង់សម្រេចកិច្ចការអ្វីមួយ គឺទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" វានឹងកើតឡើងភ្លាម។

48. ហើយទ្រង់នឹងបង្រៀនដល់គាត់(អ៊ីសា)នូវការសរសេរ និងភាពឆ្លាតវៃ ព្រមទាំងបង្រៀនដល់គាត់នូវគម្ពីរតាវ៉ាត និងគម្ពីរអ៊ិញជីល

49. ព្រមទាំងជាអ្នកនាំសារម្នាក់ទៅកាន់អម្បូរអ៊ីស្រាអែល (ដោយគាត់នឹងនិយាយទៅកាន់ពួកគេថា៖) ពិតណាស់ ខ្ញុំបានមកកាន់ពួកអ្នកដោយនាំមកនូវសញ្ញាកស្តុតាងពីព្រះជាម្ចាស់របស់ពួកអ្នក។ ពិតប្រាកដណាស់ ខ្ញុំអាចសូនរូបបក្សីអំពីដីឥដ្ឋឱ្យពួកអ្នក ហើយខ្ញុំក៏ផ្លុំចូលទៅក្នុងវា ពេលនោះ វាក៏ក្លាយជាសត្វបក្សីមួយ(ដែលមានជីវិត)ដោយការអនុញ្ញាតពីអល់ឡោះ។ ហើយខ្ញុំអាចព្យាបាលជនពិការភ្នែក និងអ្នកកើតឃ្លង់ ព្រមទាំងអាចប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញដោយការអនុញ្ញាតពីអល់ឡោះជាម្ចាស់។ ហើយខ្ញុំអាចប្រាប់ពួកអ្នកនូវចំណីអាហារដែលពួកអ្នកនឹងបរិភោគ និងចំណីអាហារដែលពួកអ្នកត្រូវស្តុកទុកនៅក្នុងផ្ទះរបស់ពួកអ្នក។ ពិតប្រាកដណាស់ នៅក្នុងរឿងរ៉ាវទាំងនោះ គឺជាភស្តុតាងមួយសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។

50. និងជាអ្នកបញ្ជាក់នូវអ្វីដែលមានពីមុនខ្ញុំនៃគម្ពីរតាវ៉ាត ហើយក៏ដើម្បីអនុញ្ញាតឱ្យពួកអ្នកនូវប្រការមួយចំនួនដែលគេធ្លាប់បានហាមឃាត់មកលើពួកអ្នក(កាលពីមុន)។ ហើយខ្ញុំបាននាំមកកាន់ពួកអ្នកនូវសញ្ញាកស្តុតាង(ដ៏ច្បាស់លាស់)ពីព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ ហើយប្រតិបត្តិតាមខ្ញុំ។

51. ពិតប្រាកដណាស់ អល់ឡោះគឺជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នកគោរពសក្ការៈទៅចំពោះទ្រង់(តែមួយគត់)។ នេះហើយគឺជាមាគ៌ាដ៏ត្រឹមត្រូវ។

52. ហើយនៅពេលព្យាការីអ៊ីសាមានអារម្មណ៍ដឹងថាមានការប្រឆាំងពីសំណាក់ពួកគេ(មកចំពោះគាត់) គាត់ក៏បាននិយាយ(ទៅកាន់អម្បូរអ៊ីស្រាអែល)ថា៖ តើអ្នកណាជាអ្នកជួយខ្ញុំក្នុងការអំពាវនាវទៅកាន់អល់ឡោះនោះ? ពួកសាវ័ក(របស់គាត់)បានឆ្លើយថា៖ ពួកយើងគឺជាអ្នកជួយសាសនារបស់អល់ឡោះ។ ពួកយើងមានជំនឿចំពោះអល់ឡោះ ហើយសូមអ្នកធ្វើសាក្សីផងចុះថា ពិតប្រាកដណាស់ ពួកយើងជាអ្នកប្រគល់ខ្លួនចំពោះអល់ឡោះ(ជាអ្នកមូស្លីម)។

53. ឱព្រះជាម្ចាស់របស់ពួកយើង! ពួកយើងមានជំនឿហើយចំពោះអ្វីដែលទ្រង់បានបញ្ចុះមក ហើយពួកយើងក៏បានប្រតិបត្តិតាមអ្នកនាំសារ(ព្យាការីអ៊ីសា)ផងដែរ។ ហេតុនេះ សូមទ្រង់មេត្តាកត់ត្រាឱ្យពួកយើងស្ថិតក្នុងចំណោមបណ្តាអ្នកដែលធ្វើសាក្សីផងចុះ។

54. ពួកគេបានប្រើឧបាយកល(ព្យាយាមតាមសម្លាប់ព្យាការីអ៊ីសា) ហើយអល់ឡោះក៏បានប្រើឧបាយកលតបទៅពួកគេវិញដែរ។ ហើយអល់ឡោះជាអ្នកដែលប្រសើរបំផុតក្នុងការតបតចំពោះអ្នកដែលប្រើឧបាយកលទាំងឡាយ។

55. (ចូរអ្នកនឹកឃើញ) ខណៈពេលដែលទ្រង់បានមានបន្ទូលទៅកាន់ព្យាការីអ៊ីសាថា៖ ឱអ៊ីសា! ពិតប្រាកដណាស់ យើងគឺជាអ្នកដកយកអ្នកពីផែនដី(ទាំងដែលអ្នកមិនទាន់ស្លាប់) ហើយយើងជាអ្នកដែលលើកអ្នកមកកាន់យើង ព្រមទាំងជម្រះសម្អាតអ្នកពីពួកដែលប្រឆាំង ហើយនិងធ្វើឱ្យបណ្តាអ្នកដែលដើរតាមអ្នកមានភាពខ្ពង់ខ្ពស់ជាងពួកដែលប្រឆាំងរហូតដល់ថ្ងៃបរលោក។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកអ្នក គឺឆ្ពោះមកកាន់យើង(តែមួយគត់)។ ពេលនោះ យើងនឹងកាត់សេចក្តីរវាងពួកអ្នកចំពោះអ្វីដែលពួកអ្នកធ្លាប់ខ្វែងគំនិតគ្នានៅក្នុងវា។

56. រីឯពួកដែលប្រឆាំងវិញនោះ ពិតប្រាកដណាស់ គេនឹងជាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតទាំងក្នុងលោកិយ និងថ្ងៃបរលោក។ ហើយសម្រាប់ពួកគេ គឺគ្មានអ្នកជួយឡើយ។

57. ឯចំណែកបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ពិតប្រាកដណាស់ គេនឹងប្រទានឱ្យពួកគេនូវផលបុណ្យរបស់ពួកគេយ៉ាងពេញលេញ។ ហើយអល់ឡោះមិនស្រលាញ់ពួកដែលបំពានឡើយ។

58. អ្វីដែលយើងបានពិពណ៌នាវាប្រាប់ដល់អ្នក(ព្យាការីមូហាំម៉ាត់)គឺស្ថិតក្នុងចំណោមសញ្ញាកស្តុតាង(ដ៏ច្បាស់លាស់)និងជាការរំឭកមួយប្រកបដោយគតិបណ្ឌិត។

59. ជាការពិតណាស់ ការប្រៀបធៀប(ការបង្កើត)ព្យាការីអ៊ីសាចំពោះអល់ឡោះជាម្ចាស់ គឺដូចជា(ការបង្កើត)ព្យាការីអាដាំដែរ។ ទ្រង់បានបង្កើតគាត់អំពីដី។ បន្ទាប់មក ទ្រង់បានមានបន្ទូលទៅកាន់គាត់ថា៖ ចូរឯងកើតចុះ។ ពេលនោះ គាត់ក៏កើតឡើងភ្លាម។

60. (នេះជា)សេចក្តីពិតមកពីព្រះជាម្ចាស់របស់អ្នក។ ហេតុនេះ ចូរអ្នកកុំស្ថិតក្នុងចំណោមអ្នកដែលមានមន្ទិលសង្ស័យឱ្យសោះ។

61. ដូចនេះ ជនណាដែលជជែកដេញដោលនឹងអ្នក(ឱព្យាការីមូហាំម៉ាត់)ក្នុងរឿងនោះ(រឿងរ៉ាវរបស់ព្យាការីអ៊ីសា)ក្រោយពីចំណេះដឹងបានមកដល់អ្នកហើយនោះ ចូរអ្នកពោល(ទៅកាន់ពួកគេ)ថា៖ សូមពួកអ្នកមកទីនេះ! យើងនឹងហៅកូនចៅរបស់ពួកយើងនិងកូនចៅរបស់ពួកអ្នក ហើយនិងកិរិយារបស់ពួកយើងនិងកិរិយារបស់ពួកអ្នក ព្រមទាំងខ្លួនពួកយើងនិងខ្លួនពួកអ្នក។ បន្ទាប់មក ពួកយើងនឹងទទូច(ទៅកាន់អល់ឡោះ)សុំឱ្យបណ្តាសារបស់អល់ឡោះធ្លាក់ទៅលើពួកដែលភូតកុហក។

62. ពិតប្រាកដណាស់ នេះគឺជាដំណឹងពិត(ដោយគ្មានការមន្ទិលសង្ស័យ)។ ហើយគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

63. តែប្រសិនបើពួកគេងាកចេញវិញនោះ ពិតប្រាកដណាស់ អល់ឡោះមហាដឹងបំផុតចំពោះពួកដែលបង្កវិនាសកម្ម។

64. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ឱពួកអះលីគីតាប(ពួកដែលគេផ្តល់គម្ពីរឱ្យ)! សូមពួកអ្នកអញ្ជើញមករកពាក្យសម្តីមួយដែលមានស្មើភាពគ្នារវាងពួកយើងនិងពួកអ្នក នោះគឺ ពួកយើងមិនត្រូវគោរពសក្ការៈចំពោះអ្វីផ្សេងក្រៅពីអល់ឡោះ ហើយពួកយើងមិនធ្វើស្តីរិកចំពោះទ្រង់នូវអ្វីមួយឡើយ ហើយក៏មិនយកគ្នាឯង(មនុស្សលោកដូចគ្នា)ធ្វើជាព្រះជាម្ចាស់ក្រៅពីអល់ឡោះនោះដែរ។ តែប្រសិនបើពួកគេងាកចេញ ចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ពោលថា៖ សូមពួកអ្នកធ្វើសាក្សីផងចុះថា ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលប្រគល់ខ្លួនចំពោះអល់ឡោះ(ជាជនមូស្លីម)។

65. ឱពួកអះលីគីតាប! ហេតុអ្វីបានជាពួកអ្នកដេញដោលគ្នាអំពីសាសនារបស់ព្យាការីអ៊ីព្រហ៊ីម ខណៈដែលគេមិនបានបញ្ចុះគម្ពីរតាវ៉ត និងអ៊ិញជីលនោះឡើយ លើកលែងតែក្រោយពី(ជំនាន់)គាត់។ តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

66. ពួកអ្នក គឺជាពួកដែលជជែកដេញដោលក្នុងរឿងដែលពួកអ្នកបានដឹង(ពាក់ព័ន្ធនឹងកិច្ចការសាសនារបស់ពួកអ្នក និងអ្វីដែលគេបញ្ចុះមកកាន់ពួកអ្នក)។ ដូច្នេះ ហេតុអ្វីបានជាពួកអ្នកជជែកដេញដោលចំពោះរឿង(ព្យាការីអ៊ីព្រហ៊ីម)ដែលពួកអ្នកគ្មានចំណេះដឹងអំពីវាសោះបែបនេះ? ហើយអល់ឡោះទ្រង់ដឹងបំផុត ខណៈដែលពួកអ្នកមិនដឹងឡើយ។

67. ព្យាការីអ៊ីព្រហ៊ីមមិនមែនស្ថិតនៅលើសាសនាយូដានោះឡើយ ហើយក៏មិនមែនស្ថិតនៅលើសាសនាគ្រីស្តនោះដែរ។ ក៏ប៉ុន្តែគាត់ជាអ្នកដែលស្អាតស្អំ ជាអ្នកដែលប្រគល់ខ្លួនចំពោះអល់ឡោះតែមួយគត់(ជាអ្នកមូស្លីម) ហើយគាត់ក៏ពុំមែនស្ថិតក្នុងចំណោមពួកមុស្រីគីន(ពួកពហុទេពនិយម)នោះដែរ។

68. ពិតប្រាកដណាស់ មនុស្សដែលជិតស្និទ្ធនឹងព្យាការីអ៊ីព្រហ៊ីមបំផុត គឺបណ្តាអ្នកទាំងឡាយដែលដើរតាមគាត់(នាសម័យកាលរបស់គាត់) និងព្យាការី(មូហាំម៉ាត់) ហើយនិងបណ្តាអ្នកដែលមានជំនឿ(នៃប្រជាជាតិនេះ)។ ហើយអល់ឡោះជាអ្នកគាំពារបណ្តាអ្នកដែលមានជំនឿ។

69. ក្នុងចំណោមពួកអះលីគីតាប គឺមានក្រុមមួយដែលពួកគេប្រាថ្នាចង់ធ្វើឱ្យពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)វង្វេង តែពួកគេមិនបានធ្វើឱ្យនរណាម្នាក់វង្វេងក្រៅពីខ្លួនឯងប៉ុណ្ណោះ។ ប៉ុន្តែពួកគេមិនដឹងខ្លួនឡើយ។

70. ឱពួកអះលីគីតាប! ហេតុអ្វីបានជាពួកអ្នកប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់អល់ឡោះ ខណៈដែលពួកអ្នកបានដឹងឮ(ថាវាជាការពិត)ហើយនោះ?

71. ឱពួកអះលីគីតាប! ហេតុអ្វីបានជាពួកអ្នកលាយឡំប្រការពិតជាមួយនឹងប្រការមិនពិត ហើយពួកអ្នកលាក់បាំងការពិត ខណៈដែលពួកអ្នកបានដឹងហើយនោះ?

72. ហើយមានមួយក្រុមក្នុងចំណោមពួកអះលីគីតាបបាននិយាយថា៖ ចូរពួកអ្នកមានជំនឿចំពោះអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចះឱ្យបណ្តាអ្នកមានជំនឿនៅពេលព្រឹក ហើយត្រូវបដិសេធនឹងវាវិញនៅពេលល្ងាច សង្ឃឹមថាពួកគេ(អ្នកមានជំនឿ)នឹងវិលត្រឡប់(ចាកចេញពីសាសនារបស់ពួកគេវិញ)។

73. (ហើយពួកគេបាននិយាយទៀតថា៖) ហើយចូរពួកអ្នកកុំមានជំនឿឲ្យសោះ លើកលែងតែអ្នកណាដែលកាន់តាមសាសនារបស់ពួកអ្នកប៉ុណ្ណោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពិតប្រាកដណាស់ ការចង្អុលបង្ហាញ(ដ៏ពិតប្រាកដ)នោះ គឺជាការចង្អុលបង្ហាញរបស់អល់ឡោះ។ (ពួកអ្នកនិយាយដូចនេះ)ដោយពួកអ្នកបារម្ភខ្លាចគេផ្តល់ឱ្យនរណាម្នាក់ដូចអ្វីដែលគេបានផ្តល់ឱ្យពួកអ្នក ឬពួកអ្នកបារម្ភខ្លាចពួកគេជជែកយកឈ្នះពួកអ្នកនៅចំពោះមុខព្រះជាម្ចាស់របស់ពួកអ្នកប៉ុណ្ណោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពិតប្រាកដណាស់ ការប្រោសប្រទាននោះ គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់អល់ឡោះជាម្ចាស់ដោយទ្រង់ប្រទានវាដល់ជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាវិសេសវិសាល មហាដឹងបំផុត។

74. ទ្រង់កំណត់ក្តីមេត្តាករុណារបស់ទ្រង់ចំពោះបុគ្គលណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមានភាពសប្បុរសធំធេងបំផុត។

75. ហើយក្នុងចំណោមពួកអះលីគីតាបផងដែរ មានអ្នកខ្លះ ប្រសិនបើអ្នកទុកចិត្តគេដោយផ្ញើទ្រព្យសម្បត្តិជាច្រើនទុកជាមួយនឹងគេ គេនឹងប្រគល់វាឱ្យអ្នកវិញ។ ហើយមានអ្នកខ្លះទៀត ប្រសិនបើអ្នកទុកចិត្តគេដោយផ្ញើតែទ្រព្យសម្បត្តិបន្តិចបន្តួចក៏ដោយ ក៏គេនឹងមិនប្រគល់វាឱ្យអ្នកវិញឡើយ ទាល់តែអ្នកព្យាយាមទាមទារវិញជដែលៗ(ទើបគេព្រមប្រគល់ឱ្យ)។ នោះគឺដោយសារតែពួកគេនិយាយថា៖ គ្មានទោសពៃអ្វីមកលើពួកយើងក្នុងការយកទ្រព្យសម្បត្តិរបស់ពួក(អារ៉ាប់)ដែលជាអនក្ខរជននោះឡើយ ហើយពួកគេបាននិយាយប្រឌិតកុហកទៅលើអល់ឡោះ ខណៈដែលពួកគេបានដឹងហើយនោះ។

76. ផ្ទុយទៅវិញ ជនណាហើយដែលបានបំពេញនូវកិច្ចសន្យារបស់ខ្លួន ព្រមទាំងគោរពកោតខ្លាចអល់ឡោះនោះ ពិតប្រាកដណាស់ អល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលកោតខ្លាច។

77. ពិតប្រាកដណាស់ ពួកដែលយកកិច្ចសន្យារបស់អល់ឡោះ ហើយនិងការស្បថរបស់ខ្លួនទៅប្តូរយកកម្រៃបន្តិចបន្តួចនោះ ពួកគេពុំមានចំណែកអ្វីពីផលបុណ្យនៅថ្ងៃបរលោកឡើយ ហើយអល់ឡោះនឹងមិនមានបន្ទូលទៅកាន់ពួកគេ និងមិនទតមើលទៅកាន់ពួកគេឡើយនៅថ្ងៃបរលោក ហើយទ្រង់ក៏មិនជម្រះសម្អាតពួកគេ(ពីភាពកំខ្វក់ បាបកម្ម ការប្រឆាំង)នោះដែរ។ ហើយពួកគេនឹងទទួលទណ្ឌកម្មដ៏ឈឺចាប់បំផុត។

78. ហើយពិតប្រាកដណាស់ នៅក្នុងចំណោមពួកគេ(ពួកយូដា) គឺមានក្រុមមួយដែលគ្រលាស់អណ្តាតរបស់ពួកគេសូត្រគម្ពីរ(តាវ៉ាត) ដើម្បីឱ្យពួកអ្នកគិតស្មានថា វា(អ្វីដែលពួកគេសូត្រ)គឺមកពីគម្ពីរ ខណៈដែលវាមិនមែនជាផ្នែកមួយនៃគម្ពីរ(តាវ៉ាត)ឡើយ។ ហើយពួកគេនិយាយទៀតថា៖ វាគឺមកពីអល់ឡោះ ខណៈដែលវាពុំមែនមកពីអល់ឡោះឡើយ។ ហើយពួកគេនិយាយប្រឌិតកុហកទៅលើអល់ឡោះ ខណៈដែលពួកគេបានដឹងហើយនោះ។

79. មិនគប្បីឡើយចំពោះមនុស្សដែលអល់ឡោះផ្តល់ឱ្យគេនូវគម្ពីរ ចំណេះដឹង ហើយនិងភាពជាព្យាការី ក្រោយមក គេបែរជានិយាយទៅកាន់មនុស្សលោកថា៖ ចូរពួកអ្នកតាំងខ្លួនជាអ្នកគោរពសក្ការៈមកចំពោះខ្ញុំផ្សេងពីអល់ឡោះនោះ។ ក៏ប៉ុន្តែ(គេត្រូវនិយាយថា៖) ចូរពួកអ្នកក្លាយខ្លួនជាអ្នកចេះដឹងជ្រៅជ្រះ តាមរយៈអ្វីដែលពួកអ្នកបានបង្រៀនដល់មនុស្សនូវគម្ពីរ(ដែលគេបានបញ្ចុះមក) និងតាមរយៈអ្វីដែលពួកអ្នកបានរៀនសូត្រ។

80. ហើយគេក៏មិនគប្បីផងដែរក្នុងការប្រើពួកអ្នកឱ្យយកបណ្តាម៉ាឡាអ៊ីកាត់ និងបណ្តាព្យាការីទាំងឡាយធ្វើជាព្រះជាម្ចាស់នោះ។ តើសមទេដែលគេប្រើពួកអ្នកឱ្យប្រឆាំង(នឹងអល់ឡោះ)បន្ទាប់ពីពួកអ្នកបានប្រគល់ខ្លួនចំពោះទ្រង់(ក្លាយជាជនមូស្លីម)ហើយនោះ?

81. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹកឃើញ នៅពេលដែលអល់ឡោះបានដាក់កិច្ចសន្យាយ៉ាងម៉ឺងម៉ាត់ចំពោះបណ្តាព្យាការីទាំងឡាយថា៖ ទោះបីជាយើងបានប្រទានដល់ពួកអ្នកនូវគម្ពីរ និងគតិបណ្ឌិតក៏ដោយ បន្ទាប់មក (ពេលណា)មានអ្នកនាំសារម្នាក់(គឺព្យាការីមូហាំម៉ាត់)បានមកដល់ពួកអ្នកដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃអ្វី(គម្ពីរ)ដែលមាននៅជាមួយពួកអ្នក គឺពួកអ្នកត្រូវតែមានជំនឿចំពោះគេ និងជួយគាំទ្រដល់គេ។ ទ្រង់បានមានបន្ទូលថា៖ តើពួកអ្នកទទួលស្គាល់ដូចនេះ និងព្រមទទួលយកនូវកិច្ចសន្យាដ៏ម៉ឺងម៉ាត់របស់យើងដែរឬទេ? ពួកគេបានឆ្លើយថា៖ ពួកយើងព្រមទទួលស្គាល់ហើយ។ ទ្រង់បានមានបន្ទូលថា៖ ដូចនេះ ចូរពួកអ្នកធ្វើសាក្សីចុះ យើងក៏ស្ថិតក្នុងចំណោមអ្នកធ្វើសាក្សីជាមួយពួកអ្នកដែរ។

82. ដូចនេះ ជនណាហើយដែលបានងាកចេញបន្ទាប់ពីនោះ អ្នកទាំងនោះហើយគឺជាអ្នកដែលប្រព្រឹត្តអំពើខុសឆ្គង។

83. ដូច្នេះ តើពួកគេស្វែងរកសាសនាផ្សេងក្រៅពីសាសនារបស់អល់ឡោះ(សាសនាអ៊ីស្លាម)ឬ ខណៈដែលបណ្តាអ្នកដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺសុទ្ធតែប្រគល់ខ្លួនចំពោះទ្រង់ទាំងស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្តនោះ? ហើយពួកគេនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ(នៅថ្ងៃបរលោក)។

84. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពួកយើងមានជំនឿចំពោះអល់ឡោះ និងអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះមកឱ្យពួកយើង ហើយនិងអ្វីដែលគេបានបញ្ជូនទៅឱ្យព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្មាឯល ព្យាការីអ៊ីស្ហាក ព្យាការីយ៉ាក់កូប និងពូជពង្សរបស់ព្យាការីយ៉ាក់កូប(ដែលជាព្យាការី) ហើយនិងអ្វីដែលគេបានប្រទានឱ្យព្យាការីមូសា និងព្យាការីអ៊ីសា ព្រមទាំងអ្វី(គម្ពីរទាំងអស់)ដែលគេបានប្រទានឱ្យបណ្តាព្យាការីទាំងឡាយមកពីព្រះជាម្ចាស់របស់ពួកគេ។ ពួកយើងមិនបែងចែករវាងនរណាម្នាក់ក្នុងចំណោមពួកគេឡើយ ហើយចំពោះអល់ឡោះ(តែមួយគត់)ដែលពួកយើងប្រគល់ខ្លួន(ចូលអ៊ីស្លាម)។

85. ហើយជនណាដែលស្វែងរកសាសនាផ្សេងក្រៅពីសាសនាអ៊ីស្លាម គេនឹងមិនទទួលយក(សាសនានោះ)អំពីរូបគេឡើយ ហើយនៅថ្ងៃបរលោករូបគេនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់។

86. តើឱ្យអល់ឡោះផ្តល់ការចង្អុលបង្ហាញយ៉ាងដូចម្តេចចំពោះក្រុមមួយដែលពួកគេបានប្រឆាំងបន្ទាប់ពីពួកគេមានជំនឿ(ចំពោះអល់ឡោះ) ហើយពួកគេក៏បានទទួលស្គាល់ដែរថា ពិតប្រាកដណាស់ អ្នកនាំសារ(មូហាំម៉ាត់)គឺជាការពិត ហើយគាត់ក៏បាននាំមកឱ្យពួកគេនូវបណ្តាភស្តុតាងជាច្រើនដ៏ច្បាស់លាស់ហើយនោះ? ហើយអល់ឡោះមិនផ្តល់ការចង្អុលបង្ហាញចំពោះក្រុមដែលបំពានឡើយ។

87. ពួកទាំងនោះ ការតបស្នងរបស់ពួកគេ គឺនឹងត្រូវទទួលបណ្តាសាពីអល់ឡោះ ពីបណ្តាម៉ាឡាអ៊ីកាត់ និងពីមនុស្សលោកទាំងអស់។

88. ពួកគេនឹងស្ថិតនៅជាក្នុងវា(បណ្តាសា និងឋាននរក)ជានិច្ច ហើយទណ្ឌកម្មនឹងមិនត្រូវបានគេបន្ធូរបន្ថយចំពោះពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេលនោះដែរ។

89. លើកលែងតែបណ្តាអ្នកដែលបានសារភាពកំហុសបន្ទាប់ពីនោះ ព្រមទាំងបានកែខ្លួនប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

90. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿបន្ទាប់ពីពួកគេបានជឿហើយនោះ ក្រោយមក ពួកគេកាន់តែបន្ថែមភាពគ្មានជំនឿរបស់ពួកគេ(រហូតដល់សេចក្តីស្លាប់បានមកដល់) គឺគេនឹងមិនទទួលយកការសារភាពកំហុសរបស់ពួកគេឡើយ។ ពួកទាំងនោះហើយ គឺជាពួកដែលវង្វេង។

91. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ហើយពួកគេបានស្លាប់ក្នុងភាពជាអ្នកគ្មានជំនឿនោះ បើទោះជាពួកគេមានមាសប្រាក់ពេញផែនដី ក៏គេ(អល់ឡោះ)មិនទទួលយកពីនរណាម្នាក់ក្នុងចំណោមពួកគេនោះដែរ សូម្បីតែពួកគេយកវាមកលោះខ្លួនពួកគេ(ឲ្យរួចផុតពីទណ្ឌកម្ម)ក៏ដោយ។ ពួកទាំងនោះហើយ គឺជាពួកដែលត្រូវទទួលទណ្ឌកម្មដ៏សែនឈឺចាប់បំផុត ហើយពួកគេគ្មានអ្នកជួយឡើយ។

92. ពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)មិនទាន់ឈានទៅដល់(ផលបុណ្យ និងឋានៈនៃ)មនុស្សល្អឡើយ លុះត្រាតែពួកអ្នកបរិច្ចាគអំពីអ្វីដែលពួកអ្នកស្រលាញ់។ ហើយអ្វីក៏ដោយដែលពួកអ្នកបានបរិច្ចាគនោះ ពិតប្រាកដណាស់ អល់ឡោះមហាដឹងបំផុតចំពោះវា។

93. រាល់ចំណីអាហារទាំងអស់ធ្លាប់ត្រូវបានអនុញ្ញាតចំពោះអម្បូរអ៊ីស្រាអែល(ទទួលទាន) លើកលែងតែអ្វីដែលអ៊ីស្រាអែល(ព្យាការីយ៉ាក់កូប)បានហាមឃាត់ទៅលើខ្លួនគាត់ផ្ទាល់មុននឹងគេបានបញ្ចុះគម្ពីរតាវ៉ាត ប៉ុណ្ណោះ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នក(ពួកយូដា)យកគម្ពីរតាវ៉ាតមក ហើយចូរពួកអ្នកអានវាមើល៍ ប្រសិនបើពួកអ្នកជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកបានអះអាង)មែននោះ។

94. ដូច្នេះ ជនណាហើយដែលប្រឌិតរឿងកុហកទៅលើអល់ឡោះជាម្ចាស់បន្ទាប់ពីនោះ ពិតប្រាកដណាស់ ពួកទាំងនោះហើយ គឺជាពួកដែលបំពាន។

95. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ អ្វីដែលអល់ឡោះបានមានបន្ទូល គឺជាការពិត។ ហេតុនេះ ចូរពួកអ្នកដើរតាមសាសនារបស់ព្យាការីអ៊ីព្រហ៊ីមដ៏ស្អាតស្អំចុះ ហើយរូបគាត់មិនស្ថិតក្នុងចំណោមពួកមុស្លីគីន(ពួកពហុទេពនិយម)ឡើយ។

96. ពិតប្រាកដណាស់ គេហដ្ឋានដំបូងគេដែលត្រូវគេដាក់សម្រាប់មនុស្សលោក(ដើម្បីធ្វើសក្ការៈចំពោះអល់ឡោះជាម្ចាស់)នោះ គឺស្ថិតនៅឯក្រុងម៉ាក្កះដែលប្រកបដោយពរជ័យ និងជាការចង្អុលបង្ហាញដល់ពិភពទាំងអស់ផងដែរ។

97. នៅក្នុងវា មានសញ្ញាកស្តតាងជាច្រើនដ៏ច្បាស់លាស់ ដែលក្នុងចំណោមនោះគឺម៉ាកមអ៊ីព្រហ៊ីម។ ជនណាហើយដែលបានចូលទៅទីនោះ គឺនឹងមានសុវត្ថិភាព។ ហើយអល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចទៅលើមនុស្សឱ្យធ្វើធម្មយាត្រាហាជ្ជ៍នៅឯពៃទុលឡោះចំពោះជនណាដែលមានលទ្ធភាពទៅដល់ទីនោះ។ ហើយជនណាដែលប្រឆាំងនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់មិនត្រូវការអ្វីមួយពីពិភពទាំងអស់ឡើយ។

98. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ឱពួកអះលីគីតាប! ហេតុអ្វីបានជាពួកអ្នកប្រឆាំងនឹងបណ្តាកសិតាងទាំងឡាយរបស់អល់ឡោះ? ហើយអល់ឡោះជាសាក្សីចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

99. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ឱពួកអះលីគីតាប! ហេតុអ្វីបានជាពួកអ្នករារាំងអ្នកមានជំនឿពីមាគ៌ារបស់អល់ឡោះ ដោយពួកអ្នកចង់ឱ្យមាគ៌ានោះវៀចវេរ ខណៈដែលពួកអ្នក គឺជាសាក្សីស្រាប់(ថាវាជាមាគ៌ាពិត)ហើយនោះ? ហើយអល់ឡោះទ្រង់មិនព្រងើយកន្តើយចំពោះអ្វីដែលពួកអ្នកបានប្រព្រឹត្តនោះឡើយ។

100. ឱបណ្តាអ្នកដែលមានជំនឿ! ប្រសិនបើពួកអ្នកដើរតាមក្រុមមួយក្នុងចំណោមពួកអះលីគីតាប ពួកគេនឹងធ្វើឱ្យពួកអ្នកត្រឡប់ទៅរកភាពគ្មានជំនឿវិញក្រោយពីពួកអ្នកមានជំនឿហើយនោះជាមិនខាន។

101. តើពួកអ្នកប្រឆាំងយ៉ាងដូចម្តេច ខណៈដែលពួកអ្នកត្រូវបានគេសូត្រឲ្យស្តាប់នូវបណ្តាវាក្យខណ្ឌរបស់អល់ឡោះ ហើយអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់) ក៏ស្ថិតនៅជាមួយពួកអ្នកផងដែរនោះ? ជនណាដែលប្រកាន់ខ្ជាប់នឹងអល់ឡោះ(គម្ពីរគួរអាន និងស៊ុណ្ណៈ) ពិតប្រាកដណាស់រូបគេនឹងត្រូវបានគេចង្អុលបង្ហាញទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

102. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់នូវការកោតខ្លាចមួយដ៏ពិតប្រាកដ។ ហើយពួកអ្នកមិនត្រូវស្លាប់ជាដាច់ខាត លើកលែងតែពួកអ្នកជាជនមូស្លីម។

103. ហើយចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ប្រកាន់ខ្ជាប់នឹងខ្សែរបស់អល់ឡោះ(គម្ពីរគួរអាន និងស៊ុណ្ណៈ)ទាំងអស់គ្នា និងមិនត្រូវបែកបាក់គ្នាឡើយ។ ហើយចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់អល់ឡោះចំពោះពួកអ្នក ខណៈដែលពួកអ្នកធ្លាប់ជាសត្រូវនឹងគ្នា(មុនពេលដែលអ៊ីស្លាមបានមកដល់) ក្រោយមក ទ្រង់បានផ្សះផ្សារវាងដួងចិត្តរបស់ពួកអ្នក(តាមរយៈសាសនាអ៊ីស្លាម)។ ពេលនោះ ដោយការប្រោសប្រទានរបស់ទ្រង់ ពួកអ្នកក៏បានក្លាយជាបងប្អូននឹងគ្នា(ក្នុងសាសនា)។ ហើយពួកអ្នកធ្លាប់ស្ថិតនៅលើមាត់រណ្តៅនៃឋាននរក ប៉ុន្តែអល់ឡោះជាម្ចាស់បានសង្គ្រោះពួកអ្នកឱ្យរួចផុតពីវាវិញ(តាមរយៈសាសនាអ៊ីស្លាម)។ ដូច្នោះដែរ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជាក់ប្រាប់ពួកអ្នកនូវវាក្យខណ្ឌទាំងឡាយរបស់ទ្រង់ សង្ឃឹមថាពួកអ្នកទទួលបានការចង្អុលបង្ហាញ។

104. ហើយចូរពួកអ្នកបង្កើតឱ្យមានក្រុមមួយក្នុងចំណោមពួកអ្នក ដែលអំពាវនាវទៅរកប្រការល្អ ហើយពួកគេប្រើគ្នាឱ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់។ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលជោគជ័យ(ទាំងក្នុងលោកិយ និងថ្ងៃបរលោក)។

105. ហើយចូរពួកអ្នកកុំធ្វើដូច(ពួកអះលីគីតាប)ដែលបានបែកបាក់គ្នា និងបានខ្វែងគំនិតគ្នាបន្ទាប់ពីកសិតាងយ៉ាងច្បាស់លាស់បានមកដល់ពួកគេហើយនោះឱ្យសោះ។ ហើយពួកទាំងនោះ ពួកគេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

106. គឺនៅថ្ងៃដែលផ្ទៃមុខ(អ្នកមានជំនឿ) សភ្លឺ និងផ្ទៃមុខ(ពួកគ្មានជំនឿ) ខ្មៅងងឹត។ រីឯពួកដែលផ្ទៃមុខរបស់ពួកគេខ្មៅងងឹតនោះ (មានគេសួរទៅកាន់ពួកគេថា៖) តើពួកអ្នកប្រឆាំង(នឹងអល់ឡោះ)ក្រោយពីពួកអ្នកបានជឿហើយឬ? ដូច្នេះ ចូរពួកអ្នកភ្លក់នូវទណ្ឌកម្ម(របស់អល់ឡោះ)ដោយសារតែការប្រឆាំងរបស់ពួកអ្នកនោះចុះ។

107. ចំណែកឯបណ្តាអ្នកដែលផ្ទៃមុខរបស់ពួកគេសភ្លឺវិញ ពួកគេស្ថិតនៅក្នុងក្តីមេត្តាករុណារបស់អល់ឡោះ(ឋានសួគ៌)។ ពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

108. ទាំងនោះគឺជាបណ្តាវាក្យខណ្ឌរបស់អល់ឡោះដែលយើងបានសូត្រឲ្យអ្នកស្តាប់យ៉ាងពិតប្រាកដ។ ហើយអល់ឡោះទ្រង់មិនប្រាថ្នាបំពានទៅលើពិភពទាំងអស់ឡើយ។

109. ហើយអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលមាននៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយកិច្ចការទាំងអស់ គឺត្រូវគេនាំត្រឡប់ទៅកាន់អល់ឡោះ។

110. ពួកអ្នក(ឱប្រជាជាតិរបស់ព្យាការីមូហាំម៉ាត់)គឺជាប្រជាជាតិមួយដែលល្អប្រពៃជាងគេបំផុតដែលគេបានបញ្ចេញ(បង្កើត)មកសម្រាប់មនុស្សលោក ដោយពួកអ្នកប្រើគ្នាឱ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ ព្រមទាំងមានជំនឿចំពោះអល់ឡោះ។ ហើយប្រសិនបើពួកអះលីគីតាបមានជំនឿ(លើព្យាការីមូហាំម៉ាត់)នោះ វាគឺជាការប្រសើរបំផុតសម្រាប់ពួកគេ។ ក្នុងចំណោមពួកគេ គឺមានអ្នកដែលមានជំនឿ តែភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស(អជំនឿ)។

111. ពួកគេមិនអាចបង្កគ្រោះថ្នាក់ដល់ពួកអ្នកបានជាដាច់ខាត ក្រៅតែពីការបញ្ឆិចិត្តប៉ុណ្ណោះ។ ហើយប្រសិនបើពួកគេធ្វើសង្គ្រាមប្រយុទ្ធជាមួយពួកអ្នកនោះ ពួកគេប្រាកដជានឹងរត់ត្រឡប់ក្រោយជាមិនខាន។ ក្រោយមក ពួកគេក៏នឹងមិនត្រូវបានគេជួយនោះដែរ។

112. ភាពអាប់ឱនត្រូវបានគេដាក់លើពួកគេ(ពួកយូដា)ទោះបីជាពួកគេស្ថិតនៅទីកន្លែងណាក៏ដោយ លើកលែងតែ(ពួកគេ)ទទួលបានកិច្ចព្រមព្រៀង(សន្តិភាព)ពីអល់ឡោះ និងពីមនុស្សលោក(ណាម្នាក់)ប៉ុណ្ណោះ។ ពួកគេវិលត្រឡប់ទៅវិញដោយទទួលរងនូវការខឹងសម្បាពីអល់ឡោះ ហើយភាពក្រខ្សត់ត្រូវបានហ៊ុមព័ទ្ធពួកគេ។ នោះគឺដោយសារតែពួកគេបានប្រឆាំងនឹងបណ្តាកសិណ្ឌតាងទាំងឡាយរបស់អល់ឡោះ និងបានសម្លាប់ព្យាការីទាំងឡាយដោយបំពាន។ នោះគឺដោយសារតែពួកគេបានប្រឆាំង និងបានបំពាន(ទៅលើព្រំដែនរបស់អល់ឡោះ)។

113. ពួកគេទាំងអស់ មិនមែនសុទ្ធតែដូចគ្នានោះឡើយ។ ក្នុងចំណោមពួកអះលីគីតាប គឺមានក្រុមមួយដែលប្រកាន់ខ្ជាប់(នឹងសាសនារបស់អល់ឡោះ)ដោយពួកគេសូត្រនូវបណ្តាវាក្យខណ្ឌរបស់អល់ឡោះនៅពេលយប់ ខណៈដែលពួកគេស៊ូជោត(សឡាត)។

114. ពួកគេមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោក ហើយពួកគេប្រើគ្នាឱ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ ព្រមទាំងរួសរាន់ក្នុងការប្រព្រឹត្តអំពើល្អទាំងឡាយ។ អ្នកទាំងនោះហើយ គឺស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

115. អ្វីក៏ដោយដែលអ្នកទាំងនោះបានធ្វើនៃប្រការល្អ(ទោះបីតិចក្តីច្រើនក្តី)ក៏គេមិនធ្វើឱ្យវាបាត់បង់នោះដែរ។ ហើយអល់ឡោះមហាដឹងបំផុតចំពោះអ្នកដែលកោតខ្លាច។

116. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ទ្រព្យសម្បត្តិរបស់ពួកគេ និងកូនចៅរបស់ពួកគេមិនអាចការពារពួកគេពីអល់ឡោះជាម្ចាស់បន្តិចណាឡើយ។ ពួកទាំងនោះហើយគឺជាពួកឋាននរកដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

117. ការប្រៀបធៀបនូវអ្វីដែលពួកគេ(ពួកគ្មានជំនឿ)បានបរិច្ចាគក្នុងជីវិតលោកិយនេះ គឺប្រៀបដូចជាខ្យល់ត្រជាក់ខ្លាំងដែលបានបក់បោកទៅលើដំណាំរបស់ក្រុមមួយដែលបានបំពានលើខ្លួនឯង។ ពេលនោះ វាក៏បានបំផ្លាញដំណាំនោះអស់។ ហើយអល់ឡោះមិនបានបំពានទៅលើពួកគេឡើយ(ចំពោះរឿងនោះ)ក៏ប៉ុន្តែពួកគេទៅវិញទេដែលជាអ្នកបំពាន(លើខ្លួនឯង)។

118. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកអ្នកផ្សេងក្រៅពីគ្នាឯងធ្វើជាមិត្តជិតស្និទ្ធ ដោយពួកអ្នកបង្ហាញឱ្យពួកគេបានដឹងពីអាថ៌កំបាំងរបស់ពួកអ្នកឱ្យសោះ។ ពួកគេរំពឹងថា ពួកអ្នកនឹងទទួលរងនូវគ្រោះថ្នាក់។ ពិតប្រាកដណាស់ ការស្អប់ខ្ពើម(ពីសំណាក់ពួកគេ)បានលេចឡើងនៅលើអណ្តាតរបស់ពួកគេ។ ហើយភាពស្អប់ខ្ពើមដែលពួកគេលាក់ទុកនៅក្នុងទ្រូងរបស់ពួកគេ គឺធំឆេងជាងនោះទៅទៀត។ ពិតប្រាកដណាស់ យើងបានបញ្ជាក់ប្រាប់ដល់ពួកអ្នកនូវភស្តុតាងដ៏ច្បាស់លាស់ជាច្រើន ប្រសិនបើពួកអ្នកចេះគិតពិចារណា។

119. ពួកអ្នក គឺបែបនេះឯង។ ពួកអ្នកស្រលាញ់ពួកគេ តែពួកគេវិញមិនបានស្រលាញ់ពួកអ្នកឡើយ។ ហើយពួកអ្នកមានជំនឿលើបណ្តាគម្ពីរទាំងអស់(រួមទាំងគម្ពីររបស់ពួកគេផងដែរ)។ ហើយនៅពេលដែលពួកគេបានជួបនឹងពួកអ្នក ពួកគេនិយាយថា៖ ពួកយើងមានជំនឿហើយ។ តែនៅពេលពួកគេចាកចេញទៅវិញ ពួកគេបានខាំចុងម្រាមដៃខ្លួនឯងដោយការចងកំហឹង(ចំពោះពួកអ្នក)។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកស្លាប់ទាំងការចងកំហឹងបែបនេះចុះ។ ពិតប្រាកដណាស់ អល់ឡោះមហាដឹងនូវអ្វីដែលនៅក្នុងដួងចិត្ត(របស់ពួកគេ)។

120. ប្រសិនបើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ទទួលបានប្រការល្អ វាធ្វើឲ្យពួកគេមិនសប្បាយចិត្តឡើយ។ តែប្រសិនបើពួកអ្នកទទួលរងនូវប្រការអាក្រក់វិញ ពួកគេនឹងសប្បាយចិត្តចំពោះរឿងនោះមិនខាន។ ហើយប្រសិនបើពួកអ្នកអត់ធ្មត់ ព្រមទាំងកោតខ្លាចនោះ ឧបាយកលរបស់ពួកគេនឹងមិនអាចបង្កគ្រោះថ្នាក់អ្វីដល់ពួកអ្នកបានឡើយ។ ពិតប្រាកដណាស់ អល់ឡោះដឹងជ្រួតជ្រាបបំផុតចំពោះអ្វីដែលពួកគេប្រព្រឹត្ត។

121. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលអ្នកបានចាកចេញពីគ្រួសាររបស់អ្នកនៅពេលព្រឹក(ទៅធ្វើសង្គ្រាមអ៊ូហ៊ុទ)ដោយអ្នកបានកំណត់ទីតាំងឱ្យបណ្តាអ្នកដែលមានជំនឿដើម្បីឈរជើងប្រយុទ្ធ។ ហើយអល់ឡោះមហាឮ មហាដឹងបំផុត។

122. (ចូរអ្នកនឹកឃើញ) នៅពេលដែលមានពីរក្រុមក្នុងចំណោមពួកអ្នក(គឺអម្បូរសាឡាម៉ះ និងអម្បូរហារីសៈ) មានបំណងត្រឡប់ក្រោយ ប៉ុន្តែអល់ឡោះជាអ្នកជួយដល់ពួកគេទាំងពីរក្រុមនោះ។ ដូច្នេះ ចូរឱ្យបណ្តាអ្នកដែលមានជំនឿប្រគល់ការទុកចិត្តលើអល់ឡោះចុះ។

123. ហើយប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានជួយពួកអ្នកនៅក្នុងសមរភូមិហ្គាទើរ ខណៈដែលពួកអ្នកមានភាពទន់ខ្សោយ។ ដូចនេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះចុះ សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

124. (ចូរអ្នកនឹកឃើញ) នៅពេលដែលអ្នកបាននិយាយទៅកាន់បណ្តាអ្នកដែលមានជំនឿថា៖ តើមិនគ្រប់គ្រាន់ទេឬសម្រាប់ពួកអ្នកដោយព្រះជាម្ចាស់របស់ពួកអ្នកទ្រង់បញ្ជូនម៉ាឡាអ៊ីកាត់ចំនួនបីពាន់នាក់(មកជួយពួកអ្នក)នោះ?

125. ពិតមែនហើយ។ ប្រសិនបើពួកអ្នកអត់ធ្មត់(នៅក្នុងការប្រយុទ្ធជាមួយពួកគេ)និងកោតខ្លាច(ចំពោះអល់ឡោះ)ហើយទ័ពជំនួយរបស់សត្រូវបានមកដល់ពួកអ្នកយ៉ាងឆាប់រហ័សនោះ (ប្រសិនបើវាកើតឡើងដូច្នោះមែន) ប្រាកដជាព្រះជាម្ចាស់របស់អ្នកនឹងបញ្ជូនម៉ាឡាអ៊ីកាត់ចំនួនប្រាំពាន់នាក់ដោយមានសញ្ញាសម្គាល់ដ៏ច្បាស់លាស់(មកជួយពួកអ្នកបន្ថែមទៀត)ជាមិនខាន។

126. អល់ឡោះមិនធ្វើឱ្យរឿងនោះកើតឡើងឡើយ លើកលែងតែដើម្បីជាការផ្តល់ដំណឹងរីករាយដល់ពួកអ្នក និងដើម្បីឱ្យដួងចិត្តរបស់ពួកអ្នកមានភាពនឹងនរនឹងវាប៉ុណ្ណោះ។ ហើយគ្មានទេជ័យជម្នះដ៏ពិតប្រាកដនោះ លើកលែងតែមកពីអល់ឡោះជាម្ចាស់ដែលមហាខ្លាំងពូកែ មហាគតិបណ្ឌិតប៉ុណ្ណោះ។

127. ដើម្បីកាត់ផ្តាច់(បំផ្លាញ)ក្រុមមួយក្នុងចំណោមពួកដែលគ្មានជំនឿ ឬបំបាក់ពួកគេប៉ុណ្ណោះ។ ពេលនោះ ពួកគេនឹងត្រឡប់ទៅវិញទាំងភាពអាម៉ាស់។

128. អ្នកគ្មានសិទ្ធិអ្វីឡើយនៅក្នុងរឿងនេះ ទោះជាទ្រង់ទទួលយកការសារភាពកំហុសរបស់ពួកគេ(ឲ្យពួកគេចូលសាសនាអ៊ីស្លាម)ឬមួយក៏ទ្រង់ដាក់ទណ្ឌកម្មពួកគេក៏ដោយ ពីព្រោះពួកគេគឺជាពួកដែលបំពាន។

129. ហើយអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ទ្រង់អភ័យទោសចំពោះជនណាដែលទ្រង់មានចេតនា និងដាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

130. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំស៊ីការប្រាក់ដែលជាការបន្ថែមទ្វេដងទៅលើប្រាក់ដើម(របស់ពួកអ្នក)ឱ្យសោះ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

131. ចូរពួកអ្នកខ្លាចភ្លើងនរកដែលគេត្រៀមទុកសម្រាប់ពួកដែលគ្មានជំនឿ។

132. ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសារ(របស់ទ្រង់) សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រលាញ់។

133. ហើយចូរពួកអ្នករួសរាន់ទៅកាន់ការអភ័យទោសពីព្រះជាម្ចាស់របស់ពួកអ្នក និងឋានសួគ៌(របស់ទ្រង់)ដែលទទឹងរបស់វាគឺប្រៀបដូចផ្ទៃមេឃជាច្រើនជាន់និងផែនដីដែលអល់ឡោះជាម្ចាស់ទ្រង់បានត្រៀមទុកម្រាប់បណ្តាអ្នកដែលកោតខ្លាច។

134. គឺបណ្តាអ្នកដែលបរិច្ចាគ(ទ្រព្យសម្បត្តិរបស់ខ្លួន)ទាំងក្នុងស្ថានភាពធូរធារ និងក្នុងស្ថានភាពក្រខ្សត់ និងបណ្តាអ្នកដែលចេះទប់កំហឹងរបស់ខ្លួន ហើយនិងបណ្តាអ្នកដែលចេះអធ្យាស្រ័យដល់មនុស្សលោក។ ហើយអល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បំផុតចំពោះបណ្តាអ្នកដែលសាងអំពើល្អ។

135. ហើយនិងបណ្តាអ្នកដែលកាលណាពួកគេប្រព្រឹត្តបាបកម្ម ឬបំពានលើខ្លួនឯង គឺពួកគេនឹកឃើញដល់អល់ឡោះ។ ពេលនោះពួកគេក៏សុំការអភ័យទោសចំពោះបាបកម្មរបស់ពួកគេ។ ហើយគ្មានអ្នកណាដែលអាចអភ័យទោសចំពោះបាបកម្មទាំងឡាយក្រៅពីអល់ឡោះឡើយ ហើយពួកគេក៏មិនបន្តប្រព្រឹត្តទង្វើនោះទៀតដែរ ខណៈដែលពួកគេដឹងហើយនោះ។

136. អ្នកទាំងនោះ ការតបស្នងរបស់ពួកគេ គឺការទទួលបាននូវការអភ័យទោសពីព្រះជាម្ចាស់របស់ពួកគេ ហើយនិងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ហើយនោះគឺជាការតបស្នងដ៏ប្រពៃបំផុតសម្រាប់បណ្តាអ្នកដែលសាងអំពើល្អ។

137. ពិតប្រាកដណាស់ មាគ៌ាជាច្រើន(របស់អល់ឡោះ)បានកន្លងផុតទៅមុនពួកអ្នករួចទៅហើយ។ ហេតុនេះ ចូរពួកអ្នកធ្វើដំណើរលើផែនដី ហើយពិនិត្យមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបដិសេធនោះយ៉ាងដូចម្តេច?

138. នេះគឺជាការបញ្ជាក់យ៉ាងច្បាស់ដល់មនុស្សលោក និងជាការចង្អុលបង្ហាញ ព្រមទាំងជាដំបូន្មានសម្រាប់បណ្តាអ្នកដែលកោតខ្លាច។

139. ហើយពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)មិនត្រូវមានភាពទន់ខ្សោយ និងកុំមានទុក្ខព្រួយ ពីព្រោះពួកអ្នក គឺជាអ្នកដែលមានភាពខ្ពង់ខ្ពស់ ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។

140. ប្រសិនបើពួកអ្នកទទួលរងរបួស(ក្នុងថ្ងៃសមរភូមិអ៊ូហ៊ុទ)ក៏មានក្រុមមួយ(ពួកគ្មានជំនឿ)ទទួលរងរបួសដូចពួកអ្នកដែរ។ ហើយបណ្តាថ្ងៃទាំងនោះ យើងបានផ្លាស់ប្តូរវារាងមនុស្សលោក (ម្តងទទួលជោគជ័យ ម្តងទទួលបរាជ័យ) គឺដើម្បីអល់ឡោះដឹងថា តើអ្នកណាជាអ្នកដែលមានជំនឿពិតប្រាកដ ហើយទ្រង់ជ្រើសយកនរណាម្នាក់ក្នុងចំណោមពួកអ្នកឱ្យពលីជីវិត (ក្នុងមាគ៌ារបស់ទ្រង់)។ ហើយអល់ឡោះមិនស្រលាញ់ពួកដែលបំពានឡើយ។

141. ហើយក៏ដើម្បីសម្អាតបណ្តាអ្នកមានជំនឿទាំងឡាយពីបាបកម្មរបស់ពួកគេ និងបំផ្លាញពួកដែលគ្មានជំនឿ។

142. តើពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)នឹកស្មានថា ពួកអ្នកនឹងអាចចូលឋានសួគ៌បាន ខណៈដែលអល់ឡោះមិនទាន់វែកញែកច្បាស់លាស់រវាងអ្នកដែលតស៊ូក្នុងចំណោមពួកអ្នក និងអ្នកដែលមានការអត់ធ្មត់ផងនោះឬ?

143. ហើយពិតប្រាកដណាស់ ពួកអ្នកធ្លាប់ប្រាថ្នាចង់ស្លាប់មុននឹងពួកអ្នកប្រឈមនឹងវា(កាលពីក្នុងសមរភូមិហ្គាទើរ)។ ពិតប្រាកដណាស់ ពួកអ្នកបានជួបវាហើយ(ក្នុងថ្ងៃសមរភូមិអ៊ូហ៊ុទនេះ) ខណៈដែលពួកអ្នកមើលឃើញវាផ្ទាល់នឹងភ្នែក។

144. ព្យាការីមូហាំម៉ាត់គ្រាន់តែជាអ្នកនាំសារម្នាក់ដូចបណ្តាអ្នកនាំសារទាំងឡាយដែលបានកន្លងផុតទៅកាលពីមុននោះដែរ។ ប្រសិនបើគាត់ស្លាប់ ឬត្រូវបានគេសម្លាប់នោះ តើពួកអ្នកនឹងត្រឡប់ចេញពីសាសនា(អ៊ីស្លាម)របស់ពួកអ្នកឬ? ហើយជនណាដែលវិលត្រឡប់ចេញពីសាសនារបស់ខ្លួននោះ ពិតប្រាកដណាស់វាមិនអាចបង្កគ្រោះថ្នាក់អ្វីចំពោះអល់ឡោះបន្តិចណាឡើយ។ ហើយអល់ឡោះជាម្ចាស់នឹងតបស្នងចំពោះបណ្តាអ្នកដែលដឹងគុណ។

145. ហើយជីវិតនីមួយៗមិនអាចស្លាប់នោះឡើយ លុះត្រាតែមានការអនុញ្ញាតពីអល់ឡោះដែលបានកត់ត្រាពេលកំណត់(នៃអាយុជីវិតរបស់គេ)ប៉ុណ្ណោះ។ ជនណាហើយចង់បានផលតបស្នងនៅលើលោកិយ យើងនឹងប្រទានឱ្យគេអំពីវា។ ហើយជនណាដែលចង់បានផលតបស្នងនៅថ្ងៃបរលោក យើងក៏នឹងប្រទានឱ្យគេអំពីវា(ដូចគ្នា)។ ហើយយើងនឹងតបស្នងដល់បណ្តាអ្នកដែលដឹងគុណ។

146. ហើយមានព្យាការីយ៉ាងច្រើនដែលអ្នកដើរតាមគាត់ជាច្រើនបានចូលរួមប្រយុទ្ធជាមួយនឹងគាត់ ប៉ុន្តែពួកគេមិនបានកំសាកវាយដោយសារតែអ្វីដែលពួកគេទទួលរងក្នុងមាគ៌ារបស់អល់ឡោះនោះឡើយ ហើយពួកគេក៏មិនទន់ខ្សោយ និងមិនចុះញ៉ែនោះដែរ។ ហើយអល់ឡោះស្រលាញ់បណ្តាអ្នកដែលអត់ធ្មត់។

147. ហើយ(អ្នកទាំងនោះ) ពាក្យសម្តីរបស់ពួកគេ គឺគ្មានអ្វីក្រៅពីការពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំផងចុះនូវបាបកម្មទាំងឡាយរបស់យើងខ្ញុំ ហើយនិងការជ្រុលជ្រួសក្នុងកិច្ចការរបស់យើងខ្ញុំ។ ហើយសូមព្រះអង្គមេត្តាពង្រឹងគោលជំហររបស់យើងខ្ញុំព្រមទាំងជួយយើងខ្ញុំឱ្យមានជ័យជម្នះលើក្រុមដែលគ្មានជំនឿផងចុះ។

148. ដូច្នេះ អល់ឡោះជាម្ចាស់ក៏បានប្រទានឱ្យពួកគេនូវផលបុណ្យនៅក្នុងលោកិយ ហើយនិងផលបុណ្យដ៏ល្អប្រពៃបំផុត(ឋានសួគ៌)នៅថ្ងៃបរលោក។ ហើយអល់ឡោះស្រលាញ់បណ្តាអ្នកដែលសាងអំពើល្អ។

149. ឱបណ្តាអ្នកដែលមានជំនឿ! ប្រសិនបើពួកអ្នកប្រតិបត្តិតាមពួកប្រឆាំង នោះពួកគេច្បាស់ជានឹងធ្វើឱ្យពួកអ្នកវិលត្រឡប់ចេញពីសាសនារបស់ពួកអ្នក។ ពេលនោះ ពួកអ្នកនឹងវិលត្រឡប់ទៅវិញដោយភាពខាតបង់ជាមិនខាន។

150. ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់គឺជាអ្នកគាំពាររបស់ពួកអ្នក ហើយទ្រង់ជាអ្នកជួយដ៏ល្អបំផុត។

151. យើង(អល់ឡោះ)នឹងបញ្ចូលភាពភ័យខ្លាចទៅក្នុងដួងចិត្តរបស់ពួកដែលប្រឆាំង ដោយសារតែការធ្វើស៊ីរិករបស់ពួកគេចំពោះអល់ឡោះនូវអ្វីដែលទ្រង់មិនបានបញ្ចុះនូវភស្តុតាងសំអាងណាមួយសោះនោះ។ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺឋាននរក ជាទីស្នាក់អាស្រ័យដ៏អាក្រក់បំផុតសម្រាប់ពួកដែលបំពាន។

152. ពិតប្រាកដណាស់ អល់ឡោះទ្រង់បានសម្រេចឱ្យពួកអ្នកនូវការសន្យារបស់ទ្រង់(ចំពោះពួកអ្នក)ដោយពួកអ្នកបានសម្លាប់ពួកគេ(សត្រូវ)យ៉ាងខ្លាំងក្លាដោយការអនុញ្ញាតពីទ្រង់។ លុះពេលដែលពួកអ្នកបរាជ័យ ហើយពួកអ្នកបានខ្វែងយោបល់គ្នាចំពោះបទបញ្ជាដែលគាត់(ព្យាការីមូហាំម៉ាត់)បានដាក់មកលើពួកអ្នក ហើយពួកអ្នកបានល្មើសទៅនឹងបទបញ្ជា(របស់អ្នកនាំសារ) ក្រោយពីទ្រង់បានឱ្យពួកអ្នកឃើញនូវអ្វីដែលពួកអ្នកពេញចិត្ត(ជ័យជម្នះ)។ ក្នុងចំណោមពួកអ្នក គឺមានអ្នកដែលប្រាថ្នាចង់បានលោកិយ(ទ្រព្យជ័យភណ្ឌ)។ ហើយក្នុងចំណោមពួកអ្នក ក៏មានអ្នកដែលចង់បាន(ផលបុណ្យ)បរលោកផងដែរ។ ក្រោយមក ទ្រង់បានបង្វែរពួកអ្នកចេញពីពួកគេ(សត្រូវ) ដើម្បីជាការសាកល្បងពួកអ្នក។ ហើយពិតប្រាកដណាស់ ទ្រង់បានអភ័យទោសដល់ពួកអ្នក(ចំពោះការល្មើសនឹងបទបញ្ជារបស់អ្នកនាំសារ)។ ហើយអល់ឡោះជាអ្នកដែលមានក្តីសន្តោសប្រណីដ៏ធំធេងបំផុតចំពោះបណ្តាអ្នកដែលមានជំនឿ។

153. ចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)នឹកឃើញ នៅពេលដែលពួកអ្នករត់ឡើងភ្នំ ហើយពួកអ្នកមិនក្រឡេកមើលទៅនរណាម្នាក់ឡើយ ខណៈដែលអ្នកនាំសារស្រែកហៅពួកអ្នកពីខាងក្រោយពួកអ្នក។ ពេលនោះ អល់ឡោះបានឲ្យពួកអ្នកទទួលរងនូវទុក្ខសោកផ្ទួនៗ ដើម្បីកុំឱ្យពួកអ្នកមានទុក្ខព្រួយទៅលើអ្វីដែលបានកន្លងផុតទៅពីពួកអ្នក ហើយនិងអ្វីដែលពួកអ្នកទទួលរងគ្រោះ។ ហើយអល់ឡោះមហាដឹងជ្រួតជ្រាបនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

154. ក្រោយពីពួកអ្នកទទួលរងនូវទុក្ខសោកហើយនោះ ទ្រង់បានបញ្ចុះភាពនឹងនរទៅលើពួកអ្នក ដោយធ្វើឱ្យមួយក្រុមក្នុងចំណោមពួកអ្នក(អ្នកដែលមានជំនឿពិត)ងងុយគេង។ ចំណែកឯមួយក្រុមផ្សេងទៀត(ពួកពុតត្បុត)គ្មានខ្វល់ខ្វាយអ្វីក្រៅពីខ្លួនឯងប៉ុណ្ណោះដោយពួកគេគិតមិនត្រឹមត្រូវទៅលើអល់ឡោះនូវការគិតស្មានរបស់ពួកល្ងង់ខ្លៅ។ ពួកគេនិយាយថា៖ តើពួកយើងមានសិទ្ធិជ្រើសរើសចំពោះបញ្ហានេះ(ការចេញធ្វើសង្គ្រាម)ឬទេ? ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ កិច្ចការទាំងអស់គឺស្ថិតនៅលើអល់ឡោះជាម្ចាស់(តែមួយគត់)។ ពួកពុតត្បុតទាំងនោះបានលាក់ទុកក្នុងខ្លួនពួកគេនូវអ្វីដែលពួកគេមិនបង្ហាញឱ្យអ្នកបានដឹង ខណៈដែលពួកគេបាននិយាយថា៖ ប្រសិនបើពួកយើងមានសិទ្ធិអ្វីបន្តិចនៅក្នុងរឿងនោះ ពួកយើងនឹងមិនត្រូវបានគេសម្លាប់នៅទីកន្លែងនេះឡើយ។ ចូរអ្នកឆ្លើយតបថា៖ ទោះបីជាពួកអ្នកស្ថិតនៅក្នុងផ្ទះរបស់ពួកអ្នកក៏ដោយ ក៏អ្នកដែលត្រូវបានគេកំណត់ឱ្យស្លាប់នោះនឹងចេញទៅរកកន្លែងដែលពួកគេត្រូវស្លាប់ជាមិនខាន។ (ការធ្វើដូច្នោះ)ដើម្បីអល់ឡោះសាកល្បងនូវអ្វីដែលមាននៅក្នុងទ្រូងរបស់ពួកអ្នក ហើយនិងដើម្បីវែកញែកនូវអ្វីដែលនៅក្នុងចិត្តរបស់ពួកអ្នក(នៃភាពមានជំនឿ និងភាពពុតត្បុត)។ ហើយអល់ឡោះដឹងបំផុតចំពោះអ្វីដែលមាននៅក្នុងដួងចិត្ត។

155. ពិតប្រាកដណាស់ អ្នកដែលបានរត់គេចក្នុងចំណោមពួកអ្នក(សហការីព្យាការីមូហាំម៉ាត់)នៅថ្ងៃជួបគ្នា(រវាងពួកមុស្លីគីននិងអ្នកអ៊ីស្លាមនៅក្នុងសមរភូមិអ៊ូហ៊ុទ)នោះ ការពិតគឺស្មែតនបានអូសទាញពួកគេឱ្យធ្វើខុសដោយសារតែទង្វើ(ល្មើស)មួយចំនួនដែលពួកគេបានប្រព្រឹត្ត។ ជាការពិតណាស់ អល់ឡោះបានអភ័យទោសឱ្យពួកគេហើយ។ ពិតប្រាកដណាស់ អល់ឡោះមហាអភ័យទោស មហាខន្តីបំផុត។

156. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំធ្វើដូចពួកដែលប្រឆាំងឱ្យសោះ ដោយពួកគេនិយាយទៅកាន់សាច់ញាតិរបស់ខ្លួននៅពេលណាដែលពួកគេធ្វើដំណើរ(ស្វែងរកលាភសក្ការៈ)នៅលើផែនដី ឬចេញធ្វើសង្គ្រាមថា៖ ប្រសិនបើពួកគេនៅជាមួយពួកយើង ពួកគេក៏មិនស្លាប់ ហើយក៏មិនត្រូវបានគេសម្លាប់នោះដែរ។ អល់ឡោះឲ្យពួកគេគិតបែបនេះ គឺដើម្បីឱ្យពួកគេកាន់តែមានវិប្បដិសារីក្នុងចិត្តរបស់ពួកគេថែមទៀត។ ហើយអល់ឡោះជាអ្នកផ្តល់ជីវិត និងជាអ្នកដកយកជីវិត។ ហើយអល់ឡោះមហាឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

157. ហើយប្រសិនបើពួកអ្នកត្រូវបានគេសម្លាប់ក្នុងមាគ៌ារបស់អល់ឡោះ ឬបានស្លាប់(ដោយមូលហេតុផ្សេងៗ)នោះ ពិតប្រាកដណាស់ ពួកអ្នកនឹងទទួលបានការអភ័យទោស និងការអាណិតស្រលាញ់ពីអល់ឡោះ ដែលវាល្អប្រសើរជាងអ្វី(លាភសក្ការៈ)ដែលពួកគេកំពុងតែប្រមូលទុកទៅទៀត។

158. ហើយបើទោះជាពួកអ្នកស្លាប់ ឬត្រូវបានគេសម្លាប់ក៏ដោយ ក៏ពួកអ្នកពិតជានឹងត្រូវគេប្រមូលផ្តុំទៅកាន់អល់ឡោះជាម្ចាស់ដែរ។

159. ពិតប្រាកដណាស់ ដោយក្តីមេត្តាករុណាពីអល់ឡោះ គឺរូបអ្នក(ឱព្យាការីមូហាំម៉ាត់)មានភាពទន់ភ្លន់ជាមួយពួកគេ(សហការីរបស់អ្នក)។ តែប្រសិនបើអ្នកមានអាកប្បកិរិយាកោងកាច និងមានចិត្តរឹងរូសវិញនោះ អ្នកដែលនៅជុំវិញអ្នក ពួកគេនឹងរត់ចេញពីអ្នកជាមិនខានឡើយ។ ដូចនេះ ចូរអ្នកអធ្យាស្រ័យឱ្យពួកគេ ហើយសុំការអភ័យទោស(ពីអល់ឡោះ)ដល់ពួកគេ និងពិភាក្សាកិច្ចការផ្សេងៗជាមួយពួកគេ។ ហើយនៅពេលដែលអ្នកបានសម្រេចចិត្តធ្វើអ្វីមួយហើយនោះ ចូរអ្នកប្រគល់ការទុកចិត្តលើអល់ឡោះ។ ពិតណាស់ អល់ឡោះស្រលាញ់បណ្តាអ្នកដែលប្រគល់ការទុកចិត្ត។

160. ប្រសិនបើអល់ឡោះជួយពួកអ្នក នោះគ្មាននរណាម្នាក់អាចយកឈ្នះពួកអ្នកបានឡើយ។ តែប្រសិនបើទ្រង់បោះបង់ពួកអ្នកវិញ តើមាននរណាដែលអាចជួយពួកអ្នកក្រោយពីទ្រង់(បោះបង់ពួកអ្នកហើយនោះ)? ដូច្នេះ ចូរឱ្យបណ្តាអ្នកដែលមានជំនឿប្រគល់ការទុកចិត្តលើអល់ឡោះ(តែមួយគត់)។

161. គ្មានព្យាការីណាម្នាក់ដែលក្បត់នោះទេ។ ជនណាហើយដែលបានក្បត់ នៅថ្ងៃបរលោក គេនឹងនាំមកនូវអ្វីដែលខ្លួនបានក្បត់នោះមកជាមួយ។ ក្រោយមក គេនឹងតបស្នងយ៉ាងពេញលេញដល់បុគ្គលគ្រប់រូបចំពោះអ្វីដែលរូបគេបានប្រព្រឹត្ត ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

162. តើអ្នកដែលប្រតិបត្តិតាមអ្វីដែលអល់ឡោះពេញចិត្ត ដូចនឹងអ្នកដែលប្រព្រឹត្តល្មើសដែលទទួលការក្រោធខឹងពីអល់ឡោះឬ? ហើយកន្លែងស្នាក់នៅរបស់គេ គឺនរកជើហាន់ណាំ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

163. ពួកគេមានឋានៈផ្សេងៗគ្នាចំពោះអល់ឡោះជាម្ចាស់។ ហើយអល់ឡោះមហាឃើញបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

164. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់បានប្រទាននូវឧបការគុណដល់បណ្តាអ្នកមានជំនឿ ខណៈដែលទ្រង់បានតែងតាំងពីក្នុងចំណោមពួកគេនូវអ្នកនាំសារម្នាក់អំពីជាតិសាសន៍របស់ពួកគេ ដោយគាត់សូត្រនូវបណ្តាវាក្យខណ្ឌរបស់ទ្រង់ឱ្យពួកគេស្តាប់ និងជម្រះសម្អាតពួកគេ ព្រមទាំងបង្រៀនដល់ពួកគេនូវគម្ពីរគួរអាន និងគតិបណ្ឌិត(ស៊ុណ្ណៈ)ខណៈដែលកាលពីមុនពួកគេស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

165. ហេតុអ្វីបានជានៅពេលដែលពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ទទួលរងគ្រោះថ្នាក់មួយ(ក្នុងសង្គ្រាមអ៊ូហ៊ុទ)ដែលពួកអ្នកធ្លាប់បានធ្វើឱ្យពួកគេទទួលគ្រោះថ្នាក់ដូចនោះទ្វេដងកាលពីមុន(ក្នុងសង្គ្រាមហ្គាទើរ) ពួកអ្នកបែរជានិយាយថា៖ តើរឿងនេះកើតឡើង(ចំពោះពួកយើង)បែបណា? ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលចុះថា៖ វាគឺកើតឡើងដោយសារតែខ្លួនពួកអ្នកផ្ទាល់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មានអានុភាពលើអ្វីៗទាំងអស់។

166. ហើយអ្វីដែលបានកើតឡើងចំពោះពួកអ្នកនៅថ្ងៃជួបគ្នា(ថ្ងៃសង្គ្រាមអ៊ូហ៊ុទ) គឺដោយការអនុញ្ញាតពីអល់ឡោះ និងដើម្បីទ្រង់ស្តែងឱ្យឃើញនូវបណ្តាអ្នកដែលមានជំនឿ(ពិតប្រាកដ)។

167. ហើយនិងដើម្បីស្តែងចេញឱ្យឃើញផងដែរនូវពួកពុតត្បុត។ ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ "ចូរពួកអ្នកមកចូលរួមធ្វើសង្គ្រាមក្នុងមាគ៌ារបស់អល់ឡោះ ឬចូរពួកអ្នកការពារ" ពួកគេឆ្លើយថា៖ ប្រសិនបើពួកយើងដឹងថានឹងមានសង្គ្រាមនោះ ពួកយើងប្រាកដជានឹងចូលរួមជាមួយពួកអ្នកមិនខាន។ ស្ថានភាពរបស់ពួកគេ(ពួកពុតត្បុត)នៅថ្ងៃនោះគឺកៀកនឹងភាពគ្មានជំនឿខ្លាំងជាងភាពមានជំនឿ។ ពួកគេនិយាយនឹងមាត់របស់ពួកគេនូវអ្វីដែលពុំមាននៅក្នុងចិត្តរបស់ពួកគេ។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលពួកគេកំពុងតែលាក់ទុក(ក្នុងចិត្ត)។

168. គឺជាពួកដែលនិយាយទៅកាន់សាច់ញាតិរបស់ខ្លួន(ដែលទទួលរងគ្រោះ) ទាំងដែលពួកគេមិនបានចូលរួមក្នុងសង្គ្រាមផងនោះថា៖ ប្រសិនបើពួកគេស្តាប់តាមពួកយើង ពួកគេក៏មិនត្រូវបានគេសម្លាប់នោះដែរ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ឆ្លើយតបថា៖ ចូរពួកអ្នកការពារខ្លួនពួកអ្នកពីសេចក្តីស្លាប់ទៅមើល៍ ប្រសិនបើពួកអ្នកពិតជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកបានអះអាង)មែននោះ។

169. ហើយចូរអ្នក(ព្យាការីមូហាំម៉ាត់)កុំគិតស្មានថា បណ្តាអ្នកដែលត្រូវបានគេសម្លាប់(ពលីជីវិត)ក្នុងមាគ៌ារបស់អល់ឡោះនោះជាមនុស្សស្លាប់ឱ្យសោះ។ ផ្ទុយទៅវិញ ពួកគេមានជីវិតរស់នៅឯព្រះជាម្ចាស់របស់ពួកគេដោយពួកគេត្រូវបានប្រទានឲ្យនូវលាភសក្ការៈ(ជាច្រើនប្រភេទ)។

170. ពួកគេសប្បាយរីករាយនឹងអ្វីដែលអល់ឡោះបានប្រទានឱ្យពួកគេនៃភាពសប្បុរសរបស់ទ្រង់ ហើយពួកគេផ្តល់ដំណឹងរីករាយដល់អ្នកដែលនៅរស់(ដែលមិនទាន់ពលីជីវិត)ថា៖ គ្មានការភ័យខ្លាចឡើយចំពោះពួកគេ ហើយក៏គ្មានទុក្ខព្រួយអ្វីចំពោះពួកគេនោះដែរ(នៅថ្ងៃបរលោក)។

171. ពួកគេសប្បាយរីករាយជាមួយនឹងឧបការគុណ និងក្តីសប្បុរសពីអល់ឡោះជាម្ចាស់។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់មិនធ្វើឱ្យផលបុណ្យរបស់បណ្តាអ្នកដែលមានជំនឿបាត់បង់បន្តិចណាឡើយ។

172. បណ្តាអ្នកដែលបានឆ្លើយតបទៅនឹងបទបញ្ជារបស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់(ដែលអំពាវនាវឱ្យចេញទៅធ្វើសង្គ្រាម ហាំរ៉ែកអាល់អាសាត់)ក្រោយពីពួកគេបានទទួលរងរបួស(នៅក្នុងសមរភូមិអ៊ូហ៊ុទ)នោះ សម្រាប់បណ្តាអ្នកដែលធ្វើអំពើល្អក្នុងចំណោមពួកគេ ហើយបានកោតខ្លាចអល់ឡោះ ពួកគេនឹងទទួលបានផលបុណ្យដ៏ធំធេង(ឋានសួគ៌)។

173. គឺបណ្តាអ្នកដែលមនុស្សលោក(ពួកមុស្លីគីន)បាននិយាយទៅកាន់ពួកគេថា៖ ពិតប្រាកដណាស់ ពួកគេ(សត្រូវ)បានប្រមូលគ្នាដើម្បីប្រយុទ្ធនឹងពួកអ្នក។ ហេតុនេះ ចូរពួកអ្នកខ្លាចពួកគេចុះ។ ក៏ប៉ុន្តែ ពួកគេកាន់តែមានជំនឿខ្លាំងឡើង ហើយពួកគេថែមទាំងនិយាយថា៖ អល់ឡោះជាម្ចាស់តែមួយគត់គឺគ្រប់គ្រាន់ហើយសម្រាប់ពួកយើង ហើយទ្រង់ជាអ្នកគាំពារដ៏ប្រសើរបំផុត។

174. ពេលនោះ ពួកគេក៏បានវិលត្រលប់មក(ពីសង្គ្រាម)វិញ ដោយឧបការគុណពីអល់ឡោះ និងការប្រោសប្រទានរបស់ទ្រង់ដោយពុំមានប្រការអាក្រក់អ្វីប៉ះពាល់ដល់ពួកគេឡើយ ហើយពួកគេប្រតិបត្តិតាមអ្វីដែលអល់ឡោះពេញចិត្ត។ ហើយអល់ឡោះជាអ្នកដែលមានការសន្តោសប្រណីដ៏ធំធេងបំផុត។

175. ការពិតរឿងនោះ គឺស៊ែតនបានបំភ័យកូនចៅរបស់វា(អ្នកដែលដើរតាមវា)។ ដូច្នេះ ចូរពួកអ្នកកុំខ្លាចពួកវា តែពួកអ្នកត្រូវខ្លាចយើងវិញ ប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿ។

176. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំឱ្យពួកដែលប្រញាប់ប្រញាល់ក្នុងការប្រឆាំងនោះធ្វើឱ្យអ្នកមានទុក្ខព្រួយឱ្យសោះ ពីព្រោះពួកគេមិនអាចបង្កគ្រោះថ្នាក់អ្វីមួយដល់អល់ឡោះឡើយ។ តាមពិត អល់ឡោះមានចេតនាមិនឱ្យពួកគេទទួលបានលាភសំណាងនៅថ្ងៃបរលោកប៉ុណ្ណោះ។ ហើយសម្រាប់ពួកគេនឹងត្រូវទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

177. ពិតប្រាកដណាស់ ពួកដែលយកសេចក្តីជំនឿប្តូរយកភាពគ្មានជំនឿ ពួកគេមិនអាចបង្កគ្រោះថ្នាក់អ្វីមួយដល់អល់ឡោះបានឡើយ ហើយពួកគេនឹងទទួលទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

178. ហើយចូរកុំឱ្យពួកដែលប្រឆាំងគិតស្មានថា ជាការពិតណាស់ ការដែលយើងពន្យារអាយុជីវិតដល់ពួកគេ (ឲ្យមានអាយុវែង) នោះ គឺជាការល្អប្រសើរសម្រាប់ខ្លួនពួកគេឱ្យសោះ។ តាមពិត យើងពន្យារអាយុជីវិតដល់ពួកគេ គឺដើម្បីបន្ថែមនូវបាបកម្មដល់ពួកគេប៉ុណ្ណោះ ហើយពួកគេនឹងទទួលទណ្ឌកម្មយ៉ាងអាម៉ាស់បំផុត។

179. អល់ឡោះមិនបណ្តោយឱ្យបណ្តាអ្នកដែលមានជំនឿស្ថិតនៅក្នុងស្ថានភាពដូចពួកអ្នកបច្ចុប្បន្ន (រស់នៅលាយឡំជាមួយនឹងពុតត្បុត) នោះឡើយ លុះត្រាតែទ្រង់វែកញែកវាងប្រការអាក្រក់ចេញពីប្រការល្អ (ញែកពួកពុតត្បុតចេញពីអ្នកមានជំនឿ)។ ហើយមិនមែនជាគតិបណ្ឌិតរបស់អល់ឡោះនោះឡើយដែលទ្រង់ឱ្យពួកអ្នកដឹងពីប្រការអាថ៌កំបាំងនោះ ក៏ប៉ុន្តែអល់ឡោះទ្រង់ជ្រើសរើសក្នុងចំណោមបណ្តាអ្នកនាំសាររបស់ទ្រង់ចំពោះជនណាដែលទ្រង់មានចេតនា។ ដូច្នេះ ចូរពួកអ្នកមានជំនឿចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។ ប្រសិនបើពួកអ្នកមានជំនឿ ហើយគោរពកោតខ្លាចអល់ឡោះនោះ សម្រាប់ពួកអ្នកនឹងទទួលបានផលបុណ្យយ៉ាងធំធេង។

180. ហើយចូរកុំឱ្យពួកដែលកំណាញ់នូវអ្វីដែលអល់ឡោះបានប្រទានឱ្យពួកគេនៃការប្រោសប្រទានរបស់ទ្រង់នោះគិតស្មានថា វាជាប្រការល្អសម្រាប់ពួកគេឱ្យសោះ។ ផ្ទុយទៅវិញ វាជាប្រការអាក្រក់សម្រាប់ពួកគេទៅវិញទេ។ គេនឹងយកអ្វីដែលពួកគេកំណាញ់ (មិនព្រមបរិច្ចាគ) នោះដាក់ព័ទ្ធទៅលើករបស់ពួកគេនៅថ្ងៃបរលោក។ ហើយមរតកទាំងអស់ដែលនៅលើមេឃជាច្រើនជាន់និងនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ (តែមួយគត់)។ ហើយអល់ឡោះដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

181. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានឮហើយនូវពាក្យសម្តីរបស់ពួក (យូដា) ដែលនិយាយថា៖ "ពិតប្រាកដណាស់ អល់ឡោះជាអ្នកក្រីក្រ។ រីឯពួកយើងគឺជាអ្នកមាន"។ យើង (អល់ឡោះ) នឹងកត់ត្រាទុកនូវអ្វីដែលពួកគេបាននិយាយ និងការដែលពួកគេសម្លាប់ព្យាការីជាច្រើនដោយអយុត្តិធម៌ ហើយយើងនឹងមានបន្ទូល (ទៅកាន់ពួកគេ) ថា៖ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មដែលឆាបឆេះ (នៅក្នុងឋាននរក)។

182. (ទណ្ឌកម្ម) នោះគឺដោយសារតែអ្វីដែលពួកអ្នកបានសាងដោយដៃទាំងពីររបស់ពួកអ្នកផ្ទាល់ ហើយពិតណាស់ អល់ឡោះជាម្ចាស់មិនបំពានទៅលើខ្ញុំបម្រើរបស់ទ្រង់ណាម្នាក់ឡើយ។

183. គឺពួកដែលនិយាយថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់បានផ្តែផ្តាំចំពោះពួកយើង (នៅក្នុងគម្ពីររបស់ទ្រង់) ថា មិនឱ្យពួកយើងមានជំនឿលើអ្នកនាំសារណាម្នាក់ឡើយ លុះត្រាតែអ្នកនាំសារនោះបាននាំមកឱ្យពួកយើងនូវគួរហ្ពាន (តង្វាយ) ដែលមានភ្លើង (ពីលើមេឃ) ឆាបឆេះគួរហ្ពាននោះ។ ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ ពិតប្រាកដណាស់ បណ្តាអ្នកនាំសារជាច្រើនមុនខ្ញុំបាននាំមកកាន់ពួកអ្នកនូវកេស្តុតាងជាច្រើនដ៏ច្បាស់លាស់ ហើយពួកគេក៏បាននាំមក (នូវកេស្តុតាង) ដូចដែលពួកអ្នកបានរៀបរាប់នេះដែរ ក៏ប៉ុន្តែហេតុអ្វីបានជាពួកអ្នកសម្លាប់ពួកគេទៅវិញ ប្រសិនបើពួកអ្នកជាអ្នកដែលនិយាយពិត (ចំពោះអ្វីដែលពួកអ្នកអះអាង) មែននោះ?

184. តែប្រសិនបើពួកគេបដិសេធនឹងអ្នកនោះ ពិតប្រាកដណាស់ បណ្តាអ្នកនាំសារជាច្រើនមុនអ្នកក៏ត្រូវបានគេបដិសេធ (មិនជឿ) ដែរ។ ពួកគេបាននាំមកនូវកេស្តុតាងជាច្រើនដ៏ច្បាស់លាស់ និងបណ្តាគម្ពីរ (ដែលមានការទូន្មាន) ហើយនិងគម្ពីរដែលមានការចង្អុលបង្ហាញ។

185. រាល់ជីវិតទាំងអស់ គឺត្រូវក្លក់រសជាតិនៃសេចក្តីស្លាប់។ ហើយនៅថ្ងៃបរលោក ពួកអ្នកនឹងត្រូវគេតបស្នងយ៉ាងពេញលេញចំពោះផលបុណ្យរបស់ពួកអ្នក។ ដូចនេះ ជនណាហើយដែលត្រូវបានគេ(អល់ឡោះ)បញ្ចៀសពីភ្លើងនរក ហើយបញ្ចូលទៅក្នុងឋានសួគ៌នោះ គឺគេពិតជាទទួលបានជោគជ័យ។ ហើយជីវិតលោកិយ គ្មានអ្វីក្រៅពីការត្រេកត្រអាល និងបោកបញ្ឆោតប៉ុណ្ណោះ។

186. ពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ប្រាកដជានឹងត្រូវបានគេសាកល្បងចំពោះទ្រព្យសម្បត្តិ និងខ្លួនប្រាណរបស់ពួកអ្នក ហើយពួកអ្នកពិតជានឹងបានឮនូវពាក្យដែលបង្កការឈឺចាប់ជាច្រើនពីសំណាក់ពួកដែលត្រូវបានប្រទានគម្ពីរឲ្យ(ពួកយូដា និងពួកគ្រឹះស្ថាន)មុនពួកអ្នក និងពីសំណាក់ពួកមុស្រីគីន។ តែប្រសិនបើពួកអ្នកអត់ធ្មត់ និងកោតខ្លាចអល់ឡោះ ពិតប្រាកដណាស់ ទាំងនោះគឺជាកិច្ចការដែលតម្រូវឱ្យមានការតាំងចិត្តខ្ពស់បំផុត។

187. ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)នឹកឃើញ នៅពេលដែលអល់ឡោះទ្រង់បានដាក់កិច្ចសន្យាដ៏មុឺងម៉ាត់ទៅលើពួកដែលគេផ្តល់គម្ពីរឲ្យថា ពួកអ្នកត្រូវតែបកស្រាយបំភ្លឺវា(គម្ពីររបស់អល់ឡោះ)ដល់មនុស្សលោក ហើយពួកអ្នកមិនត្រូវលាក់បាំងវានោះឡើយ។ ក៏ប៉ុន្តែពួកគេបែរជាបោះបង់កិច្ចសន្យានោះដាក់ពីក្រោយខ្នងពួកគេ ហើយបានប្តូរវាជាមួយនឹងកម្រៃបន្តិចបន្តួចទៅវិញ។ ពិតជាអាក្រក់បំផុត កម្រៃដែលពួកគេប្តូរយកនោះ។

188. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)កុំគិតស្មានថា ពួកដែលសប្បាយរីករាយជាមួយនឹងអ្វីដែលពួកគេបានប្រព្រឹត្ត ហើយពួកគេចូលចិត្តឱ្យអ្នកដទៃកោតសរសើរចំពោះអ្វីដែលពួកគេមិនបានធ្វើសោះនោះ ចូរអ្នកកុំគិតស្មានឲ្យសោះថា ពួកគេនឹងអាចរួចផុតពីទណ្ឌកម្មនោះ។ ផ្ទុយទៅវិញ ពួកគេនឹងទទួលទណ្ឌកម្មដ៏ឈឺចាប់បំផុត។

189. ហើយអំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយអល់ឡោះជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។

190. ពិតប្រាកដណាស់ នៅក្នុងការបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយនិងការផ្លាស់ប្តូរគ្នារវាងពេលយប់និងពេលថ្ងៃ គឺជាភស្តុតាងដ៏ច្បាស់លាស់សម្រាប់បញ្ញាជនទាំងឡាយ។

191. គឺបណ្តាអ្នកដែលរឭកទៅចំពោះអល់ឡោះជាម្ចាស់ទាំងក្នុងពេលឈរ ពេលអង្គុយ និងពេលដែលពួកគេទម្រេតខ្លួន ហើយពួកគេសញ្ជឹងគិតពិចារណាពីការបង្កើតមេឃជាច្រើនជាន់និងផែនដី(ដោយពួកគេពោលថា៖)បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ព្រះអង្គមិនបានបង្កើតអ្វីទាំងអស់នេះជាការលេងសើចនោះទេ។ ព្រះអង្គដ៏វិសុទ្ធ! ដូចនេះ សូមទ្រង់មេត្តាបញ្ចៀសយើងខ្ញុំពីទណ្ឌកម្មភ្លើងនរកផងចុះ។

192. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ ជនណាហើយដែលទ្រង់បានបញ្ចូលរូបគេទៅក្នុងឋាននរកនោះ គឺទ្រង់ពិតជាបានធ្វើឱ្យគេទទួលការអាម៉ាស់។ ហើយសម្រាប់ពួកបំពាន គឺគ្មានអ្នកជួយឡើយ។

193. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ យើងខ្ញុំបានឮហើយអ្នកដែលអំពាវនាវទៅកាន់ការមានជំនឿ(នោះគឺព្យាការីមូហាំម៉ាត់ដែលគាត់បានអំពាវនាវថា៖) ចូរពួកអ្នកមានជំនឿចំពោះព្រះជាម្ចាស់របស់ពួកអ្នក។ ពេលនោះ យើងខ្ញុំក៏មានជំនឿ(តាមការអំពាវនាវនោះ)។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាអភ័យទោសដល់យើងខ្ញុំចំពោះបាបកម្មទាំងឡាយនៃយើងខ្ញុំ ហើយសូមទ្រង់មេត្តាលុបលាងនូវទង្វើអាក្រក់ទាំងឡាយនៃយើងខ្ញុំ ព្រមទាំងសូមទ្រង់មេត្តាឱ្យយើងខ្ញុំបានស្លាប់ជាមួយបណ្តាអ្នកដែលសាងអំពើល្អផងចុះ។

194. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាប្រទានឱ្យយើងខ្ញុំនូវអ្វីដែលទ្រង់បានសន្យាដល់យើងខ្ញុំតាមរយៈ(សម្តីនៃ)បណ្តាអ្នកនាំសាររបស់ទ្រង់ ហើយសូមទ្រង់កុំធ្វើឲ្យយើងខ្ញុំទទួលនូវភាពអាម៉ាស់នៅថ្ងៃបរលោកអ្វី។ ពិតប្រាកដណាស់ ទ្រង់មិនធ្វើខុសនឹងការសន្យាឡើយ។

195. ដូច្នេះ ព្រះជាម្ចាស់របស់ពួកគេក៏បានឆ្លើយតបចំពោះពួកគេថា៖ ពិតប្រាកដណាស់ យើងមិនបំបាត់ផលបុណ្យនៃទង្វើកុសលរបស់នរណាម្នាក់ក្នុងចំណោមពួកអ្នកឡើយ មិនថាប្រុស មិនថាស្រី។ ការវិនិច្ឆ័យរវាងពួកអ្នកនៅក្នុងសាសនា(អ៊ីស្លាម)នោះគឺដូចគ្នា។ ដូចនេះ បណ្តាអ្នកដែលភៀសខ្លួន និងត្រូវបានគេបណ្តេញចេញអំពីស្រុកភូមិរបស់ពួកគេ ហើយទទួលរងនូវការធ្វើទុក្ខបុកម្នេញនៅក្នុងមាគ៌ារបស់យើង ព្រមទាំងបានប្រយុទ្ធ និងត្រូវបានគេសម្លាប់(ពលីជីវិត)នោះ យើងពិតជានឹងលុបលាងដល់ពួកគេនូវរាល់អំពើអាក្រក់ទាំងឡាយរបស់ពួកគេ ហើយយើងពិតជានឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរពីក្រោមវា ជាផលបុណ្យ(ការតបស្នង)អំពីអល់ឡោះ(ចំពោះពួកគេ)។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានផលបុណ្យ(ការតបស្នង)ដ៏ល្អប្រពៃបំផុត។

196. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)កុំឱ្យការផ្លាស់ប្តូរទីកន្លែងរបស់ពួកដែលប្រឆាំងនៅក្នុងស្រុកទេសនោះបោកប្រាស់អ្នកឱ្យសោះ។

197. វាគ្រាន់តែជាការសប្បាយរីករាយមួយរយៈពេលខ្លីប៉ុណ្ណោះ។ ក្រោយមក ទីកន្លែងរិលត្រឡប់របស់ពួកគេ គឺនរកជើងហាន់ណាំ ហើយវាជាកន្លែងរស់នៅដ៏អាក្រក់បំផុត។

198. ក៏ប៉ុន្តែ បណ្តាអ្នកដែលកោតខ្លាចព្រះជាម្ចាស់របស់ពួកគេ សម្រាប់ពួកគេនឹងទទួលបានឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពួកគេនឹងស្ថិតនៅក្នុងនោះជាអមតៈ ជាកន្លែងស្នាក់នៅមកពីអល់ឡោះ(សម្រាប់ពួកគេ)។ ហើយអ្វីដែលមាននៅឯអល់ឡោះ គឺល្អប្រសើរសម្រាប់បណ្តាអ្នកដែលសាងទង្វើកុសល។

199. ហើយពិតប្រាកដណាស់ ក្នុងចំណោមពួកអះលីគីតាប គឺមានអ្នកដែលមានជំនឿលើអល់ឡោះ និងអ្វីដែលគេបានបញ្ចុះមកឱ្យពួកអ្នក ហើយនិងអ្វីដែលគេបានបញ្ចុះទៅឱ្យពួកគេ។ ពួកគេឱនលំទោនចំពោះអល់ឡោះ ហើយពួកគេមិនយកវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះទៅប្តូរដោយនឹងកម្រៃបន្តិចបន្តួចនោះឡើយ។ អ្នកទាំងនោះ សម្រាប់ពួកគេ គឺផលបុណ្យរបស់ពួកគេដែលនៅឯព្រះជាម្ចាស់របស់ពួកគេ។ ជាការពិតណាស់ អល់ឡោះជាអ្នកជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

200. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកអត់ធ្មត់ ហើយចូរអត់ធ្មត់ឱ្យបានខ្លាំង(ជាងពួកគ្មានជំនឿ)។ ហើយចូរពួកអ្នកប្រកាន់គោលជំហរតស៊ូប្រយុទ្ធ និងកោតខ្លាចអល់ឡោះ សង្ឃឹមថា ពួកអ្នកនឹងទទួលបានជោគជ័យ។

ជំពូក អាន់នីសាក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកកោតខ្លាចព្រះជាម្ចាស់របស់ពួកអ្នកដែលបានបង្កើតពួកអ្នកចេញអំពីខ្លួនមនុស្សតែម្នាក់(ព្យាការីអាដាំ) ហើយទ្រង់បានបង្កើតចេញអំពីគាត់នូវភរិយារបស់គាត់(ហាវ៉ា) ហើយទ្រង់បានបង្កើតចេញអំពីពួកគាត់ទាំងពីរនោះនូវមនុស្សប្រុស និងមនុស្សស្រីជាច្រើន។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះដែលក្នុងនាមរបស់ទ្រង់ពួកអ្នកទាមទារសិទ្ធិពីគ្នាទៅវិញទៅមក ហើយត្រូវប្រុងប្រយ័ត្នចំពោះការកាត់ផ្តាច់ចំណងសាច់សាលោហិត។ ពិតប្រាកដណាស់ អល់ឡោះគឺជាអ្នកឃ្លាំមើលពួកអ្នក។

2. ហើយចូរពួកអ្នក(ឱបណ្តាអ្នកដែលទទួលពាក្យបណ្តាំ)ផ្តល់ឲ្យក្មេងកំព្រានូវទ្រព្យសម្បត្តិរបស់ពួកគេ(ឱ្យបានគ្រប់ចំនួនកាលណាពួកគេពេញវ័យ) ហើយចូរពួកអ្នកកុំប្តូរយកទ្រព្យសម្បត្តិល្អៗ(របស់ក្មេងកំព្រា)ជាមួយនឹងទ្រព្យសម្បត្តិដែលមិនល្អ(របស់ពួកអ្នក)ឱ្យសោះ។ ហើយពួកអ្នកមិនត្រូវស៊ីទ្រព្យសម្បត្តិក្មេងកំព្រាដោយយកវាមកលាយឡំ(ជាក់បញ្ចូលគ្នា)ជាមួយនឹងទ្រព្យសម្បត្តិរបស់ពួកអ្នកឡើយ។ ជាការពិតណាស់ វាគឺជាបាបកម្មដ៏ធំធេងបំផុត។

3. ហើយប្រសិនបើពួកអ្នកបារម្ភខ្លាចមិនអាចផ្តល់ភាពយុត្តិធម៌ដល់ក្មេងកំព្រាបាន(ប្រសិនបើពួកអ្នករៀបការជាមួយពួកនាង)ចូរពួកអ្នករៀបការជាមួយនឹងស្ត្រីណាដែលជាទីពេញចិត្តសម្រាប់ពួកអ្នក ចំនួនពីរនាក់ ឬបីនាក់ ឬបួននាក់។ តែប្រសិនបើពួកអ្នកបារម្ភខ្លាចមិនអាចផ្តល់ភាពយុត្តិធម៌ដល់ពួកនាង(ភរិយាទាំងឡាយ)បានទេនោះ ចូររៀបការជាមួយស្ត្រីតែម្នាក់បានហើយ ឬក៏ជាមួយស្ត្រីបម្រើដាច់ដៃដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកអ្នក។ នោះជាការប្រសើរបំផុតដើម្បីការពារកុំឱ្យពួកអ្នកមានភាពលម្អៀង។

4. ហើយចូរពួកអ្នកផ្តល់ឱ្យស្ត្រីទាំងឡាយនូវខាន់ស្លារបស់ពួកនាង។ តែប្រសិនបើពួកនាងស្ម័គ្រចិត្តប្រគល់ជូននូវចំណែកណាមួយនៃខាន់ស្លានោះទៅឱ្យពួកអ្នក ចូរពួកអ្នកទទួលយកវាដោយរីករាយចុះ។

5. ហើយចូរពួកអ្នក(ឱអាណាព្យាបាលទាំងឡាយ)កុំផ្តល់នូវទ្រព្យសម្បត្តិដែលអល់ឡោះបានឱ្យពួកអ្នកគ្រប់គ្រងវាឱ្យទៅអ្នកដែលមានបញ្ញាខ្សោយ(មិនទាន់ចេះចាត់ចែងទ្រព្យសម្បត្តិ)ឱ្យសោះ។ ហើយចូរពួកអ្នកផ្តល់ការហូបចុក និងការស្លៀកពាក់ដល់ពួកគេអំពីទ្រព្យសម្បត្តិទាំងនោះចុះ ហើយចូរនិយាយទៅកាន់ពួកគេនូវពាក្យសម្តីដែលល្អប្រពៃ។

6. ហើយចូរពួកអ្នក(ឱអាណាព្យាបាលទាំងឡាយ)ធ្វើការសាកល្បងក្មេងកំព្រាទាំងនោះនៅពេលណាដែលពួកគេគ្រប់អាយុរៀបការ(ពេញវ័យ)។ ប្រសិនបើពួកអ្នកឃើញថាពួកគេចេះចាត់ចែងទ្រព្យសម្បត្តិហើយនោះ ចូរពួកអ្នកប្រគល់នូវទ្រព្យសម្បត្តិរបស់ពួកគេឱ្យទៅពួកគេវិញចុះ។ ហើយពួកអ្នកមិនត្រូវយកទ្រព្យសម្បត្តិរបស់ពួកគេចំណាយបំពានហួសពីព្រំដែន(ដែលគេបានអនុញ្ញាត)និងឆ្លៀតឱកាស(យកទ្រព្យសម្បត្តិពួកគេ)មុនពេលពួកគេធំដឹងក្តីឡើយ។ ហើយប្រសិនបើគេ(អាណាព្យាបាលរបស់ក្មេងកំព្រា)ជាអ្នកមាន ចូរឱ្យគេឈប់យកទ្រព្យសម្បត្តិនោះ។ តែប្រសិនបើគេជាអ្នកក្រ ចូរឱ្យគេយកទ្រព្យសម្បត្តិនោះក្នុងចំនួនដែលសមរម្យ។ ហើយនៅពេលដែលពួកអ្នកប្រគល់ទ្រព្យសម្បត្តិរបស់ពួកគេ(ក្មេងកំព្រា)ឱ្យពួកគេវិញនោះ ចូរពួកអ្នករកអ្នកធ្វើសាក្សីលើការប្រគល់ទ្រព្យសម្បត្តិនោះផង។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកជំនុំជម្រះ។

7. សម្រាប់បុរស គឺទទួលបានចំណែកអំពីកេរមរតកដែលឪពុកម្តាយ និងសាច់ញាតិបានបន្សល់ទុក(ក្រោយពេលស្លាប់)។ ហើយសម្រាប់ស្ត្រី ក៏ទទួលបានចំណែកអំពីកេរមរតកដែលឪពុកម្តាយ និងសាច់ញាតិបានបន្សល់ទុកដូចគ្នាដែរ ទោះតិច ឬច្រើន។ វាជាចំណែកដែលត្រូវបានកំណត់(យ៉ាងច្បាស់លាស់)។

8. បើកាលណាសាច់ញាតិ ក្មេងកំព្រា និងជនក្រីក្រ(ដែលគ្មានសិទ្ធិទទួលកេរមរតក)បានមកចូលរួមក្នុងពេលបែងចែកកេរមរតកនោះ ចូរពួកអ្នកផ្តល់ឱ្យពួកគេ(ជាប្រការគួរគប្បី)មួយចំណែកនៃទ្រព្យសម្បត្តិនោះ(មុនពេលបែងចែកកេរមរតក)។ ហើយចូរពួកអ្នកនិយាយទៅកាន់ពួកគេនូវពាក្យសម្តីដែលល្អប្រពៃ។

9. ហើយចូរឲ្យអ្នកដែលមានក្តីបារម្ភពីកូនចៅរបស់ខ្លួនដែលទន់ខ្សោយដែលពួកគេបានបន្សល់ទុកក្រោយពេលស្លាប់នោះ(បារម្ភខ្លាចពួកគេកំព្រីកំព្រាគ្មានទីពឹង)។ ដូចនេះ ចូរឱ្យពួកគេកោតខ្លាចអល់ឡោះ(ដោយត្រូវធ្វើល្អចំពោះក្មេងកំព្រាដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន) ហើយចូរឱ្យពួកគេនិយាយនូវពាក្យសម្តីដែលល្អត្រឹមត្រូវ។

10. ពិតប្រាកដណាស់ ពួកដែលស៊ីទ្រព្យសម្បត្តិក្មេងកំព្រាដោយបំពាននោះ តាមពិត ពួកគេកំពុងតែស៊ីភ្លើងចូលទៅក្នុងពោះខ្លួនឯងប៉ុណ្ណោះ។ ហើយភ្លើងនរកនឹងឆាបឆេះពួកគេ(នៅថ្ងៃបរលោក)។

11. អល់ឡោះបានដាក់បង្គាប់លើពួកអ្នកឱ្យធ្វើការបែងចែកកេរមរតកដល់កូនៗរបស់ពួកអ្នក។ សម្រាប់កូនប្រុសម្នាក់ត្រូវទទួលបានចំណែកស្មើនឹងចំណែកកូនស្រីពីរនាក់។ ដូច្នេះ ប្រសិនបើសពមានតែកូនស្រី ហើយមានលើសពីពីរនាក់ គឺពួកនាងត្រូវទទួលបានចំណែកពីរភាគបីនៃចំណែកមរតក(ដែលបានបន្សល់ទុក)នោះ។ តែប្រសិនបើសពមានកូនស្រីតែម្នាក់ សម្រាប់នាងគឺទទួលបានចំណែកពាក់កណ្តាល(នៃមរតក)។ ហើយសម្រាប់ឪពុកម្តាយនៃសព គឺម្នាក់ៗនៃពួកគាត់ទាំងពីរត្រូវទទួលបានចំណែកមួយភាគប្រាំមួយនៃចំណែកមរតកនោះ ប្រសិនបើសពនោះមានកូន។ តែប្រសិនបើសពគ្មានកូន ហើយក៏គ្មានអ្នកទទួលមរតកផ្សេងទៀត ក្រៅពីឪពុកម្តាយទាំងពីររបស់គេទេនោះ គឺសម្រាប់ម្តាយត្រូវទទួលបានចំណែកមរតកមួយភាគបី។ ហើយប្រសិនបើសពនោះមានបងប្អូនច្រើន(ចាប់ពីពីរនាក់ឡើងទៅ មិនថាប្រុសឬស្រី) សម្រាប់ម្តាយ គឺទទួលបាន(ចំណែកមរតក)មួយភាគប្រាំមួយ។ (ការបែងចែកកេរមរតកបែបនេះ) គឺក្រោយពីបានបំពេញនូវបណ្តាំ(របស់សព) និងសងបំណុល(ដែលសពបានជំពាក់គេ)រួចរាល់។ ពួកអ្នកមិនដឹងទេថា ក្នុងចំណោមឪពុកម្តាយរបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នក តើអ្នកណាដែលអាចផ្តល់ផលប្រយោជន៍ដល់ពួកអ្នកជាងគេនោះ។ (ហើយការបែងចែកកេរមរតកបែបនេះ) វាជាកាតព្វកិច្ចមកពីអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះមហាដឹងបំផុត មហាគតិបណ្ឌិតបំផុត។

12. ហើយសម្រាប់ពួកអ្នក(ឱស្វាមីទាំងឡាយ) គឺទទួលបានចំណែកពាក់កណ្តាលនៃកេរមរតកដែលភរិយារបស់ពួកអ្នកបានបន្សល់ទុក ប្រសិនបើពួកនាងគ្មានកូន(មិនថាកូនប្រុសឬកូនស្រី)។ តែប្រសិនបើពួកនាងមានកូន គឺពួកអ្នកត្រូវទទួលបានចំណែកមួយភាគបួននៃកេរមរតកដែលពួកនាងបានបន្សល់ទុកក្រោយពីបានបំពេញនូវពាក្យបណ្តាំ(របស់ពួកនាង) និងសងបំណុល(ដែលនាងជំពាក់គេ)រួចអស់។ ហើយសម្រាប់ពួកនាង(ភរិយាទាំងឡាយ) គឺទទួលបានចំណែកមួយភាគបួននៃកេរមរតកដែលពួកអ្នក(ឱស្វាមីទាំងឡាយ)បានបន្សល់ទុក ប្រសិនបើពួកអ្នកគ្មានកូន(មិនថាកូនប្រុសឬកូនស្រី)។ តែប្រសិនបើពួកអ្នកមានកូន គឺសម្រាប់ពួកនាងត្រូវទទួលបានចំណែកមួយភាគប្រាំបីនៃកេរមរតកដែលពួកអ្នកបានបន្សល់ទុកក្រោយពីបានបំពេញនូវពាក្យបណ្តាំ(របស់ពួកអ្នក) និងសងបំណុល(ដែលពួកអ្នកជំពាក់គេ)រួចរាល់។ ហើយប្រសិនបើបុរសម្នាក់ ឬស្ត្រីបានស្លាប់ ហើយគេគ្មានឪពុក ហើយក៏គ្មានកូនទេ តែពួកគេទាំងពីរ(មិនថាប្រុស ឬស្រី) មានបងប្អូនប្រុស(ខាងម្តាយ)ម្នាក់ ឬបងប្អូនស្រី(ខាងម្តាយ)ម្នាក់ ដូចនេះ សម្រាប់ពួកគេម្នាក់ៗ គឺទទួលបានចំណែកមួយភាគប្រាំមួយ(នៃមរតកនោះ)។ ហើយប្រសិនបើពួកគេ(បងប្អូនប្រុសខាងម្តាយ ឬបងប្អូនស្រីខាងម្តាយ)មានគ្នាច្រើនលើសពីមួយនាក់ សម្រាប់ពួកគេទាំងអស់គ្នា គឺទទួលចំណែកមរតកមួយភាគបីរួមគ្នាក្រោយពីបានបំពេញនូវពាក្យបណ្តាំ(របស់សព) និងបានសងបំណុល(ដែលសពជំពាក់គេ)រួចរាល់ដោយមិនត្រូវបង្កផលប៉ះពាល់(ដល់អ្នកដែលទទួលកេរមរតកឡើយ)។ វាជាកាតព្វកិច្ចមកពីអល់ឡោះ។ ហើយអល់ឡោះមហាដឹង មហាខន្តីបំផុត។

13. ទាំងនោះ គឺជាក្បួនច្បាប់របស់អល់ឡោះ។ ហើយជនណាដែលគោរពប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ គេ(អល់ឡោះ)នឹងបញ្ចូលជននោះទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ នោះហើយគឺជាជោគជ័យដ៏ធំធេងបំផុត។

14. តែជនណាដែលបានប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ព្រមទាំងបានបំពានព្រំដែន(ក្បួនច្បាប់)របស់ទ្រង់នោះ គេ(អល់ឡោះ)នឹងបញ្ចូលរូបគេទៅក្នុងឋាននរកដោយរូបគេស្ថិតនៅក្នុងនោះជាអមតៈ ហើយរូបគេនឹងទទួលទណ្ឌកម្មដ៏អាម៉ាស់បំផុត។

15. ហើយចំពោះស្ត្រីដែលប្រព្រឹត្តអំពើអសីលធម៌ហ្សីណា(រួមមេត្រីរវាងបុរសនិងស្ត្រីដោយមិនបានរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់អ៊ីស្លាម)ក្នុងចំណោមបណ្តាស្ត្រីរបស់ពួកអ្នក ចូរពួកអ្នករកមនុស្សប្រុសបួននាក់ក្នុងចំណោមពួកអ្នកធ្វើជាសាក្សីលើពួកនាង។ ប្រសិនបើពួកគេបានធ្វើសាក្សី(បញ្ជាក់ដូច្នោះ)ហើយនោះ ចូរពួកអ្នកឃុំខ្លួនពួកនាងនៅក្នុងផ្ទះរហូតដល់ពួកនាងបាត់បង់ជីវិត ឬរហូតដល់អល់ឡោះជាម្ចាស់បានផ្តល់ដំណោះស្រាយផ្សេងដល់ពួកនាង(ក្រៅពីការឃុំខ្លួន)។

16. ហើយបុរសនិងស្ត្រីដែលប្រព្រឹត្តអំពើអសីលធម៌ហ្សីណាក្នុងចំណោមពួកអ្នក ចូរពួកអ្នកដាក់ទោសពួកគេទាំងពីរដោយការបញ្ឈឺ។ តែប្រសិនបើពួកគេទាំងពីរបានសារភាពកំហុស និងបានកែខ្លួនវិញនោះ ចូរពួកអ្នកបញ្ឈប់ការបញ្ឈឺពួកគេចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ជាអ្នកទទួលការសារភាពកំហុស ជាអ្នកដែលមហាអាណិតស្រលាញ់បំផុត។

17. តាមពិត អល់ឡោះជាម្ចាស់ទ្រង់ទទួលយកការសារភាពកំហុសតែចំពោះបុគ្គលណាដែលបានប្រព្រឹត្តអំពើអាក្រក់ដោយភាពល្ងង់ខ្លៅ ក្រោយមក ពួកគេបានសារភាពកំហុសភ្លាម(មុនពេលសេចក្តីស្លាប់មកដល់)។ ពិតណាស់ អ្នកទាំងនោះហើយដែលអល់ឡោះទទួលយកការសារភាពកំហុសរបស់ពួកគេ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

18. ហើយទ្រង់នឹងមិនទទួលយកការសារភាពកំហុសនោះឡើយ ចំពោះជនណាដែលប្រព្រឹត្តអំពើអាក្រក់រហូតដល់សេចក្តីស្លាប់មកដល់ម្នាក់ៗនៃពួកគេទើបគេនិយាយថាៈ "ពិតណាស់ ពេលនេះ ខ្ញុំសូមសារភាពកំហុសហើយ" ហើយ(ក៏ដូចគ្នាដែរ)ពួកដែលស្លាប់ក្នុងខណៈពេលដែលពួកគេស្ថិតក្នុងភាពគ្មានជំនឿនោះ។ ពួកទាំងនោះហើយដែលយើងបានរៀបចំសម្រាប់ពួកគេនូវទណ្ឌកម្មដ៏សែនខ្លោចផ្សាបំផុត។

19. ឱបណ្តាអ្នកដែលមានជំនឿ! គេមិនអនុញ្ញាតឱ្យពួកអ្នកយកប្រពន្ធឪពុករបស់ពួកអ្នកធ្វើជាកេរមរតកទាំងបង្ខំឡើយ។ ហើយពួកអ្នកមិនត្រូវរក្សាទុក(មិនព្រមលែងលះ)ភរិយារបស់ពួកអ្នកក្នុងគោលបំណងឱ្យពួកនាងលះបង់ឱ្យពួកអ្នកនូវខាន់ស្លាមួយចំនួនដែលពួកអ្នកបានផ្តល់ឱ្យពួកនាងនោះឡើយ លើកលែងតែពួកនាងប្រព្រឹត្តអំពើអសីលធម៌(ហ្សីណា)ជាក់ស្តែង។ ហើយចូរពួកអ្នករួមរស់ជាមួយនឹងពួកនាងប្រកបដោយគុណធម៌។ ហើយប្រសិនបើពួកអ្នកមិនពេញចិត្តពួកនាងដោយប្រការណាមួយ(ចូរអត់ធ្មត់) ជួនកាល អ្វីដែលពួកអ្នកមិនពេញចិត្តនោះ អល់ឡោះនឹងធ្វើឱ្យវាល្អប្រសើរលើសលប់វិញ(ក៏អាចថាបាន)។

20. ប្រសិនបើពួកអ្នកមានបំណងលែងលះភរិយា(របស់ពួកអ្នក)ដោយយកភរិយាផ្សេងទៀត ហើយពួកអ្នកបានផ្តល់ទ្រព្យសម្បត្តិជាច្រើន(ជាខាន់ស្លា)ដល់ពួកនាងហើយនោះ គឺពួកអ្នកមិនត្រូវយកអ្វីមួយអំពីវាមកវិញឡើយ។ តើពួកអ្នកយកវា(ប្រាក់ខាន់ស្លា)វិញទាំងបំពាន និងជាអំពើបាបយ៉ាងច្បាស់លាស់បែបនេះឬ?

21. តើពួកអ្នកយកវាមកវិញយ៉ាងដូចម្តេច ខណៈដែលពួកអ្នកធ្លាប់រួមរស់ជាមួយគ្នា ហើយពួកនាងក៏បានទទួលយកនូវកិច្ចសន្យាដ៏ម៉ឺងម៉ាត់អំពីពួកអ្នកហើយនោះ?

22. ហើយចូរពួកអ្នកកុំរៀបការជាមួយនឹងស្ត្រីដែលឪពុករបស់ពួកអ្នកបានរៀបការជាមួយនាងរួចហើយនោះ៖ ឱ្យសោះ លើកលែងតែអ្វីដែលបានកន្លងផុតទៅ(មុនអ៊ីស្លាមបានមកដល់)។ ពិតណាស់ការធ្វើដូចនេះ៖ វាគឺជារឿងស្មោកគ្រោក ជាមូលហេតុដែលធ្វើឱ្យអល់ឡោះខឹងសម្បា និងជាមាគ៌ាដ៏អាក្រក់បំផុត។

23. គេ(អល់ឡោះ)បានហាមឃាត់ពួកអ្នកមិនឱ្យរៀបការជាមួយម្តាយរបស់ពួកអ្នក កូនស្រីរបស់ពួកអ្នក បងប្អូនស្រីបង្កើតរបស់ពួកអ្នក ម្តាយមីងខាងឪពុករបស់ពួកអ្នក ម្តាយមីងខាងម្តាយរបស់ពួកអ្នក ក្មួយស្រីពីបងប្អូនប្រុសរបស់ពួកអ្នក ក្មួយស្រីពីបងប្អូនស្រីរបស់ពួកអ្នក ម៉ែដោះរបស់ពួកអ្នកដែលបានបំបៅពួកអ្នក និងបងប្អូនស្រីតាមរយៈការបំបៅដោះតែមួយ(ជាមួយពួកអ្នក) ម្តាយក្មេករបស់ពួកអ្នក កូនស្រីប្រពន្ធរបស់ពួកអ្នក(កូនចុង)ដែលបានធំធាត់នៅក្នុងផ្ទះរបស់ពួកអ្នកប្រសិនបើពួកអ្នកបានរួមដំណេកជាមួយម្តាយរបស់ពួកនាង(កូនចុង)រួចហើយនោះ។ តែប្រសិនបើពួកអ្នកមិនទាន់បានរួមដំណេកជាមួយម្តាយរបស់ពួកនាងទេនោះ គឺគ្មានទោសពៃអ៊ីឡើយលើពួកអ្នកក្នុងការរៀបការជាមួយពួកនាង(កូនស្រីចុង)នោះហើយ(ទ្រង់ក៏បានហាមឃាត់ផងដែរមិនឱ្យរៀបការជាមួយ)នឹងប្រពន្ធរបស់កូនប្រុសបង្កើតរបស់ពួកអ្នក(កូនប្រសារ)ហើយនិង(ហាមឃាត់មិនឱ្យរៀបការជាមួយ)ស្ត្រីពីរនាក់ដែលជាបងប្អូនបង្កើតនឹងគ្នា លើកលែងតែអ្វីដែលបានកន្លងផុតទៅ(មុនអ៊ីស្លាមមកដល់)ប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុតចំពោះពួកគេ។

24. ហើយ(ទ្រង់ក៏បានហាមឃាត់មិនឱ្យរៀបការនឹង)ស្ត្រីដែលមានប្តី លើកលែងតែទាសីដែលនៅក្រោមការគ្រប់គ្រងរបស់ពួកអ្នក។(ទាំងនោះ)ជាការកំណត់របស់អល់ឡោះចំពោះពួកអ្នក។ ហើយទ្រង់បានអនុញ្ញាតឱ្យពួកអ្នក(អាចរៀបការ)នឹងស្ត្រីផ្សេងក្រៅពីនោះ ដោយពួកអ្នកអាចស្វែងរកដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកអ្នកដើម្បីរៀបការស្របច្បាប់ ពុំមែនក្នុងបំណងប្រព្រឹត្តហ្ស៊ីណា(នឹងពួកនាង)នោះឡើយ។ តាមរយៈការរៀបការស្របច្បាប់ជាមួយពួកនាង ចូរពួកអ្នកផ្តល់ឱ្យពួកនាងនូវខាន់ស្លារបស់ពួកនាងដែលជាកាតព្វកិច្ចលើពួកអ្នក។ ហើយគ្មានទោសពៃចំពោះពួកអ្នកឡើយនូវអ្វីដែលពួកអ្នកបានឯកភាពគ្នានឹងវា(ខាន់ស្លា)បន្ទាប់ពីពួកអ្នកបានកំណត់វារួច។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិតបំផុត។

25. ហើយជនណាមួយក្នុងចំណោមពួកអ្នកដែលគ្មានលទ្ធភាពរៀបការជាមួយនឹងស្ត្រីល្អបរិសុទ្ធដែលមានជំនឿទេនោះ ដូច្នេះគេអាចរៀបការជាមួយនឹងទាសីជាអ្នកមានជំនឿដែលនៅក្រោមការគ្រប់គ្រងរបស់ពួកអ្នក។ ហើយអល់ឡោះទ្រង់ដឹងបំផុតពីសេចក្តីជំនឿរបស់ពួកអ្នក។ ពួកអ្នក គឺមានភាពស្មើគ្នាទៅវិញទៅមក។ ដូច្នេះ ចូរពួកអ្នករៀបការជាមួយពួកនាង(ទាសី)ដោយមានការអនុញ្ញាតពីម្ចាស់របស់ពួកនាង ហើយចូរពួកអ្នកផ្តល់ឱ្យពួកនាងនូវខាន់ស្លារបស់ពួកនាងដោយសមរម្យ ប្រសិនបើពួកនាងជាស្ត្រីស្អាតស្អំ ពុំមែនជាស្ត្រីពេស្យា និងពុំមែនជាស្ត្រីដែលពួកអ្នកយកធ្វើជាស្រីកំណាន់នោះឡើយ។ ហើយប្រសិនបើពួកនាង(ទាសី)បានរៀបការរួច ក្រោយមកពួកនាងបានប្រព្រឹត្តអំពើអសីលធម៌ហ្ស៊ីណា ពួកនាងត្រូវទទួលពាក់កណ្តាលនៃទណ្ឌកម្មដែលដាក់លើស្ត្រីមានសេរីភាព។ នោះគឺចំពោះអ្នកដែលខ្លាចធ្លាក់ខ្លួនក្នុងប្រការហ្ស៊ីណាក្នុងចំណោមពួកអ្នក។ តែការអត់ធ្មត់(មិនរៀបការជាមួយទាសី)គឺជាការប្រសើរសម្រាប់ពួកអ្នក។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

26. អល់ឡោះជាម្ចាស់មានបំណងបញ្ជាក់ប្រាប់ដល់ពួកអ្នក និងចង្អុលបង្ហាញពួកអ្នកនូវបណ្តាមាគ៌ារបស់អ្នកជំនាន់មុនពួកអ្នក និងទទួលយកការសោរភាពកំហុសរបស់ពួកអ្នក។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

27. ហើយអល់ឡោះទ្រង់មានបំណងទទួលយកការសោរភាពកំហុសរបស់ពួកអ្នក។ តែពួកដែលដើរតាមទំនើងចិត្តរបស់ខ្លួនវិញពួកគេចង់ឱ្យពួកអ្នកងាកចេញពីមាគ៌ាដ៏ត្រឹមត្រូវយ៉ាងឆ្ងាយបំផុត។

28. អល់ឡោះទ្រង់មានបំណងបន្ទូរបន្ថយដល់ពួកអ្នក។ ហើយមនុស្សលោកត្រូវបានគេបង្កើតមកដោយមានភាពទន់ខ្សោយ។

29. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកទ្រព្យសម្បត្តិគ្នាទៅវិញទៅមកដោយខុសច្បាប់ឱ្យសោះ លើកលែងតែតាមរយៈការធ្វើជំនួញដែលមានការឯកភាពគ្នារវាងពួកអ្នកប៉ុណ្ណោះ។ ហើយចូរពួកអ្នកកុំសម្លាប់ខ្លួនឯង។ ពិតណាស់ អល់ឡោះទ្រង់មហាអាណិតស្រលាញ់បំផុតចំពោះពួកអ្នក។

30. ហើយជនណាបានធ្វើដូច្នោះដោយភាពជាសត្រូវ និងការបំពាននោះ ពិតណាស់ យើងនឹងបញ្ចូលរូបគេទៅក្នុងភ្លើងនរក ហើយរឿងនោះ គឺងាយស្រួលបំផុតចំពោះអល់ឡោះជាម្ចាស់។

31. ប្រសិនបើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ជៀសវាងពីបាបកម្មធំៗនូវអ្វីដែលគេបានហាមឃាត់ពួកអ្នកនោះ យើងនឹងលុបលាងនូវអំពើអាក្រក់របស់ពួកអ្នក ហើយយើងនឹងបញ្ចូលពួកអ្នកទៅកាន់កន្លែងមួយដ៏ឧត្តុង្គឧត្តម(ឋានសួគ៌)។

32. ហើយចូរពួកអ្នកកុំប្រាថ្នាចង់បានដូចអ្វីដែលអល់ឡោះបានប្រទានឱ្យអ្នកខ្លះក្នុងចំណោមពួកអ្នកឲ្យសោះ។ សម្រាប់បុរសគឺទទួលបាននូវចំណែកនៃអ្វីដែលពួកគេបានប្រព្រឹត្ត ហើយសម្រាប់ស្ត្រី ក៏ទទួលបាននូវចំណែកនៃអ្វីដែលពួកនាងបានប្រព្រឹត្ត(ដូចគ្នា)។ ហើយចូរពួកអ្នកសុំពីអល់ឡោះនូវក្តីសប្បុរសរបស់ទ្រង់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

33. ហើយសម្រាប់បុគ្គលគ្រប់រូប យើងបានបង្កើតសម្រាប់គេឱ្យមាននូវអ្នកស្នងមរតកពីឪពុកម្តាយនិងសាច់សាលោហិតដែលបានបន្សល់ទុក។ ហើយអ្នកដែលពួកអ្នកបានស្បថសច្ចាជាមួយពួកគេថានឹងជួយដល់ពួកគេនោះ ចូរផ្តល់ឱ្យពួកគេនូវចំណែករបស់ពួកគេ(ពីមរតកនោះ)។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាសាក្សីលើអ្វីៗទាំងអស់។

34. បុរសទាំងឡាយ គឺជាអ្នកគ្រប់គ្រងលើស្ត្រីដោយសារតែអល់ឡោះទ្រង់លើកតម្កើងពួកគេឲ្យមានភាពប្រសើរលើសគ្នា និងដោយសារតែអ្វីដែលពួកគេបានចំណាយអំពីទ្រព្យសម្បត្តិរបស់ពួកគេ(លើការផ្គត់ផ្គង់ពួកនាង)។ ហើយស្ត្រីគ្រប់លក្ខណ៍នោះ គឺជាស្ត្រីដែលគោរពប្រតិបត្តិ(ចំពោះអល់ឡោះ) ជាស្ត្រីដែលថែរក្សាខ្លួននៅពេលអវត្តមានស្វាមីដោយការថែរក្សាពីអល់ឡោះ(ដល់ពួកនាង)។ ដោយឡែកស្ត្រីទាំងឡាយដែលពួកអ្នក(ស្វាមី)បារម្ភនូវការមិនគោរពរបស់ពួកនាង(ចំពោះពួកអ្នក)នោះ ចូរពួកអ្នកដាស់តឿនពួកនាង បំបែកកន្លែងគេងពីពួកនាង និងវាយអប់រំពួកនាង(ស្រាលៗដែលមិនបង្ករបួសស្នាម)។ ហើយប្រសិនបើពួកនាងស្តាប់បង្គាប់ពួកអ្នកវិញហើយនោះ ចូរពួកអ្នកកុំស្វែងរកផ្លូវបំពានលើពួកនាងឱ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្ពង់ខ្ពស់ មហាធំធេងបំផុត។

35. ហើយប្រសិនបើពួកអ្នក(ឱអាណាព្យាបាល)បារម្ភខ្លាចមានការប្រេះឆារវាងគេទាំងពីរ(ប្តីប្រពន្ធ) ចូរពួកអ្នកបញ្ជូនបុគ្គលដែលយុត្តិធម៌ម្នាក់ពីសាច់ញាតិខាងប្តី និងបុគ្គលដែលយុត្តិធម៌ម្នាក់ទៀតពីសាច់ញាតិខាងប្រពន្ធ។ ប្រសិនបើគេទាំងពីរចង់បានការផ្សះផ្សា នោះអល់ឡោះជាម្ចាស់នឹងឱ្យពួកគេទាំងពីរត្រូវរៀបគ្នាវិញមិនខានឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាជ្រួតជ្រាបបំផុត។

36. ហើយចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់) និងមិនត្រូវធ្វើស៊ីរិកចំពោះទ្រង់នឹងអ្វីមួយឡើយ។ ហើយចូរពួកអ្នកធ្វើល្អចំពោះឪពុកម្តាយ ញាតិសន្តាន ក្មេងកំព្រា ជនក្រីក្រ អ្នកជិតខាងដែលជាសាច់ញាតិ អ្នកជិតខាងដែលមិនមែនជាសាច់ញាតិ អ្នករួមដំណើរជាមួយគ្នា អ្នកដំណើរដាច់ស្បៀង និងទាសករដែលនៅក្រោមការគ្រប់គ្រងរបស់ពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនស្រលាញ់អ្នកដែលអួតក្អេងក្អាងឡើយ។

37. (ហើយទ្រង់ក៏មិនស្រលាញ់ដែរ)ពួកដែលកំណាញ់ ហើយថែមទាំងប្រើមនុស្សលោកឱ្យកំណាញ់(ដូចពួកគេ) ព្រមទាំងលាក់បាំងនូវអ្វីដែលអល់ឡោះបានប្រទានដល់ពួកគេនៃភាពសប្បុរសរបស់ទ្រង់។ ហើយយើងបានរៀបចំសម្រាប់ពួកដែលប្រឆាំងនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

38. ហើយ(ក៏ដូចគ្នាដែរ)ពួកដែលបរិច្ចាគទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីចង់ឱ្យមនុស្សលោកឃើញ ខណៈដែលពួកគេគ្មានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោកឡើយ។ ហើយជនណាដែលយកស្មែតនធ្វើជាគូកនរបស់ខ្លួននោះ ពិតណាស់ ស្មែតននោះគឺជាគូកនដ៏អាក្រក់បំផុត។

39. តើមានអ្វីកើតឡើងលើពួកគេប្រសិនបើពួកគេមានជំនឿលើអល់ឡោះនិងថ្ងៃបរលោក ហើយបរិច្ចាគ(មួយចំណែក)អំពីអ្វីដែលអល់ឡោះទ្រង់បានប្រទានជាលាភសក្ការៈដល់ពួកគេនោះ? ហើយអល់ឡោះមហាដឹងបំផុតចំពោះពួកគេ។

40. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនបំពាន(លើនរណាម្នាក់)ប៉ុនលំអងធូលីឡើយ។ ហើយប្រសិនបើជាទង្វើល្អ គឺទ្រង់នឹងបង្កើនផលបុណ្យរបស់វាទ្វេដង ព្រមទាំងបន្ថែមទៅលើផលបុណ្យទ្វេដងនោះនូវផលបុណ្យដ៏ធំធេងពីលើនោះទៀត។

41. តើ(ស្ថានភាពពួកគេ)យ៉ាងដូចម្តេចទៅនៅពេលដែលយើងនាំមកពីគ្រប់ប្រជាជាតិទាំងអស់នូវសាក្សីម្នាក់(ព្យាការីរបស់ពួកគេ) ហើយយើងក៏បាននាំអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មកធ្វើជាសាក្សីលើពួកគេ(ប្រជាជាតិរបស់អ្នក)ដែរនោះ?

42. នាថ្ងៃនោះ(ថ្ងៃបរលោក) ពួកដែលគ្មានជំនឿ និងបានប្រឆាំងនឹងអ្នកនាំសារ ពួកគេមានបំណងចង់ឱ្យខ្លួនឯងក្លាយជាធូលីដី។ ហើយពួកគេមិនអាចលាក់បាំងរឿងអ្វីមួយពីអល់ឡោះឡើយ។

43. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំប្រតិបត្តិសឡាតខណៈពេលដែលពួកអ្នកស្រវឹង រហូតទាល់តែពួកអ្នកដឹងនូវអ្វីដែលពួកអ្នកកំពុងនិយាយ ហើយកុំសឡាត(និងកុំចូលម៉ាស្ជិត)ក្នុងពេលដែលពួកអ្នកមានជួនុប លើកលែងតែការដើរកាត់ប៉ុណ្ណោះ រហូតទាល់តែពួកអ្នកងូតទឹកសម្អាតខ្លួនសិន ។ ហើយប្រសិនបើពួកអ្នកមានជំងឺ ឬជាអ្នកដំណើរ ឬក៏នរណាម្នាក់ក្នុងចំណោមពួកអ្នកបានបន្ទោបង់ ឬក៏ពួកអ្នកបានរួមដំណេកជាមួយភរិយា ហើយពួកអ្នកគ្មានទឹក(ឬមិនអាចប្រើប្រាស់ទឹកបាន)ទេនោះ ចូរពួកអ្នកតាយ៉ាំមុំដោយប្រើដីស្អាត ដោយពួកអ្នកត្រូវជូតមុខ និងដៃរបស់ពួកអ្នក(នឹងដីនោះ)ចុះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាអធ្យាស្រ័យ មហាអភ័យទោសបំផុត។

44. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬចំពោះរឿងរ៉ាវរបស់ពួក(យូដា)ដែលគេប្រទានឱ្យពួកគេនូវចំណេះដឹងមួយចំណែកអំពីគម្ពីរ(តាវ៉ាត) តែពួកគេបែរជាប្តូរយកភាពវង្វេង ហើយពួកគេមានបំណងធ្វើឱ្យពួកអ្នកវង្វេងចេញពីមាគ៌ាដ៏ត្រឹមត្រូវ?

45. ហើយអល់ឡោះទ្រង់ដឹងបំផុតពីសត្រូវរបស់ពួកអ្នក។ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាអ្នកគាំពារ ហើយក៏គ្រប់គ្រាន់ដែរដែលមានអល់ឡោះជាអ្នកជួយ។

46. ក្នុងចំណោមពួកយូដា មានអ្នកដែលកែប្រែបន្ទូលរបស់អល់ឡោះជាម្ចាស់ខុសពីកន្លែងដើមរបស់វា(ដែលទ្រង់បានបញ្ចុះមក) ហើយពួកគេនិយាយថា៖ ពួកយើងបានឮហើយ តែពួកយើងមិនគោរពតាមឡើយ (ហើយពួកគេនិយាយទៀតថា៖) ចូរអ្នកស្តាប់(សម្តីពួកយើង) ប៉ុន្តែអ្នកបែរជាមិនព្រមស្តាប់ និងប្រើពាក្យ "រ៉ាអីណា" ដោយនិយាយបន្លំក្នុងចេតនាប្រមាថមាក់ងាយ(ចំពោះព្យាការី) និងចង់បង្ខូចសាសនាអ៊ីស្លាម។ តែប្រសិនបើពួកគេនិយាយថា៖ "ពួកយើងបានឮហើយ និងបានគោរពតាមហើយ (និងនិយាយថា)៖ សូមអ្នកស្តាប់(សម្តីពួកយើង) ហើយប្រើពាក្យ "អ៊ុនហ្ស៊ុរណា"(ជំនួសវិញ) វាគឺជាការប្រសើរបំផុតសម្រាប់ពួកគេ និងជាពាក្យដែលត្រឹមត្រូវជាង។ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទ្រង់បានដាក់បណ្តាសាពួកគេដោយសារតែការប្រឆាំងរបស់ពួកគេ។ ហេតុនេះ ពួកគេមិនមានជំនឿឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

47. ឱបណ្តាអ្នកដែលត្រូវបានគេប្រទានគម្ពីរឱ្យ! ចូរពួកអ្នកមានជំនឿលើអ្វីដែលយើងបានបញ្ចុះមក(ឱ្យព្យាការីមូហាំម៉ាត់)ដើម្បីបញ្ជាក់នូវអ្វីដែលមាននៅជាមួយពួកអ្នក(នៃគម្ពីរតោរ៉ាតនិងគម្ពីរអ៊ិញជីល)មុនពេលដែលយើងបំផ្លាញឥន្ទ្រីយាម្មណ៍ដែលមាននៅលើផ្ទៃមុខ និងបង្វិលវាដាក់ទៅផ្នែកខាងក្រោយវិញ ឬយើងដាក់បណ្តាសាពួកគេ ដូចដែលយើងបានដាក់បណ្តាសាក្រុមដែលបំពានថ្ងៃសៅរ៍។ ហើយបទបញ្ជារបស់អល់ឡោះ គឺពិតជាត្រូវបានអនុវត្ត។

48. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនអភ័យទោសឱ្យអ្នកដែលធ្វើស៊ីរិកចំពោះទ្រង់ឡើយ តែទ្រង់នឹងអភ័យទោសឱ្យចំពោះបាបកម្មផ្សេងពីនេះ ចំពោះជនណាដែលទ្រង់មានចេតនា។ ហើយជនណាដែលធ្វើស៊ីរិកនឹងអល់ឡោះជាម្ចាស់នោះ ពិតប្រាកដណាស់ រូបគេពិតជាបានប្រព្រឹត្តបាបកម្មមួយដ៏ធ្ងន់ធ្ងរបំផុត។

49. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬអំពីរឿងរ៉ាវរបស់ពួកដែលលើកសរសើរខ្លួនឯងជាអ្នកស្អាតស្អំនោះ? ផ្ទុយទៅវិញ មានតែអល់ឡោះតែមួយគត់ដែលជាអ្នកធ្វើឱ្យស្អាតស្អំ(ពីបាបកម្ម)ចំពោះជនណាដែលទ្រង់មានចេតនា ហើយពួកគេមិនត្រូវបានគេបំពានបន្តិចណាឡើយ សូម្បីប៉ុនសសៃឆ្នាក៏ដោយ។

50. ចូរអ្នកមើលចុះ(ឱអ្នកនាំសារមូហាំម៉ាត់) តើពួកគេបានប្រឌិតរឿងកុហកទៅលើអល់ឡោះជាម្ចាស់(ដោយការលើកសរសើរខ្លួនឯង)យ៉ាងដូចម្តេច? គ្រប់គ្រាន់ហើយដែលទង្វើទាំងនោះជាបាបកម្មដ៏ច្បាស់លាស់។

51. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬនូវពួក(យូដា)ដែលគេបានប្រទានចំណេះដឹងមួយផ្នែកនៃគម្ពីរឱ្យពួកគេ តែពួកគេបែរជាមានជំនឿលើព្រះនានាដែលពួកគេយកមកគោរពសក្ការៈផ្សេងពីអល់ឡោះទៅវិញ ហើយពួកគេនិយាយចំពោះពួកគ្មានជំនឿថា ពិតប្រាកដណាស់ ពួកទាំងនេះស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវជាងបណ្តាអ្នកមានជំនឿទៅទៀត?

52. ពួកទាំងនោះហើយជាពួកដែលត្រូវបានអល់ឡោះដាក់បណ្តាសាពួកគេ។ ជនណាហើយដែលអល់ឡោះទ្រង់បានដាក់បណ្តាសានោះ គឺអ្នក(ព្យាការីមូហាំម៉ាត់)នឹងមិនឃើញមានអ្នកដែលជួយគាំពារគេនោះឡើយ។

53. ឬមួយពួកគេមានចំណែកនៅក្នុងការគ្រប់គ្រងអ្វីមួយ? បើដូច្នោះមែននោះ ពួកគេនឹងមិនផ្តល់ឱ្យនរណាម្នាក់បន្តិចណាឡើយ។

54. ឬមួយពួកគេច្រណែននឹងមនុស្សលោក(ព្យាការីមូហាំម៉ាត់ និងបណ្តាមិត្តភក្តិរបស់លោក)ចំពោះអ្វីដែលអល់ឡោះបានប្រទានឱ្យពួកគេនៃក្តីសប្បុរសរបស់ទ្រង់? ហើយជាការពិតណាស់ យើងក៏បានប្រទានឱ្យពូជពង្សព្យាការីអ៊ីព្រហ៊ីមនូវគម្ពីរ និងគតិបណ្ឌិត ហើយយើងក៏បានប្រទានឲ្យពួកគេនូវអំណាចដ៏ធំធេងផងដែរ។

55. ជាការពិតណាស់ ក្នុងចំណោមពួកគេ(ពួកអះលីគីតាប)មានអ្នកដែលមានជំនឿ ហើយក្នុងចំណោមពួកគេ ក៏មានអ្នកដែលប្រឆាំងនឹងវាផងដែរ។ គ្រប់គ្រាន់ហើយ(សម្រាប់ពួកគេ)នូវនរកដ៏ហាន់ណាំដែលឆេះយ៉ាងសន្ធោសន្ធៅ។

56. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់យើងនោះ យើងនឹងបញ្ចូលពួកគេទៅក្នុងភ្លើងនរក។ រាល់ពេលដែលស្បែករបស់ពួកគេបានឆេះខ្លោចអស់ យើងនឹងផ្លាស់ប្តូរស្បែកផ្សេងទៀតឱ្យពួកគេដើម្បីឱ្យពួកគេភ្លក់នូវទណ្ឌកម្ម(ជាបន្តទៀត)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

57. ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល យើងនឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពួកគេនឹងស្ថិតនៅទីនោះជាអមតៈ។ នៅក្នុងនោះ ពួកគេមានភរិយាដ៏ស្អាតស្អំជាច្រើន ហើយយើងនឹងបញ្ចូលពួកគេទៅក្នុងម្លប់ដ៏ត្រឈឹងត្រឈៃ។

58. ពិតប្រាកដណាស់ អល់ឡោះទ្រង់បានបង្គាប់ប្រើពួកអ្នកឱ្យប្រគល់បញ្ញើទាំងឡាយ(ដែលគេផ្ញើ)ឱ្យទៅម្ចាស់ដើមរបស់គេវិញ។ ហើយនៅពេលដែលពួកអ្នកកាត់ក្តីរវាងមនុស្សលោក ចូរពួកអ្នកកាត់ក្តី(ឱ្យពួកគេ)ដោយយុត្តិធម៌។ ពិតប្រាកណាស់ ជាការប្រសើរបំផុតដែលអល់ឡោះទ្រង់ផ្តល់ដំបូន្មានដល់ពួកអ្នកចំពោះរឿងនេះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាឮ មហាឃើញបំផុត។

59. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងចូរពួកអ្នកប្រតិបត្តិតាមអ្នកនាំសារ ហើយនិងមេដឹកនាំរបស់ពួកអ្នក។ ហើយប្រសិនបើពួកអ្នកខ្វែងគំនិតគ្នាពីបញ្ហាអ្វីមួយ ចូរពួកអ្នកត្រឡប់បញ្ហានោះទៅកាន់អល់ឡោះ(គម្ពីរគួរអាន)និងអ្នកនាំសារ(ស៊ុណ្ណះ)ប្រសិនបើពួកអ្នកពិតជាមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោកមែននោះ។ នោះជាការប្រសើរ និងទទួលបានលទ្ធផលចុងក្រោយដ៏ល្អផងដែរ។

60. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬពួកដែលអះអាងថា ជាការពិតណាស់ ពួកគេពិតជាមានជំនឿចំពោះអ្វីដែលគេបានបញ្ចុះមកឱ្យអ្នក និង(មានជំនឿ)ចំពោះអ្វីដែលគេបានបញ្ចុះឱ្យអ្នក(នាំសារ)ជំនាន់មុនអ្នក ដោយពួកគេមានបំណងចង់ប្រគល់ការកាត់ក្តីទៅឱ្យតហ្ងូត ខណៈដែលពួកគេត្រូវបានគេ(អល់ឡោះ)បង្គាប់ប្រើឱ្យប្រឆាំងនឹងវា។ ហើយស្មែតនមានបំណងចង់ឱ្យពួកគេវង្វេងយ៉ាងសែនឆ្ងាយ។

61. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកមករកអ្វីដែលអល់ឡោះបានបញ្ចុះមក និងមករកអ្នកនាំសារ នោះអ្នកនឹងឃើញពួកគេបែរចេញពីអ្នកទាំងស្អប់ខ្ពើម។

62. តើ(ស្ថានភាពពួកពុតត្បុត)យ៉ាងដូចម្តេច នៅពេលដែលមានគ្រោះអាក្រក់បានកើតឡើងចំពោះពួកគេដោយសារតែអ្វីដែលពួកគេបានសាងនោះ? បន្ទាប់មក ពួកគេនឹងមករកអ្នកដោយពួកគេស្បថនឹងអល់ឡោះជាម្ចាស់ថា៖ ពួកយើងគ្មានបំណងអ្វីក្រៅពីភាពល្អប្រសើរ និងការត្រូវរ៉ូវគ្នាវិញតែប៉ុណ្ណោះ។

63. ពួកទាំងនោះហើយដែលអល់ឡោះដឹងនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេ។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ងាកចេញពីពួកគេចុះ និងត្រូវដាស់រឭកពួកគេ ហើយចូរអ្នកនិយាយទៅកាន់ពួកគេនូវពាក្យសម្តីណាដែលមានប្រសិទ្ធិភាពបំផុត។

64. ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់ឡើយ លើកលែងតែដើម្បីឱ្យគេ(មនុស្សលោក)ប្រតិបត្តិតាមគាត់ដោយការអនុញ្ញាតពីអល់ឡោះ។ ហើយបើនៅពេលដែលពួកគេបានបំពានលើខ្លួនឯង ហើយពួកគេបានមកជួបអ្នកខណៈដែលអ្នកនៅមានជីវិត ដោយពួកគេសុំការអភ័យទោសពីអល់ឡោះ ហើយអ្នកនាំសារក៏បានជួយសុំអភ័យទោសឱ្យពួកគេដែរនោះ ពិតណាស់ពួកគេពិតជានឹងឃើញថា អល់ឡោះជាម្ចាស់គឺជាអ្នកទទួលនូវការសារភាពកំហុស និងមហាអាណិតស្រលាញ់បំផុត។

65. មិនដូច្នោះឡើយ សូមស្បថនឹងព្រះជាម្ចាស់របស់អ្នក! ពួកគេមិនមានជំនឿ(ពិតប្រាកដ)ឡើយ លុះត្រាតែពួកគេប្រគល់ឱ្យអ្នកកាត់ក្តីនូវរាល់ការខ្វែងគំនិតគ្នារវាងពួកគេ ក្រោយមក ពួកគេគ្មានការចង្អៀតចង្អល់នៅក្នុងចិត្តចំពោះអ្វីដែលអ្នកបានវិនិច្ឆ័យ ហើយពួកគេទទួលយកដោយការពេញចិត្ត។

66. ហើយជាការពិតណាស់ ប្រសិនបើយើងដាក់បទបញ្ជាលើពួកគេ(ពួកពុតត្បុត)ថា៖ ចូរពួកអ្នកសម្លាប់ខ្លួនឯង ឬចាកចេញពីលំនៅឋានរបស់ពួកអ្នក នោះពួកគេនឹងមិនធ្វើតាមបទបញ្ជា(របស់យើង)នោះឡើយ លើកលែងតែមួយចំនួនតូចនៃពួកគេប៉ុណ្ណោះ។ ហើយប្រសិនបើពួកគេធ្វើតាមអ្វីដែលគេបានដាស់រឭកពួកគេនោះ គឺល្អប្រសើរសម្រាប់ពួកគេ និងធ្វើឱ្យជំនឿរបស់ពួកគេកាន់តែរឹងមាំថែមទៀត។

67. បើដូច្នោះ យើងពិតជានឹងប្រទានឱ្យពួកគេនូវផលបុណ្យដ៏ធំធេងបំផុតអំពីយើង។

68. ហើយយើងពិតជានឹងចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

69. ហើយជនណាដែលប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសារ ជាការពិតណាស់ អ្នកទាំងនោះពួកគេនឹងស្ថិតនៅជាមួយបណ្តាអ្នកដែលអល់ឡោះបានប្រទានឧបការគុណឱ្យពួកគេ ដូចជាបណ្តាព្យាការី បណ្តាអ្នកជឿតាមព្យាការី បណ្តាអ្នកពលី និងបណ្តាអ្នកសាងកុសលទាំងឡាយ។ អ្នកទាំងនោះហើយគឺជាកល្យាណមិត្តដ៏ល្អបំផុត។

70. ទាំងនោះ គឺជាការប្រោសប្រទានពីអល់ឡោះជាម្ចាស់។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកមហាដឹងបំផុត។

71. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នករៀបចំខ្លួនដោយប្រុងប្រយ័ត្ន(ពីសត្រូវ) ហើយចូរពួកអ្នកចេញទៅប្រយុទ្ធម្តងមួយក្រុមៗ ឬក៏ចេញទៅប្រយុទ្ធទាំងអស់គ្នាតែម្តង។

72. ហើយពិតប្រាកដណាស់ ក្នុងចំណោមពួកអ្នក(ឱបណ្តាជនមូស្លីមទាំងឡាយ) គឺមានអ្នកដែលអល់អែក(ក្នុងការចេញច្បាំង)។ ហើយប្រសិនបើពួកអ្នកទទួលរងគ្រោះថ្នាក់ណាមួយ គេនឹងនិយាយថា៖ ជាការពិតណាស់ អល់ឡោះជាម្ចាស់បានប្រោសប្រទានដល់ខ្ញុំ ខណៈដែលខ្ញុំមិនបានទៅចូលរួមជាមួយពួកគេ។

73. តែប្រសិនបើពួកអ្នកទទួលបានការប្រោសប្រទានពីអល់ឡោះវិញនោះ គេពិតជានឹងនិយាយចេញមក ហាក់ដូចជារវាងពួកអ្នកនឹងរូបគេគ្មានមនោសញ្ចេតនាអ្វីនឹងគ្នាសោះថា៖ ខ្ញុំសោកស្តាយណាស់! ប្រសិនបើខ្ញុំស្ថិតនៅជាមួយពួកគេនោះ ខ្ញុំពិតជានឹងទទួលបានជោគជ័យដ៏ធំធេង(ដូចពួកគេ)ជាមិនខាន។

74. ដូច្នេះ ចូរឱ្យបណ្តាអ្នកដែលយកជីវិតលោកិយប្តូរយកថ្ងៃបរលោកនោះធ្វើសង្គ្រាមក្នុងមាគ៌ារបស់អល់ឡោះចុះ។ ហើយជនណាដែលធ្វើសង្គ្រាមក្នុងមាគ៌ារបស់អល់ឡោះ ហើយត្រូវបានគេសម្លាប់ ឬទទួលបរាជ័យនោះ ពិតណាស់ យើងនឹងប្រទានឱ្យគេនូវផលបុណ្យដ៏ធំធេងបំផុត(ឋានសួគ៌)។

75. តើហេតុអ្វីបានជាពួកអ្នក(អ្នកមានជំនឿ)មិនធ្វើសង្គ្រាម ក្នុងមាគ៌ារបស់អល់ឡោះ និង(ជួយសង្គ្រោះ)ពួកដែលទន់ខ្សោយក្នុងចំណោមបុរសនិងស្ត្រី ហើយនិងក្មេងៗដែលពួកគេកំពុងតែបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាជួយសង្គ្រោះយើងខ្ញុំចេញពីភូមិស្រុក(ម៉ាក្កៈ)នេះ ដែលអ្នករស់នៅទីនេះជាពួកបំពានផងចុះ ហើយសូមព្រះអង្គមេត្តាប្រទានដល់យើងខ្ញុំនូវអ្នកគាំពារកិច្ចការរបស់យើងខ្ញុំពីព្រះអង្គ ហើយនិង(ប្រទាន)អ្នកជួយដល់យើងខ្ញុំពីព្រះអង្គផងចុះ។

76. បណ្តាអ្នកដែលមានជំនឿ គឺពួកគេប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះ។ រីឯពួកគ្មានជំនឿវិញ ពួកគេប្រយុទ្ធក្នុងមាគ៌ាតហ្ងូត។ ហេតុនេះ ចូរពួកអ្នកប្រយុទ្ធប្រឆាំងនឹងបក្សពួករបស់ស្មៃតនចុះ។ ជាការពិតណាស់ ល្បិចកលរបស់ស្មៃតនគឺទន់ខ្សោយបំផុត។

77. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬពីរឿងរ៉ាវរបស់អ្នកដែលគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកហាមឃាត់ដៃរបស់ពួកអ្នក(ពីការធ្វើសង្គ្រាម) ហើយចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់(មុនពេលដែលគេបានដាក់កាតព្វកិច្ចឱ្យធ្វើសង្គ្រាម)។ តែនៅពេលដែលគេបានដាក់កាតព្វកិច្ចលើពួកគេឱ្យធ្វើសង្គ្រាម ស្រាប់តែមួយក្រុមក្នុងចំណោមពួកគេមានការភ័យខ្លាចចំពោះមនុស្សលោកបីដូចជាពួកគេខ្លាចអល់ឡោះ ឬខ្លាំងជាងខ្លាចអល់ឡោះទៅទៀត ហើយពួកគេបាននិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ហេតុអ្វីបានជាព្រះអង្គដាក់កាតព្វកិច្ចសង្គ្រាមមកលើយើងខ្ញុំ? ហេតុអ្វីបានជាព្រះអង្គមិនពន្យារពេលបន្តិចទៀតដល់យើងខ្ញុំ(ដើម្បីបានរីករាយនឹងជីវិតលោកិយសិន)? ចូរអ្នកពោលទៅកាន់ពួកគេថា៖ ការត្រេកត្រអាលក្នុងលោកិយនេះ គឺតិចតួចបំផុត។ រីឯថ្ងៃបរលោកវិញ គឺប្រសើរបំផុតសម្រាប់អ្នកដែលកោតខ្លាច(អល់ឡោះជាម្ចាស់) ហើយពួកអ្នកមិនត្រូវបានគេបំពានឡើយ សូម្បីតែបន្តិច។

78. ទោះបីជាពួកអ្នកនៅទីកន្លែងណាក៏ដោយ ក៏សេចក្តីស្លាប់នឹងទៅដល់ពួកអ្នកដែរ សូម្បីតែពួកអ្នកស្ថិតនៅក្នុងវិមានដែលត្រូវបានស្តាបនាយ៉ាងរឹងមាំក៏ដោយ។ ហើយប្រសិនបើពួកគេ(ពួកពុតត្បុត)ទទួលបានប្រការល្អ ពួកគេនិយាយថា៖ នេះគឺមកពីអល់ឡោះ។ តែប្រសិនបើពួកគេទទួលបានប្រការអាក្រក់វិញ ពួកគេនិយាយថា៖ នេះគឺមកពីអ្នក។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ប្រការទាំងនោះ គឺមកពីអល់ឡោះជាម្ចាស់ទាំងអស់។ តើហេតុអ្វីបានជាក្រុមទាំងនោះ ហាក់ដូចជាពួកគេមិនយល់ពីពាក្យសម្តី(ដែលអ្នកនិយាយ)បែបនេះ?

79. អ្វីដែលអ្នកទទួលបាននៃប្រការល្អ គឺមកពីអល់ឡោះជាម្ចាស់។ ហើយអ្វីដែលអ្នកទទួលបាននៃប្រការអាក្រក់ គឺមកពីខ្លួនអ្នកផ្ទាល់។ ហើយជាការពិតណាស់ យើងបានតែងតាំងអ្នក(ឱព្យាការីមូហាំម៉ាត់)ជាអ្នកនាំសារម្នាក់សម្រាប់មនុស្សលោក។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាសាក្សី។

80. ជនណាដែលប្រតិបត្តិតាមអ្នកនាំសារ(មូហាំម៉ាត់)គឺរូបគេពិតជាបានគោរពប្រតិបត្តិតាមអល់ឡោះ។ ជនណាហើយដែលងាកចេញ(ពីការប្រតិបត្តិតាមអ្នក)ជាការពិតណាស់ យើងមិនបានតែងតាំងអ្នកជាអ្នកឃ្លាំមើល(ពួកគេ)ឡើយ។

81. ហើយពួកគេ(ពួកពុតត្បុត)និយាយថា៖ ពួកយើងប្រតិបត្តិតាម(អ្នក)។ តែនៅពេលដែលពួកគេបានចាកចេញពីអ្នកវិញ ក្រុមមួយក្នុងចំណោមពួកគេបានរៀបចំផែនការយ៉ាងសម្ងាត់ផ្ទុយពីអ្វីដែលគេនិយាយទៅវិញ។ ហើយអល់ឡោះទ្រង់នឹងកត់ត្រានូវអ្វី(ផែនការអាក្រក់)ដែលពួកគេរៀបចំ។ ហេតុនេះ ចូរអ្នកងាកចេញពីពួកគេ ហើយប្រគល់ការទុកចិត្តចំពោះអល់ឡោះចុះ។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកត្រូវបានគេផ្តល់ទំនុកចិត្ត។

82. ហេតុអ្វីបានជាពួកគេមិនត្រិះរិះពិចារណាពីគម្ពីរគួរអាន? ហើយប្រសិនបើគម្ពីរនេះមកពីអ្នកផ្សេងក្រៅពីអល់ឡោះវិញនោះ ពួកគេប្រាកដជានឹងឃើញមានការខ្វែងគំនិតគ្នាជាច្រើននៅក្នុងគម្ពីរនេះជាមិនខាន។

83. ហើយនៅពេលដែលព័ត៌មានស្តីពីសុវត្ថិភាព(របស់អ្នកមូស្លីម)ឬព័ត៌មានពីការភ័យខ្លាចបានមកដល់ពួកគេ(ពួកពុតត្បុត)ពួកគេផ្សព្វផ្សាយវាភ្លាម(ទាំងដែលមិនទាន់ដឹងថា តើព័ត៌មាននោះពិតឬមិនពិត)។ តែប្រសិនបើពួកគេផ្តល់ព័ត៌មាននោះទៅកាន់អ្នកនាំសារ និងទៅកាន់មេដឹកនាំវិញនោះ អ្នកដែលមានការយល់ដឹងពីបញ្ហានោះក្នុងចំណោមពួកគេប្រាកដជានឹងដឹងជាមិនខាន(ថាតើត្រូវធ្វើដូចម្តេចចំពោះព័ត៌មាននោះ)។ ហើយប្រសិនបើគ្មានការប្រោសប្រទានពីអល់ឡោះមកលើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)និងក្តីមេត្តាករុណារបស់ទ្រង់ទេនោះ ពួកអ្នកប្រាកដជានឹងដើរតាមស្មែតនជាមិនខានលើកលែងតែមួយចំនួនតូចប៉ុណ្ណោះ។

84. ដូចនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះចុះ។ អ្នកមិនត្រូវបានគេដាក់បន្ទុកលើអ្នកដទៃក្រៅពីខ្លួនឯងឡើយ។ ហើយចូរអ្នកជំរុញបណ្តាអ្នកដែលមានជំនឿ(ឱ្យប្រយុទ្ធក្នុងមាគ៌ាអល់ឡោះ)។ សង្ឃឹមថាអល់ឡោះជាម្ចាស់នឹងទប់ស្កាត់អំណាចរបស់ពួកគ្មានជំនឿ។ ហើយអល់ឡោះជាអ្នកមានអានុភាពខ្លាំងក្លា និងជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

85. ជនណាហើយដែលធ្វើអន្តរាគមន៍នូវប្រការល្អណាមួយ គេនឹងទទួលបានចំណែក(ផលបុណ្យ)អំពីវា។ ហើយជនណាដែលធ្វើអន្តរាគមន៍នូវប្រការអាក្រក់ណាមួយ គេក៏នឹងទទួលបានចំណែក(បាបកម្ម)អំពីវាដូចគ្នា។ ហើយអល់ឡោះជាសាក្សីលើរាល់អ្វីៗទាំងអស់។

86. ហើយនៅពេលដែលមាននរណាម្នាក់ស្វាគមន៍(ឱ្យសាឡាម)លើពួកអ្នក ចូរពួកអ្នកស្វាគមន៍(តបសាឡាម)វិញឱ្យល្អជាងនោះ ឬដូចអ្វីដែលគេបានស្វាគមន៍។ ពិតប្រាកដណាស់ អល់ឡោះជាអ្នកជំនុំជម្រះនូវរាល់អ្វីៗទាំងអស់។

87. អល់ឡោះ(តែមួយគត់) គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់ពិតជានឹងប្រមូលផ្តុំពួកអ្នក(ទាំងអស់គ្នា)នៅថ្ងៃបរលោកដោយគ្មានការសង្ស័យចំពោះវាឡើយ។ ហើយគ្មានពាក្យសម្តីនរណាម្នាក់ដែលពិតជាងបន្ទូលរបស់អល់ឡោះនោះឡើយ។

88. តើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)មានបញ្ហាអ្វីទើបធ្វើឱ្យពួកអ្នកបែកបាក់ជាពីរក្រុមនៅក្នុងរឿងរបស់ពួកពុតត្បុតនោះ? អល់ឡោះជាម្ចាស់បានត្រឡប់ពួកគេ(ទៅរកភាពគ្មានជំនឿ និងភាពវង្វេង)ដោយសារតែអ្វីដែលពួកគេបានប្រព្រឹត្ត។ តើពួកអ្នកចង់ផ្តល់ការចង្អុលបង្ហាញដល់អ្នកដែលអល់ឡោះធ្វើឲ្យវង្វេងឬ? ជនណាដែលអល់ឡោះធ្វើឱ្យវង្វេងហើយនោះ អ្នក(ព្យាការីមូហាំម៉ាត់)នឹងមិនឃើញមានផ្លូវណាមួយសម្រាប់ជននោះឡើយ។

89. ពួកគេ(ពួកពុតត្បុត)ប្រាថ្នាថា ប្រសិនបើពួកអ្នកប្រឆាំងដូចដែលពួកគេបានប្រឆាំងដែរនោះ ពួកអ្នកនឹងមានភាពស្មើគ្នានឹងពួកគេដែរ។ ដូចនេះ ចូរពួកអ្នកកុំយកនរណាម្នាក់ក្នុងចំណោមពួកគេធ្វើជាអ្នកគាំពារឱ្យសោះ លុះត្រាតែពួកគេកៀសខ្លួនក្នុងមាគ៌ារបស់អល់ឡោះ។ តែប្រសិនបើពួកគេងាកចេញ ចូរពួកអ្នកចាប់ពួកគេ និងសម្លាប់ពួកគេនៅទីណាក៏ដោយដែលពួកអ្នកជួបពួកគេ។ ហើយចូរពួកអ្នកកុំយកនរណាម្នាក់ក្នុងចំណោមពួកគេធ្វើជាអ្នកគាំពារ និងជាអ្នកជួយ(ពួកអ្នក)ឱ្យសោះ។

90. លើកលែងតែអ្នកដែលភ្ជាប់ខ្លួនជាមួយនឹងក្រុមមួយដែលរវាងពួកអ្នក(អ្នកមានជំនឿ)និងពួកគេមានកិច្ចព្រមព្រៀងជាមួយគ្នា ឬក៏ពួកដែលបានមកជួបពួកអ្នក ខណៈដែលចិត្តរបស់ពួកគេមានការធុញថប់ដោយពួកគេមិនចង់ធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នក ហើយក៏មិនចង់ធ្វើសង្គ្រាមប្រឆាំងនឹងក្រុមរបស់ពួកគេដែរ។ ហើយប្រសិនបើអល់ឡោះជាម្ចាស់មានចេតនាទ្រង់ពិតជានឹងធ្វើឱ្យពួកគេត្រួតត្រាលើពួកអ្នក ពេលនោះពួកគេនឹងធ្វើសង្គ្រាមឈ្នះពួកអ្នកជាមិនខាន។ តែប្រសិនបើពួកគេបានដកថយ ដោយមិនធ្វើសង្គ្រាមជាមួយពួកអ្នក និងធ្វើការចរចាសន្តិភាពជាមួយពួកអ្នក ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនបើកផ្លូវ(មិនអនុញ្ញាត)ឱ្យពួកអ្នកធ្វើអ្វីទៅលើពួកគេឡើយ។

91. ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)នឹងជួបប្រទះមួយក្រុមផ្សេងទៀត(នៃពួកគេ)មានបំណងចង់បានសុវត្ថិភាពពីពួកអ្នក និងចង់បានសុវត្ថិភាពពីក្រុមរបស់ពួកគេដែរ។ រាល់ពេលដែលពួកគេត្រូវបានគេអំពាវនាវទៅរកភាពវឹកវរ(ប្រឆាំងនឹងអល់ឡោះ និងធ្វើស្ទីរិកចំពោះទ្រង់) ពួកគេទទួលវាយ៉ាងលឿន។ ពិតប្រាកដណាស់ ប្រសិនបើពួកគេមិនព្រមដកថយ មិនព្រមចរចាសន្តិភាពជាមួយពួកអ្នក និងមិនបញ្ឈប់ការធ្វើសង្គ្រាមប្រឆាំងជាមួយពួកអ្នកទេនោះ ចូរពួកអ្នកចាប់ខ្លួនពួកគេ និងសម្លាប់ពួកគេចុះនៅគ្រប់ទីកន្លែងណាក៏ដោយដែលពួកអ្នកជួបពួកគេ។ ពួកទាំងនោះហើយ យើងបានផ្តល់ហេតុផលយ៉ាងច្បាស់លាស់ឱ្យពួកអ្នកទៅលើពួកគេ(អាចចាប់ខ្លួន ឬសម្លាប់ពួកគេ)។

92. អ្នកមានជំនឿមិនត្រូវសម្លាប់អ្នកមានជំនឿដូចគ្នាឡើយ លើកលែងតែដោយអចេតនាប៉ុណ្ណោះ។ ហើយជនណាសម្លាប់អ្នកមានជំនឿដោយអចេតនា គេត្រូវដោះលែងទាសីដែលមានជំនឿម្នាក់ឱ្យមានសេរីភាព និងត្រូវបង់ពិន័យឱ្យទៅគ្រួសារជនរងគ្រោះ លើកលែងតែពួកគេ(គ្រួសារជនរងគ្រោះ)មានការអធ្យាស្រ័យ។ ហើយប្រសិនបើជនរងគ្រោះស្ថិតក្នុងក្រុមសត្រូវរបស់ពួកអ្នក តែរូបគេជាអ្នកមានជំនឿ ចាំបាច់ទៅលើឃាតករត្រូវដោះលែងទាសីដែលមានជំនឿម្នាក់ឱ្យមានសេរីភាព។ ហើយប្រសិនបើជនរងគ្រោះ ស្ថិតក្នុងក្រុមមួយដែលរវាងពួកអ្នកនិងពួកគេមានកិច្ចព្រមព្រៀងសន្តិភាពនឹងគ្នា(តែមិនមែនជាអ្នកមានជំនឿ) គឺត្រូវបង់ពិន័យទៅឱ្យគ្រួសារជនរងគ្រោះ និងត្រូវដោះលែងទាសីដែលមានជំនឿម្នាក់ឱ្យមានសេរីភាព។ តែប្រសិនបើគេគ្មានលទ្ធភាព គឺគេត្រូវបួសពីរខែជាប់គ្នា ជាការទទួលសារភាពកំហុសពីអល់ឡោះ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

93. ជនណាហើយដែលបានសម្លាប់អ្នកមានជំនឿម្នាក់ដោយចេតនា ការតបស្នងចំពោះជននោះ គឺនរកជើហាន់ណាំដោយគេត្រូវស្ថិតនៅក្នុងនោះជាអមតៈ ព្រមទាំងទទួលនូវការខឹងសម្បាពីអល់ឡោះ និងបណ្តាសាពីទ្រង់។ ហើយទ្រង់បានរៀបចំសម្រាប់ជននោះនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

94. ឱបណ្តាអ្នកដែលមានជំនឿ! កាលណាពួកអ្នកចេញដំណើរទៅធ្វើសង្គ្រាមក្នុងមាគ៌ារបស់អល់ឡោះ ចូរពួកអ្នកពិនិត្យឱ្យបានច្បាស់លាស់។ ហើយចូរពួកអ្នកកុំនិយាយទៅកាន់អ្នកដែលបានបង្ហាញដល់ពួកអ្នកពីភាពជាអ៊ីស្លាមរបស់គេថា៖ "អ្នកពុំមែនជាអ្នកដែលមានជំនឿនោះទេ" ដោយស្វែងរកផលប្រយោជន៍លោកិយឲ្យសោះ ពីព្រោះនៅជាមួយអល់ឡោះជាម្ចាស់គឺមានទ្រព្យដ៏យកណ្តាលដ៏ច្រើនលើសលប់។ ក៏ដូចនោះដែរ កាលពីមុន ពួកអ្នកក៏ធ្លាប់(លាក់បាំងសេចក្តីជំនឿរបស់ខ្លួន)បែបនោះដែរ។ ពេលនោះអល់ឡោះជាម្ចាស់ក៏បានប្រោសប្រទានដល់ពួកអ្នក(នូវសាសនាអ៊ីស្លាម)។ ហេតុនេះ ចូរពួកអ្នកពិនិត្យឱ្យបានច្បាស់លាស់(មុនសម្រេចចិត្តធ្វើកិច្ចការអ្វីមួយ)។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

95. មិនស្មើគ្នានោះទេរវាងបណ្តាអ្នកមានជំនឿដែលមិនបានចេញទៅប្រយុទ្ធ ហើយនិងបណ្តាអ្នក(មានជំនឿ)ដែលបានចេញទៅប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះដោយ(លះបង់ទាំង)ទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកគេនោះ លើកលែងតែអ្នកដែលច្បាប់អនុគ្រោះឱ្យប៉ុណ្ណោះ។ អល់ឡោះបានប្រទានឱ្យបណ្តាអ្នកដែលតស៊ូដោយ(លះបង់)ទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកគេនូវឋានៈខ្ពង់ខ្ពស់ជាងបណ្តាអ្នកដែលមិនបានចេញទៅប្រយុទ្ធ។ ហើយគេទាំងពីរ(ទាំងអ្នកដែលបានចេញទៅប្រយុទ្ធ និងអ្នកដែលច្បាប់អនុគ្រោះឲ្យ)អល់ឡោះបានសន្យានូវប្រការល្អ(ដល់ពួកគេ)។ តែអល់ឡោះទ្រង់ប្រទានឱ្យបណ្តាអ្នកដែលចេញទៅប្រយុទ្ធដោយទ្រង់ផ្តល់ឱ្យពួកគេនូវផលបុណ្យដ៏ធំធេងលើសពីបណ្តាអ្នកដែលមិនបានចេញទៅប្រយុទ្ធ។

96. ផលបុណ្យនេះ មានកម្រិតខ្ពស់ទាប(ជាងគ្នា) និងការអភ័យទោស ព្រមទាំងក្តីមេត្តាករុណាអំពីទ្រង់ដល់ពួកគេ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

97. ពិតប្រាកដណាស់ បណ្តាអ្នកដែលម៉ាឡាអ៊ីកាត់បានដកយកជីវិតពួកគេខណៈដែលពួកគេជាអ្នកបំពានលើខ្លួនឯង ពួកគេ(ម៉ាឡាអ៊ីកាត់)នឹងសួរថា៖ តើពួកអ្នកធ្លាប់ស្ថិតក្នុងស្ថានភាពដូចម្តេច? ពួកគេឆ្លើយថា៖ ពួកយើងធ្លាប់ជាអ្នកទន់ខ្សោយនៅលើផែនដី។ ពួកគេសួរទៀតថា៖ តើផែនដីរបស់អល់ឡោះមិនមានភាពធំទូលាយសម្រាប់ឱ្យពួកអ្នកកៀសខ្លួនចេញទេឬ? ពួកទាំងនោះ ទីជម្រករបស់ពួកគេ គឺនរកជើហាន់ណាំ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

98. លើកលែងតែអ្នកដែលទន់ខ្សោយក្នុងចំណោមបុរស ឬស្ត្រី ឬក្មេងតូចៗដែលគ្មានលទ្ធភាពការពារខ្លួន(ពីការបំពាននិងការគៀបសង្កត់) និងមិនស្គាល់ផ្លូវ(ដើម្បីគេចពីការគៀបសង្កត់)ប៉ុណ្ណោះ។

99. ជាការពិតណាស់ អ្នកទាំងនោះ សង្ឃឹមថាអល់ឡោះជាម្ចាស់នឹងអធ្យាស្រ័យដល់ពួកគេ។ ហើយអល់ឡោះមហាអធ្យាស្រ័យមហាអភ័យទោសបំផុត។

100. ហើយជនណាដែលបានកៀសខ្លួនក្នុងមាគ៌ារបស់អល់ឡោះជាម្ចាស់នោះ គេនឹងជួបប្រទះនៅលើទឹកដីដែលគេបានកៀសខ្លួនទៅកាន់នោះនូវការផ្លាស់ប្តូរជាច្រើន និងលាភសក្ការៈដ៏សម្បូរបែប។ ហើយជនណាដែលចាកចេញពីលំនៅឋានរបស់ខ្លួនក្នុងនាមជាអ្នកកៀសខ្លួនដើម្បីអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ក្រោយមក គេក៏ទទួលមរណៈភាព(ក្នុងពេលធ្វើដំណើរ)នោះ ពិតប្រាកដណាស់ ផលបុណ្យរបស់គេ គឺស្ថិតនៅលើអល់ឡោះ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

101. ហើយនៅពេលដែលពួកអ្នកធ្វើដំណើរនៅលើផែនដីនេះ គឺគ្មានទោសពៃអ្វីឡើយចំពោះពួកអ្នកក្នុងការបង្រួមសឡាត(ដែលមានបួនរ៉ាក្អាត់ មកត្រឹមពីរ៉ាក្អាត់)នោះ ប្រសិនបើពួកអ្នកខ្លាចពួកដែលប្រឆាំងវាយប្រហារមកលើពួកអ្នក។ ពិតប្រាកដណាស់ ពួកដែលប្រឆាំងនោះ ពួកគេគឺជាសត្រូវយ៉ាងច្បាស់លាស់ចំពោះពួកអ្នក។

102. ហើយកាលណាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ស្ថិតក្នុងចំណោមពួកគេ(ក្នុងពេលកំពុងប្រយុទ្ធនឹងសត្រូវ) ហើយអ្នកចង់ដឹកនាំពួកគេសឡាតនោះ ចូរឲ្យមួយក្រុមក្នុងចំណោមពួកគេឈរសេឡាតជាមួយអ្នក ហើយចូរឱ្យពួកគេកាន់អាវុធរបស់ពួកគេ(ជាប់នឹងខ្លួន)។ នៅពេលដែលពួកគេ(ក្រុមទីមួយ)បានស៊ូជោតហើយនោះ ចូរឱ្យពួកគេនៅពីក្រោយខ្នងពួកអ្នក ហើយឱ្យមួយក្រុមទៀតដែលមិនទាន់បានសឡាតនោះ ឱ្យពួកគេចូលមកសឡាតជាមួយអ្នក ហើយចូរឱ្យពួកគេប្រុងប្រយ័ត្ន(ចំពោះសត្រូវ) ព្រមទាំងកាន់អាវុធជាប់នឹងខ្លួនពួកគេ(ជានិច្ច)។ ពួកសត្រូវមានបំណងចង់ឱ្យពួកអ្នកធ្វេសប្រហែសពីសព្វាវុធ និងសម្ភារៈសឹកផ្សេងៗរបស់ពួកអ្នក (ខណៈពេលដែលពួកអ្នកកំពុងសឡាត) ដើម្បីពួកគេវាយសង្គ្រប់មកលើពួកអ្នកតែម្តង។ ហើយគ្មានទោសពៃអ្វីឡើយចំពោះពួកអ្នកដែលមិនកាន់អាវុធជាប់ខ្លួនប្រសិនបើពួកអ្នកជួបនឹងភ្លៀង ឬក៏ពួកអ្នកមានជំងឺនោះ តែពួកអ្នកត្រូវប្រកាន់ការប្រុងប្រយ័ត្ន(ជានិច្ច)។ ពិតប្រាកដណាស់ អល់ឡោះទ្រង់បានរៀបចំសម្រាប់ពួកដែលប្រឆាំងនោះនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

103. ហើយនៅពេលដែលពួកអ្នកបំពេញកាតព្វកិច្ចសឡាតរួចរាល់ហើយនោះ ចូរពួកអ្នករំឭកទៅចំពោះអល់ឡោះទាំងពេលឈរ ពេលអង្គុយ និងនៅពេលដែលពួកអ្នកទម្រេតខ្លួន។ ហើយនៅពេលដែលពួកអ្នកមានភាពនឹងនរឡើងវិញហើយនោះ ចូរពួកអ្នកប្រតិបត្តិសឡាត(ឱ្យបានពេញលេញដូចធម្មតា)។ ពិតប្រាកដណាស់ការសឡាត គឺជាកាតព្វកិច្ចមួយដែលគេបានដាក់ទៅលើបណ្តាអ្នកមានជំនឿដោយមានពេលវេលាកំណត់ច្បាស់លាស់។

104. ហើយចូរពួកអ្នកកុំទន់ខ្សោយក្នុងការប្រយុទ្ធមុខជាមួយនឹងក្រុម(ដែលប្រឆាំង)ឱ្យសោះ។ ប្រសិនបើពួកអ្នកទទួលរងការឈឺចាប់ ពិតប្រាកដណាស់ ពួកគេក៏ទទួលការឈឺចាប់ដូចដែលពួកអ្នកឈឺចាប់ដែរ។ តែពួកអ្នកមានសង្ឃឹមចំពោះអល់ឡោះនូវអ្វីដែលពួកគេមិនមានសង្ឃឹមឡើយ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

105. ពិតប្រាកដណាស់ យើងបានបញ្ចុះគម្ពីរគួរអានឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែលពោរពេញទៅដោយសេចក្តីពិតដើម្បីឱ្យអ្នកកាត់សេចក្តីរវាងមនុស្សលោកទៅតាមអ្វីដែលអល់ឡោះបានបង្រៀនអ្នក។ ហើយចំពោះពួកដែលក្បត់នឹងទំនុកចិត្តនោះ ចូរអ្នកកុំការពារពួកគេឱ្យសោះ។

106. ហើយចូរអ្នកសុំការអភ័យទោសពីអល់ឡោះជាម្ចាស់។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

107. ហើយចូរអ្នកកុំការពារបុគ្គលដែលក្បត់ខ្លួនឯងឱ្យសោះ។ ហើយអល់ឡោះមិនស្រលាញ់ពួកដែលតែងតែក្បត់ និងសាងបាបកម្មនោះឡើយ។

108. ពួកគេអាចលាក់បាំងពីមនុស្សលោកបាន តែពួកគេមិនអាចលាក់បាំងពីអល់ឡោះជាម្ចាស់បានឡើយ ព្រោះទ្រង់នៅជាមួយពួកគេ(ជានិច្ច) ខណៈពេលដែលពួកគេរៀបចំគម្រោងសម្ងាត់នៃពាក្យសម្តីដែលទ្រង់មិនពេញចិត្ត។ ហើយអល់ឡោះទ្រង់ដឹងជ្រួតជ្រាបបំផុតចំពោះអ្វីដែលពួកគេប្រព្រឹត្ត។

109. ពួកអ្នកជាអ្នកដែលបានជួយការពារពួកគេ(ពួកក្បត់)នៅក្នុងជីវិតលោកិយនេះ។ ដូចនេះ តើអ្នកណាដែលអាចការពារពួកគេនៅចំពោះអល់ឡោះជាម្ចាស់នាថ្ងៃបរលោក? ឬមួយមានអ្នកដែលអាចគាំពារពួកគេនាថ្ងៃនោះបាន?!

110. ហើយជនណាដែលបានប្រព្រឹត្តអំពើអាក្រក់អ្វីមួយ ឬបំពានលើខ្លួនឯង ក្រោយមក គេបានសុំការអភ័យទោសពីអល់ឡោះជាម្ចាស់នោះ គេនឹងឃើញថា អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

111. ហើយជនណាដែលបានប្រព្រឹត្តទង្វើបាបកម្ម តាមពិតទណ្ឌកម្មរបស់គេនឹងធ្លាក់ទៅលើខ្លួនឯងប៉ុណ្ណោះ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

112. ហើយជនណាដែលបានប្រព្រឹត្តកំហុសឆ្គង(ដោយអចេតនា) ឬសាងបាបកម្មអ្វីមួយដោយចេតនា ក្រោយមក គេទម្លាក់កំហុសនោះទៅលើអ្នកដែលគ្មានកំហុស ពិតប្រាកដណាស់ គេនឹងស្ពាយនូវការមួលបង្កាច់ និងបាបកម្មយ៉ាងជាក់ច្បាស់។

113. ហើយប្រសិនបើគ្មានការប្រោសប្រទានរបស់អល់ឡោះមកលើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) និងក្តីមេត្តាករុណារបស់ទ្រង់ទេនោះ ប្រាកដជាក្រុមមួយក្នុងចំណោមពួកគេនឹងធ្វើឱ្យអ្នកវង្វេងពីការពិតជាមិនខាន។ ប៉ុន្តែពួកគេមិនបានធ្វើឱ្យ(នរណាម្នាក់)វង្វេងក្រៅតែពីខ្លួនឯងប៉ុណ្ណោះ។ ហើយពួកគេមិនអាចបង្កគ្រោះថ្នាក់ដល់អ្នកបន្តិចណាឡើយ។ ហើយអល់ឡោះបានបញ្ចុះមកឱ្យអ្នកនូវគម្ពីរ(គួរអាន) និងគតិបណ្ឌិត(ស៊ុណ្ណះ) ព្រមទាំងបានបង្រៀនអ្នកនូវអ្វីដែលអ្នកមិនធ្លាប់បានដឹង។ ហើយការប្រោសប្រទានរបស់អល់ឡោះមកចំពោះអ្នក គឺធំធេងបំផុត។

114. ការខ្សឹបខ្សៀវគ្នាច្រើនរវាងពួកគេនោះ គឺមិនមានភាពល្អប្រសើរឡើយ លើកលែងតែអ្នកដែលប្រើឱ្យបរិច្ចាគទាន ឬប្រើគេឱ្យធ្វើអំពើល្អ ឬប្រើឲ្យផ្សះផ្សាគ្នារវាងមនុស្សលោកប៉ុណ្ណោះ។ ហើយជនណាដែលធ្វើដូច្នោះដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះនោះ យើងនឹងប្រទានឱ្យគេនូវផលបុណ្យដ៏ធំធេង។

115. ហើយជនណាដែលបដិសេធនឹងអ្នកនាំសារក្រោយពីការចង្អុលបង្ហាញបានបញ្ជាក់ច្បាស់ដល់គេ ហើយគេនៅតែដើរតាមមាគ៌ាផ្សេងពីមាគ៌ារបស់អ្នកមានជំនឿទៀតនោះ យើងនឹងទុកគេចោលជាមួយអ្វីដែលគេបានជ្រើសរើសនោះ ហើយយើងនឹងបញ្ចូលគេទៅក្នុងឋាននរកជើហាន់ណាំ ។ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

116. ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនអភ័យទោសឱ្យអ្នកដែលធ្វើស្ហីរិក(ពហុទេពនិយម)នឹងទ្រង់ឡើយ តែទ្រង់នឹងអភ័យទោសឲ្យចំពោះបាបកម្មផ្សេងពីនេះចំពោះជនណាដែលទ្រង់មានចេតនា។ ហើយជនណាដែលធ្វើស្ហីរិកនឹងអល់ឡោះនោះ គេពិតជាបានវង្វេងដ៏សែនឆ្ងាយ(ពីមាគ៌ាដ៏ត្រឹមត្រូវ)។

117. ពួកគេមិនបួងសួងសុំពីអ្នកណាផ្សេងក្រៅអល់ឡោះជាម្ចាស់ឡើយ លើកលែងតែរូបបដិមាករប៉ុណ្ណោះ។ ហើយពួកគេក៏មិនបួងសួងសុំពីនរណាក្រៅពីស្តេតនដែលប្រឆាំងនោះដែរ។

118. អល់ឡោះបានដាក់បណ្តាសាវា(ស្តេតន)។ ហើយវាបាននិយាយថា៖ ខ្ញុំពិតជានឹងយកមួយចំណែកជាក់លាក់នៃបណ្តាខ្ញុំបម្រើរបស់ទ្រង់(ឱ្យងាកចេញពីការពិត)ជាមិនខាន។

119. ខ្ញុំប្រាកដជានឹងធ្វើឲ្យពួកគេវង្វេង និងបោកបញ្ឆោតពួកគេ ហើយខ្ញុំប្រាកដជានឹងប្រើពួកគេឱ្យកាត់ស្លឹកត្រចៀកសត្វពាហនៈមិនខានឡើយ ហើយខ្ញុំក៏ប្រាកដជានឹងប្រើឱ្យពួកគេផ្លាស់ប្តូរការបង្កើតរបស់អល់ឡោះផងដែរ។ ជនណាដែលយកស្តេតនធ្វើជាអ្នកគាំពារក្រៅពីអល់ឡោះនោះ ពិតប្រាកដណាស់ គេពិតជានឹងទទួលនូវការខាតបង់មួយយ៉ាងច្បាស់លាស់។

120. វាបានសន្យាជាមួយពួកដែលដើរតាមវា និងបញ្ឆោតពួកគេឱ្យរវើរវាយ។ ហើយស្តេតនមិនបានសន្យាអ្វីជាមួយពួកគេក្រៅពីការបោកបញ្ឆោតនោះឡើយ។

121. ពួកទាំងនោះហើយដែលទីជម្រករបស់ពួកគេ គឺនរកជើហាន់ណាំ ហើយពួកគេគ្មានផ្លូវណាដែលអាចគេចចេញពីវាបាននោះឡើយ។

122. ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសល យើងនឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ដោយពួកគេស្ថិតនៅទីនោះជាអមត:។ ការសន្យារបស់អល់ឡោះគឺជាការពិត ហើយក៏គ្មាននរណាម្នាក់ដែលនិយាយពាក្យពិតជាងអល់ឡោះនោះដែរ។

123. កិច្ចការនោះមិនអាស្រ័យលើការស្រមើស្រមៃរបស់ពួកអ្នក(អ្នកមានជំនឿ)ឡើយ ហើយក៏មិនមែនអាស្រ័យលើការស្រមើស្រមៃរបស់ពួកអះលីគីតាបនោះដែរ។ ជនណាដែលសាងនូវទង្វើអាក្រក់ គេនឹងតបស្នងផលអាក្រក់ដល់ជននោះ ហើយគេនឹងមិនឃើញមានអ្នកគាំពារ និងអ្នកជួយដល់ជននោះក្រៅពីអល់ឡោះឡើយ។

124. ហើយជនណាដែលបានសាងទង្វើកុសល មិនថាបុរសឬស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះ ពិតប្រាកដណាស់ ពួកគេនឹងបានចូលឋានសួគ៌ ហើយពួកគេនឹងមិនត្រូវបានគេបំពានសូម្បីតែបន្តិចនោះឡើយ។

125. ហើយគ្មាននរណាម្នាក់ដែលល្អក្នុងសាសនាជាងអ្នកដែលបានប្រគល់ខ្លួនរបស់គេទៅចំពោះអល់ឡោះ ហើយរូបគេជាមនុស្សល្អ ព្រមទាំងដើរតាមសាសនារបស់ព្យាការីអ៊ីព្រហ៊ីម(សាសនាអ៊ីស្លាម)ដោយចិត្តស្មោះសរនោះឡើយ។ ហើយអល់ឡោះទ្រង់បានជ្រើសយកព្យាការីអ៊ីព្រហ៊ីមធ្វើជាអ្នកជំនិត(របស់ទ្រង់)។

126. ហើយអ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងអ្វីៗដែលមាននៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយអល់ឡោះទ្រង់ជ្រួតជ្រាបលើអ្វីៗទាំងអស់។

127. ហើយពួកគេនឹងសុំអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ឲ្យបកស្រាយអំពីច្បាប់ទាក់ទងទៅនឹងស្ត្រី។ ចូរអ្នកពោលថា៖ អល់ឡោះនឹងបំភ្លឺដល់ពួកអ្នកអំពីរឿងរបស់ពួកនាង ហើយនិងអ្វីដែលគេបានសូត្រប្រាប់ពួកអ្នកនៅក្នុងគម្ពីរគួរអានពាក់ព័ន្ធនឹងក្មេងស្រីកំព្រាទាំងឡាយ ដែលពួកអ្នកមិនបានផ្តល់ឲ្យពួកនាងនូវអ្វីដែលគេបានកំណត់ឲ្យពួកនាង ហើយពួកអ្នកក៏គ្មានបំណងរៀបការជាមួយពួកនាងនោះដែរ។ (ទ្រង់នឹងបំភ្លឺដល់ពួកអ្នកផងដែរ)ពាក់ព័ន្ធនឹងកុមារដែលមានភាពទន់ខ្សោយ និងការដែលពួកអ្នកត្រូវបំពេញកាតព្វកិច្ចចំពោះក្មេងកំព្រាដោយភាពយុត្តិធម៌។ ហើយអ្វីក៏ដោយដែលពួកអ្នកបានធ្វើអំពីប្រការល្អនោះ ពិតប្រាកដណាស់អល់ឡោះទ្រង់ដឹងបំផុតចំពោះវា។

128. ហើយប្រសិនបើស្ត្រី(ជាភរិយា)មានការបារម្ភខ្លាច(កើតមាន)នូវការស្អប់ខ្ពើម ឬការមិនពេញចិត្តចំពោះនាងពីសំណាក់ស្វាមីរបស់នាងនោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេទាំងពីរក្នុងការផ្សះផ្សារ ហើយការផ្សះផ្សារនោះ វាល្អប្រសើរសម្រាប់គេទាំងពីរ(ជាងការលែងលះ)។ ជាការពិតណាស់ ចិត្តរបស់មនុស្សតែងតែមានភាពកំណាញ់។ តែប្រសិនបើពួកអ្នកធ្វើល្អ និងកោតខ្លាចអល់ឡោះនោះ ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

129. ហើយពួកអ្នក(ឱស្វាមីទាំងឡាយ)មិនអាចផ្តល់ភាពយុត្តិធម៌រវាងបណ្តាភរិយាទាំងឡាយនោះឡើយ បើទោះបីជាពួកអ្នកព្យាយាមយ៉ាងណាក៏ដោយ។ តែពួកអ្នកកុំលម្អៀងម្ខាងៗ(ស្រលាញ់ភរិយាណាម្នាក់)ហួសហេតុពេក ដោយពួកអ្នកទុកពួកនាងដូចវត្ថុដែលគេព្យួរចោល។ ហើយប្រសិនបើពួកអ្នកផ្សះផ្សាគ្នា និងកោតខ្លាចអល់ឡោះនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

130. តែប្រសិនបើគេទាំងពីរបែកបាក់គ្នា(លែងលះ)នោះ អល់ឡោះជាម្ចាស់នឹងផ្តល់ឱ្យម្នាក់ៗក្នុងចំណោមគេទាំងពីរមានភាពគ្រប់គ្រាន់ដោយការប្រោសប្រទានរបស់ទ្រង់។ ហើយអល់ឡោះជាម្ចាស់មហាវិសេសវិសាល មហាគតិបណ្ឌិតបំផុត។

131. ហើយអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយពិតណាស់ យើងបានដាក់បទបញ្ជាចំពោះពួកដែលគេផ្តល់គម្ពីរឲ្យមុនពួកអ្នក និងចំពោះពួកអ្នកឲ្យកោតខ្លាចអល់ឡោះ។ តែប្រសិនបើពួកអ្នកប្រឆាំងវិញនោះ ជាការពិតណាស់ អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហើយទ្រង់មហាមានលើសលប់ ជាអ្នកដែលត្រូវគេកោតសរសើរបំផុត។

132. ហើយអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកដែលត្រូវគេផ្តល់ទំនុកចិត្ត។

133. ប្រសិនបើទ្រង់មានចេតនានោះ ទ្រង់នឹងបំផ្លាញពួកអ្នកជាមិនខាន ឱមនុស្សលោកទាំងឡាយ ហើយទ្រង់នឹងបង្កើតក្រុមផ្សេងទៀត(មកជំនួសវិញ)។ ហើយអល់ឡោះទ្រង់មានអានុភាពបំផុតលើរឿងនោះ។

134. ជនណាដែលចង់បានតែផលបុណ្យក្នុងលោកិយនោះ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មានផលបុណ្យទាំងក្នុងលោកិយ និងបរលោក។ ហើយអល់ឡោះមហាឮ មហាឃើញបំផុត។

135. ឱបណ្តាអ្នកដែលមានជំនឿ! ចូរតាំងខ្លួនជាអ្នកដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ក្នុងនាមជាអ្នកធ្វើសាក្សីសម្រាប់អល់ឡោះ សូម្បីតែចំពោះខ្លួនឯង ឬឪពុកម្តាយរបស់ពួកអ្នក ឬសាច់ញាតិពួកអ្នកខ្លួនឯងក៏ដោយ។ បើទោះគេជាអ្នកក្រីក្រ ឬជាអ្នកមានក៏ដោយ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអាទិភាពជាងគេទាំងពីរទៅទៀត។ ដូច្នេះ ចូរពួកអ្នកកុំដើរតាមទំនើងចិត្តដែលធ្វើឲ្យពួកអ្នកឃ្លាតឆ្ងាយពីភាពយុត្តិធម៌។ ហើយប្រសិនបើពួកអ្នកកែប្រែ(ការពិតក្នុងការធ្វើសាក្សី) ឬពួកអ្នកបដិសេធ(មិនព្រមធ្វើសាក្សី)វិញនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

136. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ចូរពួកអ្នកមានជំនឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងគម្ពីរ(គួរអាន)ដែលទ្រង់បានបញ្ចុះទៅលើអ្នកនាំសាររបស់ទ្រង់ ព្រមទាំងគម្ពីរដែលទ្រង់បានបញ្ចុះកាលពីមុន។ ហើយជនណាដែលគ្មានជំនឿលើអល់ឡោះ បណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្តាគម្ពីររបស់ទ្រង់ បណ្តាអ្នកនាំសាររបស់ទ្រង់ ហើយនិងថ្ងៃបរលោកនោះ ជាការពិតណាស់ រូបគេពិតជាបានវង្វេងយ៉ាងឆ្ងាយបំផុត(ពីមាគ៌ាដែលត្រឹមត្រូវ)។

137. ពិតប្រាកដណាស់ អ្នកដែលមានជំនឿ ក្រោយមកពួកគេគ្មានជំនឿ ក្រោយមកពួកគេមានជំនឿវិញ ក្រោយមកទៀត ពួកគេបែរជាគ្មានជំនឿវិញទៀត បន្ទាប់មកពួកគេកាន់តែបន្ថែមនូវភាពគ្មានជំនឿនោះ អល់ឡោះជាម្ចាស់នឹងមិនអភ័យទោសដល់ពួកគេឡើយ ហើយទ្រង់ក៏មិនចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ា(ដ៏ត្រឹមត្រូវ)នោះដែរ។

138. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងដល់ពួកពុតត្បុតថា ពិតប្រាកដណាស់ ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

139. គឺពួកគេដែលយកពួកគ្មានជំនឿធ្វើជាអ្នកគាំពារផ្សេងពីបណ្តាអ្នកដែលមានជំនឿ។ តើពួកគេស្វែងរកភាពខ្លាំងក្លាពីពួកទាំងនោះ(ពួកគ្មានជំនឿ)ឬ? ពិតប្រាកដណាស់ ភាពខ្លាំងក្លាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។

140. ហើយពិតប្រាកដណាស់ ទ្រង់បានបញ្ចុះទៅលើពួកអ្នក(អ្នកមានជំនឿ)នៅក្នុងគម្ពីរ(គួរអាន)ថា៖ ពិតប្រាកដណាស់ នៅពេលដែលពួកអ្នកស្តាប់ឮបណ្តាវាក្យខណ្ឌរបស់អល់ឡោះត្រូវបានគេបដិសេធនិងសើចចំអកចំពោះវានោះ ចូរពួកអ្នកកុំអង្គុយជាមួយពួកគេ លុះត្រាតែពួកគេលើកទៅនិយាយរឿងផ្សេងក្រៅពីរឿងនោះ។ ពិតប្រាកដណាស់ ប្រសិនបើពួកអ្នកបន្តការអង្គុយជាមួយពួកគេ ពួកអ្នកក៏ដូចពួកគេដែរ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងប្រមូលផ្តុំពួកពុតត្បុត និងពួកគ្មានជំនឿជាក់ក្នុងឋាននរកជើហាន់ណាំទាំងអស់គ្នា។

141. គឺពួក(ពុតត្បុត)ដែលកំពុងរង់ចាំមើលនូវអ្វីដែលនឹងកើតឡើងចំពោះពួកអ្នក។ ប្រសិនបើពួកអ្នកទទួលបានជ័យជម្នះពីអល់ឡោះ ពួកគេនិយាយថា៖ តើពួកយើងមិនបានស្ថិតក្នុងចំណោមពួកអ្នកទេឬ? តែនៅពេលដែលពួកគ្មានជំនឿទទួលបានជ័យជម្នះវិញ ពួកគេនិយាយថា៖ តើពួកយើងមិនបានជួយរៀបចំកិច្ចការរបស់ពួកអ្នក និងការពារពួកអ្នកពីបណ្តាអ្នកដែលមានជំនឿទេឬ? ពិតណាស់ អល់ឡោះជាម្ចាស់នឹងកាត់សេចក្តីរវាងពួកអ្នកនៅថ្ងៃបរលោក។ ហើយទ្រង់នឹងមិនឱ្យពួកដែលគ្មានជំនឿមានកស្តតាងណាមួយមកដាក់បន្ទុកលើអ្នកមានជំនឿជាដាច់ខាត។

142. ពិតប្រាកដណាស់ ពួកពុតត្បុតទាំងនោះកំពុងតែបោកបញ្ឆោតអល់ឡោះជាម្ចាស់ ប៉ុន្តែទ្រង់ទៅវិញទេដែលជាអ្នកបោកបញ្ឆោតពួកគេនោះ។ ហើយនៅពេលដែលពួកគេក្រោកឈរសេឡាត គឺពួកគេក្រោកឈរទាំងខ្ជិលច្រអូសក្នុងគោលបំណងចង់ឲ្យមនុស្សលោកឃើញប៉ុណ្ណោះ។ ហើយពួកគេមិនរំឭកចំពោះអល់ឡោះជាម្ចាស់ឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

143. ពួកគេមានការស្ទាក់ស្ទើររវាងក្រុមទាំងពីរនោះ ដោយពួកគេមិនស្ថិតក្នុងចំណោមក្រុមនេះ (ក្រុមអ្នកមានជំនឿ) ហើយក៏មិនស្ថិតក្នុងចំណោមក្រុមនោះ (ក្រុមគ្មានជំនឿ) ដែរ។ ជនណាហើយដែលអល់ឡោះធ្វើឱ្យវង្វេងហើយនោះ គឺអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) នឹងមិនឃើញមានផ្លូវណាមួយសម្រាប់ជននោះឡើយ។

144. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកពួកគ្មានជំនឿនឹងអល់ឡោះធ្វើជាអ្នកគាំពារផ្សេងពីបណ្តាអ្នកមានជំនឿឱ្យសោះ។ តើពួកអ្នកចង់បង្កើតភស្តុតាងដ៏ច្បាស់លាស់មួយសម្រាប់ឱ្យអល់ឡោះដាក់បន្ទុកលើពួកអ្នកឬ?

145. ពិតប្រាកដណាស់ពួកពុតត្បុត គឺស្ថិតនៅបាតក្រោមបង្អស់នៃឋាននរក។ ហើយអ្នក (ព្យាការីមូហាំម៉ាត់) នឹងមិនឃើញមានអ្នកជួយពួកគេនោះឡើយ។

146. លើកលែងតែអ្នកដែលបានសារភាពកំហុស និងកែប្រែ (ទង្វើរបស់ខ្លួន) ហើយប្រកាន់ខ្ជាប់នឹងកិច្ចសន្យា (បទបញ្ជា) របស់អល់ឡោះ ព្រមទាំងមានចិត្តស្មោះសនឹងសាសនារបស់ពួកគេចំពោះអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ពិតណាស់ អ្នកទាំងនោះហើយដែលស្ថិតនៅជាមួយបណ្តាអ្នកមានជំនឿ។ ហើយអល់ឡោះនឹងប្រទានឱ្យបណ្តាអ្នកដែលមានជំនឿនូវផលបុណ្យដ៏ធំធេង។

147. អល់ឡោះជាម្ចាស់មិនត្រូវការដាក់ទណ្ឌកម្មពួកអ្នកនោះទេប្រសិនបើពួកអ្នកបានដឹងគុណ និងមានជំនឿ (ចំពោះទ្រង់) នោះ។ ហើយអល់ឡោះមហាដឹងគុណ មហាជ្រួតជ្រាបបំផុត។

148. អល់ឡោះជាម្ចាស់ទ្រង់មិនពេញចិត្តចំពោះការលាតត្រដាងនូវពាក្យសម្តីអាក្រក់ឡើយ លើកលែងតែអ្នកដែលត្រូវបានគេបំពានប៉ុណ្ណោះ។ ហើយអល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

149. ប្រសិនបើពួកអ្នកបង្ហាញនូវប្រការល្អ ឬលាក់បាំងវា (មិនចង់ឱ្យអ្នកដទៃដឹង) ឬក៏អត់ឱនឱ្យអ្នកដែលបានធ្វើអាក្រក់មកលើខ្លួននោះ ជាការពិតណាស់ អល់ឡោះជាម្ចាស់មហាអធ្យាស្រ័យ និងមានអានុភាពបំផុត។

150. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿនឹងអល់ឡោះ និងបណ្តាអ្នកនាំសាររបស់ទ្រង់ ហើយពួកគេចង់បែងចែករវាងអល់ឡោះ និងអ្នកនាំសារទាំងឡាយរបស់ទ្រង់ ហើយពួកគេនិយាយថា៖ ពួកយើងជឿលើអ្នកនាំសារខ្លះ ហើយបដិសេធអ្នកនាំសារខ្លះទៀត ព្រមទាំងចង់ប្រកាន់យកផ្លូវមួយរវាងប្រការនោះ

151. ពួកទាំងនោះ គឺជាពួកដែលគ្មានជំនឿយ៉ាងពិតប្រាកដ។ ហើយយើងបានរៀបចំសម្រាប់ពួកដែលគ្មានជំនឿនូវទណ្ឌកម្មយ៉ាងអាម៉ាស់បំផុត។

152. រីឯបណ្តាអ្នកដែលមានជំនឿលើអល់ឡោះ និងបណ្តាអ្នកនាំសាររបស់ទ្រង់ ហើយពួកគេមិនបែងចែករវាងនរណាម្នាក់ក្នុងចំណោមពួកគាត់ទេនោះ អ្នកទាំងនោះទ្រង់នឹងប្រទានដល់ពួកគេនូវផលបុណ្យរបស់ពួកគេ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

153. ពួកអះលីគីតាបនឹងសុំឲ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បញ្ចុះគម្ពីរមួយក្បាលពីលើមេឃឲ្យពួកគេ។ ជាការពិតណាស់ ពួកគេបានសុំពីព្យាការីមូសានូវរឿងដែលធំធេងជាងនេះទៅទៀត ដោយពួកគេនិយាយថា៖ សូមអល់ឡោះជាម្ចាស់បង្ហាញខ្លួនឱ្យពួកយើងបានឃើញទ្រង់ផ្ទាល់នឹងភ្នែកផង។ ពេលនោះ រន្ទះក៏បានបាញ់ពួកគេព្រោះតែការបំពានរបស់ពួកគេ។ បន្ទាប់មក ពួកគេបានយករូបសំណាក់កូនគោ(មកគោរពសក្ការៈ)ក្រោយពីកស្តុតាងដ៏ច្បាស់លាស់ជាច្រើនបានមកដល់ពួកគេហើយនោះ។ ក្រោយមក យើងក៏បានអធ្យាស្រ័យ(ដល់ពួកគេ)ចំពោះរឿងនោះទៀត។ ហើយយើងបានប្រទានដល់ព្យាការីមូសានូវសញ្ញាកស្តុតាងដ៏ច្បាស់លាស់។

154. ហើយយើងបានលើកភ្នំតួរដាក់ពីលើពួកគេដោយការដាក់កិច្ចសន្យាយ៉ាងមឹងម៉ាត់ទៅលើពួកគេ។ ហើយយើងបានមានបន្ទូលទៅកាន់ពួកគេថា៖ ចូរពួកអ្នកចូលតាមទ្វារ(ទីក្រុងយេរូសាឡឹម)ដោយឱនក្បាលចុះ។ ហើយយើងក៏បានមានបន្ទូលទៅកាន់ពួកគេទៀតថា៖ ចូរពួកអ្នកកុំបំពាន(ដោយចេញទៅនេសាទ)នៅថ្ងៃសៅរ៍ឱ្យសោះ។ ហើយយើងបានដាក់កិច្ចសន្យាដ៏មឹងម៉ាត់បំផុតទៅលើពួកគេ។

155. (ហើយយើងបានដាក់បណ្តាសាពួកគេ)ដោយសារតែពួកគេបានក្បត់កិច្ចសន្យារបស់ពួកគេ និងដោយសារតែភាពគ្មានជំនឿរបស់ពួកគេចំពោះបណ្តាកស្តុតាងទាំងឡាយរបស់អល់ឡោះ ព្រមទាំងការដែលពួកគេសម្លាប់ព្យាការីជាច្រើនដោយមិនត្រឹមត្រូវ ហើយនិងដោយសារតែពាក្យសម្តីរបស់ពួកគេដែលនិយាយថា៖ ដួងចិត្តរបស់ពួកយើងមានគម្រប(បិទជិត)។ ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់បានបោះត្រាភ្ជិតទៅលើដួងចិត្ត(របស់ពួកគេ)ដោយសារតែការប្រឆាំងរបស់ពួកគេ។ ដូច្នេះ ពួកគេគ្មានជំនឿឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

156. ហើយ(យើងបានដាក់បណ្តាសាពួកគេផងដែរ)ដោយសារតែភាពគ្មានជំនឿរបស់ពួកគេ និងការនិយាយចោទប្រកាន់របស់ពួកគេទៅលើម៉ារយ៉ាំ(នាងម៉ារី)នូវការមួលបង្កាច់យ៉ាងធំធេង(ចោទនាងថាបានប្រព្រឹត្តហ្ស៊ីណា)។

157. ហើយ(យើងក៏បានដាក់បណ្តាសាពួកគេផងដែរ)ដោយសារតែពាក្យសម្តីរបស់ពួកគេដែលនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងបានសម្លាប់ម៉ាសៀហ អ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ (យេស៊ូគ្រីស្ត បុត្ររបស់នាងម៉ារី)ដែលជាអ្នកនាំសាររបស់អល់ឡោះ។ តាមពិត ពួកគេមិនបានសម្លាប់គាត់ ហើយក៏មិនបានចងឆ្កាងគាត់នោះដែរ។ ក៏ប៉ុន្តែ គេ(អល់ឡោះ)បានធ្វើឱ្យបុរសម្នាក់ដូចទៅនឹងព្យាការីអ៊ីសាដល់ពួកគេ។ ពិតប្រាកដណាស់ ពួក(យូដា និងពួកគ្រីស្ទាន)ដែលបានខ្វែងគំនិតគ្នាក្នុងរឿងនោះ ពិតជាស្ថិតក្នុងភាពមន្ទិលសង្ស័យអំពីវា។ ពួកគេមិនបានដឹងច្បាស់អំពីរឿងនេះឡើយ ក្រៅតែពីតាមការស្មានប៉ុណ្ណោះ ហើយពួកគេក៏មិនបានសម្លាប់គាត់(ព្យាការីអ៊ីសា)យ៉ាងច្បាស់ប្រាកដនោះដែរ។

158. ផ្ទុយទៅវិញ អល់ឡោះបានលើកគាត់ទៅកាន់ទ្រង់។ ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

159. ហើយពួកអះលីគីតាប(ទាំងអស់)នឹងមានជំនឿចំពោះគាត់មុនពេលគាត់ទទួលមរណភាព(ក្រោយពីគាត់ត្រឡប់មកផែនដីវិញ)។ ហើយនៅថ្ងៃបរលោក គាត់នឹងធ្វើជាសាក្សីចំពោះពួកគេ។

160. ពិតប្រាកដណាស់ដោយសារតែការបំពានរបស់ពួកយូដានោះ យើងបានដាក់បម្រាមទៅលើពួកគេ(មិនឱ្យទទួលទាន)នូវចំណីអាហារល្អៗមួយចំនួនដែលគេធ្លាប់បានអនុញ្ញាតឱ្យពួកគេ។ ហើយ(ការហាមឃាត់បែបនេះ)ក៏ដោយសារតែការរារាំងរបស់ពួកគេយ៉ាងច្រើនពីមាគ៌ារបស់អល់ឡោះ។

161. ហើយក៏ដោយសារតែការពាក់ព័ន្ធរបស់ពួកគេជាមួយនឹងការប្រាក់ ខណៈដែលគេបានហាមឃាត់ពួកគេមិនឱ្យពាក់ព័ន្ធនឹងវា និងដោយសារតែពួកគេស៊ីទ្រព្យសម្បត្តិអ្នកដទៃដោយខុសច្បាប់។ ហើយយើងបានរៀបចំសម្រាប់ពួកដែលគ្មានជំនឿក្នុងចំណោមពួកគេនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

162. ក៏ប៉ុន្តែបណ្តាអ្នកដែលមានចំណេះដឹងជ្រៅជ្រះក្នុងចំណោមពួកគេ(ពួកយូដា) និងបណ្តាអ្នកមានជំនឿដែលពួកគេមានជំនឿចំពោះអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះទៅឱ្យអ្នក(ព្យាការីមូហាំម៉ាត់) ហើយនិងអ្វី(គម្ពីរទាំងឡាយ)ដែលគេបញ្ចុះ(ទៅឱ្យបណ្តាអ្នកនាំសារទាំងឡាយ)មុនអ្នក ហើយពួកគេប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ព្រមទាំងមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោកទៀតនោះ អ្នកទាំងនោះ យើងនឹងប្រទានឱ្យពួកគេនូវផលបុណ្យដ៏ធំធេង។

163. ពិតប្រាកដណាស់ យើងបានផ្តល់វ៉ាហ៊ីទៅកាន់អ្នក(ព្យាការីមូហាំម៉ាត់)ដូចដែលយើងបានផ្តល់វ៉ាហ៊ីទៅកាន់ព្យាការីនួហ និងព្យាការីជាច្រើនទៀតបន្ទាប់ពីគាត់ផងដែរ។ យើងក៏បានផ្តល់វ៉ាហ៊ីទៅកាន់ព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្មាអែល ព្យាការីអ៊ីស្ហាក ព្យាការីយ៉ាក់កូប ព្រមទាំងបណ្តាកូនចៅរបស់ព្យាការីយ៉ាក់កូប ហើយនិងព្យាការីអ៊ីសា ព្យាការីអៃយ៉ូប ព្យាការីយូនុស ព្យាការីហារូន និងព្យាការីស៊ូឡៃម៉ានផងដែរ។ ហើយយើងបានប្រទានឱ្យព្យាការីហ្សាវូតនូវគម្ពីរហ្សាពួរ។

164. ហើយ(យើងបានបញ្ជូន)បណ្តាអ្នកនាំសារជាច្រើនដោយយើងបាននិទានពីប្រវត្តិរបស់ពួកគាត់ប្រាប់ដល់អ្នក(នៅក្នុងគម្ពីរគួរអាន)កាលពីមុន ហើយ(យើងក៏បានបញ្ជូន)បណ្តាអ្នកនាំសារជាច្រើនទៀតផងដែរដោយយើងមិនបាននិទានពីប្រវត្តិរបស់ពួកគាត់ប្រាប់ដល់អ្នកឡើយ។ ហើយអល់ឡោះបានមានបន្ទូលទៅកាន់ព្យាការីមូសាដោយផ្ទាល់។

165. (យើងបានបញ្ជូន)បណ្តាអ្នកនាំសារជាច្រើនដើម្បីធ្វើជាអ្នកផ្តល់ដំណឹងរីករាយ និងជាអ្នកព្រមានបន្លាច ដើម្បីកុំឱ្យមនុស្សលោកមានលេសតវ៉ាចំពោះអល់ឡោះបន្ទាប់ពី(ទ្រង់បានបញ្ជូន)បណ្តាអ្នកនាំសារហើយនោះ។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

166. ទោះជាពួកយូដាមិនព្រមមានជំនឿលើអ្នកក៏ដោយ ក៏អល់ឡោះទ្រង់ធ្វើសាក្សីចំពោះភាពត្រឹមត្រូវនៃអ្វី(គម្ពីរគួរអាន)ដែលបានបញ្ចុះទៅឱ្យអ្នកដែរ។ ទ្រង់បានបញ្ចុះវាដោយចំណេះដឹងរបស់ទ្រង់។ ហើយបណ្តាម៉ាឡាអ៊ីកាត់ទាំងឡាយក៏បានធ្វើសាក្សីដូចនេះផងដែរ។ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាសាក្សី។

167. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ និងបានរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះនោះ ជាការពិតណាស់ ពួកគេគឺជាពួកដែលវង្វេងដ៏សែនឆ្ងាយបំផុត។

168. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ និងបានបំពាននោះ អល់ឡោះជាម្ចាស់ទ្រង់មិនអភ័យទោសឱ្យពួកគេឡើយ ហើយទ្រង់ក៏មិនចង្អុលបង្ហាញផ្លូវ(ដែលអាចរំដោះពួកគេពីទណ្ឌកម្ម)នោះដែរ។

169. លើកលែងតែផ្លូវ(ដែលនាំទៅកាន់)នរកជើហាន់ណាំប៉ុណ្ណោះដោយពួកគេស្ថិតនៅទីនោះជាអមត:។ ហើយកិច្ចការទាំងនោះគឺមានភាពងាយស្រួលបំផុតចំពោះអល់ឡោះជាម្ចាស់។

170. ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ អ្នកនាំសារ(មូហាំម៉ាត់)ដែលនាំមកនូវសេចក្តីពិតពីព្រះជាម្ចាស់របស់ពួកអ្នកនោះបានមកដល់ពួកអ្នកហើយ។ ហេតុនេះ ចូរពួកអ្នកមានជំនឿ(ចំពោះអ្វីដែលគាត់បាននាំមកចុះ) វាជាការប្រសើរបំផុតសម្រាប់ពួកអ្នក។ តែប្រសិនបើពួកអ្នកប្រឆាំងវិញនោះ ពិតប្រាកដណាស់ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់ និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហើយអល់ឡោះទ្រង់មហាដឹង មហាគតិបណ្ឌិត។

171. ឱពួកអះលីគីតាប! ចូរពួកអ្នកកុំជ្រុលនិយម(បំពានព្រំដែនកំណត់)ក្នុងសាសនារបស់ពួកអ្នក ហើយចូរពួកអ្នកកុំនិយាយចោទប្រកាន់ទៅលើអល់ឡោះ ក្រៅពីការពិតឱ្យសោះ។ តាមពិត ម៉ាសៀហ អ៊ីសាកូនប្រុសរបស់ម៉ារយ៉ាំ គឺជាអ្នកនាំសារម្នាក់របស់អល់ឡោះ និងជាពាក្យបន្ទូលរបស់ទ្រង់ដែលបានបញ្ជូនទៅកាន់ម៉ារយ៉ាំ(នាងម៉ារី) ព្រមទាំងជាវិញ្ញាណមួយពីទ្រង់(ដែលម៉ាឡាអ៊ីកាត់ជីព្រីលបានផ្លុំទៅតាមបទបញ្ជារបស់ទ្រង់)។ ហេតុនេះ ចូរពួកអ្នកមានជំនឿចំពោះអល់ឡោះ និងបណ្តាអ្នកនាំសាររបស់ទ្រង់ ហើយពួកអ្នកមិនត្រូវនិយាយថា "ព្រះមានបី"(ព្រះត្រីឯក)នោះឡើយ។ ចូរពួកអ្នកបញ្ឈប់(ការនិយាយពាក្យនេះ) វាជាការប្រសើរសម្រាប់ពួកអ្នក។ តាមពិត អល់ឡោះគឺជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈតែមួយគត់។ ទ្រង់មហាបរិសុទ្ធពីការមានបុត្រ។ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងអ្វីៗដែលមាននៅលើផែនដីគឺជាកម្មសិទ្ធិរបស់ទ្រង់។ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាអ្នកគាំពារ។

172. អាល់ម៉ាសៀហ(ព្យាការីអ៊ីសា)មិនដែលបដិសេធថា រូបគាត់ជាខ្ញុំបម្រើរបស់អល់ឡោះជាម្ចាស់នោះឡើយ ហើយបណ្តាម៉ាឡាអ៊ីកាត់ដែលជាអ្នកជំនិត(របស់អល់ឡោះ)ក៏ដូចគ្នាដែរ។ ជនណាហើយដែលបដិសេធនឹងការគោរពសក្ការៈចំពោះទ្រង់ និងមានភាពក្អេងក្អាង(មិនព្រមគោរពសក្ការៈចំពោះទ្រង់)នោះ ពិតប្រាកដណាស់ ទ្រង់នឹងប្រមូលផ្តុំពួកគេទៅកាន់ទ្រង់ទាំងអស់គ្នា។

173. រីឯបណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលវិញនោះ ទ្រង់នឹងប្រទានដល់ពួកគេនូវផលបុណ្យ(ចំពោះទង្វើ)របស់ពួកគេ ហើយទ្រង់នឹងបន្ថែមដល់ពួកគេថែមទៀតដោយក្តីសប្បុរសរបស់ទ្រង់។ រីឯពួកដែលបានបដិសេធ និងមានភាពក្អេងក្អាង(មិនព្រមគោរពសក្ការៈចំពោះទ្រង់)នោះ ជាការពិតណាស់ ទ្រង់នឹងដាក់ទណ្ឌកម្មពួកគេយ៉ាងឈឺចាប់បំផុត។ ហើយពួកគេនឹងមិនឃើញមានអ្នកគាំពារ និងអ្នកជួយណាសម្រាប់ពួកគេក្រៅពីអល់ឡោះឡើយ។

174. ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ កស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ពួកអ្នក(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកអ្នកហើយ។ ហើយយើងបានបញ្ចុះទៅកាន់ពួកអ្នកនូវពន្លឺដ៏ច្បាស់លាស់បំផុត(គម្ពីរគួរអាន)។

175. រីឯបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ ហើយពួកគេប្រកាន់ខ្ជាប់នឹងវា(គម្ពីរគួរអាន) ពិតប្រាកដណាស់ ទ្រង់នឹងបញ្ចូលពួកគេទៅក្នុងក្តីមេត្តាករុណា(ឋានសួគ៌)និងការប្រោសប្រទានពីទ្រង់។ ហើយទ្រង់នឹងចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

176. ពួកគេនឹងសុំឱ្យអ្នកបកស្រាយច្បាប់(ក្នុងរឿងមរតក "សពគ្មានញាតិដូរខ្សែផ្ចាល់")។ ចូរអ្នកពោលចុះថា៖ អល់ឡោះនឹងបកស្រាយច្បាប់ស្តីពីបញ្ហាមរតកសពគ្មានញាតិដូរខ្សែផ្ចាល់នេះដល់ពួកអ្នកគឺ ប្រសិនបើបុគ្គលម្នាក់បានស្លាប់ដោយគេគ្មានកូន តែគេមានបងប្អូនស្រីម្នាក់ ដូច្នេះ នាងត្រូវទទួលបានមរតកពាក់កណ្តាលនៃទ្រព្យសម្បត្តិដែលសពបានបន្សល់ទុក។ ចំណែកឯបងប្អូនប្រុសរបស់សពម្នាក់ត្រូវទទួលមរតកពីទ្រព្យសម្បត្តិនោះក្នុងលក្ខណៈមិនកំណត់ចំនួននោះឡើយប្រសិនបើសពគ្មានកូន។ ហើយប្រសិនបើសពនោះមានបងប្អូនស្រីលើសពីពីរនាក់ឡើងទៅ គឺសម្រាប់ពួកនាងត្រូវទទួលបានពីរភាគបីនៃមរតក(រួមគ្នា)ដែលសពបានបន្សល់ទុក។ តែប្រសិនបើសពនោះមានបងប្អូនច្រើននាក់ មានទាំងប្រុសទាំងស្រីដូចនេះសម្រាប់បុរសម្នាក់គឺទទួលបានចំណែកស្មើនឹងចំណែកស្ត្រីពីរនាក់។ អល់ឡោះទ្រង់បញ្ជាក់ដល់ពួកអ្នកដើម្បីកុំឱ្យពួកអ្នកវង្វេង។ ហើយអល់ឡោះទ្រង់មហាដឹងនូវរាល់អ្វីៗទាំងអស់។

ជំពូក អាល់ម៉ាអ៊ីដះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ចូរពួកអ្នកអនុវត្តតាមកិច្ចសន្យាទាំងឡាយ(របស់ពួកអ្នក)។ គេបានអនុញ្ញាតដល់ពួកអ្នកអាចបរិភោគសាច់សត្វ៣ហាន:ទាំងឡាយ(សត្វអូដ្ឋ គោ និងពពែ) លើកលែងតែអ្វីដែលគេនឹងសូត្រប្រាប់ដល់ពួកអ្នក ហើយនិងការបរបាញ់សត្វលើគោកក្នុងពេលដែលពួកអ្នកកំពុងតែស្ថិតក្នុងតំណមអៀហរ៉ាម។ ពិតប្រាកដណាស់ អល់ឡោះទ្រង់កាត់សេចក្តីទៅតាមអ្វីដែលទ្រង់មានចេតនា។

2. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ចូរពួកអ្នកកុំល្មើសនឹងអត្តសញ្ញាណទាំងឡាយរបស់អល់ឡោះ។ ហើយចូរពួកអ្នកកុំបំពានក្នុងបណ្តាខែពិសិដ្ឋ(ដោយការធ្វើសង្គ្រាម) កុំល្មើសចំពោះសត្វជំនូន និងសត្វដែលមានពាក់ប្រឡោក ហើយក៏មិនត្រូវបំពានចំពោះអ្នកទាំងឡាយណាដែលមានបំណងមកពែតុលហារ៉ាមដើម្បីស្វែងរកការប្រោសប្រទាន និងការពេញចិត្តពីព្រះជាម្ចាស់របស់ពួកគេនោះដែរ។ នៅពេលណាដែលពួកអ្នកបានបញ្ចប់តំណមអៀហរ៉ាមហើយនោះ គឺពួកអ្នកអាចបរបាញ់សត្វបាន។ ហើយចូរពួកអ្នកកុំបណ្តោយឱ្យការស្អប់ខ្ពើមចំពោះក្រុមមួយដែលរារាំងពួកអ្នកពីម៉ាស្ជិតអាល់ហារ៉ាមនោះ ធ្វើឱ្យពួកអ្នកបំពានឱ្យសោះ។ ហើយចូរពួកអ្នក(ឱបណ្តាពួកដែលមានជំនឿ)សហការគ្នាក្នុងការធ្វើនូវទង្វើល្អ និងការកោតខ្លាចអល់ឡោះ តែមិនត្រូវសហការគ្នាលើអំពើបាប និងភាពជាសត្រូវនឹងគ្នាឡើយ។ ចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

3. គេ(អល់ឡោះ)បានដាក់បម្រាមទៅលើពួកអ្នក(មិនឱ្យបរិភោគ)សត្វស្លាប់ដោយមិនបានសំឡេះ ឈាម សាច់ជ្រូក និងសត្វដែលគេព្រឹកនាមអ្នកផ្សេងក្រៅពីព្រះនាមអល់ឡោះ(នៅពេលសំឡេះ) សត្វស្លាប់ដោយត្រូវគេវាតក សត្វស្លាប់ដោយការវាយ សត្វស្លាប់ដោយធ្លាក់ពីទីខ្ពស់ សត្វស្លាប់ដោយការជល់គ្នា និងសត្វដែលត្រូវសត្វសាហាវខាំ លើកលែងតែពួកអ្នកសំឡេះវាទាន់(មុននឹងវាស្លាប់) ហើយនិងសត្វដែលគេសំឡេះសម្រាប់សែនចំពោះបដិមា។ (ហើយគេក៏ហាមឃាត់ផងដែរចំពោះ)ការទស្សន៍ទាយដោយប្រើព្រួញផ្សងសំណាង។ ទាំងនោះ គឺជាអំពើល្មើស(ចំពោះអល់ឡោះ)។ ថ្ងៃនេះ ពួកគ្មានជំនឿបានអស់សង្ឃឹមពីសាសនារបស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកុំខ្លាចពួកគេឱ្យសោះ តែពួកអ្នកត្រូវកោតខ្លាចយើងវិញ។ នៅក្នុងថ្ងៃនេះដែរ យើងបានបំពេញសាសនារបស់ពួកអ្នកឱ្យពួកអ្នក ហើយយើងបានបង្ក្រប់ឧបការគុណរបស់យើងដល់ពួកអ្នក និងបានពេញចិត្តជ្រើសយកអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក។ ចំពោះជនណាដែលកាល:ទេស:បង្ខំឱ្យបរិភោគសត្វស្លាប់ព្រោះតែភាពស្រេកឃ្លាន ដោយគេគ្មានបំណងប្រព្រឹត្តបាបកម្មទេនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

4. ពួកគេ(មិត្តភក្តិរបស់អ្នក)នឹងសួរអ្នកថា៖ តើអ្វីខ្លះដែលគេអនុញ្ញាតឱ្យពួកគេ(អាចបរិភោគបាន)? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ អល់ឡោះជាម្ចាស់ទ្រង់អនុញ្ញាតឱ្យពួកអ្នកនូវចំណីអាហារដែលល្អៗ និង(អនុញ្ញាត)ឱ្យបរិភោគសត្វទាំងឡាយដែលទទួលបានពីសត្វប្រមាញ់ដែលពួកអ្នកបង្ហាត់វាឱ្យចេះចាប់សត្វតាមបែបបទដែលអល់ឡោះបានបង្រៀនពួកអ្នក។ ដូចនេះ ចូរពួកអ្នកបរិភោគចុះនូវអ្វីដែលសត្វប្រមាញ់ចាប់បានឱ្យពួកអ្នក ហើយចូរពួកអ្នករំឭកព្រះនាមអល់ឡោះ(សូត្រពីសមិលឡះ)ទៅលើសត្វនោះចុះ។ ចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាអ្នកដែលជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

5. ថ្ងៃនេះ គេ(អល់ឡោះ)បានអនុញ្ញាតឲ្យពួកអ្នកនូវចំណីអាហារដែលល្អៗ។ ចំណីអាហារពួកអះលីគីតាបត្រូវបានអនុញ្ញាតឲ្យពួកអ្នក ហើយចំណីអាហារពួកអ្នក ក៏ត្រូវបានអនុញ្ញាតឱ្យពួកគេ(ដូចគ្នាដែរ)។ ហើយគេអនុញ្ញាតឲ្យពួកអ្នកអាចរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីដែលមានភាពស្អាតស្អំក្នុងចំណោមបណ្តាស្ត្រីដែលមានជំនឿ និងបណ្តាស្ត្រីដែលមានភាពស្អាតស្អំក្នុងចំណោមបណ្តាស្ត្រីនៃពួកដែលគេផ្តល់គម្ពីរឲ្យមុនពួកអ្នក(ពួកអះលីគីតាប) ប្រសិនបើពួកអ្នកបានផ្តល់ប្រាក់ខាន់ស្លាដល់ពួកនាង ខណៈដែលពួកអ្នកជាមនុស្សស្អាតស្អំ ពុំមែនក្នុងគោលបំណងយកពួកនាងធ្វើជាស្រីកំណាន់នោះទេ។ ហើយជនណាដែលប្រឆាំងនឹងសេចក្តីជំនឿនោះ ពិតប្រាកដណាស់ ទង្វើរបស់គេនឹងត្រូវក្លាយជាអសារបង់ ហើយនៅថ្ងៃបរលោក រូបគេនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់។

6. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! នៅពេលដែលពួកអ្នកមានបំណងចង់ប្រតិបត្តិសឡាត ចូរពួកអ្នកលាងមុខរបស់ពួកអ្នក និងដៃទាំងពីររបស់ពួកអ្នករហូតដល់កែងដៃ ហើយចូរពួកអ្នកជូតក្បាល និងលាងជើងទាំងពីររហូតដល់ភ្នែកគោល។ តែប្រសិនបើពួកអ្នកមានជូនុបវិញនោះ ពួកអ្នកត្រូវងូតទឹក(ជូនុប)។ ហើយប្រសិនបើពួកអ្នកមានជំងឺ ឬស្ថិតក្នុងការធ្វើដំណើរ ឬនរណាម្នាក់ក្នុងចំណោមពួកអ្នកបានបន្ទោបង់ ឬប៉ះពាល់(រួមដំណេក)ជាមួយស្ត្រី តែពួកអ្នកគ្មានទឹក(ដើម្បីជម្រះសម្អាត)ទេនោះ ចូរពួកអ្នកតាយ៉ាំមុមនឹងដីស្អាត ដោយពួកអ្នកត្រូវជូតមុខ និងដៃទាំងពីរ(ត្រឹមកដៃ)របស់ពួកអ្នកនឹងដីនោះចុះ។ អល់ឡោះជាម្ចាស់ទ្រង់មិនចង់ធ្វើឱ្យពួកអ្នកមានការលំបាកឡើយ ក៏ប៉ុន្តែទ្រង់ចង់ជម្រះសម្អាតពួកអ្នក និងដើម្បីជាការបំពេញនូវឧបការគុណរបស់ទ្រង់ចំពោះពួកអ្នក សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

7. ហើយចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់អល់ឡោះចំពោះពួកអ្នក និង(នឹកឃើញ)កិច្ចសន្យារបស់ទ្រង់ដែលបានសន្យាជាមួយពួកអ្នក ខណៈដែលពួកអ្នកបាននិយាយថា៖ ពួកយើងបានឮហើយ និងបានគោរពប្រតិបត្តិតាមហើយ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលមាននៅក្នុងដួងចិត្ត។

8. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកតាំងខ្លួនជាអ្នកដែលប្រកាន់ខ្ជាប់នឹងកាតព្វកិច្ចទាំងឡាយរបស់អល់ឡោះ និងតាំងខ្លួនជាសាក្សីដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌។ ហើយចូរកុំបណ្តោយឱ្យការស្អប់ខ្ពើមចំពោះក្រុមមួយធ្វើឱ្យពួកអ្នកបោះបង់នូវភាពយុត្តិធម៌ឱ្យសោះ។ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ព្រោះវាជិតបំផុតទៅកាន់ការកោតខ្លាច។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

9. អល់ឡោះជាម្ចាស់បានសន្យាចំពោះបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលនូវការអភ័យទោស និងផលបុណ្យដ៏ធំធេងបំផុត។

10. រីឯពួកដែលគ្មានជំនឿ ព្រមទាំងបានបដិសេធនឹងបណ្តាកស្តុតាងទាំងឡាយរបស់យើងវិញនោះ ពួកទាំងនោះហើយគឺជាពួកនរកជើហ្មឹម។

11. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ចូរពួកអ្នកនឹកឃើញដល់ឧបការគុណទាំងឡាយរបស់អល់ឡោះ(ដែលទ្រង់បានប្រទាន)ដល់ពួកអ្នក នៅពេលដែលក្រុមមួយមានបំណងវាយប្រហារពួកអ្នកដោយដៃរបស់ពួកគេ តែអល់ឡោះបានរារាំងដៃពួកគេពីពួកអ្នក។ ចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ហើយចូរឱ្យបណ្តាអ្នកដែលមានជំនឿទាំងឡាយប្រគល់ការទុកចិត្តលើអល់ឡោះចុះ។

12. ហើយជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានដាក់កិច្ចសន្យាយ៉ាងមុឺងម៉ាត់ទៅលើអម្បូរអ៊ីស្រាអែល ហើយយើងបានចាត់តាំងមនុស្សចំនួនដប់ពីរនាក់ក្នុងចំណោមពួកគេធ្វើជាមេដឹកនាំ។ អល់ឡោះបានមានបន្ទូលថា៖ ពិតប្រាកដណាស់ យើងនៅជាមួយពួកអ្នក(ដោយការជួយនិងការគាំពារ)។ ប្រសិនបើពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយមានជំនឿចំពោះបណ្តាអ្នកនាំសារទាំងឡាយរបស់យើង និងលើកតម្កើងពួកគេ ព្រមទាំងពួកអ្នកបានឲ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ប្រសើរនោះ យើងពិតជានឹងលុបបំបាត់នូវអំពើអាក្រក់ទាំងឡាយរបស់ពួកអ្នក ហើយយើងប្រាកដជានឹងបញ្ចូលពួកអ្នកទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ដូច្នេះ ជនណាហើយក្នុងចំណោមពួកអ្នកដែលបានប្រឆាំងបន្ទាប់ពីនោះ ពិតប្រាកដណាស់ រូបគេពិតជាបានវង្វេងចេញពីមាគ៌ាដ៏ត្រឹមត្រូវ។

13. ជាការពិតណាស់ ដោយសារតែការក្បត់កិច្ចសន្យារបស់ពួកគេនោះហើយ ទើបយើងបានដាក់បណ្តាសាពួកគេ ហើយយើងបានធ្វើឱ្យដួងចិត្តរបស់ពួកគេភ្លាយទៅជារឹងរូស។ ពួកគេបានកែប្រែបន្ទូលរបស់អល់ឡោះចេញពីអត្ថន័យដើមរបស់វា ព្រមទាំងបានភ្លេច(បោះបង់)នូវកាតព្វកិច្ចមួយចំនួននៃអ្វីដែលគេបានរំឭកពួកគេអំពីវា។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នៅតែឃើញទង្វើក្បត់កើតចេញពីពួកគេ លើកលែងតែមួយចំនួនតូចក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហេតុនេះ ចូរអ្នកអភ័យទោស និងអធ្យាស្រ័យដល់ពួកគេចុះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលធ្វើល្អ។

14. ហើយយើងក៏បានដាក់កិច្ចសន្យាទៅលើពួកដែលនិយាយថា ពិតណាស់ ពួកយើងគឺជាណាស់រ៉ា(សាវ័កព្យាការីអ៊ីសា)ផងដែរ តែពួកគេបានភ្លេច(បោះបង់)នូវកាតព្វកិច្ចមួយចំនួននៃអ្វីដែលគេបានរំឭកពួកគេអំពីវា។ ហើយយើងបានធ្វើឱ្យកើតមាននូវភាពជាសត្រូវ និងការស្អប់ខ្ពើមគ្នាយ៉ាងខ្លាំងរវាងពួកគេរហូតដល់ថ្ងៃបរលោក។ ហើយអល់ឡោះជាម្ចាស់នឹងប្រាប់ពួកគេនូវអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

15. ឱពួកអះលីគីតាប! ពិតប្រាកដណាស់ អ្នកនាំសាររបស់យើង(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកអ្នកដោយគាត់បានបកស្រាយបញ្ជាក់នូវរឿងរ៉ាវជាច្រើនប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានលាក់បាំងពីគម្ពីរ ហើយគាត់ក៏បានអធ្យាស្រ័យយ៉ាងច្រើនផងដែរ។ ពិតប្រាកដណាស់ ពន្លឺមួយ និងជាគម្ពីរមួយដែលបញ្ជាក់យ៉ាងច្បាស់មកពីអល់ឡោះនោះ គឺបានមកដល់ពួកអ្នកហើយ។

16. អល់ឡោះទ្រង់ចង្អុលបង្ហាញតាមរយៈវា(គម្ពីរគួរអាន)ចំពោះជនណាដែលដើរតាមអ្វីដែលទ្រង់ពេញចិត្តឆ្ពោះទៅកាន់មាគ៌ាទាំងឡាយណាដែលមានសន្តិភាព ហើយទ្រង់នឹងបញ្ចេញពួកគេពីភាពងងឹតសូន្យសុងទៅកាន់ពន្លឺដោយការអនុញ្ញាតរបស់ទ្រង់ ព្រមទាំងចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

17. ជាការពិតណាស់ ពិតជាភ្លាយជាពួកគ្មានជំនឿហើយ អ្នកដែលនិយាយថា៖ អល់ឡោះ គឺជាអាល់ម៉ាសៀហ អ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ នោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើអ្នកណាដែលមានសមត្ថភាពអាចរារាំងអល់ឡោះបានប្រសិនបើទ្រង់មានចេតនាចង់បំផ្លាញអាល់ម៉ាសៀហកូនប្រុសរបស់ម៉ារយ៉ាំ និងម្តាយរបស់គាត់ ព្រមទាំងអ្នកដែលនៅលើផែនដីទាំងអស់នោះ? ហើយការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី ព្រមទាំងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរគឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ទ្រង់បង្កើតអ្វីមួយតាមដែលទ្រង់មានចេតនា។ ហើយអល់ឡោះទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

18. ទាំងពួកយូដា និងពួកគ្រីស្ទានសុទ្ធតែបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងគឺជាបុត្ររបស់អល់ឡោះ និងជាសំណព្វចិត្តរបស់ទ្រង់។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ (បើដូច្នោះមែន)ចុះហេតុអ្វីបានជាទ្រង់ដាក់ទណ្ឌកម្មពួកអ្នកព្រោះតែបាបកម្មរបស់ពួកអ្នក? ផ្ទុយទៅវិញ ពួកអ្នកគ្រាន់តែជាមនុស្សលោកធម្មតាដូចគេឯងប៉ុណ្ណោះ។ ទ្រង់អភ័យទោសដល់ជនណាដែលទ្រង់មានចេតនា ហើយដាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា។ ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី ព្រមទាំងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយចំពោះទ្រង់(តែមួយគត់)ជាកន្លែងដែលត្រូវវិលត្រឡប់។

19. ឱពួកអះលីគីតាប! ជាការពិតណាស់ អ្នកនាំសាររបស់យើង(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកអ្នកដើម្បីបញ្ជាក់ដល់ពួកអ្នក ក្រោយពីបានដាច់មួយរយៈពេលនូវការបញ្ឈប់បណ្តាអ្នកនាំសារ ដើម្បីកុំឱ្យពួកអ្នកនិយាយដោះសាថា៖ គ្មានអ្នក(នាំសារដែល)ផ្តល់ដំណឹងរីករាយ និងព្រមានបន្លាចបានមកដល់ពួកយើងនោះទេ។ ជាការពិតណាស់ (ឥឡូវនេះ) អ្នកដែលផ្តល់ដំណឹងរីករាយ និងជាអ្នកព្រមានបន្លាច(ពោលគឺអ្នកនាំសារមូហាំម៉ាត់)នោះបានមកដល់ពួកអ្នកហើយ។ ហើយអល់ឡោះទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

20. ហើយចូរអ្នកនឹកឃើញ(ឱអ្នកនាំសារមូហាំម៉ាត់) នៅពេលដែលព្យាការីមូសាបាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់អល់ឡោះ(ដែលទ្រង់បានប្រទាន)ដល់ពួកអ្នក ខណៈដែលទ្រង់បានចាត់បញ្ជូននូវបណ្តាព្យាការីជាច្រើនពីក្នុងចំណោមពួកអ្នក និងបានចាត់តាំងពួកអ្នកឲ្យធ្វើជាអ្នកគ្រប់គ្រង ព្រមទាំងបានប្រទានឱ្យពួកអ្នកនូវអ្វីដែលទ្រង់មិនដែលប្រទានឱ្យនរណាម្នាក់នៅលើពិភពលោក(នៅក្នុងសម័យកាលនេះ)ឡើយ។

21. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកចូលទៅកាន់ទឹកដីដ៏ស្អាតស្អំ(ក្រុងយេរូសាឡឹម)ដែលអល់ឡោះបានកត់ត្រា(សន្យា)ចំពោះពួកអ្នកចុះ ហើយចូរពួកអ្នកកុំចុះចាញ់នៅចំពោះមុខពួកផ្តាច់ការឱ្យសោះ ជាហេតុធ្វើឱ្យពួកអ្នកក្លាយជាពួកដែលខាតបង់។

22. ពួកគេបានតបថា៖ ឱមូសា! ជាការពិតណាស់ នៅក្នុងទឹកដីនេះ គឺមានមនុស្សមួយក្រុមដែលខ្លាំងពូកែ(ដែលរារាំងពួកយើងមិនឱ្យចូល)។ ដូច្នេះ ពួកយើងនឹងមិនចូលទៅកាន់ទីនោះជាដាច់ខាត លុះត្រាតែពួកគេចាកចេញពីទីនោះសិន។ ប្រសិនបើពួកគេចាកចេញពីទីនោះ ពួកយើងពិតជានឹងចូលទៅ។

23. មានបុរសពីរនាក់ក្នុងចំណោមអ្នកដែលកោតខ្លាច(ចំពោះអល់ឡោះ)ដែលអល់ឡោះបានប្រទានឧបការគុណដល់គេទាំងពីរបាននិយាយថា៖ ចូរពួកអ្នកសម្រុកចូលទៅកាន់ពួកគេតាមទ្វារ(ក្រុងចុះ)។ នៅពេលដែលពួកអ្នកបានចូលដល់ក្នុងហើយនោះ ពិតណាស់ពួកអ្នកនឹងទទួលបានជ័យជម្នះជាមិនខាន។ ហើយចូរពួកអ្នកប្រគល់ការទុកចិត្តលើអល់ឡោះចុះ ប្រសិនបើពួកអ្នកគឺជាអ្នកដែលមានជំនឿមែននោះ។

24. ពួកគេនិយាយថា៖ ឱមូសា!ពិតប្រាកដណាស់ ពួកយើងនឹងមិនចូលក្នុងក្រុងនេះជាដាច់ខាត ដរាបណាពួកគេនៅទីនោះ។ ហេតុនេះ ចូរអ្នក និងព្រះជាម្ចាស់របស់អ្នកចូលទៅ ហើយចូរអ្នកទាំងពីរប្រយុទ្ធ(នឹងពួកទាំងនោះ)ចុះ។ ពិតប្រាកដណាស់ ពួកយើងអង្គុយនៅទីនេះហើយ។

25. គាត់(ព្យាការីមូសា)បានពោលថា៖ បពិត្រព្រះជាម្ចាស់! រូបខ្ញុំគ្មានអំណាចគ្រប់គ្រងអ្វីក្រៅពីខ្លួនឯង និងបងប្រុសរបស់ខ្ញុំ(ព្យាការីហារូន)នោះឡើយ។ ហេតុនេះ សូមព្រះអង្គមេត្តាបំបែករវាងពួកយើងនិងក្រុមដែលប្រព្រឹត្តល្មើសផងចុះ។

26. ទ្រង់បានតបថា៖ ពិតប្រាកដណាស់ ទឹកដីដ៏ស្អាតស្អំនេះត្រូវបានហាមឃាត់ចំពោះពួកគេរយៈពេលសែសិបឆ្នាំ។ ពួកគេនឹងវង្វេង(គ្មានគោលដៅ)នៅលើផែនដី។ ហេតុនេះ ចូរអ្នកកុំព្រួយបារម្ភចំពោះក្រុមប្រព្រឹត្តល្មើសឲ្យសោះ។

27. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)និទានប្រាប់ពួកគេ(ពួកយូដា)ពីរឿងរ៉ាវកូនប្រុសទាំងពីររបស់ព្យាការីអាដាំ(គឺកាពិល និងហាពិល)ដោយពិតប្រាកដ ខណៈដែលគេទាំងពីរបានធ្វើគួរបូជា(តង្វាយទៅកាន់អល់ឡោះ)។ ពេលនោះ គេបានទទួលយក(ការធ្វើគួរបូជា)ពីមនុស្សម្នាក់ក្នុងចំណោមគេទាំងពីរ(ហាពិល) តែគេមិនទទួលយកពីម្នាក់ទៀត(កាពិល)ឡើយ។ កាពិលបាននិយាយថា៖ ខ្ញុំប្រាកដជានឹងសម្លាប់ឯង។ ហាពិលបានតបវិញថា៖ តាមពិតអល់ឡោះជាម្ចាស់ទ្រង់ទទួលយកតែពីអ្នកដែលកោតខ្លាចប៉ុណ្ណោះ។

28. ប្រសិនបើអ្នកលើកដៃរបស់អ្នកសម្លាប់ខ្ញុំនោះ ខ្ញុំនឹងមិនលើកដៃរបស់ខ្ញុំសម្លាប់អ្នកវិញនោះឡើយ។ ពិតប្រាកដណាស់ ខ្ញុំកោតខ្លាចអល់ឡោះជាព្រះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់។

29. ពិតណាស់ ខ្ញុំចង់ឱ្យបាបកម្មរបស់ខ្ញុំនិងបាបកម្មរបស់អ្នកធ្លាក់ទៅលើអ្នកដែលជាហេតុធ្វើឲ្យអ្នកស្ថិតក្នុងចំណោមពួកឋាននរក។ ហើយនោះគឺជាការតបស្នងចំពោះពួកដែលបំពាន។

30. ពេលនោះ តណ្ហារបស់គេ(កាពិល)បានអូសទាញរូបគេឱ្យសម្លាប់ប្អូនប្រុសរបស់ខ្លួន(ហាពិល)។ ពេលនោះ គេក៏បានសម្លាប់គាត់ ហើយគេក៏ក្លាយទៅជាអ្នកដែលស្ថិតក្នុងចំណោមពួកដែលខាតបង់។

31. ក្រោយមក អល់ឡោះជាម្ចាស់ក៏បានបញ្ជូនសត្វក្អែកមួយក្បាលឱ្យមកកកាយដី (នៅនឹងមុខកពេល) ដើម្បីឱ្យគេឃើញពីរបៀបបិទបាំងខ្លួនប្រាណ (បញ្ចៃះសព) ប្អូនប្រុសរបស់គេ។ គេក៏និយាយថា៖ ឱអនិច្ចារូបខ្ញុំ! ហេតុអ្វីបានជាខ្ញុំអសមត្ថភាពមិនអាចធ្វើដូចសត្វក្អែកនេះដើម្បីបិទបាំងខ្លួនប្រាណ (បញ្ចៃះសព) ប្អូនប្រុសរបស់ខ្ញុំ? ពេលនោះរូបគេក៏ក្លាយទៅជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលមានវិប្បដិសារី។

32. ដោយមូលហេតុនោះហើយទើបយើងបានប្រាប់ដល់អម្បូរអ៊ីស្រាអែលឱ្យបានដឹងថា ជាការពិតណាស់ ជនណាហើយដែលបានសម្លាប់បុគ្គលណាម្នាក់ដោយខុសច្បាប់ ឬបានបង្កវិនាសកម្មនៅលើផែនដី គឺរូបគេហាក់បីដូចជាបានសម្លាប់មនុស្សលោកទាំងអស់ ហើយជនណាដែលសង្គ្រោះជីវិតបុគ្គលម្នាក់ ហាក់បីដូចជាគេបានសង្គ្រោះជីវិតមនុស្សលោកទាំងអស់ដូច្នោះដែរ។ ហើយជាការពិតណាស់ បណ្តាអ្នកនាំសាររបស់យើងបានមកដល់ពួកគេ (អម្បូរអ៊ីស្រាអែល) ដោយនាំមកនូវភស្តុតាងដ៏ច្បាស់លាស់ជាច្រើន។ តែទោះជាយ៉ាងនេះក្តី ក៏ភាគច្រើននៃពួកគេ គឺជាពួកដែលបំពាននៅលើផែនដីបន្ទាប់ពីនោះដដែល។

33. តាមពិត ការតបស្នងចំពោះពួកដែលធ្វើសង្គ្រាមប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ និងព្យាយាមបង្កវិនាសកម្មនៅលើផែនដីនោះ គឺត្រូវប្រហារជីវិត ឬចងឆ្កាង ឬកាត់ដៃកាត់ជើងរបស់ពួកគេឆ្លាស់គ្នា (កាត់ដៃខាងស្តាំនិងជើងខាងឆ្វេង) ឬក៏និរទេសពួកគេចេញពីស្រុកភូមិ។ នោះគឺជាភាពអាម៉ាស់សម្រាប់ពួកគេនៅក្នុងលោកិយ។ ហើយនៅថ្ងៃបរលោក ពួកគេនឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

34. លើកលែងតែបណ្តាអ្នកដែលបានសារភាពកំហុសមុនពេលដែលពួកអ្នក (មេដឹកនាំ) ចាប់ខ្លួនពួកគេបានប៉ុណ្ណោះ។ ដូច្នេះ ចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

35. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ និងត្រូវស្វែងរកផ្លូវទៅកាន់ទ្រង់ ព្រមទាំងតស៊ូ (ប្រយុទ្ធ) ក្នុងមាគ៌ារបស់ទ្រង់ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

36. ជាការពិតណាស់ ពួកដែលគ្មានជំនឿ ប្រសិនបើពួកគេមានកម្មសិទ្ធិលើអ្វីៗទាំងអស់នៅលើផែនដីនេះ និងមានអ្វីដូចនឹងផែនដីនេះ (មកបន្ថែម) ទៀត ដើម្បីពួកគេយករបស់ទាំងនោះទៅលោះខ្លួនរបស់ពួកគេពីទណ្ឌកម្មរបស់អល់ឡោះនៅថ្ងៃបរលោកក៏ដោយ ក៏គេមិនទទួលយក (ការលោះនោះ) ពីពួកគេដែរ ហើយពួកគេនឹងត្រូវទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

37. ពួកគេមានបំណងចង់ចេញពីឋាននរក តែពួកគេមិនអាចចេញពីវាបានឡើយ ហើយពួកគេនឹងត្រូវទទួលទណ្ឌកម្មជារៀងរហូត។

38. ចំពោះចោរប្រុស និងចោរស្រី ចូរពួកអ្នក (ឱអ្នកកាត់ក្តីទាំងឡាយ) កាត់ដៃស្តាំទាំងពីររបស់ពួកគេចុះ ជាការតបស្នងចំពោះគេទាំងពីរដោយសារតែអ្វីដែលគេទាំងពីរបានប្រព្រឹត្ត ជាទណ្ឌកម្មពីអល់ឡោះ។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

39. ក៏ប៉ុន្តែចំពោះជនណាដែលបានសារភាពកំហុស ហើយបានកែខ្លួនវិញនោះ ជាការពិតណាស់ អល់ឡោះជាម្ចាស់នឹងទទួលយកការសារភាពកំហុសរបស់គេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

40. តើអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) មិនដឹងទេឬថា ជាការពិតណាស់ អំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់នោះ? ទ្រង់ជាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា និងអភ័យទោសចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាម្ចាស់មានអានុភាពលើអ្វីៗទាំងអស់។

41. ឱអ្នកនាំសារ(មូហាំម៉ាត់)! ចូរអ្នកកុំព្រួយបារម្ភចំពោះពួក(ពុតត្បុត)ដែលប្រញាប់ប្រញាល់នៅក្នុងការប្រឆាំងក្នុងចំណោមពួកដែលនិយាយថា៖ "ពួកយើងមានជំនឿ" នៅលើបបូរមាត់របស់ពួកគេ ប៉ុន្តែចិត្តរបស់ពួកគេគ្មានជំនឿឡើយ និង(កុំព្រួយបារម្ភ)ចំពោះពួកយូដាដែលពួកគេស្តាប់តែពាក្យកុហក(ពីថ្នាក់ដឹកនាំកំពូលៗរបស់ពួកគេ) និងស្តាប់តែពីក្រុមផ្សេងដោយពួកគេមិនបានមករកអ្នកឡើយ។ ពួកគេកែប្រែពាក្យបន្ទូលរបស់អល់ឡោះ(នៅក្នុងគម្ពីរតៅរ៉ត)ខុសពីកន្លែងដើមរបស់វា។ ពួកគេនិយាយថា៖ ប្រសិនបើគេ(ព្យាការីមូហាំម៉ាត់)នាំប្រការនេះមក(ប្រការដែលស្របនឹងចំណង់ចំណូលចិត្តពួកគេ) ចូរពួកអ្នកទទួលយកចុះ។ តែប្រសិនបើគេមិននាំប្រការនោះមកទេនោះ ចូរពួកអ្នកប្រុងប្រយ័ត្ន។ ហើយជនណាដែលអល់ឡោះមានចេតនាធ្វើឱ្យគេវង្វេងនោះ គឺអ្នកនឹងមិនឃើញមានអ្នកការពារពួកគេពីភាពវង្វេងឡើយ។ អ្នកទាំងនោះហើយជាពួកដែលអល់ឡោះមិនចង់ជម្រះសម្អាតចិត្តពួកគេ(ពីភាពគ្មានជំនឿ)។ ពួកគេនឹងទទួលនូវភាពអាម៉ាស់ជាទីបំផុតនៅក្នុងលោកិយ។ ហើយនៅថ្ងៃបរលោក ពួកគេនឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

42. (ពួកយូដាទាំងនោះ) គឺពួកដែលចូលចិត្តស្តាប់នូវពាក្យកុហកបំផុត និងចូលចិត្តស៊ីទ្រព្យសម្បត្តិដែលគេហាមឃាត់។ ដូចនេះ ប្រសិនបើពួកគេមករកអ្នក(ដើម្បីឱ្យអ្នកកាត់ក្តីដល់ពួកគេ) ចូរអ្នកកាត់ក្តីរវាងពួកគេ ឬងាកចេញពីពួកគេចុះ។ ប្រសិនបើអ្នកងាកចេញ(មិនកាត់ក្តីឱ្យពួកគេទេ)នោះ ក៏ពួកគេមិនអាចបង្កគ្រោះថ្នាក់អ្វីមួយដល់អ្នកបានដែរ។ តែប្រសិនបើអ្នកកាត់ក្តី ចូរអ្នកកាត់ក្តីរវាងពួកគេដោយយុត្តិធម៌។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលប្រកាន់នូវភាពយុត្តិធម៌។

43. តើពួកគេស្វែងរកការកាត់ក្តីពីអ្នកយ៉ាងដូចម្តេច ខណៈដែលពួកគេមានគម្ពីរតៅរ៉តនៅជាមួយពួកគេ ដែលនៅក្នុងនោះគឺមានច្បាប់បញ្ញត្តិរបស់អល់ឡោះ។ ក្រោយមក ពួកគេបានបែរចេញ(មិនទទួលយកការកាត់ក្តីរបស់អ្នក)បន្ទាប់ពីនោះទៅវិញ។ ពួកទាំងនោះ មិនមែនជាអ្នកដែលមានជំនឿឡើយ។

44. ពិតប្រាកដណាស់ យើងបានបញ្ចុះគម្ពីរតៅរ៉ត(ទៅឱ្យព្យាការីមូសា) ដែលក្នុងនោះ គឺមាននូវការចង្អុលបង្ហាញ និងពន្លឺ។ បណ្តាព្យាការីទាំងឡាយ(នៃអម្ប៉ូរអ៊ីស្រាអែល)ដែលពួកគាត់ជាអ្នកដែលប្រគល់ខ្លួនចំពោះអល់ឡោះបានកាត់ក្តីតាមរយៈគម្ពីរនេះដល់ពួកយូដា ហើយពួកអ្នករ៉ាប្បាផ្សាសនា និងពួកមេដឹកនាំ(របស់ពួកគេក៏កាត់ក្តីតាមគម្ពីរនេះដែរ) ដោយសារគេ(អល់ឡោះ)ប្រើឱ្យពួកគេថែរក្សាគម្ពីររបស់អល់ឡោះ និងចាត់ពួកគេធ្វើជាសាក្សីលើគម្ពីរនេះ។ ហេតុនេះ ចូរពួកអ្នក(ឱពួកយូដា)កុំខ្លាចមនុស្សលោកឱ្យសោះ តែពួកអ្នកត្រូវខ្លាចយើងវិញ។ ហើយចូរពួកអ្នកកុំយកបណ្តាវាក្យខណ្ឌរបស់យើងប្តូរយកកម្រៃបន្តិចបន្តួចឱ្យសោះ។ ហើយជនណាដែលមិនកាត់ក្តីតាមអ្វីដែលអល់ឡោះបានបញ្ចុះមកទេនោះ ពិតណាស់ពួកគេគឺជាពួកដែលប្រឆាំង ។

45. ហើយយើងបានដាក់កាតព្វកិច្ចទៅលើពួកគេនៅក្នុងវា(គម្ពីរតៅរ៉ត)ថា ពិតប្រាកដណាស់ ជីវិតត្រូវសងដោយជីវិត ភ្នែកត្រូវសងដោយភ្នែក ច្រមុះត្រូវសងដោយច្រចុះ ត្រចៀកត្រូវសងដោយត្រចៀក ធ្មេញត្រូវសងដោយធ្មេញ ហើយការបង្កគ្រោះបួសស្នាម គឺត្រូវដាក់ទោសឱ្យដូចអ្វីដែលជនរងគ្រោះទទួលរង។ តែជនណាដែលអធ្យាស្រ័យដល់ជនល្មើស គឺជននោះត្រូវបានគេ(អល់ឡោះ)លុបលាងបាបកម្មរបស់គាត់។ ហើយជនណាដែលមិនកាត់ក្តីតាមអ្វីដែលអល់ឡោះបានបញ្ចុះមកទេនោះ ពិតណាស់ពួកគេ គឺជាពួកដែលបំពាន។

46. ហើយយើងបានឱ្យព្យាការីអ៊ីសាកូនប្រុសម៉ារយ៉ាំដើរតាមលំអានរបស់ពួកគាត់(បណ្តាព្យាការីនៃអម្ប៉ូរអ៊ីស្រាអែល)ដោយគាត់ជាអ្នកដែលមានជំនឿនឹងអ្វីដែលមាននូវជាមួយគាត់នៃគម្ពីរតៅរ៉ត។ ហើយយើងបានប្រទានឱ្យគាត់នូវគម្ពីរអ៊ិញជីលដែលផ្តុំទៅដោយការចង្អុលបង្ហាញ និងពន្លឺ ហើយនិងដើម្បីបញ្ជាក់នូវអ្វីដែលមាននូវជាមួយគាត់នៃគម្ពីរតៅរ៉ត ព្រមទាំងជាមគ្គទេសក៍ និងជាដំបូន្មានសម្រាប់បណ្តាអ្នកដែលកោតខ្លាច។

47. ហើយចូរឱ្យអ្នកដែលកាន់តាមគម្ពីរអ៊ិញជីល(ពួកគ្រឹស្ទាន)កាត់ក្តីតាមអ្វីដែលអល់ឡោះបានបញ្ចុះនៅក្នុងវា។ ជនណាហើយដែលមិនកាត់ក្តីតាមអ្វីដែលអល់ឡោះបានបញ្ចុះមកទេនោះ ជាការពិតណាស់ ពួកទាំងនោះ គឺជាពួកដែលប្រព្រឹត្តល្មើស។

48. ហើយយើងបានបញ្ចុះគម្ពីរ(គួរអាន)ទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)យ៉ាងពិតប្រាកដ ដើម្បីបញ្ជាក់ទៅលើបណ្តាគម្ពីរមុនៗ និង(ដើម្បី)ប៉ាំញាក់ពីភាពត្រឹមត្រូវនៃបណ្តាគម្ពីរទាំងនោះ។ ហេតុនេះ ចូរអ្នកកាត់សេចក្តីរវាងពួកគេទៅតាមអ្វីដែលអល់ឡោះបានបញ្ចុះមក ហើយចូរអ្នកកុំធ្វើតាមទំនើងចិត្តរបស់ពួកគេដោយបោះបង់ចោលនូវអ្វីដែលគេបានបញ្ចុះទៅឱ្យអ្នកអំពីការពិតនោះឱ្យសោះ។ រាល់ប្រជាជាតិនីមួយៗ គឺយើងបានបង្កើតច្បាប់បញ្ញត្តិ និងមាគ៌ា(សម្រាប់ពួកគេប្រតិបត្តិ)។ ហើយប្រសិនបើអល់ឡោះមានចេតនា ទ្រង់នឹងបង្កើតពួកអ្នកជាប្រជាជាតិតែមួយមិនខាន ក៏ប៉ុន្តែដើម្បីទ្រង់សាកល្បងពួកអ្នកចំពោះអ្វីដែលទ្រង់បានផ្តល់ឱ្យពួកអ្នក។ ហេតុនេះ ចូរពួកអ្នករួសរាន់ទៅកាន់ការសាងអំពើល្អ។ ហើយកន្លែងវិលត្រឡប់របស់ពួកអ្នកទាំងអស់គ្នា គឺទៅកាន់អល់ឡោះជាម្ចាស់(នៅថ្ងៃបរលោក)។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់ខ្វែងគំនិតគ្នានៅក្នុងវា។

49. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កាត់សេចក្តីរវាងពួកគេទៅតាមអ្វីដែលអល់ឡោះបានបញ្ចុះមក ហើយចូរអ្នកកុំធ្វើតាមទំនើងចិត្តរបស់ពួកគេ និងត្រូវប្រុងប្រយ័ត្នកុំឱ្យពួកគេធ្វើឱ្យអ្នកវង្វេងចេញពីប្រការមួយចំនួនដែលអល់ឡោះបានបញ្ចុះទៅកាន់អ្នកឱ្យសោះ។ តែប្រសិនបើពួកគេងាកចេញវិញនោះ អ្នកត្រូវដឹងថា តាមពិតអល់ឡោះទ្រង់មានបំណងដាក់ទណ្ឌកម្មពួកគេចំពោះបាបកម្មមួយចំនួនរបស់ពួកគេ។ ហើយពិតណាស់ មនុស្សលោកភាគច្រើន គឺជាពួកដែលប្រព្រឹត្តល្មើស។

50. តើពួកគេស្វែងរកច្បាប់របស់ពួកអវិជ្ជាឬ? ហើយគ្មានច្បាប់ណាដែលប្រសើរជាងច្បាប់ដែលមកពីអល់ឡោះជាម្ចាស់នោះទេចំពោះក្រុមដែលជឿជាក់។

51. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកពួកយូដានិងពួកគ្រឹស្ទានធ្វើជាអ្នកគាំពារឱ្យសោះ។ ពួកគេគឺជាអ្នកគាំពារគ្នាទៅវិញទៅមក។ ហើយជនណាក្នុងចំណោមពួកអ្នកដែលយកពួកគេធ្វើជាអ្នកគាំពារនោះ ពិតណាស់ រូបគេស្ថិតក្នុងក្រុមពួកគេហើយ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

52. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងឃើញពួក(ពុតត្បុត)ដែលក្នុងចិត្តរបស់ពួកគេមានជំងឺ ប្រញាប់រួសរាន់ក្នុងការចងសម្ព័ន្ធភាពជាមួយនឹងពួកទាំងនោះ(ពួកយូដានិងពួកគ្រឹស្ទាន)ដោយពួកគេនិយាយថា៖ ពួកយើងខ្លាចទទួលរងប្រការអាក្រក់(ពីបណ្តាអ្នកមានជំនឿ)។ ជួនកាល អល់ឡោះអាចនាំមកនូវជ័យជម្នះ ឬបទបញ្ជាណាមួយមកពីទ្រង់ក៏ថាបាន។ ពេលនោះ ពួកគេនឹងក្លាយទៅជាអ្នកដែលមានវិប្បដិសារីចំពោះអ្វីដែលពួកគេបានលាក់បាំងក្នុងខ្លួនរបស់ពួកគេ(នៃភាពពុតត្បុត)ជាមិនខាន ។

53. ហើយបណ្តាអ្នកដែលមានជំនឿបាននិយាយថា៖ តើពួកទាំងនោះឬដែលបានស្បថនឹងអល់ឡោះយ៉ាងមឺងម៉ាត់ថា ពិតណាស់ពួកគេនឹងនៅជាមួយពួកអ្នកនោះ? ទង្វើ(កុសល)ទាំងឡាយរបស់ពួកគេបានក្លាយជាអសារបង់ ហើយពួកគេក៏ក្លាយទៅជាពួកដែលខាតបង់។

54. ឱបណ្តាអ្នកដែលមានជំនឿ! ជនណាក្នុងចំណោមពួកអ្នកដែលបោះបង់សាសនារបស់ខ្លួន(ត្រឡប់ទៅរកភាពគ្មានជំនឿវិញ)នោះ ពិតណាស់អល់ឡោះនឹងនាំមកនូវក្រុមមួយផ្សេងទៀតដែលទ្រង់ស្រលាញ់ពួកគេ ហើយពួកគេក៏ស្រលាញ់ទ្រង់វិញដែរ។ ពួកគេមានភាពទន់ភ្លន់ចំពោះបណ្តាអ្នកដែលមានជំនឿ ហើយតឹងរឹងចំពោះពួកដែលគ្មានជំនឿ។ ពួកគេតស៊ូក្នុងមាគ៌ារបស់អល់ឡោះ ហើយពួកគេមិនខ្លាចការស្តីបន្ទោសពីនរណាម្នាក់ឡើយ។ ទាំងនោះ គឺជាការប្រោសប្រទានរបស់អល់ឡោះដែលទ្រង់ប្រទានវាដល់ជនណាដែលទ្រង់មានចេតនា ។ ហើយអល់ឡោះមហាវិសេសវិសាល មហាដឹងបំផុត។

55. តាមពិតអ្នកគាំពាររបស់ពួកអ្នក គឺអល់ឡោះជាម្ចាស់ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងបណ្តាអ្នកមានជំនឿដែលប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយពួកគេជាអ្នកឱនលំទោន(ចំពោះអល់ឡោះ)។

56. ហើយជនណាដែលយកអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងបណ្តាអ្នកដែលមានជំនឿទាំងឡាយធ្វើជាអ្នកគាំពារជាការពិតណាស់ ក្រុមរបស់អល់ឡោះនោះ ពួកគេគឺជាអ្នកដែលទទួលជោគជ័យ។

57. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកពួកដែលយកសាសនារបស់ពួកអ្នក(សាសនាអ៊ីស្លាម)ជាការសើចចំអកនិងលេងសើចក្នុងចំណោមពួកដែលគេបានផ្តល់គម្ពីរឱ្យមុនពួកអ្នក(ពួកយូដា និងពួកគ្រីស្ទាន) និងពួកគ្មានជំនឿទាំងនោះធ្វើជាអ្នកគាំពារឱ្យសោះ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ ប្រសិនបើពួកអ្នក គឺជាអ្នកដែលមានជំនឿមែននោះ។

58. ហើយនៅពេលដែលពួកអ្នកអំពាវនាវទៅកាន់ការសឡាត ពួកគេក៏យកវាជាការសើចចំអក និងលេងសើចដែរ។ នោះគឺដោយសារតែពួកគេជាពួកដែលមិនចេះគិតពិចារណា។

59. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ឱពួកអះលីគីតាប! តើការដែលពួកអ្នកចងគំនុំនឹងពួកយើងនេះ គឺគ្មានអ្វីក្រៅពី(ដោយសារតែ)ពួកយើងមានជំនឿចំពោះអល់ឡោះ ព្រមទាំង(មានជំនឿ)ចំពោះអ្វីដែលទ្រង់បានបញ្ចុះមកឱ្យពួកយើង និងអ្វីដែលទ្រង់បានបញ្ចុះទៅឱ្យអ្នកជំនាន់មុន ហើយនិង(ការដែលពួកយើងមានជំនឿថា)ភាគច្រើននៃពួកអ្នកគឺជាពួកដែលប្រព្រឹត្តល្មើសនោះឬ?

60. ចូរអ្នកពោលថា៖ តើចង់ឱ្យខ្ញុំប្រាប់ពួកអ្នកពីអ្នកដែលអាក្រក់ជាងនោះទៅទៀតនៅចំពោះអល់ឡោះដែរឬទេ? គឺអ្នកដែលអល់ឡោះបានដាក់បណ្តាសាដល់រូបគេ និងខឹងសម្បាចំពោះរូបគេ ព្រមទាំងធ្វើឱ្យរូបរាងរបស់ពួកគេក្លាយទៅជាសត្វស្វា សត្វជ្រូក និងជាអ្នកគោរពសក្ការៈចំពោះតហ្ងូត។ ពួកទាំងនោះហើយ គឺជាពួកដែលស្ថិតនៅកន្លែងដ៏អាក្រក់បំផុត និងវង្វេងចេញពីមាគ៌ាដ៏ត្រឹមត្រូវ។

61. ហើយនៅពេលដែលពួកគេ(ពួកអះលីគីតាប)បានមកជួបពួកអ្នក ពួកគេនិយាយថា៖ ពួកយើងមានជំនឿហើយ។ តែធាតុពិតនៅពេលដែលពួកគេចូលមក គឺស្ថិតក្នុងភាពគ្មានជំនឿ ហើយនៅពេលដែលពួកគេចេញទៅវិញ ក៏ដូចគ្នាដែរ។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេលាក់បាំង។

62. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងឃើញភាគច្រើននៃពួកគេ គឺរួសរាន់ក្នុងការប្រព្រឹត្តបាបកម្ម ការបង្កភាពជាសត្រូវ និងស៊ីទ្រព្យសម្បត្តិដែលគេហាមឃាត់។ អ្វីដែលពួកគេបានប្រព្រឹត្ត គឺអាក្រក់បំផុត។

63. ហេតុអ្វីបានជាពួកមេដឹកនាំ និងពួកដែលមានចំណេះដឹងជ្រៅជ្រះរបស់ពួកគេមិនហាមឃាត់ពួកគេអំពីពាក្យសម្តីដែលមានបាបកម្ម(កុតកុហក ធ្វើសាក្សីបោកប្រាស់) និងស៊ីទ្រព្យសម្បត្តិដែលគេហាមឃាត់? អ្វីដែលពួកគេបានធ្វើ គឺពិតជាអាក្រក់បំផុត។

64. ហើយពួកយូដាបាននិយាយថា៖ ព្រះហស្តរបស់អល់ឡោះ គឺក្តាប់ជិត(កំណាញ់)។ (តាមពិត)ដៃរបស់ពួកគេទៅវិញទេដែលក្តាប់ជិតនោះ ហើយពួកគេត្រូវបានគេដាក់បណ្តាសាដោយសារតែពាក្យសម្តីបែបនេះ។ ផ្ទុយទៅវិញ ព្រះហស្តទាំងពីររបស់អល់ឡោះ គឺលា(បើកទូលាយ)។ ទ្រង់ប្រទាន(អ្វីមួយ)តាមតែទ្រង់មានចេតនា។ ហើយអ្វីដែលគេបញ្ចុះទៅឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះ គ្មានបានបន្ថែមអ្វីដល់ពួកគេក្រៅតែពីធ្វើឱ្យពួកគេតឹតែបំពាន និងប្រឆាំងថែមទៀតនោះឡើយ។ ហើយយើងបានដាក់នូវភាពជាសត្រូវនឹងគ្នា និងការស្អប់ខ្ពើមគ្នារវាងពួកគេរហូតដល់ថ្ងៃបរលោក។ រាល់ពេលដែលពួកគេបញ្ឆេះភ្លើងសង្គ្រាម គឺអល់ឡោះទ្រង់ពន្លត់វាវិញ។ ហើយពួកគេព្យាយាមបង្កវិនាសកម្មនៅលើផែនដី។ ហើយអល់ឡោះទ្រង់មិនស្រលាញ់ពួកដែលបង្កវិនាសកម្មឡើយ។

65. ហើយប្រសិនបើពួកអះលីគីតាបមានជំនឿ និងកោតខ្លាចអល់ឡោះនោះ យើងប្រាកដជានឹងលុបបំបាត់នូវកំហុសឆ្គងទាំងឡាយរបស់ពួកគេចេញពីពួកគេ ហើយយើងនឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ណាអ៊ីមជាមិនខាន។

66. ហើយប្រសិនបើពួកគេប្រតិបត្តិតាមគម្ពីរតាវរ៉ាត និងគម្ពីរអ៊ិញជីល ហើយនិងអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះទៅឱ្យពួកគេពីព្រះជាម្ចាស់របស់ពួកគេនោះ យើងនឹងប្រទានដល់ពួកគេនូវលាភសក្ការៈពីខាងលើពួកគេ(តាមរយៈការបញ្ចុះទឹកភ្លៀង)និងពីខាងក្រោមពួកគេ(ធ្វើឱ្យរុក្ខជាតិនានាដុះនៅលើផែនដី)។ ក្នុងចំណោមពួកគេ មានអ្នកដែលប្រកាន់ជំហរកណ្តាល(ស្ថិតនៅលើការពិត)។ តែភាគច្រើននៃពួកគេ អ្វីពួកគេបានប្រព្រឹត្ត គឺអាក្រក់បំផុត។

67. ឱអ្នកនាំសារ(មូហាំម៉ាត់)! ចូរអ្នកផ្សព្វផ្សាយ(ដល់មនុស្សលោក)នូវអ្វីដែលគេបានបញ្ចុះទៅកាន់អ្នកពីព្រះជាម្ចាស់របស់អ្នក។ ប្រសិនបើអ្នកមិនធ្វើទេនោះ គឺអ្នកមិនបានផ្សព្វផ្សាយសាររបស់ទ្រង់ឡើយ។ ហើយអល់ឡោះនឹងការពារអ្នកពីមនុស្សលោក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនចង្អុលបង្ហាញចំពោះក្រុមដែលគ្មានជំនឿឡើយ។

68. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱពួកអះលីគីតាប! ពួកអ្នកពុំមែនស្ថិតនៅលើអ្វីមួយ(សាសនាត្រឹមត្រូវ)ឡើយ លុះត្រាតែពួកអ្នកប្រតិបត្តិតាមគម្ពីរតាវរ៉ាត និងគម្ពីរអ៊ិញជីល ហើយនិងអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះទៅឱ្យពួកអ្នកពីព្រះជាម្ចាស់របស់ពួកអ្នក។ ហើយអ្វីដែលគេបញ្ចុះទៅឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះ គ្មានបានបន្ថែមអ្វីដល់ពួកគេក្រៅតែពីធ្វើឱ្យពួកគេរឹតតែបំពាន និងប្រឆាំងថែមទៀតនោះឡើយ។ ហេតុនេះ ចូរអ្នកកុំអស់សង្ឃឹមទៅលើក្រុមដែលប្រឆាំង។

69. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ ពួកយូដា ពួកសពីអ៊ីន(ពួកគេគឺជាក្រុមមួយនៃអ្នកដែលដើរតាមបណ្តាព្យាការីមួយចំនួន)និងពួកគ្រីស្ទាន ជនណាហើយដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ព្រមទាំងបានសាងទង្វើកុសលនោះ ពិតប្រាកដណាស់ ពួកគេមិនមានការភ័យខ្លាចអ្វីឡើយ ហើយពួកគេក៏មិនមានការព្រួយបារម្ភនោះដែរ។

70. ជាការពិតណាស់ យើងបានដាក់កិច្ចសន្យាទៅលើអម្បូរអ៊ីស្រាអែល ហើយយើងបានបញ្ជូនអ្នកនាំសារជាច្រើនទៅកាន់ពួកគេ។ រាល់ពេលដែលអ្នកនាំសារម្នាក់បានទៅដល់ពួកគេដោយនាំមកនូវអ្វីដែលមិនស្របតាមទំនើងចិត្តពួកគេ មួយចំនួននៃពួកគាត់(បណ្តាអ្នកនាំសារ)ត្រូវបានពួកគេបដិសេធ ហើយមួយចំនួនទៀត ត្រូវបានពួកគេសម្លាប់ចោល។

71. ហើយពួកគេ(ពួកអះលីគីតាប)គិតស្មានថា (អំពើល្មើសរបស់ពួកគេ) គ្មានផ្តល់គ្រោះថ្នាក់អ្វីដល់ពួកគេនោះឡើយ។ ដូចនេះពួកគេក៏ធ្វើខ្វាក់ ធ្វើថ្លង់(មិនទទួលយកការពិត)។ បន្ទាប់មក អល់ឡោះបានអភ័យទោសដល់ពួកគេ។ ក្រោយមក ភាគច្រើននៃពួកគេនៅតែធ្វើខ្វាក់ ធ្វើថ្លង់ដដែល។ ហើយអល់ឡោះមហាឃើញបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

72. ពិតជាក្លាយជាពួកគ្មានជំនឿហើយអ្នកដែលនិយាយថា៖ អល់ឡោះជាម្ចាស់ គឺអាល់ម៉ាសៀហអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំនោះ ខណៈដែលអាល់ម៉ាសៀហ(ខ្លួនឯង)បាននិយាយថា៖ ឱអម្បូរអ៊ីស្រាអែល! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះដែលជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ជាការពិត ជនណាហើយដែលបានធ្វើស្ហ៊ីរិក(ពហុទេពនិយម)នឹងអល់ឡោះនោះ អល់ឡោះជាម្ចាស់ពិតជាបានដាក់បម្រាមលើរូបគេមិនឱ្យចូលឋានសួគ៌ ហើយកន្លែងស្នាក់អាស្រ័យរបស់គេ គឺនរកដើហាន់ណាំ។ ហើយសម្រាប់ពួកដែលបំពាន គឺគ្មានអ្នកជួយឡើយ។

73. ពិតជាក្លាយជាពួកគ្មានជំនឿហើយអ្នកដែលនិយាយថា៖ អល់ឡោះជាម្ចាស់ គឺជាព្រះត្រៃឯក។ តាមពិត គ្មានព្រះជាម្ចាស់ឯណាដែលគេត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ក្រៅពីព្រះជាម្ចាស់តែមួយអង្គគត់នោះឡើយ។ ហើយប្រសិនបើពួកគេមិនព្រមបញ្ឈប់នូវអ្វីដែលពួកគេនិយាយទេនោះ អ្នកដែលប្រឆាំងក្នុងចំណោមពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុតជាមិនខាន។

74. តើពួកគេមិនព្រមសារភាពកំហុសចំពោះអល់ឡោះ និងសុំការអភ័យទោសពីទ្រង់ទៀតឬ? ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

75. អាល់ម៉ាសៀហ កូនប្រុសរបស់ម៉ារយ៉ាំ (យេស៊ូគ្រីស្ទ បុត្រនាងម៉ារី) ពុំមែនជាអ្វីក្រៅពីជាអ្នកនាំសារម្នាក់ដូចដែលអ្នកនាំសារជាច្រើនបានកន្លងផុតទៅមុនគាត់នោះឡើយ ហើយម្តាយរបស់គាត់ គឺជាស្ត្រីដែលសច្ចៈត្រឹមត្រូវបំផុត។ អ្នកទាំងពីរចេះទទួលទានអាហារ(ដូចគេឯងដែរ)។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះថា តើយើងបានបង្ហាញភស្តុតាងយ៉ាងច្បាស់លាស់ជាច្រើនដល់ពួកគេយ៉ាងដូចម្តេច? បន្ទាប់មក ចូរអ្នកពិនិត្យមើលទៀតចុះថា តើពួកគេងាកចេញពីការពិតយ៉ាងដូចម្តេច?

76. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះដែលមិនអាចការពារពួកអ្នកពីគ្រោះថ្នាក់ និងមិនអាចផ្តល់ផលប្រយោជន៍នោះឬ? ហើយអល់ឡោះមហាឮ មហាដឹង។

77. ចូរអ្នកពោលថា៖ ឱពួកអះលីគីតាប(ពួកគ្រីស្ទាន)! ចូរពួកអ្នកកុំជ្រុលនិយមក្នុងសាសនារបស់ពួកអ្នកខុសពីការពិតឲ្យសោះ ហើយចូរពួកអ្នកកុំដើរតាមទំនើងចិត្តរបស់ក្រុមមួយដែលបានវង្វេងកាលពីមុន ហើយពួកគេបានធ្វើឱ្យមនុស្សជាច្រើនវង្វេង និងពួកគេខ្លួនឯងក៏បានវង្វេងចេញពីមាគ៌ាត្រឹមត្រូវដែរ។

78. គេ(អល់ឡោះ)បានដាក់បណ្តាសាពួកដែលគ្មានជំនឿក្នុងចំណោមអម្បូរអ៊ីស្រាអែលនៅក្នុងគម្ពីរហ្សាពួររបស់ព្យាការីហ្សាវូទ និងនៅក្នុងគម្ពីរអ៊ិញជីលរបស់ព្យាការីអ៊ីសាកូនប្រុសម៉ារយ៉ាំ។ នោះគឺដោយសារតែអ្វីដែលពួកគេបានប្រឆាំង ហើយពួកគេបានបំពាន(លើបម្រាមរបស់អល់ឡោះ)។

79. ពួកគេមិនធ្លាប់បានហាមឃាត់គ្នាពីអំពើល្មើសដែលពួកគេបានប្រព្រឹត្តវានោះឡើយ។ អ្វីដែលពួកគេបានប្រព្រឹត្ត ពិតជាអាក្រក់បំផុត។

80. អ្នកនឹងឃើញភាគច្រើននៃពួកគេ(ពួកយូដា)យកពួកគ្មានជំនឿធ្វើជាអ្នកគាំពារ។ អ្វីដែលពួកគេបានធ្វើសម្រាប់ខ្លួនឯងពិតជាអាក្រក់បំផុត ជាមូលហេតុដែលនាំឱ្យអល់ឡោះជាម្ចាស់ទ្រង់ខឹងសម្បាចំពោះពួកគេ ព្រមទាំងស្ថិតនៅក្នុងទណ្ឌកម្ម(ឋាននរក)ជារៀងរហូត។

81. ហើយប្រសិនបើពួកគេ(ពួកយូដា)មានជំនឿចំពោះអល់ឡោះ និងព្យាការីរបស់ទ្រង់ ព្រមទាំងមានជំនឿចំពោះអ្វីដែលទ្រង់បញ្ចុះទៅកាន់គាត់មែននោះ ពួកគេនឹងមិនយកពួកទាំងនោះធ្វើជាអ្នកគាំពារឡើយ។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស។

82. អ្នកពិតជានឹងជួបប្រទះមនុស្សដែលជាសត្រូវធំបំផុតចំពោះបណ្តាអ្នកដែលមានជំនឿ គឺពួកយូដា និងពួកដែលធ្វើស៊ីរិក(ពហុទេពនិយម)។ ហើយអ្នកក៏ពិតជានឹងជួបប្រទះផងដែរមនុស្សជំនិតនៃពួកគេមានចិត្តស្រលាញ់ចំពោះបណ្តាអ្នកដែលមានជំនឿ គឺបណ្តាអ្នកដែលនិយាយថា៖ ជាការពិតណាស់ ពួកយើងគឺជាណាស់រ៉ា។ នោះគឺដោយសារតែក្នុងចំណោមពួកគេមានអ្នកដែលមានចំណេះដឹងជ្រៅជ្រះ(ផ្នែកសាសនា)និងជាអ្នកដែលគោរពសក្ការៈ(ចំពោះអល់ឡោះជាម្ចាស់តែមួយ)។ ហើយពិតប្រាកដណាស់ ពួកគេមិនក្រអឺតក្រទមឡើយ។

83. ហើយនៅពេលដែលពួកគេស្តាប់ឮនូវអ្វីដែលគេបានបញ្ចុះទៅកាន់អ្នកនាំសារ(មូហាំម៉ាត់)គឺអ្នកនឹងឃើញពួកគេយំសម្រក់ទឹកភ្នែកដោយសារតែអ្វីដែលពួកគេបានដឹងអំពីសេចក្តីពិត។ ពួកគេបានពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! យើងខ្ញុំមានជំនឿហើយ។ ហេតុនេះ សូមព្រះអង្គមេត្តាកត់ត្រាពួកយើងបញ្ចូលជាមួយនឹងបណ្តាអ្នកដែលធ្វើសាក្សីផងចុះ ។

84. តើមានមូលហេតុអ្វីដែលរារាំងពួកយើងមិនឱ្យមានជំនឿលើអល់ឡោះនិងអ្វីដែលទ្រង់បានបញ្ចុះមកនៃសេចក្តីពិតនោះ? ហើយពួកយើងសង្ឃឹមថា ព្រះជាម្ចាស់របស់ពួកយើងនឹងបញ្ចូលពួកយើង(ទៅក្នុងឋានសួគ៌)ជាមួយនឹងបណ្តាអ្នកសាងកុសលទាំងឡាយ។

85. ដូចនេះ អល់ឡោះជាម្ចាស់ក៏បានតបស្នងផលបុណ្យដល់ពួកគេចំពោះអ្វីដែលពួកគេបាននិយាយនោះនូវឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពួកគេស្ថិតនៅក្នុងវាជាអមតៈ។ នោះហើយគឺជាការតបស្នងចំពោះបណ្តាអ្នកដែលសាងអំពើល្អ។

86. រីឯពួកដែលគ្មានជំនឿ និងបានបដិសេធចំពោះបណ្តាវាក្យខណ្ឌរបស់យើងវិញ ពួកទាំងនោះគឺជាពួកនរកើហ៊ឹម។

87. ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ចូរពួកអ្នកកុំជាក់បម្រាមនូវរបស់ល្អៗដែលអល់ឡោះបានអនុញ្ញាតដល់ពួកអ្នក និងកុំបំពាន(ព្រំដែនរបស់អល់ឡោះ)ឲ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះមិនស្រលាញ់ពួកដែលបំពានឡើយ។

88. ហើយចូរពួកអ្នកទទួលទាននូវអ្វីដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកអ្នកដែលគេអនុញ្ញាត(ហាឡាល់)និងស្អាតស្អំ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ ដែលទ្រង់នោះហើយជាអ្នកដែលពួកអ្នកត្រូវមានជំនឿ។

89. អល់ឡោះជាម្ចាស់ទ្រង់មិនយកទោសពៃរ៍ពួកអ្នកចំពោះពាក្យសម្បថដែលពួកអ្នកស្បថដោយអចេតនានោះឡើយ ប៉ុន្តែទ្រង់យកទោសពៃរ៍ពួកអ្នកចំពោះពាក្យសម្បថដែលកើតឡើងចេញពីការប្តេជ្ញាចិត្តរបស់ពួកអ្នក។ ដូចនេះ ការពិន័យចំពោះវាគឺត្រូវផ្តល់អាហារដល់អ្នកក្រីក្រចំនួនដប់នាក់នៃអាហារដោមធ្យមដែលពួកអ្នកផ្តល់ឲ្យក្រុមគ្រួសាររបស់ពួកអ្នកទទួលទាន ឬផ្តល់ជាសម្លៀកបំពាក់ដល់ពួកគេ ឬក៏ដោះលែងទាសីម្នាក់(ដែលមានជំនឿ)ឱ្យមានសេរីភាព។ តែប្រសិនបើគេគ្មានទេនោះ គឺត្រូវបួសចំនួនបីថ្ងៃ។ នោះគឺជាការដាក់ពិន័យលាសម្បថរបស់ពួកអ្នក នៅពេលដែលពួកអ្នកបានស្បថស្បែ(តែពួកអ្នកមិនបានធ្វើតាមពាក្យសម្បថនោះ)។ ហើយចូរពួកអ្នកការពារសម្បថរបស់ពួកអ្នក(មិនត្រូវស្បថផ្តេសផ្តាស)។ ក៏ដូច្នោះដែរ អល់ឡោះទ្រង់បញ្ជាក់ប្រាប់ពួកអ្នកនូវបណ្តាច្បាប់បញ្ញត្តិរបស់ទ្រង់ សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

90. ឱបណ្តាអ្នកមានជំនឿ! ពិតប្រាកដណាស់ គ្រឿងស្រវឹង ល្បែងស៊ីសង រូបបដិមា និងព្រួញទស្សន៍ទាយ គឺជាអំពើកខ្វក់ដែលស្ថិតក្នុងទង្វើរបស់ស្មែតន។ ហេតុនេះ ចូរពួកអ្នកចៀសវាងឱ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

91. តាមពិតស្មែតនមានបំណងចង់បង្កនូវភាពជាសត្រូវ និងការស្អប់ខ្ពើមគ្នារវាងពួកអ្នកតាមរយៈគ្រឿងស្រវឹងនិងល្បែងស៊ីសងនេះ ហើយរារាំងពួកអ្នកពីការរំឭកអល់ឡោះ និងការប្រតិបត្តិសឡាត។ ដូច្នេះ តើពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ជាអ្នកបោះបង់(អំពើអបាយមុខទាំងនេះ)ដែរឬទេ?

92. ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងប្រតិបត្តិតាមអ្នកនាំសារ ហើយត្រូវប្រុងប្រយ័ត្ន(ពីការប្រព្រឹត្តល្មើស)។ តែប្រសិនបើពួកអ្នកងាកចេញ ពួកអ្នកត្រូវដឹងថា តាមពិត កាតព្វកិច្ចលើអ្នកនាំសាររបស់យើង គឺការផ្សព្វផ្សាយដ៏ច្បាស់លាស់ប៉ុណ្ណោះ។

93. គ្មានទោសពៃរ៍នោះទេចំពោះបណ្តាអ្នកដែលមានជំនឿនិងបានសាងទង្វើកុសលចំពោះអ្វី(ស្រា)ដែលពួកគេបានទទួលទាន(មុនពេលដែលវាត្រូវបានដាក់បម្រាម)កាលណាពួកគេបានកោតខ្លាចអល់ឡោះ និងមានជំនឿ ព្រមទាំងបានសាងទង្វើកុសលនោះ។ បន្ទាប់មក ពួកគេកោតខ្លាចអល់ឡោះ និងមានជំនឿ។ ក្រោយមកទៀត ពួកគេកោតខ្លាចអល់ឡោះ និងសាងអំពើល្អ។ ហើយអល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលសាងអំពើល្អ។

94. ឱបណ្តាអ្នកដែលមានជំនឿ! អល់ឡោះទ្រង់ពិតជានឹងសាកល្បងពួកអ្នកនឹងប្រការទាំងឡាយដែលជំរុញពួកអ្នកឱ្យធ្វើការបរបាញ់សត្វព្រៃ(ខណៈដែលពួកអ្នកស្ថិតក្នុងតំណមអៀហរ៉ាម)ដោយពួកអ្នកចាប់វាដោយដៃរបស់ពួកអ្នក និងដោយប្រើលំពែង ដើម្បីអល់ឡោះទ្រង់ដឹងថា ជនណាដែលកោតខ្លាចទ្រង់ក្នុងពេលអាថ៌កំបាំង។ ដូច្នេះ ជនណាដែលបានបំពានព្រំដែន(ច្បាប់)បន្ទាប់ពីនោះ សម្រាប់រូបគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

95. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំសម្លាប់សត្វប្រមាញ់ខណៈដែលពួកអ្នកស្ថិតក្នុងតំណមអៀហរ៉ាម។ ជនណាហើយក្នុងចំណោមពួកអ្នកបានសម្លាប់វាដោយចេតនា ការពិន័យចំពោះទង្វើនោះ គឺត្រូវសំឡេះសត្វ(មួយផ្សេងទៀត)ដូចទៅនឹង(ប្រភេទ)សត្វដែលគេបានសម្លាប់នោះវិញ។ អ្នកដែលវិនិច្ឆ័យ(កាត់សេចក្តី)ក្នុងរឿងនេះ គឺបុរសពីរនាក់ដែលប្រកបដោយភាពយុត្តិធម៌ក្នុងចំណោមពួកអ្នក។ ហើយអ្វីដែលបុរសទាំងពីរនាក់នេះបានវិនិច្ឆ័យ គឺគេត្រូវធ្វើដូចអ្វីដែលគេបានធ្វើចំពោះសត្វជំនួនដែរ ដោយត្រូវបញ្ជូនសត្វនោះទៅសំឡេះនៅឯកាក់ហ្គះ(ទឹកដីម៉ាក្កៈ)ឬទទួលការពិន័យជាអាហារចែកជូនដល់ជនក្រីក្រ ឬត្រូវបួសជំនួសឱ្យការផ្តល់អាហារ ដើម្បីឱ្យគេភ្លក់លទ្ធផលនៃការបំពានបម្រាមរបស់ខ្លួន។ អល់ឡោះជាម្ចាស់បានអធ្យាស្រ័យចំពោះអ្វីដែលបានកន្លងផុតទៅ(មុនពេលដែលបម្រាមនេះបានដាក់ចុះមក)។ ហើយជនណាដែលត្រឡប់ទៅប្រព្រឹត្តទង្វើនោះ(ក្រោយពីបម្រាមបានដាក់មកហើយនោះ)អល់ឡោះជាម្ចាស់នឹងផ្តន្ទាទោសចំពោះគេ។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងក្លា មហាខ្លាំងពូកែ។

96. គេបានអនុញ្ញាតដល់ពួកអ្នកអាចនេសាទសត្វក្នុងទឹក និងអ្វីដែលមាននៅក្នុងសមុទ្រ សម្រាប់ជាប្រយោជន៍ដល់ពួកអ្នក និងអ្នកដំណើរទាំងឡាយ។ ហើយគេហាមឃាត់ពួកអ្នកចំពោះការប្រមាញ់សត្វលើគោកដរាបណាពួកអ្នកកំពុងស្ថិតក្នុងតំណមអៀហរ៉ាម។ ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ដែលគេនឹងប្រមូលផ្តុំពួកអ្នកទៅកាន់ទ្រង់(នៅថ្ងៃបរលោក)។

97. អល់ឡោះជាម្ចាស់បានចាត់ទុកកាក់ហ្គះដែលជាវិហារដ៏ពិសិដ្ឋ ខៃបម្រាម សត្វជំនួន និងសត្វដែលគេបំពាក់ប្រឡោក ជាការទ្រទ្រង់មួយសម្រាប់មនុស្សលោក។ នោះគឺដើម្បីឱ្យពួកអ្នកដឹងថា ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាដឹងបំផុតនូវអ្វីដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីដែលមាននៅលើផែនដី។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

98. ចូរពួកអ្នក(ឱមនុស្សលោកទាំងឡាយ)ដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះជាអ្នកដាក់ទណ្ឌកម្មដ៏ខ្លាំងក្លាបំផុត។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

99. ពុំមានកាតព្វកិច្ចអ្វីទៅលើអ្នកនាំសារ ក្រៅពីការផ្សព្វផ្សាយ(សាររបស់អល់ឡោះ)នោះឡើយ។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលពួកអ្នកលាតត្រដាង និងអ្វីដែលពួកអ្នកលាក់បាំង។

100. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ប្រការអាក្រក់ និងប្រការល្អ គឺមិនស្មើគ្នាឡើយ សូម្បីតែប្រការអាក្រក់នោះមានច្រើនធ្វើឱ្យអ្នកចាប់អារម្មណ៍ក៏ដោយ។ ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ ឱបណ្តាអ្នកដែលមានវិចារណញ្ញាណទាំងឡាយ សង្ឃឹមថាពួកអ្នកនឹងទទួលជោគជ័យ។

101. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំសួរដេញដោល(អ្នកនាំសារ)ពីរឿងរ៉ាវជាច្រើន(ដែលមិនចាំបាច់) ព្រោះថាប្រសិនបើរឿងនោះត្រូវបានគេលាតត្រដាងឱ្យពួកអ្នកបានដឹងវិញនោះ វានឹងធ្វើឱ្យមានផលអាក្រក់ចំពោះពួកអ្នកជាមិនខាន។ តែប្រសិនបើពួកអ្នក(នៅតែ)សួរពីប្រការនោះ ខណៈដែលគម្ពីរគួរអានកំពុងត្រូវបានបញ្ចុះមក គេនឹងបញ្ជាក់ប្រាប់ពួកអ្នកជាមិនខាន។ អល់ឡោះបានអធ្យាស្រ័យដល់ពួកអ្នកចំពោះបញ្ហានោះ(បញ្ហាដែលគម្ពីរគួរអានមិនបានលើកឡើង)។ ហើយអល់ឡោះមហាអភ័យទោស មហាខន្តីបំផុត។

102. ជាការពិតណាស់ មានក្រុមមួយនៅជំនាន់មុនពួកអ្នក ពួកគេបានសួរដេញដោលបែបនេះដែរ។ ក្រោយមក ពួកគេក៏ក្លាយទៅជាពួកប្រឆាំងដោយសារតែមូលហេតុនោះ។

103. អល់ឡោះជាម្ចាស់មិនបានចាត់ទុកសត្វប៉ាហ៊ីរ៉ោះ សាអ៊ីហ្គះ វ៉ាស៊ីឡះ និងហាមី(ថាជាសត្វដែលទ្រង់ហាមឃាត់ដូចដែលពួកមុស្លីគឺនបានហាមឃាត់លើខ្លួនឯង)នោះឡើយ ក៏ប៉ុន្តែពួកដែលគ្មានជំនឿទេដែលប្រឌិតរឿងកុហកទៅលើអល់ឡោះជាម្ចាស់នោះ។ ហើយភាគច្រើននៃពួកគេ គឺមិនពិចារណាឡើយ។

104. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកមករកអ្វីដែលអល់ឡោះបានបញ្ចុះមក(គម្ពីរគួរអាន)និងមកកាន់អ្នកនាំសារ(ស៊ុណ្ណះ) ពួកគេឆ្លើយថា៖ គ្រប់គ្រាន់ហើយសម្រាប់ពួកយើងចំពោះអ្វីដែលពួកយើងបានឃើញដូនតារបស់ពួកយើង(បន្សល់ទុក)។ តើសូម្បីតែដូនតារបស់ពួកគេមិនចេះដឹងអ្វីទាល់តែសោះ ហើយក៏មិនទទួលបានការចង្អុលបង្ហាញ(ក៏ពួកគេនៅតែធ្វើតាមដែរឬ?)។

105. ឱបណ្តាអ្នកដែលមានជំនឿ! ពួកអ្នកត្រូវទទួលខុសត្រូវចំពោះខ្លួនឯង។ ជនដែលវង្វេងមិនអាចបង្កគ្រោះថ្នាក់ដល់ពួកអ្នកនោះឡើយនៅពេលដែលពួកអ្នកទទួលបានការចង្អុលបង្ហាញហើយនោះ។ កន្លែងវិលត្រលប់របស់ពួកអ្នកទាំងអស់គ្នាគឺទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់នៅថ្ងៃបរលោក)។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

106. ឱបណ្តាអ្នកដែលមានជំនឿ! កាលណាសេចក្តីស្លាប់បានខិតជិតមកដល់នរណាម្នាក់ក្នុងចំណោមពួកអ្នក ចូរឱ្យគេរកមនុស្សពីរនាក់ដែលយុត្តិធម៌ក្នុងចំណោមពួកអ្នក(អ្នកមូស្លីម)ឬអ្នកផ្សេងក្រៅពីពួកអ្នក(អ្នកមិនមែនមូស្លីម)ឱ្យធ្វើសាក្សីនៅពេលធ្វើពាក្យបណ្តាំ ប្រសិនបើពួកអ្នកស្ថិតក្នុងការធ្វើដំណើរ ហើយគ្រោះមរណៈបានមកដល់ពួកអ្នក។ ចូរពួកអ្នកឃាត់គេទាំងពីរទុកសិនបន្ទាប់ពីសឡាតណាមួយ ប្រសិនបើពួកអ្នកមានការសង្ស័យ(ចំពោះការធ្វើសាក្សីរបស់គេទាំងពីរ) រួចឱ្យពួកគេទាំងពីរស្បថចំពោះអល់ឡោះជាម្ចាស់ថា៖ ពួកយើងមិនយកពាក្យសម្បថនេះទៅដោះដូរនឹងកម្រៃណាមួយឡើយ ទោះបីជាសាច់ញាតិក៏ដោយ ហើយពួកយើងក៏មិនលាក់បាំងការធ្វើសាក្សីរបស់អល់ឡោះនោះដែរ។ ពិតណាស់ ប្រសិនបើពួកយើងធ្វើដូច្នេះ នោះពួកយើងនឹងស្ថិតក្នុងចំណោមអ្នកដែលសាងបាបកម្មជាមិនខាន។

107. ក្រោយមកប្រសិនបើគេរកឃើញថា គេទាំងពីរសក្តិសមនឹងទទួលបាបកម្ម(កូតកុហកនៅក្នុងការធ្វើសាក្សី និងការស្បថ)ដូច្នេះ ចូរឱ្យគេរកសាក្សីពីរនាក់ទៀតមកជំនួសវិញ ដែលជាសាច់ញាតិជិតបំផុតរបស់អ្នកស្លាប់ រួចឱ្យគេទាំងពីរស្បថនឹងអល់ឡោះជាម្ចាស់ថា៖ ការធ្វើសាក្សីរបស់ពួកយើង គឺត្រឹមត្រូវជាងការធ្វើសាក្សីរបស់គេទាំងពីរ(សាក្សីមុន) ហើយពួកយើងមិនបំពានសម្បថនោះទេ។ ពិតណាស់ ប្រសិនបើពួកយើងធ្វើដូច្នេះ នោះពួកយើងនឹងស្ថិតក្នុងចំណោមអ្នកដែលបំពានជាមិនខាន។

108. ការធ្វើដូច្នោះគឺកៀកបំផុតក្នុងការធ្វើឱ្យពួកគេធ្វើសាក្សីឱ្យបានត្រឹមត្រូវ ឬធ្វើឱ្យពួកគេខ្លាចគេច្រានចោលពាក្យសម្បថ(របស់ខ្លួន)បន្ទាប់ពីពួកគេបានស្បថរួច។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ និងស្តាប់បង្គាប់ទ្រង់។ ហើយអល់ឡោះមិនចង្អុលបង្ហាញដល់ក្រុមដែលប្រព្រឹត្តល្មើសឡើយ។

109. នៅថ្ងៃដែលអល់ឡោះជាម្ចាស់នឹងប្រមូលផ្តុំអ្នកនាំសារទាំងឡាយ រួចទ្រង់បានមានបន្ទូលថា៖ តើពួកអ្នកត្រូវបានពួកគេ(ប្រជាជាតិរបស់ខ្លួន)ឆ្លើយតបយ៉ាងដូចម្តេចខ្លះ? ពួកគាត់បានឆ្លើយថា៖ ពួកយើងមិនបានដឹងអ្វីឡើយ។ ជាការពិតណាស់ ព្រះអង្គតែមួយគត់ដែលជាអ្នកដឹងនូវប្រការអាថ៌កំបាំងទាំងឡាយ។

110. ហើយ(ចូរអ្នកនឹកឃើញ នៅពេលដែលអល់ឡោះបានមានបន្ទូលថា៖ ឱអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ! ចូរអ្នកនឹកឃើញនូវឧបការគុណរបស់យើងដែលបានប្រទានដល់អ្នក និងម្តាយរបស់អ្នក ខណៈដែលយើងបានពង្រឹងដល់អ្នកតាមរយៈម៉ាឡាអ៊ីកាត់ដីព្រិល ដោយឱ្យអ្នកអាចនិយាយទៅកាន់មនុស្សតាំងពី(នៅជាទារក)នៅក្នុងអង្រឹង និងទាំងពេលដែលអ្នកមានវ័យចំណាស់។ ហើយ(ចូរអ្នកនឹកឃើញ)ខណៈដែលយើងបានបង្រៀនអក្សរ គតិបណ្ឌិត គម្ពីរតាវ៉ឹត និងគម្ពីរអ៊ិញជីលដល់អ្នក។ ហើយ(ចូរអ្នកនឹកឃើញ)ខណៈដែលអ្នកសូនដីឥដ្ឋធ្វើដូចជារូបបក្សី ដោយការអនុញ្ញាតពីយើង រួចមកអ្នកក៏ផ្លុំទៅក្នុងវា ហើយវាក៏ក្លាយទៅជាបក្សីមួយក្បាលដោយការអនុញ្ញាតពីយើង។ ហើយអ្នកអាចព្យាបាលជនពិការភ្នែកពីកំណើត និងអ្នកមានជំងឺឃ្លង់(ឱ្យជាសះស្បើយ)ដោយការអនុញ្ញាតពីយើង។ ហើយអ្នកអាចប្រោសអ្នកស្លាប់ឱ្យរស់ឡើងវិញដោយការអនុញ្ញាតពីយើង។ ហើយ(ចូរអ្នកនឹកឃើញ)ខណៈដែលយើងបានរារាំងអម្បូរអ៊ីស្រាអែលពី(ការប៉ុនប៉ងសម្លាប់)អ្នក នៅពេលដែលអ្នកបាននាំមកឱ្យពួកគេនូវសញ្ញាភស្តុតាងជាច្រើនដ៏ច្បាស់លាស់។ ប៉ុន្តែពួកគ្មានជំនឿក្នុងចំណោមពួកគេបែរជានិយាយថា៖ នេះគ្មានអ្វីក្រៅពីជាមន្តអាគមយ៉ាងច្បាស់លាស់ទៅវិញ។

111. ហើយ(ចូរអ្នកនឹកឃើញ) ខណៈដែលយើងបានបណ្តាលចិត្តដល់ពួកហាវ៉ារីយូន(សាវ័កព្យាការីអ៊ីសា)ថាៈ ចូរពួកអ្នកមានជំនឿចំពោះយើង និង(មានជំនឿ)ចំពោះអ្នកនាំសាររបស់យើង ពួកគេក៏បានពោលថាៈ ពួកយើងមានជំនឿហើយ ហើយសូមព្រះអង្គមេត្តាធ្វើសាក្សីថា ជាការពិតណាស់ ពួកយើងគឺជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

112. (ចូរអ្នកនឹកឃើញ)នៅពេលដែលពួកហាវ៉ារីយូនបាននិយាយថាៈ ឱអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ! តើព្រះជាម្ចាស់របស់អ្នកអាចបញ្ចុះមកឱ្យពួកយើងនូវតុអាហារមួយពីលើមេឃបានដែរឬទេ? គាត់បានតបថាៈ ចូរពួកអ្នកកោតខ្លាចអល់ឡោះប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿមែននោះ។

113. ពួកគេបានតបថាៈ ពួកយើងចង់ទទួលទានអំពីអាហារនោះ និងដើម្បីឱ្យចិត្តរបស់ពួកយើងមានភាពនឹងនរ ហើយនិងដើម្បីឱ្យពួកយើងដឹងថា អ្នកពិតជាអ្នកស្មោះត្រង់ចំពោះពួកយើងពិតមែន។ ហើយពួកយើងនឹងស្ថិតក្នុងចំណោមអ្នកធ្វើសាក្សីលើរឿងនេះ។

114. ព្យាការីអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំក៏បានបួងសួងថាៈ បពិត្រអល់ឡោះជាព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបញ្ចុះតុអាហារមួយពីលើមេឃមកឱ្យយើងខ្ញុំ ដើម្បីធ្វើជាថ្ងៃបុណ្យរបស់យើងខ្ញុំ សម្រាប់ជំនាន់យើងខ្ញុំ ក៏ដូចជាអ្នកជំនាន់ក្រោយព្រមទាំងដើម្បីជាសញ្ញាភស្តុតាងមួយពីព្រះអង្គ។ សូមព្រះអង្គមេត្តាប្រទានលាភសក្ការៈដល់យើងខ្ញុំផង។ ហើយព្រះអង្គ ជាអ្នកប្រទានលាភសក្ការៈដ៏ប្រសើរបំផុត។

115. អល់ឡោះទ្រង់បានមានបន្ទូលថាៈ ពិតប្រាកដណាស់ យើងជាអ្នកបញ្ចុះវា(តុអាហារ)ទៅឱ្យពួកអ្នក។ ដូច្នេះ ជនណាហើយក្នុងចំណោមពួកអ្នកដែលគ្មានជំនឿបន្ទាប់ពីនោះ ជាការពិតណាស់ យើងនឹងដាក់ទណ្ឌកម្មរបគេនូវទណ្ឌកម្មមួយ(ដ៏ធ្ងន់ធ្ងរបំផុត)ដែលយើងមិនធ្លាប់បានដាក់លើនរណាម្នាក់នៃពិភពទាំងឡាយឡើយ។

116. ហើយ(ចូរអ្នកនឹកឃើញ) ខណៈដែលអល់ឡោះជាម្ចាស់ទ្រង់សួរថាៈ ឱអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ! តើអ្នកឬដែលបាននិយាយទៅកាន់មនុស្សលោកថាៈ ចូរពួកអ្នកយកខ្ញុំ និងម្តាយរបស់ខ្ញុំធ្វើជាព្រះជាម្ចាស់ក្រៅពីអល់ឡោះនោះ? គាត់បានឆ្លើយថាៈ ព្រះអង្គមហាស្អាតស្អំ! មិនគប្បីឡើយសម្រាប់ខ្ញុំក្នុងការនិយាយនូវអ្វីដែលពុំមែនជាការពិតសោះនោះ។ ប្រសិនបើខ្ញុំបាននិយាយបែបនេះមែន ប្រាកដជាព្រះអង្គបានដឹងជាមិនខាន។ ព្រះអង្គដឹង(ទាំងអស់)នូវអ្វីដែលមាននៅក្នុងខ្លួនរបស់ខ្ញុំ តែខ្ញុំមិនដឹងនូវអ្វីដែលមាននៅក្នុងខ្លួនព្រះអង្គឡើយ។ ជាការពិតណាស់ ព្រះអង្គតែមួយគត់ដែលជាអ្នកដឹងនូវប្រការអាថ៌កំបាំងទាំងឡាយ។

117. ខ្ញុំមិនបាននិយាយទៅកាន់ពួកគេក្រៅតែពីអ្វីដែលទ្រង់បានប្រើខ្ញុំនោះទេ គឺចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)ដែលជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ហើយខ្ញុំជាអ្នកធ្វើសាក្សីលើពួកគេដរាបណាខ្ញុំមានវត្តមាននៅក្នុងចំណោមពួកគេ។ តែនៅពេលដែលព្រះអង្គបានឱ្យខ្ញុំស្លាប់(លើកខ្ញុំយកទៅលើមេឃ) គឺព្រះអង្គជាអ្នកឃ្លាំមើលទៅលើពួកគេ។ ហើយព្រះអង្គទ្រង់ជាសាក្សីលើអ្វីៗទាំងអស់។

118. ប្រសិនបើព្រះអង្គដាក់ទណ្ឌកម្មពួកគេ ពិតប្រាកដណាស់ ពួកគេគឺជាខ្ញុំបម្រើរបស់ព្រះអង្គ។ តែប្រសិនបើព្រះអង្គអភ័យទោសឱ្យពួកគេ ពិតប្រាកដណាស់ ព្រះអង្គគឺជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

119. អល់ឡោះបានមានបន្ទូលថាៈ នេះគឺជាថ្ងៃដែលបណ្តាអ្នកដែលសច្ចៈទាំងឡាយទទួលបានប្រយោជន៍ពីភាពសច្ចៈរបស់ខ្លួន។ សម្រាប់ពួកគេនឹងទទួលបានឋានសួគ៌ដែលមានទន្លេជាច្រើនហូរកោត់ពីក្រោមវា ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ អល់ឡោះបានពេញចិត្តចំពោះពួកគេ ហើយពួកគេក៏បានពេញចិត្តចំពោះទ្រង់វិញដែរ។ នោះហើយ គឺជាជោគជ័យដ៏ធំធេងបំផុត។

120. ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី និងអ្វីដែលមាននៅក្នុងវា គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

ជំពូក អាល់អន់អាម

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. សេចក្តីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី ព្រមទាំងបានបង្កើតភាពងងឹត(ពេលយប់)និងពន្លឺ(ពេលថ្ងៃ)។ ទោះជាបែបនេះក៏ដោយ ក៏ពួកគ្មានជំនឿនៅតែចាត់ទុកអ្នកផ្សេងប្រៀបស្មើនឹងទ្រង់(គោរពសក្ការៈអ្នកផ្សេងរួមជាមួយនឹងទ្រង់)ដដែល។

2. ទ្រង់គឺជាអ្នកដែលបានបង្កើតពួកអ្នក(ឱមនុស្សលោកទាំងឡាយ)អំពីដីឥដ្ឋ។ បន្ទាប់មក ទ្រង់បានកំណត់អាយុកាល(របស់ពួកអ្នក) និងបានកំណត់ពេលវេលាមួយផ្សេងទៀត(ថ្ងៃបរលោក)នៅនឹងទ្រង់។ ក្រោយមក ពួកអ្នកនៅតែមានមន្ទិលសង្ស័យដដែល។

3. ហើយអល់ឡោះ(ជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ)ទាំងនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី។ ទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកលាក់បាំង និងអ្វីដែលពួកអ្នកលាតត្រដាង។ ហើយទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

4. ហើយគ្មានភស្តុតាងណាមួយក្នុងចំណោមភស្តុតាងនៃព្រះជាម្ចាស់របស់ពួកគេ(ពួកមុស្លីគីន)បានមកដល់ពួកគេឡើយ លើកលែងតែពួកគេបែរចេញអំពីវា។

5. ជាការពិតណាស់ ពួកគេបានបដិសេធនឹងសេចក្តីពិតនៅពេលដែលវាបានមកដល់ពួកគេ។ ហើយដំណឹងទាំងឡាយដែលពួកគេធ្លាប់បានសើចចំអកចំពោះវានោះ នឹងមកដល់ពួកគេជាមិនខាន។

6. តើពួកគេ(ពួកគ្មានជំនឿ)មិនបានឃើញទេឬថា តើមានប្រជាជាតិប៉ុន្មានហើយមុនពួកគេដែលយើងបានបំផ្លាញនោះ? យើងបានប្រទានអំណាចដល់ពួកគេលើផែនដីនូវអ្វីដែលយើងពុំធ្លាប់បានប្រទានឱ្យពួកអ្នកនោះឡើយ។ ហើយយើងបានបញ្ចាំះទឹកភ្លៀងយ៉ាងច្រើនទៅលើពួកគេ និងបានធ្វើឱ្យមានទន្លេជាច្រើនហូរពីក្រោម(លំនៅឋានរបស់)ពួកគេ។ ពេលនោះ យើងក៏បានបំផ្លាញពួកគេដោយសារតែបាបកម្មរបស់ពួកគេ ហើយអល់ឡោះបានបង្កើតប្រជាជាតិមួយផ្សេងទៀតបន្ទាប់ពីពួកគេ។

7. ហើយបើទោះបីជាយើងបានបញ្ចុះទៅឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរមួយដែលត្រូវបានសរសេរនៅក្នុងក្រដាសដោយពួកគេបានប៉ះគម្ពីរនោះដោយដៃរបស់ពួកគេក៏ដោយ ក៏ពួកគ្មានជំនឿនៅតែនិយាយថា៖ នេះគឺគ្មានអ្វីក្រៅពីមន្តអាគមយ៉ាងច្បាស់នោះឡើយ។

8. ហើយពួកគេបាននិយាយថា៖ ប្រសិនបើគេ(អល់ឡោះ)បញ្ចុះម៉ាឡាអ៊ីកាត់ម្នាក់មកជាមួយគាត់(ព្យាការីមូហាំម៉ាត់)នោះ(ពួកយើងប្រាកដជានឹងមានជំនឿជាមិនខាន)។ ប្រសិនបើយើង(អល់ឡោះ)បញ្ចុះម៉ាឡាអ៊ីកាត់មួយរូប(តាមការទាមទារបស់ពួកគេនោះ) ច្បាស់ជាកិច្ចការនោះនឹងត្រូវបញ្ចប់។ ក្រោយមក ពួកគេនឹងមិនត្រូវបានគេពន្យារពេលឱ្យឡើយ។

9. ហើយប្រសិនបើយើងបញ្ជូនអ្នកនាំសារជាម៉ាឡាអ៊ីកាត់វិញនោះ ប្រាកដជាយើងបង្កើតម៉ាឡាអ៊ីកាត់នោះក្នុងរូបភាពជាបុរស ហើយយើងនឹងធ្វើឲ្យពួកគេកាន់ច្រឡំដូចដែលពួកគេកាន់ច្រឡំមិនខាន។

10. ហើយជាការពិតណាស់ មានអ្នកនាំសារជាច្រើនមុនអ្នកក៏ត្រូវបានគេចំអកឡកឡឺយដែរ។ ពេលនោះ ពួកដែលចំអកឡកឡឺយក្នុងចំណោមពួកគេត្រូវបានហ៊ុមព័ទ្ធទៅដោយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានចំអកឡកឡឺយចំពោះវា។

11. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកធ្វើដំណើរនៅលើផែនដីនេះ បន្ទាប់មក ចូរពួកអ្នកពិចារណាមើលចុះថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបដិសេធនោះទៅជាយ៉ាងណា?

12. ចូរអ្នកពោលថា៖ តើអ្វីដែលមាននៅលើមេឃជាច្រើនជាន់និងផែនដីជាកម្មសិទ្ធិរបស់អ្នកណា? ចូរអ្នកឆ្លើយ(ប្រាប់ពួកគេ)ថា៖ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ទ្រង់បានកំណត់នូវក្តីមេត្តាករុណាលើខ្លួនទ្រង់ផ្ទាល់។ ទ្រង់ពិតជានឹងប្រមូលផ្តុំពួកអ្នកនៅថ្ងៃបរលោកដែលគ្មានការមន្ទិលសង្ស័យចំពោះវាឡើយ។ ពួកដែលខាតបង់ខ្លួនឯងនោះ ជាការពិតណាស់ ពួកគេគ្មានជំនឿឡើយ។

13. ការគ្រប់គ្រងអ្វីៗទាំងអស់ មិនថាស្ថិតនៅពេលយប់ឬពេលថ្ងៃ គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

14. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើឲ្យខ្ញុំយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាអ្នកគាំពារឬ ខណៈដែលទ្រង់គឺជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយទ្រង់ជាអ្នកដែលប្រទានលាភសក្ការៈដល់គេ ពុំមែនគេប្រទានលាភសក្ការៈដល់ទ្រង់ឡើយនោះ? ចូរអ្នកពោលទៀតថា៖ ពិតប្រាកដណាស់ ខ្ញុំត្រូវបានគេបញ្ជាឱ្យក្លាយទៅជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)ដំបូងគេបង្អស់(ក្នុងចំណោមប្រជាជាតិនេះ)។ ហើយអ្នកមិនត្រូវក្លាយខ្លួនស្ថិតក្នុងចំណោមពួកដែលធ្វើស្តីរិកឡើយ។

15. ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ ខ្ញុំខ្លាចទណ្ឌកម្មនៅថ្ងៃដ៏ធ្ងន់ធ្ងរបំផុត(ថ្ងៃបរលោក)ប្រសិនបើខ្ញុំប្រព្រឹត្តល្មើសនឹងព្រះជាម្ចាស់របស់ខ្ញុំ។

16. ជនណាដែលត្រូវបានគេ(អល់ឡោះ)បញ្ចៀសពីទណ្ឌកម្មនៅថ្ងៃនោះ គឺទ្រង់ពិតជាមានក្តីមេត្តាចំពោះគេ។ ហើយនោះ គឺជាជោគជ័យមួយដ៏ច្បាស់លាស់។

17. ហើយប្រសិនបើអល់ឡោះឱ្យគ្រោះថ្នាក់អ្វីមួយប៉ះទង្គិចអ្នក(ឱកូនចៅអាហ្វាំ)នោះ គឺគ្មានអ្នកដែលអាចការពាររូបគេក្រៅពីទ្រង់ឡើយ។ ហើយប្រសិនបើទ្រង់ឱ្យអ្នកទទួលបាននូវប្រការល្អវិញនោះ ពិតប្រាកដណាស់ ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

18. ហើយទ្រង់ជាអ្នកមានអានុភាពលើសលប់ទៅលើបណ្តាខ្ញុំបម្រើរបស់ទ្រង់។ ហើយទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

19. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើមានអ្វីដែលជាសាក្សីធំជេងបំផុត(ដែលបញ្ជាក់ពីភាពស្មោះត្រង់របស់ខ្ញុំ)? ចូរអ្នកឆ្លើយថា៖ គឺអល់ឡោះជាម្ចាស់។ ទ្រង់នោះហើយជាសាក្សីរវាងខ្ញុំនិងរវាងពួកអ្នក។ ហើយគេបានផ្តល់វ៉ាហ៊ីដល់ខ្ញុំនូវគម្ពីរគួរអោននេះដើម្បីឱ្យខ្ញុំព្រមានបន្លាចពួកអ្នកតាមរយៈវា ហើយនិងជនណាដែលគម្ពីរនេះបានទៅដល់រូបគេ។ តើពួកអ្នកហ៊ានធ្វើសាក្សីថា ពិតប្រាកដណាស់ មានព្រះផ្សេង(ដែលត្រូវគោរពសក្ការៈ)រួមជាមួយនឹងអល់ឡោះដែរឬទេ? ចូរអ្នកតបថា៖ ខ្ញុំមិនធ្វើសាក្សីនោះឡើយ។ ចូរអ្នកពោលទៀតថា៖ តាមពិត ទ្រង់គឺជាព្រះជាម្ចាស់(ដែលត្រូវគោរពសក្ការៈ)តែមួយគត់ ហើយពិតប្រាកដណាស់ ខ្ញុំមិនជាប់ពាក់ព័ន្ធនឹងអ្វីដែលពួកអ្នកកំពុងតែធ្វើស្តីរិកនោះឡើយ។

20. ពួកដែលយើងបានប្រទានគម្ពីរដល់ពួកគេ(ពួកយូដានិងគ្រីស្ទាន) ពួកទាំងនោះស្គាល់គាត់(ព្យាការីមូហាំម៉ាត់)ច្បាស់ប្រៀបដូចជាពួកគេស្គាល់កូនចៅរបស់ពួកគេដូច្នោះដែរ។ ពួកដែលខាតបង់ខ្លួនឯងនោះ ជាការពិតណាស់ ពួកគេគ្មានជំនឿឡើយ។

21. ហើយគ្មានអ្នកណាដែលបំពានជាងអ្នកដែលចោទប្រកាន់កុតកុហកទៅលើអល់ឡោះជាម្ចាស់ ឬបដិសេធនឹងកស្តតាងទាំងឡាយរបស់ទ្រង់នោះឡើយ។ ជាការពិតណាស់ ពួកដែលបំពាននោះ ពួកគេគឺមិនទទួលជោគជ័យឡើយ។

22. ហើយនៅថ្ងៃដែលយើងនឹងប្រមូលផ្តុំពួកគេទាំងអស់គ្នា ក្រោយមក យើងមានបន្ទូលទៅកាន់ពួកដែលធ្វើស៊ីរិកថា៖ តើព្រះនានាដែលពួកអ្នកធ្លាប់បានអះអាង(ថាជាដៃគូរបស់អល់ឡោះ)នោះនៅឯណាទៅ ?

23. ក្រោយមក ពួកគេគ្មានពាក្យដោះសាអ្វីឡើយ ក្រៅតែពីពួកគេនិយាយថា៖ ពួកយើងសូមស្បថនឹងអល់ឡោះជាព្រះជាម្ចាស់របស់យើងខ្ញុំ! ពួកយើងពុំធ្លាប់ជាអ្នកដែលធ្វើស៊ីរិក(គោរពសក្ការៈអ្នកផ្សេងរួមជាមួយទ្រង់)នោះឡើយ។

24. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មើលចុះ ថាតើពួកគេកុតកុហកចំពោះខ្លួនឯងយ៉ាងដូចម្តេច ? ហើយអ្វីដែលពួកគេធ្លាប់បានប្រឌិតឡើង(ធ្វើជាព្រះ)នោះ បានបាត់ចេញពីពួកគេ។

25. ហើយក្នុងចំណោមពួកគេ(ពួកមុស្លីគីន) គឺមានជនដែលស្តាប់អ្នក(សូត្រគម្ពីរគួរអាន)។ តែយើងបានដាក់គម្របនៅលើដួងចិត្តរបស់ពួកគេមិនឲ្យពួកគេយល់ពីវា(គម្ពីរគួរអាន) ព្រមទាំងបានដាក់ឆ្នុកនៅក្នុងត្រចៀករបស់ពួកគេផងដែរ។ ហើយបើទោះបីជាពួកគេបានឃើញរាល់សញ្ញាកស្តតាងទាំងអស់ក៏ដោយ ក៏ពួកគេគ្មានជំនឿចំពោះវាដែរ។ លុះដល់ពេលពួកគេបានទៅជួបអ្នក ពួកគេបានប្រកែកដេញដោលនឹងអ្នកដោយពួកដែលគ្មានជំនឿបាននិយាយថា៖ ពិតប្រាកដណាស់ នេះគឺគ្មានអ្វីក្រៅពីរឿងនិទានរបស់អ្នកជំនាន់មុននោះឡើយ។

26. ពួកគេហាមឃាត់អ្នកដទៃមិនឲ្យមានជំនឿ(ចំពោះអ្នកនាំសារ) ហើយពួកគេផ្ទាល់ក៏គ្មានជំនឿដែរ។ ហើយពួកគេមិនបានបំផ្លាញអ្វីនោះឡើយ ក្រៅតែពីខ្លួនឯងប៉ុណ្ណោះ។ ប៉ុន្តែពួកគេមិនដឹងខ្លួនឡើយ។

27. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញពេលដែលពួកគេត្រូវបានគេយកទៅបង្ហាញខ្លួននៅមុខឋាននរក។ ពេលនោះ ពួកគេនិយាយថា៖ ឱអនិច្ចាពួកយើង! ប្រសិនបើពួកយើងត្រូវគេឲ្យវិលត្រឡប់(ទៅកាន់ជីវិតលោកិយម្តងទៀត) ពួកយើងពិតជានឹងមិនបដិសេធបណ្តាកស្តតាងរបស់ព្រះជាម្ចាស់នៃយើងឡើយ ហើយពួកយើងនឹងស្ថិតក្នុងចំណោមបណ្តាអ្នកដែលមានជំនឿជាមិនខាន។

28. ផ្ទុយទៅវិញ អ្វីដែលពួកគេបានលាក់បាំងកាលពីមុននោះបានលាតត្រដាងដល់ពួកគេ។ ហើយបើទោះជាពួកគេត្រូវបានគេឲ្យវិលត្រឡប់(ទៅកាន់ជីវិតលោកិយវិញ)ក៏ដោយ ក៏ពួកគេពិតជានឹងប្រព្រឹត្តនូវអ្វីដែលគេបានហាមឃាត់ពួកគេដដែល។ ហើយពិតប្រាកដណាស់ ពួកគេគឺជាពួកដែលកុតកុហក។

29. ហើយពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ វាគ្មានអ្វីក្រៅពីជីវិតលោកិយរបស់ពួកយើងប៉ុណ្ណោះ ហើយពួកយើងក៏មិនត្រូវបានគេបង្កើតឲ្យរស់ឡើងវិញនោះដែរ។

30. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញពេលដែលពួកគេ(ពួកគ្មានជំនឿ)ត្រូវបានគេឲ្យឈរនៅចំពោះមុខព្រះជាម្ចាស់របស់ពួកគេ។ ទ្រង់បានមានបន្ទូលថា៖ តើពុំមែនទេឬ នេះគឺជាការពិតនោះ ? ពួកគេឆ្លើយថា៖ វាជាការពិតមែនហើយ សូមស្បថនឹងព្រះជាម្ចាស់របស់ពួកយើង។ ទ្រង់បានតបថា៖ ដូច្នេះ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រឆាំង។

31. ពិតប្រាកដណាស់ ពិតជាខាតបង់ហើយពួកដែលបដិសេធនឹងការជួបអល់ឡោះជាម្ចាស់(នៅថ្ងៃបរលោក)នោះ។ លុះនៅពេលដែលថ្ងៃបរលោកបានមកដល់ពួកគេភ្លាម។(មួយរំពេច) ពួកគេក៏និយាយថា៖ គួរឱ្យសោកស្តាយបំផុតសម្រាប់ពួកយើងចំពោះការធ្វេសប្រហែសរបស់ពួកយើងនៅក្នុងវា(លោកិយ) ខណៈដែលពួកគេរែកពន់បាបកម្មរបស់ខ្លួនលើខ្នងរបស់ពួកគេ។ តើពុំមែនទេឬ អ្វីដែលពួកគេរែកពន់នោះ គឺអាក្រក់ជាទីបំផុត។

32. ហើយជីវិតលោកិយ គ្មានអ្វីក្រៅពីជាល្បែងកំសាន្ត និងជាការបោកបញ្ឆោតប៉ុណ្ណោះ។ រីឯឋានបរលោកវិញ គឺល្អប្រសើរបំផុតសម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)។ តើពួកអ្នក(ឱពួកមុស្លីគីន)មិនចេះពិចារណាទេឬ?

33. យើងពិតជាបានដឹងថា ពាក្យសម្តី(បដិសេធ)របស់ពួកគេ ធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានទុក្ខព្រួយ។ តាមពិតពួកគេមិនបានបដិសេធនឹងអ្នកនោះឡើយ ក៏ប៉ុន្តែពួកដែលបំពាន គឺពួកគេប្រឆាំងនឹងបណ្តាភស្តុតាងរបស់អល់ឡោះ។

34. ជាការពិតណាស់ បណ្តាអ្នកនាំសារជាច្រើនមុនអ្នក ក៏ត្រូវបានគេបដិសេធដូចគ្នាដែរ ប៉ុន្តែពួកគេបានអត់ធ្មត់ចំពោះការបដិសេធ និងការធ្វើទុក្ខបុកម្នេញ រហូតដល់ជំនួយរបស់យើងបានមកដល់ពួកគាត់។ ហើយគ្មានការកែប្រែនូវពាក្យបន្ទូលរបស់អល់ឡោះឡើយ។ ហើយពិតប្រាកដណាស់ ដំណឹង(រឿងរ៉ាវ)របស់បណ្តាអ្នកនាំសារ(ជំនាន់មុន)គឺបានមកដល់អ្នកហើយ។

35. ប្រសិនបើការងាកចេញរបស់ពួកគេបង្កការលំបាកខ្លាំងដល់អ្នក ដូច្នេះប្រសិនបើអ្នកមានលទ្ធភាពស្វែងរករូងមួយចូលទៅក្នុងដី ឬជណ្តើរមួយឡើងទៅលើមេឃ ហើយអ្នកអាចនាំយកភស្តុតាងណាមួយមកឱ្យពួកគេ(ចូរអ្នកធ្វើចុះ)។ ហើយប្រសិនបើអល់ឡោះមានចេតនា ទ្រង់ប្រាកដជានឹងប្រមូលផ្តុំពួកគេឱ្យស្ថិតលើការចង្អុលបង្ហាញជាមិនខាន។ ដូចនេះ អ្នកមិនត្រូវស្ថិតក្នុងចំណោមអ្នកដែលមិនដឹងរឿងនោះឡើយ។

36. តាមពិត មានតែអ្នកដែលស្តាប់(ពាក្យសម្តីរបស់ព្យាការីមូហាំម៉ាត់)ទេដែលឆ្លើយតប(ទទួលយកអ្វីដែលគាត់បាននាំមក)នោះ។ ហើយចំពោះអ្នកដែលស្លាប់វិញ អល់ឡោះជាម្ចាស់នឹងបង្កើតពួកគេឱ្យរស់ឡើងវិញ(នៅថ្ងៃបរលោក)។ បន្ទាប់មកពួកគេនឹងត្រូវគេនាំត្រលប់ទៅកាន់ទ្រង់(តែមួយគត់)។

37. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះសញ្ញាភស្តុតាងមួយពីព្រះជាម្ចាស់របស់គាត់មកឱ្យគាត់តែម្តងទៅ? ចូរអ្នកឆ្លើយថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានសមត្ថភាពក្នុងការបញ្ចុះសញ្ញាភស្តុតាងណាមួយ។ ក៏ប៉ុន្តែភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

38. ហើយសត្វគ្រប់ប្រភេទដែលមាននៅលើផែនដី និងបក្សីដែល(ហើរ)ត្រដាងស្លាបរបស់វា គឺមានអម្ប្រាជាច្រើនផ្សេងៗដូចពួកអ្នក(មនុស្សលោក)ដែរ។ យើងមិនបានទុកចោលអ្វីមួយក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)ឡើយ។ បន្ទាប់មកពួកគេនឹងត្រូវគេប្រមូលផ្តុំទៅកាន់ព្រះជាម្ចាស់របស់ពួកគេវិញ។

39. ហើយពួកដែលបានបដិសេធនឹងបណ្តាភស្តុតាងរបស់យើង ប្រៀបដូចជាមនុស្សថ្លង់និងមនុស្សគ ដែលស្ថិតក្នុងភាពងងឹតសូន្យសុងដូច្នោះដែរ។ ជនណាហើយដែលអល់ឡោះមានចេតនា ទ្រង់នឹងឱ្យរូបគេវង្វេង ហើយជនណាហើយដែលទ្រង់មានចេតនា ទ្រង់នឹងធ្វើឱ្យរូបគេស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ។

40. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើទណ្ឌកម្មរបស់អល់ឡោះបានមកដល់ពួកអ្នកឬថ្ងៃបរលោកបានមកដល់ពួកអ្នក តើពួកអ្នកនឹងបួងសួងសុំពីអ្នកផ្សេងក្រៅពីអល់ឡោះឬ(ក្នុងខណៈពេលនោះ) ប្រសិនបើពួកអ្នកជាអ្នកដែលត្រឹមត្រូវ(ចំពោះការអះអាងរបស់ពួកអ្នក)មែននោះ?

41. ផ្ទុយទៅវិញ ចំពោះទ្រង់(តែមួយគត់)ដែលពួកអ្នកនឹងបួងសួងសុំ។ ពេលនោះ ទ្រង់នឹងបញ្ចៀសពួកអ្នកពីអ្វីដែលពួកអ្នកបួងសួងសុំ ប្រសិនបើទ្រង់មានចេតនា ហើយពួកអ្នកនឹងបំភ្លេចនូវអ្វីដែលពួកអ្នកបានធ្វើស្ទើរតែជាមិនខាន។

42. ជាការពិតណាស់ យើងបានបញ្ជូន(អ្នកនាំសារ)ទៅកាន់ប្រជាជាតិជាច្រើនមុនអ្នក(តែពួកគេបានបដិសេធ)។ ពេលនោះ យើងបានឱ្យពួកគេទទួលរងនូវភាពក្រខ្សត់ និងជំងឺឈឺថ្កាត់ សង្ឃឹមថាពួកគេនឹងបន្ទាបខ្លួន។

43. ប្រសិនបើពួកគេបន្ទាបខ្លួននៅពេលដែលពួកគេទទួលនូវគ្រោះរបស់យើងនោះ(ច្បាស់ជាយើងនឹងអាណិតអាសូរដល់ពួកគេជាមិនខាន)។ ក៏ប៉ុន្តែដួងចិត្តរបស់ពួកគេមានភាពរឹងរូស ហើយស្មែតនបានតុបតែងលម្អដល់ពួកគេនូវអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

44. ហើយនៅពេលដែលពួកគេបានបោះបង់ចោលនូវអ្វីដែលគេបានរំលឹកពួកគេតាមរយៈវា(ភាពក្រខ្សត់ ជំងឺឈឺថ្កាត់) យើងក៏បានបើកនូវបណ្តាទ្វារ(នៃសេចក្តីល្អ)ទាំងឡាយដល់ពួកគេ។ លុះនៅពេលដែលពួកគេសប្បាយរីករាយនឹងអ្វីដែលគេបានផ្តល់ឲ្យពួកគេនោះ យើងក៏បានដាក់ទណ្ឌកម្មភ្លាមៗ។ ហើយនៅពេលនោះ ពួកគេក៏បាត់បង់អស់នូវក្តីសង្ឃឹម។

45. ពេលនោះ ក្រុមដែលបំពានត្រូវបានគេបំផ្លាញផ្តាច់ពូជ។ ហើយសេចក្តីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

46. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើអល់ឡោះទ្រង់ដកយកសោតវិញ្ញាណ(ការឮ)របស់ពួកអ្នក និងចក្ខុវិញ្ញាណ(ការមើលឃើញ)របស់ពួកអ្នក ព្រមទាំងបោះត្រាភ្ជិតទៅលើចិត្តរបស់ពួកអ្នកនោះ តើមានព្រះផ្សេងឯណាក្រៅពីអល់ឡោះដែលនឹងនាំវាមកឱ្យពួកអ្នកវិញ? ចូរអ្នកពិចារណាចុះ ថាតើយើងបានបង្ហាញកស្តុតាងជាច្រើនប្រភេទដល់ពួកគេយ៉ាងដូចម្តេច? បន្ទាប់មក ពួកគេនៅតែងាកចេញដដែល។

47. ចូរអ្នកពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើទណ្ឌកម្មរបស់អល់ឡោះបានមកដល់ពួកអ្នកភ្លាមៗ ឬមកដល់ស្តែងៗ(ឃើញផ្ទាល់នឹងភ្នែក) តើមានអ្នកណាដែលត្រូវគេបំផ្លាញ ក្រៅតែពីក្រុមដែលបំពាននោះ?

48. ហើយយើងមិនបានបញ្ជូនអ្នកនាំសារទាំងឡាយនោះឡើយ លើកលែងតែដើម្បីធ្វើជាអ្នកផ្តល់ដំណឹងរីករាយ(ដល់អ្នកមានជំនឿ) និងជាអ្នកព្រមានបន្លាច(ដល់ពួកគ្មានជំនឿ)។ ដូច្នេះ ជនណាហើយដែលមានជំនឿ និងបានកែប្រែ(ទង្វើរបស់ខ្លួន)នោះ គឺពួកគេគ្មានការភ័យខ្លាចនោះឡើយ ហើយក៏គ្មានទុក្ខព្រួយនោះដែរ។

49. រីឯពួកដែលបានបដិសេធនឹងបណ្តាកស្តុតាងទាំងឡាយរបស់យើង គឺពួកគេនឹងទទួលនូវទណ្ឌកម្មជាមិនខានដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តល្មើស។

50. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំមិនដែលប្រាប់ពួកអ្នកថា ខ្ញុំមានឃ្លាំង(នៃលាភសក្ការៈ)របស់អល់ឡោះនោះឡើយ ហើយខ្ញុំក៏មិនដឹងនូវប្រការអាថ៌កំបាំងនោះដែរ។ ហើយខ្ញុំក៏មិនដែលប្រាប់ពួកអ្នកដែរថា ពិតប្រាកដណាស់ រូបខ្ញុំគឺជាម៉ាឡាអ៊ីកាត់នោះទេ។ តាមពិត ខ្ញុំគ្រាន់តែដើរតាមអ្វីដែលគេ(អល់ឡោះ)បានផ្តល់ជាវ៉ាហ៊ីមកឱ្យខ្ញុំប៉ុណ្ណោះ។ ចូរអ្នកពោលថា៖ តើស្មើគ្នាដែរឬទេរវាងមនុស្សខ្វាក់(គ្មានជំនឿ) និងអ្នកដែលអាចមើលឃើញ(មានជំនឿ)? តើពួកអ្នក(ឱពួកមុស្លីគីន)មិនចេះពិចារណាទេឬ?

51. ហើយតាមរយៈវា(គម្ពីរគួរអាន) ចូរអ្នកព្រមានបន្លាចបណ្តាអ្នកដែលខ្លាចគេប្រមូលផ្តុំទៅកាន់ព្រះជាម្ចាស់របស់ពួកគេ(នាថ្ងៃបរលោក)ថា សម្រាប់ពួកគេ គ្មានអ្នកគាំពារ និងអ្នកដែលអាចជួយអន្តរាគមន៍ណាផ្សេងពីទ្រង់ឡើយ។ សង្ឃឹមថាពួកគេនឹងកោតខ្លាច(អល់ឡោះ)។

52. ហើយចូរអ្នកកុំបណ្តេញបណ្តាអ្នកដែលបួងសួង(គោរពសក្ការៈ)ចំពោះព្រះជាម្ចាស់របស់ខ្លួន ទាំងពេលព្រឹកនិងពេលល្ងាច ដោយពួកគេមានចិត្តស្មោះត្រង់ចំពោះទ្រង់ឱ្យសោះ។ អ្នកគ្មានតួនាទីអ្វីបន្តិចសោះឡើយក្នុងការកាត់សេចក្តីលើពួកគេ ហើយពួកគេក៏គ្មានតួនាទីអ្វីបន្តិចណាដែរក្នុងការកាត់សេចក្តីលើអ្នក។ ជាការពិតណាស់ ប្រសិនបើអ្នកបណ្តេញពួកគេ នោះរូបអ្នកនឹងស្ថិតនៅក្នុងចំណោមពួកដែលបំពានជាមិនខាន។

53. ហើយដូច្នោះដែរ យើងបានសាកល្បងចំពោះពួកគេមួយចំនួន(អ្នកមានដែលគ្មានជំនឿ)នឹងពួកគេមួយចំនួនទៀត(អ្នកក្រដែលមានជំនឿ) ដើម្បីឱ្យពួកគេ(អ្នកមាន)និយាយថា៖ តើពួកទាំងនោះឬដែលអល់ឡោះជាម្ចាស់បានប្រោសប្រទានដល់ពួកគេក្នុងចំណោមពួកយើងនោះ? តើពុំមែនទេឬ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតចំពោះបណ្តាអ្នកដែលដឹងគុណ។

54. ហើយនៅពេលដែលបណ្តាអ្នកដែលមានជំនឿនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើងបានមកជួបអ្នក(ព្យាការីមូហាំម៉ាត់) ចូរអ្នកនិយាយថា៖ សូមសន្តិភាពកើតមានដល់ពួកអ្នក។ ព្រះជាម្ចាស់របស់ពួកអ្នកបានដាក់កំណត់ក្តីមេត្តាករុណាលើខ្លួនទ្រង់ផ្ទាល់ថា៖ ជាការពិតណាស់ ជនណាដែលបានប្រព្រឹត្តអំពើអាក្រក់ដោយល្ងង់ខ្លៅក្នុងចំណោមពួកអ្នក ក្រោយមកគេបានសារភាពកំហុសបន្ទាប់ពីនោះ និងបានកែប្រែ(ទង្វើរបស់ខ្លួន)វិញនោះ ជាការពិតណាស់ ទ្រង់មហាអភ័យទោសមហាអាណិតស្រលាញ់។

55. ហើយដូច្នោះដែរ យើងបានបញ្ជាក់នូវសញ្ញាកស្តុតាងទាំងឡាយ(របស់យើង) ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីផ្លូវរបស់ពួកដែលប្រព្រឹត្តអំពើអាក្រក់។

56. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ជាការពិតណាស់ គេបានហាមឃាត់ខ្ញុំមិនឱ្យគោរពសក្ការៈចំពោះអ្វីដែលពួកអ្នកកំពុងគោរពសក្ការៈ(ចំពោះពួកវា)ក្រៅពីអល់ឡោះឡើយ។ ចូរអ្នកពោលទៀតថា៖ ខ្ញុំមិនធ្វើតាមទំនើងចិត្តរបស់ពួកអ្នកឡើយ។ ជាការពិតណាស់ ខ្ញុំប្រាកដជាវង្វេងជាមិនខានប្រសិនបើខ្ញុំធ្វើដូច្នោះ ហើយខ្ញុំក៏នឹងមិនស្ថិតក្នុងចំណោមអ្នកដែលទទួលបានការចង្អុលបង្ហាញនោះដែរ។

57. ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ ខ្ញុំស្ថិតនៅលើកស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ខ្ញុំ តែពួកអ្នកបែរជាបដិសេធនឹងវាទៅវិញ។ ខ្ញុំគ្មានអ្វី(ទណ្ឌកម្ម)ដែលពួកអ្នកទទូចសុំឱ្យឆាប់មកដល់នោះទេ។ តាមពិត ការកាត់សេចក្តី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ទ្រង់នឹងកាត់សេចក្តីប្រកបដោយការពិត។ ហើយទ្រង់ជាអ្នកកាត់សេចក្តីដ៏ប្រសើរបំផុត។

58. ចូរអ្នកពោលចុះថា៖ ប្រសិនបើខ្ញុំមានអ្វី(ទណ្ឌកម្ម)ដែលពួកអ្នកទទូចសុំឱ្យឆាប់មកដល់មែននោះ កិច្ចការរវាងខ្ញុំនិងពួកអ្នកនឹងត្រូវបញ្ចប់ជាមិនខាន។ ហើយអល់ឡោះទ្រង់ដឹងបំផុតចំពោះពួកដែលបំពាន។

59. ហើយកូនសោទាំងឡាយនៃប្រការអោថ៌កំបាំង គឺស្ថិតនៅជាមួយទ្រង់(តែមួយគត់)។ គ្មាននរណាម្នាក់ដឹងអំពីវាក្រៅពីទ្រង់ឡើយ។ ហើយទ្រង់ដឹងនូវរាល់អ្វីដែលមាននៅលើគោក និងអ្វីដែលមាននៅក្នុងសមុទ្រ។ គ្មានស្លឹកឈើមួយសន្លឹកណាដែលជ្រុះនោះឡើយ លើកលែងតែទ្រង់ដឹងអំពីវា ហើយក៏គ្មានគ្រាប់ធញ្ញជាតិណាមួយដែលកប់ក្នុងដីងងឹត ឬមានសំណើម ឬក្រៀមស្វិត លើកលែងតែមានចារទុកជាស្រេចនៅក្នុងលិខិតកំណត់ត្រាដ៏ច្បាស់លាស់(ឡាវហ៊ុលម៉ះហ្វូស)។

60. ហើយទ្រង់ជាអ្នកដែលធ្វើឱ្យពួកអ្នកស្លាប់នៅពេលយប់(គេងលក់) ហើយទ្រង់ដឹងនូវអ្វីដែលអ្នកធ្វើនៅពេលថ្ងៃ។ បន្ទាប់មកទ្រង់ធ្វើឱ្យពួកអ្នករស់ឡើងវិញ(ក្រោកពីគេង)ដើម្បីបំពេញនូវអាយុកាល(របស់ពួកអ្នក)ដែលត្រូវបានកំណត់។ ហើយបន្ទាប់មក កន្លែងវិលត្រឡប់របស់ពួកអ្នក គឺទៅកាន់ទ្រង់(តែមួយគត់)។ បន្ទាប់មកទៀត ទ្រង់នឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

61. ហើយទ្រង់ជាអ្នកមានអានុភាពលើបណ្តាខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ហើយគេបានបញ្ជូនម៉ាឡាអ៊ីកាត់ដ៏ឧត្តមទៅកាន់ពួកអ្នក(ដើម្បីកត់ត្រាទង្វើទាំងអស់របស់ពួកអ្នក)។ លុះដល់សេចក្តីស្លាប់បានមកដល់នរណាម្នាក់ក្នុងចំណោមពួកអ្នក ម៉ាឡាអ៊ីកាត់របស់យើងក៏បានដកយកជីវិតរបស់គេ ហើយពួកគេមិនធ្វេសប្រហែសឡើយ។

62. ក្រោយមក ពួកគេក៏ត្រូវបានគេនាំត្រលប់ទៅកាន់អល់ឡោះដែលជាព្រះជាម្ចាស់គ្រប់គ្រងពួកគេដ៏ពិតប្រាកដ។ តើពុំមែនទេឬ ការកាត់សេចក្តី គឺជាកម្មសិទ្ធិរបស់ទ្រង់ ហើយទ្រង់ជាអ្នកជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

63. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើអ្នកណាជាអ្នកជួយសង្គ្រោះពួកអ្នកពីភាពងងឹតសូន្យសុង ទាំងនៅលើគោក និងនៅក្នុងសមុទ្រនោះ? ពួកអ្នកបួងសួងសុំពីទ្រង់(តែមួយគត់)ដោយឱនលំទោន និងស្ងៀមស្ងាត់ថា៖ ប្រសិនបើព្រះអង្គសង្គ្រោះយើងខ្ញុំពីគ្រោះនេះ យើងខ្ញុំពិតជានឹងស្ថិតក្នុងចំណោមអ្នកដែលដឹងគុណជាមិនខាន។

64. ចូរអ្នកពោលថា៖ អល់ឡោះជាអ្នកជួយសង្គ្រោះពួកអ្នកអំពីវា និងអំពីគ្រោះអាសន្នទាំងឡាយ។ តែក្រោយមក ពួកអ្នកបែរជាធ្វើស្ទីរិក(នឹងទ្រង់)ទៅវិញ។

65. ចូរអ្នកពោលចុះថា៖ អល់ឡោះគឺជាអ្នកដែលមានសមត្ថភាពបំផុតលើការបញ្ជូនទណ្ឌកម្មទៅកាន់ពួកអ្នកពីខាងលើពួកអ្នក ឬពីខាងក្រោមជើងពួកអ្នក ឬអាចធ្វើឱ្យចិត្តរបស់ពួកអ្នកច្របូកច្របល់ ហើយពួកអ្នកកាប់សម្លាប់គ្នាទៅវិញទៅមក។ ចូរអ្នកពិចារណាមើលចុះថា តើយើងបង្ហាញភស្តុតាងជាច្រើនប្រភេទ(ដល់ពួកគេ)យ៉ាងដូចម្តេចខ្លះ? សង្ឃឹមថាពួកគេនឹងឈ្វេងយល់។

66. ហើយក្រុមរបស់អ្នកបានបដិសេធនឹងវា(គម្ពីគួរអាន) ខណៈដែលវា គឺជាការពិត។ ចូរអ្នកពោលទៅកាន់ពួកគេចុះថា៖ ខ្ញុំពុំមែនជាអ្នកទទួលខុសត្រូវលើពួកអ្នកនោះទេ។

67. រាល់ព័ត៌មាន(រឿងរ៉ាវ)ទាំងអស់សុទ្ធតែមានការកំណត់។ ដូចនេះ ពួកអ្នកនឹងដឹងជាមិនខាន។

68. ហើយនៅពេលដែលអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញពួកដែលនិយាយលេងសើចចំពោះសញ្ញាភស្តុតាងទាំងឡាយរបស់យើង ចូរអ្នកដកខ្លួនចេញពីពួកគេរហូតដល់ពួកគេនិយាយលេងសើចពីរឿងផ្សេង។ ហើយនៅពេលដែលស្មែតនបានធ្វើឱ្យអ្នកភ្លេច ចូរអ្នកកុំអង្គុយជាមួយក្រុមដែលបំពានទាំងនោះ(តទៅទៀត)ក្រោយពីអ្នកបាននឹកឃើញហើយនោះ។

69. ហើយពុំមែនជាតួនាទីរបស់បណ្តាអ្នកដែលកោតខ្លាចអល់ឡោះក្នុងការជំនុំជម្រះពួកគេ(ពួកបំពាន)បន្តិចណាឡើយ។ ក៏ប៉ុន្តែគ្រាន់តែជាការរំលឹក(ដល់ពួកគេប៉ុណ្ណោះ) សង្ឃឹមថាពួកគេកោតខ្លាច។

70. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បណ្តោយពួកដែលយកសាសនារបស់ពួកគេធ្វើជាការកំសាន្ត និងជាការលេងសើចទាំងនោះចុះ។ ពួកគេត្រូវបានជីវិតលោកិយបោកបញ្ឆោតពួកគេ។ ហើយចូរអ្នកដាស់តឿន(មនុស្សលោក)តាមរយៈវា(គម្ពីគួរអាន)ចុះ ដើម្បីកុំឱ្យមានបុគ្គលណាម្នាក់ត្រូវទទួលរងភាពមហន្តរាយ ដោយសារតែទង្វើដែលខ្លួនបានប្រព្រឹត្ត។ សម្រាប់បុគ្គលម្នាក់ៗ គឺគ្មានអ្នកគាំពារ និងអ្នកជួយអន្តរាគមន៍ណាក្រៅពីអល់ឡោះនោះឡើយ។ ហើយបើទោះបីជាគេចង់លោះខ្លួន(ពីទណ្ឌកម្ម))ដោយថ្នូរណាមួយក៏ដោយ ក៏គេមិនទទួលយកការលោះនោះដែរ។ ពួកទាំងនោះហើយ គឺជាពួកដែលត្រូវបានគេបញ្ជូនទៅកាន់ភាពអន្តរាយ ដោយសារតែទង្វើដែលខ្លួនបានប្រព្រឹត្ត។ គ្រឿងផឹករបស់ពួកគេ គឺទឹកក្តៅពុះកញ្ជ្រោល និងទណ្ឌកម្មដ៏ឈឺចាប់បំផុត ដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រឆាំង។

71. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើឱ្យយើងគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះដែលពួកវាមិនអាចផ្តល់ផលប្រយោជន៍ ហើយក៏មិនអាចបង្កគ្រោះថ្នាក់ដល់យើងផងនោះឬ? ហើយពួកយើងត្រូវចេញពីភាពមានជំនឿបន្ទាប់ពីអល់ឡោះបានចង្អុលបង្ហាញផ្លូវដល់យើងហើយនោះ ប្រៀបដូចជាអ្នកដែលពពួកស្តេតនបានពង្វក់រូបគេនៅលើផែនដីនេះ ខណៈដែលរូបគេមានមិត្តភក្តិជាច្រើនដែលអំពាវនាវគេទៅរកការចង្អុលបង្ហាញ(ដោយនិយាយថា៖) ចូរអ្នកមកកាន់ពួកយើងមក(តែគេបែរជាបដិសេធ)។ ចូរអ្នកពោលទៅកាន់ពួកគេថា៖ ការចង្អុលបង្ហាញរបស់អល់ឡោះ គឺជាការចង្អុលបង្ហាញដ៏ពិតប្រាកដ។ ហើយគេបានប្រើពួកយើងឱ្យប្រគល់ខ្លួន(ជាជនមូស្លីម)ចំពោះព្រះជាម្ចាស់នៃពិភពទាំងអស់។

72. ហើយទ្រង់បានបង្គាប់ប្រើឱ្យប្រតិបត្តិសឡាត និងកោតខ្លាចចំពោះទ្រង់។ ហើយពួកអ្នកនឹងត្រូវគេប្រមូលផ្តុំទៅកាន់ទ្រង់(តែមួយគត់)។

73. ហើយទ្រង់ជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីយ៉ាងពិតប្រាកដ។ នៅថ្ងៃដែលទ្រង់មានបន្ទូល(ចំពោះអ្វីមួយ)ថា៖ "ចូរកើតចុះ" វាក៏កើតឡើងភ្លាមមួយរំពេច។ បន្ទូលរបស់ទ្រង់ គឺជាការពិត។ ហើយអំណាចគ្រប់គ្រងនៅថ្ងៃដែលគេផ្លុំត្រែ(ថ្ងៃបរលោក)គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ទ្រង់ជាអ្នកដឹងបំផុតចំពោះប្រការអោបំកំបាំង និងប្រការដែលលាតត្រដាង។ ហើយទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

74. (ចូរអ្នកនឹកឃើញ) នៅពេលដែលព្យាការីអ៊ីព្រហ៊ីមបានពោលទៅកាន់ឪពុករបស់គាត់"អាហ្សើរ"ថា៖ តើពុកយករូបបដិមាទាំងនេះធ្វើជាព្រះឬ? ជាការពិតណាស់ ខ្ញុំឃើញពុក និងក្រុមរបស់ពុកស្ថិតនៅក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

75. ក៏ដូច្នោះដែរ យើងបានឱ្យព្យាការីអ៊ីព្រហ៊ីមបានឃើញនូវអំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី និងដើម្បីឱ្យរូបគាត់ស្ថិតក្នុងចំណោមអ្នកដែលមានជំនឿជឿជាក់យ៉ាងពិតប្រាកដ។

76. ហើយនៅពេលដែលពេលរាត្រីបានគ្របដណ្តប់ទៅលើគាត់ គាត់ក៏បានឃើញផ្កាយ។ ពេលនោះ គាត់បាននិយាយថា៖ នេះជាព្រះជាម្ចាស់របស់ខ្ញុំ។ ហើយនៅពេលដែលវាលិចបាត់ទៅវិញ គាត់ក៏និយាយថា៖ ខ្ញុំមិនចូលចិត្តអ្វីដែលលិចបាត់ទៅវិញនោះទេ។

77. ហើយនៅពេលដែលគាត់ឃើញដួងចន្ទរះឡើង គាត់ក៏បាននិយាយថា៖ នេះជាព្រះជាម្ចាស់របស់ខ្ញុំ។ តែនៅពេលដែលវាលិចបាត់ទៅវិញ គាត់ក៏និយាយថា៖ ប្រសិនបើព្រះជាម្ចាស់របស់ខ្ញុំ(អល់ឡោះ)មិនចង្អុលបង្ហាញរូបខ្ញុំទេនោះ ច្បាស់ជាខ្ញុំនឹងស្ថិតក្នុងចំណោមក្រុមដែលវង្វេងជាមិនខាន។

78. នៅពេលដែលគាត់បានឃើញព្រះអាទិត្យរះឡើង គាត់ក៏និយាយថា៖ នេះជាព្រះជាម្ចាស់របស់ខ្ញុំ ព្រោះមួយនេះធំជាងគេ។ តែនៅពេលដែលវាលិចបាត់ទៅវិញ គាត់ក៏បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ពិតណាស់ ខ្ញុំមិនពាក់ព័ន្ធនឹងអ្វីដែលពួកអ្នកកំពុងតែធ្វើស្តីរិកនោះឡើយ។

79. ជាការពិតណាស់ ខ្ញុំតម្រង់មុខរបស់ខ្ញុំទៅកាន់(អល់ឡោះ)អ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីដោយមានភាពស្មោះស(ចំពោះទ្រង់តែមួយគត់)។ ហើយខ្ញុំមិនស្ថិតក្នុងចំណោមពួកដែលធ្វើស្តីរិកនោះឡើយ។

80. ហើយក្រុមរបស់គាត់បានប្រកែកដេញដោលជាមួយនឹងគាត់។ គាត់ក៏បាននិយាយ៖ តើពួកអ្នកមកប្រកែកដេញដោលជាមួយខ្ញុំនៅក្នុងការមានជំនឿចំពោះអល់ឡោះ(តែមួយគត់)ឬ ខណៈដែលទ្រង់ពិតជាបានចង្អុលបង្ហាញខ្ញុំហើយនោះឬ? ហើយខ្ញុំមិនខ្លាចញញើតចំពោះអ្វី(រូបបដិមាទាំងឡាយ)ដែលពួកអ្នកកំពុងតែធ្វើស្តីរិកនឹងវានោះឡើយ លើកលែងតែអ្វីមួយដែលព្រះជាម្ចាស់របស់ខ្ញុំមានចេតនាប៉ុណ្ណោះ។ ការដឹងរបស់ព្រះជាម្ចាស់របស់ខ្ញុំទូលំទូលាយគ្របដណ្តប់លើអ្វីៗទាំងអស់។ តើពួកអ្នកមិននឹកឃើញទេឬ?

81. តើឱ្យខ្ញុំខ្លាចញញើតចំពោះអ្វី(រូបជិមានានា)ដែលពួកអ្នកកំពុងតែធ្វើស្ដីរែកនោះយ៉ាងដូចម្ដេចទៅ បើពួកអ្នកមិនទាំងខ្លាចញញើតចំពោះការដែលពួកអ្នកធ្វើស្ដីរែកចំពោះអល់ឡោះនូវអ្វីដែលទ្រង់មិនបានបញ្ចុះភស្ដុតាងបញ្ជាក់ដល់ពួកអ្នកអំពីវាផងនោះ? តើក្រុមណាមួយក្នុងចំណោមក្រុមទាំងពីរនេះដែលសក្តិសមនឹងទទួលបាននូវសុវត្ថិភាពជាង ប្រសិនបើពួកអ្នកបានដឹង។

82. បណ្ដាអ្នកដែលមានជំនឿ ហើយមិនលាយឡំជំនឿរបស់ខ្លួនជាមួយនឹងប្រការស្ដីរែកអ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបាននូវសុវត្ថិភាព ហើយពួកគេគឺជាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

83. ហើយទាំងនោះជាភស្ដុតាងរបស់យើងដែលយើងបានប្រទានវាដល់ព្យាការីអ៊ីព្រហ៊ីមដើម្បីតទល់ជាមួយនឹងក្រុមរបស់គាត់។ យើងលើកឋានៈសក្តិចំពោះជនណាដែលយើងមានចេតនា។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកមហាគតិបណ្ឌិតមហាដឹងបំផុត។

84. ហើយយើងបានប្រទានដល់គាត់នូវព្យាការីអ៊ីស្ហាក(ជាកូន)និងព្យាការីយ៉ាក់កូប(ជាចៅ)។ ម្នាក់ៗក្នុងចំណោមអ្នកទាំងពីរយើងបានចង្អុលបង្ហាញ(ដល់ពួកគេ)។ ហើយព្យាការីនួហ យើងបានចង្អុលបង្ហាញ(ដល់គាត់)កាលពីមុនផងដែរ។ ហើយក្នុងចំណោមពូជអម្បូររបស់គាត់(ព្យាការីនួហ)គឺព្យាការីហ្វាវូទ ព្យាការីសូឡៃម៉ាន ព្យាការីអៃយ៉ូប ព្យាការីយូសុហ្វ ព្យាការីមូសា និងព្យាការីហារូន(ក៏យើងបានចង្អុលបង្ហាញដល់ពួកគេផងដែរ)។ ក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះបណ្ដាអ្នកសាងអំពើល្អ។

85. ហើយ(ក៏ដូចគ្នាដែរ) ព្យាការីហ្សាការីយ៉ា ព្យាការីយ៉ះយ៉ា ព្យាការីអ៊ីសា និងព្យាការីអ៊ិលយ៉ាស់។ ហើយអ្នកទាំងអស់នោះ គឺស្ថិតក្នុងចំណោមបណ្ដាអ្នកដែលសាងទង្វើកុសល។

86. ហើយ(ក៏ដូចគ្នាផងដែរ) ព្យាការីអ៊ីស្មាអែល ព្យាការីអិលយ៉ាសាក់ ព្យាការីយូនុស និងព្យាការីលូត។ ហើយយើងបានលើកតម្កើងពួកគេម្នាក់ៗ ឱ្យខ្ពង់ខ្ពស់ជាងគេទាំងអស់លើពិភពលោក។

87. ហើយក្នុងចំណោមដីជូនដីតា កូនចៅ និងបងប្អូនរបស់ពួកគេ(ក៏យើងបានចង្អុលបង្ហាញពួកគេផងដែរ)។ យើងបានជ្រើសរើសពួកគេ និងបានចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

88. នោះគឺជាការចង្អុលបង្ហាញរបស់អល់ឡោះដោយទ្រង់ចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់។ តែប្រសិនបើពួកគេ(បណ្ដាព្យាការី)បានធ្វើស្ដីរែកវិញនោះ ទង្វើ(កុសល)ទាំងឡាយដែលពួកគេធ្លាប់បានសាងនឹងត្រូវចាត់ទុកជាអសារបង់ជាមិនខាន។

89. អ្នកទាំងនោះហើយដែលយើងបានប្រទានឱ្យពួកគេនូវគម្ពីរ គតិបណ្ឌិត និងភាពជាព្យាការី។ តែប្រសិនបើអ្នកទាំងនោះ(អ្នកស្រុកម៉ាក្កៈ)បដិសេធចំពោះវា(អ្វីដែលយើងបានប្រទានដល់ព្យាការី) ជាការពិតណាស់ យើងនឹងប្រគល់វាទៅឱ្យក្រុមផ្សេងទៀតដែលមិនមែនជាពួកដែលបដិសេធចំពោះវា(ជំនួសវិញ)។

90. អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានការចង្អុលបង្ហាញពីអល់ឡោះ។ ដូចនេះ តាមរយៈការចង្អុលបង្ហាញរបស់ពួកគេ ចូរអ្នកដើរតាមវាចុះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ ខ្ញុំមិនទាមទារកម្រៃពីពួកអ្នកលើការផ្សព្វផ្សាយ(គម្ពីរគួរអាន)នោះទេ។ ពិតណាស់វា(គម្ពីរគួរអាន)គ្មានអ្វីក្រៅពីការដាស់រំឭកដល់ពិភពទាំងឡាយនោះឡើយ។

91. ហើយពួកគេ(ពួកមុស្លីគីន)មិនបានលើកតម្កើងអល់ឡោះឱ្យសក្តិសមនឹងឋានៈរបស់ទ្រង់នោះឡើយ ខណៈដែលពួកគេនិយាយថា៖ អល់ឡោះជាម្ចាស់មិនបានបញ្ចុះអ្វីមួយទៅកាន់មនុស្សលោកនោះឡើយ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ តើអ្នកណាជាអ្នកដែលបានបញ្ចុះគម្ពីរ(តាវ៉ាត)ដែលព្យាការីមូសាបាននាំមកជាពន្លឺ និងជាការចង្អុលបង្ហាញដល់មនុស្សលោកនោះ? ពួកអ្នក(ពួកយូដា)បានសរសេរវាដាក់ទៅក្នុងសៀវភៅផ្សេងៗ ដោយពួកអ្នកបង្ហាញនូវផ្នែកខ្លះអំពីវា ហើយលាក់បាំងនូវផ្នែកជាច្រើនទៀតអំពីវា។ ហើយគេបានបង្រៀនពួកអ្នក(ឱជនជាតិអារ៉ាប់)នូវអ្វី(គម្ពីរគួរអាន)ដែលពួកអ្នកនិងដីដូនជីតារបស់ពួកអ្នកមិនធ្លាប់បានដឹងពីមុនមក។ ចូរអ្នកពោលថា៖ គឺអល់ឡោះជាម្ចាស់ (ជាអ្នកបញ្ចុះវាមក)។ បន្ទាប់មក ចូរអ្នកបណ្តោយពួកគេឱ្យលេងសើចក្នុងភាពវង្វេងរបស់ពួកគេនោះចុះ។

92. ហើយគម្ពីរនេះ(គម្ពីរគួរអាន)យើងបានបញ្ចុះវាមកប្រកបដោយពរជ័យ និងជាអ្នកបញ្ជាក់ទៅលើបណ្តាគម្ពីរដែលបានបញ្ចុះមកកាលពីមុន និងដើម្បីឱ្យអ្នកដាស់តឿនព្រមានអ្នកស្រុកម៉ាក្កៈ និងអ្នកដែលនៅជុំវិញវា(មនុស្សលោកទាំងអស់)។ ហើយបណ្តាអ្នកដែលមានជំនឿចំពោះថ្ងៃបរលោក គឺពួកគេមានជំនឿចំពោះវា(គម្ពីរគួរអាន)ហើយពួកគេជាអ្នកដែលថែរក្សាលើការប្រតិបត្តិសឡាតរបស់ពួកគេ។

93. គ្មានអ្នកណាម្នាក់ដែលបំពានជាងអ្នកដែលបានប្រឌិតកុហកទៅលើអល់ឡោះជាម្ចាស់ ឬនិយាយថា៖ អល់ឡោះបានផ្តល់វ៉ាហ៊ីដល់ខ្ញុំ ខណៈដែលទ្រង់មិនបានផ្តល់វ៉ាហ៊ីដល់ជននោះបន្តិចណាឡើយ ឬក៏និយាយថា៖ ខ្ញុំនឹងបញ្ចុះ(គម្ពីរមួយ)ដូចអ្វី(គម្ពីរគួរអាន)ដែលអល់ឡោះបានបញ្ចុះមកនោះដែរ។ ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញពួកបំពានទាំងនោះក្នុងពេលដែលពួកគេជិតស្លាប់ ខណៈម៉ាឡាអ៊ីកាត់លូកដៃរបស់ពួកគេទៅកាន់ពួកនោះ(ដើម្បីដកហូតព្រលឹង)។ (ម៉ាឡាអ៊ីកាត់បាននិយាយថា៖) ចូរពួកឯង(ព្រលឹង)ចេញពីខ្លួនមក! នៅថ្ងៃនេះ គេនឹងតបស្នងដល់ពួកឯងនូវទណ្ឌកម្មដ៏អាម៉ាស់បំផុតដោយសារតែអ្វីដែលពួកឯងធ្លាប់បាននិយាយ(ប្រឌិតកុហក)ទៅលើអល់ឡោះខុសពីការពិត ហើយពួកឯងធ្លាប់បានក្អេងក្អាង(មិនជឿ)ចំពោះបណ្តាកស្តុតាងទាំងឡាយរបស់ទ្រង់។

94. ហើយជាការពិតណាស់ ពួកអ្នកមកកាន់យើងនៅថ្ងៃនេះដោយខ្លួនទទេដូចដែលយើងបានបង្កើតពួកអ្នកកាលពីដំបូងដូច្នោះដែរ ហើយពួកអ្នកបានបោះបង់ចោលនូវអ្វីដែលយើងបានប្រទានឱ្យពួកអ្នកនៅពីក្រោយខ្នងពួកអ្នក។ ហើយយើងក៏មិនឃើញអ្នកជួយអន្តរាគមន៍ដែលពួកអ្នកធ្លាប់បានអះអាងថា ពួកវាជាដៃគូ(របស់អល់ឡោះ)នោះនៅជាមួយពួកអ្នកនោះដែរ។ ជាការពិតណាស់ ទំនាក់ទំនងរវាងពួកអ្នកត្រូវបានកាត់ផ្តាច់។ ហើយអ្វីដែលពួកអ្នកធ្លាប់បានអះអាងនោះ ក៏បានរសាត់បាត់អស់ពីពួកអ្នក។

95. ជាការពិតណាស់ អល់ឡោះជាអ្នកធ្វើឱ្យគ្រាប់ធញ្ញជាតិប្រេះបែក និងធ្វើឱ្យរុក្ខជាតិដុះចេញពីគ្រាប់នោះ។ ទ្រង់បញ្ចេញរបស់មានជីវិតពីរបស់ស្លាប់ និងជាអ្នកបញ្ចេញរបស់ស្លាប់ពីរបស់មានជីវិត។ (អ្នកបង្កើតអ្វីទាំងអស់)នោះគឺអល់ឡោះជាម្ចាស់។ ដូចនេះ តើពួកអ្នកងាកចេញ(ពីការពិត)យ៉ាងដូចម្តេច?

96. ហើយទ្រង់គឺជាអ្នកញែកពន្លឺពេលព្រឹក(ចេញពីភាពងងឹតនៅពេលយប់) ហើយទ្រង់ធ្វើឱ្យពេលយប់ក្លាយពេលសម្រាក និងធ្វើឱ្យព្រះអាទិត្យនិងព្រះចន្ទធ្វើចលនាតាមការកំណត់។ នោះគឺជាការកំណត់របស់ព្រះជាម្ចាស់ដែលមហាខ្លាំងពូកែ មហាដឹងបំផុត។

97. ហើយទ្រង់ជាអ្នកដែលបានបង្កើតផ្កាយជាច្រើនសម្រាប់ពួកអ្នក(ឱកូនចៅអាហ្វាំ)ដើម្បីឱ្យពួកអ្នកយកវា(ធ្វើជាគ្រឿវិស័យ)បង្ហាញផ្លូវពួកអ្នកនៅក្នុងពេលយប់ងងឹតទាំងនៅលើគោកនិងនៅលើផ្ទៃសមុទ្រ។ ជាការពិតណាស់ យើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងជាច្រើនសម្រាប់ក្រុមដែលចេះដឹង។

98. ហើយទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នកមកពីមនុស្សតែម្នាក់(ព្យាការីអាហ្វាំ)។ ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវកន្លែងចាប់កំណើត(ក្នុងស្បូនម្តាយ) និងកន្លែងផ្ទុក(ក្នុងឆ្អឹងខ្នងឪពុក)។ ជាការពិតណាស់ យើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងជាច្រើនសម្រាប់ក្រុមដែលឈ្វេងយល់។

99. ហើយទ្រង់ជាអ្នកដែលបានបញ្ចុះទឹកភ្លៀងពីលើមេឃ។ ហើយតាមរយៈទឹកភ្លៀងនេះ យើងបានបណ្តុះនូវរុក្ខជាតិគ្រប់ប្រភេទ។ ហើយយើងបានបណ្តុះចេញពីរុក្ខជាតិនោះនូវដំណាំបៃតង។ យើងបានបង្កើតចេញពីដំណាំបៃតងនោះនូវគ្រាប់ធញ្ញជាតិជាច្រើន។ ហើយពីលំអងផ្កាល្មើ យើងបានបញ្ចេញជាចង្កោមផ្លែដែលនៅជិត(ងាយស្រួលបេះ)។ ហើយយើងបានបញ្ចេញចម្ការជាច្រើនអំពីទំពាំងបាយជូរ ដើមអូលីវ និងដើមទទឹមដែល(ស្លឹករបស់វា)ស្រដៀងគ្នា តែ(ផ្លែរបស់វា)ខុសគ្នា។ ចូរពួកអ្នកសម្លឹងមើលទៅកាន់ផ្លែរបស់វានៅពេលដែលវាចាប់ផ្តើមចេញក្តិប និងនៅពេលដែលវាទុំចុះ។ ជាការពិតណាស់ នៅក្នុងរឿងទាំងអស់នោះ គឺជាភស្តុតាងដ៏ច្បាស់លាស់សម្រាប់ក្រុមដែលមានជំនឿ។

100. ហើយពួកគេ(ពួកមុស្លីគីន)បានចាត់ទុកជិនជាដៃគូរបស់របស់អល់ឡោះ ខណៈដែលទ្រង់ជាអ្នកដែលបានបង្កើតពួកគេ។ ហើយពួកគេបានប្រឌិតកុហកថាទ្រង់មានបុត្រា និងបុត្រីជាច្រើននាក់ដោយគ្មានចំណេះដឹង។ ទ្រង់មហាបរិសុទ្ធ និងមហាខ្ពង់ខ្ពស់បំផុតអំពីអ្វីដែលពួកគេបានពិពណ៌នា។

101. ទ្រង់ជាអ្នកដែលបង្កើតមេឃជាច្រើនជាន់និងផែនដីដោយគ្មានគំរូពីមុនឡើយ។ តើទ្រង់មានបុត្រាយ៉ាងដូចម្តេច បើទ្រង់គ្មានភរិយាផងនោះ? ហើយទ្រង់បានបង្កើតគ្រប់អ្វីៗទាំងអស់។ ហើយទ្រង់ដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

102. នោះហើយគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក(ឱមនុស្សលោកទាំងឡាយ)។ គ្មានព្រះឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់ជាអ្នកបង្កើតអ្វីៗទាំងអស់។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈចំពោះទ្រង់(តែមួយគត់)។ ហើយទ្រង់ជាអ្នកថែរក្សាលើអ្វីៗទាំងអស់។

103. គ្មាននរណាម្នាក់អាចមើលឃើញទ្រង់បានឡើយ(នៅក្នុងលោកិយនេះ) តែទ្រង់ទេដែលជាអ្នកមើលឃើញអ្វីទាំងអស់។ ទ្រង់មហាទន់ភ្លន់ មហាដឹងបំផុត។

104. ជាការពិតណាស់ កស្តុតាងជាច្រើនពីព្រះជាម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកហើយ។ ដូច្នេះ បុគ្គលណាហើយដែលបានឃើញ(អនុវត្តតាម)វាគឺសម្រាប់ខ្លួនគេផ្ទាល់។ រីឯបុគ្គលណាដែលមើលមិនឃើញ(មិនអនុវត្តតាម)គ្រោះថ្នាក់នៃទង្វើនោះ វាក៏ធ្លាក់ទៅលើរូបគេដូចគ្នា។ ហើយខ្ញុំ(ព្យាការីមូហាំម៉ាត់)មិនមែនជាអ្នកទទួលខុសត្រូវលើពួកអ្នកនោះឡើយ។

105. ក៏ដូច្នោះដែរ យើងបានបកស្រាយបញ្ជាក់នូវបណ្តាវាក្យខណ្ឌជាច្រើន(នៃគម្ពីរគួរអាន)។ ហើយពួកគេ(ពួកមុស្លីគីន)នឹងនិយាយថា៖ អ្នក(ព្យាការីមូហាំម៉ាត់)បានសិក្សាវា(ពីពួកអះលីគីតាប)ប៉ុណ្ណោះ។ ហើយយើងនឹងបកស្រាយបញ្ជាក់វាសម្រាប់ក្រុមដែលចេះដឹង និងទទួលយកការពិត។

106. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អនុវត្តតាមអ្វីដែលគេបានផ្តល់វ៉ាហ៊ីដល់អ្នកពីព្រះជាម្ចាស់របស់អ្នកចុះ។ គ្មានព្រះឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ហើយចូរអ្នកងាកចេញពីពួកដែលធ្វើស៊ីរិក។

107. ហើយប្រសិនបើអល់ឡោះទ្រង់មានចេតនា គឺពួកគេមិនធ្វើស៊ីរិកនោះឡើយ។ ហើយយើងមិនបានចាត់តាំងអ្នក(ព្យាការីមូហាំម៉ាត់)ធ្វើជាអ្នកទទួលខុសត្រូវលើពួកគេឡើយ ហើយអ្នកក៏មិនមែនជាអ្នកគ្រប់គ្រងលើពួកគេដែរ។

108. ហើយចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)កុំជេរប្រមាថពួកដែលគោរពសក្ការៈផ្សេងពីអល់ឡោះឱ្យសោះដែលជាហេតុធ្វើឲ្យពួកគេជេរប្រមាថអល់ឡោះដោយបំពានទាំងល្ងង់ខ្លៅវិញ។ ដូច្នោះដែរ យើងបានតុបតែងលម្អសម្រាប់រាល់ប្រជាជាតិនីមួយៗនូវទង្វើរបស់ពួកគេ(ទាំងល្អ ទាំងអាក្រក់)។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកគេ(នៅថ្ងៃបរលោក)គឺទៅកាន់ព្រះជាម្ចាស់របស់ពួកគេ(អល់ឡោះ)វិញ។ ពេលនោះ ទ្រង់នឹងប្រាប់ពួកគេពីអ្វីដែលពួកគេបានប្រព្រឹត្ត។

109. ហើយពួកគេ(ពួកមុស្លីតីន)បានស្បថនឹងអល់ឡោះយ៉ាងមុឺងម៉ាត់ថា៖ ប្រសិនបើសញ្ញាកស្តុតាងណាមួយ(ដែលពួកគេបានស្នើសុំនោះ)បានមកដល់ពួកគេ នោះពួកគេប្រាកដជានឹងមានជំនឿលើវាជាមិនខាន។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត សញ្ញាកស្តុតាងទាំងឡាយ គឺស្ថិតនៅឯអល់ឡោះជាម្ចាស់។ តើអ្វីទៅដែលធ្វើឱ្យពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ដឹងថា ទោះជាសញ្ញាកស្តុតាងនោះមកដល់ ក៏ពួកគេនៅតែមិនមានជំនឿដដែលនោះ?

110. ហើយយើងនឹងបង្វែរដួងចិត្ត និងចក្ខុរបស់ពួកគេ(ពួកគ្មានជំនឿ)ដូចដែលពួកគេមិនមានជំនឿនឹងវា(គម្ពីរគួរអាន)តាំងពីដំបូង ហើយយើងបានបណ្តោយពួកគេឱ្យស្ថិតនៅក្នុងភាពវង្វេងរបស់ពួកគេដោយពួកគេមានភាពស្រពិចស្រពិល(ជារៀងរហូត)។

111. ហើយពិតប្រាកដណាស់ បើទោះបីជាយើងបញ្ជូនម៉ាឡាអ៊ីកាត់ទៅកាន់ពួកគេ ហើយមនុស្សស្លាប់អាចនិយាយប្រាប់ពួកគេ(ពីការពិត) ព្រមទាំងយើងប្រមូលផ្តុំឱ្យពួកគេ(រាល់អ្វីដែលពួកគេទាមទារ)ដាក់ពីមុខពួកគេក៏ដោយ ក៏ពួកគេមិនមានជំនឿនោះដែរ លើកលែងតែ(ជនណាដែល)អល់ឡោះមានចេតនាប៉ុណ្ណោះ។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនដឹងនោះឡើយ។

112. ក៏ដូច្នោះដែរ យើងបានធ្វើឲ្យមានសម្រាប់គ្រប់ព្យាការីនូវសត្រូវជាស្តែនជិន និងស្តែនមនុស្សដែលពួកវាទាំងនោះបានពង្វក់អូសទាញគ្នាទៅវិញទៅមកដោយការតុបតែងលម្អប្រការដែលអាក្រក់(ឱ្យមើលឃើញថាជាប្រការល្អ)ដើម្បីជាការបោកប្រាស់(ពួកគេ)។ ហើយប្រសិនបើព្រះជាម្ចាស់របស់អ្នកមានចេតនា ពួកគេក៏មិនអាចធ្វើដូច្នោះបាននោះដែរ។ ហេតុនេះ ចូរអ្នកបណ្តោយពួកគេ និងអ្វីដែលពួកគេបានប្រឌិតកុហកនោះចុះ។

113. និងដើម្បីឱ្យដួងចិត្តរបស់ពួកដែលគ្មានជំនឿនឹងថ្លែបរលោកទោរទន់ទៅរកវា(អ្វីដែលពួកវាពង្វក់គ្នាទៅវិញទៅមកនោះ)និងពួកគេពេញចិត្ត ព្រមទាំងដើម្បីឱ្យពួកគេទទួលនូវផលកម្មនៃអ្វីដែលពួកគេបានសាង។

114. តើសមហេតុផលដែរឬទេដែលខ្ញុំទទួលយកការកាត់សេចក្តីផ្សេងពីអល់ឡោះនោះ ខណៈដែលទ្រង់ជាអ្នកដែលបញ្ចុះគម្ពីរ(គួរអាន)ដែលបកស្រាយបញ្ជាក់យ៉ាងច្បាស់លាស់(នូវរាល់ប្រការទាំងអស់)ទៅកាន់ពួកអ្នកនោះ? ហើយចំពោះពួកដែលយើងបានប្រទានគម្ពីរដល់ពួកគេ(ពួកយូដា និងគ្រីស្ទាន)នោះ ពួកគេដឹងយ៉ាងច្បាស់ថា ជាការពិតណាស់ វា(គម្ពីរគួរអាន)គឺត្រូវបានបញ្ចុះមកពីព្រះជាម្ចាស់របស់អ្នកយ៉ាងពិតប្រាកដ។ ហេតុនេះ ចូរអ្នកកុំស្ថិតក្នុងចំណោមពួកដែលមានការមន្ទិលសង្ស័យឱ្យសោះ។

115. ហើយបន្ទូលនៃព្រះជាម្ចាស់របស់អ្នក(គម្ពីរគួរអាន)គឺបានបញ្ចប់យ៉ាងពេញលេញដោយត្រឹមត្រូវនិងយុត្តិធម៌បំផុត។ គ្មាននរណាអាចផ្លាស់ប្តូរបន្ទូលរបស់ទ្រង់ឡើយ។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

116. ប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ធ្វើតាមមនុស្សភាគច្រើននៅលើផែនដីនោះ ពួកគេនឹងធ្វើឱ្យអ្នកវង្វេងចេញពីមាគ៌ារបស់អល់ឡោះជាមិនខាន។ ពិតណាស់ ពួកគេមិនដើរតាមអ្វីក្រៅពីការស្មាននោះឡើយ ហើយពួកគេគ្មានអ្វីក្រៅពីការភូតកុហកប៉ុណ្ណោះ។

117. ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ដឹងបំផុតចំពោះអ្នកដែលវង្វេងចេញពីមាគ៌ារបស់ទ្រង់ ហើយទ្រង់ដឹងបំផុតចំពោះអ្នកដែលទទួលបានការចង្អុលបង្ហាញ។

118. ហើយចូរពួកអ្នកបរិភោគចុះនូវសត្វដែលគេរំឭកព្រះនាមរបស់អល់ឡោះទៅលើវា(នៅពេលសំឡះ) ប្រសិនបើពួកអ្នកពិតជាអ្នកមានជំនឿចំពោះសញ្ញាកស្តុតាងរបស់ទ្រង់មែននោះ។

119. តើមានអ្វីដែលរារាំងពួកអ្នក(ឱបណ្តាអ្នកមានជំនឿទាំងឡាយ)មិនឱ្យទទួលទាននូវអ្វី(សត្វដែលគេសំឡេះ)ដែលគេបានរំឭកព្រះនាមអល់ឡោះទៅលើវា ខណៈដែលទ្រង់ពិតជាបានបញ្ជាក់ដល់ពួកអ្នករួចនូវអ្វីដែលគេហាមឃាត់ទៅលើពួកអ្នក លើកលែងតែពួកអ្នកមានតម្រូវការចាំបាច់បំផុតចំពោះវាប៉ុណ្ណោះ។ ហើយជាការពិតណាស់ មនុស្សភាគច្រើនបានធ្វើឱ្យគេវង្វេងដោយសារចំណង់តណ្ហារបស់ពួកគេដោយគ្មានចំណេះដឹង។ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ដឹងបំផុតចំពោះពួកដែលបំពាន។

120. ហើយចូរពួកអ្នកបោះបង់ចោលនូវអំពើបាបទាំងឡាយ ទាំងលាតត្រដាង និងលាក់កំបាំង។ ជាការពិតណាស់ ពួកដែលប្រព្រឹត្តអំពើបាប គេ(អល់ឡោះ)នឹងតបស្នងដល់ពួកគេចំពោះអ្វីដែលពួកគេបានសាង។

121. ហើយចូរពួកអ្នក(ឱជនមូស្លីមទាំងឡាយ)កុំបរិភោគឱ្យសោះនូវអ្វី(សត្វ)ដែលគេមិនបានរំឭកព្រះនាមរបស់អល់ឡោះទៅលើវា(នៅពេលសំឡេះ)។ ជាការពិត នោះគឺជាអំពើល្មើស(ចំពោះអល់ឡោះ)។ ហើយជាការពិតណាស់ ស្មែតនពួកវាកំពុងតែពង្វក់អូសទាញអ្នកគាំពាររបស់ពួកវាដើម្បីឱ្យពួកគេជជែកដេញដោលជាមួយនឹងពួកអ្នក។ ហើយប្រសិនបើពួកអ្នកធ្វើតាមពួកគេ នោះពួកអ្នកនឹងក្លាយជាពួកដែលធ្វើស្ទីរិកជាមិនខាន។

122. តើមនុស្សដែលស្លាប់(ស្ថិតនៅក្នុងភាពគ្មានជំនឿ អវិជ្ជា និងអំពើល្មើស) ក្រោយមក យើងបានធ្វើឱ្យគេរស់ឡើងវិញ(មានជំនឿ ចំណេះដឹង និងគោរពប្រតិបត្តិអល់ឡោះ) ហើយយើងបានផ្តល់ឱ្យគេនូវពន្លឺមួយដោយគេដើរក្នុងចំណោមមនុស្សលោកនឹងពន្លឺនោះ ដូចគ្នាទៅនឹងអ្នកដែលស្ថិតក្នុងភាពងងឹតសូន្យសុងដែលមិនអាចចេញពីវារួចដែរឬទេ? ក៏ដូច្នោះដែរ គេបានតុបតែងលម្អដល់ពួកគ្មានជំនឿនូវអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

123. ហើយក៏ដូច្នោះដែរ យើងបានបង្កើតឱ្យមាននៅគ្រប់ភូមិស្រុកទាំងអស់នូវពួកមេកន្ទ្រាញដែលអាក្រក់ដើម្បីឱ្យពួកគេប្រើល្បិចកលក្នុងភូមិស្រុកនោះ។ តាមពិត ពួកគេមិនបានប្រើល្បិចកល(ទៅលើនរណាម្នាក់)ឡើយ លើកលែងតែទៅលើខ្លួនឯងប៉ុណ្ណោះ ប៉ុន្តែពួកគេមិនដឹងខ្លួនឡើយ។

124. ហើយនៅពេលដែលសញ្ញាកស្តុតាងណាមួយបានមកដល់ពួកគេ ពួកគេនិយាយថា៖ ពួកយើងមិនមានជំនឿជាដាច់ខាតលុះត្រាតែគេនាំមកឱ្យពួកយើងដូចអ្វីដែលគេបានប្រទានទៅឱ្យបណ្តាអ្នកនាំសាររបស់អល់ឡោះ។ អល់ឡោះដឹងបំផុតចំពោះជនណាដែលសក្តិសមនឹងទទួលសាររបស់ទ្រង់។ ពួកជនដែលក្រអឺតក្រទមទាំងនោះនឹងទទួលនូវភាពថោកទាបបំផុតនៅឯអល់ឡោះ និងទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតដោយសារតែកលល្បិចដែលពួកគេធ្លាប់បានរៀបចំ។

125. ជាការពិតណាស់ ជនណាហើយដែលអល់ឡោះទ្រង់មានចេតនាចង្អុលបង្ហាញដល់រូបគេ ទ្រង់នឹងបើកចិត្តគេទៅកាន់សាសនាអ៊ីស្លាម។ រីឯជនណាហើយដែលទ្រង់មានចេតនាឱ្យរូបគេវង្វេង ទ្រង់នឹងធ្វើឱ្យចិត្តរបស់គេចង្អៀតចង្អល់ ប្រៀបដូចជារូបគេឡើងទៅលើមេឃដូច្នោះដែរ។ ក៏ដូច្នោះដែរ អល់ឡោះទ្រង់ដាក់ទណ្ឌកម្មចំពោះពួកដែលគ្មានជំនឿ។

126. ហើយនេះគឺជាមាគ៌ានៃព្រះជាម្ចាស់របស់អ្នកដ៏ត្រឹមត្រូវ។ ពិតណាស់ យើងបានបញ្ជាក់នូវភស្តុតាងជាច្រើនសម្រាប់ក្រុមដែលចេះគិតពិចារណា។

127. សម្រាប់ពួកគេ គឺទទួលបាននូវលំនៅឋានដែលមានសន្តិភាព(ឋានសួគ៌)នៅឯព្រះជាម្ចាស់របស់ពួកគេ។ ហើយទ្រង់ជាអ្នកដែលគាំពារពួកគេដោយសារតែអ្វី(ទង្វើកុសល)ដែលពួកគេធ្លាប់បានសាង។

128. ហើយនៅថ្ងៃដែលទ្រង់នឹងប្រមូលផ្តុំពួកគេទាំងអស់គ្នា។ (ទ្រង់បានមានបន្ទូលថា៖) ឱក្រុមជិនទាំងឡាយ! ជាការពិតណាស់ ពួកឯងបានធ្វើឱ្យមនុស្សជាច្រើនវង្វេង។ ហើយអ្នកដែលដើរតាមពួកគេក្នុងចំណោមមនុស្សបានតបថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! យើងខ្ញុំសុទ្ធតែបានទទួលផលប្រយោជន៍ពីគ្នាទៅវិញទៅមក។ ហើយ(ឥឡូវនេះ)ពួកយើងបានដល់ពេលវេលាដែលទ្រង់បានកំណត់ចំពោះយើងខ្ញុំហើយ។ ទ្រង់បានមានបន្ទូលថា៖ ឋាននរក គឺជាទីស្នាក់អាស្រ័យរបស់ពួកអ្នកដោយពួកអ្នកស្ថិតក្នុងវាជាអមតៈ លើកលែងតែអ្វីដែលអល់ឡោះមានចេតនាប៉ុណ្ណោះ។ ជាការពិតណាស់ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មហាគតិបណ្ឌិត មហាដឹងបំផុត។

129. ហើយក៏ដូច្នោះដែរ យើងបានឲ្យពួកដែលបំពានគ្រប់គ្រងលើគ្នាទៅវិញទៅមកដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

130. (ទ្រង់បានមានបន្ទូលទៅកាន់ពួកគេនៅថ្ងៃបរលោកថា៖) ឱក្រុមជិន និងមនុស្សលោកទាំងឡាយ! តើមិនបានមកដល់ពួកអ្នកទេឬ បណ្តាអ្នកនាំសារក្នុងចំណោមពួកអ្នកដែលពួកគេសូត្រឲ្យពួកអ្នកស្តាប់នូវបណ្តាវាក្យខណ្ឌរបស់យើង ព្រមទាំងព្រមានបន្លាចពួកអ្នកពីការជួបជុំគ្នានៅថ្ងៃរបស់ពួកអ្នក(ថ្ងៃបរលោក)នោះ? ពួកគេបានឆ្លើយថា៖ ពួកយើងសូមធ្វើសាក្សីប្រឆាំងនឹងខ្លួនឯង(ថាពិតជាដូច្នោះមែន)។ ហើយឆាកជីវិតលោកិយបានបោកប្រាស់ពួកគេ។ ហើយពួកគេបានធ្វើសាក្សីប្រឆាំងនឹងខ្លួនឯងទៀតថា ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលធ្លាប់បានប្រឆាំង។

131. នោះគឺដោយសារតែព្រះជាម្ចាស់របស់អ្នកមិនបំផ្លាញភូមិស្រុកណាមួយដោយបំពាន ខណៈដែលអ្នកភូមិស្រុកនោះមិនដឹងខ្លួននោះឡើយ។

132. ហើយសម្រាប់ពួកគេម្នាក់ៗមានឋានៈរៀងៗខ្លួនអាស្រ័យទៅតាមទង្វើរបស់ពួកគេ។ ហើយព្រះជាម្ចាស់របស់អ្នកទ្រង់មិនធ្វេសប្រហែសចំពោះអ្វីដែលពួកគេបានប្រព្រឹត្តនោះឡើយ។

133. ហើយព្រះជាម្ចាស់របស់អ្នកមហាមានលើសលប់ ប្រកបដោយក្តីមេត្តាករុណា។ ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងបំផ្លាញពួកអ្នក ហើយទ្រង់នឹងជំនួសដោយក្រុមផ្សេងបន្ទាប់ពីពួកអ្នកតាមអ្វីដែលទ្រង់មានចេតនា ដូចដែលទ្រង់បានបង្កើតពួកអ្នកចេញពីពូជអម្បូរនៃក្រុមផ្សេងទៀតនោះដែរ។

134. ពិតប្រាកដណាស់ អ្វីដែលគេបានសន្យាចំពោះពួកអ្នក(ឱពួកគ្មានជំនឿទាំងឡាយ)គឺពិតជានឹងមកដល់(យ៉ាងពិតប្រាកដ)ហើយពួកអ្នកគ្មានសមត្ថភាព(ក្នុងការរត់គេច)នោះឡើយ។

135. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកប្រកាន់ខ្ជាប់តាមមាគ៌ា(វង្វេង)របស់ពួកអ្នកចុះ ខ្ញុំក៏នឹងប្រកាន់ខ្ជាប់តាមមាគ៌ា(ត្រឹមត្រូវ)របស់ខ្ញុំដែរ។ ហើយពួកអ្នកគង់តែនឹងដឹងថា តើនរណាដែលជាអ្នកទទួលបានលទ្ធផលចុងក្រោយដ៏ល្អប្រសើរនោះ។ ពិតប្រាកដណាស់ ពួកដែលបំពាននឹងមិនទទួលបានជោគជ័យនោះឡើយ។

136. ហើយពួកគេ(ពួកមុស្លឹគីន)បានបង្កើតមួយចំណែកនៃផលានុផល(ដែលបានមកពីការដាំដុះ) និងសត្វពាហនៈសម្រាប់អល់ឡោះដោយពួកគេនិយាយអះអាងថា៖ (មួយចំណែក)នេះគឺសម្រាប់អល់ឡោះ ហើយ(មួយចំណែក)នេះគឺសម្រាប់ព្រះនានារបស់ពួកយើង។ ជាការពិតណាស់ អ្វីដែល(ពួកគេរៀបចំ)សម្រាប់ព្រះនានារបស់ពួកគេនោះ គឺមិនបានទៅដល់អល់ឡោះឡើយ។ តែអ្វីដែលពួកគេ(បានរៀបចំ)សម្រាប់អល់ឡោះនោះ គឺបានទៅដល់ព្រះនានារបស់ពួកគេ។ អ្វីដែលពួកគេបានវិនិច្ឆ័យនេះ គឺអាក្រក់ជាទីបំផុត។

137. ហើយក៏ដូច្នោះដែរ ព្រះនានារបស់ពួកគេ(ដែលជាស្មៃតន)បានតុបតែងលម្អដល់ពួកមុស្លីគីនយ៉ាងច្រើនផងដែរ ដោយឱ្យពួកគេសម្លាប់កូនៗខ្លួនឯងដើម្បីបំផ្លាញពួកគេ និងដើម្បីបំភ័ន្តទៅលើពួកគេនូវសាសនារបស់ពួកគេ។ ប្រសិនបើអល់ឡោះមានចេតនា ពួកគេនឹងមិនធ្វើដូច្នោះឡើយ។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បណ្តោយពួកគេ និងអ្វីដែលពួកគេប្រឌិតកុហកនោះចុះ។

138. ហើយពួកគេបានអះអាងថា៖ សត្វពាហនៈ និងផលានុផលទាំងនេះ គឺត្រូវបានហាមឃាត់មិនឱ្យបរិភោគឡើយ លើកលែងតែជនណាដែលពួកយើងចង់(ឱ្យបរិភោគ)ប៉ុណ្ណោះ។ ហើយចំពោះសត្វពាហនៈទាំងនោះដែរ ខ្នងរបស់វា គឺត្រូវបានហាមឃាត់(មិនឱ្យជិះនិងដឹកជញ្ជូនឥវ៉ាន់)ឡើយ។ ហើយសត្វពាហនៈទាំងនោះផងដែរ ពួកគេមិនរំឭកព្រះនាមអល់ឡោះទៅលើវា(នៅពេលសំឡេះនោះទេ)ដោយពួកគេមួលបង្កាច់ទៅលើទ្រង់។ ទ្រង់នឹងតបស្នងដល់ពួកគេចំពោះអ្វីដែលពួកគេធ្លាប់បានមួលបង្កាច់នោះ។

139. ហើយពួកគេនិយាយទៀតថា៖ គភ៌ដែលមានក្នុងពោះសត្វពាហនៈទាំងនេះ(ប្រសិនបើកើតមកស់)គឺវាសម្រាប់តែបុរសៗរបស់ពួកយើងប៉ុណ្ណោះ(ទទួលទាន)ហើយវាត្រូវបានហាមឃាត់ចំពោះស្ត្រីៗរបស់ពួកយើង(មិនឱ្យទទួលទានឡើយ)។ តែប្រសិនបើសត្វនោះកើតមកហើយស្លាប់ គឺពួកគេមានចំណែកដូចគ្នា(អាចបរិភោគបានដូចគ្នា)។ ទ្រង់នឹងតបស្នងដល់ពួកគេចំពោះអ្វីដែលពួកគេពណ៌នា។ ពិតប្រាកដណាស់ ទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

140. ពិតប្រាដកណាស់ ពិតជាខាតបង់ហើយពួកដែលបានសម្លាប់កូនៗរបស់ខ្លួនដោយល្ងីល្ងើ និងល្ងង់ខ្លៅ ហើយបានហាមឃាត់ខ្លួនឯងនូវអ្វី(សត្វពាហនៈ)ដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកគេ ដោយប្រឌិតមួលបង្កាច់ទៅលើអល់ឡោះ។ ជាការពិតណាស់ ពួកគេបានវង្វេង(ពីមាគ៌ាដ៏ត្រឹមត្រូវ) ហើយពួកគេក៏មិនមែនជាអ្នកដែលទទួលបានការចង្អុលបង្ហាញនោះដែរ។

141. ហើយទ្រង់ជាអ្នកដែលបានបង្កើតនូវចម្ការដំណាំជាច្រើន ដោយ(ដំណាំខ្លះ)ឡើងទ្រើង និង(ដំណាំខ្លះទៀត)មិនឡើងទ្រើង។ ហើយដើមល្មើ និងដំណាំផ្សេងៗជាច្រើនទៀតដែលមានផ្លែនិងរសជាតិខុសៗគ្នា ព្រមទាំងដើមអូលីវ និងដើមទទឹមដែលស្លឹករបស់វាមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែ(ផ្លែរបស់វា)មានរសជាតិខុសគ្នា។ ចូរពួកអ្នកបរិភោគផ្លែរបស់វាចុះនៅពេលដែលវាចេញផ្លែ ហើយចូរពួកអ្នកបរិច្ចាគហ្សាកាត់របស់វានៅថ្ងៃប្រមូលផល។ ហើយពួកអ្នកមិនត្រូវខ្ជះខ្ជាយឡើយ។ ជាការពិតណាស់ ទ្រង់មិនស្រលាញ់ពួកដែលខ្ជះខ្ជាយនោះទេ។

142. ហើយក្នុងចំណោមសត្វពាហនៈនោះដែរ គឺ(ទ្រង់បានបង្កើតឲ្យមាន)សត្វដែលអាចដឹកជញ្ជូនបាន និង(សត្វដែល)មិនអាចដឹកជញ្ជូនបាន។ ចូរពួកអ្នកបរិភោគចុះនូវអ្វីដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកអ្នក ហើយមិនត្រូវដើរតាមជំហានរបស់ស្មៃតនឡើយ។ ជាការពិតណាស់ វាគឺជាសត្រូវយ៉ាងច្បាស់លាស់ចំពោះពួកអ្នក។

143. (ទ្រង់បានបង្កើតនូវសត្វពាហនៈចំនួន)ប្រាំបីប្រភេទ គឺសត្វចៀមមួយគូ និងសត្វពពែមួយគូ(ញីនិងឈ្មោល)។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើទ្រង់បានហាមឃាត់សត្វឈ្មោលទាំងពីរប្រភេទនេះ ឬសត្វញីទាំងពីរប្រភេទនេះ ឬក៏អ្វីដែលមាននៅក្នុងផ្ទៃពោះសត្វញីទាំងពីរប្រភេទនោះ? ចូរពួកអ្នក(ឱពួកមុស្លីគីន)ប្រាប់ខ្ញុំដោយផ្អែកលើចំណេះដឹងមក ប្រសិនបើពួកអ្នកជាអ្នកដែលត្រឹមត្រូវ(ចំពោះអ្វីដែលពួកអ្នកបានអះអាង)មែននោះ។

144. ហើយនិងសត្វអូដ្ឋមួយគូ និងសត្វគោមួយគូ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើទ្រង់បានហាមឃាត់សត្វឈ្មោលទាំងពីរប្រភេទនេះ ឬសត្វញីទាំងពីរប្រភេទនេះ ឬក៏អ្វីដែលមាននៅក្នុងផ្ទៃពោះសត្វញីទាំងពីរប្រភេទនោះ? ឬមួយក៏ពួកអ្នក(ឱពួកមុស្លីគីន)មានវត្តមានក្នុងពេលដែលអល់ឡោះបានផ្តាំផ្ញើពួកអ្នកចំពោះការហាមឃាត់នេះ? ពិតណាស់ គ្មាននរណាម្នាក់ដែលបំពានជាងអ្នកដែលប្រឌិតកុហកទៅលើអល់ឡោះដើម្បីធ្វើឱ្យមនុស្សវង្វេងដោយគ្មានចំណេះដឹងនោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

145. ចូរអ្នកពោលចុះថា៖ ខ្ញុំមិនបានប្រទះឃើញនៅក្នុងអ្វីដែលគេបានផ្តល់ជាវាហ៊ីមកកាន់ខ្ញុំនូវការដាក់បម្រាមទៅលើអាហារណាមួយមិនឲ្យបរិភោគនោះឡើយ លើកលែងតែសត្វដែលបានស្លាប់(ដោយមិនបានសំឡេះត្រឹមត្រូវតាមច្បាប់អ៊ីស្លាម) ឬឈាមដែលហូរ ឬសាច់ជ្រូកនោះទេ ពីព្រោះវាជារបស់កខ្វក់ ឬក៏វាត្រូវបានគេសំឡេះជាតង្វាយចំពោះអ្នកផ្សេងក្រៅពីអល់ឡោះ។ តែចំពោះជនណាដែលមានភាពចាំបាច់ខ្លាំង(ឱ្យទទួលទានអាហារទាំងនេះ) ដោយគេពុំមែនជាអ្នកដែលបំពាន ហើយក៏ពុំមែនជាអ្នករំលងព្រំដែន(នៃតម្រូវការចាំបាច់របស់ខ្លួន)ដែរនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រឡាញ់បំផុត។

146. ហើយចំពោះពួកយូដា យើងបានដាក់បម្រាមទៅលើពួកគេ(មិនឱ្យទទួលទាន)រាល់សត្វដែលមានក្រចកជាប់គ្នា។ ហើយចំពោះសត្វគោ និងសត្វពពែ យើងបានហាមឃាត់ពួកគេ(មិនឲ្យបរិភោគ)នូវខ្លាញ់របស់វា លើកលែងតែខ្លាញ់ជាប់ឆ្អឹងខ្នង ឬខ្លាញ់ជាប់ពោះវៀន ឬក៏ខ្លាញ់ជាប់ឆ្អឹងរបស់វាប៉ុណ្ណោះ។ នោះគឺជាការតបស្នងរបស់យើងចំពោះពួកគេដោយសារតែការបំពានរបស់ពួកគេ។ ហើយពិតណាស់ យើងគឺជាអ្នកសច្ចៈបំផុត(ចំពោះរាល់អ្វីដែលយើងបានប្រាប់)។

147. តែប្រសិនបើពួកគេបដិសេធចំពោះអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ចូរអ្នកពោលចុះថា៖ ព្រះជាម្ចាស់របស់ពួកអ្នកទ្រង់មានក្តីមេត្តាករុណាដ៏ទូលំទូលាយបំផុត។ ហើយគ្មាននរណាដែលអាចរុញច្រានទណ្ឌកម្មរបស់ទ្រង់ចេញពីក្រុមដែលប្រព្រឹត្តល្មើសបានឡើយ។

148. ពួកដែលធ្វើស្តីរកនឹងនិយាយថា៖ ប្រសិនបើអល់ឡោះមានចេតនា ពួកយើង និងជីដូនជីតារបស់ពួកយើងនឹងមិនធ្វើស្តីរកឡើយ ហើយពួកយើងក៏មិនដាក់បម្រាមចំពោះអ្វីមួយ(ដែលទ្រង់បានអនុញ្ញាត)នោះដែរ។ ក៏ដូច្នោះដែរ អ្នកជំនាន់មុនពួកគេក៏បានបដិសេធ(នឹងបណ្តាអ្នកនាំសារ)ដូចគ្នាដែរ រហូតដល់ពួកគេបានភ្លក់នូវទណ្ឌកម្មរបស់យើង។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ តើពួកអ្នកមានចំណេះដឹង(កស្តុតាងដែលបញ្ជាក់លើសម្តីរបស់ពួកអ្នក)ដែរឬទេ? សូមពួកអ្នកបញ្ចេញវាឲ្យពួកយើងមក? ជាការពិតណាស់ ពួកអ្នកគ្មានតាមអ្វីក្រៅពីការស្មាននោះឡើយ ហើយពួកអ្នកក៏គ្មានអ្វីក្រៅពីការកូតកុហកនោះដែរ។

149. ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានកស្តុតាងយ៉ាងច្បាស់លាស់។ ហើយប្រសិនបើទ្រង់មានចេតនា ទ្រង់ប្រាកដជានឹងចង្អុលបង្ហាញពួកអ្នកទាំងអស់គ្នាមិនខានឡើយ។

150. ចូរអ្នកពោលថា៖ ចូរពួកអ្នកនាំមកនូវសាក្សីទាំងឡាយរបស់ពួកអ្នកដែលពួកគេបានធ្វើសាក្សីថា ពិតប្រាកដណាស់ អល់ឡោះទ្រង់បានដាក់បម្រាមចំពោះប្រការនេះមក។ ប្រសិនបើពួកគេធ្វើសាក្សី(ដោយគ្មានចំណេះដឹង)នោះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំធ្វើសាក្សីជាមួយពួកគេ។ ហើយចូរអ្នកកុំដើរតាមទំនើងចិត្តរបស់ពួកដែលបដិសេធនឹងបណ្តាកស្តុតាងរបស់យើង ហើយនិងពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក ខណៈដែលពួកគេចាត់ទុកអ្នកផ្សេងប្រៀបស្មើនឹងទ្រង់(គោរពសក្ការៈអ្នកផ្សេងរួមជាមួយនឹងទ្រង់)នោះ។

151. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ សូមពួកអ្នកមកទីនេះ ខ្ញុំនឹងសូត្រឱ្យពួកអ្នកស្តាប់នូវអ្វីដែលព្រះជាម្ចាស់របស់ពួកអ្នកទ្រង់បានដាក់បម្រាមលើពួកអ្នកគឺ៖ ពួកអ្នកមិនត្រូវធ្វើស្តីរកចំពោះទ្រង់នឹងអ្វីមួយជាដាច់ខាត ហើយត្រូវធ្វើល្អចំពោះឪពុកម្តាយ។ ពួកអ្នកមិនត្រូវសម្លាប់កូនខ្លួនឯងដោយសារ(ខ្លាច)ក្រនោះឡើយ។ យើង(អល់ឡោះ)ជាអ្នកដែលផ្តល់លាភសក្ការៈដល់ពួកអ្នកនិងដល់ពួកគេ(កូនចៅ)។ ហើយពួកអ្នកមិនត្រូវទៅជិត(បៀតបៀន)អំពើអសីលធម៌(ហ្សីណា)នោះឡើយ ទោះដោយបើកចំហ ឬលាក់បាំង។ ហើយពួកអ្នកក៏មិនត្រូវសម្លាប់ជីវិតដែលអល់ឡោះបានហាមឃាត់នោះដែរ លើកលែងតែដោយការពិត(មានហេតុផលត្រឹមត្រូវស្របច្បាប់)។ ទាំងនោះ គឺជាអ្វីដែលទ្រង់បានផ្តែផ្តាំវាចំពោះពួកអ្នក សង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

152. ហើយពួកអ្នកមិនត្រូវបៀតបៀនទ្រព្យសម្បត្តិក្មេងកំព្រាឡើយ លើកលែងតែតាមវិធីសាស្ត្រដែលល្អ (ផ្តល់ផលប្រយោជន៍ដល់ក្មេងកំព្រានោះ) រហូតដល់គេធំពេញវ័យ។ ហើយចូរពួកអ្នកបំពេញនូវការវាល់ និងការថ្លឹងដោយសុក្រឹត។ យើងមិនដាក់បន្ទុកលើនរណាម្នាក់ហួសពីសមត្ថភាពរបស់គេឡើយ។ ហើយនៅពេលដែលពួកអ្នកនិយាយស្តី ចូរពួកអ្នកនិយាយពាក្យពិត សូម្បីតែចំពោះសាច់ញាតិក៏ដោយ។ ហើយចូរពួកអ្នកអនុវត្តនូវកិច្ចសន្យារបស់អល់ឡោះ។ ទាំងនោះ គឺជាអ្វីដែលទ្រង់បានផ្តែផ្តាំវាចំពោះពួកអ្នក សង្ឃឹមថាពួកអ្នកនឹងចងចាំ។

153. ហើយនេះជាមាគ៌ារបស់យើងដ៏ត្រឹមត្រូវ។ ហេតុនេះ ចូរពួកអ្នកដើរតាមវាចុះ។ តែពួកអ្នកមិនត្រូវដើរតាមមាគ៌ាទាំងឡាយផ្សេងឡើយដែលជាហេតុធ្វើឲ្យពួកអ្នកបែកបាក់ (ប្រាស់ចាក) ពីមាគ៌ារបស់ទ្រង់។ ទាំងនោះ គឺជាអ្វីដែលទ្រង់បានផ្តែផ្តាំវាចំពោះពួកអ្នក សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច (អល់ឡោះ)។

154. បន្ទាប់មក យើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ (តាវ៉ាត) ដើម្បីជាការបំពេញនូវឧបការគុណទៅលើអ្នកដែលសាងកុសល និងដើម្បីជាការបកស្រាយបញ្ជាក់ (យ៉ាងលម្អិត) នូវគ្រប់កិច្ចការទាំងឡាយ ព្រមទាំងជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណា (របស់ទ្រង់)។ សង្ឃឹមថា ពួកគេនឹងមានជំនឿចំពោះការជួបព្រះជាម្ចាស់របស់ពួកគេ (នៅថ្ងៃបរលោក)។

155. ហើយនេះគឺជាគម្ពីរ (គួរអាន) ដែលយើងបានបញ្ចុះវាប្រកបដោយពរជ័យ។ ហេតុនេះ ចូរពួកអ្នកដើរតាមវា និងកោតខ្លាច (ប្រុងប្រយ័ត្នពីការធ្វើផ្ទុយនឹងវា)។ សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រលាញ់។

156. ដើម្បីកុំឱ្យពួកអ្នក (មុស្លីគីនអារ៉ាប់) និយាយថា៖ តាមពិត គេបានបញ្ចុះនូវគម្ពីរទៅឲ្យតែមនុស្សពីរក្រុមមុនពួកយើង (ពួកយូដា និងពួកគ្រីស្ទាន) ប៉ុណ្ណោះ។ ហើយពួកយើងមិនចេះសូត្រគម្ពីររបស់ពួកគេនោះទេ។

157. និងដើម្បីកុំឱ្យពួកអ្នកនិយាយថា៖ ប្រសិនបើគេបញ្ចុះគម្ពីរណាមួយមកកាន់ពួកយើងនោះ ប្រាកដជាពួកយើងនឹងទទួលបានការចង្អុលបង្ហាញជាងពួកគេជាមិនខាន។ ពិតប្រាកដណាស់ (នៅពេលនេះ) ភស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ពួកអ្នក (គឺគម្ពីរគួរអាន) ដែលជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណានោះ បានមកដល់ពួកអ្នកហើយ។ ជាការពិតណាស់ គ្មាននរណាដែលបំពានខ្លាំងជាងអ្នកដែលបដិសេធនឹងបណ្តាភស្តុតាងរបស់អល់ឡោះ និងបែរចេញពីវានោះឡើយ។ យើងនឹងតបស្នងដល់ពួកដែលបែរចេញពីភស្តុតាងទាំងឡាយរបស់យើងនូវទណ្ឌកម្មដ៏អាក្រក់បំផុតដោយសារតែអ្វីដែលពួកគេធ្លាប់បានបែរចេញ។

158. ពួកគេមិនរង់ចាំអ្វីក្រៅពីការមកដល់របស់ម៉ាឡាអ៊ីកាត់ (ដើម្បីដកហូតព្រលឹងពួកគេ) ឬក៏ការមកដល់នៃព្រះជាម្ចាស់របស់អ្នក ឬក៏ការមកដល់នៃសញ្ញាមួយចំនួននៃព្រះជាម្ចាស់របស់អ្នក (សញ្ញាថ្ងៃបរលោក) នោះឡើយ។ នៅថ្ងៃដែលសញ្ញាមួយចំនួននៃព្រះជាម្ចាស់របស់អ្នកបានមកដល់ (ពេលដែលថ្ងៃរះពីទិសខាងលិច) ការមានជំនឿ គឺមិនផ្តល់ប្រយោជន៍អ្វីដល់បុគ្គលណាឡើយ ប្រសិនបើគេមិនមានជំនឿពីមុនមក ឬមានជំនឿហើយតែមិនបានសាងទង្វើកុសល (ពីមុនមក) ទេនោះ។ ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ ចូរពួកអ្នករង់ចាំ (ប្រការទាំងនេះ) ចុះ។ ពិតណាស់ ពួកយើងក៏ជាអ្នករង់ចាំដែរ។

159. ពិតប្រាកដណាស់ ពួកដែលធ្វើឱ្យសាសនារបស់ពួកគេបែកបាក់ ហើយពួកគេបែងចែកជាក្រុមៗនោះ គឺអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) គ្មានអ្វីពាក់ព័ន្ធនឹងពួកគេបន្តិចណាឡើយ។ តាមពិត កិច្ចការរបស់ពួកគេ គឺទៅកាន់អល់ឡោះជាម្ចាស់។ បន្ទាប់មក (នៅថ្ងៃបរលោក) ទ្រង់នឹងប្រាប់ពួកគេពីអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

160. ជនណាដែលនាំមកនូវទង្វើល្អមួយ នោះគេនឹងទទួលបានការតបស្នងវិញទ្វេជាដប់។ តែជនណាដែលបាននាំមកនូវទង្វើអាក្រក់មួយ គឺគេមិនតបស្នងអ្វី (ដល់រូបគេ) លើសពីវានោះឡើយ ហើយពួកគេក៏មិនត្រូវបានគេបំពាននោះដែរ។

161. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ខ្ញុំត្រូវបានព្រះជាម្ចាស់របស់ខ្ញុំចង្អុលបង្ហាញទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ ជាសាសនាដ៏ពិតដែលជាសាសនារបស់ព្យាការីអ៊ីព្រហ៊ីមដ៏ស្អាតស្អំ(សាសនាអ៊ីស្លាម)។ ហើយគាត់ពុំមែនស្ថិតក្នុងចំណោមពួកដែលធ្វើស្ហ៊ីរិកឡើយ។

162. ចូរអ្នកពោលចុះថា៖ ជាការពិតណាស់ ការសឡាតរបស់ខ្ញុំ ការសំឡេះសត្វរបស់ខ្ញុំ ការរស់នៅរបស់ខ្ញុំ និងការស្លាប់របស់ខ្ញុំ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

163. គ្មានដៃគូរួមជាមួយនឹងទ្រង់ឡើយ។ ប្រការទាំងនេះហើយដែលគេ(អល់ឡោះ)ដាក់បទបញ្ជាលើខ្ញុំ។ ហើយខ្ញុំគឺជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)ជំបូងគេបង្អស់។

164. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើឱ្យខ្ញុំយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាព្រះឬ ខណៈដែលទ្រង់គឺជាព្រះជាម្ចាស់នៃអ្វីៗទាំងអស់នោះ? បុគ្គលគ្រប់រូបដែលសាងអំពើបាប គឺមិនធ្លាក់ទៅលើអ្នកផ្សេងក្រៅពីខ្លួនឯងនោះឡើយ ហើយបុគ្គលគ្រប់រូបក៏មិនទទួលខុសត្រូវចំពោះអំពើបាបរបស់អ្នកផ្សេងនោះដែរ។ បន្ទាប់មក កន្លែងវិលត្រឡប់របស់ពួកអ្នកគឺទៅកាន់ព្រះជាម្ចាស់របស់ពួកអ្នក(តែមួយគត់)។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់បានខ្វែងគំនិតគ្នាចំពោះវា។

165. ហើយទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នកឱ្យធ្វើជាអ្នកគ្រប់គ្រងនៅលើផែនដី(ពីមួយជំនាន់ទៅមួយជំនាន់) ហើយទ្រង់បានលើកឋានៈបុគ្គលមួយចំនួននៃពួកអ្នកឱ្យប្រសើរលើសគ្នាដើម្បីសាកល្បងពួកអ្នកចំពោះអ្វីដែលទ្រង់បានប្រទានដល់ពួកអ្នក។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់រហ័សបំផុតក្នុងការដាក់ទណ្ឌកម្ម ហើយពិតប្រាកដណាស់ ទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

ជំពូក អាល់អាក់ប៉ាហ្វ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម សទ។

2. (គម្ពីរគួរអាន) គឺជាគម្ពីរមួយដែលគេ(អល់ឡោះ)បានបញ្ចុះវាមកកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ហេតុនេះ ចូរកុំមានការចង្អៀតចង្អល់នៅក្នុងចិត្តរបស់អ្នកអំពីវា។ (ទ្រង់បញ្ចុះវា)ដើម្បីឱ្យអ្នកព្រមានបន្លាច(មនុស្សលោក)នឹងគម្ពីរនេះ ព្រមទាំងដើម្បីជាការរំឭកដល់បណ្តាអ្នកដែលមានជំនឿ។

3. ចូរពួកអ្នកដើរតាមអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះមកឱ្យពួកអ្នកពីព្រះជាម្ចាស់របស់ពួកអ្នកចុះ។ ហើយពួកអ្នកមិនត្រូវដើរតាមមេដឹកនាំដែលអាក្រក់ក្រៅពីទ្រង់ឡើយ។ អ្វីដែលពួកអ្នកចងចាំ គឺតិចតួចបំផុត។

4. តើមានស្រុកភូមិប៉ុន្មានហើយដែលយើងបានបំផ្លាញដោយទណ្ឌកម្មរបស់យើងបានទៅដល់ភូមិស្រុកនោះ ខណៈពេលដែលពួកគេកំពុងគេងលក់នៅពេលយប់ ឬកំពុងតែគេងសម្រាកនៅពេលថ្ងៃ?

5. នៅពេលដែលទណ្ឌកម្មរបស់យើងបានទៅដល់ពួកគេ ពួកគេគ្មានអ្វីអះអាងក្រៅតែពីនិយាយ(ទទួលស្គាល់)ថា៖ ពិតប្រាកដណាស់ ពួកយើងជាពួកបំពាននោះឡើយ។

6. យើងពិតជានឹងសួរអ្នកទាំងឡាយ(ប្រជាជាតិ)ដែលយើងបានបញ្ជូន(អ្នកនាំសារ)ទៅកាន់ពួកគេ ហើយយើងក៏ពិតជានឹងសួរបណ្តាអ្នកនាំសារទាំងឡាយផងដែរ។

7. ហើយយើងប្រាកដជានឹងរៀបរាប់ប្រាប់ពួកគេ(ពីទង្វើរបស់ពួកគេ)ដោយចំណេះដឹង ហើយយើងពុំមែនជាអ្នកអវត្តមានពីពួកគេ(មិននៅជាមួយពួកគេ)នោះឡើយ។

8. ហើយការថ្លឹង(ទង្វើ)នៅថ្ងៃនោះ(ថ្ងៃបរលោក)គឺយុត្តិធម៌បំផុត។ ដូច្នេះ ជនណាហើយដែលជញ្ជីង(ទង្វើល្អរបស់គេ)មានទម្ងន់ធ្ងន់នោះ ពិតណាស់ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានជោគជ័យ។

9. រីឯជនណាហើយដែលជញ្ជីង(ទង្វើល្អរបស់គេ)មានទម្ងន់ស្រាលនោះ ពួកទាំងនោះហើយគឺជាពួកដែលខាតបង់ខ្លួនឯងដោយសារតែពួកគេធ្លាប់បានបំពានចំពោះបណ្តាកសិណតាងទាំងឡាយរបស់យើង។

10. ហើយពិតប្រាកដណាស់ យើងបានផ្តល់អំណាចគ្រប់គ្រងនៅលើផែនដីដល់ពួកអ្នក(ឱកូនចៅអាហ្វាំ) ហើយយើងក៏បានប្រទានដល់ពួកអ្នកនូវកត្តាទ្រទ្រង់ជីវិតរស់នៅ(សម្រាប់ពួកអ្នក)នៅលើផែនដីផងដែរ។។ អ្វីដែលពួកអ្នកដឹងគុណនោះ គឺតិចតួចបំផុត។

11. ហើយពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នក។ ក្រោយមក យើងបានធ្វើឱ្យពួកអ្នកមានរូបរាង។ ក្រោយមកទៀត យើងបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ទាំងឡាយថា៖ ចូរពួកអ្នកស៊ូជោត(គោរព)ចំពោះអាហ្វាំ។ ពេលនោះ ពួកគេក៏ស៊ូជោតលើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលមិនស្ថិតក្នុងចំណោមអ្នកស៊ូជោតទាំងឡាយ។

12. (ពេលនោះ)ទ្រង់បានមានបន្ទូលថា៖ តើអ្វីទៅដែលរារាំងឯងមិនឱ្យស៊ូជោតនៅពេលដែលយើងប្រើឯង(ឱ្យស៊ូជោត)នោះ? វាបានតបថា៖ ខ្ញុំល្អប្រសើរជាងគាត់។ ព្រះអង្គបង្កើតរូបខ្ញុំអំពីភ្លើង ហើយព្រះអង្គបានបង្កើតរូបគាត់អំពីដី។

13. អល់ឡោះបានមានបន្ទូលទៀតថា៖ ចូរឯងចុះចេញពីវា(ឋានសួគ៌)ចុះ។ មិនសក្តិសមទេសម្រាប់ឯងដែលក្អេងក្អាងនៅក្នុងឋានសួគ៌នេះ។ ហេតុនេះ ចូរឯងចាកចេញចុះ។ ពិតណាស់ ឯងគឺស្ថិតក្នុងចំណោមពួកដែលទាបថោកបំផុត។

14. វាបាននិយាយថា៖ សូមព្រះអង្គមេត្តាពន្យារពេលដល់ខ្ញុំរហូតដល់ថ្ងៃដែលពួកគេត្រូវបានគេបង្កើតឲ្យរស់ឡើងវិញ(ថ្ងៃបរលោក)ផងចុះ។

15. ទ្រង់បានតបថា៖ ពិតប្រាកណាស់ ឯងគឺស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេពន្យារពេលឱ្យ។

16. វាក៏បាននិយាយថា៖ ដោយសារតែព្រះអង្គបានធ្វើឱ្យខ្ញុំវង្វេង ខ្ញុំប្រាកដជានឹងអូសទាញពួកគេឱ្យចេញពីមាគ៌ាដ៏ត្រឹមត្រូវរបស់ព្រះអង្គជាមិនខាន។

17. ក្រោយមក ខ្ញុំប្រាកដជានឹងទៅដល់ពួកគេ(អូសទាញពួកគេ)ពីខាងមុខ ពីខាងក្រោយ ពីខាងស្តាំ និងពីខាងឆ្វេងពួកគេ។ ហើយព្រះអង្គនឹងមិនឃើញថា ពួកគេភាគច្រើនជាអ្នកដែលដឹងគុណនោះឡើយ។

18. ទ្រង់បានមានបន្ទូលថា៖ ចូរឯងចុះចេញពីវា(ឋានសួគ៌)ដោយត្រូវគេស្អប់ខ្ពើម និងត្រូវគេបណ្តេញចេញចុះ។ ជនណាហើយដែលដើរតាមឯងក្នុងចំណោមពួកគេ យើងប្រាកដជានឹងបំពេញនរកជើហាន់ណាំអំពីពួកឯងទាំងអស់គ្នាជាមិនខាន។

19. (ទ្រង់បានមានបន្ទូលថា៖) ឱអាដាំ! ចូរអ្នកនិងភរិយារបស់អ្នកស្នាក់នៅក្នុងឋានសួគ៌នេះចុះ ហើយអ្នកទាំងពីរអាចទទួលទានតាមអ្វីដែលអ្នកទាំងពីរប្រាថ្នា។ ក៏ប៉ុន្តែអ្នកទាំងពីរមិនត្រូវទៅជិតដើមឈើមួយដើមនេះជាដាច់ខាតដែលជាហេតុធ្វើឲ្យអ្នកទាំងពីរស្ថិតក្នុងចំណោមពួកដែលបំពានជាមិនខាន។

20. ពេលនោះ ស្មែតនបានញុះញង់គេទាំងពីរ(ព្យាការីអាដាំ និងភរិយារបស់គាត់)ដើម្បីលាតត្រដាងឱ្យពួកគេទាំងពីរបានឃើញនូវកេរខ្មាសរបស់ពួកគេទាំងពីរដែលគេ(អល់ឡោះ)បានបិទបាំងមិនឱ្យគេទាំងពីរមើលឃើញ ហើយវាបាននិយាយថា៖ ព្រះជាម្ចាស់របស់អ្នកទាំងពីរមិនបានហាមឃាត់អ្នកទាំងពីរអំពីដើមឈើនេះនោះឡើយ លើកលែងតែដើម្បីកុំឱ្យអ្នកទាំងពីរក្លាយជាម៉ាឡាអ៊ីកាត់ ឬដើម្បីកុំឱ្យអ្នកទាំងពីរស្ថិតក្នុងចំណោមអ្នកដែលមានជីវិតអមតៈ(នៅក្នុងឋានសួគ៌)ប៉ុណ្ណោះ។

21. ហើយវាបានស្បថចំពោះមុខពួកគេទាំងពីរថា៖ ពិតប្រាកដណាស់ ខ្ញុំគឺស្ថិតក្នុងចំណោមអ្នកផ្តល់ដំបូន្មានដល់អ្នកទាំងពីរ។

22. ដូច្នេះ វាបានព្យាយាមធ្វើឱ្យពួកគេទាំងពីរ(ចេញពីឋានសួគ៌)ដោយការបោកប្រាស់។ នៅពេលដែលគេទាំងពីរទទួលទានពីដើមឈើ(ដែលគេហាមឃាត់)នោះ កេរខ្មាសរបស់គេទាំងពីរក៏បានលាតត្រដាងឡើង ហើយគេទាំងពីរក៏បានបេះស្លឹកឈើឋានសួគ៌មកបិទបាំងកេរខ្មាសរបស់ខ្លួន។ ពេលនោះ ព្រះជាម្ចាស់របស់ពួកគេទាំងពីរបានហៅគេទាំងពីរ(ដោយបន្ទូលរបស់ទ្រង់)ថា៖ តើយើងមិនបានហាមឃាត់អ្នកទាំងពីរពីដើមឈើនេះ និងប្រាប់អ្នកទាំងពីរថា ពិតប្រាកដណាស់ស្មែតន គឺជាសត្រូវយ៉ាងច្បាស់លាស់ចំពោះអ្នកទាំងពីរទេឬ?

23. គេទាំងពីរបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! យើងខ្ញុំបានបំពានលើខ្លួនឯងហើយ។ ប្រសិនបើព្រះអង្គមិនអភ័យទោស និងមិនមានក្តីមេត្តាដល់យើងខ្ញុំទេនោះ ច្បាស់ជាយើងខ្ញុំនឹងស្ថិតក្នុងចំណោមពួកដែលខាតបង់ជាមិនខាន។

24. ទ្រង់បានមានបន្ទូលថា៖ ចូរពួកអ្នកចុះចេញ(ពីឋានសួគ៌នេះ)ចុះ។ ពួកអ្នកនឹងក្លាយជាសត្រូវនឹងគ្នាទៅវិញទៅមក។ ហើយផែនដីគឺជាកន្លែងសម្រាប់ពួកអ្នកស្នាក់អាស្រ័យ និងសោយសុខរហូតដល់ថ្ងៃអវសាន(នៃជីវិត)។

25. ទ្រង់បានមានបន្ទូលថា៖ នៅលើផែនដីនេះ ពួកអ្នកនឹងមានជីវិតរស់នៅ ហើយពួកអ្នកនឹងត្រូវស្លាប់នៅលើផែនដីនេះ ហើយពួកអ្នកក៏នឹងត្រូវគេបញ្ចេញអំពីវាមកវិញផងដែរ(នៅថ្ងៃបរលោក)។

26. ឱកូនចៅអាហ្វាំ(មនុស្សលោក)! ជាការពិតណាស់ យើងបានបញ្ចុះទៅឲ្យពួកអ្នកនូវសម្លៀកបំពាក់សម្រាប់បិទបាំងកេរខ្មាសរបស់ពួកអ្នក និងសម្រាប់តុបតែងខ្លួនប្រាណ។ ចំណែកឯសម្លៀកបំពាក់នៃការកោតខ្លាច គឺល្អប្រសើរជាងនេះទៅទៀត។ ទាំងនោះគឺស្ថិតក្នុងចំណោមសញ្ញាកស្តុតាងទាំងឡាយរបស់អល់ឡោះ សង្ឃឹមថា ពួកអ្នកនឹងចងចាំ។

27. ឱកូនចៅអាហ្វាំ! ចូរកុំឱ្យស៊ែតនបោកបញ្ឆោតពួកអ្នក ដូចដែលវាធ្លាប់បានធ្វើឲ្យឪពុកម្តាយទាំងពីរបស់ពួកអ្នកចេញពីឋានសួគ៌ឲ្យសោះដោយវាបានធ្វើឱ្យសម្លៀកបំពាក់របស់គាត់ទាំងពីរបូតចេញពីគាត់ទាំងពីរ ដើម្បីលាតត្រដាងឲ្យឃើញនូវកេរខ្មាសរបស់គាត់ទាំងពីរ(ស្ថិតក្នុងភាពអាក្រាត)។ ជាការពិតណាស់ វានិងបក្សពួករបស់វាអាចមើលឃើញពួកអ្នកខណៈដែលពួកអ្នកមិនអាចមើលឃើញពួកវាឡើយ។ ពិតប្រាកដណាស់ យើងបានធ្វើឱ្យស៊ែតនក្លាយជាមេដឹកនាំសម្រាប់ពួកដែលគ្មានជំនឿ។

28. ហើយនៅពេលដែលពួកគេ(ពួកមុស្រីគីន)ប្រព្រឹត្តនូវទង្វើអាក្រក់ណាមួយ ពួកគេនិយាយថា៖ ពួកយើងធ្លាប់បានឃើញជីដូនជីតារបស់ពួកយើងប្រព្រឹត្តបែបនេះ ហើយអល់ឡោះបានប្រើពួកយើងឱ្យធ្វើដូច្នោះ។ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបថា៖ ពិតប្រាកដណាស់ អល់ឡោះមិនបានប្រើឱ្យប្រព្រឹត្តនូវទង្វើអាក្រក់ឡើយ។ តើពួកអ្នកនិយាយប្រឌិតទៅលើអល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹងឬ?

29. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំបានប្រើឱ្យប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌។ ហើយទ្រង់បានបង្គាប់ប្រើពួកអ្នកឱ្យមានភាពស្មោះស(ក្នុងការគោរពសក្ការៈចំពោះទ្រង់)នៅរាល់ម៉ាស្ជិត និងត្រូវបួងសួងសុំពីទ្រង់(តែមួយគត់)ដោយចិត្តជ្រះថ្លាសម្រាប់សាសនារបស់ទ្រង់។ ដូចដែលទ្រង់បានបង្កើតពួកអ្នកពីដំបូងនោះដែរ ពួកអ្នកនឹងត្រឡប់(ទៅកាន់ទ្រង់វិញ)។

30. ក្រុមមួយទទួលបានការចង្អុលបង្ហាញ។ រីឯក្រុមមួយទៀត ពួកគេសក្តិសមនឹងទទួលភាពវង្វេង។ ជាការពិតណាស់ ពួកគេបានយកស៊ែតនធ្វើជាអ្នកគាំពារក្រៅពីអល់ឡោះ ហើយពួកគេគិតស្មានថា ពិតណាស់ ពួកគេគឺជាអ្នកដែលទទួលបាននូវការចង្អុលបង្ហាញ។

31. ឱកូនចៅអាហ្វាំ! ចូរពួកអ្នកតុបតែងលម្អខ្លួនប្រាណពួកអ្នកនៅរាល់ៗម៉ាស្ជិត(ពេលប្រតិបត្តិសឡាត)។ ហើយចូរពួកអ្នកបរិភោគ និងផឹកចុះ តែពួកអ្នកមិនត្រូវខ្ជះខ្ជាយឡើយ។ ជាការពិតណាស់ ទ្រង់មិនស្រលាញ់ពួកដែលខ្ជះខ្ជាយនោះឡើយ។

32. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើនរណាជាអ្នកដាក់បម្រាមលើពួកអ្នកមិនឲ្យស្លៀកសម្លៀកបំពាក់ល្អៗដែលអល់ឡោះបានផ្តល់ឲ្យខ្ញុំបម្រើរបស់ទ្រង់ និងចំណីអាហារល្អៗដែលទ្រង់បានប្រទានវាជាលាភសក្ការៈដល់ពួកអ្នកនោះ? ចូរអ្នកពោលចុះថា៖ ប្រការទាំងនេះ គឺសម្រាប់បណ្តាអ្នកដែលមានជំនឿ(និងអ្នកផ្សេងក្រៅពីពួកគេ)នៅក្នុងជីវិតលោកិយនេះ តែវាគឺសម្រាប់តែពួកគេ(អ្នកមានជំនឿ)ប៉ុណ្ណោះនៅថ្ងៃបរលោក។ ក៏ដូច្នោះដែរ យើងបានបកស្រាយបញ្ជាក់នូវបណ្តាកស្តុតាងទាំងឡាយសម្រាប់ក្រុមដែលចេះដឹង។

33. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត ព្រះជាម្ចាស់របស់ខ្ញុំបានហាមឃាត់មិនឱ្យប្រព្រឹត្តនូវទង្វើអាក្រក់ទាំងឡាយ មិនថាដោយបើកចំហ ឬលាក់បាំងឡើយ។ ទ្រង់ក៏បានហាមឃាត់ពីអំពើបាបទាំងឡាយ និងការបំពារបំពាន(លើគ្នា)ដោយអយុត្តិធម៌ និងមិនឱ្យពួកអ្នកធ្វើស្ហ៊ីរិក(ពហុទេពនិយម)ចំពោះអល់ឡោះនូវអ្វីដែលទ្រង់មិនបានបញ្ចុះកស្តតាងណាមួយចំពោះវា ព្រមទាំងមិនឲ្យពួកអ្នកនិយាយប្រឌិតទៅលើអល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹងនោះឡើយ។

34. ហើយរាល់ប្រជាជាតិនីមួយៗ គឺមានអាយុកាលកំណត់រួចជាស្រេច។ ដូចនេះ នៅពេលដែលអាយុកាលកំណត់របស់ពួកគេបានមកដល់ហើយនោះ គឺពួកគេមិនអាចសុំពន្យារពេលបានឡើយ ហើយក៏មិនអាចសុំវាមកដល់មុនពេលកំណត់បានដែរ។

35. ឱកូនចៅអាហ្វាំ! ប្រសិនបើបណ្តាអ្នកនាំសារពីក្នុងចំណោមពួកអ្នកបានមកដល់ពួកអ្នក ដោយពួកគាត់សូត្រឱ្យពួកអ្នកស្តាប់នូវបណ្តាវាក្យខណ្ឌរបស់យើងនោះ (ចូរពួកអ្នកគោរពប្រតិបត្តិតាមពួកគាត់ចុះ)។ ជាការពិតណាស់ ជនណាដែលកោតខ្លាច(អល់ឡោះ) ព្រមទាំងបានកែលម្អ(នូវទង្វើរបស់ខ្លួន)នោះ ពួកគេពិតជាគ្មានការភ័យខ្លាច ហើយក៏គ្មានការព្រួយបារម្ភអ្វីនោះដែរ។

36. រីឯពួកដែលបានបដិសេធនឹងបណ្តាកស្តតាងរបស់យើង ព្រមទាំងក្អេងក្អាង(មិនទទួលយកវា) ពួកទាំងនោះហើយគឺជាពួកឋាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។

37. ហើយគ្មាននរណាម្នាក់ដែលបំពានជាងអ្នកដែលប្រឌិតរឿងកុហកទៅលើអល់ឡោះ ឬបដិសេធនឹងបណ្តាកស្តតាងរបស់ទ្រង់នោះឡើយ។ ពួកទាំងនោះនឹងទទួលបាននូវចំណែករបស់ពួកគេដែលបានកត់ត្រាទុកនៅក្នុងបញ្ជីកំណត់ត្រា។ លុះដល់ពេលដែលអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងបានមកដល់ពួកគេដើម្បីដកហូតព្រលឹងរបស់ពួកគេនោះ ម៉ាឡាអ៊ីកាត់បានសួរថា៖ តើឯណាទៅអ្វីដែលពួកអ្នកធ្លាប់បានគោរពសក្ការៈ(ចំពោះពួកវា)ក្រៅពីអល់ឡោះជាម្ចាស់នោះ? ពួកគេបានតបថា៖ ពួកវាបានបាត់ចេញពីពួកយើងហើយ ហើយពួកគេបានធ្វើសាក្សី(ទទួលស្គាល់)ទៅលើខ្លួនឯងថា៖ ពិតប្រាកដណាស់ពួកគេធ្លាប់ជាពួកដែលប្រឆាំង។

38. ទ្រង់បានមានបន្ទូលថា៖ ចូរពួកអ្នកចូលឋាននរកជាមួយប្រជាជាតិដែលបានកន្លងផុតទៅមុនពួកអ្នកក្នុងចំណោមពួកជិននិងមនុស្សលោកចុះ។ រាល់ពេលដែលប្រជាជាតិមួយបានចូល(ក្នុងឋាននរក) ពួកគេក៏បានដាក់បណ្តាសាចំពោះអ្នកដែលចូលមុនខ្លួន។ លុះដល់ពេលដែលពួកគេបានចូលក្នុងនរកទាំងអស់គ្នាហើយនោះ ពួកដែលចូលនរកក្រោយគេ(អ្នកដែលដើរតាម)បាននិយាយចំពោះពួកដែលបានចូលនរកមុនខ្លួន(ពួកមេដឹកនាំ)ថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពួក(មេដឹកនាំ)ទាំងនោះហើយដែលបានធ្វើឱ្យពួកយើងវង្វេង។ ហេតុនេះ សូមព្រះអង្គមេត្តាដាក់ទណ្ឌកម្មនៃឋាននរកដល់ពួកគេទ្វេដងផងចុះ។ ទ្រង់បានមានបន្ទូលថា៖ គ្រប់ក្រុមទាំងអស់នឹងទទួលនូវទណ្ឌកម្មទ្វេដង ក៏ប៉ុន្តែពួកអ្នកមិនបានដឹងឡើយ។

39. ពួកដែលចូលនរកមុន(ពួកមេដឹកនាំ)បាននិយាយទៅកាន់ពួកដែលចូលនរកក្រោយ(ពួកដែលដើរតាមពួកគេ)ថា៖ ពួកអ្នកគ្មានអ្វីពិសេសលើសពួកយើងនោះឡើយ។ ហេតុនេះ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

40. ពិតប្រាកដណាស់ ពួកដែលបានបដិសេធនឹងកស្តតាងទាំងឡាយរបស់យើង និងក្អេងក្អាងចំពោះវា(មិនព្រមទទួលយក) គេនឹងមិនបើកទ្វារមេឃសម្រាប់ពួកគេឡើយ ហើយពួកគេក៏មិនអាចចូលឋានសួគ៌បាននោះដែរ លុះត្រាតែសត្វអូដ្ឋអាចចូលក្នុងរន្ធម្ជុលបាន។ ក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះអ្នកដែលប្រព្រឹត្តិអាក្រក់ទាំងឡាយ។

41. សម្រាប់ពួកគេមានកម្រាលពីភ្លើងនរក(នៅពីក្រោមពួកគេ) និងភ្លើងនរកគ្របពីលើពួកគេ។ ក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះពួកដែលបំពាន។

42. រីឯបណ្ដាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល យើង(អល់ឡោះ)មិនដាក់បន្ទុកលើបុគ្គលណាម្នាក់ហួសពីសមត្ថភាពរបស់គេនោះឡើយ។ អ្នកទាំងនោះ គឺជាអ្នកឋានសួគ៌ដោយពួកគេស្ថិតនៅក្នុងវាជាអមតៈ។

43. ហើយយើងបានដកនូវភាពឈ្នានីសចេញពីដួងចិត្តរបស់ពួកគេ ព្រមទាំងមានទន្លេជាច្រើនហូរកាត់ពីក្រោមពួកគេ។ ហើយពួកគេនិយាយថា៖ សេចក្ដីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលទ្រង់បានចង្អុលបង្ហាញពួកយើងនូវប្រការទាំងនេះ ហើយពួកយើងមិនអាចទទួលបានការចង្អុលបង្ហាញ(ដោយខ្លួនឯង)ឡើយ ប្រសិនបើអល់ឡោះមិនចង្អុលបង្ហាញពួកយើងទេនោះ។ ជាការពិតណាស់ បណ្ដាអ្នកនាំសារនៃព្រះជាម្ចាស់របស់ពួកយើងបាននាំមកនូវសេចក្ដីពិត។ ហើយមានគេប្រកាសប្រាប់ពួកគេថា៖ ពិតប្រាកដណាស់ នេះគឺជាឋានសួគ៌ដែលគេផ្ដល់វាជាមរតកដល់ពួកអ្នកដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

44. ហើយបណ្ដាអ្នកឋានសួគ៌បានស្រែកសួរពួកឋាននរកថា៖ ពិតប្រាកដណាស់ ពួកយើងបានឃើញហើយថា អ្វីដែលព្រះជាម្ចាស់របស់ពួកយើងបានសន្យានោះ គឺជាការពិត។ តើពួកអ្នកបានឃើញថា អ្វីដែលព្រះជាម្ចាស់របស់ពួកអ្នកបានសន្យា(ព្រមានពីឋាននរក)នោះ គឺជាការពិតដែរឬទេ? ពួកគេបានឆ្លើយថា៖ ពិតមែនហើយ។ ពេលនោះ មានអ្នកប្រកាសម្នាក់បានប្រកាសប្រាប់រវាងពួកគេថា៖ ពិតប្រាកដណាស់ បណ្ដាសារបស់អល់ឡោះ គឺធ្លាក់ទៅលើពួកដែលបំពាន។

45. គឺពួកដែលរារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះ ព្រមទាំងមានបំណងធ្វើឱ្យមាគ៌ានោះមានភាពវៀចវេរ។ ហើយពួកគេ គឺជាពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក។

46. ហើយនៅចន្លោះរវាងក្រុមទាំងពីរ(ក្រុមឋានសួគ៌ និងក្រុមឋាននរក) គឺមានជញ្ជាំងខណ្ឌ។ នៅពីលើជញ្ជាំងខណ្ឌនោះ គឺមានបុរសជាច្រើនដែលពួកគេស្គាល់ក្រុមទាំងពីរតាមរយៈសញ្ញាសម្គាល់របស់ពួកគេ។ ហើយពួកគេបានស្រែកហៅអ្នកឋានសួគ៌ថា៖ សូមសន្តិភាពកើតមានដល់ពួកអ្នក។ ពួកគេមិនទាន់បានចូលវា(ឋានសួគ៌)នោះទេ តែពួកគេមានសង្ឃឹមថានឹងបានចូល។

47. ហើយនៅពេលដែលពួកគេបានបង្វែរក្រសែភ្នែករបស់ពួកគេសម្លឹងមើលទៅកាន់ពួកឋាននរកវិញ ពួកគេក៏បួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាកុំឲ្យយើងខ្ញុំស្ថិតនៅជាមួយនឹងក្រុមដែលបំពាននោះឡើយ។

48. ហើយពួកអាក់រ៉ាហ្វបានស្រែកហៅពួកបុរស។(នៃពួកឋាននរក)ដែលពួកគេស្គាល់ពួកនោះតាមរយៈសញ្ញាសម្គាល់របស់ពួកគេថា៖ អ្វីដែលពួកអ្នកខិតខំប្រមូល(ទ្រព្យសម្បត្តិ និងកូនចៅ) និងអ្វីដែលពួកអ្នកធ្លាប់មានភាពក្អេងក្អាង(បដិសេធការពិត)នោះ គឺមិនអាចផ្ដល់ផលប្រយោជន៍អ្វីដល់ពួកអ្នកបានឡើយ។

49. (អល់ឡោះបានមានបន្ទូលទៅកាន់ពួកគ្មានជំនឿថា៖) តើអ្នកទាំងនោះឬដែលពួកអ្នកបានស្បថថា៖ អល់ឡោះជាម្ចាស់នឹងមិនប្រទានក្ដីមេត្តាករុណាដល់ពួកគេទេនោះ? (ហើយទ្រង់ក៏បានមានបន្ទូលទៅកាន់បណ្ដាអ្នកមានជំនឿថា៖) ចូរពួកអ្នកចូលទៅក្នុងឋានសួគ៌ចុះដោយគ្មានការភ័យខ្លាចអ្វីទៅលើពួកអ្នកនោះឡើយ ហើយពួកអ្នកក៏គ្មានការព្រួយបារម្ភអ្វីនោះដែរ។

50. ហើយពួកឋាននរកបានស្រែកហៅបណ្ដាអ្នកឋានសួគ៌ថា៖ សូមពួកអ្នកជួយផ្ដល់ទឹក ឬក៏ផ្ដល់នូវអ្វីដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកអ្នកមកពួកយើងបន្តិចផង។ ពួកគេបានតបថា៖ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានដាក់បម្រាមរបស់ទាំងពីរនេះ(ចំណីអាហារនិងទឹក)ចំពោះពួកដែលគ្មានជំនឿ។

51. គឺពួកដែលបានយកសាសនារបស់ខ្លួនជាការលេងសើច និងជាការកម្សាន្ត ហើយឆាកជីវិតលោកិយបានបោកបញ្ឆោតពួកគេ។ ដូច្នេះ នៅថ្ងៃនេះ (ថ្ងៃបរលោក) យើងបំភ្លេចពួកគេវិញ ដូចដែលពួកគេធ្លាប់បានភ្លេចពីជំនួបរបស់ពួកគេនាថ្ងៃនេះ និងដោយសារតែអ្វីដែលពួកគេធ្លាប់បានបដិសេធចំពោះបណ្តាភស្តុតាងទាំងឡាយរបស់យើង។

52. ហើយជាការពិតណាស់ យើងបាននាំមកឱ្យពួកគេនូវគម្ពីរ (គួរអាន) នេះដោយយើងបានបកស្រាយពន្យល់ដោយចំណេះដឹង (ពីយើង) ជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាចំពោះក្រុមដែលមានជំនឿ។

53. តើពួកគេ (ពួកគ្មានជំនឿ) គ្មានរង់ចាំអ្វីក្រៅពីអ្វី (ទណ្ឌកម្ម) ដែលគេធ្លាប់បានប្រាប់ពួកគេ (ក្នុងគម្ពីរគួរអាន) ទេឬ? នៅថ្ងៃដែលរាល់អ្វីដែលគេធ្លាប់បានប្រាប់ពួកគេបានមកដល់ ពួកដែលបានភ្លេចវា (គម្ពីរគួរអាន) កាលពីមុន ពួកគេនឹងនិយាយថា៖ ពិតប្រាកដណាស់ បណ្តាអ្នកនាំសារនៃព្រះជាម្ចាស់របស់ពួកយើងបាននាំមកនូវការពិត។ ដូចនេះ តើពួកយើងមានអ្នកអន្តរាគមន៍ណាដែលអាចជួយអន្តរាគមន៍ដល់ពួកយើង ឬក៏បញ្ជូនពួកយើងឲ្យត្រឡប់ (ទៅកាន់លោកិយវិញ) ដើម្បីពួកយើងនឹងសាងនូវទង្វើ (កុសល) ផ្សេងពីទង្វើ (អាក្រក់) ដែលពួកយើងធ្លាប់បានសាងដៃឬទេ? ជាការពិតណាស់ ពួកគេបានខាតបង់ខ្លួនឯង ហើយអ្វី (ព្រះនានា) ដែលពួកគេធ្លាប់បានប្រឌិតឡើងនោះ បានបាត់បង់ពីពួកគេ។

54. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នក គឺអល់ឡោះដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីរយៈពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ទ្រង់គង់ខ្ពស់លើអារ៉ស្ហ។ ទ្រង់បានធ្វើឲ្យពេលថ្ងៃត្រូវបាត់បង់ដោយ (ភាពងងឹតនៃ) ពេលរាត្រី ហើយពេលនីមួយៗ (ពេលយប់និងពេលថ្ងៃ) ត្រូវផ្លាស់ប្តូរវេនគ្នាយ៉ាងឆាប់រហ័ស។ ហើយទ្រង់បានបង្កើតព្រះអាទិត្យ ព្រះចន្ទ និងហ្វូងតារាជាច្រើនដោយពួកវាដើរតាមបទបញ្ជារបស់ទ្រង់។ តើពុំមែនទេឬ ការបង្កើត និងកិច្ចការទាំងឡាយ គឺជាកម្មសិទ្ធិរបស់ទ្រង់ (តែមួយគត់) នោះ។ មហាកិត្តិគុណបំផុតអល់ឡោះព្រះជាម្ចាស់នៃពិភពទាំងអស់។

55. ចូរពួកអ្នកបួងសួងសុំពីព្រះជាម្ចាស់របស់ពួកអ្នកដោយការឱនលំទោន និងដោយស្ងាត់ៗ (មិនទាមទារឱ្យគេមើលឃើញ)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនស្រលាញ់ពួកដែលបំពានឡើយ។

56. ហើយចូរពួកអ្នកកុំបង្កវិនាសកម្មនៅលើផែនដីឲ្យសោះក្រោយពីវាមានភាពល្អប្រសើរហើយនោះ។ ហើយចូរពួកអ្នកបួងសួងសុំពីទ្រង់ដោយខ្លាច (ទណ្ឌកម្ម) និងមានក្តីសង្ឃឹម។ ជាការពិតណាស់ ក្តីមេត្តាករុណារបស់អល់ឡោះ គឺស្ថិតនៅជិតបំផុតនឹងបណ្តាអ្នកដែលសាងអំពើល្អ។

57. ហើយទ្រង់ជាអ្នកដែលបញ្ជូនខ្យល់ជាដំណឹងរីករាយពីក្តីករុណារបស់ទ្រង់ដែលនៅខាងមុខ (ធ្លាក់ភ្លៀង)។ លុះដល់ពេលដែលខ្យល់នោះបាននាំមកនូវដុំពពកដ៏ធ្ងន់ (ពោរពេញដោយទឹក) យើងក៏បានស្រោចស្រពវាទៅលើតំបន់ដែលរាំងស្ងួតដោយយើងបានបញ្ចុះទឹកភ្លៀងចេញពីដុំពពកនោះ។ ហើយតាមរយៈទឹកភ្លៀងនោះ យើងបានបញ្ចេញនូវផលានុផលគ្រប់ប្រភេទ។ ក៏ដូច្នោះដែរ យើងនឹងបញ្ចេញអ្នកស្លាប់ (ចេញពីផ្នូររបស់ពួកគេ) សង្ឃឹមថាពួកអ្នកនឹងចងចាំ។

58. ហើយដីដែលមានជីជាតិនោះ វានឹងដុះចេញនូវរុក្ខជាតិរបស់វាដោយការអនុញ្ញាតពីព្រះជាម្ចាស់របស់វា។ រីឯដីដែលគ្មានជីជាតិវិញ វាមិនអាចដុះចេញអ្វីឡើយលើកលែងតែដោយលំបាកប៉ុណ្ណោះ។ ក៏ដូច្នោះដែរ យើងបានលើកឡើងនូវភស្តុតាងជាច្រើនប្រភេទសម្រាប់ក្រុមដែលចេះដឹងគុណ។

59. ជាការពិតណាស់ យើងបានបញ្ជូនព្យាការីនូហទៅកាន់ក្រុមរបស់គាត់ដោយគាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ (តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ។ ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពួកអ្នក (ឱក្រុមរបស់ខ្ញុំ) ទទួលរងនូវទណ្ឌកម្មនៅថ្ងៃដ៏មហិមា (ថ្ងៃបរលោក)។

60. ពួកមេដឹកនាំក្នុងចំណោមក្រុមរបស់គាត់បានតបថា៖ ជាការពិតណាស់ យើងឃើញថា អ្នកស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

61. គាត់បានតបវិញថា៖ ឱក្រុមរបស់ខ្ញុំ! រូបខ្ញុំមិនមែនជាអ្នកដែលវង្វេងនោះឡើយ។ ក៏ប៉ុន្តែ ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសារម្នាក់ពីព្រះជាម្ចាស់នៃពិភពទាំងឡាយ។

62. ខ្ញុំផ្សព្វផ្សាយដល់ពួកអ្នកនូវសារទាំងឡាយនៃព្រះជាម្ចាស់របស់ខ្ញុំ និងផ្តល់ដំបូន្មានដល់ពួកអ្នក ហើយខ្ញុំដឹងអំពីអល់ឡោះនូវអ្វីដែលពួកអ្នកមិនបានដឹង។

63. តើពួកអ្នកមានការចម្លែកក្នុងចិត្តឬដែលការរំឭកពីព្រះជាម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកតាមរយៈបុរសម្នាក់ក្នុងចំណោមពួកអ្នកនោះ? (គាត់មកដល់ពួកអ្នក)ដើម្បីព្រមានបន្លាចពួកអ្នក(ពីទណ្ឌកម្ម) និងដើម្បីឲ្យពួកអ្នកកោតខ្លាចអល់ឡោះ ហើយនិងសង្ឃឹមថា ពួកអ្នកនឹងត្រូវបានគេអាណិតស្រលាញ់។

64. ប៉ុន្តែពួកគេបានបដិសេធចំពោះគាត់។ ដូច្នេះ យើង(អល់ឡោះ)ក៏បានសង្គ្រោះរូបគាត់ និងអ្នកដែលនៅជាមួយគាត់ក្នុងសំពៅ ហើយយើងបានឲ្យពួកដែលបានបដិសេធនឹងបណ្តាកស្តុតាងទាំងឡាយរបស់យើងលិចលង់(ក្នុងទឹកជំនន់)។ ពិតណាស់ ពួកគេគឺជាក្រុមដែលខ្វាក់(មើលមិនឃើញការពិត)។

65. ហើយយើងបានបញ្ជូនទៅកាន់ក្រុមអាទនូវព្យាការីហ៊ូទដែលជាបងប្អូនរបស់ពួកគេ។ គាត់បានពោលថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ។ តើពួកអ្នកមិនកោតខ្លាច(ទ្រង់)ទេឬ?

66. ពួកមេដឹកនាំដែលជាអ្នកប្រឆាំងក្នុងចំណោមក្រុមរបស់គាត់បាននិយាយថា៖ ជាការពិតណាស់ ពួកយើងឃើញថា អ្នកជាមនុស្សអន់បញ្ញា ហើយពួកយើងគិតថា អ្នកគឺពិតជាស្ថិតក្នុងចំណោមអ្នកដែលកុហក។

67. គាត់បានតបវិញថា៖ ឱក្រុមរបស់ខ្ញុំ! ខ្ញុំមិនមែនជាមនុស្សអន់បញ្ញានោះឡើយ។ ក៏ប៉ុន្តែ ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសារម្នាក់ពីព្រះជាម្ចាស់នៃពិភពទាំងឡាយ។

68. ខ្ញុំផ្សព្វផ្សាយដល់ពួកអ្នកនូវសារទាំងឡាយនៃព្រះជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំជាអ្នកផ្តល់ដំបូន្មានដ៏ទៀងត្រង់ម្នាក់សម្រាប់ពួកអ្នក។

69. តើពួកអ្នកមានការចម្លែកក្នុងចិត្តដែលការរំឭកពីព្រះម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកតាមរយៈបុរសម្នាក់ក្នុងចំណោមពួកអ្នកនោះដើម្បីគាត់ព្រមានបន្លាចពួកអ្នក(ពីទណ្ឌកម្ម)នោះឬ? ហើយចូរពួកអ្នកចងចាំ ខណៈដែលទ្រង់បានបង្កើតពួកអ្នកជាអ្នកស្នងតំណែង(គ្រប់គ្រងផែនដី)បន្ទាប់ពីក្រុមរបស់ព្យាការីនួហ ហើយបានបន្ថែមឲ្យពួកអ្នកនូវរាងកាយរឹងមាំខ្លាំងក្លា(លើសពីពួកគេ)។ ហើយចូរពួកអ្នកចងចាំនូវឧបការគុណទាំងឡាយរបស់អល់ឡោះ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

70. ពួកគេបាននិយាយថា៖ តើអ្នកបានមកដល់ពួកយើងដើម្បីឲ្យពួកយើងគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ ហើយបោះបង់ចោលនូវអ្វីដែលជីដូនជីតារបស់ពួកយើងធ្លាប់គោរពបូជា(ពីមុនមក)នោះឬ? ដូច្នេះ ចូរអ្នកនាំមកឱ្យពួកយើងនូវអ្វី(ទណ្ឌកម្ម)ដែលគេបានសន្យាចំពោះពួកយើងនោះមក ប្រសិនបើអ្នកពិតជាស្ថិតក្នុងចំណោមអ្នកដែលសច្ចៈ(និយាយពិត)មែននោះ។

71. គាត់បានតបថា៖ ទណ្ឌកម្ម និងការខឹងសម្បាពីព្រះជាម្ចាស់របស់ពួកអ្នកប្រាកដជានឹងធ្លាក់ទៅលើពួកអ្នកជាមិនខាន។ តើពួកអ្នកប្រកែកដេញដោលជាមួយខ្ញុំពីឈ្មោះទាំងឡាយដែលពួកអ្នក និងជីដូនជីតារបស់ពួកអ្នកបានដាក់ឈ្មោះឱ្យពួកវា(ថាជាព្រះ)ដោយអល់ឡោះជាម្ចាស់ក៏មិនបានបញ្ជាះនូវភស្តុតាងណាមួយបញ្ជាក់ពីវានោះឬ? ដូច្នេះ ចូរពួកអ្នករង់ចាំមើល(ទណ្ឌកម្ម)ចុះ។ ពិតប្រាកដណាស់ ខ្ញុំក៏ស្ថិតក្នុងចំណោមអ្នកដែលរង់ចាំមើលជាមួយពួកអ្នកផងដែរ។

72. ដូច្នេះ យើងក៏បានសង្គ្រោះគាត់ និងអ្នក(មានជំនឿ)ដែលនៅជាមួយគាត់ដោយក្តីមេត្តាករុណាពីយើង ហើយយើងបានបំផ្លាញផ្តាច់ពូជពួកដែលបានបដិសេធនឹងបណ្តាភស្តុតាងរបស់យើង។ ហើយពួកគេពុំមែនជាអ្នកដែលមានជំនឿឡើយ។

73. ហើយយើងបានបញ្ជូនទៅកាន់ក្រុមសាមូទនូវព្យាការីសឡេះដែលជាបងប្អូនរបស់ពួកគេ។ គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ។ ពិតប្រាកដណាស់ ភស្តុតាងយ៉ាងជាក់ច្បាស់ពីព្រះជាម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកហើយ។ នេះគឺជាសត្វអូដ្ឋញីរបស់អល់ឡោះ ជាសញ្ញាភស្តុតាងមួយសម្រាប់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នកបណ្តោយវាឱ្យដើរកចំណីស៊ីនៅលើផែនដីរបស់អល់ឡោះចុះ ហើយពួកអ្នកមិនត្រូវប៉ះពាល់វាដោយប្រការអាក្រក់ណាមួយឡើយ។ បើមិនដូច្នោះទេ ពួកអ្នកនឹងត្រូវទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់ជាមិនខាន។

74. ហើយចូរពួកអ្នកចងចាំ ខណៈដែលទ្រង់បានតែងតាំងពួកអ្នកជាអ្នកស្នងតំណែង(គ្រប់គ្រងផែនដី)បន្ទាប់ពីក្រុមអាទ និងបានផ្តល់លំនៅឋានដល់ពួកអ្នកនៅលើភពផែនដីនេះដោយពួកអ្នកបានសាងសង់វិមាននៅលើដីរាប ហើយបានចោះភ្នំជាច្រើនធ្វើជាផ្ទះ។ ដូច្នេះ ចូរពួកអ្នកចងចាំនូវឧបការគុណទាំងឡាយរបស់អល់ឡោះ ហើយពួកអ្នកមិនត្រូវដើរបង្កវិនាសកម្មនៅលើផែនដីឡើយ។

75. ពួកមេដឹកនាំដែលក្រអឺតក្រទមនៃក្រុមរបស់គាត់បាននិយាយទៅកាន់អ្នកទន់ខ្សោយដែលជាអ្នកមានជំនឿក្នុងចំណោមពួកគេថា៖ តើពួកអ្នកដឹងច្បាស់ឬទេដែលថា ពិតណាស់ សឡេះ ជាអ្នកដែលត្រូវបានព្រះជាម្ចាស់របស់គេបញ្ជូនមកនោះ? ពួកគេបានឆ្លើយថា៖ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលមានជំនឿចំពោះអ្វីដែលគាត់បាននាំមក។

76. ពួកដែលក្រអឺតក្រទម(ពួកមេដឹកនាំ)បាននិយាយទៀតថា៖ ពិតណាស់ ពួកយើងជាអ្នកដែលគ្មានជំនឿចំពោះអ្វីដែលពួកអ្នកបានជឿនោះឡើយ។

77. ដូច្នេះ ពួកគេក៏បានសំឡេះសត្វអូដ្ឋញីដោយពួកគេក្រអឺតក្រទមចំពោះបទបញ្ជានៃព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេថែមទាំងនិយាយ(ចំអកឡកឡឺយ)ថា៖ ឱ សឡេះ! ចូរអ្នកនាំមកឱ្យពួកយើងនូវអ្វី(ទណ្ឌកម្ម)ដែលអ្នកបានសន្យាចំពោះពួកយើងនោះមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកនាំសារ(របស់អល់ឡោះ)មែននោះ។

78. ពេលនោះ រញ្ជួយដីដ៏ខ្លាំងក្លាមួយបានឆក់យកជីវិតពួកគេ ហើយពួកគេក៏បាន(ស្លាប់)ក្លាយជាសាកសពនៅក្នុងផ្ទះរបស់ពួកគេ។

79. បន្ទាប់មក ព្យាការីសឡេះក៏បានបែរចេញពីពួកគេ ហើយគាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ខ្ញុំពិតជាបានផ្សព្វផ្សាយដល់ពួកអ្នកនូវសារទាំងឡាយនៃព្រះជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំក៏បានផ្តល់ដំបូន្មានដល់ពួកអ្នកផងដែរ។ ក៏ប៉ុន្តែពួកអ្នកមិនចូលចិត្តអ្នកដែលផ្តល់ដំបូន្មានទាំងឡាយនោះឡើយ។

80. ហើយ(ចូរអ្នកនឹកឃើញពីរឿងរបស់)ព្យាការីលូត ខណៈដែលគាត់បាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ តើពួកអ្នកប្រព្រឹត្តនូវទង្វើអសីលធម៌(ស្រឡាញ់ភេទដូចគ្នា)ដែលគ្មាននរណាម្នាក់នៅលើពិភពលោកធ្លាប់បានប្រព្រឹត្តវាមុនពួកអ្នកនោះឬ?

81. ពិតប្រាកដណាស់ ពួកអ្នកពិតជាបានយកបុរសទាំងឡាយមកបំពេញចំណង់តណ្ហាក្រៅពីស្ត្រី។ ផ្ទុយទៅវិញ ពួកអ្នកគឺជាក្រុមដែលបំពានព្រំដែន(របស់អល់ឡោះ)។

82. ហើយក្រុមរបស់គាត់ពុំបានឆ្លើយតបចំពោះអ្វីនោះឡើយ ក្រៅពីពួកគេនិយាយថា៖ ចូរពួកអ្នកបណ្តេញពួកគេ(លូត និងក្រុមគ្រួសារ)ចេញពីភូមិស្រុករបស់ពួកអ្នកចុះ។ ពិតណាស់ ពួកគេគឺជាពួកមនុស្សដែលចង់ជម្រះសម្អាតខ្លួន(ពីការរួមមេត្រីជាមួយបុរសដូចគ្នា)។

83. ដូច្នេះ យើងក៏បានសង្គ្រោះរូបគេ និងក្រុមគ្រួសាររបស់គេ លើកលែងតែប្រពន្ធរបស់គេប៉ុណ្ណោះដែលស្ថិតក្នុងចំណោមអ្នកដែលអន្តរាយ។

84. ហើយយើងបានបញ្ជូនភ្លៀង(ជាដុំថ្ម)មួយមេយ៉ាងធំទៅលើពួកគេ។ ដូចនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិចារណាមើលចុះថា តើលទ្ធផលចុងក្រោយរបស់ពួកដែលប្រព្រឹត្តអំពើអាក្រក់នោះយ៉ាងដូចម្តេច?

85. ហើយយើងបានបញ្ជូនទៅកាន់ក្រុមម៉ាទយ៉ាន់នូវព្យាការីស៊ូអែបដែលជាបងប្អូនរបស់ពួកគេ។ គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ។ ពិតប្រាកដណាស់ កស្តុតាងយ៉ាងជាក់ច្បាស់ពីព្រះជាម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកហើយ។ ហេតុនេះ ចូរពួកអ្នកបំពេញនូវការវាល់ និងការថ្លឹងឱ្យបានគ្រប់(កុំបំបាត់ភ្នែកជញ្ជីង)។ ហើយពួកអ្នកមិនត្រូវបំបាត់(ឬបន្លំ)មនុស្សលោកចំពោះទំនិញរបស់ពួកគេ(ថ្លឹងមិនគ្រប់)នោះឡើយ ហើយក៏មិនត្រូវបង្កវិនាសកម្មនៅលើផែនដីនោះដែរក្រោយពេលដែលវាមានភាពល្អប្រសើរហើយនោះ។ នោះគឺជាការប្រសើរសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿ។

86. ហើយពួកអ្នកមិនត្រូវអង្គុយនៅតាមដងផ្លូវនានាដើម្បីប្លន់យកទ្រព្យសម្បត្តិ និងរារាំងពីមាគ៌ារបស់អល់ឡោះចំពោះអ្នកដែលមានជំនឿលើទ្រង់ ដោយពួកអ្នកមានបំណងឱ្យវា(មាគ៌ាអល់ឡោះ)មានភាពវៀចវេរនោះឡើយ។ ហើយចូរពួកអ្នកនឹកឃើញ ខណៈដែលពួកអ្នកមានគ្នាតិច ទ្រង់បានធ្វើឱ្យពួកអ្នកមានគ្នាច្រើន។ ហើយចូរពួកអ្នកពិនិត្យមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបង្កវិនាសកម្មនោះយ៉ាងដូចម្តេច?

87. ហើយប្រសិនបើក្រុមមួយក្នុងចំណោមពួកអ្នកមានជំនឿចំពោះអ្វីដែលខ្ញុំបាននាំមក ហើយក្រុមមួយទៀតគ្មានជំនឿចំពោះវាទេនោះ ដូច្នេះ ចូរពួកអ្នកអត់ធ្មត់(រង់ចាំមើល)ចុះ រហូតដល់អល់ឡោះទ្រង់កាត់សេចក្តីរវាងពួកយើង។ ហើយទ្រង់គឺជាអ្នកកាត់សេចក្តីដ៏ប្រសើរបំផុត។

88. ពួកមេដឹកនាំដែលក្រអឺតក្រទមក្នុងចំណោមក្រុមរបស់គាត់បាននិយាយថា៖ ឱស៊ូអែប! ពួកយើងប្រាកដជានឹងបណ្តេញអ្នកនិងបណ្តាអ្នកដែលមានជំនឿជាមួយអ្នកចេញពីស្រុកភូមិរបស់យើងនេះ ឬក៏អ្នកត្រូវតែលែងត្រឡប់មកកាន់សាសនារបស់ពួកយើងវិញ។ គាត់បានពោលថា៖ តើទោះជាពួកយើងមិនពេញចិត្តក៏ដោយឬ?

89. ពួកយើងប្រាកដជាប្រឌិតកុហកទៅលើអល់ឡោះជាមិនខានប្រសិនបើពួកយើងត្រឡប់ទៅកាន់សាសនារបស់ពួកអ្នកក្រោយពីអល់ឡោះទ្រង់បានសង្គ្រោះពួកយើងអំពីវាហើយនោះ។ វាមិនត្រឹមត្រូវឡើយសម្រាប់ពួកយើងប្រសិនបើពួកយើងវិលត្រឡប់ទៅកាន់វា(សាសនាខុសឆ្គងរបស់ពួកអ្នក)វិញនោះ លើកលែងតែអល់ឡោះជាព្រះជាម្ចាស់របស់ពួកយើងមានចេតនាប៉ុណ្ណោះ។ ចំណេះដឹងនៃព្រះជាម្ចាស់របស់យើងទូលំទូលាយជ្រួតជ្រាបលើរាល់អ្វីៗទាំងអស់។ ចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)ដែលពួកយើងប្រគល់ការទុកចិត្ត។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាវិនិច្ឆ័យរវាងយើងខ្ញុំនិងក្រុមរបស់យើងខ្ញុំដោយយុត្តិធម៌ផងចុះ។ ហើយទ្រង់ជាអ្នកវិនិច្ឆ័យដ៏ប្រសើរបំផុត។

90. ហើយពួកមេដឹកនាំដែលគ្មានជំនឿក្នុងចំណោមក្រុមរបស់គាត់បាននិយាយ(ព្រមានក្រុមរបស់ពួកគេ)ថា៖ ប្រសិនបើពួកអ្នកតាមស៊ូអែបនោះ ពិតប្រាកដណាស់ ពួកអ្នកពិតជាពួកដែលខាតបង់ជាមិនខាន។

91. ពេលនោះ រញ្ជួយដីដ៏ខ្លាំងក្លាមួយបានឆក់យកជីវិតពួកគេ ហើយពួកគេក៏បាន(ស្លាប់)ក្លាយជាសាកសពនៅក្នុងផ្ទះរបស់ពួកគេ។

92. ពួកដែលបានបដិសេធនឹងព្យាការីស៊ូអែប(បានវិនាសអន្តរាយទាំងអស់)ហាក់បីដូចជាពួកគេមិនធ្លាប់បានរស់នៅទីនោះឡើយ។ ពួកដែលបដិសេធនឹងព្យាការីស៊ូអែបនោះ ពួកគេគឺជាពួកដែលខាតបង់។

93. ហើយគាត់(ព្យាការីស៊ូអែប)បានបែរចេញពីពួកគេ ហើយនិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ខ្ញុំពិតជាបានផ្សព្វផ្សាយដល់ពួកអ្នកនូវសារទាំងឡាយនៃព្រះជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំក៏បានផ្តល់ដំបូន្មានដល់ពួកអ្នកផងដែរ។ ដូច្នេះ តើឱ្យខ្ញុំសោកស្តាយចំពោះក្រុមដែលគ្មានជំនឿនោះយ៉ាងដូចម្តេច?

94. ហើយយើងមិនបានបញ្ជូនព្យាការីណាម្នាក់ទៅកាន់ភូមិស្រុកណាមួយ(ហើយពួកគេប្រឆាំងនឹងគាត់នោះឡើយ)លើកលែងតែយើងធ្វើឲ្យអ្នកស្រុកភូមិនោះជួបប្រទះនូវភាពក្រខ្សត់ និងជំងឺផ្សេងៗ ដោយសង្ឃឹមថា ពួកគេនឹងឱនលំទោន(ចំពោះអល់ឡោះ)។

95. បន្ទាប់មក យើងបានផ្លាស់ប្តូរស្ថានភាពអាក្រក់នោះដោយជំនួសមកវិញនូវភាពល្អប្រសើរ រហូតដល់ពួកគេបានចម្រើនឡើង។ តែពួកគេបែរជានិយាយថា៖ ដីដូនដីតារបស់ពួកយើងក៏ធ្លាប់បានជួបប្រទះនូវជំងឺ និងទុក្ខលំបាក(ដូចគ្នានេះដែរ)។ ពេលនោះ យើងក៏បានដាក់ទណ្ឌកម្មពួកគេភ្លាមៗខណៈដែលពួកគេមិនដឹងខ្លួនឡើយ។

96. ហើយប្រសិនបើអ្នកភូមិស្រុកទាំងនោះមានជំនឿ និងកោតខ្លាច(អល់ឡោះ)នោះ យើងប្រាកដជានឹងបើកឱ្យពួកគេនូវពរជ័យពីលើមេឃនិងផែនដីជាមិនខាន។ ក៏ប៉ុន្តែ ពួកគេបានបដិសេធ។ ដូចនេះ យើងក៏បានដាក់ទណ្ឌកម្មពួកគេដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

97. តើអ្នកភូមិស្រុកទាំងនោះគិតថា ពួកគេអាចមានសុវត្ថិភាព(រួចផុត)ពីទណ្ឌកម្មរបស់យើងដែលអាចមកដល់ពួកគេនៅពេលយប់ ខណៈដែលពួកគេកំពុងគេងលង់លក់នោះឬ?

98. ឬក៏អ្នកភូមិស្រុកទាំងនោះគិតថា ពួកគេអាចគេចផុតពីទណ្ឌកម្មរបស់យើងដែលអាចមកដល់ពួកគេនៅពេលព្រឹក ខណៈដែលពួកគេកំពុងតែធ្វេសប្រហែសនោះឬ?

99. តើអ្នកភូមិស្រុកទាំងនោះគិតថា ពួកគេអាចរួចផុតពីគម្រោងការរបស់អល់ឡោះឬ? ពិតប្រាកដណាស់ គ្មាននរណាម្នាក់គិតថាពួកគេអាចរួចផុតពីគម្រោងការរបស់អល់ឡោះនោះឡើយ លើកលែងតែក្រុមដែលខាតបង់ប៉ុណ្ណោះ។

100. តើមិនទាន់ច្បាស់លាស់ទៀតឬសម្រាប់អ្នកដែលបានគ្រប់គ្រងនៅលើផែនដីបន្ទាប់ពីអ្នកដែលរស់នៅទីនោះបានវិនាសអន្តរាយដែលថា ពិតប្រាកដណាស់ ប្រសិនបើអល់ឡោះទ្រង់មានចេតនា ទ្រង់នឹងដាក់ទណ្ឌកម្មពួកគេចំពោះបាបកម្មរបស់ពួកគេនោះ? ហើយយើងបានបោះត្រាក្លិតទៅលើដួងចិត្តរបស់ពួកគេ។ ដូច្នេះ ពួកគេមិនអាចស្តាប់ឮ(ការដាស់តឿន)ឡើយ។

101. ភូមិស្រុកទាំងនោះ យើងបាននិទានប្រាប់ដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវរឿងរ៉ាវរបស់វា។ ជាការពិតណាស់ បណ្តាអ្នកនាំសាររបស់ពួកគេបានទៅដល់ពួកគេដោយនាំមកនូវភស្តុតាងដ៏ច្បាស់លាស់ជាច្រើន។ ប៉ុន្តែ ពួកគេពុំមានជំនឿចំពោះអ្វីដែលពួកគេធ្លាប់បានបដិសេធពីមុននោះឡើយ។ ក៏ដូច្នោះដែរ អល់ឡោះទ្រង់នឹងបោះត្រាក្លិតទៅលើដួងចិត្តរបស់ពួកដែលគ្មានជំនឿ(នឹងព្យាការីមូហាំម៉ាត់)។

102. ហើយយើង(អល់ឡោះ)មិនបានឃើញថា ភាគច្រើននៃពួកគេជាអ្នកគោរពតាមសន្យា(បទបញ្ជារបស់អល់ឡោះ)នោះឡើយ។ ប៉ុន្តែយើងបានឃើញថា ភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស។

103. ក្រោយមក យើងបានតែងតាំងបន្ទាប់ពីពួកគេ(អ្នកនាំសារទាំងនោះ)នូវព្យាការីមូសាដោយនាំមកនូវសញ្ញាភស្តុតាងជាច្រើនរបស់យើងទៅកាន់ហ្វៀរអោន និងក្រុមរបស់គេ តែពួកគេបែរជាបំពាន(ប្រឆាំង)ចំពោះវាទៅវិញ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបង្កវិនាសកម្មនោះទៅជាយ៉ាងណា?

104. ហើយព្យាការីមូសាបាននិយាយថា៖ ឱហ្វៀរអោន! ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសារម្នាក់មកពីព្រះជាម្ចាស់នៃពិភពទាំងឡាយ។

105. ជាការសក្តិសមសម្រាប់ខ្ញុំនោះ គឺខ្ញុំមិននិយាយអ្វីមួយចំពោះអល់ឡោះក្រៅពីការពិតឡើយ។ ជាការពិតណាស់ ខ្ញុំបាននាំមកកាន់ពួកអ្នកនូវសញ្ញាភស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ សូមអ្នក(ឱហ្វៀរអោន)មេត្តាដោះលែងអម្បូរអ៊ីស្រាអែលឲ្យទៅជាមួយខ្ញុំ។

106. គេ(ហ្វៀរអោន)បានតបថា៖ ប្រសិនបើអ្នកបាននាំសញ្ញាភស្តុតាងណាមួយមកមែននោះ ចូរអ្នកនាំវា(មកបង្ហាញយើង)មក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកទៀងត្រង់មែននោះ។

107. ពេលនោះ ព្យាការីមូសាក៏បានបោះដំបងរបស់គាត់ ស្រាប់តែវាក៏ក្លាយទៅជាសត្វពស់មួយយ៉ាងធំ។

108. ហើយគាត់បានដកដៃរបស់គាត់(ចេញពីហោប៉ៅអាវរបស់គាត់)។ ពេលនោះ វាគឺមានពណ៌សភ្លឺថ្លាសម្រាប់អ្នកទស្សនាទាំងឡាយ។

109. ពួកមេដឹកនាំនៃក្រុមរបស់ហ្វៀនអោនក៏បាននិយាយថា៖ តាមពិត រូបគេនេះពិតជាគ្រូមន្តអាគមដ៏ប៉ិនប្រសព្វ។

110. គេមានបំណងចង់បណ្តេញពួកអ្នកចេញពីទឹកដីរបស់ពួកអ្នក។ (ហើយហ្វៀរអោនក៏និយាយថា៖) តើពួកអ្នកចង់ឱ្យខ្ញុំធ្វើដូចម្តេច(ចំពោះមូសា)?

111. ពួកគេ(ពួកមន្ត្រី)បានតបថា៖ សូមអ្នកពន្យារពេលឱ្យគេ និងបងប្រុសរបស់គេសិនចុះ ហើយសូមអ្នកបញ្ជូនមនុស្សទៅកាន់ទីក្រុងទាំងឡាយដើម្បីប្រមូល(គ្រូមន្តអាគមមក)។

112. ពួកគេនឹងនាំមកនូវគ្រូមន្តអាគមដែលប៉ិនប្រសព្វបំផុតទាំងអស់មកឲ្យអ្នក។

113. ហើយនៅពេលដែលគ្រូមន្តអាគមទាំងនោះបានមកដល់ហ្វៀនអោន ពួកគេបានសួរថា៖ តើពួកយើងមានង្វាន់ដែរឬទេ ប្រសិនបើពួកយើងជាអ្នកឈ្នះ(មូសា)នោះ?

114. គេ(ហ្វៀរអោន)បានតបថា៖ បាទ ពិតជាមាន ហើយពិតណាស់ ពួកអ្នកនឹងស្ថិតក្នុងចំណោមមនុស្សជំនិត(របស់យើង)។

115. ពួកគេ(គ្រូមន្តអាគម)បាននិយាយថា៖ ឱមូសា! អ្នកអាចបោះ(ដំបងរបស់អ្នក)មុន ឬក៏ពួកយើងជាអ្នកបោះមុន។

116. គាត់បានតបថា៖ ចូរពួកអ្នកបោះ(មុន)ចុះ។ នៅពេលដែលពួកគេបោះ ពួកគេបានប្រើមន្តអាគមបំភាន់ភ្នែកមនុស្ស និងបានធ្វើឲ្យមនុស្សមានការភ័យខ្លាច ហើយពួកគេបាននាំមកនូវមន្តអាគមដ៏មហិមា។

117. ហើយយើង(អល់ឡោះ)បានផ្តល់វាហ៊ីទៅកាន់ព្យាការីមូសាថា៖ ចូរអ្នកបោះដំបងរបស់អ្នកចុះ។ រំពេចនោះ(ដំបងក៏បានក្លាយទៅជាសត្វពស់)វាក៏បានលេបអ្វីដែលពួកគេបានបោកប្រាស់(បំភាន់ភ្នែកមនុស្ស)។

118. នៅពេលនោះ ការពិតក៏បានលេចឡើង ហើយអ្វីដែលពួកគេ(គ្រូមន្តអាគម)បានធ្វើវាឡើងក៏ក្លាយជាឥតបានការ។

119. ដូច្នេះ ពួកគេ(គ្រូមន្តអាគម)ក៏ត្រូវទទួលបរាជ័យនៅទីនោះ ហើយពួកគេ(ហ្វៀរអោននិងបក្សពួក)ក៏បានវិលត្រឡប់ទៅវិញដោយភាពអាម៉ាស់បំផុត។

120. ហើយគ្រូមន្តអាគមទាំងនោះ ក៏បានលំឱនកាយស៊ូជោត(ចំពោះអល់ឡោះជាម្ចាស់)។

121. ពួកគេបាននិយាយថា៖ ពួកយើងមានជំនឿនឹងព្រះជាម្ចាស់នៃពិភពទាំងឡាយហើយ

122. ដែលជាព្រះជាម្ចាស់របស់ព្យាការីមូសា និងព្យាការីហារូន។

123. ហ្វៀរអោនបាននិយាយថា៖ តើពួកឯងមានជំនឿលើគេមុននឹងយើងអនុញ្ញាតឲ្យពួកឯងឬ? ពិតប្រាកដណាស់ នេះគឺជាឧបាយកលដែលពួកឯងបានរៀបចំវានៅក្នុងទីក្រុងនេះដើម្បីបណ្តេញអ្នកដែលនៅទីនេះចេញតែប៉ុណ្ណោះ។ ដូច្នេះ ពួកឯងគង់តែនឹងដឹង។

124. យើងពិតជានឹងកាត់ដៃជើងពួកឯងឆ្លាស់គ្នា។ ក្រោយមក យើងពិតជានឹងចងឆ្កាងពួកឯងទាំងអស់គ្នាជាមិនខាន។

125. ពួកគេ(គ្រូមន្តអាគម)បានតបថា៖ ជាការពិតណាស់ ពួកយើងនឹងវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកយើង(តែមួយគត់)។

126. ហើយការដែលអ្នកផ្តន្ទាទោសពួកយើងនោះ គឺគ្មានអ្វីក្រៅពីដោយសារតែពួកយើងមានជំនឿនឹងបណ្តាកស្តុតាងនៃព្រះជាម្ចាស់របស់ពួកយើងនៅពេលដែលវាបានមកដល់ពួកយើងនោះឡើយ។ (បន្ទាប់មក ពួកគេបានបួងសួងថា៖) បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមទ្រង់មេត្តាប្រទានភាពអត់ធ្មត់ដល់យើងខ្ញុំ ព្រមទាំងឱ្យយើងខ្ញុំបានស្លាប់ក្នុងនាមជាអ្នកមូស្លីមផងចុះ។

127. ហើយពួកមេដឹកនាំនៃក្រុមរបស់ហ្វៀរអោនបាននិយាយថា៖ តើអ្នកបណ្តោយឱ្យមូសា និងក្រុមរបស់គេដើរបង្កវិនាសកម្មនៅលើផែនដី ហើយបោះបង់អ្នកនិងព្រះនានារបស់អ្នកឬ? គេបានតបថា៖ (ទេ!) យើងពិតជានឹងសម្លាប់កូនប្រុសទាំងឡាយរបស់ពួកគេ ហើយទុកជីវិតកូនស្រីទាំងឡាយរបស់ពួកគេ។ ជាការពិតណាស់ ពួកយើងគឺជាអ្នកដែលមានអំណាចខ្លាំងក្លាលើពួកគេ។

128. ព្យាការីមូសាបាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ ចូរពួកអ្នក(បួងសួង)សុំជំនួយពីអល់ឡោះជាម្ចាស់ និងត្រូវមានភាពអត់ធ្មត់។ ជាការពិតណាស់ ផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)ដោយទ្រង់ប្រទានវាដល់ជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់។ ហើយលទ្ធផលចុងក្រោយ(ដ៏ល្អប្រសើរ) គឺសម្រាប់បណ្តាអ្នកដែលកោតខ្លាច។

129. ពួកគេបានតបថា៖ ពួកយើងត្រូវបានគេធ្វើបាបទាំងមុន និងក្រោយពេលដែលអ្នកមកដល់ពួកយើងថែមទៀត។ គាត់បាននិយាយថា៖ សង្ឃឹមថាព្រះជាម្ចាស់របស់ពួកអ្នកនឹងបំផ្លាញសត្រូវរបស់ពួកអ្នក ហើយនិងឱ្យពួកអ្នកជាអ្នកស្នងតំណែងគ្រប់គ្រងនៅលើផែនដី។ ហើយទ្រង់នឹងរង់ចាំមើល ថាតើពួកអ្នកនឹងធ្វើដូចម្តេច(ដឹងគុណ ឬមិលគុណ)។

130. ហើយជាការពិតណាស់ យើងបានដាក់ទណ្ឌកម្មទៅលើក្រុមហ្វៀរអោនដោយឱ្យពួកគេទទួលរងនូវគ្រោះឡើក្យ និងកង្វះខាតផលដំណាំ។ សង្ឃឹមថា ពួកគេនឹងនឹករលឹក។

131. ហើយនៅពេលដែលប្រការល្អបានមកដល់ពួកគេ ពួកគេនិយាយថា៖ ពួកយើងសក្តិសមនឹងទទួលបានរបស់ទាំងនេះ។ តែប្រសិនបើពួកគេជួបប្រទះនូវប្រការអាក្រក់ ពួកគេបែរជាមានប្រផ្នូលអាក្រក់ទៅលើព្យាការីមូសា និងអ្នកដែលនៅជាមួយគាត់(អម្ប្រាអ៊ីស្រាអែល)ទៅវិញ។ តើពុំមែនទេឬ តាមពិត អ្វីទាំងអស់ដែលកើតឡើងចំពោះពួកគេ គឺជាការកំណត់ពីអល់ឡោះជាម្ចាស់(ទាំងអស់)។ ក៏ប៉ុន្តែភាគច្រើននៃពួកគេ គឺមិនដឹងឡើយ ។

132. ហើយពួកគេ(ក្រុមរបស់ហ្វៀរអោន)បាននិយាយថា៖ ទោះបីជាអ្នកនាំមកនូវសញ្ញាកស្តុតាងណាមួយមកកាន់ពួកយើងដើម្បីបង្វែរពួកយើង(ចេញពីសាសនាពួកយើង)ក៏ដោយ ក៏ពួកយើងមិនជឿចំពោះអ្នកនោះដែរ។

133. ដូច្នេះ យើងក៏បានបញ្ជូនទៅកាន់ពួកគេនូវទឹកជំនន់ សត្វកណ្តុប សត្វចៃ សត្វកង្កែប និងឈាមជាសញ្ញាកស្តុតាងដាច់ដោយឡែកពីគ្នា។ ប៉ុន្តែពួកគេនៅតែក្អេងក្អាង(មិនមានជំនឿ) ហើយពួកគេ គឺជាក្រុមដែលប្រព្រឹត្តអាក្រក់។

134. ហើយនៅពេលដែលទណ្ឌកម្មទាំងនោះធ្លាក់ទៅលើពួកគេ ពួកគេក៏និយាយថា៖ ឱមូសា! សូមអ្នកបួងសួងសុំពីព្រះជាម្ចាស់របស់អ្នកនូវអ្វីដែលទ្រង់បានសន្យានឹងអ្នកឲ្យពួកយើងផង។ ប្រសិនបើអ្នកអាចដកយកទណ្ឌកម្មចេញពីពួកយើង នោះពួកយើងប្រាកដជាមានជំនឿចំពោះអ្នក ហើយពួកយើងប្រាកដជានឹងដោះលែងអម្ប្រាអ៊ីស្រាអែលឱ្យទៅជាមួយអ្នកជាមិនខាន។

135. ប៉ុន្តែនៅពេលដែលយើង(អល់ឡោះ)បានដកយកទណ្ឌកម្មចេញពីពួកគេក្នុងអំឡុងពេលរំលងកំណត់មួយដែលកំណត់ថាទណ្ឌកម្មធ្លាក់លើពួកគេ ពួកគេបែរជាក្បត់នូវការសន្យា(របស់ខ្លួន)ទៅវិញ។

136. ដូច្នេះ យើងបានផ្តន្ទាទោសពួកគេដោយយើងបានពន្លិចពួកគេទៅក្នុងទឹកសមុទ្រ ដោយសារតែពួកគេបានបដិសេធចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើង ហើយពួកគេធ្លាប់ជាពួកដែលព្រងើយកន្តើយចំពោះវា។

137. ហើយយើងបានផ្តល់ឱ្យអ្នកដែលត្រូវគេជិះជាន់ធ្វើបាប (អម្បូរអ៊ីស្រាអែល) នូវមេគកនៅទិសខាងកើតនិងទិសខាងលិចនៃផែនដីដែលយើងបានផ្តល់ពរជ័យចំពោះវា។ ហើយបន្ទូលនៃព្រះជាម្ចាស់របស់អ្នកទៅចំពោះអម្បូរអ៊ីស្រាអែលបានបញ្ចប់យ៉ាងពេញលេញដោយសារតែពួកគេបានអត់ធ្មត់។ ហើយយើងបានកម្ទេចនូវអ្វីដែលហ្វៀរអោន និងក្រុមរបស់គេបានធ្វើ ហើយនិងអ្វីដែលពួកគេបានកសាង។

138. ហើយយើងបានចម្លងអម្បូរអ៊ីស្រាអែលឱ្យឆ្លងផុតសមុទ្រ។ ពេលនោះ ពួកគេបានឆ្លងកាត់ក្រុមមួយដែលកំពុងតែគោរពសក្ការៈចំពោះរូបបដិមារបស់ពួកគេ។ ពួកគេបាននិយាយថា៖ ឱមូសា! សូមអ្នកបង្កើតរូបបដិមាមួយឱ្យពួកយើង (គោរពសក្ការៈ) ដូចដែលពួកទាំងនោះមានរូបបដិមា (សម្រាប់គោរពសក្ការៈ) ផង។ គាត់បានតបថា៖ ពិតប្រាកដណាស់ ពួកអ្នកគឺជាក្រុមដែលល្ងង់ខ្លៅ។

139. ពិតប្រាកដណាស់ ពួកទាំងនោះនឹងត្រូវគេបំផ្លាញដោយសារតែអ្វីដែលពួកគេកំពុងតែប្រព្រឹត្ត។ ហើយអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តនោះ គឺក្លាយជាឥតបានការ។

140. គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! តើឱ្យខ្ញុំស្វែងរកព្រះផ្សេងក្រៅពីអល់ឡោះឱ្យពួកអ្នកគោរពសក្ការៈយ៉ាងដូចម្តេច ខណៈដែលទ្រង់បានលើកតម្កើងពួកអ្នកជាងគេលើពិភពលោកនោះ?

141. ហើយ (ចូរពួកអ្នកនឹកឃើញ) នៅពេលដែលយើងបានសង្គ្រោះពួកអ្នកពីបក្សពួកហ្វៀរអោន ខណៈដែលពួកគេបានឱ្យពួកអ្នកភ្លក់នូវទារុណកម្មយ៉ាងព្រៃផ្សៃបំផុត ដោយពួកគេសម្លាប់កូនប្រុសទាំងឡាយរបស់ពួកអ្នក ហើយទុកជីវិតកូនស្រីរបស់ពួកអ្នក។ ហើយនៅក្នុងរឿងនោះ គឺជាការសាកល្បងដ៏ធំធេងបំផុតពីព្រះជាម្ចាស់របស់ពួកអ្នក។

142. យើងបានសន្យានឹងព្យាការីមូសារយៈពេលសាមសិបយប់ និងបានបន្ថែមដប់យប់ទៀតដែលធ្វើឱ្យគ្រប់ចំនួនសែសិបយប់នៃការជួបសន្ទនានឹងព្រះជាម្ចាស់របស់គាត់។ ហើយព្យាការីមូសាបាននិយាយទៅកាន់បងប្រុសរបស់គាត់ ព្យាការីហារូន ថា៖ ចូរអ្នកធ្វើជាមេដឹកនាំក្រុមរបស់ខ្ញុំជំនួសខ្ញុំសិនចុះ ហើយត្រូវកែលម្អ (កិច្ចការរបស់ពួកគេ) និងមិនត្រូវដើរតាមមាគ៌ារបស់ពួកដែលបង្កវិនាសកម្មឡើយ។

143. ហើយនៅពេលដែលព្យាការីមូសាបានមកដល់ដើម្បីជួបសន្ទនាជាមួយយើង (អល់ឡោះ) ហើយព្រះជាម្ចាស់របស់គាត់បានមានបន្ទូលជាមួយនឹងគាត់ (ពេលនោះ) ព្យាការីមូសាក៏និយាយថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាបង្ហាញឱ្យខ្ញុំអាចមើលទៅកាន់ព្រះអង្គផង។ ទ្រង់បានតបថា៖ អ្នកមិនអាចមើលយើងឃើញនោះឡើយ។ ប៉ុន្តែ ចូរអ្នកមើលទៅកាន់ភ្នំនោះចុះ។ ប្រសិនបើវានៅនឹងថ្កល់នៅកន្លែងរបស់វាដដែល នោះអ្នកនឹងអាចឃើញយើងជាមិនខាន។ នៅពេលដែលព្រះជាម្ចាស់របស់គាត់បានបង្ហាញខ្លួនទៅកាន់ភ្នំនោះ ទ្រង់បានធ្វើឱ្យភ្នំនោះរាបស្មើ (ក្លាយជាធូលី) ហើយព្យាការីមូសាក៏បានដួលសន្លប់។ នៅពេលដែលគាត់ដឹងខ្លួនវិញ គាត់ក៏ពោលថា៖ ព្រះអង្គមហាស្អាតស្អំ។ ខ្ញុំសូមសារភាពកំហុសចំពោះព្រះអង្គ ហើយខ្ញុំគឺជាអ្នកដែលមានជំនឿមុនគេបង្អស់។

144. ទ្រង់បានមានបន្ទូលថា៖ ឱមូសា! ពិតប្រាកដណាស់ យើងបានជ្រើសរើសអ្នកឱ្យមានភាពខ្ពង់ខ្ពស់លើសមនុស្សទាំងឡាយតាមរយៈសាររបស់យើង និងតាមរយៈបន្ទូលរបស់យើង (ដោយផ្ទាល់ទៅកាន់អ្នក)។ ដូច្នេះ ចូរអ្នកទទួលយកនូវអ្វីដែលយើងបានប្រទានដល់អ្នក ហើយអ្នកត្រូវស្ថិតក្នុងចំណោមអ្នកដែលដឹងគុណទាំងឡាយ។

145. ហើយយើងបានកត់ត្រាឱ្យគាត់(ព្យាការីមូសា)លើបន្ទះក្តារនូវរាល់អ្វីៗទាំងអស់ ជាការទូន្មាន និងជាការបកស្រាយបំភ្លឺនូវរាល់កិច្ចការទាំងឡាយ។ ហេតុនេះ ចូរអ្នក(ឱព្យាការីមូសា)ទទួលយកវា(គម្ពីរតោរ៉ាត)ដោយមុឺងម៉ាត់។ ហើយចូរអ្នកបង្គាប់ក្រុមរបស់អ្នកឱ្យពួកគេទទួលយកដោយប្រសើរបំផុត។ យើងនឹងបង្ហាញពួកអ្នកពីលទ្ធផលចុងក្រោយរបស់ពួកដែលប្រព្រឹត្តល្មើស។

146. យើងនឹងបង្វែរពួកដែលក្រអឺតក្រទមនៅលើផែនដីដោយមិនត្រឹមត្រូវនោះចេញពីការឈ្វេងយល់នូវបណ្តាសញ្ញាកស្តុតាងរបស់យើង។ ហើយបើទោះបីជាពួកគេបានឃើញរាល់សញ្ញាកស្តុតាងទាំងអស់ក៏ដោយ ក៏ពួកគេមិនមានជំនឿចំពោះវាដែរ។ ប្រសិនបើពួកគេបានឃើញមាគ៌ាដែលត្រឹមត្រូវ គឺពួកគេមិនយកវាធ្វើជាមាគ៌ាឡើយ។ តែប្រសិនបើពួកគេឃើញមាគ៌ាដែលមិនត្រឹមត្រូវវិញ គឺពួកគេយកវាធ្វើជាមាគ៌ា(ដើរតាមស្តាម)។ នោះគឺដោយសារតែពួកគេបានបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង ហើយពួកគេព្រងើយកន្តើយចំពោះវា។

147. ហើយពួកដែលបដិសេធនឹងបណ្តាកស្តុតាងទាំងឡាយរបស់យើង និងការជួប(អល់ឡោះ)នៅថ្ងៃបរលោកនោះ ទង្វើទាំងឡាយរបស់ពួកគេនឹងត្រូវចាត់ទុកជាអសារបង់។ តើគេមិនតបស្នងដល់ពួកគេក្រៅតែពីអ្វីដែលពួកគេបានប្រព្រឹត្តទេឬ?

148. ហើយក្រោយពីគាត់(ចាកចេញទៅកាន់ការសន្ទនាជាមួយនឹងព្រះជាម្ចាស់របស់គាត់នោះ) ក្រុមរបស់ព្យាការីមូសាបានយកគ្រឿងអលង្ការរបស់ពួកគេធ្វើជារូបសំណាក់កូនគោដែលគ្មានវិញ្ញាណ តែមានសំឡេង។ តើពួកគេមិនឃើញទេឬថាជាការពិតណាស់ រូបសំណាក់កូនគោនោះមិនអាចនិយាយនឹងពួកគេ ហើយក៏មិនអាចចង្អុលបង្ហាញពួកគេទៅកាន់មាគ៌ាត្រឹមត្រូវណាមួយនោះដែរ។ ពួកគេបានយកវា(ធ្វើជាព្រះ)ខណៈដែលពួកគេគឺជាពួកដែលបំពាន។

149. ហើយនៅពេលដែលពួកគេមានការស្តាយក្រោយ(ចំពោះទង្វើដែលខ្លួនបានធ្វើ)ហើយពួកគេបានដឹងថា ជាការពិតណាស់ពួកគេបានវង្វេង(ចេញពីមាគ៌ាត្រឹមត្រូវ)ពួកគេក៏បានពោលថា៖ ប្រសិនបើព្រះជាម្ចាស់របស់ពួកយើងមិនអាណិតស្រលាញ់ពួកយើង ហើយអភ័យទោសដល់ពួកយើងទេនោះ ពួកយើងប្រាកដជានឹងស្ថិតក្នុងចំណោមពួកដែលខាតបង់ជាមិនខាន។

150. ហើយនៅពេលដែលព្យាការីមូសាបានត្រឡប់ទៅកាន់ក្រុមរបស់គាត់វិញ រូបគាត់ពោរពេញទៅដោយការខឹងសម្បា និងទុក្ខព្រួយ(ចំពោះពួកគេ)។ គាត់បាននិយាយថា៖ ការដែលពួកអ្នកធ្វើផ្ទុយនឹងបទបញ្ជារបស់ខ្ញុំបន្ទាប់ពីខ្ញុំអវត្តមាននោះ គឺពិតជាអាក្រក់បំផុត។ តើពួកអ្នកប្រញាប់ប្រញាល់មុននឹងបទបញ្ជាព្រះជាម្ចាស់របស់ពួកអ្នកមកដល់ពួកអ្នកឬ? ហើយគាត់បានគ្រវែងផែនចារឹក(គម្ពីរតោរ៉ាត)នោះ ហើយចាប់ទាញសក់ក្បាលបងប្រុសរបស់គាត់មករកគាត់។ ព្យាការីហារូនបាននិយាយថា៖ ឱប្អូនប្រុស! ពិតប្រាកដណាស់ ក្រុមនេះបានមើលស្រាលចំពោះខ្ញុំ ហើយពួកគេស្ទើរតែសម្លាប់ខ្ញុំទៅទៀត(នៅពេលដែលខ្ញុំហាមឃាត់ពួកគេ)។ ដូចនេះ ចូរអ្នកកុំស្តីបន្ទោសខ្ញុំដែលជាហេតុធ្វើឱ្យសត្រូវសប្បាយរីករាយ និងកុំចាត់ទុកខ្ញុំស្ថិតក្នុងចំណោមក្រុមដែលបំពានឱ្យសោះ។

151. ព្យាការីមូសាបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាអភ័យទោសដល់ខ្ញុំនិងបងប្រុសរបស់ខ្ញុំ និងបញ្ចូលយើងខ្ញុំឱ្យស្ថិតក្នុងក្តីមេត្តាករុណារបស់ព្រះអង្គផងចុះ។ ហើយព្រះអង្គ គឺជាអ្នកដែលមហាអាណិតស្រលាញ់ជាងគេបំផុត។

152. ជាការពិតណាស់ ពួកដែលបានយករូបសំណាក់កូនគោ(មកគោរពសក្ការៈ)នោះ ពួកគេនឹងទទួលនូវការខឹងសម្បាពីព្រះជាម្ចាស់របស់ពួកគេ ហើយនិងទទួលនូវភាពអាប់ឱនៅក្នុងឆាកជីវិតលោកិយនេះ។ ហើយក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះពួកដែលប្រឌិតកុហក(ទៅលើអល់ឡោះ)។

153. ហើយបណ្ដាអ្នកដែលបានប្រព្រឹត្តនូវទង្វើអាក្រក់ ក្រោយមក ពួកគេបានសារភាពកំហុសបន្ទាប់ពីនោះ ព្រមទាំងមានជំនឿវិញ ពិតប្រាកណាស់ ក្រោយពី(ការសារភាពកំហុសរបស់ពួកគេ)នោះ ព្រះជាម្ចាស់របស់អ្នក គឺមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

154. ហើយនៅពេលដែលកំហឹងបានរសាយចេញពីព្យាការីមូសានោះ គាត់ក៏បានយកផែនចារឹកនោះមកវិញ។ ហើយនៅក្នុងផែនចារឹកនោះ គឺពោរពេញដោយការចង្អុលបង្ហាញ និងក្តីមេត្តាករុណាចំពោះអ្នកដែលកោតខ្លាចចំពោះព្រះជាម្ចាស់របស់ពួកគេ។

155. ហើយព្យាការីមូសាបានជ្រើសរើសបុរសចំនួនចិតសិបនាក់ពីក្រុមរបស់គាត់មកកាន់កន្លែងកំណត់របស់យើង។ នៅពេលដែលការរញ្ជួយដីបានឆក់យកជីវិតរបស់ពួកគេ(ព្រោះតែពួកគេសុំចង់ឃើញអល់ឡោះផ្ទាល់នឹងភ្នែក) ព្យាការីមូសាក៏បានពោលថា៖ បពិត្រព្រះជាម្ចាស់! ប្រសិនបើព្រះអង្គមានចេតនា ព្រះអង្គនឹងបំផ្លាញពួកគេ រួមទាំងរូបខ្ញុំមុនពេលពួកគេមកដល់ជាមិនខាន។ តើព្រះអង្គបំផ្លាញពួកយើង ដោយសារតែអ្វីដែលពួកល្ងង់ខ្លៅក្នុងចំណោមពួកយើងបានប្រព្រឹត្តឬ? ជាការពិតណាស់ វាគ្មានអ្វីក្រៅតែពីជាការសាកល្បងរបស់ព្រះអង្គប៉ុណ្ណោះដែលព្រះអង្គធ្វើឱ្យវង្វេងដោយសារវា ចំពោះជនណាដែលព្រះអង្គមានចេតនា ហើយចង្អុលបង្ហាញចំពោះជនណាដែលព្រះអង្គមានចេតនា។ ព្រះអង្គគឺជាអ្នកគាំពាររបស់យើងខ្ញុំ។ ដូចនេះ សូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំ ព្រមទាំងអាណិតស្រលាញ់ចំពោះយើងខ្ញុំផង។ ហើយព្រះអង្គគឺជាអ្នកដែលអភ័យទោសដ៏ប្រសើរបំផុត។

156. ហើយសូមព្រះអង្គមេត្តាកត់ត្រាដល់យើងខ្ញុំនូវទង្វើកុសលទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក។ ពិតប្រាកដណាស់ យើងខ្ញុំសូមសារភាពកំហុសទៅកាន់ព្រះអង្គ។ ទ្រង់បានមានបន្ទូលថា៖ ទណ្ឌកម្មរបស់យើងគឺនឹងធ្លាក់ទៅលើជនណាដែលយើងមានចេតនា។ ចំណែកឯក្តីមេត្តាករុណារបស់យើងវិញ គឺគ្របដណ្ដប់លើអ្វីៗទាំងអស់។ ហើយយើងនឹងកំណត់វា(ក្តីមេត្តាករុណារបស់យើង)សម្រាប់បណ្ដាអ្នកដែលកោតខ្លាច ហើយពួកគេបរិច្ចាគហ្សាកាត់ ព្រមទាំងបណ្ដាអ្នកដែលមានជំនឿនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង។

157. គឺបណ្ដាអ្នកដែលដើរតាមអ្នកនាំសារ(មូហាំម៉ាត់)ជាព្យាការីម្នាក់ដែលជាអនក្ខរជន ដែលពួកគេ(ពួកអះលីគីតាប)បានប្រទះឃើញ(លក្ខណៈសម្បត្តិរបស់)គាត់ត្រូវបានកត់ត្រានៅក្នុងគម្ពីរតាវ៉ាត និងគម្ពីរអ៊ិញជីលដែលនៅជាមួយពួកគេ។ គាត់បង្គាប់ប្រើពួកគេឱ្យសាងអំពើល្អ និងហាមឃាត់ពួកគេពីអំពើអាក្រក់ ហើយអនុញ្ញាតឱ្យពួកគេនូវចំណីអាហារដែលល្អៗ និងហាមឃាត់ពួកគេនូវចំណីអាហារដែលអាក្រក់ ព្រមទាំងដកចេញពីពួកគេនូវបន្ទុកដ៏លំបាក(កាតព្វកិច្ច)ទាំងឡាយរបស់ពួកគេដែលគេធ្លាប់បានដាក់ទៅលើពួកគេ(កាលពីមុន)។ ដូចនេះ បណ្ដាអ្នកដែលមានជំនឿចំពោះគាត់ លើកតម្កើងគាត់ និងជួយដល់គាត់ ព្រមទាំងអនុវត្តតាមគម្ពីរគួរអានដែលគេបានបញ្ចុះមកឲ្យគាត់ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលជោគជ័យ។

158. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱមនុស្សលោកទាំងឡាយ! ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នកទាំងអស់គ្នា ដែលអំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ជាអ្នកដែលផ្តល់ជីវិត និងជាអ្នកដកយកជីវិតនោះឡើយ។ ដូច្នេះ ចូរពួកអ្នកមានជំនឿចំពោះអល់ឡោះ និងមានជំនឿចំពោះអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ជាព្យាការីម្នាក់ដែលជាអនក្ខរជនដែលគាត់មានជំនឿលើអល់ឡោះ និងចំពោះបន្ទូលរបស់ទ្រង់។ ហើយចូរពួកអ្នកប្រតិបត្តិតាមគាត់ចុះ សង្ឃឹមថា ពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញ។

159. ហើយក្នុងចំណោមក្រុមរបស់ព្យាការីមូសា គឺមានក្រុមមួយដែលស្ថិតនៅលើមាគ៌ាត្រឹមត្រូវដោយពួកគេចង្អុលបង្ហាញអ្នកដទៃទៅកាន់ការពិត និងកាត់សេចក្តីដោយយុត្តិធម៌។

160. ហើយយើងបានបំបែកពួកគេ(អម្បូរអ៊ីស្រាអែល)ទៅជាដប់ពីរកុលសម្ព័ន្ធ។ ហើយយើងបានផ្តល់វាហ៊ីទៅកាន់ព្យាការីមូសា នៅពេលដែលក្រុមរបស់គាត់បានស្នើសុំឱ្យផ្តល់ទឹកដល់ពួកគេថា៖ ចូរអ្នកវាយថ្មនឹងដំបងរបស់អ្នកចុះ។ ពេលនោះ វាក៏បានបាញ់ទឹកចេញជាដប់ពីរន្ធ(ទៅតាមចំនួនកុលសម្ព័ន្ធទាំងដប់ពីរ)។ ពិតណាស់ រាល់កុលសម្ព័ន្ធនីមួយៗ គឺដឹងពីកន្លែងផឹកទឹករបស់ពួកគេរៀងៗខ្លួន។ ហើយយើងបានធ្វើឱ្យមានពពកបាំងជាម្លប់ពីលើពួកគេ។ ហើយយើងបានបញ្ចុះមកឱ្យពួកគេនូវអាល់ម៉ាន់(កេសដ្ឋៈដែលមានរសជាតិផ្អែមដូចទឹកឃ្មុំ) និងអាស់សាល់វ៉ា(បក្សីមួយប្រភេទដែលស្រដៀងនឹងសត្វក្រួច)។ (យើងបានមានបន្ទូលថា៖) ចូរពួកអ្នកទទួលទាននូវចំណីអាហារល្អៗដែលយើងបានប្រទានឱ្យពួកអ្នកចុះ។ ហើយពួកគេមិនបានបំពានលើយើងឡើយ ក៏ប៉ុន្តែ ពួកគេបំពានទៅលើខ្លួនឯងទៅវិញទេ។

161. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលគេ(អល់ឡោះ)បានមានបន្ទូលទៅកាន់ពួកគេ(អម្បូរអ៊ីស្រាអែល)ថា៖ ចូរពួកអ្នកចូលទៅកាន់ទីក្រុងនេះ(ក្រុងយេរូសាឡឹម) ហើយចូរពួកអ្នកទទួលទាននូវផែនានុផលរបស់វាតាមដែលពួកអ្នកចង់ ហើយពួកអ្នកត្រូវពោលថា៖ "សូមទ្រង់មេត្តាអភ័យទោសដល់យើងខ្ញុំផង"។ ហើយចូរពួកអ្នកចូលតាមទ្វារទាំងឡាយ(របស់វា)ដោយឱនលំទោនចុះ នោះយើងនឹងអភ័យទោសដល់ពួកអ្នកចំពោះកំហុសឆ្គងទាំងឡាយរបស់ពួកអ្នក។ ហើយយើងនឹងបន្ថែម(ប្រការល្អ)ដល់បណ្តាអ្នកដែលសាងអំពើល្អ។

162. តែពួកដែលបំពានវិញបែរជាផ្លាស់ប្តូរពាក្យពេចន៍ខុសពីពាក្យពេចន៍ដែលគេបាននិយាយទៅកាន់ពួកគេ។ ដូចនេះ យើងក៏បានបញ្ចុះទណ្ឌកម្មពីលើមេឃទៅលើពួកគេដោយសារតែអ្វីដែលពួកគេបានបំពាន។

163. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកគេ(ពួកយូដា)អំពីភូមិស្រុកមួយដែលស្ថិតនៅជិតសមុទ្រ នៅពេលដែលពួកគេបានបំពាន(បម្រាមដោយចេញទៅនេសាទ)នៅថ្ងៃសៅរ៍ ខណៈដែលត្រីផុសចេញមកកាន់ពួកគេយ៉ាងច្រើននៅក្នុងថ្ងៃសៅរ៍។ តែនៅក្នុងថ្ងៃផ្សេងវិញ ត្រីទាំងនោះមិនបានផុសចេញមកកាន់ពួកគេនោះទេ។ ក៏ដូច្នោះដែរ យើងបានសាកល្បងពួកគេដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តល្មើស។

164. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលក្រុមមួយក្នុងចំណោមពួកគេបាននិយាយថា៖ ហេតុអ្វីបានជាពួកអ្នកណែនាំក្រុមដែលអល់ឡោះនឹងបំផ្លាញពួកគេ ឬដាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត? ពួកគេ(អ្នកដែលណែនាំ)បាននិយាយថា៖ (ពួកយើងណែនាំដល់ពួកគេ)គឺដើម្បីជាហេតុផលសំអាងមួយចំពោះព្រះជាម្ចាស់របស់ពួកអ្នក ហើយនិងសង្ឃឹមថា ពួកគេនឹងកោតខ្លាច។

165. ហើយនៅពេលដែលពួកគេ(ពួកប្រឆាំង)បានភ្លេចនូវអ្វីដែលគេណែនាំពួកគេ(បញ្ឈប់ការចេញទៅនេសាទនៅថ្ងៃសៅរ៍)នោះ យើងក៏រំដោះតែបណ្តាអ្នកដែលបានហាមឃាត់គ្នាពីអំពើអាក្រក់ប៉ុណ្ណោះ(ឱ្យរួចផុតពីទណ្ឌកម្ម)។ ហើយយើងបានដាក់ទណ្ឌកម្មយ៉ាងខ្លាំងក្លាចំពោះពួកដែលបំពានដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តល្មើស។

166. ហើយនៅពេលដែលពួកគេបានបំពានព្រំដែននៃអ្វីដែលគេបានហាមឃាត់ពួកគេនោះ យើងក៏បានមានបន្ទូលទៅកាន់ពួកគេថា៖ ចូរពួកឯងកើតទៅជាសត្វស្វាដ៏អាប់ឱនចុះ។

167. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានប្រកាសនូវដំណឹងមួយថា ជាការពិតណាស់ ទ្រង់ពិតជានឹងបញ្ជូនទៅកាន់ពួកគេ(ពួកយូដា)នូវអ្នកដែលធ្វើឱ្យពួកគេអាប់ឱន ជាទណ្ឌកម្មដ៏អាក្រក់(ចំពោះពួកគេ)រហូតដល់ថ្ងៃបរលោក។ ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក គឺជាអ្នកដាក់ទណ្ឌកម្មយ៉ាងរហ័សបំផុត ហើយពិតប្រាកដណាស់ ទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

168. ហើយយើងបានបំបែកពួកគេនៅលើផែនដីនេះជាក្រុមៗ។ ក្នុងចំណោមពួកគេ គឺមានអ្នកដែលសាងទង្វើកុសល ហើយក្នុងចំណោមពួកគេផងដែរ គឺមានអ្នកដែលធ្វើផ្សេងពីនេះ។ ហើយយើងបានសាកល្បងពួកគេនូវរឿងល្អ និងរឿងអាក្រក់ជាច្រើន សង្ឃឹមថាពួកគេនឹងវិលត្រឡប់(បញ្ឈប់ពីអំពើល្មើសនានា)។

169. ហើយក្រោយពីពួកទាំងនោះ(កន្លងផុត)ទៅ មានអ្នកជំនាន់ក្រោយបានមកស្នងមរតកគម្ពីរ(តាវ៉ាត)ពីពួកគេ) ដោយអ្នកទាំងនោះបានយកគម្ពីរទៅប្តូរយកទ្រព្យសម្បត្តិដ៏តិចតួច។ ហើយពួកគេនិយាយ(ស្រមៃ)ថា៖ គេនឹងអភ័យទោសដល់ពួកយើង។ ហើយប្រសិនបើទ្រព្យសម្បត្តិដ៏តិចតួចនោះបានមកដល់ពួកគេ ពួកគេនឹងទទួលយកវាម្តងហើយម្តងទៀត។ តើគេមិនបានដាក់កិច្ចសន្យាយ៉ាងមឺងម៉ាត់ទៅលើពួកគេក្នុងគម្ពីរទេឬដែលថា ពួកគេមិនត្រូវនិយាយអ្វីពាក់ព័ន្ធនឹងអល់ឡោះក្រៅពីការពិតនោះឡើយ ខណៈដែលពួកគេបានរៀនសូត្រនូវអ្វីដែលមាននៅក្នុងគម្ពីរហើយនោះ។ ហើយលំនៅឋាននៅថ្ងៃបរលោក គឺល្អប្រសើរបំផុតសម្រាប់បណ្តាអ្នកដែលកោតខ្លាច។ តើពួកអ្នកគ្មានវិចារណញ្ញាណទេឬ?

170. ហើយបណ្តាអ្នកដែលប្រកាន់ខ្ជាប់តាមគម្ពីរ(តាវ៉ាត)និងបានប្រតិបត្តិសឡាតនោះ ជាការពិតណាស់ យើងមិនធ្វើឱ្យបាត់បង់នូវផលបុណ្យរបស់អ្នកដែលសាងទង្វើកុសលឡើយ។

171. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលយើងបានលើកភ្នំ(តួរ)ជាក់ពីលើពួកគេ(អម្ប្រាអ៊ីស្រាអែល) ប្រៀបដូចជាម្លប់(ដែលគ្របពីលើពួកគេ)ហើយពួកគេនឹកស្មានថា ពិតណាស់វានឹងធ្លាក់សង្កត់លើពួកគេ។ (អល់ឡោះបានមានបន្ទូលទៅកាន់ពួកគេថា៖) ចូរពួកអ្នកទទួលយកនូវអ្វីដែលយើងបានប្រទានឲ្យពួកអ្នកឱ្យបានខ្ជាប់ខ្ជួន។ ហើយចូរពួកអ្នកចងចាំនូវអ្វី(ក្បួនច្បាប់)ដែលមាននៅក្នុងវា សង្ឃឹមថាពួកអ្នកនឹងកោតខ្លាច។

172. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានបញ្ចេញពីឆ្អឹងខ្នងរបស់កូនចៅអាដាំនូវពូជពង្សរបស់ពួកគេ ហើយទ្រង់បានឱ្យពួកគេទទួលស្គាល់លើខ្លួនឯង(នូវភាពជាព្រះជាម្ចាស់របស់ទ្រង់)។ (ទ្រង់បានមានបន្ទូលថា៖) តើយើងមិនមែនជាព្រះជាម្ចាស់របស់ពួកអ្នកទេឬ? ពួកគេបានឆ្លើយថា៖ ប្រាកដហើយ ពួកយើងទទួលស្គាល់ហើយ(ថាទ្រង់ជាព្រះជាម្ចាស់របស់ពួកយើង)។ (ទ្រង់បានមានបន្ទូលទៀតថា៖ ការធ្វើដូចនេះ) គឺដើម្បីកុំឱ្យនៅថ្ងៃបរលោកពួកអ្នកនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងមិនធ្លាប់ដឹងឮរឿងនេះឡើយ។

173. ឬក៏ពួកអ្នកនិយាយថា ពិតប្រាកដណាស់ ជីដូនជីតារបស់ពួកយើងបានធ្វើស៊ីរិក(នឹងអល់ឡោះ) ហើយពួកយើងគ្រាន់តែជាពូជពង្សជំនាន់ក្រោយពួកគេប៉ុណ្ណោះ។ តើព្រះអង្គនឹងបំផ្លាញពួកយើងដោយសារតែទង្វើរបស់ពួកដែលប្រព្រឹត្តខុស(ជំនាន់មុន)ឬ?

174. ហើយក៏ដូច្នោះដែរ យើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងទាំងឡាយ សង្ឃឹមថាពួកគេនឹងវិលត្រឡប់(ងាកចេញពីទង្វើស៊ីរិក)។

175. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រឱ្យពួកគេ(អម្ប្រាអ៊ីស្រាអែល)ស្តាប់ចុះនូវរឿងរ៉ាវរបស់បុរសម្នាក់ដែលយើងបានផ្តល់ឱ្យគេនូវសញ្ញាកស្តុតាងរបស់យើង ក៏ប៉ុន្តែគេបែរជាបោះបង់វាចោលទៅវិញ។ ពេលនោះ ស្មៃតនក៏បានអូសទាញរូបគេឲ្យដើរតាមវា។ ដូច្នេះ រូបគេក៏ស្ថិតចំណោមពួកដែលវង្វេង។

176. ហើយប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងលើកតម្កើងរូបគេតាមរយៈវា(សញ្ញាកស្តុតាងទាំងនោះ)ជាមិនខាន។ ក៏ប៉ុន្តែ រូបគេទោរទន់ទៅរកចំណង់តណ្ហាលោកិយ ព្រមទាំងដើរតាមទំនើងចិត្តរបស់ខ្លួនឯង។ ជាការពិតណាស់ បុគ្គលបែបនេះ គឺប្រៀបដូចជាសត្វឆ្កែមួយក្បាលដូច្នោះដែរ ដែលទោះបីជាអ្នកដេញវា ឬក៏លែងវាចោលក៏វានៅតែលៀនអណ្តាត។ នោះហើយគឺជាការប្រៀបធៀបចំពោះក្រុមដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)និទានរឿងរ៉ាវទាំងនោះប្រាប់ពួកគេចុះ សង្ឃឹមថា ពួកគេចេះគិតពិចារណា។

177. ការប្រៀបធៀបក្រុមដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើងនោះ គឺអាក្រក់បំផុត។ ហើយពួកគេគឺជាពួកដែលធ្លាប់បានបំពានលើខ្លួនឯង។

178. ជនណាហើយដែលអល់ឡោះទ្រង់ចង្អុលបង្ហាញនោះ រូបគេគឺជាអ្នកដែលទទួលបានការចង្អុលបង្ហាញដ៏ពិតប្រាកដ។ រីឯជនណាហើយដែលទ្រង់ធ្វើឱ្យរូបគេវង្វេង ពួកទាំងនោះហើយ គឺជាពួកដែលខាតបង់។

179. ហើយជាការពិតណាស់ យើងបានបង្កើតពួកជិន និងមនុស្សលោកជាច្រើនសម្រាប់ដាក់ក្នុងនរកដើហាន់ណាំ (ដោយសារតែ)ពួកគេមានចិត្ត តែពួកគេមិនយកវាមកពិចារណា។ ពួកគេមានភ្នែក ប៉ុន្តែពួកគេមិនយកភ្នែករបស់ពួកគេមើល(សញ្ញាកស្តុតាងរបស់អល់ឡោះ)ហើយពួកគេមានត្រចៀកតែពួកគេមិនយកវាមកស្តាប់(វាក្យខណ្ឌទាំងឡាយរបស់ទ្រង់)ឡើយ។ ពួកទាំងនោះប្រៀបដូចជាសត្វពាហនៈ។ ផ្ទុយទៅវិញ ពួកគេវង្វេងជាង(សត្វពាហនៈទាំងនោះ)ទៅទៀត។ ពួកទាំងនោះ គឺជាពួកដែលព្រងើយកន្តើយ។

180. ហើយសម្រាប់អល់ឡោះជាម្ចាស់ ទ្រង់មានព្រះនាមដ៏ល្អប្រពៃជាច្រើន។ ហេតុនេះ ចូរពួកអ្នកបួងសួងសុំពីទ្រង់តាមរយៈព្រះនាមទាំងនោះចុះ។ ហើយចូរពួកអ្នកបោះបង់ពួកដែលកែប្រែព្រះនាមរបស់ទ្រង់ចុះ។ គេនឹងតបស្នងដល់ពួកគេដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

181. ហើយក្នុងចំណោមអ្នកដែលយើងបានបង្កើតនោះ គឺមានក្រុមមួយដែលទទួលបានការចង្អុលបង្ហាញទៅកាន់ការពិត (និងអំពាវនាវអ្នកដទៃទៅកាន់ការពិតនោះ) ហើយនិងកាត់សេចក្តីដោយយុត្តិធម៌។

182. ហើយពួកដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង យើងនឹងល្បួងពួកគេដោយពួកគេមិនដឹងខ្លួនឡើយ។

183. ហើយយើងនឹងពន្យារពេល(ដាក់ទណ្ឌកម្ម)ដល់ពួកគេ។ ជាការពិតណាស់ គម្រោងការរបស់យើង គឺខ្លាំងក្លាបំផុត។

184. តើពួកគេមិនគិតពិចារណាទេឬដែលថា មិត្តភក្តិរបស់ពួកគេ(ព្យាការីមូហាំម៉ាត់)ពុំមែនជាមនុស្សវិកលចរិកឡើយ។ តាមពិតរូបគាត់ គ្មានអ្វីក្រៅពីជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់ប៉ុណ្ណោះ។

185. តើពួកគេមិនសម្លឹងមើលទៅចំពោះការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី ហើយនិងអ្វីគ្រប់យ៉ាងដែលអល់ឡោះបានបង្កើតនៅក្នុងវាទាំងពីរ ព្រមទាំង(សម្លឹងមើល)ទៅកាន់ឆាកជីវិតរបស់ពួកគេដែលអាចនឹងមកដល់ទីបញ្ចប់(ក្នុងពេលឆាប់ៗ)ទេឬ? ដូច្នេះ តើមានគម្ពីរណាមួយក្រោយពីវា(គម្ពីរគួរអាន)ទៀតដែលពួកគេមានជំនឿចំពោះវានោះ?

186. ជនណាហើយដែលអល់ឡោះធ្វើឱ្យរូបគេវង្វេង ពិតណាស់ រូបគេគ្មានអ្នកចង្អុលបង្ហាញណា(ក្រៅពីទ្រង់)ឡើយ។ ហើយអល់ឡោះនឹងបណ្តោយឱ្យពួកគេស្ថិតក្នុងភាពវង្វេងដោយពួកគេមានភាពស្រពេចស្រពិល។

187. ពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីថ្ងៃបរលោក ថាតើពេលណាទើបវាកើតឡើង? ចូរអ្នកពោលចុះថា៖ តាមពិតចំណេះដឹងអំពីថ្ងៃនោះ គឺនៅឯព្រះជាម្ចាស់របស់ខ្ញុំ(តែមួយគត់)។ គ្មាននរណាម្នាក់ដែលដឹងពីពេលវេលាកំណត់របស់វាឡើយ គឺមានតែទ្រង់ប៉ុណ្ណោះ។ វាជារឿងអាថ៌កំបាំងបំផុតទាំងនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី។ វានឹងមិនមកដល់ពួកអ្នកឡើយ លើកលែងតែភ្លាមៗ(មួយរំពេច)។ ពួកគេសួរអ្នកហាក់បីដូចជាអ្នកប្រាថ្នាចង់ដឹងអំពីវា។ ចូរអ្នកពោលថា៖ តាមពិតចំណេះដឹងអំពីវា គឺនៅឯអល់ឡោះជាម្ចាស់(តែមួយគត់)ក៏ប៉ុន្តែមនុស្សលោកភាគច្រើនមិនបានដឹងឡើយ។

188. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំគ្មានសមត្ថភាពអ្វីអាចផ្តល់ផលប្រយោជន៍ដល់ខ្លួនឯង ហើយក៏មិនអាចការពារគ្រោះថ្នាក់(ចេញពីខ្លួនខ្ញុំ)នោះដែរ លើកលែងតែអ្វីដែលអល់ឡោះទ្រង់មានចេតនាប៉ុណ្ណោះ។ ប្រសិនបើខ្ញុំអាចដឹងពីប្រការអោចំកំបាំងមែននោះ ខ្ញុំប្រាកដជានឹងទទួលបានប្រការល្អជាច្រើនជាមិនខាន ហើយប្រការអាក្រក់ក៏មិនអាចមកប៉ះពាល់រូបខ្ញុំនោះដែរ។ តាមពិតរូបខ្ញុំគ្មានអ្វីក្រៅពីជាអ្នកព្រមានបន្លាច និងផ្តល់ដំណឹងរីករាយដល់ក្រុមដែលមានជំនឿប៉ុណ្ណោះ។

189. ទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នក(ឱបុរសនិងស្ត្រីទាំងឡាយ)ចេញពីមនុស្សតែម្នាក់(ព្យាការីអាហ្សាំ) ហើយទ្រង់បានបង្កើតចេញពីមនុស្សតែម្នាក់នោះនូវភរិយារបស់គាត់ដើម្បីឲ្យគាត់រួមរស់ជាមួយនាង។ នៅពេលដែលគាត់បានរួមមេត្រីជាមួយនាង នាងក៏មានផ្ទៃពោះដោយបានពពោះដ៏ស្រាលនៅពេលដំបូង រួចនាងបានបន្តពពោះបែបនេះ។ នៅពេលដែលផ្ទៃពោះ(របស់នាង)កាន់តែធ្ងន់ គេទាំងពីរក៏បានបួងសួងសុំពីអល់ឡោះជាព្រះជាម្ចាស់របស់គេទាំងពីរថា៖ ប្រសិនបើព្រះអង្គប្រទានឱ្យយើងខ្ញុំនូវកូនដ៏ល្អម្នាក់ ពួកយើងពិតជានឹងក្លាយទៅជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលដឹងគុណ(ទ្រង់)ជាមិនខាន។

190. នៅពេលដែលគេទាំងពីរទទួលនូវកូនដ៏ល្អម្នាក់ គេទាំងពីរបែរជាបានធ្វើស៊ីរិកនឹងអល់ឡោះជាម្ចាស់ចំពោះអ្វី(កូន)ដែលទ្រង់បានប្រទានដល់គេទាំងពីរទៅវិញ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្ពង់ខ្ពស់បំផុតអំពីអ្វីដែលពួកគេបានធ្វើស៊ីរិក។

191. តើពួកគេយកអ្នកដែលមិនបានបង្កើតអ្វីមួយសោះមកធ្វើស៊ីរិក(នឹងអល់ឡោះ)ទាំងដែលពួកវាត្រូវបានគេ(អល់ឡោះ)បង្កើតយ៉ាងដូចម្តេច?

192. ពួកវាមិនអាចជួយអ្វីដល់ពួកគេឡើយ ហើយក៏មិនអាចជួយខ្លួនឯងបាននោះដែរ។

193. ហើយប្រសិនបើពួកអ្នក(ឱពួកមុស្លីគីន)បួងសួងសុំឲ្យពួកវាចង្អុលបង្ហាញ(ពួកអ្នក)ក៏ពួកវាមិនអាចធ្វើតាមពួកអ្នកបានដែរ។ វាដូចតែគ្នាទេចំពោះពួកអ្នក ទោះបីជាពួកអ្នកបួងសួងសុំពីពួកវា ឬក៏ពួកអ្នកនៅស្ងៀម(មិនបួងសួងសុំពីពួកវា)ក៏ដោយ។

194. ពិតប្រាកដណាស់ អ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈចំពោះពួកវាក្រៅពីអល់ឡោះនោះ ពួកវាក៏ជាខ្ញុំបម្រើ(របស់អល់ឡោះ)ដូចពួកអ្នកដែរ។ ដូច្នេះ ចូរពួកអ្នកបួងសួងសុំពីពួកវា ហើយឱ្យពួកវាឆ្លើយតបចំពោះពួកអ្នកមើល៍ ប្រសិនបើពួកអ្នក គឺជាអ្នកទៀងត្រង់មែននោះ។

195. តើពួកវា(រូបបដិមាទាំងនោះ)មានជើងដែលអាចដើរបានដែរឬទេ? ឬតើពួកវាមានដៃដែលអាចចាប់កាន់បានដែរឬទេ? ឬតើពួកវាមានភ្នែកដែលអាចមើលឃើញបានដែរឬទេ? ឬតើពួកវាមានត្រចៀកដែលអាចស្តាប់ឮដែរទេ? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកបួងសួងសុំពីព្រះនានារបស់ពួកអ្នក។ បន្ទាប់មក ចូរពួកអ្នកប្រើល្បិចដាក់ខ្ញុំចុះ ហើយកុំពន្យារពេលឱ្យខ្ញុំឱ្យសោះ។

196. ជាការពិតណាស់ អ្នកដែលគាំពាររូបខ្ញុំ(ព្យាការីមូហាំម៉ាត់)គឺអល់ឡោះជាម្ចាស់ដែលជាអ្នកបញ្ចុះគម្ពីរ(គួរអាន)ហើយទ្រង់ក៏ជាអ្នកគាំពារអ្នកសាងទង្វើកុសលទាំងឡាយផងដែរ។

197. ហើយពួក(បដិមា)ដែលពួកអ្នក(ឱពួកមុស្លីគីន)កំពុងតែបួងសួងសុំក្រៅពីទ្រង់នោះ ពួកវាមិនអាចជួយពួកអ្នកបានឡើយ ហើយពួកវាក៏មិនអាចជួយខ្លួនឯងបានដែរ។

198. ហើយប្រសិនបើពួកអ្នកបួងសួងសុំឲ្យពួកវាចង្អុលបង្ហាញ(ពួកអ្នក) នោះពួកវាមិនបានស្តាប់ឮឡើយ។ ហើយអ្នកឃើញពួកវាសម្លឹងមកកាន់អ្នក តែពួកវាមើលមិនឃើញឡើយ។

199. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទទួលយកការអធ្យាស្រ័យ(ពីមនុស្ស) និងប្រើគ្នាឱ្យធ្វើល្អ ហើយត្រូវបែរចេញពីពួកល្ងង់ខ្លៅ។

200. ហើយប្រសិនបើស្តែតនមកញុះញង់អ្នកនូវប្រការណាមួយ ចូរអ្នកសុំការបញ្ជៀសពីអល់ឡោះ។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

201. ជាការពិតណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)នៅពេលដែលមានក្រុមមួយនៃពួកស្តែតនមកញុះញង់ពួកគេ(ឱ្យប្រព្រឹត្តបាបកម្ម) គឺពួកគេនឹកឃើញ(ដល់អល់ឡោះ)។ ពេលនោះ ពួកគេគឺជាអ្នកដែលមើលឃើញ(ប្រការត្រឹមត្រូវ)។

202. ចំណែកឯបងប្អូនរបស់ស្តែតន(ក្នុងចំណោមពួកមនុស្សអាក្រក់)វិញ ពួកវានៅតែបន្តែមឱ្យពួកគេនូវភាពវង្វេង។ ក្រោយមកពួកវាមិនធ្វេសប្រហែសឡើយ។

203. ហើយប្រសិនបើអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) មិនបាននាំមកនូវសញ្ញាកស្តុតាងណាមួយមកកាន់ពួកគេទេនោះ ពួកគេនឹងនិយាយថា៖ ហេតុអ្វីបានជាអ្នកមិនបង្កើតសញ្ញាកស្តុតាង(ដោយខ្លួនឯងទៅ)? ចូរអ្នកពោលចុះថា៖ តាមពិត ខ្ញុំគ្រាន់តែដើរតាមអ្វីដែលគេផ្តល់ជាវ៉ាហ៊ីឲ្យខ្ញុំពីព្រះជាម្ចាស់របស់ខ្ញុំប៉ុណ្ណោះ។ (គម្ពីរគួរអាន)នេះ គឺជាសញ្ញាកស្តុតាងពីព្រះជាម្ចាស់របស់ពួកអ្នក និងជាការចង្អុលបង្ហាញ ព្រមទាំងជាក្តីមេត្តាករុណាសម្រាប់ក្រុមដែលមានជំនឿ។

204. ហើយនៅពេលដែលមានគេសូត្រគម្ពីរគួរអាន ចូរពួកអ្នកត្រងត្រាប់ស្តាប់ និងនៅស្ងៀម សង្ឃឹមថាគេនឹងអាណិតស្រលាញ់ដល់ពួកអ្នក។

205. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រឭកទៅចំពោះព្រះជាម្ចាស់របស់អ្នកក្នុងខ្លួនរបស់អ្នកដោយបន្ទាបខ្លួន និងកោតខ្លាច និងមិនត្រូវតម្លើងសំឡេងខ្លាំងៗនោះឡើយទាំងនៅពេលព្រឹកនិងនៅពេលល្ងាច។ ហើយចូរអ្នកកុំធ្វើខ្លួនឲ្យស្ថិតក្នុងចំណោមពួកដែលព្រងើយកន្តើយឡើយ។

206. ពិតប្រាកដណាស់ អ្នកដែលនៅជិតព្រះម្ចាស់របស់អ្នក(បណ្តាម៉ាឡាអ៊ីកាត់) ពួកគេមិនក្រអឺតក្រទមចំពោះការគោរពសក្ការៈទ្រង់ឡើយ។ ហើយពួកគេលើកតម្កើងទ្រង់ និងក្រាបស៊ូជោតចំពោះទ្រង់(តែមួយគត់)។

ជំពូក អាល់អាន់ហ្សាល

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីទ្រព្យជ័យកណ្ឌ។ ចូរអ្នកតបថា៖ ទ្រព្យជ័យកណ្ឌទាំងនោះ គឺសម្រាប់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងផ្សះផ្សាទំនាក់ទំនងរវាងពួកអ្នក។ ហើយចូរពួកអ្នកគោរពប្រតិបត្តិអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿមែននោះ។

2. តាមពិត បណ្តាអ្នកដែលមានជំនឿ(យ៉ាងពិតប្រាកដ)នោះ គឺបណ្តាអ្នកដែលនៅពេលមានគេរំឭកចំពោះអល់ឡោះជាម្ចាស់ ដួងចិត្តរបស់ពួកគេមានភាពញាប់ញ័រ។ ហើយនៅពេលដែលមានគេសូត្រនូវបណ្តាវាក្យខណ្ឌរបស់ទ្រង់ឱ្យពួកគេស្តាប់ វាធ្វើឱ្យសេចក្តីជំនឿរបស់ពួកគេកាន់តែកើនឡើងថែមទៀត។ ហើយពួកគេប្រគល់ការទុកចិត្តចំពោះព្រះជាម្ចាស់របស់ពួកគេ(តែមួយគត់)។

3. គឺបណ្តាអ្នកដែលប្រតិបត្តិសឡាត ហើយពួកគេធ្វើការបរិច្ចាគទានចំពោះអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេ។

4. អ្នកទាំងនោះហើយ គឺជាអ្នកដែលមានជំនឿយ៉ាងពិតប្រាកដ។ ហើយសម្រាប់ពួកគេ នឹងទទួលបានឋានៈ(ដ៏ខ្ពង់ខ្ពស់)នៅឯព្រះជាម្ចាស់របស់ពួកគេ ព្រមទាំងការអភ័យទោស និងលាភសក្ការៈដ៏ប្រពៃ(ឋានសួគ៌)។

5. ដូច្នេះដែរ ព្រះជាម្ចាស់របស់អ្នកទ្រង់បានប្រើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ឱ្យចាកចេញពីលំនៅឋានរបស់អ្នកយ៉ាងពិតប្រាកដ ទោះបីជាមានមួយក្រុមក្នុងចំណោមអ្នកមានជំនឿមិនពេញចិត្តក៏ដោយ។

6. ពួកគេជជែកដេញដោលនឹងអ្នកក្នុងរឿងពិត(ការធ្វើសង្គ្រាម)ក្រោយពីវាបានបង្ហាញយ៉ាងច្បាស់ហើយនោះ ហាក់បីដូចជាពួកគេត្រូវបាននាំទៅរកសេចក្តីស្លាប់ ខណៈដែលពួកគេកំពុងតែឃើញវានឹងភ្នែករបស់ពួកគេដូច្នោះដែរ។

7. ហើយ(ចូរពួកអ្នកនឹកឃើញ)នៅពេលដែលអល់ឡោះជាម្ចាស់បានសន្យានឹងពួកអ្នកថា ពិតប្រាកដណាស់ ពួកអ្នកនឹងទទួលជ័យជម្នះលើក្រុមមួយក្នុងចំណោមក្រុមទាំងពីរ(ក្រុមក្បួនដឹកទំនិញ និងក្រុមកងទ័ព)។ ហើយពួកអ្នកពេញចិត្តចង់ទទួលបានជ័យជម្នះលើក្រុមក្បួនដឹកទំនិញដោយមិនបាច់ប្រយុទ្ធគ្នា។ តែអល់ឡោះជាម្ចាស់ទ្រង់ចង់ពង្រឹងការពិតដោយបន្ទូលរបស់ទ្រង់(ដាក់បទបញ្ជាឱ្យចេញច្បាំង)និងកាត់ផ្តាច់ឫសគល់ពួកដែលប្រឆាំង។

8. ដើម្បីបញ្ជាក់នូវការពិត ហើយលុបបំបាត់នូវប្រការដែលមិនពិត ទោះបីជាពួកដែលប្រព្រឹត្តអាក្រក់មិនពេញចិត្តក៏ដោយ។

9. (ចូរពួកអ្នកនឹកឃើញ)ខណៈដែលពួកអ្នកសុំជំនួយពីព្រះជាម្ចាស់របស់ពួកអ្នក។ ពេលនោះ ទ្រង់បានឆ្លើយតបចំពោះពួកអ្នក(ដោយបន្ទូលរបស់ទ្រង់ថា៖)យើងជាអ្នកពង្រឹងដល់ពួកអ្នក ដោយទ្រង់បានបញ្ជូនម៉ាឡាអ៊ីកាត់ចំនួនមួយពាន់នាក់មកជាបន្តបន្ទាប់គ្នា។

10. ការដែលអល់ឡោះបញ្ជូនម៉ាឡាអ៊ីកាត់មក គឺគ្មានអ្វីក្រៅពីជាការផ្តល់ដំណឹងរីករាយ(ដល់ពួកអ្នក)និងដើម្បីធ្វើឱ្យចិត្តរបស់ពួកអ្នកមានភាពនឹងរនឹងវានោះឡើយ។ ហើយគ្មានជ័យជម្នះនោះឡើយ លើកលែងតែមកពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

11. (ចូរពួកអ្នកនឹកឃើញ) នៅពេលដែលទ្រង់បានឱ្យការងងុយគេងគ្របដណ្តប់លើពួកអ្នក ជាសុវត្ថិភាពមួយអំពីទ្រង់ ហើយទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃមកឱ្យពួកអ្នកដើម្បីជម្រះសម្អាតពួកអ្នក និងបំបាត់ការញុះញង់របស់ស្មៃតនចេញពីពួកអ្នក ព្រមទាំងដើម្បីចងភ្ជាប់ដួងចិត្តរបស់ពួកអ្នក និងជាការពង្រឹងជើងរបស់ពួកអ្នក(ឲ្យមានភាពងាយស្រួលក្នុងការដើរ)។

12. នៅពេលដែលព្រះជាម្ចាស់របស់អ្នក(ឱព្យាការីមូហាំម៉ាត់)បានផ្តល់វាហ៊ីទៅកាន់ម៉ាឡាអ៊ីកាត់(ក្នុងសមរភូមិហ្គាទើរ)ថាៈជាការពិតណាស់ យើងនៅជាមួយពួកអ្នក។ ដូច្នេះ ចូរពួកអ្នកពង្រឹងកម្លាំងចិត្តរបស់អ្នកមានជំនឿ។ យើងនឹងបញ្ចូលភាពភ័យខ្លាចទៅក្នុងដួងចិត្តរបស់ពួកគ្មានជំនឿ។ ហេតុនេះ ចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)វាយកញ្ឆឹងក និងកាត់រាល់សន្លាក់ឆ្អឹងទាំងអស់របស់ពួកគេចុះ។

13. នោះគឺដោយសារតែពួកគេបានប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។ ហើយជនណាដែលប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ជាការពិតណាស់ អល់ឡោះគឺជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

14. (ទណ្ឌកម្ម)នោះគឺសម្រាប់ពួកអ្នក(ឱពួកដែលប្រឆាំង)។ ដូច្នេះ ចូរពួកអ្នកភ្លក់វាចុះ(នៅក្នុងលោកិយ)។ ហើយពិតប្រាកដណាស់ សម្រាប់ពួកដែលប្រឆាំងនឹងទទួលទណ្ឌកម្មក្នុងឋាននរក(នៅថ្ងៃបរលោក)។

15. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលពួកអ្នកបានជួបនឹងពួកដែលប្រឆាំង(នៅក្នុងសមរភូមិ)ដោយប្រឈមមុខជាមួយពួកគេនោះ ចូរពួកអ្នកកុំបែរខ្នងដាក់ពួកគេ(រត់ត្រឡប់ក្រោយ)ឱ្យសោះ។

16. ហើយជនណាដែលបានបែរខ្នងរបស់ខ្លួនដាក់ពួកគេ(រត់ត្រឡប់ក្រោយ)នៅក្នុងថ្ងៃនោះដោយមិនមែនក្នុងគោលបំណងរកល្បិចកលដើម្បីប្រយុទ្ធ ឬមិនមែនជាការដកថយទៅរកក្រុម(អ្នកមានជំនឿ)ទេនោះ ជាការពិតណាស់ ជននោះពិតជាបានវិលត្រឡប់មកវិញដោយនាំមកនូវការខឹងសម្បាពីអល់ឡោះជាម្ចាស់ជាមិនខាន ហើយកន្លែងស្នាក់អាស្រ័យរបស់គេ គឺនរកដើហាន់ណាំ។ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត ។

17. ជាការពិតណាស់ ពួកអ្នកមិនបានសម្លាប់ពួកគេ(នាថ្ងៃសមរភូមិហ្គាទើរ)នោះឡើយ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទៅវិញទេដែលបានសម្លាប់ពួកគេនោះ។ ហើយអ្នក(ឱព្យាការីមូហាំម៉ាត់)ក៏មិនបានគប់(គ្រាប់គ្រួស)នោះដែរនៅពេលដែលអ្នកគប់(ទៅលើពួកគេ)នោះ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទៅវិញទេដែលបានគប់(ទៅលើពួកគេ)។ ហើយទ្រង់នឹងសាកល្បងបណ្តាអ្នកមានជំនឿអំពីរឿងនោះនូវការសាកល្បងដ៏ល្អប្រសើរ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

18. ជ័យជម្នះដែលពួកអ្នកទទួលបាននោះ គឺមកពីអល់ឡោះជាម្ចាស់។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ គឺជាអ្នកដែលធ្វើឱ្យល្បិចកលរបស់ពួកប្រឆាំងទន់ខ្សោយ។

19. ប្រសិនបើពួកអ្នក(ឱពួកមុស្លីគីន)សុំឱ្យ(អល់ឡោះ)ដាក់ទណ្ឌកម្ម ពិតប្រាកដណាស់ ទណ្ឌកម្មនោះបានមកដល់ពួកអ្នកហើយ។ ហើយប្រសិនបើពួកអ្នកបញ្ឈប់(ការប្រឆាំង) នោះវាជាការប្រសើរសម្រាប់ពួកអ្នក។ តែប្រសិនបើពួកអ្នកវិលត្រឡប់(ទៅកាន់ការប្រឆាំង)វិញ យើងនឹងត្រឡប់ឱ្យពួកអ្នក(នូវភាពបរាជ័យដូចមុន) ហើយក្រុមរបស់ពួកអ្នកនឹងមិនអាចជួយជាប្រយោជន៍អ្វីដល់ពួកអ្នកបន្តិចនោះឡើយ ទោះបីជា(ពួកអ្នក)មានគ្នាច្រើនក៏ដោយ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលមានជំនឿ។

20. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយពួកអ្នកមិនត្រូវងាកចេញ(ប្រឆាំង)នឹងទ្រង់នោះឡើយ ខណៈដែលពួកអ្នកបានស្តាប់ឮ(បណ្តាវាក្យខណ្ឌរបស់ទ្រង់)ហើយនោះ។

21. ហើយចូរពួកអ្នកកុំធ្វើដូចពួក(ពុតត្បុត និងពួកមុស្លីគីន)ដែលពួកគេនិយាយថាៈ ពួកយើងបានឮហើយ ខណៈដែលពួកគេមិនបានស្តាប់ឮ(ទាញប្រយោជន៍ពីអ្វីដែលខ្លួនបានស្តាប់ឮ)សោះនោះ។

22. ជាការពិតណាស់ សត្វលោកដែលអាក្រក់បំផុតនៅចំពោះមុខអល់ឡោះជាម្ចាស់នោះ គឺអ្នកដែលថ្លង់(មិនព្រមស្តាប់ការពិត)និងអ្នកដែលគ(មិននិយាយការពិត)ដែលពួកគេគ្មានការគិតពិចារណានោះឡើយ។

23. ហើយប្រសិនបើអល់ឡោះជាម្ចាស់ទ្រង់ដឹងថា ក្នុងខ្លួនពួកគេមានភាពល្អប្រសើរនោះ ទ្រង់ប្រាកដជានឹងធ្វើឱ្យពួកគេស្តាប់ឮជាមិនខាន។ ហើយបើទោះជាទ្រង់ធ្វើឱ្យពួកគេស្តាប់ឮក៏ដោយ ក៏ពួកគេនៅតែបែរចេញ(ពីការមានជំនឿ)នោះដែរ ខណៈដែលពួកគេគឺជាពួកដែលងាកចេញ។

24. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកឆ្លើយតបចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ នៅពេលដែលទ្រង់អំពាវនាវពួកអ្នកទៅរកមាគ៌ាដែលត្រឹមត្រូវនោះ។ ហើយចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះទ្រង់អាចរារាំងរវាងបុគ្គល និងចិត្តរបស់គេ(ពីអ្វីដែលគេប្រាថ្នា) ហើយពិតប្រាកដណាស់ ពួកអ្នកនឹងត្រូវគេប្រមូលផ្តុំទៅកាន់ទ្រង់(តែមួយគត់)។

25. ហើយចូរពួកអ្នកកោតខ្លាចនូវភាពវឹកវរដែលមិនត្រឹមតែធ្លាក់ទៅលើពួកដែលបំពានក្នុងចំណោមពួកអ្នកនោះទេ (តែវាក៏អាចប៉ះពាល់ដល់អ្នកផ្សេងទៀតក្រៅពីពួកគេផងដែរ)។ ហើយចូរពួកអ្នកដឹងថា ពិតប្រាកដណាស់ អល់ឡោះគឺជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

26. ហើយ(ចូរពួកអ្នកនឹកឃើញ) នៅពេលដែលពួកអ្នកមានគ្នាតិច និងជាអ្នកដែលទន់ខ្សោយនៅលើផែនដី(កាលនៅក្រុងម៉ាក្កៈ)។ ពួកអ្នកខ្លាចសត្រូវរបស់ពួកអ្នកធ្វើបាបពួកអ្នក តែអល់ឡោះទ្រង់បានផ្តល់កន្លែងជ្រកកោនដល់ពួកអ្នក(នៅក្រុងម៉ាទីណៈ) ហើយទ្រង់បានពង្រឹងពួកអ្នកដោយឱ្យពួកអ្នកទទួលជ័យជម្នះ(នៅក្នុងសមរភូមិហ្គាទើរ) ព្រមបានប្រទាននូវលាភសក្ការៈដ៏ល្អៗដល់ពួកអ្នក សង្ឃឹមថា ពួកអ្នកនឹងដឹងគុណ។

27. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំក្បត់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ និងក្បត់នឹងទំនុកចិត្តដែលគេបានផ្ញើនឹងពួកអ្នក ខណៈដែលពួកអ្នកបានដឹងហើយនោះ។

28. ហើយចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ ទ្រព្យសម្បត្តិរបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នក គឺគ្រាន់តែជាការសាកល្បង(ពីអល់ឡោះ)ប៉ុណ្ណោះ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មាននូវផលបុណ្យដ៏ធំធេង។

29. ឱបណ្តាអ្នកដែលមានជំនឿ! ប្រសិនបើពួកអ្នកកោតខ្លាចអល់ឡោះ ទ្រង់នឹងធ្វើឱ្យពួកអ្នកចេះបែងចែក(រវាងប្រការពិតនិងប្រការមិនពិត) ហើយទ្រង់នឹងលុបលាងនូវរាល់អំពើអាក្រក់ទាំងឡាយរបស់ពួកអ្នកចេញពីពួកអ្នក ព្រមទាំងអភ័យទោសដល់ពួកអ្នក(នូវបាបកម្មទាំងឡាយ)។ ហើយអល់ឡោះជាម្ចាស់ គឺជាអ្នកដែលមានភាពសប្បុរសដ៏ធំធេងបំផុត។

30. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលពួកប្រឆាំងបានរៀបចំល្បិចកលប្រឆាំងនឹងអ្នកដើម្បីឃុំឃាំងអ្នក ឬសម្លាប់អ្នក ឬនិរទេសអ្នក(ចេញពីភូមិស្រុក)។ ពួកគេបានប្រើល្បិចកល តែអល់ឡោះក៏បានរៀបចំគម្រោងការ(ចំពោះពួកគេ)វិញដែរ។ ហើយអល់ឡោះជាអ្នករៀបចំគម្រោងការដ៏ប្រសើរបំផុត។

31. ហើយនៅពេលដែលមានគេសួរបណ្ដាវាក្យខណ្ឌរបស់យើងឱ្យពួកគេស្ដាប់ ពួកគេនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងបានឮហើយ។ ប្រសិនបើពួកយើងចង់ ពួកយើងប្រាកដជាអាចនិយាយដូច(គម្ពីរគួរអាន)នេះបានជាមិនខាន។ ពិតប្រាកដណាស់ (គម្ពីរគួរអាន)នេះគ្មានអ្វីក្រៅជារឿងព្រេងនិទានរបស់អ្នកជំនាន់មុននោះឡើយ។

32. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ បពិត្រអល់ឡោះជាម្ចាស់! ប្រសិនបើ(អ្វីដែលព្យាការីមូហាំម៉ាត់បាននាំមក)នេះ គឺជាការពិតមកពីព្រះអង្គមែននោះ សូមព្រះអង្គមេត្តាបញ្ចុះភ្លៀងជុំវិញពីលើមេឃមកលើពួកយើង ឬក៏នាំនូវទណ្ឌកម្មដ៏ខ្លោចផ្សាមកកាន់ពួកយើងមក។

33. ហើយអល់ឡោះទ្រង់មិនដាក់ទណ្ឌកម្មពួកគេ ខណៈដែលរូបអ្នកនៅជាមួយពួកគេនោះឡើយ ហើយអល់ឡោះក៏មិនមែនជាអ្នកដាក់ទណ្ឌកម្មពួកគេ ខណៈដែលពួកគេសុំការអភ័យទោស(ពីទ្រង់)នោះដែរ។

34. តើមានអ្វីដែលរារាំងមិនឱ្យអល់ឡោះដាក់ទណ្ឌកម្មពួកគេ(ពួកមុស្លីគីន) ខណៈដែលពួកគេបានរារាំងអ្នកដទៃពីម៉ាស្ជិតអាល់ហារ៉ម ហើយពួកគេក៏មិនមែនជាអ្នកគាំពាររបស់ទ្រង់ដែរនោះ? តាមពិត អ្នកគាំពាររបស់អល់ឡោះនោះ គឺមានតែអ្នកដែលកោតខ្លាចប៉ុណ្ណោះ។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនដឹងឡើយ។

35. ហើយការគោរពសក្ការៈរបស់ពួកគេនៅឯម៉ាស្ជិតហារ៉មនោះ គ្មានអ្វីក្រៅពីការហួចលេង និងទះដៃនោះឡើយ។ ហេតុនេះ ចូរពួកអ្នក(នៃពួកមុស្លីគីន)ភ្លក់រសជាតិទណ្ឌកម្មចុះ ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រឆាំង។

36. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនោះ ពួកគេបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេដើម្បីរារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះ។ ពិតណាស់ ពួកគេនឹងបរិច្ចាគវា។ ក្រោយមក ពួកគេនឹងស្ដាយក្រោយ។ ក្រោយមកទៀត ពួកគេនឹងត្រូវទទួលបរាជ័យ។ ហើយពួកដែលប្រឆាំងនឹងត្រូវគេប្រមូលទៅកាន់នរកដើហាន់ណាំ។

37. ដើម្បីអល់ឡោះទ្រង់ញែកប្រការអាក្រក់ចេញពីប្រការល្អ។ ហើយទ្រង់នឹងដាក់អ្វីដែលអាក្រក់ទាំងអស់នោះគរលើគ្នាជាបន្តបន្ទាប់ រួចទ្រង់នឹងដាក់វាទៅក្នុងនរកដើហាន់ណាំ។ ពួកទាំងនោះហើយ គឺជាពួកដែលខាតបង់។

38. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ពួកគ្មានជំនឿថា៖ ប្រសិនបើពួកគេបញ្ឈប់(ភាពគ្មានជំនឿ)នោះ គេនឹងអភ័យទោសដល់ពួកគេនូវអ្វី(បាបកម្ម)ដែលពួកគេបានសាងកន្លងមក។ តែប្រសិនបើពួកគេវិលត្រឡប់(ទៅរកភាពគ្មានជំនឿ)វិញនោះ ពិតប្រាកដណាស់ មាគ៌ារបស់អ្នកជំនាន់មុនបានកើតឡើងរួចទៅហើយ។

39. ហើយចូរពួកអ្នក(ឱបណ្ដាអ្នកដែលមានជំនឿ)ប្រយុទ្ធនឹងពួកគេ រហូតទាល់តែភាពវឹកវរ(អំពើស្ហ្មីក និងការរារាំងអ្នកមូស្លីមពីសាសនារបស់អល់ឡោះ)លែងកើតមាន ហើយសាសនា(ការគោរពសក្ការៈ)ទាំងអស់ គឺសម្រាប់អល់ឡោះជាម្ចាស់(តែមួយ)។ ហើយប្រសិនបើពួកគេបញ្ឈប់(នូវអំពើទាំងអស់នោះ) ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ឃើញបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

40. តែប្រសិនបើពួកគេបែរចេញវិញនោះ ចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់គឺជាអ្នកគាំពាររបស់ពួកអ្នក។ ទ្រង់ជាអ្នកគាំពារដ៏ប្រសើរបំផុត ហើយក៏ជាអ្នកជួយដ៏ល្អប្រសើរបំផុតផងដែរ។

41. ហើយចូរពួកអ្នក(ឱបណ្ដាអ្នកដែលមានជំនឿ)ដឹងចុះថា ជាការពិតណាស់ ទ្រព្យជ័យកណ្ដាអ្វីមួយដែលពួកអ្នកទទួលបាន គឺមួយភាគប្រាំ(១/៥)សម្រាប់អល់ឡោះ និងសម្រាប់អ្នកនាំសារ(របស់ទ្រង់) សម្រាប់សាច់ញាតិ(របស់លោក) សម្រាប់កូនកំព្រា សម្រាប់ជនក្រីក្រ និងសម្រាប់អ្នកដំណើរដាច់ស្បៀង ប្រសិនបើពួកអ្នកមានជំនឿចំពោះអល់ឡោះ ហើយនិងអ្វីដែលយើងបានបញ្ជូនទៅកាន់ខ្ទុំបម្រើរបស់យើង(ព្យាការីមូហាំម៉ាត់)នៅថ្ងៃបែងចែកខុសត្រូវ(ថ្ងៃសមរភូមិហ្គាទើរ) ជាថ្ងៃដែលក្រុមទាំងពីរជួបគ្នាមែននោះ។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានសមត្ថភាពលើអ្វីៗទាំងអស់។

42. (ចូរពួកអ្នកនឹកឃើញ) ខណៈដែលពួកអ្នកនៅជិតជ្រុងម្ខាងនៃជ្រលង (ប៉ែកខាងក្រុងម៉ាទីណៈ) ហើយពួកគេ (ពួកមុស្ហរីគីន) ស្ថិតនៅជ្រុងម្ខាងទៀតឆ្ងាយពីជ្រលង (ប៉ែកខាងក្រុងម៉ាក្កៈ)។ ចំណែកឯក្បួនដឹកទំនិញ (របស់ពួកគេ) គឺស្ថិតនៅកន្លែងទាបជាងពួកអ្នក (ប៉ែកខាងឆ្នេរសមុទ្រក្រហម)។ ហើយបើទោះបីជាពួកអ្នកសន្យាគ្នា (ណាត់គ្នាថានឹងជួបគ្នានៅតំបន់ហ្គាទើរក៏ដោយ) ក៏ពួកអ្នកមិនអាចជួបគ្នានៅកន្លែងដែលបានសន្យានោះដែរ ក៏ប៉ុន្តែ (អល់ឡោះទ្រង់បានប្រមូលផ្តុំពួកអ្នកឲ្យជួបគ្នាដោយគ្មានការសន្យាគ្នាជាមុន) ដើម្បីទ្រង់បំពេញនូវកិច្ចការដែលបានកំណត់រួច ដើម្បីឲ្យពួកគ្មានជំនឿនៅតែបន្តគ្មានជំនឿ និងដើម្បីឲ្យអ្នកដែលមានជំនឿកាន់តែជឿថែមទៀត។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

43. (ចូរអ្នកនឹកឃើញ) នៅពេលដែលអល់ឡោះបានបង្ហាញឱ្យអ្នកបានឃើញក្នុងសុបិនរបស់អ្នកថា ពួកគេ (ពួកមុស្ហរីគីន) មានគ្នាតិច។ ប្រសិនបើយើងឱ្យអ្នកបានឃើញពួកគេមានគ្នាច្រើនវិញនោះ ច្បាស់ជាពួកអ្នកនឹងបរាជ័យ និងមានការខ្វែងគំនិតគ្នាក្នុងរឿងនោះជាមិនខាន។ ក៏ប៉ុន្តែ ទ្រង់បានផ្តល់សុវត្ថិភាព (ដល់ពួកអ្នកពីបញ្ហានេះ)។ ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុងចិត្ត។

44. ហើយ (ចូរពួកអ្នកនឹកឃើញ) នៅពេលដែលគេបង្ហាញឱ្យពួកអ្នកបានឃើញពួកគេមានចំនួនតិចក្នុងក្រសែភ្នែករបស់ពួកអ្នកនៅពេលដែលពួកអ្នកបានជួបនឹងពួកគេ ហើយគេក៏បានឱ្យពួកគេឃើញពួកអ្នកមានចំនួនតិចក្នុងក្រសែភ្នែករបស់ពួកគេផងដែរ ដើម្បីឱ្យអល់ឡោះសម្រេចកិច្ចការដែលបានកំណត់រួច។ ហើយកិច្ចការទាំងអស់នឹងត្រូវគេនាំត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់ (តែមួយគត់)។

45. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលពួកអ្នកប្រឈមមុខនឹងក្រុមមួយ (ក្នុងចំណោមពួកប្រឆាំង) ចូរពួកអ្នកមានជំហររឹងមាំ ហើយចូរពួកអ្នករំឭកចំពោះអល់ឡោះជាម្ចាស់ឱ្យបានច្រើន សង្ឃឹមថាពួកអ្នកនឹងទទួលជ័យជម្នះ។

46. ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ និងមិនត្រូវខ្វែងគំនិតគ្នានោះឡើយដែលជាហេតុធ្វើឱ្យពួកអ្នកទទួលបរាជ័យ ហើយបាត់បង់នូវភោពខ្លាំងក្លារបស់ពួកអ្នក។ ហើយចូរពួកអ្នកអត់ធ្មត់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលអត់ធ្មត់។

47. ហើយចូរពួកអ្នកកុំធ្វើដូចពួក (មុស្ហរីគីន) ដែលចាកចេញពីលំនៅឋានរបស់ពួកគេប្រកបដោយភាពក្អេងក្អាង និងចង់ឱ្យមនុស្សលោកឃើញ ព្រមទាំងរារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះឱ្យសោះ។ ហើយអល់ឡោះដឹងជ្រួតជ្រាបនូវអ្វីដែលពួកគេប្រព្រឹត្ត។

48. ហើយ (ចូរពួកអ្នកនឹកឃើញ) ខណៈដែលស្តេចបានតុបតែងលម្អដល់ពួកគេ (ពួកមុស្ហរីគីន) នូវទង្វើរបស់ពួកគេ ហើយវាបាននិយាយថា៖ គ្មាននរណាម្នាក់ក្នុងចំណោមមនុស្សលោកអាចយកឈ្នះលើពួកអ្នកបានឡើយនៅថ្ងៃនេះ ហើយពិតប្រាកដណាស់ ខ្ញុំជាអ្នកចាំជួយពួកអ្នក។ ក៏ប៉ុន្តែ នៅពេលដែលក្រុមទាំងពីរបានជួបគ្នា ស្តេចនក៏បានរត់ចេញពីពួកគេ ហើយនិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំមិនជាប់ពាក់ព័ន្ធជាមួយពួកអ្នកឡើយ។ ជាការពិតណាស់ ខ្ញុំបានឃើញនូវអ្វី (ម៉ាឡាអ៊ីកាត់) ដែលពួកអ្នកមើលមិនឃើញ។ ពិតប្រាកដណាស់ ខ្ញុំខ្លាចអល់ឡោះ។ ហើយអល់ឡោះជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

49. (ចូរពួកអ្នកនឹកឃើញ) នៅពេលដែលពួកពុតត្បុត និងអ្នកដែលដួងចិត្តរបស់ពួកគេមានជំងឺ (មានជំនឿទន់ខ្សោយ) បាននិយាយថា៖ អ្នក (មូស្លីម) ទាំងនោះ សាសនារបស់ពួកគេបានបោកប្រាស់ពួកគេ។ ជនណាហើយដែលប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់នោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

50. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញ នៅពេលដែលម៉ាឡាអ៊ីកាត់ដកយកព្រលឹងរបស់ពួកដែលគ្មានជំនឿនោះ (អ្នកនឹងឃើញ)ម៉ាឡាអ៊ីកាត់វាយមុខពួកគេ និងវាយខ្នងរបស់ពួកគេ (ហើយនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មដែលឆេះសន្ធោសន្ធៅ។

51. នោះគឺដោយសារតែអ្វី(អំពើអាក្រក់)ដែលពួកអ្នកបានសាងដោយផ្ទាល់ដៃរបស់ពួកអ្នក ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនមែនជាអ្នកដែលបំពានទៅលើខ្ញុំបម្រើ(របស់ទ្រង់ណាម្នាក់)ឡើយ។

52. ដូចជាអ្វីដែលបានកើតឡើងចំពោះបក្សពួករបស់ហ្វៀរអោន និងអ្នកជំនាន់មុនពួកគេនោះដែរ។ ពួកគេបានប្រឆាំងនឹងសញ្ញាកស្តតាងទាំងឡាយរបស់អល់ឡោះ។ ដូចនេះ ទ្រង់ក៏បានដាក់ទណ្ឌកម្មពួកគេដោយសារតែបាបកម្មរបស់ពួកគេ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងក្លា ជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

53. នោះគឺដោយសារតែអល់ឡោះជាម្ចាស់ទ្រង់មិនមែនជាអ្នកដែលកែប្រែឧបការគុណណាមួយដែលទ្រង់ប្រទានវាដល់ក្រុមណាមួយឡើយ លុះត្រាតែពួកគេកែប្រែដោយខ្លួនឯងប៉ុណ្ណោះ។ ហើយពិតណាស់ អល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

54. ដូចជាអ្វីដែលបានកើតឡើងចំពោះបក្សពួករបស់ហ្វៀរអោន និងអ្នកជំនាន់មុនពួកគេនោះដែរ។ ពួកគេបានបដិសេធចំពោះសញ្ញាកស្តតាងទាំងឡាយនៃព្រះជាម្ចាស់របស់ពួកគេ។ ហេតុនេះ យើងក៏បានបំផ្លាញពួកគេដោយសារតែបាបកម្មរបស់ពួកគេ។ ហើយយើងបានពន្លិចបក្សពួកហ្វៀរអោនឲ្យលិចលង់(ក្នុងទឹកសមុទ្រ)។ ហើយរាល់ក្រុមទាំងនោះ ពួកគេគឺជាពួកដែលឆ្គាប់បានបំពាន។

55. ជាការពិតណាស់ សត្វលោកដែលអាក្រក់បំផុតនៅចំពោះមុខអល់ឡោះជាម្ចាស់នោះ គឺពួកដែលប្រឆាំង ដោយពួកគេពុំមានជំនឿឡើយ។

56. គឺពួកដែលអ្នក(ព្យាការីមូហាំម៉ាត់)បានចុះកិច្ចព្រមព្រៀងជាមួយនឹងពួកគេ ក្រោយមក ពួកគេបានក្បត់កិច្ចព្រមព្រៀងរបស់ពួកគេរាល់លើក ហើយពួកគេមិនកោតខ្លាច(អល់ឡោះ)ឡើយ។

57. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានជួបពួកដែលក្បត់កិច្ចព្រមព្រៀងទាំងនោះក្នុងសមរភូមិ ចូរអ្នកដាក់ទណ្ឌកម្មពួកគេឱ្យបានខ្លាំងក្លាបំផុតរហូតដល់អ្នកផ្សេងក្រៅពីពួកគេខ្លាចរអាផងដែរ ដើម្បីឱ្យពួកគេនឹកឃើញ។

58. តែប្រសិនបើអ្នកមានការបារម្ភខ្លាចក្រុមមួយក្បត់(កិច្ចព្រមព្រៀង) ចូរអ្នកប្រាប់ឱ្យពួកគេបានដឹងពីការរំលាយកិច្ចព្រមព្រៀងដើម្បីឱ្យពួកអ្នកនិងពួកគេបានដឹងស្មើគ្នា។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនស្រលាញ់ពួកដែលក្បត់កិច្ចព្រមព្រៀងឡើយ។

59. ហើយចូរពួកប្រឆាំងកុំគិតស្មានថា ពួកគេអាចរួចផុតពីទណ្ឌកម្ម(របស់អល់ឡោះ)ឱ្យសោះ។ ពិតប្រាកដណាស់ ពួកគេមិនអាចគេចផុតពីវាបានឡើយ។

60. ហើយចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)រៀបចំតាមលទ្ធភាពរបស់ពួកអ្នកក្នុងការត្រៀមនូវកម្លាំងទ័ព និងទ័ពសេះដោយពួកអ្នកត្រូវបន្លាចវាដល់សត្រូវរបស់អល់ឡោះ និងសត្រូវរបស់ពួកអ្នក ព្រមទាំងក្រុមផ្សេងទៀតក្រៅពីពួកគេដែលពួកអ្នកមិនស្គាល់ពួកគេនោះទេ តែអល់ឡោះទ្រង់ស្គាល់ពួកគេ។ ហើយអ្វីក៏ដោយដែលពួកអ្នកបានបរិច្ចាគក្នុងមាគ៌ារបស់អល់ឡោះនោះ ទ្រង់នឹងតបស្នងដល់ពួកអ្នកវិញជាមិនខាន ហើយពួកអ្នកមិនត្រូវបានគេបំពានឡើយ។

61. ហើយប្រសិនបើពួកគេ(សត្រូវ)ទោរទន់ទៅរកសន្តិភាព(ចរចាបញ្ចប់សង្គ្រាម)នោះ ដូច្នេះ អ្នកក៏ត្រូវទោរទន់ទៅរកសន្តិភាពវិញដែរ ហើយត្រូវប្រគល់ការទុកចិត្តលើអល់ឡោះ។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

62. តែប្រសិនបើពួកគេមានបំណង(ប្រើល្បិចកល)បោកប្រាស់អ្នក ជាការពិតណាស់ អល់ឡោះជាម្ចាស់(តែមួយគត់)គឺគ្រប់គ្រាន់ហើយសម្រាប់អ្នក។ ទ្រង់ជាអ្នកពង្រឹងដល់អ្នកតាមរយៈជំនួយរបស់ទ្រង់ និងតាមរយៈអ្នកមានជំនឿទាំងឡាយ។

63. ហើយទ្រង់បានបង្រួបបង្រួមរវាងដួងចិត្តរបស់ពួកគេ។ ទោះបីជាអ្នកបរិច្ចាគអ្វីដែលមាននៅលើផែនដីនេះទាំងអស់(ដើម្បីបង្រួបបង្រួមរវាងដួងចិត្តពួកគេ)ក៏ដោយ ក៏អ្នកមិនអាចបង្រួបបង្រួមរវាងដួងចិត្តពួកគេបាននោះដែរ។ ក៏ប៉ុន្តែ អល់ឡោះជាម្ចាស់ទៅវិញទេដែលអាចបង្រួបបង្រួមរវាងពួកគេបាន។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

64. ឱព្យាការី(មូហាំម៉ាត់)! អល់ឡោះជាម្ចាស់ និងអ្នកទាំងឡាយដែលដើរតាមអ្នកក្នុងចំណោមបណ្តាអ្នកមានជំនឿនោះ គឺគ្រប់គ្រាន់ហើយសម្រាប់អ្នក។

65. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកជំរុញបណ្តាអ្នកមានជំនឿលើការប្រយុទ្ធ។ ប្រសិនបើក្នុងចំណោមពួកអ្នកមានគ្នាត្រឹមតែម្ភៃនាក់ដែលជាអ្នកអត់ធ្មត់(ប្រយុទ្ធនឹងពួកប្រឆាំង)នោះ គឺអាចយកឈ្នះពីររយនាក់(នៃពួកប្រឆាំង)បាន។ ហើយប្រសិនបើក្នុងចំណោមពួកអ្នកមានគ្នាត្រឹមមួយរយនាក់ គឺអាចយកឈ្នះមួយពាន់នាក់នៃពួកប្រឆាំងបាន ដោយសារតែពួកគេ គឺជាក្រុមមួយដែលគ្មានការយល់ដឹង។

66. ពេលនេះ អល់ឡោះជាម្ចាស់ទ្រង់បានបន្ធូរបន្ថយដល់ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ព្រោះទ្រង់ដឹងថា ពួកអ្នកមានភាពទន់ខ្សោយ។ ដូច្នេះ ទ្រង់ក៏បានបន្ធូរបន្ថយដល់ពួកអ្នក ជាភាពទន់ភ្លន់(មេត្តាករុណា)របស់ទ្រង់ចំពោះពួកអ្នក។ ដូចនេះ ប្រសិនបើក្នុងចំណោមពួកអ្នកមានគ្នាមួយរយនាក់ដែលជាអ្នកអត់ធ្មត់នោះ គឺអាចយកឈ្នះពីររយនាក់(នៃពួកប្រឆាំង)បាន។ ហើយប្រសិនបើក្នុងចំណោមពួកអ្នកមានគ្នាមួយពាន់នាក់ គឺអាចយកឈ្នះ(ពួកប្រឆាំង)ពីរពាន់នាក់បានដោយការអនុញ្ញាតពីអល់ឡោះ។ ហើយអល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលអត់ធ្មត់។

67. មិនគប្បីឡើយចំពោះព្យាការី(មូហាំម៉ាត់)ក្នុងការទុកឈ្លើយសឹក រហូតទាល់តែគាត់បានសម្លាប់(ពួកប្រឆាំង)នៅលើផែនដីបានច្រើនសិន។ ពួកអ្នកចង់បានទ្រព្យសម្បត្តិ(ទទួលយកការលោះឈ្លើយសឹកក្នុងសង្គ្រាមហ្គាទើរ)តែអល់ឡោះជាម្ចាស់ទ្រង់ចង់(ផ្តល់ផលបុណ្យដល់ពួកអ្នក)នាថ្ងៃបរលោក។ ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

68. ប្រសិនបើគ្មានការកំណត់ពីអល់ឡោះពីមុនមក(ដែលអនុញ្ញាតឲ្យយកទ្រព្យជ័យភណ្ឌ និងការលោះឈ្លើយសឹក)ទេនោះ ពួកអ្នកប្រាកដជានឹងទទួលនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុតជាមិនខានចំពោះអ្វីដែលពួកអ្នកទទួលយក។

69. ដូច្នេះ ចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ទទួលទានចុះនូវអ្វីដែលបានមកពីទ្រព្យជ័យភណ្ឌដែលគេអនុញ្ញាត និងស្អាតស្អំ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

70. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកពោលទៅកាន់ឈ្លើយសឹក(មុស្លីគីន)ដែលនៅក្នុងដៃពួកអ្នកថា៖ ប្រសិនបើអល់ឡោះដឹងថា ក្នុងចិត្តរបស់ពួកអ្នកមានគោលបំណងល្អ ទ្រង់ច្បាស់ជានឹងផ្តល់ឱ្យពួកអ្នកនូវអ្វីដែលល្អប្រសើរជាងអ្វី(ទ្រព្យលោះខ្លួន)ដែលគេបានយកពីពួកអ្នកជាមិនខាន ហើយទ្រង់នឹងអភ័យទោសដល់ពួកអ្នកទៀតផង។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

71. តែប្រសិនបើពួកគេ(ឈ្លើយសឹកមុស្លីគីន)មានបំណងចង់ក្បត់អ្នក ពិតប្រាកដណាស់ ពួកគេក៏ធ្លាប់បានក្បត់អល់ឡោះពីមុនរួចហើយដែរ។ ប៉ុន្តែទ្រង់បានជួយ(អ្នក)ឱ្យយកឈ្នះលើពួកគេ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

72. ជាការពិតណាស់ បណ្តាអ្នកដែលមានជំនឿ និងបានធ្វើចំណាកស្រុក ព្រមទាំងបានតស៊ូ(ដោយចំណាយ)ទាំងទ្រព្យសម្បត្តិ និងខ្លួនប្រាណរបស់ពួកគេក្នុងមាគ៌ារបស់អល់ឡោះ(ពួកមូហាជីរីន) ហើយនិងបណ្តាអ្នកដែលបានផ្តល់ទីជម្រកនិងបានជួយដល់ពួកគេ(ពួកអាន់សរ)នោះ អ្នកទាំងនោះ គឺជាអ្នកគាំពារគ្នាទៅវិញទៅមក។ រីឯបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ តែមិនបានធ្វើចំណាកស្រុក គឺគ្មានកាតព្វកិច្ចលើពួកអ្នកក្នុងការជួយនិងការពារពួកគេនោះទេ លុះត្រាតែពួកគេធ្វើចំណាកស្រុក(ក្នុងមាគ៌ាអល់ឡោះ)ដែរ។ ហើយប្រសិនបើពួកគេសុំឱ្យពួកអ្នកជួយក្នុងនាមសាសនា គឺចាំបាច់លើពួកអ្នកត្រូវជួយ(ពួកគេ)លើកលែងតែរវាងពួកអ្នក និងពួកដែលបានចុះកិច្ចព្រមព្រៀងជាមួយពួកអ្នកប៉ុណ្ណោះ។ ហើយអល់ឡោះឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

73. ហើយពួកដែលគ្មានជំនឿ ពួកគេជាអ្នកគាំពារគ្នាទៅវិញទៅមក។ ប្រសិនបើពួកអ្នកធ្វើដូច្នោះ(យកពួកគ្មានជំនឿធ្វើជាអ្នកគាំពារ) នោះភាពវឹកវរ និងវិនាសកម្មយ៉ាងធំធេងនឹងកើតមាននៅលើផែនដីជាមិនខាន។

74. ហើយបណ្តាអ្នកដែលមានជំនឿ និងបានធ្វើចំណាកស្រុក ព្រមទាំងបានតស៊ូក្នុងមាគ៌ារបស់អល់ឡោះ(ពួកមូហាជីរីន) ហើយនិងបណ្តាអ្នកដែលបានផ្តល់ទីជម្រកនិងបានជួយដល់ពួកគេ(ពួកអាន់សរ) អ្នកទាំងនោះហើយ គឺជាអ្នកដែលមានជំនឿយ៉ាងពិតប្រាកដ។ សម្រាប់ពួកគេនឹងទទួលបានការអភ័យទោស និងលាភសក្ការៈដ៏ឧត្តុង្គឧត្តម(ឋានសួគ៌)។

75. ហើយបណ្តាអ្នកដែលមានជំនឿបន្ទាប់(ពីពួកមូហាជីរីន និងពួកអាន់សរ) ហើយពួកគេបានធ្វើចំណាកស្រុក ព្រមទាំងបានតស៊ូ(ក្នុងមាគ៌ាអល់ឡោះ)ជាមួយនឹងពួកអ្នក អ្នកទាំងនោះក៏ស្ថិតក្នុងចំណោមពួកអ្នកដែរ។ ហើយចំពោះសាច់សាលោហិតពួកគេសក្តិសមបំផុតចំពោះសិទ្ធិទទួលមរតកពីគ្នាទៅវិញទៅមកនៅក្នុងច្បាប់របស់អល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

ជំពូក អាត់តាវហ្គះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នេះគឺជាការកាត់ផ្តាច់ទំនាក់ទំនងរបស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ចំពោះអ្នកទាំងឡាយដែលពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)បានចុះកិច្ចព្រមព្រៀងជាមួយក្នុងចំណោមពួកមុស្លីគីន។

2. ដូច្នេះ ចូរពួកអ្នក(ឱពួកមុស្លីគីន)ធ្វើដំណើរនៅលើផែនដីរយៈពេលបួនខែ(ដោយសុវត្ថិភាព)ចុះ។ ហើយចូរពួកអ្នកដឹងចុះថា ជាការពិតណាស់ ពួកអ្នកនឹងមិនអាចគេចផុតពី(ទណ្ឌកម្ម)អល់ឡោះឡើយ ហើយជាការពិតណាស់ អល់ឡោះជាម្ចាស់ជាអ្នកធ្វើឱ្យពួកគ្មានជំនឿអាប់ឱន។

3. ហើយនេះជាសេចក្តីប្រកាសពីអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ទៅកាន់មនុស្សលោកទាំងអស់នាថ្ងៃបុណ្យហាជ្ជីធំ(ថ្ងៃទី១០ខែហ្ស៊ុលហិជ្ជះ)ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ និងអ្នកនាំសាររបស់ទ្រង់មិនពាក់ព័ន្ធនឹងពួកមុស្លីគីនទៀតឡើយ។ ដូច្នេះ ប្រសិនបើពួកអ្នក(ឱពួកមុស្លីគីន)សារភាពកំហុសនោះ វាជាការប្រសើរបំផុតសម្រាប់ពួកអ្នក។ តែប្រសិនបើពួកអ្នកងាកចេញវិញនោះ ចូរពួកអ្នកដឹងចុះថា ពួកអ្នកពិតជាមិនអាចគេផុតពីអល់ឡោះជាម្ចាស់ឡើយ។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងដល់ពួកគ្មានជំនឿនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

4. លើកលែងតែពួកមុស្លីគីនទាំងឡាយណាដែលពួកអ្នកបានចុះកិច្ចព្រមព្រៀងជាមួយពួកគេ ក្រោយមក ពួកគេមិនបានបំពាននូវប្រការណាមួយចំពោះពួកអ្នក(ក្នុងកិច្ចព្រមព្រៀងនោះ)ហើយពួកគេក៏មិនបានគាំទ្រនរណាម្នាក់ប្រឆាំងនឹងពួកអ្នកនោះដែរ។ ដូច្នេះ ចូរពួកអ្នកបំពេញនូវកិច្ចព្រមព្រៀងនោះដល់ពួកគេរហូតដល់ពេលកំណត់របស់ពួកគេចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បណ្តាអ្នកដែលកោតខ្លាច។

5. ដូចនេះ បើកាលណាបណ្តាខែពិសិដ្ឋ(ដែលពួកអ្នកបានឱ្យពួកមុស្លីគីនមានសុវត្ថិភាពនោះ)បានបញ្ចប់ ចូរពួកអ្នកសម្លាប់ពួកមុស្លីគីនចុះនៅកន្លែងណាក៏ដោយដែលពួកអ្នកបានជួបពួកគេ ហើយចូរពួកអ្នកចាប់ពួកគេជាឈ្លើយសឹក និងឡោមព័ទ្ធពួកគេ ព្រមទាំងចាំឃ្លាំមើលពួកគេគ្រប់ទីកន្លែង។ តែប្រសិនបើពួកគេសារភាពកំហុស ហើយប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់នោះ ដូច្នេះ ចូរពួកអ្នកបោះបង់(បញ្ឈប់)ការសម្លាប់ពួកគេចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

6. ហើយប្រសិនបើនរណាម្នាក់ក្នុងចំណោមពួកមុស្លីគីនបានសុំឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជួយការពាររូបគេនោះ ចូរអ្នកឆ្លើយតបចំពោះសំណើរបស់គេចុះដើម្បីឱ្យគេបានស្តាប់បន្ទូលរបស់អល់ឡោះ(គម្ពីរគួរអាន)។ ក្រោយមក ចូរអ្នកនាំគេទៅកាន់កន្លែងដែលមានសុវត្ថិភាពចុះ។ នោះគឺដោយតែពួកគេ គឺជាក្រុមមួយដែលមិនយល់ដឹងឡើយ។

7. មិនត្រឹមត្រូវទេដែលពួកមុស្លីគីនមានកិច្ចព្រមព្រៀងជាមួយអល់ឡោះនិងជាមួយអ្នកនាំសាររបស់ទ្រង់នោះ លើកលែងតែអ្នកទាំងឡាយដែលពួកអ្នក(ឱអ្នកមូស្លីម)បានចុះកិច្ចព្រមព្រៀងជាមួយពួកគេនៅឯម៉ាស្ជិតអាល់ហារ៉ែមប៊ុណ្ណោះ។ ដូច្នេះ ប្រសិនបើពួកគេនៅតែគោរពកិច្ចព្រមព្រៀងជាមួយពួកអ្នកនោះ ចូរពួកអ្នកគោរពកិច្ចព្រមព្រៀងជាមួយពួកគេវិញចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បណ្តាអ្នកដែលកោតខ្លាច។

8. តើ(ពួកគេអាចមានកិច្ចព្រមព្រៀងពីអល់ឡោះ)យ៉ាងដូចម្តេច បើនៅពេលដែលពួកគេមានប្រៀបលើពួកអ្នក គឺពួកគេមិនខ្វល់ថាពួកអ្នកជាសាច់ញាតិ ហើយក៏មិនខ្វល់ថាពួកអ្នកមានកិច្ចព្រមព្រៀង(ជាមួយពួកគេ)ផងនោះ? ពួកគេយល់ព្រមជាមួយពួកអ្នកតែនឹងមាត់របស់ពួកគេប៉ុណ្ណោះ តែចិត្តរបស់ពួកគេវិញ គឺបដិសេធ។ ហើយភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស។

9. ពួកគេបានយកបណ្តាវាក្យខណ្ឌរបស់អល់ឡោះប្តូរនឹងកម្រៃបន្តិចបន្តួច។ ពិតណាស់ ពួកគេបានរារាំង(ខ្លួនឯង និងរារាំងអ្នកដទៃ)ពីមាគ៌ារបស់ទ្រង់។ ពិតប្រាកណាស់ អ្វីដែលពួកគេប្រព្រឹត្តនោះ គឺអាក្រក់បំផុត។

10. ពួកគេមិនខ្វល់ថាអ្នកមានជំនឿនោះជាជាសាច់ញាតិ(ពួកគេ) ឬមានកិច្ចព្រមព្រៀង(ជាមួយពួកគេ)នោះឡើយ។ ហើយពួកគេ គឺជាពួកដែលបំពាន។

11. ហើយប្រសិនបើពួកគេសារភាពកំហុស និងប្រតិបត្តិសឡាត ព្រមទាំងបរិច្ចាគហ្សាកាត់នោះ ពិតប្រាកដណាស់ ពួកគេគឺជាបងប្អូនរួមសាសនារបស់ពួកអ្នក។ ហើយយើងបកស្រាយបញ្ជាក់នូវបណ្តាវាក្យខណ្ឌរបស់យើងសម្រាប់ក្រុមដែលយល់ដឹង។

12. តែប្រសិនបើពួកគេបានរំលោយកិច្ចព្រមព្រៀងរបស់ពួកគេក្រោយពីបានចុះកិច្ចព្រមព្រៀង(ជាមួយពួកអ្នក) ព្រមទាំងបានមើលងាយសាសនារបស់ពួកអ្នក ចូរពួកអ្នកប្រយុទ្ធនឹងពួកមេដឹកនាំនៃពួកប្រឆាំងចុះ។ ពិតប្រាកដណាស់ គ្មានកិច្ចព្រមព្រៀងអ្វីសម្រាប់ពួកគេទៀតនោះឡើយ។ សង្ឃឹមថាពួកគេនឹងបញ្ឈប់(ទង្វើទាំងនោះ)។

13. ហេតុអ្វីបានជាពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)មិនប្រយុទ្ធនឹងក្រុមមួយដែលបានរំលោយកិច្ចព្រមព្រៀងរបស់ពួកគេ និងមានបំណងបណ្តេញអ្នកនាំសារ(ចេញពីក្រុងម៉ាក្កៈ)ព្រមទាំងពួកគេជាពួកដែលផ្តើមប្រយុទ្ធនឹងពួកអ្នកដំបូងគេបង្អស់នោះ? តើពួកអ្នកខ្លាចពួកគេឬ? ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទៅវិញទេដែលសក្តិសមនឹងពួកអ្នកខ្លាចទ្រង់នោះ ប្រសិនបើពួកអ្នក គឺជាអ្នកដែលមានជំនឿមែននោះ។

14. ចូរពួកអ្នកប្រយុទ្ធនឹងពួកគេចុះ។ អល់ឡោះជាម្ចាស់នឹងដាក់ទណ្ឌកម្មពួកគេដោយស្នាដៃរបស់ពួកអ្នក និងធ្វើឱ្យពួកគេអាប់ឱន ព្រមទាំងជួយពួកអ្នកឱ្យយកឈ្នះលើពួកគេ ហើយនិងធ្វើឱ្យទុក្ខកង្វល់ទាំងឡាយសោយចេញពីដួងចិត្តក្រុមដែលមានជំនឿ។

15. ហើយទ្រង់នឹងធ្វើឱ្យកំហឹងរសាយចេញពីដួងចិត្តរបស់ពួកគេ(អ្នកមានជំនឿ)ផងដែរ។ ហើយអល់ឡោះនឹងទទួលយកនូវការសារភាពកំហុសចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

16. តើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)នឹកស្មានថា ពួកអ្នកត្រូវបានគេបោះបង់(មិនទទួលសាកល្បងពីអល់ឡោះ)ឬ? (ពួកអ្នកពិតជានឹងត្រូវបានគេសាកល្បង) ដើម្បីឱ្យអល់ឡោះដឹងច្បាស់ថា តើអ្នកណាដែលតស៊ូ(ប្រយុទ្ធ)ក្នុងចំណោមពួកអ្នក ហើយពួកគេមិនយកអ្នកផ្សេងក្រៅពីអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងអ្នកមានជំនឿធ្វើជាអ្នកគាំពារឡើយ។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

17. មិនសក្តិសមឡើយសម្រាប់ពួកមុស្លីគឺនក្នុងការកសាងនិងថែទាំបណ្តាម៉ាស្ជិតរបស់អល់ឡោះ ទាំងដែលពួកគេជាអ្នកដែលទទួលស្គាល់លើខ្លួនឯងនូវភាពគ្មានជំនឿនោះ។ ពួកទាំងនោះ ទង្វើរបស់ពួកគេនឹងក្លាយជាអសារបង់ ហើយពួកគេនឹងត្រូវស្ថិតក្នុងឋាននរកជាអមតៈ។

18. តាមពិតអ្នកដែល(សក្តិសមក្នុងការ)កសាងនិងថែទាំបណ្តាម៉ាស្ជិតរបស់អល់ឡោះ គឺអ្នកដែលមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោក ហើយពួកគេប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយពួកគេមិនខ្លាច(នរណាម្នាក់)ក្រៅពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ អ្នកទាំងនោះ សង្ឃឹមថាជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលទទួលបានការចង្អុលបង្ហាញ។

19. តើពួកអ្នក(ឱពួកមុស្លីគីន)ចាត់ទុកការផ្គត់ផ្គង់ទឹកដល់អ្នកដែលធ្វើហាជ្ជី និងការថែទាំម៉ាស្ជិតអាល់ហារ៉ែម ដូចគ្នានឹងអ្នកដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ព្រមទាំងតស៊ូ(ប្រយុទ្ធ)ក្នុងមាគ៌ារបស់អល់ឡោះឬ? ពួកគេ(ទាំងពីរក្រុម)មិនស្មើគ្នានោះឡើយចំពោះអល់ឡោះជាម្ចាស់។ ហើយអល់ឡោះទ្រង់មិនចង្អុលបង្ហាញក្រុមដែលបំពានឡើយ។

20. បណ្តាអ្នកដែលមានជំនឿ និងបានធ្វើចំណាកស្រុក ព្រមទាំងបានតស៊ូក្នុងមាគ៌ារបស់អល់ឡោះដោយទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកគេនោះ គឺមានឋានៈខ្ពង់ខ្ពស់បំផុតនៅឯអល់ឡោះជាម្ចាស់។ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានជោគជ័យ។

21. ព្រះជាម្ចាស់របស់ពួកគេបានផ្តល់ដំណឹងរីករាយដល់ពួកគេពីក្តីមេត្តាករុណាអំពីទ្រង់ និងការពេញចិត្ត(របស់ទ្រង់ចំពោះពួកគេ)ព្រមទាំងឋានសួគ៌ ដោយពួកគេទទួលបាននូវបរមសុខគ្មានទីបញ្ចប់ឡើយនៅក្នុងវា។

22. ពួកគេស្ថិតនៅទីនោះជាអមតៈ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មានផលបុណ្យដ៏ធំធេងបំផុត។

23. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកដីដូនដីតារបស់ពួកអ្នក និងបងប្អូនរបស់ពួកអ្នកធ្វើជាអ្នកគាំពារឱ្យសោះ ដរាបណាពួកគេពេញចិត្តភាពគ្មានជំនឿជាងការមានជំនឿនោះ។ ហើយជនណាដែលយកពួកគេធ្វើជាអ្នកគាំពារក្នុងចំណោមពួកអ្នក ពិតប្រាកដណាស់ ពួកទាំងនោះ គឺជាពួកដែលបំពាន។

24. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើឪពុកម្តាយរបស់ពួកអ្នក(ឱអ្នកមានជំនឿ) កូនចៅរបស់ពួកអ្នក បងប្អូនរបស់ពួកអ្នក ប្រពន្ធរបស់ពួកអ្នក សាច់ញាតិរបស់ពួកអ្នក និងទ្រព្យសម្បត្តិរបស់ពួកអ្នកដែលពួកអ្នកខិតខំប្រមូលហើយនិងជំនួញដែលពួកអ្នកខ្លាចខាតបង់វា ព្រមទាំងលំនៅឋាន(របស់ពួកអ្នក)ដែលពួកអ្នកពេញចិត្តវានោះ ជាទីស្រលាញ់ពេញចិត្តចំពោះពួកអ្នកជាងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយនិងការតស៊ូក្នុងមាគ៌ារបស់ទ្រង់នោះ ចូរពួកអ្នករង់ចាំចុះ រហូតដល់កិច្ចការ(ទណ្ឌកម្ម)របស់ទ្រង់បានមកដល់។ ហើយអល់ឡោះជាម្ចាស់ទ្រង់មិនចង្អុលបង្ហាញក្រុមដែលប្រព្រឹត្តល្មើសឡើយ។

25. ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានជួយពួកអ្នកក្នុងសមរភូមិជាច្រើន។ ហើយនៅថ្ងៃសមរភូមិហ៊ូណែនវិញ នៅពេលដែលចំនួនដ៏ច្រើនរបស់ពួកអ្នកបានធ្វើឱ្យពួកអ្នកមានមោទនភាព ក៏ប៉ុន្តែវាមិនបានផ្តល់ផលប្រយោជន៍អ្វីបន្តិចដល់ពួកអ្នកនោះឡើយ។ ហើយផែនដីដែលធំទូលាយប្រៃជាតូចចង្អៀតសម្រាប់ពួកអ្នក។ ក្រោយមក ពួកអ្នកបានរត់បកក្រោយ(ចេញពីសត្រូវ)។

26. បន្ទាប់មក អល់ឡោះជាម្ចាស់បានបញ្ចុះភាពនឹងនរបស់ទ្រង់ទៅលើអ្នកនាំសាររបស់ទ្រង់ និងទៅលើបណ្តាអ្នកដែលមានជំនឿ។ ហើយទ្រង់បានបញ្ចុះកងទ័ព(ម៉ាឡាអ៊ីកាត់)ជាច្រើនដែលពួកអ្នកមើលមិនឃើញពួកគេ(ឱ្យមកជួយពួកអ្នក) ហើយទ្រង់បានដាក់ទណ្ឌកម្មពួកដែលប្រឆាំង។ ហើយនោះ គឺជាការតបស្នងចំពោះពួកដែលប្រឆាំង។

27. ក្រោយមក អល់ឡោះជាម្ចាស់ទ្រង់បានទទួលយកនូវការសោកស្តាយកំហុសបន្ទាប់ពីនោះចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

28. ឱបណ្តាអ្នកដែលមានជំនឿ! ពិតប្រាកដណាស់ ពួកមុស្លីគីន គឺមានភាពកខ្វក់។ ហេតុនេះ ចូរកុំឱ្យពួកគេចូលក្នុងម៉ាស្ជិតអាល់ហារ៉ម(ទឹកដីម៉ាក្កៈ)ឲ្យសោះបន្ទាប់ពីឆ្នាំនេះទៅ(ឆ្នាំទីប្រាំបួនហិជ្រ៉ាៈ)។ ហើយប្រសិនបើពួកអ្នក(ឱអ្នកមានជំនឿ)បារម្ភខ្លាចភាពក្រីក្រនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងផ្តល់ភាពគ្រប់គ្រាន់ដល់ពួកអ្នកដោយភាពសប្បុរសរបស់ទ្រង់ ប្រសិនបើទ្រង់មានចេតនា។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិត។

29. ចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ប្រយុទ្ធនឹងពួកដែលគេផ្តល់គម្ពីរឲ្យ(ពួកយូដា និងគ្រីស្ទាន)ដែលមិនមានជំនឿចំពោះអល់ឡោះ ហើយក៏គ្មានជំនឿចំពោះថ្ងៃបរលោក និងមិនចៀសវាងពីប្រការទាំងឡាយដែលអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់បានហាមឃាត់ ព្រមទាំងមិនប្រកាន់ខ្ជាប់នូវសាសនាដ៏ត្រឹមត្រូវ(សាសនាអ៊ីស្លាម)រហូតដល់ពួកគេព្រមបង់ពន្ធដោយផ្ទាល់ដៃរបស់ពួកគេដោយភាពចុះញ៊ូម។

30. ហើយពួកយូដាបាននិយាយថាៈ អ៊ូហ៊ៃរ៍ គឺជាបុត្ររបស់អល់ឡោះ។ ចំណែកឯពួកគ្រីស្ទានវិញបាននិយាយថាៈ អាល់ម៉ាសៀហ(យេស៊ូគ្រីស្ទ) គឺជាបុត្ររបស់អល់ឡោះ។ នោះគឺគ្រាន់តែជាពាក្យសម្តី(ប្រឌិត)ដែលចេញពីមាត់របស់ពួកគេប៉ុណ្ណោះ។ វាដូចគ្នាទៅនឹងពាក្យសម្តីរបស់ពួកប្រឆាំងជំនាន់មុនដូច្នោះដែរ។ អល់ឡោះក៏បានបំផ្លាញពួកគេ។ តើពួកគេត្រូវបានគេបង្វែរចេញ(ពីសេចក្តីពិត)យ៉ាងដូចម្តេច?

31. ពួកគេបានយកអ្នកចេះដឹងរបស់ពួកគេ និងពួកបុព្វជិតរបស់ពួកគេធ្វើជាព្រះជាម្ចាស់ក្រៅពីអល់ឡោះ ព្រមទាំងបានយកអាល់ម៉ាសៀហ(ព្យាការីអ៊ីសា)កូនប្រុសរបស់ម៉ារយ៉ាំ(ធ្វើជាព្រះផងដែរ)។ ហើយគេមិនបានប្រើពួកគេនោះឡើយលើកលែងតែឲ្យពួកគេគោរពសក្ការៈចំពោះព្រះជាម្ចាស់តែមួយគត់។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់មហាស្អាតស្អំបំផុតអំពីអ្វីដែលពួកគេកំពុងតែធ្វើស្ហ៊ីរិក។

32. ពួកគេមានបំណងចង់ពន្លត់ពន្លឺរបស់អល់ឡោះ(សាសនាអ៊ីស្លាម)ដោយមាត់របស់ពួកគេ តែអល់ឡោះបដិសេធ(មិនឱ្យគោលបំណងរបស់ពួកគេបានសម្រេចឡើយ)។ ផ្ទុយទៅវិញ ទ្រង់បំពេញពន្លឺរបស់ទ្រង់ ទោះបីជាពួកប្រឆាំងមិនពេញចិត្តក៏ដោយ។

33. ទ្រង់ជាអ្នកដែលបានបញ្ជូនអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ដោយនាំមកនូវការចង្អុលបង្ហាញ(គម្ពីរគួរអាន)និងសាសនាពិត(សាសនាអ៊ីស្លាម)ដើម្បីឱ្យសាសនានេះមានភាពខ្ពង់ខ្ពស់លើសសាសនាដទៃទៀតទាំងអស់ បើទោះបីជាពួកមុស្លីគីនមិនពេញចិត្តក៏ដោយ។

34. ឱបណ្តាអ្នកដែលមានជំនឿ! ជាការពិតណាស់ ភាគច្រើននៃអ្នកចេះដឹងរបស់ពួកយូដា និងពួកបុព្វជិតរបស់ពួកគ្រីស្ទាន គឺពួកគេយកទ្រព្យសម្បត្តិមនុស្សលោកដោយខុសច្បាប់ ថែមទាំងបានរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះ។ ចំណែកពួកដែលប្រមែប្រមូលមាសប្រាក់ ហើយមិនបានចេញហ្សាកាត់វាក្នុងមាគ៌ារបស់អល់ឡោះទេនោះ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងដល់ពួកគេនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

35. នៅថ្ងៃ(បរលោក)ដែលគេយកមាសប្រាក់នោះទៅដុតក្នុងភ្លើងនរកដើហាន់ណាំ រួចគេយកវាទៅដុតរោលលើថ្ងាស ចំហៀងខ្លួន និងខ្នងរបស់ពួកគេ។ (ហើយមានគេនិយាយទៅកាន់ពួកគេថាៈ) នេះហើយជាអ្វីដែលពួកអ្នកខំប្រមែប្រមូលទុកសម្រាប់ខ្លួនឯងនោះ។ ដូចនេះ ចូរពួកអ្នកភ្លក់ចុះនូវអ្វីដែលពួកអ្នកខិតខំប្រមែប្រមូលទុកនោះ។

36. ពិតប្រាកដណាស់ ចំនួនខែ(ក្នុងមួយឆ្នាំ)នៅឯអល់ឡោះជាម្ចាស់នោះ គឺមានចំនួនដប់ពីរខែដែលបានចារទុកនៅក្នុងគម្ពីររបស់អល់ឡោះ(ឡាវ៉ហ៊ុលម៉ះហ្វ៊ូស)តាំងពីថ្ងៃដែលទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដីមកម្ល៉េះ។ ក្នុងចំណោមនោះ គឺមានបួនខែជាខែបម្រាម។ នោះហើយគឺជាសាសនាដ៏ត្រឹមត្រូវ។ ហេតុនេះ ចូរពួកអ្នកកុំបំពានខ្លួនឯងនៅក្នុងបណ្តាខែទាំងនោះឱ្យសោះ។ ហើយចូរពួកអ្នកប្រយុទ្ធនឹងពួកមុស្លីគីនទាំងអស់ដូចដែលពួកគេបានប្រយុទ្ធនឹងពួកអ្នកទាំងអស់គ្នាដែរ។ ហើយចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលកោតខ្លាច។

37. តាមពិត ការលើកខែបម្រាម(ទៅកាន់ខែផ្សេង)គឺកាន់តែបន្ថែមភាពគ្មានជំនឿ(ដល់ពួកគេ)។ ហើយដោយសារការលើកខែនេះ ពួកគ្មានជំនឿត្រូវបានគេ(ស្ហែតន)ធ្វើឲ្យវង្វេង ដោយពួកគេបានអនុញ្ញាតឱ្យ(ធ្វើសង្គ្រាម)ក្នុងខែបម្រាមមួយឆ្នាំដោយជំនួសនូវខែបម្រាមនេះទៅឆ្នាំក្រោយវិញដើម្បីឱ្យស្របនឹងចំនួនខែបម្រាមដែលអល់ឡោះទ្រង់បានដាក់បម្រាម(មិនឱ្យធ្វើសង្គ្រាម)។ ដូចនេះ ពួកគេបានអនុញ្ញាតនូវអ្វីដែលអល់ឡោះបានហាមឃាត់។ គេ(ស្ហែតន)បានតុបតែងលម្អសម្រាប់ពួកគេនូវអំពើអាក្រក់ទាំងឡាយរបស់ពួកគេ។ ហើយអល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលប្រឆាំងឡើយ។

38. ឱបណ្តាអ្នកដែលមានជំនឿ! តើមានរឿងអ្វីចំពោះពួកអ្នកបានជានៅពេលដែលមានគេនិយាយទៅកាន់ពួកអ្នកថាៈ ចូរពួកអ្នកចេញទៅប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះ ពួកអ្នកបែរជាខ្ជិលច្រអូស និងបន្តស្ថិតក្នុងលំនៅឋានរបស់ពួកអ្នកទៅវិញ? តើពួកអ្នកពេញចិត្តនឹងជីវិតលោកិយជាង(ការសោយសុខនៅ)ថ្ងៃបរលោកឬ? ជាការពិតណាស់ ភាពត្រេកត្រអាលនៃជីវិតលោកិយនេះ មិនអាចប្រៀបនឹងថ្ងៃបរលោកបានឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

39. ប្រសិនបើពួកអ្នកមិនចេញទៅប្រយុទ្ធទេនោះ ទ្រង់ប្រាកដជានឹងដាក់ទណ្ឌកម្មពួកអ្នកនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត ហើយទ្រង់នឹងជំនួសក្រុមមួយផ្សេងក្រៅពីពួកអ្នកជាមិនខាន ហើយពួកអ្នកក៏មិនអាចបង្កគ្រោះថ្នាក់អ្វីបន្តិចដល់ទ្រង់នោះឡើយ។ ហើយអល់ឡោះទ្រង់មានសមត្ថភាពលើអ្វីៗទាំងអស់។

40. ប្រសិនបើពួកអ្នកមិនជួយដល់គាត់(ព្យាការីមូហាំម៉ាត់)ទេនោះ ពិតប្រាកដណាស់ អល់ឡោះបានជួយដល់គាត់(រួចទៅហើយ)ខណៈពេលដែលពួកគ្មានជំនឿបានបណ្តេញគាត់ និងអាពូហ្គាកើរ នៅពេលដែលគាត់ទាំងពីរស្ថិតក្នុងរូងភ្នំ(ស៊ូរ)។ ពេលនោះ គាត់បាននិយាយទៅកាន់មិត្តរបស់គាត់(អាពូហ្គាកើរ)ថាៈ ចូរអ្នកកុំព្រួយ! ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយពួកយើង(ទ្រង់គាំទ្រ និងជួយពួកយើង)។ ខណៈនោះ អល់ឡោះជាម្ចាស់ក៏បានបញ្ចុះនូវភាពនឹងនរបស់ទ្រង់ទៅកាន់គាត់ ហើយទ្រង់បានពង្រឹងដល់គាត់តាមរយៈកងទ័ព(ម៉ាឡាអ៊ីកាត់)យ៉ាងច្រើនដែលពួកអ្នកមិនអាចមើលឃើញពួកគេបាន។ ហើយទ្រង់បានធ្វើឱ្យពាក្យពេចន៍របស់ពួកប្រឆាំងទាបថោកបំផុត។ រីឯពាក្យបន្ទូលរបស់អល់ឡោះវិញ គឺខ្ពង់ខ្ពស់ឡើង។ ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

41. ចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ចេញទៅប្រយុទ្ធទាំងក្នុងពេលងាយស្រួល និងពេលលំបាក ហើយចូរពួកអ្នកតស៊ូប្រយុទ្ធដោយទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកអ្នកក្នុងមាគ៌ារបស់អល់ឡោះ។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង។

42. ប្រសិនបើវា(ការធ្វើដំណើរដែលអ្នកអំពាវនាវពួកគេទៅកាន់នោះ)ជាទ្រព្យដ៏យកណ្តាដែលនៅជិត(ងាយយកបាន)ហើយការធ្វើដំណើរមិនលំបាកទេនោះ ប្រាកដជាពួកគេ(ពួកពុតត្បុត)នឹងគោរពតាមអ្នក(ចេញទៅប្រយុទ្ធជាមួយអ្នក)ជាមិនខាន។ ក៏ប៉ុន្តែ ផ្លូវធ្វើដំណើរ គឺវែងឆ្ងាយ លំបាកដល់ពួកគេ(ទើបពួកគេមិនចេញទៅជាមួយពួកអ្នក)។ ហើយពួកគេនឹងស្បថ(កុហក)ចំពោះអល់ឡោះថាៈ ប្រសិនបើពួកយើងមានលទ្ធភាពនោះ ពួកយើងប្រាកដជានឹងចេញទៅ(ប្រយុទ្ធ)ជាមួយពួកអ្នកជាមិនខានឡើយ។ ពួកគេកំពុងតែបំផ្លាញខ្លួនឯង។ ហើយអល់ឡោះទ្រង់ដឹងបំផុតថា ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។

43. អល់ឡោះជាម្ចាស់បានអភ័យទោសដល់អ្នក(ចំពោះការដែលអ្នកអនុញ្ញាតឱ្យពួកគេមិនចេញទៅប្រយុទ្ធ)។ ហេតុអ្វីបានជាអ្នកអនុញ្ញាតឱ្យពួកគេ(មិនចេញទៅប្រយុទ្ធ)បែបនេះ? លុះត្រាតែអ្នកដឹងច្បាស់ថា អ្នកណាដែលស្មោះត្រង់ និងដឹងថាអ្នកណាដែលភូតកុហកសិន។

44. បណ្ដាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងថ្ងៃបរលោក គឺគ្មានហេតុផលអ្វីដែលពួកគេសុំអនុញ្ញាតពីអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនចេញទៅតស៊ូប្រយុទ្ធ(ក្នុងមាគ៌ាអល់ឡោះ)ដោយទ្រព្យសម្បត្តិ និងខ្លួនប្រាណរបស់ពួកគេនោះឡើយ។ ហើយអល់ឡោះទ្រង់ដឹងបំផុតចំពោះបណ្ដាអ្នកដែលកោតខ្លាច។

45. តាមពិត ពួកដែលសុំអនុញ្ញាតពីអ្នក(មិនចេញទៅប្រយុទ្ធ)នោះ គឺជាពួកដែលគ្មានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ហើយដួងចិត្តរបស់ពួកគេមានការមន្ទិលសង្ស័យ។ ហើយពួកគេមានភាពស្ទាក់ស្ទើរដោយសារតែភាពសង្ស័យរបស់ខ្លួន។

46. ហើយប្រសិនបើពួកគេពិតជាមានបំណងចង់ចេញ(ទៅប្រយុទ្ធ)មែននោះ ប្រាកដជាពួកគេរៀបចំខ្លួន(សម្រាប់ការប្រយុទ្ធ)ជាមិនខានឡើយ។ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់មិនពេញចិត្តឱ្យពួកគេចាកចេញ(ទៅប្រយុទ្ធជាមួយអ្នក)ឡើយ។ ដូច្នេះ ទ្រង់បានធ្វើឱ្យពួកគេមានភាពខ្ជិលច្រអូស។ ហើយមានគេនិយាយថា៖ ចូរពួកអ្នកស្នាក់នៅជាមួយអ្នកស្នាក់នៅផ្ទះទាំងឡាយចុះ។

47. ប្រសិនបើពួកគេចេញទៅ(ប្រយុទ្ធ)ជាមួយពួកអ្នក ក៏ពួកគេគ្មានបានបន្ថែមអ្វីដល់ពួកអ្នកក្រៅពីបង្កគ្រោះថ្នាក់នោះដែរ ហើយពួកគេរួសរាន់ក្នុងការចូលជួររបស់ពួកអ្នកដើម្បីបង្កនូវភាពវឹកវរដល់ពួកអ្នកប៉ុណ្ណោះ។ ហើយក្នុងចំណោមពួកអ្នក គឺមានអ្នកដែលស្ដាប់តាមពួកគេផងដែរ។ ហើយអល់ឡោះដឹងបំផុតចំពោះពួកដែលបំពាន។

48. ជាការពិតណាស់ ពួកគេ(ពួកពុតត្បុត)ធ្លាប់បានព្យាយាមបង្កភាពវឹកវរតាំងពីមុន(សង្គ្រាមតាពូក)មកម្ល៉េះ ហើយពួកគេបានរៀបចំឧបាយកលជាច្រើនប្រភេទប្រឆាំងនឹងអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រហូតទាល់តែការពិត(ជំនួយពីអល់ឡោះ)មកដល់។ ហើយកិច្ចការរបស់អល់ឡោះ(សាសនាអ៊ីស្លាម)បានស្ដែងឡើង ខណៈដែលពួកគេមិនពេញចិត្តនោះឡើយ។

49. ហើយក្នុងចំណោមពួកគេ មានអ្នកដែលនិយាយថា៖ ឱអ្នកនាំសាររបស់អល់ឡោះ! សូមអ្នកអនុញ្ញាតដល់ខ្ញុំ(មិនចេញទៅធ្វើសង្គ្រាម)ផង ហើយសូមអ្នកកុំធ្វើឲ្យខ្ញុំទទួលនូវភាពវឹកវរ។ តើពុំមែនទេឬ ពួកគេបានធ្លាក់ក្នុងភាពវឹកវររួចទៅហើយ។ ហើយពិតប្រាកដណាស់ នរកជើហាន់ណាំនឹងហ៊ុមព័ទ្ធពួកដែលប្រឆាំង។

50. ប្រសិនបើអ្នកទទួលបាននូវប្រការល្អ គឺធ្វើឲ្យពួកគេ(ពួកពុតត្បុត)មិនពេញចិត្តឡើយ។ តែប្រសិនបើអ្នកទទួលរងនូវគ្រោះថ្នាក់វិញនោះ ពួកគេនិយាយថា៖ ពួកយើងបានការពារខ្លួនរបស់ពួកយើង (ដោយមិនចេញទៅប្រយុទ្ធ)តាំងពីមុន។ ហើយពួកគេនាំគ្នាបែរចេញទាំងសប្បាយរីករាយ។

51. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ គ្មានអ្វីដែលប៉ះពាល់មកលើពួកយើងឡើយ លើកលែងតែអ្វីដែលអល់ឡោះទ្រង់បានចារកំណត់សម្រាប់ពួកយើងប៉ុណ្ណោះ។ ទ្រង់ជាអ្នកគាំពារពួកយើង។ ហើយចំពោះទ្រង់(តែមួយគត់)ដែលបណ្ដាអ្នកមានជំនឿប្រគល់ការទុកចិត្ត។

52. ចូរអ្នកពោលថា៖ តើពួកអ្នករង់ចាំឱ្យកើតឡើងចំពោះពួកយើងដែលគ្មានអ្វីក្រៅពីប្រការល្អមួយក្នុងចំណោមប្រការល្អទាំងពីរ(ទទួលជ័យជម្នះ ឬពលីជីវិត))នោះឬ? រីឯពួកយើងវិញ ក៏កំពុងរង់ចាំមើលអ្វីដែលកើតឡើងចំពោះពួកអ្នកដែរ ដោយអល់ឡោះឲ្យពួកអ្នកទទួលនូវទណ្ឌកម្មពីទ្រង់ ឬ(ដាក់ទណ្ឌកម្មពួកអ្នក)ដោយស្នាដៃពួកយើងផ្ទាល់។ ហេតុនេះ ចូរពួកអ្នករង់ចាំមើលចុះ។ ពិតណាស់ ពួកយើងក៏ជាអ្នករង់ចាំមើលជាមួយពួកអ្នកដែរ។

53. ចូរអ្នកពោលថា៖ ចូរពួកអ្នកធ្វើការបរិច្ចាគចុះ។ ទោះបី(ពួកអ្នកបរិច្ចាគ)ដោយពេញចិត្ត ឬមិនពេញចិត្តក៏ដោយ ក៏គេ(អល់ឡោះ)មិនទទួលយកពីពួកអ្នកដែរ ពីព្រោះពួកអ្នកគឺជាក្រុមដែលធ្លាប់ប្រព្រឹត្តល្មើស។

54. ហើយគ្មានអ្វីដែលរារាំងពួកគេមិនឱ្យគេ(អល់ឡោះ)ទទួលយកការបរិច្ចាគពីពួកគេនោះឡើយ លើកលែងតែដោយសារពួកគេប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយពួកគេមិនប្រតិបត្តិសឡាតឡើយ លើកលែងតែដោយភាពខ្ជិលច្រអូស ហើយពួកគេក៏មិនបរិច្ចាគទាននោះដែរ លើកលែងតែពួកគេ(បរិច្ចាគទាំង)មិនពេញចិត្តប៉ុណ្ណោះ។

55. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំឱ្យទ្រព្យសម្បត្តិរបស់ពួកគេ និងកូនចៅរបស់ពួកគេធ្វើឱ្យអ្នកចាប់អារម្មណ៍ឱ្យសោះ។ តាមពិត អល់ឡោះទ្រង់មានបំណងដាក់ទណ្ឌកម្មពួកគេតាមរយៈប្រការទាំងនេះនៅក្នុងជីវិតលោកិយ ហើយទ្រង់ដកយកជីវិតពួកគេ ខណៈដែលពួកគេជាពួកដែលប្រឆាំង។

56. ហើយពួកគេ(ពួកពុតត្បុត)ស្បថនឹងអល់ឡោះថា ពិតប្រាកដណាស់ ពួកគេស្ថិតក្នុងចំណោមពួកអ្នក ខណៈដែលពួកគេមិនមែនស្ថិតក្នុងចំណោមពួកអ្នកនោះឡើយ។ ប៉ុន្តែពួកគេ គឺជាក្រុមដែលភ័យខ្លាច។

57. ប្រសិនបើពួកគេមានកន្លែងជ្រកកោន ឬមានរូងភ្នំ ឬក៏មានរូងក្រោមដី(ដែលអាចលាក់ខ្លួនបាននោះ) ពួកគេប្រាកដជានឹងទៅរកទីនោះជាមិនខាន។ ហើយពួកគេនឹងចូលទៅទាំងប្រញាប់ប្រញាល់បំផុត។

58. ហើយក្នុងចំណោមពួកគេមានអ្នកដែលរិះគន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ក្នុងរឿង(បែងចែក)ទ្រព្យបរិច្ចាគទាន។ ពិតប្រាកដណាស់ ប្រសិនបើគេផ្តល់មួយចំណែកអំពីវាដល់ពួកគេ គឺពួកគេពេញចិត្ត។ តែប្រសិនបើគេមិនផ្តល់អំពីវាដល់ពួកគេទេនោះ ស្រាប់តែពួកគេខឹងសម្បា។

59. ហើយប្រសិនបើពួកគេពេញចិត្តនូវអ្វីដែលអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់បានផ្តល់ឱ្យពួកគេ ហើយពួកគេនិយាយថា៖ អល់ឡោះជាម្ចាស់(តែមួយគត់)គឺគ្រប់គ្រាន់ហើយសម្រាប់ពួកយើង។ អល់ឡោះនឹងប្រទានឱ្យពួកយើងដោយភាពសប្បុរសរបស់ទ្រង់ ហើយអ្នកនាំសាររបស់ទ្រង់(ក៏នឹងផ្តល់ឱ្យពួកយើងនូវអ្វីដែលអល់ឡោះបានផ្តល់ដល់គាត់ដែរ)។ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលសង្ឃឹមចំពោះអល់ឡោះ។ (ប្រសិនបើពួកគេធ្វើដូច្នោះ គឺវាល្អប្រសើរបំផុតចំពោះពួកគេជាងការដែលពួកគេនិយាយរិះគន់)។

60. តាមពិត ទ្រព្យហ្សាកាត់នោះ គឺសម្រាប់តែអ្នកក្រខ្សត់ អ្នកទីទាល់ក្រ អ្នកដែលប្រមូលហ្សាកាត់ អ្នកដែលគេទាក់ទាញចិត្តពួកគេ អ្នកដែលចង់រំដោះខ្លួនពីនឹមទាសភាព អ្នកដែលលិចលង់ក្នុងបំណុល អ្នកដែលតស៊ូក្នុងមាគ៌ារបស់អល់ឡោះ និងសម្រាប់អ្នកដំណើរដាច់ស្បៀង ជាកាតព្វកិច្ចមកពីអល់ឡោះ។ ហើយអល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិត។

61. ហើយក្នុងចំណោមពួកគេ គឺមានអ្នកដែលបង្កការឈឺចាប់ដល់ព្យាការី(មូហាំម៉ាត់)ដោយពួកគេនិយាយថា៖ គាត់ស្តាប់រាល់ពាក្យពេចន៍ទាំងអស់(មិនថាល្អ ឬអាក្រក់)។ ចូរអ្នកពោលថា៖ គាត់ស្តាប់តែអ្វីដែលល្អសម្រាប់ពួកអ្នកប៉ុណ្ណោះ ហើយគាត់ជឿជាក់ចំពោះអល់ឡោះ និងជឿជាក់ចំពោះបណ្តាអ្នកដែលមានជំនឿ ព្រមទាំងមានចិត្តអាណិតស្រលាញ់ចំពោះបណ្តាអ្នកដែលមានជំនឿក្នុងចំណោមពួកអ្នក។ ហើយពួកដែលបង្កការឈឺចាប់ដល់អ្នកនាំសាររបស់អល់ឡោះនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងឈឺចាប់បំផុត។

62. ពួកគេស្បថនឹងអល់ឡោះនៅចំពោះមុខពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)ដើម្បីផ្គាប់ចិត្តពួកអ្នកប៉ុណ្ណោះ។ តែអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ទៅវិញទេដែលសក្តិសមបំផុតសម្រាប់ពួកគេផ្គាប់ចិត្ត ប្រសិនបើពួកគេជាអ្នកមានជំនឿមែននោះ។

63. តើពួកគេមិនបានដឹងទេឬថា ពិតប្រាកដណាស់ ជនណាហើយដែលប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់នោះ ពិតប្រាកដណាស់ សម្រាប់រូបគេ គឺនរកដើហាន់ណាំដោយត្រូវស្ថិតក្នុងនោះជាអមតៈ។ នោះហើយជាភាពអាម៉ាស់មួយដ៏ធំធេងបំផុត។

64. ពួកពុតត្បុតទាំងនោះបារម្ភខ្លាចដំពូកណាមួយត្រូវបានបញ្ជូនទៅលើពួកគេដោយរៀបរាប់ប្រាប់បណ្តាអ្នកមានជំនឿពីអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកបន្តការសើចចំអក(ចំពោះសាសនារបស់អល់ឡោះ)ទៀតចុះ។ ជាការពិតណាស់ អល់ឡោះជាអ្នកដែលលាតត្រដាងនូវអ្វីដែលពួកអ្នកកំពុងតែបារម្ភខ្លាចនោះ។

65. ហើយប្រសិនបើអ្នកសួរពួកគេ នោះពួកគេប្រាកដជាឆ្លើយថា៖ តាមពិត ពួកយើងគ្រាន់តែចំអកលេង និងនិយាយលេងសើចប៉ុណ្ណោះ។ ចូរអ្នកពោលចុះថា៖ តើចំពោះអល់ឡោះ និងបណ្តាវាក្យខណ្ឌរបស់ទ្រង់ ព្រមទាំងអ្នកនាំសាររបស់ទ្រង់ ពួកអ្នកយកមកចំអកលេងសើចឬ?

66. ពួកអ្នកមិនបាច់និយាយដោះសានោះឡើយ។ ពិតណាស់ ពួកអ្នកបានក្លាយជាអ្នកគ្មានជំនឿហើយ ក្រោយពីពួកអ្នកមានជំនឿរួច។ ប្រសិនបើយើងលើកលែងទោសឱ្យក្រុមណាមួយក្នុងចំណោមពួកអ្នក យើងក៏នឹងដាក់ទណ្ឌកម្មក្រុមមួយទៀតដែរ ដោយសារពួកគេគឺជាពួកដែលប្រព្រឹត្តអាក្រក់។

67. ពួកពុតត្បុតទាំងប្រុស ទាំងស្រី គឺមានលក្ខណៈដូចគ្នា។ ពួកគេប្រើគ្នាឱ្យប្រព្រឹត្តអំពើអាក្រក់ និងហាមឃាត់គ្នាពីអំពើល្អ ហើយពួកគេមានភាពកំណាញ់(ចំពោះការបរិច្ចាគទាន)។ ពួកគេភ្លេចអល់ឡោះ ដូច្នេះ ទ្រង់ក៏បំភ្លេចពួកគេវិញដែរ។ ពិតប្រាកដណាស់ ពួកពុតត្បុត ពួកគេគឺជាពួកដែលប្រព្រឹត្តល្មើស។

68. អល់ឡោះជាម្ចាស់ទ្រង់បានសន្យាចំពោះពួកពុតត្បុតទាំងប្រុស ទាំងស្រី និងពួកគ្មានជំនឿនូវនរកជើងាន់ណាំ ដោយពួកគេស្ថិតនៅទីនោះជាអមតៈ។ វាគ្រប់គ្រាន់សម្រាប់ពួកគេ។ អល់ឡោះបានដាក់បណ្តាសាពួកគេ។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មជានិរន្តរ៍។

69. (ទង្វើរបស់ពួកអ្នកនេះ) គឺដូចទៅនឹងអ្នកជំនាន់មុនពួកអ្នកដែរ។ ពួកគេមានកម្លាំងខ្លាំងក្លាជាងពួកអ្នក ហើយមានទ្រព្យសម្បត្តិ និងកូនចៅច្រើនជាងពួកអ្នកទៅទៀត។ ពួកគេសោយសុខនឹងអ្វីដែលគេបានប្រទានដល់ពួកគេ។ ហើយពួកអ្នកក៏សោយសុខនឹងអ្វីដែលគេបានប្រទានដល់ពួកអ្នកដូចដែលអ្នកជំនាន់មុនបានសោយសុខនឹងអ្វីដែលគេបានប្រទានដល់ពួកគេដែរ។ ហើយពួកអ្នកនិយាយចំអក(នឹងការពិត) ដូចដែលពួកគេបាននិយាយចំអកដូចគ្នាដែរ។ ពួកទាំងនោះ ទង្វើកុសលទាំងឡាយរបស់ពួកគេត្រូវវិនាសជាអសារបង់ ហើយពួកទាំងនោះ គឺជាពួកដែលខាតបង់។

70. តើមិនបានមកដល់ពួកគេទេឬនូវរឿងរ៉ាវរបស់អ្នកជំនាន់មុនពួកគេ ដូចជាក្រុមរបស់ព្យាការីនួហ ក្រុមអាទ ក្រុមសាមូទ ក្រុមរបស់ព្យាការីអ៊ីព្រហ៊ីម អ្នកស្រុកម៉ាទយ៉ាន់ និងភូមិស្រុកក្រុមរបស់ព្យាការីលូត? បណ្តាអ្នកនាំសាររបស់ពួកគេបាននាំមកឱ្យពួកគេនូវសញ្ញាកស្តែងដ៏ច្បាស់លាស់ជាច្រើន។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មិនបានបំពានលើពួកគេឡើយ។ ក៏ប៉ុន្តែ ពួកគេទៅវិញទេដែលបំពានលើខ្លួនឯងនោះ។

71. ហើយបណ្តាអ្នកមានជំនឿទាំងប្រុសទាំងស្រី គឺជាអ្នកគាំពារគ្នាទៅវិញ។ ពួកគេប្រើគ្នាឱ្យធ្វើអំពើល្អ ហើយហាមឃាត់គ្នាពីអំពើអាក្រក់។ ពួកគេប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយពួកគេគោរពប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ អ្នកទាំងនោះហើយដែលអល់ឡោះជាម្ចាស់នឹងផ្តល់ក្តីមេត្តាករុណាដល់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

72. អល់ឡោះជាម្ចាស់ទ្រង់បានសន្យាចំពោះបណ្តាអ្នកដែលមានជំនឿទាំងប្រុសទាំងស្រីនូវឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅទីនោះជាអមតៈ ព្រមទាំងមានគេហដ្ឋានយ៉ាងល្អប្រណីតនៅក្នុងឋានសួគ៌អាត់និន។ ហើយការពេញចិត្តពីអល់ឡោះ គឺធំធេងជាងនោះទៅទៀត។ នោះហើយជាជោគជ័យដ៏ធំធេងបំផុត។

73. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកតស៊ូប្រយុទ្ធនឹងពួកគ្មានជំនឿ និងពួកពុតត្បុត ហើយត្រូវតស៊ូឱ្យខ្លាំងក្លាជាមួយពួកគេ។ កន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺឋាននរកជើងាន់ណាំ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

74. ពួកគេស្បថនឹងអល់ឡោះថា៖ ពួកគេមិនបាននិយាយ(ប្រមាថចំពោះអ្នក និងសាសនារបស់អ្នក)នោះឡើយ ខណៈដែលពួកគេពិតជាបាននិយាយនូវពាក្យសម្តីដែល(នាំឲ្យពួកគេក្លាយជា)គ្មានជំនឿ ហើយពួកគេបានក្លាយជាអ្នកដែលគ្មានជំនឿក្រោយពីពួកគេបានចូលអ៊ីស្លាមហើយនោះ។ ហើយពួកគេប៉ុនប៉ងធ្វើនូវអ្វីដែលពួកគេមិនអាចសម្រេចបាន។ ពួកគេមិនអាចរកអ្វីមកប្រមាថដល់គាត់(ព្យាការីមូហាំម៉ាត់)នោះឡើយ លើកលែងតែអល់ឡោះទ្រង់បានប្រោសប្រទានឱ្យពួកគេដោយឱ្យពួកគេមានបានតាមរយៈការប្រោសប្រទានដល់អ្នកនាំសាររបស់ទ្រង់ប៉ុណ្ណោះ។ ហើយប្រសិនបើពួកគេសារភាពកំហុសវាជាការប្រសើរបំផុតសម្រាប់ពួកគេ។ តែប្រសិនបើពួកគេងាកចេញវិញនោះ អល់ឡោះទ្រង់នឹងដាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្មដ៏ឈឺចាប់បំផុតទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយសម្រាប់ពួកគេនៅលើផែនដីនេះ គឺគ្មានអ្នកគាំពារ និងគ្មានអ្នកជួយឡើយ។

75. ហើយក្នុងចំណោមពួកគេ គឺមានអ្នកដែលបានសន្យានឹងអល់ឡោះថា៖ ប្រសិនបើអល់ឡោះជាម្ចាស់ផ្តល់ឱ្យពួកយើងនូវការប្រោសប្រទាន(លាភសក្ការៈ)អំពីទ្រង់នោះ ពួកយើងប្រាកដជានឹងធ្វើការបរិច្ចាគទាន ហើយពួកយើងប្រាកដជានឹងស្ថិតក្នុងចំណោមបណ្តាអ្នកដែលសាងទង្វើកុសលមិនខានឡើយ។

76. តែនៅពេលដែលទ្រង់បានប្រទានឱ្យពួកគេនូវការប្រោសប្រទានអំពីទ្រង់នោះ ពួកគេបែរជាកំណាញ់ចំពោះវាទៅវិញ។ ហើយពួកគេថែមទាំងបានបែរចេញ ខណៈដែលពួកគេជាពួកដែលប្រឆាំងថែមទៀត។

77. ដូចនេះ គេក៏ដាក់ទណ្ឌកម្មពួកគេដោយដាក់ភាពពុតត្បុតទៅក្នុងដួងចិត្តរបស់ពួកគេ រហូតដល់ថ្ងៃដែលពួកគេជួបទ្រង់ដោយសារតែពួកគេក្បត់នឹងអល់ឡោះចំពោះអ្វីដែលពួកគេបានសន្យានឹងទ្រង់ និងចំពោះអ្វីដែលពួកគេធ្លាប់បានកុហក។

78. តើពួកគេមិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតពីប្រការអាថ៌កំបាំងរបស់ពួកគេ និងការខ្សឹបខ្សៀវគ្នា(រៀបចំឧបាយកល)របស់ពួកគេនោះ? ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតនូវប្រការអាថ៌កំបាំងទាំងឡាយ។

79. ពួកដែលមើលស្រាលសប្បុរសជនទាំងឡាយរបស់អ្នកមានជំនឿដែលពួកគេបានបរិច្ចាគទ្រព្យសម្បត្តិ និងអ្នកដែលពុំសូវមានទ្រព្យធនក្នុងការបរិច្ចាគ តែពួកគេបានបរិច្ចាគតាមលទ្ធភាពដែលពួកគេមាន ដោយពួកគេសើចចំអកឱ្យអ្នកទាំងនោះ។ ដូចនេះ អល់ឡោះជាម្ចាស់ក៏បានសើចចំអកចំពោះពួកគេវិញដែរ ហើយពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

80. ទោះបីជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សុំការអភ័យទោស(ពីអល់ឡោះ)ឱ្យពួកគេ ឬមិនសុំការអភ័យទោសឱ្យពួកគេ ហើយទោះបីអ្នកសុំការអភ័យទោសឱ្យពួកគេចិតសិបដងទៀតក៏ដោយ ក៏អល់ឡោះជាម្ចាស់មិនអភ័យទោសដល់ពួកគេនោះដែរ។ នោះគឺដោយសារតែពួកគេបានប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។ ហើយអល់ឡោះទ្រង់មិនចង្អុលបង្ហាញចំពោះក្រុមដែលប្រព្រឹត្តល្មើសឡើយ។

81. ពួក(ពុតត្បុត)ដែលមិនទៅចូលរួមប្រយុទ្ធទាំងនោះ ពួកគេសប្បាយរីករាយក្នុងការស្នាក់នៅ(មិនចេញទៅប្រយុទ្ធ)របស់ពួកគេដោយប្រព្រឹត្តផ្ទុយពី(បទបញ្ជា)អ្នកនាំសាររបស់អល់ឡោះ ហើយពួកគេមិនពេញចិត្តក្នុងការតស៊ូប្រយុទ្ធដោយទ្រព្យសម្បត្តិ និងខ្លួនប្រាណរបស់ពួកគេក្នុងមាគ៌ារបស់អល់ឡោះឡើយ ហើយពួកគេថែមទាំងនិយាយថា៖ ចូរពួកអ្នកកុំចេញ(ទៅប្រយុទ្ធ)ក្នុងពេលថ្ងៃក្តៅ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ភ្លើងនរកជើហាន់ណាំ គឺក្តៅខ្លាំងជាងនេះទៅទៀត ប្រសិនបើពួកគេបានដឹង។

82. ហេតុនេះ ចូរឱ្យពួកគេសើចសប្បាយបន្តិចសិនចុះ(ក្នុងលោកិយ) ហើយពួកគេនឹងយំសោកច្រើនបំផុត(នៅថ្ងៃបរលោក)ជាមិនខាន ជាការតបស្នងចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

83. ប្រសិនបើអល់ឡោះទ្រង់បញ្ជូនអ្នក(ឱព្យាការីមូហាំម៉ាត់)ឱ្យត្រឡប់ទៅកាន់ក្រុមមួយក្នុងចំណោមពួកគេ ហើយពួកគេសុំការអនុញ្ញាតពីអ្នកឲ្យពួកគេអាចចេញទៅ(ប្រយុទ្ធក្នុងសង្គ្រាមផ្សេងទៀត)នោះ ចូរអ្នកពោលចុះថា៖ ពួកអ្នកមិនអាចចេញទៅ(សមរភូមិផ្សេងទៀត)ជាមួយខ្ញុំបានជាដាច់ខាត ហើយពួកអ្នកក៏មិនអាចប្រយុទ្ធនឹងសត្រូវជាមួយនឹងខ្ញុំបាននោះដែរ។ ពិតប្រាកដណាស់ ពួកអ្នកបានពេញចិត្តក្នុងការស្នាក់នៅ(មិនចេញទៅប្រយុទ្ធ)តាំងពីដំបូង(ក្នុងសមរភូមិតាពួក)មកហើយ។ ហេតុនេះ ចូរពួកអ្នកបន្តការស្នាក់នៅជាមួយនឹងអ្នកដែលមិនអាចចេញទៅប្រយុទ្ធទាំងឡាយ(អ្នកជំងឺ ស្ត្រី...)ទៀតចុះ។

84. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនត្រូវសឡាតទៅលើសពនរណាម្នាក់នៃពួកគេ(ពួកពុតត្បុត)ដែលបានស្លាប់ជាដាច់ខាត ហើយអ្នកក៏មិនត្រូវឈរនៅឯទីផ្នូររបស់គេ(សុំការអភ័យទោសឱ្យគេ)នោះដែរ។ ពិតប្រាកដណាស់ ពួកគេបានប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយពួកគេបានស្លាប់ក្នុងខណៈដែលពួកគេជាពួកដែលប្រព្រឹត្តល្មើស។

85. ហើយចូរអ្នកកុំឱ្យទ្រព្យសម្បត្តិរបស់ពួកគេ និងកូនចៅរបស់ពួកគេធ្វើឱ្យអ្នកចាប់អារម្មណ៍ឱ្យសោះ។ តាមពិត អល់ឡោះទ្រង់មានបំណងដាក់ទណ្ឌកម្មពួកគេតាមរយៈប្រការទាំងនេះនៅក្នុងជីវិតលោកិយ ហើយទ្រង់ដកយកជីវិតពួកគេ ខណៈដែលពួកគេជាពួកដែលប្រឆាំង។

86. ហើយនៅពេលដែលគេបញ្ចុះជំពូកណាមួយដែលឱ្យពួកគេមានជំនឿចំពោះអល់ឡោះ និងត្រូវតស៊ូប្រយុទ្ធជាមួយអ្នកនាំសាររបស់ទ្រង់នោះ ពួកដែលមានទ្រព្យសម្បត្តិក្នុងចំណោមពួកគេបានសុំការអនុញ្ញាតពីអ្នក(មិនចូលរួមប្រយុទ្ធ)ហើយពួកគេនិយាយថា៖ សូមអ្នកមេត្តាទុកពួកយើងឲ្យនៅជាមួយអ្នកដែលស្នាក់នៅ(មិនអាចចេញទៅប្រយុទ្ធ)ទាំងឡាយផងចុះ។

87. ពួកគេពេញចិត្ត(នឹងឱ្យខ្លួនរបស់ពួកគេទទួលនូវភាពអាប់ឱន)ដោយការនៅជាមួយអ្នកដែលមិនអាចចេញទៅប្រយុទ្ធទាំងឡាយ(ដែលច្បាប់បានអនុគ្រោះ)។ ហើយគេ(អល់ឡោះ)បានបោះត្រាក្លិតទៅលើដួងចិត្តរបស់ពួកគេ។ ដូច្នេះ ពួកគេមិនយល់ដឹងអ្វីឡើយ។

88. ចំណែកឯអ្នកនាំសារ(មូហាំម៉ាត់) និងបណ្តាអ្នកមានជំនឿដែលនៅជាមួយគាត់វិញ ពួកគេបានតស៊ូប្រយុទ្ធដោយទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកគេ។ អ្នកទាំងនោះហើយ សម្រាប់ពួកគេនឹងទទួលបាននូវប្រការល្អជាច្រើន។ ហើយអ្នកទាំងនោះ ពួកគេគឺជាអ្នកដែលទទួលបានជោគជ័យ។

89. អល់ឡោះបានត្រៀមទុកសម្រាប់ពួកគេនូវឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅទីនោះជាអមតៈ។ នោះហើយ គឺជាជោគជ័យដ៏ធំធេង។

90. ហើយពួកដែលដោះសាក្នុងចំណោមពួកអារ៉ាប់ជនបទបានមកដល់ដើម្បីឱ្យគេអនុញ្ញាតឱ្យពួកគេ(អាចអវត្តមានពីសមរភូមិ)។ ហើយពួកដែលមិនជឿជាក់ចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ពួកគេស្នាក់នៅ(មិនចេញទៅប្រយុទ្ធដោយមិនមកសុំការអនុញ្ញាតតែម្តង)។ ពួកដែលប្រឆាំងក្នុងចំណោមពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

91. គ្មានទោសពៃអ្វីឡើយចំពោះអ្នកទន់ខ្សោយទាំងឡាយ(ស្ត្រីកេទ មនុស្សចាស់ កូនក្មេង) និងអ្នកជំងឺ ហើយនិងអ្នកដែលមិនមានទ្រព្យដើម្បីបរិច្ចាគ(ចំពោះការដែលពួកគេមិនចេញទៅប្រយុទ្ធ)នោះ ប្រសិនបើពួកគេមានភាពស្មោះត្រង់ចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។ គ្មានហេតុផលណាដែលត្រូវយកទោសពៃចំពោះបណ្តាអ្នកដែលសាងអំពើល្អឡើយ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

92. ហើយក៏គ្មានទោសពៃអ្វីនោះដែរ(ចំពោះអ្នកដែលមិនបានទៅចូលរួមប្រយុទ្ធ) នៅពេលដែលពួកគេបានមកជួបនឹងអ្នកដោយសុំឲ្យអ្នកដឹកពួកគេ(ទៅសមរភូមិ)ហើយអ្នកបានតបទៅកាន់ពួកគេថា៖ ខ្ញុំគ្មានអ្វីសម្រាប់ដឹកពួកអ្នក(ទៅសមរភូមិ)នោះឡើយ។ ពួកគេក៏ត្រឡប់ទៅវិញទាំងស្រក់ទឹកភ្នែកដោយភាពទុក្ខព្រួយ ព្រោះតែពួកគេគ្មានអ្វីសម្រាប់បរិច្ចាគ។

93. តាមពិតអ្នកដែលត្រូវទទួលទោសពៃរ៍នោះ គឺចំពោះតែអ្នកទាំងឡាយណាដែលពួកគេសុំការអនុញ្ញាតពីអ្នក(មិនចេញទៅប្រយុទ្ធ) ខណៈដែលពួកគេមានលទ្ធភាព(ទាំងទ្រព្យសម្បត្តិ និងខ្លួនប្រាណ)ប៉ុណ្ណោះ។ ពួកគេពេញចិត្ត(នឹងឱ្យខ្លួនរបស់ពួកគេទទួលនូវភាពអាប់ឱន)ដោយការនៅជាមួយអ្នកដែលមិនអាចចេញទៅប្រយុទ្ធទាំងឡាយ(ដែលច្បាប់បានអនុគ្រោះ)។ ហើយអល់ឡោះបានបោះត្រាភ្ជិតទៅលើដួងចិត្តរបស់ពួកគេ។ ដូច្នេះ ពួកគេមិនដឹងអ្វីឡើយ។

94. ពួកគេ(ពួកពុតត្បុត)នឹងនិយាយដោះសាទៅកាន់ពួកអ្នក(អ្នកមានជំនឿ)នៅពេលដែលពួកអ្នកវិលត្រឡប់(មកពីសមរភូមិ)ទៅកាន់ពួកគេវិញ។ ចូរអ្នកពោលថា៖ ពួកអ្នកមិនចាំបាច់ដោះសាអ្វីនោះទេ។ ពួកយើងមិនជឿពួកអ្នកឡើយ។ ពិតណាស់ អល់ឡោះទ្រង់បានប្រាប់ពួកយើងពីរឿងរ៉ាវរបស់ពួកអ្នកអស់ទៅហើយ។ ហើយអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់នឹងរង់ចាំមើលទង្វើរបស់ពួកអ្នក។ ក្រោយមក គេនឹងនាំពួកអ្នកត្រឡប់ទៅកាន់(ព្រះជាម្ចាស់)អ្នកដែលដឹងបំផុតនូវប្រការអាថ៌កំបាំង និងប្រការដែលលាតត្រដាង។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

95. ពួកគេនឹងស្បថនឹងអល់ឡោះនៅចំពោះមុខពួកអ្នកនៅពេលដែលពួកអ្នកវិលត្រឡប់មកកាន់ពួកគេដើម្បីកុំឲ្យពួកអ្នកស្តីបន្ទោសពួកគេ។ ហេតុនេះ ចូរពួកអ្នកងាកចេញពីពួកគេចុះ។ ពិតប្រាកដណាស់ ពួកគេមានភាពកខ្វក់។ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺនរកជើហាន់ណាំ ជាការតបស្នងចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

96. ពួកគេស្បថចំពោះពួកអ្នកដើម្បីឱ្យពួកអ្នកអនុគ្រោះដល់ពួកគេ។ ប្រសិនបើពួកអ្នកអនុគ្រោះដល់ពួកគេនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនអនុគ្រោះដល់ក្រុមដែលប្រព្រឹត្តល្មើសឡើយ។

97. ចំពោះពួកអារ៉ាប់ជនបទ ភាពគ្មានជំនឿ និងភាពពុតត្បុត(របស់ពួកគេ)គឺខ្លាំងជាង(អ្នកទីក្រុង)ទៅទៀត(ដោយសារចិត្តពួកគេមានភាពរឹងរូស និងមិនសូវចូលចំណេះអ្នកចេះដឹង)។ (ដូចនេះ) ពួកគេសក្តិសមនឹងមិនដឹងពីក្បួនច្បាប់ផ្សេងៗដែលអល់ឡោះបានបញ្ចុះមកឱ្យអ្នកនាំសាររបស់ទ្រង់(បែបនេះហើយ)។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

98. ហើយក្នុងចំណោមពួកអារ៉ាប់ជនបទ មានអ្នកចាត់ទុកអ្វីដែលគេបរិច្ចាគ(ក្នុងមាគ៌ារបស់អល់ឡោះ)នោះ គឺជាការខាតបង់ ហើយរូបគេរង់ចាំមើលប្រការអាក្រក់កើតមានលើពួកអ្នក(បណ្តាអ្នកមានជំនឿ)។ ប៉ុន្តែ(តាមពិត)ប្រការអាក្រក់នោះ គឺកើតមានទៅលើពួកគេទៅវិញទេ។ ហើយអល់ឡោះមហាឮ មហាដឹងបំផុត។

99. ហើយក្នុងចំណោមពួកអារ៉ាប់ជនបទ ក៏មានអ្នកដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ហើយចាត់ទុកអ្វីដែលគេបរិច្ចាគ(ក្នុងមាគ៌ាអល់ឡោះនោះ) គឺជាការបញ្ជិតខ្លួនទៅចំពោះអល់ឡោះ និងទទួលបាននូវការបួងសួងពីអ្នកនាំសារ(របស់អល់ឡោះ)ដែរ។ តើពុំមែនទេឬ ទង្វើទាំងនោះ គឺជាការខិតខ្លួនជិត(ទៅចំពោះអល់ឡោះ)សម្រាប់ពួកគេនោះ? អល់ឡោះនឹងបញ្ចូលពួកគេទៅក្នុងក្តីមេត្តាករុណារបស់ទ្រង់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

100. បណ្តាអ្នកដែលរួសរាន់ទៅកាន់ការមានជំនឿដំបូងគេក្នុងចំណោមអ្នកមូហាជីរីន និងអ្នកអាន់សារ ហើយនិងបណ្តាអ្នកដែលដើរ(តាមមាគ៌า)ពួកគេដោយល្អប្រពៃនោះ អល់ឡោះជាម្ចាស់ទ្រង់ពេញចិត្តចំពោះពួកគេ ហើយពួកគេក៏ពេញចិត្តចំពោះទ្រង់វិញដែរ។ ហើយទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅក្នុងនោះជាអមត:។ នោះហើយជាជោគជ័យដ៏ធំធេង។

101. ហើយក្នុងចំណោមពួកអារ៉ាប់ជនបទដែលរស់នៅជុំវិញពួកនោះ គឺមានពួកពុតត្បុត។ ហើយក្នុងចំណោមអ្នកដែលរស់នៅក្នុងក្រុងម៉ាទីណៈ ក៏មានពួកដែលបន្តស្ថិតក្នុងភាពពុតត្បុតដែរ ដែលអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនស្គាល់ពួកគេនោះទេ តែយើងស្គាល់ពួកគេ។ យើងនឹងដាក់ទណ្ឌកម្មពួកគេពីរដង។ ក្រោយមក ពួកគេនឹងត្រូវគេបញ្ជូនត្រឡប់ទៅកាន់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត(បាតនរក)។

102. ហើយ(ក្នុងចំណោមពួកគេដែរ)មានអ្នកផ្សេងទៀតដែលពួកគេទទួលស្គាល់កំហុសរបស់ខ្លួន(ដែលមិនបានចូលរួមប្រយុទ្ធ)ដោយពួកគេលាយឡំអំពើល្អជាមួយនឹងអំពើអាក្រក់ផ្សេងទៀត។ សង្ឃឹមថាអល់ឡោះជាម្ចាស់នឹងទទួលយកការសារភាពកំហុសរបស់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

103. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជកយកពីទ្រព្យសម្បត្តិរបស់ពួកគេមួយចំនួនជាទ្រព្យហ្សាកាត់ ដើម្បីជាការដម្រះសម្អាតពួកគេ(ពីអំពើល្មើស)និងលើកឋានៈរបស់ពួកគេ ហើយចូរអ្នកបួងសួងឱ្យពួកគេផង។ ពិតប្រាកដណាស់ ការបួងសួងរបស់អ្នក គឺជាភាពនឹងនរសម្រាប់ពួកគេ។ ហើយអល់ឡោះមហាឮ មហាដឹងបំផុត។

104. តើពួកគេមិនបានដឹងទេឬថា ពិតប្រាកដណាស់អល់ឡោះជាម្ចាស់ទ្រង់ទទួលយកការសារភាពកំហុសពីបណ្តាខ្ញុំបម្រើរបស់ទ្រង់ និងទទួលយកការបរិច្ចាគទាំងឡាយ។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកទទួលយកការសារភាពកំហុស មហាអាណិតស្រលាញ់បំផុត។

105. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកធ្វើចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងបណ្តាអ្នកមានជំនឿទាំងឡាយនឹងមើលឃើញទង្វើរបស់ពួកអ្នក។ ហើយគេនឹងនាំពួកអ្នកត្រឡប់ទៅកាន់(ព្រះជាម្ចាស់)អ្នកដែលដឹងបំផុតនូវប្រការអាថ៌កំបាំង និងប្រការដែលលាតត្រដាង។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកនូវអ្វីដែលអ្នកធ្លាប់បានសាង។

106. ហើយ(ក្នុងចំណោមអ្នកដែលអវត្តមានពីសង្គ្រាមតាពួកនោះដែរ) មានអ្នកផ្សេងទៀតដែលពួកគេត្រូវបានគេពន្យារពេលរង់ចាំការសម្រេចរបស់អល់ឡោះ ដោយទ្រង់អាចនឹងដាក់ទណ្ឌកម្មពួកគេ ឬក៏ទទួលយកការសារភាពកំហុសរបស់ពួកគេ។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

107. ហើយ(ក្នុងចំណោមពួកពុតត្បុតនោះដែរគឺមាន)ពួកដែលបានកសាងម៉ាស្ជិតដើម្បីបង្កគ្រោះ(ដល់អ្នកមូស្លីម) និងភាពគ្មានជំនឿ ហើយនិងបំបែកបំបាក់រវាងបណ្តាអ្នកដែលមានជំនឿ ព្រមទាំងដើម្បីជាការត្រៀមសម្រាប់ជនដែលធ្វើសង្គ្រាមប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់តាំងពីមុន(ពេលសាងសង់)មកម្ល៉េះ។ ហើយពួកគេប្រាកដជានឹងស្បថថា៖(ក្នុងការកសាងម៉ាស្ជិតនេះ) ពួកយើងគ្មានបំណងអ្វីក្រៅពីធ្វើល្អនោះឡើយ។ ហើយអល់ឡោះទ្រង់ធ្វើសាក្សីថា ពិតប្រាកដណាស់ ពួកគេគឺជាអ្នកដែលកុហក។

108. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)កុំសឡាតក្នុងម៉ាស្ជិតនេះជាដាច់ខាត។ ពិតប្រាកដណាស់ ម៉ាស្ជិត(គួហ្លាក)ដែលត្រូវបានសង់ឡើងនៅលើការកោតខ្លាច(អល់ឡោះ)តាំងពីថ្ងៃដំបូងនោះ គឺសក្តិសមបំផុតសម្រាប់អ្នកក្នុងការសឡាតនៅក្នុងវាជាង(ម៉ាស្ជិតនេះ)។ នៅទីនោះ មានបុរសជាច្រើនដែលពួកគេចូលចិត្តជម្រះសម្អាត(ពីប្រការអាក្រក់ទាំងឡាយ)។ ហើយអល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលជម្រះសម្អាត។

109. តើអ្នកដែលបានសាងសង់សំណង់របស់ខ្លួននៅលើការកោតខ្លាច និងការពេញចិត្តពីអល់ឡោះល្អប្រសើរជាង ឬអ្នកដែលសាងសង់សំណង់របស់ខ្លួននៅលើមាត់ជ្រោះដែលហៀបតែនឹងបាក់ស្រុត ហើយរូបគេនិងសំណង់របស់គេនឹងធ្លាក់ទៅជាមួយគ្នាទៅក្នុងនរកជើងហ៊ាន់ណាំនោះ ប្រសើរជាង? ហើយអល់ឡោះមិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

110. សំណង់(ម៉ាស្ជិត)របស់ពួកគេដែលពួកគេបានកសាងនោះ នៅតែជាក្តីមន្ទិលសង្ស័យក្នុងដួងចិត្តរបស់ពួកគេ រហូតដល់ដួងចិត្តរបស់ពួកគេត្រូវបានកាត់ផ្តាច់(ស្លាប់ ឬត្រូវគេសម្លាប់)។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

111. ពិតប្រាកដណាស់ អល់ឡោះទ្រង់បានទិញ(ប្តូរ)ពីបណ្តាអ្នកមានជំនឿនូវជីវិតរបស់ពួកគេ និងទ្រព្យសម្បត្តិរបស់ពួកគេ ដោយប្រទានដល់ពួកគេវិញនូវឋានសួគ៌។ ពួកគេប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះ ដោយពួកគេបានសម្លាប់(ពួកប្រឆាំង) ហើយពួកគេក៏ត្រូវបានគេសម្លាប់វិញដែរ។ ការសន្យារបស់អល់ឡោះចំពោះរឿងនេះ គឺជាការពិតដែលមានបញ្ជាក់នៅក្នុងគម្ពីរតាវរ៉ត គម្ពីរអ៊ិញជីល និងគម្ពីរគួរអាន។ ហើយគ្មាននរណាម្នាក់ដែលគោរពពាក្យសន្យាជាងអល់ឡោះឡើយ។ ដូច្នេះចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)សប្បាយរីករាយជាមួយនឹងការលក់ដូររបស់ពួកអ្នកដែលបានព្រមព្រៀងវា(ជាមួយនឹងអល់ឡោះ)ចុះ។ នោះហើយគឺជាជោគជ័យដ៏ធំធេងបំផុត។

112. (ពួកគេទាំងនោះ) គឺបណ្តាអ្នកដែលសារភាពកំហុស អ្នកដែលគោរពសក្ការៈ(ចំពោះអល់ឡោះ) អ្នកដែលកោតសរសើរ(ដល់អល់ឡោះ) អ្នកដែលបួស អ្នកដែលរុកុ អ្នកដែលស៊ូជោត(ក្នុងពេលប្រតិបត្តិសឡាត) អ្នកដែលប្រើគ្នាឱ្យធ្វើអំពើល្អ អ្នកដែលហាមឃាត់គ្នាពីអំពើអាក្រក់ ហើយនិងបណ្តាអ្នកថែរក្សាច្បាប់បញ្ញត្តិទាំងឡាយរបស់អល់ឡោះ។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ។

113. មិនគប្បីឡើយចំពោះព្យាការី និងបណ្តាអ្នកមានជំនឿដែលពួកគេសុំការអភ័យទោសពីអល់ឡោះឱ្យពួកមុស្ស៊ីគីននោះ ទោះបីជាពួកគេនោះជាសាច់ញាតិនឹងគ្នាក៏ដោយ បន្ទាប់ពីគេបានបញ្ជាក់យ៉ាងច្បាស់ដល់ពួកគេថា ពិតប្រាកដណាស់ពួកគេ គឺជាពួកនរកជើហ៊ឹមហើយនោះ។

114. ហើយការសុំអភ័យទោសរបស់ព្យាការីអ៊ីព្រហ៊ីមឱ្យឪពុករបស់គាត់នោះ គឺគ្មានអ្វីក្រៅពីដោយសារតែគាត់បានសន្យានឹងឪពុករបស់គាត់ថា នឹងសុំការអភ័យទោស(ពីអល់ឡោះ)ឱ្យគាត់ប៉ុណ្ណោះ។ តែនៅពេលដែលវាបានបញ្ជាក់ច្បាស់ដល់គាត់ថា ពិតប្រាកដណាស់ ឪពុករបស់គាត់ គឺជាសត្រូវរបស់អល់ឡោះនោះ គាត់ក៏បានដកខ្លួនចេញពីឪពុករបស់គាត់វិញ។ ពិតប្រាកដណាស់ ព្យាការីអ៊ីព្រហ៊ីម គឺអ្នកដែលឱនលំទោនចំពោះអល់ឡោះ ជាអ្នកខន្តីបំផុត។

115. ហើយអល់ឡោះមិនធ្វើឱ្យក្រុមណាមួយវង្វេងក្រោយពីពួកគេទទួលបានការចង្អុលបង្ហាញនោះឡើយ លុះត្រាតែទ្រង់បានបញ្ជាក់ប្រាប់ដល់ពួកគេនូវប្រការដែលពួកគេចាំបាច់ត្រូវចៀសវាង។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវគ្រប់អ្វីៗទាំងអស់។

116. ពិតប្រាកដណាស់ អំណាចគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ទ្រង់ប្រទានជីវិត និងដកហូតជីវិត។ ហើយសម្រាប់ពួកអ្នក គ្មានអ្នកគាំពារ និងគ្មានអ្នកជួយណាក្រៅពីអល់ឡោះឡើយ។

117. ជាការពិតណាស់ អល់ឡោះទ្រង់បានទទួលយកការសារភាពកំហុសពីព្យាការី(មូហាំម៉ាត់) ពីអ្នកមូហាជីរីន និងអ្នកអាន់សារីដែលពួកគេបានគោរពតាមគាត់(ព្យាការីមូហាំម៉ាត់)ក្នុងពេលវេលាដ៏លំបាកបំផុត(សមរភូមិតាពូក) ក្រោយពីដួងចិត្តក្រុមមួយក្នុងចំណោមពួកគេស្ទើរតែបោះបង់(ការប្រយុទ្ធ)ទៅហើយ។ ក្រោយមក ទ្រង់បានទទួលយកការសារភាពកំហុសពីពួកគេ។ ពិតប្រាកដណាស់ ទ្រង់មហាមេត្តាករុណា មហាអាណិតស្រលាញ់បំផុតចំពោះពួកគេ។

118. ហើយ(ទ្រង់ក៏ទទួលយកការសារភាពកំហុសផងដែរ)ពីបុគ្គលបីរូបដែលពួកគេមិនបានចូលរួម(ក្នុងសមរភូមិតាពូក) រហូតដល់ផែនដីដែលមានភាពទូលំទូលាយនោះបែរជាចង្អៀតចំពោះពួកគេ ហើយដួងចិត្តរបស់ពួកគេក៏មានភាពចង្អៀតចង្អល់ផងដែរ(ដោយត្រូវគេទុកចោល) ហើយពួកគេបានដឹងថា គ្មានកន្លែងជ្រកកោនណាក្រៅពីអល់ឡោះ(សម្រាប់ពួកគេ)ឡើយ លើកលែងតែការវិលត្រឡប់ទៅកាន់ទ្រង់ប៉ុណ្ណោះ។ ក្រោយមក អល់ឡោះក៏បានចង្អុលបង្ហាញពួកគេឱ្យធ្វើការសារភាពកំហុស ហើយទ្រង់បានទទួលយកនូវការសារភាពកំហុសរបស់ពួកគេ។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកដែលទទួលយកការសារភាពកំហុស មហាអាណិតស្រលាញ់បំផុត។

119. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះ ហើយចូរពួកអ្នកស្ថិតនៅជាមួយបណ្តាអ្នកដែលទៀងត្រង់។

120. ចំពោះអ្នក(មានជំនឿ)ដែលរស់នៅក្រុងម៉ាទីណៈ និងពួកអារ៉ាប់ជនបទដែលរស់នៅជុំវិញពួកគេ គឺពួកគេមិនដែលបោះបង់អ្នកនាំសាររបស់អល់ឡោះនោះឡើយ ហើយពួកគេក៏មិនស្រលាញ់ខ្លួនឯងជាងគាត់នោះដែរ។ នោះគឺដោយសារតែការស្រេកទឹក ការនឿយហត់ និងការស្រេកឃ្លានមិនប៉ះពាល់ដល់ពួកគេនៅក្នុង(ការតស៊ូក្នុង)មាគ៌ារបស់អល់ឡោះឡើយ។ ពួកគេមិនឈានជើងទៅកន្លែងណាដែលធ្វើឱ្យពួកប្រឆាំងមានកំហឹង ហើយពួកគេក៏មិនដែលជួបប្រទះនូវគ្រោះអ្វីពីសត្រូវនោះដែរ ក្រៅពីអ្វីដែលគេបានកត់ត្រាឱ្យពួកគេនូវទង្វើកុសលប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះមិនបំបាត់ផលបុណ្យរបស់បណ្តាអ្នកដែលសាងអំពើល្អឡើយ។

121. ហើយទោះបីជាពួកគេបរិច្ចាគទ្រព្យសម្បត្តិតិចក្តី ច្រើនក្តី ហើយទោះបីជាពួកគេឆ្លងកាត់ជ្រលងភ្នំណាមួយក៏ដោយ គឺសុទ្ធតែត្រូវបានគេកត់ត្រាសម្រាប់ពួកគេដើម្បីឱ្យអល់ឡោះនឹងតបស្នងដល់ពួកគេនូវអ្វី(ផលបុណ្យ)ដែលប្រសើរជាងអ្វីដែលពួកគេធ្លាប់បានសាងទៅទៀត។

122. ហើយចំពោះបណ្តាអ្នកដែលមានជំនឿ គឺមិនគប្បីចេញទៅធ្វើសង្គ្រាមទាំងអស់គ្នានោះទេ។ ដូច្នេះ រាល់ក្រុមនីមួយៗត្រូវទុកមនុស្សមួយចំនួននៃពួកគេឲ្យស្នាក់នៅ(មិនចេញទៅប្រយុទ្ធ)ដើម្បីឱ្យពួកគេឈ្វេងយល់ពីសាសនា(អ៊ីស្លាម) និងដើម្បីទូន្មានក្រុមរបស់ខ្លួននៅពេលដែលក្រុមនោះបានត្រឡប់មកកាន់ពួកគេវិញ។ សង្ឃឹមថាពួកគេនឹងប្រុងប្រយ័ត្ន(ពីទណ្ឌកម្មរបស់អល់ឡោះ)។

123. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រយុទ្ធនឹងពួកប្រឆាំងដែលនៅជិតពួកអ្នកបំផុត និងបង្ហាញឲ្យពួកគេឃើញពីភាពខ្លាំងក្លារបស់ពួកអ្នក។ ហើយចូរពួកអ្នកដឹងចុះថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលកោតខ្លាច។

124. ហើយនៅពេលដែលជំពូកណាមួយ(នៃគម្ពីរគួរអាន)ត្រូវបានបញ្ចុះមក ក្នុងចំណោមពួកគេ(ពួកពុតត្បុត) មានអ្នកខ្លះនិយាយថា៖ តើមានអ្នកណាក្នុងចំណោមពួកអ្នកដែលការបញ្ចុះជំពូកមួយនេះធ្វើឱ្យជំនឿរបស់គេកាន់តែកើនឡើងនោះ? ចំណែកឯបណ្តាអ្នកដែលមានជំនឿវិញ ពិតណាស់(ការបញ្ចុះជំពូកនេះ)គឺធ្វើឲ្យជំនឿរបស់ពួកគេកាន់តែកើនឡើង ហើយពួកគេមានភាពសប្បាយរីករាយ។

125. រីឯពួកដែលក្នុងចិត្តរបស់ពួកគេមានជំងឺវិញ ជាការពិតណាស់ វាកាន់តែបន្ថែមនូវភាពស្រពេចស្រពិលទៅលើភាពស្រពេចស្រពិលរបស់ពួកគេថែមទៀត ហើយពួកគេស្លាប់ ខណៈពេលដែលពួកគេជាពួកគ្មានជំនឿ។

126. តើពួក(ពុតត្បុត)ទាំងនោះមិនឃើញថា ពិតណាស់ពួកគេត្រូវបានគេសាកល្បងជារៀងរាល់ឆ្នាំ ចំនួនមួយដង ឬពីរដងទេឬ? ក្រោយមក ពួកគេនៅតែមិនសារភាពកំហុស(ចំពោះអល់ឡោះ) និងមិនភ្ញាក់រលឹកដដែល។

127. ហើយនៅពេលដែលជំពូកណាមួយ(នៃគម្ពីរគួរអាន)ត្រូវបានបញ្ចុះមក ពួកគេក្រលេកមើលគ្នាទៅវិញទៅមក (រួចនិយាយថា៖) តើមាននរណាម្នាក់មើលឃើញពួកអ្នកដែរឬទេ? ក្រោយមក ពួកគេក៏ចាកចេញ(ពីកន្លែងជួបជុំនោះ)។ អល់ឡោះជាម្ចាស់បានបង្វែរចិត្តពួកគេដោយសារតែពួកគេ គឺជាក្រុមដែលគ្មានការយល់ដឹង។

128. ជាការពិតណាស់ អ្នកនាំសារម្នាក់(ព្យាការីមូហាំម៉ាត់)ដែលចេញមកអំពីពូជពង្សរបស់ពួកអ្នក(ជនជាតិអារ៉ាប់)បានមកដល់ពួកអ្នកហើយ។ គាត់ជាអ្នកទទួលរងការលំបាកដូចអ្វីដែលពួកអ្នកបានទទួលរងដែរ។ គាត់យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពួកអ្នក ហើយគាត់ជាអ្នកដែលមានភាពទន់ភ្លន់ និងក្តីមេត្តាករុណាចំពោះបណ្តាអ្នកដែលមានជំនឿ។

129. តែប្រសិនបើពួកគេបែរចេញ(ពីអ្នក)នោះ ចូរអ្នកពោលថា៖ អល់ឡោះជាម្ចាស់តែមួយគត់ គឺគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ចំពោះទ្រង់តែ(មួយគត់)ដែលខ្ញុំប្រគល់ការទុកចិត្ត ហើយទ្រង់ជាព្រះជាម្ចាស់នៃអារ៉ស្តដ៏ធំធេង។

ជំពូក យូនុស

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម រ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ ទាំងនោះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ដែលប្រកបដោយគតិបណ្ឌិត។

2. តើវាជារឿងភ្ញាក់ផ្អើលសម្រាប់មនុស្សឬដែលយើងបានផ្តល់វាហ៊ីទៅកាន់បុរសម្នាក់ក្នុងចំណោមពួកគេ(ព្យាការីមូហាំម៉ាត់)ដោយឲ្យគេដាស់តឿនព្រមានមនុស្សលោក(ពីទណ្ឌកម្មអល់ឡោះ)នោះ? ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿថា៖ ពិតប្រាកដណាស់ ពួកគេនឹងទទួលបានផលបុណ្យដ៏ល្អប្រពៃពីព្រះជាម្ចាស់របស់ពួកគេដោយសារតែអ្វីដែលពួកគេធ្លាប់បានសាងពីមុន។ ពួកគ្មានជំនឿបាននិយាយថា៖ ពិតប្រាកដណាស់(ព្យាការីមូហាំម៉ាត់)នេះគឺជាគ្រូមន្តអាគមយ៉ាងជាក់ច្បាស់។

3. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នក គឺអល់ឡោះដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីរយៈពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ទ្រង់នៅលើអារ៉ស្តេ។ ទ្រង់ចាត់ចែងកិច្ចការទាំងឡាយ។ គ្មាននរណាម្នាក់អាចធ្វើអន្តរាគមន៍(ដល់អ្វីមួយ)បានឡើយ លើកលែងតែបន្ទាប់ពីទ្រង់បានអនុញ្ញាតប៉ុណ្ណោះ។ នោះគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈចំពោះទ្រង់(តែមួយគត់)។ តើពួកអ្នកមិននឹករឭកទេឬ?

4. ទៅកាន់ទ្រង់(តែមួយគត់)ជាកន្លែងវិលត្រឡប់របស់ពួកអ្នកទាំងអស់គ្នា(នៅថ្ងៃបរលោក)។ ការសន្យារបស់អល់ឡោះគឺជាការពិត។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកផ្តើមបង្កើតអ្វីៗទាំងអស់(ដោយគ្មានគំរូពីមុនមក)។ បន្ទាប់មក ទ្រង់នឹងត្រឡប់គេ(ឱ្យមានវត្តមាន)សារជាថ្មី(បន្ទាប់ពីគេបានស្លាប់)ដើម្បីទ្រង់នឹងតបស្នងដល់បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលដោយភាពយុត្តិធម៌បំផុត។ ចំណែកឯពួកដែលគ្មានជំនឿនោះ ពួកគេនឹងទទួលបានទឹកធឹកដែលក្តៅ និងទណ្ឌកម្មដ៏ឈឺចាប់បំផុត ដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រឆាំង។

5. ទ្រង់គឺជាអ្នកដែលបានបង្កើតព្រះអាទិត្យឲ្យមានរស្មីចែងចាំង ហើយ(បង្កើត)ព្រះចន្ទឲ្យមានពន្លឺ ហើយទ្រង់បានកំណត់ដំណើរគោចររបស់វា(ជាខ្នើត-រនោច)ដើម្បីឲ្យពួកអ្នកបានដឹងពីចំនួនឆ្នាំ និងការគណនា(ពេលវេលា)។ អល់ឡោះមិនបានបង្កើតអ្វីៗទាំងនោះឡើយ លើកលែងតែដោយការពិត(គតិបណ្ឌិតច្បាស់លាស់)។ ទ្រង់បកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងទាំងឡាយសម្រាប់ក្រុមដែលចេះដឹង។

6. ពិតប្រាកដណាស់ ការផ្លាស់ប្តូរគ្នារវាងពេលយប់និងពេលថ្ងៃ ហើយនិងអ្វីដែលអល់ឡោះបានបង្កើតនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលកោតខ្លាច(ទ្រង់)។

7. ប្រាកដណាស់ ពួកដែលមិនរំពឹងថានឹងជួបយើង(អល់ឡោះ)ហើយពួកគេពេញចិត្តជីវិតលោកិយ ព្រមទាំងស្ងប់ចិត្តនឹងវា ហើយនិងពួកដែលព្រងើយកន្តើយចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើងនោះ

8. ពួកទាំងនោះ កន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺឋាននរក ដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

9. ពិតប្រាកដណាស់ បណ្ដាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលនោះ ព្រះជាម្ចាស់របស់ពួកគេនឹងចង្អុលបង្ហាញពួកគេដោយសារតែការមានជំនឿរបស់ពួកគេ។ (ទ្រង់នឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌)ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមពួកគេក្នុងឋានសួគ៌ណាអ៊ីម។

10. ការបួងសួងរបស់ពួកគេនៅក្នុងឋានសួគ៌នោះគឺ "អល់ឡោះជាម្ចាស់! ព្រះអង្គមហាស្អាតស្ដុះ"។ ហើយពាក្យស្វាគមន៍របស់ពួកគេនៅក្នុងឋានសួគ៌នោះគឺ សាឡាម(សន្តិភាព)។ ហើយនៅចុងបញ្ចប់នៃការបួងសួងរបស់ពួកគេ (ពួកគេពោលថា៖) សេចក្ដីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

11. ហើយប្រសិនបើអល់ឡោះឆ្លើយតបភ្លាមៗចំពោះការបួងសួងរបស់មនុស្សនូវប្រការអាក្រក់(ពេលដែលពួកគេបួងសួងសុំ) ដូចដែលទ្រង់ឆ្លើយតបភ្លាមៗចំពោះពួកគេនូវប្រការល្អនោះ ប្រាកដជាអាយុកាលកំណត់របស់ពួកគេនឹងត្រូវបញ្ចប់ជាមិនខាន។ ក៏ប៉ុន្តែទ្រង់ពន្យារពេលឱ្យពួកដែលមិនប្រាថ្នាថានឹងជួបយើងឱ្យស្ថិតនៅក្នុងភាពវង្វេងរបស់ពួកគេ ដោយពួកគេមានភាពស្រពិចស្រពិល(ជារឿងរហូត)។

12. ហើយនៅពេលគ្រោះថ្នាក់ណាមួយកើតឡើងចំពោះមនុស្ស គឺគេបួងសួងសុំពីយើងទាំងដោយដេកផ្ដៀង ឬអង្គុយ ឬឈរ។ តែនៅពេលដែលយើងដកយកគ្រោះនោះចេញពីរូបគេវិញ គេក៏បន្តធ្វើដូចមុន ហាក់បីដូចជារូបគេមិនបានបួងសួងសុំពីយើងឱ្យដកយកគ្រោះដែលគេជួបប្រទះនោះដូច្នោះដែរ។ ក៏ដូច្នោះដែរ គេបានតុបតែងលម្អសម្រាប់ពួកដែលបំពានដោយសារតែអ្វីដែលពួកគេធ្លាប់បានសាង។

13. ហើយជាការពិតណាស់ យើងបានបំផ្លាញប្រជាជាតិជាច្រើនមុនពួកអ្នក(ឱពួកមុស្លីគីន)នៅពេលដែលពួកគេបានបំពាន។ ហើយបណ្ដាអ្នកនាំសាររបស់ពួកគេបាននាំមកឱ្យពួកគេនូវភស្ដុតាងយ៉ាងច្បាស់លាស់ជាច្រើន ប៉ុន្តែពួកគេមិនមានជំនឿនោះឡើយ។ ក៏ដូច្នោះដែរ យើងនឹងតបស្នងដល់ក្រុមដែលប្រព្រឹត្តល្មើសទាំងឡាយ។

14. ក្រោយមក យើងបានបង្កើតពួកអ្នក(ឱមនុស្សលោក)ឱ្យធ្វើជាអ្នកស្នងការគ្រប់គ្រងលើផែនដីបន្ទាប់ពីពួកគេ ដើម្បីយើងនឹងពិនិត្យមើលថា តើពួកអ្នកនឹងធ្វើដូចម្ដេច?

15. ហើយនៅពេលដែលគេសូត្របណ្ដាវាក្យខណ្ឌរបស់យើងឱ្យពួកគេស្ដាប់ ពួកដែលមិនរំពឹងថានឹងជួបយើងបាននិយាយថា៖ ចូរអ្នក(ឱមូហាំម៉ាត់)នាំមកនូវគម្ពីរគួរអានផ្សេងក្រៅពី(គម្ពីរ)នេះ ឬផ្លាស់ប្ដូរវា។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ វាមិនត្រឹមត្រូវនោះទេក្នុងការដែលខ្ញុំផ្លាស់ប្ដូរវាតាមទំនើងចិត្តខ្ញុំនោះ។ ខ្ញុំមិនដើរតាមអ្វីក្រៅពីវាហ៊ីដែលគេបានផ្ដល់មកឱ្យខ្ញុំឡើយ។ ពិតប្រាកដណាស់ ខ្ញុំខ្លាចទណ្ឌកម្មនាថ្ងៃដ៏ធំធេង(ថ្ងៃបរលោក) ប្រសិនបើខ្ញុំល្មើសនឹងព្រះជាម្ចាស់របស់ខ្ញុំនោះ។

16. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើអល់ឡោះមានចេតនានោះ ខ្ញុំក៏មិនសូត្រវា(គម្ពីរគួរអាន)ឱ្យពួកអ្នកស្ដាប់ ហើយគេក៏មិនឱ្យពួកអ្នកដឹងអំពីវានោះដែរ។ ជាការពិតណាស់ ខ្ញុំបានរស់នៅជាមួយនឹងពួកអ្នកមួយរយៈកាលដ៏យូរមុននឹងវា(ត្រូវបានគេបញ្ចុះមក)។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

17. ជាការពិតណាស់ គ្មាននរណាម្នាក់ដែលបំពានជាងអ្នកដែលប្រឌិតកុហកទៅលើអល់ឡោះ ឬបដិសេធនឹងបណ្ដាវាក្យខណ្ឌរបស់ទ្រង់នោះឡើយ។ ពិតប្រាកដណាស់ ពួកដែលប្រព្រឹត្តល្មើសនោះនឹងមិនទទួលជោគជ័យឡើយ។

18. ហើយពួកគេ(ពួកមុស្លីគីន)បានគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះដែលពួកវាមិនអាចបង្កគ្រោះថ្នាក់ និងមិនអាចផ្ដល់ផលប្រយោជន៍ដល់ពួកគេផងនោះ។ ហើយពួកគេបាននិយាយថា៖ ពួកវាទាំងនោះ គឺជាអ្នកជួយអន្តរាគមន៍ដល់ពួកយើងនៅចំពោះមុខអល់ឡោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកកំពុងតែប្រាប់អល់ឡោះជាម្ចាស់នូវអ្វីដែលទ្រង់មិនដឹងសោះទាំងនៅលើមេឃជាច្រើនជាន់និងនៅលើផែនដីនោះឬ? ទ្រង់មហាបរិសុទ្ធ និងខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេកំពុងតែធ្វើស្ដីរិក។

19. ហើយមនុស្សធ្លាប់ជាប្រជាជាតិតែមួយ(មានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់) តែក្រោយមក ពួកគេបានខ្វែងគំនិតគ្នា។ ហើយប្រសិនបើគ្មានការកំណត់ពីព្រះជាម្ចាស់របស់អ្នកពីមុនមកទេនោះ ទ្រង់ប្រាកដជានឹងកាត់សេចក្តីរវាងពួកគេចំពោះអ្វីដែលពួកគេខ្វែងគំនិតគ្នា(នៅក្នុងលោកិយនេះ)ជាមិនខានឡើយ។

20. ហើយពួកគេនិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះឱ្យគាត់(ព្យាការីមូហាំម៉ាត់)នូវសញ្ញាកស្តុតាងណាមួយពីព្រះជាម្ចាស់របស់គាត់មក? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត មានតែអល់ឡោះ(តែមួយគត់)ដែលដឹងពីប្រការអាថ៌កំបាំងទាំងឡាយ។ ដូច្នេះ ចូរពួកអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ ខ្ញុំក៏ស្ថិតក្នុងចំណោមអ្នកដែលរង់ចាំមើលជាមួយពួកអ្នកដែរ។

21. ហើយនៅពេលដែលយើងបានឱ្យមនុស្សលោកភ្លក់រសជាតិនៃក្តីមេត្តាករុណា(ឧបការគុណ) ក្រោយពីគ្រោះបានកើតឡើងចំពោះពួកគេនោះ ស្រាប់តែពួកគេបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើងទៅវិញ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ អល់ឡោះជាម្ចាស់ គឺជាអ្នកដែលតបតនឹងឧបាយកលយ៉ាងលឿនបំផុត។ ពិតប្រាកដណាស់ អ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងនឹងកត់ត្រានូវឧបាយកលដែលពួកអ្នកបានរៀបចំ។

22. ទ្រង់ជាអ្នកដែលសម្រួលដល់ការធ្វើដំណើររបស់ពួកអ្នក(ឱមនុស្សលោក)ទាំងនៅលើគោក និងនៅលើផ្ទៃទឹក។ លុះដល់ពេលពួកអ្នកស្ថិតនៅក្នុងសំពៅ ហើយមានខ្យល់បរិសុទ្ធបានបក់បោកមកលើពួកគេ ហើយពួកគេសប្បាយរីករាយនោះ វាស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំងបានបក់បោកមកលើពួកគេ ព្រមទាំងមានរលកបក់បោកមកលើពួកគេពីគ្រប់ទិសទី ហើយពួកគេគិតថា៖ ពិតប្រាកដណាស់ ភាពអន្តរាយបានហ៊ុមព័ទ្ធពួកគេហើយនោះ ពួកគេក៏បួងសួងសុំពីអល់ឡោះជាម្ចាស់ដោយភាពស្មោះសចំពោះសាសនារបស់ទ្រង់ថា៖ ប្រសិនបើព្រះអង្គជួយសង្គ្រោះយើងខ្ញុំពីគ្រោះមហន្តរាយនេះ យើងខ្ញុំពិតជានឹងស្ថិតក្នុងចំណោមអ្នកដែលដឹងគុណ(ទ្រង់)ជាមិនខាន។

23. តែនៅពេលដែលទ្រង់បានជួយសង្គ្រោះពួកគេ(ពីគ្រោះមហន្តរាយ)ហើយនោះ ស្រាប់តែពួកគេបែរជាបង្កវិនាសកម្មនៅលើផែនដីដោយមិនត្រឹមត្រូវទៅវិញ។ ឱមនុស្សលោកទាំងឡាយ! ការបំពានរបស់ពួកអ្នក គឺនឹងធ្លាក់ទៅលើខ្លួនពួកអ្នកផ្ទាល់ប៉ុណ្ណោះ។ ការត្រេកត្រអាលនឹងជីវិតលោកិយ(គឺគ្រាន់តែបណ្តោះអាសន្ន)។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកអ្នក គឺមកកាន់យើង(តែមួយគត់)។ ពេលនោះ យើងនឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

24. តាមពិត ការប្រៀបធៀបឆាកជីវិតលោកិយនេះ គឺប្រៀបដូចជាទឹកភ្លៀងដែលយើងបានបញ្ចុះវាពីលើមេឃដែលធ្វើឱ្យរុក្ខជាតិនៅលើផែនដីដុះចម្រុះគ្នានូវអ្វីដែលមនុស្ស និងសត្វអាចបរិភោគបាន។ លុះដល់ពេលដែលដីបានបញ្ចេញនូវភាពស្រស់បំព្រង និងភាពស្រស់ស្អាតរបស់វា(តាមរយៈរុក្ខជាតិជាច្រើនប្រភេទ) ហើយម្ចាស់របស់វាគិតថា ពួកគេជាអ្នកដែលមានលទ្ធភាព(អាចប្រមូលផលអំពីវាបាន)ហើយនោះ ស្រាប់តែបទបញ្ជារបស់យើងក៏បានមកដល់នៅពេលយប់ ឬពេលថ្ងៃ។ ពេលនោះ យើងក៏បានធ្វើឱ្យវាត្រូវខូចខ្ទេចខ្ទីអស់ ហាក់ដូចជាមិនធ្លាប់មានអ្វីសោះកាលពីម្សិលៗ។ ក៏ដូច្នោះដែរ យើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងជាច្រើនសម្រាប់ក្រុមដែលចេះគិតពិចារណា។

25. ហើយអល់ឡោះទ្រង់អំពាវនាវទៅកាន់លំនៅឋាននៃសន្តិភាព(ឋានសួគ៌) ហើយទ្រង់ចង្អុលបង្ហាញជនណាដែលទ្រង់មានចេតនាទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ(សាសនាអ៊ីស្លាម)។

26. សម្រាប់បណ្តាអ្នកដែលបានសាងអំពើល្អ នឹងទទួលបាននូវប្រការល្អ(ឋានសួគ៌) ហើយនិងការបន្ថែមលើសពីនោះទៅទៀត(មើលឃើញព្រះភក្ត្រអល់ឡោះជាម្ចាស់)។ គ្មានធូលីខ្មៅគ្របដណ្តប់លើផ្ទៃមុខរបស់ពួកគេឡើយ ហើយក៏គ្មានភាពអាប់ឱន(គ្របដណ្តប់លើវា)នោះដែរ។ អ្នកទាំងនោះហើយ គឺជាអ្នកឋានសួគ៌ដោយពួកគេស្ថិតនៅទីនោះជាអមតៈ។

27. រីឯពួកដែលសាងអំពើអាក្រក់ ការតបស្នងចំពោះអំពើអាក្រក់នោះ គឺតាមទំហំនៃអំពើអាក្រក់(របស់ពួកគេ) ហើយភាពអាប់ឱនបានគ្របដណ្តប់លើពួកគេ។ សម្រាប់ពួកគេ គឺគ្មានអ្នកការពារពី(ទណ្ឌកម្ម)អល់ឡោះឡើយ ហាក់ដូចជាមុខរបស់ពួកគេត្រូវបានគ្របដណ្តប់ដោយភាពងងឹតនៃពេលរាត្រីដូច្នោះដែរ។ ពួកទាំងនោះហើយ គឺជាពួកឋាននរកដោយពួកគេស្ថិតនៅទីនោះជាអមតៈ។

28. (ហើយចូរអ្នកនឹកឃើញ) នៅថ្ងៃដែលយើងនឹងប្រមូលផ្តុំពួកគេទាំងអស់គ្នា។ ក្រោយមក យើងមានបន្ទូលទៅកាន់ពួកដែលបានធ្វើស៊ីរិកថាៈ ចូរពួកអ្នក និងព្រះនានារបស់ពួកអ្នកប្រកាន់ខ្ជាប់នឹងទីកន្លែងរបស់ពួកអ្នកចុះ។ ហើយយើងបានបំបែកវាងពួកគេ។ ហើយព្រះនានារបស់ពួកគេបាននិយាយថាៈ ពួកអ្នកមិនធ្លាប់គោរពសក្ការៈមកចំពោះពួកយើងឡើយ។

29. (ពួកវាបន្តថាៈ) គ្រប់គ្រាន់ហើយដែលអល់ឡោះគឺជាសាក្សីរវាងពួកយើងនិងពួកអ្នក។ ពិតប្រាកដណាស់ ពួកយើងមិនមានអារម្មណ៍(មិនដឹងមិនឮ)ចំពោះការគោរពសក្ការៈរបស់ពួកអ្នកនោះឡើយ។

30. នៅទីនោះ(កន្លែងកាត់សេចក្តី) ជីវិតគ្រប់រូបនឹងបានដឹងនូវអ្វីដែលខ្លួនធ្លាប់បានសាង។ ហើយពួកគេត្រូវបានគេនាំត្រឡប់ទៅកាន់អល់ឡោះដែលជាព្រះជាម្ចាស់ដ៏ពិតប្រាកដរបស់ពួកគេ។ ហើយអ្វី(ព្រះនានា)ដែលពួកគេធ្លាប់បានប្រឌិតឡើង(ថាជាព្រះនោះ) បានរសាត់បាត់បង់ពីពួកគេ។

31. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ តើនរណាជាអ្នកប្រទានលាភសក្ការៈឱ្យពួកអ្នកពីលើមេឃ និងផែនដី? តើអ្នកណាជាអ្នកគ្រប់គ្រងការឮ និងការឃើញ? ហើយតើនរណាជាអ្នកដែលបញ្ចេញរបស់មានជីវិតពីរបស់ស្លាប់ និងបញ្ចេញរបស់ស្លាប់ពីរបស់មានជីវិត? ហើយតើនរណាជាអ្នកចាត់ចែងកិច្ចការទាំងឡាយ? ពួកគេនឹងឆ្លើយថាៈ គឺអល់ឡោះជាម្ចាស់(តែមួយគត់)។ ចូរអ្នកពោលថាៈ ដូច្នេះ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

32. ជាការពិតណាស់ នោះហើយគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នកយ៉ាងពិតប្រាកដ។ ដូច្នេះ តើមានអ្វីទៀតបន្ទាប់ពីការពិត ក្រៅតែពីភាពវង្វេងនោះ? ហេតុនេះ តើពួកអ្នកត្រូវបានគេបង្វែរ(ចេញពីការពិត)យ៉ាងដូចម្តេច?

33. ក៏ដូច្នោះដែរ បន្ទូលនៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានកំណត់ចំពោះពួកដែលប្រព្រឹត្តល្មើសរួចទៅហើយថាៈ ពិតប្រាកដណាស់ ពួកគេគឺគ្មានជំនឿឡើយ។

34. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ តើក្នុងចំណោមព្រះនានារបស់ពួកអ្នកមានអ្នកដែលផ្តើមបង្កើតអ្វីៗទាំងអស់(ដោយគ្មានគំរូពីមុនមក) បន្ទាប់មក ត្រឡប់វា(ឲ្យមានវត្តមាន)សារជាថ្មី(បន្ទាប់ពីស្លាប់)ដែរឬទេ? ចូរអ្នកពោលចុះថាៈ អល់ឡោះទ្រង់ជាអ្នកផ្តើមបង្កើតអ្វីៗទាំងអស់(ដោយគ្មានគំរូពីមុនមក)។ បន្ទាប់មក ទ្រង់នឹងត្រឡប់គេ(ឱ្យមានវត្តមាន)សារជាថ្មីឡើងវិញ(បន្ទាប់ពីគេបានស្លាប់)។ ដូច្នេះ តើពួកអ្នក(ឱពួកមុស្លីគីន)ត្រូវបានគេបង្វែរ(ចេញពីការពិត)យ៉ាងដូចម្តេច?

35. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ តើក្នុងចំណោមព្រះនានារបស់ពួកអ្នកមានអ្នកអាចចង្អុលបង្ហាញទៅកាន់ការពិតដែរឬទេ? ចូរអ្នកពោលថាៈ អល់ឡោះ(តែមួយគត់)ដែលអាចចង្អុលបង្ហាញទៅកាន់ការពិតបាន។ ដូច្នេះ តើអ្នកដែលអាចចង្អុលបង្ហាញ(អ្នកដទៃ)ទៅការពិតបានសក្តិសមនឹងឲ្យគេដើរតាមជាង ឬក៏អ្នកដែលមិនអាចសូម្បីតែចង្អុលបង្ហាញខ្លួនឯង លើកលែងតែត្រូវការគេចង្អុលបង្ហាញនោះ(សក្តិសមជាង)? ដូចនេះ តើពួកអ្នកវិនិច្ឆ័យ(ចំពោះរឿងនេះ)ដោយរបៀបណា?

36. ហើយភាគច្រើននៃពួកគេ(ពួកមុស្លីគីន) គឺមិនជើរតាមអ្វីក្រៅតែពីការស្មានប៉ុណ្ណោះ។ ពិតប្រាកដណាស់ ការស្មានមិនអាចផ្តល់ជាប្រយោជន៍អ្វីដល់ការជឿងច្បាស់បន្តិចណាឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

37. ហើយវាមិនត្រឹមត្រូវនោះទេដែលថា គម្ពីរគួរអាននេះត្រូវបានគេបង្កើតឡើង និងថាវាមិនមែនមកពីអល់ឡោះជាម្ចាស់នោះ។ ផ្ទុយទៅវិញ វា(គម្ពីរគួរអាន)គឺជាការបញ្ជាក់ទៅលើបណ្តាគម្ពីរដែលបានបញ្ចុះពីមុនវា និងជាការអធិប្បាយបញ្ជាក់លម្អិតអំពីក្បួនច្បាប់នានាដោយគ្មានការសង្ស័យឡើយនៅក្នុងវាដែលថា ពិតណាស់វា(ត្រូវបានបញ្ចុះ)មកពីព្រះជាម្ចាស់នៃពិភពទាំងអស់។

38. ផ្ទុយទៅវិញ ពួកគេ(ពួកមុស្លីគីន)បែរជានិយាយថា៖ គាត់(ព្យាការីមូហាំម៉ាត់)បានប្រឌិតវាឡើង។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ ចូរពួកអ្នកនាំមកនូវជំពូកណាមួយដែលដូចនឹងវា(គម្ពីរគួរអាន) ហើយចូរពួកអ្នកហៅអ្នកណាដែលពួកអ្នកអាចហៅពួកគេបានក្រៅពីអល់ឡោះ(ឲ្យមកជួយពួកអ្នក)ចុះ ប្រសិនបើពួកអ្នក គឺជាអ្នកទៀងត្រង់មែននោះ។

39. ផ្ទុយទៅវិញ ពួកគេ(ប្រញាប់)បដិសេធនឹងវា(គម្ពីរគួរអាន)មុនពេលដែលពួកគេមិនទាន់ទាំងឈ្វេងយល់អំពីវាសោះ ខណៈដែលភាពជាក់ស្តែងរបស់វាមិនទាន់បានមកដល់ពួកគេផងនោះ។ ក៏ដូច្នោះដែរ អ្នកជំនាន់មុនពួកគេក៏បានបដិសេធដូចគ្នាដែរ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះថា តើលទ្ធផលចុងក្រោយរបស់ពួកដែលបំពាននោះទៅជាយ៉ាងណា?

40. ហើយក្នុងចំណោមពួកគេ មានអ្នកខ្លះមានជំនឿនឹងវា(គម្ពីរគួរអាន) ហើយមានអ្នកខ្លះទៀត មិនមានជំនឿនឹងវាឡើយ។ ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងបំផុតចំពោះពួកដែលបង្កវិនាសកម្ម។

41. ហើយប្រសិនបើពួកគេបដិសេធនឹងអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ចូរអ្នកពោលចុះថា៖ ទង្វើរបស់ខ្ញុំ គឺសម្រាប់ខ្ញុំ ហើយទង្វើរបស់ពួកអ្នក គឺសម្រាប់ពួកអ្នក។ ពួកអ្នកមិនពាក់ព័ន្ធនឹងអ្វីដែលខ្ញុំបានប្រព្រឹត្តនោះឡើយ ហើយខ្ញុំក៏មិនពាក់ព័ន្ធនឹងអ្វីដែលពួកអ្នកបានប្រព្រឹត្តនោះដែរ។

42. ហើយក្នុងចំណោមពួកគេ(ពួកមុស្លីគីន) មានអ្នកខ្លះកំពុងតែស្តាប់អ្នក(សូត្រគម្ពីរគួរអាន)។ ដូច្នេះ តើអ្នកមានលទ្ធភាពអាចឱ្យមនុស្សថ្លង់ស្តាប់ឮឬ បើទោះជាពួកគេមិនចេះគិតពិចារណាក៏ដោយនោះ?

43. ហើយក្នុងចំណោមពួកគេមានអ្នកដែលមើលទៅកាន់អ្នក(ឱអ្នកនាំសារ)។ ដូច្នេះ តើអ្នកមានសមត្ថភាពអាចចង្អុលបង្ហាញមនុស្សខ្វាក់ឬ បើទោះជាពួកគេមើលមិនធ្លាប់មើលឃើញក៏ដោយនោះ?

44. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនបំពានលើមនុស្សលោកបន្តិចណាឡើយ។ ក៏ប៉ុន្តែ មនុស្សលោកវិញទេដែលបំពានលើខ្លួនឯងនោះ។

45. ហើយនៅថ្ងៃដែលទ្រង់ប្រមូលផ្តុំពួកគេ(ថ្ងៃបរលោក) ពួកគេហាក់ដូចជាមិនធ្លាប់បានរស់នៅ(ក្នុងលោកិយ)នោះឡើយ លើកលែងតែត្រឹមរយៈពេលមួយម៉ោងនៃពេលថ្ងៃដែលពួកគេស្គាល់គ្នាទៅវិញទៅមកប៉ុណ្ណោះ។ ពិតជាបានខាតបង់ហើយពួកដែលបដិសេធនឹងការជួបអល់ឡោះ(នៅថ្ងៃបរលោក) ហើយពួកគេក៏មិនធ្លាប់ទទួលបានការចង្អុលបង្ហាញនោះដែរ។

46. ហើយបើទោះបីជាយើងបង្ហាញឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មើលឃើញមួយចំនួន(នៃទណ្ឌកម្ម)ដែលយើងបានសន្យាចំពោះពួកគេ ឬក៏យើងឱ្យអ្នកស្លាប់(មុនអ្នកបានឃើញវា)ក៏ដោយ ក៏កន្លែងវិលត្រឡប់របស់ពួកគេ គឺមកកាន់យើងដដែល។ បន្ទាប់មក អល់ឡោះ គឺជាសាក្សីចំពោះអ្វីដែលពួកគេបានប្រព្រឹត្ត។

47. ហើយរាល់ប្រជាជាតិនីមួយៗគឺមានអ្នកនាំសារម្នាក់។ ដូច្នេះនៅពេលដែលអ្នកនាំសាររបស់ពួកគេបានមកដល់គេ (អល់ឡោះ)នឹងកាត់សេចក្តីរវាងពួកគេដោយយុត្តិធម៌។ ហើយពួកគេមិនត្រូវបានគេបំពាននោះឡើយ។

48. ហើយពួកគេ(ពួកគ្មានជំនឿ)និយាយថា៖ តើការសន្យា(ដាក់ទណ្ឌកម្ម)នេះនឹងមកដល់នៅពេលណា ប្រសិនបើពួកអ្នកគឺជាអ្នកទៀងត្រង់មែននោះ?

49. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំគ្មានសមត្ថភាពអាចការពារគ្រោះថ្នាក់ចេញពីខ្លួនខ្ញុំ ហើយក៏មិនអាចផ្តល់ផលប្រយោជន៍(ដល់ខ្លួនឯង)នោះដែរ លើកលែងតែអ្វីដែលអល់ឡោះទ្រង់មានចេតនាប៉ុណ្ណោះ។ រាល់ប្រជាជាតិនីមួយៗគឺមានអាយុកាលកំណត់រួចជាស្រេច។ ដូចនេះ នៅពេលដែលអាយុកាលកំណត់របស់ពួកគេបានមកដល់ហើយនោះ គឺពួកគេមិនអាចពន្យារពេលនោះឡើយ ហើយក៏មិនអាចឱ្យវាមកដល់មុនពេលកំណត់នោះដែរ ទោះបីមួយវិនាទីក៏ដោយ។

50. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើពួកអ្នកយល់ឃើញយ៉ាងណា ប្រសិនបើទណ្ឌកម្មរបស់ទ្រង់បានមកដល់ពួកអ្នកនៅពេលយប់ ឬនៅពេលថ្ងៃនោះ តើអ្វីដែលពួកប្រព្រឹត្តល្មើសប្រញាប់ចង់បានអំពីវានោះ?

51. តើរហូតទាល់តែវា(ទណ្ឌកម្ម)កើតឡើងឬ ទើបពួកអ្នកមានជំនឿនឹងវា? តើពេលនេះ (ទើបពួកអ្នកមានជំនឿឬ) ខណៈដែលពីមុនមក ពួកអ្នកធ្លាប់សុំឱ្យវាឆាប់កើតឡើងនោះ?

52. ក្រោយមក(បន្ទាប់ពីទណ្ឌកម្មមកដល់) មានគេនិយាយទៅកាន់ពួកបំពានថា៖ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មជាអមតៈនេះ។ តើពួកអ្នកមិនត្រូវបានគេតបស្នងទៅតាមអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តទេឬ?

53. ហើយពួកគេនឹងស្នើឱ្យអ្នកប្រាប់(ពីទណ្ឌកម្ម)ថា តើវាជាការពិតឬ? ចូរអ្នកពោលថា៖ ពិតមែនហើយ សូមស្បថនឹងអល់ឡោះ វាគឺជាការពិត ហើយពួកអ្នកមិនអាចគេចផុតពីវាបានឡើយ។

54. ហើយប្រសិនបើរាល់អ្នកបំពានមានអ្វីទាំងអស់នៅលើផែនដី(អាចយកមកលោះរូបគេពីទណ្ឌកម្ម)នោះ ប្រាកដជាគេយកវាមកលោះខ្លួនគេជាមិនខាន។ ហើយពួកគេបានលាក់បាំងវិប្បដិសារី(របស់ខ្លួន)នៅពេលដែលពួកគេបានឃើញទណ្ឌកម្ម(នៅថ្ងៃបរលោក)។ ហើយគេ(អល់ឡោះ)នឹងកាត់សេចក្តីរវាងពួកគេដោយយុត្តិធម៌ ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

55. តើពុំមែនទេឬដែលរាល់អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់ និងលើផែនដី គឺជាម្ចាស់កម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)នោះ? ហើយតើពុំមែនទេឬដែលការសន្យារបស់អល់ឡោះ គឺជាការពិតនោះ? ក៏ប៉ុន្តែភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

56. ទ្រង់ជាអ្នកផ្តល់ជីវិត និងជាអ្នកដកយកជីវិត។ ហើយគេនឹងនាំពួកអ្នកត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។

57. ឱមនុស្សលោកទាំងឡាយ! ជាការពិតណាស់ ដំបូន្មានពីព្រះជាម្ចាស់របស់ពួកអ្នក(គម្ពីរគួរអាន)បានមកដល់ពួកអ្នកហើយ ហើយវាជាឱសថព្យាបាលនូវអ្វីដែលមាននៅក្នុងដួងចិត្ត ជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់បណ្តាអ្នកដែលមានជំនឿ។

58. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ដោយការប្រោសប្រទានរបស់អល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់(ចំពោះពួកអ្នក) ចូរពួកអ្នកសប្បាយរីករាយចុះ។ វាគឺល្អប្រសើរជាងអ្វី(ទ្រព្យសម្បត្តិ)ដែលពួកគេខំប្រមូលទុកទៅទៀត។

59. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកយល់យ៉ាងណាចំពោះលាភសក្ការៈដែលអល់ឡោះបានប្រទានដល់ពួកអ្នក ដោយពួកអ្នកបានដាក់ជាបំរាមទៅចំពោះរបស់ខ្លះ ហើយរបស់ខ្លះទៀត ពួកអ្នកអនុញ្ញាត។ ចូរអ្នកពោលទៀតថា៖ តើអល់ឡោះទ្រង់អនុញ្ញាតឱ្យពួកអ្នក(អាចធ្វើដូច្នោះ) ឬមួយក៏ពួកអ្នកប្រឌិតពាក្យភូតកុហកទៅលើអល់ឡោះ(ដោយខ្លួនឯង)?

60. ហើយតើអ្វីមួយដែលពួកប្រឌិតកុហកទៅលើអល់ឡោះនោះគិតថានឹងកើតឡើងចំពោះពួកគេនៅថ្ងៃបរលោកនោះ? ពិតប្រាកដណាស់ អល់ឡោះទ្រង់មានការប្រោសប្រណីបំផុតចំពោះមនុស្សលោក ក៏ប៉ុន្តែភាគច្រើននៃពួកគេមិនដឹងគុណឡើយ។

61. ហើយគ្មានកិច្ចការណាមួយដែលអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានធ្វើ និងគ្មានអ្វីមួយដែលអ្នកបានសូត្រអំពីគម្ពីរគួរអានហើយក៏គ្មានអ្វីមួយដែលពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)បានធ្វើនោះដែរ លើកលែងតែយើងឃើញពួកអ្នកនៅពេលដែលពួកអ្នកបានធ្វើវា។ ហើយគ្មានអ្វីមួយអាចលាក់បាំងពីព្រះជាម្ចាស់របស់អ្នកបានឡើយ សូម្បីតែប៉ុនលំអងធូលីដ៏តូចបំផុតនៅលើផែនដី ឬនៅលើមេឃក៏ដោយ ហើយមិនថាវាតូចជាងនេះ ឬធំជាងនេះឡើយ លើកលែងតែវាត្រូវបានកត់ត្រាទុកនៅក្នុងគម្ពីរកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)យ៉ាងច្បាស់លាស់។

62. តើពុំមែនទេឬ បណ្តាអ្នកមានជំនឿដ៏ស្មោះត្រង់លើអល់ឡោះ ពួកគេគ្មានការភ័យខ្លាច ហើយពួកគេក៏មិនមានទុក្ខព្រួយដែរនោះ?

63. គឺបណ្តាអ្នកដែលមានជំនឿ ហើយពួកគេកោតខ្លាច(អល់ឡោះ)។

64. ពួកគេនឹងទទួលបានដំណឹងរីករាយទាំងនៅក្នុងជីវិតលោកិយ និងនៅថ្ងៃបរលោក។ បន្ទូលរបស់អល់ឡោះ គឺគ្មានការផ្លាស់ប្តូរឡើយ។ នោះហើយគឺជាជោគជ័យដ៏ធំធេង។

65. សូមអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំឲ្យពាក្យសម្តីរបស់ពួកគេធ្វើឲ្យអ្នកមានទុក្ខព្រួយ។ ពិតប្រាកដណាស់ អំណាចដ៏ខ្លាំងក្លាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ទ្រង់មហាឮ មហាដឹងបំផុត។

66. តើពុំមែនទេឬដែលថាអ្នកដែលនៅលើមេឃជាច្រើនជាន់ និងអ្នកដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)នោះ? ហើយពួកដែលគោរពសក្ការៈចំពោះអ្វីផ្សេងក្រៅពីអល់ឡោះនោះមិនបានប្រតិបត្តិតាមព្រះនានា(របស់ពួកគេ)នោះឡើយ។ តាមពិត ពួកគេដើរតាមតែការស្មាន(របស់ពួកគេ)ប៉ុណ្ណោះ។ ហើយពួកគេក៏គ្មានអ្វីក្រៅពីការប្រឌិតភូតកុហកនោះ។

67. ទ្រង់ជាអ្នកដែលបានបង្កើតពេលយប់សម្រាប់ពួកអ្នក(ឱមនុស្សលោក)ដើម្បីឱ្យពួកអ្នកបានសម្រាកនៅក្នុងវា ហើយទ្រង់បានបង្កើតពេលថ្ងៃជាពន្លឺ។ ពិតប្រាកដណាស់ នៅក្នុងរឿងទាំងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលស្តាប់ឮ(ចេះគិតពិចារណា)។

68. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ អល់ឡោះទ្រង់មានបុត្រ។ ទ្រង់មហាស្អាតស្អំបំផុត។ ទ្រង់មហាមានលើសលប់។ អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលមាននៅលើផែនដីគឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ពួកអ្នក(ឱពួកមុស្លីគីន)គ្មានអំណះអំណាងអ្វីមកបញ្ជាក់ចំពោះរឿងនេះឡើយ។ តើពួកអ្នកនិយាយ(ចោទប្រកាន់)ទៅលើអល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹងឬ?

69. ចូរអ្នក(ឱអ្នកនាំសារ)ពោលថា៖ ពិតប្រាកដណាស់ ពួកដែលបានប្រឌិតកុហកទៅលើអល់ឡោះ ពួកគេនឹងមិនទទួលបានជោគជ័យឡើយ។

70. ភាពត្រេកត្រអាលក្នុងលោកិយ(គឺមួយរយៈពេលខ្លីប៉ុណ្ណោះ)។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកគេ គឺឆ្ពោះមកកាន់យើង(តែមួយគត់)។ បន្ទាប់មក យើងនឹងឱ្យពួកគេភ្លក់នូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រឆាំង។

71. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)និទានប្រាប់ពួកគេ(ពួកមុស្លីគីន)នូវរឿងរ៉ាវរបស់ព្យាការីនួហ នៅពេលគាត់បានពោលទៅកាន់ក្រុមរបស់គាត់ថា៖ ឱក្រុមរបស់ខ្ញុំ! ប្រសិនបើការរស់នៅរបស់ខ្ញុំ និងការដាស់រំឭករបស់ខ្ញុំពីកស្តុតាងនានារបស់អល់ឡោះមានភាពធ្ងន់ធ្ងរសម្រាប់ពួកអ្នកនោះ ជាការពិតណាស់ ចំពោះអល់ឡោះ(តែមួយគត់)ដែលខ្ញុំប្រគល់ការទុកចិត្ត។ ហេតុនេះ ចូរពួកអ្នករៀបចំកិច្ចការរបស់ពួកអ្នក និងហៅព្រះនានារបស់ពួកអ្នក(ឱ្យពួកគេមកជួយពួកអ្នក)ចុះ។ បន្ទាប់មក ចូរកុំឱ្យល្បិចកលរបស់ពួកអ្នកក្លាយជារឿងអាថ៌កំបាំងឱ្យសោះ(សូមធ្វើវាដោយបើកចំហ)។ ក្រោយមកទៀត ចូរពួកអ្នកធ្វើទារុណកម្មលើខ្ញុំមកចុះ និងមិនត្រូវពន្យារពេលដល់ខ្ញុំឡើយ។

72. ហើយប្រសិនបើពួកអ្នកងាកចេញ(ពីការអំពាវនាវរបស់ខ្ញុំ) ពួកអ្នកត្រូវដឹងថា ពិតប្រាកដណាស់ ខ្ញុំមិនបានសុំការតបស្នងពីពួកអ្នកឡើយ។ ផ្ទុយទៅវិញ ការតបស្នង(ផលបុណ្យ)របស់ខ្ញុំ គឺស្ថិតនៅលើអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ហើយគេបានបង្គាប់ប្រើខ្ញុំឱ្យក្លាយជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន(ជាអ្នកមូស្លីម)។

73. ប៉ុន្តែពួកគេបានបដិសេធចំពោះគាត់។ ដូច្នេះ យើងក៏បានជួយសង្គ្រោះគាត់ និងអ្នកដែលនៅជាមួយគាត់នៅក្នុងសំពៅ ហើយយើងបានធ្វើឱ្យពួកគេ(អ្នកមានជំនឿលើព្យាការីនួហ)ជាអ្នកស្នងការគ្រប់គ្រង(លើផែនដីបន្ទាប់ពីពួកគេ)។ យើងបានពន្លិចពួកដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង(ដោយទឹកជំនន់)។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះថា តើលទ្ធផលចុងក្រោយរបស់ពួកដែលត្រូវបានគេព្រមាននោះយ៉ាងដូចម្តេច?

74. ក្រោយមក យើងបានតែងតាំងអ្នកនាំសារជាច្រើនបន្ទាប់ពីគេ(ព្យាការីនួហ)ទៅកាន់ក្រុមរបស់ពួកគេដោយនាំមកឱ្យពួកគេនូវសញ្ញាកស្តុតាងយ៉ាងច្រើន។ ប៉ុន្តែពួកគេនៅតែមិនមានជំនឿចំពោះអ្វីដែលពួកគេ(អ្នកជំនាន់មុន)បានបដិសេធដដែល។ ក៏ដូច្នោះដែរ យើងបានបោះត្រាភ្ជិតទៅលើដួងចិត្តរបស់ពួកដែលបំពាន។

75. ក្រោយមកទៀត យើងក៏បានតែងតាំងបន្ទាប់ពីអ្នកនាំសារទាំងនោះនូវព្យាការីមូសា និងព្យាការីហារូនទៅកាន់ហ្វៀរអោន និងបក្សពួករបស់គេជាមួយនឹងសញ្ញាកស្តុតាងជាច្រើនរបស់យើង។ ប៉ុន្តែពួកគេបែរជាក្រអឺតក្រទម(មិនព្រមមានជំនឿ)ហើយពួកគេគឺជាក្រុមដែលប្រព្រឹត្តល្មើស។

76. ហើយនៅពេលដែលសេចក្តីពិតអំពីយើងបានទៅដល់ពួកគេ ពួកគេបែរជានិយាយថា៖ ពិតប្រាកដណាស់ នេះគឺជាមន្តអាគមយ៉ាងច្បាស់លាស់។

77. ព្យាការីមូសាបាននិយាយថា៖ តើពួកអ្នកនិយាយមួលបង្កាច់ចំពោះសេចក្តីពិតនៅពេលដែលវាបានមកដល់ពួកអ្នកឬ? តើនេះឬជាមន្តអាគមនោះ ខណៈដែលគ្រូមន្តអាគមទាំងឡាយ គឺមិនទទួលបានជោគជ័យឡើយ។

78. ពួកគេបានតបថា៖ តើអ្នកមកកាន់ពួកយើងដើម្បីឱ្យពួកយើងបែរចេញពីអ្វី(សាសនា)ដែលពួកយើងបានឃើញដីដូនដីតារបស់ពួកយើងប្រកាន់យក និងដើម្បីឱ្យអ្នកទាំងពីរទទួលបានអំណាចគ្រប់គ្រងនៅលើផែនដីនេះឬ? ពួកយើងមិនទទួលស្គាល់អ្នកទាំងពីរ(ថាជាអ្នកនាំសារពីព្រះជាម្ចាស់)ឡើយ។

79. ហើយហ្វៀរអោនបាននិយាយថា៖ ចូរពួកអ្នកនាំគ្រូមន្តអាគមដែលខ្លាំងពូកែទាំងអស់មកកាន់យើង។

80. ហើយនៅពេលដែលគ្រូមន្តអាគមទាំងអស់បានមកដល់ ព្យាការីមូសាបាននិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នក(ឱពួកគ្រូមន្តអាគមទាំងឡាយ)បោះនូវអ្វីដែលពួកអ្នកចង់បោះនោះចុះ។

81. ហើយនៅពេលពួកគេបានបោះ(នូវមន្តអាគមរបស់ពួកគេ)ព្យាការីមូសាក៏បាននិយាយថា៖ អ្វីដែលពួកអ្នកបាននាំមកនោះវាគ្រាន់តែជាមន្តអាគមប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះនឹងធ្វើឱ្យវាក្លាយជាអសារបង់(គ្មានប្រសិទ្ធភាព)ឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនសម្រួលដល់កិច្ចការរបស់ពួកដែលបង្កវិនាសកម្មឡើយ។

82. ហើយអល់ឡោះនឹងបញ្ជាក់ឲ្យឃើញនូវការពិតតាមរយៈពាក្យបន្ទូលរបស់ទ្រង់ បើទោះបីជាពួកដែលប្រព្រឹត្តល្មើសទាំងឡាយមិនពេញចិត្តក៏ដោយ។

83. ហើយគ្មាននរណាដែលមានជំនឿលើព្យាការីមូសាឡើយ លើកលែងតែយុវជនក្នុងចំណោមក្រុមរបស់គាត់(ដែលជាអម្បូរអ៊ីស្រាអែល)ប៉ុណ្ណោះ ខណៈដែលពួកគេបារម្ភខ្លាចហ្វៀរអោននិងក្រុមមន្ត្រីរបស់គេបង្ករភាពវឹកវរដល់ពួកគេ(បង្វែរពួកគេចេញពីការមានជំនឿតាមរយៈការធ្វើទារុណកម្ម)។ ពិតប្រាកដណាស់ ហ្វៀរអោន គឺជាអ្នកដែលក្អេងក្អាងបំផុតនៅលើផែនដី ហើយពិតប្រាកដណាស់ រូបគេគឺស្ថិតក្នុងចំណោមពួកដែលបំពាន។

84. ហើយព្យាការីមូសាបាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ប្រសិនបើពួកអ្នកមានជំនឿលើអល់ឡោះជាម្ចាស់នោះ ចូរពួកអ្នកប្រគល់ការទុកចិត្តទៅលើទ្រង់(តែមួយគត់)ប្រសិនបើពួកអ្នកជាអ្នកប្រគល់ខ្លួន(ជាជនមូស្លីម)មែននោះ។

85. ពេលនោះ ពួកគេបានតបថា៖ ពួកយើងបានប្រគល់ការទុកចិត្តទៅចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)ហើយ។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាកុំឲ្យពួកយើងក្លាយជាការសាកល្បងសម្រាប់ក្រុមដែលបំពាន។

86. ហើយសូមព្រះអង្គមេត្តាសង្គ្រោះយើងខ្ញុំចេញពីក្រុមដែលគ្មានជំនឿដោយក្តីមេត្តាករុណារបស់ទ្រង់ផងចុះ។

87. ហើយយើង(អល់ឡោះ)បានផ្តល់វាហ៊ីទៅកាន់ព្យាការីមូសានិងបងប្រុសរបស់គេ(ព្យាការីហារូន)ថា៖ ចូរអ្នកទាំងពីរតាំងទីលំនៅសម្រាប់ក្រុមរបស់អ្នកទាំងពីរនៅក្នុងប្រទេសអេហ្ស៊ីបនេះ។ ហើយចូរពួកអ្នកធ្វើលំនៅឋានរបស់ពួកអ្នកតម្រង់ទៅកាន់ទិសគិបឡាត់(ពៃទុលមឹកទីស)និងត្រូវប្រតិបត្តិសឡាត។ ហើយចូរអ្នក(ឱព្យាការីមូសា)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ។

88. ហើយព្យាការីមូសាបានពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ ព្រះអង្គបានប្រទានដល់ហ្វៀរអោននិងក្រុមមន្ត្រីរបស់គេនូវគ្រឿងលម្អ និងទ្រព្យសម្បត្តិជាច្រើននៅក្នុងជីវិតលោកិយនេះ។ ប៉ុន្តែពួកគេបែរជាយកវបស់ទាំងនោះធ្វើឱ្យពួកគេវង្វេងចេញពីមាគ៌ារបស់ទ្រង់ទៅវិញ។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេចុះ ហើយសូមព្រះអង្គធ្វើឱ្យចិត្តរបស់ពួកគេមានភាពរឹងរូស(មិនទទួលយកការពិត)ដោយពួកគេនឹងមិនមានជំនឿនោះឡើយ រហូតដល់ពួកគេឃើញទណ្ឌកម្មដ៏ឈឺចាប់បំផុត។

89. ទ្រង់បានតបថា៖ ជាការពិតណាស់ យើងបានទទួលយកការបួងសួងរបស់អ្នកទាំងពីរហើយ។ ដូច្នេះ ចូរអ្នកទាំងពីរប្រកាន់ខ្ជាប់(នឹងសាសនារបស់អ្នកទាំងពីរ)ចុះ ហើយចូរអ្នកទាំងពីរកុំដើរតាមមាគ៌ារបស់ពួកដែលគ្មានចំណេះដឹង។

90. ហើយយើងបានចម្លងអម្បូរអ៊ីស្រាអែលឲ្យឆ្លងផុតសមុទ្រ។ ពេលនោះ ហ្វៀរអោននិងទាហានរបស់គេបានដេញតាមពីក្រោយពួកគេដោយការបំពាន និងភាពជាសត្រូវ។ លុះពេលដែលគេ(ហ្វៀរអោន)បានលិចលង់(ក្នុងទឹកសមុទ្រ) គេក៏ពោលថា៖ ខ្ញុំមានជំនឿហើយថា ពិតប្រាកដណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពដ៏ពិតប្រាកដក្រៅពីព្រះជាម្ចាស់ដែលអម្បូរអ៊ីស្រាអែលបានជឿទៅលើទ្រង់នោះឡើយ ហើយខ្ញុំស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន(ចំពោះទ្រង់)។

91. តើពេលនេះ(ទើបឯងមានជំនឿ)ឬ? ជាការពិតណាស់ ឯងធ្លាប់បានប្រឆាំងកាលពីមុន ហើយឯងធ្លាប់ស្ថិតក្នុងចំណោមពួកដែលបង្កវិនាសកម្ម។

92. ដូច្នេះ នៅក្នុងថ្ងៃនេះ យើងនឹងស្រង់សាកសពឯង(ចេញពីសមុទ្រ)ដើម្បីឲ្យឯងក្លាយជាសញ្ញាកស្តុតាងមួយសម្រាប់អ្នកជំនាន់ក្រោយ។ តែជាការពិតណាស់ ភាគច្រើននៃមនុស្សលោក គឺព្រងើយកន្តើយចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើង។

93. ហើយជាការពិតណាស់ យើងបានរៀបចំទីលំនៅដល់អម្បូរអ៊ីស្រាអែលនូវលំនៅឋានមួយដ៏ល្អប្រពៃ(នៅក្នុងទឹកដីស្តាម) ហើយយើងបានប្រទានលាភសក្ការៈអំពីរបស់ល្អៗជាច្រើនដល់ពួកគេ។ ហើយពួកគេមិនបានខ្វែងគំនិតគ្នាឡើយ(ក្នុងកិច្ចការសាសនា) រហូតដល់ចំណេះដឹង(គម្ពីរគួរអាន)បានមកដល់ពួកគេ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងកាត់សេចក្តីរវាងពួកគេនៅថ្ងៃបរលោកចំពោះអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នាចំពោះវា។

94. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានការមន្ទិលសង្ស័យចំពោះអ្វី(គម្ពីរគួរអាន)ដែលយើងបានបញ្ចុះមកឱ្យអ្នកនោះ ចូរអ្នកសួរពួក(អះលីគីតាប)ដែលសូត្រគម្ពីរមុនអ្នក។ ជាការពិតណាស់ សេចក្តីពិតពីព្រះជាម្ចាស់របស់អ្នកបានមកដល់អ្នកហើយ។ ហេតុនេះ ចូរអ្នកកុំស្ថិតក្នុងចំណោមពួកដែលមានការមន្ទិលសង្ស័យឱ្យសោះ។

95. ហើយចូរអ្នកកុំស្ថិតក្នុងចំណោមពួកដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់អល់ឡោះដែលជាហេតុធ្វើឱ្យអ្នកស្ថិតក្នុងចំណោមពួកដែលខាតបង់។

96. ពិតប្រាកដណាស់ ពួកដែលពាក្យបន្ទូលរបស់អល់ឡោះបានកំណត់លើពួកគេ(ថាពួកគេគ្មានជំនឿហើយនោះ) គឺពួកគេនឹងមិនមានជំនឿជាដាច់ខាត។

97. ហើយបើទោះបីជាសញ្ញាកស្តុតាងទាំងអស់បានមកដល់ពួកគេក៏ដោយ(ក៏ពួកគេគ្មានជំនឿនោះដែរ) រហូតទាល់តែពួកគេបានឃើញទណ្ឌកម្មដ៏ឈឺចាប់(ផ្ទាល់នឹងភ្នែក)។

98. ហើយគ្មានភូមិស្រុកណាមួយដែលមានជំនឿ ហើយជំនឿនោះផ្តល់ប្រយោជន៍ដល់ពួកគេ(នៅពេលដែលពួកគេឃើញទណ្ឌកម្មផ្ទាល់នឹងភ្នែកហើយនោះ)នោះឡើយ លើកលែងតែក្រុមរបស់ព្យាការីយូនូសប៉ុណ្ណោះ។ នៅពេលពួកគេមានជំនឿហើយនោះ យើងក៏បានដកទណ្ឌកម្មដ៏អាម៉ាស់ក្នុងជីវិតលោកិយចេញពីពួកគេ ហើយបានផ្តល់ភាពសុខសាន្តដល់ពួកគេរហូតដល់ពេលកំណត់។

99. ហើយប្រសិនបើព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានចេតនានោះ អ្នកដែលរស់នៅលើផែនដីទាំងអស់ពិតជាមានជំនឿជាមិនខាន។ ដូច្នេះ តើអ្នកអាចបង្ខំមនុស្សលោកឱ្យពួកគេក្លាយជាអ្នកដែលមានជំនឿឬ?

100. ហើយគ្មានបុគ្គលណាម្នាក់មានជំនឿឡើយ លើកលែងតែដោយការអនុញ្ញាតពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ហើយទ្រង់នឹងដាក់ទណ្ឌកម្មទៅលើពួកដែលមិនគិតពិចារណា។

101. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកពិចារណាមើលចុះ៖ ថាតើអ្វីខ្លះដែលមាននៅលើមេឃជាច្រើនជាន់ និងនៅលើផែនដីនោះ? ប៉ុន្តែសញ្ញាកស្តុតាង និងអ្នកដាស់តឿនព្រមាន(អ្នកនាំសារ)ទាំងឡាយ គឺពុំផ្តល់ជាប្រយោជន៍អ្វីដល់ក្រុមដែលគ្មានជំនឿឡើយ។

102. ដូច្នេះ តើពួកទាំងនោះមិនរង់ចាំអ្វីក្រៅពី(ក្តីវិនាស)ដូចបណ្តាថ្ងៃ(វិនាស)របស់ពួកជំនាន់មុនពួកគេនោះឬ? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ដូច្នេះ ចូរពួកអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ ខ្ញុំក៏ស្ថិតក្នុងចំណោមអ្នកដែលរង់ចាំមើលជាមួយពួកអ្នកដែរ។

103. ក្រោយមក យើងនឹងជួយសង្គ្រោះបណ្តាអ្នកនាំសាររបស់យើង និងអ្នកទាំងឡាយដែលមានជំនឿ។ ក៏ដូច្នោះដែរ ជាក្តីសប្បុរសអំពីយើង គឺយើងជួយសង្គ្រោះបណ្តាអ្នកដែលមានជំនឿ។

104. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱមនុស្សលោកទាំងឡាយ! ប្រសិនបើពួកអ្នកមានភាពមន្ទិលសង្ស័យចំពោះសាសនារបស់ខ្ញុំនោះ ជាការពិតណាស់ ខ្ញុំមិនគោរពសក្ការៈចំពោះអ្នកណាដែលពួកអ្នកគោរពសក្ការៈចំពោះពួកវា(ព្រះនានា)ក្រៅពីអល់ឡោះនោះឡើយ។ ក៏ប៉ុន្តែ ខ្ញុំគោរពសក្ការៈចំពោះអល់ឡោះ(តែមួយគត់)ដែលជាអ្នកដកយកជីវិតរបស់ពួកអ្នក។ ហើយគេ(អល់ឡោះ)បានប្រើខ្ញុំឲ្យស្ថិតក្នុងចំណោមអ្នកដែលមានជំនឿ។

105. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រកាន់ឲ្យខ្ជាប់នូវសាសនាដ៏ត្រឹមត្រូវ(សាសនាអ៊ីស្លាម)។ ហើយអ្នកមិនត្រូវក្លាយជាអ្នកដែលស្ថិតក្នុងចំណោមពួកដែលធ្វើស៊ីរិកឡើយ។

106. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនត្រូវបួងសួងសុំពីអ្នកផ្សេងក្រៅពីអល់ឡោះដែលពួកវាមិនអាចផ្តល់ផលប្រយោជន៍ ហើយក៏មិនអាចបង្កគ្រោះថ្នាក់ដល់អ្នកនោះឡើយ។ តែប្រសិនបើអ្នកធ្វើដូច្នោះ ពិតប្រាកដណាស់ អ្នកពិតជាស្ថិតក្នុងចំណោមពួកដែលបំពានជាមិនខាន។

107. ហើយប្រសិនបើអល់ឡោះឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទទួលរងនូវគ្រោះណាមួយនោះ គឺគ្មានអ្នកដែលអាចដកយកគ្រោះនោះចេញ(ពីអ្នក)ក្រៅពីទ្រង់នោះឡើយ។ ហើយប្រសិនបើទ្រង់មានចេតនាផ្តល់ឱ្យអ្នកនូវប្រការល្អវិញនោះ ក៏គ្មាននរណាដែលអាចរារាំងនូវការប្រោសប្រទានរបស់ទ្រង់បាននោះដែរ។ ទ្រង់ផ្តល់វាទៅឱ្យជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់។ ហើយទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

108. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱមនុស្សលោកទាំងឡាយ! ជាការពិតណាស់ សេចក្តីពិត(គម្ពីរគួរអាន)ពីព្រះជាម្ចាស់របស់ពួកអ្នកបានមកដល់ពួកអ្នកហើយ។ ដូច្នេះ ជនណាដែលទទួលបានការចង្អុលបង្ហាញ តាមពិត(ផលនៃ)ការចង្អុលបង្ហាញនោះ គឺសម្រាប់ខ្លួនគេផ្ទាល់។ ហើយប្រសិនបើជនណាបានវង្វេងវិញនោះ តាមពិត(គ្រោះថ្នាក់នៃ)ភាពវង្វេងនោះ គឺនឹងធ្លាក់ទៅលើខ្លួនគេវិញ(ដូចគ្នា)។ ហើយខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវចំពោះពួកអ្នកនោះឡើយ។

109. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដើរតាមអ្វីដែលគេបានផ្តល់វាំហ៊ីមកកាន់អ្នក ហើយចូរអ្នកអត់ធ្មត់ចុះ រហូតដល់អល់ឡោះទ្រង់កាត់សេចក្តី។ ហើយទ្រង់ជាអ្នកកាត់សេចក្តីដ៏ប្រសើរបំផុត

ជំពូក ហ៊ូដ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាមរ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ (នេះគឺជា) គម្ពីរមួយដែលបណ្តាវាក្យខណ្ឌទាំងឡាយរបស់វាមានភាពសុក្រឹតឥតខ្ចោះ។ បន្ទាប់មក គេបានបកស្រាយបញ្ជាក់(នូវបញ្ហាផ្សេងៗនៅក្នុងវា)ដែលមកពីព្រះជាម្ចាស់ដ៏មហាគតិបណ្ឌិត មហាដឹងបំផុត។

2. ដើម្បីកុំឲ្យពួកអ្នកគោរពសក្ការៈ(ចំពោះអ្នកផ្សេង)ក្រៅពីអល់ឡោះជាម្ចាស់ឡើយ។ ពិតប្រាកដណាស់ ខ្ញុំជាអ្នកដាស់តឿនព្រមាន និងជាអ្នកផ្តល់ដំណឹងរីករាយមកពីទ្រង់ដល់ពួកអ្នក។

3. ហើយចូរអ្នក(ឱមនុស្សលោកទាំងឡាយ)សុំការអភ័យទោសពីព្រះជាម្ចាស់របស់ពួកអ្នក។ បន្ទាប់មក ចូរពួកអ្នកសារភាពកំហុសទៅចំពោះទ្រង់ នោះទ្រង់នឹងផ្តល់ឱ្យពួកអ្នកនូវភោគសុខសាន្ត(ក្នុងជីវិតលោកិយ) រហូតដល់ពេលវេលាដែលត្រូវបានកំណត់(ស្លាប់)។ ហើយទ្រង់នឹងប្រទានឱ្យរាល់អ្នកដែលមានភាពខ្ពង់ខ្ពស់(ក្នុងការគោរពប្រតិបត្តិចំពោះទ្រង់)នូវភាពខ្ពង់ខ្ពស់(ផលបុណ្យ)របស់គេ។ តែប្រសិនបើពួកអ្នកងាកចេញវិញនោះ ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពួកអ្នកទទួលរងនូវទណ្ឌកម្មនាថ្ងៃដ៏ធំធេង(ថ្ងៃបរលោក)។

4. កន្លែងវិលត្រឡប់របស់ពួកអ្នកទាំងអស់គ្នា គឺទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

5. តើពុំមែនទេឬដែលថា ពិតប្រាកដណាស់ ពួកគេ(ពួកមុស្លីគីន)បានលាក់បាំង(ភាពគ្មានជំនឿ)នៅក្នុងចិត្តរបស់ពួកគេដោយគិតស្មានថា ពួកគេអាចលាក់បាំងពីទ្រង់បាន។ តើពុំមែនទេឬ ខណៈពេលពួកគេគ្របក្បាលរបស់ពួកគេនឹងសម្លៀកបំពាក់របស់ពួកគេនោះ ទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេលាក់បាំង និងអ្វីដែលពួកគេលាតត្រដាង។ ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុងដួងចិត្ត។

6. ហើយរាល់សត្វលោកដែលរស់នៅលើកពផែនដីនេះ គឺសុទ្ធតែត្រូវបានអល់ឡោះទ្រង់ផ្តល់លាភសក្ការៈដល់ពួកវាទាំងអស់។ ហើយទ្រង់ដឹងបំផុតនូវកន្លែងស្នាក់នៅរបស់វា និងកន្លែងដែលវាត្រូវស្លាប់។ ហើយរាល់ប្រការទាំងនោះ គឺមាននៅក្នុងគម្ពីរ(កំណត់ត្រា)យ៉ាងច្បាស់លាស់។

7. ហើយទ្រង់គឺជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីក្នុងរយៈពេលប្រាំមួយថ្ងៃ។ ហើយអារ៉ស្តរបស់ទ្រង់ គឺនៅពីលើទឹក ដើម្បីទ្រង់នឹងសាកល្បងពួកអ្នក(ឱមនុស្សលោក) ថាតើនរណាម្នាក់ក្នុងចំណោមពួកអ្នកដែលសាងអំពើល្អជាងគេ។ ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតណាស់ពួកអ្នកនឹងត្រូវគេបង្កើតឱ្យរស់ឡើងវិញក្រោយពេលស្លាប់នោះ ប្រាកដជាពួកដែលគ្មានជំនឿនឹងនិយាយថា៖ (គម្ពីរគួរអាន)នេះគឺគ្មានអ្វីក្រៅពីមន្តអាគមដ៏ច្បាស់លាស់នោះឡើយ។

8. ហើយប្រសិនបើយើងពន្យារពេលដាក់ទណ្ឌកម្មពួកគេ រហូតដល់ពេលកំណត់មួយនោះ ប្រាកដជាពួកគេនឹងនិយាយ(ក្នុងន័យចំអក)ថា៖ តើអ្វីទៅដែលរារាំងវា(មិនឲ្យកើតឡើង)នោះ? តើមិនមែនទេឬ នៅថ្ងៃដែលវា(ទណ្ឌកម្ម)មកដល់ពួកគេនោះ គឺគ្មាននរណាម្នាក់អាចបង្វែរវាចេញពីពួកគេបានឡើយ។ ហើយទណ្ឌកម្មដែលពួកគេធ្លាប់សើចចំអកចំពោះវានោះ បានហ៊ុមព័ទ្ធពួកគេ។

9. ហើយប្រសិនបើយើងឱ្យមនុស្សលោកភ្លក់នូវភាពសុខសាន្តអំពីយើង ក្រោយមក យើងដកយកវាចេញពីពួកគេវិញនោះ នោះពួកគេនឹងមានការអស់សង្ឃឹម និងរមិលគុណជាខ្លាំង។

10. តែប្រសិនបើយើងបានឱ្យពួកគេភ្លក់នូវឧបការគុណដ៏ទូលំទូលាយ ក្រោយពីពួកគេទទួលរងនូវទុក្ខលំបាកនោះ ពួកគេប្រាកដជានឹងនិយាយថា៖ ប្រការអាក្រក់ទាំងឡាយបានឃ្លាតចេញអំពីខ្ញុំហើយ។ ពិតប្រាកដណាស់ រូបគេ គឺមានភាពសប្បាយរីករាយ និងក្រអឺតក្រទមបំផុត។

11. លើកលែងតែបណ្តាអ្នកដែលអត់ធ្មត់ និងបានសាងនូវទង្វើកុសលប៉ុណ្ណោះ។ អ្នកទាំងនោះ ពួកគេនឹងទទួលបានការអភ័យទោស និងផលបុណ្យដ៏ធំធេងបំផុត។

12. ដូច្នេះ ប្រហែលជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងបោះបង់ចោលនូវការផ្សព្វផ្សាយបទបញ្ជាមួយចំនួនដែលគេ(អល់ឡោះ)បានផ្តល់វាហ៊ីទៅកាន់អ្នក ហើយទ្រូងរបស់អ្នកមានភាពចង្អៀតចង្អល់(ក្នុងការផ្សព្វផ្សាយវា)ដោយខ្លាចក្រែងពួកគេនិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះកំណប់ទ្រព្យមកឱ្យគាត់(ព្យាការីមូហាំម៉ាត់) ឬនាំម៉ាឡាអ៊ីកាត់ម្នាក់មកជាមួយគាត់? តាមពិត រូបអ្នកគ្រាន់តែជាអ្នកដាស់តឿនព្រមាន(ពួកគេ)ប៉ុណ្ណោះ។ ហើយអល់ឡោះជាអ្នកគាំពាររលើរាល់អ្វីៗទាំងអស់។

13. ឬមួយពួកគេ(ពួកមុស្លីគីន)នឹងនិយាយថា៖ គាត់(ព្យាការីមូហាំម៉ាត់)បានប្រឌិតនូវគម្ពីរគួរអាននេះឡើង។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកនាំយកដប់ជំពូកដែលដូចនឹងវាដែលពួកអ្នកចោទថា វាត្រូវបានគេប្រឌិតឡើងនេះមក ហើយចូរពួកអ្នកកោះហៅអ្នកណាដែលពួកអ្នកអាចហៅមកបានក្រៅពីអល់ឡោះ(ដើម្បីជួយពួកអ្នក)ប្រសិនបើពួកអ្នក ជាអ្នកដែលទៀងត្រង់មែននោះ។

14. តែប្រសិនបើពួកគេមិនអាចឆ្លើយតបចំពោះពួកអ្នក(ឱអ្នកដែលមានជំនឿ)បានទេនោះ ចូរពួកអ្នកដឹងចុះថា៖ តាមពិតគេបានបញ្ចុះវា(គម្ពីរគួរអាន)មកដោយចំណេះដឹងរបស់អល់ឡោះ។ ហើយពិតណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់នោះឡើយ។ ដូច្នេះ តើពួកអ្នកនឹងប្រគល់ខ្លួនចំពោះទ្រង់(ក្លាយខ្លួនជាអ្នកមូស្លីម)ដែរឬទេ?

15. ជនណាដែលប្រាថ្នាចង់បានជីវិតរស់នៅក្នុងលោកិយ និងភាពស្រស់បំព្រងរបស់វា នោះយើងនឹងប្រទានឱ្យពួកគេនូវផលបុណ្យនៃទង្វើរបស់ពួកគេ(ក្នុងលោកិយនេះ)យ៉ាងពេញលេញ ដោយពួកគេមិនត្រូវបានគេបំបាត់ឡើយ។

16. ពួកទាំងនោះ សម្រាប់ពួកគេនៅថ្ងៃបរលោកគឺគ្មានអ្វីក្រៅពីភ្លើងនរកឡើយ ហើយផលនៃអ្វីដែលគេបានសាងបានរលាយសាបសូន្យអំពីពួកគេ ហើយទង្វើ(កុសល)ដែលពួកគេបានប្រព្រឹត្តត្រូវក្លាយជាអសារបង់។

17. តើអ្នកដែលស្ថិតនៅលើកស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់គេ(ព្យាការីមូហាំម៉ាត់) ហើយមានសាក្សីម្នាក់ពីទ្រង់(ម៉ាឡាអ៊ីកាត់ជីព្រីល)បានសូត្រវា ព្រមទាំងមានពីមុនវាផងដែរនូវគម្ពីររបស់ព្យាការីមូសា(គម្ពីរតាវ៉ាត) ដែលជាប្រមុខដឹកនាំ និងជាក្តីអាណិតស្រលាញ់ផងនោះ(ដូចគ្នានឹងពួកដែលប្រាថ្នាចង់បានជីវិតរស់នៅក្នុងលោកិយដែលនឹងសាបសូន្យឬ?)អ្នកទាំងនោះ ពួកគេមានជំនឿនឹងវា(គម្ពីរគួរអាន)។ ហើយជនណាដែលគ្មានជំនឿនឹងវា(គម្ពីរគួរអាន)ក្នុងចំណោមក្រុមទាំងឡាយនោះ ពិតណាស់ ឋាននរកគឺជាកន្លែងសន្យាសម្រាប់គេ។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំមានការមន្ទិលសង្ស័យចំពោះវាឱ្យសោះ។ ពិតប្រាកដណាស់វាជាសេចក្តីពិតពីព្រះជាម្ចាស់របស់អ្នក។ ក៏ប៉ុន្តែមនុស្សលោកភាគច្រើនមិនមានជំនឿឡើយ។

18. ហើយគ្មាននរណាម្នាក់ដែលបំពានដាងអ្នកដែលបានប្រឌិតរឿងកុហកទៅលើអល់ឡោះជាម្ចាស់ឡើយ។ ពួកទាំងនោះនឹងត្រូវគេយកទៅបង្ហាញនៅចំពោះមុខព្រះជាម្ចាស់របស់ពួកគេ(នៅថ្ងៃបរលោក)។ ហើយមានសាក្សីជាច្រើនបាននិយាយថា៖ ពួកទាំងនោះ គឺជាពួកដែលបានកុហកទៅលើព្រះជាម្ចាស់របស់ពួកគេ។ តើពុំមែនទេឬ បណ្តាសារបស់អល់ឡោះគឺធ្លាក់ទៅលើពួកដែលបំពាន?

19. គឺពួកដែលរារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះ និងចង់ឱ្យមាគ៌ានោះមានភាពវៀចវេរ ហើយពួកគេគឺជាពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក។

20. ពួកទាំងនោះ ពួកគេគ្មានលទ្ធភាពរត់គេច(ពីទណ្ឌកម្មអល់ឡោះ)នៅលើផែនដីបានឡើយ ហើយពួកគេក៏គ្មានអ្នកគាំពារណាក្រៅពីអល់ឡោះនោះដែរ។ គេនឹងបន្ថែមទណ្ឌកម្មទ្វេដងទៅលើពួកគេ(នាថ្ងៃបរលោក)។ ពួកគេគ្មានលទ្ធភាពស្តាប់ឮ ហើយក៏គ្មានលទ្ធភាពមើលឃើញ(អ្វីដែលផ្តល់ផលប្រយោជន៍ដល់ពួកគេ)ឡើយ។

21. ពួកទាំងនោះហើយគឺជាពួកដែលខាតបង់ខ្លួនឯង។ ហើយអ្វី(ព្រះនានា)ដែលពួកគេធ្លាប់បានប្រឌិតឡើងនោះ បានបាត់បង់ពីពួកគេ។

22. ជាការពិត នៅថ្ងៃបរលោក ពួកគេគឺជាពួកដែលខាតបង់យ៉ាងធ្ងន់ធ្ងរបំផុត។

23. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ហើយពួកគេបន្ទាបខ្លួនទៅចំពោះព្រះជាម្ចាស់របស់ពួកគេនោះ អ្នកទាំងនោះហើយគឺជាអ្នកឋានសួគ៌។ ពួកគេនឹងស្ថិតនៅក្នុងវាជាអមតៈ។

24. ការប្រៀបធៀបរវាងក្រុមទាំងពីរនេះ គឺប្រៀបដូចជាមនុស្សពិការភ្នែក ហើយថ្លង់ និងអ្នកមើលឃើញ ហើយស្តាប់ឮដូច្នោះដែរ។ តើក្រុមទាំងពីរនេះស្មើគ្នាដែរឬទេ? ដូច្នេះ តើពួកអ្នកមិនគិតពិចារណា(យកជាមេរៀន)ទេឬ?

25. ហើយជាការពិតណាស់ យើងបានបញ្ជូនព្យាការីនួហទៅកាន់ក្រុមរបស់គាត់។ (គាត់បាននិយាយថា៖) ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់សម្រាប់ពួកអ្នក។

26. ពួកអ្នកមិនត្រូវគោរពសក្ការៈ(ចំពោះអ្នកផ្សេង)ក្រៅពីអល់ឡោះឡើយ។ ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពួកអ្នកទទួលនូវទណ្ឌកម្មនាថ្ងៃដ៏ឈឺចាប់បំផុត។

27. ពួកមេដឹកនាំដែលជាពួកប្រឆាំងក្នុងចំណោមក្រុមរបស់គាត់បាននិយាយថា៖ ពួកយើងមិនបានឃើញអ្នក(មានលក្ខណៈពិសេសអ្វី)ក្រៅពីជាមនុស្សធម្មតាដូចពួកយើងប៉ុណ្ណោះ។ ពួកយើងមិនបានឃើញអ្នកដែលដើរតាមអ្នកនោះ ក្រៅពីមនុស្សដែលទន់ខ្សោយនៃពួកយើងដែលឆាប់ជឿគេ(ដោយគ្មានការពិចារណា)នោះឡើយ ហើយពួកយើងក៏មិនបានឃើញថាអ្នកមានភាពខ្ពង់ខ្ពស់លើសពួកយើងនោះដែរ។ ផ្ទុយទៅវិញ ពួកយើងគិតថា ពួកអ្នកជាពួកដែលកុហក។

28. គាត់បានតបវិញថា៖ ឱក្រុមរបស់ខ្ញុំ! តើពួកអ្នកយល់យ៉ាងណា ប្រសិនបើខ្ញុំស្ថិតនៅលើសញ្ញាកស្តតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ខ្ញុំ ហើយទ្រង់បានប្រទានដល់ខ្ញុំនូវក្តីមេត្តាករុណាអំពីទ្រង់ តែគេមិនបានឲ្យពួកអ្នកមើលឃើញវា(ព្រោះតែភាពអវិជ្ជារបស់ពួកអ្នក)នោះ តើខ្ញុំត្រូវបង្ខំពួកអ្នក(ឱ្យមានជំនឿ)ចំពោះវា ទាំងដែលពួកអ្នកមិនពេញចិត្តចំពោះវានោះឬ?

29. ឱក្រុមរបស់ខ្ញុំ! ខ្ញុំមិនបានស្នើសុំទ្រព្យសម្បត្តិពីពួកអ្នកចំពោះ(ការផ្សព្វផ្សាយ)វានោះឡើយ។ ពិតណាស់ ផលបុណ្យរបស់ខ្ញុំគឺស្ថិតនៅលើអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ហើយខ្ញុំក៏មិនមែនជាអ្នកដែលបណ្តេញអ្នកមានជំនឿ(ដែលក្រីក្រ)នោះដែរ។ ជាការពិតណាស់ ពួកគេនឹងជួបព្រះជាម្ចាស់របស់ពួកគេ(នាថ្ងៃបរលោក)។ ប៉ុន្តែខ្ញុំឃើញថា ពួកអ្នកគឺជាក្រុមដែលល្ងង់ខ្លៅ។

30. ឱក្រុមរបស់ខ្ញុំ! តើអ្នកណាដែលនឹងជួយខ្ញុំឲ្យរួចផុតពី(ទណ្ឌកម្មរបស់)អល់ឡោះ ប្រសិនបើខ្ញុំបណ្តេញពួកគេ(បណ្តាអ្នកមានជំនឿ)ចេញនោះ? តើពួកអ្នកមិនចេះពិចារណាទេឬ?

31. ហើយខ្ញុំមិននិយាយទៅកាន់ពួកអ្នកថា៖ ខ្ញុំមានឃ្លាំងទ្រព្យជាច្រើនរបស់អល់ឡោះ ហើយថាខ្ញុំដឹងពីប្រការអាថ៌កំបាំងនោះដែរ។ ខ្ញុំក៏មិនបាននិយាយដែរថា៖ ពិតប្រាកដណាស់រូបខ្ញុំគឺជាម៉ាឡាអ៊ីកាត់នោះ។ ខ្ញុំក៏មិននិយាយទៅកាន់អ្នក(ក្រីក្រ)ដែលពួកអ្នកមើលងាយពួកគេថា៖ "អល់ឡោះទ្រង់មិនផ្តល់នូវការចង្អុលបង្ហាញដល់ពួកគេ" នោះដែរ។ អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេ។ ពិតប្រាកដណាស់ ប្រសិនបើខ្ញុំនិយាយដូច្នេះមែននោះ គឺរូបខ្ញុំពិតជាស្ថិតក្នុងចំណោមពួកដែលបំពានជាមិនខាន។

32. ពួកគេបាននិយាយថា៖ ឱនួហ! ពិតប្រាកដណាស់ អ្នកបានប្រកែកគ្នាជាមួយពួកយើង និងបានប្រកែកជាមួយពួកយើងនេះច្រើនលើកមកហើយ។ ហេតុនេះ ចូរអ្នកនាំមកកាន់ពួកយើងនូវអ្វី(ទណ្ឌកម្ម)ដែលអ្នកបានសន្យានឹងពួកយើងនោះមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់មែននោះ។

33. គាត់បានតបវិញថា៖ តាមពិត គឺមានតែអល់ឡោះជាម្ចាស់ប៉ុណ្ណោះដែលអាចនាំវា(ទណ្ឌកម្ម)មកកាន់ពួកអ្នកនោះប្រសិនបើទ្រង់មានចេតនា។ ហើយពួកអ្នកគ្មានលទ្ធភាពអាចគេចផុត(ពីវា)បានឡើយ។

34. ហើយដំបូន្មានរបស់ខ្ញុំមិនអាចផ្តល់ផលប្រយោជន៍អ្វីដល់ពួកអ្នកនោះឡើយទោះបីជាខ្ញុំចង់ផ្តល់ដំបូន្មានដល់ពួកអ្នកក៏ដោយប្រសិនបើអល់ឡោះមានបំណងឲ្យពួកអ្នកវង្វេងហើយនោះ។ ទ្រង់គឺជាព្រះជាម្ចាស់របស់ពួកអ្នក។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។

35. ឬមួយពួកគេនិយាយថា៖ គាត់(ព្យាការីនួហ)បានប្រឌិតកុហកទៅលើអល់ឡោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើខ្ញុំប្រឌិតវាមែននោះ រូបខ្ញុំតែម្នាក់គត់ដែលជាអ្នកទទួលខុសត្រូវចំពោះបាបកម្មរបស់ខ្ញុំនោះ។ ហើយខ្ញុំមិនពាក់ព័ន្ធនឹងបាបកម្មដែលពួកអ្នកបានប្រព្រឹត្តនោះឡើយ។

36. ហើយគេ(អល់ឡោះ)បានផ្តល់វ៉ាហ៊ីទៅកាន់ព្យាការីនួហថា៖ ពិតប្រាកដណាស់ គ្មានអ្នកណាម្នាក់នៃក្រុមរបស់អ្នក(ឱព្យាការីនួហ)មានជំនឿទៀតនោះទេ ក្រៅតែពីអ្នកដែលមានជំនឿរួចប៉ុណ្ណោះ។ ហេតុនេះ ចូរអ្នក(ឱព្យាការីនួហ)កុំកើតទុក្ខដោយសារតែអ្វីដែលពួកគេបានប្រព្រឹត្តឱ្យសោះ។

37. ហើយចូរអ្នកធ្វើសំពៅមួយក្រោមការត្រួតពិនិត្យរបស់យើង និងតាមរយៈវ៉ាហ៊ីពីយើង។ ហើយអ្នកមិនត្រូវសុំពីយើងឱ្យពន្យារពេលដល់ពួកដែលបំពាននោះឡើយ។ ពិតណាស់ ពួកគេគឺជាពួកដែលត្រូវគេពន្លិចឲ្យលិចលង់(ដោយចៀសមិនផុតឡើយ)។

38. ហើយគាត់ក៏បាន(ចាប់ផ្តើម)ធ្វើសំពៅ។ រាល់ពេលដែលពួកមេដឹកនាំនៃក្រុមរបស់គាត់បានដើរឆ្លងកាត់ ពួកគេតែងសើចចំអកឱ្យគាត់។ គាត់ក៏បានតបវិញថា៖ ប្រសិនបើពួកអ្នកសើចចំអកឱ្យយើង(នាថ្ងៃនេះ) ពិតប្រាកដណាស់យើងនឹងសើចចំអកឱ្យពួកអ្នកវិញដូចអ្វីដែលពួកអ្នកសើចចំអកឲ្យយើងជាមិនខាន។

39. ហើយពួកអ្នកប្រាកដជានឹងដឹងថា តើអ្នកណាដែលទណ្ឌកម្មនឹងធ្លាក់ទៅលើរូបគេដែលធ្វើឱ្យរូបគេអាម៉ាស់ ហើយនិងត្រូវទទួលនូវទណ្ឌកម្មជានិរន្តរ៍នោះ។

40. លុះពេលដែលបទបញ្ជារបស់យើង(អល់ឡោះ)បានមកដល់ ហើយទឹកបានផុសចេញយ៉ាងច្រើនពីក្នុងដី យើងក៏បានមានបន្ទូល(ទៅកាន់ព្យាការីនូហ)ថា៖ ចូរអ្នកនាំយកសត្វគ្រប់ប្រភេទមួយគូៗ(ញី ឈ្មោល)ផ្ទុកនៅលើសំពៅនេះ ហើយនិងក្រុមគ្រួសាររបស់អ្នកផងដែរ លើកលែងតែអ្នកណាដែលគេបានសម្រេចរួចមកហើយ(ថារូបគេនឹងត្រូវលិចលង់ក្នុងទឹកជំនន់) និងត្រូវដឹកអ្នកដែលមានជំនឿផងដែរ។ ហើយគ្មានអ្នកដែលមានជំនឿជាមួយគាត់ឡើយ លើកលែងតែមួយចំនួនតូចប៉ុណ្ណោះ។

41. ហើយគាត់(ព្យាការីនូហ)បាននិយាយថា៖ ចូរពួកអ្នកឡើងជិះលើសំពៅនេះក្នុងព្រះនាមអល់ឡោះដែលឱ្យសំពៅនេះធ្វើដំណើរ និងធ្វើឲ្យវាឈប់។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

42. ហើយសំពៅបានដឹកពួកគេធ្វើដំណើរឆ្លងកាត់រលកធំៗប្រៀបដូចភ្នំ។ ហើយព្យាការីនូហបានស្រែកហៅកូនប្រុសរបស់គាត់(ដែលជាអ្នកគ្មានជំនឿ)ដែលស្ថិតនៅកន្លែងមួយ(ដាច់ពីក្រុមអ្នកមានជំនឿ)ថា៖ ឱកូនសម្លាញ់! ចូរកូនឡើងជិះ(លើសំពៅ)ជាមួយពួកយើងមក ហើយចូរកូនកុំស្ថិតក្នុងចំណោមពួកដែលគ្មានជំនឿឱ្យសោះ។

43. គេបានតបថា៖ ខ្ញុំនឹងទៅជ្រកនៅលើភ្នំដែលអាចការពារខ្ញុំអំពីទឹក(ជំនន់)។ គាត់ក៏តបវិញថា៖ នៅថ្ងៃនេះ គ្មានអ្នកដែលអាចរារាំងពីបទបញ្ជារបស់អល់ឡោះបានឡើយ លើកលែងតែជនណាដែលទ្រង់អាណិតស្រលាញ់(ចំពោះគេ)ប៉ុណ្ណោះ។ ហើយទឹករលកបានបំបែករវាងគេទាំងពីរនាក់(ឪពុក និងកូន)។ ដូចនេះ រូបគេក៏ស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេធ្វើឲ្យលិចលង់(ក្នុងទឹកជំនន់)។

44. (ក្រោយពីទឹកជំនន់បានបញ្ចប់) ទ្រង់បានមានបន្ទូលថា៖ ឱដី! ចូរឯងលេបទឹករបស់ឯងទៅវិញចុះ។ ឱមេឃ! ចូរឯងបញ្ឈប់ការបង្ហុះទឹកភ្លៀងមកទៀតចុះ។ ពេលនោះ ទឹកក៏បានស្រកទៅវិញអស់។ ហើយបទបញ្ជា(របស់អល់ឡោះ)ក៏ត្រូវបានសម្រេច ហើយសំពៅនោះក៏បានចតនៅលើភ្នំ"ជូទី"។ ហើយមានគេនិយាយថា៖ វិនាសអន្តរាយចុះចំពោះក្រុមដែលបំពាន។

45. ហើយព្យាការីនូហក៏បានស្រែកបួងសួងទៅកាន់ព្រះជាម្ចាស់របស់គាត់ ដោយគាត់បានពោលថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ កូនប្រុសរបស់ខ្ញុំក៏ជាក្រុមគ្រួសាររបស់ខ្ញុំដែរ ហើយពិតប្រាកដណាស់ ការសន្យារបស់ព្រះអង្គ គឺជាការពិត។ ហើយព្រះអង្គគឺជាអ្នកកាត់សេចក្តីដ៏យុត្តិធម៌បំផុត។

46. ទ្រង់បានតបថា៖ ឱនូហ! ពិតណាស់ រូបគេមិនមែនស្ថិតក្នុងក្រុមគ្រួសាររបស់អ្នកឡើយ ព្រោះថា ទង្វើរបស់គេពុំមែនជាទង្វើកុសលឡើយ។ ហេតុនេះ ចូរអ្នកកុំសុំពីយើងនូវអ្វីដែលអ្នកមិនមានចំណេះដឹងអំពីវាឱ្យសោះ។ ពិតប្រាកដណាស់ យើងសូមជាស់តឿនអ្នក ខ្លាចក្រែងអ្នកស្ថិតក្នុងចំណោមពួកដែលល្ងង់ខ្លៅ។

47. ព្យាការីនូហបានពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតណាស់ ខ្ញុំសូមការបញ្ជៀសពីព្រះអង្គអំពីការដែលរូបខ្ញុំសុំពីព្រះអង្គនូវអ្វីដែលខ្ញុំគ្មានចំណេះដឹងអំពីវា។ ប្រសិនបើព្រះអង្គមិនអភ័យទោសដល់រូបខ្ញុំ និងមិនមានក្តីមេត្តាករុណាចំពោះរូបខ្ញុំទេនោះ រូបខ្ញុំប្រាកដជាស្ថិតក្នុងចំណោមពួកដែលខាតបង់ជាមិនខាន។

48. ទ្រង់បានមានបន្ទូលថា៖ ឱនូហ! ចូរអ្នកចុះទៅកាន់ដីដោយសុខសុវត្ថិភាពអំពីយើង ព្រមទាំងពរជ័យដែលកើតមានទៅលើអ្នក និងទៅលើប្រជាជាតិដែលនៅជាមួយអ្នក។ ហើយចំពោះប្រជាជាតិជាច្រើនទៀត(ដែលជាពួកគ្មានជំនឿ)នោះ យើងនឹងផ្តល់ឲ្យពួកគេនូវការសោយសុខ(ក្នុងជីវិតលោកិយនេះ)។ ក្រោយមក ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុតពីយើង(នាថ្ងៃបរលោក)។

49. ទាំងនេះ គឺស្ថិតក្នុងចំណោមដំណឹងអាថ៌កំបាំងដែលយើងបានផ្តល់វាជាវ៉ាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ រូបអ្នក និងក្រុមរបស់អ្នកមិនធ្លាប់បានដឹងអំពីវាពីមុនមកនោះឡើយ។ ហេតុនេះ ចូរអ្នកអត់ធ្មត់ចុះ។ ជាការពិតណាស់ លទ្ធផលចុងក្រោយ(ដ៏ល្អប្រពៃ) គឺសម្រាប់បណ្តាអ្នកដែលកោតខ្លាចអល់ឡោះ។

50. ហើយ(យើងបានបញ្ជូន)ទៅកាន់ក្រុមអាទនូវព្យាការីហ៊ូទដែលជាបងប្អូនរបស់ពួកគេ។ គាត់(ព្យាការីហ៊ូទ)បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយគត់។ សម្រាប់ពួកអ្នក គឺគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់នោះឡើយ។ ពួកអ្នកគ្មានអ្វីក្រៅពីជាអ្នកដែលប្រឌិតភូតកុហកនោះទេ។

51. ឱក្រុមរបស់ខ្ញុំ! ខ្ញុំមិនបានសុំពីពួកអ្នកនូវកែម្រៃចំពោះ(ការផ្សព្វផ្សាយ)វានោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺនៅលើ(ព្រះជាម្ចាស់)អ្នកដែលបានបង្កើតរូបខ្ញុំប៉ុណ្ណោះ។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

52. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកសុំការលើយទោសពីព្រះជាម្ចាស់របស់ពួកអ្នកចុះ។ ក្រោយមក ចូរពួកអ្នកសារភាពកំហុសចំពោះទ្រង់ នោះទ្រង់នឹងបញ្ចាំះទឹកភ្លៀងយ៉ាងច្រើនមកលើពួកអ្នក ហើយទ្រង់នឹងបន្ថែមដល់ពួកអ្នកនូវភាពខ្លាំងក្លាទៅលើភាពខ្លាំងក្លារបស់ពួកអ្នកថែមទៀត។ ហើយពួកអ្នកមិនត្រូវបែរចេញ(ពីអ្វីដែលខ្ញុំអំពាវនាវពួកអ្នក)ក្នុងនាមជាពួកដែលប្រព្រឹត្តល្មើសនោះឡើយ។

53. ពួកគេបានតបវិញថា៖ ឱហ៊ូទ! អ្នកមិនបាននាំមកនូវសញ្ញាកស្តុតាងដ៏ច្បាស់លាស់ណាមួយមកកាន់ពួកយើងឡើយ។ ពួកយើងមិនមែនជាអ្នកបោះបង់(ការគោរពសក្ការៈ)ព្រះនានារបស់ពួកយើងដោយស្តាប់តាមសម្តីរបស់អ្នកនោះឡើយ ហើយពួកយើងក៏មិនមែនជាអ្នកដែលមានជំនឿលើអ្នកនោះដែរ។

54. ពួកយើងមិននិយាយអ្វីក្រៅពីការនិយាយថា៖ ព្រះមួយចំនួនរបស់ពួកយើងបានធ្វើឱ្យអ្នកក្លាយជាមនុស្សវិកលចរិតនោះឡើយ។ គាត់ក៏បានតបវិញថា៖ ពិតប្រាកដណាស់ ខ្ញុំសូមយកអល់ឡោះធ្វើជាសាក្សី ហើយពួកអ្នកក៏ត្រូវធ្វើសាក្សីដែរថា៖ ជាការពិតណាស់ ខ្ញុំមិនពាក់ព័ន្ធនឹងអ្វីដែលពួកអ្នកកំពុងតែធ្វើស្ទើរឹក

55. ក្រៅពីទ្រង់ឡើយ។ ដូច្នេះ ចូរពួកអ្នកទាំងអស់គ្នារៀបចំល្បិចកលប្រឆាំងនឹងខ្ញុំចុះ។ ក្រោយមក ចូរពួកអ្នកកុំពន្យារពេលដល់ខ្ញុំឱ្យសោះ។

56. ពិតប្រាកដណាស់ ខ្ញុំបានប្រគល់ការទុកចិត្តទៅលើអល់ឡោះជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ រាល់សត្វលោកទាំងអស់(នៅលើផែនដីនេះ) គឺសុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំ គឺស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ។

57. តែប្រសិនបើពួកអ្នកងាកចេញ(មិនទទួលយក)វិញនោះ ពិតប្រាកដណាស់ ខ្ញុំបានផ្សព្វផ្សាយនូវសារដែលគេផ្តល់មកកាន់ខ្ញុំដល់ពួកអ្នកហើយ។ ហើយព្រះជាម្ចាស់របស់ខ្ញុំនឹងជំនួសក្រុមមួយផ្សេងទៀតក្រៅពីពួកអ្នក។ ពួកអ្នកមិនអាចបង្កគ្រោះថ្នាក់អ្វីបន្តិចដល់ទ្រង់ឡើយ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំជាអ្នកថែរក្សាលើរាល់អ្វីៗទាំងអស់។

58. ហើយនៅពេលដែលបទបញ្ជារបស់យើងបានមកដល់ យើងក៏បានសង្គ្រោះព្យាការីហ៊ូទ និងបណ្តាអ្នកមានជំនឿដែលនៅជាមួយគាត់ដោយក្តីមេត្តាករុណាពីយើង ហើយយើងបានសង្គ្រោះពួកគេពីទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

59. នោះហើយជាក្រុមអាទ។ ពួកគេបានប្រឆាំងនឹងសញ្ញាកស្តុតាងនៃព្រះជាម្ចាស់របស់ពួកគេ និងបានប្រព្រឹត្តល្មើសចំពោះបណ្តាអ្នកនាំសាររបស់ទ្រង់ ព្រមទាំងបានដើរតាមបទបញ្ជារបស់រាល់ជនទាំងឡាយដែលក្អេងក្អាង ចចេសរឹងរូស(ចំពោះការពិត)។

60. ហើយពួកគេនឹងទទួលបណ្តាសា(ពីអល់ឡោះ)ទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ តើពុំមែនទេឬ ក្រុមអាទបានប្រឆាំងនឹងព្រះជាម្ចាស់របស់ពួកគេ។ តើពុំមែនទេឬ ក្តីវិនាសអន្តរាយ គឺធ្លាក់ទៅលើពួកអាទនៃក្រុមរបស់ព្យាការីហ៊ូទ?

61. ហើយ(យើងបានបញ្ជូន)ទៅកាន់ក្រុមសាមូទនូវព្យាការីសឡេះដែលជាបងប្អូនរបស់ពួកគេ។ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយគត់។ សម្រាប់ពួកអ្នក គឺគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់បានបង្កើតពួកអ្នកពីដី និងបានឱ្យពួកអ្នករស់នៅលើវាផងដែរ។ ហេតុនេះ ចូរពួកអ្នកសុំការអភ័យទោសពីទ្រង់។ បន្ទាប់មក ចូរពួកអ្នកសារភាពកំហុសចំពោះទ្រង់ចុះ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំជាអ្នកដែលនៅជិតបង្កើយ និងជាអ្នកដែលឆ្លើយតប(ចំពោះអ្នកទាំងឡាយដែលបានបួងសួងទៅកាន់ទ្រង់)។

62. ពួកគេបានតបវិញថា៖ ឱ សឡេះ! ជាការពិតណាស់ រូបអ្នកធ្លាប់ជាបុគ្គលដែលគេសង្ឃឹម (ថានឹងក្លាយជាមេដឹកនាំ) ក្នុងចំណោមពួកអ្នកមុនពេលដែលអ្នកពោលអះអាងបែបនេះ។ តើអ្នកហាមឃាត់ពួកយើងមិនឱ្យគោរពសក្ការៈចំពោះអ្វី(ព្រះនានា)ដែលដីជូនដីតារបស់ពួកយើងធ្លាប់គោរពសក្ការៈនោះឬ? ពិតប្រាកដណាស់ ពួកយើងមានការមន្ទិលសង្ស័យយ៉ាងខ្លាំងចំពោះអ្វីដែលអ្នកកំពុងតែអំពាវនាវពួកយើងទៅកាន់វានោះ។

63. គាត់បានពោលថា៖ ឱក្រុមរបស់ខ្ញុំ! តើពួកអ្នកយល់យ៉ាងណា ប្រសិនបើខ្ញុំស្ថិតនៅលើសញ្ញាកស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ខ្ញុំ ហើយទ្រង់បានប្រទានដល់ខ្ញុំនូវក្តីមេត្តាករុណាអំពីទ្រង់។ ដូច្នេះ តើនរណាដែលអាចជួយខ្ញុំឱ្យរួចផុតពី(ទណ្ឌកម្មរបស់)អល់ឡោះបាន ប្រសិនបើខ្ញុំប្រឆាំងនឹងទ្រង់នោះ? ពិតប្រាកដណាស់ ពួកអ្នកមិនបានបន្ថែមនូវអ្វីដល់ខ្ញុំក្រៅពីការខាតបង់នោះឡើយ។

64. ឱក្រុមរបស់ខ្ញុំ! នេះគឺជាសត្វអូដ្ឋញីរបស់អល់ឡោះ ជាកស្តុតាងមួយសម្រាប់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នកបណ្តោយវាឱ្យដើរកចំណីស៊ីនៅលើផែនដីរបស់អល់ឡោះចុះ ហើយពួកអ្នកមិនត្រូវប៉ះពាល់វាដោយប្រការអាក្រក់ណាមួយឡើយ។ បើមិនដូច្នោះទេ ពួកអ្នកនឹងត្រូវទទួលនូវទណ្ឌកម្មឆាប់ៗនេះជាមិនខាន។

65. តែពួកគេបានសំឡេះវា(សត្វអូដ្ឋនោះ)។ ពេលនោះ គាត់(ព្យាការីសឡេះ)បាននិយាយថា៖ ចូរពួកអ្នកសោយសុខក្នុងលំនៅឋានរបស់ពួកអ្នករយៈពេលបីថ្ងៃចុះ។ (ក្រោយមក ទណ្ឌកម្មរបស់អល់ឡោះនឹងមកដល់ពួកអ្នកជាមិនខាន)។ នោះជាការសន្យាមួយ(ដែលនឹងកើតឡើងដោយចៀសមិនផុត) ពុំមែនជារឿងកុហកឡើយ។

66. ហើយនៅពេលដែលបទបញ្ជារបស់យើងបានមកដល់ យើងបានសង្គ្រោះព្យាការីសឡេះ និងបណ្តាអ្នកមានជំនឿដែលនៅជាមួយគាត់ដោយក្តីមេត្តាករុណាពីយើង ព្រមទាំង(ឱ្យពួកគេរួចផុត)ពីភាពអាម៉ាស់នាថ្ងៃនោះ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) គឺមហាខ្លាំងក្លា មហាខ្លាំងពូកែបំផុត។

67. ហើយសម្រែកដ៏ខ្លាំងមួយបានឆក់យកជីវិតពួកដែលបំពាន(ក្រុមសាមូទ) ហើយពួកគេក៏បាន(ស្លាប់)ក្លាយជាសាកសពនៅក្នុងផ្ទះរបស់ពួកគេ។

68. ហាក់បីដូចជាពួកគេមិនធ្លាប់បានរស់នៅទីនោះសោះឡើយ។ តើពុំមែនទេឬ ក្រុមសាមូទបានប្រឆាំងនឹងព្រះជាម្ចាស់របស់ពួកគេ។ តើពុំមែនទេឬ ក្តីវិនាសអន្តរាយ គឺធ្លាក់ទៅលើក្រុមសាមូទ?

69. ហើយជាការពិតណាស់ បណ្តាអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងបានមកដល់ព្យាការីអ៊ីព្រហ៊ីមដោយនាំមកនូវដំណឹងល្អ។ ពួកគេបាននិយាយថា៖ សាឡាម(សូមសន្តិភាពកើតមានដល់អ្នក) ហើយគាត់ក៏តបវិញថា៖ សាឡាម(សូមសន្តិភាពកើតមានដល់អ្នកដូចគ្នាដែរ)។ ក្រោយមក គាត់ក៏បាននាំមកឱ្យពួកគេនូវកូនគោអាំងមួយក្បាល(ដើម្បីទទួលពួកគេ)។

70. នៅពេលដែលគាត់បានឃើញដៃរបស់ពួកគេ(ម៉ាឡាអ៊ីកាត់)មិនលូកចាប់សាច់(ដើម្បីទទួលទាន)គាត់បានបដិសេធពួកគេចំពោះទង្វើនេះ ហើយគាត់ក៏មានអារម្មណ៍ភ័យខ្លាចចំពោះពួកគេ។ ពួកគេក៏និយាយថា៖ ចូរអ្នកកុំខ្លាច។ ពួកយើងត្រូវបានគេ(អល់ឡោះ)បញ្ជូនទៅកាន់ក្រុមរបស់ព្យាការីលូត។

71. ហើយប្រពន្ធរបស់គាត់(នាងសារ៉ោះ)បានឈរស្តាប់នៅទីនោះដោយនាងបានសើចញញឹម។(ម៉ាឡាអ៊ីកាត់បានបន្តថា៖)ពួកយើងសូមផ្តល់ដំណឹងរីករាយដល់នាងនូវ(កំណើតកូនប្រុសម្នាក់ឈ្មោះ)អ៊ីស្ហាក ហើយបន្ទាប់ពីអ៊ីស្ហាក គឺយ៉ាក់កូប(ជាចៅ)។

72. នាងបាននិយាយ(ដោយភ្ញាក់ផ្អើល)ថា៖ អស្ចារ្យម្ល៉េះខ្ញុំ! តើឱ្យខ្ញុំមានកូនយ៉ាងដូចម្តេច ខណៈដែលខ្ញុំមានវ័យចំណាស់ ហើយប្តីរបស់ខ្ញុំ(ព្យាការីអ៊ីព្រហ៊ីម)នេះទៀតសោត ក៏មានវ័យចំណាស់ណាស់ហើយដែរនោះ? នេះគឺជារឿងមួយចម្លែកណាស់។

73. ពួកគេ(ម៉ាឡាអ៊ីកាត់)បានតបថា៖ តើនាងមានការចម្លែកចិត្តចំពោះកិច្ចការរបស់អល់ឡោះឬ? សូមក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់ពួកអ្នក ឱក្រុមគ្រួសារ(អ៊ីព្រហ៊ីម)។ ពិតប្រាកដណាស់ ទ្រង់ជាទីកោតសរសើរមហាថ្កុំថ្កើងបំផុត។

74. ហើយនៅពេលដែលភាពភ័យខ្លាចបានរសាយចេញពីព្យាការីអ៊ីព្រហ៊ីម ហើយដំណឹងល្អក៏បានមកដល់គាត់(ពីការមានកូនប្រុស និងចៅប្រុស)នោះ គាត់ក៏បានជជែកវែកញែកជាមួយអ្នកនាំសាររបស់យើង(ម៉ាឡាអ៊ីកាត់)ពីរឿងក្រុមរបស់ព្យាការីលូត។

75. ពិតប្រាកដណាស់ ព្យាការីអ៊ីព្រហ៊ីមគឺជាមនុស្សខន្តី ជាអ្នកដែលតែងតែបួងសួង និងជាអ្នកដែលតែងសារភាពកំហុស(ចំពោះអល់ឡោះ)។

76. (ម៉ាឡាអ៊ីកាត់បានពោលថា៖) ឱព្យាការីអ៊ីព្រហ៊ីម! ចូរអ្នកងាកចេញពីរឿងនេះចុះ(បោះបង់ការជជែកដេញដោល)។ ជាការពិតណាស់ បទបញ្ជានៃព្រះជាម្ចាស់របស់អ្នកពិតជាបានមកដល់ហើយ។ ហើយពិតប្រាកដណាស់ ទណ្ឌកម្មនឹងមកដល់ពួកគេ(ក្រុមរបស់ព្យាការីលូត)ដោយមិនត្រូវបានគេច្រានចោលឡើយ។

77. ហើយនៅពេលដែលអ្នកនាំសាររបស់យើង(ម៉ាឡាអ៊ីកាត់)បានមកដល់ព្យាការីលូត(ក្នុងរូបភាពជាមនុស្សប្រុស)វត្តមានរបស់ពួកគេធ្វើឲ្យគាត់មានការព្រួយបារម្ភ និងមានភាពតានតឹង(ក្នុងចិត្ត)យ៉ាងខ្លាំង។ ហើយគាត់ក៏បាននិយាយថា៖ ថ្ងៃនេះគឺជាថ្ងៃមួយដ៏លំបាកបំផុត។

78. ហើយក្រុមរបស់គាត់ក៏បានមកជួបគាត់ទាំងប្រញាប់ប្រញាល់ដោយសារពីមុនមកពួកគេធ្លាប់បានប្រព្រឹត្តអំពើអាក្រក់(រួមភេទនឹងបុរសដូចគ្នា)។ គាត់បាននិយាយថា៖ ទាំងនេះគឺជាកូនស្រីរបស់ខ្ញុំ។ ពួកនាងមានភាពស្អាតស្អំបំផុតសម្រាប់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ ហើយចូរកុំធ្វើឱ្យខ្ញុំអាម៉ាស់នៅចំពោះមុខភ្ញៀវរបស់ខ្ញុំឱ្យសោះ។ តើក្នុងចំណោមពួកអ្នក(ឱក្រុមរបស់ខ្ញុំ)គ្មានបុរសណាម្នាក់ដែលមានសតិបញ្ញាល្អទេឬ?

79. ពួកគេបានតបវិញថា៖ ជាការពិតណាស់ អ្នកបានដឹងហើយថា ពួកយើងមិនត្រូវការកូនស្រីរបស់អ្នកនោះទេ ហើយអ្នកក៏បានដឹងដែរថា តើអ្វីទៅដែលពួកយើងត្រូវការនោះ។

80. គាត់បាននិយាយថា៖ ប្រសិនបើខ្ញុំមានកម្លាំងអាចទប់ទល់នឹងពួកអ្នកឬក៏មានញាតិមិត្តដែលអាចជួយដល់ខ្ញុំបាននោះ(ខ្ញុំនឹងការពារភ្ញៀវរបស់ខ្ញុំពីពួកអ្នកជាមិនខាន)។

81. ពួកគេ(ម៉ាឡាអ៊ីកាត់)បាននិយាយថា៖ ឱព្យាការីលូត! ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកនាំសារនៃព្រះជាម្ចាស់របស់អ្នក។ ពួកគេមិនអាចប៉ះពាល់ដល់អ្នកនូវប្រការអាក្រក់ណាមួយជាជាច់ខាត។ ដូច្នេះ ចូរអ្នកនាំក្រុមគ្រួសាររបស់អ្នកចាកចេញ(ពីភូមិនេះ)នៅពេលពាក់កណ្តាលយប់ ហើយចូរកុំឱ្យនរណាម្នាក់ក្នុងចំណោមពួកអ្នកងាកក្រោយឱ្យសោះ លើកលែងតែប្រពន្ធរបស់អ្នកប៉ុណ្ណោះ ពីព្រោះនាងក៏នឹងទទួល(ទណ្ឌកម្ម)ដូចអ្វីដែលពួកគេទទួលរងដែរ។ ជាការពិតណាស់ ពេលសន្យារបស់ពួកគេនោះ គឺនៅពេលទៀបភ្លឺ។ តើពុំមែនទេឬ ពេលទៀបភ្លឺនោះ គឺនៅកៀកបំផុត។

82. ដូច្នេះ នៅពេលដែលបទបញ្ជារបស់យើងបានមកដល់ យើងក៏បានធ្វើឱ្យភូមិស្រុកនោះក្រឡាប់ពីលើចុះក្រោម។ ហើយយើងបានបញ្ចុះភ្លៀងដុំថ្មពីដីឥដ្ឋដែលគេដុតទៅលើភូមិស្រុកនោះជាបន្តបន្ទាប់។

83. ដោយវាមានសញ្ញាសម្គាល់ពីព្រះជាម្ចាស់របស់អ្នក។ ហើយវាស្ថិតនៅមិនឆ្ងាយពីពួកដែលបំពាន(ពួកគូរ៉ូស្ហ)នោះឡើយ។

84. ហើយ(យើងបានបញ្ជូន)ទៅកាន់កុលសម្ព័ន្ធម៉ាទយ៉ាន់នូវព្យាការីស៊ូអែបដែលជាបងប្អូនរបស់ពួកគេ។ គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ហើយចូរពួកអ្នកកុំកេងបំបាត់ក្នុងការវាល់ និងការថ្លឹងឲ្យសោះ។ ពិតប្រាកដណាស់ ខ្ញុំសង្កេតឃើញថាពួកអ្នកមានជីវភាពល្អប្រសើរហើយ។ ពិតប្រាកដណាស់ ខ្ញុំខ្លាចពួកអ្នកទទួលនូវទណ្ឌកម្មនាថ្ងៃដែលគ្មានកន្លែងអាចគេចផុត(ពីវា)បានឡើយ។

85. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកបង្រ្កប់នូវការវាល់ និងការថ្លឹងដោយយុត្តិធម៌(គ្រប់ចំនួន)។ ហើយចូរពួកអ្នកកុំកេងប្រវ័ញ្ចមនុស្សលោកនូវកម្មសិទ្ធិរបស់ពួកគេឱ្យសោះ។ ហើយពួកអ្នកក៏មិនត្រូវបង្កវិនាសកម្មលើផែនដីឡើយ។

86. អ្វីដែលអល់ឡោះបន្សល់ទុក គឺល្អបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។ ហើយខ្ញុំមិនមែនជាអ្នកដែលឃ្លាំមើល(លើទង្វើរបស់)ពួកអ្នកឡើយ។

87. ពួកគេបាននិយាយថា៖ ឱស៊ូអែប! តើការសឡាតរបស់អ្នកបានបញ្ជាអ្នកឲ្យប្រើពួកយើងបោះបង់នូវអ្វីដែលដីដូនដីតារបស់ពួកយើងធ្លាប់បានគោរពសក្ការៈ ឬក៏បញ្ជាអ្នកឲ្យប្រើពួកយើងមិនឲ្យចាត់ចែងទ្រព្យសម្បត្តិរបស់ពួកយើងតាមអ្វីដែលពួកយើងចង់ឬ? ជាការពិតណាស់ អ្នកគឺជាមនុស្សដែលមានភាពខន្តី និងមានបញ្ញាឈ្លាសវៃម្នាក់។

88. គាត់បានតបថា៖ ឱក្រុមរបស់ខ្ញុំ! តើពួកអ្នកយល់យ៉ាងណា ប្រសិនបើខ្ញុំស្ថិតនៅលើសញ្ញាកស្តុតាងដ៏ច្បាស់លាស់ពីព្រះជាម្ចាស់របស់ខ្ញុំ ហើយទ្រង់បានប្រទានដល់ខ្ញុំនូវលាភសក្ការៈដែលល្អប្រពៃនោះ? ខ្ញុំមិនមានបំណងប្រឆាំងនឹងពួកអ្នកចំពោះអ្វីដែលខ្ញុំបានហាមឃាត់ពួកអ្នកនោះឡើយ។ ខ្ញុំគ្រាន់តែមានបំណងកែលម្អ(ពួកអ្នកឱ្យល្អប្រសើរ)តាមលទ្ធភាពរបស់ខ្ញុំប៉ុណ្ណោះ។ ហើយការណែនាំរបស់ខ្ញុំមិនអាចទទួលបានផលឡើយ លើកលែងតែការអនុញ្ញាតពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ចំពោះទ្រង់(តែមួយគត់)ដែលខ្ញុំប្រគល់ការទុកចិត្ត ហើយចំពោះទ្រង់(តែមួយគត់)ដែលខ្ញុំនឹងវិលត្រឡប់(សារភាពកំហុស)។

89. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកកុំបង្កនូវភាពជាសត្រូវជាមួយខ្ញុំខ្លាចក្រែងពួកអ្នកទទួលរងដូចអ្វីដែលក្រុមរបស់ព្យាការីនួហ ឬក្រុមរបស់ព្យាការីហ៊ូទ ឬក្រុមរបស់ព្យាការីសឡេះបានទទួលរង។ ចំណែកឯក្រុមរបស់ព្យាការីលូតវិញ គឺនៅមិនឆ្ងាយពីពួកអ្នកនោះឡើយ។

90. ហើយចូរពួកអ្នកសុំការអភ័យទោសពីព្រះជាម្ចាស់របស់ពួកអ្នក។ ក្រោយមក ចូរពួកអ្នកសារភាពកំហុសចំពោះទ្រង់ចុះ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំដ៏មហាករុណា មហាអាណិតស្រលាញ់បំផុត។

91. ពួកគេបាននិយាយថា៖ ឱស៊ូអែប! ពួកយើងមិនសូវយល់ច្រើនទេចំពោះអ្វីដែលអ្នកនិយាយ តែពួកយើងឃើញថា នៅក្នុងចំណោមពួកយើង អ្នកគឺជាមនុស្សដែលមានភាពទន់ខ្សោយ។ ហើយប្រសិនបើគ្មានសាច់ញាតិរបស់អ្នក(នៅលើសាសនារបស់ពួកយើង)ទេនោះ ពួកយើងនឹងគប់សម្លាប់អ្នកនឹងដុំថ្មជាមិនខាន។ ហើយអ្នកមិនមែនជាអ្នកដែលខ្លាំងក្លាសម្រាប់ពួកយើងឡើយ។

92. គាត់បានតបវិញថា៖ ឱក្រុមរបស់ខ្ញុំ! តើសាច់ញាតិរបស់ខ្ញុំមានភាពខ្លាំងក្លាលើពួកអ្នកជាងអល់ឡោះជាម្ចាស់ឬ? ពួកអ្នកយកទ្រង់ដាក់នៅពីក្រោយខ្នងពួកអ្នក។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំដឹងជ្រួតជ្រាបបំផុតនូវអ្វីដែលពួកអ្នកកំពុងប្រព្រឹត្ត។

93. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកប្រកាន់ខ្ជាប់មាគ៌ារបស់ពួកអ្នកចុះ។ ចំណែកខ្ញុំក៏ប្រកាន់ខ្ជាប់(តាមមាគ៌ារបស់ខ្ញុំ)ដែរ។ ពួកអ្នកគង់តែនឹងដឹងថា តើជនណាដែលទណ្ឌកម្មដ៏អាម៉ាស់នឹងមកដល់រូបគេ ហើយតើជនណាដែលជាអ្នកភូតកុហកនោះ។ ហេតុនេះ ចូរពួកអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ ខ្ញុំក៏ជាអ្នករង់ចាំមើលជាមួយពួកអ្នកដែរ។

94. ហើយនៅពេលដែលបទបញ្ជារបស់យើងបានមកដល់ យើងបានសង្គ្រោះព្យាការីស៊ូអែប និងបណ្តាអ្នកមានជំនឿដែលនៅជាមួយគាត់ដោយក្តីមេត្តាករុណាពីយើង ហើយសម្រែកដ៏ខ្លាំងមួយបានឆក់យកជីវិតពួកដែលបំពាន(ពួកម៉ាទយ៉ាន់)ហើយពួកគេក៏បាន(ស្លាប់)ក្លាយជាសាកសពនៅក្នុងផ្ទះរបស់ពួកគេ។

95. ហាក់បីដូចជាពួកគេមិនធ្លាប់បានរស់នៅទីនោះពីមុនមកសោះ។ តើពុំមែនទេ ភាពអន្តរាយ គឺសម្រាប់ពួកម៉ាទយ៉ាន់ ដូចដែលក្រុមសាមូទបានទទួលនូវភាពអន្តរាយដែរ។

96. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនព្យាការីមូសាដោយនាំមកនូវសញ្ញាកស្តតាងទាំងឡាយរបស់យើង ព្រមទាំងអំណះអំណាងយ៉ាងច្បាស់លាស់

97. ទៅកាន់ហ្វៀរអោន និងក្រុមមន្ត្រីរបស់គេ។ ពិតប្រាកដណាស់ ពួកមន្ត្រីទាំងនោះបានធ្វើតាមបទបញ្ជារបស់ហ្វៀរអោន។ ហើយបទបញ្ជារបស់ហ្វៀរអោន គឺមិនមានភាពត្រឹមត្រូវឡើយ។

98. គេ(ហ្វៀរអោន)នឹងនាំមុខក្រុមរបស់គេនាថ្ងៃបរលោក រហូតដល់គេបញ្ចូលពួកគេទាំងអស់គ្នាទៅក្នុងឋាននរក។ ហើយវាជាកន្លែងដ៏អាក្រក់បំផុតសម្រាប់ដែលចូលទៅក្នុងវា។

99. ហើយបណ្តាសាក៏ធ្លាក់ទៅលើពួកគេផងដែរនៅក្នុងលោកិយនេះ និងនៅថ្ងៃបរលោក។ អ្វីដែលពួកគេទទួលបាន(ទាំងបណ្តាសា និងទណ្ឌកម្ម)នេះ គឺអាក្រក់បំផុត។

100. ទាំងនោះ គឺជារឿងរ៉ាវនៃភូមិស្រុកមួយចំនួនដែលយើងបាននិទានប្រាប់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ក្នុងចំណោមស្រុកភូមិទាំងនេះ មានស្រុកភូមិខ្លះបានបន្សល់ទុកស្លាកស្នាម(ដល់អ្នកជំនាន់ក្រោយ) និងខ្លះទៀតមិនបានបន្សល់ទុកស្លាកស្នាមអ្វីឡើយ(បន្ទាប់ពីការបំផ្លាញនោះ)។

101. ហើយយើងមិនបានបំពានទៅលើពួកគេឡើយ ក៏ប៉ុន្តែពួកគេទៅវិញទេដែលបានបំពានលើខ្លួនឯង។ ហើយព្រះនានារបស់ពួកគេដែលពួកគេធ្លាប់គោរពសក្ការៈចំពោះពួកវាក្រៅពីអល់ឡោះនោះ មិនអាចជួយជាប្រយោជន៍អ្វីដល់ពួកគេឡើយ នៅពេលដែលបទបញ្ជានៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានមកដល់ហើយនោះ។ ហើយពួកវាក៏មិនបានបន្ថែមអ្វីដល់ពួកគេក្រៅពីការខាតបង់នោះដែរ។

102. ក៏ដូច្នោះដែរ ព្រះជាម្ចាស់របស់អ្នកទ្រង់ដាក់ទណ្ឌកម្មទៅលើភូមិស្រុកទាំងឡាយព្រោះតែពួកគេជាអ្នកដែលបំពាន។ ពិតប្រាកដណាស់ ទណ្ឌកម្មរបស់ទ្រង់ គឺឈឺចាប់ និងធ្ងន់ធ្ងរបំផុត។

103. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាមេរៀនមួយសម្រាប់ជនណាដែលខ្លាចទណ្ឌកម្មនាថ្ងៃបរលោក។ នោះគឺជាថ្ងៃដែលមនុស្សទាំងអស់ត្រូវបានគេប្រមូលផ្តុំទៅកាន់ទ្រង់។ ហើយនោះជាថ្ងៃដែលសត្វលោកទាំងអស់មានវត្តមាន។

104. ហើយយើងមិនពន្យារពេលវា (ថ្ងៃបរលោក) ក្រៅពីពេលដែលត្រូវបានគេកំណត់នោះឡើយ។

105. ពេលដែលថ្ងៃនោះមកដល់ គ្មានបុគ្គលណាម្នាក់អាចនិយាយបានឡើយ លើកលែងតែមានការអនុញ្ញាតពីទ្រង់ប៉ុណ្ណោះ។ ហើយក្នុងចំណោមពួកគេ គឺមានអ្នកដែលអពមង្គល និងមានអ្នកដែលមានសុភមង្គល (ចូលឋានសួគ៌)។

106. ចំណែកឯពួកដែលអពមង្គលនោះ ពួកគេនឹងស្ថិតក្នុងឋាននរក។ សម្រាប់ពួកគេនៅក្នុងនោះ ពួកគេដកដង្ហើមចេញចូលខ្លាំងៗទាំងដង្ហក់។

107. ពួកគេស្ថិតនៅក្នុងនោះជាអមត: ដរាបណាមេឃជាច្រើនជាន់និងផែនដី (ថ្ងៃបរលោក) នៅមានវត្តមាន លើកលែងតែអ្វីដែលព្រះជាម្ចាស់របស់អ្នកទ្រង់មានចេតនាប៉ុណ្ណោះ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។

108. រីឯអ្នកដែលមានសុភមង្គលវិញ ពួកគេនឹងស្ថិតនៅក្នុងឋានសួគ៌ដោយពួកគេស្ថិតនៅទីនោះជាអមត: ដរាបណាមេឃជាច្រើនជាន់ និងផែនដី (ថ្ងៃបរលោក) នៅមានវត្តមាន លើកលែងតែអ្វីដែលព្រះជាម្ចាស់របស់អ្នកទ្រង់មានចេតនាប៉ុណ្ណោះ។ ជាការប្រោសប្រទានមួយដែលមិនមានការកាត់ផ្តាច់ (ពីពួកគេ) ឡើយ។

109. ហេតុនេះ ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) កុំមានការមន្ទិលសង្ស័យចំពោះអ្វីដែលពួកគេ (មុស្លីគីន) ទាំងនោះគោរពសក្ការៈឱ្យសោះ។ ពួកគេគោរពសក្ការៈដូចតែអ្វីដែលដីដូនដីតារបស់ពួកគេបានគោរពសក្ការៈកាលពីមុនប៉ុណ្ណោះ។ ហើយយើងនឹងបំពេញឱ្យពួកគេនូវចំណែករបស់ពួកគេ (អំពីទណ្ឌកម្ម) ដោយពុំមានការខ្វះខាតឡើយ។

110. ហើយជាការពិតណាស់ យើងបានប្រទានឲ្យព្យាការីមូសានូវគម្ពីរ (តាវ៉ត)។ ពេលនោះ ពួកគេបែរជាមានការខ្វែងគំនិតគ្នាចំពោះវាទៅវិញ។ ហើយប្រសិនបើគ្មានការកំណត់ពីមុនពីព្រះជាម្ចាស់របស់អ្នកទេនោះ ទ្រង់ប្រាកដជានឹងដាក់ទណ្ឌកម្មពួកគេ (ក្នុងលោកិយនេះ) ជាមិនខានឡើយ។ ហើយពិតណាស់ ពួកគេ គឺស្ថិតនៅក្នុងភាពសង្ស័យយ៉ាងខ្លាំងចំពោះវា (គម្ពីរគួរអាន)។

111. ហើយជាការពិតណាស់ រាល់ក្រុមទាំងនោះ ព្រះជាម្ចាស់របស់អ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពិតជានឹងបំពេញឱ្យពួកគេនូវ (ការតបស្នងចំពោះ) ទង្វើរបស់ពួកគេ។ ជាការពិតណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

112. ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ប្រកាន់ខ្ជាប់ជានិច្ច (នូវមាគ៌ាដ៏ត្រឹមត្រូវ) ដូចដែលគេបានដាក់បទបញ្ជាចំពោះអ្នក។ ហើយអ្នកដែលបានសារភាពកំហុសជាមួយអ្នក (ក៏ដូចគ្នាដែរ)។ ហើយចូរពួកអ្នកកុំបំពានព្រំដែន (ច្បាប់) ឱ្យសោះ។ ពិតប្រាកដណាស់ ទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

113. ហើយចូរពួកអ្នកកុំទោរទន់ទៅរកពួកដែលបំពាន ដែលជាហេតុធ្វើឱ្យពួកអ្នកត្រូវទទួលរងនូវភ្លើងនរកឲ្យសោះ។ ហើយពួកអ្នកគ្មានអ្នកគាំពារណាក្រៅពីអល់ឡោះឡើយ។ បន្ទាប់មក ពួកអ្នកក៏មិនត្រូវបានគេជួយនោះដែរ។

114. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រតិបត្តិសឡាតនៅចុងវេលាទាំងពីរនៃពេលថ្ងៃ (ពេលព្រលឹម និងពេលល្ងាច) និងពេលមួយនៃពេលយប់ផងដែរ។ ជាការពិតណាស់ អំពើល្អវានឹងលុបបំបាត់នូវអំពើអាក្រក់ទាំងឡាយ។ នោះគឺជាការរំឭកមួយសម្រាប់អ្នកដែលនឹករលឹកទាំងឡាយ។

115. ហើយចូរអ្នកអត់ធ្មត់ចុះ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មិនធ្វើឱ្យផលបុណ្យរបស់អ្នកដែលសាងអំពើល្អបាត់បង់ឡើយ។

116. ហេតុអ្វីបានជាក្នុងចំណោមប្រជាជាតិជាច្រើនមុនពួកអ្នក គ្មានអ្នកដែលសាងអំពើល្អនៅសេសសល់ដើម្បីហាមឃាត់ពីការបង្កវិនាសកម្មលើផែនដី ? (គ្មានសេសសល់ឡើយ) លើកលែងតែមួយចំនួនតូចនៃអ្នកដែលយើងបានសង្គ្រោះក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហើយពួកដែលបំពានបានដើរតាមអ្វីដែលពួកគេត្រេកត្រអាល(ក្នុងលោកិយ) ហើយគឺជាពួកដែលប្រព្រឹត្តល្មើស។

117. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានបំផ្លាញភូមិស្រុកដោយបំពាន ខណៈដែលអ្នកស្រុកភូមិនោះគឺជាមនុស្សល្អនោះឡើយ។

118. ហើយប្រសិនបើព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានចេតនា ទ្រង់ពិតជានឹងធ្វើឲ្យពួកគេជាប្រជាជាតិតែមួយជាមិនខាន។ (ប៉ុន្តែទ្រង់ពុំមានចេតនាដូច្នោះឡើយ។) ដូច្នេះ ពួកគេនៅតែបន្តមានការខ្វែងគំនិតគ្នា។

119. លើកលែងតែជនណាដែលព្រះជាម្ចាស់របស់អ្នកមានក្តីមេត្តាករុណាចំពោះគេប៉ុណ្ណោះ។ ដូច្នោះហើយដែលទ្រង់បង្កើតពួកគេ។ ដូច្នេះ ក្នុងចំណោមពួកគេ មានអ្នកដែលមានសំណាងអាក្រក់ និងអ្នកដែលមានសំណាងល្អ។ ហើយពាក្យបន្ទូលនៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានកំណត់រួចជាស្រេចថា៖ ទ្រង់នឹងបំពេញនរកដើហាន់ណាំពីពួកជិន និងមនុស្សលោកទាំងអស់។

120. ហើយរាល់រឿងរ៉ាវរបស់បណ្តាអ្នកនាំសារដែលយើងបាននិទានវាប្រាប់ដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទាំងនោះ គឺដើម្បីពង្រឹងចិត្តរបស់អ្នកឲ្យមានភាពនឹងនរតាមរយៈវា។ ហើយនៅក្នុងជំពូកនេះ គឺបាននាំមកឱ្យអ្នកនូវការពិត និងដំបូន្មានព្រមទាំងជាការរំឭកដល់បណ្តាអ្នកដែលមានជំនឿ។

121. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ពួកដែលគ្មានជំនឿថា៖ ចូរពួកអ្នកប្រកាន់ខ្ជាប់មាគ៌ារបស់ពួកអ្នកចុះ។ ចំណែកពួកយើងក៏ប្រកាន់ខ្ជាប់(តាមមាគ៌ារបស់ពួកយើង)ដែរ។

122. ហើយចូរពួកអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ ពួកយើងក៏ជាអ្នករង់ចាំមើលដូចគ្នាដែរ។

123. ហើយប្រការអាថ៌កំបាំងទាំងឡាយដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ កិច្ចការទាំងអស់នឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់(តែមួយគត់នៅថ្ងៃបរលោក)។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)គោរពសក្ការៈចំពោះទ្រង់ និងប្រគល់ការទុកចិត្តទៅលើទ្រង់ចុះ។ ហើយព្រះជាម្ចាស់របស់អ្នកមិនព្រងើយកន្តើយចំពោះអ្វីដែលពួកអ្នកប្រព្រឹត្តនោះឡើយ។

ជំពូក យូសុះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម រ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ ទាំងនោះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ដ៏ច្បាស់លាស់បំផុត។

2. ពិតប្រាកដណាស់ យើងបានបញ្ចុះគម្ពីរគួរអានជាភាសាអារ៉ាប់ សង្ឃឹមថាពួកអ្នក(ឱពួកអារ៉ាប់)នឹងឈ្វេងយល់។

3. យើងនឹងនិទានប្រាប់ដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវរឿងមួយដែលល្អជាងគេបំផុតតាមរយៈគម្ពីរគួរអាននេះ ដែលយើងបានផ្តល់វាហ៊ីទៅកាន់អ្នក ខណៈដែលមុននឹងគេបញ្ចុះវាមករូបអ្នកគឺស្ថិតនៅក្នុងចំណោមអ្នកដែលមិនដឹង(អំពីរឿងនេះ)ឡើយ។

4. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលព្យាការីយូសុះបាននិយាយទៅកាន់ឪពុករបស់គាត់ (ព្យាការីយ៉ាក់កូប)ថា៖ ឱលោកឪពុក! ពិតប្រាកដណាស់ ខ្ញុំបានសុបិនឃើញផ្កាយដប់មួយដួង ព្រះអាទិត្យ និងព្រះចន្ទ ដោយខ្ញុំបានឃើញពួកវាក្រាបស៊ូជោតមកចំពោះខ្ញុំ។

5. គាត់(ឪពុកព្យាការីយូសុះ)បានតបថា៖ ឱកូនសម្លាញ់របស់ពុក! ចូរកូនកុំនិទានពីសុបិនរបស់កូនប្រាប់ដល់បងប្អូនរបស់កូនឱ្យសោះ ដែលជាហេតុធ្វើឱ្យពួកគេរៀបចំឧបាយកលប្រឆាំងនឹងកូន។ ពិតប្រាកដណាស់ ស្មែតនគឺជាសត្រូវយ៉ាងច្បាស់លាស់នឹងមនុស្ស។

6. ហើយដូច្នោះដែរ ព្រះជាម្ចាស់របស់អ្នកទ្រង់ជ្រើសរើសអ្នក(ឱព្យាការីយូសុះ) និងបានបង្រៀនអ្នកឱ្យចេះកាត់សុបិន។ ហើយទ្រង់បានបំពេញឧបការគុណរបស់ទ្រង់ចំពោះអ្នក និងពូជពង្សរបស់ព្យាការីយ៉ាក់កូប ដូចដែលទ្រង់បានបំពេញវាទៅចំពោះជីតាទាំងពីររបស់អ្នក គឺព្យាការីអ៊ីព្រហ៊ីម និងព្យាការីអ៊ីស្ហាកពីមុនមកដែរ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកមហាដឹង មហាគតិបណ្ឌិត។

7. ជាការពិតណាស់ ចំពោះ(រឿងរ៉ាវរបស់)ព្យាការីយូសុះ និងបងប្អូនរបស់គាត់ គឺជាមេរៀនមួយសម្រាប់អ្នកទាំងឡាយដែលស្វែងរក(ពីរឿងរ៉ាវរបស់ពួកគេ)។

8. នៅពេលដែលពួកគេ(បងប្អូនរបស់គាត់)បាននិយាយគ្នាថា៖ ពិតប្រាកដណាស់ យូសុះ និងប្អូនប្រុសបង្កើតរបស់គេ(ពុនយ៉ាមីន) គឺជាទីស្រលាញ់ពេញចិត្តចំពោះឪពុកយើងជាងពួកយើង ទាំងដែលពួកយើងមានគ្នាច្រើនក៏ដោយ។ ជាការពិតណាស់ ឪពុករបស់យើងស្ថិតក្នុងភាពខុសឆ្គង(លម្អៀង)យ៉ាងច្បាស់លាស់។

9. ចូរពួកអ្នកសម្លាប់យូសុះ ឬយកគេទៅបំបរបង់ចោលនៅកន្លែងឆ្ងាយចុះ នោះឪពុករបស់ពួកអ្នកនឹងងាកមក(ស្រឡាញ់)តែពួកអ្នកវិញ។ ហើយក្រោយពីនោះមក ពួកអ្នកនឹងក្លាយជាក្រុមមួយដែលល្អត្រឹមត្រូវវិញ។

10. ម្នាក់ក្នុងចំណោមពួកគេបាននិយាយថា៖ ចូរពួកអ្នកកុំសម្លាប់យូសុះ តែពួកអ្នកត្រូវបោះគេចូលទៅក្នុងបាតអណ្តូងវិញ នោះអ្នកដំណើរមួយចំនួន(ដែលឆ្លងកាត់ទីនោះ)នឹងរើសយកគេជាមិនខាន ប្រសិនបើពួកអ្នកចង់ធ្វើដូច្នោះមែននោះ។

11. (ក្រោយពេលពួកគេបានឯកភាពគ្នារួច) ពួកគេក៏និយាយថា៖ ឱ ឪពុករបស់ពួកយើង! ហេតុអ្វីបានជាពុកមិនទុកចិត្តពួកយើងឲ្យមើលថែយូសុះ? ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកផ្តល់ដំបូន្មានដល់រូបគេ។

12. សូមពុកបញ្ជូនរូបគេទៅជាមួយពួកយើងនៅថ្ងៃស្អែក ដើម្បីឱ្យគេបានរីករាយ និងការលេងសប្បាយផងចុះ។ ពិតប្រាកដណាស់ ពួកខ្ញុំគឺជាអ្នកមើលថែរក្សារូបគេ។

13. គាត់(ឪពុករបស់ពួកគេ)បានតបថា៖ ពិតណាស់ យើងមានការព្រួយបារម្ភនៅពេលដែលពួកឯងយកគេទៅជាមួយ ហើយយើងបារម្ភខ្លាចរូបគេត្រូវឆ្កែចចកខាំស៊ី ខណៈដែលពួកឯងធ្វេសប្រហែសចំពោះរូបគេ។

14. ពួកគេតបថា៖ ប្រសិនបើរូបគេត្រូវឆ្កែចចកខាំស៊ី ខណៈដែលពួកយើងជាក្រុមដែលខ្លាំងក្លានោះ បើដូច្នោះមែន ពួកយើងគឺជាពួកដែលខាតបង់(គ្មានបានការ)នោះឡើយ។

15. នៅពេលដែលពួកគេបាននាំរូបគេ(ព្យាការីយូសុះ)ទៅជាមួយ ហើយពួកគេបានឯកភាពគ្នាលើការបោះរូបគេទៅក្នុងអណ្តូង ហើយនោះ យើងក៏បានផ្តល់វាហ៊ីទៅកាន់រូបគេ(ព្យាការីយូសុះ)ថា៖ ពិតប្រាកដណាស់ អ្នកប្រាកដជានឹងប្រាប់ពួកគេពីទង្វើដែលពួកគេធ្វើនេះ(នៅថ្ងៃណាមួយ)ជាមិនខាន ខណៈដែលពួកគេមិនដឹងខ្លួនឡើយ។

16. ហើយពួកគេបានវិលត្រឡប់មកជួបនឹងឪពុករបស់ពួកគេវិញនៅពេលព្រលប់ ដោយពួកគេបានធ្វើពុតជាយំ។

17. ពួកគេបាននិយាយថា៖ ឱ ឪពុករបស់ពួកយើង! ពិតប្រាកដណាស់ ពួកយើងបានរត់ប្រណាំងគ្នាលេង ហើយពួកយើងបានទុកយូសុះនៅជាមួយឥវ៉ាន់របស់ពួកយើង ស្រាប់តែឆ្កែចចកបានមកខាំស៊ីគេ។ ក៏ប៉ុន្តែ (ទោះជាយ៉ាងណា)ពុកមិនជឿពួកយើងឡើយ ទោះបីជាពួកយើង គឺជាអ្នកដែលទៀងត្រង់ក៏ដោយ។

18. ហើយពួកគេបាននាំមកនូវអាវរបស់ព្យាការីយូសុះដែលប្រឡាក់ទៅដោយឈាមក្លែងក្លាយ។ គាត់ក៏បាននិយាយថា៖ ផ្ទុយទៅវិញ ពួកឯងបាននាំគ្នាប្រឌិតរឿងនេះឡើងដោយខ្លួនឯងប៉ុណ្ណោះ។ ដូចនេះ ការអត់ធ្មត់គឺប្រសើរបំផុត។ ហើយមានតែអល់ឡោះទេដែលត្រូវបានគេសុំឱ្យជួយ(បង្ហាញការពិត)ទៅលើអ្វីដែលពួកអ្នកបានរៀបរាប់នោះ។

19. ហើយក្បួនអ្នកដំណើរក៏បានមកដល់(កន្លែងអណ្តូង)។ ពេលនោះ ពួកគេក៏បានបញ្ជូនអ្នកដងទឹករបស់ពួកគេ(ឲ្យទៅដងទឹក)។ អ្នកដងទឹកក៏បានទម្លាក់យោងទឹករបស់គេ (ហើយព្យាការីយូសុះក៏បានតោងខ្សែនោះឡើងមក)។ គេក៏ពោលថា៖ អូហ៍ អស្ចារ្យមែន! នេះជាក្មេងប្រុសទេតើ! ហើយពួកគេក៏បានលាក់រូបគេ(ព្យាការីយូសុះ)ទុកជាទំនិញ។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេបានធ្វើ។

20. ហើយពួកគេបានលក់យូសុះក្នុងតម្លៃមួយដ៏ថោកបំផុត គឺតែប៉ុន្មានទៀរហាំ(លុយអារ៉ាប់ជំនាន់ដើម)ប៉ុណ្ណោះ។ ហើយពួកគេគឺជាពួកដែលមិនឲ្យតម្លៃចំពោះយូសុះឡើយ។

21. ហើយបុរសម្នាក់មកពីប្រទេសអេហ្ស៊ីបដែលបានទិញព្យាការីយូសុះនោះបាននិយាយទៅកាន់ភរិយារបស់ខ្លួនថា៖ ចូរនាងរៀបចំកន្លែងស្នាក់នៅសម្រាប់គេឲ្យបានសមរម្យផង សង្ឃឹមថាគេអាចផ្តល់ផលប្រយោជន៍ដល់ពួកយើង ឬក៏ពួកយើងអាចយកគេធ្វើជាកូនចិញ្ចឹមតែម្តងក៏បាន។ ក៏ដូច្នោះដែរ យើង(អល់ឡោះ)បានផ្តល់ឲ្យព្យការីយូសុះគ្រប់គ្រងនៅក្នុងទឹកដី(ប្រទេសអេហ្ស៊ីប)នេះ ហើយយើងបានបង្រៀនគេឲ្យចេះកាត់សុបិន។ អល់ឡោះជាអ្នកដែលមានអានុភាពបំផុតលើកិច្ចការរបស់ទ្រង់។ ក៏ប៉ុន្តែមនុស្សភាគច្រើនមិនដឹងឡើយ។

22. ហើយនៅពេលដែលគេ(ព្យាការីយ៉ូសុះ)ធំពេញវ័យនោះ យើងបានប្រទានដល់គេនូវភាពឈ្លាសវៃ និងចំណេះដឹង។ ក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះបណ្តាអ្នកដែលសាងអំពើល្អ។

23. ហើយភរិយារបស់អាហ្ស៊ីសបានហៅព្យាការីយ៉ូសុះ(យ៉ាងទន់ភ្លន់) ខណៈដែលគាត់ស្ថិតក្នុងផ្ទះរបស់នាងដើម្បីប្រព្រឹត្តនូវទង្វើអសីលធម៌ ហើយនាងបានបិទទ្វារទាំងអស់។ នាងក៏បាននិយាយថា៖ សូមអ្នកមកកាន់ខ្ញុំមក! គាត់ក៏បានពោលថា៖ ខ្ញុំសុំពឹងអល់ឡោះបញ្ចៀសខ្ញុំ(ពីរឿងនេះ)។ ពិតប្រាកដណាស់ ចៅហ្វាយរបស់ខ្ញុំ(អាហ្ស៊ីស)បានផ្តល់កន្លែងស្នាក់នៅដ៏ប្រសើរដល់ខ្ញុំ។ ហើយពិតប្រាកដណាស់ ពួកដែលបំពាននោះ គឺមិនទទួលជោគជ័យឡើយ។

24. ពិតប្រាកដណាស់ នាងមានបំណងប្រព្រឹត្តនូវទង្វើអសីលធម៌ចំពោះគាត់ ហើយគាត់ក៏មានបំណងប្រព្រឹត្តទង្វើបែបនេះចំពោះនាងវិញដែរ ប្រសិនបើគាត់មិនបានឃើញសញ្ញាភស្តុតាងនៃព្រះជាម្ចាស់របស់គាត់ទេនោះ។ នោះគឺដើម្បីយើងនឹងបញ្ចៀសរូបគេពីប្រការអាក្រក់ និងទង្វើអសីលធម៌ទាំងឡាយ។ ពិតប្រាកដណាស់ រូបគេគឺស្ថិតក្នុងចំណោមខ្ញុំបម្រើរបស់យើងដ៏ស្មោះស។

25. គេទាំងពីរ(ព្យាការីយ៉ូសុះ និងភរិយាអាហ្ស៊ីស)បានប្រញាប់ប្រញាប់ទៅរកទ្វារ(ម្នាក់រត់គេចម្នាក់រារាំង)ហើយនាងក៏បានធ្វើឱ្យអាវរបស់គាត់រហែកពីខាងក្រោយ ហើយគេទាំងពីរក៏បានប្រទះឃើញស្វាមីរបស់នាងឯមាត់ទ្វារ។ នាងបាននិយាយថា៖ គ្មានការតបស្នងអ្វីសម្រាប់អ្នកដែលមានបំណងអាក្រក់មកលើភរិយារបស់អ្នក(ឱអាហ្ស៊ីស) ក្រៅពីការចាប់ដាក់គុក ឬក៏ដាក់ទណ្ឌកម្មដ៏ឈឺចាប់បំផុត(ចំពោះគេ)នោះឡើយ។

26. ព្យាការីយ៉ូសុះក៏បានតបថា៖ តាមពិត នាងទេដែលទាមទារឱ្យខ្ញុំប្រព្រឹត្តទង្វើអសីលធម៌ជាមួយនាងនោះ។ ហើយសាក្សីម្នាក់អំពីគ្រួសាររបស់នាងបានធ្វើសាក្សីថា៖ ប្រសិនបើអាវរបស់គេរហែកពីខាងមុខ នោះនាងជាអ្នកនិយាយពិត ហើយគេគឺស្ថិតក្នុងចំណោមអ្នកដែលនិយាយកុហក។

27. តែប្រសិនបើអាវរបស់គេរហែកពីខាងក្រោយវិញនោះ នាងគឺជាអ្នកដែលនិយាយកុហក ហើយរូបគេស្ថិតក្នុងចំណោមអ្នកដែលនិយាយពិត។

28. ហើយនៅពេលដែលគាត់(អាហ្ស៊ីស)បានឃើញអាវរបស់គេរហែកពីខាងក្រោយ គាត់ក៏បាននិយាយថា៖ ពិតណាស់ វាគ្រាន់តែជាល្បិចកលរបស់ពួកនាងប៉ុណ្ណោះ។ ពិតប្រាកដណាស់ ល្បិចកលរបស់ពួកនាង គឺធំធេងបំផុត។

29. (គាត់បានបន្តថា៖) ឱយ៉ូសុះ! សូមអ្នកបំភ្លេចរឿងនេះចោលចុះ។ ហើយចូរនាងសុំការអភ័យទោសចំពោះទោសកំហុសរបស់នាង។ ជាការពិតណាស់ រូបនាងគឺស្ថិតក្នុងចំណោមអ្នកដែលប្រព្រឹត្តខុសឆ្គង។

30. ហើយមានស្ត្រីមួយចំនួនដែលនៅទីក្រុងបាននិយាយថា៖ ភរិយារបស់អាហ្ស៊ីសបានហៅអ្នកបម្រើរបស់ខ្លួនដើម្បីប្រព្រឹត្តទង្វើអសីលធម៌ជាមួយរូបគេ។ ជាការពិតណាស់ ក្តីស្រលាញ់បានធ្វើឱ្យនាងងប់ងល់។ យើងពិតជាឃើញថា នាងស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

31. នៅពេលដែលនាង(ភរិយាអាហ្ស៊ីស)បានស្តាប់ឮពាក្យរិះគន់របស់ស្ត្រីទាំងនោះ នាងក៏បានចាត់ឱ្យគេទៅអញ្ជើញស្ត្រីទាំងនោះ ហើយនាងបានរៀបចំកន្លែងសម្រាប់ឱ្យពួកនាងទទួលទានខ្លួន និងបានផ្តល់ឱ្យស្ត្រីទាំងអស់នោះនូវកាំបិតម្នាក់មួយ(សម្រាប់ចិតផ្លែឈើ)។ ហើយនាងក៏បាននិយាយ(ទៅកាន់ព្យាការីយ៉ូសុះ)ថា៖ ចូរអ្នកចេញទៅកាន់ពួកនាងចុះ។ នៅពេលដែលស្ត្រីទាំងនោះបានឃើញគាត់ ពួកនាងមានការភ្ញាក់ផ្អើលជាខ្លាំង(ចំពោះសម្រស់ដ៏ស្រស់ស្អាតរបស់គាត់) ហើយពួកនាងក៏បានចិតដៃខ្លួនឯង ព្រមទាំងបាននិយាយថា៖ អល់ឡោះទ្រង់មហាស្អាតស្មើ! នេះមិនមែនជាមនុស្សនោះទេ។ តាមពិត នេះគឺជាម៉ាឡាអ៊ីកាត់មួយរូបដ៏ឧត្តុង្គឧត្តម។

32. នាង(ករិយាអាហ្សីស)ក៏បាននិយាយ(ទៅកាន់ស្ត្រីទាំងនោះ)ថា៖ គេនេះហើយជាអ្វីដែលពួកនាងរិះគន់ខ្ញុំចំពោះគេនោះ។ ពិតប្រាកដណាស់ ខ្ញុំបានទាមទារចង់ប្រព្រឹត្តទង្វើអសីលធម៌ជាមួយនឹងគេពិតមែន តែគេបានបដិសេធ។ ហើយប្រសិនបើគេមិនព្រមធ្វើតាមអ្វីដែលខ្ញុំទាមទារពីគេទេនោះ រូបគេពិតជានឹងត្រូវគេចាប់ឃុំឃាំង ហើយរូបគេនឹងស្ថិតក្នុងចំណោមអ្នកដែលអាប់ឱនមិនខានឡើយ។

33. គាត់(ព្យាការីយ៉ូសុះ)បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់របស់ខ្ញុំ! មន្ទីរឃុំឃាំង គឺជាទីពេញចិត្តចំពោះខ្ញុំជាងអ្វី(ទង្វើអសីលធម៌)ដែលពួកនាងល្បួងខ្ញុំឱ្យទៅរកវាទៅទៀត។ ប្រសិនបើទ្រង់មិនបញ្ចៀសរូបខ្ញុំពីល្បិចកលរបស់ពួកនាងទេនោះ ខ្ញុំប្រាកដជានឹងលម្អៀងទៅរកពួកនាង ហើយខ្ញុំនឹងស្ថិតក្នុងចំណោមពួកដែលល្ងង់ខ្លៅជាមិនខាន។

34. ពេលនោះ ព្រះជាម្ចាស់របស់គាត់ក៏បានឆ្លើយតបចំពោះគាត់។ ដូច្នេះ ទ្រង់ក៏បានបញ្ចៀសរូបគាត់ពីកលល្បិចរបស់ពួកនាង។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

35. បន្ទាប់មក ក្រោយពេលដែលពួកគេបានឃើញនូវកស្តុតាងនានាមក គំនិតផ្សេងក៏បានលេចឡើងចំពោះពួកគេថា ពួកគេត្រូវតែឃុំឃាំងគាត់(ព្យាការីយ៉ូសុះ)មួយរយៈពេលសិន(ដើម្បីកុំឱ្យរឿងអាស្រូវនោះកាន់តែរីកសុសសាយ)។

36. ហើយមានយុវជនពីរនាក់ទៀតក៏បានចូលទៅក្នុងមន្ទីរឃុំឃាំងនោះជាមួយគាត់ដែរ។ ម្នាក់ក្នុងចំណោមគេទាំងពីរបាននិយាយថា៖ ខ្ញុំបានសុបិនឃើញថា ខ្ញុំបានច្របាច់ទំពាំងបាយជូរធ្វើជាស្រា។ ហើយម្នាក់ទៀតបាននិយាយថា៖ ពិតណាស់ ខ្ញុំបានសុបិនឃើញខ្ញុំកំពុងទូលនំប៉័ងនៅលើក្បាលរបស់ខ្ញុំ ស្រាប់តែមានបក្សីមកចឹកស៊ីនំប៉័ងនោះ។ សូមអ្នក(ឱយូសុះ)បកស្រាយប្រាប់ពួកយើងពីអត្ថន័យរបស់វាផង។ ពិតណាស់ យើងឃើញថា អ្នកគឺស្ថិតក្នុងចំណោមមនុស្សល្អម្នាក់។

37. គាត់បានតបថា៖ (មិនត្រឹមតែប៉ុណ្ណោះទេ) សូម្បីតែម្ហូបអាហារដែលគេយកមកឱ្យអ្នកទាំងពីរ ក៏ខ្ញុំអាចបកស្រាយពីលក្ខណៈរបស់វាប្រាប់អ្នកទាំងពីរបានដែរមុនពេលដែលវាមកដល់អ្នកទាំងពីរ។ នោះគឺជាអ្វីដែលព្រះជាម្ចាស់របស់ខ្ញុំទ្រង់បានបង្រៀនដល់ខ្ញុំ។ ពិតប្រាកដណាស់ ខ្ញុំបានបោះបង់ចោលសាសនារបស់ក្រុមដែលមិនមានជំនឿចំពោះអល់ឡោះ ហើយពួកគេគឺជាពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក។

38. ហើយខ្ញុំបានដើរតាមសាសនារបស់ជីដូនជីតាខ្ញុំ គឺព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្ហាក និងព្យាការីយ៉ាក់កូប។ មិនត្រឹមត្រូវឡើយសម្រាប់ពួកយើងក្នុងការយកអ្វីមួយមកធ្វើស្ពឹកនឹងអល់ឡោះនោះ។ ទាំងនោះគឺជាការប្រោសប្រទានរបស់អល់ឡោះចំពោះពួកយើង និងចំពោះមនុស្សលោកទាំងអស់។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនដឹងគុណឡើយ។

39. (គាត់បន្តថា៖) ឱមិត្តរួមមន្ទីរឃុំឃាំងទាំងពីររបស់ខ្ញុំ! តើ(ការគោរពសក្ការៈចំពោះ)ព្រះជាច្រើនផ្សេងៗល្អជាង ឬ(ការគោរពសក្ការៈចំពោះ)អល់ឡោះដែលជាព្រះជាម្ចាស់តែមួយគត់ ជាអ្នកដែលមានអំណាចបំផុតនោះល្អជាង?

40. អ្វី(ព្រះនានា)ដែលពួកអ្នកកំពុងគោរពសក្ការៈក្រៅពីទ្រង់នោះ គ្រាន់តែជាឈ្មោះដែលពួកអ្នក និងជីដូនជីតារបស់ពួកអ្នកបានដាក់ឈ្មោះឲ្យពួកវាប៉ុណ្ណោះដោយអល់ឡោះមិនបានបញ្ជាក់តស្តុតាងណាមួយបញ្ជាក់ទៅលើវាឡើយ។ ការកាត់សេចក្តីគឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ទ្រង់បានដាក់បទបញ្ជាលើពួកអ្នកមិនឱ្យគោរពសក្ការៈ(ចំពោះអ្វីផ្សេង)ក្រៅពីទ្រង់ឡើយ។ នោះហើយជាសាសនាដ៏ត្រឹមត្រូវ។ ក៏ប៉ុន្តែមនុស្សលោកភាគច្រើនមិនបានដឹងឡើយ។

41. ឱមិត្តរួមមន្ទីរឃុំឃាំងទាំងពីររបស់ខ្ញុំ! រីឯម្នាក់ក្នុងចំណោមអ្នកទាំងពីរ(ដែលសុបិនឃើញច្របាច់ទំពាំងបាយជូរធ្វើស្រា) គឺនឹងភ្លាយជាអ្នកចាក់ស្រាថ្វាយស្តេច។ ចំណែកឯម្នាក់ទៀតវិញ រូបគេនឹងត្រូវបានគេចាប់ឆ្កាង ហើយបក្សីនឹងមកចឹក(ស៊ីសាច់)ក្បាលរបស់គេ។ កិច្ចការដែលអ្នកទាំងពីរស្នើសុំឱ្យបកស្រាយនោះ គឺបានចប់សព្វគ្រប់ហើយ។

42. ហើយគាត់បាននិយាយទៅកាន់អ្នកដែលគាត់ដឹងថានឹងត្រូវបានរួចទោសក្នុងចំណោមគេទាំងពីរ(ពោលគឺអ្នកដែលចាក់ស្រាថ្វាយស្តេច)ថា៖ ចូរអ្នកជួយរំឭករឿងរ៉ាវរបស់ខ្ញុំថ្វាយដល់ព្រះរាជារបស់អ្នកឱ្យបានដឹងផង។ ប៉ុន្តែ ស្តេតនបានធ្វើឱ្យគេភ្លេចរឿងនោះថ្វាយដល់ព្រះរាជា។ ហេតុនេះ គាត់(ព្យាការីយ៉ូសុះ)ក៏បន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងនោះអស់រយៈពេលប៉ុន្មានឆ្នាំក្រោយមកទៀត។

43. ហើយព្រះរាជាបានមានបន្ទូលថា៖ ពិតប្រាកដណាស់ យើងបានសុបិនឃើញគោញីជាត់ប្រាំពីរក្បាលត្រូវបានគោស្តមប្រាំពីរក្បាលស៊ីពួកវា និងបានឃើញស្រូវសាឡីស្រស់ប្រាំពីរកួរ ហើយប្រាំពីរកួរទៀតស្ងួត។ ឱពួកមន្ត្រីទាំងឡាយ! ចូរពួកអ្នកបកស្រាយប្រាប់យើងពីសុបិនរបស់យើងមក ប្រសិនបើពួកអ្នកជាអ្នកចេះកាត់សុបិនមែននោះ។

44. ពួកគេ(ក្រុមមន្ត្រី)បានឆ្លើយថា៖ វាជាសុបិនដែលច្របូកច្របល់(គ្មានអត្ថន័យអ្វីឡើយ) ហើយពួកយើងក៏មិនមែនជាអ្នកដែលមានចំណេះដឹងខាងកាត់សុបិននោះដែរ។

45. ហើយអ្នកដែលបានរួចទោសក្នុងចំណោមអ្នកទាំងពីរបាននឹកឃើញ(ដល់ព្យាការីយ៉ូសុះ)ក្រោយពីគេបានភ្លេចគាត់អស់មួយរយៈបាននិយាយថា៖ ខ្ញុំនឹងប្រាប់ពួកអ្នកពី(អត្ថន័យនៃ)ការកាត់សុបិននោះ។ ដូចនេះ សូមទ្រង់មេត្តាចាត់ខ្ញុំទៅកាន់រូបគេ។

46. (បុរសនោះបាននិយាយថា៖) ឱយ៉ូសុះដែលជាអ្នកទៀងត្រង់អើយ! សូមអ្នកកាត់សុបិនឲ្យយើងផងចុះចំពោះ(ការសុបិនឃើញ)គោញីជាត់ប្រាំពីរក្បាលត្រូវបានគោស្តមប្រាំពីរក្បាលស៊ីពួកវា ហើយ(និងបានឃើញ)ស្រូវសាឡីស្រស់ប្រាំពីរកួរ និងប្រាំពីរកួរទៀតស្ងួត ដើម្បីខ្ញុំត្រឡប់ទៅកាន់មនុស្ស(ព្រះរាជា និងមន្ត្រីរបស់ទ្រង់)វិញ សង្ឃឹមថាពួកគេនឹងបានដឹង(ពីអត្ថន័យសុបិននោះ)។

47. ព្យាការីយ៉ូសុះបាននិយាយថា៖ ពួកអ្នកត្រូវដាំដំណាំចំនួនប្រាំពីរឆ្នាំជាប់ៗគ្នា។ ហើយអ្វីដែលពួកអ្នកបានច្រូតទុកនោះ ចូរពួកអ្នករក្សាទុកទាំងកួររបស់វា លើកលែងតែមួយចំនួនតូចដែលពួកអ្នកត្រូវការបរិភោគវាប៉ុណ្ណោះ។

48. បន្ទាប់ពីរយៈពេលនោះកន្លងផុតទៅ នឹងមានប្រាំពីរឆ្នាំទៀតមកដល់ដែលពួកអ្នកនឹងជួបប្រទះនូវគ្រោះរាំងស្ងួតដែលធ្វើឱ្យមនុស្សលោកបរិភោគអស់នូវអ្វីដែលពួកអ្នកបានប្រមូលទុកសម្រាប់ពួកគេ លើកលែងតែបន្តិចបន្តួចដែលពួកអ្នករក្សាវាទុក(ធ្វើជាពូជ)ប៉ុណ្ណោះ។

49. ហើយបន្ទាប់ពីរយៈពេលនោះទៅ នឹងមានមួយឆ្នាំទៀតនឹងមកដល់ដែលមនុស្សលោកនឹងទទួលបានភ្លៀងបរិបូរ។ ហើយក្នុងឆ្នាំនោះដែរ មនុស្សនឹងនាំគ្នាផលិតនូវកេសជ្ជៈ។

50. ព្រះរាជាក៏បានមានបន្ទូលថា៖ ចូរពួកអ្នកនាំគេមកជួបយើង។ ហើយនៅពេលដែលអ្នកនាំសារ(របស់ព្រះរាជា)បានមកដល់គាត់(ព្យាការីយ៉ូសុះ) គាត់ក៏បាននិយាយថា៖ ចូរអ្នកត្រឡប់ទៅកាន់ព្រះរាជារបស់អ្នក ហើយសូមឲ្យទ្រង់សួរនាំស្ត្រីដែលបានចិតដៃខ្លួនឯងទាំងនោះ ថាតើមានរឿងអ្វីកើតឡើង។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់ដឹងបំផុតចំពោះឧបាយកលរបស់ពួកនាង។

51. ទ្រង់បានមានបន្ទូល(ទៅកាន់ស្ត្រីទាំងនោះ)ថា៖ តើមានអ្វីកើតឡើងនៅពេលដែលពួកនាងមានបំណងឲ្យយ៉ូសុះប្រព្រឹត្តទង្វើអសីលធម៌(ជាមួយនឹងពួកនាង)នោះ? ពួកនាងបានឆ្លើយថា៖ អល់ឡោះទ្រង់មហាស្អាតស្ងួ! យើងខ្ញុំមិនធ្លាប់បានដឹងពីភាពអាស្រូវរបស់គេ(ព្យាការីយ៉ូសុះ)ឡើយ។ ពេលនោះ ភរិយារបស់អាហ្ស៊ីសក៏បានពោលថា៖ ពេលនេះ ការពិតបានលាតត្រដាងអស់ហើយ គឺខ្ញុំទេដែលមានបំណងប្រព្រឹត្តទង្វើអសីលធម៌លើរូបគេ(ព្យាការីយ៉ូសុះ)នោះ។ ហើយពិតប្រាកដណាស់ រូបគេពិតជាស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់។

52. (នាងបានបន្តថា៖) នោះគឺដើម្បីឱ្យគាត់បានដឹងថា ពិតប្រាកដណាស់ ខ្ញុំមិនបានក្បត់គាត់នៅពេលដែលគាត់អវត្តមានឡើយ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនបង្ហាញផ្លូវចំពោះឧបាយកលរបស់ពួកក្បត់ឡើយ។

53. ហើយខ្ញុំក៏មិនអះអាងថាខ្លួនខ្ញុំស្អាតស្អំនោះដែរ។ ជាការពិតណាស់ តណ្ហាតែងតែប្រើឲ្យប្រព្រឹត្តអំពើអាក្រក់ លើកលែងតែជនណាដែលព្រះជាម្ចាស់របស់ខ្ញុំអាណិតស្រឡាញ់ប៉ុណ្ណោះ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំមហាអភ័យទោស មហាអាណិតស្រឡាញ់បំផុត។

54. ព្រះរាជាបានមានបន្ទូលថា៖ ចូរពួកអ្នកនាំគេមកជួបយើង។ យើងនឹងតែងតាំងគេជាមនុស្សជំនិតរបស់យើង។ នៅពេលដែលទ្រង់បានមានបន្ទូលជាមួយនឹងគាត់(ព្យាការីយូសុះ)រួច ទ្រង់ក៏មានបន្ទូលថា៖ ជាការពិតណាស់ ចាប់ពីថ្ងៃនេះតទៅអ្នកគឺជាអ្នកដែលមានឋានៈសក្តិខ្ពង់ខ្ពស់ និងជាទីទុកចិត្តសម្រាប់យើង។

55. គាត់បានតបថា៖ សូមទ្រង់តែងតាំងខ្ញុំឱ្យធ្វើជាអ្នកគ្រប់គ្រងឃ្លាំងទាំងឡាយនៅក្នុងទឹកដី(អេហ្ស៊ីប)នេះផងចុះ។ ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកដែលគ្រប់គ្រងថែរក្សា និងមានចំណេះដឹងច្បាស់លាស់។

56. ក៏ដូច្នោះដែរ យើង(អល់ឡោះ)បានប្រទានឱ្យយូសុះនូវអំណាចគ្រប់គ្រងនៅលើទឹកដី(អេហ្ស៊ីប)ដោយគេអាចស្នាក់នៅ និងធ្វើដំណើរទៅកាន់កន្លែងណាក៏បានតាមដែលគេប្រាថ្នា។ យើងប្រទាននូវក្តីមេត្តាករុណារបស់យើងទៅចំពោះជនណាដែលយើងមានចេតនា ហើយយើងមិនបំបាត់ផលបុណ្យរបស់បណ្តាអ្នកដែលសាងអំពើល្អឡើយ។

57. ហើយផលបុណ្យនៅថ្ងៃបរលោក គឺល្អប្រសើរជាងសម្រាប់បណ្តាអ្នកដែលមានជំនឿ ហើយពួកគេកោតខ្លាច(ទ្រង់)។

58. ហើយបងប្អូនរបស់ព្យាការីយូសុះបានមកដល់(ទឹកដីអេហ្ស៊ីប) រួចពួកគេបានចូលទៅជួបគាត់។ ពេលនោះ គាត់ក៏ស្គាល់ពួកគេ តែពួកគេមិនស្គាល់គាត់ឡើយ។

59. ហើយនៅពេលគាត់(ព្យាការីយូសុះ)បានរៀបចំឱ្យពួកគេ(បងប្អូនរបស់គាត់)នូវបង្វេចស្បៀងរបស់ពួកគេរួចរាល់ គាត់ក៏បាននិយាយថា៖ ចូរពួកអ្នកនាំប្អូនប្រុសរបស់ពួកអ្នកពីឪពុករបស់ពួកអ្នកមកជួបខ្ញុំ។ តើពួកអ្នកមិនឃើញទេឬថា ខ្ញុំពិតជាបានវាល់ឱ្យពួកអ្នកយ៉ាងគ្រប់ចំនួន ហើយខ្ញុំគឺជាអ្នកទទួលភ្ញៀវដែលល្អជាងគេនោះ?

60. តែប្រសិនបើពួកអ្នកមិនបាននាំគេមកជួបខ្ញុំទេនោះ ខ្ញុំនឹងមិនវាល់(ស្បៀងអាហារ)ឱ្យពួកអ្នកទៀតឡើយ ហើយចូរពួកអ្នកកុំមករកខ្ញុំទៀតឱ្យសោះ។

61. ពួកគេក៏បានតបថា៖ ពួកយើងនឹងព្យាយាមសុំយកគេពីឪពុករបស់គេ។ ពិតប្រាកដណាស់ ពួកយើងពិតជានឹងធ្វើវាឲ្យបាន។

62. គាត់(ព្យាការីយូសុះ)បាននិយាយទៅកាន់កម្មកររបស់គាត់ថា៖ ចូរពួកអ្នកដាក់លុយកាក់របស់ពួកគេទៅក្នុងក្បួនដំណើររបស់ពួកគេវិញ(ដោយសម្ងាត់) ដើម្បីឲ្យពួកគេដឹងនៅពេលដែលពួកគេត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ពួកគេវិញ សង្ឃឹមថា(វានឹងជំរុញ)ពួកគេត្រឡប់មកវិញ(ម្តងទៀត)។

63. នៅពេលដែលពួកគេបានត្រឡប់ទៅកាន់ឪពុករបស់ពួកគេវិញ ពួកគេបាននិយាយថា៖ ឱលោកឪពុករបស់យើង! ការវាល់(ដោះដូរស្បៀង)នឹងត្រូវបានគេហាមឃាត់ពីពួកយើង(ប្រសិនបើពួកយើងមិនបាននាំប្អូនប្រុសរបស់ពួកយើងទៅជាមួយទេនោះ)។ ហេតុនេះ សូមពុកមេត្តាបញ្ជូនប្អូនប្រុសរបស់ពួកយើងទៅជាមួយពួកយើងផងចុះដើម្បីឲ្យពួកយើងទទួលបានការវាល់(ស្បៀងអាហារ)។ ពិតណាស់ ពួកយើងជាអ្នករក្សាការពារគេដ៏ល្អ។

64. ឪពុករបស់ពួកគេបានតបថា៖ តើឱ្យយើងទុកចិត្តពួកឯងចំពោះរូបគេ(ពុនយ៉ាមីន)ដូចដែលយើងបានទុកចិត្តពួកឯងចំពោះបងប្រុសបង្កើតរបស់គេ(ព្យាការីយ៉ូសុះ)ពីមុនមកនោះឬ? ពិតប្រាកដណាស់ អល់ឡោះគឺជាអ្នកថែរក្សាដ៏ល្អបំផុត ហើយទ្រង់ជាអ្នកដែលមានក្តីអាណិតស្រលាញ់ជាងគេបំផុត។

65. ហើយនៅពេលដែលពួកគេបានបើកមើលបង្វេច(ស្បៀង)របស់ពួកគេ ពួកគេក៏ប្រទះឃើញលុយកាក់របស់ពួកគេត្រូវបានគេបង្វិលត្រឡប់មកឱ្យពួកគេវិញ។ ពេលនោះ ពួកគេក៏និយាយថា៖ ឱលោកឪពុករបស់ពួកយើង! តើពួកយើងចង់បានអ្វីទៀត! នេះគឺជាលុយថ្លៃស្បៀងរបស់ពួកយើងដែលគេបានបង្វិលវាមកឱ្យពួកយើងវិញ។ ពួកយើងបានទទួលនូវស្បៀងអាហារសម្រាប់គ្រួសាររបស់ពួកយើង ហើយអាចថែរក្សាបងប្អូនរបស់ពួកយើង ព្រមទាំងអាចបន្ថែមការអាល់(ដោះដូរស្បៀង)មួយបន្ទុកសត្វអូដ្ឋទៀត។ នោះគឺជារឿងដែលងាយស្រួលបំផុតសម្រាប់គាត់(អាហ្ស៊ីស)។

66. គាត់បាននិយាយទៅកាន់ពួកគេថា៖ យើងនឹងមិនបញ្ជូនរូបគេ(ពុនយ៉ាមីន)ទៅជាមួយពួកឯងជាដាច់ខាត លុះត្រាតែពួកឯងធ្វើកិច្ចសន្យាមួយដោយស្បថនឹងអល់ឡោះថា ពួកឯងពិតជានឹងនាំគេ(ប្អូនប្រុស)ត្រឡប់មកជួបយើងវិញ លើកលែងតែមានគ្រោះហ៊ុមព័ទ្ធពួកឯងទាំងអស់គ្នា(ដោយមិនអាចចេញរួច)ប៉ុណ្ណោះ។ ហើយនៅពេលដែលពួកគេបានធ្វើកិច្ចសន្យាជាមួយគាត់រួចរាល់ គាត់ក៏បានពោលថា៖ អល់ឡោះជាម្ចាស់ទ្រង់គឺជាសាក្សីចំពោះអ្វីដែលពួកយើងបាននិយាយ។

67. ហើយឪពុករបស់ពួកគេបាននិយាយ(ផ្តែផ្តាំពួកគេ)ថា៖ ឱកូនសម្លាញ់! ចូរពួកឯងកុំចូលតាមច្រកទ្វារតែមួយ តែពួកឯងត្រូវចូលតាមច្រកទ្វារផ្សេងៗគ្នា។ យើងមិនអាចការពារពួកអ្នកឯងពី(ការកំណត់របស់)អល់ឡោះបន្តិចណាឡើយ។ ពិតប្រាកដណាស់ ការកាត់សេចក្តីនោះ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ចំពោះទ្រង់(តែមួយគត់)ដែលយើងប្រគល់ការទុកចិត្ត ហើយចំពោះទ្រង់(តែមួយគត់)ដែលបណ្តាអ្នកដែលប្រគល់ការទុកចិត្តទាំងឡាយត្រូវប្រគល់ការទុកចិត្ត។

68. ហើយនៅពេលដែលពួកគេបានចូលតាមច្រកទ្វារផ្សេងៗគ្នាតាមការណែនាំរបស់ឪពុកពួកគេ គឺវាមិនអាចការពារពួកគេបន្តិចសោះឡើយនូវអ្វីដែលអល់ឡោះទ្រង់បានកំណត់ទៅលើពួកគេនោះ។ តាមពិតវាគ្រាន់តែជាអារម្មណ៍ខ្វល់ខ្វាយរបស់ព្យាការីយ៉ាក់កូបចំពោះកូនៗរបស់គាត់ប៉ុណ្ណោះ។ ពិតប្រាកដណាស់ គាត់ជាអ្នកដែលយល់ដឹងចំពោះអ្វីដែលយើងបានបង្រៀនដល់គេ។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនដឹងឡើយ។

69. ហើយនៅពេលដែលពួកគេបានចូលទៅជួបព្យាការីយ៉ូសុះ គាត់ក៏បានឱបបងប្អូនប្រុសបង្កើតរបស់គាត់។ គាត់និយាយថា៖ ជាការពិតណាស់ ខ្ញុំគឺជាបងប្រុសបង្កើតរបស់អ្នក យ៉ូសុះ។ ហេតុនេះ សូមអ្នកកុំមានការព្រួយបារម្ភចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

70. ហើយនៅពេលដែលគាត់(ព្យាការីយ៉ូសុះ)បានរៀបចំបង្វេចស្បៀងអាហារឲ្យពួកគេរួចហើយនោះ គាត់ក៏បានដាក់ផ្តិលមាស(របស់ស្តេច)ទៅក្នុងថង់ប្អូនប្រុសបង្កើតរបស់គាត់(ពុនយ៉ាមីន)។ រួចមក មានអ្នកប្រកាសម្នាក់បានស្រែកប្រកាសទៅកាន់ពួកគេថា៖ ឱម្ចាស់អូដ្ឋដែលដឹកស្បៀង! ពិតប្រាកដណាស់ ពួកអ្នកគឺជាចោរ។

71. ពួកគេបាននិយាយដោយដើរសំដៅទៅកាន់អ្នកប្រកាសនោះថា៖ តើពួកអ្នកបានបាត់អ្វី?

72. ពួកគេបានឆ្លើយថា៖ ពួកយើងបានបាត់ផ្តិលមាសរបស់ស្តេច។ ហើយសម្រាប់អ្នកណាដែលអាចរកឃើញផ្តិលរបស់ស្តេចនោះ យើងធានាថានឹងផ្តល់ង្វាន់ដល់អ្នកនោះ(នូវស្បៀងអាហារ)មួយបន្ទុកសត្វអូដ្ឋ។

73. ពួកគេបាននិយាយថា៖ សូមស្បថនឹងអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ពួកអ្នកបានដឹងហើយថា ពួកយើងមកទីនេះមិនមែនដើម្បីបង្កវិនាសកម្ម(បញ្ហា)នៅក្នុងទឹកដីនេះនោះឡើយ ហើយពួកយើងក៏មិនធ្លាប់ធ្វើជាចោរនោះដែរ។

74. ពួកគេ(ពួកដែលស្រែកប្រកាស)ក៏បានតបវិញថា៖ ដូចនេះ តើអ្វីទៅជាការពិន័យចំពោះវា ប្រសិនបើពួកអ្នកជាអ្នកដែលភូតកុហក?

75. ពួកគេបានតបថា៖ ការពិន័យចំពោះវា គឺជនណាដែលគេរកឃើញ(ផ្តិលមាសនោះ)នៅក្នុងថង់របស់ខ្លួន គឺត្រូវប្រគល់ខ្លួនធ្វើជាទាសករ។ ក៏ដូច្នោះដែរ យើងនឹងតបស្នងដល់ពួកដែលបំពាន។

76. ពេលនោះ គាត់(ព្យាការីយ៉ូសុះ)ក៏ចាប់ផ្តើមឆែកឆេរបង្វែចស្បៀងរបស់ពួកគេ មុននឹងបង្វែចស្បៀងប្អូនប្រុសបង្កើតរបស់គាត់។ បន្ទាប់មក គាត់ក៏បានបញ្ចេញនូវផ្តិលមាសនោះចេញពីបង្វែចស្បៀងប្អូនប្រុសបង្កើតរបស់គាត់។ ក៏ដូច្នោះដែរ យើង(អល់ឡោះ)បានរៀបចំផែនការសម្រាប់យ៉ូសុះ។ គាត់មិនអាចយកប្អូនប្រុសរបស់គាត់ឲ្យអនុវត្តតាមច្បាប់របស់ព្រះរាជាបានឡើយ លើកលែងតែអល់ឡោះទ្រង់មានចេតនាប៉ុណ្ណោះ។ យើងលើកឋានៈចំពោះជនណាដែលយើងមានចេតនា។ ហើយនៅពីលើបុគ្គលដែលមានចំណេះដឹងទាំងឡាយ គឺមានអ្នកដែលមានចំណេះដឹងខ្លាំងជាង(ហើយនៅពីលើចំណេះដឹងទាំងអស់នោះ គឺអល់ឡោះជាម្ចាស់ដែលជាអ្នកដឹងបំផុត)។

77. ពួកគេ(បងប្អូនរបស់ព្យាការីយ៉ូសុះ)បាននិយាយថា៖ ប្រសិនបើគេ(ប្អូនប្រុសបង្កើតរបស់ព្យាការីយ៉ូសុះ)បានលួចនោះ ពិតណាស់ បងប្រុសបង្កើតរបស់គេក៏ធ្លាប់បានលួចពីមុនមកដែរ។ ហើយព្យាការីយ៉ូសុះបានលាក់ទុកការឈឺចាប់នោះ ហើយគាត់មិនបានបង្ហាញឲ្យពួកគេបានដឹងនោះទេ។ គាត់បាននិយាយ(ក្នុងចិត្ត)ថា៖ ពួកអ្នកហ្នឹងឯងជាប្រភេទមនុស្សដែលអាក្រក់នោះ។ ហើយអល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតអ្វីដែលពួកអ្នកចោទប្រកាន់។

78. ពួកគេ(បងប្អូនរបស់ព្យាការីយ៉ូសុះ)បាននិយាយថា៖ ឱលោកម្ចាស់! ពិតប្រាកដណាស់ រូបគេមានឪពុកម្នាក់ដែលចាស់ជរា។ ហេតុនេះ សូមលោកយកនរណាម្នាក់ក៏បានក្នុងចំណោមពួកយើងជំនួសគេចុះ។ ពិតណាស់ ពួកយើងឃើញថាលោកស្ថិតក្នុងចំណោមអ្នកដែលធ្វើល្អ។

79. គាត់បានតបថា៖ សូមអល់ឡោះបញ្ជៀសពួកយើងពីការចាប់អ្នកផ្សេងក្រៅតែពីអ្នកដែលពួកយើងបានប្រទះឃើញផ្តិលមាសរបស់ស្តេចនៅជាមួយគេ។ ពិតប្រាកដណាស់ ប្រសិនបើពួកយើងធ្វើដូច្នោះនោះ ពួកយើងពិតជាអ្នកដែលបំពានជាមិនខាន។

80. ដូច្នោះ នៅពេលដែលពួកគេបានអស់សង្ឃឹមពីរឿងនោះ ពួកគេក៏បានបែរចេញពីមនុស្សលោកដើម្បីនិយាយពិភាក្សាគ្នា។ បងប្រុសច្បងរបស់ពួកគេបាននិយាយថា៖ តើពួកអ្នកមិននឹកឃើញទេឬថា ពិតប្រាកដណាស់ ឪពុករបស់ពួកអ្នកបានឱ្យពួកអ្នកធ្វើកិច្ចសន្យានឹងអល់ឡោះ(ថានឹងនាំរូបគេត្រឡប់ទៅកាន់គាត់វិញ)ហើយកាលពីមុនទៀត ពួកអ្នកបានធ្វើឱ្យបាត់យ៉ូសុះរួចមកហើយ។ ជាការពិតណាស់ ខ្ញុំនឹងមិនចាកចេញពីទឹកដី(អេហ្ស៊ីប)នេះជាដាច់ខាត លុះត្រាណាតែលោកឪពុករបស់ខ្ញុំអនុញ្ញាតឱ្យខ្ញុំ(ត្រឡប់ទៅវិញ)ឬក៏អល់ឡោះទ្រង់វិនិច្ឆ័យឱ្យខ្ញុំ(នាំយកប្អូនប្រុសរបស់ខ្ញុំមកវិញ)។ ហើយអល់ឡោះគឺជាអ្នកវិនិច្ឆ័យដ៏ប្រសើរបំផុត។

81. (គាត់បានបន្តថា៖) ចូរពួកអ្នកត្រឡប់ទៅកាន់ឪពុករបស់ពួកអ្នកវិញចុះ ហើយពួកអ្នកត្រូវប្រាប់គាត់ថា៖ ឱ លោកឪពុករបស់ពួកយើង! ជាការពិតណាស់ កូនប្រុសរបស់ពុកបានលួចរបស់គេ(ផ្តិលមាសរបស់ស្តេច)ហើយពួកយើងមិនធ្វើសាក្សីក្រៅតែពីអ្វីដែលពួកយើងបានដឹងនោះឡើយ ហើយពួកយើងក៏មិនមែនជាអ្នកដែលថែរក្សា(ដឹង)នូវប្រការអាថ៌កំបាំងនោះដែរ។

82. សូមពុកសួរអ្នកស្រុកដែលនៅជាមួយពួកយើងនៅទីនោះ និងក្បួនអ្នកដំណើរដែលពួកយើងបានវិលត្រឡប់មកជាមួយគ្នាចុះ។ ពិតប្រាកដណាស់ ពួកយើងជាអ្នកដែលទៀងត្រង់។

83. គាត់បានតបថា៖ ផ្ទុយទៅវិញ ពួកឯងទេដែលជាអ្នកប្រឌិតរឿងនេះឡើងដោយខ្លួនឯងនោះ។ ដូចនេះ ការអត់ធ្មត់ គឺជាការប្រសើរបំផុត។ សង្ឃឹមថាអល់ឡោះនឹងនាំពួកគេទាំងអស់មកជួបយើងវិញជាមិនខាន។ ពិតប្រាកដណាស់ ទ្រង់មហាដឹងមហាគតិបណ្ឌិតបំផុត។

84. ហើយគាត់(ព្យាការីយ៉ាក់កូប)ក៏បានបែរចេញពីពួកគេ និងបាននិយាយថា៖ គួរឱ្យអាណោចអាធម្មណាស់ចំពោះយូសុះ។ ហើយភ្នែកទាំងគូរបស់គាត់ក៏ប្រែទៅជាពណ៌ស(ងងឹតភ្នែក) ដោយសារតែទុក្ខព្រួយ ខណៈដែលរូបគាត់ពេញទៅដោយកង្វល់ជាខ្លាំង។

85. ពួកគេបាននិយាយថា៖ សូមស្បថនឹងអល់ឡោះ! ពុកនៅតែនឹករលឹកដល់យូសុះ រហូតដល់ធ្វើឱ្យជំងឺរបស់ពុកកាន់តែធ្ងន់ធ្ងរ ឬរហូតដល់ពុកស្លាប់។

86. គាត់បានតបវិញថា៖ តាមពិត យើងគ្រាន់តែគូញត្បែរនូវទុក្ខសោកនិងទុក្ខព្រួយរបស់យើងទៅកាន់អល់ឡោះជាម្ចាស់តែប៉ុណ្ណោះ។ ហើយយើងដឹងពីអល់ឡោះនូវអ្វីដែលពួកអ្នកមិនបានដឹងឡើយ។

87. ឱកូនៗរបស់ពុក! ចូរពួកឯងទៅ ហើយស៊ើបសួរដំណឹងរបស់យូសុះ និងប្អូនប្រុសរបស់គេចុះ ហើយចូរពួកឯងកុំអស់សង្ឃឹមពីក្តីមេត្តាករុណារបស់អល់ឡោះឲ្យសោះ។ ជាការពិតណាស់ គ្មានជនណាដែលអស់សង្ឃឹមពីក្តីមេត្តាករុណារបស់អល់ឡោះឡើយ លើកលែងតែក្រុមដែលគ្មានជំនឿប៉ុណ្ណោះ។

88. នៅពេលដែលពួកគេបានចូលទៅជួបគាត់(ព្យាការីយូសុះ) ពួកគេបាននិយាយថា៖ ឱលោកម្ចាស់! ពួកយើងនិងក្រុមគ្រួសារបានជួបប្រទះនូវទុក្ខលំបាក ហើយពួកយើងបាននាំមកនូវលុយកាក់បន្តិចបន្តួចប៉ុណ្ណោះ។ ហេតុនេះ សូមលោកមេត្តាជួយវាល់(ដោះដូរស្បៀង)ដល់ពួកយើងឱ្យបានគ្រប់គ្រាន់ ព្រមទាំងមេត្តាជួយបរិច្ចាគបន្ថែមដល់ពួកយើង(ពីលើនោះ)ផង។ ជាការពិតណាស់ អល់ឡោះជាម្ចាស់នឹងតបស្នងដល់អ្នកដែលបរិច្ចាគទាំងឡាយ។

89. គាត់ក៏បានពោលថា៖ តើពួកអ្នកបានដឹងនូវអ្វីដែលពួកអ្នកបានធ្វើទៅលើយូសុះ និងប្អូនប្រុសរបស់គេដែរឬទេ ខណៈដែលពួកអ្នកជាអ្នកល្ងង់ខ្លៅនោះ?

90. ពួកគេក៏សួរថា៖ តើអ្នកគឺជាយូសុះមែនឬ? គាត់បានតបថា៖ យើងហ្នឹងហើយជាយូសុះ ហើយនេះ ជាប្អូនប្រុសបង្កើតរបស់ខ្ញុំ(ពុនយ៉ាមីន)។ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានប្រោសប្រទានដល់ពួកយើង។ ពិតណាស់ ជនណាហើយដែលកោតខ្លាចអល់ឡោះ និងមានភាពអត់ធ្មត់នោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនបំបាត់ផលបុណ្យរបស់អ្នកដែលសាងអំពើល្អឡើយ។

91. ពួកគេក៏និយាយថា៖ សូមស្បថនឹងអល់ឡោះជាម្ចាស់! ជាការពិតណាស់ អល់ឡោះទ្រង់បានលើកតម្កើងអ្នកឱ្យខ្ពង់ខ្ពស់ជាងពួកយើង។ ហើយពិតប្រាកដណាស់ ពួកយើងជាពួកដែលធ្លាប់ធ្វើខុស។

92. គាត់បានតបថា៖ គ្មានការស្តីបន្ទោសអ្វីឡើយចំពោះពួកអ្នកនៅក្នុងថ្ងៃនេះ។ អល់ឡោះនឹងអភ័យទោសដល់ពួកអ្នក។ ហើយទ្រង់គឺជាអ្នកដែលមហាអាណិតស្រលាញ់បំផុត។

93. (គាត់បន្តថា៖) ចូរពួកអ្នកនាំយកអាវរបស់ខ្ញុំនេះ ហើយយកវាគ្រវាសលើផ្ទៃមុខឪពុករបស់ខ្ញុំចុះ នោះគាត់នឹងមើលឃើញវិញជាមិនខាន ហើយចូរពួកអ្នកនាំក្រុមគ្រួសាររបស់ពួកអ្នកទាំងអស់មកជួបខ្ញុំ។

94. ហើយនៅពេលដែលក្បួនដំណើរបានទៅដល់(ភូមិរបស់ពួកគេ) ឪពុករបស់ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ យើងធុំក្លិនយូសុះ ប្រសិនបើពួកអ្នកមិនបានចាត់ទុកខ្ញុំជាមនុស្សវង្វេងទេនោះ។

95. ពួកគេ(កូនៗរបស់គាត់)បាននិយាយថា៖ សូមស្បថនឹងអល់ឡោះ! លោកពុកនៅតែស្ថិតក្នុងភាពវង្វេងវង្វាន់ដូចកាលពីមុនដដែល។

96. នៅពេលដែលអ្នកនាំដំណឹងល្អបានមកដល់ គេក៏បានគ្រវាសអាវនោះទៅលើផ្ទៃមុខរបស់គាត់(ព្យាការីយ៉ាក់កូប)។ ពេលនោះ គាត់ក៏មើលឃើញឡើងវិញ។ គាត់ក៏និយាយថា៖ តើយើងមិនធ្លាប់បានប្រាប់ពួកឯងទេឬថា ជាការពិតណាស់ យើងដឹងពីអល់ឡោះនូវអ្វីដែលពួកឯងមិនបានដឹងនោះ?

97. ពួកគេបាននិយាយថា៖ ឱលោកឪពុករបស់ពួកខ្ញុំ! សូមពុកមេត្តាសុំការអភ័យទោស(ពីអល់ឡោះ)ដល់ពួកខ្ញុំចំពោះបាបកម្មទាំងឡាយរបស់ពួកខ្ញុំផង។ ជាការពិតណាស់ ពួកខ្ញុំធ្លាប់ជាអ្នកដែលធ្វើខុស។

98. គាត់បានតបថា៖ យើងនឹងសុំការអភ័យទោសពីព្រះជាម្ចាស់របស់យើងឱ្យពួកអ្នក។ ជាការពិតណាស់ ទ្រង់មហាអភ័យទោសមហាអាណិតស្រលាញ់បំផុត។

99. នៅពេលដែលពួកគេបានចូលទៅជួបព្យាការីយូសុះ គាត់(ព្យាការីយូសុះ)ក៏បានស្នុះទៅឱបឪពុកម្តាយរបស់គាត់ ហើយគាត់បាននិយាយថា៖ ចូរពួកអ្នកចូលមករស់នៅក្នុងប្រទេសអេហ្ស៊ីបចុះ នោះពួកអ្នកនឹងមានសុវត្ថិភាព ប្រសិនបើអល់ឡោះទ្រង់មានចេតនា។

100. ហើយគាត់(ព្យាការីយូសុះ)បានឲ្យឪពុកម្តាយរបស់គាត់អង្គុយនៅលើកៅអីធំ ហើយពួកគេក៏បានលំឱនកាយស៊ូជោតចំពោះគាត់(ក្នុងន័យគោរពលើកតម្កើងប៉ុណ្ណោះ ពុំមែនក្នុងន័យជាការគោរពសក្ការៈឡើយ)។ គាត់ក៏បាននិយាយថា៖ ឱលោកឪពុកជាទីស្រឡាញ់របស់ខ្ញុំ! នេះហើយជាអត្ថន័យនៃសុបិនរបស់ខ្ញុំកាលពីមុន។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់បានធ្វើឲ្យវាកើតឡើងប្រាកដមែន។ ហើយពិតណាស់ ទ្រង់បានធ្វើល្អចំពោះខ្ញុំ ខណៈដែលទ្រង់បានបញ្ចេញខ្ញុំពីមន្ទីរឃុំឃាំង និងបាននាំអ្នកទាំងអស់គ្នាចេញពីទីជនបទ(មកកាន់ទីនេះ) ក្រោយពីស្មៃតនបានបំបែកបំបាក់រវាងខ្ញុំ និងបងប្អូនរបស់ខ្ញុំ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ខ្ញុំមហាទន់ភ្លន់ចំពោះអ្វីដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ ទ្រង់មហាដឹង មហាគតិបណ្ឌិត។

101. (គាត់បានបន្តថា៖) បពិត្រព្រះជាម្ចាស់! ជាការពិតណាស់ ព្រះអង្គបានប្រទានដល់ខ្ញុំនូវអំណាចគ្រប់គ្រង(នៅក្នុងទឹកដីអេហ្ស៊ីប) ហើយព្រះអង្គបានបង្រៀនខ្ញុំឱ្យចេះកាត់សុបិន។ បពិត្រព្រះជាម្ចាស់ដែលជាអ្នកបង្កើតមេឃជាច្រើនជាន់និងផែនដី! ព្រះអង្គជាអ្នកគាំពារខ្ញុំទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក។ សូមព្រះអង្គមេត្តាបញ្ចប់ជីវិតរបស់ខ្ញុំក្នុងនាមជាអ្នកមូស្លីម និងឲ្យរូបខ្ញុំស្ថិតនៅជាមួយបណ្តាអ្នកសាងកុសលទាំងឡាយផង។

102. ទាំងនោះគឺស្ថិតក្នុងចំណោមរឿងរ៉ាវអាថ៌កំបាំងដែលយើងបានផ្តល់វ៉ាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ អ្នកមិនបានស្ថិតនៅជាមួយពួកគេ(បងប្អូនរបស់ព្យាការីយូសុះ)នោះឡើយនៅពេលពេលដែលពួកគេបានឯកភាពគ្នាលើកិច្ចការរបស់ពួកគេ ខណៈដែលពួកគេរៀបចំនូវឧបាយកលនោះ។

103. ហើយមនុស្សលោកភាគច្រើនគ្មានជំនឿឡើយបើទោះបីជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ព្យាយាម(ពន្យល់)យ៉ាងណាក៏ដោយ។

104. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានទាមទារកម្រៃពីពួកគេ(ចំពោះការផ្សព្វផ្សាយគម្ពីរគួរអាន)នោះឡើយ។ ពិតណាស់វា(គម្ពីរគួរអាន)គ្មានអ្វីក្រៅពីការរំឭកទូន្មានដល់មនុស្សលោកទាំងអស់នោះឡើយ។

105. ហើយមានសញ្ញាកស្តុតាងជាច្រើនដែលមាននៅលើមេឃជាច្រើនជាន់និងនៅលើផែនដីដែលពួកគេឆ្លងកាត់វា តែពួកគេបែរជាងាកចេញអំពីវាទៅវិញ។

106. ហើយពួកគេភាគច្រើនគ្មានជំនឿចំពោះអល់ឡោះឡើយ មានតែពួកគេជាពួកដែលធ្វើស្ហ៊ីរិកទៅវិញ។

107. តើពួកគេ(ពួកមុស្លីគីន)អាចមានសុវត្ថិភាពដែរឬទេ នៅពេលដែលទណ្ឌកម្មរបស់អល់ឡោះដែលគ្របដណ្តប់លើពួកគេបានមកដល់ពួកគេ ឬក៏ថ្ងៃបរលោកមកដល់ពួកគេភ្លាមៗ ខណៈដែលពួកគេមិនបានដឹងខ្លួននោះ ?

108. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ នេះគឺជាមាគ៌ារបស់ខ្ញុំដែលខ្ញុំកំពុងតែអំពាវនាវទៅកាន់អល់ឡោះ ដែល(មាគ៌ានេះ)ស្ថិតនៅលើកស្តុតាងយ៉ាងច្បាស់លាស់ដែលរូបខ្ញុំផ្ទាល់ ព្រមទាំងអ្នកដែលដើរតាមខ្ញុំ(ក៏អំពាវនាវទៅកាន់វា)ដែរ។ អល់ឡោះជាម្ចាស់មហាស្អាតស្អំ។ ហើយខ្ញុំមិនមែនស្ថិតក្នុងចំណោមពួកដែលធ្វើស្ហ៊ីរិកនោះឡើយ។

109. ហើយយើងមិនបានបញ្ជូននរណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ក្រៅតែពីបុរសៗ ដោយយើងបានផ្តល់វាហ៊ីទៅកាន់ពួកគេក្នុងចំណោមអ្នកស្រុកភូមិពួកគេនោះឡើយ។ ដូចនេះ តើពួកគេមិនបានធ្វើដំណើរនៅលើផែនដី ហើយពិនិត្យពិចារណាមើលថា តើលទ្ធផលចុងក្រោយនៃពួកជំនាន់មុនពួកគេ(ដែលបដិសេធនោះ)ទៅជាយ៉ាងណា ? ហើយឋានបរលោក គឺល្អប្រសើរបំផុតសម្រាប់អ្នកដែលកោតខ្លាចអល់ឡោះ។ ដូច្នេះ តើពួកអ្នកមិនចេះគិតពិចារណាទេឬ ?

110. លុះដល់ពេលដែលបណ្តាអ្នកនាំសារទាំងឡាយបានអស់សង្ឃឹម ហើយពួកគេ(ពួកគ្មានជំនឿ)គិតស្មានថា ពិតណាស់ពួកគេត្រូវបានគេ(អ្នកនាំសារ)បោកប្រាស់ ពេលនោះ ជំនួយរបស់យើងក៏បានមកដល់ពួកគេ ហើយយើងក៏បានសង្គ្រោះជនណាដែលយើងមានចេតនា។ ហើយទណ្ឌកម្មរបស់យើងមិនត្រូវបានគេច្រានចេញពីក្រុមឧក្រិដ្ឋជនឡើយ។

111. ជាការពិតណាស់ នៅក្នុងរឿងរ៉ាវរបស់ពួកគេទាំងនោះ គឺជាមេរៀនមួយសម្រាប់បញ្ញាជនទាំងឡាយ។ ហើយវា(គម្ពីរគួរអាន)មិនមែនជាពាក្យសម្តីដែលត្រូវបានគេប្រឌិតឡើងនោះឡើយ ក៏ប៉ុន្តែវាគឺជាការបញ្ជាក់ចំពោះបណ្តាគម្ពីរទាំងឡាយពីមុនវា និងជាការបកស្រាយនូវរាល់អ្វីគ្រប់យ៉ាង ព្រមទាំងជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់ក្រុមដែលមានជំនឿ។

ជំពូក អាល់អ៉ែន៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម រ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ ទាំងនេះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ហើយនិងអ្វី(គម្ពីរគួរអាន)ដែលគេបញ្ចុះមកពីព្រះជាម្ចាស់របស់អ្នក គឺជាការពិត។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនមានជំនឿឡើយ។

2. អល់ឡោះជាអ្នកដែលបានលើកមេឃជាច្រើនជាន់ឲ្យខ្ពស់ឡើងដោយគ្មានសសរ ដូចដែលពួកអ្នកបានឃើញ(ផ្ទាល់នឹងភ្នែកស្រាប់)។ ក្រោយមក ទ្រង់នៅលើអារ៉ស្ស។ ហើយទ្រង់បានបង្កើតព្រះអាទិត្យនិងព្រះចន្ទ។ ពួកវាទាំងអស់សុទ្ធតែធ្វើដំណើរ(តាមគន្លងរបស់វា)រហូតដល់ពេលកំណត់។ ទ្រង់ចាត់ចែងកិច្ចការ និងបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងទាំងឡាយ សង្ឃឹមថាពួកអ្នកមានការជឿជាក់ចំពោះការជួបនឹងព្រះជាម្ចាស់របស់ពួកអ្នក(នាថ្ងៃបរលោក)។

3. ទ្រង់ជាអ្នកលាតសន្ធឹងផែនដី ហើយទ្រង់បានបង្កើតឲ្យមានភ្នំ និងទន្លេជាច្រើននៅលើវា។ ហើយរាល់ប្រភេទនៃផលានុផលទាំងឡាយនៅលើផែនដី ទ្រង់បានបង្កើតវាឱ្យមានជាគូៗ(មានញីមានឈ្មោល)។ ទ្រង់បានធ្វើឱ្យពេលយប់គ្របដណ្តប់លើពេលថ្ងៃ។ ជាការពិតណាស់ ទាំងនោះគឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលគិតពិចារណា។

4. ហើយនៅលើផែនដី គឺមានតំបន់ជាច្រើនដែលនៅជាប់ៗគ្នា និងមានចម្ការជាច្រើន ដូចជា ទំពាំងបាយជូរ មានដំណាំ ហើយនិងដើមល្មើដែលបែកគុម្ព និងដើមល្មើដែលមិនបែកគុម្ពដែល(ដំណាំទាំងនោះ)គេស្រោចស្រពដោយទឹកតែមួយតែយើងធ្វើឲ្យវាមានភាពល្អប្រសើរផ្សេងៗគ្នាក្នុងការទទួលទាន។ ពិតប្រាកដណាស់ នៅក្នុងរឿងទាំងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលចេះគិតពិចារណា។

5. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានការងឿងឆ្ងល់(ពីរឿងអ្វីមួយ) ពិតប្រាកដណាស់ អ្វីដែលអ្នកគួរឆ្ងល់នោះ គឺសម្តីរបស់ពួកគេដែលនិយាយថា៖ តើនៅពេលដែលពួកយើង(បានស្លាប់)ក្លាយទៅជាដីហើយនោះ តើពួកយើងត្រូវបានគេបង្កើត(ឲ្យរស់ឡើងវិញ)សាជាថ្មីយ៉ាងដូចម្តេច? ពួកទាំងនោះហើយ គឺជាពួកដែលប្រឆាំងនឹងព្រះជាម្ចាស់របស់ពួកគេ។ ហើយពួកទាំងនោះនឹងត្រូវគេជាក់ច្រវាក់(អំពីភ្លើងនរក)នៅលើករបស់ពួកគេ។ ពួកទាំងនោះ គឺជាពួកឋាននរកដោយពួកគេស្ថិតនៅក្នុងនោះជាអមត:។

6. ហើយពួកគេសុំឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់នូវប្រការអាក្រក់(ទណ្ឌកម្ម) មុននឹងប្រការល្អ(ជំនឿ)។ ពិតប្រាកដណាស់ ទណ្ឌកម្មបែបនេះបានកើតឡើងរួចមកហើយចំពោះអ្នកជំនាន់មុនពួកគេ។ ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ពោរពេញដោយការអភ័យទោសដល់មនុស្សលោកចំពោះការបំពានរបស់ពួកគេ។ ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់ជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

7. ហើយពួកគ្មានជំនឿបាននិយាយ(ដោយភាពរឹងរូស)ថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះនូវសញ្ញាកស្តុតាង(អច្ឆរិយភាព)ណាមួយពីព្រះជាម្ចាស់របស់គេដល់រូបគេ(ព្យាការីមូហាំម៉ាត់)? តាមពិតអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)គ្រាន់តែជាអ្នកដាស់តឿនព្រមានប៉ុណ្ណោះ។ ហើយរាល់ក្រុមនីមួយៗ គឺតែងតែមានអ្នកដែលចង្អុលបង្ហាញ(ព្យាការី)។

8. អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុងផ្ទៃពោះរបស់ស្ត្រីគ្រប់រូប ហើយទ្រង់ដឹងនូវអ្វីដែលកើតមាននៅក្នុងស្បូនស្ត្រី នៃការមិនគ្រប់ខែ ឬលើសខែ។ ហើយរាល់អ្វីៗទាំងអស់ គឺត្រូវបានកំណត់យ៉ាងជាក់លាក់នៅឯទ្រង់។

9. ទ្រង់ជាអ្នកដឹងនូវប្រការអាថ៌កំបាំង និងអ្វីដែលលាតត្រដាង ជាម្ចាស់ដ៏មហាធំធេង មហាខ្ពង់ខ្ពស់បំផុត។

10. ក្នុងចំណោមពួកអ្នក មិនថាអ្នកដែលនិយាយលាក់លៀម ឬនិយាយដោយបើកចំហ មិនថាអ្នកដែលបិទបាំង (ទង្វើរបស់ខ្លួន) នៅពេលយប់ និងអ្នកដែលបង្ហាញ (នូវទង្វើរបស់ខ្លួន) នៅក្នុងពេលថ្ងៃ (ក៏ទ្រង់ដឹង) ដូចតែគ្នាដែរ។

11. សម្រាប់ទ្រង់ គឺមានម៉ាឡាអ៊ីកាត់ជាច្រើនដែលនៅផ្លាស់ប្តូរគ្នាឃ្លាំមើលមនុស្សលោកពីខាងមុខ និងពីខាងក្រោយដោយពួកគេ ថែរក្សាមនុស្សលោកទៅតាមបទបញ្ជារបស់អល់ឡោះ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មិនផ្លាស់ប្តូរអ្វីមួយចំពោះក្រុមណាមួយឡើយ លើកលែងតែពួកគេផ្លាស់ប្តូរវាដោយខ្លួនឯងប៉ុណ្ណោះ។ ហើយនៅពេលដែលអល់ឡោះទ្រង់មានបំណងចង់ឲ្យក្រុមណាមួយទទួលនូវប្រការអាក្រក់ គឺគ្មានអ្នកដែលអាចរុញច្រានវាចេញឡើយ។ ហើយសម្រាប់ពួកគេ (មនុស្សលោកទាំងឡាយ) គឺគ្មាននរណាក្រៅពីអល់ឡោះជាអ្នកគាំពារនោះឡើយ។

12. ហើយទ្រង់គឺជាអ្នកដែលធ្វើឱ្យពួកអ្នក (ឱមនុស្សលោក) ឃើញផ្លេកបន្ទោរ ដោយធ្វើឱ្យពួកអ្នកមានទាំងភាពភ័យខ្លាច និងក្តីសង្ឃឹម (ពីការមានភ្លៀងធ្លាក់)។ ហើយទ្រង់បានបង្កើតពពកយ៉ាងក្រាស់ (ពេញទៅដោយទឹកភ្លៀង)។

13. ហើយផ្គរលាន់បានលើកតម្កើង និងថ្លែងសរសើរចំពោះទ្រង់ ហើយបណ្តាម៉ាឡាអ៊ីកាត់ទាំងឡាយក៏បានលើកតម្កើងទ្រង់ ដោយការកោតខ្លាចចំពោះទ្រង់ផងដែរ។ ហើយទ្រង់បានបញ្ជូនរន្ទះជាច្រើន ដោយទ្រង់ធ្វើឲ្យទទួលរងគ្រោះដោយសារវាចំពោះជនណាដែលទ្រង់មានចេតនា។ ហើយពួកគេ (ពួកគ្មានជំនឿ) បានប្រកែកគ្នាក្នុងរឿងអល់ឡោះ ខណៈដែលទ្រង់គឺជាអ្នកជាក់ទណ្ឌកម្មយ៉ាងខ្លាំងក្លាបំផុត

14. ការបួងសួងដ៏ពិតប្រាកដ គឺសម្រាប់ទ្រង់ (តែមួយគត់)។ ហើយពួក (រូបបដិមាទាំងឡាយ) ដែលគេបួងសួងសុំក្រៅពីទ្រង់នោះ ពួកវាមិនអាចឆ្លើយតបអ្វីមួយចំពោះពួកគេឡើយ ប្រៀបដូចជាមនុស្សម្នាក់ដែលលាបាតដៃទាំងពីររបស់គេទៅរកទឹក ដើម្បីឲ្យទឹកធ្លាក់ចូលមាត់របស់គេ តែទឹកនោះ គឺមិនអាចមកដល់មាត់របស់គេបានឡើយ។ ហើយការបួងសួងរបស់ពួកគ្មានជំនឿ គឺគ្មានអ្វីក្រៅពីស្ថិតនៅក្នុងភាពវង្វេងប៉ុណ្ណោះ។

15. ហើយអ្នកដែលនៅលើមេឃជាច្រើនជាន់និងនៅលើផែនដីបានលំឱនកាយស៊ូជោតចំពោះអល់ឡោះទាំងស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត។ ហើយស្រមោលរបស់ពួកគេ (ក៏បានឱនលំទោនចំពោះទ្រង់) ទាំងនៅពេលព្រឹក និងពេលល្ងាចផងដែរ។

16. ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ តើអ្នកណាជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី? ចូរអ្នកឆ្លើយថា៖ គឺអល់ឡោះ។ ហើយចូរអ្នកពោលទៀតថា៖ ដូច្នេះ តើពួកអ្នកយកអ្នកផ្សេងក្រៅពីទ្រង់ធ្វើជាអ្នកគាំពារទាំងដែលពួកវា (អសមត្ថភាព) សូម្បីតែផ្តល់ជាប្រយោជន៍ដល់ខ្លួនឯង ឬការពារគ្រោះថ្នាក់ពីខ្លួនឯងបានផងនោះឬ? ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលទៀតថា៖ តើស្មើគ្នាដែរឬទេរវាងមនុស្សខ្វាក់ (គ្មានជំនឿ) និងអ្នកដែលមើលឃើញ (មានជំនឿ)? ឬក៏តើស្មើគ្នាដែរឬទេរវាងភាពងងឹត និងពន្លឺ? ឬមួយពួកគេបានយកព្រះនានាមកធ្វើជាដៃគូរួមជាមួយអល់ឡោះ ហើយថាពួកវាបានបង្កើតអ្វីៗដូចការបង្កើតរបស់ទ្រង់ដែរ ដោយពួកគេមានការភ័ន្តច្រឡំរវាងអ្វីដែលអល់ឡោះបង្កើត និងអ្វីដែលពួកវាបានបង្កើត? ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ អល់ឡោះ (តែមួយគត់) ជាអ្នកបង្កើតរាល់អ្វីៗទាំងអស់។ ហើយទ្រង់ជាព្រះជាម្ចាស់តែមួយគត់ ជាអ្នកមានអំណាចបំផុត។

17. ទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃ ហើយវាក៏បានហូរទៅតាមជ្រលងដងអូរអោស្រ័យទៅតាមទំហំរបស់វា ហើយវាបាននាំមកជាមួយនូវពពុះដុំៗ(លើផ្ទៃទឹក)។ ហើយសារធាតុដែលគេដុតរំលាយក្នុងភ្លើងដើម្បីចម្រាញ់ជាគ្រឿងអលង្ការ ឬសម្ភារៈប្រើប្រាស់ផ្សេងៗ ក៏មានពពុះដូចគ្នាដែរ។ ក៏ដូចគ្នាដែរ អល់ឡោះទ្រង់លើកឧទាហរណ៍(ប្រៀបធៀប)រវាងប្រការពិត និងប្រការមិនពិត។ ចំពោះពពុះ វានឹងរលាយបាត់បង់ទៅ(គ្មានផលប្រយោជន៍)។ ចំណែកឯអ្វីដែលផ្តល់ប្រយោជន៍ដល់មនុស្សវិញ វានឹងនៅបិតថេរលើផែនដី។ ក៏ដូចគ្នាដែរ អល់ឡោះទ្រង់បានលើកនូវឧទាហរណ៍ជាច្រើនទៀត។

18. សម្រាប់បណ្តាអ្នកដែលបានឆ្លើយតបចំពោះព្រះជាម្ចាស់របស់ពួកគេ គឺនឹងទទួលបាននូវប្រការល្អ(ឋានសួគ៌)។ ចំណែកឯពួកដែលមិនឆ្លើយតបចំពោះទ្រង់វិញ ប្រសិនបើពួកគេមានអ្វីៗទាំងអស់នៅលើផែនដី ថែមទាំងមានដូចនេះពីលើទៀត ពួកគេប្រាកដជានឹងយកវាទៅលោះខ្លួនពួកគេ(ពីទណ្ឌកម្ម)ជាមិនខាន។ ពួកទាំងនោះនឹងទទួលបាននូវការកាត់សេចក្តីដ៏អាក្រក់បំផុត។ ហើយកន្លែងស្នាក់នៅរបស់ពួកគេ គឺឋាននរកដើហាន់ណាំ។ ហើយវាជាកន្លែងស្នាក់នៅដ៏អាក្រក់បំផុត។

19. ដូចនេះ តើអ្នកដែលដឹងថា តាមពិតអ្វីដែលគេបានបញ្ចុះមកកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពីព្រះជាម្ចាស់របស់អ្នក គឺជាការពិតនោះ ដូចទៅនឹងអ្នកដែលពិការភ្នែក(មិនដឹងការពិត)ដែរឬទេ? តាមពិត គឺមានតែបញ្ញាជនប៉ុណ្ណោះដែលយកជាមេរៀន។

20. គឺបណ្តាអ្នកដែលអនុវត្តយ៉ាងពេញលេញនូវកិច្ចសន្យារបស់អល់ឡោះ ហើយពួកគេមិនក្បត់កិច្ចសន្យានោះឡើយ។

21. និងបណ្តាអ្នកដែលផ្សារភ្ជាប់នូវអ្វី(ចំណងសាច់សាលោហិត)ដែលអល់ឡោះប្រើឱ្យផ្សារភ្ជាប់ ហើយពួកគេខ្លាចព្រះជាម្ចាស់របស់ពួកគេ ព្រមទាំងភ័យខ្លាចចំពោះការជំនុំជម្រះដ៏អាក្រក់។

22. ហើយនិងបណ្តាអ្នកដែលអត់ធ្មត់ដោយស្វែងរកការពេញចិត្តពីព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេប្រតិបត្តិសឡាត និងបរិច្ចាគនូវអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេទាំងលាក់បាំង និងបើកចំហ ព្រមទាំងតបតចំពោះអំពើអាក្រក់(ដែលគេធ្វើមកលើខ្លួនគេ)ដោយអំពើល្អ។ បណ្តាអ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបាននូវលទ្ធផលដ៏គួរឱ្យកោតសរសើរ។

23. គឺឋានសួគ៌អាត់និនដែលពួកគេនឹងចូលក្នុងវា ព្រមទាំងអ្នកដែលធ្វើអំពើល្អក្នុងចំណោមឪពុកម្តាយរបស់ពួកគេ ភរិយារបស់ពួកគេ និងកូនចៅរបស់ពួកគេ។ ហើយម៉ាឡាអ៊ីកាត់បានចូលទៅកាន់ពួកគេពីគ្រប់ទ្វារទាំងអស់។

24. (ម៉ាឡាអ៊ីកាត់ស្វាគមន៍ពួកគេដោយពោលថា៖) សូមសន្តិភាពកើតមានដល់ពួកអ្នកដោយសារតែអ្វីដែលពួកអ្នកបានអត់ធ្មត់។ ដូច្នេះ លំនៅឋានចុងក្រោយ(របស់ពួកអ្នក)គឺល្អបំផុត។

25. ហើយចំពោះពួកដែលបានក្បត់កិច្ចសន្យារបស់អល់ឡោះក្រោយពីទ្រង់បានដាក់កិច្ចសន្យា ហើយពួកគេកាត់ផ្តាច់នូវអ្វី(ចំណងសាច់សាលោហិត)ដែលអល់ឡោះបានប្រើឱ្យផ្សារភ្ជាប់ ព្រមទាំងបង្កវិនាសកម្មនៅលើផែនដី ពួកទាំងនោះសម្រាប់ពួកគេនឹងទទួលនូវការដាក់បណ្តាសា និងទទួលនូវលទ្ធផលចុងក្រោយដ៏អាក្រក់បំផុត(ឋាននរក)។

26. អល់ឡោះជាម្ចាស់ទ្រង់បើកទូលាយនូវលាភសក្ការៈចំពោះជនណាដែលទ្រង់មានចេតនា និងរឹតត្បិត(ចំពោះជនណាដែលទ្រង់មានចេតនា)។ ហើយពួកគេ(ពួកប្រឆាំង)សប្បាយរីករាយនឹងជីវិតលោកិយ។ ហើយជីវិតលោកិយបើប្រៀបនឹងថ្ងៃបរលោកនោះ គឺគ្មានអ្វីក្រៅពីការត្រេកត្រអាល(មួយរយៈពេលខ្លី)ប៉ុណ្ណោះ។

27. ហើយពួកប្រឆាំងបាននិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះទៅឲ្យគាត់(ព្យាការីមូហាំម៉ាត់)នូវសញ្ញាកស្តុតាងមួយពីព្រះជាម្ចាស់របស់គាត់? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ធ្វើឲ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនា ហើយទ្រង់ចង្អុលបង្ហាញទៅកាន់ទ្រង់ចំពោះជនណាដែលវិលត្រឡប់(សារភាពកំហុស)ទៅកាន់ទ្រង់។

28. គឺបណ្តាអ្នកដែលមានជំនឿ ហើយចិត្តរបស់ពួកគេមានភាពនឹងនរដោយការនឹករឭកចំពោះអល់ឡោះ។ តើមិនមែនទេឬការរឭកចំពោះអល់ឡោះ គឺធ្វើឱ្យដួងចិត្តនឹងនរនោះ?

29. បណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលនោះ ពួកគេនឹងទទួលបាននូវការរស់នៅដ៏ល្អប្រសើរ(នាថ្ងៃបរលោក)និងទទួលនូវលទ្ធផលចុងក្រោយដ៏ប្រពៃបំផុត(ឋានសួគ៌)។

30. ក៏ដូច្នោះដែរ យើងបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទៅកាន់ប្រជាជាតិមួយ ដោយមានប្រជាជាតិជាច្រើនបានកន្លងផុតទៅមុនពួកគេដើម្បីឱ្យអ្នកស្បត្រឱ្យពួកគេស្តាប់នូវអ្វី(គម្ពីរគួរអាន)ដែលយើងបានផ្តល់ជាវ៉ាហ៊ីទៅកាន់អ្នក ខណៈដែលពួកគេប្រឆាំងនឹងព្រះជាម្ចាស់ដ៏មហាសប្បុរស។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ទ្រង់គឺជាព្រះជាម្ចាស់របស់ខ្ញុំដែលគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ខ្ញុំប្រគល់ការទុកចិត្តចំពោះទ្រង់(តែមួយគត់)ហើយទៅកាន់ទ្រង់ផងដែរ ការសារភាពកំហុសរបស់ខ្ញុំ។

31. ហើយប្រសិនបើគម្ពីរគួរអានអាចធ្វើឱ្យភ្នំទាំងឡាយរំកិល(ចេញពីកន្លែងរបស់វា)ឬធ្វើឱ្យផែនដីបែកខ្ញែក ឬធ្វើឱ្យមនុស្សស្លាប់អាចនិយាយបាន(នោះវានឹងក្លាយជាកស្តុតាងមួយដ៏ច្បាស់លាស់ដូចអ្វីដែលពួកគេទាមទារមិនខាន)។ ផ្ទុយទៅវិញកិច្ចការទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ដូច្នេះ តើបណ្តាអ្នកដែលមានជំនឿមិនដឹងទេឬថា ប្រសិនបើអល់ឡោះទ្រង់មានចេតនា នោះទ្រង់នឹងចង្អុលបង្ហាញមនុស្សលោកទាំងអស់ជាមិនខាន។ ហើយចំពោះពួកដែលប្រឆាំងពួកគេនៅតែបន្តទទួលរងនូវគ្រោះមហន្តរាយដោយសារតែអ្វីដែលពួកគេបានប្រព្រឹត្ត ឬក៏មហន្តរាយនោះនឹងកើតឡើងនៅជិតលំនៅឋានរបស់ពួកគេ រហូតទាល់តែកិច្ចសន្យារបស់អល់ឡោះបានមកដល់។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនក្បត់សន្យាឡើយ។

32. ជាការពិតណាស់ បណ្តាអ្នកនាំសារជាច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ក៏ត្រូវបានគេសើចចំអកចំពោះពួកគាត់ដូចគ្នាដែរ។ ហើយយើងបានពន្យារពេល(ដាក់ទណ្ឌកម្ម)ដល់ពួកប្រឆាំង។ បន្ទាប់មក យើងក៏បានដាក់ទណ្ឌកម្មពួកគេ។ ដូច្នេះ តើទណ្ឌកម្ម(របស់យើងទៅលើពួកគេនោះ)យ៉ាងដូចម្តេចដែរ?

33. ដូច្នេះ តើអ្នកដែលគ្រប់គ្រងលើរាល់បុគ្គលគ្រប់រូបនូវទង្វើដែលពួកគេប្រព្រឹត្ត(សក្តិសមត្រូវបានគោរពសក្ការៈជាង ឬក៏រូបសំណាក់ដែលអសមត្ថភាពទាំងនោះសក្តិសមជាង)? ហើយពួកគេ(ពួកប្រឆាំង)បានយកព្រះនានាមកធ្វើជាដៃគូជាមួយនឹងអល់ឡោះជាម្ចាស់។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នករៀបរាប់ឈ្មោះពួកវាមក។ ឬមួយពួកអ្នកប្រាប់ដល់ទ្រង់នូវអ្វីដែលទ្រង់មិនបានដឹង នៅលើផែនដីនេះ ឬមួយក៏អ្វីដែលពួកអ្នកប្រាប់ទ្រង់គ្រាន់តែជាសម្តីដែលគ្មានការពិតឬ? ផ្ទុយទៅវិញ គេ(ស្ងែតន)បានតុបតែងលម្អសម្រាប់ពួកប្រឆាំងនូវឧបាយកលរបស់ពួកគេ ហើយបានរារាំងពួកគេពីមាគ៌ាត្រឹមត្រូវ។ ហើយជនណាដែលអល់ឡោះធ្វើឲ្យវង្វេងហើយនោះ គឺរូបគេគ្មានអ្នកចង្អុលបង្ហាញឡើយ។

34. ពួកគេនឹងទទួលនូវទណ្ឌកម្មនៅក្នុងលោកិយនេះ។ ហើយទណ្ឌកម្មនៅថ្ងៃបរលោកគឺធ្ងន់ធ្ងរជាងនេះទៅទៀត។ ហើយពួកគេគ្មានអ្នកការពារពី(ទណ្ឌកម្ម)អល់ឡោះឡើយ។

35. លក្ខណៈនៃឋានសួគ៌ដែលគេ(អល់ឡោះ)បានសន្យាចំពោះបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)នោះ គឺមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ផលានុផលរបស់វា និងម្លប់របស់វា គឺមានជានិរន្តន៍។ នោះហើយជាលទ្ធផលចុងក្រោយរបស់បណ្តាអ្នកដែលកោតខ្លាច។ រីឯលទ្ធផលចុងក្រោយរបស់ពួកប្រឆាំងវិញ គឺឋាននរក។

36. ហើយបណ្តាអ្នកដែលយើងបានប្រទានឱ្យពួកគេនូវគម្ពីរ(ពួកយូដា និងពួកគ្រីស្ទាន) ពួកគេមានភាពរីករាយចំពោះអ្វីដែលគេបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ហើយក្នុងចំណោមក្រុមជាច្រើន(នៃពួកគេ) ក៏មានអ្នកដែលបដិសេធនូវប្រការមួយចំនួនអំពីវាផងដែរ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត គេបានប្រើខ្ញុំឱ្យគោរពសក្ការៈចំពោះអល់ឡោះ(តែមួយគត់) ហើយមិនឱ្យខ្ញុំយកអ្នកផ្សេងមកធ្វើជាដៃគូរួមនឹងទ្រង់ឡើយ។ ខ្ញុំបួងសួងទៅកាន់ទ្រង់(តែមួយគត់) ហើយកន្លែងវិលត្រឡប់របស់ខ្ញុំ ក៏ទៅកាន់ទ្រង់(តែមួយគត់)ដែរ។

37. ក៏ដូច្នោះដែរ យើងបានបញ្ចុះវា(គម្ពីរគួរអាន)ជាក្បួនច្បាប់ និងជាភាសាអារ៉ាប់។ តែប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដើរតាមទំនើងចិត្តរបស់ពួកគេ(ពួកអះលីគីតាប) ក្រោយពីចំណេះដឹងបានមកដល់អ្នកហើយនោះ សម្រាប់រូបអ្នក គឺគ្មានអ្នកគាំពារ(ជួយឱ្យយកឈ្នះលើសត្រូវ) និងអ្នកការពារពី(ទណ្ឌកម្ម)អល់ឡោះឡើយ។

38. ហើយជាការពិតណាស់ យើងបានបញ្ជូនអ្នកនាំសារជាច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ហើយយើងបានរៀបចំឱ្យពួកគេមានភរិយា និងកូនចៅ។ ហើយគ្មានអ្នកនាំសារណាម្នាក់អាចនាំមកនូវសញ្ញាកស្តតាងណាមួយនោះឡើយលើកលែងតែដោយការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ។ រាល់កិច្ចការទាំងអស់ គឺត្រូវបានកំណត់រួចជាស្រេចនៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)។

39. អល់ឡោះទ្រង់លុបបំបាត់នូវអ្វីដែលទ្រង់មានចេតនា ហើយទ្រង់រក្សាទុក(នូវអ្វីដែលទ្រង់មានចេតនា)។ ហើយសៀវភៅកំណត់ត្រាគោល(ឡាវហ៊ុលម៉ះហ្វូស)គឺនៅនឹងទ្រង់។

40. បើទោះបីជាយើងបង្ហាញឱ្យអ្នក(ឱព្យាការីមូហាំម៉ាត់)បានឃើញនូវទណ្ឌកម្មមួយចំនួនដែលយើងបានសន្យានឹងពួកគេឬក៏យើងឱ្យអ្នកស្លាប់(មុនបានឃើញវា)ក៏ដោយ ក៏តួនាទីរបស់អ្នក គ្រាន់តែផ្សព្វផ្សាយ(សារ)ប៉ុណ្ណោះ។ ចំណែកឯការកាត់សេចក្តី គឺជាតួនាទីរបស់យើង។

41. តើពួកគេ(ពួកប្រឆាំង)មិនឃើញទេឬថា ជាការពិតណាស់ យើងបានរំដោះយកទឹកដីរបស់ពួកគេដោយយើងបានកាត់បន្ថយវាបន្តិចម្តងៗនៅគ្រប់ទិសទីទាំងអស់។ ហើយអល់ឡោះទ្រង់ជាអ្នកកាត់សេចក្តី ដោយគ្មានអ្នកណាម្នាក់ដែលអាចពិនិត្យវិនិច្ឆ័យលើការកាត់សេចក្តីរបស់ទ្រង់ឡើយ។ ហើយទ្រង់ជាអ្នកដែលជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

42. ហើយជាការពិតណាស់ ពួកជំនាន់មុនពួកគេក៏បានប្រើឧបាយកល(ប្រឆាំងនឹងបណ្តាព្យាការីរបស់ពួកគេ)ដែរ។ ក៏ប៉ុន្តែគម្រោងការទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ទ្រង់ដឹងទាំងអស់នូវអ្វីដែលបុគ្គលគ្រប់រូបបានប្រព្រឹត្ត។ ហើយពួកប្រឆាំងនឹងដឹងថា តើលទ្ធផលចុងក្រោយដ៏ប្រសើរបំផុតនោះ គឺសម្រាប់អ្នកណា?

43. ហើយពួកប្រឆាំងបាននិយាយថា៖ រូបអ្នក(ព្យាការីមូហាំម៉ាត់)មិនមែនជាអ្នកនាំសារឡើយ។ ចូរអ្នកតបថា៖ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាសាក្សីរវាងខ្ញុំនិងពួកអ្នក ហើយ(ក៏គ្រប់គ្រាន់ដែរ)ដែលមានអ្នកដែលមានចំណេះដឹងខាងគម្ពីរ(ធ្វើជាសាក្សី)នោះ។

ជំពូក អ៊ីព្រហ៊ីម

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាមរ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ គម្ពីរ(គួរអាន)ដែលយើងបានបញ្ចុះវាទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)គឺដើម្បីឱ្យអ្នកនាំមនុស្សលោកចេញពីភាពងងឹត(គ្មានជំនឿ)ទៅកាន់ពន្លឺ(ការមានជំនឿ)តាមការអនុញ្ញាតពីព្រះជាម្ចាស់របស់ពួកគេទៅកាន់មាគ៌ារបស់អ្នកដ៏មហាខ្លាំងពូកែ ជាអ្នកដែលគេកោតសរសើរ។

2. អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងអ្វីៗដែលមាននៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយភាពអន្តរាយនៃទណ្ឌកម្មដ៏ធ្ងន់ធ្ងរ គឺសម្រាប់ពួកដែលគ្មានជំនឿ។

3. គឺពួកដែលស្រឡាញ់ពេញចិត្តឆាកជីវិតលោកិយជាងថ្ងៃបរលោក ហើយពួកគេរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះ ព្រមទាំងមានបំណងចង់ឱ្យមាគ៌ានោះមានភាពវៀចវេរ។ ពួកទាំងនោះ គឺស្ថិតនៅក្នុងភាពវង្វេងដ៏សែនឆ្ងាយ។

4. ហើយរាល់អ្នកនាំសារដែលយើងបានបញ្ជូនទៅ គឺសុទ្ធតែជាអ្នកនិយាយភាសានៃក្រុមរបស់គេ ដើម្បីបកស្រាយបញ្ជាក់ដល់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ធ្វើឱ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនា និងចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ហើយទ្រង់គឺជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

5. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនព្យាការីមូសាដោយនាំមកនូវសញ្ញាកស្តុតាងជាច្រើនរបស់យើង។ (យើងបានដាក់បទបញ្ជាដល់គេថា៖) ចូរអ្នកនាំក្រុមរបស់អ្នកចេញពីភាពងងឹត(វង្វេង)ទៅកាន់ពន្លឺ(ការចង្អុលបង្ហាញ)និងត្រូវរំឭកពួកគេពីបណ្តាថ្ងៃរបស់អល់ឡោះ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់គ្រប់បុគ្គលដែលជាអ្នកអត់ធ្មត់និងដឹងគុណ។

6. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្យាការីមូសាបាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់អល់ឡោះដែលបានប្រទានដល់ពួកអ្នក ខណៈដែលទ្រង់បានសង្គ្រោះពួកអ្នកពីបក្សពួកហ្វៀរអោនដែលពួកគេបានឱ្យពួកអ្នកភ្លក់នូវទារុណកម្មដ៏ព្រៃផ្សៃបំផុត។ ហើយពួកគេបានសម្លាប់កូនប្រុសទាំងឡាយរបស់ពួកអ្នក និងទុកជីវិតកូនស្រីទាំងឡាយរបស់ពួកអ្នក។ នៅក្នុងរឿងនោះ គឺជាការសាកល្បងដ៏ធំធេងបំផុតពីព្រះជាម្ចាស់របស់ពួកអ្នក។

7. (គាត់បានបន្តទៀតថា៖) ចូរពួកអ្នកចងចាំ នៅពេលដែលព្រះជាម្ចាស់របស់ពួកអ្នកបានប្រកាសថា៖ ប្រសិនបើពួកអ្នកដឹងគុណ យើងពិតជានឹងបន្ថែម(ការប្រោសប្រទាន)ដល់ពួកអ្នកទៀត។ តែប្រសិនបើពួកអ្នកប្រឆាំង(រមិលគុណ)វិញ ពិតប្រាកដណាស់ ទណ្ឌកម្មរបស់យើង គឺធ្ងន់ធ្ងរបំផុត។

8. ហើយព្យាការីមូសាបាននិយាយថា៖ ប្រសិនបើពួកអ្នក រួមទាំងអ្នកដែលនៅលើផែនដីទាំងអស់ប្រឆាំង(នឹងអល់ឡោះ ក៏គ្មានផ្តល់គ្រោះថ្នាក់អ្វីដល់ទ្រង់នោះដែរ)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់ ជាអ្នកដែលគេកោតសរសើរបំផុត។

9. តើរឿងរ៉ាវរបស់អ្នកជំនាន់មុនពួកអ្នក(ពួកគ្មានជំនឿ)មិនបានមកដល់ពួកអ្នកទេឬ ដូចជាក្រុមរបស់ព្យាការីនួហ ក្រុមអាទ ក្រុមសាមូទ ព្រមទាំងក្រុមជាច្រើនទៀតបន្ទាប់ពីពួកគេ ដែលគ្មាននរណាម្នាក់ដឹងពី(ចំនួនរបស់)ពួកគេក្រៅពីអល់ឡោះនោះ? បណ្តាអ្នកនាំសាររបស់ពួកគេបាននាំមកនូវសេចក្តីសុគតាងយ៉ាងច្បាស់លាស់ជាច្រើនមកកាន់ពួកគេ តែពួកគេបានយកដៃរបស់ពួកគេដាក់ក្នុងមាត់(ដោយកំហឹង) ហើយពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងមិនមានជំនឿចំពោះអ្វីដែលគេបានបញ្ជូនវាមកជាមួយពួកអ្នកឡើយ ហើយពិតណាស់ ពួកយើងមានការសង្ស័យយ៉ាងខ្លាំងចំពោះអ្វីដែលពួកអ្នកកំពុងតែអំពាវនាវពួកយើងទៅកាន់វានោះ។

10. បណ្តាអ្នកនាំសាររបស់ពួកគេបានតបថា៖ តើ(ពួកអ្នក)មានការសង្ស័យចំពោះអល់ឡោះឬ ខណៈដែលទ្រង់គឺជាអ្នកដែលបង្កើតមេឃជាច្រើនជាន់និងផែនដីនោះ? ទ្រង់អំពាវនាវពួកអ្នក(ទៅកាន់ការមានជំនឿចំពោះទ្រង់) ដើម្បីទ្រង់អភ័យទោសដល់ពួកអ្នកចំពោះបាបកម្មទាំងឡាយរបស់ពួកអ្នក ហើយទ្រង់នឹងពន្យារពេលដល់ពួកអ្នករហូតដល់ពេលវេលាកំណត់។ ពួកគេបានតបវិញថា៖ ពួកអ្នកគ្រាន់តែជាមនុស្សលោកធម្មតាដូចពួកយើងប៉ុណ្ណោះ។ ពួកអ្នកមានបំណងចង់រារាំងពួកយើងពីអ្វីដែលដីជូនដីតារបស់ពួកយើងធ្លាប់បានគោរពសក្ការៈ។ ហេតុនេះ ចូរពួកអ្នកនាំមកឱ្យពួកយើងនូវសេចក្តីសុគតាងដ៏ច្បាស់លាស់មួយមក។

11. បណ្តាអ្នកនាំសាររបស់ពួកគេបានតបទៅកាន់ពួកគេវិញថា៖ ពិតមែនហើយ ពួកយើងគ្រាន់តែជាមនុស្សលោកធម្មតាដូចពួកអ្នកដែរ ក៏ប៉ុន្តែអល់ឡោះទ្រង់លើកតម្កើងចំពោះជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់។ ហើយពួកយើងមិនអាចនាំមកនូវសេចក្តីសុគតាងណាមួយមកកាន់ពួកអ្នកឡើយ លើកលែងតែដោយការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ។ ហើយចំពោះអល់ឡោះ(តែមួយគត់)ដែលបណ្តាអ្នកមានជំនឿទាំងឡាយប្រគល់ការទុកចិត្ត។

12. តើមានអ្វីដែលរារាំងពួកយើងមិនឱ្យប្រគល់ការទុកចិត្តទៅចំពោះទ្រង់ ខណៈដែលទ្រង់បានចង្អុលបង្ហាញពួកយើងនូវមាគ៌ាដ៏ត្រឹមត្រូវនិងច្បាស់លាស់នោះ? ហើយពួកយើងត្រូវតែអត់ធ្មត់ចំពោះអ្វីដែលពួកអ្នកធ្វើទុក្ខបុកម្នេញមកលើពួកយើង។ ហើយចំពោះអល់ឡោះ(តែមួយគត់)ដែលបណ្តាអ្នកដែលប្រគល់ការទុកចិត្តទាំងឡាយប្រគល់ការទុកចិត្ត(លើទ្រង់)។

13. ហើយពួកដែលប្រឆាំងបាននិយាយទៅកាន់បណ្តាអ្នកនាំសាររបស់ពួកគេថា៖ យើងពិតជានឹងបណ្តេញពួកអ្នកចេញពីភូមិស្រុករបស់ពួកយើង ឬពួកអ្នកត្រូវតែវិលត្រឡប់មកកាន់សាសនារបស់ពួកយើងវិញ។ ពេលនោះ ព្រះជាម្ចាស់របស់អ្នកនាំសារទាំងនោះបានផ្តល់វាហ៊ីទៅកាន់ពួកគេថា៖ យើងពិតជានឹងបំផ្លាញពួកដែលបំពានជាមិនខាន។

14. ហើយយើងនឹងឱ្យពួកអ្នករស់នៅលើទឹកដីនេះបន្ទាប់ពី(ការបំផ្លាញ)ពួកគេ។ នោះគឺសម្រាប់អ្នកដែលខ្លាចនូវភាពធំធេងរបស់យើង និងខ្លាចការព្រមាន(ពីទណ្ឌកម្មរបស់យើង)។

15. ហើយពួកគេ(អ្នកនាំសារ)ក៏បានបួងសួងសុំឱ្យទ្រង់ជួយពួកគេឱ្យមានជ័យជម្នះលើសត្រូវ។ ហើយភាពអន្តរាយ គឺសម្រាប់រាល់បុគ្គលដែលក្បែងក្បាង ចចេសរឹងរូស។

16. នៅខាងមុខរូបគេ គឺនរកដើហាន់ណាំ។ នៅក្នុងនោះ គេនឹងឱ្យជននោះផឹកនូវទឹកខ្ទុះឈាម។

17. រូបគេទ្រាំផឹកវាទាំងលំបាកវេទនាស្ទើរតែមិនអាចលេបចូល។ ហើយសេចក្តីស្លាប់មកដល់រូបគេពីគ្រប់ទិសទីទាំងអស់ ក៏ប៉ុន្តែរូបគេមិនស្លាប់នោះឡើយ។ ហើយនៅខាងមុខជននោះ គឺមានទណ្ឌកម្មដ៏សែនខ្លោចផ្សា(ជាច្រើនផ្សេងទៀត)។

18. ការប្រៀបធៀបពួកដែលគ្មានជំនឿចំពោះព្រះជាម្ចាស់របស់ពួកគេ ទង្វើរបស់ពួកគេប្រៀបដូចជាធូលីដែលត្រូវបានខ្យល់បោកបក់យ៉ាងខ្លាំងនៅថ្ងៃដែលមានព្យុះសង្ឃរាបោកបក់។ ពួកគេមិនទទួលបានផលប្រយោជន៍ពីអ្វីដែលពួកគេបានសាងបន្តិចណាឡើយ។ នោះហើយគឺជាការវង្វេងដ៏សែនឆ្ងាយ។

19. តើពួកអ្នក(ឱមនុស្សលោកទាំងឡាយ)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបង្កើតមេឃជាច្រើនជាន់និងបានបង្កើតផែនដីយ៉ាងពិតប្រាកដនោះ? ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងបំផ្លាញពួកអ្នក ហើយទ្រង់នឹងនាំមកនូវអ្នកថ្មីផ្សេងទៀត(ជំនួសពួកអ្នក)ជាមិនខាន។

20. ហើយនោះមិនមែនជារឿងដែលធ្ងន់ធ្ងរ(ពិបាក)សម្រាប់អល់ឡោះនោះឡើយ។

21. ហើយពួកគេនឹងចេញពីផ្នូរទាំងអស់គ្នាឆ្ពោះទៅកាន់អល់ឡោះជាម្ចាស់(នាថ្ងៃបរលោក)។ ហើយពួកទន់ខ្សោយ(អ្នកដើរតាមគេ)បាននិយាយទៅកាន់ពួកមេដឹកនាំ(របស់ខ្លួន)ថា៖ ពិតប្រាកដណាស់ ពួកយើងធ្លាប់បានដើរតាមពួកអ្នក។ ដូច្នេះ តើពួកអ្នកអាចការពារពួកយើងពីទណ្ឌកម្មរបស់អល់ឡោះបន្តិចណាដែរឬទេ? ពួកគេបានតបវិញថា៖ ប្រសិនបើអល់ឡោះចង្អុលបង្ហាញពួកយើងនោះ ពួកយើងក៏នឹងចង្អុលបង្ហាញដល់ពួកអ្នកដែរ។ វាដូចតែគ្នាទេចំពោះពួកយើង ទោះជាពួកយើងត្អូញត្អែរ ឬពួកយើងទ្រាំអត់ធ្មត់ក៏ដោយ ក៏ពួកយើងគ្មានកន្លែងដែលអាចគេចពីទណ្ឌកម្ម)នោះដែរ។

22. នៅពេលដែលកិច្ចការទាំងអស់បានសម្រេចហើយនោះ ស្តេចនបាននិយាយថា៖ ជាការពិតណាស់ អល់ឡោះបានសន្យានឹងពួកអ្នកនូវការសន្យាមួយដែលពិតប្រាកដ។ ហើយខ្ញុំក៏បានសន្យានឹងពួកអ្នកដែរ តែខ្ញុំបានក្បត់សន្យាជាមួយពួកអ្នក។ ខ្ញុំគ្មានអំណាចអ្វីលើពួកអ្នក(ដែលអាចឲ្យពួកអ្នកដើរតាម)នោះឡើយ ក្រៅតែពីខ្ញុំគ្រាន់តែអំពាវនាវពួកអ្នកប៉ុណ្ណោះ ហើយពួកអ្នកក៏បានតាមខ្ញុំ។ ហេតុនេះ ចូរពួកអ្នកកុំបន្ទោសខ្ញុំឱ្យសោះ តែពួកអ្នកត្រូវបន្ទោសខ្លួនឯងវិញ។ ខ្ញុំមិនមែនជាអ្នកដែលអាចជួយការពារពួកអ្នក(ពីទណ្ឌកម្ម)នោះឡើយ ហើយពួកអ្នកក៏មិនមែនជាអ្នកដែលអាចជួយការពារខ្ញុំបាននោះដែរ។ ខ្ញុំសូមបដិសេធចំពោះការដែលពួកអ្នកយកខ្ញុំធ្វើជាដៃគូរួមជាមួយអល់ឡោះកាលពីមុន(ក្នុងលោកិយ)។ ពិតប្រាកដណាស់ ពួកដែលបំពាន សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

23. ហើយគេនឹងបញ្ចូលបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពួកគេស្ថិតនៅទីនោះជាអមតៈដោយការអនុញ្ញាតពីព្រះជាម្ចាស់របស់ពួកគេ។ ការស្វាគមន៍របស់ពួកគេនៅក្នុងនោះ គឺសាឡាម(សន្តិភាព)។

24. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា តើអល់ឡោះទ្រង់លើកឧទាហរណ៍ប្រៀបធៀបយ៉ាងដូចម្តេចចំពោះពាក្យសម្តីដែលល្អ(កាលីម៉ៈតាវហេទ)ដូចទៅនឹងដើមឈើដ៏ល្អមួយដើម(ដើមល្មើ)ដែលឫសរបស់វាចាក់ចូល(ក្នុងដី)យ៉ាងរឹងមាំ ហើយមែកធាងរបស់វាចាក់ឆ្ពោះទៅលើមេឃនោះ?

25. វាផ្តល់នូវផែលានុផលរបស់វាគ្រប់ពេលវេលាដោយការអនុញ្ញាតពីព្រះជាម្ចាស់របស់វា។ ហើយអល់ឡោះទ្រង់លើកយកឧទាហរណ៍ជាច្រើនសម្រាប់មនុស្សលោក សង្ឃឹមថាពួកគេនឹករលឹក។

26. ហើយការប្រៀបធៀបពាក្យសម្តីដែលអាក្រក់(ពាក្យស្តីរិក)គឺប្រៀបដូចជាដើមឈើដែលអាក្រក់មួយដើម(ដើមហាន់ហ្សល់)ដែលគេអាចដកទាំងឫសបានដោយវាគ្មានភាពរឹងមាំ(ជាប់ទៅនឹងដី)ឡើយ។

27. អល់ឡោះជាម្ចាស់ទ្រង់ពង្រឹងដល់បណ្តាអ្នកដែលមានជំនឿនឹងពាក្យសម្តីដែលរឹងមាំ(កាលីម៉ៈស្ហាហ្ស៊ៈ)ទាំងនៅក្នុងជីវិតលោកិយ និងនៅថ្ងៃបរលោក។ ហើយអល់ឡោះជាម្ចាស់នឹងធ្វើឱ្យពួកដែលបំពានវង្វេង។ ហើយអល់ឡោះទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។

28. តើអ្នកមិនបានឃើញទេ ពួកដែលជ្រើសយកកាពគ្មានជំនឿជំនួសឲ្យការដឹងគុណចំពោះឧបការគុណរបស់អល់ឡោះ ហើយពួកគេធ្វើឱ្យក្រុមរបស់ពួកគេធ្លាក់ទៅក្នុងកន្លែងដែលវិនាសអន្តរាយ។

29. នោះគឺនរកដើហាន់ណាំដែលពួកគេនឹងចូលទៅក្នុងវា ហើយវាជាកន្លែងស្នាក់នៅដ៏អាក្រក់បំផុតនោះ។

30. ហើយពួកគេ(ពួកមុស្លីគីន)បានយកព្រះនានាមកធ្វើជាដៃគូរួមជាមួយនឹងអល់ឡោះដើម្បីធ្វើឱ្យអ្នកដទៃវង្វេងចេញពីមាគ៌ារបស់ទ្រង់។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកត្រេកត្រអាលសិនចុះ។ ពិតប្រាកដណាស់ កន្លែងវិលត្រឡប់របស់ពួកអ្នក គឺឆ្ពោះទៅកាន់ឋាននរក។

31. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ខ្ញុំបម្រើរបស់យើងដែលជាអ្នកមានជំនឿឲ្យពួកគេប្រតិបត្តិសឡាត និងបរិច្ចាគអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេទាំងលាក់បាំង និងលាតត្រដាងមុននឹងថ្ងៃមួយ(ថ្ងៃបរលោក)បានមកដល់ដែលគ្មានទេការលក់ដូរ ហើយក៏គ្មានដៃរចំណងមិត្តភាព(ក្នុងថ្ងៃនោះ)។

32. អល់ឡោះជាម្ចាស់ទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដី។ ហើយទ្រង់បានបញ្ចុះពីលើមេឃនូវទឹកភ្លៀង ដោយតាមរយៈទឹកភ្លៀងនោះ ទ្រង់បានបញ្ចេញនូវផលានុផលជាច្រើនប្រភេទជាលាភសក្ការៈសម្រាប់ពួកអ្នក(មនុស្សលោក)។ ហើយទ្រង់បានបង្កើតឱ្យមានសំពៅសម្រាប់ពួកអ្នកដែលធ្វើដំណើរនៅលើផ្ទៃសមុទ្រទៅតាមបទបញ្ជារបស់ទ្រង់។ ហើយបានបង្កើតទន្លេជាច្រើនសម្រាប់ពួកអ្នកផងដែរ។

33. ហើយទ្រង់បានបង្កើតព្រះអាទិត្យនិងព្រះចន្ទសម្រាប់ពួកអ្នកដែលវាទាំងពីរធ្វើចលនាតាមគន្លងរបស់វា ព្រមទាំងបានបង្កើតសម្រាប់ពួកអ្នកផងដែរនូវពេលយប់ និងពេលថ្ងៃ។

34. ហើយទ្រង់បានផ្តល់ឱ្យពួកអ្នកនូវគ្រប់អ្វីៗដែលពួកអ្នកសុំពីទ្រង់។ ហើយប្រសិនបើពួកអ្នករាប់នូវឧបការគុណរបស់អល់ឡោះនោះ គឺពួកអ្នកមិនអាចរាប់វាអស់ឡើយ។ ពិតប្រាកដណាស់ មនុស្សលោក គឺជាអ្នកដែលបំពាន រមិលគុណបំផុត ។

35. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្យាការីអ៊ីព្រហ៊ីមបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាធ្វើឱ្យទឹកដីនេះ(ក្រុងម៉ាក្កៈ)មានសុខសុវត្ថិភាពផងចុះ ហើយសូមព្រះអង្គមេត្តាបញ្ចៀសរូបខ្ញុំ និងកូនចៅរបស់ខ្ញុំពីការគោរពសក្ការៈរូបបដិមានានាផង។

36. បពិត្រព្រះជាម្ចាស់! ជាការពិតណាស់ ពួកវា(រូបបដិមាទាំងនេះ)បានធ្វើឱ្យមនុស្សជាច្រើនវង្វេង។ ហេតុនេះ ជនណាហើយដែលដើរតាមខ្ញុំ ពិតប្រាកដណាស់ រូបគេគឺស្ថិតក្នុងក្រុមរបស់ខ្ញុំ។ រីឯជនណាហើយដែលប្រឆាំងនឹងខ្ញុំ ជាការពិតណាស់ ព្រះអង្គមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

37. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ជាការពិតណាស់ ខ្ញុំបានទុកកូនចៅរបស់ខ្ញុំមួយចំនួនឱ្យរស់នៅឯជ្រលងភ្នំមួយ(ទឹកដីម៉ាក្កៈ)ដែលគ្មានដំណាំអ្វីនៅក្នុងវាឡើយ គឺនៅឯគេហដ្ឋានរបស់ព្រះអង្គដ៏ពិសិដ្ឋ(ពៃតុលឡោះ)។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! (ខ្ញុំទុកពួកគេនៅទីនោះ)គឺដើម្បីឱ្យពួកគេប្រតិបត្តិសឡាត។ ហេតុនេះ សូមព្រះអង្គមេត្តាធ្វើឱ្យដួងចិត្តមនុស្សមួយចំនួនស្រឡាញ់ពេញចិត្តទៅកាន់ពួកគេ ព្រមទាំងប្រទាននូវលាភសក្ការៈដល់ពួកគេអំពីផលានុផលនានាផង សង្ឃឹមថា ពួកគេនឹងថ្លែងអំណរគុណ។

38. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ព្រះអង្គដឹងបំផុតទាំងអ្វីដែលពួកយើងលាក់បាំង ទាំងអ្វីដែលពួកយើងលាតត្រដាង ហើយគ្មានអ្វីមួយអាចលាក់បាំងពីអល់ឡោះបានឡើយ មិនថានៅលើផែនដី មិនថានៅលើមេឃនោះឡើយ។

39. ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលទ្រង់បានប្រទានឲ្យខ្ញុំនូវអ៊ីស្មាអែល និងអ៊ីស្ហាកទាំងដែលខ្ញុំមានវ័យចំណាស់ទៅហើយនោះ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំមហាឮបំផុតនូវការបួងសួង។

40. បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាធ្វើឱ្យរូបខ្ញុំ និងកូនចៅរបស់ខ្ញុំជាអ្នកដែលប្រតិបត្តិសឡាតយ៉ាងខ្ជាប់ខ្ជួនផង។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាទទួលយកនូវការបួងសួង(របស់ខ្ញុំ)ផងចុះ។

41. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាអភ័យទោសដល់រូបខ្ញុំ និងឪពុកម្តាយរបស់ខ្ញុំ ព្រមទាំងបណ្តាអ្នកមានជំនឿទាំងឡាយនៅថ្ងៃជំនុំជម្រះផងចុះ។

42. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំគិតស្មានថា អល់ឡោះទ្រង់ព្រងើយកន្តើយចំពោះអ្វីដែលពួកបំពានបានប្រព្រឹត្តឱ្យសោះ។ តាមពិត គេគ្រាន់តែពន្យារពេលដល់ពួកគេរហូតដល់ថ្ងៃមួយ(ថ្ងៃបរលោក)ដែលភ្នែកទាំងឡាយសម្លឹងមើលដោយភ័យរន្ធត់។

43. ពួកគេក្រោកចេញពីផ្នូររបស់ពួកគេទាំងប្រញាប់ប្រញាល់ដោយងើយក្បាលរបស់ពួកគេ ដោយមិនទម្លាក់ក្រសែភ្នែកឡើយ។ ចំណែកឯចិត្តរបស់ពួកគេវិញ គឺទទេស្អាត។

44. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដាស់តឿនព្រមានមនុស្សលោកពីថ្ងៃមួយដែលទណ្ឌកម្មនឹងមកដល់ពួកគេ។ ពេលនោះ ពួកដែលបំពាននឹងនិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាពន្យារពេលដល់យើងខ្ញុំនូវរយៈពេលដ៏ខ្លីមួយផងចុះ នោះពួកយើងនឹងឆ្លើយតបចំពោះការអំពាវនាវរបស់ព្រះអង្គ ហើយពួកយើងនឹងដើរតាមបណ្តាអ្នកនាំសារទាំងឡាយជាមិនខាន។ (ទ្រង់បានតបថា៖) តើពួកអ្នកមិនធ្លាប់បានស្បថស្បែកាលពីមុន(លើលោកិយ)ទេឬដែលថាពួកអ្នកនឹងមិនមានការផ្លាស់ប្តូរ(ពីជីវិតលោកិយទៅកាន់ជីវិតបរលោក)នោះ?

45. ហើយពួកអ្នកបានមកស្នាក់នៅក្នុងលំនៅឋានរបស់ពួកដែលបំពានលើខ្លួនឯង។ ហើយវាបានបញ្ជាក់យ៉ាងច្បាស់ហើយដល់ពួកអ្នក ថាតើយើងបានធ្វើបែបណាចំពោះពួកគេ។ ហើយយើងបានលើកជាឧទហរណ៍ជាច្រើនសម្រាប់ពួកអ្នក។

46. ហើយជាការពិតណាស់ ពួកគេបានរៀបចំនូវឧបាយកលរបស់ពួកគេ(ដើម្បីសម្លាប់ព្យាការីមូហាំម៉ាត់) តែឧបាយកលរបស់ពួកគេ គឺនៅនឹងទ្រង់(ទ្រង់ដឹងអំពីវា)។ ហើយឧបាយកលរបស់ពួកគេ មិនអាចធ្វើឱ្យភ្នំទាំងឡាយរលត់រលាយឡើយ។

47. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំគិតស្មានថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ក្បត់កិច្ចសន្យាជាមួយនឹងបណ្តាអ្នកនាំសាររបស់ទ្រង់ឱ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ ជាអ្នកដែលមានអានុភាពក្នុងការផ្តន្ទាទោស។

48. នៅថ្ងៃដែលគេផ្លាស់ប្តូរផែនដីនេះទៅជាផែនដីផ្សេង ហើយមេឃជាច្រើនជាន់វិញ(ក៏ដូចគ្នាដែរ)។ ហើយពួកគេបានក្រោកចេញពីផ្នូរទៅកាន់អល់ឡោះជាម្ចាស់តែមួយគត់ដែលមានអំណាចខ្លាំងពូកែបំផុត។

49. ហើយនៅថ្ងៃនោះ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងឃើញពួកដែលប្រព្រឹត្តល្មើសត្រូវបានគេចងដៃចងជើងភ្ជាប់ច្រវាក់។

50. សម្លៀកបំពាក់របស់ពួកគេធ្វើអំពីជ័រ(ងាយឆេះ) ហើយភ្លើងនរកនឹងគ្របដណ្តប់ពេញផ្ទៃមុខរបស់ពួកគេ។

51. ដើម្បីអល់ឡោះនឹងតបស្នងដល់បុគ្គលគ្រប់រូបចំពោះអ្វីដែលពួកគេបានប្រព្រឹត្ត។ ពិតប្រាកដណាស់ អល់ឡោះជាអ្នកជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

52. (គម្ពីរគួរអាន)នេះ គឺជាការប្រកាសមួយ(ពីអល់ឡោះ)ដល់មនុស្សលោក និងដើម្បីដាស់តឿនព្រមានពួកគេតាមរយៈវា ហើយនិងដើម្បីឱ្យពួកគេដឹងថា៖ តាមពិត ទ្រង់គឺជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈតែមួយគត់ ព្រមទាំងដើម្បីឱ្យបញ្ញាជនទាំងឡាយនឹករលឹក។

ជំពូក អាល់ហ៊ិជ្រ៍

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាមរ៉ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន (ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ ទាំងនេះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ និងជាវាក្យខណ្ឌនៃគម្ពីរគួរអានដ៏ច្បាស់លាស់។

2. (នៅថ្ងៃបរលោក) ពួកដែលគ្មានជំនឿមានក្តីស្រមៃថា ប្រសិនបើពួកគេជាអ្នកមូស្លីម (នោះពួកគេនឹងអាចមានឱកាសចេញពីឋាននរកវិញបាន)។

3. ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) បណ្តោយឱ្យពួកគេទទួលទាន និងត្រេកត្រអាល (នឹងជីវិតលោកិយ) ព្រមទាំងឱ្យការស្រមើស្រមៃនោះធ្វើឱ្យពួកគេងប់ងល់ចុះ។ ពិតប្រាកដណាស់ ពួកគេគង់តែនឹងដឹង។

4. ហើយយើងមិនបានបំផ្លាញភូមិស្រុកណាមួយឡើយ លើកលែងតែវាមានការកំណត់ពេលវេលាយ៉ាងច្បាស់លាស់។

5. វាមិនអាចមកដល់ប្រជាជាតិណាមួយមុនពេលកំណត់របស់វានោះឡើយ ហើយវាក៏មិនអាចមកយឺតជាងពេលកំណត់នោះដែរ។

6. ហើយពួកគេ (ពួកគ្មានជំនឿនៃអ្នកស្រុកម៉ាក្កៈ) បាននិយាយថា៖ ឱអ្នកដែលត្រូវបានគេបញ្ចុះគម្ពីរគួរអានមក! ពិតប្រាកដណាស់ អ្នកជាមនុស្សវិកលចរិត។

7. ហេតុអ្វីបានជាអ្នកមិននាំម៉ាឡាអ៊ីកាត់មកកាន់ពួកយើង ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់មែននោះ?

8. (អល់ឡោះបានតបថា៖) យើងមិនបញ្ចុះម៉ាឡាអ៊ីកាត់នោះទេ លើកលែងតែមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ។ ហើយពួកគេក៏មិនមែនជាអ្នកដែលត្រូវបានគេពន្យារពេលនោះដែរ (ពេលដែលទណ្ឌកម្មមកដល់នោះ)។

9. ពិតប្រាកដណាស់ យើងជាអ្នកដែលបានបញ្ចុះគម្ពីរគួរអាន ហើយពិតប្រាកដណាស់ យើងគឺជាអ្នកដែលថែរក្សាវា។

10. ហើយជាការពិតណាស់ យើងបានបញ្ជូននូវអ្នកនាំសារជាច្រើនមុនអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ទៅកាន់ក្រុមប្រជាជាតិជំនាន់មុនជាច្រើន។

11. ហើយរាល់អ្នកនាំសារទាំងឡាយដែលបានមកដល់ពួកគេ គឺសុទ្ធតែត្រូវបានពួកគេសើចចំអក។

12. ក៏ដូច្នោះដែរ យើងនឹងបញ្ចូលវា (ការប្រឆាំង) ទៅក្នុងដួងចិត្តរបស់ពួកប្រព្រឹត្តល្មើសទាំងឡាយ។

13. ពួកគេមិនមានជំនឿចំពោះវា(គម្ពីរគួរអាន)ឡើយ។ ហើយជាការពិតណាស់ មាគ៌ារបស់ពួក(បដិសេធ)ជំនាន់មុន គឺបានកើតឡើងរួចមកហើយ។

14. ហើយប្រសិនបើយើងបើកទ្វារណាមួយនៃមេឃាឱ្យពួកគេនោះ ពួកគេនៅតែបន្តឡើងទៅលើវារហូត(ដើម្បីមើលឃើញពីភាពអស្ចារ្យនៃការគ្រប់គ្រងរបស់អល់ឡោះ)។

15. ពួកគេប្រាកដជានឹងនិយាយថា៖ តាមពិតភ្នែករបស់ពួកយើងត្រូវបានគេបំភ័ន្តប៉ុណ្ណោះ។ ផ្ទុយទៅវិញ ពួកយើងជាក្រុមមួយដែលត្រូវមន្តអាគមគេប៉ុណ្ណោះ។

16. ហើយជាការពិតណាស់ យើងបានបង្កើតហ្វូងតារាជាច្រើននៅលើមេឃ ហើយយើងបានលម្អវាសម្រាប់អ្នកដែលគយគន់មើល។

17. ហើយយើងបានការពារវា(មេឃ)ពីរាល់ពពួកស្មៃតនដែលត្រូវបានគេដាក់បណ្តាសា។

18. លើកលែងតែស្មៃតនណាដែលបានលួចស្តាប់(ដំណឹងពីម៉ាឡាអ៊ីកាត់)ប៉ុណ្ណោះ។ ហើយអាចម៍ផ្កាយដ៏ភ្លឺច្បាស់បានតាម(ដុតកម្ទេច)វា។

19. ហើយចំពោះផែនដី យើងបានលាតសន្ធឹងវា ហើយយើងបានបង្កើតភ្នំជាច្រើននៅលើវា(ដើម្បីជាលំនឹង) ព្រមទាំងបានបណ្តុះនូវរុក្ខជាតិគ្រប់ប្រភេទនៅលើវាទៅតាមការកំណត់(បរិមាណរបស់វា)យ៉ាងច្បាស់លាស់។

20. ហើយយើងបានបង្កើតនៅលើផែនដីនូវកត្តាទ្រទ្រង់ជីវិតរស់នៅសម្រាប់ពួកអ្នក និងសម្រាប់អ្នក(ផ្សេងទៀតក្រៅពីពួកអ្នក)ដែលពួកអ្នកមិនមែនជាអ្នកផ្តល់លាភសក្ការៈដល់គេឡើយ។

21. ហើយរាល់អ្វីៗទាំងអស់ គឺសុទ្ធតែមាននៅជាមួយយើងនូវឃ្លាំងផ្ទុករបស់វា ហើយយើងបញ្ចុះវាទៅតាមបរិមាណដែលបានកំណត់ច្បាស់លាស់។

22. ហើយយើងបានបញ្ជូនខ្យល់ឱ្យទៅប្រមូលផ្តុំពពក ហើយយើងបានបញ្ចុះទឹកភ្លៀងពីលើមេឃ(ចេញពីដុំពពកនោះ) និងបានផ្តល់ទឹកភ្លៀងនោះដល់អ្នកទាំងអស់គ្នាផឹក។ ហើយពួកអ្នក(ឱមនុស្សលោក)ពុំមែនជាអ្នកដែលស្តុកវា(ទឹក)ទុកនោះឡើយ។

23. ហើយពិតប្រាកដណាស់ យើងជាអ្នកដែលប្រទានជីវិត និងដកយកជីវិត។ ហើយយើងជាអ្នកទទួលមរតក(ផែនដី និងអ្វីៗដែលនៅលើវា)។

24. ហើយជាការពិតណាស់ យើងដឹងអំពីពួកជំនាន់មុនពួកអ្នក ហើយយើងក៏ដឹងពីអ្នកជំនាន់ក្រោយផងដែរ។

25. ហើយជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ជាអ្នកប្រមូលផ្តុំពួកគេ(នៅថ្ងៃបរលោក)។ ពិតប្រាកដណាស់ ទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

26. ហើយជាការពិតណាស់ យើងបានបង្កើតមនុស្សលោក(ព្យាការីអាហ្សាំ)ពីជីឥដ្ឋសួតចេញពីជីកក់ខ្មៅដែលត្រូវបានគេសូនជារូបរាង។

27. ហើយចំពោះអ៊ីព្លិស យើងបានបង្កើតវាកាលពីមុនអំពីភ្លើងដែលក្តៅបំផុត ។

28. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ពិតណាស់ យើងនឹងបង្កើតមនុស្សម្នាក់ពីឥដ្ឋសួតចេញពីជីកក់ខ្មៅដែលត្រូវបានគេសូនជារូបរាង។

29. ហើយនៅពេលដែលយើងបានធ្វើឱ្យគេមានរូបរាងសមសួន និងបានផ្លុំវិញ្ញាណរបស់យើងចូលទៅក្នុងខ្លួនគេហើយនោះ ចូរពួកអ្នកស៊ូជោតទៅចំពោះគេចុះ។

30. ពេលនោះ ម៉ាឡាអ៊ីកាត់បានស៊ូជោត(ចំពោះព្យាការីអាហ្សាំ)ទាំងអស់គ្នា។

31. លើកលែងតែអ៊ីព្លិសប៉ុណ្ណោះដែលបដិសេធមិនស្ថិតក្នុងចំណោមអ្នកស៊ូជោតទាំងឡាយឡើយ។

32. ទ្រង់បានមានបន្ទូល(ទៅកាន់អ៊ីព្លិស)ថា៖ តើអ្វីដែលរារាំងឯងមិនឲ្យស្ថិតក្នុងចំណោមអ្នកស៊ូជោតទាំងឡាយនោះ?

33. វាបានតបថា៖ ខ្ញុំមិនក្រាបស៊ូជោតចំពោះមនុស្សម្នាក់ដែលព្រះអង្គបានបង្កើតរូបគេពីជីឥដ្ឋសួតចេញពីជីកក់ខ្មៅដែលត្រូវបានសូនជារូបរាងនោះឡើយ។

34. ទ្រង់បានតបថា៖ ចូរឯងចាកចេញពីទីនេះ(ឋានសួគ៌)ចុះ ពីព្រោះឯងត្រូវគេបណ្តេញចេញហើយ។

35. ហើយពិតប្រាកដណាស់ ឯងនឹងត្រូវទទួលនូវបណ្តាសារហូតដល់ថ្ងៃបរលោក។

36. អ៊ីព្លិសបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាពន្យារពេលដល់ខ្ញុំ រហូតដល់ថ្ងៃដែលគេធ្វើឲ្យសព្វភាវៈទាំងឡាយរស់ឡើងវិញផងចុះ។

37. ទ្រង់បានតបថា៖ ពិតប្រាកដណាស់ ឯងស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេពន្យារពេល

38. រហូតដល់ថ្ងៃដែលគេបានកំណត់យ៉ាងច្បាស់លាស់(ថ្ងៃបរលោក)។

39. អ៊ីព្លិសបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! ព្រោះតែព្រះអង្គធ្វើឱ្យខ្ញុំវង្វេង ខ្ញុំប្រាកដជានឹងតុបតែងលម្អ(នូវប្រការអាក្រក់)ចំពោះពួកគេនៅលើផែនដី ហើយខ្ញុំប្រាកដជានឹងធ្វើឱ្យពួកគេទាំងអស់គ្នាវង្វេងជាមិនខាន។

40. លើកលែងខ្ញុំបម្រើរបស់ព្រះអង្គដែលព្រះអង្គបានចង្អុលបង្ហាញពួកគេឱ្យមានភាពស្មោះស(គោរពសក្ការៈចំពោះទ្រង់តែមួយ)ក្នុងចំណោមពួកគេប៉ុណ្ណោះ។

41. អល់ឡោះបានមានបន្ទូលថា៖ នេះគឺជាមាគ៌ាមួយដ៏ត្រឹមត្រូវដែលឆ្ពោះមកកាន់យើង។

42. ពិតប្រាកដណាស់ ខ្ញុំបម្រើរបស់យើង(ដែលស្មោះស)នោះ ឯងគ្មានអំណាចអ្វីអូសទាញពួកគេ(ឲ្យវង្វេងឡើយ) លើកលែងតែអ្នកដែលដើរតាមឯងក្នុងចំណោមពួកដែលវង្វេងប៉ុណ្ណោះ។

43. ហើយពិតប្រាកដណាស់ នរកដើហាន់ណាំ គឺជាកន្លែងដែលគេសន្យាសម្រាប់ពួកគេទាំងអស់គ្នា។

44. វាមានទ្វារចំនួនប្រាំពីរ។ រាល់ទ្វារនីមួយៗ គឺត្រូវបានគេបែងចែកជាក្រុមៗក្នុងចំណោមពួកគេ(អ្នកដែលដើរតាមអ៊ីព្លិស) យ៉ាងច្បាស់លាស់។

45. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) គឺស្ថិតនៅក្នុងឋានសួគ៌ និងមានប្រភពទឹកជាច្រើន។

46. (មានគេនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នកចូលក្នុងវា(ឋានសួគ៌)ប្រកបដោយសន្តិភាព និងសុវត្ថិភាព។

47. ហើយយើង(អល់ឡោះ)បានដកយកនូវការច្រណែនឈ្នានីសចេញពីដួងចិត្តរបស់ពួកគេឱ្យពួកគេស្រលាញ់គ្នាដូចបងប្អូន ដោយពួកគេអង្គុយលើគ្រែទល់មុខគ្នា។

48. ក្នុងឋានសួគ៌នោះ ពួកគេគ្មានភាពនឿយហត់ឡើយ ហើយពួកគេក៏មិនត្រូវគេបណ្តេញចេញពីវានោះដែរ។

49. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រាប់ខ្ញុំបម្រើរបស់យើងឱ្យបានដឹងថា៖ ពិតប្រាកដណាស់ យើងគឺជាព្រះជាម្ចាស់ដ៏មហា អភ័យទោស មហាអាណិតស្រលាញ់បំផុត។

50. ហើយពិតប្រាកដណាស់ ទណ្ឌកម្មរបស់យើង ក៏ជាទណ្ឌកម្មដ៏សែនឈឺចាប់បំផុតដែរ។

51. ហើយចូរអ្នកប្រាប់ពួកគេឱ្យបានដឹងពីរឿងរ៉ាវភ្ញៀវរបស់ព្យាការីអ៊ីព្រហ៊ីម(ដែលជាម៉ាឡាអ៊ីកាត់)។

52. នៅពេលដែលពួកគេបានចូលទៅជួបគាត់ ពេលនោះពួកគេបាននិយាយថា៖ សាឡាម(សូមសន្តិភាពកើតមានដល់អ្នក)។ (នៅពេលដែលពួកគេមិនទទួលទានអាហារដែលគាត់រៀបចំជូន) គាត់ក៏និយាយថា៖ ពិតប្រាកដណាស់ យើងមានការ ភ័យខ្លាចចំពោះពួកអ្នក។

53. ពួកគេបានតបថា៖ ចូរអ្នកកុំភ័យខ្លាច។ ពិតណាស់ ពួកយើងនាំដំណឹងល្អមួយនៃការទទួលបានកូនប្រុសដ៏មានចំណេះដឹង ម្នាក់មកប្រាប់អ្នក។

54. គាត់បានតបវិញថា៖ តើពួកអ្នកផ្តល់ដំណឹងរីករាយដល់ខ្ញុំ(ពីការមានកូន)ឬ ខណៈដែលខ្ញុំមានវ័យចាស់ជរាហើយនោះ? តើអ្នកសំអាងលើអ្វីចំពោះការផ្តល់ដំណឹងរីករាយនេះ?

55. ពួកគេក៏តបវិញថា៖ ពួកយើងផ្តល់ដំណឹងរីករាយមួយដែលជាការពិតដល់អ្នក។ ហេតុនេះ ចូរអ្នកកុំស្ថិតក្នុងចំណោមអ្នក ដែលអស់សង្ឃឹមឱ្យសោះ។

56. គាត់បាននិយាយថា៖ គ្មានជនណាដែលអស់សង្ឃឹមពីក្តីមេត្តាករុណានៃព្រះជាម្ចាស់របស់គេឡើយ លើកលែងតែពួកដែលវង្វេងប៉ុណ្ណោះ។

57. គាត់បានបន្តថា៖ តើអ្វីទៅជាភារកិច្ចរបស់ពួកអ្នក ឱបណ្តាអ្នកនាំសារទាំងឡាយ?

58. ពួកគេ(ម៉ាឡាអ៊ីកាត់ទាំងនោះ)បាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងត្រូវបានគេបញ្ជូនទៅកាន់ក្រុមដែលប្រព្រឹត្តល្មើស(ក្រុមព្យាការីលូត)។

59. លើកលែងតែក្រុមគ្រួសាររបស់ព្យាការីលូត(ដែលជាអ្នកមានជំនឿ)ប៉ុណ្ណោះ។ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលជួយសង្គ្រោះពួកគេទាំងអស់គ្នា(ពីការបំផ្លិចបំផ្លាញនោះ)។

60. លើកលែងតែភរិយារបស់គាត់ប៉ុណ្ណោះ។ ពិតណាស់ ពួកយើងបានកំណត់រួចមកហើយថា ពិតប្រាកដណាស់ រូបនាងគឺស្ថិតក្នុងចំណោមពួកដែលត្រូវទទួលរងនូវការបំផ្លាញ។

61. ហើយនៅពេលដែលអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)បានទៅដល់ក្រុមគ្រួសាររបស់ព្យាការីលូត

62. គាត់បាននិយាយថា៖ ពួកអ្នកគឺជាក្រុមដែលគេមិនស្គាល់ឡើយ។

63. ពួកគេ(ម៉ាឡាអ៊ីកាត់)បាននិយាយថា៖ តាមពិត ពួកយើងបាននាំមកឱ្យអ្នកនូវអ្វី(ទណ្ឌកម្ម)ដែលពួកគេមានការមន្ទិលសង្ស័យចំពោះវា។

64. ហើយពួកយើងបាននាំមកឱ្យអ្នកនូវការពិត ហើយពិតប្រាកដណាស់ ពួកយើងគឺជាអ្នកទៀងត្រង់។

65. ហេតុនេះ ចូរអ្នកនាំក្រុមគ្រួសាររបស់អ្នកចាកចេញនៅពេលពាក់កណ្តាលយប់ ហើយអ្នកត្រូវដើរពីក្រោយពួកគេ និងមិនត្រូវឱ្យនរណាម្នាក់ក្នុងចំណោមពួកអ្នកងាកក្រោយជាដាច់ខាត។ ហើយចូរពួកអ្នកបន្តដំណើរទៅកាន់ទីណាដែលគេបញ្ជាពួកអ្នកឱ្យទៅចុះ។

66. នោះហើយជាកិច្ចការដែលយើងបានកំណត់វា ពោលគឺក្រុមទាំងនោះនឹងត្រូវគេបំផ្លាញ(កម្ទេច)ផ្តាច់ពូជនៅពេលដែលចូលដល់វេលាទៀបភ្លឺ។

67. ហើយអ្នកភូមិ(សាទូម)បានមកដល់(កន្លែងព្យាការីលូត)ដោយភាពសប្បាយរីករាយ។

68. ព្យាការីលូតបាននិយាយទៅកាន់ពួកគេថា៖ ពិតប្រាកដណាស់ អ្នកទាំងនោះគឺជាភ្ញៀវរបស់ខ្ញុំ។ ហេតុនេះ ចូរពួកអ្នកកុំធ្វើឱ្យខ្ញុំអាម៉ាស់មុខឱ្យសោះ។

69. ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ និងកុំធ្វើឱ្យខ្ញុំអាប់ឱន។

70. ពួកគេបានតបវិញថា៖ តើពួកយើងមិនបានហាមឃាត់អ្នកមិនឱ្យទទួលភ្ញៀវណាម្នាក់ក្នុងចំណោមមនុស្សលោក(ដែលជាបុរស)ទេឬ?

71. ព្យាការីលូតបាននិយាយថា៖ ពួកគេទាំងនេះជាកូនស្រីរបស់ខ្ញុំ។ (ចូរពួកអ្នករៀបការជាមួយពួកនាងចុះ) ប្រសិនបើពួកអ្នកមានចង់បំពេញចំណង់តណ្ហានោះ។

72. ហើយយើង(អល់ឡោះ)សូមស្បថនឹងជីវិតរបស់អ្នក(ព្យាការីមូហាំម៉ាត់)ថា៖ ពិតប្រាកដណាស់ ពួកគេគឺស្ថិតនៅក្នុងភាពវង្វេងយ៉ាងខ្លាំងដោយមិនដឹងអ្វីឡើយ។

73. ពេលនោះ សម្រែកយ៉ាងខ្លាំងបានឆក់យកជីវិតពួកគេនៅពេលថ្ងៃរះ។

74. ហើយយើង(អល់ឡោះ)បានធ្វើឱ្យភូមិស្រុកនោះក្រឡាប់ពីលើចុះក្រោម ហើយយើងបានបញ្ចុះទៅលើពួកគេនូវភ្លៀងដុំថ្មពីដីឥដ្ឋ។

75. ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់អ្នកដែលពិនិត្យមើលដោយការពិចារណា។

76. ហើយពិតប្រាកដណាស់វា(ភូមិស្រុកក្រុមព្យាការីលូត)នោះ គឺស្ថិតនៅចំផ្លូវធំដែលអ្នកដំណើរឆ្លងកាត់(អាចមើលឃើញ)។

77. ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់បណ្តាអ្នកដែលមានជំនឿ។

78. ហើយពិតប្រាកដណាស់ ក្រុមអៃកៈ(ក្រុមរបស់ព្យាការីស៊ូអែប) គឺពិតជាពួកដែលបំពាន។

79. ដូចនេះ យើងក៏បានផ្តន្ទាទោសពួកគេ។ ហើយពិតណាស់ វាទាំងពីរ(ភូមិស្រុកក្រុមព្យាការីលូត និងព្យាការីស៊ូអែប) គឺស្ថិតនៅចំផ្លូវធំដែលអ្នកដំណើរឆ្លងកាត់(អាចមើលឃើញ)។

80. ហើយជាការពិតណាស់ ក្រុមដែលរស់នៅជ្រលងហិជ្ជរ៍(ក្រុមព្យាការីសេឡេះ)បានបដិសេធនឹងបណ្តាអ្នកនាំសារទាំងអស់។

81. ហើយយើងបានប្រទាននូវសញ្ញាកស្តុតាងជាច្រើនដល់ពួកគេ ក៏ប៉ុន្តែពួកគេបែរជាងាកចេញអំពីវាទៅវិញ។

82. ហើយពួកគេបានចោះភ្នំជាច្រើនធ្វើជាលំនៅឋាន(ដើម្បីស្នាក់នៅ)ដោយសុវត្ថិភាព។

83. ហើយសម្រែកមួយដ៏ខ្លាំងបានឆក់យកជីវិតពួកគេនៅពេលទៀបភ្លឺ។

84. ហើយអ្វីដែលពួកគេបានប្រឹងប្រែងស្វែងរក(ទ្រព្យសម្បត្តិ លំនៅឋាន...) គឺមិនអាចផ្តល់ជាប្រយោជន៍អ្វីដល់ពួកគេឡើយ។

85. ហើយយើងមិនបានបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយនិងអ្វីៗដែលនៅចន្លោះវាទាំងពីរឡើយ លើកលែងតែមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ។ ហើយជាការពិតណាស់ ថ្ងៃបរលោកនឹងមកដល់(យ៉ាងពិតប្រាកដ)។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អនុគ្រោះ(ដល់ពួកគេ)នូវការអនុគ្រោះមួយដ៏ប្រពៃ។

86. ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) គឺជាអ្នកបង្កើត(អ្វីទាំងអស់) និងមហាជ្ញឹងបំផុត។

87. ហើយជាការពិតណាស់ យើងបានផ្តល់ឱ្យអ្នកនូវដំពូកអាល់ហ្វាទីហៈដែលមានប្រាំពីរវាក្យខណ្ឌ និងគម្ពីរគួរអានដ៏ឧត្តុង្គឧត្តម។

88. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំសម្លឹងដោយភ្នែកទាំងគូរបស់អ្នកទៅកាន់អ្វី(លាភសក្ការៈលោកិយ)ដែលយើងបានប្រទានវាទៅឱ្យក្រុមមួយក្នុងចំណោមពួកគេ(ពួកប្រឆាំង)ឱ្យសោះ។ ហើយចូរអ្នកកុំកើតទុក្ខចំពោះ(ការបដិសេធរបស់)ពួកគេ និងត្រូវឱនលំទោនទៅចំពោះបណ្តាអ្នកមានជំនឿ។

89. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពិតណាស់ ខ្ញុំគឺជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់(ពីទណ្ឌកម្មរបស់អល់ឡោះ)។

90. ដូចអ្វី(ទណ្ឌកម្ម)ដែលអល់ឡោះបានទម្លាក់វាទៅលើពួកដែលបែងចែក(គម្ពីររបស់ទ្រង់)។

91. គឺពួកដែលបែងចែកគម្ពីរគួរអានទៅជាផ្នែកៗ។

92. ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានស្បថថា៖ (នៅថ្ងៃបរលោក)យើងប្រាកដជានឹងសួរពួកទាំងនោះទាំងអស់គ្នាជាមិនខាន

93. ពីអ្វីដែលពួកគេបានប្រព្រឹត្ត។

94. ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រកាសដោយចំហពីអ្វីដែលគេបានបង្គាប់ប្រើអ្នក ហើយចូរអ្នកងាកចេញពីពួកដែលធ្វើស្ពឹរិក។

95. ជាការពិតណាស់ មានយើង(តែមួយ)គឺគ្រប់គ្រាន់សម្រាប់អ្នកពីពួកដែលចំអកឡកឡឺយ។

96. គឺពួកដែលយកអ្នកផ្សេងធ្វើជាព្រះរួមនឹងអល់ឡោះជាម្ចាស់។ ដូច្នេះ ពួកគេគង់តែនឹងដឹងជាមិនខាន។

97. ហើយពិតប្រាកដណាស់ យើងដឹងថា អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិតជាមានភាពតាងតឹងនៅក្នុងចិត្តរបស់អ្នកចំពោះអ្វីដែលពួកគេនិយាយ។

98. ហេតុនេះ ចូរអ្នកលើកតម្កើងដោយការកោតសរសើរដល់ព្រះជាម្ចាស់របស់អ្នក។ ហើយចូរអ្នកស្ថិតក្នុងចំណោមបណ្តាអ្នកដែលគោរពសក្ការៈ(ចំពោះអល់ឡោះ)។

99. ហើយចូរអ្នកបន្តគោរពសក្ការៈចំពោះព្រះជាម្ចាស់របស់អ្នក រហូតដល់សេចក្តីស្លាប់បានមកដល់អ្នក។

ជំពូក អាន់ណាះល៍

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. បទបញ្ជារបស់អល់ឡោះ(ថ្ងៃបរលោក) គឺជិតមកដល់ហើយ។ ហេតុនេះ ចូរពួកអ្នក(ពួកគ្មានជំនឿ)កុំទាមទារឱ្យវាឆាប់មកដល់(មុនពេលកំណត់)។ ទ្រង់មហាបរិសុទ្ធ និងខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស្តីរិក។

2. ទ្រង់បានបញ្ចុះម៉ាឡាអ៊ីកាត់ដោយនាំនូវរ៉ាហ៊ីតាមបទបញ្ជារបស់ទ្រង់ទៅកាន់ជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់ដោយឲ្យពួកគេដាស់តឿនព្រមានថា៖ ពិតប្រាកដណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីយើងឡើយ។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចមកចំពោះយើង។

3. ទ្រង់បានបង្កើតមេឃជាច្រើនជាន់ និងផែនដីដោយពិតប្រាកដ។ ទ្រង់មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស្តីរិក។

4. ទ្រង់បានបង្កើតមនុស្សពីតំណក់ទឹកកាម តែគេបែរជាក្លាយជាអ្នកដែលជជែកដេញដោល(ជំទាស់នឹងការពិត)យ៉ាងច្បាស់លាស់។

5. ហើយចំពោះសត្វពាហនៈ ទ្រង់បានបង្កើតវាសម្រាប់(ជាប្រយោជន៍ដល់)ពួកអ្នក។ ក្នុងចំណោមនោះ ពួកអ្នកអាចទទួលបានភាពកក់ក្តៅ និងអាចទាញយកប្រយោជន៍ផ្សេងៗ ហើយពួកអ្នកក៏អាចទទួលទានអំពីវាបានផងដែរ។

6. ហើយពួកអ្នកក៏អាចទទួលបានពីវា(សត្វពាហនៈ)នោះផងដែរ នូវភាពស្រស់ស្អាត(ដែលនាំមកនូវភាពរីករាយ)នៅពេលដែលពួកអ្នកនាំវាត្រឡប់មកក្រោល(នៅពេលល្ងាច) និងនៅពេលដែលពួកអ្នកនាំវាទៅឃ្វាលវិញ(នៅពេលព្រឹក)។

7. ហើយវាក៏អាចដឹកជញ្ជូនទំនិញធ្ងន់ៗរបស់ពួកអ្នកទៅកាន់ទឹកដីមួយដែលពួកអ្នកមិនអាចធ្វើដំណើរទៅដល់ឡើយលើកលែងតែ(ទៅដល់)ទាំងលំបាក។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ពួកអ្នកមហាករុណា មហាអាណិតស្រលាញ់បំផុត។

8. ហើយចំពោះសត្វសេះ សត្វសេះទេស និងសត្វលា គឺសម្រាប់ឲ្យពួកអ្នកជិះ និងជាការលម្អ។ ហើយទ្រង់បានបង្កើតអ្វី(ផ្សេងទៀត)ដែលពួកអ្នកមិនដឹង។

9. ហើយសម្រាប់អល់ឡោះ គឺការបញ្ជាក់ពីមាគ៌ាដែលត្រឹមត្រូវ។ តែមានមាគ៌ាខ្លះទៀត ជាមាគ៌ាដែលមានភាពវៀចវេរ។ ហើយប្រសិនបើទ្រង់មានចេតនា ទ្រង់ប្រាកដជានឹងចង្អុលបង្ហាញពួកអ្នកទាំងអស់គ្នាជាមិនខាន។

10. ទ្រង់ជាអ្នកបញ្ចុះទឹកភ្លៀងពីលើមេឃ។ តាមរយៈទឹកភ្លៀងនេះ គឺសម្រាប់ពួកអ្នកអាចទទួលទាន និងសម្រាប់រុក្ខជាតិ(លូតលាស់)ដើម្បីឲ្យពួកអ្នកអាចឃ្វាលសត្វ(នៅកន្លែងនោះ)បានផងដែរ។

11. តាមរយៈទឹកភ្លៀងនោះដែរ ទ្រង់ធ្វើឱ្យដំណាំជាច្រើនដុះចេញមក និងដើមអូលីវ ដើមល្មើ ដើមទំពាំងបាយជូរ ហើយនិងផលានុផលលក្រប់ប្រភេទជាច្រើនទៀតសម្រាប់ពួកអ្នក។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តែងសម្រាប់ក្រុមដែលចេះគិតពិចារណា។

12. ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវពេលយប់ ពេលថ្ងៃ ព្រះអាទិត្យ និងព្រះចន្ទ ហើយនិងហ្វូងតារាជាច្រើនដោយពួកវាគោរពទៅតាមបទបញ្ជារបស់ទ្រង់។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលឈ្វេងយល់។

13. ហើយអ្វីដែលទ្រង់បានបង្កើតសម្រាប់ពួកអ្នកនៅលើផែនដីនេះ គឺមានពណ៌សម្បុរបស់វាខុសៗគ្នា។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយសម្រាប់ក្រុមដែលនឹករលឹក។

14. ហើយទ្រង់ជាអ្នកដែលបានបង្កើតសមុទ្រសម្រាប់ឲ្យពួកអ្នកអាចយកសាច់ស្រស់(ត្រី)អំពីវាមកទទួលទាន និងអាចយកចេញអំពីវានូវគ្រឿងអលង្ការដែលពួកអ្នកអាចយកវាមកពាក់(ជាគ្រឿងលម្អ)បាន។ ហើយពួកអ្នកបានឃើញសំពៅទាំងឡាយធ្វើដំណើរនៅលើវា(ផ្ទៃសមុទ្រ)ដើម្បីពួកអ្នកស្វែងរកការប្រោសប្រទានពីទ្រង់(តាមរយៈជួញដូរ)និងសង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

15. ហើយទ្រង់បានបោះភ្ជាប់នៅលើផែនដីនូវភ្នំជាច្រើនដើម្បីកុំឲ្យវាញ័ររញ្ជួយដល់ពួកអ្នក និងបានបង្កើតនូវទន្លេ និងផ្លូវជាច្រើនដើម្បីឲ្យពួកអ្នកទទួលបានការចង្អុលបង្ហាញ(ទៅកាន់គោលដៅ)។

16. ហើយ(ទ្រង់បានបង្កើតនៅលើផែនដីផងដែរនូវ)សញ្ញាសម្គាល់ជាច្រើន និង(បានបង្កើតនូវ)ហ្វូងតារាដោយពួកគេអាចយកធ្វើជាត្រីវិស័យ(នៅពេលយប់)។

17. ដូច្នេះ តើអ្នកដែលបានបង្កើត(អ្វីៗទាំងអស់នេះ) ដូចនឹងអ្នកដែលមិនបានបង្កើតអ្វីសោះឬ? ហេតុនេះ តើពួកអ្នកមិននឹករលឹកទេឬ?

18. ហើយប្រសិនបើពួកអ្នក(ឱមនុស្សលោក)រាប់នូវឧបការគុណរបស់អល់ឡោះនោះ គឺពួកអ្នកមិនអាចរាប់វាអស់ឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

19. ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកលាក់បាំង និងអ្វីដែលពួកអ្នកលាតត្រដាង។

20. ហើយអ្នកដែលពួកគេគោរពសក្ការៈ(ចំពោះវា)ផ្សេងពីអល់ឡោះជាម្ចាស់នោះ ពួកវាមិនបានបង្កើតអ្វីមួយឡើយ។ ផ្ទុយទៅវិញ ពួកគេត្រូវបានគេបង្កើត។

21. ពួកវាគ្រាន់តែជារបស់ដែលគ្មានវិញ្ញាណ គ្មានជីវិតនោះឡើយ។ ហើយពួកវាក៏មិនដឹងដែរថា តើពេលណាពួកវាត្រូវបានគេបង្កើតឱ្យរស់ឡើងវិញនោះ។

22. ព្រះជាម្ចាស់របស់ពួកអ្នកដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដនោះ គឺព្រះជាម្ចាស់តែមួយគត់។ ហើយពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក ដួងចិត្តរបស់ពួកគេ គឺបដិសេធ(ពីភាពជាព្រះជាម្ចាស់តែមួយរបស់អល់ឡោះ)។ ហើយពួកគេ គឺជាពួកដែលក្រអឺតក្រទម។

23. គ្មានការសង្ស័យអ្វីឡើយដែលថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតពីអ្វីដែលពួកគេលាក់បាំង និងអ្វីដែលពួកគេលាតត្រដាង។ ពិតប្រាកដណាស់ ទ្រង់មិនចូលចិត្តពួកដែលក្រអឺតក្រទមឡើយ។

24. ហើយនៅពេលដែលមានគេសួរទៅកាន់ពួកគេ(ពួកដែលបដិសេធ)ថា៖ តើព្រះជាម្ចាស់របស់ពួកអ្នកបានបញ្ចុះអ្វីមក? ពួកគេឆ្លើយថា៖ គឺគ្រាន់តែជារឿងព្រេងរបស់មនុស្សជំនាន់មុនប៉ុណ្ណោះ។

25. ដើម្បីឲ្យពួកគេរែកពុននូវបាបកម្មរបស់ពួកគេយ៉ាងពេញលេញនៅថ្ងៃបរលោក ហើយនិងបាបកម្មរបស់ពួកដែលត្រូវបានពួកគេធ្វើឱ្យវង្វេងដោយគ្មានចំណេះដឹង។ ពិតប្រាកដណាស់ អ្វីដែលពួកគេរែកពុននោះ គឺអាក្រក់បំផុត។

26. ជាការពិតណាស់ ពួក(ប្រឆាំង)ជំនាន់មុនពួកគេបានប្រើល្បិចកល(ចំពោះអ្នកនាំសាររបស់ពួកគេ)។ តែអល់ឡោះបានកម្ទេចគ្រឹះនៃផ្ទះសម្បែងរបស់ពួកគេ ហើយដំបូល(ផ្ទះ)បានធ្លាក់សង្កត់ពីលើពួកគេ។ ហើយនៅពេលនោះ ទណ្ឌកម្មក៏បានមកដល់ពួកគេដោយពួកគេមិនដឹងខ្លួនឡើយ។

27. ក្រោយមកនៅថ្ងៃបរលោក អល់ឡោះជាម្ចាស់នឹងធ្វើឱ្យពួកគេអាម៉ាស់ ហើយទ្រង់មានបន្ទូលថា៖ តើឯណាទៅព្រះនានាដែលពួកអ្នកធ្លាប់បានតស៊ូប្រឆាំងនឹងបណ្តាអ្នកនាំសារ និងអ្នកមានជំនឿព្រោះតែពួកវានោះ? ពួកដែលគេផ្តល់ចំណេះដឹងឲ្យបាននិយាយថា៖ ជាការពិតណាស់ ភាពអាម៉ាស់ និងទណ្ឌកម្មនៅថ្ងៃនេះ គឺធ្លាក់ទៅលើពួកដែលប្រឆាំង។

28. ពួកដែលម៉ាឡាអ៊ីកាត់បានដកយកជីវិតពួកគេ ខណៈដែលពួកគេជាពួកដែលបំពានលើខ្លួនឯង។ ពេលនោះ ពួកគេបានប្រគល់ខ្លួន(នៅពេលដែលសេចក្តីស្លាប់បានមកដល់ពួកគេ ហើយពួកគេបដិសេធថា៖) ពួកយើងមិនធ្លាប់បានប្រព្រឹត្តអំពើល្មើសឡើយ។ (មានគេនិយាយទៅកាន់ពួកគេថា៖) ពុំដូច្នោះឡើយ ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

29. ដូច្នេះ ចូរពួកអ្នកចូលតាមទ្វារនានានៃនរកដើហាន់ណាំដោយពួកអ្នកស្ថិតនៅទីនោះជាអមតៈ។ ពិតណាស់ កន្លែងស្នាក់នៅរបស់ពួកដែលក្រអឺតក្រទមនោះ គឺអាក្រក់បំផុត។

30. ហើយមានគេនិយាយទៅកាន់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)ថា៖ តើព្រះជាម្ចាស់របស់ពួកអ្នកបានបញ្ចុះអ្វីមក? ពួកគេបានឆ្លើយថា៖ គឺប្រការល្អ។ សម្រាប់បណ្តាអ្នកដែលធ្វើល្អនៅក្នុងជីវិតលោកិយនេះ គឺនឹងទទួលបានផលល្អ។ ចំណែកឯនៅឋានបរលោកវិញ គឺល្អប្រសើរជាងនោះទៅទៀត។ ហើយលំនៅឋានរបស់អ្នកដែលកោតខ្លាច(អល់ឡោះ)នោះ គឺល្អប្រសើរបំផុត។

31. គឺឋានសួគ៌អាត់និនដែលពួកគេនឹងចូលទៅក្នុងវាដោយមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ នៅក្នុងឋានសួគ៌នោះ ពួកគេនឹងទទួលបាននូវអ្វីគ្រប់យ៉ាងដែលពួកគេប្រាថ្នា។ ក៏ដូចគ្នាដែរ អល់ឡោះជាម្ចាស់នឹងតបស្នងដល់បណ្តាអ្នកដែលកោតខ្លាច។

32. គឺបណ្តាអ្នកដែលម៉ាឡាអ៊ីកាត់បានដកយកជីវិតពួកគេដោយដួងចិត្តរបស់ពួកគេជ្រះស្អាតពីភាពគ្មានជំនឿ។ ម៉ាឡាអ៊ីកាត់បានពោលថា៖ សូមសន្តិភាពកើតមានដល់ពួកអ្នក។ ចូរពួកអ្នកចូលទៅក្នុងឋានសួគ៌ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តចុះ។

33. តើពួកគេ(ពួកមុស្រីគីន)មិនរង់ចាំអ្វីក្រៅពីម៉ាឡាអ៊ីកាត់ ឬក៏បទបញ្ជានៃព្រះជាម្ចាស់របស់អ្នក(ទណ្ឌកម្ម)មកដល់ពួកគេឬ? ក៏ដូចគ្នាដែរ អ្នកជំនាន់មុនពួកគេក៏បានធ្វើដូច្នោះដែរ។ ហើយអល់ឡោះមិនបានបំពានលើពួកគេឡើយ តែពួកគេទៅវិញទេដែលបានបំពានលើខ្លួនឯងនោះ។

34. ហើយពួកគេបានទទួលរងនូវប្រការអាក្រក់(ទណ្ឌកម្ម)ដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។ ហើយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានសើចចំអកនោះបានហ៊ុមព័ទ្ធពួកគេ។

35. ហើយពួកដែលធ្វើស្ហ៊ីកបាននិយាយថា៖ ប្រសិនបើអល់ឡោះមានចេតនា នោះពួកយើង និងជីដូនជីតារបស់ពួកយើងមិនគោរពសក្ការៈអ្វីផ្សេងក្រៅពីទ្រង់នោះឡើយ ហើយពួកយើងក៏មិនដាក់បម្រាមនូវអ្វីមួយដែលទ្រង់មិនដាក់បម្រាមនោះដែរ។ ក៏ដូចគ្នាដែរ អ្នកជំនាន់មុនពួកគេក៏បានធ្វើដូច្នោះដែរ។ ហើយតួនាទីរបស់បណ្តាអ្នកនាំសារទាំងឡាយ គឺគ្មានអ្វីក្រៅពីការផ្សព្វផ្សាយ(សារ)ដ៏ច្បាស់លាស់នោះឡើយ។

36. ហើយជាការពិតណាស់ យើងបានតែងតាំងទៅកាន់រាល់ប្រជាជាតិនីមួយនូវអ្នកនាំសារម្នាក់ ដោយប្រើឲ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះ(តែមួយគត់)និងចៀសឆ្ងាយពីតហ្ឃូត(ការគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះ)។ ពេលនោះ ក្នុងចំណោមពួកគេ គឺមានអ្នកដែលអល់ឡោះចង្អុលបង្ហាញ។ ហើយក្នុងចំណោមពួកគេផងដែរ គឺមានអ្នកដែលភាពវង្វេងចាំបាច់ត្រូវតែកើតឡើងចំពោះពួកគេ។ ហេតុនេះ ចូរពួកអ្នកធ្វើដំណើរនៅលើផែនដីចុះ ហើយចូរពួកអ្នកពិនិត្យមើល ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបដិសេធនោះយ៉ាងដូចម្តេចដែរ?

37. ទោះបីជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ព្យាយាមលើការចង្អុលបង្ហាញពួកគេក៏ដោយ ក៏អល់ឡោះជាម្ចាស់មិនចង្អុលបង្ហាញចំពោះជនដែលគេធ្វើឲ្យគេវង្វេងនោះដែរ។ ហើយសម្រាប់ពួកគេ គ្មានអ្នកដែលជួយនោះឡើយ។

38. ហើយពួកគេបានស្បថនឹងអល់ឡោះដោយការស្បថយ៉ាងមុឺងម៉ាត់ថា៖ អល់ឡោះជាម្ចាស់ទ្រង់នឹងមិនធ្វើឲ្យអ្នកដែលស្លាប់រស់ឡើងវិញឡើយ។ មិនដូច្នោះឡើយ។ ការសន្យាទៅលើរឿងនោះ គឺជាការពិត។ ក៏ប៉ុន្តែ មនុស្សភាគច្រើនមិនដឹងឡើយ។

39. (ទ្រង់ឲ្យពួកគេរស់ឡើងវិញ)ដើម្បីបញ្ជាក់ដល់ពួកគេនូវអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នានៅក្នុងវា និងដើម្បីឲ្យពួកដែលប្រឆាំងដឹងថា ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលធ្លាប់បានភូតកុហក។

40. តាមពិត បន្ទូលរបស់យើងទៅកាន់អ្វីមួយនៅពេលដែលយើងមានបំណងឲ្យវាកើតឡើងនោះ យើងគ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" នោះវានឹងកើតឡើងភ្លាម។

41. ហើយបណ្តាអ្នកដែលធ្វើចំណាកស្រុកក្នុងនាមអល់ឡោះក្រោយពីពួកគេត្រូវបានគេបំពាននោះ យើងពិតជានឹងផ្តល់កន្លែងស្នាក់ដ៏ល្អប្រពៃឲ្យពួកគេនៅក្នុងលោកិយនេះ។ ហើយសម្រាប់ផលបុណ្យនៅថ្ងៃបរលោកវិញ គឺធំធេងជាងនេះទៅទៀត ប្រសិនបើពួកគេបានដឹង។

42. គឺបណ្តាអ្នកដែលបានអត់ធ្មត់ ព្រមទាំងប្រគល់ការទុកចិត្តទៅចំពោះព្រះជាម្ចាស់របស់ពួកគេ(តែមួយគត់)។

43. ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ក្រៅពីបុរសៗដែលយើងបានផ្តល់វាហ៊ីទៅកាន់ពួកគេនោះឡើយ។ ដូច្នេះ ចូរពួកអ្នកសួរពួកដែលគេផ្តល់គម្ពីរឲ្យ (ពួកយូដា និងពួកគ្រីស្ទាន)ចុះ ប្រសិនបើពួកអ្នកមិនដឹងទេនោះ។

44. (យើងបានបញ្ជូនពួកគេ)ដោយនាំមកនូវសញ្ញាកស្តុតាងដ៏ច្បាស់លាស់ និងគម្ពីរជាច្រើន។ ហើយយើងបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរគួរអានដើម្បីឲ្យអ្នកបកស្រាយបញ្ជាក់ដល់មនុស្សលោកនូវអ្វីដែលគេបានបញ្ចុះទៅកាន់ពួកគេ សង្ឃឹមថាពួកគេចេះត្រិះរិះពិចារណា។

45. តើពួកដែលរៀបចំផែនការអាក្រក់នានាមានសុវត្ថិភាពដែរឬទេ ប្រសិនបើអល់ឡោះជាម្ចាស់ឲ្យពួកគេលិចចូលទៅក្នុងដី(ធរណីស្រូប)ឬក៏ទណ្ឌកម្មមកដល់ពួកគេដោយពួកគេមិនដឹងខ្លួននោះ?

46. ឬក៏ទ្រង់នឹងដាក់ទណ្ឌកម្មពួកគេក្នុងខណៈដែលពួកគេធ្វើដំណើរចុះឡើង(ដើម្បីស្វែងរកលាភសក្ការៈ)នោះ? ពិតណាស់ ពួកគេមិនអាចគេចផុត(ពីទណ្ឌកម្ម)បានឡើយ។

47. ឬក៏ទ្រង់ដាក់ទណ្ឌកម្មពួកគេខណៈដែលពួកគេភ័យខ្លាច(អំពីវា)នោះ? ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នកមហាមេត្តាករុណា មហាអាណិតស្រលាញ់បំផុត។

48. តើពួកគេ(ពួកដែលបដិសេធ)មិនមើលទៅកាន់អ្វីដែលអល់ឡោះបានបង្កើតទេឬ? ស្រមោលរបស់វាម្ដងរេទៅខាងស្ដាំម្ដងទៅខាងឆ្វេងដោយវា(ស្រមោល)ឱនស៊ូជោតចំពោះអល់ឡោះ ខណៈដែលពួកវាជាអ្នកដែលគោរពតាម(បទបញ្ជា)។

49. ហើយអ្វីៗដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលមាននៅលើផែនដីនៃពពួកសត្វ ព្រមទាំងបណ្ដាម៉ាឡាអ៊ីកាត់ទាំងឡាយ ពួកគេទាំងនោះក្រាបស៊ូជោតចំពោះអល់ឡោះជាម្ចាស់(តែមួយគត់) ហើយពួកគេមិនក្រអឺតក្រទមឡើយ។

50. ពួកគេខ្លាចព្រះជាម្ចាស់របស់ពួកគេដែលនៅខាងលើ និងគោរពតាមនូវអ្វីដែលគេបង្គាប់ប្រើពួកគេ។

51. ហើយអល់ឡោះទ្រង់បានមានបន្ទូលថា៖ ចូរពួកអ្នកកុំយកព្រះពីរមកគោរពសក្ការៈឱ្យសោះ។ តាមពិត ទ្រង់(អល់ឡោះ) គឺជាព្រះជាម្ចាស់តែមួយគត់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចមកចំពោះយើង(តែមួយគត់)។

52. ហើយអ្វីដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយការគោរពសក្ការៈដោយចិត្តស្មោះសជាប់ជានិច្ច គឺសម្រាប់ទ្រង់(តែមួយគត់)។ ដូចនេះ តើពួកអ្នកកោតខ្លាចអ្នកផ្សេងក្រៅពីអល់ឡោះឬ?

53. ហើយឧបការគុណដែលពួកអ្នក(ឱមនុស្សលោក)ទទួលបាន គឺមកពីអល់ឡោះ(តែមួយគត់)។ ក្រោយមក នៅពេលគ្រោះបានកើតឡើងចំពោះពួកអ្នក គឺពួកអ្នកបួងសួងអង្វរករទៅកាន់ទ្រង់។

54. ក្រោយមកទៀត នៅពេលដែលទ្រង់ដកយកគ្រោះទាំងនោះចេញពីពួកអ្នក ស្រាប់តែមួយក្រុមក្នុងចំណោមពួកអ្នកបែរជាធ្វើស្ដីរិកនឹងព្រះជាម្ចាស់របស់ពួកគេទៅវិញ។

55. ដើម្បីពួកគេរមិលគុណចំពោះអ្វីដែលយើងបានប្រទានដល់ពួកគេ។ ដូច្នេះ ចូរពួកអ្នកសោយសុខ(មួយរយៈពេលខ្លី)សិនចុះ។ ជាការពិតណាស់ ពួកអ្នកគង់តែនឹងដឹងជាមិនខាន។

56. ហើយពួកគេ(ពួកមុស្លរីគីន)បានរៀបចំសម្រាប់ពួក(ព្រះនានា)ដែលមិនដឹងអ្វីសោះនោះនូវចំណែកមួយពីលាភសក្ការៈដែលយើងបានប្រទានដល់ពួកគេ។ សូមស្បថនឹងអល់ឡោះថា៖ ពួកអ្នកពិតជានឹងត្រូវគេសួរអំពីអ្វីដែលពួកអ្នកបានប្រឌិតឡើងនេះជាមិនខាន។

57. ហើយពួកគេបានចាត់ទុកកូនស្រី ថាជាបុត្រីរបស់អល់ឡោះជាម្ចាស់។ ទ្រង់មហាស្អាតស្ដុ(ពីអ្វីដែលពួកគេចោទប្រកាន់)។ ហើយពួកគេចាត់ទុកអ្វី(កូនប្រុស)ដែលពួកគេពេញចិត្ត(ចង់បាន)នោះជារបស់ខ្លួនឯង។

58. ហើយនៅពេលដែលមានគេប្រាប់ដំណឹងដល់នរណាម្នាក់នៃពួកគេពីកំណើតកូនស្រី មុខរបស់គេប្រែទៅជាខ្មៅ ហើយរូបគេពោរពេញទៅដោយទុក្ខព្រួយ។

59. គេលាក់ខ្លួន(គេចមុខ)អំពីក្រុមរបស់ខ្លួនព្រោះតែដំណឹងអាក្រក់ដែលគេទទួលបាន។ (គេគិតក្នុងចិត្តថា៖) តើគេគួររក្សាទុកកូនស្រីនេះឱ្យអាប់ឱនដល់កិត្តិយស ឬក៏យកទៅកប់ក្នុងដី(ទាំងរស់)? តើពុំមែនទេឬអ្វីដែលពួកគេកំណត់នោះ គឺអាក្រក់បំផុត។

60. សម្រាប់ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក គឺមានលក្ខណៈសម្បត្តិអាក្រក់បំផុត។ តែសម្រាប់អល់ឡោះជាម្ចាស់វិញ ទ្រង់មានលក្ខណៈសម្បត្តិដ៏មហាខ្ពង់ខ្ពស់។ ហើយទ្រង់គឺមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

61. ហើយប្រសិនបើអល់ឡោះដាក់ទណ្ឌកម្មមនុស្សលោកដោយសារតែការបំពាន ទ្រង់នឹងមិនទុកឱ្យសត្វលោកណាមួយមានជីវិតរស់នៅលើផែនដីឡើយ។ ក៏ប៉ុន្តែ ទ្រង់ពន្យារពេលដល់ពួកគេរហូតដល់ពេលវេលាដែលត្រូវបានកំណត់។ ដូច្នេះ នៅពេលដែលអាយុកាលរបស់ពួកគេបានមកដល់ហើយនោះ គឺពួកគេមិនអាចសុំពន្យារពេលបានឡើយ ហើយក៏មិនអាចសុំឱ្យមកដល់មុនពេលកំណត់បានដែរ សូម្បីមួយវិនាទីក៏ដោយ។

62. ហើយពួកគេចាត់ទុកអ្វី(កូនស្រី)ដែលពួកគេស្អប់(មិនចង់បាន)នោះសម្រាប់អល់ឡោះទៅវិញ។ ហើយអណ្តាតរបស់ពួកគេបាននិយាយដោយកុហកថា៖ ពិតណាស់ ពួកគេនឹងទទួលបានលទ្ធផលដ៏ល្អប្រសើរ។ គ្មានការសង្ស័យឡើយដែលថា ពិតប្រាកដណាស់ សម្រាប់ពួកគេគឺភ្លើងនរក ហើយពិតណាស់ ពួកគេត្រូវបានគេបោះបង់ចោល។

63. សូមស្បថនឹងអល់ឡោះ! ជាការពិតណាស់យើងបានបញ្ជូនអ្នកនាំសារទៅកាន់ប្រជាជាតិជាច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ពេលនោះ ស្មែតនបានតុបតែងលម្អសម្រាប់ពួកគេនូវទង្វើ(អាក្រក់)របស់ពួកគេ។ ហើយវាជាអ្នកគាំពាររបស់ពួកគេក្នុងលោកិយនេះ។ ហើយនៅថ្ងៃបរលោក ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

64. ហើយយើងមិនបានបញ្ចុះគម្ពីរ(គួរអាន)ទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះឡើយ លើកលែងតែដើម្បីឱ្យអ្នកបញ្ជាក់ដល់ពួកគេចំពោះអ្វីដែលពួកគេបានខ្វែងគំនិតគ្នានៅក្នុងវា ព្រមទាំងជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់ក្រុមដែលមានជំនឿចំពោះអល់ឡោះ។

65. ហើយអល់ឡោះទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃ។ បន្ទាប់មក តាមរយៈទឹកភ្លៀងនេះ ទ្រង់បានធ្វើឱ្យដីរស់ឡើងវិញក្រោយពីវាស្ងួតហួតហែង។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តែងមួយសម្រាប់ក្រុមដែលស្តាប់ឮ(យកវាមកពិចារណា)។

66. ហើយពិតប្រាកដណាស់ ចំពោះសត្វពាហនៈ គឺជាមេរៀនមួយសម្រាប់ពួកអ្នក(មនុស្សលោក)។ យើងបានផ្តល់ឱ្យពួកអ្នកទទួលទានអំពីអ្វីដែលនៅក្នុងពោះរបស់វាដែលនៅរវាងលាមក និងឈាមនូវទឹកដោះដ៏បរិសុទ្ធ និងមានរសជាតិឆ្ងាញ់សម្រាប់អ្នកដែលទទួលទាន។

67. ហើយចំពោះផលានុផលនៃដើមល្មើ និងទំពាំងបាយជូរ ពួកអ្នកអាចយកវាមកចំរាញ់ចេញជាគ្រឿងស្រវឹង និងធ្វើជាចំណីអាហារដ៏ល្អ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាកស្តែងមួយសម្រាប់ក្រុមដែលឈ្វេងយល់។

68. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានបញ្ជូនសារទៅកាន់សត្វឃ្មុំថា៖ ចូរឯងតាំងសំបុកនានានៅតាមភ្នំ និងនៅតាមដើមឈើមួយចំនួន ក៏ដូចជានៅតាមដំបូលដែលមនុស្សសាងសង់។

69. ក្រោយមក ចូរឯងស៊ីអំពីផលានុផលទាំងឡាយ ហើយចូរឯងហោះហើរតាមផ្លូវនានារបស់ដែលព្រះជាម្ចាស់របស់ឯងបានបង្ហាញប្រាប់ដោយងាយស្រួលចុះ។ ទឹកឃ្មុំដែលចេញពីពោះរបស់វា គឺមានពណ៌ខុសៗគ្នា ដែលនៅក្នុងនោះ គឺជាឱសថព្យាបាលសម្រាប់មនុស្សលោក។ ពិតប្រាកដណាស់នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តែងមួយសម្រាប់ក្រុមដែលចេះគិតពិចារណា។

70. ហើយអល់ឡោះទ្រង់បានបង្កើតពួកអ្នក។ ក្រោយមក ទ្រង់ដកយកជីវិតរបស់ពួកអ្នក។ ហើយក្នុងចំណោមពួកអ្នក មានអ្នកដែលគេទុកអាយុជីវិតរហូតដល់ជំណាក់កាលអាក្រក់បំផុតនៃជីវិត (ចាស់ជរា) ដោយគេមិនដឹងនូវអ្វីដែលគេធ្លាប់បានដឹងពីមុននោះទេ (ព្រោះតែភាពវង្វេងវង្វាន់)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាមានអានុភាពបំផុត។

71. ហើយអល់ឡោះទ្រង់បានលើកតម្កើងមនុស្សមួយចំនួននៃពួកអ្នកឱ្យប្រសើរជាងគ្នាចំពោះលាភសក្ការៈ។ ចំពោះអ្នកដែលគេ (អល់ឡោះ) បានលើកតម្កើង ពួកគេមិនចង់ផ្តល់លាភសក្ការៈរបស់ខ្លួនឲ្យទៅខ្ញុំបម្រើដាច់ថ្លៃរបស់ពួកគេដើម្បីឱ្យខ្ញុំបម្រើដាច់ថ្លៃនោះមានភាពស្មើគ្នាជាមួយនឹងពួកគេ (ដែលជាចៅហ្វាយ) ឡើយ។ (ចុះហេតុអ្វីបានជាពួកគេពេញចិត្តចង់ឲ្យអល់ឡោះជាម្ចាស់មានភាពស្មើគ្នាជាមួយនឹងខ្ញុំបម្រើរបស់ទ្រង់?) ដូច្នេះ តើចំពោះឧបការគុណរបស់អល់ឡោះពួកគេមិលគុណឬ?

72. ហើយអល់ឡោះទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវគ្រឿយារបស់ពួកអ្នក (ឱមនុស្សលោក) ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកចេញពីគ្រឿយារបស់ពួកអ្នកនូវកូនចៅជាច្រើន ព្រមទាំងបានប្រទាននូវលាភសក្ការៈដល់ពួកអ្នកនូវចំណីអាហារដែលល្អៗ។ ដូច្នេះ តើចំពោះប្រការខុសឆ្គង (រូបបដិមា និងព្រះនានា) ពួកគេមានជំនឿតែចំពោះឧបការគុណរបស់អល់ឡោះ ពួកគេបែរជាមិលគុណឬ?

73. ហើយពួកគេគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះដែលពួកវាគ្មានសិទ្ធិផ្តល់លាភសក្ការៈអ្វីបន្តិចដល់ពួកគេទាំងពីលើមេឃជាច្រើនជាន់ និងនៅលើផែនដីនោះឡើយ ហើយពួកវាក៏គ្មានសមត្ថភាពនោះដែរ។

74. ហេតុនេះ ចូរពួកអ្នក (ឱមនុស្សលោក) កុំយកអល់ឡោះជាម្ចាស់ទៅប្រៀប (នឹងរូបបដិមាទាំងនោះ)។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុត តែពួកអ្នកវិញមិនដឹងអ្វីឡើយ។

75. អល់ឡោះជាម្ចាស់ទ្រង់លើកនូវឧទាហរណ៍មួយ គឺខ្ញុំបម្រើដាច់ថ្លៃម្នាក់ដែលនៅក្រោមការគ្រប់គ្រងរបស់គេ ដែលរូបគេ (ខ្ញុំបម្រើ) គ្មានលទ្ធភាពអ្វីបន្តិចឡើយ ហើយនិងអ្នកដែលយើងបានប្រទានដល់គេនូវលាភសក្ការៈដ៏ល្អប្រពៃអំពីយើងដោយគេអាចបរិច្ចាគវាទាំងដោយស្ងាត់កំបាំង និងដោយបើកចំហ។ តើអ្នកទាំងពីរមានភាពស្មើគ្នាដែរឬទេ? ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

76. ហើយអល់ឡោះជាម្ចាស់ទ្រង់បានលើកនូវឧទាហរណ៍ (មួយទៀត) គឺបុរសពីរនាក់ដោយម្នាក់ក្នុងចំណោមគេទាំងពីរ ជាមនុស្សគដែលគ្មានលទ្ធភាពធ្វើអ្វីឡើយ ហើយរូបគេគឺជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះអាណាព្យាបាលរបស់ខ្លួនថែមទៀត។ ទោះបីជាគេ (អាណាព្យាបាល) ប្រើជននោះឲ្យទៅទីណាក៏ដោយ ក៏រូបគេមិនដែលនាំមកវិញនូវប្រការល្អនោះដែរ។ តើមានភាពស្មើគ្នាដែរឬទេរវាងរូបគេ ហើយនិងអ្នកដែលប្រើ (មនុស្ស) ឱ្យប្រកាន់ខ្ជាប់នឹងភាពយុត្តិធម៌ ហើយរូបគេក៏ស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវដែរនោះ?

77. ហើយប្រការអាថ៌កំបាំងដែលមាននៅលើមេឃជាច្រើនជាន់និងនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ (តែមួយគត់)។ ហើយកិច្ចការនៃថ្ងៃបរលោកនោះ គឺ (នឹងមកដល់យ៉ាងឆាប់រហ័សបំផុត) ប្រៀបបាននឹងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ឬឆាប់ជាងនេះទៅទៀត។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

78. ហើយអល់ឡោះទ្រង់បានបញ្ចេញពួកអ្នក (ឱមនុស្សលោកទាំងឡាយ) ពីផ្ទៃម្តាយរបស់ពួកអ្នកដោយពួកអ្នកមិនដឹងអ្វីទាល់តែសោះ។ ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវការស្តាប់ឮ ការមើលឃើញ និងដួងចិត្ត (ចេះគិតពិចារណា) សង្ឃឹមថាពួកអ្នកនឹងដឹងគុណ (ចំពោះអល់ឡោះ)។

79. តើពួកគេ(ពួកមុស្ហរីគីន)មិនបានសម្លឹងមើលទៅកាន់សត្វបក្សីដែលហោះហើរយ៉ាងងាយស្រួលនៅលើអាកាសទេឬ? គ្មាននរណាអាចទប់វា(មិនឱ្យធ្លាក់)ក្រៅពីអល់ឡោះឡើយ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាកស្តុតាងសម្រាប់ក្រុមដែលមានជំនឿ។

80. ហើយអល់ឡោះជាម្ចាស់ទ្រង់បានបង្កើតចេញពីគេហដ្ឋានរបស់ពួកអ្នក ជាកន្លែងស្នាក់នៅ(និងសម្រាក)សម្រាប់ពួកអ្នក។ ហើយទ្រង់បានបង្កើតស្បែកសត្វពាហនៈសម្រាប់ពួកអ្នកធ្វើជាតង់ដែលវាស្រាលសម្រាប់ពួកអ្នក(ក្នុងការយកតាមខ្លួន)ក្នុងពេលធ្វើដំណើរ និង(ងាយស្រួលក្នុងការតម្លើង)នៅពេលដែលពួកអ្នកបោះទីតាំង។ ហើយទ្រង់ក៏បានបង្កើតសម្រាប់ពួកអ្នកផងដែរនូវរោមចៀម រោមសត្វអូដ្ឋ និងរោមសត្វពពែទាំងឡាយធ្វើជាគ្រឿងសង្ហារឹម និងជាគ្រឿងតុបតែងលម្អ(ដែលពួកអ្នកអាចប្រើប្រាស់វា)រហូតដល់ពេលកំណត់។

81. ហើយអល់ឡោះបានបង្កើតសម្រាប់ពួកអ្នកនូវអ្វីដែលផ្តល់ជាម្លប់ដល់ពួកគេអំពី(ដើមឈើ និងអ្វីផ្សេងទៀត)ដែលទ្រង់បានបង្កើត ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកអំពីភ្នំទាំងឡាយនូវរូងភ្នំ និងបានបង្កើតសម្រាប់ពួកអ្នកនូវសម្លៀកបំពាក់ដែលអាចការពារពួកអ្នកអំពីកម្តៅ(និងភាពត្រជាក់) ហើយនិងសម្លៀកបំពាក់(អាវក្រោះ)ដែលអាចការពារពួកអ្នកពីគ្រោះថ្នាក់(ក្នុងសមរភូមិ)។ ក៏ដូច្នោះដែរ ទ្រង់បានបំពេញនូវឧបការគុណរបស់ទ្រង់ដល់ពួកអ្នក សង្ឃឹមថាពួកអ្នកប្រគល់ខ្លួន(ចំពោះទ្រង់)។

82. តែប្រសិនបើពួកគេងាកចេញវិញ តាមពិត តួនាទីរបស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)គឺគ្រាន់តែផ្សព្វផ្សាយ(សារ)ដ៏ច្បាស់លាស់ប៉ុណ្ណោះ។

83. ពួកគេ(ពួកមុស្ហរីគីន)បានទទួលស្គាល់នូវឧបការគុណរបស់អល់ឡោះ(ភាពជាព្យាការីរបស់អ្នកនាំសារមូហាំម៉ាត់)។ ក្រោយមក ពួកគេបែរបេដិសេធចំពោះវាទៅវិញ។ ហើយភាគច្រើននៃពួកគេ គឺប្រឆាំង។

84. ហើយនៅថ្ងៃដែលយើងនឹងតែងតាំងពីរាល់ប្រជាជាតិនីមួយៗនូវ(អ្នកនាំសារម្នាក់ជា)សាក្សី។ បន្ទាប់មក គេនឹងមិនអនុញ្ញាតឱ្យពួកគ្មានជំនឿ(និយាយដោះសារ)ឡើយ ហើយពួកគេក៏មិនត្រូវបានគេសុំឱ្យវិលត្រឡប់(សារភាពកំហុសចំពោះអល់ឡោះ)នោះដែរ។

85. ហើយនៅពេលដែលពួកបំពានបានឃើញនូវទណ្ឌកម្ម ពេលនោះគេនឹងមិនបន្ធូរបន្ថយ(ទណ្ឌកម្ម)ចំពោះពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេល(ដាក់ទណ្ឌកម្ម)នោះដែរ។

86. ហើយនៅពេលដែលពួកធ្វើស៊ីរិកបានឃើញព្រះនានារបស់ពួកគេ ពួកគេនឹងនិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពួកទាំងនោះហើយជាព្រះនានារបស់ពួកយើងដែលពួកយើងធ្លាប់គោរពសក្ការៈចំពោះពួកវាផ្សេងពីព្រះអង្គនោះ។ ពេលនោះ ពួកវាក៏បានឆ្លើយតបទៅវិញថា៖ ពិតប្រាកដណាស់ ពួកអ្នកគឺជាពួកដែលភូតកុហក។

87. ហើយនៅថ្ងៃនោះ ពួកគេ(ពួកដែលធ្វើស៊ីរិក)បានប្រគល់ខ្លួនទៅចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយអ្វី(ព្រះនានា)ដែលពួកគេធ្លាប់បានប្រឌិតឡើងនោះបានបាត់បង់ចេញពីពួកគេ។

88. ពួកដែលប្រឆាំង(នឹងអល់ឡោះ) និងបានរារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះនោះ យើងនឹងបន្ថែមទណ្ឌកម្មផ្លួនៗលើពួកគេដោយសារតែពួកគេបានបង្កវិនាសកម្ម។

89. ហើយ(ចូរអ្នករំលឹក)នៅថ្ងៃដែលយើងនឹងតែងតាំងពីរាល់ប្រជាជាតិនីមួយៗនូវ(អ្នកនាំសារម្នាក់ជា)សាក្សីទៅលើពួកគេពីជាតិសាសន៍របស់ពួកគេផ្ទាល់។ ហើយយើងក៏នឹងនាំរូបអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មកធ្វើជាសាក្សីទៅលើអ្នកទាំងនោះផងដែរ។ ហើយយើងបានបញ្ចុះនូវគម្ពីរ(គួរអាន)ទៅកាន់អ្នកដើម្បីបញ្ជាក់រាល់អ្វីៗទាំងអស់ ជាការចង្អុលបង្ហាញ ជាក្តីមេត្តាករុណា និងជាដំណឹងរីករាយសម្រាប់បណ្តាអ្នកមូស្លីម។

90. ពិតប្រាកដណាស់ អល់ឡោះទ្រង់បង្គាប់ប្រើឲ្យប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ និងមានគុណធម៌ ហើយនិងបរិច្ចាគទានដល់សាច់ញាតិ ព្រមទាំងហាមឃាត់នូវទង្វើអសីលធម៌ អំពើទុច្ចរិត និងការបំពាន។ ទ្រង់ទូន្មានពួកអ្នក សង្ឃឹមថាពួកអ្នកនឹងនឹករលឹក។

91. ហើយចូរពួកអ្នកគោរពតាមកិច្ចសន្យារបស់អល់ឡោះដែលជាកាតព្វកិច្ចលើពួកអ្នក ហើយចូរពួកអ្នកកុំក្បត់នឹងពាក្យសម្បថទាំងឡាយក្រោយពីពួកអ្នកបានបញ្ជាក់វា(ស្បថ)ខណៈដែលពួកអ្នកបានយកអល់ឡោះធ្វើជាអ្នកធានាលើពួកអ្នកហើយនោះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

92. ហើយចូរពួកអ្នកកុំធ្វើខ្លួនឲ្យដូចជាស្ត្រីម្នាក់ដែលបានធ្វើឲ្យអំបោះហុងរបស់នាងខូច ក្រោយពីនាងបានរុំវាយ៉ាងណែនហើយនោះ។ ពួកអ្នកបានធ្វើឱ្យពាក្យសម្បថរបស់ពួកអ្នកក្លាយទៅជាការបោកប្រាស់គ្នារវាងពួកអ្នកដោយសារ(ពួកអ្នកឃើញថា)ក្រុមមួយ(ក្រុមរបស់ពួកអ្នក) មានភាពខ្លាំងក្លាជាងក្រុមមួយទៀត។ តាមពិត អល់ឡោះទ្រង់គ្រាន់តែសាកល្បងពួកអ្នកតាមរយៈវា(ការឲ្យគោរពតាមកិច្ចសន្យា)ប៉ុណ្ណោះ និងដើម្បីទ្រង់បញ្ជាក់ដល់ពួកអ្នកនៅថ្ងៃបរលោកចំពោះអ្វីដែលពួកអ្នកខ្វែងគំនិតគ្នានៅក្នុងវា។

93. ហើយប្រសិនបើអល់ឡោះទ្រង់មានចេតនា ទ្រង់ពិតជានឹងធ្វើឱ្យពួកអ្នកក្លាយជាប្រជាជាតិតែមួយជាមិនខាន។ ក៏ប៉ុន្តែទ្រង់ធ្វើឱ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនា និងចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ហើយពួកអ្នកពិតជានឹងត្រូវគេសួរអំពីអ្វីដែលពួកអ្នកធ្លាប់បានសាងមិនខានឡើយ។

94. ហើយចូរពួកអ្នកកុំធ្វើឲ្យពាក្យសម្បថរបស់ពួកអ្នកក្លាយជាការបោកប្រាស់គ្នារវាងពួកអ្នកដែលជាហេតុនឹងធ្វើឱ្យជើងរបស់ពួកអ្នកញ័រ(រអិលចេញពីមាគ៌ាត្រឹមត្រូវ)បន្ទាប់ពីវាមានលំនឹងហើយនោះ។ ហើយពួកអ្នកនឹងភ្លក់នូវទណ្ឌកម្មដោយសារតែពួកអ្នករារាំងអ្នកដទៃពីមាគ៌ារបស់អល់ឡោះ។ ហើយសម្រាប់ពួកអ្នកនឹងត្រូវទទួលនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

95. ហើយចូរពួកអ្នកកុំយកកិច្ចសន្យារបស់អល់ឡោះទៅប្តូរនឹងកម្រៃបន្តិចបន្តួចឱ្យសោះ។ តាមពិតអ្វីដែលមាននៅជាមួយអល់ឡោះគឺល្អប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង។

96. អ្វីដែលមាននៅជាមួយពួកអ្នកគឺនឹងបាត់បង់ទៅវិញ។ តែអ្វីដែលនៅជាមួយអល់ឡោះ គឺនៅគង់វង្សជានិច្ច។ ហើយយើងពិតជានឹងតបស្នងដល់បណ្តាអ្នកដែលអត់ធ្មត់នូវផលបុណ្យរបស់ពួកគេដែលល្អប្រសើរលើសពីអ្វីដែលពួកគេបានសាងទៅទៀត។

97. ជនណាដែលបានសាងទង្វើកុសលក្នុងចំណោមបុរសឬស្ត្រី ហើយគេជាអ្នកដែលមានជំនឿទៀតនោះ យើងពិតជានឹងផ្តល់ឲ្យគេនូវជីវិតរស់នៅដ៏ល្អប្រសើរ(ក្នុងលោកិយ)ហើយយើងពិតជានឹងតបស្នងដល់ពួកគេនូវផលបុណ្យរបស់ពួកគេ(នៅថ្ងៃបរលោក)ដែលល្អប្រសើរលើសពីអ្វីដែលពួកគេបានសាងទៅទៀត។

98. ហើយនៅពេលដែលអ្នក(ឱអ្នកមានជំនឿ)ចង់សូត្រគម្ពីរគួរអាន ចូរអ្នកបួងសួងសុំពីអល់ឡោះឱ្យបញ្ចៀសពីស្មែតនដែលត្រូវបានគេដាក់បណ្តាសា។

99. ពិតប្រាកដណាស់ វា(ស្មៃតន)គ្មានអំណាចអ្វីទៅលើបណ្តាអ្នកដែលមានជំនឿ ហើយបានប្រគល់ការទុកចិត្តទៅចំពោះព្រះជាម្ចាស់របស់ពួកគេនោះឡើយ។

100. តាមពិត អំណាចរបស់វាគឺមានតែទៅលើពួកដែលយកវាធ្វើជាអ្នកគាំពារ ហើយនិងពួកធ្វើស៊ីរិក(ព្រោះតែដើរតាមវា)ប៉ុណ្ណោះ។

101. ហើយនៅពេលដែលយើងបានផ្លាស់ប្តូរវាក្យខណ្ឌណាមួយ(នៃគម្ពីរគួរអាន)ដោយវាក្យខណ្ឌមួយផ្សេងទៀត ខណៈដែលទ្រង់ដឹងបំផុតនូវអ្វីដែលទ្រង់ត្រូវបញ្ចុះនោះ ពួកគ្មានជំនឿបែរជានិយាយថា៖ ពិតណាស់ អ្នក(ឱមូហាំម៉ាត់)គឺជាអ្នកប្រឌិតភូតកុហក(ទៅលើអល់ឡោះ)ទៅវិញ។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងនោះឡើយ។

102. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ម៉ាឡាអ៊ីកាត់ជីព្រីលបានចុះមកដោយនាំមកនូវគម្ពីរគួរអានពីព្រះជាម្ចាស់របស់អ្នកយ៉ាងពិតប្រាកដ ដើម្បីពង្រឹងដល់បណ្តាអ្នកដែលមានជំនឿ ជាការចង្អុលបង្ហាញ និងជាដំណឹងរីករាយដល់បណ្តាអ្នកមូស្លីម។

103. ហើយយើង(អល់ឡោះ)ដឹងថា ពិតណាស់ពួកគេ(ពួកមុស្រីគីន)នឹងនិយាយថា៖ "តាមពិតអ្នកដែលបង្រៀនគម្ពីរគួរអានដល់គាត់(ព្យាការីមូហាំម៉ាត់)នោះ គ្រាន់តែជាមនុស្សធម្មតាម្នាក់ប៉ុណ្ណោះ"។ ភាសារបស់អ្នកដែលពួកគេចោទថា មកបង្រៀនដល់គាត់នោះ គឺជាភាសាផ្សេងក្រៅពីភាសាអារ៉ាប់។ តែនេះ(គម្ពីរគួរអាន)គឺភាសាអារ៉ាប់យ៉ាងច្បាស់លាស់។

104. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿនឹងបណ្តាវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះនោះ គឺអល់ឡោះនឹងមិនចង្អុលបង្ហាញពួកគេឡើយ។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

105. តាមពិត អ្នកដែលប្រឌិតនូវការភូតកុហកនោះ គឺពួកដែលមិនមានជំនឿចំពោះបណ្តាវាក្យខណ្ឌរបស់អល់ឡោះនោះឯង។ ពួកទាំងនោះហើយ គឺជាពួកដែលភូតកុហក។

106. ជនណាដែលគ្មានជំនឿនឹងអល់ឡោះក្រោយពីមានជំនឿហើយនោះ (គេនឹងទទួលការខឹងសម្បាពីអល់ឡោះ) លើកលែងតែអ្នកដែលត្រូវបានគេគាបសង្កត់ ទាំងដែលចិត្តរបស់គេវិញនៅនឹងនរលើសេចក្តីជំនឿប៉ុណ្ណោះ។ ក៏ប៉ុន្តែ ជនណាដែលបើកចិត្តទទួលយកភាពគ្មានជំនឿនោះ ពួកគេនឹងទទួលនូវការខឹងសម្បាពីអល់ឡោះ ហើយសម្រាប់ពួកគេ គឺនឹងទទួលនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

107. នោះគឺដោយសារតែពួកគេពេញចិត្តជីវិតលោកិយជាងថ្ងៃបរលោក។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់មិនចង្អុលបង្ហាញក្រុមដែលគ្មានជំនឿឡើយ។

108. ពួកទាំងនោះហើយជាពួកដែលអល់ឡោះជាម្ចាស់ទ្រង់បោះត្រាក្លិតលើដួងចិត្ត ការស្តាប់ឮ និងការមើលឃើញរបស់ពួកគេ។ ហើយពួកទាំងនោះហើយ គឺជាពួកដែលព្រងើយកន្តើយ។

109. គ្មានការសង្ស័យឡើយដែលថា ពិតណាស់ពួកគេនៅថ្ងៃបរលោក គឺជាពួកដែលខាតបង់។

110. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ចំពោះបណ្តាអ្នកដែលបានធ្វើចំណាកស្រុក(ពីក្រុងម៉ាក្កៈទៅកាន់ក្រុងម៉ាទីណៈ) ក្រោយពីពួកគេត្រូវបានគេសាកល្បង បន្ទាប់មក ពួកគេបានតស៊ូ និងបានអត់ធ្មត់នោះ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក បន្ទាប់ពីរឿងទាំងនោះ គឺមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

111. (ចូររំលឹកពួកគេ) នៅថ្ងៃដែលបុគ្គលគ្រប់រូបឈ្លោះប្រកែកចំពោះខ្លួនឯង។ ហើយបុគ្គលគ្រប់រូបនឹងត្រូវបានគេតបស្នងយ៉ាងពេញលេញនូវអ្វីដែលគេបានប្រព្រឹត្តដោយពួកគេមិនត្រូវបានគេបំពានឡើយ។

112. ហើយអល់ឡោះទ្រង់បានលើកយកឧទាហរណ៍នូវភូមិស្រុកមួយ(ក្រុងម៉ាក្កៈ) ដែលធ្លាប់មានសុខសន្តិភាព និងជីវភាពសមរម្យដោយលាភសក្ការៈផ្សេងៗបានមកដល់វា(ក្រុងម៉ាក្កៈ)យ៉ាងងាយស្រួលពីគ្រប់ទីកន្លែង។ តែពួកគេបានមិលគុណចំពោះឧបការគុណរបស់អល់ឡោះទៅវិញ។ ពេលនោះ អល់ឡោះជាម្ចាស់ក៏បានឱ្យពួកគេភ្លក់រសជាតិនៃភាពអត់ឃ្លាន និងភាពភ័យខ្លាច ដោយសារតែអ្វីដែលពួកគេបានសាង។

113. ហើយពិតប្រាកដណាស់ អ្នកនាំសារម្នាក់ដែលចេញពីចំណោមពួកគេ(អ្នកស្រុកម៉ាក្កៈ)បានមកដល់ពួកគេ ក៏ប៉ុន្តែពួកគេបានបដិសេធចំពោះគាត់។ ដូច្នេះ ទ្រង់ក៏បានដាក់ទណ្ឌកម្មពួកគេ ខណៈដែលពួកគេ គឺជាពួកដែលបំពាន។

114. ហេតុនេះ ចូរពួកអ្នក(ឱខ្ញុំបម្រើរបស់អល់ឡោះ)ទទួលទានចុះអំពីចំណីអាហារដែលគេអនុញ្ញាត(ហាឡាល់) ស្អាតស្អំដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកអ្នក។ ហើយចូរពួកអ្នកដឹងគុណចំពោះឧបការគុណរបស់អល់ឡោះ ប្រសិនបើពួកអ្នកគោរពសក្ការៈចំពោះទ្រង់(តែមួយគត់)មែននោះ។

115. តាមពិត ទ្រង់បានដាក់បម្រាមទៅលើពួកអ្នកមិនឱ្យទទួលទានសត្វស្លាប់(ដែលពុំបានសំឡេះត្រឹមត្រូវតាមច្បាប់អ៊ីស្លាម) ឈាម សាច់ជ្រូក ហើយនិងអ្វីដែលគេសំឡេះ(ជាតង្វាយ)សម្រាប់អ្នកផ្សេងក្រៅពីអល់ឡោះ។ តែប្រសិនបើជនណាត្រូវបានគេបង្ខំ(ឱ្យទទួលទានអាហារទាំងនេះ) ដោយគេពុំមែនជាអ្នកដែលបំពាន ហើយក៏ពុំមែនជាអ្នករំលងព្រំដែន(នៃតម្រូវការចាំបាច់របស់ខ្លួន)ដែរនោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះរូបគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោសមហាអាណិតស្រលាញ់បំផុត។

116. ហើយចូរពួកអ្នក(ឱពួកមុស្លីគីន)កុំនិយាយនូវអ្វីដែលអណ្តាតរបស់ពួកអ្នកពិពណ៌នាដោយភូតកុហកថា៖ អាហារនេះគេអនុញ្ញាត(ឱ្យទទួលទាន) ហើយអាហារនេះគេមិនអនុញ្ញាត ដើម្បីប្រឌិតនូវពាក្យភូតកុហកទៅលើអល់ឡោះឲ្យសោះ។ ពិតប្រាកដណាស់ ពួកដែលប្រឌិតនូវពាក្យភូតកុហកទៅលើអល់ឡោះនោះនឹងមិនទទួលបានជោគជ័យឡើយ។

117. (ពួកគេទទួលបាន)ការសប្បាយរីករាយក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ។ ហើយ(ថ្ងៃបរលោក) ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងឈឺចាប់បំផុត។

118. ហើយចំពោះពួកយូដា យើងបានហាមឃាត់ចំពោះពួកគេនូវអ្វីដែលយើងបាននិទានប្រាប់អ្នកកាលពីមុន(គឺដូចមាននៅក្នុងវាក្យខណ្ឌទី១៤៦ នៃជំពូកអាល់អានអាម)។ ហើយយើងមិនបានបំពានលើពួកគេឡើយ ក៏ប៉ុន្តែពួកគេទៅវិញទេដែលបានបំពានលើខ្លួនឯង។

119. បន្ទាប់មក ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ចំពោះបណ្តាអ្នកដែលបានសាងអំពើអាក្រក់ដោយល្ងង់ខ្លៅ ក្រោយមក ពួកគេបានសារភាពកំហុស និងបានកែខ្លួនបន្ទាប់ពីនោះ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក បន្ទាប់ពីរឿងទាំងនោះ គឺមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

120. ជាការពិតណាស់ ព្យាការីអ៊ីព្រហ៊ីម គឺជាអ្នកដឹកនាំ(ទៅកាន់ប្រការល្អ) ជាអ្នកដែលគោរពប្រតិបត្តិចំពោះអល់ឡោះ និងជាអ្នកដែលស្មោះសចំពោះសាសនា ហើយគាត់មិនស្ថិតក្នុងចំណោមអ្នកដែលធ្វើស៊ីរិកឡើយ។

121. ហើយគាត់ជាអ្នកដែលដឹងគុណចំពោះឧបការគុណរបស់ទ្រង់។ ទ្រង់បានជ្រើសរើសគាត់(ធ្វើជាព្យាការី) និងបានចង្អុលបង្ហាញគាត់ទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

122. ហើយយើងបានប្រទានដល់គាត់នូវប្រការល្អនៅក្នុងលោកិយនេះ។ ហើយពិតប្រាកដណាស់ នៅថ្ងៃបរលោក គាត់នឹងស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

123. ក្រោយមក យើងបានផ្តល់វ៉ាហ៊ីដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ថាៈ ចូរអ្នកដើរតាមសាសនារបស់ព្យាការីអ៊ីព្រហ៊ីមដ៏ស្មោះស។ ហើយគាត់(ព្យាការីអ៊ីព្រហ៊ីម)មិនស្ថិតក្នុងចំណោមអ្នកដែលធ្វើស្ហ៊ីរិកឡើយ។

124. តាមពិត គេបានចាត់ទុក(ការលើកតម្កើង)ថ្ងៃសៅរ៍ គឺជាកាតព្វកិច្ចទៅលើពួក(យូដា)ដែលបានខ្វែងគំនិតគ្នានៅក្នុងវា។ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងកាត់សេចក្តីរវាងពួកគេនៅថ្ងៃបរលោកចំពោះអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នាចំពោះវា។

125. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពាវនាវទៅកាន់មាគ៌ានៃព្រះជាម្ចាស់របស់អ្នក(សាសនាអ៊ីស្លាម)ដោយគតិបណ្ឌិត និងការណែនាំដែលល្អ។ ហើយចូរអ្នកជជែកវែកញែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់ដឹងបំផុតចំពោះជនណាដែលងេងចេញពីមាគ៌ារបស់ទ្រង់ ហើយទ្រង់ក៏ដឹងបំផុតផងដែរចំពោះបណ្តាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

126. ហើយប្រសិនបើពួកអ្នកចង់ដាក់ទោសពួកគេ(សត្រូវ) ចូរពួកអ្នកដាក់ទោស(ពួកគេ)ដូចអ្វីដែលគេបានប្រព្រឹត្តមកលើពួកអ្នក។ តែប្រសិនបើពួកអ្នកអត់ធ្មត់(មិនសងសឹក) វាពិតជាប្រសើរបំផុតសម្រាប់បណ្តាអ្នកដែលអត់ធ្មត់។

127. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះ ហើយការអត់ធ្មត់របស់អ្នក គឺគ្មានអ្វីក្រៅពីការជួយពីអល់ឡោះដល់អ្នក។ ហើយចូរអ្នកកុំមានទុក្ខព្រួយចំពោះពួកគេ និងកុំព្រួយបារម្ភ ដោយសារតែល្បិចកលដែលពួកគេរៀបចំឲ្យសោះ។

128. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នៅជាមួយបណ្តាអ្នកដែលកោតខ្លាច(ទ្រង់) ហើយនិង(នៅជាមួយ)បណ្តាអ្នកដែលសាងអំពើល្អទាំងឡាយ។

ជំពូក អាល់អ៊ុសរ៉ែក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អល់ឡោះមហាស្អាតស្អំដែលបានឲ្យខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ធ្វើដំណើរនាពេលយប់ចេញពីម៉ាស្ជិទអាល់ហារ៉ែម(ទីក្រុងម៉ាក្កះ)ទៅកាន់ម៉ាស្ជិទអាល់អឹកសរ(ក្រុងយេរូសាឡឹម) ដែលយើង(អល់ឡោះ)បានប្រទានពរជ័យនៅជុំវិញវា(ម៉ាស្ជិទអាល់អឹកសរ)ដើម្បីបង្ហាញឲ្យគេ(ព្យាការីមូហាំម៉ាត់)បានឃើញនូវសញ្ញាកសុតាងទាំងឡាយរបស់យើង។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាឃើញបំផុត។

2. ហើយយើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត) និងបានចាត់ទុកវាជាការចង្អុលបង្ហាញដល់អម្បូរអ៊ីស្រាអែល(ដោយយើងបានហាមឃាត់ថា៖) ពួកអ្នកមិនត្រូវយកអ្នកផ្សេងក្រៅពីយើងធ្វើជាអ្នកគាំពារឡើយ។

3. ឱពូជអម្បូរដែលយើងបានសង្គ្រោះជាមួយនឹងព្យាការីនួហ! (ចូរពួកអ្នកយកគំរូតាមព្យាការីនួហចុះ។) ពិតប្រាកដណាស់ គាត់គឺជាខ្ញុំបម្រើម្នាក់ដែលដឹងគុណ(អល់ឡោះ)បំផុត។

4. ហើយយើងបានប្រាប់ដល់អម្បូរអ៊ីស្រាអែលនៅក្នុងគម្ពីរតាវ៉ាតថា៖ ពិតប្រាកដណាស់ ពួកអ្នកប្រាកដជានឹងបង្កវិនាសកម្មនៅលើផែនដីនេះចំនួនពីរដង ហើយពួកអ្នកពិតជាបំពានហួសព្រំដែនយ៉ាងខ្លាំងបំផុត។

5. ហើយនៅពេលដែលការបង្កវិនាសកម្មលើកទីមួយបានកើតឡើង យើងបានចាត់តាំងបណ្តាខ្ញុំបម្រើរបស់យើងដែលជាក្រុមខ្លាំងពូកែបំផុតនោះគ្រប់គ្រងទៅលើពួកអ្នក ហើយពួកគេបានចូលលុកលុយនៅចន្លោះលំនៅឋាន(របស់ពួកអ្នក)។ ហើយការសន្យា(របស់អល់ឡោះ) គឺពិតជាកើតឡើងយ៉ាងពិតប្រាកដ។

6. ក្រោយមក យើងបានត្រឡប់មកឱ្យពួកអ្នក(ឱអម្បូរអ៊ីស្រាអែល)នូវជ័យជម្នះទៅលើពួកគេវិញ។ ហើយយើងបានបន្ថែមឱ្យពួកអ្នកនូវទ្រព្យសម្បត្តិ និងកូនចៅ ព្រមទាំងបានធ្វើឱ្យពួកអ្នកមានធនធានច្រើនជាង(សត្រូវរបស់ពួកអ្នក)ថែមទៀត។

7. ប្រសិនបើពួកអ្នក(ឱអម្បូរអ៊ីស្រាអែល)សាងអំពើល្អ ផលនៃអំពើល្អនោះគឺសម្រាប់ខ្លួនពួកអ្នកផ្ទាល់។ ហើយប្រសិនបើពួកអ្នកបានសាងអំពើអាក្រក់ ផលអាក្រក់នោះក៏សម្រាប់ខ្លួនពួកអ្នកវិញដូចគ្នា។ ហើយនៅពេលដែលការបង្កវិនាសលើកទីពីរកើតឡើង (យើងក៏បានឱ្យសត្រូវរបស់ពួកអ្នកគ្រប់គ្រងទៅលើពួកអ្នកម្តងទៀត) ដើម្បីពួកគេធ្វើឱ្យពួកអ្នកអាម៉ាស់មុខ និងដើម្បីឱ្យពួកគេចូលក្នុងវិហារដូចដែលពួកគេបានចូលទៅក្នុងវាកាលពីលើកដំបូង(លើកទីមួយ) ព្រមទាំងដើម្បីពួកគេបំផ្លាញខ្ទេចខ្ទីនូវអ្វីដែលពួកគេបានត្រួតត្រា។

8. សង្ឃឹមថាព្រះជាម្ចាស់របស់ពួកអ្នក(ឱអម្បូរអ៊ីស្រាអែល)នឹងអាណិតស្រលាញ់ពួកអ្នក។ តែប្រសិនបើពួកអ្នកត្រឡប់ទៅ(បង្កវិនាសកម្ម)ម្តងទៀត យើងក៏នឹងត្រឡប់ទៅ(ដាក់ទោសពួកអ្នក)វិញដែរ។ ហើយយើងបានបង្កើតនរកជើហាន់ណាំជាកន្លែងឃុំឃាំងសម្រាប់ពួកដែលប្រឆាំង។

9. ពិតប្រាកដណាស់ គម្ពីរគួរអាននេះចង្អុលបង្ហាញ(មនុស្ស)ទៅរកមាគ៌ាដ៏ល្អត្រឹមត្រូវបំផុត(សាសនាអ៊ីស្លាម) និងផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលបានសាងនូវទង្វើកុសលថា ជាការពិតណាស់ សម្រាប់ពួកគេនឹងទទួលនូវផលបុណ្យដ៏ធំធេង។

10. ហើយជាការពិតណាស់ ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោកវិញ យើងបានត្រៀមទុកសម្រាប់ពួកគេនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត(នៅថ្ងៃបរលោក)។

11. ហើយមនុស្សលោកបួងសួងសុំឲ្យទទួលបាននូវប្រការអាក្រក់(នៅពេលដែលគេមានកំហឹង)ដូចជាការដែលគេបួងសួងសុំឲ្យទទួលបាននូវប្រការល្អដែរ។ ពិតប្រាកដណាស់ មនុស្សលោក គឺមានចរិតតក់ក្រហល់។

12. ហើយយើងបានបង្កើតពេលយប់និងពេលថ្ងៃជាសញ្ញាពីរ។ ក្រោយមក យើងបានធ្វើឲ្យសញ្ញានៃពេលយប់(គឺភាពងងឹត)ហើយបានធ្វើឲ្យសញ្ញានៃពេលថ្ងៃ គឺពន្លឺ ដើម្បីពួកអ្នកស្វែងរកការប្រោសប្រទាន(លាភសក្ការៈ)ពីព្រះជាម្ចាស់របស់ពួកអ្នក និងដើម្បីឲ្យពួកអ្នកបានដឹងពីចំនួនឆ្នាំ និងការគណនា(ពេលវេលា)។ ហើយរាល់អ្វីៗទាំងអស់ យើងបានបញ្ជាក់វាយ៉ាងលម្អិត។

13. ហើយមនុស្សគ្រប់រូបយើងបានឱ្យទង្វើរបស់គេនៅជាប់នឹងក(ប្រៀបដូចខ្សែកនៅជាប់នឹងក)របស់គេជានិច្ច។ ហើយយើងនឹងបញ្ចេញឱ្យគេនៅថ្ងៃបរលោកនូវសៀវភៅកំណត់ត្រាមួយដែលគេនឹងឃើញវាត្រូវបានបើកចំហ(នៅពីមុខគេ)។

14. (យើងមានបន្ទូលទៅកាន់គេថា៖)ចូរអ្នកអានសៀវភៅកំណត់ត្រារបស់អ្នកចុះ។ គ្រប់គ្រាន់ហើយនៅទីនេះ(ថ្ងៃបរលោក)ដោយរូបអ្នកផ្ទាល់គឺជាអ្នកគណនាចំពោះខ្លួនឯងនោះ។

15. ជនណាហើយដែលទទួលបានការចង្អុលបង្ហាញ តាមពិតការចង្អុលបង្ហាញនោះគឺសម្រាប់ខ្លួនគេផ្ទាល់។ ហើយជនណាដែលបានវង្វេង តាមពិត ការវង្វេងនោះ ក៏សម្រាប់ខ្លួនគេផ្ទាល់ដែរ។ គ្មានបុគ្គលណាម្នាក់ប៉ាប៉ងរងនូវបាបកម្មរបស់អ្នកដទៃឡើយ។ ហើយយើងមិនដែលដាក់ទណ្ឌកម្ម(លើក្រុមណាមួយឡើយ)លុះត្រាតែយើងបានតែងតាំងអ្នកនាំសារ(ទៅកាន់ពួកគេ)ជាមុនសិន។

16. ហើយនៅពេលដែលយើងមានចេតនាបំផ្លាញភូមិស្រុកណាមួយ យើងបានបញ្ជាឱ្យអ្នកដែលទទួលបានឧបការគុណច្រើន(អំពីយើងឲ្យគោរពប្រតិបត្តិមកចំពោះយើង)តែពួកគេបែរជាប្រឆាំងទៅវិញ។ ដូច្នេះ ពាក្យសម្តី(ដាក់ទណ្ឌកម្មពួកគេ)ក៏បានកើតឡើងយ៉ាងពិតប្រាកដ។ ពេលនោះ យើងក៏បានបំផ្លាញពួកគេឱ្យវិនាសសាបសូន្យ។

17. ហើយមានប្រជាជាតិជាច្រើនដែលយើងបានបំផ្លាញពួកគេបន្ទាប់ពីព្យាការីនូហ។ គ្រប់គ្រាន់ហើយដែលព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាអ្នកដែលដឹង និងឃើញបំផុតចំពោះបាបកម្មនៃខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

18. ជនណាហើយដែលប្រាថ្នាចង់បានជីវិតលោកិយ យើងនឹងផ្តល់ឱ្យគេភ្លាមៗនៅក្នុងវា(លោកិយ)នូវអ្វីដែលយើងមានចេតនាសម្រាប់ជនណាដែលយើងចង់(ផ្តល់ឲ្យ)។ ក្រោយមក យើងបានរៀបចំនរកដើហាន់ណាំសម្រាប់គេ ដែលគេនឹងចូលទៅក្នុងវា(នៅថ្ងៃបរលោក)ដោយទទួលនូវការស្តីបន្ទោស និងត្រូវបានគេបណ្តេញ(ពីក្តីមេត្តាករុណារបស់អល់ឡោះ)។

19. រីឯជនណាហើយដែលប្រាថ្នាចង់ទទួលបានថ្ងៃបរលោក ហើយគេបានតស៊ូប្រឹងប្រែងដើម្បីវា ហើយគេជាអ្នកដែលមានជំនឿទៀតនោះ ពិតណាស់ អ្នកទាំងនោះហើយដែលការខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានគេទទួលយក។

20. យើងនឹងបន្ថែមឱ្យក្រុមនីមួយៗក្នុងចំណោមពួកគេនូវលាភសក្ការៈពីព្រះជាម្ចាស់របស់អ្នក(ក្នុងលោកិយ)។ ហើយលាភសក្ការៈនៃព្រះជាម្ចាស់របស់អ្នក គឺមិនត្រូវបានគេរារាំង(ពីនរណាម្នាក់)ឡើយ។

21. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះ ថាតើយើងបានលើកតម្កើងពួកគេឱ្យមានភាពប្រសើរជាងគ្នាយ៉ាងដូចម្តេច(ក្នុងលោកិយនេះ)? ហើយនៅថ្ងៃបរលោកវិញ ពួកគេរឹតតែមានភាពខុសគ្នាខ្លាំងបំផុតទាំងហានៈ និងភាពល្អប្រសើរ។

22. ចូរអ្នក(ឱខ្ញុំបម្រើរបស់អល់ឡោះ)កុំបង្កើតព្រះផ្សេង(មកគោរពសក្ការៈ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ឱ្យសោះ ដែលជាហេតុនាំឱ្យអ្នកទទួលរងនូវការស្តីបន្ទោស និងភាពបរាជ័យ។

23. ហើយព្រះជាម្ចាស់របស់អ្នក(ឱខ្ញុំបម្រើរបស់អល់ឡោះ)បានដាក់បទបញ្ជាមិនឲ្យពួកអ្នកគោរពសក្ការៈឡើយ លើកលែងតែចំពោះទ្រង់(តែមួយគត់) និងត្រូវធ្វើល្អចំពោះឪពុកម្តាយ។ ប្រសិនបើម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរ ឬគាត់ទាំងពីរមានវ័យចាស់ជរារស់នៅជាមួយអ្នក គឺអ្នកមិនត្រូវនិយាយពាក្យសម្តីមិនសមរម្យដាក់គាត់ទាំងពីរឡើយ ហើយក៏មិនត្រូវប្រើសម្តីធ្ងន់ដាក់គាត់ទាំងពីរនោះដែរ។ តែអ្នកត្រូវនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសម្តីដែលល្អប្រពៃ(ទន់ភ្លន់)។

24. ហើយចូរអ្នកបន្ទាបខ្លួនចំពោះគាត់ទាំងពីរដោយការឱនលំទោនប្រកបដោយក្តីមេត្តាករុណា។ ហើយចូរអ្នកបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាអាណិតស្រលាញ់ដល់លោកទាំងពីរដូចដែលលោកទាំងពីរបានចិញ្ចឹមបីបាច់ខ្ញុំកាលខ្ញុំនៅតូចផងចុះ។

25. ព្រះជាម្ចាស់របស់ពួកអ្នក(ឱមនុស្សលោក)ដឹងបំផុតនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកអ្នក។ ប្រសិនបើពួកអ្នកជាមនុស្សល្អ គឺទ្រង់មហាអភ័យទោសបំផុតចំពោះអ្នកដែលវិលត្រឡប់(សារភាពកំហុស)ទៅកាន់ទ្រង់។

26. ហើយចូរអ្នក(ឱអ្នកដែលមានជំនឿ)ផ្តល់ឱ្យញាតិសន្តាន ជនក្រីក្រ និងអ្នកដំណើរដែលដាច់ស្បៀងនូវសិទ្ធិរបស់គេ។ ហើយចូរអ្នកកុំខ្ជះខ្ជាយឱ្យសោះ។

27. ពិតប្រាកដណាស់ អ្នកដែលខ្ជះខ្ជាយនោះ ពួកគេជាបងប្អូនរបស់ពួកស្តែន។ ហើយស្តែន គឺជាអ្នកដែលប្រឆាំងនឹងព្រះជាម្ចាស់របស់វា។

28. ហើយប្រសិនបើអ្នក(ព្យាការីមូហាំម៉ាត់)បែរចេញអំពីពួកគេ(មិនផ្តល់ការបរិច្ចាគ)ដោយរង់ចាំក្តីមេត្តា(លាភសក្ការៈ)ពីព្រះជាម្ចាស់របស់អ្នកដែលអ្នករំពឹងចំពោះវានោះ ដូច្នេះ ចូរអ្នកពោលទៅកាន់ពួកគេនូវសម្តីដែលទន់ភ្លន់បំផុត។

29. ហើយចូរអ្នកកុំក្តាប់ដៃរបស់អ្នកពាក់ទៅនឹងក(កំណាញ់ក្នុងការចំណាយលើផ្លូវល្អ) ហើយក៏មិនត្រូវលាដៃហួសហេតុ(ចំណាយខ្ជះខ្ជាយ)នោះដែរ ដែលជាហេតុធ្វើឱ្យអ្នកទទួលនូវការស្តីបន្ទោស និងអស់អ្វីពីខ្លួន(សម្រាប់ចំណាយ)។

30. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់បើកទូលាយនូវលាភសក្ការៈចំពោះជនណាដែលទ្រង់មានចេតនា និងត្បិតត្បៀតវា(ចំពោះជនណាដែលទ្រង់មានចេតនា)។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកដឹង និងឃើញបំផុតចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

31. ហើយពួកអ្នកមិនត្រូវសម្លាប់កូនចៅរបស់ខ្លួនព្រោះតែខ្លាចក្រនោះឡើយ។ យើងទេដែលជាអ្នកប្រទានលាភសក្ការៈដល់ពួកគេ និងដល់ពួកអ្នកនោះ។ ពិតប្រាកដណាស់ ការសម្លាប់ពួកគេ គឺជាបាបកម្មមួយដ៏ធំបំផុត។

32. ហើយពួកអ្នកមិនត្រូវទៅក្បែរប្រការហ្ស៊ីណាឡើយ។ ពិតប្រាកដណាស់ វាជាទង្វើអសីលធម៌ និងជាមាគ៌ាដ៏អាក្រក់បំផុត។

33. ហើយពួកអ្នកមិនត្រូវសម្លាប់ជីវិតដែលអល់ឡោះដាក់បម្រាមនោះឡើយ លើកលែងតែមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ។ ហើយជនណាដែលត្រូវបានគេសម្លាប់ដោយបំពាននោះ ជាការពិតណាស់ យើងប្រគល់ឱ្យអ្នកដែលគ្រប់គ្រងចំពោះកិច្ចការរបស់គេ(ជនរងគ្រោះ)នូវសិទ្ធិចាត់ចែង(ចំពោះឃាតករ)។ ដូចនេះ គេ(ភាគីជនរងគ្រោះ)មិនត្រូវបំពានព្រំដែនលើអំពើឃាតកម្មនោះឡើយ។ ពិតប្រាកដណាស់ ភាគីជនរងគ្រោះ គឺត្រូវបានគេជួយការពារ។

34. ហើយពួកអ្នកមិនត្រូវចាត់ចែងទ្រព្យសម្បត្តិក្មេងកំព្រា(កំព្រាឪពុក)នោះឡើយ លើកលែងតែទៅលើប្រការដែលល្អ(ជាផលប្រយោជន៍ដល់ក្មេងកំព្រានោះ)ប៉ុណ្ណោះ រហូតដល់គេធំដឹងក្តី។ ហើយពួកអ្នកត្រូវគោរពតាមកិច្ចសន្យា។ ពិតប្រាកដណាស់ កិច្ចសន្យានោះនឹងត្រូវគេសួរនាំ(នៅថ្ងៃបរលោក)។

35. ហើយចូរពួកអ្នកបំពេញនូវការវាល់ឱ្យបានគ្រប់នៅពេលដែលពួកអ្នកវាល់ឱ្យអ្នកដទៃ ហើយត្រូវថ្លឹងនឹងជញ្ជីងដែលមានភាពសុក្រឹតត្រឹមត្រូវ។ នោះគឺជាការល្អ និងប្រសើរបំផុតសម្រាប់លទ្ធផលចុងក្រោយ(នាថ្ងៃបរលោក)។

36. ហើយអ្នក(ឱមនុស្សលោក)កុំប្រតិបត្តិតាមអ្វីដែលអ្នកគ្មានចំណេះដឹងអំពីវាឲ្យសោះ។ ពិតប្រាកដណាស់ ការស្តាប់ឮ ការមើលឃើញ និងដួងចិត្ត ទាំងអស់នោះ នឹងត្រូវបានគេសួរ(ចំពោះការប្រើប្រាស់វា)។

37. ហើយអ្នកមិនត្រូវដើរនៅលើផែនដីនេះដោយក្រអឺតក្រទមឡើយ។ ពិតប្រាកដណាស់ អ្នកមិនអាចពុះបំបែកផែនដី(នឹងដំណើរដើរបស់អ្នក)នោះឡើយ ហើយអ្នកក៏មិនខ្ពស់ដល់ភ្នំនោះដែរ។

38. រាល់ប្រការទាំងនោះ សុទ្ធតែជាប្រការអាក្រក់ចំពោះព្រះជាម្ចាស់របស់អ្នក(ឱមនុស្សលោក)ដែលត្រូវបានទ្រង់ស្អប់ខ្ពើម។

39. ទាំងអស់នោះ គឺជាគតិបណ្ឌិតដែលព្រះជាម្ចាស់របស់អ្នកបានផ្តល់វាហ៊ីមកឱ្យអ្នក។ ហើយអ្នក(ឱមនុស្សលោក)កុំយកព្រះផ្សេងមកគោរពសក្ការៈរួមជាមួយនឹងអល់ឡោះជាម្ចាស់ឱ្យសោះ ដែលជាហេតុនាំឱ្យខ្លួនអ្នកត្រូវគេបោះចូលទៅក្នុងនរកដើហាន់ណាំដោយត្រូវគេស្តីបន្ទោស និងត្រូវបានគេបណ្តេញ(ឱ្យឃ្លាតឆ្ងាយពីប្រការល្អទាំងឡាយ)។

40. តើសក្តិសមដៃឬទេដែលថា ព្រះជាម្ចាស់របស់ពួកអ្នក(ឱពួកមុស្លីគីន)បានជ្រើសរើសកូនប្រុសសម្រាប់ពួកអ្នក ហើយទ្រង់ជ្រើសយកម៉ាឡាអ៊ីកាត់ធ្វើជាបុត្រី(សម្រាប់ទ្រង់)នោះ? ពិតប្រាកដណាស់ ពួកអ្នកកំពុងតែនិយាយនូវពាក្យចោទប្រកាន់យ៉ាងធ្ងន់ធ្ងរបំផុត។

41. ហើយជាការពិតណាស់ យើងបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគម្ពីរគួរអាននេះ(នូវក្បួនច្បាប់ ដំបូន្មាន និងឧទាហរណ៍ជាច្រើន)ដើម្បីឱ្យពួកគេ(មនុស្សលោក)នឹករលឹក។ តែវាមិនបានបន្ថែមអ្វីដល់ពួកគេ ក្រៅពីការឃ្លាតឆ្ងាយ(ពីការពិត)នោះឡើយ។

42. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ប្រសិនបើមានព្រះនានារួមជាមួយនឹងអល់ឡោះដូចដែលពួកគេបាននិយាយមែននោះ ច្បាស់ជាព្រះទាំងនោះនឹងស្វែងរកផ្លូវទៅកាន់ព្រះជាម្ចាស់នៃអារ៉ស(ដើម្បីដណ្តើមអំណាចពីទ្រង់)ជាមិនខាន។

43. ទ្រង់មហាស្អាតស្អំ មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេ(ពួកមុស្លីគីន)និយាយ។

44. មេឃទាំងប្រាំពីរជាន់និងផែនដី ព្រមទាំងអ្វីដែលមាននៅក្នុងវាសុទ្ធតែលើកតម្កើងចំពោះទ្រង់ទាំងអស់។ ហើយគ្មានអ្វីមួយដែលមិនលើកតម្កើងដោយការកោតសរសើរចំពោះទ្រង់នោះឡើយ ក៏ប៉ុន្តែពួកអ្នកមិនយល់ពីរបៀបនៃការលើកតម្កើងរបស់ពួកវាឡើយ។ ពិតប្រាកដណាស់ ទ្រង់មហាខន្តី មហាអភ័យទោសបំផុត។

45. ហើយនៅពេលដែលអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រគម្ពីរគួរអាន យើងបានដាក់នៅចន្លោះរវាងអ្នកនិងពួកដែលគ្មានជំនឿនឹងថ្ងៃបរលោកនូវរបាំងបិទជិតមួយ។

46. ហើយយើងបានដាក់គំរបគ្របលើចិត្តរបស់ពួកគេដើម្បីកុំឱ្យពួកគេយល់ពីវា(គម្ពីរគួរអាន) និងបានដាក់ធ្នូកក្នុងត្រចៀករបស់ពួកគេ។ ហើយនៅពេលដែលអ្នកវ៉ែកនៅក្នុងគម្ពីរគួរអានពីព្រះជាម្ចាស់របស់អ្នកតែមួយគត់ ពួកគេក៏បែរខ្នងរបស់ពួកគេចេញឆ្ងាយ។

47. យើងដឹងបំផុតពីរបៀបដែលអ្នកដឹកនាំរបស់ពួកគេស្តាប់វា(គម្ពីរគួរអាន)នៅពេលដែលពួកគេស្តាប់អ្នក(ព្យាការីមូហាំម៉ាត់)សូត្រនោះ។ ហើយ(យើងក៏ដឹងបំផុតផងដែរ)នៅពេលដែលពួកគេខ្សឹបខ្សៀវគ្នា ខណៈដែលពួកបំពានទាំងនោះបាននិយាយថា៖ ពួកអ្នក(ឱមនុស្សលោកទាំងឡាយ)មិនបានដើរតាមអ្នកណាក្រៅពីបុរសម្នាក់ដែលត្រូវមន្តអាគមគេនោះឡើយ។

48. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះ ថាតើពួកគេលើកឧទាហរណ៍(ប្រៀបធៀប)ចំពោះអ្នកយ៉ាងដូចម្តេច? ដូច្នេះហើយទើបពួកគេវង្វេងដោយពួកគេមិនអាចទទួលបានការចង្អុលបង្ហាញទៅកាន់មាគ៌ា(ត្រឹមត្រូវ)ឡើយ។

49. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ នៅពេលដែលពួកយើងបាន(ស្លាប់)ក្លាយទៅជាធ្មឹង ហើយរាងកាយរបស់ពួកយើងរលួយ(ទៅជាដី)ហើយនោះ តើពួកយើងពិតជានឹងត្រូវគេបង្កើតឱ្យរស់ឡើងវិញជាថ្មីឬ?

50. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នក(ឱពួកមុស្លីគីន)ក្លាយទៅជាថ្ម ឬក្លាយទៅជាដែកចុះ។

51. ឬក្លាយទៅជាភាវៈអ្វីផ្សេងទៀតដែលមានភាពធំធេងក្នុងដួងចិត្តរបស់ពួកអ្នកចុះ។ ពេលនោះ ពួកគេនឹងនិយាយថា៖ តើនរណាជាអ្នកត្រឡប់ពួកយើង(ឲ្យរស់ឡើងវិញ)? ចូរអ្នក(ព្យាការីមូហាំម៉ាត់)ពោលថា៖ គឺអ្នកដែលបានបង្កើតពួកអ្នកកាលពីដំបូងនោះឯង។ នៅពេលនោះ ពួកគេនឹងងក់ក្បាល(ចំអក)ដាក់អ្នក ហើយពួកគេនិយាយ(ផ្តើន)ថា៖ តើវានឹងកើតឡើងនៅពេលណា? ចូរអ្នកតបថា៖ សង្ឃឹមថាវានឹងកើតឡើងឆាប់ៗនេះឯង។

52. គឺនៅថ្ងៃដែលទ្រង់នឹងហៅពួកអ្នក(ឱ្យក្រោកចេញពីផ្នូរ)។ ពេលនោះ ពួកអ្នកនឹងឆ្លើយតបដោយការកោតសរសើរចំពោះទ្រង់ ហើយពួកអ្នកគិតថា៖ ពិតប្រាកដណាស់ ពួកអ្នកមិនបានរស់នៅ(ក្នុងលោកិយ)នេះឡើយ លើកលែងតែមួយរយៈពេលខ្លីប៉ុណ្ណោះ។

53. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់បណ្តាខ្ញុំបម្រើរបស់យើងឱ្យពួកគេនិយាយពាក្យសម្តីល្អៗ ព្រោះថាស្មៃតនវានឹងញុះញង់រវាងពួកគេ។ ពិតប្រាកដណាស់ ស្មៃតនគឺជាសត្រូវយ៉ាងច្បាស់លាស់ចំពោះមនុស្សលោក។

54. ព្រះជាម្ចាស់របស់ពួកអ្នក(ឱមនុស្សលោក)ទ្រង់ដឹងបំផុតចំពោះពួកអ្នក។ ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងអាណិតស្រលាញ់ពួកអ្នក ឬប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងដាក់ទណ្ឌកម្មពួកអ្នក។ ហើយយើងមិនបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ធ្វើជាអ្នកទទួលខុសត្រូវលើ(ទង្វើរបស់)ពួកគេនោះឡើយ។

55. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ដឹងបំផុតពីអ្នកដែលនៅលើមេឃជាច្រើនជាន់និងនៅលើផែនដី។ ហើយជាការពិតណាស់ យើងបានលើកតម្កើងបណ្តាព្យាការីមួយចំនួនឱ្យមានភាពល្អប្រសើរជាងគ្នា។ ហើយយើងបានប្រទានឱ្យព្យាការីហ្សាប៊ូទនូវគម្ពីរហ្សាប៊ួរ។

56. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នក(ឱពួកមុស្លីគីន)បួងសួងចុះពីអ្នកដែលពួកអ្នកបានអះអាង(ថាជាព្រះ)ផ្សេងពីអល់ឡោះ។ ជាការពិតណាស់ ពួកវាមិនអាចបញ្ចៀសគ្រោះចេញពីពួកអ្នកបានឡើយ ហើយក៏មិនអាចបង្វែរវា(ទៅកាន់អ្នកផ្សេង)បាននោះដែរ។

57. ពួកដែលពួកមុស្លីគីននៅបួងសួងសុំនោះ ពួកគេខ្លួនឯងក៏កំពុងតែស្វែងរកផ្លូវទៅកាន់ព្រះជាម្ចាស់របស់ពួកគេ(អល់ឡោះ) ដូចគ្នាដែរ ថាតើនរណាក្នុងចំណោមពួកគេដែលជិត(នឹងអល់ឡោះ)ជាងគេ ហើយពួកគេរំពឹងក្តីមេត្តាករុណាពីទ្រង់ និងខ្លាចទណ្ឌកម្មរបស់ទ្រង់។ ពិតប្រាកដណាស់ ទណ្ឌកម្មនៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) គឺជាអ្វីដែលគ្រប់គ្នាត្រូវប្រុងប្រយ័ត្ន។

58. ហើយគ្មានភូមិស្រុកណាមួយ(ដែលគ្មានជំនឿ)នោះទេ លើកលែងតែយើងជាអ្នកបំផ្លាញវា(ភូមិស្រុកនោះ) ឬដាក់ទណ្ឌកម្មវានូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុតមុននឹងថ្ងៃបរលោកមកដល់។ ទាំងនោះ គឺត្រូវបានកត់ត្រារួចជាស្រេចនៅក្នុងគម្ពីរកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)។

59. ហើយគ្មានអ្វីដែលរារាំងយើងមិនឲ្យបញ្ជូនសញ្ញាកស្តុតាង(អច្ឆរិយភាព)ទាំងឡាយនោះទេ លើកលែងតែដោយសារតែប្រជាជាតិជំនាន់មុនបានបដិសេធចំពោះវារួចមកហើយ។ ហើយយើងបានប្រទានឱ្យពួកសាមូដ(ក្រុមរបស់ព្យាការីសឡេះ)នូវសញ្ញាកស្តុតាងយ៉ាងច្បាស់លាស់ គឺសត្វអូដ្ឋញីមួយក្បាល តែពួកគេបែរជាបំពានចំពោះវាទៅវិញ។ ហើយយើងមិនបានបញ្ជូនសញ្ញាកស្តុតាង(អច្ឆរិយភាព)ទាំងឡាយនោះឡើយ លើកលែងតែដើម្បីជាការបន្លាច(ដល់ពួកគេ)ប៉ុណ្ណោះ។

60. ហើយ(ចូរអ្នកនឹកឃើញ) នៅពេលដែលយើងមានបន្ទូលទៅកាន់អ្នកថា៖ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកដឹងជ្រួតជ្រាបពីមនុស្សទាំងអស់។ ហើយយើងមិនបានបង្កើតអ្វីដែលយើងបានបង្ហាញអ្នកឱ្យបានឃើញ(នៅយប់អ៊ីសរ៉ក)នោះឡើយ លើកលែងតែដើម្បីជាការសាកល្បងសម្រាប់មនុស្សលោកប៉ុណ្ណោះ។ ហើយ(យើងក៏មិនបានបង្កើត)ដើមឈើដែលគេបានដាក់បណ្តាសានៅក្នុងគម្ពីរគួរអាន(ដើមហ្សឹកគូម)នោះដែរ (លើកលែងតែដើម្បីជាការសាកល្បងដល់ពួកគេដូចគ្នា)។ ហើយយើងបានបន្លាចពួកគេ(តាមរយៈទណ្ឌកម្ម និងសញ្ញាកស្តុតាងជាច្រើន) តែវាមិនបានបន្ថែមអ្វីដល់ពួកគេក្រៅតែពីភាពវង្វេងដ៏សែនឆ្ងាយនោះឡើយ។

61. ហើយ(ចូរអ្នករំលឹក)នៅពេលដែលយើងបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ចូរពួកអ្នកស៊ូជូតចំពោះព្យាការីអាដាំ។ ពេលនោះ ពួកគេក៏បានស៊ូជូត(ទាំងអស់គ្នា)លើកលែងតែអ៊ីព្លីសប៉ុណ្ណោះ ដោយវាបាននិយាយថា៖ តើខ្ញុំត្រូវស៊ូជូតចំពោះអ្នកដែលព្រះអង្គបានបង្កើតពីដីឥដ្ឋឬ?

62. វាបាននិយាយ(បន្ត)ថា៖ តើព្រះអង្គយល់ឃើញថា ភាវៈមួយនេះឬដែលព្រះអង្គលើកតម្កើងឲ្យប្រសើរជាងខ្ញុំនោះ? ប្រសិនបើព្រះអង្គទុកជីវិតឱ្យខ្ញុំ រហូតដល់ថ្ងៃបរលោកនោះ ខ្ញុំពិតជានឹងអូសទាញកូនចៅរបស់គេឲ្យវង្វេងជាមិនខានលើកលែងតែមួយចំនួនតូចប៉ុណ្ណោះ។

63. ទ្រង់បានមានបន្ទូលថា៖ ចូរឯង ហើយនិងអ្នកដែលដើរតាមឯងក្នុងចំណោមពួកគេចាកចេញទៅ។ ពិតប្រាកដណាស់ នរកជើហាន់ណាំនោះ គឺជាការតបស្នងសម្រាប់ពួកឯង ដែលជាការតបស្នងមួយយ៉ាងពេញលេញ។

64. ហើយចូរឯង(អ៊ីព្លីស)អូសទាញអ្នកទាំងឡាយណាដែលឯងអាចអូសទាញបានក្នុងចំណោមពួកគេ(មនុស្សលោក)ដោយសំឡេងរបស់ឯងចុះ។ ហើយចូរឯងប្រមូលទ័ពសេះ និងទ័ពថ្មើរជើងរបស់ឯង(ឱ្យពួកគេគោរពតាមឯង)។ ហើយចូរឯងចូលរួមជាមួយពួកគេនៅក្នុងទ្រព្យសម្បត្តិ និងកូនចៅរបស់ពួកគេ ព្រមទាំងសន្យាចំពោះពួកគេចុះ។ ហើយស្តែនមិនបានសន្យាអ្វីនឹងពួកគេក្រៅពីការបោកប្រាស់នោះឡើយ។

65. ពិតប្រាកដណាស់ បណ្តាខ្ញុំបម្រើរបស់យើង(ដែលជាអ្នកមានជំនឿ) គឺឯងគ្មានអំណាចអ្វីគ្រប់គ្រងលើពួកគេនោះឡើយ។ គ្រប់គ្រាន់ហើយដែលព្រះជាម្ចាស់របស់អ្នក គឺជាអ្នកគាំពារ។

66. ព្រះជាម្ចាស់របស់ពួកអ្នក(ឱមនុស្សលោក) គឺជាអ្នកដែលធ្វើឱ្យសំពៅធ្វើដំណើរលើផ្ទៃសមុទ្រសម្រាប់ពួកអ្នក ដើម្បីពួកអ្នកស្វែងរកលាភសក្ការៈរបស់ទ្រង់។ ពិតប្រាកដណាស់ ទ្រង់មហាអាណិតស្រលាញ់បំផុតចំពោះពួកអ្នក។

67. ហើយនៅពេលដែលពួកអ្នក(ពួកមុស្លីគីន)បានជួបគ្រោះនៅលើផ្ទៃសមុទ្រនោះ អ្នកដែលពួកអ្នកធ្លាប់គោរពសក្ការៈបានបាត់បង់(ពីចិត្តរបស់ពួកអ្នក)អស់ លើកលែងតែទ្រង់ប៉ុណ្ណោះ(ដែលពួកអ្នកនឹកឃើញ)។ តែនៅពេលដែលយើងបានសង្គ្រោះពួកអ្នកដល់ត្រើយ ពួកអ្នកបែរជាងាកចេញទៅវិញ។ ហើយមនុស្សលោក គឺជាអ្នកដែលរមិលគុណបំផុត។

68. តើពួកអ្នក(ឱពួកមុស្លីគីន)គិតថាមានសុវត្ថិភាពឬ ប្រសិនបើទ្រង់ធ្វើឲ្យដីស្រូបយកពួកអ្នក ឬក៏ទ្រង់បញ្ចុះភ្លៀងដុំថ្ម(ពីលើមេឃ)ទៅលើពួកអ្នកនោះ ? បន្ទាប់មក គឺពួកអ្នកគ្មានអ្នកគាំពារសម្រាប់ពួកអ្នកនោះឡើយ។

69. ឬក៏ពួកអ្នកគិតថាមានសុវត្ថិភាពឬ ប្រសិនបើទ្រង់ត្រឡប់ពួកអ្នកទៅកាន់សមុទ្រម្តងទៀត ហើយទ្រង់បញ្ជូនព្យុះសង្ឃរាទៅលើពួកអ្នក រួចគេធ្វើឱ្យពួកអ្នកលិចលង់ដោយសារតែការរមិលគុណរបស់ពួកអ្នកនោះ ? បន្ទាប់មក គឺពួកអ្នកគ្មានអ្នកដែលជួយស្នើសុំពីយើងឲ្យជួយពួកអ្នកទៀតនោះឡើយ។

70. ហើយជាការពិតណាស់ យើងបានលើកតម្កើងកូនចៅអាដាំ(មនុស្សលោក)។ ហើយយើងបានសម្រួលនូវយានដំនិះដល់ពួកគេទាំងនៅលើដីគោក និងនៅលើផ្ទៃសមុទ្រ។ ហើយយើងបានប្រទាននូវលាភសក្ការៈដល់ពួកគេអំពីប្រការល្អៗ ព្រមទាំងបានលើកតម្កើងពួកគេប្រសើរជាងការៈជាច្រើនផ្សេងទៀតដែលយើងបានបង្កើតមក។

71. (ហើយចូរអ្នកនឹកឃើញ) នៅថ្ងៃដែលយើងនឹងហៅរាល់ក្រុមនីមួយៗរួមជាមួយនឹងមេដឹកនាំរបស់ពួកគេ។ ដូច្នេះ ជនណាដែលត្រូវបានគេផ្តល់សៀវភៅកំណត់ត្រាទង្វើរបស់គេនៅដៃខាងស្តាំនោះ អ្នកទាំងនោះនឹងអានសៀវភៅកំណត់ត្រារបស់ខ្លួន(ដោយរីករាយ) ហើយពួកគេមិនត្រូវបានគេបំពានសូម្បីប៉ុនសសៃផ្ទារនោះឡើយ។

72. ជនណាហើយដែលនៅក្នុង(ជីវិតលោកិយ)នេះ ពួកគេងងឹតភ្នែក(មិនទទួលយកការពិត) នៅថ្ងៃបរលោក អ្នកនោះកាន់តែងងឹត និងវង្វេងចេញពីមាគ៌ា(នៃការចង្អុលបង្ហាញ)ថែមទៀត។

73. ហើយពួកគេ(ពួកមុស្លីគីន)ស្ទើរតែធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បែរចេញពីអ្វី(គម្ពីរគួរអាន)ដែលយើងបានផ្តល់វ៉ាហ៊ីទៅកាន់អ្នកទៅហើយដើម្បីឱ្យអ្នកប្រឌិតមកលើយើងនូវអ្វីផ្សេងពីវា(គម្ពីរគួរអាន)។ ប្រសិនបើអ្នកធ្វើដូច្នោះមែននោះ ពួកគេពិតជានឹងយកអ្នកធ្វើជាមិត្តសម្លាញ់ជាមិនខាន។

74. ហើយប្រសិនបើយើងមិនពង្រឹងរូបអ្នក(ឱ្យស្ថិតនៅលើសេចក្តីពិត)ទេនោះ ប្រាកដណាស់ អ្នកស្ទើរតែទោទន់ទៅរកពួកគេបន្តិចបន្តួចទៅហើយ។

75. ប្រសិនបើអ្នកធ្វើដូច្នោះមែននោះ យើងប្រាកដជានឹងឱ្យអ្នកភ្លក់រសជាតិ(ទណ្ឌកម្ម)ទ្វេដងនៅក្នុងលោកិយ និង(ទណ្ឌកម្ម)ទ្វេដងក្រោយពេលស្លាប់។ បន្ទាប់មក គឺអ្នកគ្មានអ្នកដែលជួយការពារអ្នកពី(ទណ្ឌកម្ម)យើងឡើយ។

76. ពួកគេ(ពួកគ្មានជំនឿ)ស្ទើរតែធ្វើឲ្យអ្នកចាកចេញពីទឹកដី(ម៉ាក្កៈ)ទៅហើយដោយសារតែការរំខានរបស់ពួកគេចំពោះអ្នក។ ប្រសិនបើដូច្នោះមែននោះ ពួកគេក៏នឹងមិនអាចរស់នៅទីនោះបន្ទាប់ពីអ្នកបានដែរ លើកលែងតែមួយរយៈពេលខ្លីប៉ុណ្ណោះ។

77. (នោះ)គឺជាក្រឹតក្រម(របស់អល់ឡោះ)ចំពោះបណ្តាអ្នកនាំសារទាំងឡាយរបស់យើងដែលយើងបានបញ្ជូនទៅមុនអ្នក។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងមិនឃើញថា ក្រឹតក្រមរបស់យើងមានការកែប្រែឡើយ។

78. ចូរអ្នកប្រតិបត្តិសឡាតចាប់ពីថ្ងៃជ្រេ(សឡាតហ្ស៊ូហ្រ និងសឡាតអាសើរ)រហូតដល់ពេលយប់(សឡាតម៉ាហ្គ្រិប និងសឡាតអ៊ីសា) ហើយនិងសឡាតស៊ូពុស(ដោយត្រូវសូត្រវែង)។ ជាការពិតណាស់ ការសឡាតស៊ូពុស គឺត្រូវបានគេធ្វើជាសាក្សី។

79. ហើយមួយផ្នែកនៃពេលយប់ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ក្រោកសឡាតដើម្បីជាសឡាតបន្ថែមសម្រាប់អ្នក សង្ឃឹមថាព្រះជាម្ចាស់របស់អ្នកនឹងតែងតាំងរូបអ្នកឲ្យស្ថិតនៅក្នុងឋានៈមួយដែលត្រូវបានគេកោតសរសើរ។

80. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាបញ្ចូលខ្ញុំតាមច្រកនៃភាពទៀងត្រង់ និងបញ្ចោញរូបខ្ញុំតាមច្រកនៃភាពទៀងត្រង់ផង។ ហើយសូមព្រះអង្គមេត្តាប្រទានឱ្យខ្ញុំនូវកែសុតាងអំពីទ្រង់ដែលនឹងជួយ(ដល់ខ្ញុំ)ផង។

81. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពេលណាដែលការពិតបានមកដល់ នោះប្រការមិនពិតនឹងត្រូវរលាយបាត់បង់។ ពិតប្រាកដណាស់ ប្រការមិនពិតនឹងត្រូវរលាយសាបសូន្យ។

82. ហើយយើងបានបញ្ចុះ(ឱ្យអ្នក)អំពីគម្ពីរគួរអាននូវអ្វីដែលជាឱសថព្យាបាល និងជាក្តីមេត្តាករុណាសម្រាប់បណ្តាអ្នកដែលមានជំនឿ។ ហើយវា(គម្ពីរគួរអាន)មិនបានបន្ថែមអ្វីដល់ពួកបំពានក្រៅតែពីភាពខាតបង់នោះឡើយ។

83. ហើយនៅពេលដែលយើងបានប្រទានឧបការគុណដល់មនុស្សលោក គេបែរជាងាកចេញ និងចេញឆ្ងាយពីការគោរពប្រតិបត្តិចំពោះទ្រង់។ តែនៅពេលដែលគេទទួលរងនូវប្រការអាក្រក់ គឺគេមានការអស់សង្ឃឹម(ពីក្តីមេត្តាករុណារបស់អល់ឡោះ)។

84. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ បុគ្គលគ្រប់រូបតែងតែប្រព្រឹត្តទៅតាមរបៀបដែលស្រដៀងទៅនឹងស្ថានភាពរបស់ខ្លួន។ ដូច្នេះ ព្រះជាម្ចាស់របស់ពួកអ្នកទ្រង់ដឹងបំផុតចំពោះជនណាដែលទទួលបានការចង្អុលបង្ហាញទៅកាន់មាគ៌ា(ត្រឹមត្រូវ)ជាងគេ។

85. ហើយពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីវិញ្ញាណ។ ចូរអ្នកពោលថា៖ វិញ្ញាណ គឺស្ថិតក្នុងចំណោមកិច្ចការនៃព្រះជាម្ចាស់របស់ខ្ញុំ ហើយពួកអ្នកមិនត្រូវបានគេផ្តល់ឱ្យនូវចំណេះដឹងនោះឡើយ លើកលែងតែបន្តិចនួចប៉ុណ្ណោះ។

86. ហើយប្រសិនបើយើងមានចេតនា យើងពិតជានឹងលុបបំបាត់នូវវាហ្ស៊ីដែលយើងបានបញ្ចុះមកឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាមិនខាន។ បន្ទាប់មក អ្នកនឹងគ្មានអ្នកណាដែលជួយគាំពារអ្នកប្រឆាំងនឹងយើងក្នុងរឿងនោះបានឡើយ។

87. ប៉ុន្តែ(យើងមិនបានលុបបំបាត់វានោះទេ)ជាក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់អ្នក។ ពិតប្រាកដណាស់ ការប្រោសប្រទានរបស់ទ្រង់ចំពោះអ្នក គឺធំធេងបំផុត។

88. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើមនុស្សលោកនិងជិនប្រមូលផ្តុំគ្នាដើម្បីនាំមកនូវគម្ពីរមួយដែលដូចទៅនឹងគម្ពីរគួរអាននេះ គឺពួកគេមិនអាចនាំមកឱ្យដូចនឹងវា(គម្ពីរគួរអាន)បាននោះឡើយ បើទោះបីជាពួកគេប្រឹងប្រែងជួយគ្នាទៅវិញទៅមកយ៉ាងណាក៏ដោយ។

89. ហើយជាការពិតណាស់ យើងបានបកស្រាយបញ្ជាក់ចំពោះមនុស្សលោកនៅក្នុងគម្ពីរគួរអាននេះនូវគ្រប់ឧទាហរណ៍ទាំងអស់។ ក៏ប៉ុន្តែមនុស្សលោកភាគច្រើនបែរជាបដិសេធ និងប្រឆាំងចំពោះវា(គម្ពីរគួរអាន)ទៅវិញ។

90. ហើយពួកគេ(ពួកមុស្តរីគីន)បាននិយាយថា៖ ពួកយើងនឹងមិនមានជំនឿចំពោះអ្នកជាដាច់ខាត លុះត្រាតែអ្នកធ្វើឱ្យប្រភពទឹកផុសចេញពីទឹកដី(ម៉ាក្កះ)សម្រាប់ពួកយើងសិន។

91. ឬក៏អ្នកមានចម្ការល្មើ និងទំពាំងបាយជូរ ហើយអ្នកអាចធ្វើឲ្យមានទន្លេជាច្រើនហូរតាមចន្លោះរបស់ចម្ការនោះ។

92. ឬក៏អ្នកធ្វើឱ្យមេឃធ្លាក់ជាបន្ទះៗមកលើពួកយើងដូចដែលអ្នកបានអះអាង ឬក៏អ្នកនាំអល់ឡោះជាម្ចាស់ និងម៉ាឡាអ៊ីកាត់(របស់ទ្រង់)មកជួបនឹងពួកយើងសិន។

93. ឬក៏អ្នកមានផ្ទះ(ដែលត្រូវបានតុបតែង)អំពីមាស ឬក៏អ្នកអាចឡើងទៅលើមេឃបានសិន។ ហើយពួកយើងក៏មិនមានជំនឿថា អ្នកបានឡើងទៅនោះដែរ លុះត្រាតែអ្នក(ចុះមកវិញដោយ)នាំមកនូវគម្ពីរមួយដើម្បីពួកយើងអានវា។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំមហាបរិសុទ្ធបំផុត! តើខ្ញុំមិនមែនជាអ្វីក្រៅតែពីជាមនុស្សលោក និងជាអ្នកនាំសារម្នាក់ទេឬ?!

94. ហើយគ្មានអ្វីដែលរារាំងមនុស្សមិនឱ្យមានជំនឿនោះឡើយនៅពេលដែលការចង្អុលបង្ហាញបានមកដល់ពួកគេហើយនោះ ក្រៅតែពីពួកគេនិយាយថា៖ តើអល់ឡោះតែងតាំងមនុស្សលោកធ្វើជាអ្នកនាំសារឬ?

95. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើនៅលើផែនដីមានបណ្តាម៉ាឡាអ៊ីកាត់ដែលរស់នៅ និងដើរដោយសុខសាន្តនោះ យើងប្រាកដជានឹងបញ្ចុះអ្នកនាំសារម្នាក់ជាម៉ាឡាអ៊ីកាត់ពីលើមេឃទៅកាន់ពួកគេជាមិនខាន។

96. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ គ្រប់គ្រាន់ហើយដែលអល់ឡោះជាសាក្សីរវាងខ្ញុំនិងពួកអ្នក។ ពិតប្រាកដណាស់ទ្រង់មហាដឹង មហាឃើញបំផុតចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

97. ហើយជនណាដែលអល់ឡោះទ្រង់ចង្អុលបង្ហាញ ពិតណាស់ រូបគេជាអ្នកដែលទទួលបានការចង្អុលបង្ហាញ(យ៉ាងពិតប្រាកដ)។ រីឯជនណាដែលទ្រង់ធ្វើឱ្យវង្វេងនោះ ពិតណាស់ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងមិនឃើញមានអ្នកគាំពារណាសម្រាប់ពួកគេក្រៅពីទ្រង់ឡើយ។ ហើយយើងនឹងប្រមូលផ្តុំពួកគេនៅថ្ងៃបរលោកដោយអូសពួកគេផ្កាប់មុខដែលពួកគេមិនអាចមើលឃើញ មិនអាចនិយាយចេញ ហើយក៏មិនអាចស្តាប់ឮនោះដែរ។ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺនរកជើហាន់ណាំ។ រាល់ពេលដែលរងើកភ្លើងរបស់វាជិតរលត់ យើងនឹងបន្ថែមអណ្តាតភ្លើងលើពួកគេថែមទៀត។

98. នោះគឺជាការតបស្នងដល់ពួកគេដោយសារតែពួកគេបានប្រឆាំងនឹងបណ្តាសញ្ញាកស្តុតាងទាំងឡាយរបស់យើង ហើយពួកគេបាននិយាយថា៖ នៅពេលដែលពួកយើងបាន(ស្លាប់)ក្លាយទៅជាឆ្អឹង និងបានបែកជាបំណែកតូចៗអស់ទៅហើយនោះ តើពួកយើងពិតជានឹងត្រូវគេបង្កើតឱ្យរស់ឡើងវិញសាជាថ្មីឬ?

99. តើពួកគេមិនបានឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ដែលជាអ្នកបានបង្កើតមេឃជាច្រើនជាន់និងផែនដីនោះ គឺជាអ្នកដែលមានសមត្ថភាពបំផុតក្នុងការបង្កើតពួកគេឱ្យដូចដើមវិញនោះ។ ហើយទ្រង់បានកំណត់នូវអាយុកាលជាក់លាក់សម្រាប់ពួកគេដែលគ្មានការសង្ស័យឡើយចំពោះវា។ ក៏ប៉ុន្តែពួកបំពានបែរជាបដិសេធ និងប្រឆាំងចំពោះរឿងនោះទៅវិញ។

100. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ប្រសិនបើពួកអ្នកជាអ្នកគ្រប់គ្រងឃ្លាំងទាំងឡាយនៃក្តីមេត្តាករុណារបស់ព្រះជាម្ចាស់របស់ខ្ញុំមែននោះ ពួកអ្នកនឹងមិនព្រមបរិច្ចាគវានោះឡើយ ព្រោះតែខ្លាចបាត់បង់។ ហើយមនុស្សលោក គឺមានភាពកំណាញ់បំផុត។

101. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវសញ្ញាកស្តុតាងយ៉ាងច្បាស់លាស់ចំនួនប្រាំបួន ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរទៅកាន់អម្បូរអ៊ីស្រាអែលចុះ នៅពេលដែលគាត់(ព្យាការីមូសា)បានមកដល់ពួកគេ ពេលនោះហ្វៀរអោនបាននិយាយទៅកាន់គាត់ថា៖ ឱមូសា! ពិតប្រាកដណាស់ ខ្ញុំយល់ថារូបអ្នក គឺជាអ្នកដែលត្រូវមន្តអាគមគេ។

102. គាត់បានតបវិញថា៖ ជាការពិតណាស់ រូបអ្នក(ឱហ្វៀរអោន)ពិតជាបានដឹងច្បាស់ថា គ្មាននរណាម្នាក់ដែលអាចបញ្ចុះនូវសញ្ញាកស្តុតាងទាំងនេះក្រៅពីព្រះជាម្ចាស់នៃមេឃានិងផែនដីនោះឡើយ។ ហើយពិតប្រាកដណាស់ ខ្ញុំដឹងច្បាស់ថាអ្នក ឱហ្វៀរអោន! គឺជាអ្នកដែលត្រូវវិនាសអន្តរាយ។

103. ពេលនោះ ហ្វៀរអោនមានបំណងចង់បណ្តេញពួកគាត់(ព្យាការីមូសា និងក្រុមរបស់គាត់)ចេញពីទឹកដី(អេហ្ស៊ីប)តែយើងបានធ្វើឱ្យគេ និងអ្នកដែលនៅជាមួយគេលិចលង់(ទៅក្នុងសមុទ្រ)។

104. ហើយក្រោយពីនោះមក យើងបានមានបន្ទូលទៅកាន់អម្បូរអ៊ីស្រាអែលថា៖ ចូរពួកអ្នករស់នៅលើទឹកដី(ស្ហាម)នេះចុះ។ ពិតប្រាកដណាស់ នៅពេលដែលការសន្យាចុងក្រោយ(ថ្ងៃបរលោក)បានមកដល់ យើងនឹងនាំពួកអ្នកមកទាំងអស់គ្នា(ដើម្បីជំនុំជម្រះ)។

105. តាមរយៈការពិត យើងបានបញ្ចុះវា(គម្ពីរគួរអាន) ហើយតាមរយៈការពិតនេះដែរ ទ្រង់បានបញ្ចុះវាមក(ដោយគ្មានការកែប្រែ)។ ហើយយើងបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មក គឺដើម្បីធ្វើជាអ្នកផ្តល់ដំណឹងរីករាយ និងព្រមានបន្លាច។

106. ហើយ(យើងបានបញ្ចុះ)គម្ពីរគួរអានដោយបានបកស្រាយបញ្ជាក់វាដើម្បីឲ្យអ្នកសូត្រឱ្យមនុស្សលោកស្តាប់(ដោយសូត្រ)មួយៗ ច្បាស់ៗ។ ហើយយើងបានបញ្ចុះវាបន្តិចម្តងៗ។

107. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកមានជំនឿលើវា(គម្ពីរគួរអាន)ឬក៏មិនមានជំនឿលើវា។ ពិតប្រាកដណាស់ បណ្តាអ្នកដែលគេបានផ្តល់ចំណេះដឹងឲ្យកាលពីមុន នៅពេលដែលមានគេសូត្រ(គម្ពីរគួរអាន)ឱ្យពួកគេស្តាប់ គឺពួកគេលំឱនកាយក្រាបស៊ូជូត(ចំពោះអល់ឡោះ)។

108. ហើយពួកគេបួងសួងថា៖ ព្រះជាម្ចាស់របស់យើងមហាបរិសុទ្ធបំផុត។ ពិតប្រាកដណាស់ កិច្ចសន្យានៃព្រះជាម្ចាស់របស់ពួកយើង ពិតជានឹងកើតឡើងយ៉ាងពិតប្រាកដ។

109. ហើយពួកគេបានឱនមុខរបស់ពួកគេ(ក្រាបស៊ូជូត) ហើយពួកគេយំ។ ហើយវាបានបន្ថែមឱ្យពួកគេនូវការឱនលំទោន(ចំពោះអល់ឡោះ)។

110. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកបួងសួងសុំពីអល់ឡោះ ឬបួងសួងសុំពីអាល់រ៉ាះម៉ាន(ម្ចាស់ដ៏មហាសប្បុរស)។ ព្រះនាមណាមួយក្នុងចំណោមព្រះនាមទាំងពីរនេះដែលពួកអ្នកបួងសួង គឺសុទ្ធតែជាព្រះនាមរបស់ទ្រង់ដ៏ល្អប្រពៃ។ ហើយចូរអ្នកកុំបញ្ចេញសំឡេងខ្លាំងពេកនៅពេលអ្នកសូត្រ(គម្ពីរគួរអាន)ក្នុងសឡាតរបស់អ្នក ហើយក៏មិនត្រូវសូត្របញ្ចេញសំឡេងតិចពេកនោះដែរ។ ប៉ុន្តែអ្នកត្រូវជ្រើសរើសយកផ្លូវកណ្តាលក្នុងចំណោមទាំងពីរនេះ(មិនសូត្រឮតិចពេក និងមិនសូត្រឮខ្លាំងពេក)។

111. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ រាល់ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលទ្រង់ពុំមានបុត្រ ពុំមានដៃគូក្នុងការគ្រប់គ្រង ហើយទ្រង់ក៏មិនទន់ខ្សោយដែលត្រូវការអ្នកគាំពារនោះដែរ។ ហើយចូរអ្នកលើកតម្កើងទ្រង់ឱ្យបានថ្កុំថ្កើងបំផុត។

ជំពូក អាល់កះហ្វ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលទ្រង់បានបញ្ចុះនូវគម្ពីរ(គួរអាន)ទៅឲ្យខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ហើយទ្រង់មិនបានដាក់អ្វីមួយដែលធ្វើឱ្យវាមានភាពវៀចវេរនោះដែរ។

2. ផ្ទុយទៅវិញ (ទ្រង់បានឲ្យវា)ប្រកបដោយភាពត្រឹមត្រូវ ដើម្បីដាស់តឿនព្រមានពីទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតពីអល់ឡោះនឹង(ដើម្បី)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកមានជំនឿដែលបានសាងទង្វើកុសលថា៖ ពិតប្រាកដណាស់ សម្រាប់ពួកគេនឹងទទួលបាននូវការតបស្នងដ៏ប្រសើរបំផុត(ឋានសួគ៌)។

3. ពួកគេរស់នៅក្នុងវាជាអមតៈ។

4. ហើយវា(គម្ពីរគួរអាន)ជាការដាស់តឿនព្រមានដល់ពួកដែលនិយាយថា៖ អល់ឡោះជាម្ចាស់ទ្រង់មានបុត្រ។

5. ពួកគេ និងដីដូនដីតារបស់ពួកគេគ្មានចំណេះដឹងអ្វីឡើយអំពីរឿងនោះ។ ពាក្យសម្តី(ចោទប្រកាន់)ដែលចេញពីមាត់របស់ពួកគេនោះ គឺធ្ងន់ធ្ងរបំផុត។ អ្វីដែលពួកគេនិយាយគ្មានអ្វីក្រៅពីពាក្យកុតកុហកនោះឡើយ។

6. អ្នក(ព្យាការីមូហាំម៉ាត់)ប្រហែលជានឹងធ្វើឱ្យខ្លួនឯងវិនាសទៅហើយព្រោះតែទុក្ខព្រួយដោយសារតែងាកចេញរបស់ពួកគេដោយពួកគេមិនមានជំនឿចំពោះគម្ពីរគួរអាននេះ។

7. ពិតប្រាកដណាស់ យើងបានបង្កើតអ្វីៗដែលមាននៅលើផែនដីជាការលម្អសម្រាប់វា(ផែនដី) ដើម្បីយើងនឹងសាកល្បងពួកគេ(មនុស្សលោក)ថាតើអ្នកណាក្នុងចំណោមពួកគេដែលសាងទង្វើបានប្រសើរជាងគេ។

8. ហើយពិតប្រាកដណាស់ យើងនឹងធ្វើឱ្យអ្វីៗដែលមាននៅលើផែនដីទាំងអស់ក្លាយទៅជាដីដែលគ្មានរុក្ខជាតិអ្វីទាំងអស់។

9. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំគិតស្មានថា រឿងរ៉ាវរបស់ក្រុមដែលនៅក្នុងរូងភ្នំ និងសិលាចារឹក(ដែលចារឈ្មោះពួកគេ)គឺស្ថិតក្នុងចំណោមសញ្ញាកស្តុតាងដ៏អស្ចារ្យរបស់យើងឱ្យសោះ។

10. (ចូរអ្នកនឹកឃើញ) នៅពេលដែលយុវជនមួយក្រុមបានទៅជ្រកកោនក្នុងរូងភ្នំ ពេលនោះពួកគេបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាប្រទានឱ្យយើងខ្ញុំនូវក្តីមេត្តាករុណាពីព្រះអង្គផង។ ហើយសូមព្រះអង្គមេត្តាសម្រួលដល់យើងខ្ញុំនូវកិច្ចការរបស់យើងខ្ញុំឆ្ពោះទៅកាន់មាគ៌ាត្រឹមត្រូវផងចុះ។

11. ពេលនោះ យើងក៏បានដាក់ឆ្នុកនៅលើត្រចៀករបស់ពួកគេ(ឱ្យពួកគេដេកលង់លក់)អស់រយៈពេលជាច្រើនឆ្នាំក្នុងរូងភ្នំ។

12. ក្រោយមក យើងក៏បានឱ្យពួកគេភ្ញាក់ពីដំណេកវិញ ដើម្បីយើងដឹងថា តើក្រុមណាមួយក្នុងចំណោមក្រុមទាំងពីរដើងច្បាស់ជាងគេពីថេរវេលានៃការស្នាក់នៅ(របស់ពួកគេក្នុងរូងភ្នំ)នោះ។

13. យើងនឹងប្រាប់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពីរឿងរ៉ាវរបស់ពួកគេយ៉ាងពិតប្រាកដ។ ពិតប្រាកដណាស់ ពួកគេគឺជាយុវជនដែលមានជំនឿលើព្រះជាម្ចាស់របស់ពួកគេ ហើយយើងក៏បានបន្ថែមឱ្យពួកគេនូវការចង្អុលបង្ហាញ។

14. ហើយយើងបានពង្រឹងដួងចិត្តរបស់ពួកគេ ខណៈដែលពួកគេបានក្រោកឈរ(នៅចំពោះមុខស្តេចដែលគ្មានជំនឿ) ដោយពួកគេបាននិយាយថា៖ ព្រះជាម្ចាស់របស់ពួកយើង គឺជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី។ ពួកយើងមិនគោរពសក្ការៈចំពោះព្រះផ្សេងក្រៅពីទ្រង់ជាដាច់ខាត។ ជាការពិតណាស់ ប្រសិនបើពួកយើងនិយាយផ្សេងពីនេះ ពួកយើងពិតជាបាននិយាយប្រាសចាកពីការពិតជាមិនខាន។

15. ពួកទាំងនេះជាក្រុមរបស់ពួកយើងដែលពួកគេបានយកព្រះនានាមកគោរពសក្ការៈក្រៅពីអល់ឡោះជាម្ចាស់ ខណៈដែលពួកគេមិនមានកស្តុតាងច្បាស់លាស់ណាមួយដើម្បីបញ្ជាក់នោះឡើយ។ ជាការពិតណាស់ គ្មាននរណាដែលបំពានជាងអ្នកដែលប្រឌិតនូវពាក្យភូតកុហកទៅលើអល់ឡោះជាម្ចាស់នោះឡើយ។

16. ហើយនៅពេលដែលពួកអ្នកបានដកខ្លួនចេញពីពួកគេ និងអ្វីដែលពួកគេគោរពសក្ការៈក្រៅពីអល់ឡោះនោះ ចូរពួកអ្នកទៅជ្រកកោនក្នុងរូងភ្នំចុះ នោះព្រះជាម្ចាស់របស់ពួកអ្នកនឹងប្រទានឱ្យពួកអ្នកនូវក្តីមេត្តាករុណាអំពីទ្រង់។ ហើយទ្រង់នឹងសម្រួលដល់ពួកអ្នកនូវរាល់កិច្ចការរបស់ពួកអ្នកឲ្យទទួលបាននូវផលប្រយោជន៍។

17. ហើយអ្នកនឹងឃើញព្រះអាទិត្យ នៅពេលដែលវារះ គឺវាបញ្ជិតទៅខាងស្តាំនៃរូងភ្នំរបស់ពួកគេ ហើយនៅពេលដែលវាលិចគឺវាបញ្ជិតទៅខាងឆ្វេង(នៃរូងភ្នំ)។ ហើយពួកគេស្ថិតនៅកន្លែងដែលទូលាយនៃរូងភ្នំ។ នោះគឺស្ថិតក្នុងចំណោមសញ្ញាភស្តុតាងរបស់អល់ឡោះជាម្ចាស់។ ជនណាហើយដែលអល់ឡោះចង្អុលបង្ហាញ ពិតប្រាកដណាស់ គេជាអ្នកដែលទទួលបានការចង្អុលបង្ហាញយ៉ាងពិតប្រាកដ។ រីឯជនណាដែលទ្រង់ធ្វើឲ្យវង្វេងនោះ គឺអ្នកនឹងមិនឃើញមានអ្នកគាំពារណាដែលអាចចង្អុលបង្ហាញគេនោះឡើយ។

18. ហើយអ្នកគិតស្មានថា ពួកគេមិនគេងនោះឡើយ ខណៈដែល(ជាក់ស្តែង)ពួកគេកំពុងតែគេងលង់លក់។ ហើយយើងបានប្រែខ្លួនរបស់ពួកគេ ម្តងទៅខាងស្តាំ ម្តងទៅខាងឆ្វេង។ ហើយឆ្កែរបស់ពួកគេដេកសណ្តូកជើងមុខទាំងពីររបស់វានៅមាត់រូង។ ប្រសិនបើអ្នកឃើញពួកគេ អ្នកពិតជានឹងរត់បែរចេញពីពួកគេ ហើយវាច្បាស់ជាធ្វើឱ្យអ្នកពោរពេញទៅដោយភាពភ័យខ្លាចអំពីពួកគេជាមិនខាន។

19. ក៏ដូច្នោះដែរ យើងបានឱ្យពួកគេភ្ញាក់ពីដំណេកវិញ ដើម្បីឱ្យពួកគេសួរនាំគ្នាទៅវិញទៅមក។ ពេលនោះ ម្នាក់ក្នុងចំណោមពួកគេបានសួរថា៖ តើពួកអ្នកគេងលង់លក់អស់រយៈពេលប៉ុន្មានហើយ? ពួកគេបានឆ្លើយថា៖ ពួកយើងបានគេងលក់(នៅទីនេះ)អស់រយៈពេលមួយថ្ងៃ ឬកន្លះថ្ងៃ។ ហើយអ្នកខ្លះទៀតនិយាយថា៖ មានតែព្រះជាម្ចាស់របស់ពួកអ្នកប៉ុណ្ណោះដែលដឹងបំផុតពីរយៈពេលដែលពួកអ្នកបានគេងលង់លក់នោះ។ ដូច្នេះ ចូរពួកអ្នកបញ្ជូននរណាម្នាក់ក្នុងចំណោមពួកអ្នកឱ្យយកក្រដាសប្រាក់របស់ពួកអ្នកទាំងនេះទៅទីក្រុង ហើយឱ្យគេរកមើល ថាតើអ្នកណាដែលមានចំណីអាហារដែលល្អជាងគេ។ ហើយចូរឱ្យគេយកចំណីអាហារនោះមកឱ្យពួកអ្នក។ ហើយចូរឱ្យគេមានភាពទន់ភ្លន់ និងមិនត្រូវឱ្យនរណាម្នាក់ដឹងពីកន្លែងរបស់ពួកអ្នកឡើយ។

20. ជាការពិតណាស់ ប្រសិនបើពួកគេដឹងពីកន្លែងពួកអ្នក នោះពួកគេប្រាកដជានឹងគប់សម្លាប់ពួកអ្នក ឬត្រឡប់ពួកអ្នកទៅកាន់សាសនារបស់ពួកគេវិញជាមិនខាន ហើយពួកអ្នកនឹងមិនទទួលជោគជ័យជារៀងរហូត។

21. ហើយក៏ដូច្នោះដែរ យើងបានលាតត្រដាងនូវរឿងរ៉ាវរបស់ពួកគេដល់អ្នកជំនាន់នោះដើម្បីឱ្យពួកគេដឹងថា៖ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត ហើយថ្ងៃបរលោក គឺ(នឹងមកដល់យ៉ាងពិតប្រាកដ)គ្មានការសង្ស័យចំពោះវាឡើយ។ នៅពេលដែលពួកគេបានខ្វែងគំនិតគ្នាពីរឿងរ៉ាវរបស់អ្នករូងភ្នំ ពេលនោះពួកគេបាននិយាយថា៖ ចូរពួកអ្នកសង់សំណង់មួយនៅលើមាត់រូងនោះចុះ។ ព្រះជាម្ចាស់របស់ពួកគេដឹងបំផុតអំពីពួកគេ។ ហើយអ្នកដែលមានឥទ្ធិពលលើកិច្ចការរបស់ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងនឹងយកកន្លែងរបស់ពួកគេធ្វើជាម៉ាស្ជិទ(ទីគោរពសក្ការៈ)។

22. ពួកគេមួយចំនួននឹងនិយាយថា៖ ពួកគេ(អ្នកនៅក្នុងរូងភ្នំ) មានគ្នាបីនាក់ ទីបួនគឺឆ្កែរបស់ពួកគេ។ ហើយអ្នកខ្លះទៀតបាននិយាយថា៖ ពួកគេមានគ្នាប្រាំនាក់ ទីប្រាំមួយគឺឆ្កែរបស់ពួកគេ ដែលសុទ្ធតែជាការសន្និដ្ឋានមិនច្បាស់លាស់។ ហើយអ្នកខ្លះទៀតបាននិយាយថា៖ ពួកគេមានគ្នាប្រាំពីរនាក់ ទីប្រាំបីគឺឆ្កែរបស់ពួកគេ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំដឹងបំផុតពីចំនួនរបស់ពួកគេ។ គ្មានអ្នកណាម្នាក់ដឹងពី(ចំនួនពិតប្រាកដរបស់)ពួកគេឡើយ លើកលែងតែមួយចំនួនតូចប៉ុណ្ណោះ។ ហេតុនេះ ចូរអ្នកកុំជជែកដេញដោលគ្នាពីរឿងរបស់ពួកគេ លើកលែងតែការដេញដោលដែលមាន(អំណះអំណាង)ច្បាស់លាស់។ ហើយចូរអ្នកកុំសួរនរណាម្នាក់ក្នុងចំណោមពួកគេ(ពួកអះលីគីតាប)អំពីរឿងរ៉ាវរបស់អ្នកដែលនៅក្នុងរូងភ្នំឡើយ។

23. ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)កុំនិយាយពីបំណងអ្វីមួយថា៖ "ពិតណាស់ ខ្ញុំនឹងធ្វើរឿងនេះនៅថ្ងៃស្អែក" ឱ្យសោះ។

24. លើកលែងតែអ្នកភ្ជាប់នឹងពាក្យ "អ៊ិនស្ហាអល់ឡោះ (ប្រសិនបើអល់ឡោះមានចេតនា)"។ ហើយចូរអ្នករឭកដល់ព្រះជាម្ចាស់របស់អ្នក ប្រសិនបើអ្នកភ្លេច។ ហើយចូរអ្នកពោលថា៖ សង្ឃឹមថាព្រះជាម្ចាស់របស់ខ្ញុំនឹងផ្តល់ការចង្អុលបង្ហាញដល់ខ្ញុំនូវមាគ៌ាដ៏ត្រឹមត្រូវដែលជិតជាងនេះទៅទៀត។

25. ហើយពួកគេបានគេងលង់លក់នៅក្នុងរូងភ្នំរបស់ពួកគេអស់រយៈពេលបីរយប្រាំបួនឆ្នាំ។

26. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវរយៈពេលដែលពួកគេបានគេងលង់លក់។ អាថ៌កំបាំងទាំងអស់ដែលនៅលើមេឃជាច្រើនជាន់និងនៅលើផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ទ្រង់មហាឃើញ និងមហាឮបំផុតចំពោះវា។ សម្រាប់ពួកគេគ្មានអ្នកគាំពារណាក្រៅពីទ្រង់ឡើយ ហើយទ្រង់ក៏គ្មាននរណាម្នាក់ជាដៃគូក្នុងការសម្រេចបទបញ្ញត្តិរបស់ទ្រង់ដែរ។

27. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រនូវអ្វីដែលគេបានផ្តល់ជាវ៉ាហ៊ីមកឱ្យអ្នកនៃគម្ពីរ(គួរអាន)ពីព្រះជាម្ចាស់របស់អ្នកចុះ។ គ្មាននរណាម្នាក់អាចប្តូរពាក្យបន្ទូលរបស់ទ្រង់បានឡើយ។ ហើយអ្នកក៏មិនអាចស្វែងរកកន្លែងជ្រកកោនណាក្រៅពីទ្រង់នោះដែរ។

28. ចូរអ្នកអត់ធ្មត់ដោយខ្លួនអ្នកផ្ទាល់ជាមួយនឹងអ្នកដែលបួងសួងទៅកាន់ព្រះជាម្ចាស់របស់ពួកគេទាំងព្រឹកទាំងល្ងាចដោយប្រាថ្នាចង់បានការពេញចិត្តពីទ្រង់។ ហើយចូរអ្នកកុំមើលរំលងពួកគេដោយចង់បានភាពលម្អនៃជីវិតលោកិយឱ្យសោះ។ ហើយអ្នកមិនត្រូវធ្វើតាមអ្នកដែលយើងបានធ្វើឱ្យចិត្តរបស់គេព្រងើយកន្តើយ(មិនយកចិត្តទុកដាក់)ចំពោះការរឭកមកចំពោះយើង ហើយដើរតាមទំនើងចិត្តរបស់ខ្លួននោះឡើយ។ ទង្វើរបស់គេបានក្លាយទៅជាអសារបង់ទៅហើយ។

29. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ សេចក្តីពិត គឺមកពីព្រះជាម្ចាស់របស់ពួកអ្នក។ ដូច្នេះ ជនណាដែលមានបំណង ចូរឱ្យគេមានជំនឿចុះ។ ជនណាដែលមានបំណង ចូរឱ្យគេប្រឆាំងចុះ។ ពិតប្រាកដណាស់ យើងបានត្រៀមទុកសម្រាប់ពួកដែលបំពាននូវភ្លើងនរកដែលជាជញ្ជាំងព័ទ្ធជុំវិញពួកគេ។ ហើយប្រសិនបើពួកគេសុំឱ្យគេផ្តល់ទឹកឱ្យ គេនឹងផ្តល់ទឹកឱ្យពួកគេនូវទឹកដែលប្រៀបដូចជាប្រេងកំពុងពុះ ដែលធ្វើឱ្យលោកមុខ(របស់ពួកគេ)។ ជាគ្រឿងផឹកដ៏អាក្រក់បំផុត និងជាកន្លែងស្នាក់នៅដ៏អាក្រក់បំផុត។

30. ជាការពិតណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលនោះ ពិតប្រាកដណាស់ យើងនឹងមិនបំបាត់នូវផលបុណ្យរបស់អ្នកដែលបានសាងអំពើល្អឡើយ។

31. អ្នកទាំងនោះ ពួកគេនឹងទទួលបាននូវឋានសួគ៌អាត់និនដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ នៅក្នុងឋានសួគ៌នោះ ពួកគេត្រូវបានតុបតែងលម្អដោយកងដៃធ្វើអំពីមាស និងស្លៀកសម្លៀកបំពាក់ពណ៌បៃតងធ្វើពីសូត្រម៉ដ្ឋខៃ និងសូត្រក្រាស់ដោយពួកគេផ្អែកខ្លួននៅលើគ្រែ(ដែលត្រូវបានតុបតែងយ៉ាងប្រណីត)។ ជាការតបស្នងដ៏ប្រសើរបំផុត និងជាកន្លែងស្នាក់នៅដ៏ល្អប្រពៃបំផុត។

32. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកយកបុរសពីរនាក់មកធ្វើជាឧទាហរណ៍ដល់ពួកគេ។ ម្នាក់ក្នុងចំណោមពួកគេយើងបានប្រទានឱ្យនូវចម្ការចំនួនពីរអំពីដើមទំពាំងបាយជូរ ហើយយើងបានធ្វើរបងព័ទ្ធជុំវិញចម្ការទាំងពីរនោះនឹងដើមល្មើ ព្រមទាំងធ្វើឱ្យមានដំណាំផ្សេងៗនៅក្នុងចន្លោះចម្ការទាំងពីរនោះទៀតផង។

33. ចម្ការនីមួយៗបានផ្តល់នូវផលានុផលរបស់វា(យ៉ាងច្រើន)ដោយគ្មានខ្វះឡើយ។ ហើយយើងបានធ្វើឱ្យមានទន្លេមួយហូរកាត់នៅចន្លោះចម្ការទាំងពីរនោះផងដែរ។

34. ហើយម្ចាស់ចម្ការនោះមានផលានុផលផ្សេងទៀត។ ពេលនោះ គេបាននិយាយទៅកាន់មិត្តភក្តិរបស់ខ្លួនខណៈដែលគេទាំងពីរកំពុងសន្ទនាគ្នាថា៖ ខ្ញុំមានទ្រព្យសម្បត្តិច្រើនជាងអ្នក និងមានអ្នកខ្លាំងចាំជួយច្រើនជាងអ្នក។

35. ហើយបុរសនោះបានចូលទៅក្នុងចម្ការរបស់ខ្លួន ខណៈដែលរូបគេជាអ្នកបំពានលើខ្លួនឯង។ គេបាននិយាយថា៖ ខ្ញុំមិនគិតថា ចម្ការនេះនឹងត្រូវវិនាសអន្តរាយនោះឡើយ។

36. ហើយខ្ញុំក៏មិនគិតថា ថ្ងៃបរលោកនឹងកើតឡើងនោះដែរ។ តែប្រសិនបើវាកើតឡើងមែន ហើយខ្ញុំនឹងត្រូវបានគេនាំត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ខ្ញុំវិញនោះ ខ្ញុំពិតជានឹងទទួលបាននូវកន្លែងវិលត្រឡប់មួយដែលល្អប្រសើរជាងចម្ការនេះទៅទៀត។

37. មិត្តភក្តិរបស់គេ(ដែលជាអ្នកមានជំនឿ)បានតបទៅកាន់គេវិញ ខណៈដែលគេទាំងពីរកំពុងសន្ទនាគ្នាថា៖ តើអ្នកប្រឆាំងនឹងអ្នកដែលបានបង្កើតរូបអ្នកអំពីដី បន្ទាប់មក អំពីទឹកកាម បន្ទាប់មកទៀត បានធ្វើឱ្យអ្នកមានរូបរាងជាមនុស្សនោះឬ?

38. ប៉ុន្តែចំពោះខ្ញុំវិញ ទ្រង់គឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំនឹងមិនយកអ្នកណាម្នាក់មកធ្វើជាដៃគូរួមជាមួយព្រះជាម្ចាស់របស់ខ្ញុំឡើយ។

39. ហេតុអ្វីបានជានៅពេលដែលអ្នកចូលទៅក្នុងចម្ការរបស់អ្នក អ្នកមិនសូត្រថា៖(អ្វីដែលអល់ឡោះមានចេតនា គឺគ្មានឥទ្ធិពលណាក្រៅពីអល់ឡោះឡើយ)? ទោះបីជាអ្នកឃើញថា រូបខ្ញុំមានទ្រព្យសម្បត្តិ និងកូនចៅតិចជាងអ្នកក៏ដោយ

40. ក៏ខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់របស់ខ្ញុំនឹងប្រទានឲ្យខ្ញុំនូវអ្វីដែលល្អប្រសើរជាងចម្ការរបស់អ្នកទៅទៀត ហើយទ្រង់នឹងបញ្ជូនទណ្ឌកម្មពីលើមេឃទៅបំផ្លាញចម្ការរបស់អ្នក។ ពេលនោះ ចម្ការរបស់អ្នកនឹងក្លាយទៅជាដីដែលគ្មានរុក្ខជាតិ។

41. ឬក៏ទឹករបស់វាត្រូវបានស្រូបចូលទៅក្នុងដីអស់។ ពេលនោះ អ្នកមិនអាចយកទឹកនោះមក(ប្រើប្រាស់)វិញឡើយ។

42. ហើយផលានុផលនៃចម្ការរបស់គេ(អ្នកគ្មានជំនឿ)ត្រូវបានបំផ្លាញខ្ទេចខ្ទី។ ពេលនោះ បុរសនោះបានទះដៃទាំងពីរ(ដោយការសោកស្តាយ)ចំពោះអ្វីដែលគេបានចំណាយលើចម្ការនោះ ខណៈដែលទ្រើងរបស់វានោះបានដួលរលំខ្ទេចខ្ទីអស់ ហើយគេបាននិយាយថា៖ ឱអនិច្ចារូបខ្ញុំ! មិនគួរណាខ្ញុំយកអ្នកណាម្នាក់មកធ្វើជាដៃគូរួមជាមួយព្រះជាម្ចាស់របស់ខ្ញុំឡើយ។

43. ហើយសម្រាប់រូបគេ គ្មានក្រុមណាមួយដែលអាចជួយរូបគេក្រៅពីអល់ឡោះឡើយ ហើយរូបគេក៏មិនអាចរារាំង(ការបំផ្លាញចម្ការ)បាននោះដែរ។

44. នៅថ្ងៃនោះ សិទ្ធិអំណាចទាំងឡាយ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់តែមួយគត់។ ទ្រង់ជាអ្នកប្រទានផលបុណ្យដ៏ប្រសើរបំផុត និងជាអ្នកប្រទាននូវលទ្ធផលចុងក្រោយដ៏ប្រសើរបំផុត។

45. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកជាឧទាហរណ៍មួយសម្រាប់ពួកគេថា ជីវិតលោកិយ គឺប្រៀបដូចជាទឹកភ្លៀងដែលយើងបានបញ្ចុះវាពីលើមេឃ។ តាមរយៈទឹកភ្លៀងនោះ រុក្ខជាតិទាំងឡាយក៏បានដុះចេញមកចម្រុះគ្នា។ ក្រោយមកដំណាំទាំងនោះក៏បានក្លាយជាក្រៀមស្វិត ហើយត្រូវបានខ្យល់បក់បោក(ទៅគ្រប់ទីកន្លែង)។ ហើយអល់ឡោះទ្រង់ជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។

46. ទ្រព្យសម្បត្តិនិងកូនចៅ គឺគ្រាន់តែជាគ្រឿងលម្អនៃជីវិតលោកិយប៉ុណ្ណោះ។ រីឯទង្វើកុសលដែលនៅបិតបៀជោនិរន្តរ៍វិញ គឺជាផលបុណ្យដែលល្អប្រសើរនៅឯព្រះជាម្ចាស់របស់អ្នក និងជាក្តីសង្ឃឹមដ៏ប្រពៃ។

47. (ហើយចូរអ្នករំលឹក)នៅថ្ងៃដែលយើងនឹងធ្វើឱ្យភ្នំទាំងឡាយរសាត់(ចេញពីកន្លែងរបស់វា)ហើយអ្នកនឹងមើលឃើញផែនដីយ៉ាងច្បាស់។ ហើយយើងនឹងប្រមូលផ្តុំពួកគេទាំងអស់ដោយមិនបន្សល់ទុកនរណាម្នាក់ក្នុងចំណោមពួកគេឡើយ។

48. ហើយមនុស្សលោកទាំងអស់ត្រូវបានគេនាំមកបង្ហាញខ្លួនជាជួរៗនៅចំពោះមុខព្រះជាម្ចាស់របស់អ្នក។ (ទ្រង់បានមានបន្ទូលថា៖) ជាការពិតណាស់ ពួកអ្នកមកជួបយើង ដូចពេលដែលយើងបានបង្កើតពួកអ្នកកាលពីដំបូងដូច្នោះដែរ។ ផ្ទុយទៅវិញ ពួកអ្នកបានគិតថា យើងមិនបានកំណត់ពេលសន្យាសម្រាប់ពួកអ្នកនោះឡើយ។

49. ហើយសៀវភៅកំណត់ត្រាទង្វើត្រូវបានគេដាក់(បង្ហាញ)។ ពេលនោះ អ្នកនឹងឃើញពួកដែលប្រព្រឹត្តល្មើសទាំងឡាយមានការភ័យខ្លាចនូវអ្វីដែលមាននៅក្នុងវា(សៀវភៅកំណត់ត្រាទង្វើរបស់ពួកគេ) ហើយពួកគេនឹងនិយាយថា៖ ឱអនិច្ចាពួកយើង! តើនេះជាសៀវភៅកំណត់ហេតុអ្វីទៅបានជាវាមិនបាត់អ្វីសោះ មិនថាតូច មិនថាធំ លើកលែងតែវាបានកត់ត្រាទុកទាំងអស់ដូច្នោះ? ហើយពួកគេបានឃើញនូវអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តនៅចំពោះមុខ(ពួកគេ)។ ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបំពានលើនរណាម្នាក់ឡើយ។

50. (ហើយចូរអ្នករំលឹក) នៅពេលដែលយើងបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ចូរពួកអ្នកក្រាបស៊ូជូតចំពោះព្យាការីអាដាំ។ ពេលនោះ ពួកគេទាំងអស់ក៏បានស៊ូជូត លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលស្ថិតក្នុងចំណោមអម្បូរជិនដោយវាបានងាកចេញពីការប្រតិបត្តិតាមបទបញ្ជានៃព្រះជាម្ចាស់របស់វា។ ដូច្នេះ តើពួកអ្នក(ឱមនុស្សទាំងឡាយ)យកវា និងកូនចៅរបស់វាធ្វើជាអ្នកគាំពារក្រៅពីយើងឬ ខណៈដែលពួកវាគឺជាសត្រូវរបស់ពួកអ្នកនោះ? ការជំនួសបែបនេះ គឺអាក្រក់បំផុតសម្រាប់ពួកដែលបំពាន។

51. យើងមិនបានយកពួកវាធ្វើជាសាក្សីនៃការបង្កើតមេឃជាច្រើនជាន់និងផែនដី និងនៅក្នុងការបង្កើតពួកគេខ្លួនឯងនោះឡើយ។ ហើយយើងក៏មិនបានយកពួកដែលវង្វេងធ្វើជាជំនួយការនោះដែរ។

52. ហើយ(ចូរអ្នកព្យាករ)នៅពេលដែលទ្រង់មានបន្ទូលថា៖ ចូរពួកអ្នកហៅដៃគូទាំងឡាយរបស់យើងដែលពួកអ្នកធ្លាប់បានអះអាងនោះមក។ ពេលនោះ ពួកគេក៏បានហៅពួកវា ប៉ុន្តែពួកវាមិនបានឆ្លើយតបចំពោះពួកគេនោះឡើយ។ ហើយយើងបានបង្កើតកន្លែងវិនាសអន្តរាយមួយរវាងពួកគេ។

53. ហើយពួកដែលប្រព្រឹត្តល្មើសទាំងឡាយបានឃើញភ្លើងនរក(ផ្ទាល់នឹងភ្នែក)ហើយពួកគេជឿជាក់ថាៈ ពិតប្រាកដណាស់ ពួកគេនឹងធ្លាក់ចូលទៅក្នុងវា ហើយពួកគេមិនមានកន្លែងណាដែលអាចគេចខ្លួនអំពីវាបានឡើយ។

54. ហើយជាការពិតណាស់ យើងបានបកស្រាយបញ្ជាក់នៅក្នុងគម្ពីរគួរអាននេះនូវរាល់ឧទាហរណ៍ទាំងអស់សម្រាប់មនុស្សលោក។ ក៏ប៉ុន្តែមនុស្សលោក គឺជាភាវៈមួយដែលជជែកដេញដោលច្រើនជាងគេ។

55. ហើយគ្មានអ្វីដែលរារាំងមនុស្សមិនឲ្យមានជំនឿនោះឡើយ ខណៈដែលការចង្អុលបង្ហាញបានមកដល់ពួកគេ និងរារាំងពួកគេមិនឲ្យសុំការអភ័យទោសពីព្រះជាម្ចាស់របស់ពួកគេនោះដែរ ក្រៅតែពីពួកគេទាមទារឲ្យក្រឹតក្រមរបស់អ្នកជំនាន់មុន(ការបំផ្លាញពួកទាំងនោះ)ធ្លាក់ទៅលើពួកគេ ឬនាំមកឲ្យពួកគេនូវទណ្ឌកម្មផ្ទាល់នឹងភ្នែក។

56. ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់នោះឡើយ លើកលែងតែជាអ្នកផ្តល់ដំណឹងរីករាយ និងដាស់តឿនព្រមានប៉ុណ្ណោះ។ ហើយពួកគ្មានជំនឿបានជជែកដេញដោល(នឹងអ្នកនាំសារ)ដោយមិនត្រឹមត្រូវ ដើម្បីធ្វើឱ្យប្រការមិនត្រឹមត្រូវរបស់ពួកគេបំបាត់នូវប្រការត្រឹមត្រូវ។ ហើយពួកគេបានចាត់ទុកបណ្តាវាក្យខណ្ឌរបស់យើង(គម្ពីរគួរអាន)និងអ្វីដែលគេព្រមានបន្លាចពួកគេនោះ ជាការលេងសើចទៅវិញ។

57. ហើយគ្មាននរណាម្នាក់ដែលបំពានខ្លាំងជាងអ្នកដែលមានគេវ៉ែកនូវសញ្ញាកសុតាងទាំងឡាយនៃព្រះជាម្ចាស់របស់គេ តែគេបែរជាងាកចេញអំពីវា ហើយភ្លេចនូវអ្វីដែលដៃទាំងពីររបស់គេបានប្រព្រឹត្តនោះឡើយ។ ពិតប្រាកដណាស់ យើងបានដាក់គម្របនៅលើដួងចិត្តរបស់ពួកគេមិនឱ្យពួកគេយល់ពីវា(គម្ពីរគួរអាន)និងបានដាក់ឆ្នុកក្នុងត្រចៀករបស់ពួក(មិនឲ្យស្តាប់ឮ)។ ហើយប្រសិនបើអ្នកអំពាវនាវពួកគេទៅកាន់ការចង្អុលបង្ហាញក៏ដោយ ក៏ពួកគេមិនទទួលការចង្អុលបង្ហាញជាដាច់ខាត។

58. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មហាអភ័យទោស និងមានក្តីមេត្តាករុណាបំផុត។ ប្រសិនបើទ្រង់យកទោសពៃរ៍ពួកគេចំពោះអ្វីដែលពួកគេបានប្រព្រឹត្តនោះ ទ្រង់ប្រាកដជានឹងដាក់ទណ្ឌកម្មពួកគេភ្លាម។(ក្នុងលោកិយ)ជាមិនខាន។ ផ្ទុយទៅវិញ សម្រាប់ពួកគេ គឺមានពេលសន្យាជាក់លាក់ដោយពួកគេគ្មានកន្លែងជ្រកកោនណាក្រៅពីទ្រង់ឡើយ។

59. ហើយភូមិស្រុកទាំងនោះ យើងបានបំផ្លាញពួកគេនៅពេលដែលពួកគេបានបំពាន។ ហើយយើងបានកំណត់ពេលវេលាជាក់លាក់មួយដើម្បីបំផ្លាញពួកគេ។

60. ហើយ(ចូរអ្នករំលឹក)នៅពេលដែលព្យាការីមូសាបាននិយាយទៅក្មេងបម្រើប្រុសរបស់គាត់ថាៈ ខ្ញុំនៅតែបន្តធ្វើដំណើរហូតទាល់តែខ្ញុំបានទៅដល់ចំណុចប្រសព្វនៃសមុទ្រពីរ ឬក៏ខ្ញុំត្រូវធ្វើដំណើរអស់រយៈពេលយ៉ាងយូរ(ទាល់តែខ្ញុំបានជួបនឹងខ្ញុំបម្រើរបស់អល់ឡោះដែលជាមនុស្សល្អម្នាក់នោះ)។

61. នៅពេលដែលគេទាំងពីរបានទៅដល់ចំណុចប្រសព្វនៃសមុទ្រពីរ គេទាំងពីរក៏បានភ្លេចត្រីរបស់ពួកគេ។ ពេលនោះ ត្រីក៏បាននៀលតាមផ្លូវរបស់វាចូលទៅក្នុងសមុទ្របាត់ទៅ។

62. ហើយនៅពេលគេទាំងពីរបានឆ្លងផុតកន្លែងនោះ(ចំណុចប្រសព្វ)គាត់បានពោលទៅកាន់ក្មេងបម្រើប្រុសរបស់គាត់ថាៈ ចូរអ្នកយកអាហារថ្ងៃត្រង់មកឱ្យយើង។ ជាការពិតណាស់ យើងមានការនឿយហត់ជាខ្លាំងក្នុងការធ្វើដំណើររបស់យើងនេះ។

63. ក្មេងបម្រើនោះបានតបថា៖ តើអ្នកនឹកឃើញទេ នៅពេលដែលពួកយើងបានសម្រាកនៅក្បែរផ្នាំងថ្មនោះ? ពិតប្រាកណាស់ ខ្ញុំបានភ្លេចត្រី(នៅទីនោះ)ហើយគ្មានអ្វីដែលធ្វើឱ្យខ្ញុំភ្លេចរំលឹកវា(ប្រាប់ដល់អ្នក)ក្រៅពីស្មៃតននោះឡើយ។ ហើយត្រីនោះក៏បាននៀលតាមផ្លូវរបស់វាចូលទៅក្នុងសមុទ្រយ៉ាងចម្លែក។

64. គាត់បានតបថា៖ នោះហើយជាអ្វី(កន្លែង)ដែលពួកយើងត្រូវស្វែងរក។ ពេលនោះ គេទាំងពីរក៏បានត្រឡប់ក្រោយតាមដានជើងរបស់គេទាំងពីរវិញ។

65. ពេលនោះ គេទាំងពីរក៏បានជួបនឹងខ្ញុំបម្រើម្នាក់ក្នុងចំណោមខ្ញុំបម្រើរបស់យើង(ព្យាការីខហ្ស៊ៀរ)ដែលយើងបានប្រទានឲ្យគេនូវក្តីមេត្តាករុណាពីយើង ហើយយើងបានបង្រៀនដល់គេនូវចំណេះដឹងអំពីយើង។

66. ព្យាការីមូសាបានពោលទៅកាន់គាត់(ព្យាការីខហ្ស៊ៀរ)៖ តើខ្ញុំអាចដើរតាមអ្នកដើម្បីឱ្យអ្នកបង្រៀនខ្ញុំអំពីចំណេះដឹងត្រឹមត្រូវដែលគេ(អល់ឡោះ)បានបង្រៀនដល់អ្នកដែរឬទេ?

67. គាត់បានតបថា៖ ពិតប្រាកដណាស់ អ្នកមិនអាចអត់ធ្មត់នៅជាមួយនឹងខ្ញុំបាននោះទេ។

68. តើអ្នកអាចអត់ធ្មត់ទៅលើអ្វី(សកម្មភាព)ដែលអ្នកមិនដឹងពីមូលហេតុរបស់វាយ៉ាងដូចម្តេច?!

69. ព្យាការីមូសាបានតបវិញថា៖ អ៊ិនស្ហាអល់ឡោះ(ប្រសិនបើអល់ឡោះមានចេតនា) អ្នកនឹងឃើញខ្ញុំជាអ្នកដែលអត់ធ្មត់។ ហើយខ្ញុំនឹងមិនធ្វើឲ្យខុសពីបទបញ្ជារបស់អ្នកនោះឡើយ។

70. គាត់តបថា៖ ដូច្នេះ ប្រសិនបើអ្នកដើរតាមខ្ញុំនោះ អ្នកមិនត្រូវសួរខ្ញុំអំពីអ្វីមួយ(ដែលអ្នកមិនពេញចិត្ត)ឡើយ រហូតទាល់តែខ្ញុំបញ្ជាក់ប្រាប់អ្នកពីមូលហេតុរបស់វា។

71. ពេលនោះគាត់ទាំងពីរក៏បានធ្វើដំណើរ។ លុះដល់ពេលដែលគាត់ទាំងពីរឡើងលើសំពៅ គាត់(ព្យាការីខហ្ស៊ៀរ)ក៏បានទម្លុះសំពៅនោះ។ នៅពេលនោះ ព្យាការីមូសាក៏និយាយថា៖ តើអ្នកទម្លុះវាដើម្បីឱ្យម្ចាស់សំពៅនេះលិចលង់ឬ? ជាការពិតណាស់ អ្នកបានធ្វើនូវរឿងមួយដ៏អាក្រក់។

72. គាត់បានតបវិញថា៖ តើខ្ញុំមិនបានប្រាប់អ្នកទេឬថា ពិតប្រាកដណាស់ អ្នកនឹងមិនអាចអត់ធ្មត់នៅជាមួយខ្ញុំបានឡើយ?

73. ព្យាការីមូសាបានតបថា៖ សូមអ្នកកុំយកទោសពៃរ៍ខ្ញុំព្រោះតែការភ្លេចភ្លាំងរបស់ខ្ញុំ ហើយសូមអ្នកកុំធ្វើឲ្យខ្ញុំលំបាកចំពោះកិច្ចការរបស់ខ្ញុំ។

74. ពេលនោះ ពួកគាត់ទាំងពីរក៏បានបន្តដំណើរ(ទៅមុខទៀត)។ លុះនៅពេលដែលគាត់ទាំងពីរបានជួបនឹងក្មេងប្រុសម្នាក់ គាត់(ព្យាការីខហ្ស៊ៀរ)ក៏បានសម្លាប់ក្មេងប្រុសនោះ។ ព្យាការីមូសាក៏បានសួរថា៖ តើអ្នកសម្លាប់ជីវិតស្អាតស្អំម្នាក់ដោយមិនត្រឹមត្រូវបែបនេះឬ?! ជាការពិតណាស់ អ្នកបានប្រព្រឹត្តនូវអំពើមួយដែលអាក្រក់បំផុត។

75. គាត់បានតបថា៖ តើខ្ញុំមិនបានប្រាប់អ្នកទេឬថា ពិតប្រាកដណាស់ អ្នកនឹងមិនអាចអត់ធ្មត់នៅជាមួយខ្ញុំបានឡើយ?

76. ព្យាការីមូសាបានក៏បានតបថា៖ ប្រសិនបើខ្ញុំសួរម្តងទៀតអំពីអ្វីមួយបន្ទាប់ពីនេះ សូមអ្នកកុំឲ្យខ្ញុំរួមដំណើរជាមួយអ្នកទៀតអី។ ពិតប្រាកដណាស់ អ្នកបានឈានដល់ការអធ្យាស្រ័យចុងក្រោយចំពោះខ្ញុំទៅហើយ។

77. ពេលនោះ គាត់ទាំងពីរក៏បន្តដំណើរទៅមុខទៀត។ លុះដល់ពេលគាត់ទាំងពីរទៅដល់ភូមិមួយ គាត់ទាំងពីរបានសុំចំណីអាហារពីអ្នកភូមិនោះ តែពួកគេបានបដិសេធមិនទទួលពួកគាត់ទាំងពីរជាភ្ញៀវឡើយ។ ក្រោយមក គាត់ទាំងពីរបានឃើញជញ្ជាំងមួយនៅក្នុងភូមិជិតដួលរលំ គាត់(ព្យាការីខហ្ស៊ៀរ)ក៏បានធ្វើឱ្យវាត្រង់ឡើងវិញ។ ព្យាការីមូសាក៏បានពោលថា៖ ប្រសិនបើអ្នកចង់ អ្នកអាចយកថ្លៃឈ្នួលចំពោះវាបាន។

78. គាត់ក៏តបវិញថា៖ នេះជាការបែកគ្នារវាងខ្ញុំ និងអ្នកហើយ។ ខ្ញុំនឹងបកស្រាយប្រាប់អ្នកនូវអ្វីដែលអ្នកមិនអាចអត់ធ្មត់ចំពោះវាបាននោះ។

79. ចំពោះរឿងសំពៅ ពិតណាស់វាជាកម្មសិទ្ធិរបស់អ្នកក្រដែលប្រកបរបរនៅលើផ្ទៃសមុទ្រ ហើយខ្ញុំមានចេតនាធ្វើឱ្យវាខូចខាត ព្រោះនៅខាងមុខ គឺមានស្តេចមួយអង្គដែលនឹងរឹបអូសយកទាំងបង្ខំនូវរាល់សំពៅទាំងឡាយណាដែលល្អៗ។

80. រីឯរឿងក្មេងប្រុសវិញ គឺឪពុកម្តាយរបស់គេជាអ្នកដែលមានជំនឿ ហើយយើងខ្លាចពេលគេធំឡើង គេនឹងអូសទាញឪពុកម្តាយរបស់គេឱ្យធ្លាក់ទៅក្នុងការបំពាន និងភាពគ្មានជំនឿ។

81. ហើយយើងចង់ឱ្យព្រះជាម្ចាស់របស់គេទាំងពីរផ្លាស់ប្តូរឱ្យគេទាំងពីរ(ដោយបង្កើត)នូវកូនម្នាក់ផ្សេងទៀតដែលល្អបរិសុទ្ធ និងជាទីស្រឡាញ់(ចំពោះគេទាំងពីរ)ជាងកូននោះ។

82. ចំណែកឯជញ្ជាំងវិញ ពិតណាស់វាជាកម្មសិទ្ធិរបស់ក្មេងកំព្រាពីរនាក់រស់នៅក្នុងទីក្រុង។ នៅពីក្រោមជញ្ជាំងនោះ គឺមានកំណប់ទ្រព្យរបស់គេទាំងពីរ ហើយឪពុករបស់ក្មេងប្រុសទាំងពីរនេះទៀតសោត គឺជាមនុស្សល្អ។ ដូចនេះ ព្រះជាម្ចាស់របស់អ្នក(ឱព្យាការីមូសា)មានបំណងចង់ឱ្យពេលដែលគេទាំងពីរពេញវ័យ ទ្រង់នឹងបញ្ចេញឲ្យគេទាំងពីរនូវកំណប់ទ្រព្យនោះ ជាក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់អ្នក។ ហើយខ្ញុំមិនបានធ្វើវាតាមតែទំនើងចិត្តរបស់ខ្ញុំឡើយ។ នោះហើយគឺជាការបកស្រាយចំពោះអ្វីដែលអ្នកមិនអាចអត់ធ្មត់ចំពោះវាបាននោះ។

83. ហើយពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីហ្ស៊ុលករណែន។ ចូរអ្នកពោលថា៖ ខ្ញុំនឹងនិទានរឿងរបស់គេមួយផ្នែកប្រាប់ដល់ពួកអ្នកដើម្បីជាការរំលឹក។

84. ពិតប្រាកដណាស់ យើង(អល់ឡោះ)បានប្រទានដល់គេនូវអំណាចគ្រប់គ្រងនៅលើផែនដី ហើយយើងបានផ្តល់ដល់គេនូវមាគ៌ាមួយចំពោះអ្វីៗគ្រប់យ៉ាង(ដើម្បីសម្រេចគោលដៅ)។

85. ហើយគេក៏បានដើរតាមមាគ៌ា(ដែលយើងបានផ្តល់ឲ្យនោះ)។

86. លុះនៅពេលដែលគេបានទៅដល់កន្លែងព្រះអាទិត្យលិច គេក៏បានឃើញវាលិចទៅក្នុងប្រភពទឹកក្តៅដែលមានកក់ខ្មៅ ហើយគេបានឃើញមនុស្ស(គ្មានជំនឿ)មួយក្រុមនៅទីនោះ។ យើងបានមានបន្ទូលថា៖ ឱហ្ស៊ុលករណែន! អ្នកអាចដាក់ទណ្ឌកម្មពួកគេ ឬក៏អ្នកអាចធ្វើល្អចំពោះពួកគេ។

87. គាត់បានតបថា៖ ចំពោះជនណាដែលបំពាន ខ្ញុំនឹងដាក់ទណ្ឌកម្មចំពោះរូបគេ។ ក្រោយមក រូបគេនឹងត្រូវគេនាំត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់គេវិញ។ ពេលនោះ ទ្រង់នឹងដាក់ទណ្ឌកម្មចំពោះរូបគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

88. រីឯជនណាដែលមានជំនឿ និងបានសាងទង្វើកុសលនោះ សម្រាប់គេនឹងទទួលបាននូវការតបស្នងដ៏ប្រសើរ(ឋានសួគ៌) ហើយខ្ញុំនឹងនិយាយទៅកាន់គេនូវពាក្យសម្តីដែលទន់ភ្លន់។

89. បន្ទាប់មក គេក៏បានដើរតាមមាគ៌ាមួយផ្សេងទៀត។

90. លុះដល់ពេលដែលគេបានទៅដល់កន្លែងដែលថ្ងៃរះ គេក៏បានឃើញវារះទៅលើក្រុមមួយដែលយើង(អល់ឡោះ)មិនបានផ្តល់អ្វីដល់ពួកគេដែលអាចបិទបាំងពីកម្តៅថ្ងៃឡើយ។

91. គឺដូច្នោះឯង។ ជាការពិតណាស់ ចំណេះដឹងរបស់យើង(អល់ឡោះ) ពិតជាបានដឹងជ្រួតជ្រាបចំពោះអ្វីដែលគេ(ហ្ស៊ុលករណែន)មាន។

92. បន្ទាប់មកទៀត គេក៏បានដើរតាមមាគ៌ាមួយផ្សេងទៀត។

93. លុះនៅពេលដែលគេបានទៅដល់ចន្លោះភ្នំទាំងពីរ គេក៏បានប្រទះឃើញមនុស្សមួយក្រុមនៅចន្លោះភ្នំទាំងពីរនោះដែលពួកគេស្ទើរតែមិនយល់នូវពាក្យសម្តី(របស់អ្នកដទៃ)ឡើយ។

94. ពួកគេបាននិយាយថា៖ ឱហ្ស៊ុលករណែន! ពិតប្រាកដណាស់ យ៉ាក់ជូចនិងម៉ាក់ជូច គឺជាពួកដែលបង្កវិនាសកម្មនៅលើផែនដី។ ហេតុនេះ តើពួកយើងអាចផ្តល់ថ្លៃឈ្នួលដល់អ្នកដើម្បីឱ្យអ្នកសាងសង់របាំងការពាររវាងពួកយើងនិងពួកវាបានដែរឬទេ?

95. គាត់ក៏បានតបថា៖ អ្វីដែលព្រះជាម្ចាស់របស់ខ្ញុំបានប្រទានឱ្យខ្ញុំ គឺប្រសើរជាងនោះទៅទៀត។ ដូច្នេះ សូមពួកអ្នកជួយខ្ញុំដោយកម្លាំងដើម្បីខ្ញុំនឹងសាងសង់របាំងការពាររវាងពួកអ្នក និងពួកវា។

96. ចូរពួកអ្នកយកដែកមួយបន្ទះៗមកឱ្យខ្ញុំ។ លុះដល់ពេលដែលវាពេញនៅចន្លោះភ្នំទាំងពីរហើយ គាត់ក៏និយាយថា៖ ចូរពួកអ្នកដុតភ្លើង(ទៅលើបន្ទះដែកទាំងនោះ)ចុះ។ លុះដល់ពេលដែលបន្ទះដែកទាំងនោះឡើង(ក្រហម)ដូចភ្លើង គាត់ក៏បាននិយាយថា៖ ចូរពួកអ្នកយកទង់ដែងរលាយមកឱ្យខ្ញុំ។ ខ្ញុំនឹងចាក់ពីលើវា។

97. ធ្វើដូច្នោះ ពួកវានឹងមិនអាចឡើងឆ្លងកាត់ជញ្ជាំងបានទេ ហើយពួកវាក៏មិនអាចទម្លុះវា(ពីខាងក្រោម)បាននោះដែរ។

98. គាត់បានបន្តថា៖ នេះជាក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់ខ្ញុំ។ តែនៅពេលដែលការសន្យានៃព្រះជាម្ចាស់របស់ខ្ញុំបានមកដល់ ទ្រង់នឹងធ្វើឱ្យវា(ជញ្ជាំងដែក)រាបស្មើដល់ដីវិញ។ ហើយការសន្យានៃព្រះជាម្ចាស់របស់ខ្ញុំ គឺជាការពិត។

99. ហើយយើង(អល់ឡោះ)នឹងព្រលែងពួកវានៅថ្ងៃនោះ(ថ្ងៃដែលការសន្យាមកដល់)ដោយពួកវានៅពពាក់ពពូនគ្នា។ ហើយគេបានផ្លុំត្រែ។ ពេលនោះ យើងក៏បានប្រមូលផ្តុំពួកគេទាំងអស់គ្នា(ដើម្បីជំនុំជម្រះ និងផ្តល់ការតបស្នង)។

100. ហើយនៅថ្ងៃនោះ យើងនឹងបង្ហាញនរកដើហាន់ណាំឱ្យពួកដែលគ្មានជំនឿបានឃើញយ៉ាងច្បាស់(ផ្ទាល់នឹងភ្នែក)។

101. គឺពួកដែលភ្នែករបស់ពួកគេមានរនាំងបាំងមិនឲ្យរំឭកមកចំពោះយើង ហើយពួកគេក៏មិនអាចស្តាប់ឮ(វាក្យខណ្ឌរបស់យើង)បាននោះដែរ។

102. តើពួកដែលគ្មានជំនឿគិតស្មានថា ពួកគេអាចយកខ្ញុំបម្រើរបស់យើងធ្វើជាអ្នកគាំពារក្រៅពីយើងបានឬ? ពិតប្រាកដណាស់ យើងបានត្រៀមនរកជើហាន់ណាំទុកសម្រាប់ពួកគ្មានជំនឿជាកន្លែងជ្រកកោន(របស់ពួកគេ)។

103. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើចង់ឱ្យខ្ញុំប្រាប់ពួកអ្នកអំពីអ្នកដែលខាតបង់ធំធេងជាងគេចំពោះទង្វើទាំងឡាយ(របស់ខ្លួន)ដែរឬទេ?

104. គឺពួកដែលការខិតខំប្រឹងប្រែងរបស់ពួកគេនៅក្នុងលោកិយបានក្លាយជាអសារបង់ ខណៈដែលពួកគេគិតថា៖ ពិតប្រាកដណាស់ ពួកគេគឺកំពុងតែធ្វើអំពើល្អ។

105. ពួកទាំងនោះ គឺជាពួកដែលប្រឆាំងនឹងសញ្ញាកស្តុតាងនៃព្រះជាម្ចាស់របស់ពួកគេ និងការជួបនឹងទ្រង់(នៅថ្ងៃបរលោក)។ ពេលនោះ ទង្វើកុសលទាំងឡាយរបស់ពួកគេ បានក្លាយជាអសារបង់។ ដូច្នេះ នៅថ្ងៃបរលោក យើងនឹងមិនផ្តល់តម្លៃអ្វីបន្តិចដល់ពួកគេនោះឡើយ។

106. ការតបស្នងសម្រាប់ពួកគេ គឺនរកជើហាន់ណាំ ដោយសារតែពួកគេបានប្រឆាំង និងបានយកសញ្ញាកស្តុតាងរបស់យើង ព្រមទាំងបណ្តាអ្នកនាំសារទាំងឡាយរបស់យើងធ្វើជាការចំអកឡកឡឺយ។

107. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ពួកគេនឹងទទួលបានឋានសួគ៌ហ្វៀរទ័សជាកន្លែងស្នាក់នៅ។

108. ពួកគេនឹងស្ថិតនៅក្នុងនោះជាអមតៈ ដោយពួកគេមិនចង់ឱ្យមានការផ្លាស់ប្តូរវាឡើយ។

109. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ប្រសិនបើទឹកសមុទ្រ គឺជាទឹកខ្មៅសម្រាប់កត់ត្រាបន្ទូលព្រះជាម្ចាស់របស់ខ្ញុំ នោះទឹកសមុទ្រនឹងត្រូវរីងស្ងួតមុននឹងបញ្ចប់ការកត់ត្រាបន្ទូលព្រះជាម្ចាស់របស់ខ្ញុំជាមិនខាន បើទោះបីពួកយើងនាំយកទឹកសមុទ្រដូចនោះទៀតមកបន្ថែមក៏ដោយ (ក៏មិនគ្រប់គ្រាន់ដែរ)។

110. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត ខ្ញុំជាមនុស្សលោកធម្មតាដូចពួកអ្នកដែរ គ្រាន់តែគេបានផ្តល់វាហ៊ីមកឱ្យខ្ញុំថា៖ តាមពិត ព្រះជាម្ចាស់របស់ពួកអ្នកដែលត្រូវគោរពសក្ការៈ គឺជាព្រះជាម្ចាស់តែមួយគត់។ ដូចនេះ ជនណាហើយដែលរំពឹងថានឹងជួបព្រះជាម្ចាស់របស់គេនោះ ចូរឱ្យគេសាងទង្វើកុសល និងមិនត្រូវយកអ្នកណាម្នាក់មកគោរពសក្ការៈរួមជាមួយនឹងព្រះជាម្ចាស់របស់គេឡើយ។

ជំពូក ម៉ារយ៉ាំ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. កាហ្វ ហា យ៉ា អ៊ីន សទ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. (នេះគឺជា)ការរំឭកពីក្តីមេត្តាករុណានៃព្រះជាម្ចាស់របស់អ្នកចំពោះខ្ញុំបម្រើរបស់ទ្រង់ គឺព្យាការីហ្សាការីយ៉ា។

3. ខណៈពេលដែលគាត់បួងសួងសុំពីព្រះជាម្ចាស់របស់គាត់នូវការបួងសួងមួយយ៉ាងស្ងាត់ៗបំផុត។

4. គាត់បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ឆ្អឹងរបស់ខ្ញុំបានទ្រុឌទ្រោមទៅហើយ ឯសក់ក្បាលរបស់ខ្ញុំក៏ស្កូវព្រោងព្រាតទៀត ហើយខ្ញុំក៏មិនធ្លាប់ត្រូវបានព្រះអង្គ ឱព្រះជាម្ចាស់បដិសេធក្នុងការបួងសួងសុំទៅចំពោះព្រះអង្គនោះដែរ។

5. ហើយពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចញាតិសន្តានរបស់ខ្ញុំ ដោយបន្ទាប់ពីខ្ញុំស្លាប់ទៅ(មិនបានអនុវត្តពេញលេញតាមក្បួនច្បាប់របស់ព្រះអង្គ)ហើយភរិយារបស់ខ្ញុំក៏ជាស្ត្រីអារថែមទៀត។ ហេតុនេះ សូមព្រះអង្គមេត្តាប្រទានដល់ខ្ញុំនូវអ្នកស្នងត្រកូលម្នាក់អំពីព្រះអង្គផងចុះ

6. ដែលគេនឹងទទួលមរតកអំពីខ្ញុំ និងទទួលមរតកពីពូជពង្សរបស់ព្យាការីយ៉ាក់កូប។ ហើយសូមព្រះអង្គ ឱព្រះជាម្ចាស់របស់ខ្ញុំមេត្តាធ្វើឱ្យគេក្លាយទៅជាអ្នកដែលជាទីគាប់ចិត្តផង។

7. (ទ្រង់បានមានបន្ទូលថា៖)ឱហ្សាការីយ៉ា! ពិតប្រាកដណាស់ យើងសូមផ្តល់ដំណឹងរីករាយដល់អ្នកនូវក្មេងប្រុស(កូនប្រុស)ម្នាក់ ឈ្មោះរបស់គេគឺ យ៉ះយ៉ា ដែលយើងមិនធ្លាប់ដាក់ឈ្មោះនេះឱ្យអ្នកណាពីមុនមកឡើយ។

8. គាត់បានតបថា៖ បពិត្រព្រះជាម្ចាស់! តើឲ្យខ្ញុំមានកូនយ៉ាងដូចម្តេច បើភរិយារបស់ខ្ញុំជាស្ត្រីអារ។ រីឯខ្ញុំវិញ ក៏ឈានដល់វ័យចំណាស់ ទ្រុឌទ្រោមហើយនោះ?!

9. ម៉ាឡាអ៊ីកាត់(ជីព្រីល)បានពោលថា៖ គឺដូច្នោះឯង។ ប៉ុន្តែព្រះជាម្ចាស់របស់អ្នកទ្រង់មានបន្ទូលថា៖ វាគឺជារឿងងាយស្រួលបំផុតសម្រាប់យើង។ ពិតប្រាកដណាស់ យើងបានបង្កើតអ្នក(ឱហ្សាការីយ៉ា)កាលពីមុនទាំងដែលអ្នកពុំទាន់មានអ្វីសោះ។

10. គាត់បានតបថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាផ្តល់និមិត្តសញ្ញាណាមួយដល់ខ្ញុំផង។ ទ្រង់បានតបវិញថា៖ និមិត្តសញ្ញារបស់អ្នក គឺអ្នកមិនអាចនិយាយជាមួយមនុស្សលោកបានឡើយក្នុងរយៈពេលបីយប់ ទាំងដែលអ្នកនៅមានសុខភាពល្អ។

11. ពេលនោះ គាត់ក៏បានចេញពីកន្លែងថ្វាយបង្គំទៅជួបនឹងក្រុមរបស់គាត់ ហើយគាត់បានធ្វើសញ្ញាទៅកាន់ពួកគេ ដោយឱ្យពួកគេលើកតម្កើងសរសើរអល់ឡោះ ទាំងព្រឹក ទាំងល្ងាច។

12. (អល់ឡោះបានមានបន្ទូលថា៖) ឱយ៉ះយ៉ា! ចូរអ្នកប្រកាន់តាមគម្ពីរតោរ៉ាតឱ្យបានខ្ជាប់ខ្ជួនបំផុត។ ហើយយើងបានប្រទានការយល់ដឹងដល់គាត់តាំងពីកុមារភាព។

13. ហើយយើងបានប្រទាននូវក្តីអាណិតស្រលាញ់អំពីយើង និងភាពបរិសុទ្ធពីអំពើបាបកម្មទាំងឡាយ។ ហើយគាត់ គឺជាអ្នកដែលកោតខ្លាច(អល់ឡោះ)។

14. ហើយគាត់ជាកូនដែលកតញ្ញូចំពោះឪពុកម្តាយ ហើយគាត់មិនដែលក្រអឺតក្រទម និងប្រឆាំងនោះឡើយ។

15. សូមសន្តិភាពកើតមានដល់គាត់នៅថ្ងៃដែលគាត់ប្រសូត និងនៅថ្ងៃដែលគាត់ស្លាប់ ហើយនិងនៅថ្ងៃដែលត្រូវគេបង្កើតឱ្យរស់ឡើងវិញ(ថ្ងៃបរលោក)។

16. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រំឭកពីរឿងរបស់ម៉ារយ៉ាំនៅក្នុងគម្ពីរ(គួរអាន)ខណៈដែលនាងបានចាកឆ្ងាយពីក្រុមគ្រួសាររបស់នាងទៅកាន់កន្លែងមួយនៅទិសខាងកើត។

17. ពេលនោះ នាងបានយករបាំងមួយមកបិទបាំងខ្លួនប្រាណរបស់នាងពីពួកគេ។ ក្រោយមក យើងបានបញ្ជូនម៉ាឡាអ៊ីកាត់របស់យើង គឺជីព្រីល ទៅកាន់នាង ដោយគេតំណែងខ្លួនជាមនុស្សពេញលក្ខណៈម្នាក់ទៅជួបនាង។

18. នាងបានពោលថា៖ ពិតប្រាកដណាស់ ខ្ញុំសុំពី(អល់ឡោះ)ម្ចាស់មហាសប្បុរសឱ្យបញ្ចៀសរូបខ្ញុំពីអ្នក ប្រសិនបើអ្នកជាអ្នកដែលកោតខ្លាច(អល់ឡោះ)នោះ។

19. ជីព្រីលបានតបវិញថា៖ តាមពិត ខ្ញុំគឺជាអ្នកនាំសារពីព្រះជាម្ចាស់របស់អ្នកដើម្បីប្រទាន(ដំណឹងរីករាយ)ដល់អ្នកនូវកូនប្រុសដែលបរិសុទ្ធម្នាក់។

20. នាងបានតបថា៖ តើឱ្យខ្ញុំមានកូនប្រុសយ៉ាងដូចម្តេច បើគ្មាននរណាម្នាក់ប៉ះពាល់ខ្ញុំ(មិនធ្លាប់រៀបការ) ហើយខ្ញុំក៏មិនធ្លាប់ប្រព្រឹត្តអំពើពេស្យាផងនោះ?!

21. ម៉ាឡាអ៊ីកាត់(ជីព្រីល)បានពោលថា៖ គឺដូច្នោះឯង។ ប៉ុន្តែព្រះជាម្ចាស់របស់អ្នកទ្រង់មានបន្ទូលថា៖ វាគឺជារឿងងាយស្រួលបំផុតសម្រាប់យើង។ ហើយយើងនឹងយកគេធ្វើជាសញ្ញាកស្តុតាងសម្រាប់មនុស្សលោក និងជាក្តីមេត្តាករុណាអំពីយើង។ ហើយវាគឺជាកិច្ចការដែលត្រូវបានកំណត់រួចជាស្រេច(នៅក្នុងឡាវហ៊ុលម៉ះហ្វូស)។

22. ដូច្នេះ នាងក៏ចាប់ផ្តើមមានគភ៌ ហើយនាងក៏បានចាកចេញទៅកន្លែងមួយដែលឆ្ងាយពីមនុស្សលោក។

23. ហើយការឈឺចាប់នៅពេលមុនសម្រាលបានជំរុញនាងឲ្យដើរទៅកាន់ដើមល្មើមួយដើម។ នាងបានពោលថា៖ ឱអនិច្ចាខ្ញុំអើយ! ប្រសិនបើខ្ញុំបានស្លាប់មុនថ្ងៃនេះ ខ្ញុំនឹងត្រូវបានគេបំភ្លេច មិនត្រូវបានគេនឹកនានោះឡើយ។

24. នៅពេលនោះ ព្យាការីអ៊ីសា(ដែលទើបប្រសូត្រ)បានស្រែកប្រាប់នាងពីក្រោមជើងរបស់នាងមកថា៖ សូមអ្នកកុំព្រួយបារម្ភអ្វី។ ជាការពិតណាស់ ព្រះជាម្ចាស់របស់អ្នកបានធ្វើឱ្យមានប្រឡាយទឹកមួយនៅពីក្រោមអ្នក។

25. ហើយសូមអ្នកចាប់អង្រួនគល់ល្មើនេះ នោះវានឹងជ្រុះនូវផ្លែទុំស្រស់ៗឱ្យអ្នកជាមិនខាន។

26. ហេតុនេះ ចូរអ្នកទទួលទាន និងផឹក(ទឹកនេះ) ហើយមានភាពរីករាយ(នឹងការទទួលបានកូនប្រុសនេះ)ចុះ។ ហើយប្រសិនបើអ្នកបានជួបមនុស្សណាម្នាក់ ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ ខ្ញុំបានសច្ចាកាន់តំណមទៅចំពោះព្រះជាម្ចាស់ដ៏មហាសប្បុរស។ ដូចនេះ ខ្ញុំមិននិយាយស្តីរកនរណាម្នាក់ឡើយក្នុងថ្ងៃនេះ។

27. បន្ទាប់មក នាងក៏បានទៅកាន់ក្រុមរបស់នាងដោយពកូនទៅជាមួយ។ (ឃើញដូចនោះ) ពួកគេក៏ពោលថា៖ ឱម៉ារយ៉ាំ! ជាការពិតណាស់ អ្នកបាននាំមកនូវរឿងប្រឌិតមួយដ៏ធំធេងបំផុត។

28. ឱប្អូនស្រីរបស់ហារូន! ឪពុករបស់អ្នកមិនមែនជាអ្នកប្រព្រឹត្តអំពើហ្ស៊ីណាទេ ហើយម្តាយរបស់អ្នកក៏មិនមែនជាស្រីពេស្យាដែរ។

29. នៅពេលនោះ នាងក៏បានចង្អុលទៅកាន់ទារកនោះ។ ពេលនោះ ពួកគេក៏និយាយថា៖ តើឱ្យពួកយើងសួរទៅកាន់ទារកដែលនៅក្នុងអង្រឹងនោះយ៉ាងដូចម្តេចទៅ?!

30. ទារកនោះ(ព្យាការីអ៊ីសា)ក៏បានពោលថា៖ ពិតប្រាកដណាស់ រូបខ្ញុំគឺជាខ្ញុំបម្រើរបស់អល់ឡោះជាម្ចាស់។ ទ្រង់បានប្រទានគម្ពីរ(អ៊ិញជីល)ដល់ខ្ញុំ និងបានតែងតាំងខ្ញុំជាព្យាការីម្នាក់។

31. ហើយទ្រង់បានធ្វើឱ្យខ្ញុំក្លាយជាអ្នកដែលមានពរជ័យគ្រប់ទីកន្លែងដែលខ្ញុំមានវត្តមាន ហើយទ្រង់បានផ្តែផ្តាំខ្ញុំឱ្យប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ដរាបណាខ្ញុំនៅមានជីវិត។

32. និងបានឱ្យខ្ញុំក្លាយជាកូនម្នាក់ដែលកតញ្ញូចំពោះម្តាយរបស់ខ្ញុំ ហើយទ្រង់មិនបានធ្វើឱ្យខ្ញុំក្លាយជាអ្នកក្រអឺតក្រទម និងប្រឆាំងនោះឡើយ។

33. ហើយសូមឱ្យសុវត្ថិភាពកើតមានដល់ខ្ញុំនៅថ្ងៃដែលខ្ញុំប្រសូត ថ្ងៃដែលខ្ញុំស្លាប់ និងនៅថ្ងៃដែលគេបង្កើតខ្ញុំឱ្យរស់ឡើងវិញ(នៅថ្ងៃបរលោក)។

34. នោះហើយគឺជាព្យាការីអ៊ីសាកូនប្រុសរបស់ម៉ារយ៉ាំ។ វាជាពាក្យពិតដែលពួកគេ(ពួកយូដា និងគ្រីស្ទាន)មានការសង្ស័យចំពោះវា។

35. មិនសក្តិសមឡើយចំពោះអល់ឡោះដែលថា ទ្រង់មានបុត្រនោះ។ ទ្រង់មហាស្អាតស្ំ។ ហើយនៅពេលដែលទ្រង់មានចេតនាចង់សម្រេចកិច្ចការអ្វីមួយ ទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" នោះវានឹងកើតឡើងភ្លាម។

36. ហើយពិតប្រាកដណាស់ អល់ឡោះគឺជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈចំពោះទ្រង់ចុះ។ នេះហើយគឺជាមាគ៌ាដ៏ត្រឹមត្រូវ។

37. ក្រោយមក ក្រុមជាច្រើនក្នុងចំណោមពួកគេក៏បានខ្វែងគំនិតគ្នា(នៅក្នុងរឿងរបស់ព្យាការីអ៊ីសា)។ ដូច្នេះ ភាពវិនាសអន្តរាយគឺសម្រាប់ពួកដែលប្រឆាំងនៅថ្ងៃជួបជុំដ៏ធំធេង(ថ្ងៃបរលោក)។

38. នៅថ្ងៃដែលពួកគេមកជួបនឹងយើង(អល់ឡោះ)នោះ ពួកគេស្តាប់ឮនិងឃើញបំផុត។ ក៏ប៉ុន្តែពួកដែលបំពាននៅក្នុងថ្ងៃនេះ(ក្នុងលោកិយ)គឺស្ថិតនៅក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

39. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដាស់តឿនព្រមានពួកគេអំពីថ្ងៃដ៏សោកស្តាយ(ថ្ងៃបរលោក) ខណៈដែលកិច្ចការត្រូវបានសម្រេច ទាំងដែលពួកគេស្ថិតក្នុងភាពព្រងើយកន្តើយ ហើយពួកគេមិនមានជំនឿឡើយ។

40. ពិតប្រាកដណាស់ យើង(អល់ឡោះ)នឹងទទួលមរតកផែនដី និងអ្វីៗទាំងអស់ដែលនៅលើផែនដី។ ហើយពួកគេនឹងត្រូវគេនាំត្រឡប់មកកាន់យើង(តែមួយគត់)។

41. ហើយចូរអ្នករំឭកពីរឿងរបស់ព្យាការីអ៊ីព្រហ៊ីមនៅក្នុងគម្ពីរ(គួរអាន)។ ពិតប្រាកដណាស់ គាត់ជាមនុស្សសច្ចៈ និងជាព្យាការីម្នាក់។

42. នៅពេលដែលគាត់បានពោលទៅកាន់ឪពុករបស់គាត់ថា៖ ឱលោកឪពុករបស់ខ្ញុំ! ហេតុអ្វីបានជាពុកគោរពសក្ការៈចំពោះអ្វីដែលមិនអាចស្តាប់ឮ មិនអាចមើលឃើញ ហើយក៏មិនអាចផ្តល់ផលប្រយោជន៍អ្វីបន្តិចដល់ពុកទាល់តែសោះនោះ?!

43. ឱលោកឪពុករបស់ខ្ញុំ! ពិតប្រាកដណាស់ ចំណេះដឹងខ្លះ(ពីអល់ឡោះ)បានមកដល់ខ្ញុំដែលវាមិនបានទៅមកដល់ពុកឡើយ។ ហេតុនេះ សូមពុកធ្វើតាមខ្ញុំ នោះខ្ញុំនឹងចង្អុលបង្ហាញពុកទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

44. ឱឪពុករបស់ខ្ញុំ! សូមពុកកុំគោរពសក្ការៈចំពោះស្មៃតនឱ្យសោះ។ ពិតប្រាកដណាស់ ស្មៃតនគឺជាអ្នកដែលប្រឆាំងនឹងព្រះជាម្ចាស់ដ៏មហាសប្បុរស។

45. ឱលោកឪពុករបស់ខ្ញុំ! ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពុកទទួលនូវទណ្ឌកម្មពីព្រះជាម្ចាស់ដ៏មហាសប្បុរស ដែលជាហេតុធ្វើឲ្យពុកក្លាយទៅជាគូកនរបស់ស្មៃតន។

46. គេក៏តបវិញថា៖ តើឯងប្រឆាំងនឹងព្រះនានារបស់យើងឬ ឱអ៊ីព្រហ៊ីម? ប្រសិនបើឯងមិនព្រមបញ្ឈប់ទេនោះ យើងពិតជានឹងគប់សម្លាប់ឯងជាមិនខាន។ ហើយចូរឯងចាកចេញឱ្យឆ្ងាយពីយើង។

47. គាត់បានតបវិញថា៖ សូមសុខសន្តិភាពកើតមានដល់លោកពុក! ខ្ញុំនឹងសុំពីព្រះជាម្ចាស់របស់ខ្ញុំឱ្យទ្រង់អភ័យទោសដល់ពុក។ ពិតប្រាកដណាស់ ទ្រង់តែងតែទន់ភ្លន់ចំពោះខ្ញុំជានិច្ច។

48. ហើយខ្ញុំនឹងចាកចេញពីពួកអ្នក និងអ្វីដែលពួកអ្នកគោរពសក្ការៈក្រៅពីអល់ឡោះ ហើយខ្ញុំនឹងបួងសួងសុំពីព្រះជាម្ចាស់របស់ខ្ញុំ។ សង្ឃឹមថា ព្រះជាម្ចាស់របស់ខ្ញុំទ្រង់មិនបដិសេធចំពោះការបួងសួង(របស់ខ្ញុំ)ឡើយ។

49. ដូច្នេះ នៅពេលដែលគាត់បានចាកចេញពីពួកគេ និងអ្វីដែលពួកគេគោរពសក្ការៈក្រៅពីអល់ឡោះនោះ យើង(អល់ឡោះ)បានប្រទានដល់គេនូវអ៊ីស្ហាក(ជាកូន) និងយ៉ាក់កូប(ជាចៅ)។ ហើយយើងក៏បានជ្រើសរើសគេទាំងពីរធ្វើជាព្យាការីផងដែរ។

50. ហើយយើងបានប្រទានដល់ពួកគេនូវក្តីមេត្តាករុណារបស់យើង និងបានផ្តល់ឲ្យពួកគេនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់(ពីសំណាក់មនុស្សគ្រប់ជំនាន់)។

51. ហើយចូរអ្នករំឭកពីរឿងរបស់ព្យាការីមូសានៅក្នុងគម្ពីរ(គួរអាន)។ ពិតប្រាកដណាស់ គាត់គឺជាអ្នកដែលត្រូវបានគេ(អល់ឡោះ)ជ្រើសរើស ហើយក៏ជាអ្នកនាំសារនិងជាព្យាការីម្នាក់ផងដែរ។

52. ហើយយើង(អល់ឡោះ)បានហៅគេនៅក្បែរភ្នំតួរប៉ែកខាងស្តាំដៃ ហើយយើងធ្វើឱ្យគេខិតមកជិតយើងដើម្បីយើងបានមានបន្ទូលជាមួយគេ។

53. ហើយដោយក្តីករុណាអំពីយើង យើងបានប្រទានដល់គេនូវបងប្រុសរបស់គេ ហារូន ជាព្យាការីម្នាក់។

54. ហើយចូរអ្នករំឭកពីរឿងរបស់ព្យាការីអ៊ីស្មាអែលនៅក្នុងគម្ពីរ(គួរអាន)។ ពិតប្រាកដណាស់ គាត់គឺជាអ្នកសច្ចៈចំពោះការសន្យា ហើយក៏ជាអ្នកនាំសារនិងជាព្យាការីម្នាក់ផងដែរ។

55. ហើយគាត់បានបង្គាប់គ្រួសាររបស់គាត់ឱ្យប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយគាត់ជាអ្នកដែលទទួលបាននូវការពេញចិត្តពីព្រះជាម្ចាស់របស់គាត់។

56. ហើយចូរអ្នករំឭកពីរឿងព្យាការីអ៊ិតទ្រីសនៅក្នុងគម្ពីរ(គួរអាន)។ ពិតប្រាកដណាស់ គាត់ជាអ្នកសច្ចៈ និងជាព្យាការីម្នាក់។

57. ហើយយើងបានលើកតម្កើងឋានៈរបស់គេឱ្យមានភាពខ្ពង់ខ្ពស់។

58. អ្នកទាំងនោះហើយជាអ្នកដែលអល់ឡោះបានប្រទាននូវឧបការគុណដល់ពួកគេនូវភាពជាព្យាការីក្នុងចំណោមកូនចៅអាដាំ និងក្នុងចំណោមអ្នកដែលយើងបានដឹកពួកគេ(ក្នុងសំពៅ)ជាមួយព្យាការីនួហ ហើយនិងក្នុងចំណោមកូនចៅរបស់ព្យាការីអ៊ីព្រហ៊ីម និងព្យាការីអ៊ីស្មាអែល ព្រមទាំងក្នុងចំណោមអ្នកទាំងឡាយដែលយើងបានផ្តល់ការចង្អុលបង្ហាញ និងបានជ្រើសរើសពួកគេ(ឱ្យក្លាយជាព្យាការី)។ នៅពេលដែលមានគេសូត្រឱ្យពួកគេស្តាប់នូវបណ្តាវាក្យខណ្ឌរបស់ព្រះជាម្ចាស់ដ៏មហាសប្បុរស គឺពួកគេក្រាបស៊ូជូត និងសម្រក់ទឹកភ្នែក(ដោយការកោតខ្លាចចំពោះអល់ឡោះ)។

59. ក្រោយមក មានអ្នកមួយចំនួនដែលដើរតាមប្រការអាក្រក់បានមកដល់បន្ទាប់ពីពួកគេ(បណ្តាព្យាការីទាំងនោះ)ដោយពួកគេបោះបង់ការប្រតិបត្តិសឡាត និងដើរតាមកិលេសតណ្ហា។ ដូច្នេះ ពួកគេគង់តែជួបនឹងភាពអន្តរាយជាមិនខាន។

60. លើកលែងតែជនណាដែលបានសារភាពកំហុស និងមានជំនឿ ហើយបានសាងទង្វើកុសលវិញប៉ុណ្ណោះ។ ពិតប្រាកដណាស់ អ្នកទាំងនោះ ពួកគេនឹងបានចូលឋានសួគ៌ ហើយពួកគេមិនត្រូវបានគេបំពានបន្តិចណាឡើយ។

61. (ពួកគេនឹងចូល)ឋានសួគ៌អាត់និនដែលព្រះជាម្ចាស់ដ៏មហាសប្បុរសបានសន្យានឹងខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដែលជាប្រការអាថ៌កំបាំង។ ហើយការសន្យារបស់ទ្រង់ គឺនឹងកើតឡើងជាក់ជាមិនខាន។

62. ពួកគេនឹងមិនឮនូវពាក្យសម្តីដែលឥតប្រយោជន៍នៅក្នុងឋានសួគ៌ឡើយ គឺមានតែពាក្យសិរីសួស្តីប៉ុណ្ណោះ។ ហើយសម្រាប់ពួកគេនឹងទទួលបាននូវលាភសក្ការៈនៅក្នុងវា ទាំងព្រឹក ទាំងល្ងាច។

63. នោះហើយជាឋានសួគ៌ដែលយើងនឹងប្រទានវាជាមរតកទៅឱ្យខ្ញុំបម្រើរបស់យើងទាំងឡាយដែលជាអ្នកកោតខ្លាច។

64. ហើយពួកយើង(ម៉ាឡាអ៊ីកាត់)គឺមិនចុះមក(ដោយចិត្តឯងនោះឡើយ)លើកលែងតែទៅតាមបទបញ្ជាព្រះជាម្ចាស់របស់អ្នក(ព្យាការីមូហាំម៉ាត់)ប៉ុណ្ណោះ។ អ្វីដែលនៅពីខាងមុខពួកយើង និងអ្វីដែលនៅពីខាងក្រោយពួកយើង ព្រមទាំងអ្វីៗដែលនៅចន្លោះនោះ គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយព្រះជាម្ចាស់របស់អ្នក គឺមិនដែលភ្លេចនោះឡើយ។

65. (ទ្រង់ជា)ព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរ។ ហេតុនេះ ចូរអ្នកគោរពសក្ការៈចំពោះទ្រង់(តែមួយគត់) និងត្រូវអត់ធ្មត់ក្នុងការគោរពសក្ការៈចំពោះទ្រង់។ តើអ្នកដឹងទេថា មានអ្នកណាដែលមាននាមដូចទ្រង់នោះ?

66. ហើយមនុស្សលោកនិយាយថា៖ នៅពេលដែលខ្ញុំបានស្លាប់ហើយនោះ តើខ្ញុំនឹងត្រូវគេបញ្ចេញ(ពីផ្នូរ)ឱ្យមានជីវិតសាជាថ្មីម្តងទៀតឬ?

67. តើមនុស្សមិននឹកឃើញទេឬថា៖ ជាការពិតណាស់ យើងបានបង្កើតរូបគេកាលពីមុន ខណៈដែលរូបគេមិនទាន់មានអ្វីសោះនោះ?

68. ហើយព្រះជាម្ចាស់របស់អ្នកបានស្បថថា៖ ពិតប្រាកដណាស់ យើងនឹងប្រមូលផ្តុំពួកគេ ហើយនិងពពួកស្មែតន។ បន្ទាប់មក យើងនឹងនាំពួកគេទៅជុំវិញនរកដើហាន់ណាំដោយដោយពួកគេលត់ជង្គង់ចុះ(នៅក្នុងឋាននរក)។

69. បន្ទាប់មក យើងពិតជានឹងដកយកអំពីក្រុមនីមួយៗនូវអ្នកដែលប្រឆាំងខ្លាំងជាងគេបំផុតចំពោះព្រះជាម្ចាស់ដ៏មហាសប្បុរសក្នុងចំណោមពួកគេ(យកមកដាក់ទណ្ឌកម្មមុនគេ)។

70. ក្រោយមកទៀត យើងពិតជាដឹងបំផុតចំពោះពួកដែលសក្តិសមត្រូវចូលឋាននរកមុនគេ។

71. ហើយក្នុងចំណោមពួកអ្នក(ឱមនុស្សលោក)គឺសុទ្ធតែត្រូវឆ្លងកាត់វា(ស្ពានស៊ីរ៉ាត)។ ហើយការឆ្លងកាត់នេះ គឺជាការកំណត់យ៉ាងដាច់ខាតពីព្រះជាម្ចាស់របស់អ្នក។

72. បន្ទាប់មក យើងនឹងសង្គ្រោះបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ហើយយើងនឹងទុកឱ្យពួកបំពានលត់ជង្គង់ចុះក្នុងនរកនោះ។

73. ហើយនៅពេលដែលមានគេសូត្របណ្តាវាក្យខណ្ឌរបស់យើងដ៏ច្បាស់លាស់ឲ្យពួកគេស្តាប់ ពួកដែលគ្មានជំនឿបាននិយាយទៅកាន់បណ្តាអ្នកដែលមានជំនឿថា៖ តើក្រុមណាមួយក្នុងចំណោមក្រុមទាំងពីរដែលមានឋានៈ និងមានកន្លែងជួបជុំដែលល្អប្រសើរជាងគេនោះ?

74. ហើយមានប្រជាជាតិជាច្រើនដែលយើងបានបំផ្លាញមុនពួកគេ(ពួកគូរ៉ូស)ដែលពួកទាំងនោះមានទ្រព្យសម្បត្តិ និងរូបសម្បត្តិល្អប្រសើរជាងពួកគេ(ពួកគូរ៉ូស)ទៅទៀត។

75. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ជនណាដែលស្ថិតក្នុងភាពវង្វេង នោះព្រះជាម្ចាស់ដ៏មហាសប្បុរសនឹងពន្យារពេលដល់គេ(ឱ្យកាន់តែវង្វេងថែមទៀត)។ លុះដល់ពេលដែលពួកគេបានឃើញអ្វីដែលគេបានសន្យាចំពោះពួកគេ(ផ្គាល់នឹងភ្នែក)អាចជាទណ្ឌកម្មភ្លាមៗ ឬក៏ថ្ងៃបរលោក ពេលនោះ ពួកគេនឹងដឹងថា តើអ្នកណាដែលស្ថិតនៅកន្លែងដែលអាក្រក់ និងមានកម្លាំងទំពខ្សោយជាង?

76. ហើយអល់ឡោះជាម្ចាស់នឹងបន្ថែមការចង្អុលបង្ហាញដល់បណ្ដាអ្នកដែលទទួលបានការចង្អុលបង្ហាញថែមទៀត។ ហើយទង្វើកុសលដែលនៅគង់វង្សជានិរន្តរ៍នោះ គឺល្អប្រសើរបំផុតចំពោះព្រះជាម្ចាស់របស់អ្នកក្នុងការផ្ដល់ការតបស្នង និងជាលទ្ធផលចុងក្រោយដ៏ប្រពៃ។

77. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញដៃរឬទេពួកដែលបានប្រឆាំងនឹងបណ្ដាកស្តុតាងរបស់យើង ហើយគេនិយាយថា៖ ខ្ញុំប្រាកដជានឹងត្រូវគេផ្ដល់ឱ្យនូវទ្រព្យសម្បត្តិ និងកូនចៅជំរើន(នាថ្ងៃបរលោក)ជាមិនខាន?

78. តើគេដឹងពីប្រការអាថ៌កំបាំង ឬមួយគេទទួលបានការសន្យាណាមួយពីព្រះជាម្ចាស់ដ៏មហាសប្បុរស(ចំពោះរឿងនោះ)ឬ?

79. មិនដូច្នោះឡើយ យើងនឹងកត់ត្រាទុកនូវអ្វីដែលគេនិយាយ ហើយយើងនឹងបន្ថែមនូវទណ្ឌកម្មលើរូបគេថែមទៀត។

80. ហើយយើងនឹងយកមរតក(ពីគេទាំងអស់)នូវអ្វីដែលគេបាននិយាយ(ខាងលើ) ហើយគេនឹងវិលត្រឡប់មកជួបយើងវិញ(នៅថ្ងៃបរលោក)ដោយខ្លួនទទេ។

81. ហើយពួកគេបានយកព្រះនានា(មកគោរពសក្ការៈ)ក្រៅពីអល់ឡោះ ដើម្បីជួយឲ្យពួកគេមានអានុភាព។

82. មិនដូច្នោះឡើយ ព្រះទាំងនោះនឹងបដិសេធចំពោះការគោរពសក្ការៈរបស់ពួកគេ(ចំពោះពួកវា) ហើយពួកវានឹងក្លាយជាសត្រូវនឹងពួកគេវិញ។

83. តើអ្នកមិនបានឃើញទេឬ ជាការពិតណាស់ យើងបានបញ្ជូនពួកស្មែតនទៅ(គ្រប់គ្រង)លើពួកប្រឆាំងដើម្បីឱ្យវាពង្វក់ពួកគេ(ឱ្យប្រព្រឹត្តអំពើល្មើស)?

84. ដូច្នេះ សូមអ្នកកុំប្រញាប់សុំឱ្យអល់ឡោះបំផ្លាញពួកគេ។ តាមពិត យើងគ្រាន់តែគណនាឲ្យពួកគេ(នូវអាយុជីវិត និងទង្វើរបស់ពួកគេ)ឱ្យបានច្បាស់លាស់ប៉ុណ្ណោះ។

85. (ហើយចូរអ្នករំឭក)នៅថ្ងៃដែលយើងនឹងប្រមូលផ្ដុំបណ្ដាអ្នកដែលកោតខ្លាចទៅកាន់ព្រះជាម្ចាស់ដ៏មហាសប្បុរសក្នុងនាមជាភ្ញៀវកិត្តិយស។

86. ហើយយើងនឹងកៀងពួកប្រព្រឹត្តល្មើសទៅកាន់នរកដើហាន់ណាំដោយភាពស្រេកឃ្លាន។

87. ពួកគេគ្មានសិទ្ធិទទួលបានការអន្តរាគមន៍នោះឡើយ លើកលែងតែបណ្ដាអ្នកដែលទទួលបានការសន្យាពីព្រះជាម្ចាស់ដ៏មហាសប្បុរសប៉ុណ្ណោះ។

88. ហើយពួកគេនិយាយថា៖ ព្រះជាម្ចាស់ដ៏មហាសប្បុរស ទ្រង់មានបុត្រ។

89. ជាការពិតណាស់ ពួកអ្នកបាននាំមកនូវប្រការមួយដែលអាក្រក់បំផុត។

90. ព្រោះតែសម្តីនេះ មេឃជាច្រើនជាន់ស្ទើរតែប្រេះបែក ផែនដីស្ទើរបែកខ្ទេចខ្ទី ហើយភ្នំទាំងឡាយស្ទើរតែរលំរលាយ

91. ដោយសារតែពួកគេបានចោទប្រកាន់ថា៖ ព្រះជាម្ចាស់ដ៏មហាសប្បុរស ទ្រង់មានបុត្រ។

92. ហើយវាមិនត្រឹមត្រូវនោះឡើយដែលថា ព្រះជាម្ចាស់ដ៏មហាសប្បុរសទ្រង់មានបុត្រនោះ។

93. រាល់អ្នកដែលនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី គឺសុទ្ធតែត្រឡប់ទៅកាន់ព្រះជាម្ចាស់ដ៏មហាសប្បុរស(នៅថ្ងៃបរលោក)ក្នុងនាមជាខ្ញុំបម្រើ(របស់ទ្រង់)ទាំងអស់។

94. ជាការពិតណាស់ ទ្រង់បានគណនាពួកគេ និងដឹងពីចំនួនពួកគេយ៉ាងច្បាស់លាស់បំផុត។

95. ហើយបុគ្គលគ្រប់រូបនឹងទៅជួបទ្រង់វិញនៅថ្ងៃបរលោករៀងៗខ្លួន។

96. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ព្រះជាម្ចាស់ដ៏មហាសប្បុរសនឹងប្រទានក្តីស្រលាញ់ដល់ពួកគេ។

97. ពិតប្រាកដណាស់ យើងបានសម្រួលវា(គម្ពីរគួរអាន)ជាភាសារបស់អ្នក(ភាសាអារ៉ាប់) ដើម្បីឱ្យអ្នកផ្តល់ដំណឹងរីករាយតាមរយៈវាដល់បណ្តាអ្នកដែលកោតខ្លាច និងដាស់តឿនព្រមានតាមរយៈវាចំពោះក្រុមដែលពូកែឈ្លោះប្រកែកគ្នា។

98. ហើយមានប្រជាជាតិជាច្រើនដែលយើងបានបំផ្លាញមុនពួកគេ(ក្រុមរបស់អ្នក)។ តើអ្នកមានអារម្មណ៍អ្វីចំពោះនរណាម្នាក់ក្នុងចំណោមពួកគេ ឬបានឮសំឡេងខ្សឹបខ្សៀវពីពួកគេដែរឬទេ?

ជំពូក តហា

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តហា (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន (ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. យើងមិនបានបញ្ចុះគម្ពីរគួរអានទៅកាន់អ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ដើម្បីឱ្យអ្នកលំបាកនោះឡើយ។

3. តែដើម្បីជាការរំឭកដល់អ្នកដែលកោតខ្លាច (អល់ឡោះ) ប៉ុណ្ណោះ។

4. ជាការបញ្ចុះមកពីអ្នកដែលបានបង្កើតផែនដី និងមេឃជាច្រើនជាន់ដែលខ្ពស់បំផុត។

5. ព្រះជាម្ចាស់ដ៏មហាសប្បុរស ទ្រង់នៅលើអារ៉ស្ស។

6. អ្វីដែលនៅលើមេឃជាច្រើនជាន់ អ្វីដែលនៅលើផែនដី អ្វីដែលនៅចន្លោះវាទាំងពីរ ហើយនិងអ្វីដែលនៅក្រោមដី គឺជាកម្មសិទ្ធិរបស់ទ្រង់ (តែមួយគត់)។

7. ហើយទោះបីជាអ្នកបញ្ចេញសំឡេងខ្លាំងៗ (ឬលាក់បាំងក៏ដោយ) ក៏ទ្រង់ដឹងបំផុតនូវការសម្ងាត់ និងអ្វីដែលកំបាំងបំផុត។

8. អល់ឡោះ (តែមួយគត់) គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់មានព្រះនាមដ៏ល្អប្រពៃជាច្រើន។

9. តើរឿងរ៉ាវរបស់ព្យាការីមូសាបានមកដល់អ្នក (ព្យាការីមូហាំម៉ាត់) ហើយឬនៅ?

10. ខណៈពេលដែលគាត់ (ព្យាការីមូសា) បានឃើញពន្លឺភ្លើង ពេលនោះគាត់ក៏បានពោលទៅកាន់គ្រួសាររបស់គាត់ថា៖ សូមពួកអ្នក (រង់ចាំ) នៅទីនេះសិនចុះ។ ពិតប្រាកដណាស់ ខ្ញុំបានឃើញពន្លឺភ្លើងមួយ។ សង្ឃឹមថា ខ្ញុំនឹងនាំយកភ្លើងមួយដុំនោះមក (បង្កាត់) ឱ្យពួកអ្នក ឬក៏ខ្ញុំអាចនឹងជួបការចង្អុលបង្ហាញនៅកន្លែងភ្លើងនោះ។

11. នៅពេលដែលគាត់បានទៅដល់កន្លែងភ្លើងនោះ គេ (អល់ឡោះ) ក៏បានហៅគាត់ថា៖ ឱមូសា!

12. ពិតប្រាកដណាស់ យើងគឺជាព្រះជាម្ចាស់របស់អ្នក! ហេតុនេះ ចូរអ្នកដោះស្បែកជើងទាំងពីររបស់អ្នកចេញ។ ពិតប្រាកដណាស់ អ្នកកំពុងស្ថិតនៅក្នុងជ្រលងភ្នំទូវ៉ាដ៏ពិសិដ្ឋ។

13. ហើយយើងបានជ្រើសរើសអ្នក(ដើម្បីផ្សព្វផ្សាយសាររបស់យើង)។ ដូច្នេះ ចូរអ្នកស្តាប់នូវអ្វីដែលគេនឹងផ្តល់វាហ៊ី(ឱ្យអ្នក)ចុះ។

14. ពិតប្រាកដណាស់ យើងគឺអល់ឡោះដែលគ្មានព្រះជាម្ចាស់ណាត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីយើងឡើយ។ ដូច្នេះ ចូរអ្នកគោរពសក្ការៈមកចំពោះយើង(តែមួយគត់) ហើយចូរអ្នកប្រតិបត្តិសឡាតដើម្បីជាការរំឭកមកចំពោះយើង។

15. ពិតប្រាកដណាស់ ថ្ងៃបរលោកនឹងមកដល់(ដោយចៀសមិនផុតឡើយ)។ យើងស្ទើរតែនឹងលាក់បាំងវាដើម្បីគេ(អល់ឡោះ)នឹងតបស្នងឱ្យរាល់បុគ្គលគ្រប់រូបនូវអ្វីដែលគេបានខិតខំប្រឹងប្រែង។

16. ដូច្នេះ ចូរអ្នក(ឱ ព្យាការីមូសា)កុំឱ្យពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក និងដើរតាមទំនើងចិត្តនោះមករារាំងអ្នកមិនឲ្យមានជំនឿចំពោះវា ដែលជាហេតុធ្វើឱ្យអ្នកវិនាសអន្តរាយឱ្យសោះ។

17. ហើយតើអ្វីទៅដែលនៅនឹងដៃស្តាំរបស់អ្នកនោះ ឱ មូសា?

18. គាត់បានតបថា៖ វាគឺជាដំបងរបស់ខ្ញុំ ដែលខ្ញុំប្រើវាសម្រាប់ច្រត់ និងសម្រាប់អន្ទេនមែកឈើឱ្យសត្វពពែរបស់ខ្ញុំ(ស៊ី) ហើយនិងសម្រាប់ប្រើជាផលប្រយោជន៍ផ្សេងទៀត។

19. ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកបោះវាចុះ ឱ មូសា!

20. ពេលនោះ គាត់ក៏បានបោះដំបង។ រំពេចនោះ វាក៏បានក្លាយទៅជាសត្វពស់មួយក្បាលដែលវារយ៉ាងលឿន។

21. ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកចាប់វាមកវិញ ហើយសូមអ្នកកុំខ្លាចឱ្យសោះ។ យើងនឹងត្រឡប់វាឱ្យទៅជាសភាពដូចដើមវិញ។

22. ហើយចូរអ្នកយកដៃ(ស្តាំ)របស់អ្នកដាក់ចូលទៅក្នុងចំហៀងខ្លួនរបស់អ្នក នោះវានឹងចេញពន្លឺសភ្លឺថ្លា ដែលជាអច្ឆរិយភាពមួយទៀត(របស់អ្នក)។

23. ដើម្បីយើងនឹងបង្ហាញឱ្យអ្នកបានឃើញនូវសញ្ញាកស្តុតាងដ៏ធំធេងរបស់យើង។

24. ចូរអ្នកទៅកាន់ហ្វៀរអោន។ ជាការពិតណាស់ គេគឺជាអ្នកដែលបំពាន។

25. ព្យាការីមូសាបានពោលថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាបើកទូលាយនូវចិត្តរបស់ខ្ញុំ(ឱ្យមានទំនុកចិត្តលើខ្លួនឯងនិងមានភាពក្លាហាន)ផងចុះ។

26. ហើយសូមព្រះអង្គមេត្តាសម្រួលដល់ខ្ញុំនូវកិច្ចការរបស់ខ្ញុំផង។

27. ហើយសូមព្រះអង្គមេត្តាផ្តល់សមត្ថភាពក្នុងការនិយាយឲ្យបានល្អដល់ខ្ញុំផង

28. ដើម្បីឱ្យពួកគេងាយយល់សម្តីរបស់ខ្ញុំ។

29. ហើយសូមព្រះអង្គមេត្តាតែងតាំងជំនួយការម្នាក់អំពីក្រុមគ្រួសាររបស់ខ្ញុំដល់រូបខ្ញុំផង។

30. គឺ ហារូន បងប្រុសរបស់ខ្ញុំ។

31. សូមព្រះអង្គមេត្តាពង្រឹងកម្លាំងខ្ញុំតាមរយៈគាត់ផង។

32. ហើយសូមឱ្យគាត់ចូលរួមនៅក្នុងកិច្ចការរបស់ខ្ញុំ

33. ដើម្បីឱ្យពួកយើងលើកតម្កើងព្រះអង្គបានកាន់តែច្រើន

34. ហើយនិងរំឭកដល់ព្រះអង្គបានកាន់តែច្រើនផងដែរ។

35. ពិតប្រាកដណាស់ ព្រះអង្គគឺជាអ្នកដែលយើញបំផុតចំពោះពួកយើង។

36. ទ្រង់បានតបថា៖ ជាការពិតណាស់ យើងបានប្រទានឱ្យអ្នកតាមសំណើរបស់អ្នកហើយ ឱមូសា!

37. ហើយជាការពិតណាស់ យើងបានប្រទានឧបការគុណឱ្យអ្នកម្តងទៀត។

38. ខណៈដែលយើងបានផ្តល់សារទៅកាន់ម្តាយរបស់អ្នកនូវអ្វីដែលយើងបានផ្តល់សារថា៖

39. ចូរនាងដាក់គេ(មូសា)ទៅក្នុងហឹប ហើយចោលហឹបនោះទៅក្នុងទន្លេចុះ។ ពេលនោះ ទឹកទន្លេនឹងនាំគេទៅកាន់មាត់ច្រាំងវិញ ហើយសត្រូវរបស់យើងនិងសត្រូវរបស់គេ(ហ្វៀរអោន)នឹងយកគេ(ទៅចិញ្ចឹម)ហើយ។ ហើយយើងបានផ្តល់ឱ្យអ្នក(ឱមូសា)នូវក្តីស្រលាញ់ពីយើង ហើយដើម្បីឲ្យគេចិញ្ចឹមបីបាច់ថែរក្សាអ្នកក្រោមការឃ្លាំមើលរបស់យើង។

40. នៅពេលដែលបងស្រីរបស់អ្នកបានដើរ(តាមឃ្លាំមើលអ្នក) ហើយនាងបាននិយាយថា៖ តើចង់ឱ្យខ្ញុំចង្អុលប្រាប់ពួកអ្នកនូវអ្នកដែលអាចមើលថែគេ(មូសា)ដែរឬទេ? ពេលនោះ យើងក៏បានបង្វិលអ្នកត្រឡប់ទៅកាន់ម្តាយរបស់អ្នកវិញ ដើម្បីឱ្យនាងរីករាយចំពោះការវិលត្រឡប់របស់អ្នក និងដើម្បីកុំឱ្យនាងព្រួយបារម្ភ។ ហើយ(ពេលដែលអ្នកធំពេញវ័យ)អ្នកបានសម្លាប់មនុស្សម្នាក់ រួចយើងក៏ជួយសង្គ្រោះអ្នកឱ្យរួចផុតពីភាពភ័យខ្លាច ហើយយើងក៏បានសាកល្បងអ្នកម្តងហើយម្តងទៀត។ ហើយអ្នកបានរស់នៅអស់រយៈកាលជាច្រើនឆ្នាំជាមួយប្រជាជនម៉ាទយ៉ាន់។ ក្រោយមក អ្នកបានមក(ជួបយើង)តាមពេលវេលាដែលបានកំណត់ ឱមូសា!

41. ហើយយើងបានជ្រើសរើសអ្នកសម្រាប់ខ្លួនយើងផ្ទាល់(ដើម្បីផ្សព្វផ្សាយសារអំពីយើង)។

42. ចូរអ្នក(ឱមូសា) និងបងប្រុសរបស់អ្នកនាំយកនូវសញ្ញាកស្តុតាងទាំងឡាយរបស់យើង ហើយចូរអ្នកទាំងពីរកុំព្រងើយកន្តើយក្នុងការរំឭកមកចំពោះយើងឱ្យសោះ។

43. ចូរអ្នកទាំងពីរទៅកាន់ហ្វៀរអោនចុះ។ ពិតប្រាកដណាស់ គេគឺជាអ្នកដែលបំពាន។

44. ហើយចូរអ្នកទាំងពីរនិយាយទៅកាន់គេ(ហ្វៀរអោន)នូវពាក្យសម្តីដែលទន់ភ្លន់ សង្ឃឹមថាគេនឹងទទួលការដាស់តឿន ឬកោតខ្លាច(អល់ឡោះ)។

45. គាត់ទាំងពីរបានតបថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ យើងខ្ញុំខ្លាចគេធ្វើទារុណកម្មយើងខ្ញុំភ្លាមៗ ឬក៏បំពាន(លើយើងខ្ញុំ)។

46. ទ្រង់បានតបវិញថា៖ ចូរអ្នកទាំងពីរកុំភ័យខ្លាចឱ្យសោះ។ ពិតប្រាកដណាស់ យើងនៅជាមួយអ្នកទាំងពីរដោយយើងឮ ហើយយើងឃើញ។

47. ដូច្នេះ ចូរអ្នកទាំងពីរទៅជួបគេ(ហ្វៀរអោន)ចុះ ហើយនិយាយទៅកាន់គេថា៖ ពិតប្រាកដណាស់ យើងទាំងពីរគឺជាអ្នកនាំសារនៃព្រះជាម្ចាស់របស់អ្នក(ឱហ្វៀរអោន)។ ដូច្នេះ សូមអ្នកដោះលែងអម្បូរអ៊ីស្រាអែលឱ្យទៅជាមួយពួកយើង ហើយសូមអ្នកឈប់ធ្វើទារុណកម្មពួកគេទៀតទៅ។ ជាការពិតណាស់ យើងបាននាំមកនូវសញ្ញាកស្តុតាងអំពីព្រះជាម្ចាស់របស់អ្នកមកកាន់អ្នក។ ហើយសូមសុខសន្តិភាពកើតមានដល់ជនណាដែលដើរតាមការចង្អុលបង្ហាញ។

48. ជាការពិតណាស់ គេបានផ្តល់វ៉ាហ៊ីមកកាន់យើងថា៖ ពិតប្រាកដណាស់ ទណ្ឌកម្មគឺនឹងធ្លាក់ទៅលើជនណាដែលបដិសេធ និងងាកចេញ(ពីអ្វីដែលបណ្តាអ្នកនាំសារបាននាំមក)។

49. ហ្វៀរអោនបានតបវិញថា៖ ដូច្នេះ តើអ្នកណាជាព្រះជាម្ចាស់របស់អ្នកទាំងពីរនោះ ឱមូសា?

50. គាត់បានតបថា៖ ព្រះជាម្ចាស់របស់ពួកយើង ទ្រង់គឺជាអ្នកដែលបានប្រទាននូវអ្វីៗគ្រប់បែបយ៉ាងនូវលក្ខណៈសម្បត្តិ(ដែលសក្តិសម)សម្រាប់វា។ បន្ទាប់មក ទ្រង់បានចង្អុលបង្ហាញ(ដល់ពួកវា)។

51. គេបានតបវិញថា៖ ហើយចុះរឿងរ៉ាវនៃប្រជាជាតិជំនាន់មុនៗនោះយ៉ាងដូចម្តេចដែរ?

52. គាត់បានតបថា៖ ចំណេះដឹងអំពីរឿងនោះ គឺនៅឯព្រះជាម្ចាស់របស់ខ្ញុំដែលមាននៅក្នុងគម្ពីរ(ឡាវហុលម៉ាសហ្វូស)។ ព្រះជាម្ចាស់របស់ខ្ញុំមិនភាន់ច្រឡំ និងមិនភ្លេចនោះឡើយ។

53. ទ្រង់គឺជាអ្នកដែលបានបង្កើតផែនដីដែលមានសណ្ឋានលាតសន្ធឹងសម្រាប់ពួកអ្នក។ ហើយទ្រង់បានបង្កើតនូវផ្លូវជាច្រើននៅលើផែនដីសម្រាប់ពួកអ្នក(ធ្វើដំណើរ)។ ហើយទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃ។ បន្ទាប់មក តាមរយៈទឹកភ្លៀងនោះ យើង(អល់ឡោះ)បានបញ្ចេញនូវរុក្ខជាតិជាច្រើនប្រភេទខុសៗគ្នា។

54. ចូរពួកអ្នកទទួលទាន និងឃ្វាលសត្វពាហនៈរបស់ពួកអ្នកចុះ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាង សម្រាប់អ្នកដែលមានប្រាជ្ញាចេះគិតពិចារណា។

55. អំពីដីនេះហើយដែលយើងបានបង្កើតពួកអ្នក ហើយយើងនឹងឱ្យពួកអ្នកត្រឡប់ទៅក្នុងដីវិញ។ ហើយអំពីដីនេះដែរ យើងនឹងបញ្ចេញពួកអ្នកសាជាថ្មីម្តងទៀត(នៅថ្ងៃបរលោក)។

56. ហើយជាការពិតណាស់ យើងបានបង្ហាញដល់គេ(ហ្វៀរអោន)នូវសញ្ញាកស្តុតាងទាំងអស់របស់យើង តែគេបែរជាបដិសេធ និងប្រឆាំងទៅវិញ។

57. ហ្វៀរអោនបាននិយាយថា៖ តើអ្នកមកជួបយើងនេះ គឺដើម្បីបណ្តេញយើងចេញពីទឹកដីរបស់យើងតាមរយៈមន្តអាគមរបស់អ្នកឬ ឱមូសា?

58. ដូច្នេះ យើងប្រាកដជានឹងនាំមកកាន់អ្នក(ឱមូសា)នូវមន្តអាគមដូចនឹងមន្តអាគមនេះជាមិនខាន។ ហេតុនេះ ចូរអ្នកកំណត់ពេលវេលា និងទីកន្លែងដែលស្មើភាពគ្នារវាងយើងនិងអ្នក(ដើម្បីតទល់គ្នា)ដោយយើងនិងអ្នកមិនត្រូវក្បត់កិច្ចសន្យាឡើយ។

59. គាត់បានតបថា៖ ពេលវេលាកំណត់ជួបគ្នារបស់ពួកអ្នក គឺនៅថ្ងៃបុណ្យដោយគេប្រមូលផ្តុំមនុស្ស(មកជួបជុំគ្នា)នៅពេលថ្ងៃរះ។

60. ហើយហ្វៀរអោនក៏បានត្រឡប់ទៅវិញ រួចគេក៏បានប្រមូលនូវគ្រូមន្តអាគមរបស់ខ្លួន។ បន្ទាប់មក គេក៏បានមកដល់(តាមការកំណត់)។

61. ព្យាការីមូសាបាននិយាយទៅកាន់ពួកគេ(គ្រូមន្តអាគម)ថា៖ ចូរពួកអ្នកប្រុងប្រយ័ត្ន។ ចូរពួកអ្នកកុំប្រឌិតកុហកទៅលើអល់ឡោះដាម្ខាស់ឲ្យសោះដែលជាហេតុនាំឱ្យគេដាក់ទណ្ឌកម្មពួកអ្នក។ ពិតជាខាតបង់ហើយពួកដែលប្រឌិតកុហក(ទៅលើអល់ឡោះ)នោះ។

62. ពេលនោះ ពួកគេ(គ្រូមន្តអាគម)ក៏បានពិភាក្សាគ្នាចំពោះកិច្ចការរបស់ពួកគេ ហើយពួកគេបានជជែកគ្នាដោយសម្ងាត់

63. ដោយពួកគេនិយាយថា៖ ពិតប្រាកដណាស់ គេទាំងពីរនាក់នេះ គឺជាគ្រូមន្តអាគមដោយគេទាំងពីរមានបំណងចង់បណ្តេញពួកអ្នកចេញពីទឹកដីរបស់ពួកអ្នកតាមរយៈមន្តអាគមរបស់គេទាំងពីរ។ ហើយពួកគេទាំងពីរចង់បំបាត់នូវមន្តអាគមដ៏អស្ចារ្យរបស់ពួកអ្នក។

64. ដូច្នេះ ចូរពួកអ្នកប្រមូលល្បិចកលរបស់ពួកអ្នក។ បន្ទាប់មក ចូរពួកអ្នកឈរជាជួរ។ ពិតប្រាកដណាស់ អ្នកណាដែលមានប្រៀបជាងគេ ពិតជានឹងទទួលបានជ័យជម្នះនៅក្នុងថ្ងៃនេះ។

65. ពួកគេ(គ្រូមន្តអាគម)បាននិយាយថា៖ ឱមូសា! អ្នកអាចបោះ(មន្តអាគមរបស់អ្នក)មុន ឬក៏ពួកយើងជាអ្នកចាប់ផ្តើមបោះមុនក៏បាន។

66. គាត់បានតបថា៖ ទេ! ចូរពួកអ្នកបោះមុនចុះ! (ពេលនោះ ពួកគេក៏បានបោះនូវអ្វីដែលពួកគេមាន) ហើយរំពេចនោះខ្សែពួរនិងដំបងរបស់ពួកគេក៏បានបំភ័ន្តភ្នែករបស់ព្យាការីមូសាឲ្យមើលឃើញថាជាសត្វពស់កំពុងតែវារលឿនដោយសារតែមន្តអាគមរបស់ពួកគេ។

67. ពេលនោះ ព្យាការីមូសាក៏មានអារម្មណ៍ភ័យខ្លាចនៅក្នុងខ្លួនរបស់គាត់។

68. យើង(អល់ឡោះ)បានមានបន្ទូលថា៖ ចូរអ្នកកុំខ្លាច។ ពិតប្រាកដណាស់ រូបអ្នក គឺជាអ្នកដែលមានប្រៀប(លើពួកគេ)។

69. ហើយចូរអ្នកបោះអ្វី(ដំបង)ដែលនៅនឹងដៃស្តាំរបស់អ្នកចុះ នោះវានឹងលេបនូវអ្វីដែលពួកគេបានធ្វើជាមិនខាន។ តាមពិត អ្វីដែលពួកគេបានធ្វើនោះ គឺគ្រាន់តែជាល្បិចកលរបស់គ្រូមន្តអាគមប៉ុណ្ណោះ។ ហើយគ្រូមន្តអាគមមិនទទួលបានជោគជ័យជាដាច់ខាត ទោះបីជាគេមកពីទីណាក៏ដោយ។

70. ពេលនោះ គ្រូមន្តអាគមទាំងនោះក៏បានក្រាបស៊ូជូត(ចំពោះអល់ឡោះ)។ ពួកគេពោលថា៖ ពួកយើងមានជំនឿនឹងព្រះជាម្ចាស់របស់ព្យាការីហារូន និងព្យាការីមូសាហើយ។

71. ហ្វៀរអោនក៏និយាយ(គំរាមពួកគេ)ថា៖ តើពួកអ្នកមានជំនឿនឹងគេ(មូសា)មុននឹងយើងអនុញ្ញាតឱ្យពួកអ្នកឬ? ពិតប្រាកដណាស់ គេគឺជាមេរបស់ពួកអ្នកដែលបានបង្រៀនដល់ពួកអ្នកនូវមន្តអាគម។ ដូច្នេះ យើងពិតជានឹងកាត់ដៃកាត់ជើងរបស់ពួកអ្នកឆ្លាស់គ្នា ហើយយើងពិតជានឹងចងឆ្កាងពួកអ្នកទៅនឹងដើមល្មើ ហើយ(ពេលនោះ)ពួកអ្នកពិតជានឹងដឹងថា តើអ្នកណាក្នុងចំណោមពួកយើងដែលដាក់ទណ្ឌកម្មខ្លាំងជាង និងស្ថិតស្ថេរជាង?

72. ពួកគេបានតបវិញថា៖ ពួកយើងមិនអាចលើកតម្កើងអ្នកជាង(ការដើរតាម)សញ្ញាកស្តុតាងយ៉ាងច្បាស់លាស់ដែលបានមកដល់ពួកយើង ហើយនិងអ្នកដែលបានបង្កើតពួកយើងនោះឡើយ។ ដូច្នេះ ចូរអ្នកធ្វើនូវអ្វីដែលអ្នកចង់ធ្វើចុះ។ តាមពិត អ្នកអាចធ្វើអ្វីបានតែនៅក្នុងជីវិតលោកិយនេះប៉ុណ្ណោះ។

73. ពិតប្រាកដណាស់ ពួកយើងមានជំនឿនឹងព្រះជាម្ចាស់របស់ពួកយើងហើយ ដើម្បីទ្រង់នឹងអភ័យទោសដល់ពួកយើងនូវកំហុសឆ្គងទាំងឡាយរបស់ពួកយើង ហើយនិងបាបកម្មនៃមន្តអាគមដែលអ្នកបានបង្ខំពួកយើង(ធ្វើទៅកាន់មូសា)។ ហើយអល់ឡោះគឺជាអ្នកដែលតបស្នងយ៉ាងប្រសើរបំផុត(ចំពោះការតបស្នង) និងស្ថិតស្ថេរជាងគេបំផុត(ចំពោះការដាក់ទណ្ឌកម្ម)។

74. ជនណាហើយដែលមកជួបនឹងព្រះជាម្ចាស់របស់គេ(នៅថ្ងៃបរលោក)ក្នុងនាមជាឧក្រិដ្ឋជននោះ ពិតណាស់ សម្រាប់រូបគេគឺនរកជើហាន់ណាំ ដោយនៅក្នុងនោះ គេនឹងមិនស្លាប់ ហើយក៏មិនរស់នោះដែរ(វេទនាបំផុតស្ទើរស្លាប់ស្ទើររស់)។

75. រីឯជនណាដែលមកជួបទ្រង់ក្នុងនាមជាអ្នកដែលមានជំនឿដែលបានសាងទង្វើកុសលនោះ ពិតប្រាកដណាស់អ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបាននូវឋានៈដ៏ខ្ពង់ខ្ពស់។

76. គឺឋានសួគ៌អាត់និនដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ នោះហើយគឺជាការតបស្នងចំពោះអ្នកដែលបានសម្អាតខ្លួន(ពីភាពគ្មានជំនឿ និងអំពើល្មើស)។

77. ហើយជាការពិតណាស់ យើងបានផ្តល់វ៉ាហ៊ីទៅកាន់ព្យាការីមូសាថា៖ ចូរអ្នកនាំខ្ញុំបម្រើរបស់យើង(អម្ប្រាអ៊ីស្រាអែល)ធ្វើដំណើរទាំងយប់(ចេញពីទឹកដីអេហ្ស៊ីប)។ ហើយចូរអ្នកវាយ(ទឹកសមុទ្រនឹងដំបង)ដើម្បីបង្កើតជាផ្លូវស្ងួតមួយសម្រាប់ពួកគេដោយអ្នកមិនត្រូវខ្លាចគេតាមទាន់ ហើយក៏មិនត្រូវខ្លាច(លិចលង់)នោះដែរ។

78. បន្ទាប់មក ហៀនអោនរួមនឹងទាហានរបស់គេក៏បានដេញតាមពួកគេ តែទឹកសមុទ្របានគ្របដណ្តប់ពួកគេ(ហៀរអោនរួមនឹងបក្សពួក)រហូតដល់គេលិចលង់។

79. ហើយហៀរអោនបានធ្វើឱ្យក្រុមរបស់គេវង្វេង ហើយគេ(ហៀនអោន)មិនបានចង្អុលបង្ហាញ(ពួកគេ)នោះឡើយ។

80. ឱអម្បូរអ៊ីស្រាអែល! ជាការពិតណាស់ យើងបានសង្គ្រោះពួកអ្នកពីសត្រូវរបស់ពួកអ្នក ហើយយើងបានសន្យានឹងពួកអ្នកនៅឯផ្នែកខាងស្តាំនៃភ្នំតួរ(ដើម្បីបញ្ចុះគម្ពីរតោរ៉ាត)។ ហើយយើងបានបញ្ចុះមកឱ្យពួកអ្នកនូវអាល់ម៉ាន់(គេសជ្ជៈដែលមានរសជាតិផ្អែមដូចទឹកឃ្មុំ) និងអាស់សាល់វ៉ា(បក្សីមួយប្រភេទដែលស្រដៀងនឹងសត្វក្រួច)។

81. ចូរពួកអ្នកទទួលទានអំពីចំណីអាហារល្អៗដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកអ្នក ហើយចូរពួកអ្នកកុំបំពានចំពោះរឿងនេះដែលជាហេតុធ្វើឱ្យការខឹងសម្បារបស់យើងធ្លាក់ទៅលើពួកអ្នក។ ជនណាហើយដែលការខឹងសម្បារបស់យើងធ្លាក់ទៅលើរូបគេនោះ ពិតណាស់រូបគេប្រាកដជាអន្តរាយជាមិនខាន។

82. ហើយពិតប្រាកដណាស់ យើងគឺជាអ្នកដែលមហាអភ័យទោសបំផុតចំពោះជនណាដែលបានសារភាពកំហុស និងបានសាងទង្វើកុសល។ បន្ទាប់មក គេបានប្រកាន់ខ្ជាប់លើមាគ៌ាដែលត្រឹមត្រូវ(រហូតដល់ស្លាប់)។

83. ហើយតើអ្វីដែលធ្វើឱ្យអ្នកប្រញាប់ប្រញាល់ចាកចោលក្រុមរបស់អ្នក ឱមូសា?

84. គាត់បានតបថា៖ ពួកគេទាំងនោះនៅខាងក្រោយខ្ញុំដែលនឹងតាមទាន់ខ្ញុំ ហើយខ្ញុំរួសរាន់មកជួបព្រះអង្គ ឱព្រះជាម្ចាស់ ដើម្បីឱ្យព្រះអង្គពេញចិត្តមកចំពោះខ្ញុំ។

85. ទ្រង់បានមានបន្ទូលថា៖ ដូច្នេះ ពិតណាស់យើងបានសាកល្បងក្រុមរបស់អ្នកបន្ទាប់ពីអ្នក(ចាកចេញពីពួកគេ) ហើយសាមីរីបានធ្វើឱ្យពួកគេវង្វេង។

86. ក្រោយមក ព្យាការីមូសាបានត្រឡប់ទៅកាន់ក្រុមរបស់គាត់វិញដោយការខឹងសម្បា និងមានទុក្ខព្រួយជាខ្លាំង(ចំពោះពួកគេ)។ គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! តើព្រះជាម្ចាស់របស់ពួកអ្នកមិនបានសន្យានឹងពួកអ្នកនូវការសន្យាមួយដ៏ល្អប្រពៃទេឬ? តើការសន្យានោះយូរពេកសម្រាប់ពួកអ្នក ឬមួយពួកអ្នកចង់ឱ្យការខឹងសម្បាពីព្រះជាម្ចាស់របស់ពួកអ្នកធ្លាក់ទៅលើពួកអ្នក ទើបបានជាពួកអ្នកល្មើសនឹងកិច្ចសន្យារបស់ខ្ញុំបែបនេះ?

87. ពួកគេបានតបវិញថា៖ ពួកយើងមិនបានល្មើសនឹងកិច្ចសន្យារបស់អ្នកដោយចិត្តឯងនោះឡើយ។ ក៏ប៉ុន្តែ (ដោយសារ) ពួកយើងត្រូវទទួលបន្ទុកលីសែងយ៉ាងធ្ងន់នូវគ្រឿងអលង្ការរបស់ក្រុម(ហៀរអោន)។ ក្រោយមក ពួកយើងក៏បានបោះវាចូល(ទៅក្នុងរណ្តៅភ្លើងមួយ)។ ពេលនោះ សាមីរីក៏បានបោះចោល(អាចម៍ដីពីដានជើងសេះរបស់ជីព្រីល)ដែរ។

88. បន្ទាប់មក សាមីរីក៏បានយកចេញនូវរូបសំណាកកូនគោមួយក្បាលដែលមានសំឡេង(ចេញពីគ្រឿងអលង្ការទាំងនោះ)មកឱ្យពួកគេ។ ពេលនោះ ពួកគេក៏និយាយថា៖ នេះហើយជាព្រះជាម្ចាស់របស់ពួកអ្នក និងជាព្រះជាម្ចាស់របស់មូសា តែគាត់បានភ្លេចវា(នៅទីនេះ)។

89. តើពួកទាំងនោះមិនឃើញទេឬថា ពិតប្រាកដណាស់ រូបសំណាក់កូនគោនោះមិនអាចឆ្លើយតបជាមួយពួកគេ ហើយវាគ្មានក៏លទ្ធភាពបង្កគ្រោះថ្នាក់ដល់ពួកគេ ហើយក៏មិនអាចផ្តល់ផលប្រយោជន៍អ្វីដែរនោះ?

90. ហើយជាការពិតណាស់ ព្យាការីហារូនក៏បាននិយាយទៅកាន់ពួកគេកាលពីមុនផងដែរថា៖ ឱក្រុមរបស់ខ្ញុំ! តាមពិត ពួកអ្នកគ្រាន់តែត្រូវបានគេសាកល្បងនឹងវា(រូបសំណាក់កូនគោ)ប៉ុណ្ណោះ។ ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នក ទ្រង់គឺព្រះជាម្ចាស់ដ៏មហាសប្បុរសបំផុត។ ដូច្នេះ ចូរពួកអ្នកតាមខ្ញុំ និងគោរពតាមបទបញ្ជារបស់ខ្ញុំ។

91. ពួកគេបានតបថា៖ ពួកយើងនៅតែគោរពសក្ការៈចំពោះវា(រូបសំណាក់កូនគោ)ដដែល រហូតទាល់តែព្យាការីមូសាវិលត្រឡប់មកកាន់ពួកយើងវិញ។

92. ព្យាការីមូសាបានពោលថា៖ ឱហារូន! តើអ្វីទៅដែលរារាំងអ្នក(មិនឲ្យហាមឃាត់ពួកគេ)នៅពេលដែលអ្នកបានឃើញពួកគេវង្វេង

93. ដោយមិនធ្វើតាមខ្ញុំបែបនេះ?! តើអ្នកប្រឆាំងនឹងបទបញ្ជារបស់ខ្ញុំឬ?!

94. ព្យាការីហារូនបានតបថា៖ ឱប្អូនប្រុសរបស់ខ្ញុំ! សូមអ្នកកុំចាប់ពុកចង្កា និងសក់ក្បាលរបស់ខ្ញុំ។ ពិតប្រាកដណាស់ ព្រោះតែខ្ញុំខ្លាចអ្នកនិយាយថា៖ "អ្នកបានបំបែកបំបាក់រវាងអម្បូរអ៊ីស្រាអែល និងមិនធ្វើតាមពាក្យផ្តែផ្តាំរបស់ខ្ញុំ"។

95. ព្យាការីមូសាបានពោលថា៖ តើមានរឿងអ្វីដែលនាំឱ្យអ្នកធ្វើដូច្នោះ ឱសាមីរី?

96. គេបានតបថា៖ ខ្ញុំបានឃើញនូវអ្វីដែលពួកគេមិនបានឃើញវា។ ពេលនោះ ខ្ញុំក៏បានយកដីមួយក្តាប់ពីដានជើងសេះរបស់ម៉ាឡាអ៊ីកាត់ដីព្រិល។ ក្រោយមក ខ្ញុំក៏បានបោះវា។ ដូច្នោះហើយវាក៏បានបំផុសខ្ញុំឱ្យមានគំនិតធ្វើដូច្នោះ។

97. ព្យាការីមូសាតបថា៖ សូមអ្នកចាកចេញទៅ! ពិតប្រាកដណាស់ សម្រាប់អ្នកនៅក្នុងជីវិត(លោកិយនេះ) គឺអ្នកមានតែពាក្យថា៖ គ្មានទំនាក់ទំនងគ្នាឡើយ។ ហើយពិតប្រាកដណាស់ សម្រាប់អ្នក គឺមានការសន្យាមួយ(នៅថ្ងៃបរលោក)ដោយគេនឹងមិនធ្វើខុសពីកិច្ចសន្យានេះជាដាច់ខាត។ ហើយចូរអ្នកមើលទៅកាន់ព្រះរបស់អ្នក(រូបសំណាក់កូនគោ)ដែលអ្នកនៅតែបន្តគោរពសក្ការៈចំពោះវានោះចុះ។ យើងពិតជានឹងដុតវា បន្ទាប់មក យើងពិតជានឹងបាចវាចូលទៅក្នុងសមុទ្រ(ដើម្បីកុំឲ្យមានសល់ស្លាកស្នាមអ្វីទាំងអស់)។

98. តាមពិត ព្រះជាម្ចាស់របស់ពួកអ្នក គឺអល់ឡោះដែលគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់ដឹងជ្រួតជ្រាបនូវគ្រប់អ្វីៗទាំងអស់។

99. ក៏ដូច្នោះដែរ យើងបាននិទានប្រាប់អ្នកពីរឿងរ៉ាវ(របស់អ្នកជំនាន់មុន)ដែលបានកន្លងផុតទៅ។ ហើយជាការពិតណាស់ យើងបានប្រទានដល់អ្នកនូវការក្រើនរំឭកមួយ(គម្ពីរគួរអាន)អំពីយើង។

100. ជនណាដែលបានងាកចេញពីវា(គម្ពីរគួរអាន) ពិតប្រាកដណាស់នៅថ្ងៃបរលោក គេនឹងត្រូវរែកពុននូវបាបកម្មដ៏ធំធេងបំផុត។

101. ពួកគេស្ថិតនៅក្នុងវា(ទណ្ឌកម្ម)ជាអមតៈ។ បន្ទុកដែលពួកគេរែកពុននៅថ្ងៃបរលោកនោះ គឺអាក្រក់បំផុតសម្រាប់ពួកគេ។

102. គឺនៅថ្ងៃដែលគេ(ម៉ាឡាអ៊ីកាត់)ផ្លុំត្រែ(ជាលើកទីពីរ)។ ហើយនៅថ្ងៃនោះ យើងនឹងប្រមូលផ្តុំពួកឧក្រិដ្ឋជនទាំងឡាយដោយភ្នែករបស់ពួកគេឡើងជាំខៀវ។

103. ពួកគេនិយាយខ្សឹបខ្សៀវគ្នាថា៖ ពួកអ្នកមិនបានរស់នៅ(ក្នុងលោកិយ)ឡើយ លើកលែងតែដប់ថ្ងៃប៉ុណ្ណោះ។

104. យើង(អល់ឡោះ)ដឹងបំផុតនូវអ្វីដែលពួកគេនិយាយ ខណៈដែលអ្នកមានបញ្ញាចេះដឹងជាងគេក្នុងចំណោមពួកគេនិយាយថា៖ ពួកអ្នកមិនបានរស់នៅ(ក្នុងលោកិយ)ឡើយ លើកលែងតែមួយថ្ងៃប៉ុណ្ណោះ។

105. ហើយពួកគេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីភ្នំទាំងឡាយ(នៅថ្ងៃបរលោក)។ ដូចនេះ ចូរអ្នកតបថា៖ វានឹងត្រូវព្រះជាម្ចាស់របស់ខ្ញុំបំបើងវាឲ្យខ្ទេចខ្ទី(ទៅជាធូលី)។

106. ហើយទ្រង់នឹងទុកផែនដីឱ្យទៅជារាបស្មើឆេងដោយគ្មានអ្វីសោះ(នៅពីលើវា)។

107. អ្នកនឹងមិនឃើញមានភាពរៀចរយនៅលើវានោះឡើយ ហើយក៏មិនឃើញមានកន្លែងខ្ពស់ទាបនោះដែរ។

108. នៅថ្ងៃនោះ ពួកគេនឹងដើរតាម(សំឡេង)អ្នកដែលស្រែកដោយមិនងាកចេញពីសំឡេងនោះឡើយ។ ហើយសំឡេងទាំងឡាយគឺនៅស្ងៀមស្ងាត់ចំពោះព្រះជាម្ចាស់ដ៏មហាសប្បុរសដោយភាពកោតខ្លាចដោយអ្នកនឹងមិនឮសំឡេងអ្វីក្រៅពីសំឡេងតិចៗនោះឡើយ។

109. នៅថ្ងៃនោះ ការអន្តរាគមន៍ គឺគ្មានផលប្រយោជន៍អ្វីឡើយ លើកលែងតែជនណាដែលព្រះជាម្ចាស់ដ៏មហាសប្បុរសបានអនុញ្ញាតដល់គេ និងយល់ព្រមឱ្យគេនិយាយ(អន្តរាគមន៍)ប៉ុណ្ណោះ។

110. ទ្រង់ដឹងបំផុតនូវអ្វីដែលនៅខាងមុខពួកគេ(ថ្ងៃបរលោក) និងអ្វីដែលនៅខាងក្រោយពួកគេ(លោកិយ)។ តែពួកគេវិញ គឺមិនដឹងអ្វីអំពីទ្រង់នោះឡើយ។

111. ហើយមុខទាំងឡាយ(របស់ពួកគេ)បានឱនឈ្ងោកចុះទៅចំពោះព្រះជាម្ចាស់ដែលមានជីវិតអមតៈ និងជាអ្នកដែលគ្រប់គ្រង។ ពិតជាខាតបង់ហើយអ្នកដែលបាននាំទៅជាមួយនូវអំពើស្មើរកជាប់ខ្លួននោះ។

112. ហើយជនណាដែលបានសាងទង្វើកុសល ហើយរូបគេជាអ្នកដែលមានជំនឿនោះ ពិតប្រាកដណាស់ គេមិនភ័យខ្លាចរងនូវភាពអយុត្តិធម៌ និងការបំពាននោះឡើយ។

113. ក៏ដូច្នោះដែរ យើងបានបញ្ចុះគម្ពីរគួរអាននេះជាភាសាអារ៉ាប់ ហើយយើងបានបកស្រាយបញ្ជាក់នៅក្នុងវានូវការព្រមានជាច្រើនប្រភេទ សង្ឃឹមថាពួកគេនឹងកោតខ្លាច ឬនាំមកឱ្យពួកគេនូវការដាស់រំឭក។

114. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្ពង់ខ្ពស់ ជាស្តេចដែលមានអំណាចគ្រប់គ្រងយ៉ាងពិតប្រាកដ។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំប្រញាប់ប្រញាល់សូត្រគម្ពីរគួរអានមុននឹងគេផ្តល់(វ៉ាហ៊ី)មកឱ្យអ្នកចប់សព្វគ្រប់ឱ្យសោះ។ ហើយចូរអ្នកពោលថា៖ "បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាបន្ថែមចំណេះដឹងដល់ខ្ញុំផងចុះ"។

115. ហើយជាការពិតណាស់ យើងបានផ្តាំផ្ញើចំពោះព្យាការីអាហ្សាំកាលពីមុន តែគេបែរជាភ្លេចទៅវិញ។ ហើយយើងមិនបានឃើញគេមានការប្តេជ្ញាចិត្ត(ចំពោះពាក្យផ្តាំផ្ញើនោះឡើយ)។

116. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលយើងបានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ថា៖ ចូរពួកអ្នកឱនសុជូតទៅចំពោះអាហ្សាំ។ ពេលនោះ ពួកគេក៏បានសុជូតទាំងអស់គ្នា លើកលែងតែអ៊ីព្លិសប៉ុណ្ណោះដែលបដិសេធ។

117. ហើយយើងបានមានបន្ទូលថា៖ ឱអាហ្សាំ! ពិតប្រាកដណាស់ នេះគឺជាសត្រូវរបស់អ្នក និងភរិយារបស់អ្នក។ ហេតុនេះ ចូរអ្នកទាំងពីរកុំឱ្យវាធ្វើឲ្យអ្នកទាំងពីរចេញពីឋានសួគ៌ឱ្យសោះដែលជាហេតុធ្វើឱ្យអ្នកទទួលនូវភាពអពមង្គល។

118. ពិតប្រាកដណាស់ សម្រាប់អ្នកនៅក្នុងឋានសួគ៌នេះ គឺគ្មានភាពអត់ឃ្លាននោះទេ ហើយក៏មិនអាក្រាតកាយនោះដែរ។

119. ហើយពិតប្រាកដណាស់ សម្រាប់អ្នកនៅក្នុងឋានសួគ៌នេះ នឹងមិនស្រេកទឹក ហើយក៏មិនត្រូវកំដៅថ្ងៃនោះឡើយ។

120. ក្រោយមក ស្មែតនបានញុះញង់គេ(ព្យាការីអាហ្សាំ) ដោយវានិយាយថា៖ ឱអាហ្សាំ! តើអ្នកចង់ឱ្យខ្ញុំបង្ហាញអ្នកពីដើមឈើមួយដែលធ្វើឲ្យអ្នកមានជីវិតអមតៈ(ពេលទទួលទានវា) និងមានអំណាចគ្រប់គ្រងដែលគ្មានទីបញ្ចប់ដែរឬទេ?

121. ពេលនោះ គេទាំងពីរក៏បានទទួលទាន(ផ្លែឈើ)អំពីដើមឈើនោះ។ ខណៈនោះ ស្រាប់តែកេរខ្មាសរបស់គេទាំងពីរក៏បានលាតត្រដាងឡើងចំពោះគេទាំងពីរ ហើយគេទាំងពីរក៏បានបេះស្លឹកឈើពីឋានសួគ៌យកមកបិទបាំង(កេរខ្មាសរបស់ខ្លួន)។ ហើយព្យាការីអាហ្សាំបានប្រព្រឹត្តល្មើសនឹងព្រះជាម្ចាស់របស់គាត់ដោយបានបំពាន(នូវអ្វីដែលទ្រង់ហាមឃាត់)។

122. ក្រោយមក ព្រះជាម្ចាស់របស់គាត់ក៏បានជ្រើសរើសគាត់ និងបានទទួលយកការសោរភាពកំហុសរបស់គាត់ ព្រមទាំងបានចង្អុលបង្ហាញដល់គាត់។

123. ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកទាំងពីរ(ព្រមទាំងអ៊ីព្លិស)ចុះចេញពីឋានសួគ៌ទាំងអស់គ្នាចុះ។ ពួកអ្នកគឺជាសត្រូវនឹងគ្នាទៅវិញទៅមក។ ហើយប្រសិនបើការចង្អុលបង្ហាញអំពីយើងបានមកដល់ពួកអ្នក ដូច្នេះ ជនណាហើយដែលដើរតាមការចង្អុលបង្ហាញរបស់យើង ពិតប្រាកដណាស់ គេនឹងមិនវង្វេង និងមិនទទួលនូវភាពអពមង្គលឡើយ។

124. តែជនណាហើយដែលបានងាកចេញពីការដាស់រំឭករបស់យើង ពិតប្រាកដណាស់ រូបគេនឹងរស់នៅប្រកបដោយភាពចង្អៀតចង្អល់។ ហើយនៅថ្ងៃបរលោក យើងនឹងប្រមូលផ្តុំគេក្នុងនាមជាអ្នកពិការភ្នែក។

125. គេបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! ហេតុអ្វីបានជាព្រះអង្គប្រមូលផ្តុំខ្ញុំមកវិញក្នុងនាមជាអ្នកដែលពិការភ្នែកបែបនេះ ខណៈដែលខ្ញុំធ្លាប់ជាអ្នកភ្នែកភ្លឺទេតើ(កាលនៅលោកិយ)?

126. ទ្រង់បានតបថា៖ គឺដូច្នេះឯង (គឺដោយសារតែ)សញ្ញាកស្តុតាងជាច្រើនរបស់យើងបានមកដល់អ្នក តែអ្នកបែរជាងាកចេញអំពីវា។ ដូច្នេះ នៅក្នុងថ្ងៃនេះ អ្នកក៏ត្រូវគេបោះបង់ចោលដូចគ្នា។

127. ក៏ដូច្នោះដែរ យើងនឹងតបស្នងចំពោះជនណាដែលព្រងើយកន្តើយ និងមិនមានជំនឿនឹងសញ្ញាកស្តុតាងនៃព្រះជាម្ចាស់របស់គេ។ ហើយទណ្ឌកម្មនៅថ្ងៃបរលោក គឺធ្ងន់ធ្ងរជាង និងស្ថិតស្ថេរជាង។

128. តើវាមិនបានបង្ហាញដល់ពួកគេ(មុស្លីនទេ)ឬថា តើមានប្រជាជាតិប៉ុន្មានហើយមុនពួកគេដែលយើងបានបំផ្លាញពួកទាំងនោះ ខណៈដែលពួកគេ(ពួកមុស្លីន)ក៏បានធ្វើដំណើរឆ្លងកាត់លំនៅឋានរបស់ពួកទាំងនោះផងដែរ? ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់អ្នកដែលមានប្រាជ្ញាចេះគិតពិចារណា។

129. ហើយប្រសិនបើគ្មានការកំណត់ជាមុនពីព្រះជាម្ចាស់របស់អ្នក(ក្នុងការពន្យារពេលដាក់ទណ្ឌកម្មពួកគេ) និងការកំណត់អាយុជីវិតជាក់លាក់ទេនោះ ទ្រង់ពិតជានឹងដាក់ទណ្ឌកម្មពួកគេភ្លាមៗជាមិនខាន។

130. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចំពោះអ្វីដែលពួកគេនិយាយ ហើយត្រូវលើកតម្កើងដោយការសរសើរចំពោះព្រះជាម្ចាស់របស់អ្នកនៅមុនពេលថ្ងៃរះ(សឡាតហ្វាជើរ) និងមុនពេលថ្ងៃលិច(សឡាតអាសើរ) ហើយនិងមួយផ្នែកនៃពេលយប់(សឡាតអ៊ីស្ហា)។ ហើយចូរអ្នកលើកតម្កើងទ្រង់នៅពេលថ្ងៃជ្រេ(សឡាតហ្ស៊ូហោរ) និងបន្ទាប់ពីថ្ងៃលិច(សឡាតម៉ាហ្គ្រីប)។ សង្ឃឹមថាអ្នកនឹង(ទទួលបានផលបុណ្យដែល)អ្នកពេញចិត្ត។

131. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំសម្លឹងដោយភ្នែកទាំងគូរបស់អ្នកទៅកាន់អ្វី(លាភសក្ការៈលោកិយ)ដែលយើងបានប្រទានវាទៅឱ្យក្រុមមួយក្នុងចំណោមពួកគេ(ពួកប្រឆាំង)ដែលគ្រាន់តែជាការលម្អនៃជីវិតលោកិយដើម្បីយើងសាកល្បងពួកគេចំពោះរឿងនោះឱ្យសោះ។ ហើយលាភសក្ការៈនៃព្រះជាម្ចាស់របស់អ្នក គឺល្អប្រសើរជាង និងស្ថិតស្ថេរជាងនោះទៅទៀត។

132. ហើយចូរអ្នកបង្គាប់ឱ្យក្រុមគ្រួសាររបស់អ្នកប្រតិបត្តិសឡាត និងចូរអ្នកអត់ធ្មត់លើការប្រតិបត្តិវា។ យើងមិនទាមទារលាភសក្ការៈពីអ្នកឡើយ។ យើងទៅវិញទេដែលជាអ្នកប្រទានលាភសក្ការៈដល់អ្នកនោះ។ ហើយលទ្ធផលចុងក្រោយ គឺសម្រាប់អ្នកដែលកោតខ្លាច(អល់ឡោះ)។

133. ហើយពួកគេ(ពួកប្រឆាំង)បាននិយាយថា៖ ហេតុអ្វីបានជាគេ(ព្យាការីមូហាំម៉ាត់)មិននាំមកនូវសញ្ញាកស្តុតាងណាមួយពីព្រះជាម្ចាស់របស់គេមកកាន់ពួកយើង? តើគម្ពីរគួរអានដែលជាការបញ្ជាក់ទៅលើបណ្តាគម្ពីរដែលបានបញ្ចុះកាលពីមុននោះមិនបានមកដល់ពួកគេទេឬ?

134. ហើយពិតប្រាកដណាស់ ប្រសិនបើយើងបំផ្លាញពួកគេ(ពួកប្រឆាំង)ដោយទណ្ឌកម្មមុននឹងយើងបញ្ជូនអ្នកនាំសារនិងគម្ពីរទៅកាន់ពួកគេនោះ ពួកគេប្រាកដជានឹងនិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ហេតុអ្វីបានជាទ្រង់មិនបញ្ជូនអ្នកនាំសារម្នាក់មកកាន់ពួកយើងដើម្បីឱ្យពួកយើងដើរតាមសញ្ញាកស្តុតាងរបស់ព្រះអង្គ(ដែលអ្នកនាំសារបាននាំមក)មុនពេលដែលភាពអាប់ឱននិងភាពអាម៉ាស់ធ្លាក់មកលើពួកយើង?

135. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ រាល់ៗបុគ្គល គឺសុទ្ធតែរង់ចាំមើល(នូវអ្វីដែលអល់ឡោះវិនិច្ឆ័យ)។ ដូច្នេះចូរពួកអ្នករង់ចាំមើលចុះ! ពួកអ្នកនឹងដឹងថា តើអ្នកណាដែលស្ថិតនៅមាគ៌ាត្រឹមត្រូវ និងអ្នកណាដែលទទួលបានការចង្អុលបង្ហាញ(ពីអល់ឡោះ)នោះ?

ជំពូក អាល់អាំពីយ៉ាក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការជំនុំជម្រះចំពោះមនុស្សលោកបានខិតជិតមកដល់ហើយ ខណៈដែលពួកគេស្ថិតនៅក្នុងភាពព្រងើយកន្តើយ និងងាកចេញ(ពីការដាស់ព្រមាននេះ)។

2. ហើយគ្មានការរំឭក(គម្ពីរគួរអាន)ថ្មីណាមួយមកពីព្រះជាម្ចាស់របស់ពួកគេបានមកដល់ពួកគេនោះឡើយ លើកលែងតែពួកគេស្តាប់វាដោយដោយលេងសើចប៉ុណ្ណោះ

3. ដោយដួងចិត្តរបស់ពួកគេព្រងើយកន្តើយ(មិនយកចិត្តទុកដាក់)ចំពោះវា។ ហើយពួកដែលបំពានបាននិយាយខ្សឹបខ្សៀវគ្នាដោយស្ងាត់ៗថា៖ តើមនុស្សម្នាក់នេះ(ព្យាការីមូហាំម៉ាត់)គ្មានអ្វីក្រៅតែពីជាមនុស្សធម្មតាដូចពួកអ្នកទេឬ? ហើយពួកអ្នកដើរតាមមន្តអាគមឬ ខណៈដែលពួកអ្នកមើលឃើញច្បាស់(ថាគេក៏ជាមនុស្សលោកធម្មតាដូចពួកអ្នក)ដែរនោះ?

4. គាត់(ព្យាការីមូហាំម៉ាត់)បាននិយាយថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់ដឹងបំផុតនូវពាក្យសម្តីដែលនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

5. ផ្ទុយទៅវិញ ពួកគេនិយាយថា៖ វា(គម្ពីរគួរអាន)គ្រាន់តែជាសុបិនដែលច្របូកច្របល់ប៉ុណ្ណោះ។ ផ្ទុយទៅវិញ គេគឺជាអ្នកប្រឌិតកុហកវាឡើង។ ផ្ទុយទៅវិញ គេគឺជាកវីនិពន្ធម្នាក់ប៉ុណ្ណោះ។ ដូច្នេះ ចូរឱ្យគេនាំមកឱ្យពួកយើងនូវអច្ឆរិយភាពណាមួយដូចអ្វីដែលគេបញ្ជូនទៅឲ្យបណ្តាអ្នក(នាំសារ)ជំនាន់មុន។

6. គ្មានភូមិស្រុកណាមួយមុនពួកគេដែលមានជំនឿនោះឡើយ(ពេលដែលពួកគេទទួលបានតាមការទាមទារ)។ ដូច្នេះ យើងក៏បំផ្លាញវា(ភូមិស្រុកនោះ)ទៅ។ តើពួកទាំងនោះ មានជំនឿឬទេ?

7. ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះឡើយ លើកលែងតែជាបុរសៗដែលយើងផ្តល់វាំហ៊ីទៅកាន់ពួកគេប៉ុណ្ណោះ។ ដូចនេះ ចូរពួកអ្នកសួរអ្នកដែលមានចំណេះដឹង(ពួកអះលីគីតាប)ចុះ ប្រសិនបើពួកអ្នកមិនដឹងនោះ។

8. ហើយយើងមិនបានបង្កើតពួកគេ(អ្នកនាំសារទាំងនោះ)ជារូបរាងកាយដែលមិនទទួលទានអាហារនោះឡើយ។ ហើយពួកគេក៏មិនមានជីវិតអមតៈនោះដែរ។

9. ក្រោយមក យើងបានធ្វើឱ្យការសន្យាចំពោះពួកគេក្លាយជាការពិតដោយយើងបានសង្គ្រោះពួកគេ ហើយនិងជនណាដែលយើងមានចេតនា និងបំផ្លាញពួកដែលល្មើសបំពាន។

10. ជាការពិតណាស់ យើងបានបញ្ចុះគម្ពីរ(គួរអាន)ទៅកាន់ពួកអ្នក ដែលមាននៅក្នុងនោះ គឺភាពខ្ពង់ខ្ពស់របស់ពួកអ្នក ។ តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

11. ហើយស្រុកភូមិជាច្រើនមកហើយដែលយើងបានបំផ្លាញវាដោយសារតែពួកគេបានបំពាន។ ហើយយើងបានបង្កើតក្រុមមួយផ្សេងទៀតបន្ទាប់ពីពួកគេ។

12. ហើយនៅពេលដែលពួកគេបានឃើញនូវទណ្ឌកម្មរបស់យើង ស្រាប់តែពួកគេរត់ចេញពីទីនោះយ៉ាងលឿន។

13. (ពេលនោះ មានសំឡេងស្រែកហៅពួកគេថា៖) ចូរពួកអ្នកកុំរត់គេចឱ្យសោះ ហើយចូរពួកអ្នកវិលត្រឡប់ទៅកាន់អ្វីដែលពួកអ្នកធ្លាប់បានសោយសុខ និង(ទៅកាន់)លំនៅឋានរបស់ពួកអ្នកវិញចុះ សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេសួរ។

14. ពួកគេបាននិយាយថា៖ ឱអនិច្ចាពួកយើង! ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាពួកដែលបំពាន។

15. ហើយពួកគេនៅតែទទួលស្គាល់ចំពោះការអះអាងរបស់ខ្លួន រហូតទាល់តែយើងធ្វើឱ្យពួកគេប្រៀបដូចជាដំណាំដែលគេច្រូតកាត់ដែលងាប់អស់។

16. ហើយយើងមិនបានបង្កើតមេឃជាច្រើនជាន់ និងផែនដី ព្រមទាំងអ្វីៗដែលមាននៅក្នុងវាទាំងពីរជាការលេងសើចនោះឡើយ។

17. ប្រសិនបើយើងមានបំណងចង់យកមហេសីឬបុត្រនោះ ប្រាកដជាយើងនឹងយកអ្នកដែលនៅក្បែរយើងជាមិនខាន ប្រសិនបើយើងចង់ធ្វើ(ដូច្នោះ)មែននោះ។

18. ផ្ទុយទៅវិញ យើងនឹងបំភ្លឺភាពពិតទៅលើភាពខុសឆ្គងវាក៏រលាយសាបសូន្យ។ ពេលនោះ ភាពខុសឆ្គងក៏ត្រូវបាត់បង់។ ហើយភាពវិនាសអន្តរាយ គឺសម្រាប់ពួកអ្នកដោយសារតែអ្វីដែលពួកអ្នកបានចោទប្រកាន់(ទៅលើអល់ឡោះ)។

19. ហើយអ្នកដែលនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយអ្នកដែលនៅក្បែរទ្រង់(ម៉ាឡាអ៊ីកាត់) ពួកគេមិនក្រអឺតក្រទមក្នុងការគោរពសក្ការៈចំពោះទ្រង់ឡើយ ហើយពួកគេក៏មិនមានការនឿយណាយនោះដែរ។

20. ពួកគេលើកតម្កើងដល់ទ្រង់ទាំងយប់ទាំងថ្ងៃដោយគ្មានការនឿយហត់នោះឡើយ។

21. ឬមួយគេ(ពួកមុស្លីគីន)បានយកព្រះនានានៅលើផែនដីធ្វើជាម្ចាស់ ដែលពួកវាមិនអាចប្រោសជីវិតដែលស្លាប់ឱ្យរស់ឡើងវិញផងនោះ?

22. ប្រសិនបើនៅលើមេឃជាច្រើនជាន់និងនៅលើផែនដីមានព្រះច្រើនក្រៅពីអល់ឡោះនោះ វាទាំងពីរ(មេឃនិងផែនដី)ច្បាស់ជាអន្តរាយជាមិនខាន។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នៃអារ៉ាស្តនោះ ទ្រង់មហាស្អាតស្អំអំពីអ្វីដែលពួកគេចោទប្រកាន់។

23. ទ្រង់មិនត្រូវបានគេសួរអំពីអ្វីដែលទ្រង់ធ្វើនោះទេ តែពួកគេទៅវិញទេដែលត្រូវបានគេសួរនោះ។

24. ឬមួយពួកគេយកព្រះនានាក្រៅពីអល់ឡោះធ្វើជាម្ចាស់? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកនាំយកនូវអំណះអំណាងរបស់ពួកអ្នកមក។ គម្ពីរគួរអានដែលនៅជាមួយខ្ញុំនេះ និងគម្ពីររបស់អ្នកជំនាន់មុនខ្ញុំ(គឺមិនមានបញ្ជាក់ពីរឿងនេះឡើយ)។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងពីការពិតនោះឡើយ។ ដូច្នេះ ពួកគេគឺជាពួកដែលងាកចេញ(ពីការពិត)។

25. ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះឡើយ លើកលែងតែយើងបានផ្តល់វាហ៊ីទៅកាន់គេថា៖ ពិតប្រាកដណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីយើងឡើយ។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈចំពោះយើង(តែមួយគត់)។

26. ហើយពួកគេនិយាយថា៖ ព្រះជាម្ចាស់ដ៏មហាសប្បុរសទ្រង់មានបុត្រ។ ទ្រង់មហាស្អាតស្អំ។ ផ្ទុយទៅវិញ ពួកគេ(ម៉ាឡាអ៊ីកាត់)គឺជាខ្ញុំបម្រើ(របស់អល់ឡោះ)ដែលត្រូវបានគេលើកតម្កើងប៉ុណ្ណោះ។

27. ពួកគេ(ម៉ាឡាអ៊ីកាត់)មិនហ៊ានផ្តើមសម្តី(របស់ពួកគេ)មុនទ្រង់នោះឡើយ។ ហើយពួកគេប្រតិបត្តិតាមបទបញ្ជារបស់ទ្រង់។

28. ទ្រង់ដឹងនូវអ្វីដែលនៅខាងមុខពួកគេ(ទង្វើកាលពីមុន) និងអ្វីដែលនៅខាងក្រោយពួកគេ(ទង្វើដែលពួកគេនឹងសាង)។ ហើយពួកគេមិនធ្វើអន្តរាគមន៍ដល់នរណានោះឡើយ លើកលែងតែជនណាដែលទ្រង់ពេញចិត្តប៉ុណ្ណោះ។ ហើយដោយការខ្លាចចំពោះទ្រង់ ពួកគេប្រុងប្រយ័ត្ន(ជានិច្ច)។

29. ហើយជនណាក្នុងចំណោមពួកគេ(ម៉ាឡាអ៊ីកាត់)ដែលនិយាយថា៖ "ពិតណាស់ ខ្ញុំគឺជាម្ចាស់ដែលត្រូវបានគេគោរពសក្ការៈក្រៅពីទ្រង់"នោះ យើងពិតជានឹងតបស្នងនូវនរកដើហាន់ណាំដល់គេ។ ក៏ដូច្នោះដែរ យើងនឹងតបស្នងដល់ពួកដែលបំពាន។

30. តើពួកដែលគ្មានជំនឿមិនបានដឹងទេឬថា ជាការពិតណាស់ មេឃជាច្រើនជាន់និងផែនដីវាទាំងពីរគឺធ្លាប់ស្ថិតនៅជាប់គ្នា។ ក្រោយមក យើងក៏បានបំបែកវាចេញពីគ្នា។ ហើយយើងបានបង្កើតរាល់អ្វីៗទាំងអស់ដែលមានជីវិតតាមរយៈទឹក។ ដូច្នេះ តើពួកគេមិនមានជំនឿទេឬ?

31. ហើយយើងបានបង្កើតនៅលើផែនដីនោះនូវភ្នំជាច្រើន(សម្រាប់ទប់លំនឹង)ដើម្បីកុំឱ្យវាញ័ររញ្ជួយដល់ពួកគេ។ ហើយយើងបានបង្កើតឱ្យមានផ្លូវធំទូលាយជាច្រើននៅលើផែនដី។ សង្ឃឹមថាពួកគេទទួលបានការចង្អុលបង្ហាញ(ទៅកាន់គោលដៅ)។

32. ហើយយើងបានបង្កើតមេឃជាដំបូលដែលត្រូវបានការពារ។ តែពួកគេ(ពួកមុស្លីគីន)បែរជាងាកចេញពីសញ្ញាកស្តុតាងនានារបស់វាដដែល។

33. ហើយទ្រង់ជាអ្នកដែលបានបង្កើតពេលយប់ ពេលថ្ងៃ ព្រះអាទិត្យ និងព្រះចន្ទ។ អ្វីៗទាំងនោះ គឺសុទ្ធតែធ្វើដំណើរតាមគន្លងរបស់វា(រៀងៗខ្លួន)។

34. ហើយយើងមិនបានបង្កើតមនុស្សណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ឱ្យមានជីវិតអមតៈនោះឡើយ។ ប្រសិនបើអ្នកក៏នឹងត្រូវស្លាប់ដែរនោះ ដូច្នេះ តើពួកគេអាចមានជីវិតអមតៈឬ?

35. រាល់ជីវិតទាំងអស់ គឺនឹងត្រូវភ្លក់រសជាតិនៃសេចក្តីស្លាប់។ ហើយយើងនឹងសាកល្បងពួកអ្នក(ឱមនុស្សលោក)ដោយប្រការអាក្រក់ និងប្រការល្អ។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់មកកាន់យើង(តែមួយគត់)។

36. ហើយនៅពេលដែលពួកប្រឆាំងបានឃើញអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ពួកគេបានយកអ្នកធ្វើជាការលេងសើច(ដោយនិយាយថា៖) តើគេនេះឬដែលមើលងាយព្រះនានារបស់ពួកអ្នកនោះ? ហើយពួកគេក៏ជាពួកដែលប្រឆាំងនឹងការរំឭករបស់ព្រះជាម្ចាស់ដ៏មហាសប្បុរស។

37. មនុស្សលោកត្រូវបានគេបង្កើតមកដោយមានចរិតអន្ទះសា។ យើងនឹងបង្ហាញឱ្យពួកអ្នកបានឃើញនូវសញ្ញាកស្តុតាងរបស់យើង។ ហេតុនេះ ចូរពួកអ្នកកុំសុំឲ្យ(ទណ្ឌកម្ម)ឆាប់មកដល់។

38. ហើយពួកគេបាននិយាយថា៖ តើការសន្យានេះនឹងមកដល់នៅពេលណា ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ?

39. ប្រសិនបើពួកប្រឆាំងបានដឹងនៅពេលដែលពួកគេមិនអាចការពារភ្លើងនរកចេញពីមុខរបស់ពួកគេ និងពីខ្នងរបស់ពួកគេបាន ហើយក៏គ្មានអ្នកណាដែលអាចជួយពួកគេបានដែរនោះ(ម្ល៉ោះពួកគេក៏នឹងមិនសុំឱ្យទណ្ឌកម្មនោះឆាប់មកដល់នោះដែរ)។

40. ផ្ទុយទៅវិញ វា(ទណ្ឌកម្ម)នឹងមកដល់ពួកគេភ្លាមៗដែលធ្វើឲ្យពួកគេស្រឡាំងកាំង។ ពេលនោះ ពួកគេគ្មានសមត្ថភាពរុញច្រានវានោះទេ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេលឲ្យនោះដែរ។

41. ហើយជាការពិតណាស់ មានបណ្តាអ្នកនាំសារដោយច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ក៏ត្រូវបានគេចំអកឡកឡឺយដែរ។ ពេលនោះ ពួកដែលចំអកឡកឡឺយក្នុងចំណោមពួកគេត្រូវបានហ៊ឹមព័ទ្ធទៅដោយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានចំអកឡកឡឺយចំពោះវានោះ។

42. ចូរអ្នកសួរទៅកាន់ពួកពោលថា៖ តើមានអ្នកណាដែលអាចការពារពួកអ្នកនៅពេលយប់និងនៅពេលថ្ងៃអំពីព្រះជាម្ចាស់ដ៏មហាសប្បុរស? ផ្ទុយទៅវិញ ពួកគេគឺជាពួកដែលងាកចេញពីការរំឭករបស់ព្រះជាម្ចាស់របស់ពួកអ្នក។

43. ឬមួយពួកគេមានព្រះនានាផ្សេងពីយើងដែលអាចការពារពួកគេ(ពីទណ្ឌកម្ម)? ពិតប្រាកដណាស់ ពួកវាគ្មានសមត្ថភាពសូម្បីតែជួយខ្លួនឯង ហើយពួកវាក៏មិនរួចផុតពីទណ្ឌកម្មរបស់យើងបាននោះដែរ។

44. ផ្ទុយទៅវិញ យើងបានផ្តល់ការសោយសុខដល់ពួកទាំងនោះ និងជីដូនជីតារបស់ពួកគេ រហូតដល់ពួកគេមានអាយុវែង។ តើពួកគេ(ប្រឆាំង)មិនឃើញទេឬថា ជាការពិតណាស់ យើងបានរំដោះយកទឹកដីរបស់ពួកគេដោយយើងបានកាត់បន្ថយវាបន្តិចម្តងៗនៅគ្រប់ទិសទីទាំងអស់។ ដូច្នេះ តើពួកគេជាអ្នកឈ្នះឬ?

45. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តាមពិត ខ្ញុំគ្រាន់តែដាស់តឿនព្រមានពួកអ្នកតាមរយៈវ៉ាហ៊ីប៉ុណ្ណោះ។ ហើយអ្នកដែលថ្លង់នោះ គឺស្តាប់មិនឮការអំពាវនាវនោះឡើយនៅពេលដែលមានគេដាស់តឿនព្រមានពួកគេនោះ។

46. ហើយប្រសិនបើមួយចំណែកនៃទណ្ឌកម្មព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ធ្លាក់ទៅលើពួកគេ នោះពួកគេប្រាកដជានឹងនិយាយថា៖ ឱអនិច្ចាពួកយើង! ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាពួកដែលបំពាន។

47. ហើយយើងនឹងដាក់ជញ្ជីងយុត្តិធម៌នៅថ្ងៃបរលោក(ដើម្បីថ្លឹងទង្វើពួកគេ)។ ដូចនេះ គ្មានជីវិតណាម្នាក់ត្រូវបានគេបំពានបន្តិចណាឡើយ សូម្បីតែវា(ទង្វើដែលត្រូវថ្លឹង)មានទំហំតូចប៉ុនគ្រាប់ស្ពៃក៏ដោយ ក៏យើងនាំវាមក(ថ្លឹង)ដែរ។ គ្រប់គ្រាន់ហើយដែលយើងជាអ្នកជំនុំជម្រះ។

48. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីមូសា និងព្យាការីហារូននូវគែម្ពីរតៅរ៉ាត ដែលជាពន្លឺ និងជាការរំឭកដល់បណ្ដាអ្នកដែលកោតខ្លាច។

49. គឺបណ្ដាអ្នកដែលខ្លាចព្រះជាម្ចាស់របស់ពួកគេទាំងអាថ៌កំបាំង ហើយពួកគេជាពួកដែលខ្លាចថ្ងៃបរលោក។

50. ហើយ(គម្ពីរគួរអាន)ដែលយើងបានបញ្ចុះមកនេះ គឺជាការរំឭកដ៏មានពរជ័យ។ ដូច្នេះ តើពួកអ្នកនៅតែបដិសេធចំពោះវាទៀតឬ?

51. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីអ៊ីព្រហ៊ីមនូវការចង្អុលបង្ហាញដល់គេកាលពីមុន។ ហើយយើងជាអ្នកដែលដឹងបំផុតចំពោះគេ។

52. នៅពេលដែលគាត់បាននិយាយទៅកាន់ឪពុករបស់គាត់ និងក្រុមរបស់គាត់ថា៖ តើរូបបដិមាដែលពួកអ្នកនាំគ្នាគោរពសក្ការៈចំពោះពួកវាទាំងនេះ គឺជាអ្វី?

53. ពួកគេតបថា៖ ពួកយើងបានឃើញដីដូនដីតារបស់ពួកយើងគោរពសក្ការៈចំពោះពួកវា។

54. គាត់ក៏តបថា៖ ពិតប្រាកដណាស់ ពួកអ្នក និងដីដូនដីតារបស់ពួកអ្នក គឺស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

55. ពួកគេក៏បានតបវិញថា៖ តើអ្នកនាំមកឱ្យពួកយើងនូវការពិត ឬមួយក៏អ្នកស្ថិតក្នុងចំណោមអ្នកដែលលេងសើច?

56. គាត់បានតបថា៖ ផ្ទុយទៅវិញ ព្រះជាម្ចាស់របស់អ្នក គឺជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដីដែលទ្រង់បានបង្កើតពួកវាមក។ ហើយខ្ញុំគឺស្ថិតក្នុងចំណោមអ្នកដែលធ្វើសាក្សីលើរឿងនោះ។

57. សូមស្បថនឹងអល់ឡោះ! ខ្ញុំពិតជានឹងរៀបចំគម្រោងការកម្ទេចបដិមារបស់ពួកអ្នក ក្រោយពីពួកអ្នកចាកចោលពួកវា(ទៅចូលរួមពិធីបុណ្យ)។

58. ពេលនោះ គាត់ក៏បានវាយកម្ទេចរូបបដិមាទាំងនោះជាបំណែកៗ លើកលែងតែបដិមាមួយដែលធំជាងគេ ដើម្បីឱ្យពួកគេត្រឡប់ទៅកាន់វា(ហើយសួរវា)។

59. (ពេលដែលពួកគេត្រឡប់មកវិញ) ពួកគេសួរថា៖ តើអ្នកណាជាអ្នកធ្វើទង្វើនេះដាក់ព្រះនានារបស់ពួកយើង? ពិតប្រាកដណាស់ អ្នកនោះពិតជាស្ថិតក្នុងចំណោមពួកដែលបំពាន។

60. ពួកគេមួយចំនួនបាននិយាយថា៖ ពួកយើងបានឮយុវជនម្នាក់និយាយអាក្រក់ពីវា(បដិមា)ដែលគេហៅ(យុវជនម្នាក់នោះ)ថា អ៊ីព្រហ៊ីម។

61. ពួកគេ(ពួកមេដឹកនាំ)បាននិយាយថា៖ ចូរពួកអ្នកនាំគេមកបង្ហាញនៅចំពោះមុខមហាជនទាំងឡាយ ដើម្បីឱ្យពួកគេធ្វើជាសាក្សី។

62. ពួកគេក៏បានសួរគាត់ថា៖ តើអ្នកឬដែលបានធ្វើនូវទង្វើបែបនេះដាក់ព្រះនានារបស់ពួកយើង ឱអ៊ីព្រហ៊ីម?

63. គាត់បានតបថា៖ ផ្ទុយទៅវិញ គឺរូបបដិមាដែលធំជាងគេនេះឯងដែលជាអ្នកធ្វើ។ ហេតុនេះ ចូរពួកអ្នកសួរពួកវាចុះ ប្រសិនបើពួកវាអាចនិយាយបានមែននោះ។

64. ពេលនោះ ពួកគេក៏បានបែរមកធ្វើការពិចារណាលើខ្លួនឯង។ ពេលនោះ ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលបំពាន។

65. ក្រោយមក ភាពចចេសរឹងរូសរបស់ពួកគេក៏បានត្រឡប់មកវិញ (ហើយពួកគេបាននិយាយថា៖) ជាការពិតណាស់ អ្នកដឹងច្បាស់ហើយថា រូបបដិមាទាំងនោះមិនអាចនិយាយអ្វីបាននោះទេ។

66. គាត់ក៏បានតបថា៖ ដូច្នេះ តើពួកអ្នកគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះដែលពួកវាមិនអាចផ្តល់ផលប្រយោជន៍អ្វី ហើយក៏មិនអាចផ្តល់គ្រោះថ្នាក់ដល់ពួកអ្នកសោះនោះឬ?

67. គួរឱ្យអាម៉ាស់បំផុតចំពោះពួកអ្នក និងចំពោះអ្វីដែលពួកអ្នកគោរពសក្ការៈផ្សេងពីអល់ឡោះនោះ។ ដូច្នេះ តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

68. ពួកគេក៏និយាយថា៖ ចូរពួកអ្នកដុតគេ ហើយសង្គ្រោះព្រះនានារបស់ពួកអ្នកចុះ ប្រសិនបើពួកអ្នកចង់ធ្វើ។

69. យើង (អល់ឡោះ) បានមានបន្ទូលថា៖ ឱភ្លើង! ចូរឯងប្រែទៅជាត្រជាក់ ហើយផ្តល់សុវត្ថិភាពដល់អ៊ីព្រហ៊ីមចុះ។

70. ហើយគេមានបំណងរៀបចំផែនការអាក្រក់ចំពោះគាត់ តែយើងបានធ្វើឱ្យពួកគេខាតបង់។

71. ហើយយើងបានជួយសង្គ្រោះគាត់ និងព្យាការីលូតទៅកាន់ទឹកដីដែលយើងបានប្រទានពរជ័យចំពោះទឹកដីនេះសម្រាប់ពិភពទាំងអស់។

72. ហើយយើងបានប្រទានបន្ថែមដល់គាត់នូវព្យាការីអ៊ីស្ហាក (ជាកូន) និងព្យាការីយ៉ាក់កូប (ជាចៅ)។ ហើយយើងបានធ្វើឱ្យពួកគេពួកគេទាំងអស់ក្លាយជាអ្នកដែលសាងកុសល។

73. ហើយយើងបានឱ្យពួកគេក្លាយទៅជាអ្នកដឹកនាំដែលចង្អុលបង្ហាញ (មនុស្សទៅកាន់ប្រការល្អ) ទៅតាមបទបញ្ជារបស់យើង។ ហើយយើងបានផ្តល់វ៉ាហ៊ីទៅកាន់ពួកគេឲ្យសាងអំពើល្អ និងប្រតិបត្តិសឡាត ហើយនិងបរិច្ចាគហ្សាកាត់។ ហើយពួកគេ គឺជាអ្នកដែលប្រគល់ខ្លួនចំពោះយើង។

74. ហើយចំពោះព្យាការីលូត យើងបានប្រទានឱ្យគេនូវការ (ចេះ) វិនិច្ឆ័យ និងចំណេះដឹង។ ហើយយើងបានសង្គ្រោះគេពីភូមិស្រុកដែលអ្នកភូមិនោះបានប្រព្រឹត្តនូវទង្វើស្មោកគ្រោក (ស្រលាញ់ភេទដូចគ្នា)។ ពិតប្រាកដណាស់ ពួកគេគឺជាក្រុមអាក្រក់ និងល្មើសច្បាប់។

75. ហើយយើងបានបញ្ចូលរូបគេ (ព្យាការីលូត) ទៅក្នុងក្តីមេត្តាករុណារបស់យើង។ ពិតប្រាកដណាស់ រូបគេស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

76. ហើយ(ចូរអ្នករំឭក)រឿងរ៉ាវរបស់ព្យាការីនួហ ខណៈដែលគេបានបួងសួងកាលពីមុន។ ពេលនោះ យើងបានទទួលយកការបួងសួងរបស់គេ។ ហើយយើងបានសង្គ្រោះរូបគេ និងក្រុមគ្រួសាររបស់គេ(អ្នកមានជំនឿ)ពីគ្រោះដ៏ធំធេង។

77. ហើយយើងបានសង្គ្រោះរូបគេពីក្រុមដែលបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង។ ពិតប្រាកដណាស់ ពួកគេគឺជាក្រុមដែលអាក្រក់។ ដូច្នេះ យើងក៏បានពន្លិចពួកគេទាំងអស់គ្នា(ក្នុងទឹកជំនន់)។

78. ហើយ(ចូរអ្នករំឭក)រឿងរ៉ាវរបស់ព្យាការីហ្វារូទ និងព្យាការីស៊ូឡៃម៉ាន ខណៈដែលគេទាំងពីរបានកាត់ក្តីចំពោះរឿងចម្ការដែលហ្វូងចៀមរបស់ក្រុមមួយបានចូលទៅចម្ការនោះខ្ទេចខ្ទី។ ហើយពិតណាស់ យើងគឺជាសាក្សីចំពោះការកាត់ក្តីរបស់ពួកគេ។

79. ក្រោយមក យើងបានឱ្យព្យាការីស៊ូឡៃម៉ានយល់ពីរឿងក្តីនេះ។ ហើយចំពោះគេទាំងពីរ យើងប្រទាននូវការវិនិច្ឆ័យ និងចំណេះដឹង។ ហើយយើងបានឱ្យភ្នំ និងសត្វស្លាបទាំងឡាយលើកតម្កើងសរសើរចំពោះយើងជាមួយព្យាការីហ្វារូទ។ ហើយយើងជាអ្នកដែលធ្វើរឿងទាំងនេះ។

80. ហើយយើងបានបង្រៀនដល់គេ(ព្យាការីហ្វារូទ)ឱ្យចេះធ្វើអាវក្រោះសម្រាប់ពួកអ្នកដើម្បីការពារពួកអ្នកពីការរងគ្រោះ(ក្នុងសមរភូមិ)។ ដូច្នេះ តើពួកអ្នក(ឱមនុស្សលោក)ជាអ្នកដែលដឹងគុណដែរឬទេ?

81. ហើយចំពោះព្យាការីស៊ូឡៃម៉ាន យើងបានផ្តល់ឱ្យគេអាចបញ្ជាខ្យល់ដែលបោកបក់យ៉ាងខ្លាំងទៅតាមបទបញ្ជារបស់គេទៅកាន់ទឹកដី(ស្តាម)ដែលយើងបានប្រទានពរជ័យចំពោះវា។ ហើយយើងជាអ្នកដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

82. ហើយក្នុងចំណោមពពួកស្មៃតន គឺមានអ្នកដែលជ្រមុជទឹកសមុទ្រ(រុករកអ្វីៗ)ឱ្យគេ(ព្យាការីស៊ូឡៃម៉ាន) និងធ្វើកិច្ចការផ្សេងពីនេះទៀត។ ហើយយើងគឺជាអ្នកថែរក្សាចំពោះពួកគេ។

83. ហើយ(ចូរអ្នករំឭក)រឿងរ៉ាវរបស់ព្យាការីអៃយ៉ូប ខណៈដែលគេបានបួងសួងពីព្រះជាម្ចាស់របស់គេថាៈ ពិតប្រាកដណាស់ ខ្ញុំបានទទួលរងនូវគ្រោះ(ជំងឺឈឺថ្កាត់ និងបាត់បង់គ្រួសារ) ហើយព្រះអង្គគឺជាអ្នកដែលអាណិតស្រលាញ់ជាងគេបំផុត។

84. ពេលនោះ យើងក៏បានឆ្លើយតបចំពោះគេ ហើយយើងបានដកយកគ្រោះនោះចេញពីរូបគេ និងបានប្រទានឱ្យគេនូវក្រុមគ្រួសារ(ដែលគេបានបាត់បង់)នោះមកវិញ ព្រមទាំងប្រទានឱ្យគេដូចអ្វីដែលធ្លាប់មាននៅជាមួយពួកគេ(កាលពីមុន)ជាក្តីមេត្តាករុណាពីយើង និងជាការរំឭកដល់អ្នកដែលគោរពសក្ការៈ(ចំពោះយើង)ទាំងឡាយ។

85. ហើយ(ចូរអ្នករំលឹក)រឿងរ៉ាវរបស់ព្យាការីអ៊ីស្មាអែល ព្យាការីអ៊ីទ្រីស និងព្យាការីហ្ស៊ុលគីហ្វល៍។ ពួកគេទាំងអស់នោះ សុទ្ធតែស្ថិតក្នុងចំណោមអ្នកដែលអត់ធ្មត់។

86. ហើយយើងបានបញ្ចូលពួកគេទៅក្នុងក្តីមេត្តាករុណារបស់យើង ដោយយើងបានឱ្យពួកគេក្លាយជាព្យាការីព្រមទាំងបញ្ចូលពួកគេទៅក្នុងឋានសួគ៌(នៅថ្ងៃបរលោក)។ ពិតប្រាកដណាស់ ពួកគេស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

87. ហើយ(ចូរអ្នករំឭក)រឿងរ៉ាវរបស់អ្នកដែលស្ថិតនៅក្នុងពោះត្រី(ព្យាការីយូនូស) ខណៈដែលគេបានចាកចេញទាំងកំហឹងដោយគេគិតស្មានថា យើងមិនយកទោសពៃរលើរូបគេឡើយ។ នៅពេលនោះ គេក៏បានបួងសួងទាំងដែលគេស្ថិតនៅក្នុងភាពងងឹត(នៅក្នុងពោះត្រី)ថាៈ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីព្រះអង្គឡើយ។ ព្រះអង្គមហាស្អាតស្អំ។ ពិតប្រាកដណាស់ ខ្ញុំទេដែលស្ថិតក្នុងចំណោមអ្នកដែលបំពាននោះ។

88. ពេលនោះ យើងក៏បានឆ្លើយតបចំពោះគេ ហើយយើងបានសង្គ្រោះរូបគេពីទុក្ខព្រួយនោះ។ ក៏ដូច្នោះដែរ យើងនឹងសង្គ្រោះបណ្ដាអ្នកដែលមានជំនឿទាំងឡាយ។

89. ហើយ(ចូរអ្នករំលឹក)រឿងរ៉ាវរបស់ហ្សាការីយ៉ា ខណៈដែលគេបានបួងសួងសុំពីព្រះជាម្ចាស់របស់គេថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាកុំទុកខ្ញុំឲ្យនៅម្នាក់ឯង(ដោយគ្មានកូនស្នងត្រកូល)ឲ្យសោះ ខណៈដែលព្រះអង្គជាអ្នកដែលផ្ដល់នូវអ្នកស្នងត្រកូលដែលល្អបំផុត។

90. ពេលនោះ យើងក៏បានឆ្លើយតបចំពោះគេ ហើយយើងបានប្រទាននូវព្យាការីយ៉ះយ៉ា(ជាកូន)ដល់រូបគេ ហើយយើងបានព្យាបាលភរិយារបស់គេ(ពីជំងឺអារ)។ ពិតប្រាកដណាស់ ពួកគេរួសរាន់ក្នុងការសាងអំពើល្អ ហើយពួកគេបួងសួងមកកាន់យើងដោយក្ដីសង្ឃឹម និងកោតខ្លាច។ ហើយពួកគេ គឺជាអ្នកដែលឱនលំទោនបំផុតមកចំពោះយើង។

91. ហើយ(ចូរអ្នករំឭក)រឿងរ៉ាវអ្នកដែលបានរក្សាភាពបរិសុទ្ធរបស់ខ្លួន(ម៉ារយ៉ាំ) ហើយយើងបានឲ្យជីព្រីលផ្លុំវិញ្ញាណទៅក្នុងខ្លួននាង។(ពេលនោះ នាងក៏មានផ្ទៃពោះ)។ ហើយនាង និងកូនប្រុសរបស់នាង(ព្យាការីអ៊ីសា)ក្លាយជាសញ្ញាកស្ដុតាងមួយសម្រាប់មនុស្សលោក។

92. ជាការពិតណាស់ សាសនារបស់ពួកអ្នកនេះ(ឱមនុស្សលោក)គឺជាសាសនាតែមួយគត់(សាសនាអ៊ីស្លាម)ហើយយើងគឺជាព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈមកចំពោះយើង(តែមួយគត់)។

93. ក៏ប៉ុន្តែ ពួកគេបានបែកបាក់គ្នាចំពោះកិច្ចការ(សាសនា)របស់ពួកគេ។ ហើយអ្នកទាំងអស់នោះ គឺនឹងវិលត្រឡប់មកកាន់យើង(តែមួយគត់)។

94. ដូច្នេះ ជនណាដែលសាងទង្វើកុសល ហើយរូបគេជាអ្នកដែលមានជំនឿទៀតនោះ គឺគេមិនបដិសេធ(បំបាត់)នូវការខំប្រឹងប្រែងរបស់គេឡើយ។ ហើយពិតប្រាកដណាស់ យើងគឺជាអ្នកកត់ត្រាសម្រាប់រូបគេ។

95. វាមិនអាចទៅរួចឡើយចំពោះស្រុកភូមិដែលយើងបានបំផ្លាញអាចវិលត្រឡប់(ទៅកាន់លោកិយវិញម្ដងទៀត)នោះ។

96. រហូតដល់ពេលដែលគេបើក(រនាំងរបស់)យ៉ាក់ជូច និងម៉ាក់ជូច។ ហើយពួកវានឹងចេញមកយ៉ាងលឿនពីតាមតំបន់ខ្ពស់ៗទាំងឡាយ។

97. ហើយការសន្យាយ៉ាងពិតប្រាកដ(ថ្ងៃបរលោក)បានខិតជិតមកដល់។ ពេលនោះ ពួកគ្មានជំនឿបានបើកភ្នែកធំៗ(ដោយពួកគេនិយាយថា៖)វិនាសអន្តរាយហើយពួកយើង! ពិតប្រាកដណាស់ ពួកយើងធ្លាប់ស្ថិតក្នុងភាពព្រងើយកន្តើយចំពោះថ្ងៃនេះ។ ផ្ទុយទៅវិញ ពួកយើងធ្លាប់ជាពួកដែលបំពាន។

98. ពិតប្រាកដណាស់ ពួកអ្នក(ពួកគ្មានជំនឿ)និងអ្វីដែលពួកអ្នកគោរពសក្ការៈផ្សេងពីអល់ឡោះ គឺជាអុសសម្រាប់ដុតបញ្ឆេះនរកជើហាន់ណាំដែលពួកអ្នកនឹងចូលទៅក្នុងវា(ជាអមតៈ)។

99. ប្រសិនបើព្រះទាំងនេះ គឺជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដមែននោះ ច្បាស់ជាពួកវានឹងមិនចូលនរក(ជាមួយពួកគេឡើយ)។ ហើយពួកគេទាំងអស់ គឺស្ថិតនៅទីនោះជាអមតៈ។

100. នៅក្នុងឋាននរកនោះ ពួកគេស្រែកថ្ងូរយ៉ាងខ្លាំង។ ហើយនៅក្នុងឋាននរកនោះ ពួកគេមិនឮអ្វីឡើយ។

101. ជាការពិតណាស់ បណ្ដាអ្នកដែលគេបានកំណត់អំពីយើងនូវកិច្ចសំណាងល្អសម្រាប់ពួកគេនោះ ពួកគេគឺជាអ្នកដែលត្រូវបានគេបញ្ឆៀសឱ្យឆ្ងាយ(ពីភ្លើងនរក)។

102. ពួកគេមិនឮសំឡេងអណ្ដាតភ្លើងនៃនរកឡើយ។ ហើយពួកគេនៅសោយសុខជាអមត:តាមអ្វីដែលពួកគេប្រាថ្នា។

103. ភាពរន្ធត់យ៉ាងក្រៃលែង(នាថ្ងៃបរលោក)មិនបានធ្វើឲ្យពួកគេភ័យខ្លាចនោះឡើយ។ ហើយម៉ាឡាអ៊ីកាត់បានទទួលរាក់ទាក់ចំពោះពួកគេ(ដោយពោលថា៖) នេះគឺជាថ្ងៃរបស់ពួកអ្នកដែលពួកអ្នកធ្លាប់ត្រូវបានគេសន្យា(នៅក្នុងលោកិយ)។

104. នៅថ្ងៃដែលយើងនឹងមូរមេឃដូចជាការមូរក្រដាសដែលបានសរសេរ។ ដូចដែលយើងបានផ្តើមបង្កើតពួកគេកាលពីដំបូងនោះដែរ យើងនឹងបង្កើតពួកគេម្តងទៀត។ ជាការសន្យារបស់យើងដ៏ពិតប្រាកដ។ ជាការពិតណាស់ យើងគឺជាអ្នកដែលធ្វើ(តាមការសន្យា)។

105. ហើយជាការពិតណាស់ យើងបានចារនៅក្នុងបណ្ដាគម្ពីរទាំងឡាយក្រោយពីយើងបានចារនៅក្នុងគម្ពីរកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)រួចថា៖ ពិតប្រាកដណាស់ផែនដី គឺខ្ញុំបម្រើរបស់យើងដែលសាងទង្វើកុសលជាអ្នកដែលទទួលមរតករបស់វា។

106. ជាការពិតណាស់នៅក្នុង(ការទូន្មាន)នេះ គឺជាមេរៀនដែលគ្រប់គ្រាន់ហើយសម្រាប់ក្រុមដែលគោរពសក្ការៈ(ចំពោះអល់ឡោះតែមួយ)។

107. ហើយយើងមិនបានបញ្ជូនអ្នក(ព្យាការីមូហាំម៉ាត់)មកនោះឡើយ លើកលែងតែដើម្បីជាក្តីមេត្តាករុណាចំពោះពិភពលោកប៉ុណ្ណោះ។

108. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តាមពិត គេគ្រាន់តែផ្តល់វាហ៊ីមកកាន់ខ្ញុំថា៖ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នកដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដនោះ គឺជាព្រះជាម្ចាស់តែមួយគត់។ ដូច្នេះ ចូរពួកអ្នកប្រគល់ខ្លួនចំពោះទ្រង់(ក្លាយជាជនមូស្លីម)។

109. តែប្រសិនបើពួកគេងាកចេញវិញ ដូច្នេះចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំបានប្រកាសប្រាប់ពួកអ្នកឲ្យបានដឹងដូចគ្នាហើយ។ ហើយខ្ញុំមិនដឹងទេថា អ្វី(ទណ្ឌកម្ម)ដែលគេសន្យាចំពោះពួកអ្នកនោះ តើវានៅជិតឬនៅឆ្ងាយនោះឡើយ។

110. ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតនូវពាក្យសម្តីដែល(ពួកអ្នក)លាតត្រដាង និងដឹងបំផុតនូវអ្វីដែលពួកអ្នកលាក់បាំង។

111. ហើយខ្ញុំក៏មិនដឹងដែរ ប្រហែលវាជាការសាកល្បងមួយសម្រាប់ពួកអ្នក និងជាការសប្បាយរីករាយមួយ(សម្រាប់ពួកអ្នក)រហូតដល់ពេលកំណត់។

112. គាត់(ព្យាការីមូហាំម៉ាត់)បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាវិនិច្ឆ័យដោយសច្ចធម៌ផងចុះ។ ហើយចំពោះព្រះជាម្ចាស់របស់យើងដ៏មហាសប្បុរស(តែមួយគត់)ដែលពួកយើងសុំឱ្យជួយប្រឆាំងនឹងអ្វីដែលពួកអ្នកបាននិយាយចោទប្រកាន់។

ជំពូក អាល់ហាដ្ទ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកកោតខ្លាចព្រះជាម្ចាស់របស់ពួកអ្នក។ ជាការពិតណាស់ ការញ័ររញ្ជួយដីនាថ្ងៃបរលោក គឺជារឿងមួយដ៏ធំធេងបំផុត។

2. នាថ្ងៃដែលពួកអ្នកនឹងឃើញថា រាល់ស្ត្រីដែលបំបៅកូនទាំងអស់ នឹងភ្លេចភ្លាំងស្មារតីពីកូនដែលខ្លួនបំបៅ។ ហើយរាល់ស្ត្រីដែលមានផ្ទៃពោះ នឹងត្រូវរលូតកូនក្នុងផ្ទៃ។ ហើយអ្នកនឹងឃើញមនុស្សលោកស្រវឹង (បាត់បង់ស្មារតី) តែពួកគេមិនមែនស្រវឹងនោះឡើយ។ ក៏ប៉ុន្តែ (ដោយសារតែ) ទណ្ឌកម្មរបស់អល់ឡោះ គឺធ្ងន់ធ្ងរបំផុត។

3. ហើយក្នុងចំណោមមនុស្សលោក មានអ្នកខ្លះដែលជជែកដេញដោលពី (សមត្ថភាព) អល់ឡោះដោយគ្មានចំណេះដឹង ហើយគេដើរតាមរាល់ស្មៃតនដែលរឹងរូស។

4. គេបានចារទៅលើវា (ស្មៃតន) ថា៖ ជនណាហើយដែលយកវាធ្វើជាអ្នកគាំពារ ពិតប្រាកដណាស់ វានឹងធ្វើឱ្យរូបគេវង្វេង ហើយនាំរូបគេទៅរកទណ្ឌកម្មនៃភ្លើងនរកជាមិនខាន។

5. ឱមនុស្សលោកទាំងឡាយ! ប្រសិនបើពួកអ្នកមានការមន្ទិលសង្ស័យចំពោះការបង្កើតឱ្យរស់ឡើងវិញ (បន្ទាប់ពីស្លាប់) នោះពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកអំពីដី។ ក្រោយមក គឺអំពីទឹកកាម។ ក្រោយមកទៀត វាក៏ក្លាយទៅជាដុំឈាម។ បន្ទាប់មក វាក៏ក្លាយទៅជាដុំសាច់ដែលមានលក្ខណៈពេញលេញ ឬមិនមានលក្ខណៈពេញលេញ (ដោយត្រូវរលូត) ដើម្បីយើងបញ្ជាក់ដល់ពួកអ្នក (ពីសមត្ថភាពរបស់យើង)។ ហើយយើងឱ្យគភ៌នោះស្ថិតនៅក្នុងស្បូនតាមអ្វីដែលយើងមានចេតនារហូតដល់ពេលដែលពេលកំណត់។ បន្ទាប់មកទៀត យើងបានបញ្ចេញពួកអ្នក (ពីផ្ទៃម្តាយ) ជាទារក។ ក្រោយមក ពួកអ្នកក៏បានធំពេញវ័យ។ ហើយក្នុងចំណោមពួកអ្នក មានអ្នកខ្លះបានស្លាប់ទៅវិញ (មុនពេលពេញវ័យ) ហើយមានអ្នកខ្លះទៀតអាចរស់នៅរហូតដល់វ័យចាស់ជរា ដើម្បីឱ្យរូបគេលែងដឹងនូវអ្វីដែលគេធ្លាប់បានដឹង (រវាំងងវាំងន់)។ ហើយអ្នកនឹងឃើញដីដែលស្ងួតហួតហែង (គ្មានរុក្ខជាតិសោះ) តែនៅពេលដែលយើងបញ្ចុះទឹកភ្លៀងទៅលើវារួចមក វាក៏កម្រើក និងរីកឡើងវិញ ហើយក៏បានដុះចេញនូវរាល់រុក្ខជាតិគ្រប់បែបយ៉ាងដ៏ស្រស់បំព្រង។

6. នោះគឺដោយសារតែអល់ឡោះ គឺជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ហើយទ្រង់ជាអ្នកធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញ។ ហើយពិតប្រាកដណាស់ ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

7. ហើយពិតប្រាកដណាស់ ថ្ងៃបរលោកនឹងមកដល់ដោយគ្មានការមន្ទិលសង្ស័យចំពោះវាឡើយ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងធ្វើឱ្យអ្នកដែលនៅក្នុងផ្នូររស់ឡើងវិញ។

8. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលជជែកដេញដោល (ពីភាពជាម្ចាស់តែមួយគត់របស់) អល់ឡោះដោយគ្មានចំណេះដឹង គ្មានការចង្អុលបង្ហាញ ហើយក៏គ្មានគម្ពីរណាមួយបញ្ជាក់នោះឡើយ។

9. គេបង្វិលករបស់ខ្លួន (ចេញពីការពិតដោយភាពក្រអឺតក្រទម) ដើម្បីធ្វើឱ្យអ្នកដទៃវង្វេងពីមាគ៌ារបស់អល់ឡោះ។ សម្រាប់រូបគេនឹងទទួលនូវភាពអាម៉ាស់នៅក្នុងលោកិយនេះ ហើយយើងនឹងឱ្យគេភ្លក់ទណ្ឌកម្មនៃភ្លើងនរកដែលឆាបឆេះនៅថ្ងៃបរលោក។

10. (មានគេនិយាយទៅកាន់ជននោះថា៖) នោះគឺដោយសារតែអ្វីដែលអ្នកបានប្រព្រឹត្តកាលពីមុន(ក្នុងលោកិយ)។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់មិនបំពានលើខ្ញុំបម្រើ(របស់ទ្រង់)ឡើយ។

11. ហើយក្នុងចំណោមមនុស្សលោក មានអ្នកដែលគោរពសក្ការៈចំពោះអល់ឡោះដោយភាពមន្ទិលសង្ស័យ។ ប្រសិនបើគេទទួលបានប្រការល្អ គេមានភាពនឹងនរចំពោះវា។ តែប្រសិនបើគេជួបប្រទះការសាកល្បង គេនឹងត្រឡប់ទៅដូចដើមវិញ ដោយរូបគេបានខាតបង់ទាំងលោកិយ និងបរលោក។ នោះគឺជាការខាតបង់យ៉ាងច្បាស់លាស់។

12. គេគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះដែលវាមិនអាចបង្កគ្រោះថ្នាក់ ហើយក៏មិនអាចផ្តល់ជាប្រយោជន៍អ្វីដល់គេសោះ។ នោះហើយជាការវង្វេងដ៏សែនឆ្ងាយបំផុត។

13. គេបួងសួងសុំពីអ្នកដែលផ្តល់គ្រោះថ្នាក់ដល់គេជាងផ្តល់ផលប្រយោជន៍។ ជាអ្នកជួយដែលអាក្រក់បំផុត និងជាគូកនដែលអាក្រក់បំផុត។

14. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងបញ្ចូលបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ធ្វើនូវអ្វីដែលទ្រង់មានបំណង។

15. ជនណាហើយដែលគិតថា ពិតប្រាកដណាស់ អល់ឡោះទ្រង់នឹងមិនជួយដល់គាត់(ព្យាការីមូហាំម៉ាត់)ទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោកទេនោះ ចូរឱ្យគេចងខ្សែទៅនឹងដំបូលផ្ទះរបស់ខ្លួន(ដើម្បីព្យួរកខ្លួនឯង) រួចចូរឲ្យគេកាត់ខ្សែនោះ។ បន្ទាប់មក ចូរឱ្យគេមើលចុះ ថាតើការធ្វើដូចនោះធ្វើឱ្យកំហឹងដែលមាននៅក្នុងខ្លួនរបស់គេបាត់បង់ដែរឬទេ?

16. ហើយក៏ដូច្នោះដែរ យើងបានបញ្ចុះវា(គម្ពីរគួរអាន)ដែលមានវាក្យខណ្ឌជាច្រើនដ៏ច្បាស់លាស់។ ហើយពិតប្រាកដណាស់ អល់ឡោះទ្រង់ចង្អុលបង្ហាញជនណាដែលទ្រង់មានបំណង។

17. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ ពួកយូដា ពួកសពីអ៊ីន(ក្រុមមួយនៃអ្នកដែលដើរតាមបណ្តាព្យាការីមួយចំនួន) ពួកគ្រីស្ទាន ពួកដែលគោរពភ្លើង និងពួកដែលធ្វើស៊ីរិក ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងកាត់សេចក្តីរវាងពួកគេនៅថ្ងៃបរលោក។ ជាការពិតណាស់ អល់ឡោះទ្រង់ជាសាក្សីលើរាល់អ្វីៗទាំងអស់។

18. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ត្រូវបានអ្នកដែលនៅលើមេឃជាច្រើនជាន់ និងអ្នកដែលនៅលើផែនដី ព្រះអាទិត្យ ព្រះចន្ទ ហ្វូងតារា ភ្នំទាំងឡាយ ដើមឈើនានា សត្វរួមទាំងមនុស្សលោកជាច្រើនបានក្រាបស៊ូជោតចំពោះទ្រង់។ ហើយក៏មានមនុស្សលោកជាច្រើនផងដែរដែលទណ្ឌកម្មនឹងធ្លាក់លើពួកគេ។ ហើយជនណាដែលអល់ឡោះទ្រង់ធ្វើឱ្យរូបគេអាប់ឱននោះ ជាការពិតណាស់ គឺគ្មាននរណាម្នាក់លើកតម្កើងរូបគេនោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។

19. ក្រុមទាំងពីរនេះ(ក្រុមអ្នកដែលមានជំនឿ និងក្រុមដែលគ្មានជំនឿ)បានឈ្លោះប្រកែកគ្នាពីរឿងព្រះជាម្ចាស់របស់ពួកគេ។ ជាការពិតណាស់ ពួកដែលគ្មានជំនឿនោះ គេនឹងកាត់សម្លៀកបំពាក់ពីភ្លើងនរកឲ្យពួកគេ ហើយគេនឹងចាក់ទឹកពុះដែលក្តៅបំផុតពីលើក្បាលពួកគេ។

20. អ្វីដែលនៅក្នុងពោះរបស់ពួកគេនោះ និងស្បែក(របស់ពួកគេ)នឹងត្រូវរលេះរលួយដោយសារតែទឹកនោះ។

21. ហើយសម្រាប់ពួកគេ គឺមានញញួរដែក(សម្រាប់វាយក្បាលពួកគេ)។

22. រាល់ពេលដែលពួកគេចង់ចេញពីឋាននរកដោយសារតែទុក្ខលំបាក(ដែលពួកគេទទួលរង)ពួកគេនឹងត្រូវបានគេ(ម៉ាឡាអ៊ីកាត់)រុញត្រឡប់ទៅក្នុងនរកវិញ។ ហើយ(មានគេនិយាយថា៖)ចូរពួកអ្នកភ្លក់នូវទណ្ឌកម្មដែលឆាបឆេះនេះចុះ។

23. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងបញ្ចូលបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ នៅក្នុងឋានសួគ៌នោះ ពួកគេត្រូវបានគេតុបតែងដោយកងដៃធ្វើអំពីមាស និងគុជខ្យង។ ហើយសម្លៀកបំពាក់របស់ពួកគេនៅក្នុងឋានសួគ៌នោះ គឺក្រណាត់សូត្រ។

24. ហើយពួកគេត្រូវបានគេចង្អុលបង្ហាញទៅរកពាក្យសម្តីដែលល្អ(កាលីម៉ះតាវហៅទ ការកោតសរសើរអល់ឡោះ...)ហើយពួកគេត្រូវបានគេចង្អុលបង្ហាញទៅរកមាគ៌ាដែលត្រូវបានគេកោតសរសើរ(សាសនាអ៊ីស្លាម)។

25. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ហើយបានរារាំងអ្នកដទៃពីមាគ៌ាអល់ឡោះ និងពីម៉ាស្ជិតអាល់ហារ៉ែមដែលយើងចាត់ទុកវាជាកន្លែងដែលមានភាពស្មើគ្នាទាំងអ្នកដែលរស់នៅទីនោះ(ក្រុងម៉ាក្កះ) និងអ្នកដែលមកពីខាងក្រៅ (ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ)។ ហើយជនណាដែលមានបំណងងាករេ(ចេញពីសេចក្តីពិត)ដោយបំពាននៅទីនោះ យើងនឹងឲ្យរូបគេភ្លក្សនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

26. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលយើងបានបញ្ជាក់ដល់ព្យាការីអ៊ីព្រហ៊ីមនូវទីតាំងកាក់ហ្គ្អះ។ (ហើយយើងបានបញ្ជាថា៖) ចូរអ្នកកុំធ្វើស្តីរិកមកចំពោះយើងនូវអ្វីមួយឱ្យសោះ។ ហើយចូរអ្នកសម្អាតគេហដ្ឋានរបស់យើង(កាក់ហ្គ្អះ)សម្រាប់អ្នកដែលតវ៉ាហ្វ និងអ្នកដែលបញ្ឈរសឡាតទាំងឡាយ។

27. ហើយចូរអ្នកប្រកាសហៅមនុស្សលោកឱ្យពួកគេមកធ្វើធម្មយាត្រាហាជ្ជ៏ នោះពួកគេនឹងមកកាន់អ្នក(តាមការអំពាវនាវ)ដោយដើរថ្មើរជើង ឬដោយជិះសត្វអូដ្ឋដែលមកពីគ្រប់ច្រកល្ហកដ៏សែនឆ្ងាយ។

28. ដើម្បីឲ្យពួកគេចូលរួមទទួលនូវផលប្រយោជន៍សម្រាប់ពួកគេ និងដើម្បីឲ្យពួកគេរំឭកព្រះនាមរបស់អល់ឡោះជាម្ចាស់(ទៅលើសត្វជំនួនដែលពួកគេសំឡេះ)នៅក្នុងបណ្តាថ្ងៃដែលត្រូវបានគេកំណត់ចំពោះអ្វីដែលទ្រង់ប្រទានជាលាភសក្ការៈដល់ពួកគេនៃសត្វពាហនៈ។ ដូច្នេះ ចូរពួកអ្នកបរិភោគអំពីវា(សត្វដែលបានសំឡេះ)ទាំងនេះ ហើយចូរបរិច្ចាគទៅដល់អ្នកដែលក្រលំបាក។

29. បន្ទាប់មក ចូរឲ្យពួកគេបំពេញនូវកិច្ចការហាជ្ជ៏របស់ពួកគេ(ដែលនៅសេសសល់) ហើយចូរឲ្យពួកគេបំពេញនូវពាក្យសច្ចារបស់ខ្លួន និងចូរឲ្យពួកគេតវ៉ាហ្វជុំវិញពៃតុលឡោះ។

30. ទាំងនោះ(គឺជាបទបញ្ជារបស់អល់ឡោះ)។ ហេតុនេះ ជនណាដែលលើកតម្កើងបទបញ្ជារបស់អល់ឡោះ វាគឺជាការប្រសើរសម្រាប់រូបគេនៅឯព្រះជាម្ចាស់របស់គេ។ ហើយគេអនុញ្ញាតឱ្យពួកអ្នកនូវសត្វពាហនៈទាំងឡាយ លើកលែងតែអ្វីដែលគេបានសូត្រប្រាប់ពួកគេ។ ហេតុនេះ ចូរពួកអ្នកចៀសវាងពីប្រការកខ្វក់នៃ(ការគោរព)រូបបដិមានានា និងចូរពួកអ្នកចៀសវាងពីពាក្យសម្តីដែលមិនត្រឹមត្រូវ។

31. (ចូរអ្នកចៀសវាងពីប្រការទាំងនោះ)ដោយចិត្តស្មោះសចំពោះអល់ឡោះ(តែមួយគត់)ដោយមិនធ្វើស្តីរិកនឹងទ្រង់ឡើយ។ ហើយជនណាដែលធ្វើស្តីរិកនឹងអល់ឡោះជាម្ចាស់នោះ ហាក់បីដូចជារូបគេធ្លាក់ពីលើមេឃ ដោយអាចត្រូវសត្វស្លាបចឹកស៊ី ឬក៏អាចត្រូវខ្យល់បក់ក្លួចយកគេទៅកាន់កន្លែងមួយដ៏ឆ្ងាយ។

32. ទាំងនោះ(ជាបទបញ្ជារបស់អល់ឡោះ)។ ហើយជនណាដែលលើកតម្កើងអត្តសញ្ញាណរបស់អល់ឡោះនោះ ជាការពិតណាស់ វាគឺបញ្ជាក់ពីចិត្តដែលកោតខ្លាច(ចំពោះអល់ឡោះ)។

33. សម្រាប់ពួកអ្នក ចំពោះសត្វជំនួនដែលពួកអ្នកសំឡេះ គឺផ្តល់ផលប្រយោជន៍ជាច្រើនរហូតពេលកំណត់(ដែលត្រូវសំឡេះ)។ បន្ទាប់មក កន្លែងដែលត្រូវសំឡេះវា គឺនៅពៃតុលឡោះ(ក្នុងទឹកដីហារ៉ម)។

34. ហើយរាល់ប្រជាជាតិនីមួយៗ យើងបានកំណត់ឱ្យមានពិធីសំឡេះសត្វដើម្បីឲ្យពួកគេរំឭកព្រះនាមរបស់អល់ឡោះ(ទៅលើសត្វសំឡេះនោះ)ចំពោះអ្វីដែលទ្រង់បានប្រទានជាលាភសក្ការៈដល់ពួកគេនៃសត្វពាហនៈ។ ជាការពិតណាស់ ព្រះជាម្ចាស់របស់ពួកអ្នកដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដនោះ គឺព្រះជាម្ចាស់តែមួយគត់។ ហេតុនេះ ចូរពួកអ្នកប្រគល់ខ្លួនចំពោះទ្រង់។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលបន្ទាបខ្លួន(ចំពោះអល់ឡោះ)ចុះ។

35. គឺបណ្តាអ្នកដែលនៅពេលណាដែលមានគេរំឭកពីអល់ឡោះ ដួងចិត្តរបស់ពួកគេមានការភ័យខ្លាច(ពីទណ្ឌកម្មរបស់ទ្រង់) ហើយពួកគេអត់ធ្មត់ចំពោះអ្វីដែលពួកគេជួបប្រទះ។ ពួកគេប្រតិបត្តិសឡាតយ៉ាងពេញលេញ និងបរិច្ចាគ(ទ្រព្យសម្បត្តិ)មួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេ។

36. ហើយចំពោះសត្វអូដ្ឋនិងសត្វគោ យើងបានបង្កើតវាសម្រាប់ពួកអ្នកជានិមិត្តសញ្ញាមួយក្នុងចំណោមនិមិត្តសញ្ញាជាច្រើនរបស់អល់ឡោះ។ ចំពោះវាគឺមានផលប្រយោជន៍យ៉ាងច្រើនសម្រាប់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នករំឭកព្រះនាមអល់ឡោះ(សូត្រ)ទៅលើសត្វអូដ្ឋដែលសំឡេះក្នុងពេលដែលវានៅឈរ។ ហើយនៅពេលដែលវាបានដួលទៅលើដីហើយនោះ ចូរពួកអ្នកទទួលទានអំពីវា ហើយផ្តល់វាឱ្យទៅអ្នកក្រដែលមិនហ៊ានសុំ និងអ្នកក្រដែលដាច់ចិត្តសុំ។ ដូច្នោះដែរ យើងបានបង្កើតវាសម្រាប់ពួកអ្នក សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

37. សាច់ និងឈាមរបស់វា(សត្វដែលសំឡេះ)មិនបានទៅដល់អល់ឡោះនោះឡើយ ក៏ប៉ុន្តែការគោរពកោតខ្លាចរបស់ពួកអ្នកទៅវិញទេដែលទៅដល់ទ្រង់នោះ។ ក៏ដូច្នោះដែរ ទ្រង់បានបង្កើតវា(ជាប្រយោជន៍)សម្រាប់ពួកអ្នកដើម្បីឱ្យពួកអ្នកលើកតម្កើងអល់ឡោះទៅលើអ្វីដែលទ្រង់បានចង្អុលបង្ហាញពួកអ្នក។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលសាងអំពើល្អ។

38. ពិតប្រាកដណាស់ អល់ឡោះការពារបណ្តាអ្នកដែលមានជំនឿ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនស្រលាញ់រាល់អ្នកដែលក្បត់ និងរមិលគុណឡើយ។

39. គេ(អល់ឡោះ)បានអនុញ្ញាតឲ្យបណ្តាអ្នក(មានជំនឿ)ដែលត្រូវបានគេប្រយុទ្ធប្រឆាំងនោះ(ធ្វើការប្រយុទ្ធតបវិញ)ដោយសារតែពួកគេត្រូវបានគេបំពាន។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពបំផុតក្នុងការជួយដល់ពួកគេ។

40. គឺបណ្តាអ្នកដែលត្រូវបានគេបណ្តេញចេញពីលំនៅឋានរបស់ខ្លួនដោយបំពាន(ដោយពួកគេមិនបានប្រព្រឹត្តបទល្មើសណាមួយ)ក្រៅតែពីពួកគេពោលថា៖ "អល់ឡោះគឺជាព្រះជាម្ចាស់របស់ពួកយើង" នោះឡើយ។ ហើយប្រសិនបើអល់ឡោះមិនទប់ស្កាត់មនុស្សលោក(មិនឲ្យបំពានគ្នា)ទៅវិញទៅមកទេនោះ ច្បាស់ជាពួកគេនឹងបំផ្លិចបំផ្លាញអាស្រមរបស់ពួកឥសី វិហាររបស់ពួកគ្រឹស្ទាន ទីគោរពបូជារបស់ពួកយូដា ហើយនិងបណ្តាម៉ាស្ជិត(របស់អ្នកអ៊ីស្លាម)ដែលគេរំឭកព្រះនាមអល់ឡោះយ៉ាងច្រើននៅក្នុងវាជាមិនខាន។ ហើយអល់ឡោះទ្រង់ពិតជានឹងជួយដល់បណ្តាអ្នកដែលជួយ(សាសនារបស់)ទ្រង់។ ពិតប្រាកដណាស់ អល់ឡោះពិតជាមហាខ្លាំងក្លា មហាខ្លាំងពូកែបំផុត។

41. គឺបណ្តាអ្នកទាំងឡាយណាដែលប្រសិនបើយើងផ្តល់អំណាចគ្រប់គ្រងឱ្យពួកគេនៅលើផែនដីនោះ ពួកគេនឹងប្រតិបត្តិសឡាត ហើយបរិច្ចាគហ្សាកាត់ ព្រមទាំងប្រើគ្នាឱ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់។ ហើយលទ្ធផលចុងក្រោយនៃកិច្ចការទាំងឡាយ គឺត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់)។

42. តែប្រសិនបើពួកគេបដិសេធនឹងអ្នក(ព្យាការីមូហាំម៉ាត់)វិញ ជាការពិតណាស់ ពួកជំនាន់មុនពួកគេ ក៏ធ្លាប់បានបដិសេធដូចគ្នាដែរ ដូចជាក្រុមរបស់ព្យាការីនួហ ក្រុមអាទ ក្រុមសាមូទ

43. ក្រុមរបស់ព្យាការីអ៊ីព្រហ៊ីម និងក្រុមរបស់ព្យាការីលូត

44. ហើយនិងក្រុមម៉ាទយ៉ាន់។ ហើយព្យាការីមូសាក៏ត្រូវបានគេបដិសេធផងដែរ។ ពេលនោះ យើងបានពន្យារពេលដល់ពួកដែលគ្មានជំនឿ។ ក្រោយមក យើងក៏បានដាក់ទណ្ឌកម្មពួកគេ។ ដូច្នេះ តើការបំផ្លាញរបស់យើងចំពោះពួកគេយ៉ាងដូចម្តេចដែរ?

45. ហើយមានភូមិស្រុកជាច្រើនមកហើយដែលយើងបានបំផ្លាញវា ខណៈដែលអ្នកស្រុកភូមិនោះជាពួកដែលបំពាន។ ពេលនោះ ផ្ទះរបស់ពួកគេក៏ត្រូវបានបំផ្លាញខ្ទេចខ្ទីអស់ អណ្តូងទឹកត្រូវបានខូចខាត ហើយវិមានដ៏ធំស្កឹមស្កៃ(ក៏ត្រូវបានវិនាសផងដែរ)។

46. ដូច្នេះ តើពួកគេ(ពួកដែលបដិសេធ)មិនបានធ្វើដំណើរនៅលើផែនដី(ដើម្បីពិនិត្យមើល)ដោយយកប្រាជ្ញា(របស់ពួកគេ)មកត្រិះរិះពិចារណា ហើយយកត្រចៀក(របស់ពួកគេ)មកស្តាប់(រឿងរ៉ាវទាំងនោះ)ទេឬ? ជាការពិតណាស់ ការពិការភ្នែកនោះ មិនមែនជាការងងឹតភ្នែក(មើលមិនឃើញ)នោះឡើយ។ ផ្ទុយទៅវិញ វាជាការពិការដួងចិត្តដែលនៅក្នុងទ្រូងទៅវិញទេ។

47. ហើយពួកគេនឹងសុំអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ឲ្យដាក់ទណ្ឌកម្មលើពួកគេភ្លាមៗ(ក្នុងលោកិយ)។ ហើយអល់ឡោះទ្រង់មិនធ្វើខុសពីការសន្យារបស់ទ្រង់ឡើយ។ ជាការពិតណាស់ មួយថ្ងៃនៅឯព្រះជាម្ចាស់របស់អ្នក(ថ្ងៃបរលោក)នោះ គឺប្រៀបដូចជាមួយពាន់ឆ្នាំ(តាមពេលវេលា)ដែលពួកអ្នករាប់(ក្នុងលោកិយនេះ)។

48. ហើយមានភូមិស្រុកជាច្រើនដែលយើងបានពន្យារពេល(ដាក់ទណ្ឌកម្ម)ចំពោះវា ខណៈដែលវា(អ្នកភូមិស្រុក)ជាអ្នកដែលបំពាន។ ក្រោយមក យើងក៏បានដាក់ទណ្ឌកម្មចំពោះវា។ ហើយមកកាន់យើង(តែមួយគត់)ដែលជាទីវិលត្រឡប់(របស់ពួកគេ)។

49. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱមនុស្សលោកទាំងឡាយ! តាមពិតសម្រាប់ពួកអ្នក ខ្ញុំគ្រាន់តែជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់ប៉ុណ្ណោះ។

50. ដូច្នេះ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងលាភសក្ការៈដ៏ប្រពៃ(ឋានសួគ៌)។

51. ហើយពួកដែលព្យាយាមប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់យើង ដោយគិតស្មានថា ពួកគេអាចយកឈ្នះបាននោះ ពួកទាំងនោះគឺជាពួកនរកជើហ៊ឹម។

52. ហើយរាល់អ្នកនាំសារ និងព្យាការីមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែលយើងបានបញ្ជូនទៅ នៅពេលណាដែលគេសូត្រ(វាក្យខណ្ឌរបស់អល់ឡោះ) គឺសុទ្ធតែមានស្មៃតនមកឆាឆៅបន្លំនៅក្នុងការសូត្ររបស់គេ។ ពេលនោះ អល់ឡោះជាម្ចាស់បានធ្វើឱ្យអ្វីដែលស្មៃតនបន្លំនោះក្លាយជាអសារបង់។ បន្ទាប់មក ទ្រង់ពង្រឹងនូវវាក្យខណ្ឌរបស់ទ្រង់។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

53. (វាធ្វើដូច្នោះ)ដើម្បីទ្រង់ធ្វើឱ្យអ្វីដែលស្នែតនបន្លំនោះក្លាយជាការសោកល្បួងមួយសម្រាប់ពួកដែលជួងចិត្តរបស់ពួកគេមានជំងឺ) និងពួកដែលមានចិត្តរឹងរូស។ ហើយពិតប្រាកដណាស់ ពួកដែលបំពាន គឺស្ថិតក្នុងភាពជាសត្រូវ និងឃ្លាតឆ្ងាយ(ពីការពិត)។

54. និងដើម្បីឱ្យបណ្តាអ្នកដែលគេបានផ្តល់ចំណេះដឹងឲ្យបានដឹងថា៖ ពិតប្រាកដណាស់ វា(គម្ពីរគួរអាន) គឺជាការពិតមកពីព្រះជាម្ចាស់របស់អ្នក។ ដូច្នេះ ពួកគេកាន់តែមានជំនឿចំពោះវា ហើយជួងចិត្តរបស់ពួកគេក៏ឱនលំទោនចំពោះវា។ ហើយពិតប្រាកដណាស់ អល់ឡោះគឺជាអ្នកចង្អុលបង្ហាញបណ្តាអ្នកដែលមានជំនឿទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

55. ហើយពួកដែលគ្មានជំនឿនៅតែមានការសង្ស័យចំពោះវា(គម្ពីរគួរអាន) រហូតទាល់តែថ្ងៃបរលោកមកដល់ពួកគេភ្លាមៗ ឬ(រហូតដល់)ទណ្ឌកម្មនៅថ្ងៃមួយដែលគ្មានសេចក្តីល្អឡើយ(សម្រាប់ពួកគេ)មកដល់ពួកគេ។

56. សិទ្ធិអំណាចនៅថ្ងៃនោះ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)ដោយទ្រង់នឹងកាត់សេចក្តីរវាងពួកគេ។ ដូចនេះ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល នឹងស្ថិតនៅក្នុងឋានសួគ៌ណាអ៊ីម។

57. រីឯពួកដែលគ្មានជំនឿ និងបានបដិសេធនូវបណ្តាវាក្យខណ្ឌរបស់យើងវិញ ជាការពិតណាស់ ពួកទាំងនោះសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងអាម៉ាស់បំផុត។

58. ហើយបណ្តាអ្នកដែលបានធ្វើចំណាកស្រុកក្នុងមាគ៌ារបស់អល់ឡោះ ក្រោយមក ពួកគេត្រូវបានគេសម្លាប់(ក្នុងសង្គ្រាម)ឬបានស្លាប់(ដោយប្រការណាមួយ)នោះ អល់ឡោះជាម្ចាស់ប្រាកដជានឹងប្រទាននូវលាភសក្ការៈដ៏ល្អប្រពៃ(ឋានសួគ៌)ដល់ពួកគេ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ គឺជាអ្នកដែលប្រទានលាភសក្ការៈដ៏ប្រសើរបំផុត។

59. ទ្រង់ពិតជានឹងបញ្ចូលពួកគេទៅកាន់កន្លែងមួយដែលពួកគេពេញចិត្តនឹងវា។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាខន្តីបំផុត។

60. ដូច្នោះឯង។ ហើយជនណាដែលតបតដូចអ្វីដែលគេបានបំពានមកលើខ្លួន(គឺគ្មានបាបកម្មនោះឡើយ)។ បន្ទាប់មក ប្រសិនបើរូបគេត្រូវបានគេបំពានម្តងទៀត ពិតប្រាកដណាស់ អល់ឡោះទ្រង់ពិតជាជួយដល់រូបគេជាមិនខាន។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអធ្យាស្រ័យ មហាអភ័យទោសបំផុត។

61. នោះគឺដោយសារតែអល់ឡោះជាម្ចាស់ទ្រង់(មានសមត្ថភាព)បញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ និងបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាឃើញបំផុត។

62. នោះក៏ព្រោះតែអល់ឡោះ ទ្រង់គឺជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ហើយអ្វីដែលពួកគេគោរពសក្ការៈក្រៅពីទ្រង់នោះ គឺជាប្រការមិនត្រឹមត្រូវ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្ពង់ខ្ពស់ មហាធំធេង។

63. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃរួចមក ដីក៏បានប្រែក្លាយទៅជាខៀវស្រងាត់(មានរុក្ខជាតិដុះ)នោះ? ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាទន់ភ្លន់មហាដឹងបំផុត។

64. អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់ ជាអ្នកដែលត្រូវបានគេកោតសរសើរបំផុត។

65. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវអ្វីៗដែលមាននៅលើផែនដី ហើយនិងសំពៅដែលធ្វើដំណើរលើផ្ទៃសមុទ្រទៅតាមបទបញ្ជារបស់ទ្រង់ ហើយទ្រង់ទប់មេឃមិនឱ្យធ្លាក់មកលើផែនដី លើកលែងតែដោយការអនុញ្ញាតពីទ្រង់នោះ? ជាការពិតណាស់ អល់ឡោះមហាសប្បុរស មហាអាណិតស្រលាញ់បំផុត។

66. ហើយទ្រង់ជាអ្នកផ្តល់ជីវិតដល់ពួកអ្នក។ ក្រោយមក ទ្រង់បានដកយកជីវិតពីពួកអ្នកវិញ។ ក្រោយមកទៀត ទ្រង់បានធ្វើឱ្យពួកអ្នកមានជីវិតឡើងវិញ(ដើម្បីជំនុំជម្រះ)។ ពិតប្រាកដណាស់ មនុស្សលោកពិតជារមិលគុណបំផុត។

67. រាល់ប្រជាជាតិនីមួយៗ យើងបានបង្កើតនូវច្បាប់បញ្ញត្តិដល់ពួកគេដោយពួកគេត្រូវអនុវត្តន៍តាមច្បាប់បញ្ញត្តិនោះ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំឱ្យពួកគេ(ពួកមុស្លីគីន)ប្រកែកជជែកដេញដោលនៅក្នុងក្បួនច្បាប់សាសនា(របស់អ្នក)ឱ្យសោះ។ ហើយចូរអ្នកអំពាវនាវទៅកាន់ព្រះជាម្ចាស់របស់អ្នក។ ពិតប្រាកដណាស់ អ្នកពិតជាស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ។

68. តែប្រសិនបើពួកគេជជែកដេញដោលជាមួយអ្នក ដូច្នេះ ចូរអ្នកពោលថា៖ អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

69. អល់ឡោះទ្រង់នឹងកាត់សេចក្តីរវាងពួកអ្នកនៅថ្ងៃបរលោកចំពោះអ្វីដែលពួកអ្នកធ្លាប់បានខ្វែងគំនិតគ្នាចំពោះវា។

70. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅលើមេឃ និងផែនដីនោះ? ពិតប្រាកដណាស់ ទាំងអស់នោះ គឺមាននៅក្នុងគម្ពីរកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)។ ពិតប្រាកដណាស់ រឿងទាំងអស់នោះ គឺជារឿងងាយស្រួលបំផុតសម្រាប់អល់ឡោះ។

71. ហើយពួកគេបានគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះដែលទ្រង់មិនបានបញ្ចុះនូវកស្តតាងណាមួយបញ្ជាក់ពីវាឡើយ ហើយពួកគេក៏គ្មានចំណេះដឹង(អំពីរឿងនោះ)ដែរ។ ហើយសម្រាប់ពួកដែលបំពាន គឺគ្មានអ្នកជួយឡើយ។

72. ហើយនៅពេលដែលមានគេសូត្របណ្តាវាក្យខណ្ឌរបស់យើងដ៏ច្បាស់លាស់ឱ្យពួកគេស្តាប់ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អាចដឹងពីការមិនពេញចិត្តនៅលើផ្ទៃមុខរបស់ពួកដែលប្រឆាំង។ ពួកគេស្ទើរតែហក់ទៅវាយអ្នកដែលសូត្រវាក្យខណ្ឌរបស់យើងឱ្យពួកគេស្តាប់នោះទៅហើយ។ ចូរអ្នកពោលចុះថា៖ តើចង់ឱ្យខ្ញុំប្រាប់ពួកអ្នកពីអ្វីដែលអាក្រក់ជាងនេះទៅទៀតឬទេ? នោះគឺភ្លើងនរកដែលអល់ឡោះទ្រង់បានសន្យាចំពោះពួកដែលប្រឆាំង ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

73. ឱមនុស្សលោកទាំងឡាយ! គេបានលើកជាឧទាហរណ៍មួយ(សម្រាប់ពួកអ្នក)។ ហេតុនេះ ចូរពួកអ្នកត្រងត្រាប់ស្តាប់។ ជាការពិតណាស់ ពួកដែលពួកអ្នកកំពុងតែគោរពសក្ការៈផ្សេងពីអល់ឡោះនោះ ពួកវាមិនអាចបង្កើតសូម្បីតែសត្វរុយមួយក្បាលនោះឡើយ បើទោះបីជាពួកវារួមគ្នាដើម្បីបង្កើតវាក៏ដោយ។ ហើយប្រសិនបើសត្វរុយយកអ្វីមួយ(អំពីសំណែនដែលគេសែន)ក៏ពួកវាមិនអាចដេញវាចេញបាននោះដែរ។ ទាំងអ្នកដែលបួងសួងសុំ និងអ្នកដែលត្រូវគេបួងសួងសុំ(រូបបដិមា)គឺទន់ខ្សោយដូចគ្នា។

74. ពួកគេមិនបានលើកតម្កើងអល់ឡោះជាម្ចាស់ឱ្យសក្តិសមនឹងឋានៈរបស់ទ្រង់នោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងក្លា មហាខ្លាំងពូកែបំផុត។

75. អល់ឡោះទ្រង់បានជ្រើសរើសមួយចំនួនពីម៉ាឡាអ៊ីកាត់ និងមួយចំនួនពីមនុស្សលោកឱ្យធ្វើជាអ្នកនាំសារ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាឃើញបំផុត។

76. ទ្រង់ដឹងបំផុតនូវអ្វីដែលនៅពីមុខពួកគេ (មុនពេលទ្រង់បង្កើតពួកគេ) និងអ្វីដែលនៅពីក្រោយពួកគេ (បន្ទាប់ពីពួកគេស្លាប់)។ ហើយកិច្ចការទាំងអស់នឹងត្រូវគេនាំត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់ (តែមួយគត់)។

77. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកឱនរូកុ និងក្រាបស៊ូជូត ហើយនិងគោរពសក្ការៈចំពោះព្រះជាម្ចាស់របស់ពួកអ្នក ព្រមទាំងសាងអំពើល្អ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

78. ហើយចូរពួកអ្នកតស៊ូប្រយុទ្ធក្នុងនាមអល់ឡោះនូវការតស៊ូមួយដ៏ពិតប្រាកដ។ ទ្រង់បានជ្រើសរើសពួកអ្នក ហើយទ្រង់មិនបានធ្វើឲ្យមានការលំបាកលើពួកអ្នកនៅក្នុងសាសនា (របស់ពួកអ្នក) នោះឡើយ គឺសាសនាឪពុករបស់ពួកអ្នក ព្យាការីអ៊ីព្រហ៊ីម។ ទ្រង់បានដាក់ឈ្មោះឱ្យពួកអ្នក ថាជាជនមូស្លីមតាំងពីមុន (ក្នុងបណ្តាគម្ពីរមុនៗ) និងនៅក្នុង (គម្ពីរគួរអាន) នេះ ដើម្បីឱ្យអ្នកនាំសារ (មូហាំម៉ាត់) ធ្វើជាសាក្សីទៅលើពួកអ្នក និងដើម្បីឱ្យពួកអ្នកធ្វើជាសាក្សីទៅលើមនុស្សលោក (ប្រជាជាតិជំនាន់មុនៗ) ផងដែរ។ ហេតុនេះ ចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ព្រមទាំងប្រកាន់ខ្ជាប់នឹងអល់ឡោះជាម្ចាស់ ព្រោះទ្រង់ធ្វើជាអ្នកគាំពាររបស់ពួកអ្នក។ ទ្រង់ជាអ្នកគាំពារ និងជាអ្នកជួយដ៏ល្អប្រសើរបំផុត។

ជំពូក អាល់មុមីនូន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពិតប្រាកដណាស់ បណ្តាអ្នកមានជំនឿពិតជាទទួលបានជោគជ័យ។
2. គឺបណ្តាអ្នកដែលមានភាពស្មើងស្មាធក្នុងការសឡាតរបស់ខ្លួន។
3. និងបណ្តាអ្នកដែលងាកចេញ(បោះបង់ចោល)ពីប្រការដែលឥតប្រយោជន៍ទាំងឡាយ។
4. និងបណ្តាអ្នកដែលបរិច្ចាគហ្សាកាត់។
5. និងបណ្តាអ្នកដែលថែរក្សាប្រដាប់កេទរបស់ខ្លួន
6. លើកលែងតែចំពោះភរិយារបស់ពួកគេ ឬស្ត្រីបម្រើដាច់ថ្លៃដែលនៅក្រោមការគ្រប់គ្រងរបស់ពួកគេប៉ុណ្ណោះ។ ជាការពិតណាស់ ពួកគេមិនត្រូវបានគេស្តីបន្ទោសឡើយ។
7. តែជនណាដែលស្វែងរកការត្រេកត្រអាលក្រៅពីនោះ ពិតប្រាកដណាស់ ពួកទាំងនោះ ពួកគេគឺជាពួកដែលបំពាន។
8. និងបណ្តាអ្នកដែលថែរក្សាទំនុកចិត្ត និងបំពេញតាមការសន្យារបស់ខ្លួន។
9. និងបណ្តាអ្នកដែលថែរក្សាលើការប្រតិបត្តិសឡាតរបស់ខ្លួន។
10. អ្នកទាំងនោះហើយ ពួកគេគឺជាអ្នកដែលត្រូវទទួលមរតក
11. ដែលពួកគេនឹងត្រូវទទួលមរតកឋានសួគ៌ហ្វៀរទ័ស(ជាឋានសួគ៌ដែលមានលំដាប់ខ្ពស់ជាងគេបំផុត)ដោយពួកគេស្ថិតនៅទីនោះជាអមតៈ។
12. ហើយជាការពិតណាស់ យើងបានបង្កើតមនុស្សលោក(ព្យាការីអាហ្សាំ)ពីដីឥដ្ឋ។
13. ក្រោយមក យើងបានបង្កើតគេអំពីទឹកកាមដោយស្ថិតនៅក្នុងស្បូនស្ត្រី(រហូតដល់ពេលប្រសូត)។

14. ក្រោយមក យើងបានធ្វើឲ្យទឹកកាមនោះក្លាយទៅជាដុំឈាម។ ក្រោយមកទៀត យើងបានធ្វើឱ្យដុំឈាមនោះក្លាយទៅជាដុំសាច់។ បន្ទាប់មក យើងបានធ្វើឲ្យដុំសាច់នោះឱ្យមានជាឆ្អឹង រួចយើងបានគ្របដណ្ដប់ឆ្អឹងនោះដោយសាច់។ បន្ទាប់មកទៀត យើងក៏បានបង្កើតវាទៅជារូបរាងមួយផ្សេងទៀត(ដោយការផ្លុំបញ្ចូលព្រលឹងទៅក្នុងវា)។ ហើយអល់ឡោះមហាឧត្តុង្គឧត្តមដែលជាអ្នកបង្កើតដ៏ប្រសើរបំផុត។

15. ក្រោយមក បន្ទាប់ពីនោះ ពួកអ្នកពិតជានឹងត្រូវស្លាប់ទៅវិញ។

16. បន្ទាប់មកទៀត នៅថ្ងៃបរលោក ពួកអ្នកពិតជានឹងត្រូវគេបង្កើតឲ្យរស់ឡើងវិញ។

17. ហើយជាការពិតណាស់ យើងបានបង្កើតនៅខាងលើពួកអ្នក(ឱមនុស្សលោក)នូវមេឃប្រាំពីរជាន់ដែលត្រួតលើគ្នា ហើយយើងមិនបានព្រងើយកន្តើយចំពោះភាវៈទាំងឡាយ(របស់យើង)ឡើយ។

18. ហើយយើងបានបញ្ចុះទឹកភ្លៀងពីលើមេឃក្នុងបរិមាណកំណត់(ជាក់លាក់)។ ហើយយើងបានឱ្យវា(ទឹកភ្លៀង)ស្ថិតនៅលើផែនដី។ ជាការពិតណាស់ យើងពិតជាអ្នកដែលមានសមត្ថភាពធ្វើឱ្យវាបាត់បង់(រីង)ទៅវិញ។

19. ហើយតាមរយៈទឹកភ្លៀងនេះ យើងបានបង្កើតនូវច្បារដំណាំជាច្រើនអំពីដើមល្មើ និងទំពាំងបាយជូរសម្រាប់ពួកអ្នក។ នៅក្នុងចម្ការទាំងនោះ មានផ្លែឈើជាច្រើនប្រភេទ។ ហើយក្នុងចំណោមផ្លែឈើទាំងនោះ ពួកអ្នកអាចបរិភោគបាន។

20. ហើយ(តាមរយៈទឹកភ្លៀងនេះដែរ យើងបានបង្កើតសម្រាប់ពួកអ្នកនូវ)ដើមហ៊ែរទូន ដែលដុះនៅតំបន់ភ្នំតួរស៊ីណាកដែលអាចចម្រាញ់ចេញជាប្រេង និងជាចំណីអាហារសម្រាប់បរិភោគ។

21. ហើយពិតប្រាកដណាស់ ចំពោះសត្វពាហនៈទាំងឡាយ គឺជាមេរៀនមួយសម្រាប់ពួកអ្នក។ យើងបានផ្តល់ឱ្យពួកអ្នកទទួលទាននូវអ្វី(ទឹកដោះ)ដែលមាននៅក្នុងពោះរបស់វា។ ហើយពួកវាក៏បានផ្តល់នូវផលប្រយោជន៍ជាច្រើនផ្សេងទៀតសម្រាប់ពួកអ្នក ហើយក្នុងចំណោមពួកវា ពួកអ្នកក៏អាចទទួលទានបានផងដែរ។

22. ហើយពួកអ្នកអាចដឹកជញ្ជូនទំនិញនៅលើវា(សត្វអូដ្ឋ) និងនៅលើសំពៅផងដែរ។

23. ហើយជាការពិតណាស់ យើងបានបញ្ជូនព្យាការីនួហទៅកាន់ក្រុមរបស់គាត់ ដោយគាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គឺគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកមិនកោតខ្លាចទ្រង់ទេឬ?

24. ពួកអ្នកដែលមានឋានៈសក្តិដែលជាពួកប្រឆាំងក្នុងចំណោមក្រុមរបស់គាត់បាននិយាយថា៖ រូបគេនេះ គឺគ្មានអ្វីក្រៅតែពីជាមនុស្សលោកធម្មតាដូចពួកអ្នកដែលចង់ធ្វើជាចៅហ្វាយនាយ(គ្រប់គ្រង)ទៅលើពួកអ្នកប៉ុណ្ណោះ។ ប្រសិនបើអល់ឡោះទ្រង់មានចេតនា ទ្រង់ប្រាកដជានឹងបញ្ជូនម៉ាឡាអ៊ីកាត់(មកកាន់ពួកយើងជាមិនខាន)។ ពួកយើងមិនដែលបានឮរឿងនេះពីបុព្វបុរសរបស់ពួកយើងជំនាន់មុននោះឡើយ។

25. រូបគេគ្មានអ្វីក្រៅពីជាបុរសដែលកើតរោគវិកលចរិតនោះឡើយ។ ហេតុនេះ ចូរពួកអ្នករង់ចាំមើលគេសិនចុះ រហូតដល់ពេលកំណត់(គេភ្ញាក់ខ្លួនវិញ)។

26. ព្យាការីនួហបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាជួយដល់ខ្ញុំចំពោះអ្វីដែលពួកគេបានបដិសេធផងចុះ។

27. ពេលនោះ យើងក៏បានផ្ដល់វ៉ាហ៊ីទៅកាន់គេ(ព្យាការីនួហ)ថា៖ ចូរអ្នកធ្វើសំពៅមួយដោយការឃ្លាំមើលពីយើង និងដោយការបង្រៀនពីយើង។ ក្រោយមក នៅពេលដែលបទបញ្ជារបស់យើងបានមកដល់ ហើយទឹកបានផុសចេញពីក្នុងដីយ៉ាងច្រើននោះ ចូរអ្នកនាំយកចូលទៅក្នុងសំពៅនោះនូវរាល់សត្វដែលមានជីវិតទាំងអស់មួយគូៗ(ញីឈ្មោល)ព្រមទាំងក្រុមគ្រួសាររបស់អ្នកផងដែរ លើកលែងតែជនណាដែលគេបានកំណត់ជាមុនក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហើយចូរអ្នកកុំបួងសួងសុំពីយើងឱ្យជួយសង្គ្រោះពួកដែលបានបំពានឱ្យសោះ។ ពិតប្រាកដណាស់ ពួកគេ គឺជាពួកដែលត្រូវគេពន្លិច(ក្នុងទឹកជំនន់)។

28. ហើយនៅពេលដែលអ្នក និងអ្នកដែលនៅជាមួយអ្នកបានឡើងលើសំពៅហើយនោះ ចូរអ្នកពោលថា៖ ការសរសើរទាំងឡាយគឺសម្រាប់អល់ឡោះជាម្ចាស់ដែលបានសង្គ្រោះពួកយើងពីក្រុមដែលបំពាន។

29. ហើយចូរអ្នកពោលថា៖ បពិតព្រះជាម្ចាស់! សូមព្រះអង្គមេត្តាឱ្យខ្ញុំបានចុះចតនៅកន្លែងមួយដែលមានពរជ័យផងចុះ។ ហើយទ្រង់ជាអ្នកប្រទានកន្លែង(ចុះចត)ដ៏ប្រសើរបំផុត។

30. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាង(ដ៏ច្បាស់លាស់)។ ហើយយើងគឺជាអ្នកដែលសាកល្បង(ប្រជាជាតិទាំងឡាយ)។

31. ក្រោយមក យើងបានបង្កើតប្រជាជាតិមួយផ្សេងទៀតបន្ទាប់ពីពួកគេ(គឺក្រុមអាទ)។

32. ហើយយើងបានបញ្ជូនអ្នកនាំសារម្នាក់ក្នុងចំណោមពួកគេ(ព្យាការីហ៊ូទ)ទៅកាន់ពួកគេ (ដោយគាត់បាននិយាយថា៖) ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)។ សម្រាប់ពួកអ្នក គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកមិនកោតខ្លាចទ្រង់ទេឬ?

33. ហើយពួកអ្នកដែលមានឋានៈសក្តិក្នុងចំណោមក្រុមរបស់គាត់ដែលជាពួកប្រឆាំង និងបដិសេធនឹងជំនួបនាថ្ងៃបរលោក ព្រមទាំងយើងបានផ្ដល់ការសោយសុខក្នុងជីវិតលោកិយដល់ពួកគេបាននិយាយថា៖ រូបគេនេះ គ្មានអ្វីក្រៅពីជាមនុស្សលោកធម្មតាដូចពួកអ្នកដែលគេទទួលទាននូវអ្វីដែលពួកអ្នកទទួលទាន ហើយផឹកនូវអ្វីដែលពួកអ្នកផឹកប៉ុណ្ណោះ។

34. ហើយប្រសិនបើពួកអ្នកប្រតិបត្តិតាមមនុស្សលោកធម្មតាម្នាក់ដូចពួកអ្នកដែរ ពិតប្រាកដណាស់ បើដូច្នេះមែននោះ ពួកអ្នកពិតជាពួកដែលខាតបង់ជាមិនខាន។

35. តើគេបានសន្យានឹងពួកអ្នកថា ពិតប្រាកដណាស់ នៅពេលដែលពួកអ្នកស្លាប់ ហើយបានក្លាយទៅជាដី និងឆ្អឹង(ដែលពុកផុយ)ហើយនោះ ពួកអ្នកពិតជានឹងត្រូវបានគេបញ្ចេញ(ពីផ្នូររបស់ពួកអ្នកម្ដងទៀត)ឬ?

36. អ្វីដែលគេបានសន្យានឹងពួកអ្នកនោះ គឺនៅឆ្ងាយសែនឆ្ងាយ(មិនអាចកើតឡើងទៅរួចឡើយ)។

37. ពិតណាស់ គ្មានជីវិតរស់នៅណាក្រៅតែពីជីវិតរស់នៅក្នុងលោកិយរបស់យើងនេះឡើយ។ ពួកយើងស្លាប់ ហើយពួកយើងរស់(កើតស្លាប់បន្តបន្ទាប់គ្នា)។ ហើយពួកយើងក៏មិនត្រូវបានគេបង្កើតឲ្យរស់ឡើងវិញម្ដងទៀតនោះដែរ។

38. រូបគេ គ្មានអ្វីក្រៅពីជាបុរសម្នាក់ដែលប្រឌិតរឿងភូតកុហកទៅលើអល់ឡោះនោះឡើយ ហើយពួកយើងក៏មិនមានជំនឿលើគេដែរ។

39. គាត់(ព្យាការីហ៊ូទ)បានពោលថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាជួយដល់ខ្ញុំចំពោះអ្វីដែលពួកគេបានបដិសេធផងចុះ។

40. ទ្រង់បានតបថា៖ ក្រោយពីរយៈពេលបន្តិចទៀតនេះ ពួកគេប្រាកដជានឹងក្លាយជាអ្នកដែលមានវិប្បដិសារីជាមិនខាន។

41. ពេលនោះ សម្រែកដ៏ខ្លាំងក្លាបានឆក់យកជីវិតពួកគេយ៉ាងពិតប្រាកដ។ ហើយយើងបានធ្វើឱ្យពួកគេ(វិនាសអន្តរាយ)ប្រៀបដូចជាសំរាម។ ដូច្នេះ ភាពវិនាសអន្តរាយ គឺសម្រាប់ក្រុមដែលបំពាន។

42. ក្រោយមក យើងបានបង្កើតប្រជាជាតិជាច្រើនផ្សេងទៀតបន្ទាប់ពីពួកគេ។

43. គ្មានប្រជាជាតិណាមួយអាចធ្វើឱ្យពេលវេលាកំណត់(នៃការបំផ្លាញពួកគេ)មកដល់មុនពេលកំណត់នោះឡើយ ហើយក៏មិនអាចពន្យារពេលបាននោះដែរ។

44. ក្រោយមក យើងបានបញ្ជូនអ្នកនាំសាររបស់យើងជាច្រើនទៀតជាបន្តបន្ទាប់។ រាល់ពេលដែលអ្នកនាំសារនោះបានទៅដល់ប្រជាជាតិរបស់ខ្លួន គឺពួកគេតែងតែបដិសេធចំពោះគាត់។ ហើយយើងបានធ្វើឱ្យពួកគេវិនាសអន្តរាយជាបន្តបន្ទាប់ផងដែរ និងបានធ្វើឲ្យពួកគេក្លាយជារឿងរ៉ាវមួយ(សម្រាប់អ្នកជំនាន់ក្រោយ)។ ដូច្នេះ ភាពវិនាសអន្តរាយ គឺសម្រាប់ក្រុមដែលគ្មានជំនឿ។

45. ក្រោយមកទៀត យើងបានបញ្ជូនព្យាការីមូសា និងបងប្រុសរបស់គេ ព្យាការីហារូន ដោយនាំមកនូវសញ្ញាកស្តតាងជាច្រើនរបស់យើង ហើយនិងអំណះអំណាងយ៉ាងច្បាស់លាស់

46. ទៅកាន់ហ្វៀរអោន និងក្រុមមន្ត្រីរបស់គេ តែពួកគេបែរជាក្រអឺតក្រទមទៅវិញ។ ហើយពួកគេធ្លាប់ជាក្រុមដែលព្រហើនក្អេងក្អាង។

47. ហើយពួកគេបាននិយាយថា៖ តើឱ្យពួកយើងមានជំនឿលើបុគ្គលពីរនាក់ដែលជាមនុស្សធម្មតាដូចពួកយើង ហើយក្រុមរបស់គេទាំងពីរ(អម្បូរអ៊ីស្រាអែល)ទៀតសោត គឺជាពួកដែលស្ថិតនៅក្រោយបង្គាប់យើងហ្នឹងឬ?

48. ហើយពួកគេបានបដិសេធចំពោះគេទាំងពីរ(ព្យាការីមូសានិងព្យាការីហារូន)។ ហេតុនេះ ពួកគេក៏ស្ថិតក្នុងចំណោមពួកដែលត្រូវបានគេបំផ្លាញ។

49. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវគីតាប(តាវ៉ាត)។ សង្ឃឹមថា ពួកគេនឹងទទួលបានការចង្អុលបង្ហាញ។

50. ហើយយើងបានធ្វើឱ្យកូនប្រុសរបស់ម៉ារយ៉ាំ(ព្យាការីអ៊ីសា) និងម្តាយរបស់គេ ក្លាយជាសញ្ញាកស្តតាងមួយ(បញ្ជាក់ពីសមត្ថភាពរបស់យើង)។ ហើយយើងបានផ្តល់ឱ្យគេទាំងពីរនូវកន្លែងមួយខ្ពស់ផុតពីដីដែលអាចស្នាក់នៅបាន និងមានប្រភពទឹក(នៅទីនោះ)ផងដែរ។

51. ឱបណ្ដាអ្នកនាំសារទាំងឡាយ! ចូរពួកអ្នកទទួលទានអំពីចំណីអាហារល្អៗ ហើយចូរពួកអ្នកសាងនូវទង្វើកុសលៗ ពិតប្រាកដណាស់ យើងដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

52. ហើយពិតប្រាកដណាស់ សាសនារបស់ពួកអ្នកនេះ គឺជាសាសនាតែមួយគត់(សាសនាអ៊ីស្លាម) ហើយយើងគឺជាព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកោតខ្លាច(មកចំពោះយើង)។

53. តែពួកគេ(អ្នកដែលដើរតាមអ្នកនាំសារ)បានបែកបាក់គ្នារវាងពួកគេនៅក្នុងកិច្ចការ(សាសនា)របស់ពួកគេជាក្រុមៗ។ រាល់ក្រុមនីមួយៗ គឺមានមោទនភាពនឹងអ្វីដែលខ្លួនមាន។

54. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បោះបង់ពួកគេឱ្យស្ថិតក្នុងភាពវង្វេងរបស់ខ្លួន រហូតដល់ពេលកំណត់ចុះ។

55. តើពួកគេគិតស្មានថា អ្វីដែលយើងបានប្រទានឲ្យពួកគេអំពីទ្រព្យសម្បត្តិ និងកូនចៅនោះ

56. គឺយើងរួសរាន់ប្រទានដល់ពួកគេនូវប្រការល្អឬ? (មិនដូច្នោះឡើយ)។ ផ្ទុយទៅវិញ ពួកគេមិនដឹងខ្លួនឡើយ។

57. ពិតប្រាកដណាស់ បណ្ដាអ្នកដែលមានការប្រុងប្រយ័ត្នដោយកោតខ្លាចព្រះជាម្ចាស់របស់ខ្លួន

58. និងបណ្ដាអ្នកដែលមានជំនឿនឹងបណ្ដាវាក្យខណ្ឌនៃព្រះជាម្ចាស់របស់ពួកគេ

59. និងបណ្ដាអ្នកដែលមិនធ្វើស៊ីរិកចំពោះព្រះជាម្ចាស់របស់ពួកគេ

60. ហើយនិងបណ្ដាអ្នកដែលព្យាយាមក្នុងកិច្ចការសប្បុរស ហើយចិត្តរបស់ពួកគេបារម្ភខ្លាច(គេមិនទទួលយក)នៅពេលដែលពួកគេវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកគេ

61. អ្នកទាំងនោះហើយ គឺជាអ្នកដែលរួសរាន់ក្នុងការសាងអំពើល្អ ហើយពួកគេជាអ្នកដែលឈានមុខគេ(ក្នុងការសាងអំពើល្អ)។

62. ហើយយើងមិនដាក់បន្ទុកលើបុគ្គលណាម្នាក់ហួសពីសមត្ថភាពរបស់គេនោះឡើយ។ ហើយនៅជាមួយយើង គឺមានសៀវភៅកំណត់ត្រាមួយដែលរៀបរាប់នូវការពិត(ប្រាប់ពួកគេ)។ ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

63. ផ្ទុយទៅវិញ ដួងចិត្តរបស់ពួកគេ(ពួកប្រឆាំង)គឺស្ថិតក្នុងភាពធ្វេសប្រហែសអំពី(គម្ពីរគួរអាន)នេះ។ ហើយសម្រាប់ពួកគេគឺមានទង្វើ(អាក្រក់)ជាច្រើនផ្សេងទៀតក្រៅពីនោះដែលពួកគេប្រព្រឹត្តវា។

64. លុះដល់ពេលដែលយើងបានឆក់យកជីវិតពួកដែលមានទ្រព្យស្តុកស្តម្ភនៃពួកគេដោយទណ្ឌកម្ម ស្រាប់តែពួកគេស្រែកសុំឲ្យជួយ។

65. (មានគេនិយាយទៅកាន់ពួកគេថា៖) ពួកអ្នកមិនត្រូវស្រែកសុំឲ្យគេជួយនៅក្នុងថ្ងៃនេះនោះទេ។ ជាការពិតណាស់ ពួកអ្នកមិនត្រូវបានគេជួយឲ្យរួចផុតពី(ទណ្ឌកម្មរបស់)យើងនោះឡើយ។

66. ជាការពិតណាស់ បណ្ដាវាក្យខណ្ឌរបស់យើងធ្លាប់ត្រូវបានគេសូត្រឱ្យពួកអ្នកស្ដាប់ហើយ តែពួកអ្នកបែរជានាំគ្នាត្រឡប់ក្រោយ(មិនព្រមស្ដាប់វា)ទៅវិញ

67. ដោយសារភាពក្រអឺតក្រទមព្រោះតែពួកអ្នកអះអាងថា ពួកអ្នកគឺជាម្ចាស់នៃទឹកដីពិសិដ្ឋ។ ហើយពួកអ្នកថែមទាំងបាននិយាយអាក្រក់អំពីវានៅពេលយប់ទៀតផង។

68. តើពួកគេ(ពួកមុស្លីគីន)មិនបានគិតពិចារណាចំពោះគម្ពីរគួរអានទេឬ? ឬមួយក៏បានមកដល់ពួកគេនូវអ្វីដែលមិនធ្លាប់ទៅដល់ជីដូនជីតារបស់ពួកគេកាលពីមុនឬ(ទើបពួកគេប្រឆាំងបែបនេះ)?

69. ឬមួយក៏ពួកគេមិនស្គាល់អ្នកនាំសាររបស់ពួកគេ(ព្យាការីមូហាំម៉ាត់)ទើបពួកគេបដិសេធនឹងគាត់បែបនេះ?

70. ឬមួយពួកគេចាត់ទុកគាត់(ព្យាការីមូហាំម៉ាត់)ជាមនុស្សវិកលចរិតឬ? ផ្ទុយទៅវិញ គាត់បាននាំមកកាន់ពួកគេនូវសេចក្ដីពិត។ តែភាគច្រើននៃពួកគេ គឺមិនពេញចិត្តនឹងសេចក្ដីពិតឡើយ។

71. ហើយប្រសិនបើសេចក្ដីពិតនោះស្របទៅតាមទំនើងចិត្តរបស់ពួកគេវិញ មេឃជាច្រើនជាន់ និងផែនដី ព្រមទាំងអ្វីដែលមាននៅក្នុងវានឹងវិនាសអន្តរាយជាមិនខាន។ ផ្ទុយទៅវិញ យើងបានផ្ដល់ឱ្យពួកគេនូវភាពខ្ពង់ខ្ពស់របស់ពួកគេ(គម្ពីរគួរអាន)។ តែពួកគេបែរជាងាកចេញពីភាពខ្ពង់ខ្ពស់នោះទៅវិញ។

72. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានទាមទារកម្រៃពីពួកគេឬ(ទើបបានជាពួកគេបដិសេធបែបនេះ)? ជាការពិតណាស់ ការតបស្នងនៃព្រះជាម្ចាស់របស់អ្នក គឺល្អប្រសើរ(ជាងនោះទៅទៀត)។ ហើយទ្រង់គឺជាអ្នកប្រទានលាភសក្ការៈដ៏ប្រសើរបំផុត។

73. ហើយពិតប្រាកដណាស់ រូបអ្នកពិតជាបានអំពាវនាវពួកគេទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ(សាសនាអ៊ីស្លាម)។

74. ហើយពិតប្រាកដណាស់ ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក គឺពួកគេងាកចេញពីមាគ៌ា(ដ៏ត្រឹមត្រូវនេះ)។

75. ហើយប្រសិនបើយើងមានក្ដីមេត្តាករុណាចំពោះពួកគេ និងដកយកចេញពីពួកគេនូវគ្រោះ(រាំងស្ងួត និងគ្រោះទុរ្ភិក្ស)ដែលពួកគេជួបប្រទះនោះ ក៏ពួកគេនឹងនៅតែស្ថិតក្នុងភាពវង្វេងរបស់ពួកគេដោយមានភាពស្រពេចស្រពិលដដែល។

76. ហើយពិតប្រាកដណាស់ យើងបានសាកល្បងពួកគេដោយគ្រោះផ្សេងៗ តែពួកគេនៅតែមិនព្រមឱនលំទោនចំពោះព្រះជាម្ចាស់របស់ពួកគេ និងមិនព្រមទទូចអង្វរករ(ចំពោះទ្រង់)ដដែល។

77. លុះនៅពេលដែលយើងបើកទ្វារនៃទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតចំពោះពួកគេ(នាថ្ងៃបរលោក) ស្រាប់តែពួកគេមានការអស់សង្ឃឹម។

78. ហើយទ្រង់ជាអ្នកដែលបង្កើតសម្រាប់ពួកអ្នកនូវសោតវិញ្ញាណ ចក្ខុវិញ្ញាណ និងដួងចិត្ត។ អ្វីដែលពួកអ្នកដឹងគុណ គឺតិចតួចបំផុត។

79. ហើយទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នក(ឱមនុស្សលោក)ឱ្យមានជីវិតនៅលើផែនដី។ ហើយពួកអ្នកនឹងត្រូវគេប្រមូលផ្ដុំទៅកាន់ទ្រង់វិញ(នៅថ្ងៃបរលោក)។

80. ហើយទ្រង់ជាអ្នកដែលផ្តល់ជីវិត និងដកយកជីវិត។ ហើយ(ការកំណត់)ភាពខុសគ្នារវាងពេលយប់និងពេលថ្ងៃ គឺជាកម្មសិទ្ធិរបស់ទ្រង់។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

81. ផ្ទុយទៅវិញ ពួកគេបាននិយាយដូចអ្វីដែលបុព្វបុរស(របស់ពួកគេ)ជំនាន់មុនបាននិយាយ

82. ដោយពួកគេនិយាយថា៖ នៅពេលដែលពួកយើងបានស្លាប់ ហើយបានក្លាយទៅជាដី និងឆ្អឹង(ដែលពុកផុយ)ហើយនោះ តើពួកយើងពិតជានឹងត្រូវបានគេបង្កើតឱ្យរស់ឡើងវិញម្តងទៀតឬ?

83. ជាការពិតណាស់ ពួកយើង និងជីដូនជីតារបស់ពួកយើងក៏ត្រូវបានគេសន្យាចំពោះរឿងនេះកាលពីមុនដូចគ្នាដែរ។ រឿងនេះគ្មានអ្វីក្រៅពីជារឿងនិទានរបស់អ្នកជំនាន់មុននោះឡើយ។

84. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើផែនដី និងអ្វីដែលមាននៅក្នុងវាជាកម្មសិទ្ធិរបស់អ្នកណា ប្រសិនបើពួកអ្នកបានដឹងមែននោះ?

85. ពួកគេនឹងឆ្លើយថា៖ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ចូរអ្នកតបថា៖ បើដូច្នេះ តើពួកអ្នកមិនភ្ញាក់រលឹកទេឬ?

86. ចូរអ្នកពោលថា៖ តើអ្នកណាជាព្រះជាម្ចាស់នៃមេឃទាំងប្រាំពីរជាន់ និងជាព្រះជាម្ចាស់នៃអារ៉ស្តដ៏ធំធេងនោះ?

87. ពួកគេនឹងឆ្លើយថា៖ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ចូរអ្នកតបថា៖ បើដូច្នោះ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

88. ចូរអ្នកពោលទៀតថា៖ តើអ្នកណាដែលអំណាចគ្រប់គ្រងអ្វីៗទាំងអស់ស្ថិតក្នុងកណ្តាប់ដៃ ហើយជាអ្នកជួយសង្គ្រោះ និងគ្មាននរណាម្នាក់អាចជួយសង្គ្រោះអ្នកដែលទ្រង់ចង់បំផ្លាញនោះឡើយ ប្រសិនបើពួកអ្នកបានដឹងមែននោះ?

89. ពួកគេនឹងឆ្លើយថា៖ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ចូរអ្នកតបថា៖ ដូច្នេះ តើពួកអ្នកត្រូវបានគេបោកបញ្ឆោតយ៉ាងដូចម្តេច?

90. ផ្ទុយទៅវិញ យើងបាននាំមកឱ្យពួកគេនូវការពិត។ ហើយពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។

91. អល់ឡោះទ្រង់គ្មានបុត្រនោះឡើយ ហើយក៏គ្មានព្រះឯណាដែលត្រូវគោពសក្ការៈដ៏ពិតប្រាកដរួមជាមួយនឹងទ្រង់នោះដែរ។ ប្រសិនបើមានមែននោះ ព្រះនីមួយៗប្រាកដជានឹងនាំយកនូវអ្វីដែលខ្លួនបានបង្កើត(ទៅគ្រប់គ្រង) ហើយពួកវានឹងយកប្រៀបលើគ្នាទៅវិញទៅមកជាមិនខាន។ អល់ឡោះជាម្ចាស់មហាស្អាតស្តុំពីអ្វីដែលពួកគេបានពណ៌នា។

92. ទ្រង់ជាអ្នកដឹងនូវប្រការដែលអាថ៌កំបាំង និងប្រការដែលលាតត្រដាង។ ហើយទ្រង់មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេធ្វើស្តីរិក។

93. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ បពិត្រព្រះជាម្ចាស់! ប្រសិនបើព្រះអង្គពិតជាបង្ហាញឱ្យខ្ញុំបានឃើញនូវអ្វី(ទណ្ឌកម្ម)ដែលទ្រង់បានសន្យានឹងពួកគេ

94. បពិត្រព្រះជាម្ចាស់! ដូចនេះ សូមព្រះអង្គមេត្តាកុំឱ្យខ្ញុំស្ថិតក្នុងចំណោមក្រុមដែលបំពាន។

95. ហើយពិតប្រាកដណាស់ យើងពិតជាអ្នកដែលមានសមត្ថភាពក្នុងការធ្វើឱ្យអ្នក(ព្យាការីមូហាំម៉ាត់)បានឃើញនូវអ្វី(ទណ្ឌកម្ម)ដែលយើងបានសន្យាចំពោះពួកគេនោះ។

96. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រុញច្រានប្រការអាក្រក់ដោយអ្វីដែលល្អប្រសើរជាង។ ហើយយើងដឹងបំផុតនូវអ្វីដែលពួកគេបានពណ៌នា។

97. ហើយចូរអ្នកពោលចុះថា៖ បពិត្រព្រះជាម្ចាស់! ខ្ញុំសុំការបញ្ជៀសពីព្រះអង្គអំពីការពង្វក់របស់ពពួកស៊ីស្តូតនផង។

98. ហើយខ្ញុំសុំការបញ្ជៀសពីព្រះអង្គ ឱព្រះជាម្ចាស់របស់ខ្ញុំ សូមបញ្ជៀសរូបខ្ញុំពីវត្តមានរបស់ពួកវាផង។

99. លុះនៅពេលដែលសេចក្ដីស្លាប់បានមកដល់នរណាម្នាក់ក្នុងចំណោមពួកគេ(ពួកមុស្លីគីន) គេនឹងនិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាឲ្យខ្ញុំបានវិលត្រឡប់(ទៅកាន់លោកិយម្ដងទៀត)ផង

100. ដើម្បីឲ្យខ្ញុំបានសាងទង្វើកុសលវិញចំពោះអ្វីដែលខ្ញុំបានបោះបង់(កាលពីមុន)។ មិនដូច្នោះឡើយ! តាមពិត វាគ្រាន់តែជាពាក្យសម្ដីដែលគេនិយាយ(ទទេៗ)ប៉ុណ្ណោះ។ ហើយនៅពីក្រោយពួកគេ គឺមានជញ្ជាំងខណ្ឌចែក(រវាងលោកិយ និងបរលោក)រហូតដល់ថ្ងៃដែលពួកគេត្រូវបានគេបង្កើតឲ្យរស់ឡើងវិញ។

101. ហើយនៅពេលដែលគេ(ម៉ាឡាអ៊ីកាត់)បានផ្លុំត្រែ ពេលនោះ គ្មានសាច់សាលោហិតអ្វីទៀតឡើយរវាងពួកគេនៅថ្ងៃនោះ ហើយពួកគេក៏មិនសួរគ្នាទៅវិញទៅមកនោះដែរ។

102. ដូច្នេះ ជនណាហើយដែលភ្នែកជញ្ជីង(នៃអំពើល្អ)របស់គេមានទម្ងន់ធ្ងន់ជាង ពិតណាស់ អ្នកទាំងនោះហើយគឺជាអ្នកដែលទទួលបានជោគជ័យ។

103. តែជនណាហើយដែលភ្នែកជញ្ជីង(នៃអំពើល្អ)របស់គេមានទម្ងន់ស្រាលជាងនោះ ពិតណាស់ ពួកទាំងនោះហើយគឺជាពួកដែលខាតបង់ខ្លួនឯងដោយត្រូវស្ថិតនៅក្នុងនរកជើហាន់ណាំជាអមតៈ។

104. ភ្លើងនរកឆាបឆេះមុខរបស់ពួកគេ ហើយពួកគេរួញក្រញង់នៅក្នុងឋាននរកនោះ។

105. (មានគេនិយាយទៅកាន់ពួកគេថា៖) តើបណ្ដាវាក្យខណ្ឌរបស់យើងមិនធ្លាប់ត្រូវបានសូត្រឱ្យពួកអ្នកស្ដាប់ ហើយពួកអ្នកធ្លាប់បានបដិសេធចំពោះវាទេឬ?

106. ពួកគេបានតបថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ទំនើងចិត្តរបស់យើងខ្ញុំបានគ្របដណ្ដប់លើយើងខ្ញុំ ហើយយើងខ្ញុំធ្លាប់ជាក្រុមមួយដែលវង្វេង។

107. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបញ្ចេញយើងខ្ញុំពីវា(ឋាននរក)ផងចុះ។ ពេលនោះ ប្រសិនបើយើងខ្ញុំត្រឡប់ទៅ(រកភាពវង្វេងទៀតនោះ) ជាការពិតណាស់ យើងខ្ញុំគឺជាពួកដែលបំពាន។

108. ទ្រង់បានតបវិញថា៖ ចូរពួកឯងស្ថិតនៅក្នុងឋាននរកនេះចុះ ហើយចូរពួកឯងកុំនិយាយនឹងយើងទៀត។

109. ពិតប្រាកដណាស់ មានក្រុមមួយក្នុងចំណោមខ្ញុំបម្រើរបស់យើង(អ្នកមានជំនឿ) ពួកគេបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! យើងខ្ញុំមានជំនឿហើយ។ ដូចនេះ សូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំ និងអាណិតស្រលាញ់ចំពោះយើងខ្ញុំផង។ ជាការពិតណាស់ ទ្រង់គឺជាអ្នកដែលអាណិតស្រលាញ់ដ៏ប្រសើរបំផុត។

110. តែពួកអ្នកបែរជាយកពួកគេជាការចំអកឡកឡឺយទៅវិញ រហូតធ្វើឲ្យពួកអ្នកភ្លេចនូវការរំឭកមកចំពោះយើង ខណៈដែលពួកអ្នកបានសើចចំអកចំពោះពួកគេ។

111. ពិតប្រាកដណាស់ នៅថ្ងៃនេះ យើងនឹងតបស្នងដល់ពួកគេ(អ្នកមានជំនឿ)ចំពោះអ្វីដែលពួកគេបានអត់ធ្មត់។ ពិតប្រាកដណាស់ ពួកគេជាពួកដែលទទួលបានជោគជ័យ។

112. ទ្រង់បានមានបន្ទូលថា៖ តើពួកអ្នកបានរស់នៅក្នុងលោកិយរយៈកាលប៉ុន្មានឆ្នាំដែរ?

113. ពួកគេបានឆ្លើយថា៖ ពួកយើងបានរស់នៅ(ក្នុងលោកិយ)ចំនួនមួយថ្ងៃ ឬកន្លះថ្ងៃតែប៉ុណ្ណោះ។ ដូច្នេះ សូមព្រះអង្គសួរអ្នកដែលចេះគណនាចុះ។

114. ទ្រង់បានតបថា៖ ពួកអ្នកមិនបានរស់នៅ(ក្នុងលោកិយ)នេះឡើយ លើកលែងតែមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ ប្រសិនបើពួកអ្នកបានដឹង។

115. តើពួកអ្នក(ឱមនុស្សលោក)គិតថា៖ ពិតណាស់ យើងបានបង្កើតពួកអ្នកទទេរៗ((គ្មានហេតុផល) ហើយពួកអ្នកពិតជាមិនត្រូវបានគេនាំត្រឡប់មកកាន់យើងវិញ(ដើម្បីជំនុំជម្រះ)នោះឬ?

116. ពិតប្រាកដណាស់ អល់ឡោះមហាខ្ពង់ខ្ពស់ ជាស្តេចដែលគ្រប់គ្រងដ៏ពិតប្រាកដ។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលជាព្រះជាម្ចាស់នៃអារ៉ស្តដ៏ឧត្តុង្គឧត្តមនោះឡើយ។

117. ហើយជនណាដែលគោរពសក្ការៈព្រះផ្សេងរួមនឹងអល់ឡោះដែលគ្មានភស្តុតាងបញ្ជាក់ចំពោះវាផងនោះ ជាការពិតណាស់ ការជំនុំជម្រះរបស់គេ គឺស្ថិតនៅលើព្រះជាម្ចាស់របស់គេ។ ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ គឺមិនទទួលជោគជ័យជាដាច់ខាត។

118. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាអភ័យទោស និងអាណិតស្រលាញ់(ចំពោះរូបខ្ញុំ)ផង។ ហើយទ្រង់គឺជាអ្នកអាណិតស្រលាញ់ដ៏ប្រសើរបំផុត។

ជំពូក អាន់ន្អរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នេះគឺជាជំពូកមួយដែលយើងបានបញ្ចុះ និងបានដាក់កាតព្វកិច្ច (ឱ្យអនុវត្តន៍តាមក្បួនច្បាប់របស់វា) ហើយយើងបានបញ្ចុះនៅក្នុងជំពូកនោះនូវបណ្តាវាក្យខណ្ឌដ៏ច្បាស់លាស់ដើម្បីឱ្យពួកអ្នកចងចាំ។

2. ស្ត្រីក្រមុំ និងបុរសកំលោះដែលប្រព្រឹត្តអំពើហ្ស៊ីណា ចូរពួកអ្នកវាយគេទាំងពីរក្នុងម្នាក់ៗចំនួនមួយរយរំពាត់។ ហើយពួកអ្នកមិនត្រូវអាណិតអាសូរចំពោះពួកគេទាំងពីរដោយមិនអនុវត្តទៅតាមច្បាប់សាសនារបស់អល់ឡោះនោះឡើយ ប្រសិនបើពួកអ្នកគឺជាអ្នកដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោកមែននោះ។ ហើយចូរឱ្យក្រុមមួយនៃអ្នកដែលមានជំនឿចូលរួមធ្វើជាសាក្សីដឹងឮក្នុងការដាក់ទណ្ឌកម្មពួកគេទាំងពីរផងដែរ។

3. បុរសដែលប្រព្រឹត្តហ្ស៊ីណា គឺមិនត្រូវរៀបការនោះឡើយលើកលែងតែជាមួយនឹងស្ត្រីដែលប្រព្រឹត្តហ្ស៊ីណា ឬស្ត្រីដែលធ្វើស្ដីរិកប៉ុណ្ណោះ។ ហើយស្ត្រីដែលប្រព្រឹត្តហ្ស៊ីណា ក៏គ្មានអ្នករៀបការនឹងនាងនោះដែរ លើកលែងជាមួយនឹងបុរសដែលប្រព្រឹត្តហ្ស៊ីណា ឬបុរសដែលធ្វើស្ដីរិកប៉ុណ្ណោះ។ ហើយគេហាមឃាត់ដូច្នោះទៅចំពោះបណ្តាអ្នកមានជំនឿទាំងឡាយ។

4. ហើយពួកដែលចោទប្រកាន់ស្ត្រីដែលបរិសុទ្ធ (ថាបានប្រព្រឹត្តអំពើហ្ស៊ីណា) ក្រោយមក ពួកគេ (អ្នកដែលចោទប្រកាន់គេ) មិនបាននាំមកនូវសាក្សីចំនួនបួនរូបមកទេនោះ ចូរពួកអ្នកវាយពួកគេចំនួនប៉ែតសិបរំពាត់ ហើយពួកអ្នកមិនត្រូវទទួលយកការធ្វើសាក្សីពីពួកទាំងនោះជាដាច់ខាត។ ហើយពួកទាំងនោះ គឺជាពួកដែលប្រព្រឹត្តល្មើស។

5. លើកលែងតែអ្នកដែលបានសារភាពកំហុសក្រោយពីនោះ ហើយបានកែខ្លួនវិញប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

6. ហើយអ្នកដែលបានចោទប្រកាន់ភរិយារបស់ខ្លួន (ថាបានប្រព្រឹត្តហ្ស៊ីណា) តែពួកគេពុំមានសាក្សីណាក្រៅពីខ្លួនឯងទេនោះ ចូរឱ្យពួកគេម្នាក់ៗស្បថចំពោះអល់ឡោះចំនួនបួនដងថា៖ ពិតប្រាកដណាស់ រូបគេ (ស្វាមី) ពិតជាស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់។

7. ហើយនៅលើកទីប្រាំ (ចូរឲ្យគេបន្ថែមថា)៖ សូមឲ្យបណ្តាសារបស់អល់ឡោះធ្លាក់លើរូបគេ ប្រសិនបើរូបគេស្ថិតក្នុងចំណោមអ្នកដែលភូតកុហក។

8. ហើយគេ (អ្នកអនុវត្តច្បាប់) ត្រូវការពារនាងពីការដាក់ទណ្ឌកម្ម (គប់នឹងដុំថ្មរហូតស្លាប់) ដោយត្រូវឱ្យនាងស្បថចំពោះអល់ឡោះចំនួនបួនដងថា៖ ពិតប្រាកដណាស់ រូបគេ (ស្វាមី) ស្ថិតក្នុងចំណោមអ្នកដែលភូតកុហក។

9. ហើយនៅលើកទីប្រាំ (ចូរឲ្យនាងបន្ថែមថា)៖ សូមឲ្យការខឹងសម្បារបស់អល់ឡោះធ្លាក់ទៅលើនាង ប្រសិនបើគេ (ស្វាមី) ស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់។

10. ហើយប្រសិនបើគ្មានការប្រោសប្រទានពីអល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់ចំពោះពួកអ្នកទេនោះ (ទ្រង់ពិតជានឹងដាក់ទណ្ឌកម្មពួកអ្នកភ្លាមៗជាមិនខាន)។ ហើយទ្រង់ជាអ្នកដែលទទួលនូវការសារភាពកំហុស មហាគតិបណ្ឌិតបំផុត។

11. ពិតប្រាកដណាស់ ពួកដែលនាំមកនូវការមួលបង្កាច់(ចោទប្រកាន់អាអ៊ីស្ហះ ថាបានប្រព្រឹត្តហ្ស៊ីណា)នោះ គឺជាក្រុមមួយនៃពួកអ្នក(ឱអ្នកមានជំនឿ)នេះឯង។ ចូរពួកអ្នកកុំគិតថា វារឿងអាក្រក់សម្រាប់ពួកអ្នកឱ្យសោះ។ ផ្ទុយទៅវិញ វាជារឿងល្អសម្រាប់ពួកអ្នកទៅវិញទេ។ សម្រាប់បុគ្គលគ្រប់រូបក្នុងចំណោមពួកគេ(ដែលបានចូលរួមក្នុងការចោទប្រកាន់នោះ) គឺត្រូវទទួលចំណែកនៃបាបកម្ម។ ហើយអ្នកដែលទទួលខុសត្រូវធំជាងគេក្នុងរឿងនេះក្នុងចំណោមពួកគេ សម្រាប់រូបគេនឹងទទួលនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

12. ហេតុអ្វីបានជានៅពេលដែលពួកអ្នកបានឮរឿងនេះ អ្នកមានជំនឿទាំងប្រុសទាំងស្រីមិនព្រមគិតស្មានល្អដោយខ្លួនពួកគេផ្ទាល់ ហើយនិយាយថា នេះគឺជាការចោទប្រកាន់យ៉ាងច្បាស់លាស់នោះ?

13. ហេតុអ្វីបានជាពួកគេ(អ្នកដែលចោទប្រកាន់)មិននាំមកនូវសាក្សីចំនួនបួននាក់ដើម្បីបញ្ជាក់? ប្រសិនបើពួកគេមិនបាននាំសាក្សីមកទេនោះ ពិតប្រាកដណាស់ ចំពោះអល់ឡោះ ពួកគេ គឺជាពួកដែលកុហក។

14. ហើយប្រសិនបើគ្មានការប្រោសប្រទានរបស់អល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់ចំពោះពួកអ្នកទាំងក្នុងលោកិយ និងនៅថ្ងៃបរលោកទេនោះ ច្បាស់ជាទណ្ឌកម្មដ៏ធំធេងបំផុតនឹងធ្លាក់ទៅលើពួកអ្នកដោយសារតែការមួលបង្កាច់របស់ពួកអ្នកជាមិនខាន។

15. នៅពេលដែលពួកអ្នកពាំនាំរឿងនោះ(រឿងមួលបង្កាច់)ដោយអណ្តាតរបស់ពួកអ្នក ហើយពួកអ្នកបាននិយាយដោយមាត់របស់ពួកអ្នកនូវអ្វីដែលពួកអ្នកមិនបានដឹង ដោយពួកអ្នកគិតស្មានថា វាគឺជារឿងតូចតាច ខណៈដែលវាគឺជារឿងធំបំផុតចំពោះអល់ឡោះជាម្ចាស់។

16. ហើយតើហេតុអ្វីបានជានៅពេលដែលពួកអ្នកបានឮរឿងនេះ ពួកអ្នកមិនព្រមនិយាយថា៖ មិនត្រឹមត្រូវនោះទេដែលយើងនាំគ្នាមកនិយាយរឿងនេះ? អល់ឡោះមហាស្អាតស្អំ។ នេះគឺជាការមួលបង្កាច់មួយដ៏ធំធេង។

17. អល់ឡោះទ្រង់ទូន្មានពួកអ្នកកុំឱ្យត្រឡប់មកធ្វើដូចនេះម្តងទៀត ប្រសិនបើពួកអ្នកជាអ្នកដែលមានជំនឿ។

18. ហើយអល់ឡោះជាម្ចាស់ទ្រង់បញ្ជាក់យ៉ាងច្បាស់ដល់ពួកអ្នកនូវបណ្តាវាក្យខណ្ឌទាំងឡាយ។ ហើយអល់ឡោះមហាដឹងមហាគតិបណ្ឌិត។

19. ពិតប្រាកដណាស់ ពួកដែលចូលចិត្តចង់ឱ្យរឿងអាស្រូវលេចឮសុះសាយក្នុងចំណោមអ្នកដែលមានជំនឿនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងឈឺចាប់បំផុតទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយអល់ឡោះទ្រង់ដឹងបំផុត។ តែពួកអ្នកវិញមិនដឹងឡើយ។

20. ហើយប្រសិនបើគ្មានការប្រោសប្រទានរបស់អល់ឡោះ ហើយនិងក្តីមេត្តាករុណារបស់ទ្រង់ចំពោះពួកអ្នកទេនោះ (ទ្រង់ពិតជានឹងដាក់ទណ្ឌកម្មពួកអ្នកភ្លាមៗជាមិនខាន)។ ហើយពិតប្រាកដណាស់ អល់ឡោះមហាអាណិតអាសូរ និងមហាអាណិតស្រលាញ់។

21. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំដើរតាមជំហានទាំងឡាយរបស់ស៊ែតន។ ជនណាហើយដែលដើរតាមជំហានទាំងឡាយរបស់ស៊ែតននោះ ជាការពិតណាស់ វានឹងប្រើឱ្យប្រព្រឹត្តនូវទង្វើអសីលធម៌ និងអំពើអាក្រក់។ ហើយប្រសិនបើគ្មានការប្រោសប្រទានពីអល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់ចំពោះពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ទេនោះ គ្មាននរណាម្នាក់ក្នុងចំណោមពួកអ្នកអាចជ្រះស្អាត(ពីបាបកម្ម)ជាដាច់ខាត ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទ្រង់ធ្វើឱ្យជ្រះស្អាត(ពីបាបកម្ម)ចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

22. ហើយចូរកុំឱ្យអ្នកដែលមានកិត្តិយសថ្លៃថ្នូរក្នុងចំណោមពួកអ្នក និងអ្នកដែលមានទ្រព្យសម្បត្តិធូរធារស្បថថានឹងឈប់បរិច្ចាគឱ្យទៅសាច់ញាតិ ជនក្រីក្រ និងអ្នកដែលភៀសខ្លួនក្នុងមាគ៌ារបស់អល់ឡោះឱ្យសោះ។ ហើយចូរឱ្យពួកគេ(អ្នកមានទ្រព្យ)អភ័យទោស និងអធ្យាស្រ័យ(ដល់អ្នកទាំងនោះ)។ តើពួកអ្នកមិនចូលចិត្តចង់ឱ្យអល់ឡោះអភ័យទោសដល់ពួកអ្នកទេឬ? ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

23. ជាការពិតណាស់ ពួកដែលចោទប្រកាន់បណ្តាស្ត្រីបរិសុទ្ធដែលមិនធ្លាប់គិតផ្តេសផ្តាសព្រមទាំងជាស្ត្រីដែលមានជំនឿទៀតនោះ (ថាបានប្រព្រឹត្តអំពើហ្ស៊ីណា) គេនឹងដាក់បណ្តាសាពួកគេទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

24. គឺនៅថ្ងៃដែលអណ្តាតរបស់ពួកគេធ្វើសាក្សីប្រឆាំងនឹងពួកគេ(ចំពោះអ្វីដែលពួកគេនិយាយ) ហើយដៃជើងរបស់ពួកគេធ្វើសាក្សីប្រឆាំងនឹងពួកគេចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

25. នៅក្នុងថ្ងៃនោះ អល់ឡោះជាម្ចាស់នឹងប្រទានដល់ពួកគេនូវការតបស្នងរបស់ពួកគេប្រកបដោយភាពយុត្តិធម៌បំផុត ហើយពួកគេនឹងដឹងថា ពិតណាស់អល់ឡោះទ្រង់គឺជាព្រះជាម្ចាស់ដ៏ពិតប្រាកដ។

26. ស្ត្រីដែលអាក្រក់ គឺសម្រាប់បុរសដែលអាក្រក់ ហើយបុរសដែលអាក្រក់ គឺសម្រាប់ស្ត្រីដែលអាក្រក់។ ចំណែកស្ត្រីដែលល្អ គឺសម្រាប់បុរសដែលល្អ ហើយបុរសដែលល្អ គឺសម្រាប់ស្ត្រីដែលល្អ។ អ្នក(ដែលល្អៗ)ទាំងនោះ គឺពួកគេចាកផុតពីអ្វីដែលពួក(ដែលអាក្រក់ៗ)ទាំងនោះបាននិយាយ(ចោទប្រកាន់)។ សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងលាភសក្ការៈដ៏ប្រពៃ(ឋានសួគ៌)។

27. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំចូលគេហដ្ឋានណាមួយក្រៅពីគេហដ្ឋានរបស់ពួកអ្នកឱ្យសោះ ទាល់តែពួកអ្នកសុំការអនុញ្ញាត និងឱ្យសាឡាម(គារវកិច្ច)ទៅកាន់ម្ចាស់ផ្ទះជាមុនសិន។ នោះគឺជាការល្អប្រសើរសម្រាប់ពួកអ្នក សង្ឃឹមថាពួកអ្នកនឹងចងចាំ។

28. តែប្រសិនបើពួកអ្នកមិនបានឃើញនរណាម្នាក់នៅក្នុងគេហដ្ឋាននោះទេ ចូរពួកអ្នកកុំចូលក្នុងគេហដ្ឋាននោះ រហូតទាល់តែមានគេអនុញ្ញាតឱ្យពួកអ្នក។ ហើយប្រសិនបើគេនិយាយទៅកាន់ពួកអ្នកថា៖ "សូមពួកអ្នកត្រឡប់ទៅវិញចុះ" នោះពួកអ្នកត្រូវតែត្រឡប់ទៅវិញ។ នោះគឺជាការស្អាតស្អំបំផុតសម្រាប់ពួកអ្នក។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

29. គ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នក ប្រសិនបើពួកអ្នកចូលក្នុងគេហដ្ឋានណាមួយដែលមិនមែនសម្រាប់រស់នៅដែលនៅក្នុងនោះ មានទ្រព្យសម្បត្តិរបស់ពួកអ្នក។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកលាតត្រដាង និងអ្វីដែលពួកអ្នកលាក់បាំង។

30. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់អ្នកមានជំនឿជាបុរសឱ្យទម្លាក់ក្រសែភ្នែករបស់ពួកគេចុះ(ពីការសម្លឹងមើលទៅកាន់អ្វីដែលច្បាប់មិនអនុញ្ញាត) ហើយចូរឱ្យពួកគេថែរក្សាប្រដាប់ភេទរបស់ខ្លួន(ពីអំពើហ្ស៊ីណា)។ នោះគឺជាការស្អាតស្អំបំផុតសម្រាប់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

31. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់បណ្តាអ្នកមានជំនឿជាស្ត្រីឲ្យពួកនាងទម្លាក់ក្រសែភ្នែកចុះ(ពីការសម្លឹងមើលទៅកាន់ប្រការដែលច្បាប់ហាមឃាត់) ហើយចូរឲ្យពួកនាងថែរក្សាប្រដាប់កេទរបស់ខ្លួន(ពីអំពើហ្ស៊ីណា)។ ហើយចូរកុំឲ្យពួកនាងបង្ហាញការតុបតែង(សម្រស់)របស់ខ្លួន លើកលែងតែអ្វី(សម្លៀកបំពាក់)ដែលស្តែងចេញជាធម្មតា។ ហើយចូរឲ្យពួកនាងយកស្បៃគ្របឲ្យបានជិតនៅបរិវេណដើមទ្រូង និងករបស់ពួកនាង។ ហើយពួកនាងមិនត្រូវបង្ហាញសម្រស់របស់ពួកនាងនោះឡើយ លើកលែងតែចំពោះប្តីរបស់ពួកនាង ឪពុករបស់ពួកនាង ឪពុកក្មេករបស់ពួកនាង កូនប្រុសទាំងឡាយរបស់ពួកនាង កូនប្រុសប្តីរបស់ពួកនាង(កូនចុង) បងប្អូនប្រុសបង្កើតរបស់ពួកនាង កូនប្រុសៗនៃបងប្អូនប្រុសបង្កើតរបស់ពួកនាង កូនប្រុសៗនៃបងប្អូនស្រីបង្កើតរបស់ពួកនាង(ក្មួយប្រុសបង្កើត) ស្ត្រីគ្នាឯង ឬក៏ខ្ញុំបម្រើដាច់ថ្លៃរបស់ពួកនាង និងអ្នកបម្រើប្រុសៗដែលគ្មានតណ្ហាចំពោះស្ត្រី ព្រមទាំងក្មេងតូចៗដែលពុំទាន់ដឹងពីកេរខ្មាសរបស់ស្ត្រី។ ហើយចូរកុំឲ្យពួកនាងដើរទន្ទ្រាំជើងរបស់ពួកនាងក្នុងគោលបំណងឲ្យគេដឹងនូវអ្វីដែលពួកនាងលាក់បាំងអំពីការតុបតែងរបស់ពួកនាង។ ហើយចូរពួកអ្នកសារភាពកំហុសចំពោះអល់ឡោះទាំងអស់គ្នាចុះ ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

32. ហើយចូរពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)រៀបការឱ្យអ្នកដែលនៅលីវក្នុងចំណោមពួកអ្នក(ដែលជាអ្នកមានសេរីភាព)និងខ្ញុំបម្រើដាច់ថ្លៃរបស់ពួកអ្នកទាំងប្រុស ទាំងស្រីដែលជាមនុស្សល្អ។ ប្រសិនបើពួកគេជាអ្នកក្រខ្សត់នោះ អល់ឡោះជាម្ចាស់នឹងផ្តល់ភាពមានបានដល់ពួកគេដោយក្តីសប្បុរសរបស់ទ្រង់។ ហើយអល់ឡោះជាម្ចាស់មហាវិសេសវិសាល និងដឹងបំផុត។

33. ហើយចូរឱ្យអ្នកដែលគ្មានលទ្ធភាពរៀបការរក្សាខ្លួនឲ្យបរិសុទ្ធ រហូតទាល់តែអល់ឡោះទ្រង់ផ្តល់ភាពមានបានដល់ពួកគេដោយការប្រោសប្រទានរបស់ទ្រង់។ ហើយចំពោះខ្ញុំបម្រើដាច់ថ្លៃរបស់ពួកអ្នកដែលស្វែងរកកិច្ចសន្យាលោះខ្លួន(ឱ្យមានសិទ្ធិសេរីភាព) ចូរពួកអ្នក(ចៅហ្វាយនាយ)ទទួលយកនូវការស្នើសុំរបស់ពួកគេ ប្រសិនបើពួកអ្នកបានដឹងថា ពួកគេមានភាពល្អប្រសើរ។ ហើយចូរពួកអ្នកផ្តល់ឲ្យពួកគេនូវទ្រព្យសម្បត្តិខ្លះដែលអល់ឡោះបានប្រទានដល់ពួកអ្នក។ ហើយពួកអ្នកមិនត្រូវបង្ខំស្រីបម្រើដាច់ថ្លៃរបស់ពួកអ្នកឱ្យប្រព្រឹត្តពេស្យាដើម្បីស្វែងរកទ្រព្យសម្បត្តិលោកិយ(ឲ្យពួកអ្នក)នោះឡើយ ប្រសិនបើពួកនាងមានបំណងចង់រក្សាខ្លួនឲ្យបរិសុទ្ធនោះ។ ហើយជនណាដែលបង្ខិតបង្ខំពួកនាង ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុតចំពោះពួកនាងបន្ទាប់ពីពួកនាងត្រូវបានគេបង្ខិតបង្ខំ។

34. ហើយជាការពិតណាស់ យើងបានបញ្ចុះទៅកាន់ពួកអ្នក(ឱមនុស្សលោក)នូវបណ្តាវាក្យខណ្ឌជាច្រើនដ៏ច្បាស់លាស់ និងរឿងរ៉ាវនៃអ្នកជំនាន់មុនពួកអ្នកដែលបានកន្លងផុត ព្រមទាំងជាដំបូន្មានសម្រាប់បណ្តាអ្នកដែលកោតខ្លាច។

35. អល់ឡោះជាម្ចាស់ ទ្រង់ជាពន្លឺនៃមេឃជាច្រើនជាន់និងផែនដី។ ពន្លឺរបស់ទ្រង់ ប្រៀបដូចជាប្រឡោះនៅនឹងជញ្ជាំងមួយ ហើយនៅក្នុងនោះ គឺមានចង្កៀង។ ចង្កៀងនោះស្ថិតក្នុងកញ្ចក់។ កញ្ចក់នោះប្រៀបដូចជាដួងតារាដែលបញ្ចេញពន្លឺចែងចាំងដូចគុជខ្សាច់ដែលត្រូវបានអុជបញ្ឆេះដោយប្រេងនៃដើមឈើដ៏មានពរជ័យ ពោលគឺដើមអូលីវ ជាដើមឈើមួយដែលគ្មានអ្វីបាំងវាពីពន្លឺថ្ងៃឡើយ មិនថាពេលថ្ងៃរះ ឬពេលថ្ងៃលិចនោះទេ។ ប្រេងរបស់វាស្ទើរតែមានពន្លឺទៅហើយ បើទោះជាគេពុំទាន់អុជភ្លើងវាក៏ដោយ។ ពន្លឺត្រួតលើពន្លឺ។ អល់ឡោះជាម្ចាស់ទ្រង់ចង្អុលបង្ហាញទៅកាន់ពន្លឺរបស់ទ្រង់(គម្ពីរគួរអាន)ចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះទ្រង់លើកជាឧទាហរណ៍ជាច្រើនសម្រាប់មនុស្សលោក។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

36. (ចង្កៀងនេះត្រូវបានគេអុជបំភ្លឺ)នៅក្នុងបណ្តាគេហដ្ឋាន(ម៉ាស្ជិត)ដែលអល់ឡោះបង្គាប់ប្រើឲ្យលើកតម្កើង និងរំឭកព្រះនាមរបស់ទ្រង់នៅក្នុងវាដោយគេប្រតិបត្តិសឡាតនៅក្នុងវាទាំងពេលព្រឹក និងពេលល្ងាច។

37. បុរសៗ(ដែលលើកតម្កើងទ្រង់ទាំងនោះ)ការធ្វើជំនួញ និងការលក់ដូរមិនអាចធ្វើឱ្យពួកគេភ្លេចពីការរំឭកចំពោះអល់ឡោះ និងប្រតិបត្តិសឡាត ហើយនិងបរិច្ចាគហ្សាកាត់នោះឡើយ។ ពួកគេភ័យខ្លាចថ្ងៃមួយដែលដួងចិត្ត និងកែវភ្នែកត្រូវក្រឡាប់ចាក់(ថ្ងៃបរលោក)។

38. ដើម្បីអល់ឡោះទ្រង់តបស្នងដល់ពួកគេយ៉ាងល្អបំផុតនូវអ្វីដែលពួកគេបានសាង ហើយទ្រង់នឹងបន្ថែមឱ្យពួកគេ(លើសពីនេះទៀត)ដោយការប្រោសប្រទានរបស់ទ្រង់។ ហើយអល់ឡោះទ្រង់ប្រទានលាភសក្ការៈដល់ជនណាដែលទ្រង់មានចេតនាដោយឥតគណនាឡើយ។

39. រីឯពួកដែលគ្មានជំនឿវិញ ទង្វើរបស់ពួកគេ ប្រៀបដូចជាការបំភាន់ភ្នែកនៅទីវាលមួយដែលអ្នកស្រេកទឹកគិតថា វាជាទឹក។ លុះនៅពេលដែលគេទៅដល់កន្លែងនោះ គឺគេពុំឃើញមានអ្វីនៅទីនោះឡើយ។ ហើយ(ពួកគ្មានជំនឿវិញ)គេនឹងប្រទះឃើញអល់ឡោះជាម្ចាស់នៅនឹងមុខគេ(នៅថ្ងៃបរលោក)។ ពេលនោះ ទ្រង់នឹងផ្តល់ឱ្យគេនូវការជំនុំជម្រះរបស់គេយ៉ាងពេញលេញ។ ហើយអល់ឡោះទ្រង់ជាអ្នកកាត់សេចក្តីយ៉ាងឆាប់រហ័សបំផុត។

40. ឬក៏(ទង្វើរបស់ពួកគេ)ប្រៀបបានទៅនឹងភាពងងឹតនៅក្នុងបាតសមុទ្រដ៏ជ្រៅមួយដែលមានរលកធំៗគ្របដណ្តប់ពីលើវាផ្នែនៗ ព្រមទាំងមានពពកខ្មៅ(ដ៏ធំមួយ)គ្របលើរលកនោះទៀត។ គឺភាពងងឹតត្រូវត្រួតពីលើគ្នាទៅវិញទៅមក។ នៅពេលដែលគេដកដៃរបស់គេចេញ គេស្ទើរតែមិនអាចមើលវាឃើញ។ ហើយជនណាដែលអល់ឡោះមិនផ្តល់ឱ្យគេនូវពន្លឺទេនោះ ជាការពិតណាស់ គឺគ្មានពន្លឺសម្រាប់គេនោះឡើយ។

41. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ត្រូវបានអ្នកដែលនៅលើមេឃជាច្រើនជាន់និងផែនដី ព្រមទាំងពពួកបក្សីដែលត្រដាងស្លាបទាំងគូរបស់វា សុទ្ធតែលើកតម្កើងចំពោះទ្រង់នោះ? រាល់ភាវៈទាំងនោះ គឺទ្រង់បានដឹងនូវការសឡាត និងការលើកតម្កើងរបស់វា(ចំពោះទ្រង់)។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។

42. ហើយការគ្រប់គ្រងមេឃជាច្រើនជាន់ និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហើយកន្លែងវិលត្រឡប់(នៅថ្ងៃបរលោក)គឺឆ្ពោះទៅកាន់អល់ឡោះ(តែមួយគត់)។

43. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ធ្វើឱ្យពពកសាត់។ ក្រោយមក ទ្រង់បានប្រមូលផ្តុំវារួចមក ទ្រង់បានធ្វើឱ្យវាគរលើគ្នា។ ពេលនោះ អ្នកនឹងឃើញទឹកភ្លៀងចេញពីចន្លោះដុំពពកនោះ។ ហើយទ្រង់បានបញ្ចុះពីលើមេឃចេញពីដុំពពកដ៏ក្រាស់ឃ្មឹកដែលប្រៀបដូចជាភ្នំនោះនូវព្រិលដោយវាត្រូវទៅលើជនណាដែលទ្រង់មានចេតនា និងបញ្ជៀសវាចេញអំពីជនណាដែលទ្រង់មានចេតនា។ ពន្លឺនៃផ្លេកបន្ទោរស្ទើរតែឆក់យកក្រសែភ្នែកទៅហើយ។

44. អល់ឡោះទ្រង់ផ្លាស់ប្តូរវេនពេលយប់និងពេលថ្ងៃ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាមេរៀនមួយសម្រាប់អ្នកដែលមានការឈ្វេងយល់។

45. ហើយអល់ឡោះទ្រង់បង្កើតរាល់សត្វលោកទាំងអស់អំពីទឹក។ ក្នុងចំណោមពួកវា មានសត្វខ្លះលូននឹងពោះរបស់វា ខ្លះទៀតដើរដោយជើងពីរ ហើយខ្លះទៀតដើរដោយជើងបួន។ អល់ឡោះទ្រង់បង្កើតនូវអ្វីដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

46. ជាការពិតណាស់ យើងបានបញ្ចុះនូវសញ្ញាកស្តែងជាច្រើនដ៏ច្បាស់លាស់។ ហើយអល់ឡោះទ្រង់ចង្អុលបង្ហាញជនណាដែលទ្រង់មានចេតនាទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

47. ហើយពួកគេ(ពួកពុតត្បុត)បាននិយាយថា៖ ពួកយើងមានជំនឿលើអល់ឡោះនិងអ្នកនាំសារ(របស់ទ្រង់)ហើយពួកយើងប្រតិបត្តិតាមហើយ។ បន្ទាប់មក មួយក្រុមក្នុងចំណោមពួកគេបែរងាកចេញក្រោយពីនោះទៅវិញ។ ហើយពួកទាំងនោះ គឺពុំមែនជាអ្នកដែលមានជំនឿឡើយ។

48. ហើយនៅពេលដែលមានគេអំពាវនាវពួកទាំងនោះទៅកាន់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដើម្បីកាត់សេចក្តីរវាងពួកគេ ស្រាប់តែមួយក្រុមក្នុងចំណោមពួកគេបែរជោងាកចេញទៅវិញ។

49. តែប្រសិនបើ(ពួកគេបានដឹងថា)ភាពត្រឹមត្រូវ គឺសម្រាប់ពួកគេ នោះពួកគេពិតជានាំគ្នាមកកាន់គាត់(ព្យាការីមូហាំម៉ាត់)ដោយការគោរពជាមិនខាន។

50. តើក្នុងចិត្តរបស់ពួកគេមានជំងឺ ឬក៏ពួកគេមានការសង្ស័យ ឬក៏ពួកគេមានការបារម្ភខ្លាចអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់មានភាពអយុត្តិធម៌ចំពោះពួកគេ? ផ្ទុយទៅវិញ ពួកទាំងនោះ ពួកគេជាពួកដែលបំពាន។

51. តាមពិត ពាក្យសម្តីរបស់បណ្តាអ្នកមានជំនឿនៅពេលដែលគេអំពាវនាវពួកគេទៅកាន់អល់ឡោះ និងទៅកាន់អ្នកនាំសាររបស់ទ្រង់ដើម្បីកាត់សេចក្តីរវាងពួកគេនោះ គឺពួកគេឆ្លើយថា៖ ពួកយើងបានឮហើយ និងបានគោរពប្រតិបត្តិតាមហើយ។ អ្នកទាំងនោះ ពួកគេគឺជាអ្នកដែលទទួលជោគជ័យ។

52. ហើយជនណាដែលប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយខ្លាចអល់ឡោះ ព្រមទាំងកោតខ្លាចទ្រង់ ជាការពិតណាស់ អ្នកទាំងនោះហើយ ពួកគេគឺជាអ្នកដែលទទួលជោគជ័យ។

53. ហើយពួកគេ(ពួកពុតត្បុត)បានស្បថនឹងអល់ឡោះនូវការស្បថយ៉ាងម៉ឺងម៉ាត់ថា៖ ប្រសិនបើអ្នក(ព្យាការីមូហាំម៉ាត់)បញ្ជាពួកគេ(ឱ្យចេញប្រយុទ្ធ)ពួកគេប្រាកដជានឹងចេញ(ទៅប្រយុទ្ធ)ជាមិនខាន។ ចូរអ្នកពោលថា៖ ពួកអ្នកពុំចាំបាច់ស្បថនោះទេ។ ការគោរពប្រតិបត្តិរបស់ពួកអ្នក ត្រូវគេបានដឹងហើយ។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

54. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ(របស់ទ្រង់)។ តែប្រសិនបើពួកអ្នកបែរចេញ តាមពិត គាត់(អ្នកនាំសារ)ទទួលខុសត្រូវនូវអ្វីដែលជាបន្ទុក(តួនាទី)របស់គាត់ ហើយពួកអ្នកវិញ គឺត្រូវទទួលខុសត្រូវនូវអ្វីដែលជាបន្ទុក(តួនាទី)របស់ពួកអ្នក។ ហើយប្រសិនបើពួកអ្នកគោរពប្រតិបត្តិតាមគាត់(ព្យាការីមូហាំម៉ាត់)នោះពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញ។ ហើយកាតព្វកិច្ចរបស់អ្នកនាំសារ គឺគ្មានអ្វីក្រៅពីការផ្សព្វផ្សាយ(សារ)ដ៏ច្បាស់លាស់នោះឡើយ។

55. អល់ឡោះជាម្ចាស់ទ្រង់បានសន្យាចំពោះបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលក្នុងចំណោមពួកអ្នកថា ទ្រង់ប្រាកដជានឹងឱ្យពួកគេក្លាយជាអ្នកគ្រប់គ្រងនៅលើផែនដី ដូចដែលទ្រង់ធ្លាប់បានផ្តល់ឱ្យអ្នក(មានជំនឿ)ជំនាន់មុនពួកគេគ្រប់គ្រង។ ហើយទ្រង់នឹងធ្វើឱ្យសាសនារបស់ពួកគេដែលទ្រង់ពេញចិត្ត(ឱ្យពួកគេទទួលយកធ្វើជាសាសនា)នោះមានភាពរឹងមាំ។ ហើយទ្រង់ប្រាកដជានឹងជំនួសឱ្យពួកគេវិញនូវសុខសន្តិភាពបន្ទាប់ពី(ពួកគេទទួលនូវ)ការភ័យខ្លាច(នៅពេលដែល)ពួកគេគោរពសក្ការៈមកចំពោះយើង(តែមួយគត់)ដោយពួកគេមិនធ្វើស្លឹរកែមកចំពោះយើងនូវប្រការណាមួយ។ ជនណាហើយដែលបានប្រឆាំងបន្ទាប់ពីនោះ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលប្រព្រឹត្តល្មើស។

56. ហើយចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយចូរប្រតិបត្តិតាមអ្នកនាំសារ(មូហាំម៉ាត់)សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រឡាញ់។

57. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំគិតស្មានថា៖ ពួកដែលគ្មានជំនឿអាចរត់គេច(ពីទណ្ឌកម្មរបស់អល់ឡោះ)នៅលើផែនដីបានឱ្យសោះ។ ហើយកន្លែងជ្រកកោនរបស់ពួកគេ គឺឋាននរកហើយវាពិតជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

58. ឱបណ្តាអ្នកដែលមានជំនឿ! ចូរឱ្យខ្ញុំបម្រើដាច់ថ្លៃដែលនៅក្រោមការគ្រប់គ្រងរបស់ពួកអ្នក និងកូនក្មេងដែលមិនទាន់ពេញវ័យក្នុងចំណោមពួកអ្នកសុំការអនុញ្ញាតពីពួកអ្នកនៅក្នុងពេលវេលាទាំងបីនេះ (មុននឹងពួកគេចូលទៅរកពួកអ្នក) គឺមុនពេលសឡាតស៊ូពុស នៅពេលថ្ងៃត្រង់ខណៈដែលពួកអ្នកដោះសម្លៀកបំពាក់របស់ពួកអ្នក និងក្រោយពេលសឡាតអ៊ីស្ហា។ (ពេលវេលា) ទាំងបីនេះ គឺជាកេរខ្មាសរបស់ពួកអ្នក។ គ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នកនិងចំពោះពួកគេចំពោះពេលវេលាផ្សេងក្រៅពីនេះ ដែលពួកអ្នកតែងចេញចូលរកគ្នាទៅវិញទៅមក។ ក៏ដូច្នោះដែរ អល់ឡោះទ្រង់បានបញ្ជាក់ដល់ពួកអ្នកនូវក្បួនច្បាប់ទាំងឡាយ (របស់ទ្រង់)។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

59. ហើយនៅពេលដែលក្មេងតូចៗនៃពួកអ្នកធំពេញវ័យហើយនោះ ចូរឱ្យពួកគេសុំការអនុញ្ញាត ដូចអ្នក (ដែលធំពេញវ័យ) មុនពួកគេសុំការអនុញ្ញាតដែរ។ ដូច្នោះដែរ អល់ឡោះជាម្ចាស់ទ្រង់បញ្ជាក់នូវបណ្តាវាក្យខណ្ឌរបស់ទ្រង់ដល់ពួកអ្នក។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិតបំផុត។

60. ហើយចំពោះស្ត្រីវ័យចំណាស់ដែលអស់ចំណង់ក្នុងការរៀបការនោះ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះពួកនាងក្នុងការដោះសម្លៀកបំពាក់ខាងក្រៅរបស់ពួកនាងដោយមិនបង្ហាញឱ្យឃើញនូវការតុបតែង (សម្រស់របស់ពួកនាង)។ តែការរក្សាភាពបរិសុទ្ធ (បិទបាំងរាងកាយឲ្យបានជិត) គឺជាការប្រសើរសម្រាប់ពួកនាង។ ហើយអល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

61. គ្មានទោសពៃរ៍អ្វីឡើយចំពោះអ្នកដែលពិការភ្នែក អ្នកដែលពិការជើង ហើយនិងអ្នកជំងឺ (ចំពោះការបោះបង់នូវកាតព្វកិច្ចមួយចំនួនដែលពួកគេគ្មានលទ្ធភាពធ្វើ)។ ហើយក៏គ្មានទោសពៃរ៍អ្វីដែរចំពោះពួកអ្នក (ឱបណ្តាអ្នកដែលមានជំនឿ) ក្នុងការទទួលទានអាហារពីក្នុងផ្ទះរបស់ពួកអ្នកផ្ទាល់ ឬផ្ទះឪពុករបស់ពួកអ្នក ឬផ្ទះម្តាយរបស់ពួកអ្នក ឬផ្ទះបងប្អូនប្រុសរបស់ពួកអ្នក ឬផ្ទះបងប្អូនស្រីរបស់ពួកអ្នក ឬផ្ទះឪពុកមាខាងឪពុករបស់ពួកអ្នក ឬផ្ទះម្តាយមីងខាងឪពុករបស់ពួកអ្នក ឬផ្ទះឪពុកមាខាងម្តាយរបស់ពួកអ្នក ឬផ្ទះម្តាយមីងខាងម្តាយរបស់ពួកអ្នក ឬផ្ទះទាំងឡាយដែលពួកអ្នកមានតួនាទីគ្រប់គ្រង ឬក៏ផ្ទះមិត្តភក្តិ (ជិតស្និទ្ធ) របស់ពួកអ្នក។ គ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នកក្នុងការទទួលទានអាហារ (ពីក្នុងផ្ទះទាំងនោះ) ជាលក្ខណៈជុំគ្នា ឬរៀងៗខ្លួន។ នៅពេលដែលពួកអ្នកចូលក្នុងផ្ទះណាមួយ (ចូរពួកអ្នកឲ្យសាឡាមចំពោះគ្នាទៅវិញទៅមក។ តែប្រសិនបើពុំមាននរណាម្នាក់នៅក្នុងផ្ទះទេនោះ) ចូរពួកអ្នកឱ្យសាឡាមចំពោះខ្លួនឯង ជាការស្វាគមន៍ដែលមានពរជ័យដ៏ប្រសើរពីអល់ឡោះជាម្ចាស់។ ក៏ដូច្នោះដែរ អល់ឡោះជាម្ចាស់ទ្រង់បញ្ជាក់នូវបណ្តាវាក្យខណ្ឌទាំងឡាយ (របស់ទ្រង់) សង្ឃឹមថាពួកអ្នកនឹងចេះគិតពិចារណា។

62. តាមពិត អ្នកដែលមានជំនឿ (យ៉ាងពិតប្រាកដ) គឺបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ ហើយនៅពេលដែលពួកគេស្ថិតនៅជាមួយគាត់ (អ្នកនាំសារ) នៅក្នុងកិច្ចប្រជុំណាមួយ គឺពួកគេមិនចាកចេញ (ពីអង្គប្រជុំ) ឡើយ លុះត្រាតែពួកគេសុំការអនុញ្ញាតពីគាត់ (ជាមុនសិន)។ ពិតប្រាកដណាស់ បណ្តាអ្នកដែលសុំការអនុញ្ញាតពីអ្នក អ្នកទាំងនោះហើយគឺជាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ (ដ៏ពិតប្រាកដ)។ ដូច្នេះ ប្រសិនបើពួកគេសុំការអនុញ្ញាតពីអ្នកចំពោះកិច្ចការមួយចំនួនរបស់ពួកគេ ចូរអ្នកអនុញ្ញាតឱ្យ (ចាកចេញ) ចំពោះជនណាដែលអ្នកចង់ក្នុងចំណោមពួកគេ ហើយចូរអ្នកសុំការអភ័យទោសពីអល់ឡោះដល់ពួកគេផង។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

63. ចូរពួកអ្នក (ឱបណ្តាអ្នកដែលមានជំនឿ) កុំហៅអ្នកនាំសាររវាងពួកអ្នក (ចំៗឈ្មោះ) ដូចដែលពួកអ្នកហៅគ្នាទៅវិញទៅមកឱ្យសោះ។ ជាការពិតណាស់ អល់ឡោះទ្រង់ដឹងចំពោះពួកដែលលួចចេញ (ពីការប្រជុំរបស់អ្នកនាំសារ) ដោយស្ងាត់ៗនៅក្នុងចំណោមពួកអ្នក (ដោយគ្មានការអនុញ្ញាត)។ ដូច្នេះ ចូរឱ្យពួកដែលធ្វើផ្ទុយនឹងបទបញ្ជារបស់គាត់ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្នដែលនឹងធ្លាក់លើពួកគេ ឬក៏ទណ្ឌកម្មដ៏ឈឺចាប់ធ្លាក់លើពួកគេ។

64. តើពុំមែនទេឬ ពិតប្រាកដណាស់ អ្វីៗដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ (តែមួយគត់) នោះ? ទ្រង់ពិតជាដឹងពីស្ថានភាពរបស់ពួកអ្នក។ ហើយនៅថ្ងៃដែលពួកគេត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ ពេលនោះ ទ្រង់នឹងប្រាប់ពួកគេពីអ្វីដែលពួកគេបានប្រព្រឹត្ត (ក្នុងលោកិយ)។ ហើយអល់ឡោះមហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

ជំពូក អាល់ហ្វរកន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. មហាពរជ័យ(អល់ឡោះជាម្ចាស់)ដែលទ្រង់បានបញ្ចុះនូវគម្ពីរគួរអានទៅកាន់ខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ដើម្បីឲ្យគាត់ក្លាយជាអ្នកដាស់តឿនព្រមានសម្រាប់ពិភពលោក។

2. ជាអ្នកដែលការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយទ្រង់គ្មានបុត្រ និងគ្មានដៃគូរួមជាមួយទ្រង់នៅក្នុងការគ្រប់គ្រងឡើយ។ ហើយទ្រង់បានបង្កើតអ្វីៗទាំងអស់ដោយទ្រង់បានកំណត់(ក្រឹត្យក្រមរបស់វា)យ៉ាងជាក់លាក់។

3. តែពួកគេបានយកអ្នកផ្សេងក្រៅពីទ្រង់ធ្វើជាព្រះដែលពួកវាមិនអាចបង្កើតអ្វីមួយទាល់តែសោះ តែពួកវាទៅវិញទេដែលត្រូវបានគេបង្កើតនោះ។ ហើយពួកវាគ្មានសមត្ថភាពអាចការពារពីគ្រោះថ្នាក់ ឬផ្តល់ផលប្រយោជន៍ដល់ខ្លួនឯងឡើយ។ ពួកវាគ្មានសមត្ថភាពផ្តល់សេចក្តីស្លាប់ មិនអាចផ្តល់ជីវិត ហើយក៏គ្មានសមត្ថភាពក្នុងការបង្កើតឲ្យរស់សាជាថ្មីនោះដែរ។

4. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ (គម្ពីរគួរអាន)នេះ គ្មានអ្វីក្រៅពីការភូតកុហកដែលគេ(ព្យាការីមូហាំម៉ាត់)បានប្រឌិតវាឡើងនោះឡើយ ហើយមានក្រុមមួយផ្សេងទៀតជួយដល់គេប៉ុណ្ណោះ។ ជាការពិតណាស់ ពួកទាំងនោះបាននាំមកនូវការបំពាន និងពាក្យកុតកុហក។

5. ហើយពួកគេនិយាយទៀតថា៖ (គម្ពីរគួរអាន)ជារឿងព្រេងនិទានរបស់មនុស្សជំនាន់មុនប៉ុណ្ណោះ ដោយគាត់(ព្យាការីមូហាំម៉ាត់)បានចម្លងវា ហើយវាត្រូវបានគេសូត្រឱ្យគាត់ស្តាប់ទាំងព្រឹក ទាំងល្ងាច។

6. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ អ្នកដែលបញ្ចុះវាមក គឺជាអ្នកដែលដឹងបំផុតនូវរឿងអាថ៌កំបាំងដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី។ ពិតប្រាកដណាស់ ទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

7. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ ហេតុអ្វីបានជាអ្នកនាំសារ(របស់អល់ឡោះ)រូបនេះ ចេះទទួលទានអាហារ និងចេះដើរផ្សារ(ដូចពួកយើងដែរ)ទៅវិញ? ហេតុអ្វីបានជាគេមិនបញ្ចុះម៉ាឡាអ៊ីកាត់ម្នាក់មកគាត់ដើម្បីឱ្យម៉ាឡាអ៊ីកាត់នោះក្លាយជាអ្នកដាស់តឿនព្រមានជាមួយគាត់ទៅ?

8. ឬក៏បញ្ចុះឱ្យគាត់នូវកំណប់ ឬក៏ផ្តល់ឱ្យគាត់មានចម្ការដែលអាចឱ្យគាត់ទទួលទានពីវា? ហើយពួកដែលបំពានបាននិយាយថា៖ ពួកអ្នក(អ្នកមានជំនឿ)មិនបានដើរតាមអ្វី ក្រៅពីបុរសម្នាក់ដែលត្រូវមន្តអាគមគេនោះឡើយ។

9. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិចារណាមើលចុះ ថាតើពួកគេបានលើកឧទាហរណ៍ចំពោះអ្នកយ៉ាងដូចម្តេច? ដូច្នេះពួកគេបានវង្វេងដោយពួកគេមិនអាចដើរនៅលើមាគ៌ា(ត្រឹមត្រូវ)នោះឡើយ។

10. ទ្រង់មហាមានពរជ័យដែលប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងធ្វើឱ្យអ្នក(ព្យាការីមូហាំម៉ាត់)មាននូវអ្វីដែលល្អប្រសើរជាងនោះទៅទៀត គឺសួនដំណាំនានាដែលមានទន្លេជាច្រើនហូរកោត់ពីក្រោមវា ហើយទ្រង់នឹងបង្កើតឱ្យអ្នកមាននូវវិមាន(ដ៏ស្តីមស្តែ)ផងដែរ។

11. ផ្ទុយទៅវិញ ពួកគេបានបដិសេធនឹងថ្ងៃបរលោក។ ហើយយើងបានត្រៀមទុកសម្រាប់ជនដែលបដិសេធនឹងថ្ងៃបរលោកនូវភ្លើង(នរក)ដែលឆាបឆេះយ៉ាងសន្ធោសន្ធៅ។

12. នៅពេលដែលនរកបានឃើញពួកគេ(ពួកប្រឆាំង)ពីកន្លែងដ៏ឆ្ងាយ ពួកគេនឹងឮសំឡេងខឹងសម្បា និងសំឡេងគ្រហឹមយ៉ាងខ្លាំងពីនរកនោះជាមិនខាន។

13. ហើយនៅពេលដែលគេបោះពួកទាំងនោះទៅក្នុងកន្លែងដ៏ចង្អៀត(នៃឋាននរក)ដោយដៃរបស់ពួកគេត្រូវបានចងភ្ជាប់ទៅនឹងក(ដោយច្រវាក់) ពួកគេក៏បួងសួងឱ្យខ្លួនឯងវិនាសអន្តរាយ។

14. (មានគេនិយាយថា៖)នៅថ្ងៃនេះ ចូរពួកអ្នកកុំបួងសួងឱ្យខ្លួនឯងវិនាសអន្តរាយតែមួយដង។ តែពួកអ្នកត្រូវបួងសួងសុំ(ឱ្យខ្លួនឯងវិនាស)ឱ្យបានច្រើនដង(ទើបត្រូវ)។

15. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើ(ទណ្ឌកម្ម)ទាំងនោះល្អប្រសើរជាង ឬក៏ឋានសួគ៌ដ៏អមតៈដែលគេបានសន្យាចំពោះអ្នកដែលកោតខ្លាច(អល់ឡោះ)នោះប្រសើរជាង ? វាជាការតបស្នង និងជាកន្លែងវិលត្រឡប់សម្រាប់ពួកគេ(អ្នកមានជំនឿ)។

16. នៅក្នុងឋានសួគ៌នោះ ពួកគេនឹងទទួលបាននូវអ្វីដែលពួកគេប្រាថ្នាជារៀងរហូត។ ហើយការសន្យារបស់ព្រះជាម្ចាស់អ្នក គឺនឹងកើតឡើងយ៉ាងពិតប្រាកដ។

17. ហើយនៅថ្ងៃដែលទ្រង់ប្រមូលផ្តុំពួកគេ(ពួកមុស្លីគីន) និងអ្វីដែលពួកគេគោរពសក្ការៈផ្សេងពីអល់ឡោះ ពេលនោះទ្រង់នឹងសួរទៅកាន់ពួកវា(ព្រះនានា)ថា៖ តើពួកឯងឬដែលបានធ្វើឱ្យខ្ញុំបម្រើរបស់យើងវង្វេង ឬមួយពួកគេបានវង្វេងចេញពីមាគ៌ា(ដ៏ត្រឹមត្រូវដោយខ្លួនឯង)?

18. ពួកវាបានឆ្លើយថា៖ ព្រះអង្គមហាស្អាតស្អំ។ មិនសក្តិសមឡើយចំពោះពួកយើងដែលយកអ្នកផ្សេងក្រៅពីព្រះអង្គធ្វើជាអ្នកគាំពារ។ ក៏ប៉ុន្តែ ព្រះអង្គបានផ្តល់ភាពសោយសុខដល់ពួកគេ និងជីដូនជីតារបស់ពួកគេ រហូតដល់ពួកគេបានភ្លេចនូវការរំឭក(ចំពោះព្រះអង្គ)។ ហើយពួកគេគឺជាក្រុមដែលវិនាសអន្តរាយ។

19. ជាការពិតណាស់ ពួកវាបានបដិសេធនឹងពួកអ្នក(ពួកមុស្លីគីន)ចំពោះអ្វីដែលពួកអ្នកបាននិយាយ។ ដូច្នេះ ពួកអ្នកមិនអាចការពារខ្លួនពីទណ្ឌកម្ម ហើយក៏មិនអាចជួយដល់ខ្លួនបាននោះដែរ។ ហើយជនណាដែលបំពានក្នុងចំណោមពួកអ្នក យើងនឹងឱ្យគេភ្លក់នូវទណ្ឌកម្មដ៏ធំធេងបំផុត។

20. ហើយយើងមិនដែលបញ្ជូនអ្នកនាំសារណាម្នាក់មុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះឡើយ លើកលែងតែពួកគេចេះទទួលទានអាហារ និងចេះដើរផ្សារ(ដូចគេឯង)នោះឡើយ។ ហើយយើងបានយកពួកអ្នក(ឱមនុស្សលោក)ធ្វើជាការសាកល្បងចំពោះគ្នាទៅវិញទៅមក ថាតើពួកអ្នកចេះអត់ធ្មត់ដែរឬទេ ? ហើយព្រះជាម្ចាស់របស់អ្នកទ្រង់មហាឃើញបំផុត។

21. ហើយពួកដែលមិនរំពឹងថានឹងជួបយើងបាននិយាយថា៖ ហេតុអ្វីបានជាគេ(អល់ឡោះ)មិនបញ្ជូនម៉ាឡាអ៊ីកាត់មកកាន់ពួកយើង ឬឱ្យពួកយើងបានឃើញព្រះជាម្ចាស់របស់ពួកយើង(ផ្ទាល់នឹងភ្នែក)តែម្តងទៅ ? ជាការពិតណាស់ ពួកគេមានភាពក្រអឺតក្រទមនៅក្នុងខ្លួនពួកគេ និងបានបំពានជ្រុលហួសហេតុបំផុត។

22. នៅថ្ងៃដែលពួកគេបានឃើញម៉ាឡាអ៊ីកាត់(ផ្ទាល់នឹងភ្នែក)នៅថ្ងៃនោះ គឺគ្មានដំណឹងកែវាយសម្រាប់ពួកឧក្រិដ្ឋទាំងឡាយឡើយ។ ហើយពួកគេ(ម៉ាឡាអ៊ីកាត់)បានពោលថា៖ (ឋានសួគ៌) ជាទីកន្លែងដែលត្រូវបានគេហាមឃាត់(ចំពោះពួកអ្នក)។

23. ហើយយើងបានត្រឡប់ទៅរកអ្វីដែលពួកគេបានប្រព្រឹត្តអំពីអំពើ(ល្អ)រួចយើងក៏បានធ្វើឱ្យវា(ក្លាយទៅជាអសារបង់)ប្រៀបដូចធូលីដែលរសាត់តាមខ្យល់។

24. នៅថ្ងៃនោះ ក្រុមអ្នកឋានសួគ៌ គឺមានកន្លែងស្នាក់នៅដ៏ល្អប្រសើរ និងមានកន្លែងសម្រាកដ៏ល្អប្រពៃបំផុត។

25. ហើយ(ចូរអ្នករំលឹក)នៅថ្ងៃដែលមេឃនឹងបែកចេញជាមួយនឹងដុំពពក(ដ៏សក្បុស)ហើយម៉ាឡាអ៊ីកាត់ទាំងឡាយត្រូវបានគេបញ្ចុះមកជាបន្តបន្ទាប់។

26. ការគ្រប់គ្រងដ៏ពិតប្រាកដនៅថ្ងៃនោះ គឺជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ដ៏មហាសប្បុរស។ ហើយវាជាថ្ងៃមួយដែលលំបាកជាទីបំផុតចំពោះពួកដែលគ្មានជំនឿ។

27. ហើយ(ចូរអ្នករំលឹក)នៅថ្ងៃដែលអ្នកបំពានខាំដៃទាំងពីររបស់ខ្លួន(ទាំងមានវិប្បដិសារីដោយគេនិយាយថា៖)ឱអនិច្ចាខ្លួនខ្ញុំអើយ! ខ្ញុំគួរតែជ្រើសយកផ្លូវដើរតាមអ្នកនាំសារ(សាសនាអ៊ីស្លាម)។

28. ឱអនិច្ចាខ្លួនខ្ញុំអើយ! មិនគួរណាខ្ញុំយកបុគ្គលម្នាក់នេះ(អ្នកគ្មានជំនឿ)ធ្វើជាមិត្តជិតស្និទ្ធឡើយ។

29. ជាការពិតណាស់ រូបគេបានធ្វើឱ្យខ្ញុំវង្វេងចេញពីគម្ពីរគួរអាន ក្រោយពីវាបានមកដល់ខ្ញុំហើយនោះ។ ហើយស៊ែតន គឺជាអ្នកដែលតែងបោកប្រាស់ចំពោះមនុស្សលោក។

30. ហើយអ្នកនាំសារ(មូហាំម៉ាត់)បាននិយាយថា៖ បពិត្រព្រះជាម្ចាស់! ជាការពិតណាស់ ក្រុមរបស់ខ្ញុំបាននាំគ្នាបោះបង់គម្ពីរគួរអាននេះ។

31. ក៏ដូច្នោះដែរ យើងបានបង្កើតសម្រាប់រាល់ព្យាការីទាំងឡាយនូវសត្រូវដែលស្ថិតក្នុងចំណោមពួកឧក្រិដ្ឋជន។ គ្រប់គ្រាន់ហើយដែលព្រះជាម្ចាស់របស់អ្នកជាអ្នកចង្អុលបង្ហាញ និងជាអ្នកដែលជួយ។

32. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះគម្ពីរគួរអាននេះទៅឱ្យគាត់(អ្នកនាំសារមូហាំម៉ាត់)ទាំងមូលតែម្តងទៅ? ក៏ដូច្នោះដែរ គឺដើម្បីពង្រឹងចិត្តរបស់អ្នក(ឲ្យមានភាពនឹងនរ)។ ហើយយើងបានបញ្ចុះវាម្តងបន្តិចៗ ដើម្បីឱ្យមានភាពងាយស្រួល(ក្នុងការយល់ និងទន្ទេញ)។

33. ហើយពួកគេ(ពួកមុស្លីគឺន)មិនបាននាំមកឲ្យអ្នកនូវឧទាហរណ៍ណាមួយនោះឡើយ លើកលែងតែយើងបាននាំមកឲ្យអ្នកនូវចម្លើយដែលពិតត្រឹមត្រូវ ហើយនិងការបកស្រាយដ៏ប្រសើរបំផុត។

34. ពួកដែលត្រូវគេប្រមូលផ្តុំ(នៅថ្ងៃបរលោក)ដោយអូសផ្កាប់មុខទៅកាន់នរកជើហាន់ណាំ ពួកទាំងនោះ គឺមានកន្លែងដ៏អាក្រក់ហើយឃ្លាតឆ្ងាយពីមាគ៌ា(ដ៏ត្រឹមត្រូវ)បំផុត។

35. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត) ហើយយើងក៏បានតែងតាំងបងប្រុសរបស់គាត់(ព្យាការីហារូន)ដែលនៅជាមួយគាត់នោះជាជំនួយការផងដែរ។

36. ហើយយើងបានមានបន្ទូលថា៖ ចូរអ្នកទាំងពីរធ្វើដំណើរទៅកាន់ក្រុមដែលបដិសេធនឹងបណ្តាកស្តុតាងទាំងឡាយរបស់យើងចុះ។ រួចមក យើងក៏បានបំផ្លាញពួកគេឱ្យវិនាសសាបសូន្យ។

37. ហើយចំពោះក្រុមរបស់ព្យាការីនួហ នៅពេលដែលពួកគេបានបដិសេធនឹងបណ្តាអ្នកនាំសារទាំងឡាយ យើងក៏បានពន្លិចពួកគេ(ក្នុងទឹកជំនន់) ហើយយើងបានយកពួកគេធ្វើជាមេរៀនមួយសម្រាប់មនុស្សលោក។ ហើយយើងបានត្រៀមទុកសម្រាប់ពួកដែលបំពាននូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

38. ហើយ(យើងក៏បានបំផ្លាញ)ក្រុមអាទ ក្រុមសាមូទ និងក្រុមរ៉ែស(ជាក្រុមរបស់ព្យាការីស៊ូអែប)ព្រមទាំងប្រជាជាតិជាច្រើនទៀតនៅរវាងពួកទាំងនោះផងដែរ។

39. ហើយរាល់ៗ(ក្រុមទាំងនោះ) យើងក៏បានលើកនូវឧទាហរណ៍ជាច្រើនបញ្ជាក់ដល់ពួកគេផងដែរ។ ហើយរាល់ៗ(ក្រុមទាំងនោះ)យើងបានបំផ្លាញឱ្យវិនាសសាបសូន្យ។

40. ហើយជាការពិតណាស់ ពួកគេ(ពួកមុស្លីគីន)បានឆ្លងកាត់ភូមិស្រុកមួយ(ក្រុមព្យាការីលូទ)ដែលត្រូវបានបំផ្លាញដោយភ្លៀងដុំថ្ម។ តើពួកគេមិនបានឃើញភូមិស្រុកនោះទេឬ? ផ្ទុយទៅវិញ ពួកគេមិនឆ្លាប់រំពឹងថា នឹងមានការបង្កើតឱ្យរស់ឡើងវិញនោះឡើយ។

41. ហើយនៅពេលដែលពួកគេបានឃើញអ្នក(ព្យាការីមូហាំម៉ាត់) ពួកគេតែងចំអកឱ្យអ្នក(ដោយនិយាយថា៖)តើម្នាក់នេះឬដែលអល់ឡោះបានតែងតាំងជាអ្នកនាំសារនោះ?

42. ជាការពិតណាស់ រូបគេស្ទើរតែធ្វើឱ្យពួកយើងងាកចេញពីព្រះនានារបស់ពួកយើងទៅហើយ ប្រសិនបើពួកយើងមិនអត់ធ្មត់លើ(ការគោរពសក្ការៈចំពោះ)វាទេនោះ។ ពួកទាំងនោះគង់តែនឹងដឹងជាមិនខាន នៅពេលដែលពួកគេបានឃើញទណ្ឌកម្ម(ផ្ទាល់នឹងភ្នែក)ថាតើនរណាដែលវង្វេងជាងគេពីមាគ៌ា(ត្រឹមត្រូវ)នោះ?

43. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញដែរឬទេ អ្នកដែលយកទំនើងចិត្តរបស់ខ្លួនធ្វើជាព្រះនោះ? ដូច្នេះ តើអ្នកជាអ្នកដែលទទួលខុសត្រូវចំពោះរូបគេឬ?

44. ឬមួយអ្នកគិតថា ភាគច្រើននៃពួកគេស្តាប់(ដោយទទួលយក)ឬក៏ចេះត្រិះរិះពិចារណាឬ? ពិតណាស់ ពួកគេគ្មានអ្វីក្រៅពីដូចសត្វធាតុនោះទេ។ ផ្ទុយទៅវិញ ពួកគេវង្វេង(ពីមាគ៌ាត្រឹមត្រូវ)ជាងនោះទៅទៀត។

45. តើអ្នកមិនបានឃើញទេឬ ថាតើព្រះជាម្ចាស់របស់អ្នកទ្រង់បន្លាយស្រមោលយ៉ាងដូចម្តេច? ប្រសិនបើទ្រង់មានចេតនាទ្រង់នឹងឲ្យវានៅនឹងមួយកន្លែងជាមិនខាន។ បន្ទាប់មក យើងបានធ្វើឲ្យព្រះអាទិត្យជាសញ្ញាសម្គាល់របស់វា(ស្រមោល)។

46. បន្ទាប់មក យើងបានដកយកស្រមោលនោះមកកាន់យើងបន្តិចម្តងៗ(អាស្រ័យទៅតាមដំណើរព្រះអាទិត្យ)។

47. ហើយទ្រង់ជាអ្នកដែលបានបង្កើតពេលយប់សម្រាប់ពួកអ្នកជាការបិទបាំង បង្កើតការគេងជាការសម្រាក ហើយទ្រង់បានបង្កើតពេលថ្ងៃដើម្បីជាការស្វែងរកការទ្រទ្រង់ជីវិត។

48. ហើយទ្រង់ជាអ្នកដែលបញ្ជូនខ្យល់ជាដំណឹងល្អ(ថានឹងមានភ្លៀងធ្លាក់)ដែលជាក្តីមេត្តាករុណារបស់ទ្រង់។ ហើយយើងបានបញ្ចុះពីលើមេឃមកនូវទឹកភ្លៀងដ៏ជ្រះស្អាត។

49. ដើម្បីយើងធ្វើឱ្យដីដែលគ្មានជីជាតិមានជីជាតិឡើងវិញតាមរយៈទឹកភ្លៀងនោះ។ ហើយយើងក៏បានផ្តល់វាទៅដល់សត្វពាហនៈ និងមនុស្សរាប់ជាច្រើនដែលយើងបានបង្កើតផងដែរ។

50. ហើយជាការពិតណាស់ យើងបានចាត់ចែងវា(ទឹកភ្លៀង)រវាងពួកគេដើម្បីឱ្យពួកគេយកវាធ្វើជាមេរៀន។ ក៏ប៉ុន្តែមនុស្សរាប់ភាគច្រើន គឺគ្មានអ្វីក្រៅពីការប្រឆាំងនោះឡើយ។

51. ហើយប្រសិនបើយើងមានចេតនា យើងពិតជានឹងបញ្ជូនទៅកាន់ភូមិស្រុកនីមួយៗនូវអ្នកដាស់តឿនព្រមាន(អ្នកនាំសារ)ម្នាក់ជាមិនខាន។

52. ដូច្នេះ ចូរអ្នកកុំគោរពតាមពួកប្រឆាំងឲ្យសោះ តែអ្នកត្រូវតស៊ូជាមួយពួកគេតាមរយៈវា(គម្ពីរគួរអាន)នូវការតស៊ូមួយដ៏ខ្លាំងក្លា។

53. ហើយទ្រង់ជាអ្នកដែលបានធ្វើឱ្យសមុទ្រពីរនៅជាប់គ្នា ដោយមួយជាទឹកសាបឆ្ងាញ់ពិសារ និងមួយទៀតប្រៃល្វីង។ ហើយទ្រង់បានធ្វើឱ្យមានរបាំងមួយដែលខ័ណ្ឌចែករវាងវាទាំងពីរ និងរារាំងវាទាំងពីរ(មិនឱ្យជ្រាបចូលគ្នា)។

54. ហើយទ្រង់ជាអ្នកដែលបានបង្កើតមនុស្សលោកពីទឹកកាម ហើយបានបង្កើតឲ្យគេមានជាសាច់សាលោហិត និងសាច់ថ្លៃ។ ហើយព្រះជាម្ចាស់របស់អ្នក គឺមានអានុភាពបំផុត។

55. តែពួកគេ(ពួកប្រឆាំង)បែរជាគោរពសក្ការៈអ្នកផ្សេងក្រៅពីអល់ឡោះនូវអ្វីដែលមិនអាចផ្តល់ផលប្រយោជន៍ ហើយក៏មិនអាចបង្កគ្រោះថ្នាក់អ្វីសោះដល់ពួកគេទៅវិញ។ ហើយអ្នកប្រឆាំង គឺជាអ្នកដែលជួយ(ស្មៃតន)ប្រឆាំងនឹងព្រះជាម្ចាស់របស់គេ។

56. ហើយយើងមិនបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មកឡើយ លើកលែងតែដើម្បីជាអ្នកផ្តល់ដំណឹងរីករាយ និងជាអ្នកដាស់តឿនព្រមានប៉ុណ្ណោះ។

57. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នង(កម្រៃ)ណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ លើកលែងតែជនណាដែលចង់ប្រកាន់យកនូវមគ៌ាឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់គេប៉ុណ្ណោះ។

58. ហើយចូរអ្នកប្រគល់ការទុកចិត្តទៅលើអ្នកដែលមានជីវិតអមត:គ្មានថ្ងៃស្លាប់ចុះ ហើយអ្នកត្រូវលើកតម្កើងដោយការសរសើរចំពោះទ្រង់។ គ្រប់គ្រាន់ហើយដែលទ្រង់ជាអ្នកដឹងបំផុតចំពោះបាបកម្មនៃខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

59. (ទ្រង់)ជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់ និងផែនដី ព្រមទាំងអ្វីៗដែលនៅចន្លោះវាទាំងពីរក្នុងរយៈពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ទ្រង់នៅលើអារ៉ស្ស។ (ទ្រង់)ជាព្រះជាម្ចាស់ដ៏មហាសប្បុរស។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បួងសួងសុំពីទ្រង់ដែលជាអ្នកមហាដឹងបំផុតនោះចុះ។

60. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេ(ពួកគ្មានជំនឿ)ថា៖ ចូរពួកអ្នកក្រាបស៊ូជោតចំពោះព្រះជាម្ចាស់ដ៏មហាសប្បុរស ពួកគេតបថា៖ តើព្រះជាម្ចាស់ដ៏មហាសប្បុរសនោះជាអ្វី? តើពួកយើងក្រាបស៊ូជោតទៅចំពោះអ្វីដែលអ្នកបានប្រើពួកយើង(ឱស៊ូជោតទៅកាន់)ឬ? ហើយវាបានធ្វើឱ្យពួកគេកាន់តែឃ្លាតឆ្ងាយ(ពីការមានជំនឿ)ថែមទៀត។

61. ទ្រង់មហាមានពរជ័យដែលបានបង្កើតនូវតារានិករជាច្រើននៅលើមេឃ និងបានបង្កើតនៅលើមេឃនោះផងដែរនូវព្រះអាទិត្យ និងព្រះចន្ទដែលបញ្ចេញពន្លឺ(ដែលទទួលបានពីព្រះអាទិត្យ)។

62. ហើយទ្រង់ជាអ្នកដែលបានបង្កើតពេលយប់និងពេលថ្ងៃឲ្យផ្លាស់វេនគ្នា សម្រាប់ជនណាដែលចង់យកធ្វើជាមេរៀន ឬក៏ចង់ដឹងគុណ(ចំពោះអល់ឡោះ)។

63. ហើយបណ្តាខ្ញុំបម្រើនៃព្រះជាម្ចាស់ដ៏មហាសប្បុរសនោះ គឺបណ្តាអ្នកដែលធ្វើដំណើរនៅលើផែនដីដោយឱនលំទោន។ ហើយនៅពេលដែលពួកល្ងង់ខ្លៅនិយាយ(អសុរស)ទៅកាន់ពួកគេ ពួកគេតបទៅវិញដោយពាក្យសម្តីល្អៗ។

64. និងបណ្តាអ្នកដែលចំណាយពេលវេលានៅពេលយប់ដើម្បីស៊ូជោត និងឈរ(ប្រតិបត្តិសឡាត)ចំពោះព្រះជាម្ចាស់របស់ពួកគេ។

65. និងបណ្តាអ្នកដែលបួងសួងសុំថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបញ្ចៀសយើងខ្ញុំពីទណ្ឌកម្មនៃនរកជើហាន់ណាំផងចុះ។ ពិតប្រាកដណាស់ ទណ្ឌកម្មរបស់វា គឺមានជានិរន្តរ៍។

66. ពិតប្រាកដណាស់ វាជាទីលំនៅ និងជាកន្លែងស្នាក់អាស្រ័យដ៏អាក្រក់បំផុត។

67. និងបណ្តាអ្នកដែលនៅពេលណាដែលពួកគេចំណាយទ្រព្យសម្បត្តិ គឺពួកគេមិនខ្ជះខ្ជាយពេក ហើយក៏ត្អិតត្អៀតពេកនោះដែរ។ តែពួកគេចំណាយដោយសមរម្យ។

68. និងបណ្តាអ្នកដែលមិនបួងសួងសុំពីអ្នកផ្សេងរួមជាមួយនឹងអល់ឡោះ ហើយពួកគេមិនសម្លាប់ជីវិតដែលអល់ឡោះទ្រង់ជាក់បម្រាមឡើយ លើកលែងតែដោយមូលហេតុត្រឹមត្រូវ ហើយពួកគេក៏មិនប្រព្រឹត្តអំពើហ្ស៊ីណានោះដែរ។ ក៏ប៉ុន្តែជនណាហើយដែលប្រព្រឹត្តនូវអំពើទាំងនោះ ពួកគេនឹងទទួលនូវបាបកម្ម។

69. រូបគេនឹងត្រូវគេបន្ថែមទណ្ឌកម្មទ្វេដងនៅថ្ងៃបរលោក។ ហើយគេនឹងស្ថិតក្នុងទណ្ឌកម្មដ៏អាម៉ាស់នេះជាអមតៈ។

70. លើកលែងតែជនណាដែលបានសារភាពកំហុស និងមានជំនឿ ហើយបានសាងទង្វើកុសលវិញប៉ុណ្ណោះ។ អ្នកទាំងនោះ គឺអល់ឡោះជាម្ចាស់នឹងផ្លាស់ប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

71. ហើយជនណាដែលបានសារភាពកំហុស និងបានសាងទង្វើកុសល ពិតប្រាដកណាស់ រូបគេបានសារភាពកំហុសចំពោះអល់ឡោះដ៏ត្រឹមត្រូវ។

72. និងបណ្តាអ្នកដែលមិនធ្វើសាក្សីកុហក។ ហើយនៅពេលដែលពួកគេដើរឆ្លងកាត់ក្រុមដែលធ្វើទង្វើឥតប្រយោជន៍ គឺពួកគេឆ្លងកាត់ដោយថ្លៃថ្នូរ(មិនចូលរួមជាមួយពួកគេឡើយ)។

73. និងបណ្តាអ្នកដែលនៅពេលណាដែលមានគេរំឭកពីបណ្តាវាក្យខណ្ឌនៃព្រះជាម្ចាស់របស់ពួកគេ គឺពួកគេមិនធ្វើជាថ្លង់ ធ្វើជាខ្វាក់នោះឡើយ។

74. និងបណ្តាអ្នកដែលបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាប្រទានដល់យើងខ្ញុំនូវភរិយា និងកូនចៅរបស់យើងខ្ញុំដែលជាទីគាប់ចិត្ត(សម្រាប់យើងខ្ញុំ)ផង ហើយសូមព្រះអង្គមេត្តាឲ្យយើងខ្ញុំក្លាយជាអ្នកដឹកនាំសម្រាប់អ្នកដែលកោតខ្លាចផងចុះ។

75. បណ្តាអ្នកទាំងនោះ ពួកគេនឹងត្រូវគេតបស្នងនូវកន្លែងដ៏ខ្ពង់ខ្ពស់បំផុត(ក្នុងឋានសួគ៌)ដោយសារតែអ្វីដែលពួកគេបានអត់ធ្មត់។ ហើយនៅក្នុងនោះ ពួកគេត្រូវបានគេ(ម៉ាឡាអ៊ីកាត់)ទទួលស្វាគមន៍ និងទទួលបាននូវសុវត្ថិភាព។

76. ពួកគេស្ថិតនៅទីនោះជាអមតៈ។ ជាទីលំនៅ និងជាកន្លែងស្នាក់អាស្រ័យដ៏ប្រសើរបំផុត។

77. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ថា៖ ព្រះជាម្ចាស់របស់ខ្ញុំមិនខ្វល់នឹងពួកអ្នកនោះឡើយប្រសិនបើគ្មានការបួងសួងរបស់ពួកអ្នកទេនោះ។ ជាការពិតណាស់ ពួកអ្នកបានបដិសេធ(នឹងអ្នកនាំសារ)។ ដូច្នេះ ទណ្ឌកម្មជានិរន្តរ៍(នឹងធ្លាក់ទៅលើពួកអ្នក)ជាមិនខានឡើយ។

ជំពូក អាស់ស៊ូអារ៉ែក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ត ស៊ីន មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ទាំងនេះជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ដ៏ច្បាស់លាស់។

3. ប្រហែលជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ធ្វើឲ្យខ្លួនឯងអន្តរាយទៅហើយព្រោះតែពួកគេមិនមានជំនឿ។

4. ប្រសិនបើយើងមានចេតនា យើងនឹងបញ្ចុះនូវសញ្ញាកស្តុតាងណាមួយពីលើមេឃទៅកាន់ពួកគេ(ពួកដែលបដិសេធ)ជាមិនខាន។ នៅពេលនោះ ច្បាស់ជាក្បាលរបស់ពួកគេនឹងឱនលំទោនមករកវា(សញ្ញាកស្តុតាងនោះ)ជាដរាបមិនខានឡើយ។

5. ហើយគ្មានការរំឭកថ្មីណាមួយពីព្រះជាម្ចាស់ដ៏មហាសប្បុរសមកដល់ពួកគេ(ពួកមុស្លីគីន)នោះឡើយ លើកលែងតែពួកគេបានងាកចេញអំពីវា។

6. ជាការពិតណាស់ ពួកគេបានបដិសេធ(នឹងគម្ពីរគួរអាន)។ ដូច្នេះ ដំណឹងដែលពួកគេធ្លាប់បានសើចចំអកចំពោះវានោះ ប្រាកដជានឹងមកដល់ពួកគេជាមិនខាន។

7. តើពួកទាំងនោះមិនបានមើលទៅកាន់ផែនដីទេឬ ថាតើយើងបានបណ្តុះនៅលើវានូវរាល់រុក្ខជាតិដ៏ល្អស្រស់បំព្រងប៉ុន្មានប្រភេទ?

8. ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាង(ដ៏ច្បាស់លាស់)។ ក៏ប៉ុន្តែ ពួកគេភាគច្រើនគ្មានជំនឿឡើយ។

9. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

10. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានហៅព្យាការីមូសាថា៖ ចូរអ្នកធ្វើដំណើរទៅកាន់ក្រុមដែលបំពាន។

11. គឺក្រុមរបស់ហ្វៀរអោន។ (ហើយអ្នកត្រូវនិយាយទៅកាន់ពួកគេថា) តើពួកគេមិនកោតខ្លាច(អល់ឡោះ)ទេឬ?

12. គាត់(ព្យាការីមូសា)បានតបថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពួកគេបដិសេធ(ចំពោះខ្ញុំ)។

13. ហើយទ្រូងរបស់ខ្ញុំមានភាពចង្អៀត ហើយអណ្តាតរបស់ខ្ញុំក៏និយាយមិនសូវច្បាស់ទៀត។ ដូច្នេះ សូមព្រះអង្គមេត្តាបញ្ជូន (ម៉ាឡាអ៊ីកាត់ដីព្រីល)ទៅកាន់ហារូន(ដើម្បីឱ្យគាត់ធ្វើជាជំនួយខ្ញុំ)ផងចុះ។

14. ហើយខ្ញុំធ្លាប់មានទោសឧក្រិដ្ឋមួយជាមួយពួកគេ។ ដូច្នេះ ខ្ញុំខ្លាចពួកគេសម្លាប់ខ្ញុំវិញ។

15. ទ្រង់បានមានបន្ទូលថា៖ មិនដូច្នោះឡើយ។ ហេតុនេះ ចូរអ្នកទាំងពីរនាំយកសញ្ញាកស្តុតាងរបស់យើង(ទៅកាន់ពួកគេ) ចុះ។ ពិតប្រាកដណាស់ យើងនៅជាមួយពួកអ្នក ជាអ្នកដឹងឮ។

16. ដូច្នេះ ចូរអ្នកទាំងពីរទៅជួបហៀរអោនចុះ ហើយនិយាយទៅកាន់គេថា៖ ពិតប្រាកដណាស់ ពួកយើង គឺជាអ្នកនាំសាររបស់ព្រះជាម្ចាស់ដែលគ្រប់គ្រងពិភពទាំងអស់។

17. សូមអ្នកដោះលែងអម្ប្យរអ៊ីស្រាអែលឱ្យទៅជាមួយពួកយើង។

18. គេ(ហៀរអោន)បានតបថា៖ តើយើងមិនបានចិញ្ចឹមបីបាច់អ្នកនៅក្នុងគ្រួសាររបស់យើងកាលអ្នកនៅតូច ហើយបានឱ្យអ្នករស់នៅជាមួយយើងជាច្រើនឆ្នាំនៃជីវិតរបស់អ្នកទេឬ?

19. ហើយអ្នកបានប្រព្រឹត្តបទឧក្រិដ្ឋមួយ(ដោយបានសម្លាប់បុរសម្នាក់)។ ហើយអ្នកគឺស្ថិតក្នុងចំណោមអ្នកដែលរមិលគុណ។

20. គាត់បានតបថា៖ ខ្ញុំពិតជាបានប្រព្រឹត្តបែបនោះមែនខណៈដែល(កាលនោះ)ខ្ញុំស្ថិតក្នុងចំណោមអ្នកដែលវង្វេង។

21. ហើយខ្ញុំក៏បានគេចចេញពីពួកអ្នកដោយសារតែខ្ញុំខ្លាចពួកអ្នក(សម្លាប់ខ្ញុំវិញ)។ ក្រោយមក ព្រះជាម្ចាស់របស់ខ្ញុំបានផ្តល់ឱ្យខ្ញុំនូវចំណេះដឹង និងបានឱ្យខ្ញុំស្ថិតក្នុងចំណោមអ្នកនាំសារទាំងឡាយ។

22. តើនោះឬដែលអ្នកចាត់ទុកជាគុណបំណាច់របស់អ្នកមានចំពោះខ្ញុំ ខណៈដែលអ្នកបានយកអម្ប្យរអ៊ីស្រាអែលធ្វើជាទាសករនោះ?

23. ហៀរអោនបាននិយាយថា៖ តើព្រះជាម្ចាស់នៃពិភពទាំងឡាយ ជាអ្វីទៅ?

24. គាត់(ព្យាការីមូសា)បានតបថា៖ គឺជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី ហើយនិងអ្វីៗដែលនៅចន្លោះវាទាំងពីរ ប្រសិនបើពួកអ្នកជាអ្នកដែលជឿជាក់មែននោះ។

25. គេ(ហៀរអោន)ក៏និយាយទៅកាន់ពួក(មន្ត្រី)ដែលនៅជុំវិញគេថា៖ តើពួកអ្នកមិនបានឮ(សម្តីរបស់មូសា)ទេឬ?

26. គាត់បានបន្តទៀតថា៖ ទ្រង់ជាព្រះជាម្ចាស់របស់ពួកអ្នក ហើយក៏ជាព្រះជាម្ចាស់ជីដូនជីតារបស់ពួកអ្នកពីមុនៗផងដែរ។

27. ហៀរអោនបាននិយាយថា៖ ជាការពិតណាស់ អ្នកនាំសាររបស់ពួកអ្នកដែលគេបញ្ជូនមកកាន់ពួកអ្នក គឺពិតជាមនុស្សវិកលចរិត។

28. ព្យាការីមូសាបានតបថា៖ ទ្រង់ជាព្រះជាម្ចាស់នៃទិសខាងកើត និងទិសខាងលិច ហើយនិងអ្វីៗដែលមាននៅចន្លោះវាទាំងពីរផងដែរ ប្រសិនបើពួកអ្នកចេះគិតពិចារណាមែននោះ។

29. ហ្វៀនអោនបាននិយាយថា៖ ប្រសិនបើអ្នកយកផ្សេងក្រៅពីយើងធ្វើជាព្រះនោះ យើងប្រាកដជានឹងឱ្យអ្នកស្ថិតក្នុងចំណោមអ្នកដែលជាប់ឃុំឃាំងជាមិនខាន។

30. គាត់បានតបថា៖ បើទោះជាខ្ញុំនាំមកកាន់អ្នកនូវអំណះអំណាងយ៉ាងច្បាស់លាស់ក៏ដោយឬ?

31. ហ្វៀនអោនបានតបថា៖ បើដូច្នោះមែន ចូរអ្នកនាំយកវាមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់មែននោះ។

32. ពេលនោះ ព្យាការីមូសាក៏បានបោះដំបងរបស់គាត់។ រំពេចនោះ វាក៏បានក្លាយទៅជាសត្វពស់យ៉ាងពិតប្រាកដ។

33. ហើយគាត់បានដកដៃរបស់គាត់ចេញ(ពីហោប៉ៅ)។ រំពេចនោះ វាក៏មានពន្លឺសភ្លឺសម្រាប់អ្នកទស្សនាទាំងឡាយ(បានឃើញ)។

34. ហ្វៀរអោនក៏និយាយទៅកាន់ពួក(មន្ត្រី)ដែលនៅជុំវិញគេថា៖ ពិតប្រាកដណាស់ (បុរសម្នាក់)នេះ គឺជាគ្រូមន្តអាគមដ៏ប៉ិនប្រសប់បំផុតម្នាក់។

35. គេចង់បណ្តេញពួកអ្នកចេញពីទឹកដីរបស់ពួកអ្នកតាមរយៈមន្តអាគមរបស់គេ។ ដូច្នេះ តើពួកអ្នកឲ្យយើងធ្វើបែបណា?

36. ពួកគេបានឆ្លើយថា៖ ចូរអ្នកពន្យារពេលឱ្យគេ និងបងប្រុសរបស់គេសិនចុះ។ ហើយចូរអ្នកបញ្ជូន(ទាហាន)ទៅគ្រប់ទីក្រុងទាំងអស់ដើម្បីប្រមូល(គ្រូមន្តអាគម)មក។

37. ពួកគេនឹងនាំមកឱ្យអ្នកនូវគ្រូមន្តអាគមដែលស្ទាត់ជំនាញបំផុតជាមិនខាន។

38. ក្រោយមក គេក៏បានប្រមូលគ្រូមន្តអាគមដើម្បីមកជួបជុំគ្នានៅថ្ងៃដែលត្រូវបានកំណត់(យ៉ាងច្បាស់លាស់)។

39. ហើយមានគេនិយាយទៅកាន់មនុស្ស(ដែលមកចូលរួមទស្សនា)ថា៖ តើពួកអ្នកមកជួបជុំគ្នាអស់ហើយឬនៅ?

40. សង្ឃឹមថា ពួកយើងនឹងតាមគ្រូមន្តអាគមទាំងនោះប្រសិនបើពួកគេជាអ្នកដែលទទួលជ័យជម្នះ។

41. ហើយនៅពេលដែលគ្រូមន្តអាគមទាំងនោះបានមកដល់ ពួកគេបាននិយាយទៅកាន់ហ្វៀរអោនថា៖ តើពួកយើងនឹងទទួលបានការតបស្នងដៃឬទេ ប្រសិនបើពួកយើងជាអ្នកឈ្នះ(លើមូសា)នោះ?

42. គេបានតបថា៖ ពិតមែនហើយ។ បើដូច្នោះមែននោះ ពិតណាស់ ពួកអ្នកនឹងបានស្ថិតក្នុងចំណោមមនុស្សជំនិត(របស់យើង)។

43. ព្យាការីមូសាបាននិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកបោះអ្វីដែលចង់បោះនោះ(មុន)ចុះ។

44. ពេលនោះ ពួកគេក៏បានបោះខ្សែនិងដំបងរបស់ពួកគេ ហើយពួកគេបានស្បថនឹងអំណាចរបស់ហ្វៀរអោនថា៖ ជាការពិតណាស់ ពួកយើង ប្រាកដជាអ្នកដែលទទួលជ័យជម្នះ។

45. បន្ទាប់មក ព្យាការីមូសាក៏បានបោះដំបងរបស់គាត់។ រំពេចនោះ (វាក៏បានក្លាយទៅជាសត្វពស់ដ៏ធំមួយ) និងលេបនូវអ្វីដែលពួកគេកំពុងបំភ័ន្តភ្នែកនោះ។

46. ពេលនោះ គ្រូមន្តអាគមទាំងនោះ ក៏បានលំឱនកាយស៊ូជោត

47. ដោយពួកគេនិយាយថា៖ ពួកយើងមានជំនឿហើយនឹងព្រះជាម្ចាស់នៃពិភពទាំងឡាយ

48. ដែលជាព្រះជាម្ចាស់របស់ព្យាការីមូសា និងព្យាការីហារូន។

49. ហ្វៀរអោនក៏និយាយថា៖ តើពួកឯងមានជំនឿលើរូបគេមុននឹងយើងអនុញ្ញាតឱ្យពួកឯងឬ? ជាការពិតណាស់ រូបគេគឺជាមេរបស់ពួកឯងដែលបានបង្រៀនមន្តអាគមដល់ពួកឯង។ ដូច្នេះ ពួកឯងគង់តែនឹងដឹងជាមិនខាន។ យើងប្រាកដជានឹងកាត់ដៃជើងរបស់ពួកឯងឆ្លាស់គ្នា ហើយយើងពិតជានឹងចងឆ្កាងពួកឯងទាំងអស់គ្នាមិនខានឡើយ។

50. ពួកគេ(គ្រូមន្តអាគម)បានតបថា៖ គ្មានបញ្ហាអ្វីឡើយ(ចំពោះពាក្យគំរាមទាំងនេះ)។ ពិតប្រាកដណាស់ ពួកយើងនឹងវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកយើងវិញជាមិនខាន។

51. ពិតប្រាកដណាស់ ពួកយើងសង្ឃឹមថា ព្រះជាម្ចាស់របស់យើងនឹងអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយរបស់ពួកយើង ព្រោះពួកយើងគឺជាអ្នកដែលមានជំនឿមុនគេ។

52. ហើយយើង(អល់ឡោះ)បានផ្តល់វ៉ាហ៊ីទៅកាន់ព្យាការីមូសាថា៖ ចូរអ្នកនាំខ្ញុំបម្រើរបស់យើង(អម្បូរអ៊ីស្រាអែល)ក៏សែខ្លួនចេញទាំងយប់។ ពិតប្រាកដណាស់ ពួកអ្នកត្រូវបានគេដេញតាមហើយ។

53. ពេលនោះ ហ្វៀរអោនក៏បានបញ្ជូន(មេទ័ព)ឱ្យប្រមូល(កងទ័ព)តាមបណ្តាក្រុងនានា។

54. (ហ្វៀរអោនបាននិយាយថា៖) ពិតប្រាកដណាស់ ពួកទាំងនោះ គឺជាពួកតូចទាប និងមានចំនួនតិចតួចប៉ុណ្ណោះ។

55. ហើយពួកគេពិតជាបានធ្វើឱ្យយើងខឹងសម្បាយ៉ាងខ្លាំង។

56. ហើយពិតណាស់ ពួកយើងទាំងអស់គ្នាបានត្រៀមលក្ខណៈរួចជាស្រេច(ដើម្បីតាមចាប់ពួកគេ)។

57. ដូច្នេះ យើង(អល់ឡោះ)ក៏បានបណ្តេញពួកគេ(ហ្វៀរអោននិងបក្សពួក)ចេញពីទឹកដីដែលពោរពេញទៅដោយសួនឧទ្យាន និងប្រភពទឹកហូរជាច្រើន

58. ព្រមទាំងឃ្លាំងទ្រព្យ និងលំនៅឋានដ៏ប្រពៃ។

59. ក៏ដូច្នោះដែរ យើងបានប្រទាន(របស់ទាំងនោះ)ឱ្យអម្បូរអ៊ីស្រាអែល។

60. ក្រោយមក ពួកទាំងនោះ(ហ្វៀរអោននិងបក្សពួក)ក៏បានតាមទាន់ពួកគេនៅពេលថ្ងៃរះ។

61. ហើយនៅពេលដែលក្រុមទាំងពីរបានឃើញគ្នា ក្រុមរបស់ព្យាការីមូសាបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងត្រូវគេតាមទាន់ហើយ។

62. ព្យាការីមូសាបានតបថា៖ មិនដូច្នោះឡើយ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់នៅជាមួយខ្ញុំ។ ទ្រង់នឹងបង្ហាញ(ផ្លូវដល់ខ្ញុំ)ជាមិនខាន។

63. នៅពេលនោះ យើង(អល់ឡោះ)បានផ្តល់វាហ៊ីទៅកាន់ព្យាការីមូសាថា៖ ចូរអ្នកវាយសមុទ្រនឹងដំបងរបស់អ្នកចុះ។ រំពេចនោះ ទឹកសមុទ្រក៏បានញែកចេញពីគ្នា(ជាដប់ពីរផ្លូវ)។ ហើយរាល់បំណែកនីមួយៗ ប្រៀបបាននឹងភ្នំដ៏ធំ។

64. ហើយយើងបានឱ្យក្រុមផ្សេងទៀត(ក្រុមហ្វៀរអោន)កាន់តែខិតទៅជិតទីនោះ(រហូតបានចូលក្នុងសមុទ្រនោះ)។

65. ហើយយើងក៏បានសង្គ្រោះព្យាការីមូសា និងអ្នកទាំងអស់ដែលនៅជាមួយគេ។

66. បន្ទាប់មក យើងបានពន្លិចក្រុមផ្សេងទៀត(ក្រុមហ្វៀរអោន)។

67. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តែងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

68. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

69. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រឱ្យពួកគេស្តាប់នូវរឿងរ៉ាវរបស់ព្យាការីអ៊ីព្រហ៊ីម។

70. ខណៈដែលគាត់បាននិយាយទៅកាន់ឪពុករបស់គាត់ និងក្រុមរបស់គាត់ថា៖ តើអ្វីទៅដែលពួកអ្នកកំពុងតែគោរពសក្ការៈនោះ ?

71. ពួកគេតបថា៖ ពួកយើងកំពុងតែគោរពសក្ការៈចំពោះរូបបដិមា ហើយពួកយើងនឹងបន្តគោរពសក្ការៈចំពោះវា(ជារៀងរហូត)។

72. គាត់បានសួរថា៖ តើពួកវាស្តាប់ឮពួកអ្នកដែរឬទេនៅពេលដែលពួកអ្នកបួងសួងនោះ?

73. ឬពួកវាអាចផ្តល់ផលប្រយោជន៍ដល់ពួកអ្នក ឬក៏អាចបង្កគ្រោះថ្នាក់ដល់ពួកអ្នកដែរឬទេ?

74. ពួកគេបានឆ្លើយថា៖ ផ្ទុយទៅវិញ ពួកយើងបានឃើញជីដូនជីតារបស់ពួកយើងធ្វើដូច្នេះ។ (ហើយពួកយើងក៏ធ្វើតាមពួកគាត់ទៅ)។

75. គាត់បានពោលថា៖ តើពួកអ្នកបានឃើញដែរឬទេថា អ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈ

76. ទាំងពួកអ្នក និងជីដូនជីតារបស់ពួកអ្នកជំនាន់មុននោះ

77. ពិតណាស់ ពួកវា គឺជាសត្រូវរបស់ខ្ញុំ លើកលែងតែ(អល់ឡោះ)ព្រះជាម្ចាស់នៃពិភពទាំងឡាយប៉ុណ្ណោះ

78. ដែលទ្រង់ជាអ្នកដែលបានបង្កើតខ្ញុំ និងចង្អុលបង្ហាញរូបខ្ញុំ។

79. ហើយទ្រង់(តែមួយគត់)ដែលជាអ្នកផ្តល់ចំណីអាហារ និងទឹកផឹកដល់ខ្ញុំ។

80. ហើយនៅពេលដែលខ្ញុំឈឺ គឺទ្រង់(តែមួយគត់)ដែលធ្វើឱ្យខ្ញុំជាសះស្បើយ។

81. ហើយទ្រង់ជាអ្នកដែលដកយកជីវិតរបស់ខ្ញុំ បន្ទាប់មក ទ្រង់បង្កើតខ្ញុំឲ្យរស់ឡើង(នាថ្ងៃបរលោក)។

82. ហើយទ្រង់(តែមួយគត់)ជាអ្នកដែលខ្ញុំសង្ឃឹមថានឹងអភ័យទោសដល់ខ្ញុំនូវកំហុសឆ្គងទាំងឡាយរបស់ខ្ញុំនៅថ្ងៃបរលោក។

83. (គាត់បានបួងសួងថា៖) បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាប្រទានដល់រូបខ្ញុំនូវគតិបណ្ឌិត និងបញ្ចូលរូបខ្ញុំទៅក្នុងចំណោមអ្នកដែលសាងទង្វើកុសលផងចុះ។

84. ហើយសូមព្រះអង្គមេត្តាផ្តល់ឱ្យខ្ញុំនូវការកោតសរសើរនិងការរំលឹកដ៏ល្អប្រពៃពីបណ្តាអ្នកជំនាន់ក្រោយផងចុះ។

85. ហើយសូមព្រះអង្គមេត្តាឱ្យខ្ញុំស្ថិតក្នុងចំណោមអ្នកដែលទទួលមរតកឋានសួគ៌ណាអ៊ីមផង។

86. ហើយសូមព្រះអង្គមេត្តាអភ័យទោសដល់ឪពុករបស់ខ្ញុំផងចុះ។ ពិតប្រាកដណាស់ រូបគាត់បានស្ថិតក្នុងចំណោមពួកដែលវង្វេង។

87. ហើយសូមព្រះអង្គមេត្តាកុំធ្វើឱ្យខ្ញុំអាម៉ាស់នៅថ្ងៃដែលពួកគេត្រូវបានគេបង្កើតឲ្យរស់ឡើងវិញ(ថ្ងៃបរលោក)ផងចុះ។

88. គឺនៅថ្ងៃដែលទ្រព្យសម្បត្តិ និងកូនចៅមិនអាចផ្តល់ជាប្រយោជន៍អ្វីនោះឡើយ។

89. លើកលែងតែជនណាដែលបានត្រឡប់ទៅជួបអល់ឡោះដោយដួងចិត្តបរិសុទ្ធប៉ុណ្ណោះ។

90. ហើយឋានសួគ៌ត្រូវបានគេបង្ខិតឱ្យទៅជិតបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)។

91. ចំណែកឯឋាននរកត្រូវបានគេបង្ហាញឲ្យពួកដែលវង្វេងបានឃើញ។

92. ហើយមានគេនិយាយទៅកាន់ពួកទាំងនោះថា៖ តើនៅឯណាទៅអ្វីដែលពួកអ្នកធ្លាប់គោរពសក្ការៈ

93. ក្រៅពីអល់ឡោះនោះ ? តើពួកវាអាចជួយពួកអ្នក ឬក៏ពួកវាអាចជួយខ្លួនឯងបានដែរឬទេ ?

94. ហើយពួកវា(រូបបដិមា) និងអ្នកដែលពួកវាធ្វើឱ្យវង្វេងនោះ ត្រូវបានគេបោះចូលទៅក្នុងនរក

95. រួមទាំងបក្សពួករបស់អ៊ីព្លីសទាំងអស់ផងដែរ។

96. ពួកវាបាននិយាយឈ្លោះប្រកែកគ្នា ខណៈដែលពួកវាស្ថិតនៅក្នុងឋាននរកនោះថា៖

97. សូមស្បថនឹងអល់ឡោះ! ពិតប្រាកដណាស់ ពួកយើងពិតជាធ្លាប់ស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់

98. ខណៈដែលពួកយើងបានឱ្យតម្លៃពួកឯងស្មើនឹងព្រះជាម្ចាស់នៃពិភពទាំងឡាយ។

99. ហើយគ្មានណាធ្វើឱ្យពួកយើងវង្វេង ក្រៅពីពួកឧក្រិដ្ឋជននោះឡើយ។

100. ដូច្នេះ សម្រាប់ពួកយើង គឺគ្មានអ្នកជួយអន្តរាគមន៍ណានោះឡើយ។

101. ហើយក៏គ្មានមិត្តជិតស្និទ្ធណា(ដែលអាចជួយពួកយើងបាន)នោះដែរ។

102. ពិតប្រាកដណាស់ ប្រសិនបើពួកយើងមានឱកាសម្តងទៀត ពួកយើងប្រាកដជានឹងស្ថិតក្នុងចំណោមអ្នកដែលមានជំនឿជាមិនខាន។

103. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

104. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

105. ក្រុមរបស់ព្យាការីនួហបានបដិសេធនឹងបណ្តាអ្នកនាំសារទាំងឡាយ។

106. នៅពេលដែលព្យាការីនួហដែលជាបងប្អូនរបស់ពួកគេបាននិយាយទៅកាន់ពួកគេថា៖ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ) ទេឬ?

107. ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

108. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

109. ហើយខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នងណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺស្ថិតនៅលើព្រះជាម្ចាស់នៃពិភពទាំងឡាយ(តែមួយគត់)។

110. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

111. ពួកគេបានតបវិញថា៖ តើឱ្យពួកយើងមានជំនឿលើអ្នកឬ ខណៈអ្នកដែលដើរតាមអ្នក គឺសុទ្ធតែជាពួកដែលមានឋានៈតូចទាបនោះ?

112. គាត់បានពោលថា៖ ខ្ញុំគ្មានកាតព្វកិច្ចត្រូវដឹងពីអ្វីដែលពួកគេបានប្រព្រឹត្តនោះឡើយ។

113. តាមពិត ការជំនុំជម្រះរបស់ពួកគេ គឺស្ថិតនៅលើព្រះជាម្ចាស់របស់ខ្ញុំប៉ុណ្ណោះ ប្រសិនបើពួកអ្នកបានដឹងនោះ។

114. ហើយខ្ញុំមិនមែនជាអ្នកដែលបណ្តេញបណ្តាអ្នកដែលមានជំនឿនោះដែរ។

115. តាមពិត ខ្ញុំគ្រាន់តែជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់ប៉ុណ្ណោះ។

116. ពួកគេបានតបថា៖ ឱនួហ! ប្រសិនបើអ្នកមិនព្រមបញ្ឈប់ទេនោះ អ្នកប្រាកដជានឹងស្ថិតក្នុងចំណោមអ្នកដែលត្រូវគេគប់សម្លាប់ជាមិនខាន។

117. គាត់ក៏បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! ជាការពិតណាស់ ក្រុមរបស់ខ្ញុំបានបដិសេធ(នឹងខ្ញុំ)។

118. ហេតុនេះ សូមព្រះអង្គមេត្តាវិនិច្ឆ័យរវាងខ្ញុំនិងពួកគេនូវការវិនិច្ឆ័យមួយ(ដ៏យុត្តិធម៌)ផង ហើយសូមព្រះអង្គមេត្តាសង្គ្រោះរូបខ្ញុំ និងបណ្តាអ្នកមានជំនឿដែលនៅជាមួយខ្ញុំផងចុះ។

119. ពេលនោះ យើង(អល់ឡោះ)ក៏បានសង្គ្រោះរូបគេ និងបណ្តាអ្នកមានជំនឿដែលនៅជាមួយគេ(ដោយផ្ទុកពួកគេ)ទៅក្នុងសំពៅមួយដែលពេញទៅដោយបន្ទុក។

120. បន្ទាប់មក យើងបានពន្លិចពួកដែលនៅសេសសល់ក្រោយពីពួកគេ។

121. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

122. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

123. ពួកអាទបានបដិសេធនឹងបណ្តាអ្នកនាំសារទាំងឡាយ។

124. ខណៈពេលដែលព្យាការីហ៊ូទដែលជាបងប្អូនរបស់ពួកគេបាននិយាយទៅកាន់ពួកគេថា៖ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

125. ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

126. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

127. ហើយខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នងណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺស្ថិតនៅលើព្រះជាម្ចាស់នៃពិភពទាំងឡាយ(តែមួយគត់)។

128. តើពួកអ្នកសាងសង់សំណង់ដ៏ស្តឹមស្តែនៅគ្រប់កន្លែងខ្ពស់ៗបែបនេះគ្រាន់តែជាការលេងសើច

129. និងចាត់ទុកវិមានទាំងឡាយហាក់បីដូចជាពួកអ្នកនឹងរស់នៅជាអមតៈនោះឬ?

130. ហើយនៅពេលដែលពួកអ្នកវាយធ្វើបាបឬសម្លាប់(នរណាម្នាក់) ពួកអ្នកវាយធ្វើបាបដោយភាពឃោរឃៅបំផុត។

131. ហេតុនេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

132. ហើយចូរពួកអ្នកខ្លាចអ្នកដែលបានប្រទាន(ឧបការគុណទាំងឡាយ)ដល់ពួកអ្នកនូវអ្វីដែលពួកអ្នកបានដឹង។

133. ទ្រង់បានប្រទាននូវសត្វពាហនៈ និងកូនចៅជាច្រើនដល់ពួកអ្នក

134. ព្រមទាំងសួនឧទ្យាន និងប្រភពទឹកជាច្រើនទៀតផង។

135. ពិតប្រាកដណាស់ ខ្ញុំខ្លាចពួកអ្នកទទួលរងនូវទណ្ឌកម្មនៅថ្ងៃដ៏មហិមា(ថ្ងៃបរលោក)។

136. ពួកគេបានតបវិញថា៖ វាដូចតែគ្នាទេសម្រាប់ពួកយើង ទោះបីជាអ្នកទូន្មាន(ដល់ពួកយើង)ឬមិនស្ថិតក្នុងចំណោមអ្នកដែលទូន្មានក៏ដោយ (ក៏ពួកយើងគ្មានជំនឿដែរ)។

137. (សាសនារបស់ពួកយើង)នេះគឺគ្មានអ្វីក្រៅពីសាសនារបស់អ្នកជំនាន់មុននោះឡើយ។

138. ហើយពួកយើងក៏មិនមែនជាអ្នកដែលត្រូវគេដាក់ទណ្ឌកម្មនោះដែរ។

139. ជាការពិតណាស់ ពួកគេបានបដិសេធចំពោះគាត់។ ដូច្នេះ យើងក៏បានបំផ្លាញពួកគេ។ ជាការពិតណាស់ នៅក្នុងរឿងនោះគឺជាសញ្ញាកស្តតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

140. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

141. ពួកសាមូទបានបដិសេធនឹងអ្នកនាំសារទាំងឡាយ។

142. ខណៈពេលដែលព្យាការីសេឡេះដែលជាបងប្អូនរបស់ពួកគេបាននិយាយទៅកាន់ពួកគេថា៖ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

143. ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

144. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

145. ហើយខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នងណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺស្ថិតនៅលើព្រះជាម្ចាស់នៃពិភពទាំងឡាយ(តែមួយគត់)។

146. តើពួកអ្នកត្រូវគេទុកឲ្យនៅទីនេះដោយសុវត្ថិភាពឬ?

147. គឺនៅក្នុងសួនឧទ្យាន និងប្រភពទឹកនានា

148. ព្រមទាំងដំណាំដាំដុះ ហើយនិងដើមល្មើដែលផ្លែរបស់វាទន់ផ្អែមធ្លាញ់។

149. ហើយពួកអ្នកបានចោះភ្នំទាំងឡាយធ្វើជាផ្ទះយ៉ាងស្ទាត់ជំនាញ។

150. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

151. ហើយចូរពួកអ្នកកុំគោរពតាមបទបញ្ជារបស់ពួកបំពានឱ្យសោះ។

152. គឺពួកដែលបង្កវិនាសកម្មនៅលើផែនដី និងមិនធ្វើឲ្យវាមានភាពល្អប្រសើរឡើយ។

153. ពួកគេបានតបថា៖ តាមពិត រូបអ្នកស្ថិតក្នុងចំណោមអ្នកដែលត្រូវមន្តអាគមច្រើន។

154. អ្នកគ្មានអ្វីក្រៅតែជាមនុស្សលោកធម្មតាដូចពួកយើងប៉ុណ្ណោះ។ ហេតុនេះ ចូរអ្នកនាំមកនូវសញ្ញាកស្តុតាងណាមួយមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់មែននោះ។

155. គាត់បានពោលថា៖ នេះគឺជាសត្វអូដ្ឋញីមួយក្បាល។ សម្រាប់វា គឺមានចំណែកផឹកទឹក ហើយសម្រាប់ពួកអ្នក ក៏មានចំណែកផឹកទឹកផងដែរទៅតាមថ្ងៃដែលគេបានកំណត់។

156. ហើយពួកអ្នកមិនត្រូវប៉ះពាល់វាដោយប្រការអាក្រក់ណាមួយនោះឡើយ ដែលជាហេតុនាំឱ្យពួកអ្នកទទួលនូវទណ្ឌកម្មនៅថ្ងៃដ៏មហិមា។

157. តែពួកគេបានសំឡេះវា។ ដូច្នេះ ពួកគេក៏បានក្លាយជាអ្នកដែលមានវិប្បដិសារី។

158. នៅពេលនោះ ទណ្ឌកម្មក៏បានឆក់យកជីវិតពួកគេ។ ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

159. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

160. ក្រុមរបស់ព្យាការីលូតបានបដិសេធនឹងបណ្តាអ្នកនាំសារទាំងឡាយ។

161. ខណៈពេលដែលព្យាការីលូតដែលជាបងប្អូនរបស់ពួកគេបាននិយាយទៅកាន់ពួកគេថា៖ តើពួកអ្នកមិនកោតខ្លាច (អល់ឡោះ)ទេឬ?

162. ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

163. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

164. ហើយខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នងណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺស្ថិតនៅលើព្រះជាម្ចាស់នៃពិភពទាំងឡាយ(តែមួយគត់)។

165. ហេតុអ្វីបានជាពួកអ្នករួមមេត្រីជាមួយនឹងបុរសដូចគ្នានៅលើផែនដី

166. ហើយពួកអ្នកបែរជាបោះបង់ការរួមមេត្រីជាមួយភរិយារបស់ខ្លួនដែលព្រះជាម្ចាស់បានបង្កើតសម្រាប់ពួកអ្នកទៅវិញ? ផ្ទុយទៅវិញ ពួកអ្នក គឺជាក្រុមដែលបំពាន។

167. ពួកគេបានតបថា៖ ឱលូត! ប្រសិនបើអ្នកមិនព្រមបញ្ឈប់ទេនោះ ពិតណាស់ រូបអ្នកប្រាកដជានឹងស្ថិតក្នុងចំណោមអ្នកដែលត្រូវគេបណ្តេញចេញ(ពីភូមិស្រុក)ជាមិនខាន។

168. គាត់បានតបវិញថា៖ ពិតប្រាកដណាស់ រូបខ្ញុំគឺស្ថិតក្នុងចំណោមអ្នកដែលស្អប់ខ្ពើមបំផុតចំពោះទង្វើរបស់ពួកអ្នក។

169. (គាត់បានបួងសួងថា៖) បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាសង្គ្រោះរូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំអំពីអ្វីដែលពួកគេបានប្រព្រឹត្តផងចុះ។

170. ពេលនោះ យើង(អល់ឡោះ)ក៏បានសង្គ្រោះរូបគេ និងក្រុមគ្រួសាររបស់គេទាំងអស់គ្នា។

171. លើកលែងតែស្ត្រីចំណាស់ម្នាក់(ប្រពន្ធរបស់គាត់)ប៉ុណ្ណោះដែលស្ថិតក្នុងចំណោមអ្នកដែលអន្តរាយ។

172. ក្រោយមក យើងក៏បានបំផ្លាញអ្នកដទៃទៀត(ពួកដែលគ្មានជំនឿ)។

173. ហើយយើងបានបញ្ចុះភ្លៀង(ដុំថ្ម)ទៅលើពួកគេ។ ភ្លៀងដែលធ្លាក់លើពួកដែលត្រូវគេព្រមាននោះ គឺពិតជាអាក្រក់បំផុត។

174. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

175. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

176. ក្រុមអៃកាសបានបដិសេធនឹងបណ្តាអ្នកនាំសារទាំងឡាយ។

177. ខណៈពេលដែលព្យាការីស៊ូអែបបាននិយាយទៅកាន់ពួកគេថា៖ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

178. ពិតប្រាកដណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

179. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

180. ហើយខ្ញុំមិនសុំពីពួកអ្នកនូវការតបស្នងណាមួយចំពោះវា(ការផ្សព្វផ្សាយសារ)នោះឡើយ។ ការតបស្នងរបស់ខ្ញុំ គឺស្ថិតនៅលើព្រះជាម្ចាស់នៃពិភពទាំងឡាយ(តែមួយគត់)។

181. ចូរពួកអ្នកបំពេញនូវការរាល់ឱ្យបានគ្រប់ ហើយពួកអ្នកមិនត្រូវស្ថិតក្នុងចំណោមអ្នកដែលគៃបំបាត់នោះឡើយ។

182. ហើយចូរពួកអ្នកថ្លឹងនឹងដញ្ជីងដែលត្រឹមត្រូវ។

183. ហើយពួកអ្នកមិនត្រូវកេងប្រវ័ញ្ចមនុស្សលោកចំពោះកម្មសិទ្ធិរបស់ពួកគេ និងមិនត្រូវបង្កើននូវការបង្កវិនាសកម្មនៅលើផែនដីនោះឡើយ។

184. ហើយចូរពួកអ្នកកោតខ្លាចអ្នកដែលបានបង្កើតពួកអ្នក និងអ្នកជំនាន់មុនៗជាច្រើន។

185. ពួកគេបានតបថា៖ តាមពិតរូបអ្នកស្ថិតក្នុងចំណោមអ្នកដែលត្រូវមន្តអាគមច្រើន។

186. អ្នកគ្មានអ្វីក្រៅតែជាមនុស្សលោកធម្មតាដូចពួកយើងប៉ុណ្ណោះ។ ហើយពួកយើងជឿជាក់ថា រូបអ្នកពិតជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលភូតកុហកប៉ុណ្ណោះ។

187. ដូច្នេះ ចូរអ្នកទម្លាក់មួយបំណែកនៃទណ្ឌកម្មពីលើមេឃមកកាន់ពួកយើងមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់មែននោះ។

188. គាត់បានតបថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

189. តែពួកគេបានបដិសេធចំពោះគាត់។ ដូច្នេះ ទណ្ឌកម្មនៃថ្ងៃដែលភ្លើងចេញពីម្លប់ពពកបានឆក់យកជីវិតពួកគេ។ ពិតប្រាកដណាស់ វាជាទណ្ឌកម្មនាថ្ងៃដ៏មហិមា។

190. ជាការពិតណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តតាងមួយ។ តែភាគច្រើននៃពួកគេ គឺគ្មានជំនឿឡើយ។

191. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

192. ហើយពិតប្រាកដណាស់ វា(គម្ពីរគួរអាន)គឺពិតជាត្រូវបានបញ្ចុះមកពីព្រះជាម្ចាស់នៃពិភពទាំងឡាយ

193. ដែលម៉ាឡាអ៊ីកាត់ជីព្រីលជាអ្នកស្មោះត្រង់បំផុតបាននាំវាមក

194. (ដោយបានសូត្រវា)ទៅលើដួងចិត្តរបស់អ្នក(ព្យាការីមូហាំម៉ាត់)ដើម្បីឱ្យអ្នកក្លាយជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដាស់តឿនព្រមាន

195. ដោយ(គេបានបញ្ចុះវា)ជាភាសាអារ៉ាប់យ៉ាងច្បាស់លាស់។

196. ហើយពិតប្រាកដណាស់ វា(គម្ពីរគួរអាន)ក៏មានបញ្ជាក់ប្រាប់នៅក្នុងបណ្តាគម្ពីរមុនៗផងដែរ។

197. តើវាមិនមែនជាសញ្ញាកស្តុតាងមួយសម្រាប់ពួកគេ(ពួកដែលបដិសេធ)ទៀតឬដែលមានពួកអ្នកប្រាជ្ញនៃអម្បូរអ៊ីស្រាអែលបានដឹងអំពីវានោះ ?

198. ហើយប្រសិនបើយើងបញ្ចុះវាទៅលើជនមួយចំនួនដែលមិនមែនជាអ្នកនិយាយភាសាអារ៉ាប់

199. រួចជននោះសូត្រវាឱ្យពួកគេស្តាប់ ក៏ពួកគេមិនមានជំនឿចំពោះវាដដែល។

200. ក៏ដូច្នោះដែរ យើងបានបញ្ចូលការបដិសេធ(ចំពោះគម្ពីរគួរអាន)ទៅក្នុងដួងចិត្តរបស់ពួកប្រព្រឹត្តល្មើស។

201. ពួកគេគ្មានជំនឿចំពោះវានោះឡើយ លុះត្រាតែពួកគេបានឃើញទណ្ឌកម្មដ៏ឈឺចាប់(ផ្ទាល់នឹងភ្នែក)។

202. រួចមកទណ្ឌកម្មក៏មកដល់ពួកគេភ្លាមៗ ខណៈពួកគេមិនដឹងខ្លួនឡើយ។

203. ពេលនោះ ពួកគេនឹងនិយាយថា៖ តើពួកយើងជាអ្នកដែលត្រូវគេពន្យារពេលឱ្យដែរឬទេ ?

204. តើពួកគេសុំឱ្យទណ្ឌកម្មរបស់យើងធ្លាក់មកលើពួកគេភ្លាមៗឬ ?

205. ដូច្នេះ តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងទេថា ប្រសិនបើយើងឱ្យពួកគេសោយសុខក្នុងរយៈពេលជាច្រើនឆ្នាំ

206. ក្រោយមក អ្វី(ទណ្ឌកម្ម)ដែលគេបានសន្យាចំពោះពួកគេបានមកដល់ពួកគេ

207. អ្វីដែលគេផ្តល់ឱ្យពួកគេបានសោយសុខនោះ គឺមិនបានផ្តល់ផលប្រយោជន៍អ្វីដល់ពួកគេឡើយ។

208. ហើយយើងមិនបានបំផ្លាញភូមិស្រុកណាមួយនោះឡើយ លើកលែងតែមានអ្នកដាស់តឿនព្រមានភូមិស្រុកនោះ(ជាមុន)

209. ដើម្បីជាការក្រើនរំឭក(ដល់ពួកគេ)។ ហើយយើងពុំមែនជាអ្នកដែលបំពាននោះឡើយ។

210. ហើយពួកស្មែតនមិនបានបញ្ចុះវា(គម្ពីរគួរអាន)នោះឡើយ។

211. មិនត្រឹមត្រូវនោះឡើយចំពោះពួកវា(ក្នុងការធ្វើដូច្នោះ) ហើយពួកវាក៏គ្មានសមត្ថភាពនោះដែរ

212. (ព្រោះ)ពិតណាស់ ពួកវាត្រូវបានគេបណ្តេញចេញមិនឱ្យស្តាប់(គម្ពីរគួរអាន)ឡើយ។

213. ហេតុនេះ ចូរអ្នកកុំគោរពសក្ការៈចំពោះព្រះផ្សេងរួមនឹងអល់ឡោះឱ្យសោះ ដែលជាហេតុធ្វើឱ្យអ្នកស្ថិតក្នុងចំណោមអ្នកដែលត្រូវទទួលទណ្ឌកម្ម។

214. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដាស់តឿនព្រមានសាច់ញាតិរបស់អ្នកដែលជិតបំផុត។

215. ហើយចូរអ្នកបន្ទាបខ្លួនរបស់អ្នកចំពោះអ្នកដែលដើរតាមអ្នកក្នុងចំណោមបណ្តាអ្នកដែលមានជំនឿទាំងឡាយ។

216. តែប្រសិនបើពួកគេប្រឆាំងនឹងអ្នក ចូរអ្នកពោលថា៖ ពិតប្រាកដណាស់ ខ្ញុំមិនពាក់ព័ន្ធនឹងអ្វីដែលពួកអ្នកប្រព្រឹត្តនោះឡើយ។

217. ហើយចូរអ្នកប្រគល់ការទុកចិត្តលើអ្នកដែលមហាខ្លាំងពូកែ មហាអាណិតស្រលាញ់បំផុតចុះ

218. ដែលទ្រង់ជាអ្នកមើលឃើញអ្នកនៅពេលដែលអ្នកក្រោកឈរប្រតិបត្តិសឡាត(តែម្នាក់ឯង)

219. និងការផ្លាស់ប្តូរ(កាយវិការរបស់អ្នក)ជាមួយបណ្តាអ្នកដែលប្រតិបត្តិសឡាតទាំងឡាយ។

220. ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

221. តើចង់ឱ្យយើង(អល់ឡោះ)ប្រាប់ពួកអ្នកទេថា តើពួកស្មែតននោះ វាចុះទៅលើអ្នកណា ?

222. គឺវាចុះទៅលើរាល់ពួកដែលភូតកុហក មានបាបកម្មច្រើន(ពួកគ្រូទាយ)។

223. ពួកវាផ្តល់អ្វីដែលវាស្តាប់ឮ(ទៅកាន់គ្រូទាយទាំងឡាយ)។ ហើយភាគច្រើននៃពួកគេ គឺជាពួកដែលភូតកុហក។

224. ហើយពួកកវីទាំងឡាយ អ្នកដែលដើរតាមពួកគេ គឺជាពួកដែលវង្វេង។

225. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬថា ពិតប្រាកដណាស់ រាល់ការនិពន្ធ(របស់ពួកគេ)មានភាពមិនច្បាស់លាស់ឡើយ។

226. ហើយពិតប្រាកដណាស់ ពួកគេនិយាយនូវអ្វីដែលពួកគេមិនបានធ្វើ។

227. លើកលែងតែកវីទាំងឡាយណាដែលមានជំនឿ និងបានសាងនូវទង្វើកុសល ព្រមទាំងរឭកដល់អល់ឡោះយ៉ាងច្រើន និងបានទទួលជ័យជម្នះ(លើសត្រូវ)ក្រោយពីពួកគេត្រូវបានគេបំពានប៉ុណ្ណោះ។ ហើយពួកដែលបំពាននឹងដឹងថា តើកន្លែងវិលត្រឡប់ណាមួយដែលពួកគេត្រូវវិលត្រឡប់ទៅកាន់(នៅថ្ងៃបរលោក)នោះ។

ជំពូក អាន់ណាំល៍

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ត ស៊ីន (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ ទាំងនេះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរគួរអាន និងជាគម្ពីរដ៏ច្បាស់លាស់។

2. ជាការចង្អុលបង្ហាញ និងជាដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ។

3. គឺបណ្តាអ្នកដែលប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយពួកគេជាអ្នកដែលជឿជាក់យ៉ាងពិតប្រាកដចំពោះថ្ងៃបរលោក។

4. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក យើងបានតុបតែងដល់ពួកគេនូវទង្វើរបស់ពួកគេ។ ជាការពិតណាស់ ពួកគេមានភាពស្រពេចស្រពិល។

5. ពួកទាំងនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងអាក្រក់បំផុត(នៅក្នុងលោកិយ)។ ហើយនៅថ្ងៃបរលោក ពួកគេគឺជាពួកដែលខាតបង់។

6. ហើយពិតប្រាកដណាស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិតជាត្រូវបានគេផ្តល់ឱ្យនូវគម្ពីរគួរអាននេះដែល(ត្រូវបានបញ្ចុះ)មកពីព្រះជាម្ចាស់ដែលមហាគតិបណ្ឌិត មហាដឹងបំផុត។

7. (ចូរអ្នកនឹកឃើញ)នៅពេលដែលព្យាការីមូសាបាននិយាយទៅកាន់ក្រុមគ្រួសាររបស់គាត់ថា៖ ពិតប្រាកដណាស់ ខ្ញុំបានឃើញពន្លឺភ្លើងមួយ។ ខ្ញុំនឹងនាំដំណឹងខ្លះអំពីវាមកកាន់ពួកអ្នក ឬនាំយកដុំភ្លើងមកបង្កាត់ឱ្យពួកអ្នកដើម្បីឱ្យពួកអ្នកមានភាពកក់ក្តៅ។

8. ហើយនៅពេលដែលគាត់បានទៅដល់ទីនោះ គេ(អល់ឡោះ)បានស្រែកហៅគាត់ថា៖ ពិតប្រាកដណាស់ គេបានប្រសិទ្ធិពរជ័យដល់អ្នកដែលនៅក្បែរពន្លឺភ្លើង ហើយនិងអ្នកដែលនៅជុំវិញវា។ ហើយអល់ឡោះជាម្ចាស់មហាបរិសុទ្ធ ជាព្រះជាម្ចាស់នៃពិភពទាំងឡាយ។

9. ឱមូសា! ជាការពិតណាស់ យើងនេះហើយគឺជាអល់ឡោះជាម្ចាស់ដែលមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

10. ហើយចូរអ្នកបោះដំបងរបស់អ្នកចុះ។ នៅពេលដែលគាត់បានឃើញដំបងនោះមានចលនាប្រៀបដូចជាសត្វពស់ គាត់ក៏រត់បកក្រោយដោយមិនត្រឡប់មកវិញឡើយ។ (ទ្រង់បានមានបន្ទូលថា៖) ឱមូសា! ចូរអ្នកកុំខ្លាចវាអី។ ពិតប្រាកដណាស់ បណ្តាអ្នកនាំសារទាំងឡាយ ពួកគេមិនមានភាពភ័យខ្លាចនៅចំពោះមុខយើងឡើយ។

11. ក៏ប៉ុន្តែ ចំពោះជនណាដែលបានបំពាន ក្រោយមកគេបានប្រព្រឹត្តអំពើល្អក្រោយពីបានប្រព្រឹត្តអំពើអាក្រក់នោះរួច ពិតប្រាកដណាស់ យើងគឺជាអ្នកដែលមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

12. ហើយចូរអ្នកដាក់ដៃរបស់អ្នកទៅក្នុងហោប៉ៅអាវរបស់អ្នកចុះ នោះវានឹងបញ្ចេញពន្លឺសភ្លឺថ្លាដោយពុំមែនជាប្រការអាក្រក់ឡើយដែលវាស្ថិតក្នុងចំណោមអច្ឆរិយភាពទាំងប្រាំបួនដែលបញ្ជូនទៅកាន់ហ្វៀរអោន និងក្រុមរបស់គេ។ ជាការពិតណាស់ ពួកគេគឺជាក្រុមដែលប្រព្រឹត្តអំពើល្មើស។

13. តែនៅពេលដែលសញ្ញាកស្តុតាងរបស់យើងបានមកដល់ពួកគេយ៉ាងជាក់ច្បាស់ ពួកគេបែរជានិយាយថា៖ នេះគឺជាមន្តអាគមយ៉ាងច្បាស់លាស់ទៅវិញ។

14. ហើយពួកគេបានប្រឆាំងនឹងវា(សញ្ញាកស្តុតាងទាំងនោះ)ទាំងបំពាន និងក្អេងក្អាង ខណៈដែលខ្លួនរបស់ពួកគេផ្ទាល់ដឹងយ៉ាងច្បាស់អំពីវា។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបង្កវិនាសកម្មនោះទៅជាយ៉ាងណា?

15. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីហ្វារូទ និងព្យាការីស៊ូឡៃម៉ាននូវចំណេះដឹងដ៏ខ្ពង់ខ្ពស់។ ហើយគេទាំងពីរបានពោលថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលបានលើកតម្កើងពួកយើង(ទាំងពីរនាក់)លើសពីខ្ញុំបម្រើរបស់ទ្រង់ដែលជាអ្នកមានជំនឿជាច្រើនផ្សេងទៀត។

16. ហើយព្យាការីស៊ូឡៃម៉ានបានទទួលមរតកពីព្យាការីហ្វារូទ(ដែលជាឪពុក)។ ហើយគាត់បាននិយាយថា៖ ឱមនុស្សលោកទាំងឡាយ! គេ(អល់ឡោះ)បានបង្រៀនយើងឱ្យយល់ពីភាសារបស់បក្សី ហើយគេបានប្រទានដល់យើងនូវអ្វីគ្រប់បែបយ៉ាង។ ពិតប្រាកដណាស់ ប្រការទាំងអស់នេះ គឺជាការប្រោសប្រទានយ៉ាងច្បាស់លាស់(អំពីទ្រង់)។

17. ហើយគេបានប្រមូលឲ្យព្យាការីស៊ូឡៃម៉ាននូវកងទ័ពរបស់គាត់មានទាំងមនុស្ស ជិន និងសត្វបក្សីទាំងឡាយ។ ជាការពិតណាស់ ពួកវាត្រូវបានដឹកនាំ(ជាក្បួន)ប្រកបដោយសណ្តាប់ធ្នាប់។

18. លុះពេលដែលពួកគេបានទៅដល់ជ្រលងសត្វស្រមោច មេក្រុមរបស់សត្វស្រមោចបាននិយាយថា៖ ឱសត្វស្រមោចទាំងឡាយ! ចូរពួកឯងនាំគ្នាចូលសំបុករបស់ពួកឯងដើម្បីកុំឲ្យស៊ូឡៃម៉ាននិងកងទ័ពរបស់គេបំផ្លាញពួកឯង ខណៈដែលពួកគេមិនដឹងខ្លួនឡើយ។

19. ពេលនោះ គាត់ក៏បានញញឹមដោយអស់សំណើចនឹងសម្តីរបស់វា ហើយគាត់បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាចង្អុលបង្ហាញដល់ខ្ញុំដើម្បីឱ្យខ្ញុំថ្លែងអំណរគុណចំពោះឧបការគុណរបស់ព្រះអង្គដែលបានប្រទានដល់ខ្ញុំ និងដល់មាតាបិតារបស់ខ្ញុំផងចុះ។ ហើយសូមឱ្យខ្ញុំបានសាងនូវទង្វើកុសលដែលព្រះអង្គពេញចិត្ត ព្រមទាំងបញ្ចូលរូបខ្ញុំទៅក្នុងចំណោមខ្ញុំបម្រើរបស់ព្រះអង្គដែលជាអ្នកសាងទង្វើកុសលដោយក្តីមេត្តាករុណារបស់ព្រះអង្គផងចុះ។

20. ហើយគាត់(ព្យាការីស៊ូឡៃម៉ាន)បានពិនិត្យហ្វូងសត្វបក្សីទាំងឡាយ ហើយគាត់ក៏បានពោលថា៖ ហេតុអ្វីបានជាខ្ញុំមិនឃើញសត្វហ៊ិទហ៊ិទ ឬមួយក៏វាអវត្តមាន(មិនបានមកចូលរួម)?

21. ខ្ញុំប្រាកដជានឹងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះវា ឬខ្ញុំនឹងសំឡេះវា ឬមួយក៏វាត្រូវនាំមកនូវហេតុផលដ៏ច្បាស់លាស់(សមហេតុផល)ណាមួយមកឱ្យខ្ញុំ។

22. តែមិនយូរប៉ុន្មាន (វាក៏បានមកដល់) ហើយវាក៏បាននិយាយថា៖ ខ្ញុំបានដឹងនូវអ្វីដែលអ្នកមិនបានដឹងអំពីវា ហើយខ្ញុំបាននាំមកឱ្យអ្នកនូវដំណឹងដ៏ច្បាស់លាស់មួយពីក្រុងសាហ្គាក់។

23. ពិតប្រាកដណាស់ ខ្ញុំបានឃើញស្ត្រីម្នាក់(ជាក្សត្រិយ៍)ដែលគ្រប់គ្រងលើពួកគេ(អ្នកស្រុកសាហ្គាក់) ហើយគេបានផ្តល់ឱ្យព្រះនាងនូវអ្វីៗគ្រប់បែបយ៉ាង ហើយព្រះនាងមានរាជបល្ល័ង្គមួយដ៏ធំអស្ចារ្យ។

24. ខ្ញុំបានឃើញព្រះនាង និងក្រុមរបស់ព្រះនាងគោរពសក្ការៈចំពោះព្រះអាទិត្យក្រៅពីអល់ឡោះ ហើយស៊ែតនបានតុបតែងលម្អដល់ពួកគេនូវទង្វើទាំងឡាយរបស់ពួកគេ និងបានរារាំងពួកគេពីមាគ៌ា(ត្រឹមត្រូវ)។ ដូច្នេះ ពួកគេមិនទទួលបានការចង្អុលបង្ហាញនោះឡើយ។

25. (ស៊ែតនធ្វើដូច្នោះ)ដើម្បីកុំឱ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ដែលជាអ្នកបញ្ចេញនូវអ្វីដែលលាក់ទុកនៅលើមេឃជាច្រើនជាន់ និងផែនដី។ ហើយទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកលាក់កំបាំង និងអ្វីដែលពួកអ្នកលាតត្រដាង។

26. អល់ឡោះជាម្ចាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលជាព្រះជាម្ចាស់នៃអារ៉ាស្ដ ដ៏ធំធេងឡើយ។

27. គាត់(ព្យាការីស៊ូឡៃម៉ាន)បានតបថា៖ យើងនឹងរង់ចាំមើល ថាតើឯងនិយាយពិត ឬក៏ឯងស្ថិតក្នុងចំណោមអ្នកដែលនិយាយកុហក។

28. ចូរឯងនាំរាជសាររបស់យើងនេះ ហើយទម្លាក់វាទៅឱ្យពួកគេ។ បន្ទាប់មក ចូរឯងងាកចេញពីពួកគេបន្តិច ហើយរង់ចាំមើលថាតើពួកគេនឹងឆ្លើយតបមកវិញយ៉ាងដូចម្តេច។

29. (ក្រោយពីទទួលបានរាជសារ) ព្រះនាងក៏បាននិយាយថា៖ ឱពួកមន្ត្រីទាំងឡាយ! ពិតប្រាកដណាស់ គេបានផ្តល់នូវរាជសារដ៏ឧត្តុង្គឧត្តមមួយដល់យើង។

30. ពិតប្រាកដណាស់ រាជសារនេះគឺមកពីស៊ូឡៃម៉ាន ហើយវាផ្តើមដោយ بسم الله الرحمن الرحيم (ក្នុងនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់)៖

31. ចូរពួកអ្នកកុំក្រអឺតក្រទមចំពោះយើងឱ្យសោះ ហើយចូរពួកអ្នកមកកាន់យើងក្នុងនាមជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

32. ព្រះនាងបាននិយាយថា៖ ឱពួកមន្ត្រីទាំងឡាយ! ចូរពួកអ្នកផ្តល់យោបល់ឱ្យយើងនៅក្នុងកិច្ចការរបស់យើងនេះ។ យើងមិនអាចសម្រេចកិច្ចការណាមួយឡើយ លុះត្រាតែពួកអ្នកមានវត្តមានជាមួយយើង។

33. ពួកគេបានតបថា៖ ពួកយើងសុទ្ធសឹងតែជាអ្នកខ្លាំងពូកែ និងជាអ្នកដែលក្លាហានបំផុត។ ហើយការសម្រេចចិត្ត គឺនៅលើព្រះនាង។ ហេតុនេះ សូមព្រះនាងពិចារណាមើលចុះ ថាតើព្រះនាងដាក់បទបញ្ជាបែបណា(មកលើពួកយើង)។

34. ព្រះនាងក៏បានតបថា៖ ជាការពិតណាស់ ក្សត្រទាំងឡាយ កាលណាពួកគេចូលទៅក្នុងភូមិស្រុកណាមួយ ពួកគេច្បាស់ជាបំផ្លិចបំផ្លាញវា និងធ្វើឱ្យអ្នកមានកិត្តិយសខ្ពង់ខ្ពស់នៃភូមិស្រុកនោះក្លាយជាជនទាបថោកជាមិនខាន។ ដូច្នោះឯងដែលពួកគេតែងតែធ្វើ។

35. ពិតប្រាកដណាស់ យើងនឹងបញ្ជូនជំនូនមួយទៅកាន់ពួកគេ ហើយរង់ចាំមើល ថាតើអ្នកនាំសារទាំងឡាយ(ដែលយើងបញ្ជូនទៅ)នឹងនាំអ្វីត្រឡប់មកវិញ។

36. ហើយនៅពេលដែលគេ(អ្នកនាំសាររបស់ក្សត្រីយ៍)បានទៅដល់ព្យាការីស៊ូឡៃម៉ាន គាត់ក៏បាននិយាយថា៖ តើពួកអ្នកផ្តល់ទ្រព្យសម្បត្តិ(ជំនួន)ទាំងនេះដល់យើងឬ? ជាការពិតណាស់ អ្វីដែលអល់ឡោះបានប្រទានដល់ខ្ញុំ គឺល្អប្រសើរជាងអ្វីដែលទ្រង់បានប្រទានដល់ពួកអ្នកទៅទៀត។ ផ្ទុយទៅវិញ ពួកអ្នកវិញទេដែលសប្បាយរីករាយនឹងជំនួនរបស់ពួកអ្នកនោះ។

37. ចូរអ្នកត្រឡប់ទៅកាន់ពួកគេវិញចុះ។ ជាការពិតណាស់ យើងពិតជានឹងនាំកងទ័ពឆ្ពោះទៅកាន់ពួកគេដែលពួកគេគ្មានសមត្ថភាពទប់ទល់នឹងវាបានឡើយ ហើយយើងប្រាកដជានឹងបណ្តេញពួកគេចេញពីវា(ទឹកដីសាហ្គាក់)យ៉ាងអាម៉ាស់។ ហើយពួកគេជាជនដែលតូចទាបបំផុត។

38. គាត់(ព្យាការីស៊ូឡៃម៉ាន)បាននិយាយថា៖ ឱមន្ត្រីទាំងឡាយ! តើនរណាម្នាក់ក្នុងចំណោមពួកអ្នកអាចនាំរាជបល្ល័ង្ករបស់ព្រះនាងមកឱ្យយើងមុននឹងពួកគេមកកាន់យើងក្នុងនាមជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)?

39. អ៊ីហ្វារីតដែលស្ថិតក្នុងចំណោមពួកជិនបានឆ្លើយថា៖ ខ្ញុំអាចនាំវាមកប្រគល់ឱ្យអ្នកបានមុននឹងអ្នកក្រោកចេញពីកន្លែងរបស់អ្នក។ ហើយពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកដែលខ្លាំងពូកែ និងជាអ្នកដែលស្មោះត្រង់បំផុត។

40. អ្នកដែលមានចំណេះដឹងជ្រៅជ្រះខាងគម្ពីរម្នាក់បាននិយាយថា៖ ខ្ញុំអាចនាំវាមកប្រគល់ឱ្យអ្នកមុននឹងអ្នកព្រិចភ្នែករបស់អ្នកទៅទៀត(ក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ)។ នៅពេលដែលគាត់បានឃើញបល្ល័ង្កនោះស្ថិតនៅចំពោះមុខរបស់គាត់ គាត់ក៏ពោលថា៖ នេះគឺជាការប្រោសប្រទានពីព្រះជាម្ចាស់របស់ខ្ញុំ ដើម្បីទ្រង់នឹងសាកល្បងខ្ញុំ ថាតើខ្ញុំដឹងគុណ ឬក៏រមិលគុណ? ហើយជនណាដែលដឹងគុណ តាមពិត គឺគេដឹងគុណសម្រាប់ខ្លួនឯងប៉ុណ្ណោះ។ រីឯជនណាដែលរមិលគុណវិញ ពិតប្រាកណាស់ ព្រះជាម្ចាស់របស់ខ្ញុំមហាមានលើសលប់ មហាសប្បុរសបំផុត។

41. គាត់បាននិយាយថា៖ ចូរពួកអ្នកផ្លាស់ប្តូររូបរាងបល្ល័ង្ករបស់ព្រះនាងដល់ព្រះនាង យើងនឹងចាំមើលថាតើព្រះនាងទទួលការចង្អុលបង្ហាញ(ឱ្យស្គាល់វា)ឬក៏ព្រះនាងស្ថិតក្នុងចំណោមអ្នកដែលមិនទទួលបានការចង្អុលបង្ហាញ។

42. នៅពេលដែលព្រះនាងមកដល់ មានគេសួរទៅកាន់ព្រះនាងថា៖ តើនេះជាបល្ល័ង្ករបស់ព្រះនាងឬ? ព្រះនាងក៏តបថា៖ ដូចជាវាហ្នឹងហើយ។(ព្យាការីស៊ូឡៃម៉ានក៏បានពោលថា៖)ហើយគេបានប្រទានដល់យើងនូវចំណេះដឹងមុនព្រះនាង ហើយពួកយើងគឺជាអ្នកប្រគល់ខ្លួន(ជាជនមូស្លីម)។

43. ហើយអ្វីដែលព្រះនាងធ្លាប់បានគោរពសក្ការៈផ្សេងពីអល់ឡោះនោះបានរារាំងព្រះនាង(ពីការគោរពសក្ការៈចំពោះអល់ឡោះតែមួយ)។ ហើយពិតប្រាកដណាស់ ព្រះនាងគឺធ្លាប់ស្ថិតក្នុងចំណោមក្រុមដែលគ្មានជំនឿ។

44. មានគេនិយាយទៅកាន់ព្រះនាងថា៖ សូមព្រះនាងអញ្ជើញចូលទៅក្នុងវិមាននេះចុះ។ ហើយនៅពេលដែលព្រះនាងបានឃើញវា ទ្រង់គិតស្មានថាវាជាទឹក រួចទ្រង់ក៏បានសើយសំពត់របស់ទ្រង់ត្រឹមស្មងជើងរបស់ទ្រង់(ដើម្បីកុំឲ្យទទឹក)។ គាត់(ព្យាការីស៊ូឡៃម៉ាន)ក៏បាននិយាយថា៖ តាមពិត វាជាវិមានមួយដែលក្រាលដោយកញ្ចក់ដែលមានទឹកនៅពីក្រោម។ ពេលនោះ ព្រះនាងក៏បានមានបន្ទូលថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំបានបំពានលើខ្លួនឯង ហើយខ្ញុំសូមប្រគល់ខ្លួន(ចូលសាសនាអ៊ីស្លាម)ជាមួយព្យាការីស៊ូឡៃម៉ានទៅចំពោះអល់ឡោះដែលជាម្ចាស់នៃពិភពទាំងអស់។

45. ហើយជាការពិតណាស់ យើងបានបញ្ជូនទៅកាន់ក្រុមសាមូទនូវព្យាការីសឡេះដែលជាបងប្អូនរបស់ពួកគេ(ដោយគាត់បង្គាប់ថា៖)ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយគត់។ ពេលនោះ ស្រាប់តែពួកគេបានបែកជាពីរក្រុមដោយបានឈ្លោះប្រកែកគ្នាទៅវិញ។

46. គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ហេតុអ្វីបានជាពួកអ្នកប្រញាប់សុំឱ្យទទួលនូវប្រការអាក្រក់មុននឹងប្រការល្អយ៉ាងដូច្នេះ? ហេតុអ្វីបានជាពួកអ្នកមិនសុំការអភ័យទោសពីអល់ឡោះ? សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រឡាញ់។

47. ពួកគេបានតបថា៖ ពួកយើងមានប្រផ្នូលអាក្រក់ដោយសារតែអ្នក និងអ្នកដែលនៅជាមួយអ្នកនេះឯង។ គាត់បានតបថា៖ ប្រផ្នូលអាក្រក់របស់ពួកអ្នក គឺនៅឯអល់ឡោះប៉ុណ្ណោះ។ ផ្ទុយទៅវិញ ពួកអ្នកគឺជាក្រុមដែលត្រូវគេសាកល្បង។

48. ហើយនៅក្នុងទីក្រុងនោះមានបុរសប្រាំបួននាក់ដែលតែងបង្កនិនាសកម្មនៅលើផែនដី ហើយពួកគេមិនព្រមធ្វើឱ្យមានភាពប្រសើរនោះឡើយ។

49. ពួកគេបាននិយាយថា៖ ពួកអ្នកត្រូវស្បថនឹងអល់ឡោះថា ពួកយើងនឹងទៅរកគេ(ព្យាការីសឡេះ) និងក្រុមគ្រួសាររបស់គេនៅយប់នេះ(ដើម្បីសម្លាប់ពួកគេចោល)។ បន្ទាប់មក ពួកយើងប្រាកដជានឹងប្រាប់អាណាព្យាបាលរបស់គេថា៖ ពួកយើងមិនបានចូលរួមក្នុងការសម្លាប់ក្រុមគ្រួសាររបស់គេនោះឡើយ។ ហើយពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលទៀងត្រង់។

50. ហើយពួកគេបានរៀបចំឧបាយកល តែយើងក៏បានរៀបចំគម្រោងការ(តបត)វិញផងដែរ ខណៈពួកគេមិនដឹងខ្លួនឡើយ។

51. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះថា តើលទ្ធផលចុងក្រោយនៃឧបាយកលរបស់ពួកគេទៅជាយ៉ាងណា? ពិតប្រាកដណាស់ យើងបានកម្ទេចពួកគេ និងក្រុមរបស់ពួកគេទាំងអស់គ្នា(ដោយគ្មានសេសសល់ម្នាក់ឡើយ)។

52. ហើយលំនៅឋានរបស់ពួកទាំងនោះបានក្លាយទៅជាទទេស្អាត(គ្មានមនុស្សរស់នៅ)ដោយសារតែការបំពានរបស់ពួកគេ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយសម្រាប់ក្រុមដែលយល់ដឹង។

53. ហើយយើងបានសង្គ្រោះបណ្តាអ្នកមានជំនឿដែលពួកគេធ្លាប់បានកោតខ្លាច(អល់ឡោះ)។

54. ហើយ(ចូរអ្នករំលឹកនូវរឿងរ៉ាវរបស់)ព្យាការីលូត នៅពេលដែលគាត់បាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ តើពួកអ្នកប្រព្រឹត្តនូវទង្វើអសីលធម៌(ស្រឡាញ់ភេទដូចគ្នា)បែបនេះឬ ខណៈដែលពួកអ្នកបានដឹង(ថាវាទង្វើស្មោគគ្រោក)ហើយនោះ?

55. តើពួកអ្នកពិតជាយកបុរស។(ដូចគ្នា)មកបំពេញចំណង់តណ្ហាក្រៅពីស្ត្រីបែបនេះឬ? ផ្ទុយទៅវិញ ពួកអ្នកគឺជាក្រុមមួយដែលល្ងង់ខ្លៅបំផុត។

56. ហើយការឆ្លើយតបនៃក្រុមរបស់គាត់ គឺគ្មានអ្វីក្រៅពីពួកគេនិយាយថា៖ ចូរពួកអ្នកបណ្តេញក្រុមគ្រួសាររបស់លូតចេញពីភូមិស្រុករបស់ពួកអ្នកចុះ។ ជាការពិតណាស់ ពួកគេជាមនុស្សស្អាតស្អំ។

57. ដូចនេះ យើងក៏បានសង្គ្រោះរូបគេ(ព្យាការីលូត)និងក្រុមគ្រួសាររបស់គេ លើកលែងតែភរិយារបស់គេប៉ុណ្ណោះដែលយើងបានកំណត់ឱ្យនាងស្ថិតក្នុងចំណោមអ្នកដែលត្រូវទទួលទណ្ឌកម្ម។

58. ហើយយើងបានបញ្ចុះភ្លៀង(ដុំថ្ម)ទៅកាន់ពួកគេ។ ភ្លៀងដែលធ្លាក់លើពួកដែលត្រូវគេព្រមាននោះ គឺពិតជាអាក្រក់បំផុត។

59. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ ហើយសូមសុខសន្តិភាពកើតមានដល់បណ្តាខ្ញុំបម្រើរបស់ទ្រង់ដែលទ្រង់បានជ្រើសរើស(ជាអ្នកនាំសារ)។ តើអល់ឡោះជាម្ចាស់ប្រសើរជាង ឬក៏អ្វីដែលពួកគេធ្វើស្តីរិកនោះ(ល្អប្រសើរជាង)?

60. ឬមួយអ្នកដែលបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយទ្រង់បានបញ្ចុះទៅកាន់ពួកអ្នកនូវទឹកភ្លៀងពីលើមេឃ ហើយតាមរយៈទឹកភ្លៀងនេះ យើងបានបណ្តុះចេញមកនូវសួនឧទ្យានជាច្រើនដែលមានភាពស្រស់បំព្រង(ល្អប្រសើរជាង)ដោយពួកអ្នកមិនអាចបណ្តុះនូវដើមឈើទាំងនោះបានឡើយ? តើមានព្រះឯណា(ដែលអាចធ្វើដូច្នោះ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ដែរឬទេ? ផ្ទុយទៅវិញ ពួកគេគឺជាក្រុមដែលងាកចេញ(ពីការពិត)។

61. ឬមួយអ្នកដែលបានធ្វើឱ្យផែនដីមានលំនឹង ហើយបានបង្កើតឲ្យមានទន្លេជាច្រើននៅចន្លោះវា ហើយនិងបានបង្កើតឱ្យមានភ្នំជាច្រើននៅលើវា ព្រមទាំងបង្កើតឱ្យមានរបាំងនៅចន្លោះរវាងសមុទ្រពីរ(ល្អប្រសើរជាង)? តើមានព្រះឯណា(ដែលអាចធ្វើដូច្នោះ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ដែរឬទេ? ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

62. ឬមួយអ្នកដែលឆ្លើយតបចំពោះអ្នកដែលជួបទុក្ខលំបាកនៅពេលដែលគេបួងសួងសុំពីទ្រង់ និងដកយកនូវរឿងអាក្រក់(ចេញពីរូបគេ) ព្រមទាំងបង្កើតពួកអ្នកឲ្យស្នងការគ្រប់គ្រងនៅលើផែនដី(ល្អប្រសើរជាង)? តើមានព្រះឯណា(ដែលអាចប្រោសប្រទានដូច្នោះ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ដែរឬទេ? អ្វីដែលពួកអ្នកយកធ្វើជាមេរៀន គឺតិចតួចបំផុត។

63. ឬក៏អ្នកដែលចង្អុលបង្ហាញពួកអ្នកនៅក្នុងភាពងងឹតទាំងនៅលើដីគោក និងនៅលើផ្ទៃសមុទ្រ និងជាអ្នកដែលបញ្ជូនខ្យល់ជាដំណឹងល្អបញ្ជាក់ពីក្តីមេត្តាករុណារបស់ទ្រង់(ទឹកភ្លៀង)ដែលនៅខាងមុខ(ល្អប្រសើរជាង)? តើមានព្រះឯណា(ដែលអាចធ្វើដូច្នោះ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ដែរឬទេ? អល់ឡោះទ្រង់មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស្តីរិក។

64. ឬមួយក៏អ្នកដែលផ្តើមបង្កើតពីដំបូង បន្ទាប់មក ទ្រង់ធ្វើឱ្យគេរស់ឡើងវិញ(ក្រោយពេលស្លាប់) និងជាអ្នកដែលប្រទានលាភសក្ការៈដល់ពួកអ្នកពីលើមេឃ និងផែនដី(ល្អប្រសើរជាង)? តើមានព្រះឯណា(ដែលអាចធ្វើដូច្នោះ)រួមជាមួយនឹងអល់ឡោះជាម្ចាស់ដែរឬទេ? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកនាំយកនូវអំណះអំណាងរបស់ពួកអ្នកមក ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ។

65. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ គ្មាននរណាម្នាក់ដែលនៅលើមេឃជាច្រើនជាន់ និងផែនដីអាចដឹងពីប្រការអាថ៌កំបាំងនោះឡើយ លើកលែងតែអល់ឡោះជាម្ចាស់(តែមួយគត់) ហើយពួកគេក៏មិនដឹងដែរថា តើពេលណាដែលពួកគេត្រូវបានគេបង្កើតឱ្យរស់ឡើងវិញនោះ។

66. ផ្ទុយទៅវិញ ពួកគេនឹងដឹងយ៉ាងច្បាស់នៅថ្ងៃបរលោក? ផ្ទុយទៅវិញ (នៅក្នុងលោកិយ)ពួកគេមានការមន្ទិលសង្ស័យចំពោះវា។ មិនតែប៉ុណ្ណោះ ពួកគេថែមទាំងងងឹត(មិនដឹងអ្វីសោះ)ពីវាទៀតផង។

67. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ តើនៅពេលដែលពួកយើងនិងជីដូនជីតារបស់ពួកយើងបាន(ស្លាប់)ក្លាយទៅជាដីហើយនោះ តើពួកយើងពិតជាត្រូវគេបង្កើតឱ្យរស់ឡើងវិញឬ?

68. ជាការពិតណាស់ ពួកយើងនិងជីដូនជីតារបស់ពួកយើងធ្លាប់ត្រូវបានគេសន្យាបែបនេះតាំងពីមុនមកម្ល៉េះ។ នេះគ្មានអ្វីក្រៅពីរឿងព្រេងនិទានរបស់អ្នកជំនាន់មុនប៉ុណ្ណោះ។

69. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នកធ្វើដំណើរនៅលើផែនដី ហើយពិចារណាមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកឧក្រិដ្ឋជននោះទៅជាយ៉ាងណា?

70. ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)កុំកើតទុក្ខចំពោះពួកគេ និងកុំពិបាកចិត្តដោយសារអ្វីដែលពួកគេបានប្រើឧបាយកល។

71. ហើយពួកគេបាននិយាយថា៖ តើការសន្យានេះនឹងកើតឡើងនៅពេលណា ប្រសិនបើពួកអ្នកជាអ្នកដែលទៀងត្រង់មែននោះ?

72. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ ជួនកាលអ្វី(ទណ្ឌកម្ម)មួយចំនួនដែលពួកអ្នកបានសុំឱ្យវាធាប់មកដល់នោះ បានខិតមកជិតពួកអ្នករួចទៅហើយ។

73. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់មានក្តីសប្បុរសបំផុតចំពោះមនុស្សលោក។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនដឹងគុណឡើយ។

74. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់ដឹងនូវអ្វីដែលចិត្តរបស់ពួកគេលាក់បាំង និងអ្វីដែលពួកគេលាតត្រដាង។

75. ហើយគ្មានអាថ៌កំបាំងណាមួយនៅលើមេឃនិងនៅលើផែនដីនោះឡើយ លើកលែងតែវាត្រូវបានកត់ត្រាទុកនៅក្នុងគម្ពីរដ៏ច្បាស់លាស់(ឡាវហ៊ុលម៉ះហ្វូស)។

76. ពិតប្រាកដណាស់ គម្ពីរគួរអាននេះ គឺនិទានប្រាប់ដល់អម្បូរអ៊ីស្រាអែលនូវរឿងរ៉ាវជាច្រើនដែលពួកគេបានខ្វែងគំនិតគ្នាចំពោះវា។

77. ហើយពិតប្រាកដណាស់វា(គម្ពីរគួរអាន)គឺជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់បណ្តាអ្នកដែលមានជំនឿ។

78. ហើយពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងកាត់សេចក្តីរវាងពួកគេដោយច្បាប់របស់ទ្រង់។ ហើយទ្រង់មហាខ្លាំងពូកែ មហាដឹងបំផុត។

79. ដូច្នេះ ចូរអ្នកប្រគល់ការទុកចិត្តលើអល់ឡោះចុះ។ ពិតប្រាកដណាស់ អ្នកស្ថិតនៅលើភាពត្រឹមត្រូវយ៉ាងច្បាស់លាស់។

80. ពិតប្រាកដណាស់ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនអាចធ្វើឱ្យអ្នកដែលស្លាប់អាចស្តាប់ឮបានឡើយ ហើយក៏មិនអាចធ្វើឱ្យអ្នកដែលថ្លង់អាចស្តាប់ឮការអំពាវនាវ(របស់អ្នក)នោះដែរ នៅពេលណាដែលពួកគេត្រឡប់ក្រោយ(បែរចេញពីអ្នក)ហើយនោះ។

81. ហើយអ្នកក៏មិនមែនជាអ្នកផ្តល់ការចង្អុលបង្ហាញដល់អ្នកងងឹតភ្នែកឲ្យចេញពីភាពវង្វេងរបស់ពួកគេនោះដែរ។ អ្នកអាចធ្វើឲ្យស្តាប់ឮតែចំពោះអ្នកដែលមានជំនឿចំពោះវាក្យខណ្ឌរបស់យើងប៉ុណ្ណោះ ព្រោះពួកគេ គឺជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

82. ហើយនៅពេលដែលពាក្យសម្តី(ដាក់ទណ្ឌកម្ម)បានធ្លាក់ទៅលើពួកគេហើយនោះ យើងនឹងបញ្ចេញទៅកាន់ពួកគេនូវសត្វមួយប្រភេទចេញពីក្នុងដីដោយវានិយាយទៅកាន់ពួកគេថា ជាការពិតណាស់ មនុស្សលោកមិនបានជឿជាក់ចំពោះសញ្ញាភស្តុតាងរបស់យើងឡើយ។

83. ហើយនៅថ្ងៃដែលយើងនឹងប្រមូលផ្តុំរាល់ប្រជាជាតិទាំងអស់នូវក្រុមមួយក្នុងចំណោមពួកដែលបានបដិសេធនឹងសញ្ញាភស្តុតាងទាំងឡាយរបស់យើង ដោយពួកគេត្រូវបានបែងចែកជាក្រុមៗ។

84. លុះនៅពេលដែលពួកគេបានមកដល់(កន្លែងជំនុំជម្រះ)ទ្រង់បានមានបន្ទូលថា៖ តើពួកអ្នកបដិសេធនឹងបណ្តាវាក្យខណ្ឌរបស់យើងឬ ខណៈដែលពួកអ្នកមិនបានដឹងច្បាស់ផងនោះ? ឬពួកអ្នកបានធ្វើអ្វីខ្លះ?

85. ហើយពាក្យសម្តី(ទណ្ឌកម្ម)បានធ្លាក់ទៅលើពួកគេដោយសារតែពួកគេបានបំពាន។ ដូច្នេះ ពួកគេមិនអាចនិយាយ(ដោះសារ)បានឡើយ។

86. តើពួកគេមិនបានឃើញទេឬថា ពិតប្រាកដណាស់ យើងបានបង្កើតពេលយប់ដើម្បីឱ្យពួកគេសម្រាកនៅក្នុងវា និង(បានបង្កើត)ពេលថ្ងៃដើម្បីឱ្យពួកគេអាចមើលឃើញ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាភស្តុតាងសម្រាប់ក្រុមដែលមានជំនឿ។

87. ហើយ(ចូរអ្នករំលឹក)នៅថ្ងៃដែលគេ(ម៉ាឡាអ៊ីកាត់)ផ្លុំត្រែ។ ពេលនោះ អ្នកដែលនៅលើមេឃជាច្រើនជាន់និងអ្នកដែលនៅលើផែនដីទាំងអស់មានការភ័យរន្ធត់ លើកលែងតែជនណាដែលទ្រង់មានចេតនាប៉ុណ្ណោះ។ ហើយរាល់ការៈទាំងអស់នៅថ្ងៃនោះ នឹងមកជួបទ្រង់ដោយការគោរពតាម។

88. ហើយអ្នកនឹងឃើញភ្នំទាំងឡាយដែលអ្នកគិតថាវានៅនឹងថ្កល់(មួយកន្លែង)នឹងរសាត់យ៉ាងលឿនដូចពពក។ ជាការបង្កើតរបស់អល់ឡោះដែលធ្វើឲ្យរាល់អ្វីៗទាំងអស់មានភាពឥតខ្ចោះ។ ពិតប្រាកដណាស់ ទ្រង់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

89. ជនណាដែលបាននាំមកនូវប្រការល្អ សម្រាប់រូបគេនឹងទទួលបាននូវអ្វីដែលប្រសើរជាងនោះ។ ហើយពួកគេជាអ្នកដែលមានសុវត្ថិភាពបំផុតពីការភ័យរន្ធត់នៅថ្ងៃនោះ។

90. តែជនណាដែលបាននាំមកនូវប្រការអាក្រក់វិញ គេនឹងគ្រវែងរូបគេទៅក្នុងឋាននរកដោយផ្កាប់មុខ។ (ហើយមានគេនិយាយទៅកាន់ពួកគេថា៖) តើគេមិនតបស្នងដល់ពួកអ្នកក្រៅតែពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តទេឬ?

91. (ចូរអ្នកពោលថា៖) តាមពិត គេបានបង្គាប់ខ្ញុំឲ្យគោរពសក្ការៈចំពោះព្រះជាម្ចាស់នៃទឹកដីនេះ(ទឹកដីម៉ាក្កៈ)ដែលទ្រង់ចាត់ទុកវាជាទឹកដីពិសិដ្ឋ។ ហើយអ្វីៗទាំងអស់ គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយរូបខ្ញុំត្រូវបានគេបង្គាប់ឲ្យស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

92. ហើយ(គេក៏បង្គាប់)ឱ្យខ្ញុំសូត្រគម្ពីរគួរអាន(ឱ្យមនុស្សលោកស្តាប់)ផងដែរ។ ដូច្នេះ ជនណាដែលទទួលបានការចង្អុលបង្ហាញ តាមពិតគេទទួលបានការចង្អុលបង្ហាញសម្រាប់ខ្លួនឯង។ រីឯជនណាដែលវង្វេងវិញនោះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិតរូបខ្ញុំគ្រាន់តែស្ថិតក្នុងចំណោមអ្នកដាស់តឿនព្រមានប៉ុណ្ណោះ។

93. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ។ ទ្រង់នឹងបង្ហាញឲ្យពួកអ្នកបានឃើញនូវសញ្ញាភស្តុតាងទាំងឡាយរបស់ទ្រង់ ហើយពួកអ្នកនឹងស្គាល់វា។ ហើយព្រះជាម្ចាស់របស់អ្នកមិនព្រងើយកន្តើយពីអ្វីដែលពួកអ្នកប្រព្រឹត្តនោះឡើយ។

ជំពូក អាល់ក៏សស្យ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ត ស៊ីន មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ទាំងនេះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ដ៏ច្បាស់លាស់។

3. យើងនឹងនិទានឱ្យអ្នកស្តាប់(ឱអ្នកនាំសារមូហាំម៉ាត់)នូវរឿងរ៉ាវយ៉ាងពិតប្រាកដរបស់ព្យាការីមូសា និងហ្វៀរអោនសម្រាប់ក្រុមដែលមានជំនឿ។

4. ជាការពិតណាស់ ហ្វៀរអោនគឺជាអ្នកដែលក្រអឺតក្រទមនៅលើទឹកដី(អេហ្ស៊ីប) ហើយគេបានធ្វើឱ្យអ្នកដែលនៅទីនោះបែកបាក់ជាក្រុមៗ។ គេជិះជាន់ធ្វើបាបក្រុមមួយក្នុងចំណោមពួកគេ(អម្ប្រាអ៊ីស្រាអែល)ដោយសម្លាប់កូនប្រុសៗរបស់ពួកគេ ហើយទុកជីវិតឱ្យកូនស្រីៗរបស់ពួកគេ។ ពិតប្រាកដណាស់ រូបគេស្ថិតនៅក្នុងចំណោមពួកដែលបង្កវិនាសកម្ម។

5. ហើយយើងមានបំណងចង់ផ្តល់នូវការប្រោសប្រទានទៅដល់អ្នកដែលត្រូវគេជិះជាន់ធ្វើបាបនៅលើទឹកដី(អេហ្ស៊ីប) និងធ្វើឱ្យពួកគេក្លាយទៅជាមេដឹកនាំ ព្រមទាំងធ្វើឱ្យពួកគេក្លាយជាអ្នកដែលទទួលមរតក(បន្ទាប់ពីហ្វៀរអោន)។

6. ហើយយើងនឹងប្រទានឱ្យពួកគេ(អម្ប្រាអ៊ីស្រាអែល)នូវការគ្រប់គ្រងនៅលើផែដី។ ហើយយើងនឹងឱ្យហ្វៀរអោន និងហាម៉ាន ព្រមទាំងពលទាហានរបស់គេទាំងពីរបានឃើញនូវអ្វីដែលពួកគេខ្លាចព្រួយបារម្ភអំពីពួកគេ(អម្ប្រាអ៊ីស្រាអែល)។

7. ហើយយើងបានផ្តល់សារទៅកាន់ម្តាយរបស់ព្យាការីមូសាថា៖ ចូរនាងបំបៅគេចុះ។ តែប្រសិនបើនាងមានការព្រួយបារម្ភចំពោះរូបគេ ចូរបណ្តែតគេតាមទន្លេ(នីល)ចុះ។ ហើយចូរនាងកុំព្រួយបារម្ភ និងកុំកើតទុក្ខ។ ពិតប្រាកដណាស់ យើងនឹងត្រឡប់រូបគេមកកាន់នាងវិញ ហើយនឹងធ្វើឱ្យរូបគេស្ថិតក្នុងចំណោមអ្នកនាំសារទាំងឡាយ។

8. ពេលនោះ ក្រុមរបស់ហ្វៀនអោនក៏បានរើសយកគេ(ទៅចិញ្ចឹម)ដែលរូបគេនឹងក្លាយទៅជាសត្រូវ និងជាក្តីកង្វល់ចំពោះពួកគេ។ ពិតប្រាកដណាស់ ហ្វៀរអោន និងហាម៉ាន ព្រមទាំងពលទាហានរបស់គេទាំងពីរ គឺជាពួកដែលប្រព្រឹត្តបាបកម្ម។

9. ហើយភរិយារបស់ហ្វៀនអោនបាននិយាយថា៖ (ក្មេងប្រុសម្នាក់នេះ)ជាប្រភពនៃក្តីរីករាយសម្រាប់ខ្ញុំនិងសម្រាប់អ្នក។ ចូរអ្នកកុំសម្លាប់គេអី សង្ឃឹមថាគេអាចនឹងមានប្រយោជន៍ដល់យើង ឬក៏យកគេធ្វើជាកូនចិញ្ចឹមតែម្តងក៏បាន។ តែពួកគេពុំបានដឹងនោះឡើយ។

10. ហើយដួងចិត្តម្តាយរបស់ព្យាការីមូសា ក្លាយទៅជាទទេស្អាត។ នាងស្ទើរតែបង្ហាញឱ្យគេបានដឹងទៅហើយ(ថានោះជាកូនរបស់នាង) ប្រសិនបើយើងមិនផ្តល់លំនឹងដល់ដួងចិត្តរបស់នាងដើម្បីឱ្យនាងស្ថិតក្នុងចំណោមដែលអ្នកមានជំនឿទេនោះ។

11. ហើយគាត់បាននិយាយទៅកាន់បងស្រីរបស់ព្យាការីមូសាថា៖ ចូរឯងតាមឃ្លាំមើលគេចុះ។ ពេលនោះ នាងក៏បានឈរមើលគេពីចម្ងាយ ខណៈដែលពួកគេមិនបានដឹងឡើយ។

12. ហើយយើងបានដាក់បម្រាមលើរូបគេ(មិនឲ្យបៅដោះ)ពីគ្រប់ស្ត្រីទាំងអស់តាំងពីមុន។ ពេលនោះ បងស្រីរបស់ព្យាការីមូសាបាននិយាយថា៖ តើចង់ឱ្យខ្ញុំចង្អុលបង្ហាញពួកអ្នកពីគ្រួសារមួយដែលអាចចិញ្ចឹមបីបាច់គេឲ្យពួកអ្នក ហើយពួកគេអាចថ្នាក់ថ្នមមើលថែគេបានយ៉ាងល្អដែរឬទេ?

13. ពេលនោះ យើងក៏បានត្រឡប់រូបគេទៅកាន់ម្តាយរបស់គេវិញដើម្បីឱ្យនាងមានក្តីរីករាយ ហើយឈប់កើតទុក្ខ និងដើម្បីឱ្យនាងដឹងថា ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ ក៏ប៉ុន្តែភាគច្រើននៃពួកគេមិនបានដឹងឡើយ។

14. ហើយនៅពេលដែលគេមានកម្លាំងមាំមួន និងធំពេញវ័យ យើងបានប្រទានដល់គេនូវគតិបណ្ឌិត និងចំណេះដឹង។ ក៏ដូច្នោះដែរ យើងនឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អ។

15. ហើយគាត់បានចូលទៅក្នុងទីក្រុងក្នុងពេលដែលមនុស្សទាំងឡាយសម្រាក។ ពេលនោះ គាត់បានប្រទះឃើញបុរសពីរនាក់កំពុងតែវាយតប់គ្នា ដោយម្នាក់មកពីក្រុមរបស់គាត់(អម្ប្រាអ៊ីស្រាអែល) ហើយម្នាក់ទៀត មកពីក្រុមសត្រូវរបស់គាត់(ក្រុមរបស់ហ្វៀរអោន)។ នៅពេលនោះ បុរសម្នាក់ដែលមកពីក្រុមរបស់គាត់ក៏បានសុំឱ្យគាត់ជួយតទល់នឹងសត្រូវរបស់ខ្លួន។ ព្យាការីមូសាក៏បានដាល់បុរសនោះ។ ភ្លាមនោះ គេក៏បានបាត់បង់ជីវិត។ គាត់ក៏និយាយថា៖ នេះគឺស្ថិតក្នុងចំណោមទង្វើរបស់ស្មែតន។ ពិតប្រាកដណាស់ ស្មែតន គឺជាសត្រូវ និងជាអ្នកធ្វើឱ្យវង្វេងយ៉ាងច្បាស់លាស់។

16. គាត់បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! ខ្ញុំពិតជាបានបំពានលើខ្លួនឯង។ ហេតុនេះ សូមព្រះអង្គមេត្តាអភ័យទោសដល់ខ្ញុំផង។ ពេលនោះ ទ្រង់ក៏បានអភ័យទោសដល់គាត់។ ពិតប្រាកដណាស់ ទ្រង់គឺជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

17. គាត់បានបួងសួងទៀតថា៖ បពិត្រព្រះជាម្ចាស់! តាមរយៈអ្វីដែលព្រះអង្គបានប្រោសប្រទានដល់ខ្ញុំ ខ្ញុំនឹងមិនធ្វើខ្លួនជាអ្នកដែលជួយដល់ពួកឧក្រិដ្ឋជនជាដាច់ខាត។

18. ក្រោយមកវាក៏បានធ្វើឱ្យគាត់ស្ថិតនៅក្នុងទីក្រុងដោយភាពភ័យខ្លាច និងចាំឃ្លាំមើល។ ពេលនោះ អ្នកដែលសុំឱ្យគាត់ជួយកាលពីម្សិលមិញ ក៏បានស្រែកឲ្យគាត់ជួយម្តងទៀត។ ព្យាការីមូសាក៏បាននិយាយទៅកាន់បុរសនោះថា៖ ពិតប្រាកដណាស់ អ្នកពិតជាអ្នកដែលវង្វេងយ៉ាងច្បាស់លាស់។

19. ហើយនៅពេលដែលគាត់មានបំណងចង់ចាប់អ្នកដែលជាសត្រូវរបស់ពួកគាត់ទាំងពីរ បុរសនោះក៏បាននិយាយថា៖ ឱមូសា! តើអ្នកចង់សម្លាប់ខ្ញុំ ដូចដែលអ្នកបានសម្លាប់មនុស្សម្នាក់កាលពីម្សិលមិញឬ? អ្នកគ្មានបំណងអ្វីក្រៅពីចង់ធ្វើជាអ្នកដែលក្អេងក្អាងនៅលើផែនដីនេះនោះឡើយ ហើយអ្នកក៏មិនចង់ធ្វើជាអ្នកដែលផ្សះផ្សារ(រវាងមនុស្សលោក)នោះដែរ។

20. ហើយមានបុរសម្នាក់ធ្វើដំណើរយ៉ាងប្រញាប់ប្រញាល់មកពីជាយក្រុងបានមកដល់(ព្យាការីមូសា)។ គាត់បាននិយាយថា៖ ឱមូសា! ពិតប្រាកដណាស់ ពួកមន្ត្រីទាំងឡាយកំពុងតែពិគ្រោះពិភាក្សាគ្នាអំពីរឿងអ្នកដើម្បីសម្លាប់អ្នក។ ដូច្នេះ ចូរអ្នកចាកចេញ(ពីទឹកដីនេះ)ចុះ។ ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកណែនាំដ៏ល្អម្នាក់សម្រាប់អ្នក។

21. ពេលនោះ គាត់ក៏បានចាកចេញពីទីនោះទាំងភ័យខ្លាច និងចាំឃ្លាំមើល។ គាត់បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាសង្គ្រោះរូបខ្ញុំពីក្រុមដែលបំពានផង។

22. ហើយនៅពេលដែលគាត់ធ្វើដំណើរតម្រង់ឆ្ពោះទៅកាន់ទឹកដីម៉ាទយ៉ាន់ គាត់បានពោលថា៖ សង្ឃឹមថាព្រះជាម្ចាស់របស់ខ្ញុំនឹងចង្អុលបង្ហាញខ្ញុំទៅកាន់មាគ៌ាដែលល្អ។

23. ហើយនៅពេលដែលគាត់បានទៅដល់(អណ្តូង)ទឹកនៃតំបន់ម៉ាទយ៉ាន់ គាត់បានឃើញមនុស្សមួយក្រុមកំពុងដងទឹកឱ្យសត្វផឹក ហើយគាត់ក៏បានឃើញស្ត្រីពីរនាក់ផ្សេងទៀតក្រៅពីពួកគេដែលកំពុងតែរារាំងសត្វរបស់ខ្លួន(ពីទឹកនោះ)។ គាត់បានសួរថា៖ តើអ្នកទាំងពីរមានបញ្ហាអ្វី? គេទាំងពីរបានតបថា៖ ពួកខ្ញុំមិនអាចឱ្យទឹកផឹក(ដល់សត្វរបស់ពួកយើង)ឡើយ ទាល់តែពួកគង្វាលទាំងនោះចាកចេញ។ ហើយឪពុករបស់ពួកខ្ញុំ ជាមនុស្សចាស់ជរា។

24. ពេលនោះ គាត់ក៏បានឲ្យទឹកដល់សត្វរបស់អ្នកទាំងពីរនោះផឹក។ បន្ទាប់មក គាត់បានត្រឡប់ទៅរកម្លប់វិញ(ដើម្បីសម្រាក) ហើយគាត់បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំពិតត្រូវការនូវអ្វីដែលល្អដែលព្រះអង្គប្រទានដល់ខ្ញុំ។

25. ពេលនោះ ស្ត្រីម្នាក់ក្នុងចំណោមអ្នកទាំងពីរក៏បានដើរមកជួបនឹងព្យាការីមូសាដោយភាពអៀនខ្មាស។ នាងនិយាយថា៖ ពិតប្រាកដណាស់ ឪពុករបស់ខ្ញុំគាត់អញ្ជើញអ្នក(ទៅជួបគាត់)ដើម្បីផ្តល់ថ្លៃឈ្នួលដល់អ្នកចំពោះការដែលអ្នកបានឱ្យទឹកដល់សត្វរបស់ពួកយើងផឹក។ នៅពេលដែលព្យាការីមូសាបានទៅជួបគាត់ ហើយបានរៀបរាប់ពីដំណើររឿងប្រាប់ដល់គាត់ គាត់ក៏ពោលថា៖ សូមអ្នកកុំខ្លាច! អ្នកបានរួចផុតពីក្រុមដែលបំពានហើយ។

26. ស្ត្រីម្នាក់ក្នុងចំណោមអ្នកទាំងពីរបាននិយាយថា៖ ឱលោកឪពុកជាទីស្រលាញ់! សូមលោកឪពុកជួលគាត់តែម្តងទៅ។ ពិតប្រាកដណាស់ មនុស្សដ៏ប្រសើរដែលលោកឪពុកជួលនោះ គឺមានទាំងកម្លាំងខ្លាំងក្លា និងភាពស្មោះត្រង់។

27. ឪពុករបស់នាងបាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំមានបំណងរៀបការម្នាក់ក្នុងចំណោមកូនស្រីទាំងពីររបស់ខ្ញុំឱ្យទៅអ្នក ដោយអ្នកត្រូវធ្វើការឱ្យខ្ញុំរយៈពេលប្រាំបីឆ្នាំ។ ប្រសិនបើអ្នកចង់បង្ក្រប់រយៈពេលដប់ឆ្នាំ វាគឺស្ថិតនៅលើអ្នក។ ហើយខ្ញុំគ្មានបំណងធ្វើឱ្យអ្នកមានការលំបាកឡើយ។ អ្នកនឹងឃើញថា ខ្ញុំស្ថិតក្នុងចំណោមមនុស្សល្អត្រឹមត្រូវម្នាក់ ប្រសិនបើអល់ឡោះមានចេតនា។

28. គាត់បានតបថា៖ នេះជាកិច្ចព្រមព្រៀងរវាងខ្ញុំនិងអ្នក។ អំឡុងពេលណាមួយក៏ដោយក្នុងអំឡុងពេលទាំងពីរ(ប្រាំបីឆ្នាំ ឬដប់ឆ្នាំ)ដែលខ្ញុំបានបំពេញ គឺគ្មានការបំពានមកលើខ្ញុំនោះឡើយ។ ហើយអល់ឡោះជាអ្នកឃ្លាំមើលចំពោះអ្វីដែលពួកយើងនិយាយ។

29. នៅពេលដែលព្យាការីមូសាបានបំពេញតាមកាលកំណត់រួចរាល់ ហើយគាត់បានធ្វើដំណើរជាមួយនឹងក្រុមគ្រួសាររបស់គាត់ គាត់ក៏បានឃើញពន្លឺភ្លើងមួយនៅក្បែរភ្នំតួរ។ គាត់ក៏បានពោលទៅកាន់ក្រុមគ្រួសាររបស់គាត់ថា៖ សូមពួកអ្នកនៅទីនេះសិនចុះ។ ពិតប្រាកដណាស់ ខ្ញុំបានឃើញពន្លឺភ្លើងមួយ។ សង្ឃឹមថាខ្ញុំនឹងនាំដំណឹងខ្លះៗពីវាមកកាន់ពួកអ្នក ឬក៏នាំយកដុំភ្លើងមកបង្កាត់ឱ្យពួកអ្នកដើម្បីឱ្យពួកអ្នកមានភាពកក់ក្តៅ។

30. ហើយនៅពេលដែលគាត់បានទៅដល់ទីនោះ គេ(អល់ឡោះ)បានស្រែកហៅគាត់ចេញពីដើមឈើមួយដើមនៅក្បែរជ្រលងភ្នំខាងស្តាំនៅទឹកន្លែងដែលប្រកបដោយពរជ័យថា៖ ឱមូសា! ពិតប្រាកដណាស់ យើងគឺអល់ឡោះ ជាព្រះជាម្ចាស់នៃពិភពទាំងអស់។

31. ហើយចូរអ្នកបោះដំបងរបស់អ្នកចុះ។ នៅពេលដែលគាត់បានឃើញដំបងនោះមានចលនាប្រៀបដូចជាសត្វពស់ គាត់ក៏រត់បកក្រោយដោយមិនត្រឡប់មកវិញឡើយ។ (ទ្រង់បានមានបន្ទូលថា៖) ឱមូសា! ចូរអ្នកចូលមក ហើយកុំខ្លាច។ ពិតប្រាកដណាស់ រូបអ្នកស្ថិតក្នុងចំណោមអ្នកដែលមានសុវត្ថិភាពហើយ។

32. ហើយចូរអ្នកដាក់ដៃរបស់អ្នកទៅក្នុងហោប៉ៅអាវរបស់អ្នកចុះ នោះវានឹងបញ្ចេញពន្លឺសភ្លឺថ្លាដោយពុំមែនជាប្រការអាក្រក់ឡើយ។ ហើយចូរអ្នកឱបដៃរបស់អ្នកដើម្បីបំបាត់ភាពភ័យខ្លាច។ ពិតណាស់ ទាំងពីរ គឺជាសញ្ញាភស្តុតាងពីរពីព្រះជាម្ចាស់របស់អ្នកទៅកាន់ហ្វៀរអោន និងពួកមន្ត្រីរបស់គេ។ ពិតប្រាកដណាស់ ពួកគេគឺជាក្រុមដែលប្រព្រឹត្តល្មើស។

33. គាត់បានតបថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំបានសម្លាប់ជីវិតម្នាក់នៃពួកគេ ហើយខ្ញុំខ្លាចពួកគេនឹងសម្លាប់ខ្ញុំវិញ។

34. ហើយបងប្រុសរបស់ខ្ញុំ ហារូន គាត់និយាយច្បាស់ជាងខ្ញុំ។ ហេតុនេះ សូមព្រះអង្គមេត្តាបញ្ជូនគាត់ឱ្យទៅជាមួយខ្ញុំជាអ្នកជួយបញ្ជាក់ពីសច្ចភាពរបស់ខ្ញុំ។ ពិតប្រាកដណាស់ ខ្ញុំបាម្ភខ្លាចពួកគេបដិសេធនឹងខ្ញុំ។

35. ទ្រង់បានតបថា៖ យើងនឹងជួយពង្រឹងដល់អ្នកតាមរយៈបងប្រុសរបស់អ្នក ហើយយើងនឹងប្រទានឱ្យអ្នកទាំងពីរនូវសញ្ញាភស្តុតាង។ ដូចនេះ ពួកគេមិនអាចធ្វើឱ្យប្រការអាក្រក់ណាមួយប៉ះពាល់ដល់អ្នកទាំងពីរបានឡើយ។ តាមរយៈបណ្តាភស្តុតាងទាំងឡាយរបស់យើង អ្នកទាំងពីរ ហើយនិងអ្នកដែលដើរតាមអ្នកទាំងពីរ គឺជាអ្នកដែលទទួលបានជោគជ័យ។

36. ហើយនៅពេលដែលព្យាការីមូសាបាននាំមកកាន់ពួកគេនូវសញ្ញាភស្តុតាងទាំងឡាយរបស់យើងដ៏ច្បាស់លាស់ ពួកគេបែរជានិយាយថា៖ នេះគ្មានអ្វីក្រៅពីមន្តអាគមដែលគេប្រឌិតវាឡើងប៉ុណ្ណោះ ហើយពួកយើងមិនដែលបានឮរឿងបែបនេះពីដីដូនដីតារបស់ពួកយើងជំនាន់មុនៗនោះឡើយ។

37. ហើយព្យាការីមូសាបាននិយាយថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់ដឹងបំផុតចំពោះជនណាដែលបាននាំមកនូវការចង្អុលបង្ហាញអំពីទ្រង់ ហើយនិងជនណាដែលទទួលបាននូវលទ្ធផលចុងក្រោយដ៏គួរឱ្យកោតសរសើរ។ ពិតប្រាកដណាស់ ពួកដែលបំពាននឹងមិនបានទទួលជោគជ័យនោះឡើយ។

38. ហើយហ្វៀរអោនបាននិយាយថា៖ ឱមន្ត្រីទាំងឡាយ! យើងមិនដែលដឹងសោះថា ពួកអ្នកមានព្រះផ្សេងដែលត្រូវគោរពសក្ការៈក្រៅពីយើងនោះ។ ដូច្នេះ ឱហាម៉ាន! ចូរអ្នកដុតដីធ្វើជាដុំឥដ្ឋឱ្យយើង រួចសង់វិមានយ៉ាងខ្ពស់មួយឱ្យយើង ដើម្បីឱ្យយើងឡើងទៅមើលព្រះជាម្ចាស់របស់មូសា។ ពិតប្រាកដណាស់ យើងគិតថារូបគេគឺស្ថិតក្នុងចំណោមអ្នកដែលភូតកុហក។

39. ហើយគេ(ហ្វៀរអោន)និងពលទាហានរបស់គេបានក្រអឺតក្រទមនៅលើទឹកដី(អេហ្ស៊ីប)ដោយមិនត្រឹមត្រូវ។ ហើយពួកគេគិតថា ពិតណាស់ ពួកគេនឹងមិនត្រូវគេនាំត្រឡប់មកកាន់យើងវិញឡើយ។

40. ដូច្នេះ យើងក៏បានក្របួចគេ និងពលទាហានទាំងឡាយរបស់គេ រួចក៏បោះពួកគេចូលទៅក្នុងសមុទ្រ។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិនិត្យមើលចុះថា តើលទ្ធផលចុងក្រោយរបស់ពួកដែលបំពានទៅជាយ៉ាងណា?

41. ហើយយើងបានធ្វើឱ្យពួកគេក្លាយជាមេដឹកនាំដែលអំពាវនាវទៅកាន់ឋាននរក។ ហើយនៅថ្ងៃបរលោក ពួកគេនឹងមិនត្រូវបានគេជួយឡើយ។

42. ហើយយើងនឹងឲ្យបណ្តាសានៅជាប់ជាមួយនឹងពួកគេនៅក្នុងលោកិយនេះ។ ហើយនៅថ្ងៃបរលោក ពួកគេគឺស្ថិតក្នុងចំណោមពួកដែលត្រូវគេស្អប់ខ្ពើម។

43. ហើយពិតប្រាកដណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត)ក្រោយពីយើងបានបំផ្លាញប្រជាជាតិជំនាន់មុនៗដើម្បីជាការបំភ្លឺដល់មនុស្សលោក ជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណា។ សង្ឃឹមថាពួកគេនឹងនឹកឃើញ។

44. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានមានវត្តមាននៅក្បែរភ្នំខាងលិចនោះទេនៅពេលដែលយើងបានដាក់បទបញ្ជាទៅកាន់ព្យាការីមូសា ហើយអ្នកក៏មិនបានស្ថិតនៅក្នុងចំណោមអ្នកធ្វើសាក្សីនោះដែរ។

45. ក៏ប៉ុន្តែ យើងបានបង្កើតនូវប្រជាជាតិជាច្រើនដោយពួកគេបានរស់នៅអស់រយៈពេលដ៏យូរ។ ហើយអ្នក(ព្យាការីមូហាំម៉ាត់)ក៏មិនបានរស់នៅជាមួយអ្នកស្រុកម៉ាទយ៉ាន់ដោយអ្នកសូត្របណ្តាវាក្យខណ្ឌរបស់យើងឱ្យពួកគេស្តាប់នោះដែរ។ ក៏ប៉ុន្តែ យើងទៅវិញទេដែលជាអ្នកបញ្ជូនសារ(ទៅកាន់អ្នក)។

46. ហើយអ្នកក៏មិនបាននៅក្បែរភ្នំតួរនោះដែរ នៅពេលដែលយើងស្រែកហៅ(ព្យាការីមូសា)នោះ។ ក៏ប៉ុន្តែ (យើងបញ្ជូនអ្នកធ្វើជាអ្នកនាំសារ)ដើម្បីជាក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់អ្នក ដើម្បីឱ្យអ្នកដាស់តឿនព្រមានដល់ក្រុមមួយដែលគ្មានអ្នកដាស់តឿនព្រមានណាម្នាក់មុនអ្នកបានទៅដល់ពួកគេនោះឡើយ។ សង្ឃឹមថាពួកគេនឹងនឹកឃើញ។

47. ហើយប្រសិនបើ(យើងមិនបានបញ្ជូនអ្នកទៅកាន់ពួកគេ) ហើយពួកគេទទួលរងគ្រោះដោយសារតែអ្វីដែលពួកគេបានប្រព្រឹត្ត នោះពួកគេនឹងនិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ហេតុអ្វីបានជាព្រះអង្គមិនបញ្ជូនអ្នកនាំសារណាម្នាក់មកកាន់យើងខ្ញុំ ដើម្បីឱ្យយើងខ្ញុំដើរតាម(ប្រតិបត្តិ)វាក្យខណ្ឌទាំងឡាយរបស់ទ្រង់ និងដើម្បីឱ្យយើងខ្ញុំក្លាយទៅជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលមានជំនឿ?

48. ហើយនៅពេលដែលសេចក្តីពិត(ព្យាការីមូហាំម៉ាត់)បានទៅដល់ពួកគេ ពួកគេបែរជានិយាយថា៖ ហេតុអ្វីបានជាគេ(អល់ឡោះ)មិនផ្តល់ឱ្យគាត់ដូចអ្វីដែលគេបានផ្តល់ឱ្យព្យាការីមូសា? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពុំមែនទេឬដែលពួកគេ(ពួកយូដា)ក៏បានប្រឆាំងនឹងអ្វីដែលគេបានផ្តល់ឲ្យព្យាការីមូសាកាលពីមុនដែរនោះ? ពួកគេបាននិយាយថា៖ វាទាំងពីរនេះ(គម្ពីរតោរ៉ែតនិងគម្ពីរគួរអាន) គឺជាមន្តអាគមដែលវាជួយជ្រោមជ្រែងគ្នាទៅវិញទៅមកប៉ុណ្ណោះ ហើយពួកគេនិយាយទៀតថា៖ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកប្រឆាំងរាល់អ្វីៗ(ដែលមាននៅក្នុងវា)។

49. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ដូច្នេះ ចូរពួកអ្នកនាំមកនូវគម្ពីរណាមួយមកពីអល់ឡោះដែលមានការចង្អុលបង្ហាញល្អប្រសើរជាងវាទាំងពីរមកចុះ នោះខ្ញុំនឹងប្រតិបត្តិតាមវាជាមិនខាន ប្រសិនបើពួកអ្នកជាអ្នកដែលទៀងត្រង់មែននោះ។

50. តែប្រសិនបើពួកគេមិនឆ្លើយតបនឹងអ្នកទេនោះ អ្នកត្រូវដឹងចុះថា៖ តាមពិត ពួកគេដើរតាមតែទំនើងចិត្តរបស់ខ្លួនប៉ុណ្ណោះ។ ហើយគ្មាននរណាម្នាក់វង្វេងជាងអ្នកដែលដើរតាមទំនើងចិត្តខ្លួនឯងដោយមិនទទួលការចង្អុលបង្ហាញពីអល់ឡោះនោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

51. ហើយជាការពិតណាស់ យើងបានបញ្ជាក់ដល់ពួកគេនូវពាក្យបន្ទូល(គម្ពីរគួរអាន) សង្ឃឹមថាពួកគេនឹងនឹករលឹក។

52. បណ្តាអ្នកដែលយើងបានប្រទានឲ្យពួកគេនូវគម្ពីរមុននឹងគម្ពីរគួរអាន ពួកគេក៏ជាអ្នកដែលមានជំនឿនឹងវា(គម្ពីរគួរអាន)ផងដែរ។

53. ហើយនៅពេលដែលមានគេសូត្រ(គម្ពីរគួរអាន)ឱ្យពួកគេស្តាប់ ពួកគេនិយាយថា៖ ពួកយើងមានជំនឿនឹងវាហើយ។ ពិតប្រាកដណាស់ វាជាសេចក្តីពិតមកពីព្រះជាម្ចាស់របស់ពួកយើង។ ពិតប្រាកដណាស់ ពួកយើងក៏ជាអ្នកមូស្លីមផងដែរមុននឹងវា(គម្ពីរគួរអាន)បានមកដល់។

54. បណ្តាអ្នកទាំងនោះ គេនឹងប្រទានឲ្យពួកគេនូវផលបុណ្យរបស់ពួកគេចំនួនពីរដងដោយសារតែអ្វីដែលពួកគេបានអត់ធ្មត់។ ហើយពួកគេរុញច្រានអំពើអាក្រក់ដោយអំពើល្អ ព្រមទាំងបរិច្ចាគនូវអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេទៀតផង។

55. ហើយនៅពេលដែលពួកគេ(អ្នកមានជំនឿទាំងនោះ)បានឮនូវពាក្យសម្តីដែលគ្មានប្រយោជន៍ គឺពួកគេងាកចេញពីវា ហើយពួកគេនិយាយថា៖ សម្រាប់ពួកយើង គឺទង្វើរបស់ពួកយើង ហើយសម្រាប់ពួកអ្នក គឺទង្វើរបស់ពួកអ្នកនោះ។ សូមសុខសន្តិភាពមានដល់ពួកអ្នក។ ពួកយើងមិនត្រូវការពួកល្ងង់ខ្លៅឡើយ។

56. ពិតប្រាកដណាស់ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនអាចផ្តល់ការចង្អុលបង្ហាញដល់ជនដែលអ្នកស្រលាញ់បានឡើយ។ ក៏ប៉ុន្តែ អល់ឡោះជាម្ចាស់ទៅវិញទេដែលផ្តល់ការចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ហើយទ្រង់ដឹងបំផុតចំពោះជនណាដែលទទួលបានការចង្អុលបង្ហាញ។

57. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថា៖ ប្រសិនបើពួកយើងដើរតាមការចង្អុលបង្ហាញដែលនៅជាមួយអ្នក គេ(សត្រូវ)នឹងបណ្តេញពួកយើងចេញពីទឹកដីរបស់ពួកយើងជាមិនខាន។ តើយើង(អល់ឡោះ)មិនបានផ្តល់ឱ្យពួកទាំងនោះនូវទឹកដីពិសិដ្ឋ(ទឹកដីម៉ាក្កះ)ដែលមានសុខសុវត្ថិភាព ហើយគេនាំទៅកាន់ទីនោះនូវផលានុផលគ្រប់ប្រភេទជាលាភសក្ការៈអំពីយើងទេឬ? ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនដឹងឡើយ។

58. ហើយមានភូមិស្រុកជាច្រើនមកហើយដែលយើងបានបំផ្លាញដោយសារតែការរមិលគុណ(របស់ពួកគេ)ចំពោះការប្រទានជីវភាពរស់នៅ(ដ៏ប្រសើរដល់ពួកគេ)។ ហើយលំនៅឋានរបស់ពួកគេ គឺគ្មានអ្នករស់នៅបន្ទាប់ពីពួកគេឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។ ហើយយើងគឺជាអ្នកដែលត្រូវទទួលមរតក។

59. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនមែនជាអ្នកដែលបំផ្លាញភូមិស្រុកណាមួយនោះឡើយ លុះត្រាតែទ្រង់បញ្ជូនទៅកាន់ភូមិស្រុកនោះនូវអ្នកនាំសារម្នាក់ដើម្បីឱ្យគេសូត្រនូវបណ្តាវាក្យខណ្ឌរបស់យើងឱ្យពួកគេស្តាប់។ ហើយយើងក៏មិនមែនជាអ្នកដែលបំផ្លាញភូមិស្រុកណាមួយនោះដែរ លើកលែងតែអ្នកស្រុកភូមិនោះជាពួកដែលបំពាន។

60. ហើយអ្វីក៏ដោយដែលគេបានប្រទានឱ្យពួកអ្នក វាគ្រាន់តែជាការសោយសុខ និងជាគ្រឿងតុបតែងលម្អនៃជីវិតលោកិយប៉ុណ្ណោះ។ តែអ្វីដែលនៅជាមួយអល់ឡោះ គឺល្អប្រសើរនិងគង់វង្សជាង។ ដូច្នេះ តើពួកអ្នកមិនចេះគិតពិចារណាទេឬ?

61. តើអ្នកដែលយើងបានសន្យាចំពោះគេនូវការសន្យាដ៏ប្រសើរមួយ(ឋានសួគ៌) ហើយរូបគេទទួលវាពិតប្រាកដនោះ ដូចគ្នានឹងអ្នកដែលយើងបានប្រទានដល់គេនូវការសោយសុខនៃជីវិតលោកិយនេះ រួចមកនៅថ្ងៃបរលោករូបគេស្ថិតក្នុងចំណោមអ្នកដែលត្រូវគេនាំទៅកាន់(ការដំនុំជម្រះ)ដែរឬទេ?

62. ហើយនៅថ្ងៃដែលទ្រង់នឹងហៅពួកគេដោយទ្រង់សួរថា៖ តើដៃគូទាំងឡាយរបស់យើងដែលពួកអ្នកធ្លាប់បានអះអាងនោះនៅឯណា?

63. ពួកដែលពាក្យសម្តី(ទណ្ឌកម្ម)ត្រូវធ្លាក់ទៅលើពួកគេបាននិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពួកទាំងនោះហើយដែលយើងខ្ញុំបានធ្វើឱ្យវង្វេង។ យើងខ្ញុំបានធ្វើឱ្យពួកគេវង្វេង ដូចដែលយើងខ្ញុំបានវង្វេង(ខ្លួនឯង)ដែរ។ យើងខ្ញុំសូមដកខ្លួនចេញ(ពីពួកគេ)ទៅកាន់ព្រះអង្គវិញហើយ។ ពួកគេមិនបានគោរពសក្ការៈចំពោះយើងខ្ញុំឡើយ។

64. ហើយមានគេនិយាយ(ទៅកាន់ពួកគេ)ថា៖ ចូរពួកអ្នកស្រែកហៅព្រះនានារបស់ពួកអ្នកមក។ ពេលនោះ ពួកគេក៏បានស្រែកហៅពួកវា ក៏ប៉ុន្តែពួកវាមិនបានឆ្លើយតបនឹងពួកគេនោះទេ ហើយពួកគេក៏បានឃើញទណ្ឌកម្ម(ផ្ទាល់នឹងភ្នែក)។ ប្រសិនបើពួកគេជាអ្នកដែលទទួលបានការចង្អុលបង្ហាញនោះ (ពួកគេនឹងមិនទទួលទណ្ឌកម្មឡើយ)។

65. ហើយនៅថ្ងៃដែលទ្រង់នឹងហៅពួកគេដោយទ្រង់សួរថា៖ តើពួកអ្នកបានឆ្លើយតបអ្វីខ្លះចំពោះអ្នកនាំសារទាំងឡាយ(របស់យើង)?

66. ដំណឹងទាំងឡាយ(ដែលពួកគេយកធ្វើជាអំណះអំណាង)បានលាក់បាំងពីពួកគេនៅថ្ងៃនោះ ហើយពួកគេក៏មិនសួរគ្នាទៅវិញទៅមកនោះដែរ។

67. រីឯជនណាដែលបានសារភាពកំហុស ហើយមានជំនឿ និងបានសាងទង្វើកុសលវិញនោះ សង្ឃឹមថា ពួកគេនឹងស្ថិតក្នុងចំណោមអ្នកដែលទទួលបានជោគជ័យ។

68. ហើយព្រះជាម្ចាស់របស់អ្នកទ្រង់បង្កើត និងជ្រើសរើសនូវអ្វីដែលទ្រង់មានចេតនា។ សម្រាប់ពួកគេ គឺគ្មានជម្រើសនោះឡើយ។ អល់ឡោះទ្រង់មហាស្អាតស្អំ និងខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស្ដីរិក។

69. ហើយព្រះជាម្ចាស់របស់អ្នកទ្រង់ដឹងបំផុតនូវអ្វីដែលជួងចិត្តរបស់ពួកគេលាក់បាំង និងអ្វីដែលពួកគេលាតត្រដាង។

70. ហើយទ្រង់គឺអល់ឡោះជាម្ចាស់ដែលគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈជ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ រាល់ការសរសើរទាំងឡាយ ទាំងលើកដំបូង(ក្នុងលោកិយ) និងចុងក្រោយ(ថ្ងៃបរលោក) គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយការកាត់សេចក្ដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់) ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

71. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើអល់ឡោះទ្រង់ធ្វើឱ្យពេលយប់កើតមានទៅលើពួកអ្នកជារៀងរហូត(ដោយគ្មានពេលថ្ងៃ) រហូតដល់ថ្ងៃបរលោកនោះ តើមានព្រះឯណាក្រៅពីអល់ឡោះជាម្ចាស់ដែលអាចនាំនូវពន្លឺមកឱ្យពួកអ្នកបាន? ដូច្នេះ តើពួកអ្នកមិនស្ដាប់ឮទេឬ?

72. ចូរអ្នកពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើអល់ឡោះទ្រង់ធ្វើឱ្យពេលថ្ងៃកើតមានទៅលើពួកអ្នកជារៀងរហូត(ដោយគ្មានពេលយប់) រហូតដល់ថ្ងៃបរលោកនោះ តើមានព្រះឯណាក្រៅពីអល់ឡោះជាម្ចាស់ដែលអាចនាំពេលយប់មកឱ្យពួកអ្នកដែលអាចឱ្យពួកអ្នកសម្រាកបាននោះ? ដូច្នេះ តើពួកអ្នកមិនមើលឃើញទេឬ?

73. ហើយក្នុងចំណោមក្ដីមេត្តាករុណារបស់ទ្រង់ គឺទ្រង់បានបង្កើតពេលយប់ និងពេលថ្ងៃសម្រាប់ពួកអ្នកដើម្បីឱ្យពួកអ្នកសម្រាក(នាពេលយប់) និងដើម្បីឱ្យពួកអ្នកស្វែងរកការប្រោសប្រទានរបស់ទ្រង់(នៅពេលថ្ងៃ) ហើយសង្ឃឹមថា ពួកអ្នកនឹងដឹងគុណ។

74. ហើយនៅថ្ងៃដែលទ្រង់នឹងហៅពួកគេដោយទ្រង់សួរថា៖ តើដៃគូទាំងឡាយរបស់យើងដែលពួកអ្នកធ្លាប់បានអះអាងនោះនៅឯណា?

75. ហើយយើង(អល់ឡោះ)នឹងដកយកពីគ្រប់ប្រជាជាតិទាំងអស់នូវសាក្សីម្នាក់(ជាព្យាការីរបស់ពួកគេ) ហើយយើងបានមានបន្ទូលថា៖ ចូរពួកអ្នកនាំមកនូវភស្ដុតាងរបស់ពួកអ្នកមក។ ពេលនោះ ពួកគេបានដឹងច្បាស់យ៉ាងថា៖ ពិតប្រាកដណាស់សេចក្ដីពិត គឺសម្រាប់អល់ឡោះ។ ហើយអ្វី(ព្រះនានា)ដែលពួកគេធ្លាប់បានប្រឌិតឡើងនោះបានបាត់បង់ពីពួកគេ។

76. ពិតប្រាកដណាស់ ការូនគឺស្ថិតក្នុងចំណោមក្រុមរបស់ព្យាការីមូសា តែគេបានក្បែងក្បាងចំពោះពួកគេ។ ហើយយើងបានប្រទានឱ្យគេនូវកំណប់ទ្រព្យមួយចំនួនដែលកូនសោទាំងឡាយរបស់វា ពិតជា(មានទម្ងន់)ធ្ងន់បំផុតដែលត្រូវការអ្នកលីដែលមានកម្លាំងជាច្រើន ខណៈដែលក្រុមរបស់គេបាននិយាយទៅកាន់គេថា៖ ចូរអ្នកកុំសប្បាយហួសហេតុពេក។ ជាការពិតណាស់ អល់ឡោះទ្រង់មិនស្រលាញ់ពួកដែលសប្បាយហួសហេតុពេកនោះឡើយ។

77. ហើយចូរអ្នកស្វែងរកផលបុណ្យសម្រាប់ថ្ងៃបរលោកតាមរយៈអ្វី(ទ្រព្យសម្បត្តិ)ដែលអល់ឡោះបានប្រទានដល់អ្នក។ ហើយចូរអ្នកកុំភ្លេចចំណែករបស់អ្នកនៅក្នុងលោកិយ។ ហើយចូរអ្នកធ្វើល្អ(ដាក់មនុស្ស) ដូចដែលអល់ឡោះបានធ្វើល្អដាក់អ្នក។ ហើយចូរអ្នកកុំស្វែងរកការបង្កវិនាសកម្មនៅលើផែនដីឱ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនស្រលាញ់ពួកដែលបង្កវិនាសកម្មឡើយ។

78. ករូនបាននិយាយថា៖ តាមពិតគេប្រទានវាដល់ខ្ញុំ គឺដោយសារតែចំណេះវិជ្ជាដែលខ្ញុំមានប៉ុណ្ណោះ។ តើរូបគេមិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់បានបំផ្លាញប្រជាជាតិជំនាន់មុនជាច្រើនមុនរូបគេដែលពួកគេ គឺជាក្រុមដែលខ្លាំងក្លា និងមានទ្រព្យសម្បត្តិច្រើនជាងរូបគេទៅទៀត? ហើយគេមិនសួរពីបាបកម្មរបស់ពួកឧក្រិដ្ឋជនទាំងឡាយឡើយ។

79. ក្រោយមក ករូនបានចាកចេញទៅកាន់ក្រុមរបស់គេក្នុងលក្ខណៈតុបតែង(ស្តែងពីភាពអំនួតរបស់ខ្លួន)។ (ឃើញដូចនេះ) ពួកដែលប្រាថ្នាចង់បានតែជីវិតលោកិយបាននិយាយថា៖ អភ័ព្វណាស់យើង! ប្រសិនបើពួកយើងមានដូចអ្វីដែលគេប្រទានឱ្យករូនដែរ(ពិតជាប្រសើរខ្លាំងណាស់)។ ពិតប្រាកដណាស់ រូបគេពិតជាមានសំណាងធំធេងណាស់។

80. រីឯបណ្តាអ្នកដែលត្រូវបានគេផ្តល់ចំណេះដឹងឱ្យវិញបាននិយាយថា៖ អន្តរាយហើយពួកអ្នក! ផលបុណ្យរបស់អល់ឡោះនោះ គឺល្អប្រសើរជាងសម្រាប់អ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសល។ ហើយគ្មាននរណាដែលទទួលយក(ការទូន្មាននេះ)ឡើយ លើកលែងតែបណ្តាអ្នកដែលអត់ធ្មត់ប៉ុណ្ណោះ។

81. ពេលនោះ យើងក៏បានឱ្យដីស្រូបយករូបគេ(ករូន)និងលំនៅឋានរបស់គេ។ ហើយសម្រាប់រូបគេ គឺគ្មានក្រុមណាមួយដែលអាចជួយរូបគេក្រៅពីអល់ឡោះឡើយ ហើយពួកគេក៏មិនអាចជួយខ្លួនឯងបាននោះដែរ។

82. ហើយពួកដែលប្រាថ្នាចង់បានដូចអ្វីដែលករូនមានកាលពីម្សិលបាននិយាយ(ដោយភាពសោកស្តាយ)ថា៖ តើអ្នកមិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បើកទូលាយនូវលាភសក្ការៈ(របស់ទ្រង់) និងត្បិតត្បៀតវាចំពោះជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់? ប្រសិនបើអល់ឡោះមិនផ្តល់ក្តីមេត្តាដល់ពួកយើងទេនោះ ប្រាកដជាទ្រង់នឹងពន្លិចពួកយើង(ចូលទៅក្នុងដី)ដែរដោយមិនខាន។ តើអ្នកមិនបានដឹងទេឬថា ពួកដែលប្រឆាំងនឹងមិនទទួលបានជោគជ័យឡើយ។

83. លំនៅឋាននៅថ្ងៃបរលោកនោះ គឺយើងបានបង្កើតវាសម្រាប់បណ្តាអ្នកដែលគ្មានបំណងក្រអឺតក្រទម និងបង្កវិនាសកម្មនៅលើផែនដីឡើយ។ ហើយលទ្ធផលចុងក្រោយ គឺសម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)។

84. ជនណាដែលបាននាំមកនូវប្រការល្អ សម្រាប់រូបគេនឹងទទួលបាននូវអ្វីដែលប្រសើរជាងនោះ។ រីឯជនណាដែលបាននាំមកនូវប្រការអាក្រក់វិញ គឺគេមិនតបស្នងដល់ពួកដែលសាងអំពើអាក្រក់ក្រៅតែពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តនោះឡើយ។

85. ពិតប្រាកដណាស់ អ្នកដែលដាក់កាតព្វកិច្ចលើអ្នក(ឲ្យផ្សព្វផ្សាយ)នូវគម្ពីរគួរអាន គឺជាអ្នកដែលត្រឡប់អ្នកទៅកាន់កន្លែងដើម(ទឹកដីម៉ាក្កៈ)វិញ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់ដឹងបំផុតចំពោះជនណាដែលនាំមកនូវការចង្អុលបង្ហាញ ហើយនិងជនណាដែលស្ថិតនៅក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

86. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនធ្លាប់រំពឹងថា គេនឹងបញ្ចុះគម្ពីរ(គួរអាន)ទៅកាន់អ្នកនោះឡើយ។ ក៏ប៉ុន្តែនោះដោយសារក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់អ្នក(ចំពោះអ្នក)ប៉ុណ្ណោះ។ ដូច្នេះ ចូរអ្នកកុំធ្វើជាអ្នកជួយជ្រោមជ្រែងដល់ពួកប្រឆាំងឱ្យសោះ។

87. ហើយចូរកុំឱ្យពួកទាំងនោះរារាំងអ្នកពីវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះក្រោយពីគេបានបញ្ចុះវាទៅកាន់អ្នកហើយនោះឱ្យសោះ។ ហើយចូរអ្នកអំពាវនាវ(មនុស្ស)ទៅកាន់ព្រះជាម្ចាស់របស់អ្នក។ ហើយចូរអ្នកកុំធ្វើខ្លួនឲ្យស្ថិតក្នុងចំណោមពួកដែលធ្វើស្តីរិកឱ្យសោះ។

88. ហើយចូរអ្នកកុំគោរពសក្ការៈព្រះផ្សេងរួមជាមួយនឹងអល់ឡោះជាម្ចាស់ឱ្យសោះ ព្រោះគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ រាល់អ្វីៗទាំងអស់នឹងត្រូវវិនាស លើកលែងតែវង់កក្រៃរបស់ទ្រង់ប៉ុណ្ណោះ។ ហើយការកាត់សេចក្តី គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។

ជំពូក អាល់អន់កាពូត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. តើមនុស្សលោកគិតស្មានថា គេនឹងបណ្តោយឲ្យពួកគេនិយាយថា "ពួកយើងមានជំនឿហើយ" ដោយពួកគេមិនត្រូវគេបានសាកល្បងឬ?

3. ជាការពិតណាស់ យើងបានសាកល្បងអ្នកជំនាន់មុនពួកគេរួចមកហើយ។ ហើយអល់ឡោះដឹងបំផុតចំពោះអ្នកដែល(មានជំនឿ)ពិត ហើយទ្រង់ដឹងបំផុតចំពោះអ្នកដែលភូតកុហក។

4. ឬមួយក៏ពួកដែលសាងអំពើអាក្រក់គិតស្មានថា ពួកគេគេចផុតពី(ទណ្ឌកម្ម)យើងឬ? អ្វីដែលពួកគេវិនិច្ឆ័យ(គិតស្មាន)នោះ គឺអាក្រក់បំផុត។

5. ជនណាដែលរំពឹងថានឹងបានជួបអល់ឡោះ(នៅថ្ងៃបរលោក)នោះ ពិតប្រាកដណាស់ កាលកំណត់អល់ឡោះប្រាកដជានឹងមកដល់ជាមិនខាន។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

6. ហើយជនណាដែលបានតស៊ូ(ក្នុងមាគ៌ារបស់អល់ឡោះ) តាមពិត គឺគេតស៊ូសម្រាប់ខ្លួនឯងប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់មិនត្រូវការអ្វីពីពិភពទាំងឡាយឡើយ។

7. ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល យើងប្រាកដជានឹងលុបបំបាត់នូវអំពើអាក្រក់របស់ពួកគេ ហើយយើងពិតជានឹងតបស្នងដល់ពួកគេប្រសើរជាងអ្វីដែលពួកគេធ្លាប់បានសាងទៅទៀត។

8. ហើយយើងបានផ្តាំផ្ញើមនុស្សលោកឱ្យធ្វើល្អចំពោះឪពុកម្តាយរបស់ខ្លួន។ តែប្រសិនបើគាត់ទាំងពីរព្យាយាមឲ្យអ្នកធ្វើស៊ីរិកមកចំពោះយើងនូវអ្វីដែលអ្នកមិនមានចំណេះដឹងអំពីវាសោះ ចូរអ្នកកុំគោរពតាមគាត់ទាំងពីរឱ្យសោះ។ កន្លែងវិលត្រឡប់របស់ពួកអ្នក គឺមកកាន់យើង(តែមួយគត់)។ ពេលនោះ យើងនឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត(ក្នុងលោកិយ)។

9. ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល យើងប្រាកដជានឹងបញ្ចូលពួកគេទៅក្នុងចំណោមអ្នកដែលសាងទង្វើកុសលទាំងឡាយ។

10. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលនិយាយថា "ពួកយើងមានជំនឿលើអល់ឡោះហើយ"។ តែនៅពេលដែលរូបគេទទួលរងនូវការធ្វើទុក្ខបុកម្នេញក្នុងនាម(ជាអ្នកមានជំនឿចំពោះ)អល់ឡោះ រូបគេបែរជាចាត់ទុកការធ្វើទុកបុកម្នេញរបស់មនុស្ស ដូចជាទណ្ឌកម្មរបស់អល់ឡោះទៅវិញ។ តែប្រសិនបើជំនួយពីព្រះជាម្ចាស់របស់អ្នកបានមកដល់ រូបគេប្រាកដជានឹងនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងធ្លាប់នៅជាមួយពួកអ្នកដែរ។ តើពុំមែនទេឬដែលថា ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវអ្វីដែលមានក្នុងដួងចិត្តការៈទាំងឡាយ?

11. ហើយអល់ឡោះទ្រង់ដឹងបំផុតចំពោះអ្នកដែលមានជំនឿ(ពិតប្រាកដ) ហើយទ្រង់ក៏ដឹងបំផុតផងដែរចំពោះពួកដែលពុតត្បុត។

12. ហើយពួកដែលគ្មានជំនឿបាននិយាយទៅកាន់បណ្ដាអ្នកដែលមានជំនឿថាៈ ចូរពួកអ្នកដើរតាមមាគ៌ា(សាសនា)របស់ពួកយើងចុះ ពួកយើងនឹងរែកពុននូវបាបកម្មទាំងឡាយរបស់ពួកអ្នក(ជំនួសពួកអ្នក)។ (តាមពិត) ពួកទាំងនោះមិនអាចរែកពុននូវបាបកម្មរបស់ពួកគេបន្តិចណាឡើយ។ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។

13. ហើយពួកទាំងនោះពិតជានឹងរែកពុននូវបាបកម្មរបស់ខ្លួនឯង និងត្រូវរែកពុនបាបកម្ម(អ្នកដែលដើរតាមពួកគេ)ថែមពីលើបាបកម្មរបស់ពួកគេទៀត។ ហើយនៅថ្ងៃបរលោក ពួកគេពិតជានឹងត្រូវគេសួរពីអ្វីដែលពួកគេធ្លាប់បានប្រឌិតភូតកុហក។

14. ហើយជាការពិតណាស់ យើងបានបញ្ជូនព្យាការីនួហទៅកាន់ក្រុមរបស់គេ ហើយគេបានរស់នៅជាមួយពួកគេអស់រយៈពេលប្រាំបួនរយហាសិបឆ្នាំ (តែពួកគេបានជិះសេធ)។ ពេលនោះ ទឹកជំនន់(ដ៏ធំមួយ)ក៏បានឆក់យកជីវិតពួកគេ ខណៈដែលពួកគេ គឺជាពួកដែលបំពាន។

15. ហើយយើងក៏បានសង្គ្រោះរូបគេ និងអ្នកដែលនៅលើសំពៅ។ ហើយយើងបានធ្វើឱ្យរឿងនោះ គឺជាមេរៀនមួយសម្រាប់ពិភពទាំងឡាយ។

16. ហើយ(ចូរអ្នករំលឹកនូវរឿងរ៉ាវ)ព្យាការីអ៊ីព្រហ៊ីម នៅពេលដែលគាត់បាននិយាយទៅកាន់ក្រុមរបស់គាត់ថាៈ ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះ(តែមួយគត់) ហើយចូរពួកអ្នកកោតខ្លាចទ្រង់។ នោះគឺជាការដែលល្អប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង។

17. តាមពិត អ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈក្រៅពីអល់ឡោះនោះ គ្រាន់តែជារូបបដិមាប៉ុណ្ណោះ។ ហើយពួកអ្នកបានប្រឌិតនូវការភូតកុហក(ដោយហៅវាថាជាព្រះ)។ ពិតប្រាកដណាស់ អ្វីដែលពួកអ្នកគោរពសក្ការៈក្រៅពីអល់ឡោះនោះ មិនអាចផ្តល់លាភសក្ការៈអ្វីដល់ពួកអ្នកបានឡើយ។ ដូច្នេះ ចូរពួកអ្នកស្វែងរកលាភសក្ការៈពីអល់ឡោះ ហើយត្រូវគោរពសក្ការៈចំពោះទ្រង់ និងត្រូវដឹងគុណទ្រង់(តែមួយគត់)។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់។

18. តែប្រសិនបើពួកអ្នកបដិសេធ(ចំពោះព្យាការីមូហាំម៉ាត់) ពិតប្រាកដណាស់ ប្រជាជាតិជំនាន់មុនពួកអ្នកក៏ធ្លាប់បានបដិសេធ(នឹងអ្នកនាំសាររបស់ពួកគេ)ដែរ។ ហើយតួនាទីរបស់អ្នកនាំសារ គឺគ្មានអ្វីក្រៅពីការផ្សព្វផ្សាយ(សារ)ដ៏ច្បាស់លាស់នោះឡើយ។

19. តើពួកទាំងនោះមិនបានឃើញទេឬថា តើអល់ឡោះទ្រង់ផ្តើមបង្កើតសត្វលោក បន្ទាប់មក ទ្រង់បង្កើតវាជាថ្មីម្តងទៀតយ៉ាងដូចម្តេច? ពិតប្រាកដណាស់ រឿងទាំងនោះគឺងាយស្រួលបំផុតចំពោះអល់ឡោះ។

20. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ ចូរពួកអ្នកធ្វើដំណើរនៅលើផែនដី ហើយពិនិត្យមើលចុះ ថាតើទ្រង់ផ្តើមបង្កើតសត្វលោកយ៉ាងដូចម្តេច? បន្ទាប់មក អល់ឡោះនឹងបង្កើតពួកគេសាជាថ្មីម្តងទៀតនៅថ្ងៃបរលោក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

21. ទ្រង់ដាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា និងមានក្តីមេត្តាករុណាចំពោះជនណាដែលទ្រង់មានចេតនា។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

22. ហើយពួកអ្នកមិនអាចរត់គេច(ពីទណ្ឌកម្មអល់ឡោះ)បានឡើយ មិនថានៅលើផែនដី ឬនៅលើមេឃនោះឡើយ។ ហើយសម្រាប់ពួកអ្នក គឺគ្មានអ្នកគាំពារ ហើយក៏គ្មានអ្នកជួយណាក្រៅពីអល់ឡោះនោះដែរ។

23. ហើយពួកដែលប្រឆាំងនឹងសញ្ញាកសុតាងទាំងឡាយរបស់អល់ឡោះ និងការជួបទ្រង់(នៅថ្ងៃបរលោក) ពួកទាំងនោះ ជាពួកដែលអស់សង្ឃឹមពីក្តីមេត្តាករុណារបស់យើង។ ហើយពួកទាំងនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

24. ហើយការឆ្លើយតបនៃក្រុមរបស់គាត់(ព្យាការីអ៊ីព្រហ៊ីម) គឺគ្មានអ្វីក្រៅពីពួកគេនិយាយថា៖ ចូរពួកអ្នកសម្លាប់គេ ឬដុតគេនោះឡើយ។ ពេលនោះ អល់ឡោះជាម្ចាស់ក៏បានសង្គ្រោះរូបគាត់ពីភ្លើង។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តែងសម្រាប់ក្រុមដែលមានជំនឿ។

25. ហើយគាត់បាននិយាយថា៖ តាមពិតអ្វីដែលពួកអ្នកយកមកគោរពសក្ការៈក្រៅពីអល់ឡោះនោះ គ្រាន់តែជារូបបដិមាប៉ុណ្ណោះដើម្បីជាការស្រលាញ់រាប់អានគ្នារវាងពួកអ្នកនៅក្នុងជីវិតលោកិយ។ ក្រោយមកនៅថ្ងៃបរលោក ពួកអ្នកនឹងដកខ្លួនចេញពីគ្នា ហើយជាក់បណ្តាសាគ្នាទៅវិញទៅមកមិនខានឡើយ។ កន្លែងស្នាក់អាស្រ័យរបស់ពួកអ្នក គឺឋាននរក។ ហើយសម្រាប់ពួកអ្នក គឺគ្មានអ្នកជួយឡើយ។

26. ពេលនោះ ព្យាការីលូតក៏មានជំនឿលើគាត់។ ហើយគាត់(ព្យាការីអ៊ីព្រហ៊ីម)បានពោលថា៖ ខ្ញុំនឹងកៀសខ្លួនទៅកាន់ព្រះជាម្ចាស់របស់ខ្ញុំ(ទៅកាន់ទឹកដីស្តាម)។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិតបំផុត។

27. ហើយយើងបានប្រទានដល់គេនូវអ៊ីស្ហាក(ជាកូន) និងយ៉ាក់កូប(ជាចៅ)។ ហើយយើងបានធ្វើឱ្យកូនចៅរបស់គេទទួលបាននូវភាពជាព្យាការី និងគម្ពីរ។ ហើយយើងបានប្រទានឱ្យគេនូវផលបុណ្យរបស់គេនៅក្នុងលោកិយនេះ។ ហើយនៅថ្ងៃបរលោករូបគេនឹងស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

28. ហើយ(ចូរអ្នករំលឹកនូវរឿងរ៉ាវ)ព្យាការីលូត នៅពេលដែលគាត់បានពោលទៅកាន់ក្រុមរបស់គាត់ថា៖ ពិតប្រាកដណាស់ពួកអ្នកពិតជាបានប្រព្រឹត្តនូវទង្វើអសីលធម៌(ដ៏អាក្រក់បំផុត)ដែលគ្មានអ្នកណាម្នាក់ក្នុងពិភពលោកធ្លាប់បានប្រព្រឹត្តវាមុនពួកអ្នកនោះឡើយ។

29. តើពួកអ្នករួមមេត្រីនឹងបុរសដូចគ្នា ហើយស្ទាក់ផ្លូវធ្វើដំណើរ ព្រមទាំងប្រព្រឹត្តអំពើអាក្រក់នៅកន្លែងជួបជុំរបស់ពួកអ្នកបែបនេះឬ? ហើយការឆ្លើយតបនៃក្រុមរបស់គាត់(ចំពោះគាត់)គឺគ្មានអ្វីក្រៅពីពួកគេនិយាយថា៖ ចូរអ្នកនាំយកទណ្ឌកម្មរបស់អល់ឡោះមកកាន់ពួកយើងមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកទៀងត្រង់មែននោះ។

30. គាត់(ព្យាការីលូត)បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាជួយខ្ញុំឱ្យទទួលជោគជ័យទៅលើក្រុមដែលបង្កវិនាសកម្មផងចុះ។

31. ហើយនៅពេលដែលអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងដែលនាំដំណឹងរីករាយទៅដល់ព្យាការីអ៊ីព្រហ៊ីមបានមកដល់ពួកគេ(ម៉ាឡាអ៊ីកាត់)បាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងត្រូវបានគេប្រើឱ្យមកបំផ្លាញអ្នកភូមិស្រុកនេះ។ ពិតប្រាកដណាស់ អ្នកភូមិស្រុកនេះ គឺជាពួកដែលបំពាន។

32. គាត់(ព្យាការីអ៊ីព្រហ៊ីម)បាននិយាយថា៖ ពិតប្រាកដណាស់ នៅក្នុងភូមិស្រុកនេះ គឺមានព្យាការីលូត(នៅក្នុងនោះ)ដែរ។ ពួកគេ(ម៉ាឡាអ៊ីកាត់)បានតបថា៖ ពួកយើងដឹងបំផុតថាអ្នកណាខ្លះដែលនៅក្នុងភូមិស្រុកនោះ។ ពួកយើងពិតជានឹងសង្គ្រោះរូបគេ និងក្រុមគ្រួសាររបស់គេ លើកលែងតែប្រពន្ធរបស់គេប៉ុណ្ណោះដែលស្ថិតក្នុងចំណោមអ្នកដែលវិនាសអន្តរាយ។

33. ហើយនៅពេលដែលអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងបានទៅដល់ព្យាការីលូត ការមកដល់របស់ពួកគេធ្វើឱ្យគាត់មានការព្រួយបារម្ភ និងកើតទុក្ខជាខ្លាំង។ ពួកគេ(ម៉ាឡាអ៊ីកាត់)បាននិយាយថា៖ ចូរអ្នកកុំភ័យខ្លាច និងកុំកើតទុក្ខ។ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកជួយសង្គ្រោះអ្នក និងក្រុមគ្រួសាររបស់អ្នក លើកលែងតែប្រពន្ធរបស់អ្នកប៉ុណ្ណោះដែលស្ថិតក្នុងចំណោមអ្នកដែលអន្តរាយ។

34. ពិតប្រាកដណាស់ ពួកយើងត្រូវបានគេប្រើឲ្យបញ្ចុះនូវទណ្ឌកម្មពីលើមេឃទៅលើអ្នកភូមិស្រុកនេះដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តល្មើស។

35. ហើយជាការពិតណាស់ យើងបានបន្សល់ទុកពីភូមិស្រុកនេះនូវសញ្ញាកស្តុតាងយ៉ាងច្បាស់លាស់សម្រាប់ក្រុមដែលចេះគិតពិចារណា។

36. ហើយយើងបានបញ្ជូនទៅកាន់តំបន់ម៉ាទយ៉ាន់នូវព្យាការីស៊ូអែបដែលជាបងប្អូនរបស់ពួកគេ។ ហើយគាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់(តែមួយគត់) ហើយពួកអ្នកត្រូវសង្ឃឹម(ទទួលបាននូវការតបស្នង)នាថ្ងៃបរលោកចុះ។ ហើយចូរពួកអ្នកកុំបង្កវិនាសកម្មនៅលើផែនដីឱ្យសោះ។

37. តែពួកគេបានបដិសេធចំពោះគាត់។ ពេលនោះ រញ្ជួយដី(ដ៏ខ្លាំង)បានឆក់យកជីវិតពួកគេ ហើយពួកគេក៏បាន(ស្លាប់)ក្លាយជាសាកសពនៅក្នុងផ្ទះរបស់ពួកគេ។

38. ហើយ(យើងក៏បានបំផ្លាញ)ក្រុមអាទ និងក្រុមសាមូទផងដែរ។ ពិតប្រាកដណាស់ វាបានបញ្ជាក់យ៉ាងច្បាស់ដល់ពួកអ្នក(អ្នកស្រុកម៉ាក្កៈ)អំពីលំនៅឋានទាំងឡាយរបស់ពួកគេ។ ហើយស្មែតនបានតុបតែងលម្អចំពោះពួកគេនូវទង្វើរបស់ពួកគេ រួចបានរារាំងពួកគេពីមាគ៌ាត្រឹមត្រូវ ខណៈដែលពួកគេ ជាអ្នកដែលមើលឃើញច្បាស់(នូវការពិត)។

39. ហើយ(យើងក៏បានបំផ្លាញ)ករូន ហ្វៀរអោន និងហាម៉ានផងដែរ។ ហើយជាការពិតណាស់ ព្យាការីមូសាបាននាំមកឱ្យពួកគេនូវសញ្ញាកស្តុតាងជាច្រើន តែពួកគេបែរជាក្រអឺតក្រទមនៅលើផែនដីទៅវិញ។ ហើយពួកគេមិនអាចគេចផុត(ពីទណ្ឌកម្មរបស់យើង)បានឡើយ។

40. ហើយយើងបានដាក់ទណ្ឌកម្មរាល់ក្រុមនីមួយ(ខាងលើ)ព្រោះតែបាបកម្មរបស់គេ។ ក្នុងចំណោមពួកគេ មានអ្នកដែលយើងបានបញ្ជូនដុំថ្មទៅលើគេ(ក្រុមព្យាការីលូត)។ ហើយក្នុងចំណោមពួកគេ មានអ្នកដែលត្រូវសម្រែកយ៉ាងខ្លាំងឆក់យកជីវិតគេ(ក្រុមព្យាការីសឡេះ និងក្រុមព្យាការីស៊ូអែប)។ ក្នុងចំណោមពួកគេ មានអ្នកដែលយើងបានធ្វើឱ្យដីស្រូបយករូបគេ(ករូន)។ ហើយក្នុងចំណោមពួកគេផងដែរ គឺមានអ្នកដែលយើងពន្លិចទៅក្នុងទឹក(ក្រុមព្យាការីនួហ ហ្វៀរអោន និងហាម៉ាន)។ ហើយអល់ឡោះពិតជាមិនបានបំពានលើពួកគេនោះឡើយ ក៏ប៉ុន្តែពួកគេទៅវិញទេដែលបំពានលើខ្លួនឯងនោះ។

41. ការប្រៀបធៀបពួកដែលយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាអ្នកគាំពារ ប្រៀបដូចទៅនឹងសត្វពីងពាងដែលបានធ្វើសំបុកដូច្នោះដែរ។ ពិតប្រាកដណាស់ សំបុកដែលអន់ជាងគេបំផុត គឺសំបុកសត្វពីងពាងហ្នឹងឯង ប្រសិនបើពួកគេបានដឹង។

42. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេគោរពសក្ការៈចំពោះពួកវាក្រៅពីទ្រង់។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

43. ទាំងនោះជាឧទាហរណ៍ដែលយើងបានលើកឡើងដល់មនុស្សលោក។ ហើយគ្មានអ្នកណាយល់អំពីវានោះឡើយ លើកលែងតែអ្នកដែលមានចំណេះដឹងប៉ុណ្ណោះ។

44. អល់ឡោះទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដីដោយពិតប្រាកដ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយសម្រាប់បណ្តាអ្នកដែលមានជំនឿ។

45. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រនូវអ្វីដែលគេបានវាហ៊ីដល់អ្នកអំពីគម្ពីរ(គួរអាន) និងប្រតិបត្តសឡាតចុះ។ ជាការពិតណាស់ សឡាតអាចហាមឃាត់ពីទង្វើអសីលធម៌ និងអំពើអាក្រក់ទាំងឡាយ។ ហើយការរំឭកទៅចំពោះអល់ឡោះគឺពិតជាធំធេងបំផុត។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

46. ហើយចូរពួកអ្នក(ឱបណ្ដាអ្នកមានជំនឿ)កុំជជែកដេញដោលជាមួយនឹងពួកអះលីគីតាប លើកលែងតែតាមវិធីសាស្ត្រដ៏ល្អ លើកលែងតែ(ជាមួយ)ពួកដែលបំពានក្នុងចំណោមពួកគេប៉ុណ្ណោះ។ ហើយចូរពួកអ្នកពោលថា៖ ពួកយើងមានជំនឿ ហើយចំពោះអ្វីដែលគេបញ្ចុះមកកាន់ពួកយើង និងបញ្ចុះមកកាន់ពួកអ្នក។ ហើយព្រះជាម្ចាស់របស់ពួកយើង និងព្រះជាម្ចាស់របស់អ្នក គឺតែមួយគត់។ ហើយពួកយើងជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

47. ក៏ដូច្នោះដែរ យើងបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរគួរអាន។ ហើយ(ក្នុងចំណោម)អ្នកដែលយើងបានផ្ដល់ឲ្យពួកគេនូវគម្ពីរ(អម្បូរអ៊ីស្រាអែល) គឺពួកគេមានជំនឿចំពោះវា(គម្ពីរគួរអាន)។ ហើយក្នុងចំណោមពួកទាំងនោះ(ពួកមុស្លឹរីគីនម៉ាក្កៈ)ក៏មានអ្នកដែលមានជំនឿចំពោះវាដែរ។ ហើយគ្មានអ្នកដែលប្រឆាំងនឹងវាក្យខណ្ឌទាំងឡាយរបស់យើងឡើយ លើកលែងតែពួកគ្មានជំនឿប៉ុណ្ណោះ។

48. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនធ្លាប់បានសូត្រ(គម្ពីរណាមួយ)មុននឹងគម្ពីរគួរអានឡើយ ហើយអ្នកក៏មិនធ្លាប់បានសរសេរអ្វីមួយនឹងដៃស្ដាំរបស់អ្នកនោះដែរ។ ប្រសិនបើដូច្នោះវិញនោះ ប្រាកដជាពួកខុសឆ្គងនឹងមានការមន្ទិលសង្ស័យជាមិនខាន។

49. ផ្ទុយទៅវិញ វាជាបណ្ដាវាក្យខណ្ឌដ៏ច្បាស់លាស់ដែលស្ថិតនៅក្នុងដួងចិត្តរបស់បណ្ដាអ្នកដែលគេបានផ្ដល់ឱ្យនូវចំណេះដឹង។ ហើយគ្មានអ្នកដែលប្រឆាំងនឹងវាក្យខណ្ឌទាំងឡាយរបស់យើងឡើយ លើកលែងតែពួកដែលបំពានប៉ុណ្ណោះ។

50. ហើយពួកគេ(ពួកមុស្លឹរីគីន)បាននិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះមកឱ្យគាត់(ព្យាការីមូហាំម៉ាត់)នូវសញ្ញាកស្តុតាងទាំងឡាយពីព្រះជាម្ចាស់របស់គេទៅ? ចូរអ្នកតបថា៖ តាមពិត សញ្ញាកស្តុតាងទាំងឡាយ គឺនៅឯអល់ឡោះជាម្ចាស់។ ហើយតាមពិត រូបខ្ញុំគ្រាន់តែជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់ម្នាក់ប៉ុណ្ណោះ។

51. តើគម្ពីរ(គួរអាន)ដែលយើងបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែលគេបានសូត្រឱ្យពួកគេស្ដាប់នោះ វាមិនទាន់គ្រប់គ្រាន់សម្រាប់ពួកគេទៀតឬ? ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាក្ដីមេត្តាករុណា និងជាដាស់រំលឹកសម្រាប់ក្រុមដែលមានជំនឿ។

52. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាម្ចាស់ជាសាក្សីរវាងខ្ញុំ និងពួកអ្នក។ ទ្រង់ដឹងបំផុតនូវអ្វីដែលនៅលើមេឃជាច្រើនជាន់ និងផែនដី។ រីឯពួកដែលមានជំនឿលើប្រការមិនត្រឹមត្រូវ ហើយគ្មានជំនឿលើអល់ឡោះជាម្ចាស់វិញនោះ ពួកទាំងនោះគឺជាពួកដែលខាតបង់។

53. ហើយពួកគេបានស្នើសុំអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ឲ្យទណ្ឌកម្មកើតឡើងភ្លាមៗ(ចំពោះពួកគេ)។ ហើយប្រសិនបើគ្មានកាលកំណត់ច្បាស់លាស់ទេនោះ ប្រាកដជាទណ្ឌកម្មនឹងមកដល់ពួកគេជាមិនខាន។ ហើយវានឹងមកដល់ពួកគេភ្លាមៗ ដោយពួកគេមិនដឹងខ្លួនឡើយ។

54. ហើយពួកគេបានស្នើសុំអ្នកឲ្យទណ្ឌកម្មកើតឡើងភ្លាមៗ(ចំពោះពួកគេ)។ ហើយពិតប្រាកដណាស់ នរកជើហាន់ណាំប្រាកដជានឹងហ៊ុមព័ទ្ធពួកដែលគ្មានជំនឿ។

55. នៅថ្ងៃ(បរលោក)ទណ្ឌកម្មនឹងគ្របដណ្ដប់ពួកគេពីខាងលើ និងនៅពីខាងក្រោមជើងពួកគេ ហើយទ្រង់បានមានបន្ទូលថា៖ ចូរពួកអ្នកភ្លក់ចុះនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

56. ឱបណ្ដាខ្ញុំបម្រើទាំងឡាយរបស់យើងដែលមានជំនឿ! ពិតប្រាកដណាស់ ផែនដីរបស់យើងគឺទូលំទូលាយណាស់។ ដូច្នេះ ចូរពួកអ្នកគោរពសក្ការៈមកចំពោះយើងតែមួយគត់។

57. រាល់ជីវិតទាំងអស់នឹងត្រូវភ្លក់រសជាតិនៃសេចក្តីស្លាប់។ បន្ទាប់មក ពួកអ្នកនឹងត្រូវគេនាំត្រឡប់មកកាន់យើងវិញ។

58. ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល យើងពិតជានឹងឱ្យពួកគេស្នាក់នៅក្នុងវិមាននៅក្នុងឋានសួគ៌ ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ការតបស្នងចំពោះបណ្តាអ្នកដែលសាងកុសលនោះ គឺប្រសើរបំផុត។

59. គឺបណ្តាអ្នកដែលបានអត់ធ្មត់ ហើយពួកគេប្រគល់ការទុកចិត្តទៅចំពោះព្រះជាម្ចាស់របស់ពួកគេ(តែមួយគត់)។

60. ហើយសត្វលោកជាច្រើនដែលពួកវាគ្មានសមត្ថភាពប្រមូលលាភសក្ការៈរបស់ខ្លួនទុកឡើយ ប៉ុន្តែអល់ឡោះទ្រង់ប្រទានលាភសក្ការៈដល់ពួកវា និងដល់ពួកអ្នក។ ហើយទ្រង់មហាឮ មហាដឹងបំផុត។

61. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកគេ(ពួកមូស្លីមីន)ថា៖ តើអ្នកណាជាអ្នកបង្កើតមេឃជាច្រើនជាន់ និងផែនដី និងធ្វើឱ្យព្រះអាទិត្យនិងព្រះចន្ទមានចលនា ប្រាកដជាពួកគេនឹងឆ្លើយថា៖ គឺអល់ឡោះ។ ដូច្នេះ តើពួកគេត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

62. អល់ឡោះទ្រង់បើកទូលាយ និងត្បិតគ្រៀតលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនា។ ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

63. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកគេថា៖ តើនរណាជាអ្នកបញ្ចុះទឹកភ្លៀងពីលើមេឃ រួចបានឱ្យដីនោះមានជីវិតឡើងវិញតាមរយៈទឹកភ្លៀងក្រោយពីវាបានស្ងួតហួតហែងហើយនោះ ពួកគេប្រាកដជាឆ្លើយថា៖ គឺអល់ឡោះជាម្ចាស់។ ចូរអ្នកពោលថា៖ រាល់ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេមិនគិតពិចារណាឡើយ។

64. ហើយឆាកជីវិតលោកិយនេះ គឺគ្មានអ្វីក្រៅពីការលេងសើច និងជាការកម្សាន្តនោះឡើយ។ តែថ្ងៃបរលោកទៅវិញទេ ទើបជាជីវិតរស់នៅដ៏ពិតប្រាកដ ប្រសិនបើពួកគេបានដឹង។

65. ហើយនៅពេលដែលពួកគេ(ពួកគ្មានជំនឿ)បានជិះលើសំពៅ ពួកគេបានបួងសួងសុំពីអល់ឡោះដោយភាពស្មោះសចំពោះទ្រង់។ តែនៅពេលដែលទ្រង់បានសង្គ្រោះពួកគេដល់ត្រើយ ពួកគេបែរជាធ្វើស្ទីរិក(ចំពោះទ្រង់)ទៅវិញ។

66. ដើម្បីពួកគេប្រឆាំងនឹងអ្វី(ឧបការគុណ)ដែលយើងបានប្រទានដល់ពួកគេ និងដើម្បីឱ្យពួកគេសោយសុខ(ក្នុងជីវិតលោកិយ)។ ដូច្នេះ ពួកគេគង់តែនឹងដឹងជាមិនខាន។

67. តើពួកទាំងនោះមិនបានឃើញទេឬ យើងបានបង្កើតទឹកដីពិសិដ្ឋដែលប្រកបដោយសុវត្ថិភាព(ទឹកដីម៉ាក្កៈ) ខណៈដែលមនុស្សនៅជុំវិញពួកគេកំពុងត្រូវបានគេវាយឆ្មក់(គ្មានសុវត្ថិភាព)? តើពួកគេមានជំនឿនឹងប្រការខុសឆ្គង ហើយបែរជាប្រឆាំងនឹងឧបការគុណអល់ឡោះទៅវិញឬ?

68. គ្មាននរណាដែលបំពានជាងអ្នកដែលប្រឌិតកុហកទៅលើអល់ឡោះ ឬបដិសេធនឹងការពិតនៅពេលដែលវាបានមកដល់រូបគេនោះឡើយ។ តើពុំមែនទេ នរកជើហាន់ណាំ គឺជាកន្លែងស្នាក់អាស្រ័យសម្រាប់ពួកដែលប្រឆាំងនោះ!

69. ហើយអ្នកដែលបានតស៊ូក្នុង(មគ៌ារបស់)យើង យើងពិតជានឹងចង្អុលបង្ហាញពួកគេនូវមគ៌ារបស់យើង។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ពិតជាស្ថិតនៅជាមួយបណ្តាអ្នកដែលសាងអំពើល្អ។

ជំពូក អាល់រ៉ូម

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. គេ(ពួកហ្គារីស៊ី)បានយកឈ្នះទៅលើពួករ៉ូម។

3. នៅត្រង់កន្លែងទាបបំផុតនៃផែនដី។ ហើយពួកគេ(ពួករ៉ូម)នឹងយកជ័យជម្នះលើពួកគេវិញជាមិនខានឡើយ ក្រោយពីពួកគេបានបរាជ័យ

4. ក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ កិច្ចការទាំងមុន ទាំងក្រោយ គឺជាកម្មសិទ្ធិរបស់អល់ឡោះ។ ហើយនៅថ្ងៃនោះ(ថ្ងៃដែលពួករ៉ូមទទួលជ័យជម្នះ) បណ្តាអ្នកមានជំនឿនឹងសប្បាយរីករាយ

5. ដោយសារតែជំនួយរបស់អល់ឡោះ។ អល់ឡោះជាម្ចាស់ទ្រង់ជួយដល់ជនណាដែលទ្រង់មានចេតនា។ ហើយទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

6. ជាការសន្យាមកពីអល់ឡោះជាម្ចាស់។ អល់ឡោះទ្រង់មិនធ្វើឲ្យខុសនូវការសន្យារបស់ទ្រង់ឡើយ។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនដឹងឡើយ។

7. ពួកគេដឹងតែរឿងជាក់ស្តែងនៃការរស់នៅក្នុងលោកិយប៉ុណ្ណោះ។ តែចំពោះថ្ងៃបរលោកពួកគេបែរជាមិនខ្វាយខ្វល់ទៅវិញ។

8. តើពួកគេមិនគិតពិចារណាចំពោះខ្លួនពួកគេផ្ទាល់ទេឬ? អល់ឡោះមិនបានបង្កើតមេឃជាច្រើននិងផែនដី ហើយនិងអ្វីៗដែលនៅចន្លោះវាទាំងពីរឡើយ លើកលែងតែដោយសេចក្តីពិត និងមានអាយុកាលកំណត់យ៉ាងច្បាស់លាស់។ ក៏ប៉ុន្តែភាគច្រើននៃមនុស្សលោក គឺគ្មានជំនឿចំពោះការជួបនឹងព្រះជាម្ចាស់របស់ពួកគេឡើយ។

9. តើពួកទាំងនោះមិនបានធ្វើដំណើរលើផែនដី ហើយពិនិត្យពិចារណាមើលទេឬ ថាតើលទ្ធផលចុងក្រោយនៃមនុស្សជំនាន់មុនពួកគេទៅជាយ៉ាងណា? ពួកទាំងនោះ គឺខ្លាំងក្លាជាងពួកគេ ហើយពួកគេបានដាំដុះ(ធ្វើកសិកម្ម)លើផ្ទៃដី និងសាងសង់(សំណង់ផ្សេងៗ)លើផែនដីច្រើនជាងអ្វីដែលពួកគេបានសាងសង់ទៅទៀត។ ហើយអ្នកនាំសារទាំងឡាយរបស់ពួកគេបាននាំមកឱ្យពួកគេនូវសញ្ញាកស្តុតាងយ៉ាងច្បាស់លាស់ជាច្រើន(តែពួកគេបានបដិសេធ)។ ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនបានបំពានលើពួកគេឡើយ ក៏ប៉ុន្តែពួកគេទៅវិញទេដែលបំពានលើខ្លួនឯង។

10. បន្ទាប់មក លទ្ធផលចុងក្រោយនៃពួកដែលសាងទង្វើអាក្រក់នោះ គឺអាក្រក់ជាទីបំផុត ព្រោះតែពួកគេបដិសេធនឹងសញ្ញាកស្តុតាងទាំងឡាយរបស់អល់ឡោះ ហើយពួកគេថែមទាំងចំអកឡកឡឺយចំពោះវាថែមទៀត។

11. អល់ឡោះជាម្ចាស់ទ្រង់ផ្តើមបង្កើតសត្វលោក។ បន្ទាប់មក ទ្រង់បានបង្កើតវាឡើងវិញ។ ក្រោយមក ពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

12. ហើយនៅពេលដែលថ្ងៃបរលោកមកដល់ ពួកឧក្រិដ្ឋជនទាំងឡាយ នឹងមានការអស់សង្ឃឹមជាខ្លាំង។

13. ហើយព្រះនានារបស់ពួកគេ(ដែលពួកគេធ្លាប់គោរពសក្ការៈ)មិនអាចជួយអន្តរាគមន៍អ្វីដល់ពួកគេឡើយ។ ហើយ(នៅថ្ងៃនោះ)ពួកគេ គឺជាអ្នកដែលប្រឆាំងនឹងព្រះនានារបស់ពួកគេវិញ។

14. ហើយនៅពេលដែលថ្ងៃបរលោកបានមកដល់ នៅក្នុងថ្ងៃនោះ ពួកគេនឹងត្រូវបែកខ្ញែកគ្នា។

15. រីឯបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ពួកគេនឹងស្ថិតនៅក្នុងសួនឧទ្យាន(ឋានសួគ៌)ប្រកបដោយភាពសប្បាយរីករាយ។

16. រីឯពួកដែលគ្មានជំនឿ និងបដិសេធនឹងបណ្តាវាក្យខណ្ឌទាំងឡាយរបស់យើង ព្រមទាំងជំនួបនាថ្ងៃបរលោក ពួកទាំងនោះ ហើយគឺជាពួកដែលត្រូវបានគេនាំទៅកាន់ទណ្ឌកម្ម។

17. ដូច្នេះ ចូរពួកអ្នកលើកតម្កើងអល់ឡោះជាម្ចាស់នៅពេលល្ងាច និងនៅពេលព្រឹកព្រលឹម។

18. ហើយការកោតសរសើរទាំងឡាយ គឺសម្រាប់ទ្រង់(តែមួយគត់)ទាំងនៅលើមេឃជាច្រើនជាន់ និងនៅលើផែនដី ទាំងពេលរសៀល និងពេលថ្ងៃត្រង់។

19. ទ្រង់បញ្ចេញរបស់មានជីវិតពីរបស់ស្លាប់ ហើយបញ្ចេញរបស់ស្លាប់ពីរបស់មានជីវិត។ ហើយទ្រង់ធ្វើឱ្យដីរស់(មានជីជាតិ)ឡើងវិញ ក្រោយពីវាបានងាប់(ស្ងួតហួតហែង)។ ហើយក៏ដូច្នោះដែរ ពួកអ្នកនឹងត្រូវគេបញ្ចេញ(ពីផ្នូរ)មកវិញ។

20. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺទ្រង់បានបង្កើតពួកអ្នក(ឱមនុស្សលោកទាំងឡាយ)អំពីដី។ បន្ទាប់មកពួកអ្នកក៏បានក្លាយជាមនុស្សដែលបានពង្រាយគ្នា(រស់នៅពាសពេញផែនដី)។

21. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺទ្រង់បានបង្កើតសម្រាប់ពួកអ្នក(ឱបុរសទាំងឡាយ)នូវភរិយាចេញពីខ្លួនរបស់ពួកអ្នកដើម្បីឱ្យពួកអ្នករួមរស់ជាមួយនាង និងបានបង្កើតឱ្យមានក្តីស្រលាញ់ និងក្តីមេត្តាករុណារវាងពួកអ្នក។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តតាងសម្រាប់ក្រុមដែលចេះពិចារណា។

22. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដី ហើយនិងភាពខុសគ្នានៃភាសានិងពណ៌សម្បុររវាងពួកអ្នក។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាកស្តតាងសម្រាប់អ្នកដែលមានចំណេះដឹង។

23. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺការគេងរបស់ពួកអ្នកនៅពេលយប់និងពេលថ្ងៃ និងការដែលពួកអ្នកស្វែងរកការប្រោសប្រទាន(លាភសក្ការៈ)របស់ទ្រង់។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តតាងសម្រាប់ក្រុមដែលស្តាប់(ដោយពិចារណា)។

24. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺទ្រង់ឱ្យពួកអ្នកបានឃើញផ្លេកបន្ទោរដោយពួកអ្នកមានការភ័យខ្លាច(ពីផ្លេកបន្ទោរ)និងប្រាថ្នាចង់បាន(ទឹកភ្លៀង)។ ហើយទ្រង់បានបញ្ចុះឱ្យពួកអ្នកនូវទឹកភ្លៀងពីលើមេឃ។ ពេលនោះ ទ្រង់ក៏បានធ្វើឱ្យដីរស់(មានជីជាតិ)ឡើងវិញ ក្រោយពីវាបានងាប់(ស្ងួតហួតហែង)តាមរយៈទឹកភ្លៀងនោះ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តតាងសម្រាប់ក្រុមដែលចេះគិតពិចារណា។

25. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ដែរនោះ គឺមេឃនិងផែនដីឈរឡើងទៅតាមបទបញ្ជារបស់ទ្រង់។ ក្រោយមកនៅពេលដែលទ្រង់បានហៅពួកអ្នកនូវការហៅមួយឱ្យចេញពីដី ពេលនោះ ពួកអ្នកក៏ចេញ(ពីផ្នូរមក)។

26. ហើយទាំងអ្នកដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ រាល់អ្វីទាំងអស់នោះ សុទ្ធតែប្រគល់ខ្លួនគោរពតាមទ្រង់។

27. ហើយទ្រង់គឺជាអ្នកផ្តើមបង្កើតសត្វលោក។ បន្ទាប់មក ទ្រង់បានបង្កើតវាឡើងវិញម្តងទៀតហើយវាជារឿងងាយស្រួលបំផុតសម្រាប់ទ្រង់។ ហើយទ្រង់មានលក្ខណៈខ្ពង់ខ្ពស់បំផុតទាំងនៅលើមេឃជាច្រើនជាន់និងផែនដី។ ហើយទ្រង់មហាខ្លាំងពូកែមហាគតិបណ្ឌិត។

28. ទ្រង់បានលើកជាឧទាហរណ៍មួយសម្រាប់ពួកអ្នកចេញពីខ្លួនរបស់ពួកអ្នកផ្ទាល់គឺ តើពួកអ្នកមានទាសករដោចថ្លៃដែលជាដៃគូរួមចំណែក(ជាមួយពួកអ្នក)ចំពោះអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកអ្នកដោយស្មើភាពគ្នាដែរឬទេ? ពួកអ្នកបារម្ភខ្លាចចំពោះពួកគេ ដូចដែលអ្នកបារម្ភខ្លាចអ្នកមួយចំនួននៃពួកអ្នកដែលមានសិទ្ធិដូចពួកអ្នកដែរ។ ក៏ដូច្នោះដែរ យើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងជាច្រើនសម្រាប់ក្រុមដែលចេះគិតពិចារណា។

29. ផ្ទុយទៅវិញ ពួកដែលបំពានបានដើរតាមចំណង់តណ្ហារបស់ខ្លួនដោយគ្មានចំណេះដឹង។ ដូច្នេះ តើមានអ្នកណាដែលអាចចង្អុលបង្ហាញដល់ជនដែលអល់ឡោះធ្វើឱ្យវង្វេងនោះ? ហើយសម្រាប់ពួកគេ ក៏គ្មានអ្នកជួយដែរ។

30. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តម្រង់មុខរបស់អ្នកទៅកាន់សាសនាដ៏ត្រឹមត្រូវ(សាសនាអ៊ីស្លាម) ជាសាសនាកំណើតដែលអល់ឡោះបានបង្កើតមនុស្សលោកឱ្យស្ថិតនៅលើវា។ គ្មានការផ្លាស់ប្តូរឡើយចំពោះការបង្កើតរបស់អល់ឡោះ។ នោះហើយជាសាសនាដ៏ត្រឹមត្រូវ។ ក៏ប៉ុន្តែមនុស្សលោកភាគច្រើនមិនបានដឹងឡើយ។

31. ហើយចូរពួកអ្នកវិលត្រឡប់ទៅកាន់ទ្រង់(ដោយការសោកស្តាយកំហុស)និងកោតខ្លាចចំពោះទ្រង់ ព្រមទាំងប្រតិបត្តិសឡាត។ ហើយចូរពួកអ្នកកុំស្ថិតក្នុងចំណោមពួកដែលធ្វើស៊ីរិក។

32. គឺពួកដែលបំបែកបំបាក់សាសនារបស់ខ្លួនដោយពួកគេបែកបាក់ជាក្រុម។ រាល់ក្រុមនីមួយ គឺគេរីករាយជាមួយនឹងអ្វីដែលខ្លួនមាន។

33. ហើយនៅពេលដែលមនុស្សលោកទទួលនូវគ្រោះនានា គឺពួកគេបួងសួងសុំពីព្រះជាម្ចាស់របស់ពួកគេ(អល់ឡោះ)ដោយវិលត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។ ក្រោយមក នៅពេលដែលទ្រង់ឲ្យពួកគេទទួលនូវក្តីមេត្តាករុណាអំពីទ្រង់ ស្រាប់តែមួយក្រុមក្នុងចំណោមពួកគេ(ត្រឡប់ទៅ)ធ្វើស៊ីរិកនឹងព្រះជាម្ចាស់របស់ពួកគេទៅវិញ។

34. ដើម្បីពួកគេរមិលគុណចំពោះអ្វី(ឧបការគុណ)ដែលយើងបានប្រទានឲ្យពួកគេ។ ហេតុនេះ ចូរពួកអ្នកសោយសុខចុះ។ ពិតណាស់ ពួកអ្នកគង់តែនឹងដឹងជាមិនខាន។

35. ឬមួយយើងបានបញ្ចុះទៅកាន់ពួកទាំងនោះនូវកស្តុតាងមួយដោយបានរៀបរាប់នូវអ្វីដែលពួកគេកំពុងតែធ្វើស៊ីរិកនឹងទ្រង់ឬ?

36. ហើយនៅពេលដែលយើងឱ្យមនុស្សលោកភ្លក់នូវក្តីមេត្តាករុណា គឺពួកគេសប្បាយរីករាយនឹងវា។ តែប្រសិនបើប្រការអាក្រក់កើតឡើងចំពោះពួកគេដោយសារតែអ្វី(បាបកម្ម)ដែលពួកគេបានប្រព្រឹត្តដោយដៃរបស់ពួកគេនោះ បែរជាពួកគេអស់សង្ឃឹមទៅវិញ។

37. តើពួកគេមិនបានឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់បើកទូលាយ និងត្បិតត្បៀតនូវលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនា? ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាកស្តុតាងសម្រាប់ក្រុមដែលមានជំនឿ។

38. ដូច្នេះ ចូរអ្នក(ឱជនមូស្លីម)ផ្តល់ជូនសាច់ញាតិ ជនក្រីក្រ និងអ្នកដំណើរដោចស្បៀងនូវសិទ្ធិរបស់គេ។ នោះគឺជាការប្រសើរបំផុតសម្រាប់អ្នកដែលចង់បានការពេញចិត្តពីអល់ឡោះ។ អ្នកទាំងនោះហើយ ពួកគេគឺជាអ្នកដែលទទួលបានជោគជ័យ។

39. ហើយអ្វីដែលពួកអ្នកបានផ្តល់ឲ្យអ្នកដទៃក្នុងគោលបំណងទទួលបានការប្រាក់ដើម្បីឲ្យទ្រព្យសម្បត្តិរបស់មនុស្សមានការកើនឡើងនោះ គឺវាមិនមានការកើនឡើងអ្វីឡើយចំពោះអល់ឡោះជាម្ចាស់។ ចំណែកឯអ្វីដែលពួកអ្នកបានផ្តល់ឲ្យអ្នកដទៃអំពីទ្រព្យហ្សាកាត់ក្នុងបំណងចង់បានការពេញចិត្តពីអល់ឡោះនោះ ពិតប្រាកដណាស់ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានការបង្កើន(ផលបុណ្យ)ទ្វេដង។

40. អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកដែលបង្កើតពួកអ្នក។ បន្ទាប់មក ទ្រង់ប្រទានលាភសក្ការៈឱ្យពួកអ្នក។ បន្ទាប់មកទៀត ទ្រង់បានដកយកជីវិតពួកអ្នក។ រួចមក ទ្រង់ឱ្យពួកអ្នករស់ឡើងវិញ។ តើក្នុងចំណោមព្រះនានារបស់ពួកអ្នក មានអ្នកដែលអាចធ្វើអ្វីមួយអំពីរឿងទាំងនោះបានដែរឬទេ? ទ្រង់មហាស្អាតស្អំ មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស៊ីរិក។

41. គ្រោះមហន្តរាយនានាដែលលេចឡើងនៅលើដីគោក និងនៅផ្ទៃទឹក គឺដោយសារតែអ្វីដែលមនុស្សលោកបានប្រព្រឹត្តដោយដៃរបស់ពួកគេផ្ទាល់នោះឯង ដើម្បីទ្រង់ឱ្យពួកគេភ្លក្ស(នូវផលតបស្នងចំពោះ)ទង្វើខ្លះៗដែលពួកគេបានប្រព្រឹត្ត។ សង្ឃឹមថាពួកគេនឹងវិលត្រឡប់(កែខ្លួន)។

42. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកធ្វើដំណើរនៅលើផែនដី ហើយពិនិត្យមើលថា តើលទ្ធផលចុងក្រោយរបស់ពួកជំនាន់មុនយ៉ាងដូចម្តេច? ភាគច្រើននៃពួកគេ គឺជាពួកដែលធ្វើស៊ីរិក។

43. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តម្រង់មុខរបស់អ្នកទៅកាន់សាសនាដ៏ត្រឹមត្រូវមុននឹងថ្ងៃមួយបានមកដល់ដែលគ្មានអ្នកណាអាចទប់ស្កាត់វាពីអល់ឡោះបានឡើយ។ នៅថ្ងៃនោះ ពួកគេត្រូវបានបែងចែកជាក្រុមៗ។

44. ជនណាដែលប្រឆាំង ពិតណាស់ ការប្រឆាំងរបស់គេ គឺនឹងធ្លាក់ទៅលើខ្លួនគេផ្ទាល់។ រីឯជនណាដែលបានសាងទង្វើកុសល គឺពួកគេបានរៀបចំសម្រាប់ខ្លួនឯង(នូវផ្លូវទៅកាន់ឋានសួគ៌)។

45. ដើម្បីទ្រង់នឹងតបស្នងដល់បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលនូវការប្រោសប្រទានរបស់ទ្រង់។ ពិតប្រាកដណាស់ ទ្រង់មិនស្រលាញ់ពួកដែលប្រឆាំងឡើយ។

46. ហើយក្នុងចំណោមសញ្ញាកសុតាងរបស់ទ្រង់ គឺទ្រង់បានបញ្ជូនខ្យល់ជាការផ្តល់ដំណឹងល្អ(ថានឹងមានភ្លៀងធ្លាក់) និងដើម្បីឱ្យពួកអ្នកភ្លក់នូវក្តីមេត្តាករុណារបស់ទ្រង់ ហើយនិងដើម្បីឱ្យសំពៅធ្វើដំណើរទៅតាមបទបញ្ជារបស់ទ្រង់ ព្រមទាំងដើម្បីឱ្យពួកអ្នកស្វែងរកនូវការប្រោសប្រទានអំពីទ្រង់ ដើម្បីពួកអ្នកថ្លែងអំណរគុណ(ចំពោះទ្រង់)។

47. ហើយជាការពិតណាស់ យើងបានបញ្ជូនអ្នកនាំសារជាច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទៅកាន់ក្រុមរបស់ពួកគេដោយនាំមកឱ្យពួកគេនូវសញ្ញាកសុតាងយ៉ាងច្បាស់លាស់(ប៉ុន្តែពួកទាំងនោះបានបដិសេធ)។ ហេតុនេះ យើងក៏បានផ្តន្ទាទោសពួកដែលប្រព្រឹត្តអំពើអាក្រក់ទាំងឡាយ។ ហើយការសង្គ្រោះបណ្តាអ្នកមានជំនឿ គឺជាសិទ្ធិ(របស់ពួកគេ)មកលើយើង។

48. អល់ឡោះទ្រង់ជាអ្នកដែលបញ្ជូនខ្យល់ដោយវាបានបក់ផាត់ពពក។ ហើយទ្រង់បានពង្រាយវា(ពពក)នៅលើផ្ទៃមេឃតាមដែលទ្រង់មានចេតនា រួចទ្រង់បានធ្វើឱ្យវាក្លាយជាដុំៗ។ ពេលនោះ អ្នកនឹងឃើញទឹកភ្លៀងចេញពីចន្លោះដុំពពកទាំងនោះ។ ហើយនៅពេលដែលទ្រង់បានឱ្យទឹកភ្លៀងនោះធ្លាក់ត្រូវជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់ ពេលនោះពួកគេមានភាពសប្បាយរីករាយ។

49. ហើយប្រាកដណាស់ មុនពេលដែលគេបញ្ចុះទឹកភ្លៀងទៅកាន់ពួកគេនោះ ពួកគេគឺជាពួកដែលពុំមានសង្ឃឹម(ថានឹងមានភ្លៀងធ្លាក់)ឡើយ។

50. ដូច្នេះ ចូរអ្នកពិនិត្យមើលចុះទៅកាន់ឥទ្ធិពលនៃក្តីមេត្តាករុណារបស់អល់ឡោះ(ទឹកភ្លៀង)នោះ ថាតើទ្រង់ធ្វើឱ្យដីដែលស្ងួតហួតហែងមានជីវិតឡើងវិញយ៉ាងដូចម្តេច? ពិតប្រាកដណាស់ អ្នកដែលអាចធ្វើដូចនោះបាន ក៏ជាអ្នកដែលអាចធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញ(នៅថ្ងៃបរលោក)ផងដែរ។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

51. ហើយប្រសិនបើយើងបញ្ជូនខ្យល់(ដែលបំផ្លិចបំផ្លាញដំណាំពួកគេ) ហើយពួកគេបានឃើញវាប្រែទៅជាពណ៌លឿង(ក្រោយពីវាមានពណ៌ខៀវស្រងាត់) ពួកគេប្រាកដជានឹងនៅតែប្រឆាំង(នឹងអល់ឡោះ)បន្ទាប់ពីនោះដដែល។

52. ហើយពិតប្រាកដណាស់ អ្នក(ព្យាការីមូហាំម៉ាត់)មិនអាចធ្វើឱ្យអ្នកស្លាប់អាចស្តាប់ឮ ហើយក៏មិនអាចធ្វើឱ្យអ្នកថ្លង់ស្តាប់ឮការអំពាវនាវនោះដែរ ប្រសិនបើពួកគេបែរខ្នងងាកចេញហើយនោះ។

53. ហើយអ្នកក៏មិនអាចចង្អុលបង្ហាញមនុស្សខ្វាក់ឱ្យចេញពីភាពវង្វេងរបស់ពួកគេនោះដែរ។ តាមពិត អ្នកអាចធ្វើឱ្យស្តាប់ឮតែចំពោះអ្នកដែលមានជំនឿចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើង ដោយពួកគេគឺជាអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)។

54. អល់ឡោះគឺជាអ្នកដែលបានបង្កើតពួកអ្នក(ឱមនុស្សលោកទាំងឡាយ)ពីភាពទន់ខ្សោយ។ ក្រោយមក បន្ទាប់ពីភាពទន់ខ្សោយ ទ្រង់បានធ្វើឱ្យពួកអ្នកមានភាពរឹងមាំ។ បន្ទាប់មកទៀត ក្រោយពីពួកអ្នកមានភាពរឹងមាំ ទ្រង់បានឱ្យពួកអ្នកមានភាពទន់ខ្សោយ និងចាស់ជរាវិញ។ ទ្រង់បង្កើតអ្វីតាមតែទ្រង់មានចេតនា។ ហើយទ្រង់មហាដឹង មាន មហាអានុភាពបំផុត។

55. ហើយនៅថ្ងៃដែលថ្ងៃបរលោកកើតឡើង ពួកដែលប្រព្រឹត្តអាក្រក់នឹងស្បថថា ពួកគេមិនបានរស់នៅក្នុងលោកិយឡើយលើកលែងតែរយៈពេលដ៏ខ្លីប៉ុណ្ណោះ។ ក៏ដូចគ្នាដែរ ពួកគេធ្លាប់ត្រូវបានបង្វែរចេញ(ពីសេចក្តីពិត)។

56. ហើយបណ្តាអ្នកដែលគេបានប្រទានចំណេះដឹង និងជំនឿដល់ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកអ្នកបានរស់នៅ(ក្នុងលោកិយ)តាមរយៈពេលដែលអល់ឡោះបានកត់ត្រាទុករហូតដល់ថ្ងៃដែលគេបង្កើតឱ្យរស់ឡើងវិញ។ ជាការពិតណាស់ នេះគឺជាថ្ងៃដែលគេបង្កើតឱ្យរស់ឡើងវិញ។ ក៏ប៉ុន្តែពួកអ្នកមិនបានដឹងឡើយ។

57. ដូច្នេះ នៅថ្ងៃនោះ លេសដោះសារទាំងឡាយរបស់ពួកបំពាន គឺគ្មានផលប្រយោជន៍អ្វីដល់ពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេទាមទារឱ្យធ្វើការសារភាពកំហុស(ពីអល់ឡោះ)នោះដែរ។

58. ហើយពិតប្រាកដណាស់ យើងបានលើកគ្រប់ឧទាហរណ៍នៅក្នុងគម្ពីរគួរអាននេះដល់មនុស្សលោក។ ហើយបើទោះបីជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នាំមកឱ្យពួកគេនូវសញ្ញាកស្តុតាង(ដែលបញ្ជាក់ពីសច្ចភាពរបស់អ្នក)ក៏ដោយ ក៏ពួកដែលប្រឆាំងប្រាកដជានឹងនិយាយថា៖ ពួកអ្នកគ្មានអ្វីក្រៅពីជាពួកដែលបោកប្រាស់នោះឡើយ។

59. ក៏ដូច្នោះដែរ អល់ឡោះនឹងបោះត្រាភ្ជិតទៅលើដួងចិត្តរបស់ពួកដែលមិនដឹង(ពីការពិត)។

60. ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះ។ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ ហើយចូរកុំឱ្យពួកដែលគ្មានការជឿជាក់(ចំពោះការបង្កើតឱ្យរស់ឡើងវិញ)ធ្វើឱ្យអ្នកទន់ខ្សោយ(បោះបង់ការអត់ធ្មត់)ឱ្យសោះ។

ជំពូក លុកម៉ាន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ទាំងនេះគឺជាបណ្តាវាក្យខណ្ឌនៃគម្ពីរ(គួរអាន)ដែលប្រកបដោយគតិបណ្ឌិត។

3. ជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់អ្នកដែលសាងអំពើល្អទាំងឡាយ។

4. គឺបណ្តាអ្នកដែលប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយពួកគេមានជំនឿយ៉ាងមុតមាំនឹងថ្ងៃបរលោក។

5. អ្នកទាំងនោះហើយដែលស្ថិតនៅលើការចង្អុលបង្ហាញពីព្រះជាម្ចាស់របស់ពួកគេ ហើយអ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានជោគជ័យ។

6. ហើយក្នុងចំណោមមនុស្សលោក គឺមានអ្នកដែលទិញយកសម្តីលេងសើចដើម្បីធ្វើឲ្យ(មនុស្សលោក)វង្វេងចេញពីមាគ៌ារបស់អល់ឡោះដោយគ្មានចំណេះដឹង ហើយយកវាក្យខណ្ឌរបស់អល់ឡោះធ្វើជាការសើចចំអក។ ពួកទាំងនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

7. ហើយនៅពេលដែលមានគេសូត្របណ្តាវាក្យខណ្ឌទាំងឡាយរបស់យើងឱ្យគេស្តាប់ គឺគេបែរចេញពីវាដោយភាពក្រអឺតក្រទមប្រៀបដូចរូបគេមិនបានឮវាសោះ ហាក់ដូចជានៅក្នុងត្រចៀកទាំងពីររបស់គេមានឆ្នុកបិទដូច្នោះដែរ។ ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងដល់គេពីទណ្ឌកម្មដ៏ឈឺចាប់បំផុតចុះ។

8. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសល សម្រាប់ពួកគេនឹងទទួលបានឋានសួគ៌ណាអ៊ីម។

9. ពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ការសន្យារបស់អល់ឡោះ គឺជាពិត។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

10. ទ្រង់បានបង្កើតមេឃជាច្រើនជាន់ដោយគ្មានសសរ(ទ្រ)ឡើយ ដូចដែលពួកអ្នកបានឃើញ ហើយទ្រង់បានបង្កើតភ្នំទាំងឡាយនៅលើផែនដីជាលំនឹងដើម្បីកុំឱ្យវាញ័ររញ្ជួយដល់ពួកអ្នក។ ហើយទ្រង់បានពង្រាយនៅលើផែនដីនូវសត្វពាហនៈជាច្រើនប្រភេទ។ ហើយយើងបានបញ្ចុះទឹកភ្លៀងពីលើមេឃ រួចយើងបានបណ្តុះនៅលើផែនដីនូវរុក្ខជាតិគ្រប់ប្រភេទដ៏ស្រស់បំព្រង។

11. នេះគឺជាការបង្កើតរបស់អល់ឡោះ។ ដូច្នេះ ចូរពួកអ្នក(ឱពួកមុស្លីគីន)បង្ហាញឱ្យយើងបានឃើញមក ថាតើមានអ្វីខ្លះដែលអ្នកផ្សេងក្រៅពីទ្រង់បានបង្កើតនោះ? ផ្ទុយទៅវិញ ពួកដែលបំពាន គឺស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

12. ហើយពិតប្រាកដណាស់ យើងបានប្រទានឱ្យលុកម៉ាននូវគតិបណ្ឌិត។ (យើងបានមានបន្ទូលថា៖) ចូរអ្នកដឹងគុណអល់ឡោះ។ ជនណាហើយដែលដឹងគុណ តាមពិតគេដឹងគុណចំពោះខ្លួនឯងប៉ុណ្ណោះ។ រីឯជនណាហើយដែលមិលគុណ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់ ជាអ្នកដែលត្រូវគេកោតសរសើរបំផុត។

13. ហើយ(ចូរអ្នករំលឹក)នៅពេលដែលលុកម៉ានបាននិយាយទៅកាន់កូនរបស់គេដោយបានទូន្មានថា៖ ឱកូនសម្លាញ់! ចូរកូនកុំធ្វើស្តីរិកនឹងអល់ឡោះជាម្ចាស់ឱ្យសោះ។ ពិតប្រាកដណាស់ អំពើស្តីរិក គឺជាការបំពានដ៏ធំធេងបំផុត។

14. ហើយយើង(អល់ឡោះ)បានផ្តែផ្តាំដល់មនុស្សលោក(ឱ្យធ្វើល្អ)ចំពោះឪពុកម្តាយរបស់ខ្លួន។ ម្តាយរបស់គេបានពពោះរូបគេដោយភាពលំបាកជាន់លើលំបាក ហើយបានផ្តាច់គេពីការបំបៅក្នុងអំឡុងពេលពីរឆ្នាំ។ (យើងបានមានបន្ទូលថា៖) ចូរអ្នកដឹងគុណមកចំពោះយើង និងទៅចំពោះឪពុកម្តាយរបស់អ្នក។ ហើយកន្លែងវិលត្រឡប់(របស់អ្នក)គឺមកកាន់យើង(តែមួយគត់)។

15. ហើយប្រសិនបើគាត់ទាំងពីរព្យាយាមឱ្យអ្នកធ្វើស្តីរិកនឹងអល់ឡោះនូវអ្វីដែលអ្នកគ្មានចំណេះដឹងអំពីវាទេនោះ ចូរអ្នកកុំធ្វើតាមគាត់ទាំងពីរឲ្យសោះ។ ប៉ុន្តែអ្នកត្រូវមានទំនាក់ទំនងជាមួយគាត់ទាំងពីរនៅក្នុងលោកិយដោយល្អប្រសើរ។ ហើយចូរអ្នកដើរតាមមាគ៌ារបស់អ្នកដែលវិលត្រឡប់មកកាន់យើង។ បន្ទាប់មក កន្លែងវិលត្រឡប់របស់ពួកអ្នក គឺមកកាន់យើង(តែមួយគត់)។ ពេលនោះ យើងនឹងប្រាប់ពួកអ្នកពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

16. ឱកូនសម្លាញ់! ប្រាកដណាស់ (មិនថាអំពើអាក្រក់ ឬអំពើល្អឡើយ) ទោះបីជាវាមានទំហំតូចប៉ុនគ្រាប់ស្ពៃ ហើយស្ថិតនៅក្នុងផ្នាំងថ្ម ឬនៅលើមេឃជាច្រើនជាន់ ឬក៏នៅលើផែនដីក៏ដោយ ក៏អល់ឡោះនឹងនាំយកវាមកដែរ(នៅថ្ងៃបរលោក)។ ពិតប្រាកដណាស់ អល់ឡោះមហាល្អិតល្អន់ មហាដឹងបំផុត។

17. ឱកូនសម្លាញ់! ចូរកូនប្រតិបត្តិសឡាត និងប្រើគ្នាឱ្យធ្វើល្អ ហាមឃាត់គ្នាពីអំពើអាក្រក់ ព្រមទាំងអត់ធ្មត់ទៅលើអ្វីដែលកើតឡើងចំពោះកូន។ ប្រាកដណាស់ នោះគឺស្ថិតក្នុងចំណោមកាតព្វកិច្ចដែលត្រូវអនុវត្ត។

18. ហើយចូរកូនកុំងាកមុខចេញពីមនុស្សលោក(ដោយភាពក្អេងក្អាង) ហើយកុំដើរនៅលើផែនដីដោយភាពក្រអឺតក្រទមឲ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះមិនស្រលាញ់បណ្តាជនដែលក្រអឺតក្រទម និងក្អេងក្អាងនោះឡើយ។

19. ហើយចូរបន្ទន់ឥរិយាបថក្នុងដំណើរដើររបស់កូន និងបន្ទន់សំឡេងរបស់កូនផងដែរ។ ពិតប្រាកដណាស់ សំឡេងដែលអាក្រក់បំផុត គឺសំឡេងរបស់សត្វលា។

20. តើពួកអ្នកមិនបានឃើញទេឬ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានសម្រួលដល់ពួកអ្នកនូវអ្វីដែលនៅលើមេឃជាច្រើនជាន់ និងអ្វីដែលនៅលើផែនដី។ ហើយទ្រង់បានបំពេញឱ្យពួកអ្នកនូវឧបការគុណទាំងឡាយរបស់ទ្រង់ ទាំងផ្នែកខាងក្រៅ និងផ្នែកខាងក្នុង។ ហើយក្នុងចំណោមមនុស្សលោក មានអ្នកដែលជជែកដេញដោលពី(ភាពជាម្ចាស់តែមួយគត់របស់)អល់ឡោះដោយគ្មានចំណេះដឹង គ្មានការចង្អុលបង្ហាញ ហើយក៏គ្មានគម្ពីរមកបំភ្លឺនោះដែរ។

21. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកដើរតាមអ្វីដែលអល់ឡោះបានបញ្ចុះមក ពួកគេឆ្លើយតបថា៖ ផ្ទុយទៅវិញ ពួកយើងដើរតាមតែអ្វីដែលពួកយើងបានឃើញជីដូនជីតារបស់ពួកយើងធ្វើប៉ុណ្ណោះ។ តើសូម្បីតែស្មែតនអំពៅនាវពួកទាំងនោះទៅកាន់ទណ្ឌកម្មដែលឆាបឆេះ(ក៏ពួកគេនៅតែធ្វើតាម)ដែរឬ?

22. ហើយជនណាដែលប្រគល់ខ្លួនទៅកាន់អល់ឡោះ ហើយគេជាមនុស្សល្អត្រឹមត្រូវទៀតនោះ ពិតប្រាកដណាស់ គេពិតជាបានប្រកាន់ខ្ជាប់នូវមូលហេតុដែលនាំទៅរកការពេញចិត្តពីអល់ឡោះ។ ហើយលទ្ធផលចុងក្រោយនៃកិច្ចការទាំងឡាយគឺវិលត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់)។

23. រីឯជនណាដែលប្រឆាំងវិញនោះ ចូរកុំឱ្យការប្រឆាំងរបស់គេធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មានទុក្ខព្រួយ។ កន្លែងវិលត្រឡប់របស់ពួកគេ គឺមកកាន់យើង(តែមួយគត់) ហើយយើងនឹងប្រាប់ពួកគេពីអ្វីដែលពួកគេប្រព្រឹត្ត។ ពិតប្រាកដណាស់ អល់ឡោះមហាដឹងនូវអ្វីដែលមាននៅក្នុងចិត្ត(របស់ពួកគេ)។

24. យើងនឹងឱ្យពួកគេសោយសុខមួយរយៈពេលខ្លីប៉ុណ្ណោះ (ក្នុងលោកិយ)។ បន្ទាប់មក យើងនឹងអូសពួកគេទៅកាន់ទណ្ឌកម្មដ៏សែនធ្ងន់ធ្ងរបំផុត (នៅថ្ងៃបរលោក)។

25. ហើយប្រសិនបើអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) សួរពួកគេថា៖ តើអ្នកណាដែលបានបង្កើតមេឃជាច្រើនជាន់ និងផែនដី? ប្រាកដជាពួកគេនឹងឆ្លើយថា៖ គឺអល់ឡោះ។ ចូរអ្នកពោលថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

26. អ្វីៗដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ (តែមួយគត់)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់ ជាទីកោតសរសើរបំផុត។

27. ហើយប្រសិនបើដើមឈើទាំងអស់នៅលើផែនដី គឺជាស្លាបប៉ាកា ហើយសមុទ្រ (ធ្វើជាទឹកថ្នាំដើម្បីសរសេរ) រួចបន្ថែមពីលើនោះនូវសមុទ្រចំនួនប្រាំពីរទៀតក៏ដោយ ក៏នៅតែមិនអាចកត់ត្រាអស់នូវបន្ទូលរបស់អល់ឡោះដែរ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

28. ការបង្កើតពួកអ្នក និងការធ្វើឲ្យពួកអ្នករស់ឡើងវិញ គឺប្រៀបដូចជាជីវិតតែមួយប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាឃើញបំផុត។

29. តើអ្នកមិនបានឃើញទេឬ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ និងបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយទ្រង់បានកំណត់គន្លងគោចររបស់ព្រះអាទិត្យនិងព្រះចន្ទ ដោយវាទាំងពីរធ្វើដំណើរហូតដល់ពេលវេលាដែលត្រូវបានកំណត់។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

30. នោះគឺដោយសារតែអល់ឡោះ (តែមួយគត់) គឺជាព្រះជាម្ចាស់ដ៏ពិតប្រាកដ ហើយអ្វីដែលពួកគេកំពុងតែគោរពសក្ការៈផ្សេងពីទ្រង់នោះ គឺជាប្រការមិនត្រឹមត្រូវ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្ពង់ខ្ពស់ មហាធំធេងបំផុត។

31. តើអ្នកមិនបានឃើញទេឬ ពិតប្រាកដណាស់ សំពៅទាំងឡាយអាចធ្វើដំណើរនៅលើផ្ទៃសមុទ្របានដោយឧបការគុណរបស់អល់ឡោះដើម្បីទ្រង់បង្ហាញឱ្យពួកអ្នក (ឱមនុស្សលោក) បានឃើញនូវសញ្ញាកស្តុតាងទាំងឡាយរបស់ទ្រង់។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់រាល់អ្នកដែលអត់ធ្មត់ និងអ្នកដែលដឹងគុណ។

32. ហើយនៅពេលដែលទឹករលកបានគ្របដណ្តប់លើពួកគេប្រៀបដូចជាពពកនោះ ពួកគេបានបួងសួងទៅកាន់អល់ឡោះដោយចិត្តស្មោះស។ តែនៅពេលដែលទ្រង់បានសង្គ្រោះពួកគេដល់ត្រើយ ស្រាប់តែមួយចំនួននៃពួកគេ គឺជាពួកដែលមិនសូវដឹងគុណទៅវិញ។ ហើយគ្មានជនណាដែលប្រឆាំងនឹងសញ្ញាកស្តុតាងរបស់យើងឡើយ លើកលែងតែរាល់អ្នកដែលក្បត់ និងអ្នកដែលរមិលគុណប៉ុណ្ណោះ។

33. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកកោតខ្លាចព្រះជាម្ចាស់របស់ពួកអ្នក។ ហើយចូរពួកអ្នកខ្លាចថ្ងៃមួយដែលឪពុកមិនអាចជួយអ្វីដល់កូន ហើយកូនក៏មិនអាចជួយអ្វីបន្តិចដល់ឪពុកនោះដែរ។ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះគឺជាការពិត។ ដូច្នេះ ចូរកុំឱ្យឆាកជីវិតលោកិយបោកប្រាស់ពួកអ្នកឱ្យសោះ ហើយចូរកុំឱ្យពួកបោកប្រាស់នោះ បោកប្រាស់ពួកអ្នកពីអល់ឡោះបានឱ្យសោះ។

34. ពិតប្រាកដណាស់ ចំណេះដឹងអំពីថ្ងៃបរលោក គឺស្ថិតនៅឯអល់ឡោះជាម្ចាស់ (តែមួយគត់)។ ទ្រង់បញ្ចុះទឹកភ្លៀង ហើយទ្រង់ដឹងនូវអ្វីដែលមាននៅក្នុងស្បូនស្ត្រី។ ហើយបុគ្គលម្នាក់ៗមិនបានដឹងទេថា តើខ្លួននឹងទទួលបានអ្វីនៅថ្ងៃស្អែក ហើយក៏គ្មាននរណាម្នាក់អាចដឹងថា តើរូបគេនឹងត្រូវស្លាប់នៅទីណានោះដែរ។ ពិតប្រាកដណាស់ អល់ឡោះមហាដឹងជ្រួតជ្រាបបំផុត។

ជំពូក អាសសាដ្ឋហ្ពះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អាលីហ្វ ឡាម មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ការបញ្ចុះគម្ពីរ(គួរអាន) គឺមកពីព្រះជាម្ចាស់នៃពិភពទាំងអស់ដោយគ្មានការមន្ទិលសង្ស័យចំពោះគម្ពីរនេះឡើយ។

3. ឬមួយពួកគេ(ពួកប្រឆាំង)និយាយថាៈ គេ(ព្យាការីមូហាំម៉ាត់)បានប្រឌិតកុហកវា(គម្ពីរគួរអាន)ឡើង។ ផ្ទុយទៅវិញ វាជាការពិតពីព្រះជាម្ចាស់របស់អ្នកដើម្បីឱ្យអ្នកដាស់តឿនព្រមានក្រុមមួយដែលមិនធ្លាប់មានអ្នកដាស់តឿនព្រមានណាម្នាក់មុនអ្នកបានទៅដល់ពួកគេនោះឡើយ។ សង្ឃឹមថា ពួកគេនឹងទទួលបានការចង្អុលបង្ហាញ។

4. អល់ឡោះគឺជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី ព្រមទាំងអ្វីៗដែលនៅចន្លោះវាទាំងពីរក្នុងរយៈពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ទ្រង់នៅលើអារ៉ស្ហ។ សម្រាប់ពួកអ្នក(ឱមនុស្សលោក) គឺគ្មានអ្នកគាំពារ និងគ្មានអ្នកជួយអន្តរាគមន៍ណាក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

5. ទ្រង់ចាត់ចែងកិច្ចការទាំងឡាយពីលើមេឃដល់ផែនដី។ បន្ទាប់មក (កិច្ចការទាំងនោះ)វានឹងឡើងទៅកាន់ទ្រង់វិញនៅថ្ងៃមួយដែលរយៈពេលរបស់វាស្មើនឹងមួយពាន់ឆ្នាំតាមអ្វីដែលពួកអ្នកគណនា(ក្នុងលោកិយ)។

6. នោះគឺជាអ្នកដែលដឹងបំផុតនូវប្រការអាថ៌កំបាំង និងប្រការដែលលាតត្រដាង ជាអ្នកដែលមហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

7. ទ្រង់ជាអ្នកដែលបង្កើតអ្វីៗទាំងអស់ឲ្យមានភាពល្អឥតខ្ចោះ។ ហើយទ្រង់បានចាប់ផ្តើមបង្កើតមនុស្ស(ព្យាការីអាដាំ)អំពីដីឥដ្ឋ។

8. បន្ទាប់មក ទ្រង់បានបង្កើតកូនចៅរបស់គេអំពីទឹកកាមដែលគ្មានតម្លៃ។

9. បន្ទាប់មក ទ្រង់បានបង្កើតគេឱ្យមានលក្ខណៈពេញលេញ ហើយទ្រង់បានផ្លុំព្រលឹងទៅក្នុងខ្លួនរបស់គេ។ ហើយទ្រង់បានបង្កើតឱ្យពួកអ្នក(ឱមនុស្សលោក)នូវសោតវិញ្ញាណ ចក្ខុវិញ្ញាណ និងដួងចិត្ត។ អ្វីដែលពួកអ្នកដឹងគុណ(អល់ឡោះ)គឺតិចតួចបំផុត។

10. ហើយពួកគេ(ពួកមុស្លីគីន)បាននិយាយថាៈ តើនៅពេលដែលពួកយើង(ស្លាប់)កប់ទៅក្នុងដីហើយនោះ តើពួកយើងនឹងត្រូវបានគេបង្កើត(ឱ្យរស់ឡើងវិញ)សាជាថ្មីឬ? ផ្ទុយទៅវិញ ពួកគេគឺជាពួកដែលគ្មានជំនឿចំពោះការជួបនឹងព្រះជាម្ចាស់របស់ពួកគេឡើយ។

11. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ ម៉ាលីគុលម៉ោតដែលទទួលបន្ទុកខាងដកយកជីវិតនឹងមកដកយកជីវិតពួកអ្នក។ បន្ទាប់មក ពួកអ្នកនឹងត្រូវគេនាំត្រឡប់មកកាន់ព្រះជាម្ចាស់របស់ពួកអ្នកវិញ។

12. ហើយប្រសិនបើអ្នកបានឃើញ នៅពេលដែលពួកឧក្រិដ្ឋជនទាំងឡាយឱនក្បាលរបស់ពួកគេចុះនៅចំពោះមុខព្រះជាម្ចាស់របស់ពួកគេ។ (ហើយពួកគេពោលថា៖) បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! យើងខ្ញុំបានឃើញ និងបានឮហើយ។ ហេតុនេះ សូមព្រះអង្គមេត្តាឱ្យយើងខ្ញុំត្រឡប់(ទៅកាន់ជីវិតលោកិយវិញម្តងទៀត)ដើម្បីឱ្យយើងខ្ញុំអាចសាងទង្វើកុសលវិញ។ ពិតប្រាកដណាស់(ពេលនេះ)យើងខ្ញុំ គឺជាអ្នកដែលជឿជាក់យ៉ាងពិតប្រាកដ។

13. ហើយប្រសិនបើយើងមានចេតនា យើងនឹងផ្តល់ឱ្យបុគ្គលគ្រប់រូបនូវការចង្អុលបង្ហាញជាមិនខាន។ ប៉ុន្តែបន្ទូលរបស់យើងបានសម្រេចអំពីយើងរួចទៅហើយថា៖ យើងពិតជានឹងបំពេញនរកដើហាន់ណាំពីពួកជិន និងមនុស្សលោកទាំងអស់។

14. (មានគេនិយាយទៅកាន់ពួកទាំងនោះថា៖) ចូរពួកអ្នកភ្លក់ចុះ(នូវរសជាតិនៃទណ្ឌកម្ម) ដោយសារតែពួកអ្នកភ្លេចពីជំនួបនៅថ្ងៃរបស់ពួកអ្នក(នៅថ្ងៃបរលោក)នេះ។ ពិតប្រាកដណាស់(នៅថ្ងៃនេះ)យើងក៏បំភ្លេចពួកអ្នកដូចគ្នា។ ហើយចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មដ៏អមតៈដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

15. ជាការពិតណាស់ អ្នកដែលមានជំនឿនឹងបណ្តាវាក្យខណ្ឌទាំងឡាយរបស់យើង នៅពេលណាគេរំលឹកពួកគេនឹងវាក្យខណ្ឌទាំងនោះ គឺពួកគេលំឱនកាយស៊ូជោត និងលើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេមិនក្រអឺតក្រទមឡើយ។

16. ខ្នងរបស់ពួកគេបានក្រោកចេញពីកន្លែងគេង។ ពួកគេបួងសួងសុំពីព្រះជាម្ចាស់របស់ពួកគេដោយការបារម្ភខ្លាច(ទណ្ឌកម្ម) និងក្តីប្រាថ្នា(ចង់បានផលបុណ្យ) ហើយពួកគេបរិច្ចាគមួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេ។

17. ជាការពិតណាស់ គ្មានបុគ្គលណាម្នាក់ដឹងនោះទេនូវអ្វីដែលគេបានរក្សាទុកសម្រាប់ពួកគេ(អ្នកមានជំនឿ)អំពីអ្វីដែលធ្វើឱ្យពួកគេគាប់ចិត្តនោះ ជាការតបស្នងចំពោះអ្វីដែលពួកគេបានប្រព្រឹត្ត(ក្នុងលោកិយ)។

18. ដូច្នេះ តើអ្នកដែលមានជំនឿ ដូចគ្នានឹងអ្នកដែលប្រព្រឹត្តល្មើសឬ? ពួកគេគឺមិនដូចគ្នាឡើយ។

19. រីឯបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ពិតណាស់ សម្រាប់ពួកគេគឺឋានសួគ៌ជាកន្លែងស្នាក់នៅ ជាកិត្តិយស(ពីអល់ឡោះចំពោះពួកគេ) និងជាការតបស្នងចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

20. ចំណែកឯពួកដែលប្រព្រឹត្តល្មើសវិញនោះ កន្លែងស្នាក់នៅរបស់ពួកគេ គឺឋាននរក។ រាល់ពេលដែលពួកគេចង់ចេញអំពីវា ពួកគេត្រូវបានគេបញ្ជូនឱ្យត្រឡប់ទៅនៅក្នុងវាវិញ។ ហើយមានគេពោលទៅកាន់ពួកគេថា៖ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មភ្លើងនរកដែលពួកអ្នកធ្លាប់បានបដិសេធ(មិនជឿ)ចំពោះវា។

21. ហើយយើងប្រាកដជានឹងឱ្យពួកទាំងនោះភ្លក់នូវទណ្ឌកម្មកម្រិតស្រាល(ក្នុងលោកិយ)មុននឹងទណ្ឌកម្មធ្ងន់ធ្ងរបំផុត(នៅថ្ងៃបរលោក)។ សង្ឃឹមថា ពួកគេនឹងវិលត្រឡប់។

22. ហើយគ្មាននរណាដែលបំពានជាងពួកដែលត្រូវបានគេទូន្មានដោយវាក្យខណ្ឌទាំងឡាយរបស់ព្រះជាម្ចាស់របស់គេក្រោយមក គេបែរជោងាកចេញពីវាទៅវិញនោះឡើយ។ ពិតប្រាកដណាស់ យើងគឺជាអ្នកផ្តន្ទាទោសដល់ពួកឧក្រិដ្ឋជនទាំងឡាយ។

23. ហើយពិតប្រាកដណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត)។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) កុំមានការមន្ទិលសង្ស័យចំពោះការជួបនឹងព្យាការីមូសា(នៅយប់អ៊ីសរ៉ែកនិងមៀកវ៉ាច)ឱ្យសោះ។ ហើយយើងបានចាត់ទុកគម្ពីរនេះ(គម្ពីរតាវ៉ាត)ជាការចង្អុលបង្ហាញដល់អម្បូរអ៊ីស្រាអែល។

24. ហើយយើងបានឱ្យពួកគេមួយចំនួន (អម្បូរអ៊ីស្រាអែល) ក្លាយទៅជាមេដឹកនាំដែលចង្អុលបង្ហាញ (ទៅកាន់ការពិត) ទៅតាមបទបញ្ជារបស់យើងនៅពេលដែលពួកគេបានអត់ធ្មត់។ ហើយពួកគេបានជឿជាក់យ៉ាងពិតប្រាកដចំពោះវាក្យខណ្ឌទាំងឡាយរបស់យើង។

25. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ទ្រង់នឹងកាត់សេចក្តីរវាងពួកគេនៅថ្ងៃបរលោកចំពោះអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នាចំពោះវា។

26. តើវាមិនទាន់បានបញ្ជាក់ច្បាស់ដល់ពួកទាំងនោះទៀតឬ ថាតើមានប្រជាជាតិជំនាន់មុនពួកគេប៉ុន្មានហើយដែលយើងបានបំផ្លាញ ដែលពួកទាំងនោះក៏បានដើរកាត់លំនៅឋានរបស់ពួកគេផងដែរនោះ? ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាង។ តើពួកគេមិនស្តាប់ឮទេឬ?

27. តើពួកទាំងនោះមិនបានឃើញទេឬថា ពិតប្រាកដណាស់ យើងបានបញ្ជូនទឹកភ្លៀងទៅកាន់ដីដែលស្ងួតហួតហែង។ ពេលនោះ តាមរយៈទឹកភ្លៀងនោះ យើងបានបង្កើតនូវដំណាំសម្រាប់សត្វពាហនៈរបស់ពួកគេ និងខ្លួនពួកគេផ្ទាល់ទទួលទាន។ តើពួកគេមិនបានឃើញទេឬ?

28. ហើយពួកគេថែមទាំងនិយាយថា៖ តើពេលណាទើបការកាត់សេចក្តីនេះមកដល់ ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ?

29. ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ពោលថា៖ ថ្ងៃកាត់សេចក្តីនោះ ការមានជំនឿរបស់ពួកប្រឆាំង (នៅលើលោកិយ) គឺគ្មានផលប្រយោជន៍អ្វីដល់ពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេលឲ្យនោះដែរ។

30. ដូច្នេះ ចូរអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) ងាកចេញពីពួកគេ ហើយរង់ចាំមើលចុះ។ ពិតប្រាកដណាស់ ពួកគេក៏ជាអ្នកដែលរង់ចាំមើលដែរ។

ជំពូក អាល់អះហ្សាប

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកកោតខ្លាចអល់ឡោះ(តែមួយគត់)ហើយមិនត្រូវប្រតិបត្តិតាមពួកគ្មានជំនឿ និងពួកពុតត្បុតឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិតបំផុត។

2. ហើយចូរអ្នកប្រតិបត្តិតាមអ្វីដែលគេបានផ្តល់វ៉ាហ៊ីទៅកាន់អ្នកពីព្រះជាម្ចាស់របស់អ្នកចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

3. ហើយចូរអ្នកប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកគាំពារ។

4. អល់ឡោះជាម្ចាស់មិនបង្កើតសម្រាប់បុរសម្នាក់ឱ្យមានបេះដូងពីរនៅក្នុងទ្រូងរបស់គេឡើយ។ ហើយទ្រង់មិនបានចាត់ទុកភរិយាទាំងឡាយរបស់ពួកអ្នកដែលពួកអ្នកនិយាយហ្ស៊ីហើរទៅកាន់នោះជាម្តាយរបស់ពួកអ្នកនោះឡើយ ហើយទ្រង់ក៏មិនចាត់ទុកកូនចិញ្ចឹមរបស់ពួកអ្នកជាកូនបង្កើតរបស់ពួកអ្នកនោះដែរ។ នោះគ្រាន់តែជាពាក្យសម្តីដែលពួកអ្នកនិយាយនឹងមាត់របស់ពួកអ្នកប៉ុណ្ណោះ។ តែអល់ឡោះជាម្ចាស់ទ្រង់មានបន្ទូលពាក្យពិត និងចង្អុលបង្ហាញទៅកាន់មាគ៌ា(ត្រឹមត្រូវ)។

5. ចូរពួកអ្នកដាក់នាមត្រកូលពួកគេ(កូនចិញ្ចឹម)ទៅតាមត្រកូលឪពុកបង្កើតពួកគេចុះ វាជារឿងយុត្តិធម៌បំផុតចំពោះអល់ឡោះ។ តែប្រសិនបើពួកអ្នកមិនស្គាល់(ឈ្មោះ)ឪពុកបង្កើតរបស់ពួកគេទេនោះ ពិតណាស់(ពួកគេគឺ)ជាបងប្អូនរួមសាសនារបស់ពួកអ្នក និងជាអ្នកដែលពួកអ្នករំដោះចេញពីភាពជាទាសករ។ ហើយគ្មានទោសពៃរ៍អ្វីឡើយលើពួកអ្នកដែលពួកអ្នកហៅនាមត្រកូលរបស់ពួកគេខុស(ដោយអចេតនា)លើកលែងតែអ្វីដែលពួកអ្នកមានចេតនាប៉ុណ្ណោះ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

6. ព្យាការី(មូហាំម៉ាត់)មានសិទ្ធិបំផុតចំពោះបណ្តាអ្នកមានជំនឿជាងពួកគេខ្លួនឯងទៅទៀត ហើយភរិយាទាំងឡាយរបស់គាត់គឺជាមាតារបស់ពួកគេ។ ហើយអ្នកដែលជាសាច់សាលោហិតនឹងគ្នា គឺមានសិទ្ធិក្នុងការទទួលកេរមរតកពីគ្នាទៅវិញទៅមកស្របទៅតាមច្បាប់របស់អល់ឡោះជាងបណ្តាអ្នកដែលមានជំនឿ និងអ្នកដែលបានភៀសខ្លួន(ក្នុងមាគ៌ាអល់ឡោះ)ទៅទៀត លើកលែងតែពួកអ្នកចង់ធ្វើល្អចំពោះមនុស្សដែលស្រឡាញ់គ្នាជិតជិតប៉ុណ្ណោះ។ ពិតណាស់ រឿងនោះគឺត្រូវបានគេកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វ៊ូស)រួចហើយ។

7. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលយើងបានទទួលយកពីបណ្តាព្យាការីទាំងឡាយនូវកិច្ចសន្យាដ៏ម៉ឺងម៉ាត់របស់ពួកគេ និង(បានទទួលយក)អំពីអ្នក ពីព្យាការីនួហ ពីព្យាការីអ៊ីព្រហ៊ីម ពីព្យាការីមូសា និងពីព្យាការីអ៊ីសា កូន ម៉ារយ៉ាំ។ ហើយយើងបានទទួលយកពីពួកគេនូវកិច្ចសន្យាមួយដ៏មុតមាំបំផុត

8. ដើម្បីទ្រង់នឹងសួរអ្នកដែលទៀងត្រង់ទាំងឡាយពីភាពសច្ចៈរបស់ពួកគេ។ ហើយទ្រង់បានត្រៀមទុកសម្រាប់ពួកដែលប្រឆាំងនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

9. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកនឹកឃើញនូវឧបការគុណរបស់អល់ឡោះជាម្ចាស់ទៅលើពួកអ្នក ខណៈដែលកងទ័ពជាច្រើន(របស់ពួកប្រឆាំង)បានមកដល់ពួកអ្នក។ ពេលនោះ យើងបានបញ្ជូនខ្យល់ និងកងទ័ព(ម៉ាឡាអ៊ីកាត់)ជាច្រើនដែលពួកអ្នកមើលមិនឃើញទៅកាន់ពួកគេ។ ហើយអល់ឡោះជាម្ចាស់ទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

10. (ចូរអ្នកនឹកឃើញ)នៅពេលដែលពួកគេ(ពួកប្រឆាំង)បានមកកាន់ពួកអ្នកពីខាងលើ និងពីខាងក្រោមពួកអ្នក។ នៅខណៈនោះ កែវភ្នែកទាំងឡាយបានស្រឡំងកាំង ហើយដួងចិត្តពោរពេញទៅដោយក្តីរន្ធត់។ ហើយពួកអ្នកនឹកស្មានចំពោះអល់ឡោះនូវការនឹកស្មានគ្រប់បែបយ៉ាង។

11. នៅទីនោះ បណ្តាអ្នកមានជំនឿត្រូវបានគេសាកល្បង ហើយពួកគេត្រូវបានគេធ្វើឲ្យ(ភ័យ)ញាប់ញ័រយ៉ាងក្រៃលែង។

12. នៅថ្ងៃនោះ ពួកពុតត្បុត និងបណ្តាអ្នកដែលនៅក្នុងដួងចិត្តរបស់ពួកគេមានជំងឺបាននិយាយថា៖ អ្វីដែលអល់ឡោះជាម្ចាស់និងអ្នកនាំសាររបស់ទ្រង់បានសន្យាចំពោះពួកយើងនោះ គឺគ្រាន់តែជាការបោកប្រាស់ប៉ុណ្ណោះ។

13. ហើយ(ចូរអ្នកនឹកឃើញ)នៅពេលដែលក្រុមមួយក្នុងចំណោមពួកគេ(ពួកពុតត្បុត)បាននិយាយថា៖ ឱអ្នកស្រុកយ៉ាសរិប(ឈ្មោះក្រុងម៉ាទីណះមុនអ៊ីស្លាមមកដល់)! គ្មានទីតាំងឈរជើងសម្រាប់ពួកអ្នកទៀតឡើយ។ ដូច្នេះ ចូរពួកអ្នកត្រឡប់ទៅវិញចុះ។ ហើយមានក្រុមមួយទៀតក្នុងចំណោមពួកគេបានសុំការអនុញ្ញាតពីព្យាការីដោយពួកគេនិយាយថា៖ "ផ្ទះរបស់ពួកយើង គ្មានអ្នកការពារឡើយ" ខណៈដែល(ការពិត)វាមិនមែនគ្មានអ្នកការពារឡើយ។ ពួកគេគ្មានបំណងអ្វីក្រៅពីរត់គេចប៉ុណ្ណោះ។

14. ហើយប្រសិនបើគេ(ពួកសត្រូវ)បានចូលលុកលុយទៅលើពួកគេពីគ្រប់ច្រកទាំងអស់ ហើយគេសុំឱ្យពួកគេវិលត្រឡប់ទៅកាន់ភាពគ្មានជំនឿ នោះពួកគេប្រាកដជាទទួលយកជាមិនខាន ហើយគ្មានអ្នកណាដែលបង្អែរបង្អង់ក្នុងការវិលត្រឡប់(ទៅរកភាពគ្មានជំនឿ)នោះឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

15. ហើយពិតប្រាកដណាស់ ពួក(ពុតត្បុត)ទាំងនោះធ្លាប់បានសន្យានឹងអល់ឡោះកាលពីមុនថា ពួកគេនឹងមិនរត់បកក្រោយទៀតឡើយ។ ហើយការសន្យារបស់អល់ឡោះ គឺត្រូវតែទទួលខុសត្រូវ។

16. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ការរត់គេចដែលពួកអ្នករត់គេច(ដោយខ្លាច)ពីសេចក្តីស្លាប់ឬ(ខ្លាច)ការប្រយុទ្ធនោះ គឺគ្មានផលប្រយោជន៍អ្វីដល់ពួកអ្នកឡើយ។ ហើយបើទោះជាបែបនោះក៏ដោយ ក៏គេមិនផ្តល់ឲ្យពួកអ្នកសោយសុខនោះដែរ លើកលែងតែមួយរយៈពេលខ្លីប៉ុណ្ណោះ។

17. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើមានអ្នកណាដែលអាចការពារពួកអ្នកពីអល់ឡោះបាន ប្រសិនបើទ្រង់មានចេតនាចង់ឱ្យពួកអ្នកទទួលនូវប្រការអាក្រក់ ឬមានចេតនាចង់ឱ្យពួកអ្នកទទួលបាននូវក្តីមេត្តាករុណានោះ? ហើយសម្រាប់ពួកគេ គឺគ្មានអ្នកគាំពារ និងគ្មានអ្នកជួយណាក្រៅពីអល់ឡោះឡើយ។

18. ជាការពិតណាស់ អល់ឡោះទ្រង់ដឹងបំផុតចំពោះពួកដែលរារាំងអ្នកដទៃក្នុងចំណោមពួកអ្នក និងពួកដែលនិយាយទៅកាន់បងប្អូនរបស់ពួកគេថា៖ "ចូរពួកអ្នកមករកពួកយើងវិញមក"។ ហើយពួកទាំងនោះមិនដែលទៅសមរភូមិឡើយ លើកលែងតែដោយកម្របំផុត។

19. ពួកគេកំណាញ់បំផុតទៅលើពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)។ ហើយបើកាលណាភាពភ័យខ្លាចបានមកដល់ អ្នកនឹងឃើញពួកគេមើលមកកាន់អ្នកដោយភ្នែកក្រឡប់ចាក់ដូចអ្នកដែលសេចក្តីស្លាប់គ្របដណ្តប់លើរូបគេ(ជិតស្លាប់)ដូច្នោះដែរ។ ហើយបើកាលណាភាពភ័យខ្លាចបានរសាយបាត់ ពួកគេក៏វាយប្រហារពួកអ្នកដោយប្រើពាក្យបញ្ជីដោយភាពកំណាញ់បំផុតចំពោះប្រការល្អ។ ពួកទាំងនោះពុំមែនជាពួកដែលមានជំនឿឡើយ។ ដូចនេះ អល់ឡោះជាម្ចាស់ក៏បានលុបបំបាត់នូវទង្វើ(កុសល)របស់ពួកគេ។ ហើយនោះ គឺជារឿងងាយស្រួលបំផុតសម្រាប់អល់ឡោះ។

20. ពួកគេ(ពួកពុតត្បុត)នឹកស្មានថា ពួកពហុក្រុមទាំងនោះនឹងមិនដកថយទៅវិញឡើយ។ ហើយប្រសិនបើពួកពហុក្រុមទាំងនោះមកម្តងទៀត ពួកគេប្រាថ្នាថា ពួកគេនឹងទៅជាមួយពួកអារ៉ាប់ជនបទដោយចាំស៊ើបសួរព័ត៌មានរបស់ពួកអ្នក។ ហើយបើទោះបីជាពួកគេស្ថិតនៅជាមួយពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ក៏ដោយ ក៏ពួកគេមិនចូលរួមប្រយុទ្ធនោះដែរ លើកលែងតែមួយចំនួនតូចប៉ុណ្ណោះ។

21. ពិតប្រាកដណាស់ សម្រាប់ពួកអ្នក ចំពោះអ្នកនាំសាររបស់អល់ឡោះ(ព្យាការីមូហាំម៉ាត់)គឺជាគំរូដ៏ល្អសម្រាប់ជនណាដែលរំពឹង(ផលបុណ្យពី)អល់ឡោះ និងថ្ងៃបរលោក ព្រមទាំងបានរំឭកទៅចំពោះអល់ឡោះយ៉ាងច្រើន។

22. ហើយនៅពេលដែលអ្នកមានជំនឿបានឃើញពួកពហុក្រុមជាច្រើន ពួកគេបាននិយាយថា៖ នេះហើយជាអ្វីដែលអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់បានសន្យាចំពោះពួកយើង។ ហើយអ្វីដែលអល់ឡោះនិងអ្នកនាំសារបានសន្យា គឺជាការពិត។ ហើយវាមិនបានបន្ថែមអ្វីដល់ពួកគេក្រៅតែពីការមានជំនឿ និងការប្រគល់ខ្លួននោះឡើយ។

23. ក្នុងចំណោមបណ្តាអ្នកមានជំនឿ គឺមានបុរសជាច្រើនដែលទៀងត្រង់ចំពោះអ្វីដែលពួកគេបានសន្យាជាមួយនឹងអល់ឡោះ។ ដូច្នេះ ក្នុងចំណោមពួកគេ មានអ្នកខ្លះបានពលីជីវិត ហើយមានអ្នកខ្លះទៀត កំពុងតែរង់ចាំ។ ហើយពួកគេពុំបានផ្លាស់ប្តូរ(នូវអ្វីដែលពួកគេបានសន្យា)នោះឡើយ។

24. ដើម្បីអល់ឡោះនឹងតបស្នងដល់បណ្តាអ្នកដែលទៀងត្រង់ចំពោះភាពសច្ចៈរបស់ពួកគេ។ ហើយទ្រង់នឹងដាក់ទណ្ឌកម្មពួកពុតត្បុត ប្រសិនបើទ្រង់មានចេតនា ឬទុកឲ្យពួកគេសោភាពកំហុស។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

25. ហើយអល់ឡោះបានឱ្យពួកគ្មានជំនឿត្រឡប់ទៅវិញជាមួយនឹងទុក្ខព្រួយរបស់ពួកគេដោយពួកគេមិនទទួលបាននូវប្រការល្អឡើយ។ ហើយអល់ឡោះបានជួយជ្រោមជ្រែងបណ្តាអ្នកមានជំនឿក្នុងការប្រយុទ្ធ(ជាមួយពួកគេ)។ ហើយអល់ឡោះជាម្ចាស់មហាខ្លាំងក្លា មហាខ្លាំងពូកែបំផុត។

26. ហើយអល់ឡោះបានឱ្យពួកអះលីគីតាបដែលបានជួយពួកទាំងនោះចុះចេញពីបន្ទាយរបស់ពួកគេ។ ហើយទ្រង់បានបញ្ចូលភាពភ័យខ្លាចទៅក្នុងដួងចិត្តរបស់ពួកគេ។ មួយក្រុមនៃពួកគេត្រូវបានពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)សម្លាប់ ហើយមួយក្រុមទៀតត្រូវបានពួកអ្នកចាប់ជាឈ្លើយសឹក។

27. ហើយទ្រង់បានឱ្យពួកអ្នកទទួលមរតកពីទឹកដី លំនៅឋាន និងទ្រព្យសម្បត្តិរបស់ពួកគេ ព្រមទាំងទឹកដីផ្សេងទៀតដែលពួកគេមិនធ្លាប់បានជាន់(កាន់កាប់)នោះពីមុនមកឡើយ។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

28. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកពោលទៅកាន់ភរិយាទាំងឡាយរបស់អ្នកថា៖ ប្រសិនបើពួកនាងចង់បានតែការរស់នៅក្នុងលោកិយ និងការតុបតែងលម្អរបស់វា ចូរពួកនាងអញ្ជើញមក ខ្ញុំនឹងឲ្យពួកនាងបានសោយសុខ ហើយខ្ញុំនឹងលែងលះពួកនាងនូវការលែងលះមួយដ៏ល្អប្រសើរ។

29. តែបើសិនជាពួកនាងចង់បាន(ការពេញចិត្តពី)អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងថ្ងៃបរលោកនោះ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានត្រៀមទុកសម្រាប់អ្នកដែលធ្វើល្អក្នុងចំណោមពួកនាងនូវផលបុណ្យដ៏ធំធេង។

30. ឱបណ្តាភរិយាទាំងឡាយរបស់ព្យាការី! ជនណាក្នុងចំណោមពួកនាងដែលបានប្រព្រឹត្តទង្វើអសីលធម៌ដ៏ច្បាស់លាស់ នោះនាងនឹងត្រូវគេដាក់ទណ្ឌកម្មទ្វេដង ហើយនោះគឺជារឿងដ៏ងាយស្រួលបំផុតសម្រាប់អល់ឡោះជាម្ចាស់។

31. ហើយជនណាក្នុងចំណោមពួកនាងដែលប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ព្រមទាំងបានសាងទង្វើកុសលយើងនឹងប្រទានឱ្យនាងនូវផលបុណ្យទ្វេដង ហើយយើងបានរៀបចំសម្រាប់នាងនូវលាភសក្ការៈដ៏ប្រពៃ(ឋានសួគ៌)។

32. ឱបណ្ដាភរិយាទាំងឡាយរបស់ព្យាការី(មូហាំម៉ាត់)! ជាការពិតណាស់ ពួកនាងមិនដូចស្ត្រីណាម្នាក់ក្នុងចំណោមស្ត្រីដទៃឡើយ ប្រសិនបើពួកនាងកោតខ្លាច(អល់ឡោះ)នោះ។ ដូច្នេះ ចូរពួកនាងកុំប្រើពាក្យសម្ដីម៉ិកម៉ក់ដែលជាហេតុធ្វើឱ្យអ្នកដែលនៅក្នុងចិត្តរបស់គេមានជំងឺ(ចំណង់តណ្ហា)ចាប់អារម្មណ៍ឲ្យសោះ។ តែចូរពួកនាងនិយាយដោយប្រើពាក្យសម្ដីល្អៗ។

33. ហើយចូរពួកនាងរក្សាខ្លួននៅក្នុងផ្ទះរបស់ពួកនាង ហើយចូរកុំបង្ហាញភាពឆើតឆាយ(របស់ពួកនាង)ដូចពួកស្ត្រីសម័យកាលអវិជ្ជាពីមុនបង្ហាញភាពឆើតឆាយនោះឱ្យសោះ។ ហើយចូរពួកនាងប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយនិងប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ តាមពិត អល់ឡោះជាម្ចាស់ទ្រង់មានបំណងចង់បំបាត់នូវភាពកខ្វក់ចេញពីពួកអ្នក ឱក្រុមគ្រួសារព្យាការី និងជម្រះសម្អាតពួកអ្នកឲ្យមានភាពជ្រះស្អាត។

34. ហើយចូរពួកនាងរំឭកនូវអ្វីដែលគេបានសូត្រនៅក្នុងផ្ទះរបស់ពួកនាងនៃបណ្ដាវាក្យខណ្ឌរបស់អល់ឡោះ(គម្ពីរគួរអាន)និងគតិបណ្ឌិត(ស៊ុណ្ណះ)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាទន់ភ្លន់ មហាដឹងបំផុត។

35. ពិតប្រាកដណាស់ បណ្ដាជនមូស្លីមទាំងប្រុសទាំងស្រី បណ្ដាអ្នកមានជំនឿទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលគោរពប្រតិបត្តិអល់ឡោះទាំងប្រុសទាំងស្រី បណ្ដាអ្នកសច្ចៈទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលអត់ធ្មត់ទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលបារម្ភខ្លាច(ចំពោះអល់ឡោះ)ទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលបរិច្ចាគទានទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលកាន់អំណត់បួសទាំងប្រុសទាំងស្រី បណ្ដាអ្នកដែលថែរក្សាកេរខ្មាសរបស់ខ្លួនទាំងប្រុសទាំងស្រី និងបណ្ដាអ្នកដែលរឭកទៅចំពោះអល់ឡោះយ៉ាងច្រើនទាំងប្រុសទាំងស្រី អ្នកទាំងនោះ អល់ឡោះជាម្ចាស់បានត្រៀមទុកសម្រាប់ពួកគេនូវការអភ័យទោសនិងផលបុណ្យដ៏ធំធេង(ហានសួគ៌)។

36. ហើយមិនត្រឹមត្រូវឡើយសម្រាប់អ្នកមានជំនឿទាំងប្រុសទាំងស្រី នៅពេលណាដែលអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់បានកំណត់នូវបទបញ្ជាណាមួយ(ចំពោះពួកគេ)ហើយនោះ ពួកគេបែរជាមានជម្រើសក្នុងកិច្ចការរបស់ពួកគេក្រៅពីនោះទៅវិញ។ ហើយជនណាដែលប្រឆាំងនឹងអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ពិតប្រាកដណាស់ រូបគេពិតជាបានវង្វេងយ៉ាងច្បាស់លាស់។

37. ហើយនៅពេលដែលអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បាននិយាយទៅកាន់អ្នកដែលអល់ឡោះបានប្រទាននូវឧបការគុណដល់គេ ហើយអ្នកក៏បានផ្ដល់នូវឧបការគុណដល់គេផងដែរនោះ(ពោលគឺហ្សៃត កូន ហារីសៈ)ថាៈ "ចូរអ្នករួមរស់ជាមួយភរិយារបស់អ្នកចុះ ហើយចូរអ្នកកោតខ្លាចអល់ឡោះ" តែអ្នកបានលាក់ទុកក្នុងចិត្តរបស់អ្នកនូវអ្វីដែលអល់ឡោះបានបង្ហាញវាដល់អ្នកដោយសារអ្នកខ្លាច(ខ្មាស)មនុស្សលោក។ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទៅវិញទេដែលសក្តិសមឱ្យអ្នកខ្លាចទ្រង់នោះ។ ហើយនៅពេលដែលហ្សៃទបានសម្រេចចិត្ត(លែងលះនាង) យើងក៏បានរៀបការនាងឱ្យទៅអ្នក ដើម្បីកុំឱ្យបណ្ដាអ្នកមានជំនឿទាំងឡាយមានទោសពៃរ៍ចំពោះការរៀបការជាមួយនឹងភរិយារបស់កូនចិញ្ចឹមរបស់ខ្លួននៅពេលដែលពួកគេ(កូនចិញ្ចឹម)បានលែងលះពួកនាងហើយនោះ។ ហើយកិច្ចការរបស់អល់ឡោះត្រូវបានគេអនុវត្តន៍។

38. គ្មានទោសពៃរ៍អ្វីឡើយលើព្យាការី(មូហាំម៉ាត់)ចំពោះអ្វីដែលអល់ឡោះបានអនុញ្ញាតដល់គាត់នោះ ព្រោះវាក៏ជាមាគ៌ា(លំអាន)របស់អល់ឡោះចំពោះបណ្ដាអ្នកជំនាន់មុនផងដែរ។ ហើយបទបញ្ជារបស់អល់ឡោះ គឺត្រូវបានកំណត់យ៉ាងជាក់ខាត។

39. (បណ្ដាព្យាការីទាំងនោះ)គឺជាអ្នកដែលបានផ្សព្វផ្សាយសារទាំងឡាយរបស់អល់ឡោះ ហើយពួកគេខ្លាចទ្រង់ ដោយពួកគេមិនខ្លាចនរណាម្នាក់ក្រៅពីអល់ឡោះឡើយ។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកថែរក្សា(នូវរាល់ទង្វើទាំងឡាយ)។

40. ព្យាការីមូហាំម៉ាត់ពុំមែនជាឪពុករបស់នរណាម្នាក់ក្នុងចំណោមបុរសរបស់ពួកអ្នកឡើយ។ ក៏ប៉ុន្តែ គាត់គឺជាអ្នកនាំសាររបស់អល់ឡោះ និងជាព្យាការីចុងក្រោយបង្អស់។ ហើយអល់ឡោះមហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

41. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នករឭកដល់អល់ឡោះឱ្យបានច្រើនបំផុត។

42. ហើយចូរពួកអ្នកលើកតម្កើងទ្រង់ ទាំងពេលព្រឹកនិងពេលល្ងាច។

43. ទ្រង់គឺជាអ្នកប្រសិទ្ធិពរជ័យដល់ពួកអ្នក ហើយបណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់(ក៏សុំពរជ័យឱ្យពួកអ្នកផងដែរ) ដើម្បីទ្រង់បញ្ចេញពួកអ្នកពីភាពងងឹតទៅកាន់ពន្លឺ។ ហើយទ្រង់មហាអាណិតស្រលាញ់បំផុតចំពោះបណ្តាអ្នកមានជំនឿ។

44. ការស្វាគមន៍របស់ពួកគេ(អ្នកមានជំនឿ)នៅថ្ងៃដែលពួកគេជួបនឹងព្រះជាម្ចាស់របស់ពួកគេនោះ គឺសាឡាម(សន្តិភាព)។ ហើយអល់ឡោះជាម្ចាស់ទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវផលបុណ្យដ៏ប្រពៃ(ឋានសួគ៌)។

45. ឱព្យាការី(មូហាំម៉ាត់)! ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នកជាសាក្សី ជាអ្នកផ្តល់ដំណឹងរីករាយ និងព្រមានបន្លាច

46. ហើយនិងជាអ្នកអំពាវនាវទៅកាន់(ការគោរពសក្ការៈ)អល់ឡោះជាម្ចាស់ដោយការអនុញ្ញាតពីទ្រង់ និងជាចង្កៀងបំភ្លឺ។

47. ហើយចូរអ្នកផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿថាៈ ពិតប្រាកដណាស់ សម្រាប់ពួកគេនឹងទទួលបាននូវការប្រោសប្រទានដ៏ធំធេង។

48. ហើយចូរអ្នកកុំប្រតិបត្តិតាមពួកគ្មានជំនឿនិងពួកពុតត្បុត និងកុំខ្វល់ពីការធ្វើទុក្ខបុកម្នេញរបស់ពួកគេ។ ហើយចូរអ្នកប្រគល់ការទុកចិត្តលើអល់ឡោះចុះ។ គ្រប់គ្រាន់ហើយដែលអល់ឡោះជាអ្នកគាំពារ។

49. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលពួកអ្នករៀបអាពាហ៍ពិពាហ៍ជាមួយបណ្តាស្ត្រីដែលមានជំនឿ ក្រោយមក ពួកអ្នកបានលែងលះពួកនាងវិញមុនពេលដែលពួកអ្នកបានរួមដំណេកជាមួយនឹងពួកនាង ជាការពិតណាស់ ពួកនាងពុំមានរយៈពេលរង់ចាំ(អ៊ិទហ្វះ)ដែលត្រូវរាប់នោះឡើយ។ តែសូមពួកអ្នកផ្តល់ឱ្យពួកនាងនូវទ្រព្យសម្បត្តិ(ជាការប៉ះប៉ូវដល់ពួកនាង) ហើយចូរបើកផ្លូវឱ្យពួកនាងដោយល្អប្រពៃ។

50. ឱព្យាការី(មូហាំម៉ាត់)! ពិតប្រាកដណាស់ យើងបានអនុញ្ញាតឱ្យអ្នកនូវភរិយាទាំងឡាយរបស់អ្នកដែលអ្នកបានប្រគល់(ឱ្យពួកនាង)នូវប្រាក់ខាន់ស្លារបស់ពួកនាងរួច ហើយនិងខ្ញុំបម្រើដាច់ស្តែដែលអល់ឡោះបានប្រទានឱ្យអ្នកពីឈ្លើយសឹក(ជាជ័យភណ្ឌ)នោះ។ ហើយ(យើងក៏បានអនុញ្ញាតឱ្យអ្នករៀបការផងដែរដោយមួយនឹង)កូនស្រីរបស់ពូមីងខាងឪពុករបស់អ្នក(ក្មួយស្រីបង្កើតខាងឪពុក) និងកូនស្រីរបស់ពូមីងខាងម្តាយរបស់អ្នក(ក្មួយស្រីបង្កើតខាងម្តាយ)ដែលពួកនាងបានភៀសខ្លួនជាមួយអ្នក ព្រមទាំងស្ត្រីដែលជាអ្នកមានជំនឿ ប្រសិនបើនាងព្រមប្រគល់ខ្លួនរបស់នាងឱ្យព្យាការី(ដោយគ្មានខាន់ស្លា) ប្រសិនបើព្យាការីចង់រៀបការជាមួយនាងដែលជាករណីពិសេសសម្រាប់តែអ្នក(ព្យាការីមូហាំម៉ាត់)ប៉ុណ្ណោះ ខុសពីបណ្តាអ្នកមានជំនឿទាំងឡាយ។ ពិតប្រាកដណាស់ យើងដឹងនូវអ្វីដែលយើងបានដាក់ជាកាតព្វកិច្ចទៅលើពួកគេ(បណ្តាអ្នកមានជំនឿ)ចំពោះរឿងភរិយារបស់ពួកគេ ហើយនិងស្ត្រីបម្រើដាច់ស្តែ ដែលនៅក្រោមការគ្រប់គ្រងរបស់ពួកគេ ដើម្បីកុំឱ្យអ្នកមានការចង្អៀតចង្អល់អ្វីឡើយ។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

51. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អាចមិនរួមមេត្រីជាមួយភរិយារូបណាដែលអ្នកប្រាថ្នាក្នុងចំណោមពួកនាង និងអាចរួមមេត្រីជាមួយភរិយាណាដែលអ្នកប្រាថ្នា។ ហើយចំពោះភរិយាណាដែលអ្នកមានបំណងត្រឡប់(ទៅរួមមេត្រីជាមួយ)ក្នុងចំណោមភរិយាដែលអ្នកបានដកខ្លួនចេញ(មិនរួមមេត្រីជាមួយ)គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះអ្នក(ក្នុងការធ្វើដូច្នេះ)។ នោះគឺភៀសបំផុតក្នុងការដែលធ្វើឱ្យពួកនាងមានភាពរីករាយ និងមិនមានទុក្ខព្រួយ ព្រមទាំងធ្វើឱ្យពួកនាងពេញចិត្តនូវអ្វីដែលអ្នកបានផ្តល់ឱ្យពួកនាងគ្រប់គ្នា។ ហើយអល់ឡោះដឹងបំផុតនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកអ្នក។ ហើយអល់ឡោះមហាដឹង មហាខន្តីបំផុត។

52. គេមិនអនុញ្ញាតឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រៀបការជាមួយស្ត្រីផ្សេងបន្ទាប់ពីនេះឡើយ ហើយគេក៏មិនអនុញ្ញាតឱ្យអ្នកលែងលះពួកនាងដើម្បីរៀបការជាមួយនឹងស្ត្រីផ្សេងទៀតនោះដែរ ទោះបីជាសម្រស់ស្រស់ស្អាតរបស់ពួកនាងធ្វើឱ្យអ្នកចាប់អារម្មណ៍ក៏ដោយ លើកលែងតែខ្ញុំបម្រើដាច់ថ្លៃដែលនៅក្រោមការគ្រប់គ្រងរបស់អ្នកប៉ុណ្ណោះ។ ហើយអល់ឡោះជាអ្នកឃ្លាំមើលលើរាល់អ្វីៗទាំងអស់។

53. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំចូលគេហដ្ឋានរបស់ព្យាការី លើកលែងតែគេអនុញ្ញាតឱ្យពួកអ្នកដើម្បីទៅទទួលទានអាហារប៉ុណ្ណោះ ដោយមិនត្រូវទៅអង្គុយរង់ចាំមុននោះឡើយ។ ក៏ប៉ុន្តែ នៅពេលដែលគេអញ្ជើញពួកអ្នក សូមពួកអ្នកចូលទៅចុះ។ ហើយបើកាលណាពួកអ្នកទទួលទានអាហាររួចរាល់ហើយនោះ សូមពួកអ្នកចាកចេញទៅ ហើយសូមកុំនៅបន្តនិយាយគ្នាលេង(បន្ទាប់ពីនោះ)ឱ្យសោះ។ ពិតប្រាកដណាស់ ការធ្វើដូច្នោះ គឺធ្វើឱ្យមានភាពទើសទាល់ដល់ព្យាការី ហើយគាត់មានការអៀនខ្មាសចំពោះពួកអ្នក។ ប៉ុន្តែអល់ឡោះទ្រង់មិនអៀនខ្មាសចំពោះរឿងត្រឹមត្រូវឡើយ។ ហើយនៅពេលដែលពួកអ្នកសុំរបស់របរណាមួយពីពួកនាង(ភរិយាព្យាការី) ចូរពួកអ្នកសុំពួកនាងពីក្រោយរបាំង។ នោះគឺជាការស្អាតស្អំបំផុតចំពោះចិត្តរបស់ពួកអ្នក និងចិត្តរបស់ពួកនាង។ ហើយមិនគប្បីឡើយចំពោះពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ក្នុងការដែលពួកអ្នកធ្វើឱ្យមានការប៉ះពាល់ដល់អ្នកនាំសាររបស់អល់ឡោះ ហើយក៏មិនត្រូវរៀបការជាមួយនឹងភរិយាទាំងឡាយរបស់គាត់ក្រោយពីគាត់(បានស្លាប់)ជាដាច់ខាត។ ពិតប្រាកដណាស់ ការធ្វើដូច្នោះ គឺជារឿងមួយដ៏ធំធេងបំផុតចំពោះអល់ឡោះជាម្ចាស់។

54. ទោះបីជាពួកអ្នកលាតត្រដាងអ្វីមួយ ឬក៏ពួកអ្នកលាក់បាំងវាក៏ដោយ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

55. គ្មានទោសពៃរ៍អ្វីឡើយចំពោះពួកនាង(ក្នុងការមិនពាក់ហ៊ីហ្ជាប)ជាមួយនឹងឪពុករបស់ពួកនាង កូនប្រុសរបស់ពួកនាង បងប្អូនប្រុសរបស់ពួកនាង ក្មួយប្រុសរបស់ពួកនាងទាំងខាងបងប្អូនប្រុសនិងខាងបងប្អូនស្រី ស្ត្រីដែលមានជំនឿ និងស្ត្រីបម្រើដាច់ថ្លៃដែលនៅក្រោមការគ្រប់គ្រងរបស់ពួកនាង។ ហើយចូរពួកនាងកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកធ្វើសាក្សីលើរាល់អ្វីៗទាំងអស់។

56. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ និងម៉ាឡាអ៊ីកាត់ទាំងឡាយរបស់ទ្រង់សឡាវ៉ាតលើព្យាការី(មូហាំម៉ាត់)។ ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកសឡាវ៉ាត និងឲ្យសាឡាមទៅលើគាត់ចុះ។

57. ពិតប្រាកដណាស់ ពួកដែលធ្វើឲ្យប៉ះពាល់ដល់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់នោះ អល់ឡោះជាម្ចាស់នឹងដាក់បណ្តាសាពួកគេទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

58. ហើយពួកដែលធ្វើឲ្យប៉ះពាល់ដល់បណ្តាអ្នកមានជំនឿទាំងប្រុសទាំងស្រី ទាំងដែលពួកគេគ្មានកំហុស ពួកទាំងនោះពិតជាប្រព្រឹត្តនូវការចោទប្រកាន់កូតកុហក និងបាបកម្មយ៉ាងច្បាស់លាស់។

59. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកពោលទៅកាន់ភរិយាទាំងឡាយរបស់អ្នក កូនស្រីទាំងឡាយរបស់អ្នក និងទៅកាន់បណ្តាស្ត្រីដែលជាអ្នកមានជំនឿទាំងឡាយឱ្យបិទបាំងរាងកាយរបស់ពួកនាង(ដោយគ្រប)ដោយស្បៃរបស់ពួកនាង(ពីលើក្បាលដល់ក្រោមទ្រូង)។ ការធ្វើដូច្នោះ គឺងាយស្រួលបំផុតនឹងឱ្យគេស្គាល់(ថាជាស្ត្រីដែលមានសិទ្ធិសេរីភាព) ហើយក៏មិនត្រូវគេបៀតបៀនពួកនាងនោះដែរ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

60. ប្រសិនបើពួកពុតត្បុត និងពួកដែលក្នុងចិត្តរបស់ពួកគេមានជំងឺ ហើយនិងពួកដែលនាំព័ត៌មានប្រឌិតក្នុងក្រុងម៉ាទីណៈមិនព្រមបញ្ឈប់(ទង្វើរបស់ពួកគេ)ទេនោះ យើងប្រាកដជានឹងឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ត្រួតត្រាលើពួកគេជាមិនខាន។ ក្រោយមក ពួកគេនឹងមិនអាចរស់នៅក្បែអ្នកនៅទីនោះទៀតឡើយ លើកលែងតែមួយរយៈពេលខ្លីប៉ុណ្ណោះ។

61. ពួកគេត្រូវបានគេដាក់បណ្តាសា។ នៅទីកន្លែងណាក៏ដោយដែលគេប្រទះឃើញពួកគេ ពួកគេនឹងត្រូវគេចាប់ជាឈ្លើយសឹក ហើយនិងត្រូវគេសម្លាប់រង្គាលជាមិនខាន។

62. នេះគឺជាមាគ៌ារបស់អល់ឡោះចំពោះពួកដែលបានកន្លងផុតទៅកាលពីមុន។ ហើយអ្នកនឹងមិនឃើញមាគ៌ារបស់អល់ឡោះមានការផ្លាស់ប្តូរឡើយ។

63. គេនឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីថ្ងៃបរលោក។ ចូរអ្នកឆ្លើយថា៖ ចំណេះដឹងអំពីវា គឺស្ថិតនៅឯអល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយតើអ្វីដែលធ្វើឱ្យអ្នកដឹងថា ថ្ងៃបរលោកនឹងមកដល់ឆាប់ៗនោះ ?

64. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដាក់បណ្តាសាពួកគ្មានជំនឿ និងបានត្រៀមទុកសម្រាប់ពួកគេនូវភ្លើងនរកដែលឆេះឆាប។

65. ពួកគេស្ថិតនៅក្នុងវាជាអមត:ដោយពួកគេគ្មានអ្នកគាំពារ ហើយក៏គ្មានអ្នកជួយនោះដែរ។

66. គឺនៅថ្ងៃដែលមុខរបស់ពួកគេត្រូវបានគេផ្តាប់ទៅក្នុងនរក។ ពួកគេនិយាយថា៖ ឱអនិច្ចាពួកយើង! គួរណាស់តែពួកយើងគោរពប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ(របស់ទ្រង់)។

67. ហើយពួកគេបានពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ យើងខ្ញុំបានគោរពប្រតិបត្តិតាមពួកមេដឹកនាំ និងពួកដែលមានឋានៈខ្ពង់ខ្ពស់នៃយើងខ្ញុំ ហើយពួកគេក៏បានធ្វើឱ្យយើងខ្ញុំវង្វេងចេញពីមាគ៌ា(ដែលត្រឹមត្រូវ)។

68. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គដាក់ទណ្ឌកម្មទ្វេដងលើពួកទាំងនោះ ហើយសូមព្រះអង្គដាក់បណ្តាសាដ៏ធ្ងន់ធ្ងរចំពោះពួកគេផងចុះ។

69. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំធ្វើខ្លួនដូចពួកដែលធ្វើទុក្ខបុកម្នេញព្យាការីមូសាឲ្យសោះ។ ពេលនោះ អល់ឡោះក៏បានឱ្យគាត់ចាកផុតពីអ្វីដែលពួកគេបាននិយាយ(ចោទប្រកាន់)។ ហើយពិតប្រាកដណាស់ គាត់(ព្យាការីមូសា)ជាអ្នកដែលមានឋានៈដ៏ឧត្តុង្គឧត្តមបំផុតចំពោះអល់ឡោះជាម្ចាស់។

70. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ និងត្រូវនិយាយនូវពាក្យសម្តីដែលត្រឹមត្រូវ

71. នោះទ្រង់នឹងកែលម្អឲ្យពួកអ្នកនូវទង្វើទាំងឡាយរបស់ពួកអ្នក ហើយទ្រង់នឹងអភ័យទោសដល់ពួកអ្នកនូវបាបកម្មទាំងឡាយរបស់ពួកអ្នក។ ហើយជនណាដែលប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ពិតប្រាកដណាស់ រូបគេពិតជាទទួលបាននូវជោគជ័យដ៏ធំធេង។

72. ពិតប្រាកដណាស់ យើងបានបង្ហាញទំនួលខុសត្រូវ(បទបញ្ជា និងការហាមឃាត់)ទៅកាន់មេឃជាច្រើនជាន់ និងផែនដី ព្រមទាំងភ្នំទាំងឡាយ ប៉ុន្តែពួកវាបានបដិសេធមិនហ៊ានទទួលយកវា និងខ្លាចមិនអាចអនុវត្តន៍បាន។ តែមនុស្សលោកបានទទួលយកវា។ ពិតប្រាកដណាស់ គេ(មនុស្សលោក) គឺជាអ្នកបំពាន និងជាអ្នកដែលល្ងង់ខ្លៅបំផុត(ចំពោះខ្លួនឯង)។

73. ដើម្បីអល់ឡោះនឹងដាក់ទណ្ឌកម្មលើពួកពុតត្បុតទាំងប្រុសទាំងស្រី និងពួកមុស្រីគីនទាំងប្រុសទាំងស្រី ហើយទទួលយកការសារភាពកំហុសរបស់បណ្តាអ្នកមានជំនឿទាំងប្រុសទាំងស្រី។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់បំផុត។

ជំពូក សាហ្ពាក់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធរបស់ទ្រង់(តែមួយគត់)។ ហើយការសរសើរទាំងឡាយនៅថ្ងៃបរលោកក៏ជាកម្មសិទ្ធិរបស់ទ្រង់ផងដែរ។ ហើយទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

2. ទ្រង់ដឹងនូវអ្វីដែលចូលទៅក្នុងដី និងអ្វីដែលចេញពីដី អ្វីដែលចុះមកពីលើមេឃ ហើយនិងអ្វីដែលឡើងទៅលើមេឃវិញ។ ហើយទ្រង់មហាអាណិតស្រលាញ់ មហាអភ័យទោសបំផុត។

3. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ ថ្ងៃបរលោកនឹងមិនអាចមកដល់(កើតឡើង)ចំពោះពួកយើងឡើយ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពុំដូច្នោះឡើយ សូមស្បថនឹងព្រះជាម្ចាស់នៃខ្ញុំ! ថ្ងៃបរលោកប្រាកដជានឹងមកដល់ពួកអ្នកពុំខានឡើយ។ (អល់ឡោះ)ជាអ្នកដែលដឹងបំផុតនូវប្រការអាថ៌កំបាំងទាំងឡាយដោយគ្មានអ្វីមួយអាចលាក់បាំងពីការដឹងរបស់ទ្រង់ឡើយ សូម្បីតែវាមានទម្ងន់តូចប៉ុនសត្វស្រមោចក៏ដោយ មិនថានៅលើមេឃជាច្រើនជាន់ ឬនៅលើផែនដីឡើយ។ ហើយក៏គ្មានអ្វីដែលតូចជាងនេះ ឬធំជាងនេះនោះឡើយ លើកលែងតែត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)យ៉ាងច្បាស់លាស់។

4. ដើម្បីទ្រង់នឹងតបស្នងដល់បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល។ អ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងលាភសក្ការៈដ៏ប្រពៃ(ឋានសួគ៌)។

5. ហើយពួកដែលព្យាយាមប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់យើងដោយគិតស្មានថាពួកគេអាចយកឈ្នះបាននោះ ពួកទាំងនោះសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងអាក្រក់ និងខ្លោចផ្សាបំផុត។

6. ហើយបណ្តាអ្នកដែលគេផ្តល់ចំណេះដឹងឲ្យបានដឹងថា៖ ពិតប្រាកដណាស់ អ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះទៅឱ្យអ្នកពីព្រះជាម្ចាស់របស់អ្នកវាគឺជាការពិត ហើយវាចង្អុលបង្ហាញទៅកាន់មាគ៌ារបស់អ្នកដែលមហាខ្លាំងពូកែ ជាអ្នកដែលត្រូវគេកោតសរសើរបំផុត។

7. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ តើពួកអ្នកចង់ឱ្យយើងប្រាប់ពួកអ្នកដែរឬទេអំពីបុរសម្នាក់ដែលបានប្រាប់ពួកអ្នកថា នៅពេលពួកអ្នកបាន(ស្លាប់)រលួយខ្ទេចខ្ទីទៅហើយនោះ ពួកអ្នកពិតជានឹងត្រូវបានគេបង្កើតឱ្យរស់សាជាថ្មីនោះ?

8. តើគេម្នាក់នេះប្រឌិតពាក្យកុហកទៅលើអល់ឡោះ ឬក៏គេជាមនុស្សវិកលចរិត? ផ្ទុយទៅវិញ ពួកដែលគ្មានជំនឿចំពោះថ្ងៃបរលោកនឹងស្ថិតនៅក្នុងទណ្ឌកម្ម និងភាពវង្វេងដ៏សែនឆ្ងាយ។

9. តើពួកទាំងនោះមិនបានឃើញទេឬនូវមេឃជាច្រើនជាន់ និងផែនដីដែលនៅពីមុខពួកគេ និងនៅពីក្រោយពួកគេនោះ? ប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងឱ្យដីស្រូបយកពួកគេ ឬយើងឱ្យមួយចំណែកនៃមេឃធ្លាក់ទៅលើពួកគេជាមិនខាន។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងមួយសម្រាប់រាល់ខ្ញុំបម្រើ(របស់អល់ឡោះ)ដែលតែងវិលត្រឡប់(សារភាពកំហុស)។

10. ហើយពិតប្រាកដណាស់ យើងបានផ្តល់ឱ្យព្យាការីហ្វាវូទនូវការប្រោសប្រទានអំពីយើង។ (យើងបានមានបន្ទូលថា៖) ឱភ្នំ និងបក្សាបក្សីទាំងឡាយ! ចូរពួកឯងទាំងអស់គ្នាលើកតម្កើងមកចំពោះយើងជាមួយព្យាការីហ្វាវូទចុះ។ ហើយយើងបានឱ្យដែកក្លាយទៅជាទន់សម្រាប់រូបគេ(ព្យាការីហ្វាវូទ)។

11. ចូរអ្នក(ឱព្យាការីហ្គាវ៉ូទ)ធ្វើអាវក្រោះឲ្យមានភាពទូលាយ និងកំណត់ទំហំរបស់វាឱ្យបានសមរម្យ ហើយចូរពួកអ្នកសាងទង្វើកុសល។ ពិតប្រាកដណាស់ យើងឃើញបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

12. ហើយយើងបានសម្រួលដល់ព្យាការីសូឡៃម៉ាន(ក្នុងការបញ្ជា)ខ្យល់ដោយវាធ្វើដំណើរមួយព្រឹកស្មើនឹងរយៈពេលធ្វើដំណើរ(ធម្មតា)មួយខែ ហើយវាធ្វើដំណើរមួយល្ងាចស្មើនឹងរយៈពេលធ្វើដំណើរមួយខែ។ ហើយយើងបានធ្វើឱ្យស្ពាន់ក្លាយទៅជាទន់សម្រាប់គេ។ ហើយក្នុងចំណោមពួកជិន គឺមានអ្នកធ្វើការឱ្យគេ(ព្យាការីសូឡៃម៉ាន)ទៅតាមបទបញ្ជានៃព្រះជាម្ចាស់របស់គេ។ ហើយអ្នកណាក្នុងចំណោមពួកវាដែលងាកចេញ(មិនធ្វើ)តាមបទបញ្ជារបស់យើងទេនោះ យើងនឹងឱ្យវាភ្លក់នូវទណ្ឌកម្មនៃភ្លើងនរកដែលឆាបឆេះ។

13. ពួកវាធ្វើការឱ្យគាត់តាមអ្វីដែលគាត់ចង់បាន ដូចជាសង់វិហារ រូបចម្លាក់ ចានធំដូចជាស្រះទឹក និងឆ្នាំងធំដែលនៅនឹងមួយកន្លែង។ (យើងបានមានបន្ទូលថា៖) ចូរពួកអ្នក ឱក្រុមគ្រួសារហ្គាវ៉ូទ សម្តែងនូវការដឹងគុណ(ចំពោះយើង)។ តែខ្ញុំបម្រើរបស់យើងដែលដឹងគុណ គឺតិចតួចបំផុត។

14. ហើយនៅពេលដែលយើងបានកំណត់ឱ្យគាត់(ព្យាការីសូឡៃម៉ាន)ស្លាប់ គឺគ្មានអ្វីដែលបង្ហាញឱ្យពួក(ជិន)ទាំងនោះដឹងថាគាត់បានស្លាប់នោះឡើយ រហូតទាល់តែសត្វកណ្តៀរបានស៊ីឈើច្រត់របស់គាត់។ នៅពេលដែលគាត់ដួល ពួកជិនទាំងនោះក៏បានដឹងថា៖ ប្រសិនបើពួកវាដឹងពីប្រការអោចំកំបាំងមែននោះ ពួកវាក៏មិនស្ថិតនៅក្នុងទណ្ឌកម្មដ៏អាម៉ាស់នោះដែរ។

15. ពិតប្រាកដណាស់ សម្រាប់កុលសម្ព័ន្ធសាហ្គាក់ ចំពោះលំនៅឋានរបស់ពួកគេ គឺជាសញ្ញាកស្តតាងមួយ គឺចម្ការពីរ ដោយមួយនៅខាងស្តាំ ហើយមួយទៀតនៅខាងឆ្វេង(នៃភូមិស្រុករបស់ពួកគេ)។ (យើងបានមានបន្ទូលថា៖) ចូរពួកអ្នកទទួលទានចុះអំពីលាភសក្ការៈនៃព្រះជាម្ចាស់របស់ពួកអ្នក ហើយចូរពួកអ្នកដឹងគុណចំពោះវា។ (វា)ជាទឹកដីដ៏ល្អប្រសើរ ហើយ(ទ្រង់)ជាម្ចាស់ដ៏មហាអភ័យទោសបំផុត។

16. ក៏ប៉ុន្តែពួកគេបានងាកចេញ។ ដូចនេះ យើងក៏បានបញ្ជូនទឹកជំនន់ដែលហូរបក់បោកយ៉ាងខ្លាំងទៅលើពួកគេ។ ហើយយើងបានផ្លាស់ប្តូរចម្ការទាំងពីររបស់ពួកគេនូវចម្ការពីរផ្សេងពីនោះដែលផ្លែរបស់វាមានរសជាតិល្វីង និងដើមឈើដែលមិនផ្តល់ផ្លែផ្កា ហើយនិងមានតែដើមពុទ្រាតិចតួចប៉ុណ្ណោះ។

17. នោះគឺជាការតបស្នងដល់ពួកគេចំពោះអ្វីដែលពួកគេរមិលគុណ។ ហើយយើងមិនបានតបស្នង(បែបនេះ)ក្រៅតែចំពោះពួកដែលរមិលគុណប៉ុណ្ណោះ។

18. ហើយយើងបានធ្វើឱ្យរវាងពួកគេ(ក្រុមសាហ្គាក់)និងរវាងភូមិស្រុកដែលយើងបានប្រទានពរជ័យនៅក្នុងវា(ទឹកដីស្តាម)នោះក្លាយជាភូមិដ្ឋានដែលស្ថិតនៅជាប់គ្នា។ ហើយយើងបានកំណត់ឱ្យការធ្វើដំណើរ(រវាងភូមិស្រុកទាំងពីរ)មានភាពងាយស្រួល។ (យើងបានមានបន្ទូលថា៖) ចូរពួកអ្នកធ្វើដំណើរនៅក្នុងទឹកដីនោះ មិនថាពេលយប់ឬពេលថ្ងៃ ប្រកបដោយសុវត្ថិភាពចុះ។

19. ក៏ប៉ុន្តែពួកគេបែរជានិយាយថា៖ "បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាធ្វើឱ្យការធ្វើដំណើររវាងពួកយើងមានរយៈចម្ងាយឆ្ងាយវិញចុះ"។ ហើយពួកគេបានបំពានលើខ្លួនឯង។ ដូច្នេះ យើងក៏បានធ្វើឱ្យ(រឿង)ពួកគេក្លាយជារឿងរ៉ាវដែលអ្នកជំនាន់ក្រោយ(លើកមកនិយាយ)ហើយយើងបានបំបែកពួកគេឱ្យបែកបាក់ខ្ចាត់ខ្ចាយ។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះគឺជាមេរៀនមួយសម្រាប់រាល់អ្នកដែលអត់ធ្មត់ និងដឹងគុណ។

20. ហើយប្រាកដណាស់ អ៊ីព្លីសបានសម្រេចនូវអ្វីដែលវាគិតស្មាន។ ដូច្នេះ ពួកគេក៏បានដើរតាមវា លើកលែងតែមួយក្រុមក្នុងចំណោមបណ្តាអ្នកដែលមានជំនឿប៉ុណ្ណោះ។

21. ហើយវាគ្មានអំណាចអ្វីទៅលើពួកគេនោះឡើយ។ ក៏ប៉ុន្តែដើម្បីឲ្យយើងដឹងថា តើជនណាដែលមានជំនឿចំពោះថ្ងៃបរលោក ក្នុងចំណោមអ្នកដែលមានការមន្ទិលសង្ស័យចំពោះវា។ ហើយព្រះជាម្ចាស់របស់អ្នកជាអ្នកថែរក្សាលើអ្វីៗទាំងអស់។

22. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកហៅពួកដែលពួកអ្នកអះអាង(ថាជាព្រះ)ក្រៅពីអល់ឡោះមក។ ពួកវាគ្មានកម្មសិទ្ធិគ្រប់គ្រងអ្វីបន្តិចឡើយ សូម្បីតែវត្ថុដែលតូចប៉ុនគ្រាប់ស្ពៃក៏ដោយ មិនថានៅលើមេឃ នៅលើផែនដីនោះឡើយ ហើយពួកវាក៏គ្មានហ៊ុនចំណែកអ្វី(ជាមួយអល់ឡោះ)នៅក្នុងវាទាំងពីរនោះដែរ។ ហើយសម្រាប់ទ្រង់ក៏ពុំមានអ្នកដែលជួយ(ដល់ទ្រង់)ក្នុងចំណោមពួកទាំងនោះដែរ។

23. ហើយការជួយអន្តរាគមន៍នោះ គឺគ្មានប្រយោជន៍អ្វីនៅចំពោះទ្រង់នោះឡើយ លើកលែងតែចំពោះជនណាដែលទ្រង់អនុញ្ញាតដល់គេប៉ុណ្ណោះ។ លុះដល់ពេលដែលភាពភ័យខ្លាចបានបាត់ចេញពីដួងចិត្តរបស់ពួកគេ(ម៉ាឡាអ៊ីកាត់)ពួកគេក៏សួរថា៖ តើព្រះជាម្ចាស់របស់ពួកអ្នកមានបន្ទូលម្តេចខ្លះ? ពួកគេបានឆ្លើយថា៖ (ទ្រង់បានមានបន្ទូល)ពិត។ ហើយទ្រង់មហាខ្ពង់ខ្ពស់ មហាឧត្តុង្គឧត្តម។

24. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើនរណាជាអ្នកដែលប្រទានលាភសក្ការៈដល់ពួកអ្នកពីលើមេឃជាច្រើនជាន់ និងផែនដី? ចូរអ្នកពោលថា៖ គឺអល់ឡោះជាម្ចាស់។ ហើយពិតប្រាកដណាស់ ពួកយើង ឬពួកអ្នកដែលនឹងស្ថិតនៅលើការចង្អុលបង្ហាញ ឬស្ថិតនៅលើភាពវង្វេងយ៉ាងច្បាស់លាស់នោះ។

25. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពួកអ្នកនឹងមិនត្រូវគេសួរពីបាបកម្មដែលពួកយើងបានប្រព្រឹត្តនោះឡើយ ហើយពួកយើងក៏មិនត្រូវគេសួរពីអ្វីដែលពួកអ្នកបានប្រព្រឹត្តនោះដែរ។

26. ចូរអ្នកពោលថា៖ ព្រះជាម្ចាស់របស់ពួកយើង ទ្រង់នឹងប្រមូលផ្តុំរវាងពួកយើង(ទាំងអស់គ្នា)។ ក្រោយមក ទ្រង់នឹងកាត់សេចក្តីរវាងពួកយើងប្រកបដោយភាពយុត្តិធម៌បំផុត។ ហើយទ្រង់គឺជាអ្នកវិនិច្ឆ័យដ៏មហាដឹងបំផុត។

27. ចូរអ្នកពោលថា៖ ចូរពួកអ្នកបង្ហាញខ្ញុំមកនូវពួកទាំងឡាយដែលពួកអ្នកយកវាមកធ្វើជាដៃគូ(គោរពសក្ការៈ)រួមនឹងអល់ឡោះជាម្ចាស់នោះ។ មិនដូច្នោះឡើយ។ ផ្ទុយទៅវិញ អល់ឡោះទ្រង់គឺជាព្រះជាម្ចាស់ដែលមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

28. ហើយយើងមិនបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នោះឡើយ លើកលែងតែទៅកាន់មនុស្សលោកទូទៅដើម្បីផ្តល់ដំណឹងរីករាយ និងដាស់តឿនព្រមាន។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនបានដឹងនោះឡើយ។

29. ហើយពួកគេនិយាយថា៖ តើការសន្យានេះនឹងមកដល់នៅពេលណា ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ?

30. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ ការសន្យាសម្រាប់ពួកអ្នកនោះ គឺនៅថ្ងៃមួយដែលពួកអ្នកមិនអាចសុំពន្យារពេលហើយក៏មិនអាចសុំឱ្យវាមកដល់មុននោះដែរ សូម្បីមួយវិនាទីក៏ដោយ។

31. ហើយពួកដែលគ្មានជំនឿបាននិយាយថា៖ ពួកយើងមិនជឿនឹងគម្ពីរគួរអាននេះជាដាច់ខាត ហើយក៏មិនជឿនឹងគម្ពីរដែលត្រូវបានបញ្ចុះពីមុនមកនោះដែរ។ ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញ ខណៈដែលពួកបំពានទាំងនោះត្រូវបានគេឱ្យឈរនៅចំពោះមុខព្រះជាម្ចាស់របស់ពួកគេ ពួកគេនឹងស្តីបន្ទោសគ្នាទៅវិញទៅមក ដោយពួកដែលទន់ខ្សោយនឹងនិយាយទៅកាន់មេដឹកនាំ(របស់ពួកគេ)ថា៖ ប្រសិនបើគ្មានពួកអ្នក(នាំពួកយើងឱ្យវង្វេង)ទេនោះ ប្រាកដជាពួកយើងនឹងក្លាយជាអ្នកដែលមានជំនឿជាមិនខាន។

32. ពួកមេដឹកនាំបាននិយាយទៅកាន់ពួកទន់ខ្សោយវិញថា៖ តើពួកយើងបានរារាំងពួកអ្នកពីការចង្អុលបង្ហាញបន្ទាប់ពីវាបានមកដល់ពួកអ្នកឬ? ផ្ទុយទៅវិញ ពួកអ្នកគឺជាពួកឧក្រិដ្ឋជន។

33. ហើយពួកទន់ខ្សោយក៏បានតបទៅកាន់ពួកមេដឹកនាំវិញថា៖ ផ្ទុយទៅវិញ ពួកអ្នកបានប្រើឧបាយកលទាំងយប់ទាំងថ្ងៃ ខណៈដែលពួកអ្នកប្រើពួកយើងឱ្យប្រឆាំងនឹងអល់ឡោះ និងឱ្យពួកយើងបង្កើតដៃគូសម្រាប់ទ្រង់។ ហើយពួកគេបានលាក់បាំងនូវវិប្បដិសារីនៅពេលដែលពួកគេបានឃើញទណ្ឌកម្មផ្ទាល់នឹងភ្នែក។ ហើយយើងបានដាក់ច្រវាក់នៅនឹងករបស់ពួកប្រឆាំង។ តើពួកគេត្រូវបានគេតបស្នងក្រៅតែពីអ្វីដែលពួកគេបានប្រព្រឹត្តឬទេ?

34. ហើយយើងមិនបានបញ្ជូនអ្នកដាស់តឿនព្រមានទៅកាន់ភូមិស្រុកមួយឡើយ លើកលែងតែពួកដែលមានឋានៈសក្តិនៃស្រុកភូមិនោះនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងជាអ្នកដែលប្រឆាំងចំពោះអ្វីដែលពួកអ្នកត្រូវបានគេបញ្ជូនមក។

35. ហើយពួកគេបាននិយាយទៀតថា៖ ពួកយើងជាអ្នកដែលមានទ្រព្យសម្បត្តិ និងកូនចៅច្រើនជាងគេ។ ហើយពួកយើងក៏នឹងមិនត្រូវគេដាក់ទណ្ឌកម្មនោះដែរ។

36. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់បើកទូលាយ និងត្បិតត្បៀតលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនា។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនបានដឹងឡើយ។

37. ហើយទ្រព្យសម្បត្តិ និងកូនចៅរបស់ពួកអ្នកមិនអាចនាំពួកអ្នកឲ្យខិតមកជិតការពេញចិត្តពីយើងនោះឡើយ ក៏ប៉ុន្តែមានតែអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលទៅវិញទេ។ អ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបានការតបស្នងទ្វេដងចំពោះអ្វីដែលពួកគេបានសាង ហើយពួកគេជាអ្នកដែលមានសុវត្ថិភាពស្ថិតនៅឯកន្លែងដ៏ខ្ពង់ខ្ពស់បំផុត(នៃឋានសួគ៌)។

38. ហើយពួកដែលព្យាយាមប្រឆាំងនឹងបណ្តាវាក្យខណ្ឌរបស់យើង ដោយគិតស្មានថាពួកគេអាចយកឈ្នះបាននោះ ពួកទាំងនោះ ហើយ គឺជាពួកដែលត្រូវបានគេនាំទៅកាន់ទណ្ឌកម្ម។

39. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់បើកទូលាយ និងត្បិតត្បៀតលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់។ ហើយអ្វីមួយដែលពួកអ្នកបានបរិច្ចាគនោះ ពិតប្រាកដណាស់ ទ្រង់នឹងជំនួសវាឱ្យពួកអ្នកវិញ។ ហើយទ្រង់ជាអ្នកប្រទានលាភសក្ការៈដ៏ប្រសើរបំផុត។

40. ហើយ(ចូរអ្នករំលឹក)នៅថ្ងៃដែលអល់ឡោះទ្រង់ប្រមូលផ្តុំពួកគេទាំងអស់គ្នា។ បន្ទាប់មក ទ្រង់បានមានបន្ទូលទៅកាន់ពួកម៉ាឡាអ៊ីកាត់ថា៖ តើពួកទាំងនោះឬដែលពួកគេធ្លាប់គោរពសក្ការៈមកចំពោះពួកអ្នកនោះ?

41. ពួកគេបានឆ្លើយតបថា៖ ព្រះអង្គមហាស្អាតស្អំ! ព្រះអង្គគឺជាអ្នកគាំពារយើងខ្ញុំ មិនមែនពួកគេឡើយ។ ផ្ទុយទៅវិញ ពួកទាំងនោះបានគោរពសក្ការៈទៅចំពោះជិនដោយភាគច្រើននៃពួកគេ គឺមានជំនឿចំពោះពួកវា។

42. ដូច្នេះនៅថ្ងៃនេះ ពួកអ្នកមិនអាចផ្តល់ផលប្រយោជន៍ ហើយក៏មិនអាចបង្កគ្រោះថ្នាក់អ្វីដល់គ្នាទៅវិញទៅមកនោះឡើយ។ ហើយយើងបានមានបន្ទូលទៅកាន់ពួកដែលបំពានថា៖ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មភ្លើងនរកដែលពួកអ្នកធ្លាប់បានបដិសេធ(មិនជឿ)ចំពោះវា។

43. ហើយនៅពេលដែលមានគេសូត្រវាក្យខណ្ឌទាំងឡាយរបស់យើងដ៏ច្បាស់លាស់ឱ្យពួកគេស្តាប់ ពួកគេនិយាយថា៖ ម្នាក់នេះ(ព្យាការីមូហាំម៉ាត់)គឺគ្មានអ្វីក្រៅតែពីចង់រារាំងពួកអ្នកពីអ្វីដែលជីដូនជីតារបស់ពួកអ្នកធ្លាប់បានគោរពសក្ការៈប៉ុណ្ណោះ។ ហើយពួកគេនិយាយទៀតថា៖ (គម្ពីរគួរអាន)នេះ គ្មានអ្វីក្រៅពីការប្រឌិត កុតកុហកនោះឡើយ។ ហើយពួកដែលប្រឆាំងបាននិយាយចំពោះសេចក្តីពិត(គម្ពីរគួរអាន)នៅពេលដែលវាបានមកដល់ពួកគេថា៖ នេះគ្មានអ្វីក្រៅពីមន្តអាគមយ៉ាងច្បាស់លាស់នោះឡើយ។

44. ហើយយើងមិនបានផ្តល់ឲ្យពួកគេនូវគម្ពីរណាមួយដល់ពួកគេដែលពួកគេសិក្សាវានោះឡើយ ហើយយើងក៏មិនបានបញ្ជូនអ្នកដាស់តឿនព្រមានណាម្នាក់ទៅកាន់ពួកគេមុនអ្នកនោះដែរ។

45. ហើយពួកជំនាន់មុនពួកគេបានបដិសេធ(ចំពោះអ្នកនាំសាររបស់ពួកគេ)។ ហើយពួកគេ(ពួកមុស្លីគីនម៉ាក្កៈ) មិនទាន់បានទទួល សូម្បីតែមួយភាគដប់នៃអ្វីដែលយើងបានប្រទានឲ្យពួកទាំងនោះផង។ ក៏ប៉ុន្តែពួកគេបានបដិសេធនឹងបណ្តាអ្នកនាំសាររបស់យើង។ ដូច្នេះ តើទណ្ឌកម្ម(របស់យើងចំពោះពួកគេ)យ៉ាងដូចម្តេចដែរ?

46. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត ខ្ញុំសូមទូន្មានពួកអ្នកនូវរឿងមួយ។ ចូរពួកអ្នកក្រោកឈរឡើងពីរនាក់ក៏បានម្នាក់ឯងក៏បានដោយស្មោះសចំពោះអល់ឡោះ។បន្ទាប់មកចូរពួកអ្នកគិតពិចារណាចុះ។មិត្តភក្តិរបស់ពួកអ្នក(ព្យាការីមូហាំម៉ាត់)មិនមែនជាមនុស្សវិកលចរិតឡើយ។ រូបគាត់គ្មានអ្វីក្រៅពីជាអ្នកដាស់តឿនព្រមានពួកអ្នកពីទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរប៉ុណ្ណោះ។

47. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំមិនទាមទារពីពួកអ្នកនូវផែលបុណ្យនោះឡើយ។វាគឺសម្រាប់ពួកអ្នកប៉ុណ្ណោះ។ចំណែកឯផលបុណ្យរបស់ខ្ញុំ គឺស្ថិតនៅលើអល់ឡោះជាម្ចាស់។ ហើយទ្រង់ជាសាក្សីលើរាល់អ្វីៗទាំងអស់។

48. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ខ្ញុំទ្រង់បំបាត់(ប្រការខុសឆ្គង)ដោយការពិត។ ហើយទ្រង់ជាអ្នកដឹងបំផុតនូវប្រការអាថ៌កំបាំងទាំងឡាយ។

49. ចូរអ្នកពោលថា៖ ការពិតបានមកដល់ ហើយប្រការមិនពិតបានបាត់បង់ ហើយវាក៏មិនត្រឡប់មកវិញនោះដែរ។

50. ចូរអ្នកពោលថា៖ ប្រសិនបើខ្ញុំវង្វេង តាមពិត ការវង្វេងនោះ គឺធ្លាក់មកលើខ្ញុំខ្លួនឯង។ តែប្រសិនបើខ្ញុំទទួលបានការចង្អុលបង្ហាញវិញនោះ គឺដោយសារតែអ្វីដែលព្រះជាម្ចាស់របស់ខ្ញុំបានផ្តល់វាហ៊ីមកកាន់ខ្ញុំ។ ពិតប្រាកដណាស់ ទ្រង់មហាឮនិងនៅជិតបំផុត។

51. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញ នៅពេលដែលពួកគេមានការភ័យខ្លាច។ ពេលនោះ ពួកគេគ្មានកន្លែងរត់គេចនោះឡើយ។ ហើយពួកគេត្រូវបានគេនាំខ្លួនមកពីកន្លែងដ៏ជិតបំផុត។

52. ហើយពួកគេនិយាយថា៖ ពួកយើងមានជំនឿនឹងវាហើយ។ តើពួកគេមានជំនឿយ៉ាងដូចម្តេច ខណៈដែលកន្លែងដែលគេទទួលយកជំនឿបានឃ្លាតឆ្ងាយពីពួកគេហើយនោះ?

53. ហើយជាការពិតណាស់ ពួកគេបានប្រឆាំងនឹងវាកាលពីមុន ហើយពួកគេបានចោទប្រកាន់ដោយការប៉ាន់ស្មានខុសយ៉ាងសែនឆ្ងាយ។

54. ហើយគេបានរារាំងរវាងពួកគេ និងរវាងអ្វីដែលពួកគេប្រាថ្នាចង់បាន ដូចដែលគេបានធ្វើចំពោះពួកដែល(មានលក្ខណៈ)ដូចពួកគេនោះដែរ។ ពិតប្រាកដណាស់ ពួកគេធ្លាប់មានភាពមន្ទិលសង្ស័យបំផុត។

ជំពូក ហ្សាវ៉ែរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលជាអ្នកបង្កើតមេឃជាច្រើនជាន់និងផែនដី។ ទ្រង់ជាអ្នកដែលឲ្យម៉ាឡាអ៊ីកាត់ធ្វើជាអ្នកនាំសារ (ដោយពួកគេ) មានស្លាបពីរ ស្លាបបី និងស្លាបបួន។ ទ្រង់បន្ថែមក្នុងការបង្កើតនូវអ្វីដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

2. អ្វីដែលទ្រង់បានប្រទានឱ្យមនុស្សលោកនៃក្តីមេត្តាករុណា (របស់ទ្រង់) គឺគ្មាននរណាម្នាក់អាចរារាំងវាបានឡើយ។ ហើយអ្វីដែលទ្រង់រារាំងនោះ ក៏គ្មាននរណាម្នាក់អាចផ្តល់វាដល់គេបន្ទាប់ពីទ្រង់បាននោះដែរ។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

3. ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នករំឭកនូវឧបការគុណរបស់អល់ឡោះមកលើពួកអ្នក។ តើមានអ្នកបង្កើតណាផ្សេងក្រៅពីអល់ឡោះជាម្ចាស់ដែលផ្តល់លាភសក្ការៈដល់ពួកអ្នកពីលើមេឃនិងផែនដីដែរឬទេ? គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកត្រូវបានគេបង្វែរ (ចេញពីការពិត) យ៉ាងដូចម្តេច?

4. ហើយប្រសិនបើពួកគេបដិសេធនឹងអ្នក (ព្យាការីមូហាំម៉ាត់) នោះ ពិតណាស់ បណ្តាអ្នកនាំសារជាច្រើនមុនអ្នកក៏ត្រូវបានគេបដិសេធដែរ។ ហើយកិច្ចការទាំងឡាយនឹងត្រូវគេនាំត្រឡប់ទៅកាន់អល់ឡោះ (តែមួយគត់)។

5. ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ ដូច្នេះ ចូរកុំឱ្យឆាកជីវិតលោកិយបោកបញ្ឆោតពួកអ្នក និងចូរកុំឱ្យមេបោកបញ្ឆោតទាំងឡាយ (ស្មៃតន) បោកបញ្ឆោតពួកអ្នកពីអល់ឡោះឱ្យសោះ។

6. ពិតប្រាកដណាស់ ស្មៃតនគឺជាសត្រូវរបស់ពួកអ្នក (ឱមនុស្សលោក)។ ដូច្នេះ ចូរពួកអ្នកចាត់ទុកវាជាសត្រូវចុះ។ តាមពិតវាអំពាវនាវអ្នកដែលដើរតាមវាដើម្បីឱ្យពួកគេស្ថិតក្នុងចំណោមពួកឋាននរកដែលឆេះឆាប។

7. ពួកដែលគ្មានជំនឿ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។ រីឯបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលវិញ សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងផលបុណ្យដ៏ធំធេង (ឋានសួគ៌)។

8. ដូច្នេះ តើជនដែលត្រូវបានគេតុបតែងលម្អទង្វើអាក្រក់របស់គេឲ្យគេមើលឃើញថាវាជាប្រការល្អ (ដូចគ្នានឹងអ្នកដែលអល់ឡោះចង្អុលបង្ហាញឬ)? ពិតប្រាកដណាស់ អល់ឡោះទ្រង់ធ្វើឱ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនា និងចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ដូច្នេះ សូមអ្នក (ឱអ្នកនាំសារមូហាំម៉ាត់) កុំធ្វើឱ្យខ្លួនឯងអន្តរាយដោយទុក្ខព្រួយព្រោះតែ (ការប្រឆាំងរបស់) ពួកគេឱ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ដឹងបំផុតចំពោះអ្វីដែលពួកគេប្រព្រឹត្ត។

9. ហើយអល់ឡោះជាអ្នកដែលបញ្ជូនខ្យល់ ហើយវាក៏បានធ្វើឱ្យពពករសាត់។ ពេលនោះ យើងបានស្រោចស្រពទឹកភ្លៀងនោះទៅកាន់ទឹកដីដែលរាំងស្ងួត។ ហើយតាមរយៈទឹកភ្លៀងនោះ យើងក៏បានឱ្យដីនោះមានជីជាតិឡើងវិញក្រោយពីវាបានស្ងួតហួតហែង។ ការបង្កើតឱ្យរស់ឡើងវិញ (នៅថ្ងៃបរលោក) ក៏ដូច្នោះដែរ។

10. ជនណាហើយដែលចង់បានភាពខ្លាំងក្លា ពិតប្រាកដណាស់ ភាពខ្លាំងក្លាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់ (តែមួយគត់)។ ហើយពាក្យពេចន៍ដែលល្អ(ការរំឭកចំពោះអល់ឡោះ) គឺឡើងទៅកាន់ទ្រង់ ហើយទង្វើកុសល ត្រូវគេលើកឡើងទៅកាន់ទ្រង់។ ហើយពួកដែលរៀបឧបាយកលអាក្រក់ សម្រាប់ពួកគេនឹងត្រូវទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។ ហើយឧបាយកលរបស់ពួកទាំងនោះនឹងត្រូវទទួលអន្តរាយ។

11. ហើយអល់ឡោះជាម្ចាស់ទ្រង់បានបង្កើតពួកអ្នកអំពីដី បន្ទាប់មកពីទឹកកាម។ បន្ទាប់មកទៀត ទ្រង់បានបង្កើតពួកអ្នកឱ្យមានជាគូៗ។ គ្មានស្ត្រីណាម្នាក់ដែលពពោះ ហើយក៏គ្មានស្ត្រីណាម្នាក់ដែលប្រសូត្របុត្រនោះដែរ លើកលែងតែទ្រង់ដឹងទាំងអស់។ ហើយគ្មានការបន្ថែម ឬកាត់បន្ថយអាយុនរណាម្នាក់នោះឡើយ លើកលែងតែត្រូវបានកត់ត្រាទុកក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)ទាំងអស់។ ពិតប្រាកដណាស់ នោះគឺជារឿងងាយស្រួលបំផុតសម្រាប់អល់ឡោះជាម្ចាស់។

12. ហើយសមុទ្រពីរមិនអាចស្មើគ្នាឡើយ គឺមួយមានរសជាតិសាប ងាយស្រួលទទួលទាន ហើយមួយទៀតមានរសជាតិប្រៃល្វីង។ ហើយរាល់សមុទ្រទាំងពីរនេះ ពួកអ្នកអាចបរិភោគនូវសាច់ស្រស់(ត្រី) ហើយពួកអ្នកក៏អាចយកចេញ(ពីសមុទ្រនោះ)នូវគ្រឿងអលង្ការដែលពួកអ្នកពាក់វាផងដែរ។ ហើយអ្នកឃើញសំពៅទាំងឡាយពុះជ្រែកផ្ទៃសមុទ្រដើម្បីស្វែងរកការប្រោសប្រទានរបស់ទ្រង់។ ហើយសង្ឃឹមថា ពួកអ្នកនឹងដឹងគុណ(អល់ឡោះ)។

13. ទ្រង់បញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ និងបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយទ្រង់បានកំណត់គន្លងគោចររបស់ព្រះអាទិត្យនិងព្រះចន្ទ ដោយវាទាំងពីរធ្វើដំណើរហូតដល់ពេលវេលាដែលត្រូវបានកំណត់។ នោះគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក។ អំណាចគ្រប់គ្រងទាំងឡាយ គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ រីឯពួកដែលពួកអ្នកគោរពសក្ការៈក្រៅពីទ្រង់នោះ ពួកវាគ្មានសមត្ថភាពអ្វីនោះឡើយ សូម្បីតែប៉ុនស្រទាប់គ្រាប់ល្មើក៏ដោយ។

14. ទោះបីជាពួកអ្នកបួងសួងសុំពីពួកវាក៏ដោយ ក៏ពួកវាមិនឮការបួងសួងរបស់ពួកអ្នកដែរ។ ហើយបើទោះបីជាពួកវាឮ ក៏ពួកវាមិនអាចឆ្លើយតបនឹងពួកអ្នកបានដែរ។ ហើយនៅថ្ងៃបរលោក ពួកវានឹងបដិសេធចំពោះការធ្វើស៊ីរិករបស់ពួកអ្នក។ ហើយគ្មាននរណាម្នាក់អាចប្រាប់ដំណឹងពិតឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាងអ្នកដែលមហាដឹងបំផុត(អល់ឡោះ)ឡើយ។

15. ឱមនុស្សលោកទាំងឡាយ! ពួកអ្នកគឺជាអ្នកដែលត្រូវការបំផុតទៅកាន់អល់ឡោះជាម្ចាស់។ ចំណែកឯអល់ឡោះជាម្ចាស់វិញ ទ្រង់មហាមានលើសលប់ ជាអ្នកដែលត្រូវគេកោតសរសើរបំផុត។

16. ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងបំផ្លាញពួកអ្នក ហើយនាំមកនូវភាវៈថ្មី(មកជំនួសពួកអ្នក)ជាមិនខាន។

17. ហើយនោះពុំមែនជារឿងដែលលំបាកសម្រាប់អល់ឡោះជាម្ចាស់ឡើយ។

18. ហើយគ្មានបុគ្គលណាម្នាក់រ៉ាប់រងនូវបាបកម្មរបស់អ្នកដទៃឡើយ។ ហើយប្រសិនបើបុគ្គលដែលមានអំពើបាបធ្ងន់ធ្ងរសុំឱ្យអ្នកដទៃរែកពុនបាបកម្មនោះ(ជំនួសខ្លួន) ក៏គ្មានគេរែកពុនអ្វីមួយអំពីវាបន្តិចនោះដែរ ទោះបីជាម្នាក់នោះ ជាសាច់ញាតិរបស់គេក៏ដោយ។ តាមពិត អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)គ្រាន់តែជាស់តឿនព្រមានចំពោះអ្នកដែលខ្លាចព្រះជាម្ចាស់របស់ពួកគេដោយអាថ៌កំបាំង ហើយពួកគេប្រតិបត្តិសឡាតប៉ុណ្ណោះ។ ហើយជនណាដែលសម្អាតខ្លួន(ពីអំពើល្មើស) តាមពិតគឺគេសម្អាតសម្រាប់ខ្លួនឯងប៉ុណ្ណោះ។ ហើយកន្លែងវិលត្រឡប់(នៅថ្ងៃបរលោក) គឺឆ្ពោះទៅកាន់អល់ឡោះ(តែមួយគត់)។

19. ហើយមិនស្មើគ្នានោះទេរវាងមនុស្សខ្វាក់ និងអ្នកដែលមើលឃើញ

20. ហើយភាពងងឹត និងពន្លឺ

21. ហើយនិងម្លប់ និងកន្លែងក្តៅ(គ្មានម្លប់)នោះ។

22. ហើយក៏មិនស្មើគ្នានោះដែរវាងមនុស្សរស់ និងមនុស្សស្លាប់នោះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ធ្វើឱ្យស្តាប់ឮ(ការចង្អុលបង្ហាញ)ចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពុំមែនជាអ្នកដែលអាចធ្វើឱ្យអ្នកដែលនៅក្នុងផ្នូរស្តាប់ឮនោះឡើយ។

23. អ្នកគ្រាន់តែជាអ្នកដាស់តឿនព្រមានម្នាក់ប៉ុណ្ណោះ។

24. ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាមួយនឹងការពិតដើម្បីឱ្យអ្នកធ្វើជាអ្នកផ្តល់ដំណឹងរីករាយ និងដាស់តឿនព្រមាន។ ហើយរាល់ប្រជាជាតិទាំងអស់ គឺតែងតែមានអ្នកដាស់តឿនព្រមាន(ទៅកាន់ពួកគេ)។

25. ហើយប្រសិនបើពួកគេបដិសេធនឹងអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ជាការពិតណាស់ អ្នកជំនាន់មុនពួកគេក៏បានបដិសេធ(នឹងអ្នកនាំសារពួកគេ)ដូចគ្នាដែរ។ បណ្តាអ្នកនាំសាររបស់ពួកគេបាននាំមកឱ្យពួកគេនូវសញ្ញាកស្តែងយ៉ាងច្បាស់លាស់ ព្រមទាំងគម្ពីរ(នៃក្បួនច្បាប់) និងគម្ពីរដែលបំភ្លឺ។

26. ដូចនេះ យើងក៏បានបំផ្លាញពួកដែលប្រឆាំង។ ដូច្នេះ តើទណ្ឌកម្ម(របស់យើងទៅលើពួកគេ)យ៉ាងដូចម្តេច?

27. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះទឹកភ្លៀងពីលើមេឃ ហើយតាមរយៈទឹកភ្លៀងនោះ យើងបានបញ្ចេញនូវផលានុផលយ៉ាងច្រើនដែលមានពណ៌ខុសៗគ្នា។ ហើយភ្នំមួយចំនួន គឺមានឆ្នូតដែលមានពណ៌ខុសៗគ្នា គឺពណ៌ស ក្រហម និងឆ្នូតពណ៌ខ្មៅងងឹត។

28. ហើយក្នុងចំណោមមនុស្សលោក សត្វល្មូន និងសត្វពាហនៈក៏មានពណ៌ខុសៗគ្នាដូច្នោះដែរ។ តាមពិត មានតែអ្នកដែលមានចំណេះដឹងទេដែលខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាអភ័យទោសបំផុត។

29. ពិតប្រាកដណាស់ បណ្តាអ្នកដែលសូត្រគម្ពីររបស់អល់ឡោះ និងបានប្រតិបត្តិសឡាត ហើយនិងបរិច្ចាគមួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេទាំងលាក់បាំង ទាំងបើកចំហដោយពួកគេរំពឹងនូវជំនួញមួយដែលគ្មានការខាតបង់។

30. ដើម្បីទ្រង់នឹងបំពេញឱ្យពួកគេនូវផលបុណ្យរបស់ពួកគេយ៉ាងពេញលេញ ព្រមទាំងបន្ថែមដល់ពួកគេនូវការប្រោសប្រទានអំពីទ្រង់។ ពិតប្រាកដណាស់ ទ្រង់មហាអភ័យទោស មហាដឹងគុណបំផុត។

31. ហើយគម្ពីរ(គួរអាន)ដែលយើងបានផ្តល់វាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)វាគឺជាការពិតដើម្បីបញ្ជាក់ទៅលើបណ្តាគម្ពីរទាំងឡាយពីមុនមក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាឃើញបំផុតចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

32. ក្រោយមក យើងបានប្រទានគម្ពីរ(គួរអាន)ដល់អ្នកដែលយើងបានជ្រើសរើសក្នុងចំណោមខ្ញុំបម្រើរបស់យើង(ប្រជាជាតិរបស់ព្យាការីមូហាំម៉ាត់)។ ក្នុងចំណោមពួកគេ មានអ្នកបំពានលើខ្លួនឯង។ ហើយក្នុងចំណោមពួកគេ គឺមានអ្នកដែលបំពេញត្រឹមតែកាតព្វកិច្ច ហើយក្នុងចំណោមពួកគេទៀត គឺមានអ្នកដែលរួសរាន់ក្នុងការសោងអំពើល្អដោយការអនុញ្ញាតពីអល់ឡោះ។ នោះគឺជាការប្រោសប្រទានដ៏ធំធេង។

33. គឺឋានសួគ៌អាត់និនដែលពួកគេនឹងចូលទៅក្នុងវាដោយពួកគេត្រូវបានគេតុបតែងនៅក្នុងនោះដោយខ្សែដៃធ្វើអំពីមាស និងគុជខ្សែង។ ហើយសម្លៀកបំពាក់របស់ពួកគេនៅក្នុងនោះ គឺក្រណាត់សូត្រ។

34. ហើយពួកគេបានពោលថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលទ្រង់បានបំបាត់នូវទុក្ខព្រួយចេញពីពួកយើង។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកយើង គឺពិតជាមហាអភ័យទោស មហាដឹងគុណបំផុត។

35. ទ្រង់គឺជាអ្នកដែលបានប្រទានឱ្យពួកយើងនូវលំនៅឋានដែលអមតៈ(ឋានសួគ៌)ដោយការប្រោសប្រទានអំពីទ្រង់។ នៅក្នុង(ឋានសួគ៌)នោះ ពួកយើងមិនទទួលនូវភោពហត់នឿយ និងក៏មិនទទួលនូវការលំបាកអ្វីឡើយ។

36. រីឯពួកដែលគ្មានជំនឿវិញ សម្រាប់ពួកគេគឺនរកដើហាន់ណាំ។ គេមិនកំណត់ឱ្យពួកគេស្លាប់ ហើយក៏មិនបន្ធូរបន្ថយនូវទណ្ឌកម្មដល់ពួកគេនោះដែរ។ ដូច្នោះដែរ យើងនឹងតបស្នងរាល់ជនដែលប្រឆាំងទាំងឡាយ។

37. ហើយពួកគេស្រែកយ៉ាងខ្លាំងនៅក្នុងឋាននរកនោះថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបញ្ចេញយើងខ្ញុំ(ពីឋាននរកវិញ)ផងចុះ ដើម្បីពួកយើងនឹងសាងទង្វើកុសលជំនួសទង្វើ(អាក្រក់)ដែលពួកយើងធ្លាប់បានសាង។ (ទ្រង់បានតបថា៖) តើពុំមែនទេឬដែលយើងបានទុកអាយុជីវិតឱ្យពួកអ្នក(ក្នុងលោកិយ)ដើម្បីធ្វើការពិចារណាចំពោះជនណាដែលចង់ពិចារណា ថែមទាំងអ្នកដាស់តឿនព្រមានក៏បានមកដល់ពួកអ្នកទៀតនោះ? ហេតុនេះ ចូរពួកអ្នកភ្លក់ចុះ(នូវទណ្ឌកម្មភ្លើងនរក)។ ពិតណាស់ សម្រាប់ពួកដែលបំពាន គឺគ្មានអ្នកជួយនោះឡើយ។

38. ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកដឹងបំផុតនូវអាថ៌កំបាំងនៃមេឃជាច្រើនជាន់ និងផែនដី។ ពិតប្រាកដណាស់ ទ្រង់មហាដឹងបំផុតនូវអ្វីដែលនៅក្នុងដួងចិត្ត។

39. ទ្រង់គឺជាអ្នកដែលបានបង្កើតពួកអ្នក(ឱបណ្តាមនុស្សលោក)ជាអ្នកស្នងការគ្រប់គ្រងនៅលើផែនដី។ ដូច្នេះ ជនណាដែលប្រឆាំង ពិតណាស់ ការប្រឆាំងរបស់គេ គឺធ្លាក់ទៅលើខ្លួនគេផ្ទាល់ប៉ុណ្ណោះ។ ហើយការប្រឆាំងរបស់ពួកគេ គឺគ្មានបានបន្ថែមអ្វីដល់ពួកប្រឆាំងនៅចំពោះអល់ឡោះជាម្ចាស់ឡើយ ក្រៅតែពីការខឹងក្រោធប៉ុណ្ណោះ។ ហើយការប្រឆាំងរបស់ពួកគេ ក៏គ្មានបានបន្ថែមអ្វីដល់ពួកប្រឆាំងក្រៅតែពីការខាតបង់នោះដែរ។

40. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំអំពីព្រះនានារបស់ពួកអ្នកដែលពួកអ្នកគោរពសក្ការៈក្រៅពីអល់ឡោះ តើមានអ្វីខ្លះនៃផែនដីដែលពួកវាបានបង្កើតនោះ? ឬមួយក៏ពួកវាបានចូលរួម(ជាមួយអល់ឡោះ)ក្នុងការបង្កើតមេឃជាច្រើនជាន់? ឬមួយក៏យើងបានប្រទានឱ្យពួកគេនូវគម្ពីរមួយដែលពួកគេយកវាជាអំណះអំណាង? ផ្ទុយទៅវិញ ពួកដែលបំពានមិនបានសន្យាអ្វីចំពោះគ្នាទៅវិញទៅមកក្រៅតែពីការបោកប្រាស់នោះឡើយ។

41. ពិតប្រាកដណាស់ អល់ឡោះទ្រង់ទប់មេឃជាច្រើនជាន់ និងផែនដីកុំឱ្យវាទាំងពីរញ័ររញ្ជួយ។ ហើយប្រសិនបើវាទាំងពីរញ័ររញ្ជួយនោះ ក៏គ្មាននរណាម្នាក់អាចទប់វាទាំងពីរក្រៅពីទ្រង់នោះដែរ។ ពិតប្រាកដណាស់ ទ្រង់មហាខន្តី មហាអភ័យទោសបំផុត។

42. ហើយពួកគេ(ពួកមុស្ហរីគីន)បានស្បថយ៉ាងម៉ឺងម៉ាត់នឹងអល់ឡោះថា៖ ប្រសិនបើមានអ្នកដាស់តឿនព្រមានបានមកដល់ពួកគេ ប្រាកដជាពួកគេនឹងទទួលបានការចង្អុលបង្ហាញជាងប្រជាជាតិទាំងឡាយជាមិនខាន។ ប៉ុន្តែនៅពេលដែលអ្នកដាស់តឿនព្រមាន(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកគេ វាមិនបានបន្ថែមអ្វីដល់ពួកគេ ក្រៅតែពីការឃ្លាតកាន់តែឆ្ងាយ(ពីការពិត)នោះឡើយ។

43. (ពួកគេស្បថបែបនោះ)ដោយភាពក្រអឺតក្រទមនៅលើផែនដី និងគម្រោងការអាក្រក់ប៉ុណ្ណោះ។ ហើយគម្រោងដ៏អាក្រក់(របស់ពួកគេ) គឺមិនធ្លាក់លើអ្នកណាក្រៅតែពីពួកដែលរៀបគម្រោងការនោះឡើយ។ ដូច្នេះ តើពួកទាំងនោះមិនរង់ចាំអ្វីក្រៅពីមាគ៌ារបស់ពួកជំនាន់មុននោះឬ? ជាការពិតណាស់ អ្នកនឹងមិនឃើញមាគ៌ារបស់អល់ឡោះមានការផ្លាស់ប្តូរឡើយ ហើយអ្នកក៏មិនឃើញមាគ៌ារបស់អល់ឡោះមានការប្រែប្រួលនោះដែរ។

44. តើពួកគេ(ពួកមុស្ហរីគីន)មិនបានធ្វើដំណើរលើផែនដី ហើយពិចារណាមើលទេឬ ថាតើលទ្ធផលចុងក្រោយនៃប្រជាជាតិជំនាន់មុនពួកគេទៅជាយ៉ាងណា ខណៈដែលពួកទាំងនោះខ្លាំងក្លាជាងពួកគេទៅទៀត? ហើយគ្មានអ្វីមួយដែលនៅលើមេឃជាច្រើនជាន់និងផែនដីអាចធ្វើឲ្យទ្រង់អសមត្ថភាពនោះឡើយ។ ពិតប្រាកដណាស់ ទ្រង់មហាដឹង មានមហាអានុភាពបំផុត។

45. ហើយប្រសិនបើអល់ឡោះយកទោសពៃរ៍មនុស្សលោកចំពោះអ្វីដែលពួកគេបានសាងនោះ ច្បាស់ជាទ្រង់មិនបន្សល់ទុកសត្វលោកណាមួយនៅលើផែនដីនោះឡើយ។ ក៏ប៉ុន្តែទ្រង់ពន្យារឱ្យពួកគេរហូតដល់ពេលកំណត់។ ហើយនៅពេលដែលកាលកំណត់របស់ពួកគេបានមកដល់ហើយនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាឃើញបំផុតចំពោះខ្ញុំបម្រើរបស់ទ្រង់។

ជំពូក យ៉ាស៊ីន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. យ៉ាស៊ីន (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. (អាល់ឡោះ)ស្បថនឹងគម្ពីរគួរអានដែលប្រកបដោយគតិបណ្ឌិត។

3. ពិតប្រាកដណាស់ អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ពិតជាស្ថិតក្នុងចំណោមបណ្តាអ្នកនាំសារទាំងឡាយ

4. ដែលស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ

5. (គម្ពីរគួរអាននេះ)ត្រូវបានគេបញ្ចុះមកពីព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាអាណិតស្រលាញ់

6. ដើម្បីឱ្យអ្នកជាស់តឿនព្រមានចំពោះក្រុមមួយដែលជីដូនជីតារបស់ពួកគេពុំធ្លាប់មានជាស់តឿនព្រមាននោះឡើយ។ ដូច្នេះ ពួកគេគឺជាពួកដែលព្រងើយកន្តើយ។

7. ពិតប្រាកដណាស់ ពាក្យពេចន៍(ទណ្ឌកម្ម)ត្រូវបានកំណត់ទៅលើភាគច្រើននៃពួកគេ។ ពិតប្រាកដណាស់ ពួកគេមិនមានជំនឿឡើយ។

8. ពិតប្រាកដណាស់ យើងបានដាក់ច្រវាក់កពួកគេ(ភ្ជាប់នឹងដៃទាំងពីរ)ដាក់ក្រោមចង្កាធ្វើឲ្យ(ក្បាល)ពួកគេងើយឡើងលើ(ជាប់ជានិច្ច)។

9. ហើយយើងបានដាក់របាំងមួយនៅពីមុខពួកគេ និងនៅពីក្រោយពួកគេ រួចយើងបានបំបាំងភ្នែកពួកគេ។ ដូច្នេះ ពួកគេមិនអាចមើលឃើញ(ការពិត)នោះឡើយ។

10. វាដូចគ្នាទេចំពោះពួកទាំងនោះ ទោះបីជាអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាស់តឿនព្រមានពួកគេ ឬក៏មិនជាស់តឿនព្រមានពួកគេក៏ដោយ ក៏ពួកគេមិនមានជំនឿនោះដែរ។

11. តាមពិតអ្នកជាស់តឿនព្រមានតែចំពោះអ្នកដែលដើរតាមការរំលឹក(គម្ពីរគួរអាន)ហើយគេខ្លាចព្រះជាម្ចាស់ដ៏មហាសប្បុរសទាំង(នៅកន្លែង)កំបាំង។ ដូច្នេះ ចូរអ្នក(ព្យាការីមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់រូបគេនូវការអភ័យទោស និងផលបុណ្យដ៏ប្រពៃ(ឋានសួគ៌)។

12. ពិតប្រាកដណាស់ យើងជាអ្នកធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញ ហើយយើងកត់ត្រាទុកនូវអ្វីដែលពួកគេបានសាង និងអ្វីៗដែលពួកគេបន្សល់ទុក។ ហើយពិតប្រាកដណាស់ រាល់អ្វីៗទាំងអស់ គឺយើងបានកត់ត្រាទុកនៅក្នុងគម្ពីរមួយ(ឡាវហ៊ិលម៉ះហ្វ៊ូស)យ៉ាងច្បាស់លាស់។

13. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកជាឧទាហរណ៍សម្រាប់ពួកគេនូវរឿងរ៉ាវរបស់អ្នកស្រុកភូមិមួយនៅពេលដែលបណ្តាអ្នកនាំសារបានទៅដល់ភូមិស្រុកនោះ។

14. ខណៈដែលយើងបានបញ្ជូន(អ្នកនាំសារ)ពីរនាក់ទៅកាន់ពួកគេ តែពួកគេបានបដិសេធនឹងគេទាំងពីរ។ ដូច្នេះ យើងក៏បានពង្រឹង(គេទាំងពីរ)ដោយអ្នកទីបីទៀត។ ហើយពួកគាត់(អ្នកនាំសារ)បាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលត្រូវបានគេបញ្ជូនមកកាន់ពួកអ្នក។

15. ពួកគេបានតបថា៖ ពួកអ្នកគ្មានអ្វីក្រៅតែជាមនុស្សលោកដូចពួកយើងប៉ុណ្ណោះ។ ហើយព្រះជាម្ចាស់ដ៏មហាសប្បុរសក៏មិនបានបញ្ចុះអ្វីមួយមកនោះដែរ។ តាមពិត ពួកអ្នកគ្រាន់តែជាមនុស្សភូតកុហកប៉ុណ្ណោះ។

16. ពួកគាត់បានតបវិញថា៖ ព្រះជាម្ចាស់របស់ពួកយើងទ្រង់ដឹងថា ពិតប្រាកដណាស់ ពួកយើងពិតជាអ្នកដែលត្រូវបានគេបញ្ជូនមកកាន់ពួកអ្នកប្រាកដមែន។

17. ហើយពួកយើងគ្មានកាតព្វកិច្ចអ្វីក្រៅពីការផ្សព្វផ្សាយ(សារ)ដ៏ច្បាស់លាស់ប៉ុណ្ណោះ។

18. ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងមានប្រផ្នូលអាក្រក់ដោយសារពួកអ្នក។ ប្រសិនបើពួកអ្នកមិនព្រមបញ្ឈប់(ការអំពាវនាវ)ទេនោះ ពួកយើងប្រាកដជានឹងគប់សម្លាប់ពួកអ្នក ហើយពួកអ្នកនឹងទទួលរងនូវទារុណកម្មដ៏សែនឈឺចាប់ពីពួកយើងជាមិនខាន។

19. ពួកគាត់ក៏តបវិញថា៖ ប្រផ្នូលអាក្រក់របស់ពួកអ្នក គឺនៅជាមួយនឹងពួកអ្នក។ តើការដែលគេទូន្មានពួកអ្នកនោះ(ជាប្រផ្នូលអាក្រក់)ឬ? ផ្ទុយទៅវិញ ពួកអ្នកគឺជាក្រុមដែលបំពាន។

20. ហើយមានបុរសម្នាក់មកពីជាយក្រុងបានមកដល់យ៉ាងប្រញាប់ប្រញាល់។ គេបាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកដើរតាមអ្នកនាំសារទាំងនោះចុះ។

21. ចូរពួកអ្នកដើរតាមអ្នកដែលមិនបានទាមទារកម្រៃអ្វីសោះពីពួកអ្នកចុះ ព្រោះពួកគេជាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

22. ហើយតើមានអ្វីដែលរារាំងខ្ញុំមិនឱ្យគោរពសក្ការៈចំពោះអ្នកដែលបានបង្កើតខ្ញុំ ហើយពួកអ្នកត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)នោះ?

23. តើឱ្យខ្ញុំយកអ្នកផ្សេងក្រៅពីទ្រង់ធ្វើជាព្រះឬ? ប្រសិនបើព្រះជាម្ចាស់ដ៏មហាសប្បុរសមានចេតនាឱ្យខ្ញុំទទួលនូវគ្រោះណាមួយនោះ ការអន្តរាគមន៍របស់ពួកវាមិនអាចផ្តល់ជាប្រយោជន៍អ្វីបន្តិចដល់ខ្ញុំឡើយ ហើយក៏មិនអាចសង្គ្រោះ(រូបខ្ញុំ)បាននោះដែរ។

24. ពិតប្រាកដណាស់ ប្រសិនបើដូច្នោះ រូបខ្ញុំប្រាកដជាស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់ជាមិនខាន។

25. ពិតប្រាកដណាស់ ខ្ញុំមានជំនឿហើយលើព្រះជាម្ចាស់របស់ពួកអ្នក(អល់ឡោះ)។ ហេតុនេះ ចូរពួកអ្នកស្តាប់ខ្ញុំ។

26. (ក្រោយពីបុរសនោះត្រូវបានគេសម្លាប់) មានគេនិយាយទៅកាន់គាត់ថា៖ ចូរអ្នកចូលឋានសួគ៌ចុះ។ គាត់ក៏បានពោលថា៖ ឱអនិច្ចាក្រុមរបស់ខ្ញុំ! គួរណាតែពួកគេបានដឹង

27. នូវអ្វីដែលព្រះជាម្ចាស់របស់ខ្ញុំបានអភ័យទោសដល់រូបខ្ញុំ និងបានឲ្យរូបខ្ញុំស្ថិតក្នុងចំណោមអ្នកដែលត្រូវគេលើកតម្កើង។

28. ហើយយើងមិនបានបញ្ជះកងទ័ព(ម៉ាឡាអ៊ីកាត់)ពីលើមេឃទៅបំផ្លាញក្រុមរបស់គេបន្ទាប់ពីរូបគេ(ត្រូវបានគេសម្លាប់)នោះឡើយ ហើយយើងក៏មិនមែនជាអ្នកបញ្ជះ(ម៉ាឡាអ៊ីកាត់)នោះដែរ។

29. វាគ្រាន់តែសម្រែកយ៉ាងខ្លាំងមួយប៉ុណ្ណោះ។ នៅពេលនោះ ពួកគេក៏ស្លាប់អស់គ្មានសល់។

30. គួរឲ្យសោកស្តាយបំផុតចំពោះខ្ញុំបម្រើទាំងឡាយ! គ្មានអ្នកនាំសារណាម្នាក់បានមកដល់ពួកគេឡើយ លើកលែងតែពួកគេសើចចំអកចំពោះគាត់ទៅវិញ។

31. តើពួកគេមិនបានឃើញទេឬ តើមានប្រជាជាតិជំនាន់មុនពួកគេប៉ុន្មានហើយដែលយើងបានបំផ្លាញនោះ? ជាការពិតណាស់ពួកទាំងនោះមិនបានវិលត្រឡប់មកកាន់ពួកគេវិញឡើយ។

32. ហើយរាល់ប្រជាជាតិទាំងអស់ ពួកគេនឹងត្រូវគេនាំមកឲ្យមានវត្តមាននៅចំពោះមុខយើងទាំងអស់គ្នា(នៅថ្ងៃបរលោក)។

33. ហើយជាសញ្ញាកស្តុតាងមួយសម្រាប់ពួកគេ គឺដីដែលស្លាប់(ស្ងួតហួតហែង) យើងបានឲ្យវារស់ឡើងវិញ(មានរុក្ខជាតិដុះតាមរយៈទឹកភ្លៀង) ហើយយើងបានបញ្ចេញពីដីនោះនូវគ្រាប់ធញ្ញជាតិ(ជាច្រើនប្រភេទ)ដោយពួកគេអាចទទួលទានអំពីវាបាន។

34. ហើយយើងបានឱ្យដីនោះមាននូវចម្ការជាច្រើនអំពីដើមល្មើ និងទំពាំងបាយជូរ។ ហើយយើងបានធ្វើឱ្យមានប្រភពទឹកបាញ់ចេញពីក្នុងវាផងដែរ

35. ដើម្បីឱ្យមនុស្សលោកទទួលទានអំពីផលានុផលរបស់វា ខណៈដែលពួកគេមិនបានប្រឹងប្រែងដោយដៃរបស់ពួកគេឡើយ។ ដូច្នេះ តើពួកគេមិនដឹងគុណ(អល់ឡោះ)ទេឬ?

36. ទ្រង់មហាស្អាតស្តុតដែលបានបង្កើតឲ្យមានជាគូៗនូវរាល់អ្វីៗទាំងអស់ ទាំងអំពីអ្វីដែលដុះចេញពីក្នុងដី និងអំពីខ្លួនរបស់គេផ្ទាល់ ហើយនិងអំពីអ្វីផ្សេងទៀតដែលពួកគេមិនបានដឹង។

37. ហើយជាសញ្ញាកស្តុតាងសម្រាប់ពួកគេផងដែរ គឺយើងបានធ្វើឱ្យពេលយប់ដកយក(ពន្លឺ)ពេលថ្ងៃ។ ពេលនោះ ស្រាប់តែពួកគេស្ថិតនៅក្នុងភាពងងឹតសូន្យសុង។

38. ហើយចំពោះព្រះអាទិត្យ គឺវាធ្វើចលនាទៅតាមគន្លងរបស់វា(យ៉ាងជាក់លាក់)។ នោះគឺជាការកំណត់របស់ព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាដឹងបំផុត។

39. រីឯព្រះចន្ទ យើងបានកំណត់វាជាដំណាក់ៗ(ជារៀងរាល់យប់) រហូតដល់វាត្រឡប់ទៅវិញ ប្រៀបដូចជាធាងល្មើដែលស្ងួត។

40. ព្រះអាទិត្យមិនអាចធ្វើដំណើរទៅទាន់ព្រះចន្ទនោះឡើយ ហើយពេលយប់ក៏មិនអាចមកដល់មុនពេលថ្ងៃនោះដែរ។ ហើយរាល់អ្វីៗទាំងនោះ គឺសុទ្ធតែធ្វើចលនាតាមគន្លងរបស់វារៀងៗខ្លួន។

41. ហើយជាសញ្ញាកស្តុតាងសម្រាប់ពួកគេផងដែរនោះ គឺយើងបានដឹកកូនចៅរបស់ពួកគេក្នុងសំពៅដែលពោរពេញ(ទៅដោយភារៈគ្រប់ប្រភេទ)។

42. ហើយយើងបានបង្កើតសម្រាប់ពួកគេនូវអ្វីដែលពួកគេជិះ(យានជំនិះផ្សេងៗ)ដូចទៅនឹងសំពៅនោះដែរ។

43. ហើយប្រសិនបើយើងមានចេតនា យើងនឹងពន្លិចពួកគេជាមិនខាន។ នៅពេលនោះ ពួកគេគ្មានអ្នកជួយ ហើយក៏មិនត្រូវបានគេសង្គ្រោះនោះដែរ។

44. លើកលែងតែដោយក្តីមេត្តាករុណាអំពីយើង និងឱ្យ(ពួកគេ)សោយសុខរហូតដល់ពេលកំណត់ប៉ុណ្ណោះ។

45. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេ(ពួកមុស្ស៊ីគីន)ថា៖ ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះអ្វីដែលនៅខាងមុខពួកអ្នក(ថ្ងៃបរលោក) និងអ្វីដែលនៅខាងក្រោយពួកអ្នក(លោកិយ) សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រឡាញ់(គឺពួកគេមិនធ្វើតាមឡើយ)។

46. ហើយគ្មានសញ្ញាកស្តុតាងណាមួយក្នុងចំណោមសញ្ញាកស្តុតាងទាំងឡាយរបស់ព្រះជាម្ចាស់ពួកគេបានមកដល់ពួកគេឡើយ លើកលែងតែពួកគេងាកចេញអំពីវា។

47. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកទាំងនោះថា៖ ចូរពួកអ្នកបរិច្ចាគអំពីអ្វីដែលអល់ឡោះបានប្រទានជាលាភសក្ការៈដល់ពួកអ្នក ពួកដែលគ្មានជំនឿនោះបានតបទៅកាន់បណ្តាអ្នកមានជំនឿវិញថា៖ តើឱ្យពួកយើងផ្តល់អាហារឱ្យអ្នកដែលប្រសិនបើអល់ឡោះទ្រង់មានចេតនា ទ្រង់ប្រាកដជានឹងប្រទានអាហារដល់គេនោះឬ? ពិតណាស់ ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)គ្មានអ្វីក្រៅពីស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់នោះឡើយ។

48. ហើយពួកគេនិយាយថា៖ តើការសន្យានេះនឹងមកដល់នៅពេលណា ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ?

49. ពួកទាំងនោះគ្មានរង់ចាំអ្វីក្រៅពីសម្រែកមួយ(សំឡេងត្រែលើកទីមួយ)ដែលឆក់យកជីវិតពួកគេ ខណៈដែលពួកគេកំពុងតែឈ្លោះប្រកែកគ្នានោះឡើយ។

50. នៅពេលនោះ ពួកគេមិនអាចធ្វើការផ្តែផ្តាំ ហើយក៏មិនអាចវិលត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ពួកគេបាននោះដែរ។

51. ហើយគេបានផ្លុំត្រែ(ជាលើកទីពីរ)។ ស្រាប់តែពេលនោះ ពួកគេក្រោកចេញពីផ្នូរយ៉ាងលឿនឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់ពួកគេ។

52. ពួកគេនិយាយថា៖ អន្តរាយហើយពួកយើង! តើនរណាជាអ្នកឲ្យពួកយើងក្រោកចេញពីផ្នូររបស់ពួកយើងនេះ? (មានគេឆ្លើយថា៖) នេះហើយជាអ្វីដែលព្រះជាម្ចាស់ដ៏មហាសប្បុរសទ្រង់បានសន្យា ហើយបណ្តាអ្នកនាំសារទាំងឡាយក៏បានប្រាប់នូវដំណឹងពិតនេះដែរ។

53. វាគ្មានអ្វីក្រៅពីសម្រែក(ផ្លុំត្រែ)តែមួយប៉ុណ្ណោះ។ ស្រាប់តែពេលនោះ ពួកគេត្រូវគេនាំមកឲ្យមានវត្តមាននៅចំពោះមុខយើងទាំងអស់គ្នា។

54. ដូច្នេះនៅថ្ងៃនេះ គ្មានជីវិតណាមួយត្រូវបានគេបំពានបន្តិចនោះឡើយ។ ហើយពួកអ្នកក៏មិនត្រូវបានតបស្នងក្រៅតែពីអ្វីដែលពួកអ្នកបានប្រព្រឹត្តនោះដែរ។

55. ពិតប្រាកដណាស់ បណ្តាអ្នកឋានសួគ៌ នៅក្នុងថ្ងៃនោះ គឺពួកគេរវល់នឹងភាពសោយសុខ។

56. ពួកគេ និងភរិយារបស់ពួកគេផ្អែកខ្លួនលើគ្រែដ៏ល្អប្រណីតក្រោមម្លប់(ដ៏ត្រជាក់ត្រជុំ)។

57. នៅក្នុងឋានសួគ៌នោះ ពួកគេនឹងទទួលបានផ្លែឈើគ្រប់ប្រភេទ ហើយពួកគេនឹងទទួលបាននូវអ្វីដែលពួកគេស្នើសុំ។

58. (ពួកគេទទួលបាន)សាឡាមដែលជាបន្ទូលពីព្រះជាម្ចាស់ដ៏មហាអាណិតស្រលាញ់បំផុត។

59. (មានគេនិយាយទៅកាន់ពួកគ្មានជំនឿថា៖) នៅថ្ងៃនេះ ឱពួកឧក្រិដ្ឋជនទាំងឡាយ ចូរពួកអ្នកញែកខ្លួនចេញ(ពីបណ្តាអ្នកមានជំនឿ)ចុះ។

60. (អល់ឡោះបានមានបន្ទូលថា៖) តើយើងមិនបានផ្តែផ្តាំអ្នកទេឬ ឱកូនចៅអាដាំថា៖ ចូរពួកអ្នកកុំគោរពសក្ការៈចំពោះស្មែតនឱ្យសោះ។ ពិតប្រាកដណាស់ វាជាសត្រូវយ៉ាងច្បាស់លាស់ចំពោះពួកអ្នក។

61. តែពួកអ្នកត្រូវគោរពសក្ការៈមកចំពោះយើងវិញ។ នេះហើយជាមាគ៌ាដ៏ត្រឹមត្រូវ។

62. ហើយជាការពិតណាស់ ស្មែតនបានធ្វើឱ្យមនុស្សយ៉ាងច្រើនក្នុងចំណោមពួកអ្នកវង្វេង។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

63. នេះហើយជាឋាននរកដើហាន់ណាំដែលពួកអ្នកធ្លាប់ត្រូវបានគេសន្យា។

64. នៅថ្ងៃនេះ ចូរពួកអ្នកចូលទៅក្នុងវាចុះដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រឆាំង។

65. នៅថ្ងៃនេះ យើងនឹងបោះត្រាក្លិតទៅលើមាត់របស់ពួកគេ ហើយដៃទាំងពីររបស់ពួកគេនឹងនិយាយមកកាន់យើង។ ចំណែកឯជើងរបស់ពួកគេធ្វើជាសាក្សីចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

66. ហើយប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងបិទភ្នែករបស់ពួកគេជាមិនខាន។ ពេលនោះ ពួកគេនឹងប្រជែងគ្នានៅលើស្ពានស៊ីរ៉ាត។ ដូចនេះ តើពួកគេអាចមើលឃើញយ៉ាងដូចម្តេច?

67. ហើយប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងផ្លាស់ប្តូររូបរាងរបស់ពួកគេដោយឱ្យពួកគេ(ខ្វិន)នៅមួយកន្លែងជាមិនខាន។ ពេលនោះ ពួកគេនឹងមិនអាច(ផ្លាស់ទី)ទៅមុខ ទៅក្រោយបាននោះឡើយ។

68. ហើយជនណាដែលយើងប្រទានឱ្យគេមានអាយុវែង យើងនឹងឱ្យគេត្រឡប់ទៅសភាពដើមវិញ(ទន់ខ្សោយដូចមុន)។ ដូច្នេះ តើពួកគេមិនគិតពិចារណាទេឬ?

69. ហើយយើងមិនបានបង្រៀនកំណាព្យដល់គេ(ព្យាការីមូហាំម៉ាត់)ឡើយ ហើយក៏មិនគប្បីសម្រាប់គេ(ក្នុងការរៀនវា)នោះដែរ។ តាមពិតវាគឺគ្មានអ្វីក្រៅពីការដាស់រំឭក និងគម្ពីរគួរអានដ៏ច្បាស់លាស់នោះឡើយ។

70. ដើម្បីឱ្យគេ(ព្យាការីមូហាំម៉ាត់)ដាស់តឿនព្រមានចំពោះអ្នកដែល(ដួងចិត្តរបស់គេ)នៅរស់។ ហើយពាក្យពេចន៍(ទណ្ឌកម្ម)ត្រូវបានកំណត់ទៅលើពួកដែលប្រឆាំង។

71. តើពួកគេមិនបានឃើញទេ ពិតប្រាកដណាស់ ក្នុងចំណោមអ្វីដែលយើងបានបង្កើតដោយដៃយើងផ្ទាល់ គឺយើងបានបង្កើតសម្រាប់ពួកគេនូវសត្វពាហនៈជាច្រើន។ ហើយពួកគេជាអ្នកគ្រប់គ្រង(លើវា)។

72. ហើយយើងបានសម្រួលវាដល់ពួកគេ ដោយក្នុងចំណោមពួកវា គឺមានខ្លះជាជំនិះរបស់ពួកគេ ហើយខ្លះទៀត ពួកគេអាចបរិភោគវាបាន។

73. ហើយសម្រាប់ពួកគេ ចំពោះសត្វពាហនៈទាំងនោះ គឺផ្តល់ជាប្រយោជន៍នានា និងផ្តល់ជាភេសជ្ជៈ(ទឹកដោះ)ផងដែរ។ ដូច្នេះតើពួកគេមិនដឹងគុណ(អល់ឡោះ)ទេឬ?

74. តែពួកគេបែរជាយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាព្រះ ដោយពួកគេសង្ឃឹមថា ពួកវានឹងជួយដល់ពួកគេទៅវិញ។

75. ពួកវាគ្មានលទ្ធភាពជួយពួកគេនោះឡើយ។ ហើយពួកគេទាំងអស់គ្នានឹងត្រូវគេនាំ(ទៅកាន់ទណ្ឌកម្ម)។

76. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំឱ្យពាក្យសម្តីរបស់ពួកគេធ្វើឱ្យអ្នកមានទុក្ខព្រួយឱ្យសោះ។ ពិតប្រាកដណាស់ យើងដឹងបំផុតនូវអ្វីដែលពួកគេលាក់បាំង និងអ្វីដែលពួកគេលាតត្រដាង។

77. តើមនុស្សលោកមិនបានឃើញទេឬ ពិតប្រាកដណាស់ យើងបានបង្កើតរូបគេអំពីទឹកកាម។ បន្ទាប់មករូបគេបែរជាក្លាយជាអ្នកពូកែដេញដោលច្រើនទៅវិញ។

78. ហើយគេបានលើកឧទាហរណ៍មកកាន់យើង តែគេបែរជាភ្លេចកំណើតខ្លួនឯងទៅវិញដោយគេនិយាយថា៖ តើអ្នកណាដែលអាចឱ្យឆ្អឹងរស់ឡើងវិញបាន ខណៈដែលវាពួកផុយទៅហើយនោះ?

79. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបថា៖ អ្នកដែលអាចឱ្យវារស់ឡើងវិញនោះ គឺអ្នកដែលបានបង្កើតវាពីដំបូងនោះឯង។ ហើយទ្រង់មហាដឹងបំផុតនូវរាល់ភាវៈទាំងអស់។

80. ទ្រង់ជាអ្នកដែលបានបង្កើតភ្លើងចេញពីដើមឈើបៃតងស្រស់សម្រាប់ពួកអ្នក។ ហើយពេលនោះ ពួកអ្នកក៏បង្កាត់ភ្លើងអំពីវា។

81. តើអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី ពុំមែនជាអ្នកដែលមានសមត្ថភាពអាចបង្កើតឱ្យដូចពួកគេ(ម្តងទៀត)ទេឬ? ពិតមែនហើយ ទ្រង់គឺជាអ្នកបង្កើត(ភាវៈទាំងអស់)មហាដឹងបំផុត។

82. តាមពិត កិច្ចការរបស់ទ្រង់ នៅពេលណាដែលទ្រង់មានចេតនាចង់ឱ្យអ្វីមួយកើតឡើងនោះ ទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" វានឹងកើតឡើងភ្លាម។

83. ពិតប្រាកដណាស់ ទ្រង់មហាស្អាតស្អំដែលអំណាចគ្រប់គ្រងអ្វីៗទាំងអស់ គឺស្ថិតក្នុងកណ្តាប់ដៃទ្រង់(តែមួយគត់)។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

ជំពូក អាសស៊ីហ្សាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងពួកម៉ាឡាអ៊ីកាត់ដែលរៀបគ្នាជាជួរ។

2. (ទ្រង់)ស្បថនឹងពួកម៉ាឡាអ៊ីកាត់ដែល(មានតួនាទី)គ្រប់គ្រងពពក។

3. ហើយ(ស្បថ)នឹងពួកម៉ាឡាអ៊ីកាត់ដែលសូត្របន្ទូលរបស់អល់ឡោះ។

4. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់ពួកអ្នក(ឱមនុស្សលោក)ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែមួយអង្គគត់។

5. ជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលនៅចន្លោះរវាងមេឃនិងផែនដី។ ហើយទ្រង់ជាព្រះជាម្ចាស់គ្រប់គ្រងព្រះអាទិត្យទាំងកន្លែងនានាដែលវារះ និងកន្លែងនានាដែលវាលិច។

6. ពិតប្រាកដណាស់ យើងបានតុបតែងលម្អមេឃលោកិយ(មេឃជាន់ទីមួយ)ដោយដួងតារាជាច្រើន។

7. និងបានការពារ(មេឃ)ពីពពួកស្មៀតនដែលបំពាន

8. ដោយមិនឲ្យពួកវាស្តាប់ឮម៉ាឡាអ៊ីកាត់ដែលនៅលើមេឃ(និយាយគ្នា)នោះឡើយ។ ហើយពួកវាត្រូវបានគេគប់(ដោយអាចម៍ផ្កាយ)ពីគ្រប់ទិសទាំងអស់

9. ដើម្បីបណ្តេញពួកវា(ឱ្យចេញឆ្ងាយ)។ ហើយពួកវានឹងត្រូវទទួលទណ្ឌកម្មជានិរន្តន៍(នៅថ្ងៃបរលោក)។

10. លើកលែងតែអ្នកដែលបានលួចស្តាប់ប៉ុណ្ណោះ។ នៅពេលនោះ អាចម៍ផ្កាយក៏បានដេញតាមដុតពួកវា។

11. ដូច្នេះ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)សួរពួកគេ(ពួកគ្មានជំនឿ)ថា៖ តើពួកគេជាការៈដែលមានភាពខ្លាំងក្លាជាង ឬមួយអ្នកដែលយើងបានបង្កើត(មានភាពខ្លាំងក្លាជាង)? ពិតប្រាកដណាស់ យើងបានបង្កើតពួកគេ(មនុស្សលោក)ពីដីដែលស្អិតប៉ុណ្ណោះ។

12. ផ្ទុយទៅវិញ រូបអ្នក(ឱព្យាការីមូហាំម៉ាត់)មានការងឿងឆ្ងល់ ខណៈដែលពួកគេចំអកឡកឡឺយ។

13. ហើយនៅពេលដែលមានគេដាស់រំលឹកពួកគេ ពួកគេមិនទទួលយកការដាស់រំលឹកនោះឡើយ។

14. ហើយនៅពេលដែលពួកគេបានឃើញសញ្ញាកស្តុតាងណាមួយ គឺពួកគេនាំគ្នាចំអកឡកឡឺយ។

15. ហើយពួកគេនិយាយថា៖ នេះគ្មានអ្វីក្រៅពីមន្តអាគមដ៏ច្បាស់លាស់នោះឡើយ។

16. នៅពេលដែលពួកយើងបានស្លាប់ ហើយពួកយើងក្លាយទៅជាដី និងឆ្អឹង(ដែលពុកផុយ)ហើយនោះ តើពួកយើងនឹងត្រូវគេបង្កើតឲ្យរស់ឡើងវិញឬ?

17. តើដីដូនដីតារបស់ពួកយើងពីមុន(ក៏ដូចគ្នាដែរ)ឬ?

18. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)តបថា៖ ពិតមែនហើយ។ ហើយពួកអ្នក គឺជាពួកដែលទាបថោកបំផុត។

19. តាមពិត វាគ្រាន់តែជាការផ្ទុំត្រែតែមួយដងប៉ុណ្ណោះ(ផ្ទុំត្រែលើកទីពីរ)។ ស្រាប់តែពេលនោះ ពួកគេ(ក៏ក្រោកចេញពីផ្នូរ)សម្លឹងមើល។

20. ហើយពួកគេនិយាយថា៖ ឱអនិច្ចាពួកយើង! នេះគឺជាថ្ងៃជំនុំជម្រះ។

21. (មានគេនិយាយទៅកាន់ពួកគេថា៖) នេះហើយជាថ្ងៃកាត់សេចក្តីដែលពួកអ្នកធ្លាប់បានបដិសេធចំពោះវា។

22. (ហើយមានគេនិយាយទៅកាន់ម៉ាឡាអ៊ីកាត់ថា៖) ចូរពួកអ្នកប្រមូលពួកដែលបំពាន និងគូកនរបស់ពួកគេ ព្រមទាំងអ្វីដែលពួកគេធ្លាប់គោរពសក្ការៈ

23. ក្រៅពីអល់ឡោះមក រួចចូរណែនាំពួកគេទៅកាន់ផ្លូវទៅនរកចុះ។

24. ហើយចូរឃាត់ខ្លួនពួកគេ(នៅទីនោះ)។ ពិតប្រាកដណាស់ ពួកគេនឹងត្រូវគេសួរចម្លើយ។

25. (មានគេនិយាយទៅកាន់ពួកគេថា៖) ហេតុអ្វីបានជាពួកអ្នកមិនព្រមជួយគ្នា?

26. ផ្ទុយទៅវិញ នៅក្នុងថ្ងៃនេះ ពួកគេគឺជាពួកដែលប្រគល់ខ្លួន។

27. ហើយពួកគេបែរសំដៅទៅរកគ្នាដោយស្តីបន្ទោសគ្នាទៅវិញទៅមក។

28. ពួកគេបាននិយាយ(ទៅកាន់ពួកមេដឹកនាំរបស់ខ្លួន)ថា៖ ពិតប្រាកដណាស់ ពួកអ្នកធ្លាប់បានមកកាន់ពួកយើងតាមរយៈផ្លូវសាសនា(ដោយការបោកបញ្ឆោត)។

29. ពួកទាំងនោះបានតបវិញថា៖ ផ្ទុយទៅវិញ ពួកអ្នកពុំធ្លាប់ជាអ្នកដែលមានជំនឿនោះឡើយ។

30. ហើយពួកយើងក៏គ្មានអំណាចអ្វី(បង្ខិតបង្ខំ)ពួកអ្នកនោះដែរ។ ផ្ទុយទៅវិញ ពួកអ្នកគឺជាក្រុមមួយដែលបំពាន។

31. ហើយពាក្យបន្ទូល(ដាក់ទណ្ឌកម្ម)របស់ព្រះជាម្ចាស់ពួកយើងចាំបាច់ត្រូវតែកើតឡើងចំពោះពួកយើង។ ពិតប្រាកដណាស់ ពួកយើងគឺជាពួកដែលត្រូវភ្លក់(ទណ្ឌកម្ម)។

32. ហើយពួកយើងបានពង្វក់ពួកអ្នកឲ្យវង្វេង។ ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាពួកដែលវង្វេង។

33. ដូច្នេះ នៅថ្ងៃនេះ ពួកគេនឹងត្រូវស្ថិតក្នុងទណ្ឌកម្មរួមគ្នា។

34. ក៏ដូច្នោះដែរ យើងក៏នឹងធ្វើដូចគ្នានេះចំពោះពួកឧក្រិដ្ឋជនទាំងឡាយផងដែរ។

35. ពិតប្រាកដណាស់ ពួកទាំងនោះ នៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ គឺពួកគេក្រអឺតក្រទម(មិនទទួលយក)ឡើយ។

36. ហើយពួកគេថែមទាំងនិយាយថា៖ តើពួកយើងត្រូវបោះបង់ព្រះនានារបស់ពួកយើងដោយសារតែកវីនិពន្ធដែលវិកលចរិតម្នាក់នេះឬ?

37. ផ្ទុយទៅវិញ គាត់(ព្យាការីមូហាំម៉ាត់)បាននាំមកនូវសេចក្តីពិត ហើយនិងបញ្ជាក់ទៅលើបណ្តាអ្នកនាំសារទាំងឡាយ(ចំពោះអ្វីដែលពួកគាត់បាននាំមក)។

38. ពិតប្រាកដណាស់ ពួកអ្នក(ឱពួកមុស្លីគីន)ប្រាកដជានឹងត្រូវភ្លក់នូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

39. ហើយពួកអ្នកក៏មិនត្រូវបានគេតបស្នងក្រៅតែពីអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តនោះដែរ។

40. លើកលែងខ្ញុំបម្រើទាំងឡាយរបស់អល់ឡោះដែលមានភាពស្មោះស(ចំពោះទ្រង់)ប៉ុណ្ណោះ។

41. អ្នកទាំងនោះ សម្រាប់ពួកគេនឹងទទួលបានលាភសក្ការៈជានិរន្តន៍

42. គឺផ្លែឈើជាច្រើនប្រភេទ។ ហើយពួកគេ គឺជាអ្នកដែលត្រូវបានលើកតម្កើង

43. ក្នុងឋានសួគ៌ណាអ៊ីម។

44. ពួកគេផ្អែកខ្លួននៅលើគ្រែដោយបែរមុខរកគ្នា។

45. មានគេចាំបម្រើកែវស្រាជុំវិញពួកគេពីប្រភពទន្លេស្រា។

46. វាមានពណ៌សដែលមានរសជាតិឆ្ងាញ់បំផុតសម្រាប់អ្នកដែលទទួលទាន។

47. វាគ្មានផលប៉ះពាល់ដល់រាងកាយឡើយ ហើយក៏មិនធ្វើឲ្យពួកគេបាត់បង់សតិបញ្ញានោះដែរ។

48. ហើយពួកគេនឹងទទួលបានស្ត្រីដែលល្អបរិសុទ្ធដែលកែវភ្នែករបស់ពួកនាងមិនសម្លឹងមើលទៅកាន់អ្នកដទៃឡើយ។

49. ពួកនាងប្រៀបដូចជាពងសត្វដែលត្រូវបានគេថែរក្សាយ៉ាងល្អ។

50. ហើយពួកគេបែរសំដៅទៅរកគ្នាដោយសួរនាំគ្នាទៅវិញទៅមក។

51. មានម្នាក់ក្នុងចំណោមពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំធ្លាប់មានមិត្តភក្តិម្នាក់។

52. គេបាននិយាយ(មកកាន់ខ្ញុំ)ថា៖ តើឯងស្ថិតក្នុងចំណោមអ្នកដែលជឿជាក់(លើការបង្កើតឱ្យរស់ឡើងវិញ)ឬ?

53. នៅពេលដែលពួកយើងស្លាប់ ហើយបានក្លាយទៅជាដី និងឆ្អឹង(ដែលពុកផុយ)ហើយនោះ តើពួកយើងពិតជានឹងត្រូវគេបង្កើតឱ្យរស់ឡើងវិញឬ?

54. គេក៏សួរថា៖ តើពួកអ្នកបានឃើញ(ម្នាក់នោះ)ដែរឬទេ?

55. នៅពេលនោះ គេក៏បានរកមើល(ជននោះ) ហើយគេក៏បានឃើញជននោះស្ថិតនៅកណ្តាលឋាននរក។

56. គេក៏និយាយថា៖ សូមស្បថនឹងអល់ឡោះ! ពិតណាស់ អ្នកស្ទើរតែបំផ្លាញខ្ញុំទៅហើយ។

57. ហើយប្រសិនបើគ្មានការប្រោសប្រទានពីព្រះជាម្ចាស់របស់ខ្ញុំទេនោះ ប្រាកដជាខ្ញុំនឹងត្រូវស្ថិតក្នុងចំណោមពួកដែលត្រូវគេនាំមក(ឲ្យទទួលទណ្ឌកម្ម)ជាមិនខាន។

58. ពិតប្រាកដណាស់ ពួកយើង(បណ្តាអ្នកចូលឋានសួគ៌)នឹងមិនស្លាប់ទៀតឡើយ

59. លើកលែងការស្លាប់លើកទីមួយរបស់ពួកយើងប៉ុណ្ណោះ។ ហើយពួកយើងក៏មិនត្រូវបានគេដាក់ទណ្ឌកម្មនោះដែរ។

60. ពិតប្រាកដណាស់ នេះគឺពិតជាជោគជ័យដ៏ធំធេងបំផុត។

61. ដើម្បីទទួលបានបែបនេះ ចូរអ្នកដែលសាងអំពើល្អទាំងឡាយ ខិតខំសាងនូវអំពើល្អ។

62. តើអ្វីទាំងនោះជាការប្រទានដ៏ល្អ ឬក៏ដើមហ្សឹកគូមល្អជាង?

63. ពិតប្រាកដណាស់ យើងបានបង្កើតដើមឈើនេះជាការសាកល្បងមួយសម្រាប់ពួកដែលបំពាន។

64. ជាការពិតណាស់ វាជាដើមឈើមួយដែលដុះចេញពីបាតនរក។

65. ផ្លែរបស់វាប្រៀបដូចជាក្បាលរបស់ពួកស្លែតន។

66. ពិតប្រាកដណាស់ ពួកគេ(ពួកមុស្ហរីគីន)ប្រាកដជានឹងទទួលទានអំពីវា។ ហើយពោះរបស់ពួកគេ គឺពេញទៅដោយផ្លែនោះ។

67. បន្ទាប់មក ពួកគេនឹងបានផឹកទឹកដ៏ក្តៅបំផុតលាយជាមួយវា។

68. បន្ទាប់មកទៀត កន្លែងរំលែត្រឡប់របស់ពួកគេ គឺឆ្ពោះទៅកាន់ឋាននរក។

69. ពិតប្រាកដណាស់ ពួកទាំងនោះបានឃើញជីដូនជីតារបស់ពួកគេស្ថិតក្នុងភាពវង្វេង។

70. ហេតុនេះ ពួកគេក៏ធ្វើតាមលំអានជីដូនជីតាពួកគេយ៉ាងឆាប់រហ័ស។

71. ហើយជាការពិតណាស់ ភាគច្រើននៃអ្នកជំនាន់មុនពួកគេបានវង្វេងមុនពួកគេទៅទៀត។

72. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនអ្នកដាស់តឿនព្រមានជាច្រើនទៅកាន់ពួកគេ (តែពួកគេបែរជាប្រឆាំង)។

73. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិចារណាមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលត្រូវគេដាស់តឿនព្រមាននោះទៅជាយ៉ាងណា ?

74. លើកលែងតែខ្ញុំបម្រើរបស់អល់ឡោះដែលមានភាពស្មោះស(ចំពោះទ្រង់)ប៉ុណ្ណោះ។

75. ហើយជាការពិតណាស់ ព្យាការីនួហបានបួងសួងសុំមកកាន់យើង(ឲ្យជួយ)។ ពិតប្រាកដណាស់ យើងជាអ្នកឆ្លើយតប (ចំពោះការបួងសួង)ដ៏ប្រសើរបំផុត។

76. ហើយយើងបានសង្គ្រោះគេ និងក្រុមគ្រួសាររបស់គេពីគ្រោះដ៏ធំធេង។

77. ហើយយើងបានធ្វើឲ្យពូជពង្សរបស់គេ គឺជាអ្នកដែលនៅសេសសល់(ក្រោយពីទឹកជំនាន់)។

78. ហើយយើងបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះរបស់គេដល់អ្នកជំនាន់ក្រោយ។

79. សូមសន្តិភាពក្នុងសាកលលោកកើតមានដល់ព្យាការីនួហ។

80. ក៏ដូច្នោះដែរ ពិតប្រាកដណាស់ យើងនឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អ។

81. ពិតប្រាកដណាស់ រូបគេស្ថិតក្នុងចំណោមខ្ញុំបម្រើរបស់យើងដែលមានជំនឿ។

82. ក្រោយមក យើងបានធ្វើឲ្យអ្នកដទៃទៀតលិចលង់។

83. ហើយពិតប្រាកដណាស់ ក្នុងចំណោមអ្នកដែលស្ថិតនៅលើមាគ៌ារបស់គាត់(ព្យាការីនួហ) គឺព្យាការីអ៊ីព្រហ៊ីម។

84. ខណៈដែលគាត់បានមកជួបព្រះជាម្ចាស់របស់គាត់ដោយដួងចិត្តស្អាតស្អំ។

85. នៅពេលដែលគាត់និយាយទៅកាន់ឪពុករបស់គាត់ និងក្រុមរបស់គាត់ថា៖ តើអ្វីទៅដែលពួកអ្នកកំពុងតែគោរពសក្ការៈនោះ?

86. តើព្រះដែលគេប្រឌិតឡើងទាំងនេះឬដែលពួកអ្នកនាំគ្នាគោរពសក្ការៈក្រៅពីអល់ឡោះនោះ?

87. ដូច្នេះ តើពួកអ្នកគិតដូចម្តេចចំពោះព្រះជាម្ចាស់នៃពិភពទាំងអស់?

88. ក្រោយមក គាត់បានសម្លឹងមើលទៅកាន់ហ្វូងតារា

89. រួចគាត់និយាយថា៖ ជាការពិតណាស់ ខ្ញុំឈឺ(មិនអាចទៅចូលរួមបុណ្យជាមួយពួកអ្នកបានទេ)។

90. ដូច្នេះ ពួកគេក៏ទុកគាត់ចោល ហើយចាកចេញទៅ។

91. ពេលនោះ គាត់ក៏បានងាកទៅរកព្រះទាំងឡាយរបស់ពួកគេ ហើយគាត់ក៏បាននិយាយថា៖ តើពួកឯងមិនទទួលទានអាហារទេឬ?

92. ហេតុអ្វីបានជាពួកឯងមិនព្រមនិយាយបែបនេះ?

93. ហើយគាត់ក៏បានដើរទៅជិតពួកវាដោយបានវាយពួកវានឹងដៃស្តាំ(របស់គាត់)។

94. ពេលនោះ ពួកគេក៏បានដើរសំដៅមកកាន់គាត់យ៉ាងលឿន។

95. គាត់ក៏បាននិយាយថា៖ តើពួកអ្នកគោរពសក្ការៈចំពោះអ្វីដែលពួកអ្នកឆ្លាក់វា(ដោយផ្ទាល់ដៃពួកអ្នក)នោះឬ

96. ខណៈដែលអល់ឡោះជាអ្នកដែលបានបង្កើតពួកអ្នក និងអ្វីដែលពួកអ្នកកំពុងធ្វើនោះ?

97. ពួកគេបាននិយាយថា៖ ចូរពួកអ្នកសង់សំណង់មួយសម្រាប់គេ ហើយបោះគេចូលទៅក្នុងភ្លើងដែលឆាបឆេះនោះចុះ។

98. ហើយពួកគេមានបំណងរៀបចំឧបាយកល(អាក្រក់)ចំពោះគេ តែយើងបានធ្វើឱ្យពួកគេបរាជ័យ។

99. ហើយគាត់ក៏បាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំនឹងធ្វើដំណើរទៅកាន់ព្រះជាម្ចាស់របស់ខ្ញុំ។ ទ្រង់នឹងចង្អុលបង្ហាញខ្ញុំជាមិនខាន។

100. បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាប្រទាននូវកូនប្រុសដ៏កតញ្ញូម្នាក់ឱ្យខ្ញុំផង។

101. ពេលនោះ យើងក៏បានផ្តល់ដំណឹងរីករាយដល់គេនូវកូនប្រុសម្នាក់ដែលអត់ធ្មត់(គឺព្យាការីអ៊ីស្មាអែល)។

102. នៅពេលដែលគេធំអាចដើរជាមួយគាត់បាន គាត់បាននិយាយថា៖ ឱកូនសម្លាញ់! ជាការពិតណាស់ ពុកបានឃើញក្នុងសុបិនថា ពិតប្រាកដណាស់ ពុកត្រូវសំឡេះកូន។ ហេតុនេះ សូមកូនគិតមើលចុះ តើកូនយល់យ៉ាងណា? គេក៏តបវិញថា៖ ឱលោកឪពុកជាទីស្រឡាញ់! សូមពុកធ្វើតាមអ្វីដែលគេបានបញ្ជាប្រើពុកចុះ។ ប្រសិនបើអល់ឡោះមានចេតនា ពុកនឹងឃើញថា រូបកូនស្ថិតក្នុងចំណោមអ្នកដែលអត់ធ្មត់។

103. ហើយនៅពេលដែលគេទាំងពីរបានប្រគល់ខ្លួន(អនុវត្តតាមបទបញ្ជារបស់ព្រះ) គាត់ក៏បានផ្កាប់មុខគេ(ព្យាការីអ៊ីស្មាអែល)ទៅនឹងដី។

104. ពេលនោះ យើងបានហៅគេថា៖ ឱអ៊ីព្រហ៊ីម!

105. ជាការពិតណាស់ អ្នកពិតជាបានអនុវត្តតាមសុបិនមែន។ ពិតប្រាកដណាស់ យើងក៏នឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អដូច្នោះដែរ។

106. ពិតប្រាកដណាស់ នេះគឺជាការសាកល្បងមួយយ៉ាងច្បាស់លាស់។

107. ហើយយើងបានលោះរូបគេ(ព្យាការីអ៊ីស្មាអែល)ដោយការសំឡេះ(សត្វចៀម)ដ៏ធំមួយ។

108. ហើយយើងបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះរបស់គេ(ព្យាការីអ៊ីព្រហ៊ីម)ដល់អ្នកជំនាន់ក្រោយ។

109. សូមសន្តិភាពកើតមានដល់ព្យាការីអ៊ីព្រហ៊ីម។

110. ពិតប្រាកដណាស់ យើងក៏នឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អដូច្នោះដែរ។

111. ពិតប្រាកដណាស់ រូបគេស្ថិតក្នុងចំណោមខ្ញុំបម្រើរបស់យើងដែលមានជំនឿ។

112. ហើយយើងបានប្រទានដំណឹងរីករាយមួយដល់គេនូវ(កូនប្រុសម្នាក់ទៀតឈ្មោះ)អ៊ីស្ហាក ជាព្យាការីម្នាក់ក្នុងចំណោមអ្នកសាងទង្វើកុសលទាំងឡាយ។

113. ហើយយើងបានប្រទាននូវពរជ័យដល់គេ(ព្យាការីអ៊ីព្រហ៊ីម) និងព្យាការីអ៊ីស្ហាក។ ក្នុងចំណោមកូនចៅរបស់គេទាំងពីរ គឺមានអ្នកដែលសាងអំពើល្អ ហើយនិងអ្នកដែលបំពានលើខ្លួនឯងយ៉ាងច្បាស់លាស់។

114. ហើយពិតប្រាកដណាស់ យើងបានប្រោសប្រទាន(នូវភាពជាព្យាការី)ដល់ព្យាការីមូសា និងព្យាការីហារូន។

115. ហើយយើងបានសង្គ្រោះគេទាំងពីរ និងក្រុមរបស់គេទាំងពីរ(អម្បូរអ៊ីស្រាអែល)ឱ្យរួចផុតពីគ្រោះដ៏ធំ។

116. ហើយយើងបានជួយដល់ពួកគេ។ ដូច្នេះ ពួកគេ គឺជាអ្នកដែលទទួលជោគជ័យ។

117. ហើយយើងបានប្រទានដល់គេទាំងពីរនូវគេម្ពីរ(តារ៉ាត)ដ៏ច្បាស់លាស់។

118. ហើយយើងបានចង្អុលបង្ហាញគេទាំងពីរនូវមាគ៌ាដ៏ត្រឹមត្រូវ។

119. ហើយយើងបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះគេទាំងពីរដល់អ្នកជំនាន់ក្រោយ។

120. សូមសន្តិភាពកើតមានដល់ព្យាការីមូសា និងព្យាការីហារូន។

121. ពិតប្រាកដណាស់ យើងក៏នឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អដូច្នោះដែរ។

122. ពិតប្រាកដណាស់ គេទាំងពីរស្ថិតក្នុងចំណោមខ្ញុំបម្រើរបស់យើងដែលមានជំនឿ។

123. ហើយពិតប្រាកដណាស់ ព្យាការីអ៊ិលយ៉ាស គឺពិតជាស្ថិតក្នុងចំណោមអ្នកនាំសារទាំងឡាយ(របស់អល់ឡោះ)។

124. ខណៈដែលគេបាននិយាយទៅកាន់ក្រុមរបស់គេថា៖ តើពួកអ្នកមិនកោតខ្លាច(អល់ឡោះ)ទេឬ?

125. តើពួកអ្នកគោរពសក្ការៈចំពោះបដិមាហ្គាក់ឡាន់ ហើយបែរជាបោះបង់ចោល(មិនគោរពសក្ការៈ)អ្នកដែលបង្កើតដ៏ប្រសើរជាងគេនោះឬ?

126. គឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក និងជាព្រះជាម្ចាស់នៃជីដូនជីតារបស់ពួកអ្នកជំនាន់មុន។

127. តែពួកគេបានបដិសេធ(មិនជឿ)ចំពោះគាត់។ ដូចនេះ ពួកគេគឺជាពួកដែលត្រូវបានគេនាំ(ទៅកាន់ទណ្ឌកម្ម)។

128. លើកលែងតែខ្ញុំបម្រើទាំងឡាយរបស់អល់ឡោះដែលមានចិត្តស្មោះសប៉ុណ្ណោះ។

129. ហើយយើងបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះរបស់គេដល់អ្នកជំនាន់ក្រោយ។

130. សូមសន្តិភាពកើតមានដល់ព្យាការីអ៊ិលយ៉ាស។

131. ពិតប្រាកដណាស់ យើងក៏នឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អដូច្នោះដែរ។

132. ពិតប្រាកដណាស់ រូបគេស្ថិតក្នុងចំណោមខ្ញុំបម្រើរបស់យើងដែលមានជំនឿ។

133. ហើយជាការពិតណាស់ ព្យាការីលូត គឺពិតជាស្ថិតក្នុងចំណោមអ្នកនាំសារទាំងឡាយ(របស់អល់ឡោះ)។

134. ខណៈពេលដែលយើងបានសង្គ្រោះរូបគេ និងក្រុមគ្រួសាររបស់គេទាំងអស់គ្នា

135. លើកលែងតែស្ត្រីចំណាស់ម្នាក់(ភរិយារបស់គេ)ប៉ុណ្ណោះដែលត្រូវគេបំផ្លាញ។

136. ក្រោយមក យើងបានបំផ្លាញអ្នកផ្សេងទៀត(ដែលនៅសល់)។

137. ហើយពិតប្រាកដណាស់ ពួកអ្នក(ឱអ្នកស្រុកម៉ាក្កៈ)ពិតជាបានឆ្លងកាត់លំនៅឋានរបស់ពួកគេ(ក្រុមរបស់ព្យាការីលូត)ទាំងពេលព្រឹក

138. និងពេលយប់។ ដូច្នេះ តើពួកអ្នកមិនគិតពិចារណាទេឬ?

139. ហើយពិតប្រាកដណាស់ ព្យាការីយូនុស គឺពិតជាស្ថិតក្នុងចំណោមអ្នកនាំសារទាំងឡាយ(របស់អល់ឡោះ)។

140. ខណៈដែលគេបានរត់គេចទៅកាន់សំពៅមួយដែលពោរពេញដោយបន្ទុក។

141. នៅពេលនោះ ពួកគេក៏បានធ្វើការចាប់ឆ្នោត ហើយរូបគេក៏ស្ថិតក្នុងចំណោមអ្នកដែលទទួលបរាជ័យ(រួចក៏ត្រូវគេបោះចូលក្នុងសមុទ្រ)។

142. ពេលនោះ ត្រីដ៏ធំមួយក៏បានលេបគាត់(ចូលទៅក្នុងពោះ) ខណៈដែលគាត់ជាអ្នកដែលត្រូវបានគេស្តីបន្ទោស។

143. ពិតប្រាកដណាស់ ប្រសិនបើរូបគេមិនមែនជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលលើកតម្កើង(ចំពោះអល់ឡោះ)យ៉ាងច្រើនទេនោះ

144. ប្រាកដជារូបគេនឹងត្រូវស្ថិតក្នុងពោះត្រីនោះរហូតដល់ថ្ងៃដែលគេបង្កើតឲ្យរស់ឡើងវិញមិនខានឡើយ។

145. ហើយយើងបានបញ្ចេញគេពីពោះត្រីមកវិញនៅឯវាលរហោស្ថានមួយ ខណៈដែលរូបគេទន់ខ្សោយ។

146. ហើយយើងបានបណ្តុះនូវរុក្ខជាតិមួយដើមជាប្រភេទដើមល្ពៅដល់គេ(ដើម្បីជ្រកម្លប់)។

147. ហើយយើងបានបញ្ជូនគេទៅកាន់ក្រុមដែលមានគ្នាមួយរយពាន់នាក់ ឬច្រើនជាងនោះទៅទៀត។

148. ពេលនោះ ពួកគេក៏មានជំនឿ។ ដូច្នេះ យើងក៏បានឱ្យពួកគេសោយសុខ(ក្នុងជីវិតលោកិយ)រហូតដល់ពេលកំណត់(ស្លាប់)។

149. ដូច្នេះ ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)សួរពួកគេ(ពួកមុស្លីគីន)ថា៖ តើកូនស្រី គឺសម្រាប់ព្រះជាម្ចាស់របស់អ្នក រីឯកូនប្រុសវិញ គឺសម្រាប់ពួកគេឬ?

150. ឬមួយយើងបានបង្កើតម៉ាឡាអ៊ីកាត់ទាំងនោះជាភេទស្រី ខណៈដែលពួកគេមានវត្តមានឬ?

151. តើពុំមែនទេឬ ពិតប្រាកដណាស់ ដោយសារតែការប្រឌិតភូតកុហករបស់ពួកគេ ពួកគេបានចោទប្រកាន់ថា៖

152. អល់ឡោះជាម្ចាស់ទ្រង់ប្រសូត្របុត្រ។ ហើយពិតប្រាកដណាស់ ពួកគេពិតជាពួកដែលភូតកុហក។

153. តើទ្រង់ជ្រើសយកកូនស្រីដោយមិនជ្រើសយកកូនប្រុសឬ?

154. តើមានអ្វីកើតឡើងចំពោះពួកអ្នក(ឱពួកមុស្លីគីន)ទើបបានជាពួកអ្នកហ៊ានកាត់សេចក្តីបែបនេះ?

155. តើពួកអ្នកមិនគិតពិចារណាទេឬ?

156. ឬមួយក៏ពួកអ្នកមានភស្តុតាងច្បាស់លាស់ណាមួយ?

157. បើដូច្នោះមែននោះ ចូរពួកអ្នកនាំយកគម្ពីររបស់ពួកអ្នកនោះមក ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ។

158. ហើយពួកគេ(ពួកមុស្លីគីន)បានចាត់ទុករវាងទ្រង់(អល់ឡោះ)និងពួកម៉ាឡាអ៊ីកាត់ ថាជាសាច់សាលោហិតនឹងគ្នា។ ហើយពិតប្រាកដណាស់ ម៉ាឡាអ៊ីកាត់បានដឹងថា ពួកទាំងនោះពិតជានឹងត្រូវគេនាំទៅកាន់ទណ្ឌកម្ម។

159. អល់ឡោះជាម្ចាស់មហាស្អាតស្អំបំផុតពីអ្វីដែលពួកគេពិពណ៌នា(ចំពោះទ្រង់)។

160. លើកលែងតែខ្ញុំបម្រើរបស់អល់ឡោះដែលមានភាពស្មោះស(ចំពោះទ្រង់)ប៉ុណ្ណោះ។

161. ពិតប្រាកដណាស់ ពួកអ្នក(ឱពួកមុស្លីគីន) និងអ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈនោះ

162. គឺពួកអ្នកពុំមែនជាអ្នកដែលអាចធ្វើឱ្យនរណាម្នាក់វង្វេងនោះឡើយ

163. លើកលែងតែជនណាដែលត្រូវបានកំណត់ឱ្យស្ថិតក្នុងនរកដើហ៊ឹមប៉ុណ្ណោះ។

164. (ម៉ាឡាអ៊ីកាត់បាននិយាយថា៖) ម្នាក់ៗក្នុងចំណោមពួកយើង គឺសុទ្ធតែមានកន្លែងដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់(នៅលើមេឃ)។

165. ហើយពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលឈរជាជួរៗ។

166. ហើយពិតណាស់ ពួកយើងគឺជាអ្នកដែលលើកតម្កើងដល់អល់ឡោះជាម្ចាស់។

167. ហើយពិតប្រាកដណាស់ ពួកគេ(ពួកមុស្លីគីន)ធ្លាប់បាននិយាយថា៖

168. ប្រសិនបើពួកយើងមានគម្ពីរមួយដូចអ្នកជំនាន់មុន

169. ប្រាកដជាពួកយើងនឹងក្លាយជាខ្ញុំបម្រើរបស់អល់ឡោះដែលមានចិត្តស្មោះស(ចំពោះទ្រង់)ជាមិនខាន។

170. តែ(ជាក់ស្តែង)ពួកគេបែរជាប្រឆាំងនឹងវាទៅវិញ។ ដូច្នេះ ពួកគេគង់តែនឹងដឹងមិនខានឡើយ។

171. ហើយពិតណាស់ ពាក្យបន្ទូលរបស់យើងបានកំណត់ចំពោះបណ្តាអ្នកនាំសារទាំងឡាយ(របស់យើង)រួចទៅហើយថា៖

172. ជាការពិតណាស់ ពួកគេជាអ្នកដែលត្រូវបានគេជួយ។

173. ហើយពិតប្រាកដណាស់ កងទ័ពរបស់យើង គឺជាអ្នកដែលទទួលបានជ័យជម្នះ។

174. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ងាកចេញពីពួកគេ រហូតដល់ពេលកំណត់មួយចុះ។

175. ហើយចូរអ្នកមើលទៅពួកគេចុះ។ ពួកគេក៏គង់តែនឹងឃើញ(ទណ្ឌកម្ម)ជាមិនខាន។

176. តើពួកទាំងនោះសុំឱ្យទណ្ឌកម្មរបស់យើងឆាប់កើតឡើងចំពោះពួកគេឬ?

177. ហើយនៅពេលដែលទណ្ឌកម្មរបស់ពួកគេបានធ្លាក់លើពួកគេ វាគឺជាពេលព្រឹកដ៏អាក្រក់បំផុតសម្រាប់ពួកដែលត្រូវគេដាស់តឿនព្រមាន។

178. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ងាកចេញពីពួកគេ រហូតដល់ពេលកំណត់មួយចុះ។

179. ហើយចូរអ្នកមើលទៅពួកគេចុះ។ ពួកគេក៏គង់តែនឹងឃើញ(ទណ្ឌកម្ម)ជាមិនខាន។

180. ព្រះជាម្ចាស់របស់អ្នក ជាព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ ទ្រង់ស្អាតស្អំបំផុតពីអ្វីដែលពួកគេពិពណ៌នា(ចំពោះទ្រង់)។

181. ហើយសូមសន្តិភាពកើតមានដល់បណ្តាអ្នកនាំសារទាំងឡាយ។

182. ហើយសេចក្តីសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

ជំពូក សទ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. សទ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ (អល់ឡោះ)ស្បថនឹងគម្ពីរគួរអានដែលផ្ទុកទៅដោយការរំឭក។

2. ផ្ទុយទៅវិញ ពួកដែលគ្មានជំនឿស្ថិតក្នុងភាពក្រអឺតក្រទម និងប្រឆាំង។

3. មានប្រជាជាតិជំនាន់មុនពួកគេជាច្រើនរួចមកហើយដែលយើងបានបំផ្លាញ។ ពេលនោះ ពួកគេបានស្រែក(សុំការសោរគាពកំហុស) ខណៈដែលពេលនោះពុំមែនជាពេលដែលអាចរួចផុត(ពីទណ្ឌកម្ម)នោះឡើយ។

4. ហើយពួកគេមានការភ្ញាក់ផ្អើលនៅពេលដែលអ្នកដាស់តឿនព្រមានម្នាក់អំពីពួកគេ(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកគេ។ ហើយពួកគ្មានជំនឿបាននិយាយថា៖ ម្នាក់នេះជាគ្រូមន្តអាគម ជាជនដែលកុហកបោកប្រាស់។

5. តើរូបគេចាត់ទុកព្រះដ៏ច្រើនថាជាព្រះតែមួយឬ? ពិតប្រាកដណាស់ នេះពិតជារឿងមួយដ៏ចម្លែក។

6. ហើយពួកមេដឹកនាំនៃពួកគេក៏បានដើរចេញ (ហើយនិយាយថា៖) ចូរពួកអ្នកប្រកាន់ខ្ជាប់ និងអត់ធ្មត់លើ(ការគោរពសក្ការៈ)ព្រះទាំងឡាយរបស់ពួកអ្នកចុះ។ ពិតណាស់ នេះគ្រាន់តែជាអ្វីដែលគេ(ព្យាការីមូហាំម៉ាត់)ចង់បានប៉ុណ្ណោះ។

7. ពួកយើងមិនធ្លាប់បានឮបែបនេះពីសាសនាចុងក្រោយនោះឡើយ។ នេះគ្រាន់តែជាការប្រឌិតកុហកប៉ុណ្ណោះ។

8. តើគេបញ្ចុះគម្ពីរគួរអានឱ្យគាត់(ព្យាការីមូហាំម៉ាត់)ដោយរំលងពួកយើងឬ? ផ្ទុយទៅវិញ ពួកទាំងនោះស្ថិតនៅក្នុងភាពសង្ស័យចំពោះការរំលឹក(វាហ៊ី)របស់យើង។ (ផ្ទុយទៅវិញ)ដោយសារតែពួកគេមិនទាន់បានភ្លក់នូវទណ្ឌកម្ម។

9. ឬមួយក៏ពួកគេមានឃ្លាំងនៃក្តីមេត្តាករុណារបស់ព្រះជាម្ចាស់របស់អ្នកដ៏មហាខ្លាំងពូកែ និងជាអ្នកដែលប្រទានឲ្យ?

10. ឬមួយក៏ពួកគេមានអំណាចគ្រប់គ្រងមេឃជាច្រើននិងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរ? បើដូច្នោះមែននោះ ចូរឱ្យពួកគេរកវិធី(ឡើងទៅលើមេឃចុះ)។

11. ពួកទាំងនោះគឺជាកងទ័ពដែលបរាជ័យ ដូចជាក្រុមអ្នកជំនាន់មុនដូច្នោះដែរ។

12. (អ្នកជំនាន់មុនពួកគេ)បានបដិសេធមុនពួកគេទៅទៀត (ដូចជា)ក្រុមរបស់ព្យាការីនួហ ក្រុមអាទ និងហ្វៀរអោនដែលមានអំណាចខ្លាំងពូកែ

13. ហើយនិងពួកសាមូទ ក្រុមរបស់ព្យាការីលូត ព្រមទាំងក្រុមអែកៈ(ក្រុមព្យាការីស៊ូអែប)។ ពួកទាំងនោះគឺជាក្រុម(ដែលប្រឆាំង)។

14. រាល់ក្រុមទាំងនោះ សុទ្ធតែបានបដិសេធនឹងបណ្តាអ្នកនាំសារ(របស់ពួកគេ)។ ដូច្នេះ ទណ្ឌកម្ម គឺសក្តិសមបំផុត(សម្រាប់ពួកគេ)។

15. ហើយពួកទាំងនោះ ពួកគេគ្មានរង់ចាំអ្វីក្រៅពីសម្រែកតែមួយប៉ុណ្ណោះ ដោយគ្មានការត្រឡប់ក្រោយនោះឡើយ។

16. ហើយពួកគេបាននិយាយ(ផ្តើន)ថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាផ្តល់ឱ្យមួយចំណែកអំពីទណ្ឌកម្ម ដល់ពួកយើងភ្លាមៗមុននឹងថ្ងៃជំនុំជម្រះមកដល់ផង។

17. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចំពោះអ្វីដែលពួកគេនិយាយ។ ហើយចូរអ្នករំឭកអំពី(រឿងរ៉ាវ)ខ្ញុំបម្រើរបស់យើង ព្យាការីហ្សាវូទ ដែលជាអ្នកមានអំណាចខ្លាំងក្លា។ ពិតប្រាកដណាស់ រូបគេជាអ្នកដែលសារភាពកំហុសច្រើនបំផុត(ចំពោះអល់ឡោះ)។

18. ពិតប្រាកដណាស់ យើងបានឱ្យភ្នំឱ្យទាំងឡាយលើកតម្កើង(មកចំពោះយើង)ជាមួយនឹងរូបគេ(ព្យាការីហ្សាវូទ)ទាំងពេលល្ងាច និងទាំងពេលព្រឹក។

19. (ហើយយើងក៏បានឱ្យ)សត្វបក្សីទាំងឡាយប្រមូលផ្តុំគ្នា(លើកតម្កើងមកចំពោះយើងជាមួយគេ)ផងដែរ ដោយពួកវាទាំងអស់សុទ្ធតែគោរពតាមគេ(ព្យាការីហ្សាវូទ)។

20. ហើយយើងបានពង្រឹងអំណាចរបស់គេ និងបានប្រទានឱ្យគេនូវភាពជាព្យាការី និងការចេះវិនិច្ឆ័យយ៉ាងច្បាស់លាស់។

21. តើដំណឹងនៃជម្លោះ(រវាងបុរសពីរនាក់)នៅពេលដែលគេទាំងពីរបានផ្លោះរបង(ចូលទៅ)កន្លែងគោរពសក្ការៈ(របស់ព្យាការីហ្សាវូទ)នោះបានមកដល់អ្នកដែរទេ(ឱអ្នកនាំសារមូហាំម៉ាត់)?

22. ខណៈដែលគេទាំងពីរបានចូលទៅកាន់ព្យាការីហ្សាវូទ ពេលនោះ គាត់មានការភិតភ័យអំពីពួកគេ។ ពួកគេក៏និយាយថា៖ សូមអ្នកកុំខ្លាច! (ពួកយើងទាំងពីរ)គឺជាគូជម្លោះនឹងគ្នាដោយសារតែម្នាក់នៃពួកយើងបានបំពានទៅលើម្នាក់ទៀត។ ដូចនេះ សូមអ្នកមេត្តាកាត់សេចក្តីរវាងពួកយើងដោយត្រឹមត្រូវផង ហើយសូមកុំឱ្យមានភាពអយុត្តិធម៌កើតឡើង និងសូមចង្អុលបង្ហាញពួកយើងទៅកាន់មាគ៌ាដែលត្រឹមត្រូវផងចុះ។

23. ពិតប្រាកដណាស់ នេះគឺជាបងប្អូនរបស់ខ្ញុំ។ គាត់មានពពែញីចំនួនកៅសិបប្រាំបួនក្បាល ចំណែកឯខ្ញុំវិញ មានពពែញីតែមួយក្បាលគត់។ ហើយគាត់បាននិយាយថា៖ សូមអ្នកប្រគល់វាឱ្យខ្ញុំ។ ហើយគាត់ប៉ិនប្រសព្វក្នុងការនិយាយស្តី(ពូកែលើកអំណះអំណាង)ជាងខ្ញុំ។

24. គាត់(ព្យាការីហ្សាវូទ)ក៏បានពោលថា៖ ពិតប្រាកដណាស់ បងប្អូនរបស់អ្នកបានបំពានលើអ្នកហើយ ខណៈដែលគាត់បានសុំឱ្យអ្នកប្រគល់ពពែញីរបស់អ្នកទៅឱ្យគាត់ថែមទៀតនោះ។ ហើយភាគច្រើននៃអ្នកដែលចូលហ៊ុនគ្នា គឺតែងតែបំពានលើគ្នាទៅវិញទៅមក លើកលែងតែបណ្តាអ្នកមានជំនឿ និងបានសាងនូវទង្វើកុសលប៉ុណ្ណោះ។ ក៏ប៉ុន្តែពួកគេមានតិចតួចណាស់។ ក្រោយមក គាត់បានដឹងច្បាស់ថា តាមពិតយើង(អល់ឡោះ)គ្រាន់តែសាកល្បងលើគេប៉ុណ្ណោះ។ ពេលនោះ គេក៏បានសុំការអភ័យទោសពីព្រះជាម្ចាស់របស់គេ ហើយបានក្រាបស៊ូជូត និងសារភាពកំហុស(ចំពោះទ្រង់)។

25. ពេលនោះ យើងក៏បានអភ័យទោសដល់គេចំពោះរឿងនោះ។ ហើយពិតណាស់ រូបគេគឺជាអ្នកដែលមានឋានៈជិតបំផុតចំពោះយើង និងមានកន្លែងវិលត្រឡប់ដ៏ប្រសើរបំផុត(នៅថ្ងៃបរលោក)។

26. ឱហ្សាវូទ! ពិតប្រាកដណាស់ យើងបានតែងតាំងអ្នកឱ្យធ្វើជាអ្នកគ្រប់គ្រងនៅលើផែនដី។ ហេតុនេះ ចូរអ្នកកាត់ក្តីរវាងមនុស្សលោកដោយយុត្តិធម៌ និងមិនត្រូវធ្វើតាមទំនើងចិត្តរបស់អ្នកដែលជាហេតុធ្វើឱ្យអ្នកវង្វេងចេញពីមាគ៌ារបស់អល់ឡោះនោះឡើយ។ ពិតប្រាកដណាស់ ពួកដែលវង្វេងចេញពីមាគ៌ារបស់អល់ឡោះ សម្រាប់ពួកគេនឹងទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតដោយសារតែពួកគេភ្លេចថ្ងៃជំនុំជម្រះ។

27. ហើយយើងមិនបានបង្កើតមេឃនិងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរដោយឥតប្រយោជន៍នោះឡើយ។ នោះគឺជាការគិតស្មានរបស់ពួកប្រឆាំងប៉ុណ្ណោះ។ ដូច្នេះ ភាពអន្តរាយនៃឋាននរក គឺសម្រាប់ពួកប្រឆាំង។

28. តើយើងចាត់ទុកបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលដូចគ្នាទៅនឹងពួកដែលបង្កវិនាសកម្មនៅលើផែនដី ឬក៏ចាត់ទុកបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)ដូចទៅនឹងពួកដែលប្រព្រឹត្តបាបកម្មឬ?

29. (គម្ពីរគួរអាននេះ)ជាគម្ពីរមួយដែលយើងបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែលប្រកបដោយពរជ័យ ដើម្បីឱ្យពួកគេត្រិះរិះពិចារណាចំពោះបណ្តាវាក្យខណ្ឌទាំងឡាយរបស់វា និងដើម្បីឱ្យបណ្តាបញ្ញាជនទាំងឡាយឈ្វេងយល់។

30. ហើយយើងបានប្រទានឱ្យព្យាការីហ្សាវូទនូវព្យាការីសូឡៃម៉ាន។ រូបគេ(ព្យាការីស៊ូឡៃម៉ាន)ជាខ្ញុំបម្រើដ៏ល្អម្នាក់។ ពិតណាស់ រូបគេគឺជាអ្នកដែលតែងតែសារភាពកំហុស(ចំពោះអល់ឡោះ)។

31. (ចូរអ្នកនឹកឃើញ)នៅពេលដែលគេបានបង្ហាញឱ្យគាត់(ព្យាការីស៊ូឡៃម៉ាន)បានឃើញនៅពេលរសៀលនូវសេតសេះដែលរត់លឿនដែលអាចឈរជើងបី ហើយលើកជើងមួយបាន។

32. ពេលនោះ គាត់បាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំបានផ្តល់អាទិភាពលើការស្រលាញ់របស់ល្អ(សត្វសេះ)ជាងការរំឭកចំពោះព្រះជាម្ចាស់របស់ខ្ញុំ រហូតដល់ថ្ងៃបានលិច(ធ្វើឱ្យខ្ញុំខកខានមិនបានសឡាតអាសើរ)។

33. ចូរពួកអ្នកនាំសេះនោះត្រឡប់មកកាន់យើងវិញ។ ពេលនោះ គាត់ក៏បានកាប់ជើង និងកសេះនោះនឹងផ្លែដាវ។

34. ហើយពិតប្រាកដណាស់ យើង(អល់ឡោះ)បានសាកល្បងព្យាការីស៊ូឡៃម៉ាន ហើយយើងបានដាក់រូបកាយមួយនៅលើបល្ល័ង្ក(កៅអីស្តេច)របស់គេ។ ក្រោយមក គេក៏បានសារភាពកំហុស(មកចំពោះយើង)។

35. គេបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាអភ័យទោសដល់រូបខ្ញុំផងចុះ ហើយសូមព្រះអង្គមេត្តាប្រទាននូវអំណាច(ជាពិសេស)ដល់ខ្ញុំដែលគ្មាននរណាម្នាក់អាចទទួលបានវាបន្ទាប់ពីខ្ញុំឡើយ។ ពិតប្រាកដណាស់ ព្រះអង្គគឺជាអ្នកដែលប្រទានដ៏លើសលប់បំផុត។

36. ហើយយើងបានសម្រួលដល់គេដោយឲ្យខ្យល់បក់បោកបានយ៉ាងល្អទៅតាមបទបញ្ជារបស់គេដោយអាចនាំរូបគេទៅកាន់ទីណាដែលគេប្រាថ្នា។

37. ហើយចំពោះស្មៃតន(ក៏ដូចគ្នាដែរ)។ ក្នុងចំណោមពួកវា មានអ្នកដែលសាងសង់ មានអ្នកដែលជ្រមុជទឹក(រាវរកវត្ថុមានតម្លៃក្នុងសមុទ្រឱ្យព្យាការីស៊ូឡៃម៉ាន)។

38. ហើយមានក្រុមផ្សេងទៀត គឺត្រូវបានដាក់ច្រវាក់ជាប់។

39. នេះគឺជាការប្រទានរបស់យើង(ដែលបានប្រទានដល់អ្នក)។ ដូច្នេះ ចូរអ្នកផ្តល់វា ឬមិនផ្តល់វា(ចំពោះជនណាដែលអ្នកប្រាថ្នាចុះ) ដោយអ្នកមិនត្រូវបានគេយកទោសពៃរ៍អ្វីឡើយ។

40. ហើយពិតប្រាកដណាស់ រូបគេគឺជាអ្នកដែលមានឋានៈជិតបំផុតចំពោះយើង និងមានកន្លែងវិលត្រឡប់ដ៏ប្រសើរបំផុត(នៅថ្ងៃបរលោក)។

41. ហើយចូរអ្នករំឭកអំពី(រឿង)ខ្ញុំបម្រើរបស់យើង ព្យាការីអ៊ីយ៉ូប នៅពេលដែលគេបានបួងសួងទៅកាន់ព្រះជាម្ចាស់របស់គេថា៖ ពិតប្រាកដណាស់ ស្មៀនជាមូលហេតុធ្វើឱ្យខ្ញុំលំបាក និងឈឺចាប់។

42. (យើងក៏បានមានបន្ទូលថា៖) ចូរអ្នកទន្ត្រាំជើងរបស់អ្នកនឹងដីចុះ។ នេះជាទឹកត្រជាក់សម្រាប់ងូត និងផឹក(ព្យាបាលជំងឺរបស់អ្នក)។

43. ហើយយើងបានប្រទានឱ្យគេនូវក្រុមគ្រួសាររបស់គេវិញ ព្រមទាំងបានបន្ថែមលើសពីនោះដល់រូបគេថែមទៀត ជាក្តីមេត្តាករុណាអំពីយើង និងជាការដាស់រំលឹកសម្រាប់បញ្ញាជនទាំងឡាយ។

44. (យើងបានមានបន្ទូលថា៖) ចូរអ្នក(ព្យាការីអ៊ីយ៉ូប)យកស្មៅមួយកណ្តាប់ដៃរួចវាយ(ទៅលើភរិយាអ្នក)ចុះ ហើយចូរអ្នកកុំបំពានពាក្យសម្បថ។ ពិតប្រាកដណាស់ យើងបានឃើញរូបគេជាអ្នកដែលអត់ធ្មត់។ (រូបគេ)ជាខ្ញុំបម្រើដ៏ល្អប្រពៃម្នាក់។ ពិតប្រាកដណាស់ រូបគេគឺជាអ្នកដែលតែងតែសារភាពកំហុស(ចំពោះអល់ឡោះ)។

45. ហើយចូរអ្នករំឭកអំពី(រឿង)ខ្ញុំបម្រើទាំងឡាយរបស់យើង គឺព្យាការីអ៊ីព្រហ៊ីម ព្យាការីអ៊ីស្ហាក និងព្យាការីយ៉ាក់កូប។ ពួកគេជាអ្នកដែលមានភាពខ្លាំងក្លា និងមានប្រាជ្ញាឈ្លាសវៃ។

46. ពិតប្រាកដណាស់ យើងបានប្រទានឱ្យពួកគេជាពិសេសដោយឱ្យជួងចិត្តរបស់ពួកគេគិតគូរជានិច្ចចំពោះថ្ងៃបរលោក។

47. ហើយពិតប្រាកដណាស់ ពួកគេស្ថិតក្នុងចំណោមបណ្តាអ្នកដែលយើងបានជ្រើសរើស(ជាអ្នកនាំសារ និងជាអ្នកដែលគោរពប្រតិបត្តិ)។

48. ហើយចូរអ្នករំឭកអំពី(រឿង)ព្យាការីអ៊ីស្មាអែល ព្យាការីអ៊ិលយ៉ាសាក់ និងព្យាការីហ្ស៊ុលគីហ្វលី។ រាល់អ្នកទាំងនោះ គឺសុទ្ធតែស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេជ្រើសរើស។

49. នេះគឺជាការរំលឹក(នៅក្នុងគម្ពីគួរអាន)។ ហើយពិតប្រាកដណាស់ សម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ពិតជានឹងទទួលបាននូវកន្លែងវិលត្រឡប់ដ៏ល្អប្រពៃ។

50. គឺឋានសួគ៌អាត់និនដែលបណ្តាទ្វារទាំងឡាយរបស់វាត្រូវបានគេបើកសម្រាប់(ទទួលស្វាគមន៍)ពួកគេ។

51. ពួកគេទម្រេតខ្លួន(លើគ្រែ)ក្នុងឋានសួគ៌នោះ។ ពួកគេស្នើសុំ(ពីអ្នកបម្រើ)នូវផ្លែឈើ និងភេសជ្ជៈជាច្រើនប្រភេទនៅក្នុងវា។

52. ហើយពួកគេមានស្ត្រីទេពអប្សរជាច្រើនដែលមិនសម្លឹងទៅកាន់បុរសណាក្រៅពីស្វាមីរបស់ពួកនាងនោះឡើយ ហើយពួកនាងមានអាយុស្មើៗគ្នា។

53. នេះគឺជាអ្វីដែលគេបានសន្យាចំពោះពួកអ្នក(អ្នកដែលកោតខ្លាច)ក្នុងថ្ងៃជំនុំជម្រះ។

54. ពិតប្រាកដណាស់ នេះគឺជាលាភសក្ការៈរបស់យើង។ វាគ្មានទីបញ្ចប់នោះឡើយ។

55. ទាំងនេះ(គឺជាការតបស្នងសម្រាប់អ្នកដែលកោតខ្លាច)។ រីឯសម្រាប់ពួកដែលបំពានវិញនឹងទទួលបានកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

56. គឺនរកដើហាន់ណាំដែលហ៊ុមព័ទ្ធពួកគេ។ ពិតណាស់ វាជាកន្លែងដ៏អាក្រក់បំផុត។

57. នេះគឺជាទឹកដ៏ក្តៅបំផុត ហើយនិងខ្ទុះឈាម។ ដូច្នេះ ចូរឱ្យពួកគេភ្លក់វាចុះ។

58. ហើយទណ្ឌកម្មផ្សេងទៀតក៏មានលក្ខណៈស្រដៀងនឹងទណ្ឌកម្មនេះដែរ។

59. (ពួកឋាននរកបានប្រកែកគ្នាថា៖) នេះគឺជាក្រុមមួយដែលបានចូលឋាននរកជាមួយពួកអ្នក។ (អ្នកទាំងនោះក៏បានឆ្លើយតបវិញថា៖) គ្មានការស្វាគមន៍អ្វីចំពោះពួកគេឡើយ។ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលត្រូវចូលឋាននរក។

60. ពួកគេក៏បាននិយាយ(ទៅកាន់មេដឹកនាំរបស់ខ្លួន)ថា៖ ផ្ទុយទៅវិញ ពួកអ្នកទៅវិញទេដែលគ្មានការស្វាគមន៍អ្វីសម្រាប់ពួកអ្នកនោះ។ ពួកអ្នកជាមូលហេតុនាំឱ្យពួកយើងត្រូវទទួលទណ្ឌកម្មនេះ។ ពិតប្រាកដណាស់ វាជាកន្លែងស្នាក់អាស្រ័យដ៏អាក្រក់បំផុត។

61. ពួកគេ(ពួកដែលដើរតាមគេ)បានបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ជនណាដែលធ្វើឲ្យយើងខ្ញុំវង្វេង សូមព្រះអង្គមេត្តាដាក់ទណ្ឌកម្មទ្វេដងដល់រូបគេផងចុះនៅក្នុងឋាននរកនេះ។

62. ហើយពួកគេ(ពួកដែលក្រអឺតក្រទម)បាននិយាយថា៖ ហេតុអ្វីបានជាពួកយើងមិនឃើញពួកបុរសៗដែលពួកយើងធ្លាប់បានចាត់ទុកពួកគេថាជាពួកមនុស្សអាក្រក់នោះ(ស្ថិតក្នុងឋាននរកជាមួយពួកយើង)?

63. តើការដែលពួកយើងមើលងាយពួកគេនោះខុស ឬមួយ(ពួកគេស្ថិតចូលឋាននរកហើយ)គ្រាន់តែពួកយើងមិនបានឃើញពួកគេ?

64. ពិតប្រាកដណាស់ ការប្រកែកគ្នារបស់ពួកឋាននរកនោះ គឺជារឿងពិត។

65. ចូរអ្នក(ឱព្យាការីមូហាំម៉ាត់)ពោលថា៖ តាមពិត ខ្ញុំគ្រាន់តែជាអ្នកដាស់តឿនព្រមានម្នាក់ប៉ុណ្ណោះ។ ហើយគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះជាម្ចាស់តែមួយគត់ដែលមហាខ្លាំងពូកែនោះឡើយ។

66. (ទ្រង់)ជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់ និងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរ ជាអ្នកដែលមហាខ្លាំងពូកែ មហាអភ័យទោសបំផុត។

67. ចូរអ្នក(អ្នកនាំសារឱមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន)គឺជាដំណឹងដ៏ធំធេង។

68. តែពួកអ្នកបែរជាងាកចេញពីគម្ពីរនេះទៅវិញ។

69. ខ្ញុំគ្មានចំណេះដឹងអ្វីពីរឿងប្រកែកគ្នារបស់ម៉ាឡាអ៊ីកាត់ដែលនៅលើមេឃនោះឡើយ។

70. តាមពិតគេផ្តល់វ៉ាហ៊ីមកកាន់ខ្ញុំនេះ គឺដោយសារតែខ្ញុំជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់ប៉ុណ្ណោះ។

71. ហើយ(ចូរអ្នករំលឹក)នៅពេលដែលព្រះជាម្ចាស់របស់អ្នកបានមានបន្ទូលទៅកាន់ពួកម៉ាឡាអ៊ីកាត់ថា៖ ពិតប្រាកដណាស់ យើងជាអ្នកបង្កើតមនុស្សម្នាក់ពីដីឥដ្ឋ(គឺព្យាការីអាដាំ)។

72. ហើយនៅពេលដែលយើងធ្វើឱ្យគេមានរូបរាងសមសួន និងបានផ្លុំបញ្ចូលវិញ្ញាណរបស់យើងទៅក្នុងខ្លួនគេហើយនោះ ចូរពួកអ្នក(ម៉ាឡាអ៊ីកាត់)ឱនស៊ូជូតចំពោះគេចុះ។

73. ពេលនោះ ម៉ាឡាអ៊ីកាត់ទាំងអស់ក៏បានឱនស៊ូជូតចំពោះគេ

74. លើកលែងតែអ៊ីព្លីសប៉ុណ្ណោះដែលក្រអឺតក្រទម(មិនព្រមស៊ូជូត)ហើយវាក៏បានស្ថិតក្នុងចំណោមពួកដែលប្រឆាំង។

75. ទ្រង់បានមានបន្ទូលថា៖ នែអ៊ីព្លីស! តើអ្វីដែលរារាំងឯងមិនឱ្យស៊ូជូតទៅចំពោះអ្វីដែលយើងបានបង្កើតដោយព្រះហស្តទាំងពីររបស់យើងនោះ? តើឯងក្អេងក្អាង ឬក៏ឯងស្ថិតក្នុងចំណោមអ្នកដែលក្រអឺតក្រទម?

76. វាបានឆ្លើយថា៖ ខ្ញុំល្អជាងរូបគេ(ព្យាការីអាហ្សាំ)។ ព្រះអង្គបង្កើតរូបខ្ញុំអំពីភ្លើង តែព្រះអង្គបានបង្កើតរូបគេពីដីឥដ្ឋប៉ុណ្ណោះ។

77. ទ្រង់បានមានបន្ទូលថា៖ ដូច្នេះ ចូរឯងចាកចេញពីទីនេះចុះ។ ពិតប្រាកដណាស់ ឯងត្រូវបានគេដាក់បណ្តាសាហើយ។

78. ហើយពិតប្រាកដណាស់ ឯងត្រូវទទួលនូវបណ្តាសាអំពីយើង រហូតដល់ថ្ងៃបរលោក។

79. វាបានតបថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាពន្យារពេលដល់រូបខ្ញុំ រហូតដល់ថ្ងៃដែលពួកគេត្រូវបានគេបង្កើតឱ្យរស់ឡើងវិញផងចុះ។

80. ទ្រង់បានតបថា៖ ពិតប្រាកដណាស់ រូបឯងស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេពន្យារពេលឲ្យ

81. រហូតដល់ថ្ងៃដែលត្រូវបានគេកំណត់យ៉ាងច្បាស់លាស់។

82. វាបាននិយាយថា៖ ជាការពិតណាស់ ខ្ញុំសូមស្បថនឹងភាពខ្លាំងពូកែរបស់ព្រះអង្គថា៖ ពិតប្រាកដណាស់ ខ្ញុំប្រាកដជានឹងធ្វើឱ្យពួកគេ(កូនចៅព្យាការីអាហ្សាំ)ទាំងអស់វង្វេងជាមិនខាន។

83. លើកលែងតែខ្ញុំបម្រើរបស់ព្រះអង្គដែលមានចិត្តស្មោះសក្នុងចំណោមពួកគេប៉ុណ្ណោះ។

84. ទ្រង់បានតបថា៖ ពិតប្រាកដណាស់ ការពិត(គឺមកអំពីយើង)ហើយបន្ទូលរបស់យើង គឺជាការពិតដែលថា៖

85. យើងពិតជានឹងបំពេញនរកជើហាន់ណាំដោយរូបឯង និងអ្នកដែលដើរតាមឯងក្នុងចំណោមពួកគេ(កូនចៅព្យាការីអាហ្សាំ)ទាំងអស់គ្នា។

86. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំមិនបានស្នើសុំកម្រៃអ្វីពីពួកអ្នកចំពោះវា(ការអំពាវនាវ)នោះឡើយ ហើយខ្ញុំក៏មិនមែនស្ថិតនៅក្នុងចំណោមពួកដែលប្រឌិតបន្ថែមនោះដែរ។

87. គម្ពីរនេះ(គម្ពីរគួរអាន)គ្មានអ្វីក្រៅពីជាការដាស់រំឭកដល់ពិភពទាំងឡាយនោះឡើយ។

88. ហើយពួកអ្នក(ឱពួកមុស្លីគីន)ប្រាកដជានឹងបានដឹងពីដំណឹងរបស់គម្ពីរនេះ(គម្ពីរគួរអាន)ក្រោយពីពេលនេះតទៅ។

ជំពូក អាសហ្ស៊ូមើរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការបញ្ចុះគម្ពីរ(គួរអាន)គឺមកពីអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

2. ពិតប្រាកដណាស់ យើងបានបញ្ចុះទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរ(គួរអាន)យ៉ាងពិតប្រាកដ។ ហេតុនេះ ចូរអ្នកគោរពសក្ការៈចំពោះអល់ឡោះប្រកបដោយភាពស្មោះសចំពោះទ្រង់ក្នុងសាសនា។

3. តើពុំមែនទេឬ សាសនាដែលបរិសុទ្ធ(សាសនាអ៊ីស្លាម)គឺជាកម្មសិទ្ធិរបស់អល់ឡោះនោះ? ហើយពួកដែលយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាអ្នកគាំពារ(ពួកគេនិយាយថាៈ)ពួកយើងមិនបានគោរពសក្ការៈចំពោះពួកវានោះឡើយ លើកលែងតែដើម្បីឱ្យពួកវាបញ្ជិតខ្លួនពួកយើងឱ្យមានឋានៈនៅជិតអល់ឡោះប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងកាត់សេចក្តីរវាងពួកគេចំពោះអ្វីដែលពួកគេមានការខ្វែងគំនិតគ្នា។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មិនចង្អុលបង្ហាញចំពោះជនដែលកុហកបោកប្រាស់ និងប្រឆាំងឡើយ។

4. ប្រសិនបើអល់ឡោះចង់យកនរណាម្នាក់ធ្វើជាបុត្រនោះ ទ្រង់ប្រាកដជានឹងជ្រើសរើសក្នុងចំណោមអ្វីដែលទ្រង់បានបង្កើតនូវអ្វីដែលទ្រង់មានចេតនាជាមិនខាន។ ទ្រង់មហាស្អាតស្អំ។ អល់ឡោះទ្រង់គឺជាព្រះជាម្ចាស់តែមួយ មហាខ្លាំងក្លាបំផុត។

5. ទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដីយ៉ាងពិតប្រាកដ។ ទ្រង់បញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ និងបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយទ្រង់បញ្ជាព្រះអាទិត្យ និងព្រះចន្ទដោយឱ្យវាទាំងពីរធ្វើដំណើរ(តាមគន្លងរៀងៗខ្លួន)រហូតដល់ពេលវេលាដែលត្រូវបានកំណត់។ តើពុំមែនទេឬ ទ្រង់មហាខ្លាំងពូកែ មហាអភ័យទោសបំផុត។

6. ទ្រង់បានបង្កើតពួកអ្នកពីមនុស្សតែម្នាក់(ព្យាការីអាហ្សាំ)។ បន្ទាប់មកទ្រង់បានបង្កើតចេញពីរូបគេនូវភរិយារបស់គេ(ហាវ៉ា)។ ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវសត្វពាហនៈចំនួនប្រាំបីគូ។ ទ្រង់បង្កើតពួកអ្នកនៅក្នុងផ្ទៃម្តាយរបស់ពួកអ្នកជាំណាក់កាលៗដោយស្ថិតក្នុងទីងងឹតបី(ពោះ ស្បូន និងសុក)។(អ្នកដែលបង្កើតអ្វីៗទាំងអស់)នោះគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក។ ការគ្រប់គ្រងទាំងអស់គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

7. ប្រសិនបើពួកអ្នក(ឱមនុស្សលោកទាំងឡាយ)ប្រឆាំងនោះ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាមានលើសលប់មិនត្រូវការពួកអ្នកឡើយ។ តែទ្រង់ក៏មិនពេញចិត្តឱ្យខ្ជុំបម្រើ(របស់ទ្រង់)ប្រឆាំងនោះដែរ។ ហើយប្រសិនបើពួកអ្នកដឹងគុណ គឺទ្រង់ពេញចិត្តចំពោះពួកអ្នក។ ហើយគ្មានបុគ្គលណាម្នាក់ប៉ាប់វេនូវបាបកម្មរបស់អ្នកដទៃឡើយ។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកអ្នក គឺឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់ពួកអ្នក(តែមួយគត់)។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។ ពិតប្រាកដណាស់ ទ្រង់មហាដឹងបំផុតនូវអ្វីដែលនៅក្នុងចិត្ត។

8. ហើយនៅពេលដែលមនុស្សបានជួបប្រទះនឹងគ្រោះ គឺរូបគេបួងសួងទៅកាន់ព្រះជាម្ចាស់របស់គេដោយវិលត្រឡប់(សារភាពកំហុស)ទៅកាន់ទ្រង់។ បន្ទាប់មក នៅពេលដែលទ្រង់ប្រទានឱ្យគេនូវឧបការគុណ រូបគេបែរជាភ្លេចនូវអ្វីដែលរូបគេបានបួងសួងទៅកាន់ទ្រង់កាលពីមុន ហើយថែមទាំងបានបង្កើតនូវដៃគូជាច្រើនសម្រាប់អល់ឡោះជាម្ចាស់ដើម្បីធ្វើឱ្យអ្នកដទៃវង្វេងពីមាគ៌ារបស់ទ្រង់ទៅវិញ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ ចូរអ្នកសោយសុខជាមួយនឹងភាពគ្មានជំនឿរបស់អ្នកមួយរយៈពេលខ្លីសិនចុះ។ ពិតប្រាដកណាស់ អ្នកគឺស្ថិតក្នុងចំណោមពួកឋាននរក។

9. តើអ្នកដែលគោរពសក្ការៈ(ចំពោះអល់ឡោះ)ដោយចំណាយពេលយប់របស់គេក្រាបស៊ូជូត និងឈរ(សឡាត)ដោយខ្លាច(ទណ្ឌកម្ម)ថ្ងៃបរលោក ហើយរំពឹងក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់គេនោះ(ល្អជាង ឬក៏ពួកប្រឆាំងល្អជាង)? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើស្មើគ្នាដែរឬទេរវាងអ្នកដែលបានដឹង និងអ្នកដែលមិនបានដឹង? តាមពិត មានតែបញ្ញាជនប៉ុណ្ណោះដែលចេះពិចារណា។

10. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ឱបណ្តាខ្ញុំបម្រើ(របស់អល់ឡោះ)ដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចព្រះជាម្ចាស់របស់ពួកអ្នក។ សម្រាប់បណ្តាអ្នកដែលសាងអំពើល្អក្នុងលោកិយនេះនឹងទទួលបានផលល្អ។ ហើយផែនដីរបស់អល់ឡោះ គឺទូលំទូលាយណាស់។ តាមពិត គេនឹងប្រទានឲ្យបណ្តាអ្នកដែលអត់ធ្មត់ទាំងឡាយនូវផលបុណ្យរបស់ពួកគេយ៉ាងពេញលេញដោយឥតគណនា។

11. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពិតប្រាកដណាស់ រូបខ្ញុំត្រូវបានគេបង្គាប់ប្រើឲ្យគោរពសក្ការៈទៅចំពោះអល់ឡោះ(តែមួយគត់)ប្រកបដោយចិត្តស្មោះចំពោះទ្រង់ក្នុងសាសនា។

12. ហើយគេក៏បានបង្គាប់ប្រើខ្ញុំឲ្យក្លាយជាអ្នកដែលកាន់សាសនាអ៊ីស្លាមដំបូងគេបង្អស់ផងដែរ។

13. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ ខ្ញុំខ្លាចទទួលទណ្ឌកម្មនៅថ្ងៃដ៏ធំធេង(ថ្ងៃបរលោក)ប្រសិនបើខ្ញុំប្រព្រឹត្តល្មើសនឹងព្រះជាម្ចាស់របស់ខ្ញុំ។

14. ចូរអ្នកពោលទៀតថា៖ ខ្ញុំគោរពសក្ការៈទៅចំពោះអល់ឡោះជាម្ចាស់(តែមួយគត់)ប្រកបដោយចិត្តស្មោះសចំពោះទ្រង់ក្នុងសាសនារបស់ខ្ញុំ។

15. ដូច្នេះ ចូរពួកអ្នក(ឱពួកមុស្លីគីន)គោរពសក្ការៈចំពោះអ្វីដែលពួកអ្នកចង់ក្រៅពីទ្រង់ចុះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ ពួកដែលខាតបង់(ពិតប្រាកដ)នោះ គឺពួកដែលខាតបង់ខ្លួនឯងនិងក្រុមគ្រួសាររបស់ខ្លួននៅថ្ងៃបរលោក។ តើមិនមែនទេឬដែលថា នោះគឺជាការខាតបង់យ៉ាងច្បាស់លាស់នោះ?

16. នៅពីលើពួកគេនិងនៅពីក្រោមពួកគេ គឺមានពពកនៃភ្លើងនរក។ នោះជាអ្វីដែលអល់ឡោះបន្លាចវាដល់ខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ឱបណ្តាខ្ញុំបម្រើទាំងឡាយ(របស់យើង)! ចូរពួកអ្នកកោតខ្លាចមកចំពោះយើងចុះ។

17. រីឯបណ្តាអ្នកដែលបានចៀសឆ្ងាយពីតហ្ងូតដោយមិនគោរពសក្ការៈចំពោះវា ព្រមទាំងសារភាពកំហុសចំពោះអល់ឡោះនោះ សម្រាប់ពួកគេនឹងទទួលបាននូវដំណឹងរីករាយ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយនេះដល់បណ្តាខ្ញុំបម្រើទាំងឡាយ(របស់យើង)ចុះ។

18. គឺបណ្តាអ្នកដែលស្តាប់នូវពាក្យសម្តីទាំងឡាយ ហើយពួកគេធ្វើតាមនូវពាក្យសម្តីដែលល្អបំផុត(បន្ទូលរបស់អល់ឡោះនិងប្រសាសន៍អ្នកនាំសាររបស់ទ្រង់)អ្នកទាំងនោះហើយ គឺជាអ្នកដែលអល់ឡោះទ្រង់ចង្អុលបង្ហាញដល់ពួកគេ ហើយអ្នកទាំងនោះហើយ គឺជាអ្នកដែលមានសតិបញ្ញាល្អប្រពៃ។

19. ចំពោះអ្នកដែលពាក្យពេចន៍ទណ្ឌកម្មត្រូវបានកំណត់ទៅលើរូបគេហើយនោះ ដូច្នេះ តើរូបអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អាចសង្គ្រោះអ្នកដែលស្ថិតក្នុងឋាននរកបានឬ?

20. ផ្ទុយទៅវិញ បណ្ដាអ្នកដែលកោតខ្លាចព្រះជាម្ចាស់របស់ពួកគេ សម្រាប់ពួកគេនឹងទទួលបានវិមានជាច្រើនសង់ពីលើគ្នាដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាផងដែរ។ ជាការសន្យារបស់អល់ឡោះ។ អល់ឡោះជាម្ចាស់មិនក្បត់ពាក្យសន្យាឡើយ។

21. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចោះទឹកភ្លៀងពីលើមេឃ ហើយទ្រង់បានបញ្ចូលវាទៅក្នុងដីកើតជាប្រភពទឹក។ បន្ទាប់មក តាមរយៈវា ទ្រង់បានបញ្ចេញនូវដំណាំដាំដុះដែលមានពណ៌ខុសៗគ្នា។ ក្រោយមក ទ្រង់បានធ្វើឱ្យដំណាំនោះប្រែទៅជាស្ងួតដោយអ្នកបានឃើញវាមានពណ៌លឿង។ រួចមក ទ្រង់ក៏បានឱ្យវាខ្ទេចខ្ទី។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាការដាស់តឿនសម្រាប់បញ្ញាជនទាំងឡាយ។

22. តើអ្នកដែលអល់ឡោះបើកចិត្តរបស់គេឱ្យទទួលយកអ៊ីស្លាម ហើយរូបគេស្ថិតនៅលើពន្លឺពីព្រះជាម្ចាស់របស់គេនោះ(ដូចគ្នានឹងអ្នកដែលមិនមានលក្ខណៈបែបនេះឬ)? ពិតប្រាកដណាស់ ភាពអន្តរាយ គឺសម្រាប់ពួកដែលចិត្តរបស់ពួកគេរឹងរូសពីការរំឭកចំពោះអល់ឡោះ។ ពួកទាំងនោះគឺស្ថិតក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

23. អល់ឡោះជាម្ចាស់ទ្រង់បានបញ្ចុះនូវបន្ទូលដ៏ល្អប្រពៃជាទីបំផុត(គម្ពីរគួរអាន)ជាគម្ពីរមួយដែលមានលក្ខណៈស្រដៀងគ្នាដោយមានរៀបរាប់នូវបញ្ហាផ្សេងៗ។ ស្បែករបស់បណ្ដាអ្នកដែលខ្លាចព្រះជាម្ចាស់របស់ពួកគេ ព្រឺញាប់ញ័រនៅពេលដែលបានឮគម្ពីរនេះ។ ក្រោយមក ស្បែក និងចិត្តរបស់ពួកគេប្រែទន់ទៅកាន់ការរំលឹកចំពោះអល់ឡោះ។ នោះគឺជាការចង្អុលបង្ហាញរបស់អល់ឡោះដែលទ្រង់ចង្អុលបង្ហាញនឹងគម្ពីរនេះចំពោះជនណាដែលទ្រង់មានចេតនា។ ហើយជនណាដែលអល់ឡោះធ្វើឱ្យវង្វេង ពិតណាស់ រូបគេគឺគ្មានអ្នកដែលចង្អុលបង្ហាញឡើយ។

24. តើអ្នកដែលត្រូវគេបោះផ្កាប់មុខទៅក្នុងទណ្ឌកម្មដ៏អាក្រក់នៅថ្ងៃបរលោក(ល្អជាង ឬអ្នកដែលសោយសុខក្នុងឋានសួគ៌ល្អជាង)? ហើយមានគេនិយាយទៅកាន់ពួកដែលបំពានថា៖ ចូរពួកអ្នកភ្លក់ចុះនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

25. អ្នកជំនាន់មុនពួកគេ(ពួកមុស្លីគីន)បានបដិសេធ(នឹងអ្នកនាំសារ) ពេលនោះ ទណ្ឌកម្មក៏បានមកដល់ពួកគេ(ភ្លាមៗ)ដោយពួកគេមិនដឹងខ្លួនឡើយ។

26. ដូច្នេះ អល់ឡោះក៏បានឱ្យពួកគេភ្លក់នូវភាពអាម៉ាស់បំផុតនៅក្នុងជីវិតលោកិយ។ ហើយទណ្ឌកម្មនៅថ្ងៃបរលោក គឺធ្ងន់ធ្ងរជាងនេះទៅទៀត ប្រសិនបើពួកគេបានដឹង។

27. ហើយពិតប្រាកដណាស់ យើងបានលើកជាឧទាហរណ៍សម្រាប់មនុស្សលោកនៅក្នុងគម្ពីរគួរអាននូវឧទាហរណ៍ជាច្រើនប្រភេទ សង្ឃឹមថាពួកគេនឹងនឹករលឹក។

28. (យើងបានបញ្ចុះ)គម្ពីរគួរអានជាភាសាអារ៉ាប់ដែលគ្មានភាពវៀចវេរ(ក្នុងគម្ពីរនេះ)ឡើយ សង្ឃឹមថាពួកគេកោតខ្លាច(អល់ឡោះ)។

29. អល់ឡោះទ្រង់បានលើកជាឧទាហរណ៍នូវបុរសម្នាក់(ជាខ្ញុំបម្រើគេ)ដែលមានចៅហ្វាយច្រើននាក់(គ្រប់គ្រង)ដែលតែងឈ្លោះប្រកែកគ្នា(ក្នុងរឿងខ្ញុំបម្រើនោះ) ហើយនិងបុរសម្នាក់ទៀត(ខ្ញុំបម្រើម្នាក់ទៀត)ដែលមានចៅហ្វាយ(គ្រប់គ្រង)តែម្នាក់។ តើស្មើគ្នាឬទេរវាងឧទាហរណ៍ទាំងពីរនេះ? ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់។ ផ្ទុយទៅវិញ ភាគច្រើននៃពួកគេ គឺមិនដឹងឡើយ។

30. ពិតប្រាកដណាស់ រូបអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងត្រូវស្លាប់ ហើយពិតប្រាកដណាស់ ពួកគេក៏នឹងត្រូវស្លាប់ដែរ។

31. ក្រោយមក នៅថ្ងៃបរលោក ពិតណាស់ ពួកអ្នក(ឱមនុស្សលោកទាំងឡាយ)នឹងឈ្លោះប្រកែកគ្នានៅចំពោះមុខព្រះជាម្ចាស់របស់ពួកអ្នកជាមិនខាន។

32. ហើយគ្មានអ្នកណាដែលបំពានជាងអ្នកដែលប្រឌិតកុហកទៅលើអល់ឡោះ និងបដិសេធនឹងភាពសច្ចៈ(សេចក្តីពិត)នៅពេលដែលវាបានមកដល់រូបគេនោះឡើយ។ តើពុំមែនទេឬដែលឋាននរក ជាកន្លែងស្នាក់អាស្រ័យសម្រាប់ពួកប្រឆាំងនោះ ?

33. រីឯអ្នកដែលនាំមកនូវភាពសច្ចៈ ហើយបានជឿជាក់ចំពោះវា អ្នកទាំងនោះហើយគឺជាអ្នកដែលកោតខ្លាច(អល់ឡោះ)។

34. សម្រាប់ពួកគេនឹងទទួលបាននូវអ្វីដែលពួកគេប្រាថ្នានៅឯព្រះជាម្ចាស់របស់ពួកគេ។ នោះហើយជាការតបស្នងរបស់បណ្តាអ្នកដែលសាងអំពើល្អ។

35. ដើម្បីអល់ឡោះនឹងលុបបំបាត់ពីពួកគេនូវទង្វើអាក្រក់ទាំងឡាយដែលពួកគេធ្លាប់បានសាង។ ហើយទ្រង់នឹងតបស្នងឱ្យពួកគេនូវផែលបុណ្យរបស់ពួកគេល្អប្រសើរជាងអ្វីដែលពួកគេធ្លាប់បានសាងនោះទៅទៀត។

36. តើមិនគ្រប់គ្រាន់ទេឬដែលអល់ឡោះជាអ្នកការពារខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)នោះ ? ហើយពួកគេបានបន្លាចអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដោយព្រះនានារបស់ពួកគេក្រៅពីទ្រង់។ ហើយជនណាដែលអល់ឡោះធ្វើឱ្យវង្វេង ពិតប្រាកដណាស់ សម្រាប់រូបគេគឺគ្មានអ្នកចង្អុលបង្ហាញឡើយ។

37. រីឯជនណាដែលអល់ឡោះចង្អុលបង្ហាញ ក៏គ្មានអ្នកណាអាចធ្វើឱ្យគេវង្វេងនោះដែរ។ តើពុំមែនទេឬដែលអល់ឡោះជាម្ចាស់មហាខ្លាំងពូកែ ជាអ្នកដែលផ្តន្ទាទោស(ពួកដែលប្រព្រឹត្តល្មើសនឹងទ្រង់)នោះ ?

38. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកទាំងនោះថា៖ តើអ្នកណាដែលបានបង្កើតមេឃជាច្រើនជាន់ និងផែនដី ពួកគេប្រាកដជាឆ្លើយថា៖ គឺអល់ឡោះ។ ចូរអ្នកពោលទៀតថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក អ្វីដែលពួកអ្នកគោរពសក្ការៈផ្សេងពីអល់ឡោះ ប្រសិនបើអល់ឡោះទ្រង់មានចេតនាចង់ឱ្យខ្ញុំទទួលនូវគ្រោះអ្វីមួយ តើពួកវាអាចការពារគ្រោះនោះបានដែរឬទេ ? ឬក៏ ប្រសិនបើទ្រង់មានចេតនាចង់ឲ្យខ្ញុំទទួលបាននូវក្តីមេត្តាករុណា តើពួកវាអាចរារាំងក្តីមេត្តាករុណារបស់ទ្រង់បានដែរឬទេ ? ចូរអ្នកពោលចុះថា៖ អល់ឡោះជាម្ចាស់តែមួយគត់ គឺគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ។ ហើយចំពោះទ្រង់តែមួយគត់ដែលបណ្តាអ្នកដែលទុកចិត្តទាំងឡាយ ប្រគល់ការទុកចិត្ត(ទៅលើទ្រង់)។

39. ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកប្រកាន់ខ្ជាប់មាគ៌ារបស់ពួកអ្នកចុះ។ ចំណែកខ្ញុំក៏ប្រកាន់ខ្ជាប់(តាមមាគ៌ារបស់ខ្ញុំ)ដែរ។ ពិតណាស់ ពួកអ្នកគង់តែនឹងដឹងជាមិនខានថា៖

40. តើអ្នកណាដែលទណ្ឌកម្ម(ក្នុងលោកិយ)នឹងធ្លាក់លើរូបគេដែលនឹងធ្វើឱ្យគេអាម៉ាស់ ហើយនិងទណ្ឌកម្មដ៏អមតៈ(នាថ្ងៃបរលោក)ធ្លាក់ទៅលើរូបគេនោះ។

41. ពិតប្រាកដណាស់ យើងបានបញ្ចុះឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរគួរអាន សម្រាប់មនុស្សលោកយ៉ាងពិតប្រាកដ។ ដូច្នេះ ជនណាហើយដែលទទួលបានការចង្អុលបង្ហាញ វាគឺសម្រាប់ខ្លួនគេផ្ទាល់។ ហើយជនណាដែលវង្វេង តាមពិតការវង្វេងនោះ គឺធ្លាក់ទៅលើរូបគេ(ដូចគ្នា)។ ហើយអ្នក(ព្យាការីមូហាំម៉ាត់)មិនមែនជាអ្នកទទួលខុសត្រូវលើពួកគេនោះឡើយ។

42. អល់ឡោះជាម្ចាស់ជាអ្នកដកយកជីវិតទាំងឡាយនៅពេលដែលគេស្លាប់ ហើយ(ជាអ្នកដកយកជីវិត)អ្នកដែលមិនទាន់ស្លាប់នៅពេលដែលគេគេងលង់លក់ផងដែរ ដោយទ្រង់ឃាត់ទុកព្រលឹងទាំងឡាយណាដែលទ្រង់បានកំណត់ឱ្យគេស្លាប់ ហើយទ្រង់បញ្ជូន(ព្រលែង)ព្រលឹងផ្សេងទៀត(ដែលមិនទាន់កំណត់ឱ្យស្លាប់) រហូតដល់ពេលវេលាដែលបានកំណត់។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាភស្តុតាងសម្រាប់អ្នកដែលចេះគិតពិចារណា។

43. ឬមួយពួកគេ(ពួកមុស្លីគីន)យកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាអ្នកជួយអន្តរាគមន៍? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើសូម្បីតែពួកវាគ្មានលទ្ធភាពគ្រប់គ្រងអ្វីបន្តិច ហើយក៏គ្មានប្រាជ្ញាចេះគិតផងនោះឬ?

44. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ការជួយអន្តរាគមន៍ទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី ក៏ជាកម្មសិទ្ធិរបស់ទ្រង់ដែរ។ ក្រោយមក ពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។

45. ហើយនៅពេលមានគេរំលឹកពីអល់ឡោះជាម្ចាស់តែមួយគត់ ចិត្តរបស់ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោកមានការស្អប់ខ្ពើម។ តែនៅពេលដែលមានគេរំលឹកពីអ្វីផ្សេងក្រៅពីទ្រង់ ស្រាប់តែពួកគេសប្បាយរីករាយ។

46. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ បពិត្រអល់ឡោះជាម្ចាស់ ជាអ្នកដែលបង្កើតមេឃជាច្រើនជាន់និងផែនដី ជាអ្នកដែលដឹងបំផុតចំពោះប្រការអាថ៌កំបាំង និងប្រការដែលលាតត្រដាង! ព្រះអង្គ(តែមួយគត់)ដែលកាត់សេចក្តីរវាងខ្ញុំបម្រើទាំងឡាយរបស់ព្រះអង្គ(នៅថ្ងៃបរលោក)ចំពោះអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នា។

47. ហើយពិតប្រាកដណាស់ ប្រសិនបើពួកបំពានមានអ្វីគ្រប់យ៉ាងទាំងអស់នៅលើផែនដី និងមានដូចនេះបន្ថែមពីលើនោះទៀត ប្រាកដជាពួកគេនឹងយកវាមកលោះខ្លួនពីទណ្ឌកម្មដ៏អាក្រក់នាថ្ងៃបរលោកជាមិនខាន។ ហើយអ្វី(ទណ្ឌកម្ម)ដែលពួកគេមិនធ្លាប់គិតស្មានដល់បានបង្ហាញឡើងចំពោះពួកគេតាមបទបញ្ជារបស់អល់ឡោះ។

48. ហើយអំពើអាក្រក់ទាំងឡាយដែលពួកគេធ្លាប់បានប្រព្រឹត្តក៏បានបង្ហាញឡើងចំពោះ(មុខ)ពួកគេផងដែរ។ ហើយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានសើចចំអកចំពោះវាក៏បានហ៊ុមព័ទ្ធពួកគេ។

49. នៅពេលដែលមនុស្សជួបនឹងគ្រោះ គឺរូបគេបានបួងសួងមកចំពោះយើង។ ក្រោយមក នៅពេលដែលយើងប្រទាននូវឧបការគុណអំពីយើងដល់រូបគេ គេបែរជានិយាយថា៖ ពិតណាស់ គេប្រទានវាឱ្យខ្ញុំដោយសារតែគេដឹង(ថាខ្ញុំសក្តិសមនឹងទទួលបាន)។ ផ្ទុយទៅវិញ វាគឺជាការសាកល្បង(ចំពោះគេ)ប៉ុណ្ណោះ។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនបានដឹងឡើយ។

50. ពិតប្រាកដណាស់ ពួក(ប្រឆាំង)ជំនាន់មុនពួកគេក៏ធ្លាប់បាននិយាយពាក្យនេះដែរ។ ដូច្នេះ អ្វីដែលពួកគេបានប្រឹងប្រែងនោះ មិនអាចផ្តល់ជាប្រយោជន៍អ្វីដល់ពួកគេឡើយ។

51. ហេតុនេះ ពួកគេក៏ទទួលនូវការតបស្នងចំពោះអំពើអាក្រក់ដែលពួកគេធ្លាប់បានប្រព្រឹត្ត។ ហើយពួកដែលបំពានក្នុងចំណោមពួកទាំងនោះ(ពួកមុស្លីគីន) ពួកគេគង់តែនឹងទទួលនូវការតបស្នងចំពោះអំពើអាក្រក់ដែលពួកគេធ្លាប់បានប្រព្រឹត្ត(ដូចពួកជំនាន់មុន)ជាមិនខាន។ ហើយពួកគេមិនអាចគេចផុត(ពីអល់ឡោះ)ឡើយ។

52. តើពួកគេមិនបានដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បើកទូលាយ និងត្បិតគ្មៀតលាភសក្ការៈចំពោះជនណាដែលទ្រង់មានចេតនានោះ? ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាភស្តុតាងសម្រាប់ក្រុមដែលមានជំនឿ។

53. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ខ្ញុំបម្រើរបស់យើងដែលបានបំពានលើខ្លួនឯងថា៖ ចូរពួកអ្នកកុំអស់សង្ឃឹមចំពោះក្តីមេត្តាករុណារបស់អល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់នឹងអភ័យទោសចំពោះបាបកម្មទាំងអស់។ ពិតប្រាកដណាស់ ទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

54. ហើយចូរពួកអ្នកវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកអ្នក ព្រមទាំងប្រគល់ខ្លួនចំពោះទ្រង់ មុនពេលដែលទណ្ឌកម្មបានមកដល់ពួកអ្នក។ ក្រោយមក ពួកអ្នកនឹងមិនត្រូវបានគេជួយឡើយ។

55. ហើយចូរពួកអ្នកប្រតិបត្តិតាមអ្វីដែលប្រសើរជាងគេបំផុត(គម្ពីរគួរអាន)ដែលគេបានបញ្ជូនទៅកាន់ពួកអ្នកពីព្រះជាម្ចាស់របស់ពួកអ្នកមុនពេលដែលទណ្ឌកម្មបានមកដល់ពួកអ្នកភ្លាម។ខណៈដែលពួកអ្នកមិនដឹងខ្លួនឡើយ។

56. ដើម្បីកុំឱ្យបុគ្គលណាម្នាក់និយាយថា៖ គួរឱ្យសោកស្តាយខ្លាំងណាស់ចំពោះអ្វីដែលខ្ញុំបានធ្វេសប្រហែសក្នុងការគោរពប្រតិបត្តិចំពោះអល់ឡោះ ហើយរូបខ្ញុំធ្លាប់ស្ថិតក្នុងចំណោមពួកដែលសើចចំអក។

57. ឬក៏និយាយថា៖ ប្រសិនបើអល់ឡោះទ្រង់ចង្អុលបង្ហាញដល់ខ្ញុំនោះ ប្រាកដជាខ្ញុំនឹងស្ថិតក្នុងចំណោមអ្នកដែលកោតខ្លាច(ចំពោះទ្រង់)ជាមិនខាន។

58. ឬក៏និយាយនៅពេលដែលគេបានឃើញទណ្ឌកម្មថា៖ ប្រសិនបើខ្ញុំអាចត្រឡប់ទៅលោកិយវិញ(ម្តងទៀត) នោះរូបខ្ញុំនឹងស្ថិតក្នុងចំណោមអ្នកដែលសាងអំពើល្អជាមិនខាន។

59. មិនដូច្នោះឡើយ។ ជាការពិតណាស់ សញ្ញាកស្តុតាងជាច្រើនរបស់យើងបានមកដល់អ្នក តែអ្នកបែរជាបដិសេធចំពោះវា និងបានក្រអឺតក្រទមទៅវិញ ហើយអ្នកថែមទាំងបានស្ថិតក្នុងចំណោមពួកដែលប្រឆាំងនឹងអល់ឡោះថែមទៀត។

60. ហើយនៅថ្ងៃបរលោក អ្នកនឹងឃើញថា ពួកដែលប្រឌិតកុហកទៅលើអល់ឡោះនោះ មុខរបស់ពួកគេខ្មៅងងឹត។ តើពុំមែនទេឬ នៅក្នុងនរកដើរហាន់ណាំ គឺជាកន្លែងស្នាក់នៅសម្រាប់ពួកដែលក្រអឺតក្រទម។

61. ហើយអល់ឡោះជាម្ចាស់នឹងសង្គ្រោះបណ្តាអ្នកដែលកោតខ្លាច(ទ្រង់)ដោយភាពជោគជ័យរបស់ពួកគេ។ ប្រការអាក្រក់(ទណ្ឌកម្ម)នឹងមិនបៀតបៀនពួកគេឡើយ ហើយពួកគេក៏ពុំមានទុក្ខព្រួយនោះដែរ។

62. អល់ឡោះជាម្ចាស់ជាអ្នកដែលបង្កើតរាល់អ្វីៗទាំងអស់។ ហើយទ្រង់ជាអ្នកថែរក្សានូវរាល់អ្វីៗទាំងអស់។

63. កូនសោ(ឃ្លាំង)នៃមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយពួកដែលប្រឆាំងនឹងវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះ ពួកទាំងនោះហើយគឺជាពួកដែលខាតបង់។

64. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ តើចំពោះអ្នកផ្សេងក្រៅអល់ឡោះឬដែលពួកអ្នកប្រើខ្ញុំឱ្យគោរពសក្ការៈនោះ ឱពួកល្ងង់ខ្លៅទាំងឡាយ!

65. ហើយជាការពិតណាស់ គេបានផ្តល់វ៉ាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) និងទៅកាន់អ្នក(នាំសារ)ជំនាន់មុនអ្នកថា៖ ប្រសិនបើអ្នកធ្វើស៊ីរិក(មកចំពោះយើង)នោះទង្វើ(កុសល)របស់អ្នកពិតជានឹងរលាយសាបសូន្យ ហើយអ្នកប្រាកដជានឹងស្ថិតក្នុងចំណោមពួកដែលខាតបង់ជាមិនខាន។

66. ផ្ទុយទៅវិញ ចំពោះអល់ឡោះ (តែមួយគត់) ចូរអ្នកគោរពសក្ការៈ ហើយចូរអ្នកស្ថិតក្នុងចំណោមបណ្ដាអ្នកដែលដឹងគុណ។

67. ហើយពួកគេ (ពួកមុស្លីគីន) មិនបានលើកតម្កើងអល់ឡោះឱ្យសក្តិសមនឹងឋានៈរបស់ទ្រង់ឡើយ ខណៈដែលផែនដីទាំងមូល គឺស្ថិតក្នុងកណ្ដាប់ដៃរបស់ទ្រង់នៅថ្ងៃបរលោក ហើយមេឃទាំងប្រាំពីរជាន់ គឺត្រូវបានមូរដោយដៃស្ដាំរបស់ទ្រង់។ ទ្រង់មហាស្អាតស្អំ មហាខ្ពង់ខ្ពស់បំផុតពីអ្វីដែលពួកគេបានធ្វើស៊ីរិក។

68. ហើយគេបានផ្លុំត្រែ ពេលនោះអ្នកដែលនៅលើមេឃជាច្រើនជាន់ និងអ្នកដែលនៅលើផែនដីនឹងត្រូវស្លាប់ទាំងអស់ លើកលែងតែជនណាដែលអល់ឡោះមានចេតនាប៉ុណ្ណោះ។ បន្ទាប់មក គេបានផ្លុំត្រែម្ដងទៀត ពេលនោះស្រាប់តែពួកគេក្រោកឈរង់ចាំមើល។

69. ហើយផែនដីត្រូវបានបំភ្លឺដោយពន្លឺនៃព្រះជាម្ចាស់របស់វា សៀវភៅកំណត់ត្រា (ទង្វើរបស់មនុស្ស) ត្រូវបានគេចែក (ឱ្យមនុស្សគ្រប់គ្នា) ហើយបណ្ដាព្យាការីនិងអ្នកធ្វើសាក្សីទាំងឡាយត្រូវបានគេនាំមក។ ហើយគេនឹងកាត់សេចក្ដីរវាងពួកគេដោយយុត្តិធម៌បំផុត ដោយពួកគេមិនត្រូវបានគេបំពានឡើយ។

70. ហើយគេនឹងតបស្នងយ៉ាងពេញលេញដល់បុគ្គលគ្រប់រូបចំពោះអ្វីដែលពួកគេប្រព្រឹត្ត។ ហើយទ្រង់ដឹងបំផុតចំពោះអ្វីដែលពួកគេបានប្រព្រឹត្ត។

71. ហើយពួកគ្មានជំនឿត្រូវបានគេកៀងទៅកាន់នរកជើហាន់ណាំទាំងហ្វូងៗ។ លុះនៅពេលដែលពួកគេបានទៅដល់វា គេបានបើកទ្វារទាំងឡាយរបស់វា ហើយឆ្មាំនរកបាននិយាយទៅកាន់ពួកគេថា៖ តើបណ្ដាអ្នកនាំសារទាំងឡាយក្នុងចំណោមពួកអ្នកមិនបានមកដល់ពួកអ្នកដោយសូត្រឱ្យពួកអ្នកស្ដាប់នូវវាក្យខណ្ឌទាំងឡាយរបស់ព្រះជាម្ចាស់ពួកអ្នក និងបានព្រមានបន្លាចពួកអ្នកពីជំនួបនៅថ្ងៃនេះទេឬ? ពួកគេឆ្លើយថា៖ ពិតមែនហើយ។ ក៏ប៉ុន្តែពាក្យទណ្ឌកម្ម គឺត្រូវបានកំណត់ឱ្យធ្លាក់ទៅលើពួកគ្មានជំនឿ។

72. មានគេនិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកចូលទៅតាមទ្វារនានារបស់នរកជើហាន់ណាំចុះដោយពួកអ្នកនឹងស្ថិតនៅក្នុងនោះជាអមតៈ។ ហើយកន្លែងស្នាក់នៅរបស់ពួកក្រអឺតក្រទម គឺអាក្រក់បំផុត។

73. រីឯបណ្ដាអ្នកដែលកោតខ្លាចព្រះជាម្ចាស់របស់ពួកគេត្រូវបានគេនាំទៅកាន់ឋានសួគ៌ទាំងក្រុមៗ។ លុះនៅពេលដែលពួកគេបានមកដល់ឋានសួគ៌ហើយនោះ គេក៏បើកទ្វារនានារបស់វាឱ្យពួកគេ ហើយឆ្មាំឋានសួគ៌បាននិយាយទៅកាន់ពួកគេថា៖ សូមសន្តិភាពកើតមានដល់ពួកអ្នក។ ពួកអ្នកស្អាតស្អំហើយ។ ដូច្នេះ ចូរពួកអ្នកចូលទៅក្នុងឋានសួគ៌ដោយស្ថិតនៅក្នុងនោះជាអមតៈចុះ។

74. ហើយពួកគេនិយាយថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាម្ចាស់ដែលបានបំពេញនូវការសន្យារបស់ទ្រង់ចំពោះពួកយើង និងបានប្រទានឱ្យពួកយើងនូវមេរតកនៃទឹកដី (ឋានសួគ៌) ដោយពួកយើងអាចរស់នៅទីកន្លែងណាក៏បានក្នុងឋានសួគ៌នេះតាមតែពួកយើងប្រាថ្នា។ ដូច្នេះ ផលបុណ្យ (ការតបស្នង) របស់បណ្ដាអ្នកដែលសាងទង្វើ (កុសល) គឺល្អប្រសើរបំផុត។

75. ហើយអ្នកនឹងឃើញម៉ាឡាអ៊ីកាត់ទាំងឡាយនៅព័ទ្ធជុំវិញអារ៉ាស្ហដោយពួកគេលើកតម្កើងដោយការកោតសរសើរដល់ព្រះជាម្ចាស់របស់ពួកគេ។ ហើយគេនឹងកាត់សេចក្ដីរវាងពួកគេដោយយុត្តិធម៌។ ហើយមានគេនិយាយថា៖ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

ជំពូក ហ្គាហ្វៀរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ការបញ្ចុះគម្ពីរ(គួរអាន) គឺមកពីអល់ឡោះជាម្ចាស់ដែលមហាខ្លាំងពូកែ មហាដឹងបំផុត។

3. (ទ្រង់)ជាអ្នកអភ័យទោសបំផុតចំពោះបាបកម្ម ជាអ្នកទទួលយកការសារភាពកំហុស ជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត ជាអ្នកដែលមានការប្រោសប្រទានបំផុត។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ កន្លែងវិលត្រឡប់(នៃខ្ញុំបម្រើទាំងអស់របស់ទ្រង់) គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

4. គ្មាននរណាដែលជជែកដេញដោលចំពោះវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះនោះឡើយ លើកលែងតែពួកដែលគ្មានជំនឿប៉ុណ្ណោះ។ ដូច្នេះ ចូរកុំឱ្យការផ្លាស់ប្តូរទីកន្លែងរបស់ពួកគេ(ពួកគ្មានជំនឿ)ក្នុងស្រុកទេសនោះបោកប្រាស់អ្នកឱ្យសោះ។

5. ក្រុមរបស់ព្យាការីនូហ និងក្រុមជាច្រើនទៀតបន្ទាប់ពីពួកគេបានបដិសេធមុនពួកទាំងនោះ(ពួកមុស្លីគីន)ទៅទៀត។ ហើយរាល់ប្រជាជាតិនីមួយៗសុទ្ធតែមានបំណងអាក្រក់ចំពោះអ្នកនាំសាររបស់ពួកគេដើម្បីសម្លាប់គេចោល។ ហើយពួកគេបានជជែកដេញដោលទាំងខុសឆ្គងដើម្បីលុបបំបាត់ការពិតនឹងភាពខុសឆ្គងនោះ។ ហេតុនេះ យើងក៏បានដាក់ទណ្ឌកម្មពួកគេ។ ដូច្នេះ តើទណ្ឌកម្មនោះយ៉ាងដូចម្តេចដែរ?

6. ក៏ដូច្នោះដែរ ពាក្យបន្ទូលនៃព្រះជាម្ចាស់របស់អ្នកគឺត្រូវបានកំណត់ទៅលើពួកគ្មានជំនឿថា ជាការពិតណាស់ ពួកគេគឺជាពួកឋាននរក។

7. បណ្តាអ្នកដែលទ្រអារ៉ស(ម៉ាឡាអ៊ីកាត់)ហើយនិងអ្នកដែលនៅជុំវិញវា គឺពួកគេកំពុងតែលើកតម្កើងដោយការកោតសរសើរដល់ព្រះជាម្ចាស់របស់ពួកគេ និងមានជំនឿចំពោះទ្រង់ ព្រមទាំងសុំការអភ័យទោស(ពីអល់ឡោះ)ដល់បណ្តាអ្នកដែលមានជំនឿ(ដោយពួកគេបួងសួងថា៖) បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ក្តីមេត្តាករុណា និងចំណេះដឹងរបស់ព្រះអង្គ គឺគ្របដណ្តប់លើអ្វីៗទាំងអស់។ ហេតុនេះ សូមព្រះអង្គមេត្តាអភ័យទោសដល់បណ្តាអ្នកដែលសារភាពកំហុស និងបានដើរតាមមាគ៌ារបស់ព្រះអង្គ ហើយសូមព្រះអង្គមេត្តាការពារពួកគេពីទណ្ឌកម្មនៃនរកដ៏ហឹមផងចុះ។

8. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបញ្ចូលពួកគេទៅក្នុងឋានសួគ៌អាត់និនដែលព្រះអង្គបានសន្យាចំពោះពួកគេ ហើយនិង(បញ្ចូលក្នុងឋានសួគ៌ជាមួយពួកគេផងដែរនូវ)ជីដូនជីតារបស់ពួកគេ ភរិយារបស់ពួកគេ និងកូនចៅរបស់ពួកគេ ដែលជាអ្នកបានសាងអំពើល្អនោះផង។ ពិតប្រាកដណាស់ ព្រះអង្គមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

9. ហើយសូមព្រះអង្គមេត្តាការពារពួកគេពីទង្វើអាក្រក់ទាំងឡាយផង។ ជនណាហើយដែលព្រះអង្គការពារនៅថ្ងៃនោះ(ថ្ងៃបរលោក) គឺព្រះអង្គពិតជាបានផ្តល់ក្តីមេត្តាករុណាដល់គេ។ នោះហើយ គឺជាជោគជ័យដ៏ធំធេង។

10. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ពួកគេត្រូវបានគេស្រែក(ប្រាប់)ថា៖ ពិតប្រាកដណាស់ ការខឹងសម្បារបស់អល់ឡោះ(ចំពោះពួកអ្នក)គឺធំធេងជាងការខឹងសម្បារបស់ពួកអ្នកចំពោះខ្លួនឯងទៅទៀត ខណៈដែលពួកអ្នក(កាលនៅលោកិយ)ត្រូវបានគេអំពាវនាវទៅកាន់ការមានជំនឿ ប៉ុន្តែពួកអ្នកបែរជាប្រឆាំង។

11. ពួកគេបានពោលថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ព្រះអង្គបានឱ្យយើងខ្ញុំស្លាប់ពីរដង និងបានឱ្យយើងខ្ញុំមានជីវិតពីរដង។ ពេលនេះ ពួកយើងទទួលស្គាល់ហើយចំពោះបាបកម្មរបស់យើងខ្ញុំ។ ដូចនេះ តើមានមធ្យោបាយអ្វីដែលអាចឱ្យពួកយើងចេញ(ពីឋាននរក)ដែរឬទេ?

12. (ទណ្ឌកម្មលើ)ពួកអ្នកនោះ គឺដោយសារតែនៅពេលណាដែលគេអំពាវនាវទៅកាន់អល់ឡោះជាម្ចាស់តែមួយគត់ ពួកអ្នកបែរជាប្រឆាំងនឹងទ្រង់។ តែប្រសិនបើគេធ្វើស៊ីរិកចំពោះទ្រង់ ពួកអ្នកបែរជាមានជំនឿទៅវិញ។ ដូច្នេះ ការកាត់សេចក្តី គឺជាកម្មសិទ្ធិរបស់អល់ឡោះដែលមហាខ្ពង់ខ្ពស់ មហាធំធេង។

13. ទ្រង់គឺជាអ្នកដែលបង្ហាញឱ្យពួកអ្នកបានឃើញនូវសញ្ញាកសុតាងទាំងឡាយរបស់ទ្រង់។ ហើយទ្រង់បានបញ្ចុះសម្រាប់ពួកអ្នកនូវទឹកភ្លៀងពីលើមេឃជាលាភសក្ការៈមួយ។ ហើយគ្មានអ្នកណាដែលនឹករលឹកឡើយ លើកលែងតែអ្នកដែលវិលត្រឡប់(ទៅកាន់ទ្រង់)ប៉ុណ្ណោះ។

14. ដូច្នេះ ចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿទាំងឡាយ)គោរពសក្ការៈចំពោះអល់ឡោះដោយចិត្តស្មោះសចំពោះទ្រង់ក្នុងសាសនា បើទោះជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ។

15. ទ្រង់មានឋានៈខ្ពស់បំផុត ជាម្ចាស់នៃអារ៉ស្ហ។ ទ្រង់ផ្តល់វ៉ាហ៊ីពីបទបញ្ជារបស់ទ្រង់ទៅឲ្យជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់ទ្រង់ដើម្បីឱ្យពួកគេព្រមានបន្លាចអំពីថ្ងៃជួបជុំ(ថ្ងៃបរលោក)។

16. នៅថ្ងៃដែលពួកគេបានបង្ហាញខ្លួន(ចំពោះមុខអល់ឡោះ)។ គ្មានអ្វីមួយអំពីពួកគេអាចលាក់បាំងពីអល់ឡោះបានឡើយ។ (ទ្រង់សួរថា៖) តើអំណាចគ្រប់គ្រងនៅថ្ងៃនេះជាកម្មសិទ្ធិរបស់អ្នកណា? (ទ្រង់បានឆ្លើយដោយអង្គឯងថា៖) ជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់តែមួយអង្គគត់ ជាម្ចាស់ដ៏មហាខ្លាំងក្លាបំផុត។

17. នៅថ្ងៃនេះ បុគ្គលគ្រប់រូបនឹងត្រូវគេតបស្នងឲ្យចំពោះអ្វីដែលរូបគេបានប្រព្រឹត្ត។ គ្មានភាពអយុត្តិធម៌នោះឡើយក្នុងថ្ងៃនេះ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត។

18. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដាស់តឿនព្រមានពួកគេពីថ្ងៃបរលោកដែលជិតមកដល់ ខណៈដែលបេះដូង(របស់ពួកគេ)លោតមកនៅដើមក(ភ័យរន្ធត់)ដោយពួកគេពោរពេញទៅដោយទុក្ខព្រួយ។ ហើយសម្រាប់ពួកដែលបំពាន គឺគ្មានមិត្តភក្តិ ហើយក៏គ្មានអ្នកជួយអន្តរាគមន៍ណាដែលទទួលយកគេនោះដែរ។

19. អល់ឡោះដឹងនូវភាពក្បត់នៃកែវភ្នែក(លួចមើលដោយស្ងាត់ៗ)ហើយនិងអ្វីដែលលាក់បាំងនៅក្នុងដួងចិត្ត។

20. ហើយអល់ឡោះទ្រង់កាត់សេចក្តីដោយភាពយុត្តិធម៌បំផុត។ ហើយអ្វី(ព្រះនានា)ដែលពួកគេគោរពសក្ការៈក្រៅពីទ្រង់នោះ ពួកវាមិនបានកាត់សេចក្តីអ្វីបន្តិចនោះឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាឮ មហាឃើញបំផុត។

21. តើពួកគេ(ពួកមុស្លីគីន)មិនបានធ្វើដំណើរនៅលើផែនដី ហើយពិចារណាមើលទេឬ ថាតើលទ្ធផលចុងក្រោយរបស់ពួក(បដិសេធ)ជំនាន់មុនពួកគេនោះយ៉ាងដូចម្តេច? ពួកទាំងនោះមានភាពខ្លាំងក្លាជាងពួកគេ ថែមទាំងបានបន្សល់ទុកនូវកេរដំណែលនានានៅលើផែនដីច្រើនជាងពួកគេទៅទៀត។ តែអល់ឡោះទ្រង់បានបំផ្លាញពួកគេដោយសារតែបាបកម្មរបស់ពួកគេ។ ហើយសម្រាប់ពួកគេ គឺគ្មានអ្នកដែលការពារពួកគេពី(ទណ្ឌកម្ម)អល់ឡោះបានឡើយ។

22. នោះគឺដោយសារតែមានអ្នកនាំសារជាច្រើនរបស់ពួកគេបានមកដល់ពួកគេដោយនាំមកនូវភស្តុតាងជាច្រើនយ៉ាងច្បាស់លាស់ តែពួកគេបែរជាប្រឆាំងទៅវិញ។ ហេតុនេះ អល់ឡោះជាម្ចាស់ក៏បានបំផ្លាញពួកគេ។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងក្លា ជាអ្នកដាក់ទណ្ឌកម្មធ្ងន់ធ្ងរបំផុត។

23. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនព្យាការីមូសាជាមួយនឹងសញ្ញាភស្តុតាងជាច្រើនរបស់យើង និងអំណះអំណាងជាច្រើនយ៉ាងច្បាស់លាស់

24. ទៅកាន់ហ្វៀរអោន និងហាម៉ាន ហើយនិងកូរូន តែពួកគេបែរជានិយាយថា៖ (ព្យាការីមូសាគឺជា)គ្រូមន្តអាគម ជាអ្នកដែលភូតកុហកបំផុតទៅវិញ។

25. ហើយនៅពេលដែលគេ(ព្យាការីមូសា)បាននាំមកឱ្យពួកគេនូវការពិតអំពីយើង ពួកគេនិយាយថា៖ ចូរពួកអ្នកសម្លាប់កូនប្រុសទាំងឡាយរបស់បណ្តាអ្នកដែលមានជំនឿជាមួយគេ ហើយទុកជីវិតកូនស្រីទាំងឡាយរបស់ពួកគេចុះ។ ហើយឧបាយកលរបស់ពួកប្រឆាំង គ្មានអ្វីក្រៅពីភាពវង្វេងនោះឡើយ។

26. ហើយហ្វៀរអោនបាននិយាយថា៖ ចូរពួកអ្នកទុកឱ្យយើងសម្លាប់មូសា ហើយឱ្យគេបួងសួងសុំពីព្រះជាម្ចាស់របស់គេ(ឱ្យការពារគេពីយើង)ចុះ។ ពិតណាស់ យើងខ្លាចគេផ្លាស់ប្តូរសាសនារបស់ពួកអ្នក ឬក៏គេបង្កវិនាសកម្មលើផែនដី។

27. ហើយព្យាការីមូសាបាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំសុំការការពារពីព្រះជាម្ចាស់របស់ខ្ញុំ និងព្រះជាម្ចាស់របស់ពួកអ្នក ឱ្យរួចផុតពីរាល់ពួកក្រអឺតក្រទមដែលគ្មានជំនឿចំពោះថ្ងៃជំនុំជម្រះ។

28. ហើយមានបុរសម្នាក់ដែលជាអ្នកមានជំនឿក្នុងចំណោមពូជពង្សរបស់ហ្វៀរអោនដែលបានលាក់បាំងសេចក្តីជំនឿរបស់ខ្លួនបាននិយាយថា៖ តើពួកអ្នកចង់សម្លាប់បុរសម្នាក់ដែលគ្រាន់តែគេនិយាយថា៖ "ព្រះជាម្ចាស់របស់ខ្ញុំ គឺអល់ឡោះ"នោះឬ ខណៈដែលរូបគេបាននាំមកឲ្យពួកអ្នកនូវសញ្ញាភស្តុតាងដ៏ច្បាស់លាស់ជាច្រើនពីព្រះជាម្ចាស់របស់ពួកអ្នកនោះ? ប្រសិនបើគេជាអ្នកភូតកុហក នោះការភូតកុហករបស់គេ គឺធ្លាក់ទៅកាន់គេវិញប៉ុណ្ណោះ។ តែប្រសិនបើគេជាអ្នកដែលនិយាយពិតវិញ នោះអ្វី(ទណ្ឌកម្ម)មួយចំនួនដែលគេសន្យាចំពោះពួកអ្នក នឹងធ្លាក់ទៅលើពួកអ្នកជាមិនខាន។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនចង្អុលបង្ហាញដល់ពួកបំពាន និងពួកដែលកុហកភូតកររនោះឡើយ។

29. ឱក្រុមរបស់ខ្ញុំ! អំណាចនៅថ្ងៃនេះ គឺជាកម្មសិទ្ធិរបស់ពួកអ្នកដោយពួកអ្នកជាអ្នកឈ្នះនៅលើទឹកដី(អេហ្ស៊ីប)នេះ។ ក៏ប៉ុន្តែតើអ្នកណាដែលជួយការពារពួកយើងឱ្យរួចផុតពីទណ្ឌកម្មរបស់អល់ឡោះ ប្រសិនបើវាមកដល់ពួកយើងនោះ? ហ្វៀរអោនបានតបថា៖ អ្វីដែលខ្ញុំបង្ហាញដល់ពួកអ្នក គឺគ្មានអ្វីក្រៅពីការយល់ឃើញរបស់ខ្ញុំនោះឡើយ ហើយអ្វីដែលខ្ញុំចង្អុលបង្ហាញពួកអ្នកនេះ ក៏គ្មានអ្វីក្រៅពីជាមាគ៌ាដ៏ត្រឹមត្រូវនោះដែរ។

30. ហើយបុរសដែលមានជំនឿនោះបាននិយាយទៀតថា៖ ឱក្រុមរបស់ខ្ញុំ! (ប្រសិនបើពួកអ្នកសម្លាប់ព្យាការីមូសា) ពិតប្រាកដណាស់ ខ្ញុំខ្លាចពួកអ្នកទទួលនូវទណ្ឌកម្ម ដូចថ្ងៃរបស់ក្រុមនានា(ដែលទទួលទណ្ឌកម្ម)។

31. ដូចជាស្ថានភាពរបស់ក្រុមព្យាការីនូហ ក្រុមអាទ ក្រុមសាមូទ និងពួកទាំងឡាយបន្ទាប់ពីពួកគេ។ ហើយអល់ឡោះទ្រង់គ្មានបំណងបំពានលើខ្ញុំបម្រើទាំងឡាយ(របស់ទ្រង់)ឡើយ។

32. ឱក្រុមរបស់ខ្ញុំ! ពិតប្រាកដណាស់ រូបខ្ញុំខ្លាចពួកអ្នកទទួលទណ្ឌកម្មនៅថ្ងៃដែលមនុស្សស្រែកហៅគ្នាទៅវិញទៅមក(ថ្ងៃបរលោក)។

33. គឺនៅថ្ងៃដែលពួកអ្នកបែរខ្នងរត់គេច។ សម្រាប់ពួកអ្នក គឺគ្មានអ្នកជួយការពារពី(ទណ្ឌកម្ម)អល់ឡោះឡើយ។ ជនណាហើយដែលអល់ឡោះធ្វើឲ្យវង្វេង ពិតប្រាកដណាស់ សម្រាប់រូបគេគឺគ្មានអ្នកដែលចង្អុលបង្ហាញនោះឡើយ។

34. ហើយជាការពិតណាស់ព្យាការីយូសុះបាននាំមកឱ្យពួកអ្នកកាលពីមុននូវសញ្ញាកស្តុតាងជាច្រើនដ៏ច្បាស់លាស់ក៏ប៉ុន្តែពួកអ្នកនៅតែមានការមន្ទិលសង្ស័យចំពោះអ្វីដែលគាត់នាំមកឱ្យពួកអ្នក។ លុះនៅពេលដែលគាត់ស្លាប់ពួកអ្នកនិយាយថា៖ អល់ឡោះជាម្ចាស់នឹងមិនតែងតាំងអ្នកនាំសារណាម្នាក់បន្ទាប់ពីគាត់ទៀតឡើយ។ ក៏ដូច្នោះដែរ អល់ឡោះទ្រង់ធ្វើឱ្យវង្វេងរាល់ជនដែលបំពានដែលមានភាពមន្ទិលសង្ស័យ។

35. ពួកដែលជជែកដេញដោលចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់អល់ឡោះដោយគ្មានអំណះអំណាងណាមួយបានមកដល់ដៃពួកគេទេនោះ វាជារឿងគួរឲ្យខឹងសម្បាបំផុតចំពោះអល់ឡោះ និងចំពោះបណ្តាអ្នកដែលមានជំនឿ។ ក៏ដូច្នោះដែរ អល់ឡោះជាម្ចាស់នឹងបោះត្រាក្លិតទៅលើរាល់ដួងចិត្តពួកដែលក្រអឺតក្រទម និងផ្តាច់ការ។

36. ហើយហ្គៀរអោនបាននិយាយថា៖ ឱហាម៉ាន! ចូរអ្នកសាងសង់សំណង់មួយឱ្យយើង សង្ឃឹមថាយើងអាចទៅដល់ទ្វារទាំងឡាយបាន។

37. គឺទ្វារមេឃាទាំងឡាយដើម្បីឲ្យយើង(ឡើង)ទៅមើលព្រះជាម្ចាស់របស់មូសា។ ហើយពិតប្រាកដណាស់ យើងគិតថារូបគេគឺជាអ្នកដែលភូតកុហក។ ដូច្នោះដែរ គេបានតុបតែងលម្អដល់ហ្គៀរអោននូវទង្វើអាក្រក់របស់គេ និងរារាំងរូបគេពីមាគ៌ា(ត្រឹមត្រូវ)។ ហើយឧបាយកលរបស់ហ្គៀរអោននោះ គឺគ្មានអ្វីក្រៅពីស្ថិតនៅក្នុងភាពខាតបង់នោះឡើយ។

38. ហើយបុរសដែលមានជំនឿនោះបាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ចូរពួកអ្នកដើរតាមខ្ញុំចុះ នោះខ្ញុំនឹងចង្អុលបង្ហាញពួកអ្នកទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

39. ឱក្រុមរបស់ខ្ញុំ! តាមពិតឆាកជីវិតលោកិយនេះ គ្រាន់តែជាការសោយសុខ(មួយរយៈពេលខ្លី)ប៉ុណ្ណោះ។ រីឯបរលោកទៅវិញទេ ទើបជាទីកន្លែងដែលអមតៈ។

40. ជនណាដែលបានសាងអំពើអាក្រក់ រូបគេនឹងត្រូវបានគេតបស្នងដូចអ្វីដែលរូបគេបានសាងនោះ។ រីឯជនណាដែលបានសាងទង្វើកុសលមិនថាបុរសឬស្ត្រី ហើយរូបគេជាអ្នកដែលមានជំនឿទៀតនោះ អ្នកទាំងនោះហើយដែលនឹងត្រូវចូលឋានសួគ៌ដោយពួកគេនឹងត្រូវគេប្រទានលាភសក្ការៈឲ្យក្នុងឋានសួគ៌នោះដោយឥតគណនាឡើយ។

41. ឱក្រុមរបស់ខ្ញុំ! ហេតុអ្វីបានជាខ្ញុំអំពាវនាវពួកអ្នកទៅរកភាពជោគជ័យ តែពួកអ្នកបែរជាអំពាវនាវខ្ញុំទៅកាន់ឋាននរកទៅវិញបែបនេះ?

42. ពួកអ្នកអំពាវនាវខ្ញុំដើម្បីឲ្យខ្ញុំប្រឆាំងនឹងអល់ឡោះ និងធ្វើស្ទីរិកចំពោះទ្រង់នូវអ្វីដែលខ្ញុំគ្មានចំណេះដឹងសោះអំពីវា ខណៈខ្ញុំវិញ គឺអំពាវនាវពួកអ្នកទៅកាន់ព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាអភ័យទោសបំផុត។

43. គ្មានការសង្ស័យឡើយ តាមពិតអ្វីដែលពួកអ្នកអំពាវនាវខ្ញុំទៅកាន់វានោះ គឺមិនសក្តិសមក្នុងការអំពាវនាវទៅកាន់វានោះឡើយ ទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។ ហើយពិតណាស់ កន្លែងវិលត្រឡប់របស់ពួកយើង គឺទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយពិតប្រាកដណាស់ ពួកដែលបំពាន ពួកគេគឺជាពួកឋាននរក។

44. ពិតណាស់ ពួកអ្នកនឹងនឹកឃើញនូវអ្វីដែលខ្ញុំបាននិយាយ(ដាស់តឿន)ទៅកាន់ពួកអ្នក។ ហើយខ្ញុំសូមប្រគល់កិច្ចការរបស់ខ្ញុំទៅកាន់អល់ឡោះ(តែមួយគត់)។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ឃើញបំផុតចំពោះខ្ញុំបម្រើទាំងឡាយ(របស់ទ្រង់)។

45. ដូច្នេះ អល់ឡោះជាម្ចាស់ក៏បានការពារពួកគេពីឧបាយកលអាក្រក់ដែលពួកគេបានរៀបចំ។ ហើយពូជពង្សរបស់ហ្វៀរអោនក៏ត្រូវបានហ៊ុមព័ទ្ធទៅដោយទណ្ឌកម្មដ៏អាក្រក់(លិចលង់ក្នុងទឹកសមុទ្រ)។

46. (ក្រោយពេលពួកគេស្លាប់)ឋាននរកត្រូវបានគេយកមកបង្ហាញពួកគេទាំងព្រឹកទាំងល្ងាច។ ហើយនៅថ្ងៃបរលោក (មានគេនិយាយថា៖) ចូរពួកអ្នកបញ្ចូលបក្សពួកហ្វៀរអោនទៅក្នុងទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតចុះ។

47. ហើយនៅពេលដែលពួកគេឈ្លោះប្រកែកគ្នានៅក្នុងឋាននរក ពួកដែលទន់ខ្សោយ(ដែលដើរតាមគេ)បាននិយាយទៅកាន់ពួកក្រអឺតក្រទម(ពួកមេដឹកនាំ)ថា៖ ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាអ្នកដែលដើរតាមពួកអ្នក។ ហេតុនេះ តើពួកអ្នកអាចទទួលជំនួសពួកយើងមួយផ្នែកនៃ(ទណ្ឌកម្ម)ភ្លើងនរកបានដែរឬទេ?

48. ពួកក្រអឺតក្រទម(ពួកមេដឹកនាំ)បានតបថា៖ ពិតណាស់ ពួកយើងស្ថិតនៅក្នុងឋាននរកទាំងអស់គ្នា។ ពិតប្រាកដណាស់ អល់ឡោះទ្រង់បានកាត់សេចក្តីរវាងខ្ញុំបម្រើទាំងឡាយ(របស់ទ្រង់)រួចទៅហើយ។

49. ហើយពួកដែលស្ថិតនៅក្នុងឋាននរកបាននិយាយទៅកាន់ឆ្មាំនរកដើហាន់ណាំថា៖ សូមពួកអ្នកមេត្តាបួងសួងសុំពីព្រះជាម្ចាស់របស់ពួកអ្នកឱ្យទ្រង់សម្រាលទណ្ឌកម្មពីពួកយើងមួយថ្ងៃផង។

50. ពួកគេបានតបវិញថា៖ តើបណ្តាអ្នកនាំសាររបស់ពួកអ្នកមិនធ្លាប់បាននាំមកកាន់ពួកអ្នកនូវសញ្ញាកស្តតាងដ៏ច្បាស់លាស់ទេឬ? ពួកគេឆ្លើយថា៖ ពិតមែនហើយ។ ឆ្មាំនរកក៏តបវិញ៖ ដូច្នេះ ចូរពួកអ្នកបួងសួងសុំ(ដោយខ្លួនឯង)ចុះ។ ហើយការបួងសួងរបស់ពួកប្រឆាំង គឺគ្មានអ្វីក្រៅពីស្ថិតក្នុងភាពវង្វេងនោះឡើយ។

51. ពិតប្រាកដណាស់ យើង(អល់ឡោះ)ប្រាកដជានឹងជួយដល់បណ្តាអ្នកនាំសាររបស់យើង និងបណ្តាអ្នកដែលមានជំនឿនៅក្នុងជីវិតលោកិយនេះ និងនៅថ្ងៃដែលសាក្សីទាំងឡាយបានមកធ្វើសាក្សី(ថ្ងៃបរលោក)។

52. គឺនៅថ្ងៃដែលការដោះសារបស់ពួកបំពានមិនអាចជួយជាប្រយោជន៍អ្វីដល់ពួកគេបានឡើយ។ ហើយសម្រាប់ពួកគេនឹងទទួលនូវបណ្តាសា និងទទួលបានកន្លែងស្នាក់នៅដ៏អាក្រក់បំផុត។

53. ហើយជាការពិតណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវការចង្អុលបង្ហាញ និងបានឲ្យអម្ប្រាអ៊ីស្រាអែលទទួលមរតកគម្ពីរ(តាវ៉ាត)។

54. ជាការចង្អុលបង្ហាញ និងជាការដាស់រំឭកសម្រាប់បញ្ញាជនទាំងឡាយ។

55. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះ។ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ ហើយចូរអ្នកសុំការអភ័យទោសចំពោះបាបកម្មរបស់អ្នក និងត្រូវលើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់អ្នកទាំងព្រឹក និងល្ងាច។

56. ពួកដែលជជែកដេញដោលចំពោះសញ្ញាកស្តតាងទាំងឡាយរបស់អល់ឡោះដោយគ្មានអំណះអំណាងណាមួយបានមកដល់ពួកគេទេនោះ តាមពិតនៅក្នុងដួងចិត្តរបស់ពួកគេ គឺគ្មានអ្វីក្រៅពីភាពក្រអឺតក្រទម។ ពួកគេនឹងមិនទទួលបាន(ដូចអ្វីដែលពួកគេចង់បាន)ជាដាច់ខាត។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សុំការការពារពីអល់ឡោះចុះ។ ពិតណាស់ទ្រង់មហាឮ មហាឃើញបំផុត ។

57. ការបង្កើតមេឃជាច្រើនជាន់និងផែនដី គឺពិតជាធំធេង(អស្ចារ្យ)ជាងការបង្កើតមនុស្សលោកទៅទៀត។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនបានដឹងឡើយ។

58. មនុស្សខ្វាក់ និងអ្នកដែលមើលឃើញ គឺមិនស្មើគ្នាឡើយ។ ហើយបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ក៏មិនស្មើគ្នានឹងពួកដែលសាងអំពើអាក្រក់នោះដែរ។ អ្វីដែលពួកអ្នកនឹករលឹក គឺតិចតួចបំផុត។

59. ជាការពិតណាស់ ថ្ងៃបរលោកប្រាកដជានឹងមកដល់ដោយគ្មានការសង្ស័យចំពោះវាឡើយ។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនជឿឡើយ។

60. ហើយព្រះជាម្ចាស់របស់ពួកអ្នកបានមានបន្ទូលថា៖ ចូរពួកអ្នកបួងសួងមកកាន់យើងចុះ នោះយើងនឹងឆ្លើយតបចំពោះពួកអ្នក។ ពិតប្រាកដណាស់ ពួកដែលក្រអឺតក្រទមមិនព្រមគោរពសក្ការៈមកចំពោះយើង ពួកគេនឹងត្រូវចូលក្នុងនរកដើហាន់ណាំដោយភាពទាបថោកបំផុត។

61. អល់ឡោះគឺជាអ្នកដែលបង្កើតពេលយប់សម្រាប់ពួកអ្នកដើម្បីឱ្យពួកអ្នកបានសម្រាកនៅក្នុងវា និង(បានបង្កើត)ពេលថ្ងៃឲ្យមានពន្លឺ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មានការប្រោសប្រទានបំផុតចំពោះមនុស្សលោក។ ក៏ប៉ុន្តែ មនុស្សលោកភាគច្រើនមិនដឹងគុណឡើយ។

62. (អ្នកដែលប្រទានឧបការគុណទាំងនោះដល់ពួកអ្នក)នោះគឺអល់ឡោះជាព្រះជាម្ចាស់របស់ពួកអ្នក ជាអ្នកដែលបង្កើតអ្វីៗទាំងអស់។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ តើពួកអ្នកត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

63. ក៏ដូច្នោះដែរ គេក៏បង្វែរពួកដែលប្រឆាំងនឹងបណ្តាកស្តុតាងទាំងឡាយរបស់អល់ឡោះ(ដូចគ្នាដែរ)។

64. អល់ឡោះទ្រង់ជាអ្នកដែលបានបង្កើតផែនដីសម្រាប់ពួកអ្នក(ឱមនុស្សលោក)ជាកន្លែងរស់នៅ និងបានបង្កើតមេឃជាសំណង់មួយ(នៅពីលើផែនដី)។ ហើយទ្រង់បានបង្កើតពួកអ្នកឱ្យមានរូបរាងល្អសមសួន ព្រមទាំងបានប្រទាននូវលាភសក្ការៈដល់ពួកអ្នកអំពីប្រការល្អៗជាច្រើន។ (អ្នកដែលប្រទានឧបការគុណទាំងនោះដល់ពួកអ្នក)នោះគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក។ អល់ឡោះមហាឧត្តុង្គឧត្តម ជាព្រះជាម្ចាស់នៃពិភពទាំងឡាយ។

65. ទ្រង់គឺជាអ្នកដែលមានជីវិត(ជាអមតៈ)។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ដូច្នេះ ចូរពួកអ្នកបួងសួងសុំពីទ្រង់ដោយភាពស្មោះសចំពោះទ្រង់ក្នុងសាសនា។ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។

66. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពិតប្រាកដណាស់ គេបានហាមឃាត់ខ្ញុំមិនឱ្យគោរពសក្ការៈទៅចំពោះអ្នកដែលពួកអ្នកគោរពសក្ការៈ(ចំពោះពួកវា)ក្រៅពីអល់ឡោះនោះឡើយនៅពេលដែលកស្តុតាងដ៏ច្បាស់លាស់ជាច្រើនពីព្រះជាម្ចាស់របស់ខ្ញុំបានមកដល់ខ្ញុំហើយនោះ។ ហើយគេបានបង្គាប់ប្រើខ្ញុំឱ្យប្រគល់ខ្លួនចំពោះព្រះជាម្ចាស់នៃពិភពទាំងអស់។

67. ទ្រង់គឺជាអ្នកដែលបានបង្កើតពួកអ្នកអំពីដី។ ក្រោយមក អំពីទឹកកាម រួចមក ក្លាយទៅជាដុំឈាម។ បន្ទាប់មក ទ្រង់បានបញ្ចេញពួកអ្នក(ពីផ្ទៃម្តាយ)ជាទារក។ បន្ទាប់មកទៀត ពួកអ្នកបានធំពេញវ័យ។ ក្រោយមក ពួកអ្នកក៏បានក្លាយទៅជាចាស់ជរា។ ហើយក្នុងចំណោមពួកអ្នក មានអ្នកខ្លះបានស្លាប់មុននោះ(មុនចាស់ជរា)។ ហើយ(ទ្រង់ធ្វើដូច្នោះ)ដើម្បីឱ្យពួកអ្នករស់រានមានជីវិតរហូតដល់ពេលកំណត់។ សង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

68. ទ្រង់ជាអ្នកផ្តល់ជីវិត និងជាអ្នកដកយកជីវិត។ នៅពេលដែលទ្រង់សម្រេចកិច្ចការអ្វីមួយ ទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ "ចូរកើតចុះ" វានឹងកើតឡើងភ្លាម។

69. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬ ពួកដែលជជែកដេញដោលចំពោះវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះនោះ ថាតើពួកគេត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

70. ពួកដែលបានបដិសេធនឹងគម្ពីរ(គួរអាន)ហើយនិងអ្វីដែលយើងបានបញ្ជូនមកតាមរយៈបណ្តាអ្នកនាំសាររបស់យើងនោះ ពួកទាំងនោះគង់តែនឹងដឹងជាមិនខាន។

71. នៅពេលដែលខ្នោះត្រូវបានដាក់ជាប់នឹងករបស់ពួកគេ និងច្រវាក់(ត្រូវបានគេចងជាប់នឹងជើង)ដោយពួកគេត្រូវបានគេអូស

72. ចូលទៅក្នុងទឹកដ៏ក្តៅបំផុត។ បន្ទាប់មក ពួកគេត្រូវបានគេដុត(នៅក្នុងភ្លើងនរក)។

73. ក្រោយមក មានគេនិយាយទៅកាន់ពួកគេថា៖ តើឯណាទៅអ្វីដែលពួកអ្នកធ្លាប់យកមកគោរពសក្ការៈ

74. ផ្សេងពីអល់ឡោះនោះ? ពួកគេបានឆ្លើយថា៖ ពួកវាបានបាត់ចេញពីពួកយើងទៅហើយ។ ផ្ទុយទៅវិញ ពួកយើងមិនធ្លាប់គោរពសក្ការៈទៅចំពោះអ្វីមួយ(ដែលសក្តិសម)កាលពីមុននោះឡើយ។ ក៏ដូច្នោះដែរ អល់ឡោះនឹងធ្វើឱ្យពួកដែលគ្មានជំនឿវង្វេង។

75. (ទណ្ឌកម្មដែលធ្លាក់លើពួកអ្នក)នោះគឺដោយសារតែអ្វីដែលពួកអ្នកធ្លាប់សប្បាយរីករាយនៅលើផែនដីដោយមិនត្រឹមត្រូវ និងដោយសារតែពួកអ្នកក្រអឺតក្រទម។

76. ចូរពួកអ្នកចូលតាមទ្វារនានារបស់នរកដើហាន់ណាំដោយស្ថិតនៅទីនោះជាអមតៈចុះ។ ពិតប្រាកដណាស់ កន្លែងរស់នៅរបស់ពួកដែលក្រអឺតក្រទម គឺអាក្រក់បំផុត។

77. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះ។ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ ហើយទោះបីជាយើងឱ្យអ្នកបានឃើញនូវប្រការខ្លះៗ(ទណ្ឌកម្ម)ដែលយើងបានសន្យាចំពោះពួកគេ ឬក៏យើងអាចឱ្យអ្នកស្លាប់(មុននោះ)ក៏ដោយ ក៏ពួកគេនឹងត្រូវគេនាំត្រឡប់មកកាន់យើង(តែមួយគត់)។

78. ហើយជាការពិតណាស់ យើងបានបញ្ជូនអ្នកនាំសារជាច្រើនមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ ក្នុងចំណោមពួកគេ មានអ្នកខ្លះយើងបាននិទានប្រាប់អ្នក(នូវរឿងរ៉ាវរបស់ពួកគេ) ហើយមានអ្នកខ្លះទៀត យើងមិនបាននិទានប្រាប់អ្នក(នូវរឿងរ៉ាវរបស់ពួកគេ)ឡើយ។ ហើយគ្មានអ្នកនាំសារណាម្នាក់អាចនាំមកនូវសញ្ញាកស្តែងណាមួយឡើយ លើកលែងតែដោយការអនុញ្ញាតពីអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។ ហើយនៅពេលដែលបទបញ្ជារបស់អល់ឡោះបានមកដល់ ទ្រង់នឹងកាត់សេចក្តី(រវាងពួកគេ)ដោយយុត្តិធម៌បំផុត។ ហើយនៅទីនោះ ពួកដែលប្រព្រឹត្តខុសនឹងទទួលនូវការខាតបង់។

79. អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកដែលបានបង្កើតសត្វពាហនៈសម្រាប់ពួកអ្នក ដោយមួយចំនួនអំពីពួកវាសម្រាប់ឱ្យពួកអ្នកជិះ ហើយមួយចំនួនទៀត ពួកអ្នកអាចទទួលទានបាន។

80. ហើយចំពោះពួកវាទាំងនោះ គឺមានផលប្រយោជន៍ជាច្រើន (ផ្សេងទៀត) សម្រាប់ពួកអ្នក។ តាមរយៈវា ពួកអ្នកអាចបំពេញតម្រូវការផ្សេងៗដោយការដឹកជញ្ជូនទៅដល់គោលដៅដែលពួកអ្នកត្រូវការ ហើយគេអាចដឹកជញ្ជូនពួកអ្នកតាមរយៈវា និងតាមរយៈសំពៅផងដែរ។

81. ហើយទ្រង់បានបង្ហាញឱ្យពួកអ្នកបានឃើញនូវសញ្ញាកស្តុតាងទាំងឡាយរបស់ទ្រង់។ ដូច្នេះ តើមានសញ្ញាកស្តុតាងណាមួយរបស់អល់ឡោះដែលពួកអ្នកមិនទទួលស្គាល់នោះ?

82. តើពួកគេមិនធ្វើដំណើរនៅលើផែនដី ហើយពិចារណាមើលទេឬ ថាតើលទ្ធផលចុងក្រោយរបស់ពួក (បដិសេធ) ជំនាន់មុនពួកគេយ៉ាងដូចម្តេច? ពួកទាំងនោះមានចំនួនច្រើនជាងពួកគេ និងមានកម្លាំងខ្លាំងក្លាជាងពួកគេ ព្រមទាំងបន្សល់ទុកនូវកេរដំណែលនៅលើផែនដីច្រើនជាងពួកគេទៅទៀត។ ក៏ប៉ុន្តែអ្វីដែលពួកគេខិតខំប្រឹងប្រែងនោះ គឺគ្មានផ្តល់ផលប្រយោជន៍អ្វីចំពោះពួកគេឡើយ។

83. ហើយនៅពេលដែលបណ្តាអ្នកនាំសាររបស់ពួកគេបាននាំមកនូវសញ្ញាកស្តុតាងជាច្រើនដ៏ច្បាស់លាស់មកកាន់ពួកគេ ពួកគេបែរជារីករាយនឹងចំណេះដឹងដែលពួកគេមានទៅវិញ។ ហើយអ្វី (ទណ្ឌកម្ម) ដែលពួកគេធ្លាប់បានសើចចំអកចំពោះវានោះ ក៏បានហ៊ុមព័ទ្ធពួកគេ។

84. នៅពេលដែលពួកគេបានឃើញទណ្ឌកម្មរបស់យើង ពួកគេក៏និយាយថា៖ ពួកយើងមានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់ហើយ ហើយពួកយើងប្រឆាំងចំពោះអ្វីដែលពួកយើងធ្លាប់បានធ្វើស៊ីរិក។

85. ក៏ប៉ុន្តែការមានជំនឿរបស់ពួកគេ គឺគ្មានប្រយោជន៍អ្វីឡើយនៅពេលដែលពួកគេបានឃើញទណ្ឌកម្មរបស់យើង (ផ្ទាល់នឹងភ្នែក) ហើយនោះ។ វាជាមាគ៌ារបស់អល់ឡោះដែលបានកំណត់រួចទៅហើយចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ហើយនៅទីនោះ ពួកប្រឆាំងក៏ត្រូវទទួលនូវការខាតបង់។

ជំពូក ហ៊ូសស៊ីឡាត់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. (គម្ពីរគួរអាននេះ)ជាការបញ្ចុះមកពីព្រះជាម្ចាស់ដ៏មហាសប្បុរស មហាអាណិតស្រលាញ់។

3. ជាគម្ពីរមួយដែលវាក្យខណ្ឌទាំងឡាយរបស់វាត្រូវបានបកស្រាយយ៉ាងច្បាស់លាស់។ ហើយគម្ពីរគួរអាននេះជាភាសាអារ៉ាប់សម្រាប់ក្រុមដែលចេះដឹង។

4. ជាអ្នកផ្តល់ដំណឹងរីករាយ និងដាស់តឿនព្រមាន។ ក៏ប៉ុន្តែភាគច្រើននៃពួកគេបែរជាងាកចេញទៅវិញដោយពួកគេមិនព្រមស្តាប់(វា)នោះឡើយ។

5. ហើយពួកគេនិយាយថា៖ ដួងចិត្តរបស់ពួកយើងមានគម្របបិទជិតចំពោះអ្វីដែលអ្នក(ព្យាការីមូហាំម៉ាត់)អំពាវនាវពួកយើងទៅកាន់វា ក្នុងត្រចៀករបស់ពួកយើងមានធ្នូកចុក ហើយនៅរវាងពួកយើងនិងអ្នក គឺមានរនាំងបាំង។ ដូច្នេះ ចូរអ្នកអនុវត្តន៍(តាមមាគ៌ារបស់អ្នកចុះ) ពិតប្រាកដណាស់ ពួកយើងក៏ជាអ្នកអនុវត្តន៍(តាមមាគ៌ារបស់ពួកយើង)ដែរ។

6. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិតខ្ញុំជាមនុស្សលោកធម្មតាដូចពួកអ្នកដែរ គ្រាន់តែគេបានផ្តល់វាហ៊ីមកកាន់ខ្ញុំថា៖ តាមពិត ព្រះជាម្ចាស់របស់ពួកអ្នកដែលពួកអ្នកត្រូវគោរពសក្ការៈ គឺជាព្រះជាម្ចាស់តែមួយគត់។ ដូច្នេះ ចូរពួកអ្នកប្រកាន់ខ្ជាប់តាមមាគ៌ាដែលនាំ(ពួកអ្នក)ទៅកាន់ទ្រង់ និងសុំការអភ័យទោសពីទ្រង់ចុះ។ ហើយភាពវិនាសអន្តរាយ គឺសម្រាប់ពួកដែលធ្វើស្ដីរិក។

7. ពួកដែលមិនព្រមបរិច្ចាគហ្សាកាត់ ពួកគេគឺជាពួកដែលគ្មានជំនឿនឹងថ្ងៃបរលោកឡើយ។

8. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល សម្រាប់ពួកគេនឹងទទួលបាននូវផលបុណ្យដែលគ្មានទីបញ្ចប់ឡើយ។

9. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ហេតុអ្វីបានជាពួកអ្នកគ្មានជំនឿនឹងអ្នកដែលបានបង្កើតផែនដីក្នុងរយៈពេលពីរថ្ងៃ ហើយពួកអ្នកបែរជាបង្កើត(ព្រះនានា)ជាដៃគូសម្រាប់ទ្រង់ទៅវិញ? (ទ្រង់)នោះហើយ គឺជាព្រះជាម្ចាស់នៃពិភពទាំងអស់។

10. ហើយនៅលើផែនដីនោះទ្រង់បានបង្កើតភ្នំជាច្រើននៅពីលើវា និងបានប្រទានពរដ៏ច្រើនចំពោះវា ព្រមទាំងបានកំណត់នៅលើវានូវស្បៀងអាហាររបស់វាក្នុងរយៈពេលបួនថ្ងៃ សម្រាប់អ្នកដែលចង់សួរ(អំពីវា)។

11. បន្ទាប់មក ទ្រង់បានសំដៅទៅកាន់មេឃ ខណៈដែលវានៅជាផ្សែងនៅឡើយ ហើយទ្រង់បានមានបន្ទូលទៅកាន់មេឃ និងផែនដីថា៖ ចូរឯងទាំងពីរគោរពតាមបទបញ្ជាយើង ទោះដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តក៏ដោយ។ ពួកវាទាំងពីរបានឆ្លើយថា៖ យើងខ្ញុំធ្វើតាមដោយស្ម័គ្រចិត្ត។

12. ហើយទ្រង់បានបង្កើតមេឃប្រាំពីរជាន់ក្នុងរយៈពេលពីរថ្ងៃ។ ហើយទ្រង់បានផ្តល់វាហ៊ីទៅកាន់មេឃរាល់ជាន់នីមួយៗនូវកិច្ចការរបស់វា។ ហើយយើង(អល់ឡោះ)បានតុបតែងលម្អមេឃផែនដីដោយហ្វូងតារាជាច្រើន ហើយបានការពារ(ពីពួកស្លែតន)។ នោះគឺជាការកំណត់របស់ព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាដឹងបំផុត។

13. តែប្រសិនបើពួកទាំងនោះងាកចេញ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំសូមដាស់តឿនព្រមានពួកអ្នកនូវទណ្ឌកម្មដូចទណ្ឌកម្មរបស់ក្រុមអាទ និងក្រុមសាមូទ។

14. ខណៈដែលអ្នកនាំសារជាច្រើនបានមកដល់ពួកគេជាបន្តបន្ទាប់ (ដោយប្រើពួកគេថា៖) ពួកអ្នកមិនត្រូវគោរពសក្ការៈ(អ្នកផ្សេង)ក្រៅពីអល់ឡោះឡើយ ពួកគេបានតបវិញថា៖ ប្រសិនបើព្រះជាម្ចាស់របស់ពួកយើងមានចេតនា ទ្រង់ប្រាកដជានឹងបញ្ចុះម៉ាឡាអ៊ីកាត់(មកកាន់ពួកយើង)ជាមិនខាន។ ពិតណាស់ ពួកយើងគឺជាពួកដែលប្រឆាំងចំពោះអ្វីដែលគេបានបញ្ជូនវាមកកាន់ពួកអ្នក។

15. ចំណែកឯក្រុមអាទ ពួកគេបានក្រអឺតក្រទមនៅលើផែនដីដោយមិនត្រឹមត្រូវ។ ហើយពួកគេនិយាយថា៖ តើមានអ្នកណាដែលខ្លាំងជាងពួកយើងទៀតនោះ? តើពួកគេមិនឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ដែលបានបង្កើតពួកគេ ទ្រង់គឺជាអ្នកដែលខ្លាំងក្លាជាងពួកគេទៅទៀតនោះ? ហើយពួកគេធ្លាប់បានប្រឆាំងនឹងសញ្ញាកស្តុតាងទាំងឡាយរបស់យើង។

16. ហើយយើងបានបញ្ជូនព្យុះត្រជាក់ខ្លាំងបំផុតទៅកាន់ពួកគេក្នុងរយៈពេលជាច្រើនថ្ងៃដ៏អាក្រក់ ដើម្បីឱ្យពួកគេភ្លក់នូវទណ្ឌកម្មដ៏អាម៉ាស់បំផុតនៅក្នុងជីវិតលោកិយ។ ហើយទណ្ឌកម្មនៅថ្ងៃបរលោក គឺកាន់តែធ្វើឱ្យពួកគេអាម៉ាស់ជាងនេះទៅទៀត។ ហើយពួកគេនឹងមិនត្រូវបានគេជួយឡើយ។

17. រីឯក្រុមសាមូទវិញ ពិតណាស់ យើងបានចង្អុលបង្ហាញពួកគេ។ ប៉ុន្តែពួកគេបែរជាពេញចិត្តភាពងងឹតជាងការចង្អុលបង្ហាញទៅវិញ។ ពេលនោះ រន្ទះនៃទណ្ឌកម្មដ៏អាម៉ាស់បំផុតក៏បានឆក់យកជីវិតពួកគេដោយសារតែអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

18. ហើយយើងបានសង្គ្រោះបណ្តាអ្នកដែលមានជំនឿដែលពួកគេធ្លាប់បានកោតខ្លាច(អល់ឡោះ)។

19. ហើយនៅថ្ងៃដែលគេប្រមូលផ្តុំសត្រូវទាំងឡាយរបស់អល់ឡោះទៅកាន់ឋាននរកដោយពួកគេត្រូវបានគេរុញបញ្ចូល(ទៅក្នុងឋាននរក)។

20. លុះនៅពេលដែលពួកគេទៅដល់ឋាននរក (ហើយពួកគេមិនទទួលស្គាល់អំពើល្មើសរបស់ខ្លួន) ពេលនោះ ត្រចៀក ភ្នែក ហើយនិងស្បែករបស់ពួកគេក៏បានធ្វើសាក្សីប្រឆាំងនឹងពួកគេចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

21. ហើយពួកគេបាននិយាយទៅកាន់ស្បែករបស់ពួកគេថា៖ ហេតុអ្វីបានជាពួកឯងធ្វើសាក្សីប្រឆាំងនឹងយើង? ពួកវាបានតបថា៖ អល់ឡោះជាអ្នកដែលឲ្យពួកយើង(អវៈយវៈ)អាចនិយាយបាន ជាអ្នកឱ្យអ្វីៗទាំងអស់ចេះនិយាយ។ ហើយទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នកតាំងពីដំបូង។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

22. ហើយពួកអ្នកមិនអាចលាក់បាំងមិនឱ្យត្រចៀករបស់ពួកអ្នក ភ្នែករបស់ពួកអ្នក និងស្បែករបស់ពួកអ្នកធ្វើសាក្សីប្រឆាំងនឹងពួកអ្នកបានឡើយ។ ក៏ប៉ុន្តែពួកអ្នកគិតស្មានថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនដឹងច្រើនទេនូវអ្វីដែលពួកអ្នកបានប្រព្រឹត្តនោះ។

23. ការគិតស្មាន(ដ៏អាក្រក់)របស់ពួកអ្នកដែលបានគិតស្មានទៅលើព្រះជាម្ចាស់របស់ពួកអ្នកនោះហើយដែលធ្វើឱ្យពួកអ្នកអន្តរាយ។ ហេតុនេះ ពួកអ្នកក៏ក្លាយទៅជាអ្នកដែលស្ថិតក្នុងចំណោមពួកដែលខាតបង់។

24. ទោះបីជាពួកគេទ្រាំអត់ធ្មត់ក៏ដោយ ក៏ឋាននរកនៅតែជាកន្លែងស្នាក់នៅសម្រាប់ពួកគេដដែល។ ហើយបើទោះជាពួកគេសុំត្រឡប់(ទៅកាន់លោកិយវិញ)ក៏ដោយ ក៏ពួកគេមិនត្រូវបានគេឆ្លើយតបនោះដែរ។

25. ហើយយើងបានរៀបចំសម្រាប់ពួកទាំងនោះឱ្យមានគូកន(អំពីពួកស្ដែតន)ដោយពួកវាតុបតែងលម្អឱ្យពួកគេទាំងពីខាងមុខនិងពីខាងក្រោយពួកគេ។ ហើយពាក្យ(ទណ្ឌកម្ម)ក៏បានធ្លាក់ទៅលើពួកគេដូចប្រជាជាតិជំនាន់មុនជាច្រើននៃពួកជិន និងមនុស្សលោកដែរ។ ពិតប្រាកដណាស់ ពួកគេធ្លាប់ជាពួកដែលខាតបង់បំផុត។

26. ហើយពួកគ្មានជំនឿបាននិយាយថា៖ ចូរពួកអ្នកកុំស្ដាប់គម្ពីរគួរអាននេះឱ្យសោះ តែពួកអ្នកត្រូវដំឡើងសំឡេងខ្លាំងវិញ សង្ឃឹមថាពួកអ្នកនឹងទទួលបានជ័យជម្នះ។

27. ដូច្នេះ យើងប្រាកដជានឹងឱ្យពួកប្រឆាំងនោះភ្លក់នូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត(នៅថ្ងៃបរលោក)។ ហើយយើងពិតជានឹងតបស្នងដល់ពួកគេនូវអ្វីដែលអាក្រក់ជាងអ្វីដែលពួកគេធ្លាប់បានសាងទៅទៀត។

28. ការតបស្នងចំពោះសត្រូវទាំងឡាយរបស់អល់ឡោះនោះ គឺឋាននរក។ នៅក្នុងនោះ សម្រាប់ពួកគេនឹងទទួលបានកន្លែងស្នាក់នៅដែលអមតៈជាការតបស្នងចំពោះការប្រឆាំងរបស់ពួកគេនឹងសញ្ញាក៏ស្ដុតាងទាំងឡាយរបស់យើង។

29. ហើយពួកប្រឆាំងបាននិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាឱ្យយើងខ្ញុំបានឃើញពួកជិន និងពួកមនុស្សដែលបានធ្វើឱ្យយើងខ្ញុំវង្វេងផង។ យើងខ្ញុំនឹងដាក់គេទាំងពីរក្រោមបាតជើងរបស់យើងខ្ញុំនៅក្នុងឋាននរក ដើម្បីឱ្យគេទាំងពីរស្ថិតក្នុងចំណោមពួកដែលស្ថិតក្នុងបាតនរក។

30. ពិតប្រាកដណាស់ បណ្ដាអ្នកដែលនិយាយថា៖ "ព្រះជាម្ចាស់របស់ពួកយើង គឺអល់ឡោះ" ក្រោយមកគេបានប្រកាន់ខ្ជាប់(ក្បួនច្បាប់របស់ទ្រង់) ម៉ាឡាអ៊ីកាត់នឹងចុះមកកាន់ពួកគេ(នៅពេលជិតស្លាប់ ដោយនិយាយថា៖) សូមពួកអ្នកកុំខ្លាច និងកុំមានទុក្ខព្រួយ ហើយសូមពួកអ្នករីករាយនឹងឋានសួគ៌ដែលពួកអ្នកធ្លាប់បានគេសន្យា។

31. ពួកយើងគឺជាអ្នកគាំពារពួកអ្នកទាំងនៅក្នុងជីវិតលោកិយ និងនៅថ្ងៃបរលោក។ ហើយនៅក្នុងឋានសួគ៌នោះ ពួកអ្នកនឹងបានទទួលបាននូវអ្វីដែលពួកអ្នកប៉ងប្រាថ្នា ហើយនៅក្នុងនោះដែរ ពួកអ្នកនឹងទទួលបាននូវអ្វីដែលពួកអ្នកស្នើសុំ។

32. ជាការទទួលស្វាគមន៍អំពីព្រះជាម្ចាស់ដ៏មហាអភ័យទោស មហាអាណិតស្រលាញ់។

33. ហើយគ្មាននរណាម្នាក់ដែលមានពាក្យសម្ដីល្អប្រសើរជាងអ្នកដែលអំពាវនាវទៅកាន់អល់ឡោះ និងបានសាងទង្វើកុសលព្រមទាំងបាននិយាយថា៖ ពិតប្រាកដណាស់ រូបខ្ញុំគឺស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)នោះឡើយ។

34. ហើយអំពើល្អ និងអំពើអាក្រក់មិនស្មើគ្នានោះទេ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបត(ចំពោះអំពើអាក្រក់)ដោយអ្វីដែលប្រសើរជាង។ ពេលនោះ អ្នកដែលរវាងរូបអ្នក និងរូបគេមានភាពជាសត្រូវនោះ នឹងក្លាយទៅជាមិត្តជិតស្និទ្ធដ៏ល្អជាមិនខាន។

35. ហើយគ្មាននរណាដែលទទួលបានបែបនេះឡើយ លើកលែងតែអ្នកដែលអត់ធ្មត់។ ហើយក៏គ្មាននរណាម្នាក់ដែលទទួលបានបែបនេះនោះដែរ លើកលែងតែអ្នកដែលមានភ័ព្វសំណាងដ៏ធំធេងប៉ុណ្ណោះ។

36. ហើយប្រសិនបើស្មៃតនបានមកញុះញង់អ្នកដោយប្រការណាមួយ ចូរអ្នកសុំការបញ្ជៀសពីអល់ឡោះចុះ។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

37. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺពេលយប់ ពេលថ្ងៃ ព្រះអាទិត្យ និងព្រះចន្ទ។ ចូរពួកអ្នកកុំស៊ូជោតចំពោះព្រះអាទិត្យ និងកុំស៊ូជោតចំពោះព្រះចន្ទឱ្យសោះ តែពួកអ្នកត្រូវស៊ូជោតចំពោះអល់ឡោះ(តែមួយគត់)ដែលបានបង្កើតពួកវាវិញ ប្រសិនបើពួកអ្នកជាអ្នកដែលគោរពសក្ការៈចំពោះទ្រង់(យ៉ាងពិតប្រាកដ)មែននោះ។

38. តែប្រសិនបើពួកអ្នកក្រអឺតក្រទម ក៏បណ្តាអ្នកដែលនៅឯព្រះជាម្ចាស់របស់អ្នក(ម៉ាឡាអ៊ីកាត់) ពួកគេលើកតម្កើងទ្រង់ទាំងយប់ ទាំងថ្ងៃដែរ ហើយពួកគេមិនមានការធុញទ្រាន់ឡើយ។

39. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ផងដែរ គឺពិតណាស់អ្នកបានឃើញផែនដីរាំងស្ងួត។ តែនៅពេលដែលយើងបានបញ្ចុះទឹកភ្លៀងទៅលើវា វាក៏រស់រានមានជីវិត និងមានរុក្ខជាតិដុះឡើង។ ពិតប្រាកដណាស់ អ្នកដែលអាចធ្វើឱ្យវា(ដី)មានជីវិតឡើងវិញ(មានរុក្ខជាតិដុះ) គឺពិតជាអ្នកដែលអាចធ្វើឱ្យអ្នកដែលស្លាប់រស់ឡើងវិញផងដែរ។ ពិតប្រាកដណាស់ ទ្រង់មានមហាអានុភាពលើអ្វីៗទាំងអស់។

40. ពិតប្រាកដណាស់ ពួកដែលងាកចេញពីបណ្តាវាក្យខណ្ឌរបស់យើង ពួកគេមិនអាចលាក់បាំងពីយើងបានឡើយ។ ដូច្នេះតើអ្នកដែលត្រូវបានគេបោះចូលទៅក្នុងភ្លើងនរកនោះប្រសើរជាង ឬក៏អ្នកដែលបានមកដល់នៅថ្ងៃបរលោកដោយមានសុវត្ថិភាព(រួចផុតពីទណ្ឌកម្ម)នោះប្រសើរជាង? ចូរពួកអ្នកធ្វើនូវអ្វីដែលពួកអ្នកចង់ចុះ។ ពិតប្រាកដណាស់ ទ្រង់ឃើញបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

41. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងគម្ពីរគួរអាននៅពេលដែលគម្ពីរនេះបានមកដល់ពួកគេហើយនោះ (ពួកគេពិតជានឹងត្រូវទទួលទណ្ឌកម្ម)។ ហើយពិតប្រាកដណាស់ វាគឺជាគម្ពីរដ៏ឧត្តុង្គឧត្តម។

42. ប្រការមិនពិតមិនអាចមកដល់គម្ពីរនេះ(គម្ពីរគួរអាន)បានឡើយ ទាំងនៅពីមុខ និងទាំងនៅពីក្រោយគម្ពីរនេះ។ ជាការបញ្ចុះមកពីព្រះជាម្ចាស់ដ៏មហាគតិបណ្ឌិត ជាអ្នកដែលត្រូវបានគេកោតសរសើរបំផុត។

43. អ្វីដែលគេនិយាយទៅកាន់អ្នក(ព្យាការីមូហាំម៉ាត់) ក៏ដូចតែអ្វីដែលគេបាននិយាយទៅកាន់បណ្តាអ្នកនាំសារជំនាន់មុនអ្នកដូចគ្នាដែរ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់មានការអភ័យទោស និងមានទណ្ឌកម្មដ៏ឈឺចាប់បំផុត។

44. ហើយប្រសិនបើយើងបញ្ចុះគម្ពីរគួរអាននេះជាភាសាផ្សេងពីភាសាអារ៉ាប់នោះ ប្រាកដជាពួកគេនឹងនិយាយថា៖ ហេតុអ្វីបានជាគេមិនបកស្រាយបញ្ជាក់នូវវាក្យខណ្ឌទាំងឡាយរបស់គម្ពីរនេះ? តើអាចទេដែលគម្ពីរគួរអាននេះជាភាសាផ្សេង ខណៈដែលគាត់(ព្យាការីមូហាំម៉ាត់)ជាជនជាតិអារ៉ាប់នោះ? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ គម្ពីរនេះ(គួរអាន)ជាការចង្អុលបង្ហាញ និងជាឱសថព្យាបាលសម្រាប់បណ្តាអ្នកដែលមានជំនឿ។ រីឯពួកដែលគ្មានជំនឿវិញ នៅក្នុងត្រចៀករបស់ពួកគេ គឺមានឆ្នុក ហើយវាគឺជាភាពងងឹតចំពោះពួកគេ។ ពួកទាំងនោះ(ហាក់បីដូចជា)ត្រូវបានគេស្រែកហៅពីទីកន្លែងដ៏ឆ្ងាយដូច្នោះដែរ។

45. ហើយពិតប្រាកដណាស់ យើងបានប្រទានឱ្យព្យាការីមូសានូវគម្ពីរ(តាវ៉ាត)។ ក្រោយមក គេបានខ្វែងគំនិតគ្នាចំពោះគម្ពីរនេះ។ ហើយប្រសិនបើគ្មានការកំណត់កាលពីមុនពីព្រះជាម្ចាស់របស់អ្នកទេនោះ ប្រាកដជាទ្រង់នឹងកាត់សេចក្តីរវាងពួកគេ(ភ្លាមៗ)ជាមិនខាន។ ហើយពិតប្រាកដណាស់ ពួកគេ(ពួកគ្មានជំនឿ)គឺស្ថិតនៅក្នុងភាពមន្ទិលសង្ស័យយ៉ាងខ្លាំងពីគម្ពីរនេះ(គម្ពីរគួរអាន)។

46. ជនណាដែលបានសាងទង្វើកុសល វាគឺសម្រាប់ខ្លួនគេផ្ទាល់។ ហើយជនណាដែលបានសាងអំពើអាក្រក់ វាក៏នឹងធ្លាក់លើរូបគេដូចគ្នា។ ហើយព្រះជាម្ចាស់របស់អ្នកមិនមែនជាអ្នកបំពានលើខ្ញុំបម្រើទាំងឡាយ(របស់ទ្រង់)ឡើយ។

47. ចំណេះដឹងនៃថ្ងៃបរលោក គឺត្រឡប់ទៅកាន់ទ្រង់(តែមួយគត់)។ គ្មានផ្លែឈើអ្វីមួយដែលចេញពីស្រទាប់របស់វា ហើយក៏គ្មានសត្វញីណាមួយពរពោះ និងកើតកូននោះដែរ លើកលែងតែដោយការដឹងរបស់ទ្រង់ទាំងអស់។ ហើយនៅថ្ងៃដែលទ្រង់ហៅពួកគេ(ពួកដែលធ្វើស្ហ៊ីរិក)ថា៖ តើដៃគូទាំងឡាយរបស់យើង(ដែលពួកអ្នកធ្លាប់អះអាង)នោះនៅឯណា? ពួកគេឆ្លើយថា៖ យើងខ្ញុំសូមទទួលស្គាល់នៅចំពោះមុខព្រះអង្គថា គ្មាននរណាម្នាក់នៃយើងខ្ញុំធ្វើសាក្សីថា ព្រះអង្គមានដៃគូឡើយ។

48. ហើយអ្វីដែលពួកគេធ្លាប់គោរពសក្ការៈកាលពីមុននោះ បានបាត់បង់អំពីពួកគេ។ ហើយពួកគេបានដឹងយ៉ាងច្បាស់ថា គ្មានកន្លែងជ្រកកោនសម្រាប់ពួកគេ(ពីទណ្ឌកម្ម)នោះឡើយ។

49. មនុស្សលោកមិនធុញទ្រាន់នឹងការសុំចង់បានប្រការល្អនោះឡើយ។ តែប្រសិនបើគេជួបប្រទះប្រការអាក្រក់វិញ ពេលនោះពួកគេនឹងមានការអស់សង្ឃឹមយ៉ាងខ្លាំង។

50. ហើយប្រសិនបើយើងបានឱ្យគេភ្លក់នូវក្តីមេត្តាករុណាអំពីយើងក្រោយពីគេទទួលនូវគ្រោះ ប្រាកដជាគេនឹងនិយាយថា៖ នេះគឺដោយសារខ្ញុំស័ក្តិសមនឹងទទួលបានវា។ ហើយខ្ញុំមិនគិតថា ថ្ងៃបរលោកនឹងកើតឡើងនោះឡើយ។ តែប្រសិនបើខ្ញុំត្រូវគេនាំត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ខ្ញុំវិញ ប្រាកដជាខ្ញុំនឹងទទួលបាននូវប្រការល្អនៅឯទ្រង់ជាមិនខាន។ ដូច្នេះយើង(អល់ឡោះ)ប្រាកដជានឹងប្រាប់ពួកដែលគ្មានជំនឿនូវអ្វីដែលពួកគេបានប្រព្រឹត្ត ហើយយើងប្រាកដជានឹងឱ្យពួកគេភ្លក់នូវទណ្ឌកម្មដ៏ខ្លាំងក្លាជាទីបំផុត។

51. ហើយនៅពេលដែលយើងបានប្រទានឧបការគុណដល់មនុស្ស គេបានបែរចេញពីការដឹងគុណ។ តែនៅពេលដែលគេជួបប្រទះនឹងប្រការអាក្រក់វិញនោះ គឺគេបួងសួងសុំយ៉ាងច្រើន។

52. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើគម្ពីរនេះ(គម្ពីរគួរអាន)ពិតជាមកពីអល់ឡោះមែនក្រោយមក ពួកអ្នកបែរជាប្រឆាំងនឹងវាទៅវិញ ថាតើអ្នកណាដែលវង្វេងជាងអ្នកដែលខ្វែងគំនិតគ្នាដ៏សែនឆ្ងាយ(អំពីការពិត)នោះ?

53. យើងនឹងឱ្យពួកគេបានឃើញនូវសញ្ញាកស្តតាងទាំងឡាយរបស់យើងគ្រប់ទិសទីនៃផែនដី និងនៅក្នុងខ្លួនរបស់ពួកគេផ្ទាល់ រហូតដល់វាបានបញ្ជាក់យ៉ាងច្បាស់សម្រាប់ពួកគេថា៖ ជាការពិតណាស់ គម្ពីរនេះ(គម្ពីរគួរអាន) គឺជាការពិត។ តើមិនគ្រប់គ្រាន់ទៀតឬដែលព្រះជាម្ចាស់របស់អ្នកទ្រង់ជាសាក្សីលើរាល់អ្វីៗទាំងអស់។

54. តើពុំមែនទេឬដែលថា ពិតណាស់ ពួកគេស្ថិតនៅក្នុងភាពមន្ទិលសង្ស័យអំពីការជួបនឹងព្រះជាម្ចាស់របស់ពួកគេ(នៅថ្ងៃបរលោក)។ តើពុំមែនទេឬដែលថា ពិតប្រាកដណាស់ ទ្រង់មហាជ្រួតជ្រាបនូវរាល់អ្វីៗទាំងអស់។

ជំពូក អាសស្ស៊ូរ៉ា

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. អ៊ីន ស៊ីន កហ្វ (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

3. វាហ៊ីដែលគេបានផ្តល់ទៅកាន់អ្នក(ព្យាការីមូហាំម៉ាត់)គឺដូចគ្នានឹងវាហ៊ីដែលគេបានផ្តល់ឱ្យបណ្តាព្យាការីជំនាន់មុនអ្នកដែរ។ អល់ឡោះជាម្ចាស់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

4. អ្វីដែលនៅលើមេឃជាច្រើនជាន់ និងអ្វីដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយទ្រង់មហាខ្ពង់ខ្ពស់ មហាធំធេង។

5. មេឃជាច្រើនជាន់ស្ទើរតែប្រេះបែកពីផ្នែកខាងលើរបស់វា ហើយម៉ាឡាអ៊ីកាត់ទាំងឡាយបានលើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់ពួកគេ និងសុំអភ័យទោសឲ្យអ្នកដែលនៅលើផែនដី។ តើពុំមែនទេឬ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

6. ហើយពួកដែលយកអ្នកផ្សេងក្រៅទ្រង់ធ្វើជាអ្នកគាំពារនោះ អល់ឡោះទ្រង់ជាអ្នកឃ្លាំមើលពួកគេ។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនមែនជាអ្នកទទួលខុសត្រូវលើពួកគេនោះឡើយ។

7. ក៏ដូច្នោះដែរ យើងបានផ្តល់វាហ៊ីទៅកាន់អ្នក(ព្យាការីមូហាំម៉ាត់)នូវគម្ពីរគួរអានជាភាសាអារ៉ាប់ដើម្បីឱ្យអ្នកដាស់តឿនព្រមានដល់អ្នកស្រុកម៉ាក្កះ និងអ្នកដែលនៅជុំវិញវា ព្រមទាំងដាស់តឿនព្រមាន(ពួកគេ)ពីថ្ងៃប្រមូលផ្តុំ(ថ្ងៃបរលោក)ដែលគ្មានការសង្ស័យឡើយចំពោះវា។ (នៅថ្ងៃនោះ) មួយក្រុមស្ថិតក្នុងឋានសួគ៌ ហើយមួយក្រុមទៀតស្ថិតក្នុងនរកដែលឆេះសន្ធោសន្ធៅ។

8. ហើយប្រសិនបើអល់ឡោះមានចេតនា ទ្រង់ប្រាកដជានឹងធ្វើឱ្យពួកគេក្លាយជាប្រជាជាតិតែមួយជាមិនខាន។ ក៏ប៉ុន្តែ ទ្រង់បញ្ចូលជនណាដែលទ្រង់មានចេតនាទៅក្នុងក្តីមេត្តាករុណារបស់ទ្រង់។ រីឯពួកដែលបំពាន សម្រាប់ពួកគេ គឺគ្មានអ្នកគាំពារ ហើយក៏គ្មានអ្នកជួយនោះដែរ។

9. ផ្ទុយទៅវិញ ពួកគេ(ពួកមុស្លរីគីន)បានយកអ្នកផ្សេងក្រៅពីអល់ឡោះធ្វើជាអ្នកគាំពារ។ ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកគាំពារ ហើយទ្រង់ជាអ្នកធ្វើឲ្យអ្នកស្លាប់រស់ឡើងវិញ(នៅថ្ងៃបរលោក)។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

10. ហើយប្រការអ្វីមួយដែលពួកអ្នកបានខ្វែងគំនិតគ្នាចំពោះវា ពិតប្រាកដណាស់ ការកាត់សេចក្តីចំពោះវា គឺទៅកាន់អល់ឡោះ(គម្ពីរគួរអាន និងស៊ុណ្ណះ)។ នោះហើយគឺអល់ឡោះដែលជាព្រះជាម្ចាស់របស់ខ្ញុំ។ ចំពោះទ្រង់(តែមួយគត់)ដែលខ្ញុំប្រគល់ការទុកចិត្ត ហើយចំពោះទ្រង់(តែមួយគត់)ដែលខ្ញុំវិលត្រឡប់។

11. ទ្រង់ជាអ្នកបង្កើតមេឃជាច្រើនជាន់និងផែនដី។ ទ្រង់បានបង្កើតសម្រាប់ពួកអ្នកអំពីខ្លួនរបស់ពួកអ្នកផ្ទាល់ឲ្យមានជាគូ ហើយក្នុងចំណោមសត្វពាហនៈក៏មានជាគូដែរ។ ទ្រង់ឲ្យពួកអ្នកមានចំនួនកាន់តែច្រើនឡើង(តាមរយៈការរៀបអាពាហ៍ពិពាហ៍)។ គ្មានអ្វីមួយអាចប្រដូចនឹងទ្រង់បានឡើយ។ ហើយទ្រង់មហាឮ មហាឃើញបំផុត។

12. កូនសោ(ឃ្លាំង)នៃមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ទ្រង់បើកទូលាយ និងគ្រិតគ្រៀតលាភសក្ការៈ(របស់ទ្រង់)ចំពោះជនណាដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ ទ្រង់មហាដឹងបំផុតនូវគ្រប់អ្វីៗទាំងអស់។

13. ទ្រង់បានដាក់ចេញនូវច្បាប់បញ្ញត្តិសាសនា(អ៊ីស្លាម)សម្រាប់ពួកអ្នក ដូចអ្វីដែលទ្រង់បានផ្តែផ្តាំវាចំពោះព្យាការីនួហានោះដែរ។ ហើយអ្វីដែលយើងបានផ្តល់វាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) គឺដូចអ្វីដែលយើងបានផ្តែផ្តាំចំពោះព្យាការីអ៊ីព្រហ៊ីម ព្យាការីមូសា និងព្យាការីអ៊ីសាដែរ គឺពួកអ្នកត្រូវបញ្ឈរសាសនា និងមិនត្រូវបែកបាក់គ្នានៅក្នុងវានោះឡើយ។ អ្វីដែលពួកអ្នកកំពុងតែអំពាវនាវពួកគេទៅកាន់នោះ គឺធ្ងន់ធ្ងរបំផុតចំពោះពួកមុស្រីគីន។ អល់ឡោះជ្រើសរើសទៅកាន់ទ្រង់ចំពោះជនណាដែលទ្រង់មានចេតនា និងចង្អុលបង្ហាញទៅកាន់ទ្រង់ចំពោះជនណាដែលវិលត្រឡប់(សារភាពកំហុស)។

14. ហើយពួកគេ(ពួកមុស្រីគីន)មិនបានបែកបាក់គ្នាឡើយ លើកលែងតែក្រោយពីចំណេះដឹងបានមកដល់ពួកគេដោយសារតែការបំពានរវាងពួកគេប៉ុណ្ណោះ។ ហើយប្រសិនបើគ្មានការកំណត់ជាមុនពីព្រះជាម្ចាស់របស់អ្នករហូតដល់ពេលកំណត់ទេនោះប្រាកដជាគេនឹងកាត់ក្តីរវាងពួកគេ(ភ្លាមៗ)ជាមិនខាន។ ហើយពិតប្រាកដណាស់ ពួកដែលទទួលមរតកគម្ពីរ(តាវ៉ាត និងអ៊ិញជីល)ក្រោយពីពួកគេ គឺស្ថិតក្នុងភាពមន្ទិលសង្ស័យយ៉ាងច្បាស់ចំពោះគម្ពីរនេះ(គម្ពីរគួរអាន)។

15. ដូច្នេះ ចំពោះសាសនាដ៏ត្រឹមត្រូវនេះ ចូរអ្នកអំពាវនាវ(មនុស្ស) ហើយចូរអ្នកប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដូចអ្វីដែលគេបានបង្គាប់ប្រើចំពោះអ្នក និងមិនត្រូវដើរតាមទំនើងចិត្តរបស់ពួកគេឡើយ។ ហើយចូរអ្នកពោលថា៖ ខ្ញុំមានជំនឿចំពោះគម្ពីរដែលអល់ឡោះបានបញ្ចុះមក។ ហើយគេបានបង្គាប់ប្រើខ្ញុំឱ្យកាត់សេចក្តីរវាងពួកអ្នកដោយយុត្តិធម៌។ អល់ឡោះ គឺជាព្រះជាម្ចាស់របស់ពួកយើង និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ទង្វើរបស់ពួកយើង គឺសម្រាប់ពួកយើង ហើយទង្វើរបស់ពួកអ្នក គឺសម្រាប់ពួកអ្នក។ គ្មានការប្រកែកគ្នានោះទេរវាងពួកយើងនិងពួកអ្នក។ អល់ឡោះទ្រង់នឹងប្រមូលផ្តុំរវាងពួកយើងទាំងអស់គ្នា។ ហើយកន្លែងវិលត្រឡប់(នៅថ្ងៃបរលោក)គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

16. ហើយពួកដែលជជែកដេញដោលពីរឿង(សាសនា)អល់ឡោះជាម្ចាស់ក្រោយពីមានគេទទួលយកវាហើយនោះ ការជជែកដេញដោលរបស់ពួកគេ គឺត្រូវសោបសូន្យនៅចំពោះមុខព្រះជាម្ចាស់របស់ពួកគេ។ ហើយពួកគេនឹងទទួលនូវកំហឹងសម្បា(ពីអល់ឡោះ)។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

17. អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកដែលបានបញ្ចុះគម្ពីរទាំងឡាយដោយពិតប្រាកដ ហើយនិងជញ្ជីងនៃភាពយុត្តិធម៌។ ហើយតើអ្វីដែលធ្វើឲ្យអ្នកដឹងថា ថ្ងៃបរលោក ជិតនឹងមកដល់នោះ?

18. ពួកដែលគ្មានជំនឿសុំឱ្យវា(ថ្ងៃបរលោក)ឆាប់មកដល់។ រីឯបណ្តាអ្នកដែលមានជំនឿវិញ ពួកគេខ្លាចថ្ងៃនោះ ហើយពួកគេដឹងច្បាស់ថា វាគឺជាការពិត។ តើពុំមែនទេឬដែលថា ពិតប្រាកដណាស់ ពួកដែលមន្ទិលសង្ស័យចំពោះថ្ងៃបរលោកនោះគឺពិតជាស្ថិតក្នុងភាពវង្វេងដ៏សែនឆ្ងាយ។

19. អល់ឡោះទ្រង់មានភាពទន់ភ្លន់បំផុតចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ទ្រង់ប្រទានលាភសក្ការៈដល់ជនណាដែលទ្រង់មានចេតនា។ ហើយទ្រង់មហាខ្លាំងក្លា មហាខ្លាំងពូកែ។

20. ជនណាដែលចង់បានផលបុណ្យថ្ងៃបរលោក យើងនឹងបន្ថែមដល់គេចំពោះផលបុណ្យរបស់គេ។ រីឯជនណាដែលចង់បានតែផលបុណ្យលោកិយ យើងនឹងប្រទានឱ្យគេអំពីវា។ ហើយនៅថ្ងៃបរលោក សម្រាប់រូបគេ គឺគ្មានទទួលបានចំណែកអ្វីឡើយ។

21. ឬមួយពួកគេមានព្រះនានាផ្សេងពីអល់ឡោះដែលបានដាក់ច្បាប់បញ្ញត្តិសាសនាសម្រាប់ពួកគេនូវអ្វីដែលអល់ឡោះមិនបានអនុញ្ញាត? ហើយប្រសិនបើគ្មានការកំណត់(ពីអល់ឡោះ)ទេនោះ ប្រាកដជាគេនឹងកាត់សេចក្តីរវាងពួកគេ(ភ្លាមៗ)ជាមិនខាន។ ហើយពិតប្រាកដណាស់ ពួកដែលបំពាន សម្រាប់ពួកគេនឹងទទួលទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

22. អ្នកនឹងឃើញពួកដែលបំពានមានការភ័យខ្លាចចំពោះអ្វីដែលពួកគេបានប្រព្រឹត្ត ខណៈដែលវា(ទណ្ឌកម្ម)ធ្លាក់លើពួកគេ។ រីឯបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលវិញនោះ ពួកគេស្ថិតនៅក្នុងសួនឧទ្យានទាំងឡាយនៃឋានសួគ៌។ ពួកគេទទួលបាននូវអ្វីដែលពួកគេប្រាថ្នានៅឯព្រះជាម្ចាស់របស់ពួកគេ។ នោះហើយគឺជាការប្រោសប្រទានដ៏ធំធេងបំផុត។

23. នោះហើយជាអ្វីដែលអល់ឡោះផ្តល់ជាដំណឹងរីករាយដល់ខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដែលមានជំនឿ និងសាងទង្វើកុសល។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំមិនទាមទារពីពួកអ្នកនូវការតបស្នងអ្វីចំពោះវាឡើយ លើកលែងតែក្តីស្រលាញ់ក្នុងភាពជាសាច់ញាតិប៉ុណ្ណោះ។ ហើយជនណាដែលបានសាងអំពើល្អមួយ យើងនឹងបន្ថែមប្រការល្អដល់គេថែមទៀត។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាដឹងគុណបំផុត។

24. ឬមួយពួកគេនិយាយថា៖ រូបគេ(ព្យាការីមូហាំម៉ាត់)ប្រឌិតកុហកទៅលើអល់ឡោះ។ ពិតណាស់ ប្រសិនបើអល់ឡោះមានចេតនា ទ្រង់នឹងបោះត្រាភ្ជិតលើដួងចិត្តរបស់អ្នក ហើយទ្រង់នឹងលុបបំបាត់ប្រការខុសឆ្គង និងពង្រឹងភាពត្រឹមត្រូវដោយបន្ទូលរបស់ទ្រង់ជាមិនខាន។ ប្រាកដណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុងដួងចិត្ត។

25. ហើយទ្រង់ជាអ្នកទទួលយកនូវការសារភាពកំហុសពីខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ និងអធ្យាស្រ័យ(លើកលែងទោស)ចំពោះអំពើអាក្រក់ទាំងឡាយ(របស់ពួកគេ)។ ហើយទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

26. ហើយទ្រង់ទទួលយកនូវការឆ្លើយតបរបស់បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ព្រមទាំងបន្ថែមដល់ពួកគេនូវការប្រោសប្រទានរបស់ទ្រង់ថែមទៀត។ រីឯពួកដែលគ្មានជំនឿ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

27. ហើយប្រសិនបើអល់ឡោះទ្រង់បើកទូលាយនូវលាភសក្ការៈចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ប្រាកដជាពួកគេនឹងបំពាននៅលើផែនដីជាមិនខាន។ ក៏ប៉ុន្តែទ្រង់បញ្ចុះទៅតាមកម្រិត(បរិមាណ)ដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ ទ្រង់មហាដឹង មហាឃើញបំផុត ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

28. ហើយទ្រង់ជាអ្នកដែលបញ្ចុះទឹកភ្លៀងក្រោយពីពួកគេបានអស់សង្ឃឹម(ថានឹងមិនមានភ្លៀងធ្លាក់) ហើយទ្រង់ស្រោចស្រពក្តីមេត្តាករុណារបស់ទ្រង់។ ហើយទ្រង់ជាអ្នកគាំពារ ជាអ្នកដែលត្រូវគេកោតសរសើរ។

29. ហើយក្នុងចំណោមសញ្ញាកស្តតាងរបស់ទ្រង់ គឺការបង្កើតមេឃជាច្រើនជាន់និងផែនដី ព្រមទាំងបានពង្រាយនូវសត្វលោកជាច្រើននៅលើវាទាំងពីរ(មេឃនិងផែនដី)។ ហើយនៅពេលណាដែលទ្រង់មានចេតនា ទ្រង់មានសមត្ថភាពបំផុតក្នុងការប្រមូលផ្តុំពួកគេ។

30. ហើយគ្រោះថ្នាក់ណាមួយដែលពួកអ្នក(មនុស្សលោក)ទទួលរង គឺដោយសារតែអ្វីដែលបានប្រព្រឹត្តដោយផ្ទាល់ដៃពួកអ្នក ហើយទ្រង់បានអធ្យាស្រ័យយ៉ាងច្រើន(ចំពោះពួកអ្នក)។

31. ហើយពួកអ្នកពុំមានសមត្ថភាព(ក្នុងការរត់គេចពីទណ្ឌកម្មអល់ឡោះ)នៅលើផែនដីនោះឡើយ។ ហើយពួកអ្នកក៏គ្មានអ្នកគាំពារ និងអ្នកជួយណាក្រៅពីអល់ឡោះនោះដែរ។

32. ហើយក្នុងចំណោមសញ្ញាកស្តុតាងរបស់ទ្រង់ គឺសំពៅ(ដ៏ធំដែលធ្វើដំណើរ)លើផ្ទៃសមុទ្រ ប្រៀបដូចជាភ្នំ។

33. ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងធ្វើឱ្យខ្យល់ឈប់បោកបក់ ហើយសំពៅនោះនឹងនៅនឹងថ្កល់លើផ្ទៃសមុទ្រជាមិនខាន។ ប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់រាល់អ្នកដែលអត់ធ្មត់ និងអ្នកដែលចេះដឹងគុណ។

34. ឬទ្រង់នឹងបំផ្លាញវាដោយសារតែអ្វី(បាបកម្ម)ដែលពួកគេបានប្រព្រឹត្ត។ ហើយទ្រង់បានអធ្យាស្រ័យ(ឱ្យពួកគេ)យ៉ាងច្រើនទៅហើយ។

35. ហើយពួកដែលជជែកដេញដោលចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើង ពួកគេបានដឹងថា សម្រាប់ពួកគេ គឺពុំមានកន្លែងជ្រកកោន(ពីទណ្ឌកម្មយើង)ឡើយ។

36. ហើយអ្វីក៏ដោយដែលគេបានប្រទានឱ្យពួកអ្នក(ឱមនុស្សលោក)វាគ្រាន់តែជាភាពត្រេកត្រអាលនៃជីវិតលោកិយប៉ុណ្ណោះ។ ក៏ប៉ុន្តែ អ្វីដែលនៅឯអល់ឡោះជាម្ចាស់ គឺល្អប្រសើរ និងបឋមបវេជ្ឈនោះទៅទៀតសម្រាប់បណ្តាអ្នកដែលមានជំនឿ ហើយពួកគេប្រគល់ការទុកចិត្តចំពោះព្រះជាម្ចាស់របស់ពួកគេ។

37. និងបណ្តាអ្នកដែលចៀសឆ្ងាយពីបាបកម្មធំៗ និងប្រការអាក្រក់ផ្សេងៗ។ ហើយនៅពេលដែលពួកគេខឹងសម្បា(ចំពោះនរណាម្នាក់)គឺពួកគេអភ័យទោសឲ្យ។

38. និងបណ្តាអ្នកដែលឆ្លើយតបចំពោះព្រះជាម្ចាស់របស់ពួកគេ ហើយពួកគេប្រតិបត្តិសឡាត ហើយពួកគេចេះពិភាក្សារវាងគ្នាក្នុងកិច្ចទាំងឡាយរបស់ពួកគេ ព្រមទាំងបរិច្ចាគមួយចំនួននៃអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកគេ។

39. និងបណ្តាអ្នកដែលនៅពេលពួកគេទទួលរងការបំពាន គឺពួកគេយកឈ្នះវិញ(ដោយមិនមានការបំពាន)។

40. ហើយការតបស្នងចំពោះអំពើអាក្រក់ គឺដូចទៅនឹងអំពើអាក្រក់នោះវិញ។ តែជនណាដែលអធ្យាស្រ័យ ហើយបានផ្សះផ្សាវិញនោះ ជាការពិតណាស់ ផលបុណ្យរបស់គេ គឺនៅឯអល់ឡោះជាម្ចាស់។ ពិតប្រាកដណាស់ ទ្រង់មិនស្រលាញ់ពួកដែលបំពានឡើយ។

41. ហើយជនណាដែលតបតក្រោយពីរងនូវការបំពាន ពិតប្រាកដណាស់ អ្នកទាំងនោះ គឺគ្មានទោសពៃរ៍អ្វីទៅលើពួកគេឡើយ។

42. តាមពិត ទោសពៃរ៍នោះ គឺសម្រាប់តែពួកដែលបំពានលើមនុស្ស និងប្រព្រឹត្តល្មើសនៅលើផែនដីដោយមិនត្រឹមត្រូវប៉ុណ្ណោះ។ ពួកទាំងនោះ សម្រាប់ពួកគេនឹងត្រូវទទួលទណ្ឌកម្មដ៏ឈឺចាប់បំផុត។

43. រីឯជនណាដែលអត់ធ្មត់ ហើយអភ័យទោសឱ្យគេ ពិតប្រាកដណាស់ នោះគឺជាកិច្ចការមួយដែលត្រូវបានគេកោតសរសើរ។

44. ហើយជនណាដែលអល់ឡោះធ្វើឱ្យវង្វេងហើយនោះ ពិតប្រាកដណាស់ សម្រាប់រូបគេ គឺគ្មានអ្នកគាំពារណាបន្ទាប់ពីទ្រង់ឡើយ។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងបានឃើញពួកដែលបំពាន នៅពេលដែលពួកគេបានឃើញទណ្ឌកម្មផ្ទាល់នឹងភ្នែក(នៅថ្ងៃបរលោក) ពួកគេនឹងនិយាយថា៖ តើពួកយើងមានផ្លូវណា(ដែលអាចត្រឡប់ទៅកាន់លោកិយវិញម្តងទៀត)ដែរឬទេ?

45. ហើយអ្នកនឹងឃើញពួកគេត្រូវបានគេបង្ហាញទៅកាន់ឋាននរក គឺពួកគេឱនលំទោនដោយភាពអាម៉ាស់ ព្រមទាំងលួចសម្លឹងមើលទៅកាន់ឋាននរកដោយ(ក្រសែភ្នែកភ័យខ្លាច)។ ហើយបណ្តាអ្នកដែលមានជំនឿបាននិយាយថា៖ ពិតប្រាកដណាស់ ពួកដែលខាតបង់(ពិតប្រាកដនោះ) គឺពួកដែលបានខាតបង់ខ្លួនឯង និងក្រុមគ្រួសាររបស់ខ្លួននៅថ្ងៃបរលោក។ តើពុំមែនទេឬដែលថា ពិតប្រាកដណាស់ ពួកដែលបំពាន នឹងស្ថិតនៅក្នុងទណ្ឌកម្មជាអមតៈ។

46. ហើយសម្រាប់ពួកគេគឺគ្មានអ្នកគាំពារណាដែលអាចជួយពួកគេក្រៅពីអល់ឡោះឡើយ។ ជនណាហើយដែលអល់ឡោះធ្វើឱ្យវង្វេង ពិតណាស់ សម្រាប់រូបគេគឺគ្មានផ្លូវណា(ដែលអាចនាំរូបគេទៅកាន់ការពិត)ឡើយ។

47. ចូរពួកអ្នក(ឱមនុស្សលោកទាំងឡាយ)ឆ្លើយតបនឹងព្រះជាម្ចាស់របស់ពួកអ្នកមុននឹងថ្ងៃមួយ(ថ្ងៃបរលោក)ដែលគ្មានអ្នកណាអាចរារាំងវាពីអល់ឡោះបានមកដល់។ នៅថ្ងៃនោះ ពួកអ្នកគ្មានកន្លែងជ្រកកោននោះឡើយ ហើយពួកអ្នកក៏គ្មានការបដិសេធនោះដែរ។

48. តែប្រសិនបើពួកគេងាកចេញ ពិតប្រាកដណាស់ យើងមិនបានបញ្ជូនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាអ្នកថែរក្សាពួកគេឡើយ។ អ្នកគ្មានតួនាទីអ្វីក្រៅពីការផ្សព្វផ្សាយប៉ុណ្ណោះ។ ហើយពិតប្រាកដណាស់ នៅពេលដែលយើងបានឱ្យមនុស្សលោកភ្លក់នូវក្តីមេត្តាករុណាអំពីយើង គឺរូបគេរីករាយនឹងវា។ តែប្រសិនបើពួកគេទទួលនូវប្រការអាក្រក់ដោយសារតែអ្វី(បាបកម្ម)ដែលពួកគេបានប្រព្រឹត្ត ជាការពិតណាស់ មនុស្សលោកគឺរមិលគុណបំផុត។

49. ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ទ្រង់បង្កើតអ្វីតាមដែលទ្រង់មានចេតនា។ ទ្រង់ប្រទានឱ្យមានតែកូនស្រីចំពោះជនណាដែលទ្រង់មានចេតនា និងប្រទានឱ្យមានតែកូនប្រុសចំពោះជនណាដែលទ្រង់មានចេតនា។

50. ឬក៏ទ្រង់ប្រទានឱ្យពួកគេទាំងកូនប្រុស ទាំងកូនស្រី។ ហើយទ្រង់ក៏អាចឱ្យជនណាដែលទ្រង់មានចេតនាជាមនុស្សគ្មានកូន(អារ)ផងដែរ។ ពិតប្រាកដណាស់ ទ្រង់មហាដឹង មហាមានអានុភាពបំផុត។

51. ហើយគ្មានមនុស្សលោកណាម្នាក់ដែលអល់ឡោះទ្រង់មានបន្ទូលទៅកាន់គេនោះឡើយ លើកលែងតែតាមរយៈវ៉ាហ៊ី ឬ(ទ្រង់មានបន្ទូល)ពីក្រោយរបាំង ឬក៏ទ្រង់បញ្ជូនអ្នកនាំសារ(ជាម៉ាឡាអ៊ីកាត់)រួចគេផ្តល់វ៉ាហ៊ីនោះដោយការអនុញ្ញាតពីទ្រង់នូវអ្វីដែលទ្រង់មានចេតនា។ ពិតប្រាកដណាស់ ទ្រង់មហាខ្ពង់ខ្ពស់ មហាគតិបណ្ឌិត។

52. ក៏ដូច្នោះដែរ យើងបានផ្តល់វ៉ាហ៊ីទៅកាន់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវគម្ពីរគួរអានអំពីយើងផ្ទាល់។ អ្នកមិនធ្លាប់បានដឹងទេថា អ្វីទៅជាគម្ពីរ និងអ្វីទៅជាជំនឿនោះ។ ប៉ុន្តែយើងបានឲ្យវា(គម្ពីរគួរអាន)ជាពន្លឺបំភ្លឺដែលយើងចង្អុលបង្ហាញតាមរយៈវាចំពោះជនណាដែលយើងមានចេតនាក្នុងចំណោមខ្ញុំបម្រើរបស់យើង។ ហើយប្រាកដណាស់ រូបអ្នកពិតជាបានចង្អុលបង្ហាញ(មនុស្សលោក)ទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

53. គឺជាមាគ៌ារបស់អល់ឡោះជាម្ចាស់ដែលអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ តើពុំមែនទេឬ កិច្ចការទាំងឡាយ គឺវិលត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់(តែមួយគត់)។

ជំពូក អាសហ៊ឺឧរូហ្ស

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហាមីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន (ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. (អល់ឡោះទ្រង់)ស្បថនឹងគម្ពីរ(គួរអាន)ដ៏ច្បាស់លាស់។

3. ពិតប្រាកដណាស់ យើងបានបញ្ចុះគម្ពីរគួរអានជាភាសាអារ៉ាប់ សង្ឃឹមថាពួកអ្នកចេះគិតពិចារណា។

4. ហើយពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន)គឺស្ថិតនៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)ដែលនៅជាមួយនឹងយើងដែលមានលក្ខណៈខ្ពង់ខ្ពស់ និងប្រកបដោយគតិបណ្ឌិត។

5. ដូច្នេះ តើយើងត្រូវបញ្ឈប់ការបញ្ចុះគម្ពីរគួរអានទៅកាន់ពួកអ្នកដោយសារតែពួកអ្នកជាក្រុមដែលបំពានឬ?

6. មានព្យាការីជាច្រើននាក់ហើយដែលយើងបានបញ្ជូនទៅកាន់អ្នកជំនាន់មុនៗ។

7. ប៉ុន្តែគ្មានព្យាការីណាម្នាក់បានមកដល់ពួកគេនោះឡើយ លើកលែងតែពួកគេចំអកឡកឡឺយចំពោះព្យាការីនោះ។

8. ដូច្នេះ យើងក៏បានបំផ្លាញពួកដែលមានកម្លាំងខ្លាំងក្លាជាងពួកទាំងនោះ(ពួកមុស្លីគីន)ទៅទៀត។ ហើយគំរូ(នៃការបំផ្លាញអ្នកជំនាន់មុន)ក៏បានកើតឡើងរួចទៅហើយ។

9. ហើយប្រសិនបើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកគេ(ពួកមុស្លីគីន)ថា៖ តើអ្នកណាដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី ប្រាកដជាពួកគេនឹងឆ្លើយថា៖ អ្នកដែលបានបង្កើតពួកវា(មេឃនិងផែនដី)គឺព្រះជាម្ចាស់ដ៏មហាខ្លាំងពូកែមហាដឹងបំផុត។

10. (ទ្រង់)ជាអ្នកដែលបានបង្កើតផែនដីឱ្យមានសណ្ឋានលាតសន្ធឹងសម្រាប់ពួកអ្នក ហើយទ្រង់បានបង្កើតនូវផ្លូវជាច្រើននៅលើវាសម្រាប់ពួកអ្នក សង្ឃឹមថាពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញ។

11. ហើយ(ទ្រង់)ជាអ្នកដែលបានបញ្ចុះទឹកភ្លៀងពីលើមេឃតាមបរិមាណ(ដែលចាំបាច់)។ ហើយតាមរយៈទឹកភ្លៀងនេះ យើងបានធ្វើឱ្យដីដែលហួតហែងមានជីជាតិឡើងវិញ។ ក៏ដូច្នោះដែរ គេនឹងបញ្ចេញពួកអ្នក(ពីផ្នូររបស់ពួកអ្នក)មកវិញ។

12. ហើយ(ទ្រង់)ក៏ជាអ្នកដែលបានបង្កើតរាល់អ្វីៗទាំងអស់ឱ្យមានជាគូៗ។ ហើយទ្រង់បានបង្កើតសម្រាប់ពួកអ្នកនូវសំពៅ និងសត្វពាហនៈដែលពួកអ្នកអាចជិះវាបាន។

13. ដើម្បីឲ្យពួកអ្នកអាចជិះលើខ្នងរបស់ពួកវា។ បន្ទាប់មក ពួកអ្នកនឹកឃើញនូវឧបការគុណនៃព្រះជាម្ចាស់របស់ពួកអ្នក នៅពេលដែលពួកអ្នកបានជិះលើខ្នងរបស់វា ហើយពួកអ្នកពោលថា៖ ទ្រង់មហាស្អាតស្អំដែលបានសម្រួលដល់ពួកយើងនូវប្រការនេះ ហើយពួកយើងពុំមែនជាអ្នកដែលមានសមត្ថភាព(ក្នុងការទទួលបានវានោះឡើយ)។

14. ហើយពិតណាស់ ពួកយើងពិតជានឹងត្រូវវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកយើង(តែមួយគត់)។

15. ហើយពួកគេ(ពួកមុស្លីគីន)បានចាត់ទុកបណ្តាខ្ញុំបម្រើរបស់ទ្រង់មួយចំនួន(ម៉ាឡាអ៊ីកាត់)ជាចំណែកមួយសម្រាប់ទ្រង់។ ពិតប្រាកដណាស់ មនុស្សលោក គឺពិតជារមិលគុណយ៉ាងច្បាស់លាស់។

16. តើ(ពួកអ្នកគិតថា)ទ្រង់ជ្រើសយកបុត្រីពីអ្វីដែលទ្រង់បានបង្កើត(សម្រាប់ខ្លួនទ្រង់)ហើយទ្រង់ជ្រើសរើសកូនប្រុសសម្រាប់ពួកអ្នកឬ?

17. ហើយនៅពេលដែលគេផ្តល់ដំណឹងដល់នរណាម្នាក់ក្នុងចំណោមពួកគេនូវអ្វី(កូនស្រី)ដែលគេបានចោទប្រកាន់ទៅលើព្រះជាម្ចាស់ដ៏មហាសប្បុរស មុខរបស់គេប្រែជាពណ៌ខ្មៅ ហើយរូបគេពោរពេញទៅដោយទុក្ខព្រួយ។

18. តើ(ពួកគេភ្ជាប់ទៅកាន់ទ្រង់)អ្នកដែលត្រូវគេចិញ្ចឹមក្នុងលក្ខណៈតុបតែង ហើយពេលដែលជជែកដេញដោល ក៏មិនចេះយកហេតុផលច្បាស់លាស់(មកបញ្ជាក់)ផងនោះឬ?

19. ហើយពួកគេចាត់ទុកម៉ាឡាអ៊ីកាត់ទាំងឡាយដែលជាខ្ញុំបម្រើរបស់ព្រះជាម្ចាស់ដ៏មហាសប្បុរស ថាជាភេទស្រី។ តើពួកទាំងនោះមានវត្តមាននៅពេលដែលទ្រង់បានបង្កើតពួកគេ(ម៉ាឡាអ៊ីកាត់)ឬ? គេនឹងកត់ត្រាទុកនូវការអះអាងរបស់ពួកទាំងនោះ ហើយពួកទាំងនោះនឹងត្រូវគេសួរ។

20. ហើយពួកគេបាននិយាយថា៖ ប្រសិនបើព្រះជាម្ចាស់ដ៏មហាសប្បុរសមានចេតនា ពួកយើងក៏មិនគោរពសក្ការៈទៅចំពោះពួកគេដែរ។ ពួកគេគ្មានចំណេះដឹងអ្វីអំពីរឿងនោះឡើយ។ ពួកគេគ្មានអ្វីក្រៅពីការភូតកុហកនោះឡើយ។

21. ឬមួយយើង(អល់ឡោះ)បានប្រទាននូវគម្ពីរណាមួយទៅឱ្យពួកគេមុនគម្ពីរនេះ(គម្ពីរគួរអាន) ហើយពួកគេជាអ្នកដែលប្រកាន់ខ្ជាប់នឹងគម្ពីរនោះ?

22. ផ្ទុយទៅវិញ ពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងបានឃើញជីដូនជីតារបស់ពួកយើងស្ថិតនៅលើសាសនាមួយ។ ហើយពិតប្រាកដណាស់ ពួកយើងជាអ្នកដែលត្រូវបានគេចង្អុលបង្ហាញឲ្យដើរតាមលំអានរបស់ពួកគេ។

23. ក៏ដូច្នោះដែរ យើងមិនបានបញ្ជូនអ្នកដាស់តឿនព្រមានមុនអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទៅកាន់ភូមិស្រុកណាមួយនោះឡើយ លើកលែងតែពួកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភនៃស្រុកភូមិនោះតែងតែនិយាយថា៖ ពិតប្រាកដណាស់ ពួកយើងបានឃើញជីដូនជីតារបស់ពួកយើងស្ថិតនៅលើសាសនាមួយ។ ហើយពិតប្រាកដណាស់ ពួកយើងជាអ្នកដែលដើរតាមលំអាន(មាគ៌ា)របស់ពួកគេ។

24. គេ(អ្នកដាស់តឿនព្រមាន)បាននិយាយថា៖ តើបើទោះជាខ្ញុំបាននាំមកឱ្យពួកអ្នកនូវអ្វីដែលល្អប្រសើរជាងអ្វីដែលពួកអ្នកបានឃើញជីដូនជីតារបស់ពួកអ្នកប្រកាន់ខ្ជាប់ក៏ដោយឬ? ពួកគេបានតបថា៖ ពិតប្រាកដណាស់ ពួកយើងជាអ្នកដែលប្រឆាំងនឹងអ្វីដែលគេបញ្ជូនពួកអ្នកឲ្យនាំមក។

25. ហេតុនេះ យើងក៏បានផ្តន្ទាទោសពួកគេ។ ដូច្នេះ ចូរអ្នកពិនិត្យមើលចុះ ថាតើលទ្ធផលចុងក្រោយរបស់ពួកដែលបដិសេធនោះទៅជាយ៉ាងណា?

26. ហើយ(ចូរអ្នករំលឹក)នៅពេលព្យាការីអ៊ីព្រហ៊ីមបាននិយាយទៅកាន់ឪពុករបស់គាត់ និងក្រុមរបស់គាត់ថា៖ ពិតប្រាកដណាស់ ខ្ញុំមិនពាក់ព័ន្ធជាមួយនឹងអ្វីដែលពួកអ្នកគោរពសក្ការៈនោះឡើយ។

27. លើកលែងអ្នកដែលបានបង្កើតខ្ញុំ(អល់ឡោះ)ប៉ុណ្ណោះ។ ពិតប្រាកដណាស់ ទ្រង់នឹងចង្អុលបង្ហាញដល់ខ្ញុំ។

28. ហើយគាត់បានធ្វើឲ្យវា(ពាក្យ)ក្លាយជាពាក្យមួយដែលនៅគង់វង្ស(សម្រាប់អ្នកជំនាន់ក្រោយ)។ សង្ឃឹមថា ពួកគេនឹងវិលត្រឡប់។

29. ផ្ទុយទៅវិញ យើងបានឲ្យពួកទាំងនោះ និងជីដូនជីតារបស់ពួកគេបានសោយសុខ រហូតដល់សេចក្តីពិត(គម្ពីរគួរអាន)និងអ្នកនាំសារដ៏ច្បាស់លាស់ម្នាក់(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកគេ។

30. តែនៅពេលដែលសេចក្តីពិត(គម្ពីរគួរអាន)បានមកដល់ពួកគេ ពួកគេបែរជានិយាយថា៖ "នេះគឺជាមន្តអាគម ហើយពិតប្រាកដណាស់ ពួកយើងគឺជាអ្នកដែលប្រឆាំងនឹងវា"ទៅវិញ។

31. ហើយពួកគេបាននិយាយទៀតថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះគម្ពីរគួរអាននេះទៅឲ្យបុរសដ៏ប៉ុប្តើងម្នាក់ដែលមកពីភូមិស្រុកពីរនេះ(ម៉ាក្កៈ ឬតអ៊ីហ្វ)ទៅ?

32. តើពួកគេបែងចែកក្តីមេត្តាករុណានៃព្រះជាម្ចាស់អ្នកឬ? យើង(អល់ឡោះ)ទេដែលបែងចែកការរស់នៅរវាងពួកគេនៅក្នុងជីវិតលោកិយនេះ ហើយយើងបានលើកឋានៈអ្នកមួយចំនួននៃពួកគេលើអ្នកមួយចំនួនទៀត ដើម្បីឲ្យពួកគេទាញយកប្រយោជន៍ពីគ្នាទៅវិញទៅមក។ ហើយក្តីមេត្តាករុណានៃព្រះជាម្ចាស់របស់អ្នក គឺល្អប្រសើរជាងអ្វី(លាភសំណាងលោកិយ)ដែលពួកគេខិតខំប្រមូលទៅទៀត។

33. ហើយប្រសិនបើមនុស្សលោកមិនមែនស្ថិតនៅជាប្រជាជាតិតែមួយ(ដែលគ្មានជំនឿ)ទេនោះ យើងប្រាកដជានឹងឲ្យគេហដ្ឋានទាំងឡាយរបស់ពួកគ្មានជំនឿមានដំបូល និងជណ្តើរធ្វើអំពីប្រាក់ដែលពួកគេអាចឡើងបានជាមិនខាន។

34. ហើយ(យើងនឹងឲ្យ)គេហដ្ឋានទាំងឡាយរបស់ពួកគេមានទ្វារ និងគ្រែជាច្រើនដែលពួកគេអាចទម្រេតខ្លួនលើវាបាន។

35. ព្រមទាំងមាសផងដែរ។ ហើយរាល់របស់ទាំងនោះគឺគ្រាន់តែជាការត្រេកត្រអាលនៃជីវិតលោកិយប៉ុណ្ណោះ។ រីឯ(ការសោយសុខ)នៅថ្ងៃបរលោកដែលនៅឯព្រះជាម្ចាស់របស់អ្នក គឺសម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)។

36. ហើយជនណាដែលងាកចេញពីការរំលឹកនៃព្រះជាម្ចាស់ដ៏មហាសប្បុរស(គម្ពីរគួរអាន)យើងនឹងឲ្យស្តេតនពង្វក់រូបគេ ហើយវានឹងក្លាយជាគូកនសម្រាប់រូបគេ។

37. ហើយពិតប្រាកដណាស់ ពួកវានឹងរារាំងពួកគេពីមាគ៌ា(ត្រឹមត្រូវ) ទាំងដែលពួកគេគិតស្មានថា ពិតណាស់ ពួកគេជាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

38. លុះនៅពេលដែលជននោះបានមកជួបយើង(នៅថ្ងៃបរលោក) គេក៏និយាយថា៖ ឱអនិច្ចា! គួរណាស់តែរវាងខ្ញុំ និងអ្នក(ស្លែតន)នៅឃ្លាតឆ្ងាយពីគ្នាដូចទិសខាងកើត និងទិសខាងលិច។ ពិតណាស់(អ្នក)ជាគូកនដ៏អាក្រក់បំផុត។

39. តែវាមិនបានផ្តល់ជាប្រយោជន៍អ្វីឡើយដល់ពួកអ្នកនៅក្នុងថ្ងៃនេះ ខណៈដែលពួកអ្នកបានបំពាន។ ជាការពិតណាស់ ពួកអ្នកស្ថិតនៅក្នុងទណ្ឌកម្មរួមជាមួយគ្នា។

40. ដូច្នេះ តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អាចធ្វើឱ្យអ្នកថ្លង់ស្តាប់ឮ ឬអាចចង្អុលបង្ហាញដល់អ្នកខ្វាក់ និងអ្នកដែលស្ថិតនៅក្នុងភាពវង្វេងយ៉ាងច្បាស់បានដែរឬ?

41. ហើយបើទោះបីជាយើងឱ្យអ្នកស្លាប់(មុន)ក៏ដោយ ក៏យើងនៅតែជាអ្នកដែលផ្តន្ទាទោសពួកគេដែរ។

42. ឬក៏យើងបង្ហាញឱ្យអ្នកបានឃើញនូវអ្វី(ទណ្ឌកម្ម)ដែលយើងបានសន្យាចំពោះពួកគេក៏ដោយ ក៏យើង(នៅតែ)ជាអ្នកដែលសមត្ថភាពលើពួកគេដដែល។

43. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ប្រកាន់ខ្ជាប់នូវអ្វីដែលគេបានផ្តល់វ៉ាហ៊ីទៅកាន់អ្នកចុះ។ ពិតប្រាកដណាស់ អ្នកគឺស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ។

44. ហើយពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន) គឺពិតជាភាពថ្កុំថ្កើងសម្រាប់អ្នក និងសម្រាប់ក្រុមរបស់អ្នកផងដែរ។ ហើយពួកអ្នកនឹងត្រូវគេសួរជាមិនខាន។

45. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរទៅកាន់អ្នកនាំសារទាំងឡាយរបស់យើងដែលយើងបានបញ្ជូនមុនអ្នកថា៖ តើយើងធ្លាប់បានបង្កើតព្រះនានាឱ្យពួកគេគោរពសក្ការៈផ្សេងពីព្រះជាម្ចាស់ដ៏មហាសប្បុរសដែរឬទេ?

46. ហើយជាការពិតណាស់ យើងបានបញ្ជូនព្យាការីមូសាដោយនាំមកនូវសញ្ញាកស្តុតាងទាំងឡាយរបស់យើងទៅកាន់ហ្វៀរអោននិងមន្ត្រីទាំងឡាយរបស់គេ ដោយគាត់(ព្យាការីមូសា)បាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកនាំសាររបស់ព្រះជាម្ចាស់នៃពិភពទាំងឡាយ។

47. តែនៅពេលដែលគាត់បាននាំមកនូវសញ្ញាកស្តុតាងជាច្រើនរបស់យើងទៅកាន់ពួកគេ ស្រាប់តែពួកគេបែរជាសើចចំអកឡកឡឺយចំពោះវាទៅវិញ។

48. ហើយយើង(អល់ឡោះ)មិនបានបង្ហាញឲ្យពួកគេបានឃើញនូវសញ្ញាកស្តុតាងណាមួយឡើយ លើកលែងតែសញ្ញាកស្តុតាងនោះមានលក្ខណៈធំធេងជាងសញ្ញាកស្តុតាងមុនៗ។ ហើយយើងបានដាក់ទណ្ឌកម្មពួកគេ(ក្នុងលោកិយ)សង្ឃឹមថាពួកគេនឹងវិលត្រឡប់។

49. ហើយពួកគេបាននិយាយ(ទៅកាន់ព្យាការីមូសា)ថា៖ ឱគ្រូមន្តអាគម! សូមអ្នកបួងសួងសុំពីព្រះជាម្ចាស់របស់អ្នកនូវអ្វីដែលទ្រង់បានសន្យានឹងអ្នក(ថានឹងដកយកទណ្ឌកម្មពីពួកយើង)។ ពិតប្រាកដណាស់ ពួកយើងពិតជាអ្នកដែលទទួលបានការចង្អុលបង្ហាញជាមិនខាន។

50. តែនៅពេលដែលយើងបានដកយកនូវទណ្ឌកម្មចេញពីពួកគេ ស្រាប់តែពួកគេបែរជាក្បត់(សម្តីខ្លួនឯង)ទៅវិញ។

51. ហើយហ្វៀរអោនបានស្រែកប្រកាសនៅក្នុងក្រុមរបស់គេដោយពោលថា៖ ឱក្រុមរបស់យើង! តើយើងមិនមែនជាស្តេចគ្រប់គ្រងប្រទេសអេហ្ស៊ីប ហើយទន្លេទាំងនេះហូរកាត់ពីក្រោមយើងទេឬ? តើពួកអ្នកមិនបានឃើញទេឬ?

52. ផ្ទុយទៅវិញ យើងល្អប្រសើរជាងបុគ្គលម្នាក់នេះ(ព្យាការីមូសា)ដែលជាមនុស្សទន់ខ្សោយ ហើយនិយាយមិនទាំងសូវច្បាស់ផងនោះ។

53. ដូចនេះ ហេតុអ្វីបានជាគេមិនបំពាក់កងដៃអំពីមាសទៅឱ្យរូបគេ ឬឱ្យម៉ាឡាអ៊ីកាត់រួមដំណើរមកជាមួយគេទៅ។

54. ហ្វៀរអោនបានធ្វើឲ្យក្រុមរបស់គេឡប់សតិ។ ដូច្នេះ ពួកគេក៏បានគោរពតាមគេ។ ពិតប្រាកដណាស់ ពួកគេគ្លាប់ជាក្រុមដែលប្រព្រឹត្តល្មើស។

55. ហើយនៅពេលដែលពួកគេធ្វើឱ្យយើងខឹងសម្បា យើងក៏បានផ្តន្ទាទោសពួកគេដោយឱ្យពួកគេទាំងអស់គ្នាលិចលង់(ក្នុងសមុទ្រ)។

56. ហើយយើងបានយកពួកគេធ្វើជាគំរូសម្រាប់អ្នកជំនាន់មុន និងជាមេរៀនសម្រាប់អ្នកផ្សេងទៀត។

57. នៅពេលដែលគេបានលើកយកកូនប្រុសរបស់ម៉ារយ៉ាំ(ព្យាការីអ៊ីសា)ធ្វើជាឧទាហរណ៍ ស្រាប់តែក្រុមរបស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នាំគ្នាស្រែកហ៊ោកញ្ជ្រៀវ។

58. ហើយពួកគេនិយាយថា៖ តើព្រះទាំងឡាយរបស់ពួកយើងល្អជាង ឬគាត់(ព្យាការីអ៊ីសា)ល្អជាង? អ្វីដែលពួកគេលើកយកគាត់មកប្រៀបធៀបសម្រាប់អ្នកបែបនេះ គឺគ្មានអ្វីក្រៅពីការប្រកែកដេញដោលនោះឡើយ។ ផ្ទុយទៅវិញ ពួកគេគឺជាក្រុមដែល(ចូលចិត្ត)ឈ្លោះប្រកែក។

59. រូបគេ(ព្យាការីអ៊ីសា)គ្មានអ្វីក្រៅតែពីជាខ្ញុំបម្រើម្នាក់ដែលយើងបានប្រទានឧបការគុណដល់គេ និងបានយកគេជាមេរៀនសម្រាប់អម្បូរអ៊ីស្រាអែលឡើយ។

60. ហើយប្រសិនបើយើងមានចេតនា ហើយយើងនឹងបង្កើតម៉ាឡាអ៊ីកាត់ឱ្យគ្រប់គ្រងផែនដីជំនួសពួកអ្នកជាមិនខាន។

61. ហើយពិតប្រាកដណាស់វា(ការចុះមកបស់ព្យាការីអ៊ីសាមុនថ្ងៃបរលោកកើតឡើង) គឺពិតជាសញ្ញាមួយនៃថ្ងៃបរលោក។ ហេតុនេះ ពួកអ្នកមិនត្រូវមានការមន្ទិលសង្ស័យចំពោះវាឡើយ។ ហើយចូរពួកអ្នកប្រតិបត្តិតាមខ្ញុំ(ព្យាការីមូហាំម៉ាត់)។ នេះហើយជាមាគ៌ាដ៏ត្រឹមត្រូវ។

62. ហើយចូរពួកអ្នកកុំឱ្យស្តែនរារាំងពួកអ្នក(ពីមាគ៌ាដ៏ត្រឹមត្រូវ)ឲ្យសោះ។ ពិតប្រាកដណាស់ វាជាសត្រូវយ៉ាងច្បាស់លាស់សម្រាប់ពួកអ្នក។

63. ហើយនៅពេលដែលព្យាការីអ៊ីសាបានមកដល់ដោយនាំមកនូវសញ្ញាកស្តែងយ៉ាងច្បាស់លាស់ គាត់បានពោលថា៖ ពិតប្រាកដណាស់ ខ្ញុំបាននាំមកកាន់ពួកអ្នកនូវគតិបណ្ឌិត ហើយខ្ញុំប្រាកដជានឹងបញ្ជាក់ប្រាប់ពួកអ្នកនូវរឿងរ៉ាវមួយចំនួនដែលពួកអ្នកមានការខ្វែងគំនិតគ្នាចំពោះវា។ ហេតុនេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ និងប្រតិបត្តិតាមខ្ញុំ។

64. ពិតប្រាកដណាស់ អល់ឡោះ ទ្រង់គឺជាព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកគោរពសក្ការៈចំពោះទ្រង់(តែមួយគត់)។ នេះហើយជាមាគ៌ាដ៏ត្រឹមត្រូវ។

65. ហើយក្រុមជាច្រើនបានខ្វែងគំនិតគ្នារវាងពួកគេ(ក្នុងរឿងព្យាការីអ៊ីសា)។ ដូច្នេះ ភាពវិនាសអន្តរាយដោយទណ្ឌកម្មនៅថ្ងៃដ៏ឈឺចាប់បំផុត គឺសម្រាប់ពួកដែលបំពាន។

66. តើពួកទាំងនោះគ្មានរង់ចាំអ្វីក្រៅពីថ្ងៃបរលោកដែលមកដល់ពួកគេភ្លាមៗ ខណៈដែលពួកគេមិនដឹងខ្លួននោះឬ?

67. មិត្តជិតស្និទ្ធទាំងឡាយនៅក្នុងថ្ងៃនោះ(ថ្ងៃបរលោក)នឹងក្លាយជាសត្រូវនឹងគ្នាទៅវិញទៅមក លើកលែងតែបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)ប៉ុណ្ណោះ។

68. (ទ្រង់នឹងមានបន្ទូលទៅកាន់ពួកគេថា៖) ឱខ្ញុំបម្រើទាំងឡាយរបស់យើង! គ្មានការភ័យខ្លាចអ្វីឡើយចំពោះពួកអ្នកនៅក្នុងថ្ងៃនេះ ហើយពួកអ្នកក៏គ្មានទុក្ខព្រួយអ្វីនោះដែរ។

69. បណ្តាអ្នកដែលមានជំនឿចំពោះសញ្ញាកសុតាងទាំងឡាយរបស់យើង ហើយពួកគេជាអ្នកដែលប្រគល់ខ្លួននោះ

70. (មានគេនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នក និងបណ្តាអ្នកដែលមានជំនឿដូចពួកអ្នក ចូលទៅក្នុងឋានសួគ៌ដោយក្តីរីករាយចុះ។

71. មានគេចាំបម្រើជុំវិញពួកគេជាមួយនឹងថាសអាហារ និងពែងផ្វើអំពីមាស។ នៅក្នុងឋានសួគ៌នោះមានអ្វីគ្រប់យ៉ាងតាមដែលគេប្រាថ្នា និង(គយគន់មើលយ៉ាង)គាប់នេត្រាផងដែរ។ ហើយពួកអ្នកស្ថិតនៅក្នុងឋានសួគ៌នេះជាអមតៈ។

72. នោះហើយជាឋានសួគ៌ដែលគេបានប្រទានវាជាមរតកដល់ពួកអ្នកដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

73. នៅក្នុងឋានសួគ៌នោះ មានផ្លែឈើជាច្រើនសម្រាប់ពួកអ្នកទទួលទានអំពីវា។

74. ពិតប្រាកដណាស់ ពួកឧក្រិដ្ឋជនទាំងឡាយ គឺស្ថិតក្នុងទណ្ឌកម្មនៃនរកជើហាន់ណាំជាអមតៈ។

75. គេមិនបន្ធូរបន្ថយ(ទណ្ឌកម្ម)ដល់ពួកគេឡើយ ហើយពួកគេស្ថិតនៅក្នុងវាដោយក្តីអស់សង្ឃឹម។

76. ហើយយើងមិនបានបំពានលើពួកគេឡើយ ប៉ុន្តែពួកគេទៅវិញទេដែលធ្លាប់ជាពួកបំពាននោះ។

77. ហើយពួកគេបានស្រែកហៅ(ឆ្មាំនរក)ថា៖ ឱម៉ាលិក! សូមឱ្យព្រះជាម្ចាស់របស់អ្នកបញ្ចប់ជីវិតពួកយើងចុះ។ គេបានតបវិញថា៖ ពិតប្រាកដណាស់ ពួកអ្នកនឹងត្រូវស្ថិតនៅ(ក្នុងនរកនេះ)ជារៀងរហូត។

78. ពិតណាស់ យើងបាននាំមកកាន់ពួកអ្នកនូវសេចក្តីពិត។ ក៏ប៉ុន្តែភាគច្រើននៃពួកអ្នកមិនពេញចិត្តនឹងសេចក្តីពិតនោះឡើយ។

79. ផ្ទុយទៅវិញ ពួកគេបានរៀបចំល្បិចកល តែយើងទៅវិញទេដែលជាអ្នករៀបចំល្បិចកល(ខ្លាំងជាងនោះ)ទៅទៀត។

80. ឬមួយក៏ពួកគេគិតស្មានថា ជាការពិតណាស់ យើងមិនឮរឿងសម្ងាត់របស់ពួកគេ និងការខ្សឹបខ្សៀវរបស់ពួកគេឬ? មិនដូច្នោះឡើយ។ ហើយអ្នកនាំសារ(ម៉ាឡាអ៊ីកាត់)របស់យើងដែលនៅជាមួយពួកគេ គឺកំពុងតែកត់ត្រា(នូវអ្វីដែលពួកគេបានធ្វើ)។

81. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ប្រសិនបើព្រះជាម្ចាស់ដ៏មហាសប្បុរសទ្រង់មានបុត្រ ពិតណាស់ ខ្ញុំគឺជាអ្នកដែលគោរពសក្ការៈ(ចំពោះបុត្រនោះ)ដំបូងគេបង្អស់។

82. ព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី និងជាព្រះជាម្ចាស់នៃអារ៉ាស្តេនោះទ្រង់មហាស្អាតស្អំបំផុតអំពីអ្វីដែលពួកគេចោទប្រកាន់។

83. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បណ្តោយឱ្យពួកគេវង្វេង និងលេងសើចចុះ រហូតដល់ពួកគេបានជួបនឹងថ្ងៃដែលគេបានសន្យាចំពោះពួកគេ(ថ្ងៃបរលោក)។

84. ហើយទ្រង់ជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈ(តែមួយគត់)នៅលើមេឃ និងជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈ(តែមួយគត់)នៅលើផែនដី។ ហើយទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

85. ទ្រង់មហាឧត្តុង្គឧត្តមដែលការគ្រប់គ្រងមេឃជាច្រើនជាន់ ជនិងផែនដី ហើយនិងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរ គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយចំណេះដឹងនៃថ្ងៃបរលោក គឺនៅឯទ្រង់។ ហើយពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ទ្រង់វិញ។

86. ហើយអ្នកដែលពួកគេកំពុងតែគោរពសក្ការៈ(ចំពោះវា)ផ្សេងពីទ្រង់នោះ គឺគ្មានអំណាចអ្វីក្នុងការជួយអន្តរាគមន៍នោះឡើយ លើកលែងតែអ្នកដែលបានធ្វើសាក្សីចំពោះការពិត ហើយពួកគេបានដឹង។

87. ហើយប្រសិនបើអ្នកសួរពួកគេថា៖ តើនរណាជាអ្នកដែលបានបង្កើតពួកគេ ប្រាកដជាពួកគេឆ្លើយថា៖ គឺអល់ឡោះ។ ដូច្នេះតើពួកគេត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

88. ហើយគាត់(ព្យាការីមូហាំម៉ាត់)បានពោលទៅកាន់ទ្រង់ថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ពួកទាំងនោះ គឺជាក្រុមដែលគ្មានជំនឿនោះឡើយ។

89. ដូច្នេះ ចូរអ្នកងាកចេញពីពួកគេចុះ ហើយពោលថា៖ សាឡាម។ ពិតប្រាកដណាស់ ពួកគេគង់តែនឹងដឹងជាមិនខាន។

ជំពូក អាត់ទូខន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. (អល់ឡោះ)ស្បថនឹងគម្ពីរគួរអានដ៏ច្បាស់លាស់។

3. ពិតប្រាកដណាស់ យើង(អល់ឡោះ)បានបញ្ចុះគម្ពីរគួរអាននៅយប់ដ៏មានពរជ័យ(យប់ឡៃឡាទុលក៏ទើរ)។ ពិតណាស់ យើងគឺជាអ្នកដាស់តឿនព្រមាន។

4. នៅក្នុងយប់នោះ គេបែងចែកនូវរាល់កិច្ចការទាំងឡាយប្រកបដោយគតិបណ្ឌិត។

5. ជាកិច្ចការមកពីយើងផ្ទាល់។ ពិតប្រាកដណាស់ យើងគឺជាអ្នកដែលបញ្ជូន(បណ្តាអ្នកនាំសារទាំងឡាយ)

6. ជាក្តីមេត្តាករុណាពីព្រះជាម្ចាស់របស់អ្នក។ ពិតប្រាកដណាស់ ទ្រង់មហាឮ មហាដឹងបំផុត។

7. (ទ្រង់)ជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរ ប្រសិនបើពួកអ្នកជាអ្នកជឿជាក់មែននោះ។

8. គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់ជាអ្នកផ្តល់ជីវិត និងជាអ្នកដកយកជីវិត ជាព្រះជាម្ចាស់របស់ពួកអ្នក និងជាព្រះជាម្ចាស់នៃដីជូនដីតារបស់ពួកអ្នកជំនាន់មុនៗ។

9. ផ្ទុយទៅវិញ ពួកគេស្ថិតនៅក្នុងភាពមន្ទិលសង្ស័យដោយពួកគេលេងសើច។

10. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រង់ចាំមើលចុះនៅថ្ងៃដែលមេឃនឹងនាំមកនូវផ្សែងយ៉ាងច្បាស់លាស់

11. ដោយវានឹងគ្របដណ្តប់លើមនុស្សលោក។ (ហើយមានគេនិយាយថា៖) នេះគឺជាទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

12. (ពេលនោះ ពួកគេក៏បួងសួងថា៖) បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាដកយកទណ្ឌកម្មពីយើងខ្ញុំផងចុះ។ យើងខ្ញុំពិតជាអ្នកដែលមានជំនឿ។

13. តើពួកគេអាចភ្ញាក់រលឹកយ៉ាងដូចម្តេច(នៅពេលនេះ) ខណៈដែលអ្នកនាំសារដ៏ច្បាស់លាស់ម្នាក់(ព្យាការីមូហាំម៉ាត់)បានមកដល់ពួកគេ

14. បន្ទាប់មក ពួកគេបែរដោបែរចេញពីគាត់ ថែមទាំងនិយាយថាៈ (គាត់ជា)មនុស្សដែលត្រូវគេពង្វក់ ជាមនុស្សវិកលចរិត ថែមទៀតនោះ?

15. ពិតប្រាកដណាស់ យើងជាអ្នកដកយកទណ្ឌកម្មបន្តិចបន្តួច(ពីពួកអ្នក)។ ពិតណាស់ ពួកអ្នកនឹងវិលត្រឡប់(ទៅកាន់ការប្រព្រឹត្តដូចមុនដដែល)។

16. នៅថ្ងៃដែលយើងដាក់ទណ្ឌកម្ម(ពួកគេ)នូវទណ្ឌកម្មដ៏ធំធេង។ ពិតប្រាកដណាស់ យើងជាអ្នកផ្តន្ទាទោស(ពួកគេ)។

17. ហើយពិតប្រាកដណាស់ យើងបានសាកល្បងក្រុមរបស់ហ្វៀរអោនមុនពួកទាំងនោះទៅទៀត ខណៈដែលអ្នកនាំសារដ៏ឧត្តុង្គឧត្តមម្នាក់(ព្យាការីមូសា)បានមកដល់ពួកគេ។

18. (គាត់បាននិយាយថាៈ) ចូរពួកអ្នកប្រគល់ខ្ញុំបម្រើរបស់អល់ឡោះ(អម្ប្រាអ៊ីស្រាអែល)ឱ្យមកខ្ញុំវិញមក។ ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសារដ៏ស្មោះត្រង់ម្នាក់សម្រាប់ពួកអ្នក។

19. ហើយចូរពួកអ្នកកុំក្រអឺតក្រទមចំពោះអល់ឡោះជាម្ចាស់ឱ្យសោះ។ ពិតប្រាកដណាស់ ខ្ញុំជាអ្នកនាំមកកាន់ពួកអ្នកនូវសញ្ញាកស្តតាងដ៏ច្បាស់លាស់។

20. ហើយពិតណាស់ ខ្ញុំសុំពីព្រះជាម្ចាស់របស់ខ្ញុំ និងជាព្រះជាម្ចាស់របស់ពួកអ្នកឱ្យការពារខ្ញុំកុំឱ្យពួកអ្នកគប់សម្លាប់រូបខ្ញុំ(នឹងដុំថ្ម)។

21. តែប្រសិនបើពួកអ្នកមិនជឿជាក់ចំពោះខ្ញុំទេនោះ សូមពួកអ្នកបណ្តោយខ្ញុំ(ឲ្យស្ថិតលើមាគ៌ារបស់ខ្ញុំ)ចុះ។

22. ពេលនោះ ព្យាការីមូសាបានពោលទៅកាន់ព្រះជាម្ចាស់របស់គាត់ថាៈ ពិតប្រាកដណាស់ ពួកទាំងនោះ គឺជាក្រុមដែលប្រឆាំង។

23. (អល់ឡោះបានបញ្ជាថាៈ) ចូរអ្នកនាំខ្ញុំបម្រើរបស់យើង(អម្ប្រាអ៊ីស្រាអែល)ចេញដំណើរទាំងយប់ទៅ។ ពិតប្រាកដណាស់ ពួកអ្នកត្រូវបានគេដេញតាមហើយ។

24. ហើយចូរអ្នកទុកទឹកសមុទ្រឱ្យនៅបែបនេះចុះ។ ពិតប្រាកដណាស់ ពួកគេ(ហ្វៀរអោននិងបក្សពួក) គឺជាកងទ័ពដែលត្រូវគេពន្លិច(ទៅក្នុងសមុទ្រ)។

25. តើពួកគេបានបន្សល់ទុកចំនួនប៉ុន្មាននៃសួនឧទ្យាន និងប្រភពទឹកនានា

26. និងចម្ការ ហើយនិងភូមិគ្រឹះដ៏ប្រណីត

27. ព្រមទាំងការស់នៅដែលពួកគេធ្លាប់បានសោយសុខនោះ?

28. ក៏ដូច្នោះដែរ យើងបានប្រទានវាជាមរតកសម្រាប់ក្រុមផ្សេងទៀត។

29. ហើយមេឃ និងផែនដីមិនបានយំស្រណោះពួកគេឡើយ ហើយពួកគេក៏មិនត្រូវបានគេពន្យារពេលឱ្យនោះដែរ។

30. ហើយជាការពិតណាស់ យើងបានសង្គ្រោះអម្បូរអ៊ីស្រាអែលពីទណ្ឌកម្មដ៏អាម៉ាស់

31. ពីសំណាក់ហ្វៀរអោន។ ពិតប្រាកដណាស់ រូបគេគឺជាអ្នកដែលក្រអឺតក្រទមម្នាក់ក្នុងចំណោមពួកដែលបំពាន។

32. ហើយជាការពិតណាស់ យើងបានជ្រើសរើសពួកគេ(អម្បូរអ៊ីស្រាអែល)ឱ្យមានភាពខ្ពង់ខ្ពស់លើពិភពលោក(នាសម័យកាលនោះ)ដោយចំណេះដឹងពីយើង។

33. ហើយយើងបានប្រទានឱ្យពួកគេនូវសញ្ញាកស្តុតាងជាច្រើនដែលក្នុងនោះមានការសាកល្បងដ៏ច្បាស់លាស់។

34. ពិតប្រាកដណាស់ ពួកទាំងនោះ(ពួកមុស្លីគីន)ប្រាកដជានឹងនិយាយថា៖

35. វាគ្មានអ្វីក្រៅពីការស្លាប់លើកទីមួយរបស់ពួកយើងនោះឡើយ ហើយពួកយើងក៏មិនត្រូវបានគេបង្កើតឱ្យរស់ឡើងវិញដែរ។

36. ដូច្នេះ ចូរអ្នក(ឱមូហាំម៉ាត់)នាំដីដូនដីតារបស់ពួកយើង(ដែលបានស្លាប់ទៅហើយនោះ)មកកាន់ពួកយើងមក ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ។

37. តើពួកគេល្អជាង ឬក៏ក្រុមទុបហ្ពាក់ និងអ្នកជំនាន់មុនពួកគេដែលយើងបានបំផ្លាញនោះ(ល្អជាង)? ពិតប្រាកដណាស់ ពួកគេធ្លាប់ជាពួកឧក្រិដ្ឋជន។

38. ហើយយើងមិនបានបង្កើតមេឃជាច្រើនជាន់ និងផែនដី ហើយនិងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរជាការលេងសើចនោះឡើយ។

39. យើងមិនបានបង្កើតវាទាំងពីរនោះ លើកលែងតែមានបុព្វហេតុច្បាស់លាស់។ ក៏ប៉ុន្តែ ភាគច្រើននៃពួកគេមិនបានដឹងឡើយ។

40. ពិតប្រាកដណាស់ ថ្ងៃកាត់សេចក្តី គឺជាពេលកំណត់របស់ពួកគេទាំងអស់គ្នា។

41. ជាថ្ងៃដែលមិត្តភក្តិមិនអាចផ្តល់ផលប្រយោជន៍អ្វីដល់គ្នាបន្តិចណាឡើយ ហើយពួកគេក៏មិនត្រូវបានគេជួយនោះដែរ។

42. លើកលែងតែជនណាដែលអល់ឡោះមានក្តីមេត្តាករុណា(ចំពោះរូបគេ)ប៉ុណ្ណោះ។ ពិតប្រាកដណាស់ ទ្រង់មហាខ្លាំងពូកែ មហាអាណិតស្រលាញ់។

43. ពិតប្រាកដណាស់ ដើមហ្ស៊ឹកគូម

44. គឺជាអាហារសម្រាប់អ្នកដែលមានបាបកម្មដ៏ធំធេង

45. ដែលវាប្រៀបបីដូចជាលោហៈធាតុដែលកំពុងពុះនៅក្នុងពោះ

46. ប្រៀបដូចជាទឹកពុះដ៏សែនក្តៅបំផុត។

47. (មានគេនិយាយទៅកាន់ឆ្មាំនរកថា៖) ចូរចាប់ជននោះ រួចទាញរូបគេបោះទៅកណ្តាលនរកដើហ៊ឹមចុះ។

48. បន្ទាប់មក ចូរពួកអ្នកចាក់ពីលើក្បាលជននោះនូវទណ្ឌកម្មអំពីទឹកដ៏សែនក្តៅបំផុត។

49. (មានគេនិយាយចំអកទៅកាន់ជននោះថា៖) ចូរអ្នកភ្លក់ចុះ។ ពិតប្រាកដណាស់ អ្នកគឺជាជនដែលខ្លាំងពូកែ និងថ្លៃថ្នូរ។

50. ជាការពិតណាស់ នេះគឺជាអ្វីដែលពួកអ្នកធ្លាប់មានការសង្ស័យចំពោះវា។

51. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) គឺស្ថិតនៅកន្លែងដែលមានសុវត្ថិភាពបំផុត។

52. គឺស្ថិតនៅក្នុងឋានសួគ៌ និងមានប្រភពទឹកជាច្រើន។

53. ពួកគេស្លៀកសម្លៀកបំពាក់ដែលធ្វើពីក្រណាត់សូត្រម៉ដ្ឋខៃ និងគ្រឹម ដោយអង្គុយទល់មុខគ្នា។

54. ក៏ដូច្នោះដែរ យើងរៀបអាពាហ៍ពិពាហ៍ឱ្យពួកគេនឹងស្ត្រីទេពអប្សរ។

55. នៅក្នុងឋានសួគ៌នោះ ពួកគេហៅឱ្យគេយកផ្លែឈើគ្រប់ប្រភេទដោយសុវត្ថិភាព។

56. នៅក្នុងនោះដែរ ពួកគេមិនភ្លក់រសជាតិស្លាប់ទៀតឡើយ ក្រៅតែពីការស្លាប់លើកដំបូង(ក្នុងលោកិយ)ប៉ុណ្ណោះ។ ហើយទ្រង់បានការពារពួកគេពីទណ្ឌកម្មនៃនរកដើហ៊ឹម។

57. ជាការប្រោសប្រទានពីព្រះជាម្ចាស់របស់អ្នក(ចំពោះពួកគេ)។ នោះហើយជាជោគជ័យដ៏ធំធេងបំផុត។

58. ជាការពិតណាស់ យើងបានធ្វើឱ្យគម្ពីរនេះ(គម្ពីរគួរអាន)មានភាពងាយស្រួល(ដោយបញ្ចុះគម្ពីរនេះ)ជាភាសារបស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) សង្ឃឹមថាពួកគេនឹងយកជាមេរៀន។

59. ដូច្នេះ ចូរអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ ពួកគេក៏ជាអ្នកដែលរង់ចាំមើលដែរ។

ជំពូក អាល់ដើស៊ុយ៉ះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ការបញ្ចុះគម្ពីរ(គួរអាន) គឺមកពីអល់ឡោះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

3. ពិតប្រាកដណាស់ នៅក្នុងការបង្កើតមេឃជាច្រើនជាន់និងផែនដី គឺជាសញ្ញាកស្តុតាងសម្រាប់បណ្តាអ្នកដែលមានជំនឿ។

4. ហើយនៅក្នុងការបង្កើតពួកអ្នក(ឱមនុស្សលោក) និងការពង្រាយសត្វទាំងឡាយ(ពាសពេញផែនដី) គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលជឿជាក់។

5. ហើយការផ្លាស់ប្តូរគ្នារវាងពេលយប់និងពេលថ្ងៃ និងទឹកភ្លៀងដែលអល់ឡោះបានបញ្ចុះពីលើមេឃ ដែលតាមរយៈវា ទ្រង់បានធ្វើឱ្យដីមានជីជាតិឡើងវិញ ក្រោយពីវាបានស្ងួតហួតហែង ព្រមទាំងការផ្លាស់ប្តូរទិសខ្យល់ គឺសុទ្ធតែជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលចេះគិតពិចារណា។

6. ទាំងនោះគឺជាបណ្តាវាក្យខណ្ឌរបស់អល់ឡោះដែលយើងបានសូត្រវាឲ្យអ្នកស្តាប់យ៉ាងពិតប្រាកដ។ ដូច្នេះ តើមានពាក្យសម្តីណាបន្ទាប់ពីអល់ឡោះ និងបណ្តាវាក្យខណ្ឌរបស់ទ្រង់ដែលពួកគេមានជំនឿនោះ ?

7. ភាពវិនាសអន្តរាយ គឺសម្រាប់រាល់អ្នកដែលកូតកុហកដែលមានបាបកម្មច្រើន។

8. ជននោះបានស្តាប់ឮវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះដែលគេបានសូត្រឱ្យរូបគេស្តាប់។ ក្រោយមក រូបគេនៅតែបន្តដោយភាពក្រអឺតក្រទម ហាក់បីដូចជារូបគេមិនបានស្តាប់ឮវាឡើយ។ ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងដល់រូបគេពីទណ្ឌកម្មដ៏សែនឈឺចាប់បំផុតចុះ។

9. ហើយនៅពេលដែលរូបគេបានដឹងពីអ្វីមួយក្នុងចំណោមវាក្យខណ្ឌរបស់យើង គេបែរជាយកវាជាការចំអកលេងសើចទៅវិញ។ ពួកទាំងនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

10. នៅពីមុខពួកគេ គឺនរកដើហាន់ណាំ។ ហើយអ្វីដែលពួកគេខិតខំស្វែងរក និងអ្វីដែលពួកគេយកមកធ្វើជាអ្នកគាំពារក្រៅពីអល់ឡោះនោះ មិនអាចជួយជាប្រយោជន៍អ្វីបន្តិចដល់ពួកគេនោះឡើយ។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ធំធេងបំផុត។

11. (គម្ពីរគួរអាន)នេះគឺជាការចង្អុលបង្ហាញ។ រីឯពួកដែលប្រឆាំងនឹងវាក្យខណ្ឌនៃព្រះជាម្ចាស់របស់ពួកគេនោះ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏អាក្រក់ និងឈឺចាប់បំផុត។

12. អល់ឡោះជាអ្នកដែលបានបង្កើតសមុទ្រសម្រាប់ពួកអ្នក(ឱមនុស្សលោក)ដើម្បីឱ្យសំពៅទាំងឡាយធ្វើដំណើរនៅលើវាទៅតាមបទបញ្ជារបស់ទ្រង់ និងដើម្បីឱ្យពួកអ្នកស្វែងរកការប្រោសប្រទានរបស់ទ្រង់ សង្ឃឹមថាពួកអ្នកនឹងដឹងគុណ។

13. ហើយទ្រង់បានបង្កើតអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដីសម្រាប់ពួកអ្នក។ អ្វីៗទាំងអស់នោះគឺមកពីទ្រង់។ ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាសញ្ញាកស្តុតាងសម្រាប់ក្រុមដែលឈ្វេងយល់។

14. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់បណ្តាអ្នកដែលមានជំនឿឲ្យពួកគេអធ្យាស្រ័យចំពោះពួកដែលមិនរំពឹងផលបុណ្យឬទណ្ឌកម្មរបស់អល់ឡោះ ដើម្បីទ្រង់នឹងតបស្នងដល់ក្រុមមួយចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

15. ជនណាដែលសាងទង្វើកុសល ពិតណាស់វាគឺសម្រាប់ខ្លួនគេផ្ទាល់។ ហើយជនណាដែលសាងទង្វើអាក្រក់ ពិតណាស់វាក៏ធ្លាក់លើរូបគេដូចគ្នា។ ក្រោយមក ពួកអ្នកនឹងត្រូវគេនាំត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកអ្នកវិញ។

16. ហើយជាការពិតណាស់ យើងបានប្រទានឱ្យអម្បូរអ៊ីស្រាអែលនូវគម្ពីរ ក្បួនច្បាប់នានា និងភាពជាព្យាការី។ ហើយយើងបានប្រទានឱ្យពួកគេនូវលោកសក្ការៈពីប្រការល្អៗជាច្រើន ព្រមទាំងបានលើកតម្កើងពួកគេឱ្យមានភាពខ្ពង់ខ្ពស់ជាងគេក្នុងសាកលលោក(នាសម័យកាលនោះ)។

17. ហើយយើងបានប្រទានឱ្យពួកគេនូវសេញ្ញាកស្តុតាងដ៏ច្បាស់លាស់ជាច្រើនពីកិច្ចការទាំងឡាយ។ ហើយពួកគេមិនបានខ្វែងគំនិតគ្នាឡើយ លើកលែងតែក្រោយពេលដែលចំណេះដឹងបានមកដល់ពួកគេព្រោះតែការបំពានរវាងពួកគេប៉ុណ្ណោះ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់នឹងកាត់សេចក្តីរវាងពួកគេនៅថ្ងៃបរលោកចំពោះអ្វីដែលពួកគេធ្លាប់បានខ្វែងគំនិតគ្នា។

18. ក្រោយមក យើងបានធ្វើឱ្យអ្នក(ព្យាការីមូហាំម៉ាត់)ស្ថិតនៅលើក្បួនច្បាប់ដ៏ច្បាស់លាស់នៃកិច្ចការសាសនា។ ដូច្នេះ ចូរអ្នកដើរតាមវាចុះ ហើយចូរអ្នកកុំដើរតាមទំនើងចិត្តរបស់ពួកដែលមិនដឹងអ្វីឲ្យសោះ។

19. ជាការពិតណាស់ ពួកគេមិនអាចជួយជាប្រយោជន៍អ្វីបន្តិចដល់អ្នកពី(ទណ្ឌកម្ម)អល់ឡោះនោះឡើយ។ ហើយពិតណាស់ពួកដែលបំពាន ពួកគេជាអ្នកគាំពារគ្នាទៅវិញទៅមក។ ហើយអល់ឡោះគឺជាអ្នកគាំពាររបស់បណ្តាអ្នកដែលកោតខ្លាច។

20. (គម្ពីរគួរអាន)នេះ គឺជាការបំភ្លឺសម្រាប់មនុស្សលោក ជាការចង្អុលបង្ហាញ និងជាក្តីមេត្តាករុណាសម្រាប់ក្រុមដែលជឿជាក់។

21. ឬមួយក៏ពួកដែលសាងអំពើអាក្រក់ទាំងនោះគិតស្មានថា យើងចាត់ទុកពួកគេដូចគ្នាទៅនឹងបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ទាំងពេលដែលពួកគេនៅមានជីវិត និងនៅពេលដែលពួកគេស្លាប់ឬ? ការវិនិច្ឆ័យរបស់ពួកគេបែបនេះ គឺអាក្រក់បំផុត។

22. ហើយអល់ឡោះទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដីដោយមានបុព្វហេតុច្បាស់លាស់ ដើម្បីគេនឹងតបស្នងរាល់បុគ្គលគ្រប់រូបទៅតាមអ្វីដែលរូបគេបានប្រព្រឹត្ត។ ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

23. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានឃើញដែរឬទេ ពួកដែលយកទំនើងចិត្តខ្លួនឯងធ្វើជាព្រះ ហើយអល់ឡោះបានធ្វើឱ្យរូបគេវង្វេងក្រោយពីចំណេះដឹង(បានទៅដល់រូបគេ)។ ហើយទ្រង់បានបោះត្រាភ្ជិតទៅលើត្រចៀករបស់គេ និងដួងចិត្តរបស់គេ ព្រមទាំងដាក់បាំងនៅលើភ្នែករបស់គេ(មិនឱ្យមើលឃើញការពិត)។ ដូច្នេះ តើមានអ្នកណាដែលអាចចង្អុលបង្ហាញរូបគេ បន្ទាប់ពីអល់ឡោះនោះ? តើពួកអ្នកមិនឃើញទេឬ?

24. ហើយពួកគេបាននិយាយថា៖ វាគ្មានអ្វីក្រៅតែពីជីវិតលោកិយរបស់យើងនោះឡើយ។ ពួកយើងស្លាប់ ពួកយើងកើត។ ហើយគ្មានអ្វីបំផ្លាញពួកយើងនោះ ក្រៅតែពី(ដំណើរទៅមុខនៃ)ពេលវេលាប៉ុណ្ណោះ។ សម្រាប់ពួកទាំងនោះ គឺគ្មានចំណេះដឹងអ្វីអំពីរឿងនោះឡើយ ហើយពួកគេក៏គ្មានអ្វីក្រៅតែពីការស្មាននោះដែរ។

25. ហើយនៅពេលដែលមានគេសូត្រវាក្យខណ្ឌដ៏ច្បាស់លាស់របស់យើងឱ្យពួកគេស្តាប់ ពួកគេគ្មានអំណះអំណាងអ្វី ក្រៅតែពីពួកគេពោលថា៖ ចូរពួកអ្នកនាំដីដូនដីតារបស់ពួកយើង(ដែលបានស្លាប់ទៅហើយនោះ)មកកាន់ពួកយើងមក ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ។

26. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ អល់ឡោះជាម្ចាស់ទ្រង់បានឱ្យពួកអ្នកមានជីវិត បន្ទាប់មក ទ្រង់ដកយកជីវិតពួកអ្នកវិញ។ ក្រោយមក ទ្រង់នឹងប្រមូលផ្តុំពួកអ្នកទៅកាន់ថ្ងៃបរលោកដែលគ្មានការមន្ទិលសង្ស័យចំពោះវានោះឡើយ។ ក៏ប៉ុន្តែ មនុស្សភាគច្រើនមិនដឹងឡើយ។

27. ហើយការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់(តែមួយគត់)។ ហើយនៅពេលដែលថ្ងៃបរលោកកើតឡើង នៅថ្ងៃនោះពួកដែលប្រព្រឹត្តខុសឆ្គងនឹងទទួលនូវការខាតបង់។

28. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងឃើញប្រជាជាតិទាំងអស់លុតជង្គង់ចុះ។ រាល់ប្រជាជាតិទាំងអស់នឹងត្រូវគេកោះហៅឱ្យទៅទទួលបញ្ជីកំណត់ត្រាទង្វើរបស់ខ្លួន។ (មានគេនិយាយទៅកាន់ពួកគេថា៖) នៅថ្ងៃនេះ ពួកអ្នក(ឱមនុស្សលោកទាំងឡាយ)នឹងត្រូវគេតបស្នងចំពោះអ្វីដែលពួកអ្នកធ្លាប់បានសាង។

29. នេះគឺជាសៀវភៅកំណត់ត្រារបស់យើង(អល់ឡោះ)ដែលនិយាយអំពីពួកអ្នកដោយពិតប្រាកដ។ ពិតប្រាកដណាស់ យើងបានឱ្យគេ(ម៉ាឡាអ៊ីកាត់)កត់ត្រាទុកនូវអ្វីៗដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

30. រីឯបណ្តាអ្នកដែលមានជំនឿនិងបានសាងទង្វើកុសលវិញនោះ ព្រះជាម្ចាស់របស់ពួកគេនឹងបញ្ចូលពួកគេទៅក្នុងក្តីមេត្តាករុណារបស់ទ្រង់។ នោះហើយជាជោគជ័យយ៉ាងច្បាស់លាស់។

31. ចំណែកឯពួកដែលគ្មានជំនឿវិញ (មានគេនិយាយទៅកាន់ពួកគេថា៖) តើវាក្យខណ្ឌទាំងឡាយរបស់យើងមិនធ្លាប់ត្រូវបានគេសូត្រឱ្យពួកអ្នកស្តាប់ទេឬ តែពួកអ្នកបែរជាក្រអឺតក្រទមទៅវិញនោះ? ហើយពួកអ្នកធ្លាប់ជាក្រុមឧក្រិដ្ឋជន។

32. ហើយនៅពេលដែលមានគេនិយាយ(ទៅកាន់ពួកអ្នក)ថា៖ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត ហើយថ្ងៃបរលោក គឺគ្មានការសង្ស័យចំពោះវាឡើយនោះ ពួកអ្នកបែរជានិយាយថា៖ ពួកយើងមិនដឹងទេថា អ្វីទៅជាថ្ងៃបរលោកនោះ។ ពួកយើងគិតថា វាគ្មានអ្វីក្រៅពីការស្មានប៉ុណ្ណោះ ហើយពួកយើងក៏មិនមែនជាអ្នកដែលជឿជាក់នោះដែរ។

33. ហើយអំពើអាក្រក់ទាំងឡាយដែលពួកគេបានសាង បានលាតត្រដាងឡើងចំពោះមុខពួកគេ ហើយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានសើចចំអកចំពោះវានោះបានហ៊ុមព័ទ្ធពួកគេ។

34. ហើយមានគេនិយាយថា៖ នៅថ្ងៃនេះយើងបំភ្លេចពួកអ្នក ដូចដែលពួកអ្នកធ្លាប់បានភ្លេចពីជំនួបរបស់ពួកអ្នកនាថ្ងៃនេះ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកអ្នក គឺឋាននរក។ ហើយសម្រាប់ពួកអ្នក គឺគ្មានអ្នកជួយឡើយ។

35. នោះគឺដោយសារតែពួកអ្នកបានយកវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះធ្វើជាការលេងសើច ហើយឆាកជីវិតលោកិយបានបោកប្រាស់ពួកអ្នក។ ដូច្នេះនៅថ្ងៃនេះ ពួកគេមិនត្រូវបានគេឲ្យចាកចេញពីឋាននរកឡើយ ហើយពួកគេក៏មិនត្រូវបានគេឱ្យវិលត្រឡប់(ទៅកាន់លោកិយវិញម្តងទៀត)នោះដែរ។

36. ពិតប្រាកដណាស់ ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃមេឃជាច្រើនជាន់ និងជាព្រះជាម្ចាស់នៃផែនដី ជាព្រះជាម្ចាស់នៃពិភពទាំងអស់។

37. ហើយអំណាចមហិមាទាំងនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

ជំពូក អាល់អះក៏ហ្វ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ហា មីម (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។

2. ការបញ្ចុះគម្ពីរ(គួរអាន) គឺមកពីអល់ឡោះជាម្ចាស់ដ៏មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

3. យើង(អល់ឡោះ)មិនបានបង្កើតមេឃជាច្រើនជាន់ និងផែនដី ហើយនិងអ្វីៗដែលនៅរវាងវាទាំងពីរនោះឡើយ លើកលែងតែជាការពិត និងមានពេលវេលាកំណត់យ៉ាងច្បាស់លាស់។ ចំណែកឯពួកគ្មានជំនឿ គឺជាពួកដែលងាកចេញពីអ្វីដែលគេបានដាស់តឿនព្រមានពួកគេ។

4. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកឃើញដែរឬទេ អ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈក្រៅពីអល់ឡោះនោះ ចូរពួកអ្នកបង្ហាញខ្ញុំមក ថាតើអ្វីមួយនៃផែនដីដែលពួកវាបានបង្កើតនោះ? ឬមួយពួកវារួមចំណែកក្នុង(ការបង្កើត)មេឃជាច្រើនជាន់(ជាមួយអល់ឡោះ)? ចូរពួកអ្នកនាំគម្ពីរមួយមុននឹងគម្ពីរនេះ(គម្ពីរគួរអាន)មកឱ្យខ្ញុំ ឬក៏ចំណេះដឹងដែលគេបានបន្សល់ទុកមក ប្រសិនបើពួកអ្នកជាអ្នកដែលទៀងត្រង់មែននោះ។

5. ហើយគ្មានអ្នកណាដែលវង្វេងជាងពួកដែលបួងសួងអ្វីផ្សេងក្រៅពីអល់ឡោះដែលវាមិនអាចឆ្លើយតបចំពោះគេបានរហូតដល់ថ្ងៃបរលោកនោះឡើយ។ ហើយពួកវាជាពួកដែលមិនដឹងអ្វីចំពោះការបួងសួងរបស់ពួកគេឡើយ។

6. ហើយនៅពេលដែលគេប្រមូលផ្តុំមនុស្សលោក ពួកវានឹងក្លាយជាសត្រូវរបស់ពួកគេ។ ហើយពួកវាបដិសេធចំពោះការគោរពសក្ការៈរបស់ពួកគេ។

7. ហើយនៅពេលដែលមានគេសូត្រវាក្យខណ្ឌទាំងឡាយរបស់យើងដ៏ច្បាស់លាស់ឱ្យពួកគេស្តាប់ ពួកដែលប្រឆាំងបាននិយាយចំពោះសេចក្តីពិត(គម្ពីរគួរអាន)នៅពេលដែលវាបានមកដល់ពួកគេថា៖ នេះគឺជាមន្តអាគមយ៉ាងច្បាស់លាស់។

8. ឬមួយពួកទាំងនោះនិយាយថា៖ គាត់(ព្យាការីមូហាំម៉ាត់)បានប្រឌិតគម្ពីរនេះ(គម្ពីរគួរអាន)នេះឡើង? ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)តបថា៖ ប្រសិនបើខ្ញុំប្រឌិតគម្ពីរនេះឡើង(ដោយខ្លួនឯង)មែននោះ ពួកអ្នកមិនអាចការពារខ្ញុំពី(ទណ្ឌកម្ម)អល់ឡោះអ្វីបន្តិចនោះឡើយ។ ទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកចោទប្រកាន់ចំពោះគម្ពីរនេះ។ គ្រប់គ្រាន់ហើយដែលទ្រង់ជាសាក្សីរវាងខ្ញុំ និងពួកអ្នក។ ហើយទ្រង់មហាអភ័យទោស មហាអាណិតស្រលាញ់។

9. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំមិនមែនជាអ្នកនាំសារដំបូងគេបង្អស់នោះឡើយ ហើយខ្ញុំក៏មិនដឹងថាគេ(អល់ឡោះ)នឹងធ្វើអ្វីចំពោះរូបខ្ញុំ និងចំពោះពួកអ្នកនោះដែរ។ ខ្ញុំមិនធ្វើតាមអ្វីក្រៅតែពីវាហ៊ីដែលគេបានផ្តល់មកកាន់ខ្ញុំឡើយ។ ហើយរូបខ្ញុំក៏គ្មានអ្វីក្រៅតែពីជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់នោះដែរ។

10. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើវា(គម្ពីរគួរអាន)មកពីអល់ឡោះពិតមែន តែពួកអ្នកបែរជាបានប្រឆាំងនឹងវា ហើយក៏មានសាក្សីម្នាក់ក្នុងចំណោមអម្បូរអ៊ីស្រាអែលបានធ្វើសាក្សីទទួលស្គាល់ដូចនេះ ហើយរូបគេក៏មានជំនឿ(ចំពោះវា)ដែរ តែពួកអ្នក បែរជាក្រអឺតក្រទមទៅវិញនោះ (តើនេះពុំមែនជាការបំពានដ៏ធ្ងន់ធ្ងរទេឬ)? ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនចង្អុលបង្ហាញចំពោះក្រុមដែលបំពានឡើយ។

11. ហើយពួកដែលគ្មានជំនឿបាននិយាយទៅកាន់បណ្តាអ្នកដែលមានជំនឿថា៖ ប្រសិនបើគម្ពីរនេះជាប្រការល្អមែននោះ មិនមែនពួកគេរួសរាន់ទៅកាន់(ការជឿជាក់ចំពោះ)គម្ពីរនេះមុនពួកយើងនោះឡើយ។ ហើយនៅពេលដែលពួកគេមិនទទួលបានការចង្អុលបង្ហាញនឹងវា នោះពួកគេនឹងនិយាយថា៖ នេះជារឿងកូតកុហកតាំងពីយូរលង់ណាស់មកហើយ។

12. ហើយមុននឹងគម្ពីរនេះ(គម្ពីរគួរអាន)គឺមានគម្ពីររបស់ព្យាការីមូសា(គម្ពីរតាវ៉ាត)ដែលជាការដឹកនាំ និងជាក្តីមេត្តាករុណា។ ហើយគម្ពីរ(គួរអាន)នេះជាអ្នកបញ្ជាក់(ទៅលើគម្ពីរទាំងឡាយដែលបានបញ្ចុះពីមុន)ជាភាសាអារ៉ាប់ ដើម្បីដាស់តឿនព្រមានដល់ពួកដែលបំពាន និងជាដំណឹងរីករាយសម្រាប់បណ្តាអ្នកដែលសាងអំពើល្អ។

13. ពិតប្រាកដណាស់ បណ្តាអ្នកដែលនិយាយថា៖ "ព្រះជាម្ចាស់របស់ពួកយើង គឺអល់ឡោះ" ក្រោយមក ពួកគេបានប្រកាន់ខ្ជាប់(ក្បួនច្បាប់របស់ទ្រង់)ពិតប្រាកដណាស់ គ្មានការភ័យខ្លាចអ្វីឡើយចំពោះពួកគេ ហើយពួកគេក៏គ្មានទុក្ខព្រួយអ្វីនោះដែរ។

14. អ្នកទាំងនោះ គឺជាអ្នកឋានសួគ៌។ ពួកគេស្ថិតនៅក្នុងនោះជាអមតៈ ជាការតបស្នងចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

15. ហើយយើង(អល់ឡោះ)បានផ្តែផ្តាំមនុស្សលោកឱ្យធ្វើល្អចំពោះឪពុកម្តាយរបស់ខ្លួន។ ម្តាយរបស់គេបានពពោះគេយ៉ាងលំបាក និងបានប្រសូត្រគេមកយ៉ាងលំបាកបំផុត។ ហើយការពពោះ និងផ្តាច់ដោះរបស់គេ គឺមានរយៈពេលសាមសិបខែ។ លុះដល់ពេលដែលគេធំពេញវ័យ និងបានឈានដល់អាយុសែសិបឆ្នាំ គេក៏បួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាឱ្យខ្ញុំចេះដឹងគុណចំពោះឧបការគុណរបស់ព្រះអង្គដែលបានប្រទានមកឱ្យខ្ញុំ និងប្រទានឱ្យឪពុកម្តាយរបស់ខ្ញុំផងចុះ ហើយសូមមេត្តាឱ្យខ្ញុំសាងនូវទង្វើកុសលដែលព្រះអង្គពេញចិត្ត និងសូមព្រះអង្គមេត្តាកែលម្អកូនចៅរបស់ខ្ញុំឲ្យខ្ញុំផង។ ពិតប្រាកដណាស់ ខ្ញុំសូមសារភាពកំហុសចំពោះព្រះអង្គ ហើយពិតប្រាកដណាស់ រូបខ្ញុំស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន។

16. អ្នកទាំងនោះហើយដែលយើងទទួលយកពីពួកគេនូវអំពើល្អទាំងឡាយដែលពួកគេបានសាង ហើយយើងនឹងអធ្យាស្រ័យចំពោះអំពើអាក្រក់ទាំងឡាយរបស់ពួកគេ ដោយស្ថិតក្នុងចំណោមអ្នកឋានសួគ៌ ជាការសន្យាដ៏ពិតប្រាកដដែលគេធ្លាប់បានសន្យាចំពោះពួកគេ។

17. ហើយអ្នកដែលបាននិយាយទៅកាន់ឪពុកម្តាយរបស់ខ្លួនថា៖ ច្បឹយអ្នកទាំងពីរ! តើអ្នកទាំងពីរសន្យានឹងខ្ញុំថា គេនឹងបញ្ចេញរូបខ្ញុំ(ពីផ្នូរមកវិញ)ខណៈដែលជាច្រើនសតវត្សមកហើយបានកន្លងផុតទៅមុនខ្ញុំ(តែគ្មានអ្នកណាម្នាក់រស់ឡើងវិញ)ផងនោះឬ? ហើយគាត់ទាំងពីរបានបួងសួងសុំពីអល់ឡោះ(ឲ្យកូនរបស់ខ្លួន)និងបាននិយាយថា៖ វិនាសអន្តរាយហើយកូន! ចូរកូនមានជំនឿចុះ។ ពិតប្រាកដណាស់ ការសន្យារបស់អល់ឡោះ គឺជាការពិត។ តែគេបានតបថា៖ នេះគ្មានអ្វីក្រៅពីជារឿងព្រេងនិទានរបស់អ្នកជំនាន់មុននោះឡើយ។

18. ពួកទាំងនោះហើយជាពួកដែលពាក្យពេចន៍(ទណ្ឌកម្ម)ត្រូវធ្លាក់លើពួកគេក្នុងចំណោមប្រជាជាតិដែលបានកន្លងផុតទៅមុនពួកគេនៃពួកជិន និងមនុស្សលោក។ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលខាតបង់។

19. ហើយរាល់ៗពួកគេ(មនុស្សល្អ និងមនុស្សអាក្រក់)គឺមានឋានៈជាច្រើនអាស្រ័យទៅតាមអ្វីដែលពួកគេបានប្រព្រឹត្ត និងដើម្បីទ្រង់តបស្នងយ៉ាងពេញលេញចំពោះទង្វើរបស់ពួកគេ។ ហើយពួកគេមិនត្រូវបានគេបំពានឡើយ។

20. ហើយនៅថ្ងៃដែលពួកគ្មានជំនឿត្រូវបានគេបង្ហាញទៅកាន់ឋាននរក(មានគេនិយាយទៅកាន់ពួកគេថា៖)ពួកអ្នកបានធ្វើឱ្យបាត់បង់នូវប្រការល្អរបស់ពួកអ្នកនៅក្នុងជីវិតលោកិយ ហើយពួកអ្នកបានសោយសុខជាមួយវារួចហើយ។ ដូច្នេះ នៅថ្ងៃនេះគេនឹងតបស្នងដល់ពួកអ្នកនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត ដោយសារតែពួកអ្នកធ្លាប់បានក្រអឺតក្រទមនៅលើផែនដីដោយមិនត្រឹមត្រូវ និងដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តល្មើស។

21. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រំលឹកពី(ព្យាការីហ៊ូទ)បងប្អូនរបស់ក្រុមអាទ នៅពេលដែលគាត់បានព្រមានក្រុមរបស់គាត់នៅឯតំបន់"អះក៏ហ្វ"។ ហើយពិតប្រាកដណាស់ មានអ្នកជាស់តឿនព្រមានជាច្រើនដែលបានកន្លងផុតទៅមុនគាត់ និងបន្ទាប់ពីគាត់(ដោយពួកគាត់បាននិយាយថា៖) ចូរពួកអ្នកកុំគោរពសក្ការៈ លើកលែងតែចំពោះអល់ឡោះប៉ុណ្ណោះ។ ពិតប្រាកដណាស់ ខ្ញុំបារម្ភខ្លាចពួកអ្នកទទួលនូវទណ្ឌកម្មនៅថ្ងៃដ៏ធំធេង(ថ្ងៃបរលោក)។

22. ពួកគេបានតបវិញថា៖ តើអ្នកមកកាន់ពួកយើងដើម្បីបង្វែរពួកយើងចេញពីព្រះទាំងឡាយរបស់ពួកយើងឬ? ដូចនេះ ចូរអ្នកនាំមកកាន់ពួកយើងនូវអ្វី(ទណ្ឌកម្ម)ដែលអ្នកបានសន្យានឹងពួកយើងនោះមក ប្រសិនបើអ្នកស្ថិតក្នុងចំណោមអ្នកទៀងត្រង់មែននោះ។

23. គាត់(ព្យាការីហ៊ូទ)បានតបវិញថា៖ តាមពិត ចំណេះដឹង(ពីរឿងនោះ)គឺនៅឯអល់ឡោះ ហើយខ្ញុំគ្រាន់តែផ្សព្វផ្សាយប្រាប់ពួកអ្នកនូវអ្វីដែលគេបានបញ្ជូនខ្ញុំឱ្យពាំនាំវាមកប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំយល់ឃើញថា ពួកអ្នកគឺជាក្រុមដែលល្ងង់ខ្លៅ។

24. ហើយនៅពេលដែលពួកគេបានឃើញវា(ទណ្ឌកម្ម)លាតសន្ធឹង(នៅលើមេឃ)តម្រង់ឆ្ពោះមកកាន់ជ្រលងភ្នំរបស់ពួកគេ ពួកគេក៏និយាយថា៖ ពពកដ៏ធំនេះនឹងនាំទឹកភ្លៀងមកកាន់ពួកយើង។ ព្យាការីហ៊ូទបានតបថា៖ (មិនដូច្នោះឡើយ។) ផ្ទុយទៅវិញ វាគឺជាអ្វីដែលពួកអ្នកសុំឱ្យវាឆាប់មកដល់នោះហើយ។ ជាខ្យល់ដែលផ្ទុកទៅដោយទណ្ឌកម្មដ៏ឈឺចាប់បំផុត។

25. វាបានបំផ្លាញអ្វីៗទាំងអស់ទៅតាមបទបញ្ជានៃព្រះជាម្ចាស់របស់វា។ ពេលនោះ ពួកគេក៏ត្រូវបានស្លាប់អស់ដោយគ្មានអ្វីនៅសេសសល់ក្រៅតែពីផ្ទះសម្បែងរបស់ពួកគេប៉ុណ្ណោះ។ ក៏ដូច្នោះដែរ យើងនឹងតបស្នងដល់ក្រុមឧក្រិដ្ឋជនទាំងឡាយ។

26. ហើយជាការពិតណាស់ យើងបានប្រទាននូវអំណាចគ្រប់គ្រងដល់ពួកគេ(ក្រុមអាទ)នូវអ្វីដែលយើងមិនបានប្រទានវាឱ្យពួកអ្នកឡើយ។ ហើយយើងបានបង្កើតឲ្យពួកគេនូវការស្តាប់ឮ ការមើលឃើញ និងប្រាជ្ញា។ ក៏ប៉ុន្តែការស្តាប់ឮ ការមើលឃើញ និងប្រាជ្ញារបស់ពួកគេមិនបានផ្តល់ប្រយោជន៍អ្វីបន្តិចដល់ពួកគេឡើយ ខណៈដែលពួកគេបានប្រឆាំងនឹងសញ្ញាកស្តុតាងទាំងឡាយរបស់អល់ឡោះ។ ហើយអ្វី(ទណ្ឌកម្ម)ដែលពួកគេធ្លាប់បានសើចចំអកចំពោះវានោះ បានហ៊ុមព័ទ្ធពួកគេ។

27. ហើយពិតប្រាកដណាស់ យើងបានបំផ្លាញភូមិឋានជាច្រើននៅជុំវិញពួកអ្នក(ឱអ្នកស្រុកម៉ាក្កៈ) ហើយយើងបានបកស្រាយបញ្ជាក់នូវសញ្ញាកស្តុតាងជាច្រើន សង្ឃឹមថាពួកគេនឹងវិលត្រលប់។

28. ហេតុអ្វីបានជាអ្នកដែលពួកគេយកមកគោរពសក្ការៈក្រៅពីអល់ឡោះដើម្បីបញ្ជិតខ្លួនទៅកាន់ព្រះជាម្ចាស់នោះ មិនជួយដល់ពួកគេ? ផ្ទុយទៅវិញ ពួកវាបានរង្គើចេញពីពួកគេ។ នោះហើយជាការកុហករបស់ពួកគេ និងអ្វីដែលពួកគេបានប្រឌិតឡើង។

29. ហើយ(ចូរអ្នករំលឹក)នៅពេលដែលយើងបានបញ្ជូនក្រុមមួយនៃពួកជិនទៅកាន់អ្នក ដើម្បីពួកគេស្តាប់គម្ពីរគួរអាន។ ហើយនៅពេលដែលពួកគេ(ពួកជិន)បានទៅដល់ ពួកគេបាននិយាយថា៖ ចូរពួកអ្នកនៅស្ងៀម។ ហើយនៅពេលដែលគេ(ព្យាការីមូហាំម៉ាត់)សូត្រចប់ ពួកគេបានត្រលប់ទៅកាន់ក្រុមរបស់ខ្លួនវិញក្នុងនាមជាដាស់តឿនព្រមាន។

30. ពួកគេ(ពួកជិន)បាននិយាយថា៖ ឱក្រុមរបស់ពួកយើង! ពិតប្រាកដណាស់ ពួកយើងបានស្តាប់ឮគម្ពីរមួយ(គម្ពីរគួរអាន)ដែលគេបានបញ្ចុះក្រោយពីព្យាការីមូសាជាការបញ្ជាក់ទៅលើគម្ពីរទាំងឡាយដែលបានបញ្ចុះមុនគម្ពីរនេះ ហើយគម្ពីរនេះចង្អុលបង្ហាញទៅកាន់សេចក្តីពិត និងទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។

31. ឱក្រុមរបស់ពួកយើង! ចូរពួកអ្នកឆ្លើយតបចំពោះអ្នកអំពាវនាវរបស់អល់ឡោះ(ព្យាការីមូហាំម៉ាត់) និងមានជំនឿចំពោះគាត់ នោះទ្រង់នឹងអភ័យទោសដល់ពួកអ្នកចំពោះបាបកម្មទាំងឡាយរបស់ពួកអ្នក ព្រមទាំងសង្គ្រោះពួកអ្នកពីទណ្ឌកម្ម ដ៏ឈឺចាប់បំផុត។

32. ជនណាហើយដែលមិនឆ្លើយតបចំពោះអ្នកអំពាវនាវរបស់អល់ឡោះទេនោះ ពិតណាស់ រូបគេមិនអាចរួចផុត(ពីទណ្ឌកម្ម អល់ឡោះ)នៅលើផែនដីនោះឡើយ ហើយរូបគេក៏គ្មានអ្នកគាំពារណាក្រៅពីទ្រង់នោះដែរ។ ពួកទាំងនោះហើយដែលស្ថិត ក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

33. តើពួកគេមិនបានឃើញទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដី និងមិនអសមត្ថភាពក្នុងការបង្កើតពួកវានោះ គឺទ្រង់ពិតជាអ្នកដែលមានសមត្ថភាពក្នុងការធ្វើឲ្យអ្នកស្លាប់រស់ឡើងវិញ? ពិតមែនហើយ ជាការពិតណាស់ ទ្រង់ពិតជាមានអានុភាពលើរាល់អ្វីៗទាំងអស់។

34. ហើយនៅថ្ងៃដែលពួកគ្មានជំនឿត្រូវបានគេបង្ហាញទៅកាន់ឋាននរក (ហើយមានគេនិយាយថា៖) តើនេះមិនមែនជាការពិត ទេឬ? ពួកគេឆ្លើយថា៖ ពិតមែនហើយ សូមស្បថនឹងព្រះជាម្ចាស់របស់ពួកយើង! គេបានបន្តថា៖ ដូច្នេះ ចូរពួកអ្នកភ្លក់ ទណ្ឌកម្មចុះ ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រឆាំង។

35. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ ដូចដែលបណ្តាអ្នកដែលមានឆន្ទៈមោះមុតក្នុងចំណោមអ្នកនាំសារទាំងឡាយ បានអត់ធ្មត់ចុះ ហើយចូរអ្នកកុំសុំឱ្យទណ្ឌកម្មធាប់មកដល់ពួកគេឱ្យសោះ។ នៅថ្ងៃដែលពួកគេ(ពួកបដិសេធ)បានឃើញអ្វី (ទណ្ឌកម្ម)ដែលគេបានសន្យាចំពោះពួកគេ (ពួកគេមានអារម្មណ៍ថា) ហាក់បីដូចជាពួកគេមិនបានរស់នៅ(លើលោកិយ) នេះឡើយ លើកលែងតែមួយរយៈពេល(ដ៏ខ្លី)នៃពេលថ្ងៃប៉ុណ្ណោះ។ (នេះជា)សេចក្តីប្រកាស(សម្រាប់ពួកគេ)។ ដូចនេះ គេមិនបំផ្លាញឡើយ លើកលែងតែក្រុមដែលប្រព្រឹត្តល្មើសប៉ុណ្ណោះ។

ជំពូក មូហាំម៉ាត់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពួកដែលគ្មានជំនឿ និងបានរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះនោះ ទ្រង់នឹងធ្វើឱ្យទង្វើ(កុសល)របស់ពួកគេក្លាយជាអសារបង់។

2. រីឯបណ្ដាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ព្រមទាំងមានជំនឿចំពោះអ្វីដែលគេបានបញ្ចុះទៅលើព្យាការីមូហាំម៉ាត់ដែលវាជាការពិតមកពីព្រះជាម្ចាស់របស់ពួកគេនោះ ទ្រង់នឹងលុបលាងនូវអំពើអាក្រក់ទាំងឡាយរបស់ពួកគេ និងកែលម្អនូវកិច្ចការទាំងឡាយរបស់ពួកគេ។

3. នោះគឺដោយសារតែពួកដែលគ្មានជំនឿ គឺពួកគេដើរតាមប្រការខុសឆ្គង។ ចំណែកឯបណ្ដាអ្នកដែលមានជំនឿវិញ គឺពួកគេដើរតាមប្រការត្រឹមត្រូវពីព្រះជាម្ចាស់របស់ពួកគេ។ ក៏ដូច្នោះដែរ អល់ឡោះជាម្ចាស់បានលើកយកគំរូរបស់ពួកគេ(ធ្វើជាឧទាហរណ៍)សម្រាប់មនុស្សលោក។

4. ហើយនៅពេលដែលពួកអ្នក(ឱបណ្ដាអ្នកដែលមានជំនឿ)បានជួបនឹងពួកគ្មានជំនឿ(នៅក្នុងសមរភូមិ) ចូរពួកអ្នកវាយកញ្ចឹងក(របស់ពួកគេ) រហូតដល់ពួកអ្នកធ្វើឲ្យពួកគេទន់ខ្សោយ។ ពេលនោះ ចូរពួកអ្នកចាប់ពួកគេជាឈ្លើយសឹក។ ក្រោយមក (ពួកអ្នកអាច)ដោះលែងពួកគេដោយគ្មានសំណង ឬដោយការលោះឈ្លើយសឹក រហូតដល់សង្គ្រាមបានបញ្ចប់។ នោះ(គឺជាច្បាប់របស់អល់ឡោះ)។ ហើយប្រសិនបើអល់ឡោះទ្រង់មានចេតនា ទ្រង់ប្រាកដជានឹងឱ្យ(អ្នកមានជំនឿ)យកជ័យជម្នះទៅលើពួកគេ(ដោយមិនចាំបាច់ប្រយុទ្ធគ្នា)ជាមិនខាន ក៏ប៉ុន្តែ គឺដើម្បីទ្រង់សាកល្បងមួយចំនួននៃពួកអ្នកនឹងអ្នកមួយចំនួនទៀត។ ហើយបណ្ដាអ្នកមានជំនឿដែលត្រូវបានគេសម្លាប់នៅក្នុងមាគ៌ារបស់អល់ឡោះនោះ ទ្រង់នឹងមិនលុបបំបាត់នូវទង្វើកុសលទាំងឡាយរបស់ពួកគេដាច់ខាត។

5. ទ្រង់នឹងចង្អុលបង្ហាញពួកគេ និងកែលម្អនូវកិច្ចការទាំងឡាយរបស់ពួកគេ។

6. ហើយទ្រង់នឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដែលទ្រង់បានពណ៌នាពីវាដល់ពួកគេ។

7. ឱបណ្ដាអ្នកដែលមានជំនឿ! ប្រសិនបើពួកអ្នកជួយ(សាសនា)អល់ឡោះ នោះទ្រង់នឹងជួយពួកអ្នកវិញ ព្រមទាំងពង្រឹងជំហររបស់ពួកអ្នក។

8. រីឯពួកដែលគ្មានជំនឿវិញ កាពវិនាសអន្តរាយគឺសម្រាប់ពួកគេ ហើយទ្រង់នឹងលុបបំបាត់នូវទង្វើ(កុសល)ទាំងឡាយរបស់ពួកគេ។

9. នោះគឺដោយសារតែពួកគេស្អប់អ្វី(គម្ពីរគួរអាន)ដែលអល់ឡោះបានបញ្ចុះមក។ ដូច្នេះ ទ្រង់ក៏បានធ្វើឲ្យទង្វើកុសលទាំងឡាយរបស់ពួកគេក្លាយជាអសារបង់។

10. តើពួកគេមិនបានធ្វើដំណើរលើផែនដី ហើយពិចារណាមើលទេឬថា តើលទ្ធផលចុងក្រោយរបស់ពួក(បដិសេធ)ជំនាន់មុនពួកគេទៅជាយ៉ាងណា? អល់ឡោះទ្រង់បានបំផ្លាញពួកគេ។ ហើយសម្រាប់ពួកដែលគ្មានជំនឿក៏នឹងទទួល(លទ្ធផលចុងក្រោយ)ដូចគ្នានេះដែរ។

11. នោះគឺដោយសារតែអល់ឡោះជាម្ចាស់ គឺជាអ្នកគាំពារបណ្តាអ្នកដែលមានជំនឿ។ រីឯពួកដែលគ្មានជំនឿវិញ សម្រាប់ពួកគេគឺគ្មានអ្នកគាំពារឡើយ។

12. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងបញ្ចូលបណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ ហើយពួកដែលគ្មានជំនឿវិញ ពួកគេសោយសុខ និងបរិភោគអាហារប្រៀបដូចសត្វពាហនៈស៊ី(ចំណី)ដូច្នោះដែរ។ ហើយឋាននរក គឺជាកន្លែងស្នាក់នៅសម្រាប់ពួកគេ។

13. ហើយមានភូមិស្រុកជាច្រើនដែលមានភាពខ្លាំងក្លាជាងភូមិស្រុករបស់អ្នក(ក្រុងម៉ាក្កៈ)ដែលគេបានបណ្តេញអ្នក(ព្យាការីមូហាំម៉ាត់)ចេញទៅទៀត តែយើងបានបំផ្លាញពួកគេដោយពួកគេគ្មានអ្នកជួយឡើយ។

14. ដូច្នេះ តើអ្នកដែលស្ថិតនៅលើកស្តូតាងយ៉ាងច្បាស់លាស់ពីព្រះជាម្ចាស់របស់គេ ដូចគ្នានឹងអ្នកដែលត្រូវបានគេតុបតែងលម្អនូវអំពើអាក្រក់របស់គេ និងដើរតាមទំនើងចិត្តរបស់ពួកគេឬ?

15. លក្ខណៈរបស់ឋានសួគ៌ដែលគេបានសន្យាចំពោះបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)នោះ គឺមានទន្លេជាច្រើនអំពីទឹកដែលមិនប្រែប្រួល និងមានទន្លេជាច្រើនអំពីទឹកដោះគោដែលមិនប្រែប្រួលរសជាតិរបស់វា ហើយនិងទន្លេជាច្រើនអំពីសុរាដែលមានរសជាតិឆ្ងាញ់ពិសារសម្រាប់អ្នកដែលទទួលទាន ព្រមទាំងមានទន្លេជាច្រើនអំពីទឹកឃ្មុំជ័បរិសុទ្ធ។ ហើយនៅក្នុងឋានសួគ៌នោះផងដែរ ពួកគេនឹងទទួលបានផ្លែឈើគ្រប់ប្រភេទ និងការអភ័យទោសពីព្រះជាម្ចាស់របស់ពួកគេ។ តើ(អ្នកដែលទទួលបានបែបនេះ)ដូចគ្នាទៅនឹងអ្នកស្ថិតនៅជាអមតៈក្នុងឋាននរក ហើយពួកគេត្រូវបានគេឱ្យផឹកទឹកដ៏សែនក្តៅបំផុតដែលធ្វើឱ្យពោះវៀនរបស់ពួកគេដាច់ដោចឬ?

16. ហើយក្នុងចំណោមពួកគេ(ពួកពុតត្បុត) គឺមានអ្នកដែលស្តាប់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)។ លុះនៅពេលដែលពួកគេបានចាកចេញអំពីអ្នក ពួកគេបាននិយាយទៅកាន់បណ្តាអ្នកដែលគេបានផ្តល់ចំណេះដឹងឲ្យថា៖ តើគេបាននិយាយអ្វីអម្បាញ់មិញ? ពួកទាំងនោះហើយដែលអល់ឡោះទ្រង់បានបោះត្រាភ្ជិតទៅលើដួងចិត្តរបស់ពួកគេ ហើយពួកគេក៏ធ្វើតាមទំនើងចិត្តរបស់ខ្លួន។

17. ចំណែកឯបណ្តាអ្នកដែលទទួលបានការចង្អុលបង្ហាញ ទ្រង់បានបន្ថែមនូវការចង្អុលបង្ហាញដល់ពួកគេថែមទៀត និងពង្រឹងដល់ពួកគេនូវការកោតខ្លាចរបស់ពួកគេ។

18. ដូច្នេះ តើពួកគេមិនរង់ចាំអ្វីក្រៅពីថ្ងៃបរលោកដែលនឹងមកដល់ពួកគេភ្លាមៗនោះឬ? ពិតប្រាកដណាស់ សញ្ញាទាំងឡាយរបស់វាបានមកដល់រួចទៅហើយ។ ដូច្នេះ តើពួកគេមានការភ្ញាក់រលឹកយ៉ាងដូចម្តេច នៅពេលដែលវា(ថ្ងៃបរលោក)បានមកដល់ពួកគេហើយនោះ?

19. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងចុះថា៖ ពិតប្រាកដណាស់ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ។ ហើយចូរអ្នកសុំការអភ័យទោសចំពោះបាបកម្មរបស់អ្នក និង(សុំការអភ័យទោស)ដល់បណ្តាអ្នកមានជំនឿ ទាំងប្រុសទាំងស្រី។ ហើយអល់ឡោះទ្រង់ដឹងបំផុតពីសកម្មភាពរបស់ពួកអ្នក និងកន្លែងស្នាក់នៅរបស់ពួកអ្នក។

20. ហើយបណ្តាអ្នកដែលមានជំនឿបាននិយាយថា៖ ហេតុអ្វីបានជាគេមិនបញ្ចុះជំពូកមួយ(ដែលប្រើឲ្យធ្វើសង្គ្រាម)? តែនៅពេលដែលគេបានបញ្ចុះនូវជំពូកមួយដែលបកស្រាយបញ្ជាក់យ៉ាងច្បាស់លាស់ ហើយគេបានលើកឡើងនៅក្នុងនោះពីការធ្វើសង្គ្រាម អ្នកនឹងឃើញពួកដែលចិត្តរបស់ពួកគេមានជំងឺ(ពួកពុតត្បុត)សម្លឹងមើលទៅកាន់អ្នក ដូចជាខ្សែភ្នែករបស់អ្នកដែលសេចក្តីស្លាប់គ្របដណ្តប់លើរូបគេដូច្នោះដែរ។ ដូច្នេះ ជារឿងដែលល្អសម្រាប់ពួកគេ

21. គឺការគោរពប្រតិបត្តិអល់ឡោះ និង(និយាយនូវ)ពាក្យសម្តីដែលល្អ។ ហើយនៅពេលដែលបទបញ្ជា(ធ្វើសង្គ្រាម)ត្រូវបានសម្រេច ប្រសិនបើពួកគេមានភាពស្មោះត្រង់ចំពោះអល់ឡោះ វាគឺជាការប្រសើរសម្រាប់ពួកគេ។

22. តើពួកអ្នកសង្ឃឹមយ៉ាងណា ប្រសិនបើពួកអ្នកងាកចេញ(ពីគម្ពីរគួរអាននិងស៊ុណ្ណះ) គឺពួកអ្នកនឹងបង្កនិាសកម្មនៅលើផែនដី ព្រមទាំងកាត់ផ្តាច់ចំណងសាច់សាលោហិតរបស់ពួកអ្នកជាមិនខាន។

23. ពួកទាំងនោះហើយដែលអល់ឡោះទ្រង់ដាក់បណ្តាសាពួកគេ ហើយទ្រង់បានធ្វើឱ្យពួកគេថ្លង់ និងបានធ្វើឱ្យភ្នែករបស់ពួកគេខ្វាក់(មើលមិនឃើញការពិត)ផងដែរ។

24. ដូច្នេះ តើពួកគេមិនត្រឹះរិះពិចារណាចំពោះគម្ពីរគួរអានទេឬ ឬមួយក៏ដួងចិត្តរបស់ពួកគេត្រូវបានចាក់សោជិត?

25. ពិតប្រាកដណាស់ ពួកដែលបែរត្រឡប់ក្រោយ(ចាកចេញពីភាពមានជំនឿ)ក្រោយពីការចង្អុលបង្ហាញបានបញ្ជាក់ដល់ពួកគេហើយនោះ គឺស្មែតនជាអ្នកតុបតែងលម្អដល់ពួកគេ និងឱ្យពួកគេមានក្តីស្រមៃវែងឆ្ងាយ។

26. នោះគឺដោយសារតែពួកគេបាននិយាយទៅកាន់ពួក(យូដា)ដែលមិនពេញចិត្តចំពោះអ្វីដែលអល់ឡោះបានបញ្ចុះមកថា៖ ពួកយើងនឹងធ្វើតាមពួកអ្នកចំពោះកិច្ចការមួយចំនួន។ ហើយអល់ឡោះទ្រង់ដឹងបំផុតនូវរឿងសម្ងាត់របស់ពួកគេ។

27. ដូច្នេះ តើ(ស្ថានភាពពួកគេ)យ៉ាងណាទៅវិញ នៅពេលដែលម៉ាឡាអ៊ីកាត់ដកយកជីវិតរបស់ពួកគេដោយបានវាយទៅលើមុខ និងខ្នងរបស់ពួកគេនោះ?

28. នោះគឺដោយសារតែពួកគេដើរតាមអ្វីដែលធ្វើឱ្យអល់ឡោះខឹងសម្បាចំពោះពួកគេ ហើយពួកគេមិនពេញចិត្តចំពោះអ្វីដែលទ្រង់ពេញចិត្ត។ ហេតុនេះ ទ្រង់ក៏បានឱ្យទង្វើកុសលទាំងឡាយរបស់ពួកគេក្លាយជាអសារបង់។

29. ឬមួយពួកដែលក្នុងចិត្តរបស់ពួកគេមានជំងឺ(ពួកពុតត្បុត)នឹកស្មានថា អល់ឡោះទ្រង់នឹងមិនបញ្ចេញភាពឈ្នានីសរបស់ពួកគេមកខាងក្រៅទេឬ?

30. ហើយប្រសិនបើយើងមានចេតនា យើងប្រាកដជាបង្ហាញឱ្យអ្នកបានឃើញពួកគេ(ពួកពុតត្បុត)។ ពេលនោះអ្នកពិតជានឹងស្គាល់ពួកគេតាមរយៈសញ្ញាសម្គាល់របស់ពួកគេជាមិនខាន។ ហើយអ្នកក៏នឹងស្គាល់ពួកគេតាមរយៈរបៀបនៃការនិយាយស្តីរបស់ពួកគេផងដែរ។ ហើយអល់ឡោះទ្រង់ដឹងបំផុតពីទង្វើរបស់ពួកអ្នក។

31. ហើយយើងប្រាកដជានឹងសាកល្បងពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ)រហូតទាល់តែយើងដឹងនូវអ្នកដែលតស៊ូ(ប្រយុទ្ធ)និងអ្នកដែលអត់ធ្មត់ក្នុងចំណោមពួកអ្នក។ ហើយយើងនឹងសាកល្បងចំពោះសកម្មភាពរបស់ពួកអ្នក។

32. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ និងបានរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះ ព្រមទាំងបានប្រព្រឹត្តផ្ទុយពីអ្នកនាំសារ(របស់ទ្រង់)ក្រោយពីការចង្អុលបង្ហាញបានបញ្ជាក់ច្បាស់ដល់ពួកគេហើយនោះ ពួកទាំងនោះមិនអាចបង្កគ្រោះថ្នាក់អ្វីបន្តិចដល់អល់ឡោះនោះឡើយ។ ហើយទ្រង់នឹងធ្វើឱ្យទង្វើកុសលទាំងឡាយរបស់ពួកគេក្លាយជាអសារបង់។

33. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ(របស់ទ្រង់) ហើយចូរកុំធ្វើឱ្យខូចនូវទង្វើកុសលទាំងឡាយរបស់ពួកអ្នកឱ្យសោះ។

34. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ និងបានរារាំង(អ្នកដទៃ)ពីមាគ៌ារបស់អល់ឡោះ ក្រោយមក ពួកគេបានស្លាប់ទាំងដែលពួកគេជាអ្នកគ្មានជំនឿនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់នឹងមិនអភ័យទោសដល់ពួកគេជាដាច់ខាត។

35. ដូច្នេះ ចូរពួកអ្នក(ឱបណ្តាពួកអ្នកមានជំនឿ)កុំទន់ខ្សោយ ហើយអំពាវនាវទៅកាន់សន្តិភាព ខណៈដែលពួកអ្នកជាអ្នកដែលមានភាពខ្លាំងក្លា(មានប្រៀបជាងពួកគេ)ឱ្យសោះ។ អល់ឡោះទ្រង់នៅជាមួយពួកអ្នក ហើយទ្រង់នឹងមិនកាត់បន្ថយ(ផលបុណ្យនៃ)ទង្វើកុសលរបស់ពួកអ្នកជាដាច់ខាត។

36. តាមការពិត ឆាកជីវិតលោកិយ គ្រាន់តែជាលេងសើច និងជាការបោកប្រាស់ប៉ុណ្ណោះ។ ហើយប្រសិនបើពួកអ្នកមានជំនឿ និងកោតខ្លាច(អល់ឡោះ) ទ្រង់នឹងប្រទានឱ្យពួកអ្នកនូវផលបុណ្យរបស់ពួកអ្នក។ ហើយទ្រង់មិនទាមទារយកពីពួកអ្នកនូវទ្រព្យសម្បត្តិទាំងអស់របស់ពួកអ្នកនោះឡើយ។

37. ប្រសិនបើទ្រង់ទាមទារវាពីពួកអ្នក រួចទ្រង់ទទូចទាមទារពីពួកអ្នក(ឱ្យបរិច្ចាគទាំងអស់) នោះពួកអ្នកនឹងកំណាញ់ ហើយទ្រង់នឹងលាតត្រដាងនូវការមិនពេញចិត្តរបស់ពួកអ្នកជាមិនខាន។

38. ឱអ្នកទាំងអស់គ្នា(ដែលជាអ្នកមានជំនឿ)! ពិតប្រាកដណាស់ ពួកអ្នកត្រូវបានគេអំពាវនាវឱ្យបរិច្ចាគ(ទ្រព្យសម្បត្តិ)ក្នុងមាគ៌ារបស់អល់ឡោះ។ ប៉ុន្តែក្នុងចំណោមពួកអ្នក គឺមានអ្នកដែលកំណាញ់។ ហើយជនណាដែលកំណាញ់ តាមពិតរូបគេកំពុងតែកំណាញ់ចំពោះខ្លួនឯងប៉ុណ្ណោះ។ អល់ឡោះមហាមានលើសលប់។ ចំណែកឯពួកអ្នក គឺដែលជាអ្នកខ្វះខាត។ ហើយប្រសិនបើពួកអ្នកងាកចេញ(ពីការមានជំនឿ) ទ្រង់នឹងជំនួសដោយក្រុមមួយទៀតក្រៅពីពួកអ្នក។ ក្រោយមក ពួកគេនឹងមិនមានលក្ខណៈ(អាក្រក់)ដូចពួកអ្នកឡើយ។

ជំពូក អាល់ហ្សាត់ហ៏

1. ពិតប្រាកដណាស់ យើងផ្តល់ឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវជ័យជម្នះមួយយ៉ាងច្បាស់លាស់។

2. ដើម្បីអល់ឡោះទ្រង់អភ័យទោសដល់អ្នកចំពោះបាបកម្មរបស់អ្នកដែលបានសាងពីមុន និងបាបកម្មដែលនៅខាងមុខ។ ហើយទ្រង់នឹងបំពេញឧបការគុណរបស់ទ្រង់ដល់អ្នក និងចង្អុលបង្ហាញអ្នកនូវមាគ៌ាដ៏ត្រឹមត្រូវ។

3. ហើយទ្រង់នឹងជួយដល់អ្នកនូវការជួយមួយដ៏រឹងមាំ។

4. ទ្រង់គឺជាអ្នកដែលបានបញ្ចុះនូវភាពនឹងនរទៅក្នុងដួងចិត្តរបស់បណ្តាអ្នកដែលមានជំនឿដើម្បីឱ្យពួកគេកាន់តែបន្ថែមនូវសេចក្តីជំនឿទៅលើសេចក្តីជំនឿរបស់ពួកគេថែមទៀត។ ហើយកងទ័ពទាំងឡាយដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយអល់ឡោះមហាដឹង មហាគតិបណ្ឌិត។

5. ដើម្បីទ្រង់នឹងបញ្ចូលបណ្តាអ្នកដែលមានជំនឿទាំងប្រុសទាំងស្រីទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅទីនោះជាអមតៈ។ ហើយទ្រង់នឹងលុបបំបាត់ពីពួកគេនូវអំពើអាក្រក់ទាំងឡាយរបស់ពួកគេ។ នោះហើយជាជោគជ័យដ៏ធំធេងបំផុតនៅឯអល់ឡោះជាម្ចាស់។

6. ហើយទ្រង់នឹងដាក់ទណ្ឌកម្មពួកពុតត្បុតទាំងប្រុសទាំងស្រី និងពួកដែលធ្វើស្តីរិកទាំងប្រុសទាំងស្រីដែលពួកគេគិតស្មានចំពោះអល់ឡោះនូវការគិតស្មានដ៏អាក្រក់។ ទណ្ឌកម្មដ៏អាក្រក់បានព័ទ្ធជុំវិញពួកគេ។ ហើយអល់ឡោះទ្រង់ខឹងសម្បាចំពោះពួកគេ ព្រមទាំងដាក់បណ្តាសាពួកគេ។ ហើយទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវនរកដើហាន់ណាំ ហើយវាគឺជាកន្លែងវិលត្រលប់ដ៏អាក្រក់បំផុត។

7. ហើយកងទ័ពទាំងឡាយដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហើយអល់ឡោះទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

8. ពិតប្រាកដណាស់ យើងបានតែងតាំងអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាអ្នកធ្វើសាក្សី និងជាអ្នកផ្តល់ដំណឹងរីករាយ ព្រមទាំងជាអ្នកដាស់តឿនព្រមាន។

9. ដើម្បីឲ្យពួកអ្នកមានជំនឿចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយជួយដល់(សាសនា)ទ្រង់ និងលើកតម្កើងទ្រង់ព្រមទាំងបញ្ជាក់ពីភាពបរិសុទ្ធចំពោះទ្រង់ ទាំងព្រឹកទាំងល្ងាច។

10. ពិតប្រាកដណាស់ បណ្តាអ្នកដែលបានធ្វើសច្ចាប្រណិធានជាមួយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) តាមពិតពួកគេបានធ្វើសច្ចាប្រណិធានជាមួយនឹងអល់ឡោះជាម្ចាស់។ ព្រះហស្តរបស់ទ្រង់នៅពីលើដៃរបស់ពួកគេ។ ដូច្នេះ ជនណាហើយដែលបានក្បត់ តាមពិតគេបានក្បត់លើខ្លួនឯងប៉ុណ្ណោះ។ ហើយជនណាដែលបានបំពេញតាមអ្វីដែលគេបានសន្យានឹងអល់ឡោះពិតប្រាកដណាស់ ទ្រង់នឹងប្រទានដល់គេនូវផលបុណ្យដ៏ធំធេង(ឋានសួគ៌)។

11. ពួកដែលមិនបានរួមដំណើរ(ទៅកាន់ទីក្រុងម៉ាក្កៈ)ក្នុងចំណោមពួកអារ៉ាប់ជនបទនឹងនិយាយទៅកាន់អ្នកថាៈ ទ្រព្យសម្បត្តិនិងក្រុមគ្រួសាររបស់ពួកយើងបានរំខានពួកយើង(មិនឱ្យរួមដំណើរជាមួយអ្នក)។ ហេតុនេះ សូមអ្នកសុំការអភ័យទោសពីអល់ឡោះដល់ពួកយើងផង។ ពួកគេនិយាយនឹងអណ្តាតរបស់ពួកគេនូវអ្វីដែលផ្ទុយពីដួងចិត្តរបស់ពួកគេ ។ ចូរអ្នកពោលចុះថាៈ តើមានអ្នកណាម្នាក់ដែលមានអំណាចអ្វីមួយអាចរារាំងពួកអ្នកពីអល់ឡោះ ប្រសិនបើទ្រង់មានចេតនាឱ្យពួកអ្នកទទួលគ្រោះ ឬមានចេតនាឲ្យពួកអ្នកទទួលបានប្រយោជន៍នោះ ? ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់មហាដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

12. ផ្ទុយទៅវិញ ពួកអ្នកគិតស្មានថា អ្នកនាំសារ(មូហាំម៉ាត់) និងបណ្តាអ្នកមានជំនឿនឹងមិនអាចរួចរួលត្រលប់ទៅកាន់ក្រុមគ្រួសារ របស់ពួកគាត់(នៅឯក្រុងម៉ាទីណៈ)វិញជាដាច់ខាត។ ហើយគេបានតុបតែងលម្អបែបនោះនៅក្នុងដួងចិត្តរបស់ពួកអ្នក ហើយពួកអ្នកគិតស្មាន(ចំពោះអល់ឡោះ)នូវការគិតស្មានដ៏អាក្រក់។ ហើយពួកអ្នកធ្លាប់ជាក្រុមមួយដែលអន្តរាយ។

13. ហើយជនណាដែលគ្មានជំនឿចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ពិតប្រាកដណាស់ យើងបានត្រៀមទុកសម្រាប់ ពួកដែលគ្មានជំនឿនូវភ្លើងនរកដែលឆេះសន្ធោសន្ធៅ។

14. ហើយការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ទ្រង់អភ័យទោសឲ្យចំពោះ ជនណាដែលទ្រង់មានចេតនា និងដាក់ទណ្ឌកម្មចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាម្ចាស់មហា អភ័យទោស មហាអាណិតស្រលាញ់។

15. ពួកដែលមិនបានរួមដំណើរ(ទៅកាន់ទីក្រុងម៉ាក្កៈ)ទាំងនោះ នៅពេលដែលពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ចេញដំណើរទៅ យកទ្រព្យជ័យកណ្តា(ដែលបានពីសមរភូមិខ័យពើរ) ពួកគេនឹងនិយាយថាៈ សូមទុកឱ្យពួកយើងទៅជាមួយពួកអ្នកផង។ ពួកទាំងនោះមានបំណងចង់ផ្លាស់ប្តូរការសន្យារបស់អល់ឡោះ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថាៈ ពួកអ្នក មិនអាចទៅជាមួយពួកយើងបានជាដាច់ខាត ពីព្រោះអល់ឡោះទ្រង់បានសន្យា(នឹងពួកយើង)កាលពីមុនរួចមកហើយ។ ពេលនោះ ពួកគេនឹងនិយាយថាៈ ផ្ទុយទៅវិញ គឺពួកអ្នកច្រណែនឈ្នានីសនឹងពួកយើងប៉ុណ្ណោះ។ ផ្ទុយទៅវិញ ពួកទាំងនោះ ទៅវិញទេដែលមិនយល់អ្វីឡើយ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

16. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលទៅកាន់ពួកដែលមិនបានចេញទៅប្រយុទ្ធក្នុងចំណោមពួកអារ៉ាប់ជនបទថាៈ ពួកអ្នក នឹងត្រូវគេអំពាវនាវទៅកាន់ក្រុមមួយដែលមានកម្លាំងខ្លាំងក្លាដោយពួកអ្នកត្រូវប្រយុទ្ធជាមួយពួកគេ ឬឱ្យពួកគេចូលអ៊ីស្លាម។ ហេតុនេះ ប្រសិនបើពួកអ្នកប្រតិបត្តិតាម នោះអល់ឡោះជាម្ចាស់នឹងប្រទានឲ្យពួកអ្នកនូវផលបុណ្យដ៏ប្រពៃ(ឋានសួគ៌)។ តែប្រសិនបើពួកអ្នកបែរចេញ ដូចដែលពួកអ្នកធ្លាប់បែរចេញ(មិនរួមដំណើរទៅកាន់ក្រុងម៉ាក្កៈ)កាលពីមុន ទ្រង់នឹងដាក់ ទណ្ឌកម្មពួកអ្នកនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

17. គ្មានទោសពៃអ៊ីឡើយចំពោះអ្នកពិការភ្នែក និងគ្មានទោសពៃអ៊ីឡើយចំពោះអ្នកពិការជើង ហើយក៏គ្មានទោសពៃអ៊ីដែរ ចំពោះអ្នកដែលមានជំងឺ(ប្រសិនបើពួកគេមិនបានចេញទៅប្រយុទ្ធនោះ)។ ហើយជនណាដែលគោរពប្រតិបត្តិតាម អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ នោះទ្រង់នឹងបញ្ចូលរូបគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា។ រីឯជនណាហើយដែលបែរចេញវិញនោះ ទ្រង់នឹងដាក់ទណ្ឌកម្មរូបគេនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

18. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានយល់ព្រម(ពេញចិត្ត)ចំពោះបណ្តាអ្នកដែលមានជំនឿ ខណៈដែលពួកគេ បានសច្ចាប្រណិធានជាមួយអ្នក(ឱព្យាការីមូហាំម៉ាត់)នៅក្រោមដើមឈើ។ ពិតណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅក្នុង ដួងចិត្តរបស់ពួកគេ។ ដូច្នេះ ទ្រង់ក៏បានបញ្ចុះភាពនឹងនរទៅលើពួកគេ និងបានតបស្នងដល់ពួកគេនូវជ័យជម្នះក្នុងពេលដ៏ ខ្លី(ខាងមុខ)

19. ព្រមទាំងទ្រព្យជ័យកណ្តាយ៉ាងច្រើនដែលពួកគេនឹងទទួលបានវា។ ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។

20. អល់ឡោះជាម្ចាស់ទ្រង់បានសន្យានឹងពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)នូវជ័យកណ្តាយ៉ាងច្រើនដែលពួកអ្នកនឹងទទួល បានវា ហើយទ្រង់បានប្រទានឱ្យពួកអ្នកភ្លាមៗនូវ(ជ័យកណ្តាខ័យពើរ)នេះ។ ហើយទ្រង់បានរារាំងដៃមនុស្សលោកមិនឲ្យ បង្កគ្រោះថ្នាក់ដល់ពួកអ្នក និងដើម្បីឱ្យវាក្លាយជាសញ្ញាកស្តុតាងមួយសម្រាប់បណ្តាអ្នកដែលមានជំនឿ។ ហើយទ្រង់នឹង ចង្អុលបង្ហាញពួកអ្នកនូវមាគ៌ាដ៏ត្រឹមត្រូវ

21. ព្រមទាំង(ជ័យកណ្ឌ)ផ្សេងទៀតដែលពួកអ្នកមិនទាន់មានលទ្ធភាពទៅលើវា តែអល់ឡោះទ្រង់ជ្រាបដឹងបំផុតចំពោះវា។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

22. ហើយប្រសិនបើពួកប្រឆាំងប្រយុទ្ធនឹងពួកអ្នក ពួកគេប្រាកដជានឹងរត់បកក្រោយវិញជាមិនខាន។ បន្ទាប់មក ពួកគេនឹងមិនមានអ្នកគាំពារឡើយ ហើយក៏មិនមានអ្នកជួយនោះដែរ។

23. វាជាមាគ៌ារបស់អល់ឡោះដែលបានកន្លងផុតទៅកាលពីមុនរួចមកហើយ។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នឹងមិនឃើញមាគ៌ារបស់អល់ឡោះមានការផ្លាស់ប្តូរឡើយ។

24. ហើយទ្រង់ជាអ្នកដែលបានរារាំងដៃពួកគេ(ពួកមុស្លីគីន)មិនឲ្យបង្កគ្រោះថ្នាក់ដល់ពួកអ្នក និងបានរារាំងដៃពួកអ្នក(អ្នកមានជំនឿ)មិនឲ្យបង្កគ្រោះថ្នាក់ដល់ពួកគេនៅកណ្តាលក្រុងម៉ាក្កៈវិញដែរ ក្រោយពីទ្រង់បានឲ្យពួកអ្នកមានលទ្ធភាពលើពួកគេ។ ហើយអល់ឡោះទ្រង់ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

25. ពួកគេ(ពួកមុស្លីគីន)គឺជាពួកដែលគ្មានជំនឿ និងបានរារាំងពួកអ្នកពីម៉ាស្ជិតអាល់ហារ៉ាម ព្រមទាំងបានឃាត់សត្វជំនូនមិនឲ្យទៅដល់កន្លែង(សំឡេះ)របស់វា។ ហើយប្រសិនបើគ្មានអ្នកដែលមានជំនឿប្រុសស្រី(ស្ថិតនៅលាយឡំជាមួយពួកគ្មានជំនឿ)ដែលពួកអ្នកមិនស្គាល់ពួកគេ ដោយពួកអ្នកអាចនឹងសម្លាប់ពួកគេ(រួមជាមួយពួកគ្មានជំនឿ)ដែលនាំឲ្យពួកអ្នកត្រូវទទួលបាបកម្មដោយពួកអ្នកមិនដឹងទេនោះ (ប្រាកដជាអល់ឡោះនឹងឲ្យពួកអ្នកគ្រប់គ្រងអំណាចលើពួកមុស្លីគីននៅពេលនោះជាមិនខាន) ដើម្បីទ្រង់នឹងបញ្ចូលជនណាដែលទ្រង់មានចេតនាទៅក្នុងក្តីមេត្តាករុណារបស់ទ្រង់។ ប្រសិនបើពួកអ្នកអាចបែងចែង(រវាងពួកគ្មានជំនឿ និងអ្នកមានជំនឿ)បាននោះ យើងប្រាកដជានឹងដាក់ទណ្ឌកម្មដល់ពួកដែលគ្មានជំនឿក្នុងចំណោមពួកគេនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុតជាមិនខាន។

26. នៅពេលដែលទ្រង់បានធ្វើឲ្យមាននៅក្នុងដួងចិត្តរបស់ពួកគ្មានជំនឿនូវភាពក្រអឺតក្រទមដែលជាភាពក្រអឺតក្រទមនៃសម័យកាលអវិជ្ជាពេលនោះ អល់ឡោះទ្រង់បានបញ្ចុះភាពនឹងនររបស់ទ្រង់ទៅលើអ្នកនាំសាររបស់ទ្រង់ និងទៅលើបណ្តាអ្នកដែលមានជំនឿ ព្រមទាំងបានឲ្យពួកគេប្រកាន់ខ្ជាប់នូវពាក្យកោតខ្លាច(គឺពាក្យ) ខណៈដែលពួកគេ គឺសក្តិសមនឹងពាក្យនេះ និងជាម្ចាស់នៃពាក្យនេះផងដែរ។ ហើយអល់ឡោះជាម្ចាស់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

27. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់បានធ្វើឱ្យសុបិនរបស់អ្នកនាំសាររបស់ទ្រង់ក្លាយជាការពិតដែលថា ពួកអ្នកពិតជានឹងបានចូលម៉ាស្ជិតអាល់ហារ៉ាម(ទឹកដីម៉ាក្កៈ)ដោយសុវត្ថិភាព ប្រសិនបើអល់ឡោះមានចេតនា ហើយបានកោរសក់ និងកាត់សក់របស់ពួកអ្នក ដោយគ្មានភ័យខ្លាចអ្វីឡើយ។ ហើយទ្រង់ដឹងបំផុតនូវអ្វីដែលពួកអ្នកមិនបានដឹង។ ដូច្នេះ ទ្រង់បានធ្វើឱ្យរឿងផ្សេងពីនោះកើតឡើយដោយការទទួលនូវជ័យជម្នះក្នុងពេលដ៏ខ្លីខាងមុខ។

28. ទ្រង់ជាអ្នកដែលបានបញ្ជូនអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ដោយនាំមកនូវការចង្អុលបង្ហាញ និងសាសនាដែលពិត(សាសនាអ៊ីស្លាម)ដើម្បីឱ្យសាសនានេះខ្ពង់ខ្ពស់លើសសាសនាផ្សេងទាំងអស់។ គ្រប់គ្រាន់ហើយដែលមានអល់ឡោះជាអ្នកធ្វើសាក្សីនោះ។

29. ព្យាការីមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ។ ហើយបណ្តាអ្នកដែលនៅជាមួយគាត់(សហាហ្គាត់) គឺពួកគេមានភាពតឹងរឹងទៅលើពួកគ្មានជំនឿ តែមានក្តីមេត្តាករុណារវាងអ្នកមានជំនឿដូចគ្នា។ អ្នកនឹងឃើញពួកគេឱនរុកុ និងក្រាបស៊ូជោតដោយប្រាថ្នាការប្រោសប្រទាន និងការពេញចិត្តពីអល់ឡោះ។ សញ្ញាសម្គាល់របស់ពួកគេ គឺមានស្លាកស្នាមស៊ូជោតនៅលើផ្ទៃមុខរបស់ពួកគេ។ នោះជាលក្ខណៈសម្បត្តិរបស់ពួកគេដែលមាននៅក្នុងគម្ពីរតាវ៉ាត។ រីឯលក្ខណៈសម្បត្តិរបស់ពួកគេដែលមាននៅក្នុងគម្ពីរអ៊ិញជីល គឺប្រៀបដូចជារុក្ខជាតិដែលបញ្ចេញនូវពន្លកបស់វា។ ក្រោយមក វាក៏រឹងមាំ និងធំឡើង ហើយក៏បានដុះត្រង់ឡើងនៅលើដើមរបស់វាដែលធ្វើឱ្យកសិករទាំងឡាយមានការពេញចិត្ត។ (ការប្រៀបធៀបដូច្នេះ) គឺដើម្បីឱ្យពួកគ្មានជំនឿមានការខឹងសម្បាចំពោះពួកគេ(សហាហ្គាត់)។ អល់ឡោះបានសន្យាចំពោះបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលក្នុងចំណោមពួកគេនូវការអភ័យទោស និងផលបុណ្យដ៏ធំធេង(ឋានសួគ៌)។

ជំពូក អាល់ហ៊ូជ្រាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំវិនិច្ឆ័យ(អ្វីមួយ)មុនអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ឲ្យសោះ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាដឹងបំផុត។

2. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំដំឡើងសំឡេងរបស់ពួកអ្នកខ្លាំងជាងសំឡេងរបស់ព្យាការី និងកុំហៅគាត់ខ្លាំងៗដូចពួកអ្នកហៅគ្នាឯងនោះឲ្យសោះ ខ្លាចក្រែងទង្វើកុសលរបស់ពួកអ្នកក្លាយជាអសារបង់ទាំងដែលពួកអ្នកមិនដឹងខ្លួន។

3. ពិតប្រាកដណាស់ បណ្តាអ្នកដែលបន្ថមសំឡេងរបស់ពួកគេនៅចំពោះមុខអ្នកនាំសាររបស់អល់ឡោះ អ្នកទាំងនោះហើយជាអ្នកដែលអល់ឡោះទ្រង់សាកល្បងចិត្តរបស់ពួកគេដើម្បីឱ្យពួកគេកោតខ្លាច(ទ្រង់)។ សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងផលបុណ្យដ៏ធំធេង។

4. ពិតប្រាកដណាស់ ពួកដែលស្រែកហៅអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពីក្រោយរបាំងនោះ ភាគច្រើននៃពួកគេមិនចេះគិតពិចារណាឡើយ។

5. ហើយប្រសិនបើពួកទាំងនោះអត់ធ្មត់ រហូតដល់អ្នកចេញមកជួបពួកគេ គឺពិតជាល្អប្រសើរសម្រាប់ពួកគេ។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

6. ឱបណ្តាអ្នកដែលមានជំនឿ! ប្រសិនបើមានអ្នកប្រព្រឹត្តល្មើសបាននាំដំណឹងអ្វីមួយមកប្រាប់ពួកអ្នក ចូរពួកអ្នកបញ្ជាក់ឱ្យបានច្បាស់ ខ្លាចក្រែងពួកអ្នកបង្កគ្រោះថ្នាក់ដល់ក្រុមមួយដោយគ្មានចំណេះដឹង ដែលជាហេតុធ្វើឲ្យពួកអ្នកមានវិប្បដិសារីចំពោះអ្វីដែលពួកអ្នកបានប្រព្រឹត្ត។

7. ហើយចូរពួកអ្នកដឹងចុះថា ជាការពិតណាស់ នៅក្នុងចំណោមពួកអ្នក គឺមានអ្នកនាំសាររបស់អល់ឡោះ។ ប្រសិនបើគាត់ធ្វើតាមពួកអ្នកក្នុងកិច្ចការជាច្រើន(ដែលពួកអ្នកផ្តល់ជាយោបល់)ប្រាកដជាពួកអ្នកនឹងមានការលំបាកជាមិនខាន។ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទ្រង់បានឱ្យសេចក្តីជំនឿជាទីស្រឡាញ់ពេញចិត្តចំពោះពួកអ្នក និងបានតុបតែងលម្អវានៅក្នុងដួងចិត្តរបស់ពួកអ្នក ហើយធ្វើឲ្យភាពគ្មានជំនឿ ការបំពាន និងការប្រព្រឹត្តល្មើសជាទីស្អប់ខ្ពើមចំពោះពួកអ្នក។ អ្នកទាំងនោះហើយជាអ្នកដែលទទួលបានការចង្អុលបង្ហាញ។

8. ជាការប្រោសប្រទាន និងជាឧបការគុណពីអល់ឡោះ(ចំពោះពួកគេ)។ ហើយអល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិត។

9. ប្រសិនបើមានពីរក្រុមក្នុងចំណោមអ្នកមានជំនឿប្រយុទ្ធគ្នា ចូរពួកអ្នកផ្សះផ្សារវាងពួកគេទាំងពីរ។ ហើយប្រសិនបើភាគីណាមួយក្នុងចំណោមភាគីទាំងពីរបានបំពានលើភាគីម្ខាងទៀត ចូរពួកអ្នកប្រយុទ្ធនឹងភាគីដែលបំពាននោះ រហូតទាល់តែពួកគេត្រឡប់ទៅរកច្បាប់របស់អល់ឡោះ។ នៅពេលដែលពួកគេបានត្រលប់(មករកច្បាប់របស់អល់ឡោះ)ហើយនោះចូរពួកអ្នកផ្សះផ្សារវាងភាគីទាំងពីរដោយយុត្តិធម៌។ ហើយចូរពួកអ្នកមានភាពយុត្តិធម៌។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បណ្តាអ្នកដែលប្រកាន់នូវភាពយុត្តិធម៌។

10. តាមពិត បណ្តាអ្នកដែលមានជំនឿ គឺជាបងប្អូននឹងគ្នា(ក្នុងសាសនា)។ ហេតុនេះ ចូរពួកអ្នកផ្សះផ្សារវាងបងប្អូនពួកអ្នក ចុះ។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ សង្ឃឹមថាពួកអ្នកនឹងត្រូវបានគេអាណិតស្រលាញ់។

11. ឱបណ្តាអ្នកដែលមានជំនឿ! ចូរកុំឱ្យក្រុមមួយមើលងាយក្រុមមួយទៀតឱ្យសោះ។ ជួនកាល ក្រុមដែលត្រូវគេមើលងាយ នោះល្អជាងក្រុមដែលមើលងាយគេទៅទៀត។ ហើយចូរកុំឱ្យស្ត្រីមើលងាយស្ត្រីដូចគ្នា។ ជួនកាល ស្ត្រីដែលត្រូវគេមើលងាយ នោះល្អជាងស្ត្រីដែលមើលងាយគេទៅទៀត។ ហើយចូរពួកអ្នកកុំបង្កាប់គ្នា និងកុំដាក់ងារឱ្យគ្នាឱ្យសោះ។ ការប្រព្រឹត្តល្មើស ក្រោយពីមានជំនឿរួចហើយនោះ គឺជាលក្ខណៈដ៏អាក្រក់បំផុត។ ហើយជនណាដែលមិនបានសារភាពកំហុសទេនោះ ពួកទាំងនោះហើយ គឺជាពួកដែលបំពាន។

12. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកចៀសវាងពីការសង្ស័យច្រើន។ ពិតណាស់ ការសង្ស័យមួយចំនួន គឺជាបាបកម្ម។ ហើយចូរពួកអ្នកកុំស៊ើប(រឿងសម្ងាត់អ្នកដទៃ) និងកុំនិយាយដើមគ្នាទៅវិញទៅមកឱ្យសោះ។ តើនរណាម្នាក់នៃពួកអ្នក ពេញចិត្តនឹងស៊ីសាច់បងប្អូនរបស់ខ្លួនដែលស្លាប់ទៅហើយនោះ? ពិតណាស់ ពួកអ្នកពិតជាស្អប់ខ្ពើមវា។ ហើយចូរពួកអ្នក កោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាអ្នកទទួលនូវការសារភាពកំហុស មហាអាណិតស្រលាញ់បំផុត។

13. ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរសម្នាក់(ព្យាការីអាហ្តាំ) និងស្ត្រីម្នាក់(ហាវ៉ា)។ ហើយយើងបានធ្វើឱ្យពួកអ្នកមានជាជនជាតិនិងកុលសម្ព័ន្ធជាច្រើនដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដ ណាស់ អ្នកដែលថ្កុំថ្កើងជាងគេនៅចំពោះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាច(អល់ឡោះ)ជាងគេ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាជ្រួតជ្រាបបំផុត។

14. ពួកអារ៉ាប់ជនបទបាននិយាយថា៖ ពួកយើងមានជំនឿហើយ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ពួកអ្នក មិនទាន់មានជំនឿឡើយ ប៉ុន្តែ ចូរពួកអ្នកនិយាយថា៖ ពួកយើងបានប្រគល់ខ្លួន(ជាជនមូស្លីម)ហើយ ខណៈដែលសេចក្តី ជំនឿមិនទាន់ចូលទៅក្នុងដួងចិត្តរបស់ពួកអ្នកទេនោះ។ ហើយប្រសិនបើពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសារ របស់ទ្រង់ នោះទ្រង់នឹងមិនធ្វើឱ្យ(ផលបុណ្យនៃ)ទង្វើកុសលរបស់ពួកអ្នកបាត់បង់បន្តិចណាឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

15. តាមពិត បណ្តាអ្នកដែលមានជំនឿ គឺអ្នកដែលមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ បន្ទាប់មក ពួកគេគ្មាន ការមន្ទិលសង្ស័យឡើយ ហើយពួកគេបានតស៊ូដោយទ្រព្យសម្បត្តិរបស់ពួកគេ និងខ្លួនប្រាណរបស់ពួកគេក្នុងមាគ៌ារបស់ អល់ឡោះ។ អ្នកទាំងនោះហើយ គឺជាអ្នកដែលមានជំនឿយ៉ាងពិតប្រាកដ។

16. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តើពួកអ្នកកំពុងប្រាប់អល់ឡោះឱ្យទ្រង់ដឹងពីសាសនារបស់ពួកអ្នកឬ ខណៈ ដែលអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីដែលនៅលើផែនដីនោះ? ហើយអល់ឡោះ មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

17. ពួក(អារ៉ាប់ជនបទ)ទាំងនោះគិតថា ពួកគេមានគុណបំណាច់មកលើអ្នកចំពោះការចូលអ៊ីស្លាមរបស់ពួកគេ។ ចូរអ្នកតប វិញចុះថា៖ ពួកអ្នកពុំមានគុណបំណាច់អ្វីមកលើខ្ញុំចំពោះការចូលអ៊ីស្លាមរបស់ពួកអ្នកនោះឡើយ។ ផ្ទុយទៅវិញ អល់ឡោះ ជាម្ចាស់ទៅវិញទេដែលមានគុណបំណាច់លើពួកអ្នក ដោយទ្រង់បានចង្អុលបង្ហាញពួកអ្នកឱ្យមានជំនឿ ប្រសិនបើពួកអ្នក ជាអ្នកទៀងត្រង់មែននោះ។

18. ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ដឹងបំផុតនូវអាថ៌កំបាំងនៃមេឃជាច្រើនជាន់និងផែនដី។ ហើយអល់ឡោះមហា ឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

ជំពូក កហ្វ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. កហ្វ (គួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ (អល់ឡោះ)ស្បថនឹងគម្ពីរគួរអានដ៏ថ្កុំថ្កើន។

2. ផ្ទុយទៅវិញ ពួកគេភ្ញាក់ផ្អើលដែលអ្នកដាស់តឿនព្រមានម្នាក់ក្នុងចំណោមពួកគេបានមកដល់ពួកគេ។ ហើយពួកគ្មានជំនឿបាននិយាយថា៖ នេះគឺជារឿងមួយដ៏ចម្លែក។

3. តើនៅពេលដែលពួកយើងបានស្លាប់ និងបានក្លាយជាដីអស់នោះ (តើពួកយើងត្រូវបានគេបង្កើតឲ្យរស់ឡើងវិញម្តងទៀតឬ)? នោះគឺជាការវិលត្រឡប់មួយដ៏សែនឆ្ងាយ(មិនអាចទៅរួចឡើយ)។

4. ពិតប្រាកដណាស់ យើង(អល់ឡោះ)ដឹងបំផុតនូវអ្វីដែលដីបានស៊ីអំពី(រាងកាយ)ពួកគេ។ ហើយនៅជាមួយយើង គឺមានសៀវភៅកំណត់ត្រាដែលត្រូវបានរក្សាទុក។

5. ផ្ទុយទៅវិញ ពួកគេ(ពួកមុស្លីគីន)បានបដិសេធនឹងសេចក្តីពិត(គម្ពីរគួរអាន)នៅពេលដែលគម្ពីរនេះបានមកដល់ពួកគេ។ ហើយពួកគេស្ថិតក្នុងភាពមិនច្បាស់លាស់។

6. តើពួកទាំងនោះមិនបានមើលទៅកាន់មេឃដែលនៅពីលើពួកគេទេឬ ថាតើយើងបានសាងសង់វា និងបានតុបតែងលម្អវាព្រមទាំងគ្មានការប្រេះស្រាំអ្វីសោះយ៉ាងដូចម្តេច?

7. ចំណែកឯផែនដី យើងបានលាតសន្ធឹងវា និងបានបង្កើតភ្នំជាច្រើននៅលើវា(ជាលំនឹង) ព្រមទាំងបានបណ្តុះនូវគ្រប់ជាតិគ្រប់ប្រភេទនៅលើវាយ៉ាងស្រស់បំព្រង

8. ដើម្បីឲ្យ(ពួកអ្នក)ឃើញច្បាស់ និងជាការរំឭកចំពោះរាល់ខ្ញុំបម្រើរបស់អល់ឡោះដែលវិលត្រឡប់ទៅរកទ្រង់។

9. ហើយយើងបានបញ្ចុះពីលើមេឃនូវទឹក(ភ្លៀង)ដែលប្រកបដោយពរជ័យ។ ហើយតាមរយៈទឹកភ្លៀងនេះ យើងបានបណ្តុះចេញនូវចម្ការដំណាំជាច្រើន និងគ្រាប់ធញ្ញជាតិដែលអាចច្រូតកាត់បាន

10. ព្រមទាំងល្មើដែលមានដើមដ៏ខ្ពស់មានចង្កោមផ្លែស្រោក់លើគ្នា

11. ដើម្បីជាលាភសក្ការៈសម្រាប់ខ្ញុំបម្រើ(របស់អល់ឡោះ)។ ហើយតាមរយៈទឹកភ្លៀងនោះផងដែរ យើងបានធ្វើឱ្យដីដែលស្ងួតហួតហែងមានជីវិតឡើងវិញ។ ក៏ដូចគ្នាដែរ ការបញ្ចេញ(ពួកអ្នកពីផ្នូរ)មកវិញ។

12. (អ្នកជំនាន់មុនពួកមុស្លីគីន)បានបដិសេធមុនពួកគេទៅទៀត (ដូចជា)ក្រុមរបស់ព្យាការីនួហ ពួករ៉ែស និងពួកសាមូទ

13. ហើយនិងក្រុមអាទ ហ្វៀរអោន ក្រុមរបស់ព្យាការីលូត

14. ក្រុមអែកៈព្រមទាំងពួកទុបហ្គាក់។ រាល់ក្រុមទាំងអស់នោះសុទ្ធតែបានបដិសេធនឹងអ្នកនាំសារទាំងឡាយ(របស់អល់ឡោះ)។ ដូច្នេះ ការសន្យា(ចំពោះពួកគេ)ក៏បានកើតឡើងពិតប្រាកដ។

15. តើយើងអសមត្ថភាពក្នុងការបង្កើតភាវៈទាំងឡាយពីដំបូងឬ? ផ្ទុយទៅវិញ ពួកគេគឺស្ថិតក្នុងភាពមន្ទិលសង្ស័យចំពោះការបង្កើតសារជាថ្មី។

16. ហើយជាការពិតណាស់ យើងបានបង្កើតមនុស្សលោក ហើយយើងដឹងច្បាស់នូវអ្វីដែលចិត្តគំនិតរបស់គេសញ្ជឹងគិតអំពីវា។ ហើយយើងនៅជិតខ្លួនគេជាងសរសៃកដែលតភ្ជាប់ទៅនឹងបេះដូងទៅទៀត។

17. ខណៈដែលម៉ាឡាអ៊ីកាត់ពីររូបអង្គុយនៅខាងស្តាំ និងខាងឆ្វេងចាំកត់ត្រា(ទង្វើរបស់គេ)។

18. រាល់ពាក្យសម្តីដែលគេនិយាយចេញមក គឺសុទ្ធតែមានអ្នកឃ្លាំមើល និងកត់ត្រាដែលនៅជាមួយគេជានិច្ច។

19. ហើយភាពឈឺចាប់នៃសេចក្តីស្លាប់បានមកដល់យ៉ាងពិតប្រាកដ។ នោះហើយជាអ្វីដែលអ្នក(មនុស្សលោក)ធ្លាប់បានរត់គេចអំពីវា។

20. ហើយគេបានផ្លុំត្រែ(ជាលើកទីពីរ)។ នោះហើយជាថ្ងៃនៃការសន្យា(ដាក់ទណ្ឌកម្មពួកគ្មានជំនឿ)។

21. ហើយបុគ្គលគ្រប់ៗរូបបានមកដល់ដោយនៅជាមួយគេ គឺមានអ្នកនាំផ្លូវ និងអ្នកធ្វើសាក្សី។

22. ពិតប្រាកដណាស់ អ្នកធ្លាប់ព្រងើយកន្តើយចំពោះរឿងនេះ។ ដូច្នេះ យើងបានបើកចេញនូវគម្រប(ដែលគ្របចិត្ត)របស់អ្នកចេញពីអ្នក។ ហេតុដូច្នេះ ការឃើញរបស់អ្នកនៅថ្ងៃនេះ គឺច្បាស់បំផុត។

23. ហើយម៉ាឡាអ៊ីកាត់ដែលកត់ត្រាទង្វើរបស់គេបាននិយាយថា៖ អ្វីដែលមាននៅជាមួយខ្ញុំនេះ គឺជាកំណត់ត្រាទង្វើដែលបានត្រៀមទុកជាស្រេច។

24. (អល់ឡោះបានមានបន្ទូលថា៖) ចូរអ្នកទាំងពីរបោះទៅក្នុងនរកដើហាន់ណាំនូវរាល់ពួកដែលប្រឆាំង ចចេសរឹងរូសចុះ។

25. ជាពួកដែលច្រើនតែរារាំងនូវប្រការល្អ ជាអ្នកដែលបំពាន និងជាអ្នកដែលមានការមន្ទិលសង្ស័យ។

26. គឺអ្នកដែលបានយកព្រះផ្សេងមកគោរពសក្ការៈរួមនឹងអល់ឡោះជាម្ចាស់។ ហេតុនេះ ចូរអ្នកទាំងពីរបោះគេទៅក្នុងទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតចុះ។

27. (ស្ហៃតនដែលជា)គូកនរបស់គេបាននិយាយថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ខ្ញុំមិនបានធ្វើឱ្យរូបគេវង្វេងនោះទេ ក៏ប៉ុន្តែរូបគេខ្លួនឯងទេដែលធ្លាប់ស្ថិតក្នុងភាពវង្វេងដ៏សែនឆ្ងាយនោះ។

28. ទ្រង់បានមានបន្ទូលថា៖ ចូរពួកឯងកុំមកឈ្លោះប្រកែកគ្នានៅចំពោះមុខយើងឱ្យសោះ។ ជាការពិតណាស់ យើងបានផ្តល់ការព្រមានដល់ពួកឯងរួចទៅហើយ(ក្នុងលោកិយ)។

29. បន្ទូលរបស់យើងមិនអាចគេកែប្រែបានឡើយ ហើយយើងក៏មិនមែនជាអ្នកដែលបំពានទៅលើខ្ញុំបម្រើទាំងឡាយ(របស់យើង)នោះដែរ។

30. (ចូរអ្នករំលឹកដល់ក្រុមរបស់អ្នក)នៅថ្ងៃដែលយើងនឹងសួរទៅកាន់នរកដើហាន់ណាំថា៖ តើឯងពេញហើយឬនៅ? វាឆ្លើយថា៖ តើមានបន្ថែមទៀតទេ?

កឃ

31. ហើយឋានសួគ៌ត្រូវបានគេដាក់ឱ្យនៅជិតបណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)ដោយវានៅមិនឆ្ងាយ(ពីពួកគេ)ឡើយ។

32. (មានគេនិយាយទៅកាន់ពួកគេថា៖) នេះហើយជាអ្វីដែលគេបានសន្យានឹងពួកអ្នក សម្រាប់រាល់អ្នកដែលវិលត្រឡប់(សារភាពកំហុស)និងអ្នកដែលថែរក្សា(នូវអ្វីដែលគេបានដាក់ជាកាតព្វកិច្ច)។

33. គឺអ្នកដែលខ្លាចព្រះជាម្ចាស់ដ៏មហាសប្បុរសដោយអាថ៌កំបាំង ហើយគេបានមកដល់(ថ្ងៃបរលោក)ដោយដួងចិត្តដែលសារភាពកំហុស។

34. (មានគេនិយាយទៅកាន់ពួកគេថា៖) សូមពួកអ្នកចូលទៅក្នុងឋានសួគ៌ដោយសុខសន្តិភាពចុះ។ នោះគឺជាថ្ងៃដែលអមតៈ។

35. នៅក្នុងនោះ ពួកគេទទួលបានតាមអ្វីដែលពួកគេប្រាថ្នា។ ហើយយើងនៅមានការបន្ថែម(លើសពីនោះ)ទៀត។

36. ហើយមានប្រជាជាតិជាច្រើនមកហើយមុនពួកគេ(ពួកមុស្លីគីន)ដែលយើងបានបំផ្លាញ ដែលពួកទាំងនោះជាពួកដែលមានភាពខ្លាំងក្លាជាងពួកគេទៅទៀត។ ហើយពួកគេបានធ្វើដំណើរក្នុងទឹកដី(របស់ខ្លួនដើម្បីគេចពីការបំផ្លាញ)។ តើពួកគេមានកន្លែងរត់គេចដែរឬទេ?

37. ប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាការដាស់រឭកសម្រាប់អ្នកដែលមានដួងចិត្ត(ចេះគិតពិចារណា) ឬនៅស្ងៀមស្ងាប់ដោយចិត្តទុកដាក់បំផុត។

38. ហើយជាការពិតណាស់ យើងបានបង្កើតមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលនៅចន្លោះរវាងវាទាំងពីរក្នុងរយៈពេលប្រាំមួយថ្ងៃ ហើយយើងគ្មានការនឿយហត់ឡើយ។

39. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះចំពោះអ្វីដែលពួកគេនិយាយ។ ហើយចូរអ្នកលើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់អ្នកមុនពេលថ្ងៃរះ និងមុនពេលថ្ងៃលិច។

40. ហើយមួយផ្នែកនៃពេលយប់ ចូរអ្នកប្រតិបត្តិសឡាត និង(លើកតម្កើងទ្រង់)ក្រោយពេលប្រតិបត្តិសឡាតរួច។

41. ហើយចូរអ្នកស្តាប់(ឱអ្នកនាំសារមូហាំម៉ាត់)នៅថ្ងៃដែលអ្នកទទួលបន្ទុកខាងផ្លុំត្រែបានផ្លុំត្រែ(ជាលើកទីពីរ)ចេញពីកន្លែងដែលជិតបំផុត

42. ជាថ្ងៃដែលពួកគេបានឮសម្រែកយ៉ាងពិតប្រាកដ។ នោះគឺជាថ្ងៃក្រោកចេញ(ពីផ្នូររបស់ពួកគេ)។

43. ពិតណាស់ យើងជាអ្នកផ្តល់ជីវិត និងជាអ្នកដកយកជីវិត។ ហើយកន្លែងវិលត្រឡប់ គឺឆ្ពោះមកកាន់យើង(តែមួយគត់)។

44. នៅថ្ងៃដែលដីបានបែកចេញពីពួកគេ(ដោយពួកគេបានក្រោកចេញពីផ្នូរ)យ៉ាងលឿន។ ហើយការប្រមូលផ្តុំ(ពួកគេ)នោះគឺជារឿងងាយស្រួលបំផុតសម្រាប់យើង។

45. យើងដឹងបំផុតនូវអ្វីដែលពួកគេនិយាយ។ ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនមែនជាអ្នកដែលអាចបង្ខំពួកគេ(ឱ្យមានជំនឿ)នោះឡើយ។ ដូច្នេះ ចូរអ្នករំលឹកតាមរយៈគម្ពីរគួរអានចំពោះអ្នកដែលខ្លាចការព្រមាន(របស់យើង)ចុះ។

ជំពូក អាល់ហ្សឺរីយ៉ាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងខ្យល់ដែលបក់បោកល្អងធូលី។

2. (ទ្រង់)ស្បថនឹងពពកដែលនាំទឹកភ្លៀងដ៏ច្រើន។

3. (ទ្រង់)ស្បថនឹងសំពៅដែលធ្វើដំណើរដោយភាពងាយស្រួល។

4. (ទ្រង់)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលបែងចែកកិច្ចការទាំងឡាយ។

5. ពិតប្រាកដណាស់ អ្វីដែលគេបានសន្យានឹងពួកអ្នក គឺជាការពិត។

6. ហើយការជំនុំជម្រះ គឺនឹងកើតឡើងយ៉ាងពិតប្រាកដ។

7. (ទ្រង់)ស្បថនឹងមេឃដែលមានភាពស្រស់ស្អាត។

8. ជាការពិតណាស់ ពួកអ្នកស្ថិតនៅលើពាក្យសម្តីខុសៗគ្នា(ចំពោះគម្ពីរគួរអាន និងព្យាការីមូហាំម៉ាត់)។

9. គេបង្វែរចេញអំពីវានូវដែនដែលត្រូវបានគេបង្វែរចេញ(ពីការមានជំនឿ)។

10. ពួកដែលភូតកុហកត្រូវបានគេដាក់បណ្តាសា។

11. គឺពួកដែលស្ថិតក្នុងភាពគ្មានជំនឿ ជាអ្នកដែលព្រងើយកន្តើយ។

12. ពួកគេសួរថា៖ តើថ្ងៃជំនុំជម្រះនឹងកើតឡើងនៅពេលណា?

13. គឺនៅថ្ងៃដែលពួកគេត្រូវបានគេដាក់ទណ្ឌកម្មនៅលើភ្លើងនរក។

14. (មានគេនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នកភ្លក់ទណ្ឌកម្មរបស់ពួកអ្នកចុះ។ នេះហើយជាអ្វីដែលពួកអ្នកធ្លាប់សុំឱ្យវាធ្លាប់មកដល់នោះ។

15. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ពួកគេស្ថិតក្នុងឋានសួគ៌ និងប្រភពទឹកជាច្រើន។

16. ពួកគេទទួលយកនូវអ្វីដែលព្រះជាម្ចាស់របស់ពួកគេបានប្រទានឱ្យពួកគេ។ ពិតប្រាកដណាស់ កាលពីមុននោះ ពួកគេធ្លាប់ជាអ្នកដែលសាងអំពើល្អ។

17. ពួកគេធ្លាប់គេងយប់តិចតួចប៉ុណ្ណោះ។

18. ហើយនៅពេលទៀបភ្លឺ(មុនហ្វាជើរ:) ពួកគេសុំការអភ័យទោស(ពីអល់ឡោះ)។

19. ហើយចំពោះទ្រព្យសម្បត្តិរបស់ពួកគេវិញ គឺមានចំណែកសម្រាប់អ្នកសុំទាន និងអ្នកក្រដែលមិនហ៊ានសុំ។

20. ហើយចំពោះផែនដី គឺជាសញ្ញាកស្តតាងសម្រាប់បណ្តាអ្នកដែលជឿជាក់។

21. និងនៅក្នុងខ្លួនរបស់ពួកអ្នក(ក៏ដូចគ្នាដែរ)។ ដូច្នេះ តើពួកអ្នកមិនឃើញទេឬ?

22. ចំណែកឯនៅលើមេឃ គឺមានលាភសក្ការៈរបស់ពួកអ្នក និងអ្វីដែលគេបានសន្យាចំពោះពួកអ្នក។

23. ទ្រង់បានស្បថនឹងខ្លួនទ្រង់ដែលជាព្រះជាម្ចាស់នៃមេឃនិងផែនដីថា៖ ជាការពិតណាស់ វា(ការសន្យានោះ) គឺជាការពិតដូចជាការដែលពួកអ្នកនិយាយនោះដែរ។

24. តើរឿងរ៉ាវនៃភ្ញៀវរបស់ព្យាការីអ៊ីព្រហ៊ីមដែលត្រូវបានគេលើកតម្កើងនោះ បានមកដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែរឬទេ?

25. ខណៈដែលពួកគេបានចូលទៅជួបគាត់ ពេលនោះពួកគេបាននិយាយថា៖ សូមសន្តិភាព(កើតមានដល់អ្នក)។ គាត់បានតបវិញថា៖ សូមសន្តិភាព(កើតមានដល់ពួកអ្នកដូចគ្នា)។ (ពួកអ្នកជា)ក្រុមដែលគេមិនស្គាល់។

26. ក្រោយមក គាត់ក៏បានដើរទៅកាន់ក្រុមគ្រួសាររបស់គាត់យ៉ាងស្ងៀមស្ងាត់ រួចគាត់បាននាំមកនូវកូនគោ(អាំង)ដ៏ធាត់មួយក្បាល(មកទទួលពួកគេ)។

27. ហើយគាត់បានដាក់វាជិតពួកគេ។ គាត់បាននិយាយថា៖ តើពួកអ្នកមិនទទួលទានទេឬ?

28. (ពេលដែលពួកគេមិនទទួលទាន) គាត់ក៏មានអារម្មណ៍ភ័យខ្លាចអំពីពួកគេ។ ពួកគេក៏និយាយថា៖ "សូមអ្នកកុំខ្លាច"។ ហើយពួកគេបានផ្តល់ដំណឹងរីករាយដល់គាត់នូវកូនប្រុសម្នាក់ដែលពោរពេញដោយចំណេះដឹង។

29. ពេលនោះ ភរិយារបស់គាត់(នាងសារ៉ោ:)បានចេញមកហើយស្រែក(ដោយក្តីរីករាយ)និងបានទះមុខខ្លួនឯង ហើយនាងបាននិយាយថា៖ ស្ត្រីចំណាស់ម្នាក់ដែលអារ(តើអាចមានកូនដែរឬ)?

30. ពួកគេ(ម៉ាឡាអ៊ីកាត់)ក៏បានតបថា៖ ដូច្នោះឯងដែលព្រះជាម្ចាស់របស់អ្នកបានមានបន្ទូល។ ជាការពិតណាស់ ទ្រង់មហាគតិបណ្ឌិត មហាដឹងបំផុត។

31. គាត់(ព្យាការីអ៊ីព្រហ៊ីម)បានសួរថា៖ តើអ្វីទៅជាភារកិច្ចរបស់ពួកអ្នក ឱអ្នកនាំសារទាំងឡាយ?

32. ពួកគេបានតបថា៖ ពិតប្រាកដណាស់ ពួកយើងត្រូវបានគេបញ្ជូនទៅកាន់ក្រុមឧក្រិដ្ឋជន(ក្រុមព្យាការីលូត)

33. ដើម្បីនាំដុំថ្មពីដីឥដ្ឋទម្លាក់លើពួកគេ

34. ដែលវាជាសញ្ញាមួយពីព្រះជាម្ចាស់របស់អ្នកចំពោះពួកដែលបំពាន។

35. ហើយយើងបានបញ្ចេញបណ្តាអ្នកមានជំនឿដែលរស់នៅក្នុងភូមិស្រុក(របស់ព្យាការីលូត)នោះ។

36. ហេតុនេះ យើងមិនបានឃើញនៅទីនោះក្រៅតែពីផ្ទះមួយនៅក្នុងចំណោមបណ្តាអ្នកមូស្លីមប៉ុណ្ណោះ។

37. ហើយយើងបានបន្សល់ទុកនៅក្នុងភូមិស្រុកនោះនូវសញ្ញាកស្តុតាងមួយសម្រាប់អ្នកដែលខ្លាចទណ្ឌកម្មដ៏ឈឺចាប់។

38. ហើយនៅក្នុងរឿងរ៉ាវរបស់ព្យាការីមូសា នៅពេលដែលយើងបានបញ្ជូនគេទៅកាន់ហ្វៀរអោនដោយនាំនូវអច្ឆរិយភាពជាច្រើនដ៏ច្បាស់លាស់នោះ (ក៏ជាសញ្ញាកស្តុតាងមួយផងដែរ)។

39. ក៏ប៉ុន្តែ ហ្វៀរអោនបានគេចចេញដោយ(ភាពក្អេងក្អាងនឹង)អំណាចរបស់ខ្លួន ហើយគេបាននិយាយថា៖ (ព្យាការីមូសា) ជាគ្រូមន្តអាគម ឬជាមនុស្សវិកលចរិត។

40. ដូច្នេះយើងបានដាក់ទណ្ឌកម្មគេ(ហ្វៀរអោន)និងកងទ័ពរបស់គេដោយយើងបានបោះពួកគេចូលទៅក្នុងសមុទ្រ ខណៈដែលរូបគេ ជាជនដែលត្រូវបានគេស្តីបន្ទោស។

41. ហើយនៅក្នុងរឿងរ៉ាវរបស់ក្រុមអាទ (ក៏ជាសញ្ញាកស្តុតាងមួយដែរ) ខណៈដែលយើងបានបញ្ជូនខ្យល់ព្យុះទៅកាន់ពួកគេ។

42. រាល់អ្វីក៏ដោយដែលខ្យល់នេះបោកបក់ត្រូវ គឺសុទ្ធតែត្រូវបានវាបំផ្លាញប្រៀបដូចជាផេះផង់។

43. ហើយនៅក្នុងរឿងរ៉ាវរបស់ពួកសាមូទ(ក៏ជាភស្តុតាងមួយផងដែរ) នៅពេលដែលគេបាននិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកសោយសុខ(មួយរយៈពេលខ្លី)សិនចុះ រហូតដល់ពេលវេលាដែលបានកំណត់។

44. ហើយពួកគេបានក្អេងក្អាងចំពោះបទបញ្ជានៃព្រះជាម្ចាស់របស់ពួកគេ។ ពេលនោះ រន្ទះក៏បានឆក់យកជីវិតពួកគេ ខណៈដែលពួកគេកំពុងតែសម្លឹងមើល។

45. នៅពេលនោះ ពួកគេគ្មានសមត្ថភាព(រត់គេចពីទណ្ឌកម្ម)នោះឡើយ ហើយពួកគេក៏មិនអាចជួយ(ខ្លួនឯង)បាននោះដែរ។

46. ហើយ(យើងបានបំផ្លាញ)ក្រុមរបស់ព្យាការីនួហមុន(ពួកគេ)។ ពិតប្រាកដណាស់ ពួកគេគ្លាប់ជាក្រុមដែលប្រព្រឹត្តល្មើស។

47. ហើយចំពោះមេឃ យើងបានបង្កើតវាដោយអានុភាពរបស់យើង ហើយពិតប្រាកដណាស់ យើងគឺជាអ្នកធ្វើឲ្យវាមានភាពធំទូលាយ។

48. ហើយចំពោះផែនដី យើងបានលាតសន្ធឹងវា ហើយយើងជាអ្នកលាតសន្ធឹងវាយ៉ាងល្អបំផុត។

49. ហើយរាល់អ្វីៗទាំងអស់ យើងបានបង្កើតវាជាគូៗ សង្ឃឹមថាពួកអ្នកនឹងនឹកឃើញ។

50. ដូច្នេះ ចូរពួកអ្នករត់គេចទៅកាន់អល់ឡោះចុះ។ ប្រាកដណាស់ ខ្ញុំគឺជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់ម្នាក់អំពីទ្រង់សម្រាប់ពួកអ្នក។

51. ហើយចូរពួកអ្នកកុំបង្កើតព្រះផ្សេង(មកគោរពសក្ការៈ)រួមជាមួយនឹងអល់ឡោះឱ្យសោះ។ ពិតប្រាកដណាស់ ខ្ញុំគឺជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់ម្នាក់អំពីទ្រង់សម្រាប់ពួកអ្នក។

52. ក៏ដូចគ្នាដែរ គ្មានអ្នកនាំសារណាម្នាក់បានមកដល់អ្នកជំនាន់មុនពួកគេឡើយ លើកលែងតែពួកទាំងនោះនិយាយថា៖(រូបគេ)ជាគ្រូមន្តអាគម ឬជាមនុស្សវិកលចរិត។

53. តើពួកគេបានផ្តាំផ្ញើគ្នាឲ្យបដិសេធនឹងអ្នកនាំសារទាំងឡាយឬ? ផ្ទុយទៅវិញ ពួកគេគឺជាក្រុមដែលបំពាន។

54. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បែរចេញពីពួកគេចុះ។ ពិតប្រាកដណាស់ អ្នកមិនត្រូវបានគេស្តីបន្ទោសឡើយ។

55. ហើយចូរអ្នកដាស់រំឭក ព្រោះការដាស់រំឭក គឺផ្តល់ផលប្រយោជន៍ដល់បណ្តាអ្នកដែលមានជំនឿ។

56. ហើយយើងមិនបានបង្កើតជិននិងមនុស្សលោកនោះឡើយ លើកលែងដើម្បីឱ្យពួកគេគោរពសក្ការៈ(មកចំពោះយើងតែមួយគត់)ប៉ុណ្ណោះ។

57. យើងមិនត្រូវការលាភសក្ការៈពីពួកគេឡើយ ហើយយើងក៏មិនត្រូវការឱ្យពួកគេផ្តល់អាហារ(ដល់យើង)នោះដែរ។

58. ប្រាកដណាស់ អល់ឡោះទ្រង់ជាអ្នកដែលប្រទានលាភសក្ការៈ ជាអ្នកដែលមានអានុភាពខ្លាំងក្លាបំផុត។

59. ពិតប្រាកដណាស់ សម្រាប់ពួកដែលបំពាន ពួកគេនឹងទទួលបានចំណែក(នៃទណ្ឌកម្ម)ដូចជាក្រុមជំនាន់មុនពួកគេដូច្នោះដែរ។ ហេតុនេះ ចូរពួកគេកុំសុំឲ្យ(ទណ្ឌកម្ម)ឆាប់មកដល់។

60. ដូច្នេះ ភាពវិនាសអន្តរាយ គឺសម្រាប់ពួកដែលគ្មានជំនឿនៅថ្ងៃដែលពួកគេត្រូវបានសន្យា(ថ្ងៃបរលោក)។

ដំពូក អាត់តួរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងភ្នំតួរ។

2. (ទ្រង់)ស្បថនឹងគម្ពីរ(គួរអាន)ដែលត្រូវបានគេកត់ត្រា

3. នៅក្នុងក្រដាសដែលត្រូវបានគេលាតត្រដាង។

4. (ទ្រង់)ស្បថនឹងពែតុលម៉ាក់មួរ ។

5. (ទ្រង់)ស្បថនឹងដំបូល(មេឃ)ដែលត្រូវបានគេលើកយ៉ាងខ្ពស់។

6. (ទ្រង់)ស្បថនឹងសមុទ្រដែលពោរពេញទៅដោយទឹក។

7. ពិតប្រាកដណាស់ ទណ្ឌកម្មនៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិតជានឹងកើតឡើងយ៉ាងពិតប្រាកដ។

8. គ្មាននរណាម្នាក់អាចរារាំងវាបានឡើយ។

9. នៅថ្ងៃដែលមេឃរង្គោះរង្គើ

10. ហើយភ្នំទាំងឡាយបានរសាត់(ចេញពីទីតាំងរបស់វា)។

11. ពិតប្រាកដណាស់ ភាពវិនាសអន្តរាយ គឺសម្រាប់ពួកដែលបដិសេធ។

12. គឺពួកដែលលេងសើចនឹងប្រការដែលមិនត្រឹមត្រូវ។

13. នៅថ្ងៃដែលពួកគេត្រូវបានគេរុញច្រានយ៉ាងខ្លាំងទៅកាន់នរកដើហាន់ណាំ។

14. (មានគេនិយាយទៅកាន់ពួកគេថា៖) នេះហើយជាភ្លើងនរកដែលពួកអ្នកធ្លាប់បានបដិសេធចំពោះវា។

15. ដូច្នេះ តើនេះជាមន្តអាគមឬ? ឬមួយក៏ពួកអ្នកមិនបានឃើញទេ?

16. ចូរពួកអ្នកភ្លក់វាចុះ។ ហើយទោះបីជាពួកអ្នកអត់ធ្មត់ឬមិនអត់ធ្មត់ក៏ដោយក៏វាដូចតែគ្នាទេចំពោះពួកអ្នក។ តាមពិតគេតបស្នងដល់ពួកអ្នកចំពោះតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្តប៉ុណ្ណោះ។

17. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ពួកគេស្ថិតនៅក្នុងឋានសួគ៌ និងបរមសុខ។

18. ពួកគេរីករាយជាមួយនឹងអ្វីដែលព្រះជាម្ចាស់របស់ពួកគេបានប្រទានដល់ពួកគេ។ ហើយព្រះជាម្ចាស់របស់ពួកគេបានការពារពួកគេពីទណ្ឌកម្មនៃនរកជើហ៊ីម។

19. ចូរពួកអ្នកទទួលទាន និងផឹកដោយក្តីរីករាយចុះដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

20. ពួកគេទម្រេតខ្លួននៅលើគ្រែទល់មុខគ្នា។ ហើយយើងរៀបអាពាហ៍ពិពាហ៍ឱ្យពួកគេនឹងស្ត្រីទេពអប្សរ។

21. ចំពោះបណ្តាអ្នកដែលមានជំនឿ និងកូនចៅរបស់ពួកគេដែលបានដើរតាមពួកគេក្នុងភាពមានជំនឿនោះ យើងនឹងឱ្យកូនចៅរបស់ពួកគេបានជួបជុំជាមួយពួកគេ(ក្នុងឋានសួគ៌) ហើយយើងមិនធ្វើឱ្យ(ផលបុណ្យនៃ)ទង្វើកុសលរបស់ពួកគេបាត់បង់បន្តិចណាឡើយ។ រាល់បុគ្គលគ្រប់រូបនឹងទទួលបានតាមអ្វីដែលខ្លួនបានសាង។

22. ហើយយើងបានបន្ថែមឱ្យពួកគេ(អ្នកឋានសួគ៌)នូវផ្លែឈើ និងសាច់ទៅតាមអ្វីដែលពួកគេចូលចិត្ត។

23. នៅក្នុងឋានសួគ៌នោះ ពួកគេហុចកែវស្រាឱ្យគ្នាទៅវិញទៅមកដែលវាមិនធ្វើឱ្យពួកគេនិយាយពាក្យសម្តីឥតប្រយោជន៍ និងពាក្យសម្តីដែលមានបាបកម្មនោះឡើយ។

24. ហើយមានក្មេងៗជាច្រើនដើរជុំវិញ(ចាំបម្រើ)ពួកគេ ដែលក្មេងៗទាំងនោះប្រៀបដូចជាគជ់ខ្សងដែលត្រូវបានរក្សាទុកដូច្នោះដែរ។

25. ហើយពួកគេបានសំដៅទៅរកគ្នាដោយសួរគ្នាទៅវិញទៅមក។

26. ពួកគេនិយាយថា៖ ពិតប្រាកដណាស់ កាលពីមុន ក្នុងពេលពួកយើងរស់នៅជាមួយក្រុមគ្រួសាររបស់ពួកយើង គឺពួកយើងធ្លាប់ជាអ្នកដែលបារម្ភខ្លាច(ទណ្ឌកម្មអល់ឡោះ)។

27. ដូច្នេះ អល់ឡោះជាម្ចាស់ក៏បានប្រោសប្រទានឱ្យពួកយើង ហើយបានការពារពួកយើងពីទណ្ឌកម្មដ៏សែនក្តៅ។

28. ពិតប្រាកដណាស់ កាលពីមុន ពួកយើងធ្លាប់បានបួងសួងទៅកាន់ទ្រង់។ ពិតប្រាកដណាស់ ទ្រង់មហាសប្បុរសមហាអាណិតស្រលាញ់បំផុត។

29. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)រំឭកចុះ ព្រោះថាជាមួយនឹងឧបការគុណនៃព្រះជាម្ចាស់របស់អ្នក គឺអ្នកមិនមែនជាគ្រូទាយ ហើយក៏មិនមែនជាមនុស្សវិកលចរិតនោះដែរ។

30. ឬមួយពួកគេ(ពួកមុស្លីគីន)និយាយថា៖ (រូបគេជា)កវីនិពន្ធម្នាក់ដែលពួកយើងនៅរង់ចាំសេចក្តីស្លាប់មកដល់រូបគេ។

31. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ចូរពួកអ្នករង់ចាំមើលចុះ។ ពិតប្រាកដណាស់ រូបខ្ញុំក៏ស្ថិតក្នុងចំណោមអ្នកដែលរង់ចាំមើលជាមួយពួកអ្នកដែរ។

32. ផ្ទុយទៅវិញ តើសតិបញ្ញារបស់ពួកគេបញ្ជាពួកគេឱ្យនិយាយដូច្នោះឬ? ផ្ទុយទៅវិញ ពួកគេជាក្រុមដែលបំពាន។

33. ឬមួយពួកគេនិយាយថា៖ រូបគាត់តាក់តែងគម្ពីរគួរអាន(ដោយខ្លួនឯង)? ផ្ទុយទៅវិញ ពួកគេមិនមានជំនឿឡើយ។

34. ដូច្នេះ ចូរឱ្យពួកគេនាំយកពាក្យពេចន៍ណាមួយដែលដូចនឹងវា(គម្ពីរគួរអាន)មក ប្រសិនបើពួកគេជាអ្នកទៀងត្រង់(ចំពោះការអះអាងរបស់ខ្លួន)មែននោះ។

35. តើពួកទាំងនោះត្រូវបានគេបង្កើតមកដោយគ្មានអ្នកបង្កើត ឬមួយក៏ពួកគេជាអ្នកបង្កើត(ខ្លួនឯង)?

36. ឬមួយពួកគេបានបង្កើតមេឃជាច្រើនជាន់និងផែនដី? ផ្ទុយទៅវិញ ពួកគេមិនជឿជាក់ឡើយ។

37. ឬមួយក៏ពួកគេមានឃ្លាំង(លាភសក្ការៈ)នៃព្រះជាម្ចាស់របស់អ្នក ឬមួយក៏ពួកគេជាអ្នកមានអំណាចខ្លាំងក្លា?

38. ឬមួយក៏ពួកគេមានជណ្តើរឡើងទៅស្តាប់(វាហ្ស៊ីរបស់អល់ឡោះ)? បើដូច្នោះ ចូរឱ្យពួកគេនាំអ្នកដែលបានស្តាប់ឮ(វាហ្ស៊ីនោះ)ក្នុងចំណោមពួកគេដោយនាំមកនូវភស្តុតាងដ៏ច្បាស់លាស់មក។

39. ឬមួយក៏បុត្រី គឺសម្រាប់ទ្រង់ ចំណែកឯកូនប្រុសវិញ គឺសម្រាប់ពួកអ្នក?

40. ឬមួយក៏អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទាមទារពីពួកគេនូវកែម្រែ(ចំពោះផ្សព្វផ្សាយសារ)ដែលធ្វើពួកគេមានការលំបាកក្នុងការបង់កែម្រែនោះ(ដល់អ្នក)?

41. ឬមួយក៏ពួកគេដឹងពីប្រការអាថ៌កំបាំង រួចពួកគេកត់ត្រាទុក(ប្រាប់ដល់មនុស្ស)?

42. ឬមួយក៏ពួកទាំងនោះមានបំណងចង់ប្រើឧបាយកល(ចំពោះអ្នក)? ជាការពិតណាស់ ពួកដែលប្រឆាំង ឧបាយកលរបស់ពួកគេ គឺត្រឡប់ទៅកាន់ខ្លួនឯងទៅវិញទេ។

43. ឬមួយក៏ពួកគេមានព្រះផ្សេងក្រៅពីអល់ឡោះ? អល់ឡោះជាម្ចាស់មហាស្អាតស្អំបំផុតពីអ្វីដែលពួកគេធ្វើស្ហ៊ីរិក។

44. ហើយប្រសិនបើពួកគេឃើញបំណែកមួយអំពីមេឃធ្លាក់ចុះមក ពួកគេនឹងនិយាយថា៖ នេះជាពពកដែលគរលើគ្នា(ធម្មតា) ប៉ុណ្ណោះ។

45. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បណ្តោយពួកគេចុះ រហូតដល់ពួកគេជួបនឹងថ្ងៃរបស់ពួកគេ(ថ្ងៃបរលោក)ដែលក្នុងថ្ងៃនោះ ពួកគេនឹងត្រូវទទួលវិនាសកម្ម។

46. គឺថ្ងៃដែលឧបាយកលរបស់ពួកគេគ្មានផ្តល់ជាប្រយោជន៍អ្វីបន្តិចសម្រាប់ពួកគេសោះឡើយ ហើយពួកគេក៏មិនត្រូវបានគេជួយដែរ។

47. ហើយប្រាកដណាស់សម្រាប់ពួកអ្នកដែលបំពានគឺនឹងទទួលនូវទណ្ឌកម្មផ្សេងពីនោះទៀត(ក្នុងលោកិយ)។ក៏ប៉ុន្តែភាគច្រើននៃពួកគេមិនបានដឹងនោះឡើយ។

48. ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចំពោះច្បាប់នៃព្រះជាម្ចាស់របស់អ្នកចុះ ត្បិតអ្នកស្ថិតនៅក្រោមការឃ្លាំមើលពីយើង។ ហើយចូរអ្នក លើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់អ្នកនៅពេលដែលអ្នកក្រោក(ទៅសឡាត និងក្រោកពីដំណេក)។

49. ហើយមួយផ្នែកនៃពេលយប់ ចូរអ្នកលើកតម្កើងដល់ទ្រង់ និងនៅពេលដែលផ្កាយហៀបលិចបាត់ពន្លឺ។

ជំពូក អាន់ណាច់ម៍

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងផ្កាយនៅពេលដែលវាលិចបាត់។

2. មិត្តភក្តិរបស់ពួកអ្នក(ព្យាការីមូហាំម៉ាត់)មិនបានវង្វេង និងមិនបានភ័ន្តច្រឡំឡើយ។

3. ហើយគាត់ក៏មិននិយាយអ្វីតាមទំនើងចិត្តនោះដែរ។

4. វា(គម្ពីរគួរអាន និងស៊ូណ្ណះ)គ្មានអ្វីក្រៅពីវ៉ាហ៊ីដែលគេបានវ៉ាហ៊ីទៅកាន់គាត់នោះឡើយ។

5. អ្នកដែលមានកម្លាំងខ្លាំងក្លា(ម៉ាឡាអ៊ីកាត់ជីព្រីល)បានបង្រៀនដល់គាត់។

6. ជាអ្នកដែលមានរូបរាងស្រស់ស្អាត ហើយគេបានបង្ហាញ(រូបរាងពិតរបស់ខ្លួន)

7. ខណៈដែលគេនៅឯជើងមេឃដ៏ខ្ពស់។

8. បន្ទាប់មក គេបានខិតទៅជិតគាត់ ហើយកាន់តែខិតជិតទៅៗ

9. ដែល(គម្លាតនេះ)មានប្រវែងរវាងចុងធ្នូទាំងពីរ ឬជិតជាងនេះ។

10. ហើយទ្រង់បានផ្តល់វ៉ាហ៊ីទៅកាន់ខ្ញុំបម្រើរបស់ទ្រង់នូវអ្វីដែលទ្រង់បានផ្តល់ជាវ៉ាហ៊ី(តាមរយៈជីព្រីល)។

11. ចិត្តរបស់គាត់(ព្យាការីមូហាំម៉ាត់)មិនបានភូតកុហកចំពោះអ្វីដែលគាត់បានឃើញនោះឡើយ។

12. តើពួកអ្នក(ឱពួកមុស្លីគីន)បដិសេធចំពោះគាត់នូវអ្វីដែលគាត់បានឃើញឬ?

13. ហើយពិតប្រាកដណាស់ គាត់បានឃើញគេ(ជីព្រីល)ម្តងទៀត

14. នៅឯ "សិទ្រ៉ាតុលមុនតាហា"។

15. នៅទីនោះ គឺមានឋានសួគ៌ម៉ាក់វ៉ា។

16. នៅពេលដែល(កិច្ចការរបស់អល់ឡោះ)បានគ្របដណ្តប់ទៅលើស៊ិទរ៉ាតុលមុនតាហានូវអ្វីដែលបានគ្របដណ្តប់។

17. កែវភ្នែករបស់គាត់មិនបានងាករេ ហើយក៏មិនបានបំពាននោះដែរ។

18. ពិតប្រាកដណាស់ គាត់បានឃើញនូវសញ្ញាកស្តុតាងដ៏ធំធេងជាច្រើននៃព្រះជាម្ចាស់របស់គាត់។

19. តើពួកអ្នក(ឱពួកមុស្លីគីន)យល់យ៉ាងណាចំពោះបដិមា ឡាត និង អ៊ុហ្សា

20. ព្រមទាំងបដិមា ម៉ាណាត មួយទៀតដែលជាបដិមាទីបី ?

21. តើកូនប្រុស គឺសម្រាប់ពួកអ្នក(ឱពួកមុស្លីគីន) រីឯកូនស្រី គឺសម្រាប់អល់ឡោះជាម្ចាស់ឬ ?

22. នោះគឺជាការបែងចែកដ៏អយុត្តិធម៌បំផុត។

23. ពួកបដិមាទាំងនោះ គឺគ្រាន់តែជាឈ្មោះដែលពួកអ្នក និងជីដូនជីតារបស់ពួកអ្នកបានដាក់ឱ្យវាប៉ុណ្ណោះ ដោយអល់ឡោះជាម្ចាស់មិនបានបញ្ចុះភស្តុតាងណាមួយបញ្ជាក់ពីវាឡើយ។ ពួកគេគ្មានធ្វើតាមអ្វីក្រៅតែពីការស្មាន និងទំនើងចិត្ត(របស់ខ្លួនប៉ុណ្ណោះ។ ហើយពិតប្រាកដណាស់ ការចង្អុលបង្ហាញពីព្រះជាម្ចាស់របស់ពួកគេបានមកដល់ពួកគេហើយ។

24. ឬមួយក៏មនុស្សលោកអាចទទួលបាននូវអ្វីដែលពួកគេប្រាថ្នា ?

25. ជាការពិតណាស់ បរលោក និងលោកិយ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។

26. ហើយមានម៉ាឡាអ៊ីកាត់ជាច្រើននៅលើមេឃជាច្រើនដាន់ដែលការជួយអន្តរាគមន៍របស់ពួកគេ គឺគ្មានផ្តល់ជាប្រយោជន៍អ្វីបន្តិចណាឡើយ លើកលែងតែក្រោយពីទ្រង់បានអនុញ្ញាតសម្រាប់ជនណាដែលទ្រង់មានចេតនា ហើយទ្រង់យល់ព្រមប៉ុណ្ណោះ។

27. ពិតណាស់ ពួកដែលគ្មានជំនឿនឹងថ្ងៃបរលោក ពួកគេបានដាក់ឈ្មោះ(កំណត់ភេទ)ឱ្យពួកម៉ាឡាអ៊ីកាត់ថាជាភេទស្រី។

28. ហើយពួកគេគ្មានចំណេះដឹងអ្វីអំពីវានោះឡើយ។ ពួកគេគ្មានតាមអ្វីក្រៅតែពីការស្មានប៉ុណ្ណោះ ហើយពិតប្រាកដណាស់ ការស្មានមិនអាចផ្តល់ជាប្រយោជន៍ក្នុងការបញ្ជាក់ពីការពិតអ្វីបន្តិចបានឡើយ។

29. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ងាកចេញពីអ្នកដែលបែរចេញពីការរំឭករបស់យើង(គម្ពីរគួរអាន) ហើយគ្មានចង់បានអ្វីក្រៅតែពីជីវិតលោកិយប៉ុណ្ណោះនោះចុះ។

30. នោះគឺជាកម្រិតនៃចំណេះដឹងរបស់ពួកគេ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទ្រង់ដឹងបំផុតចំពោះជនណាដែលវង្វេងចេញពីមាគ៌ារបស់ទ្រង់ ហើយទ្រង់ក៏ដឹងបំផុតផងដែរចំពោះជនណាដែលទទួលបានការចង្អុលបង្ហាញ។

31. ហើយអ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់) ដើម្បីទ្រង់នឹងតបស្នងដល់ពួកដែលសាងអំពើអាក្រក់នូវអ្វីដែលពួកគេបានប្រព្រឹត្ត និងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អនូវប្រការល្អ(ឋានសួគ៌)។

32. គឺបណ្តាអ្នកដែលចៀសឆ្ងាយពីបាបកម្មធំៗ និងអំពើអាក្រក់ លើកលែងតែបាបកម្មតូចតាចប៉ុណ្ណោះ។ ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកជាអ្នកដែលអភ័យទោសដ៏ទូលំទូលាយបំផុត។ ទ្រង់ដឹងបំផុតចំពោះពួកអ្នក ខណៈដែលទ្រង់បានបង្កើតពួកអ្នកអំពីដី និងក្នុងខណៈដែលពួកអ្នកនៅជាគភ៌ក្នុងផ្ទៃម្តាយរបស់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកកុំលើកសរសើរខ្លួនឯងថាជាអ្នកស្អាតស្អំឱ្យសោះ។ ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតចំពោះជនណាដែលកោតខ្លាច(ចំពោះទ្រង់ពិតប្រាកដ)។

33. តើអ្នកឃើញដៃរឬទេ អ្នកដែលបែរចេញ(ពីការគោរពប្រតិបត្តិអល់ឡោះ)

34. ហើយគេបានបរិច្ចាគ(ទ្រព្យ)បន្តិចបន្តួច ក្រោយមក គេក៏ឈប់វិញនោះ?

35. តើគេមានចំណេះដឹងពីប្រការអោថ៌កំបាំង ដោយគេបានឃើញ(ដោយផ្ទាល់ភ្នែក)ឬ?

36. ឬមួយក៏មិនមានគេប្រាប់រូបគេពីអ្វីដែលមាននៅក្នុងគម្ពីរស៊ូហ៊ុហ្វមូសា

37. និង(គម្ពីរស៊ូហ៊ុហ្វ)អ៊ីព្រហ៊ីមដែលគាត់បានបំពេញ(គ្រប់កាតព្វកិច្ច)ទេឬ?

38. ពិតណាស់ គ្មានបុគ្គលណាម្នាក់រ៉ាប់រងនូវបាបកម្មរបស់អ្នកដទៃឡើយ។

39. ហើយពិតប្រាកដណាស់ មនុស្សលោកក៏មិនបានទទួលបានអ្វីក្រៅតែពីអ្វីដែលខ្លួនបានខិតខំប្រឹងប្រែងនោះដែរ។

40. ហើយពិតប្រាកដណាស់ ការខិតខំប្រឹងប្រែងរបស់គេ ច្បាស់ជានឹងត្រូវបានគេបង្ហាញឱ្យឃើញ។

41. បន្ទាប់មក គេនឹងតបស្នងដល់រូបគេនូវការតបស្នងមួយយ៉ាងពេញលេញ។

42. ហើយជាការពិតណាស់ ទីបញ្ចប់ គឺឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់អ្នក។

43. ហើយពិតប្រាកដណាស់ ទ្រង់ជាអ្នកធ្វើឱ្យសើចសប្បាយ និងធ្វើឱ្យយំសោក។

44. ហើយពិតប្រាកដណាស់ ទ្រង់ជាអ្នកដកជីវិត និងផ្តល់ជីវិត។

45. ហើយពិតណាស់ ទ្រង់បានបង្កើតឱ្យមានជាគូៗ ភេទប្រុស ភេទស្រី

46. ពីទឹកកាមមួយតំណក់កាលណាគេបញ្ចូលទៅក្នុងស្បូន។

47. ហើយពិតប្រាកដណាស់ ការបង្កើត(ពួកគេ)ម្តងទៀត គឺស្ថិតនៅលើទ្រង់។

48. ហើយពិតប្រាកដណាស់ ទ្រង់ជាអ្នកប្រទាននូវភាពមានបាន និងធ្វើឱ្យ(ពួកគេ)មានភាពស្កប់ស្កល់។

49. ហើយទ្រង់ជាព្រះជាម្ចាស់នៃផ្កាយ "អាស់ស្យៀក"។

50. ហើយពិតប្រាកដណាស់ ទ្រង់បានបំផ្លាញក្រុមអាទដំបូង

51. ហើយនិងពួកសាមូទដោយទ្រង់មិនបានបន្សល់ទុក(នរណាម្នាក់)នោះឡើយ

52. ព្រមទាំង(បានបំផ្លាញ)ក្រុមរបស់ព្យាការីនួហាកាលពីមុនផងដែរ។ ពិតប្រាកដណាស់ ពួកគេធ្លាប់ជាពួកដែលបំពាន និងរឹងរូសបំផុត។

53. ហើយចំពោះភូមិស្រុកក្រុមព្យាការីលូត ទ្រង់ក៏បានឲ្យវាវិនាសផងដែរ។

54. ហើយទ្រង់បានគ្របដណ្តប់ភូមិឋាននោះ(ដោយជុំថ្ម)នូវអ្វីដែលបានគ្របដណ្តប់។

55. ដូចនេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកដែលអ្នកមន្ទិលសង្ស័យនោះ?

56. នេះ(ព្យាការីមូហាំម៉ាត់)គឺជាអ្នកដាស់តឿនព្រមានម្នាក់ក្នុងចំណោមអ្នកដាស់តឿនព្រមានមុនៗ។

57. ថ្ងៃបរលោកកាន់តែខិតជិតមកដល់ហើយ។

58. គ្មានអ្នកណាដែលអាចរារាំងវាបានក្រៅពីអល់ឡោះជាម្ចាស់នោះឡើយ។

59. ដូច្នេះ តើពួកអ្នកមានការងឿងឆ្ងល់ចំពោះគម្ពីរគួរអាននេះ

60. ហើយពួកអ្នកនាំគ្នាសើចចំអក(ចំពោះវា) និងមិនបានយំ

61. ខណៈដែលពួកអ្នកព្រងើយកន្តើយ(ងាកចេញអំពីវា)ឬ?

62. ហេតុនេះ ចូរពួកអ្នកស៊ូជោតចំពោះអល់ឡោះ និងគោរពសក្ការៈ(ចំពោះទ្រង់)។

ជំពូក អាល់កម៊ើរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ថ្ងៃបរលោកបានខិតជិតមកដល់ ហើយព្រះចន្ទក៏បានបែកជាពីរ(រួចហើយដែរ)។

2. តែបើទោះបីជាពួកគេ(ពួកមុស្រីគីន)បានឃើញសញ្ញាកស្តុតាងក៏ដោយ ក៏ពួកគេងាកចេញ(មិនមានជំនឿ)នោះដែរ ហើយពួកគេថែមទាំងនិយាយថា៖ វាគឺជាមន្តអាគមដែលមិនបិតថេរប៉ុណ្ណោះ។

3. ហើយពួកគេបានបដិសេធ និងបានដើរតាមទំនើងចិត្តរបស់ខ្លួន។ ហើយរាល់កិច្ចការទាំងអស់នឹងកើតឡើងជាមិនខាន។

4. ហើយពិតប្រាកដណាស់ ដំណឹង(ពីពួកជំនាន់មុន)បានមកដល់ពួកគេដែលវាគ្រប់គ្រាន់ហើយ(ក្នុងការបញ្ឈប់ពួកគេពីការប្រឆាំង)។

5. (គម្ពីគួរអាន)ជាគតិបណ្ឌិតដ៏ពេញលេញ។ តែការដាស់តឿនព្រមាននោះ មិនបានផ្តល់ផលប្រយោជន៍អ្វី(ដល់ពួកគេ)ឡើយ។

6. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បែរចេញពីពួកគេចុះ (ហើយរង់ចាំ)ថ្ងៃដែលអ្នកស្រែកហៅ(ម៉ាឡាអ៊ីកាត់)ស្រែកហៅ(ពួកគេ)ទៅកាន់កិច្ចការដ៏រន្ធត់។

7. កែវភ្នែករបស់ពួកគេទម្លាក់ចុះ ខណៈដែលពួកគេក្រោកចេញពីផ្នូរ ប្រៀបបីដូចជាសត្វកណ្តូបដែលនៅរាយប៉ាយ។

8. ពួកគេប្រញាប់ប្រញាល់ឆ្ពោះទៅកាន់អ្នកដែលបានស្រែកហៅ(ពួកគេ)នោះ។ ពួកដែលប្រឆាំងបាននិយាយថា៖ នេះគឺជាថ្ងៃដែលលំបាកវេទនាបំផុត។

9. ក្រុមរបស់ព្យាការីនួហបានបដិសេធមុនពួកគេ(ពួកមុស្រីគីន)ទៅទៀតដោយពួកគេបានបដិសេធចំពោះខ្ញុំបម្រើរបស់យើង(ព្យាការីនួហ) ហើយពួកគេបាននិយាយថា៖ (គេ)ជាមនុស្សវិកលចរិត ថែមទាំងបានគំរាមកំហែងសព្វបែបយ៉ាង។

10. ពេលនោះ គេក៏បានបួងសួងទៅកាន់ព្រះម្ចាស់របស់គេថា៖ ពិតប្រាកដណាស់ រូបខ្ញុំទន់ខ្សោយមិនអាចតបតពួកគេបានឡើយ។ ហេតុនេះ សូមព្រះអង្គមេត្តាជួយឱ្យខ្ញុំយកឈ្នះ(លើពួកគេ)ផងចុះ។

11. ពេលនោះ យើងក៏បានបើកបណ្តាទ្វារនៃមេឃដោយនាំមកនូវទឹកភ្លៀងយ៉ាងច្រើន។

12. ហើយយើងក៏បានធ្វើឱ្យផែនដីបញ្ចេញនូវប្រភពទឹកជាច្រើនផុសចេញមក។ ហើយទឹក(ដែលធ្លាក់ពីលើមេឃ និងទឹកដែលចេញពីក្នុងដី)បានជួបគ្នាទៅតាមបទបញ្ជាដែលត្រូវគេបានកំណត់។

13. ហើយយើងបានដឹករូបគេ(នៅលើសំពៅ)ដែលផ្ដុំឡើងពីបន្ទះក្ដារនិងដែកគោល។

14. វាបានធ្វើដំណើរទៅតាមការឃ្លាំមើលរបស់យើង (ហើយយើងបានពន្លិចក្រុមផ្សេងទៀត) ជាការតបស្នងដល់ជនដែលបានប្រឆាំង។

15. ហើយពិតប្រាកដណាស់ យើងបានបន្សល់វាទុកជាសញ្ញាកស្តតាងមួយ។ ដូច្នេះ តើមានអ្នកដែលយកធ្វើជាមេរៀនដែរឬទេ?

16. ដូច្នេះ តើទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើងនោះយ៉ាងដូចម្ដេចដែរ?

17. ហើយជាការពិតណាស់ យើងបានធ្វើឱ្យគម្ពីរគួរអានមានភាពងាយស្រួលសម្រាប់ការនឹករលឹក។ ដូច្នេះ តើមានអ្នកដែលទទួលយកជាមេរៀនដែរឬទេ?

18. ពួកអាទបានបដិសេធ(ចំពោះព្យាការីហ៊ូទ)។ តើទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើងនោះយ៉ាងដូចម្ដេចដែរ?

19. ជាការពិតណាស់ យើងបានបញ្ជូនខ្យល់ដែលត្រជាក់បំផុតទៅកាន់ពួកគេក្នុងថ្ងៃដ៏អាក្រក់បំផុតជាបន្តបន្ទាប់

20. ដោយវាបានគួចយកមនុស្សចេញពីផ្ទៃដី ប្រៀបដូចជាដើមល្មីដែលដាច់ចេញពីគល់។

21. ដូច្នេះ តើទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើងនោះយ៉ាងដូចម្ដេចដែរ?

22. ហើយជាការពិតណាស់ យើងបានធ្វើឱ្យគម្ពីរគួរអានមានភាពងាយស្រួលសម្រាប់ការនឹករលឹក។ ដូច្នេះ តើមានអ្នកដែលទទួលយកជាមេរៀនដែរឬទេ?

23. ពួកសាមូទបានបដិសេធនឹងការដាស់តឿនព្រមាន។

24. ហើយពួកគេបាននិយាយថា៖ តើឲ្យពួកយើងដើរតាមគេដែលជាមនុស្ស(ធម្មតា)ម្នាក់ក្នុងចំណោមពួកយើងឬ? បើដូច្នោះមែន ពួកយើងពិតជានឹងស្ថិតក្នុងភាពវង្វេង និងវិកលចរិតជាមិនខាន។

25. តើគេ(អល់ឡោះ)បញ្ចុះវ៉ាហ៊ីទៅឲ្យរូបគេដោយរំលងពួកយើងឬ? ផ្ទុយទៅវិញ រូបគេ(ព្យាការីសឡេះ) គឺជាអ្នកកុតកុហក និងក្អេងក្អាង។

26. ពួកគេគង់តែនឹងដឹងនៅថ្ងៃខាងមុខជាមិនខាន ថាតើអ្នកណាជាអ្នកកុតកុហក និងក្អេងក្អាងនោះ?

27. ជាការពិតណាស់ យើង(អល់ឡោះ)បានបញ្ជូនសត្វអូដ្ឋញីមួយក្បាលដើម្បីជាការសាកល្បងចំពោះពួកគេ។ ដូច្នេះ ចូរអ្នក(ឱព្យាការីសឡេះ)តាមដានមើលពួកគេ និងមានភាពអត់ធ្មត់ចុះ។

28. ហើយចូរអ្នកប្រាប់ពួកគេថា ជាការពិតណាស់ ទឹកត្រូវបានបែងចែក(ជាវេន)រវាងពួកគេ(និងសត្វអូដ្ឋនោះ)។ រាល់វេនផឹកនីមួយៗ គឺសម្រាប់តែម្ចាស់វេនប៉ុណ្ណោះ។

29. ពេលនោះ ពួកគេបានហៅមិត្តភក្តិម្នាក់របស់ពួកគេ ហើយគេក៏បានយកដាវ រួចក៏សម្លាប់សត្វអូដ្ឋនោះ។

30. ដូច្នេះ តើទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើងនោះយ៉ាងដូចម្តេចដែរ?

31. ពិតប្រាកដណាស់ យើងបានបញ្ជូនសម្រែកមួយយ៉ាងខ្លាំងទៅកាន់ពួកគេ (ហើយវាបានបំផ្លាញពួកគេ)។ ពេលនោះ ពួកគេប្រៀបដូចជាស្មៅស្ងួតដែលគេទុកធ្វើជាចំណីសត្វដូច្នោះដែរ។

32. ហើយជាការពិតណាស់ យើងបានធ្វើឱ្យគម្ពីរគួរអានមានភាពងាយស្រួលសម្រាប់ការរំលឹកចងចាំ។ ដូច្នេះ តើមានអ្នកដែលទទួលយកជាមេរៀនដែរឬទេ?

33. ក្រុមរបស់ព្យាការីលូតបានបដិសេធចំពោះការដាស់តឿនព្រមាន។

34. ពិតប្រាកដណាស់ យើងក៏បានបញ្ជូនព្យុះដុំថ្មទៅកាន់ពួកគេ លើកលែងតែក្រុមគ្រួសាររបស់ព្យាការីលូតប៉ុណ្ណោះដោយយើងបានសង្គ្រោះពួកគេនៅមុនពេលទៀបភ្លឺ

35. ជាឧបការគុណមួយអំពីយើង។ ក៏ដូចគ្នាដែរ យើងនឹងតបស្នងចំពោះជនណាដែលចេះដឹងគុណ។

36. ហើយជាការពិតណាស់ គេ(ព្យាការីលូត)បានដាស់តឿនព្រមានពួកគេពីទណ្ឌកម្មរបស់យើង តែពួកគេបែរជាមានការមន្ទិលសង្ស័យចំពោះការដាស់តឿនព្រមាននោះទៅវិញ។

37. ហើយជាការពិតណាស់ ពួកគេបានសុំគាត់ប្រព្រឹត្តអំពើអសីលធម៌ជាមួយភ្ញៀវរបស់គាត់។ ពេលនោះ យើងក៏បានបិទបាំងភ្នែករបស់ពួកគេ។ (ហើយមានគេនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើង។

38. ហើយពិតប្រាកដណាស់ ទណ្ឌកម្មជានិរន្តរ៍បានមកដល់ពួកគេនៅពេលព្រឹកព្រលឹម។

39. ដូច្នេះ ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្ម និងការដាស់តឿនព្រមានរបស់យើង។

40. ហើយជាការពិតណាស់ យើងបានធ្វើឱ្យគម្ពីរគួរអានមានភាពងាយស្រួលសម្រាប់ការរលឹកចងចាំ។ ដូច្នេះ តើមានអ្នកដែលទទួលយកជាមេរៀនដែរឬទេ?

41. ហើយជាការពិតណាស់ ការដាស់តឿនព្រមានបានមកដល់បក្សពួករបស់ហ្វៀរអោន។

42. ពួកគេបានបដិសេធចំពោះសញ្ញាកស្តុតាងទាំងអស់របស់យើង។ ដូច្នេះ យើងក៏បានដាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្មរបស់ព្រះជាម្ចាស់មហាខ្លាំងពូកែ ជាអ្នកមានអានុភាពបំផុត។

43. តើការប្រឆាំងរបស់ពួកអ្នក(ឱពួកមុស្លីគីន)ប្រសើរជាងពួកទាំងនោះ ឬមួយក៏ពួកអ្នកមានការធានាឱ្យរួចផុត(ពីទណ្ឌកម្ម) នៅក្នុងបណ្តាគម្ពីរ(ជំនាន់មុន)ឬ?

44. ឬមួយពួកគេនិយាយថា៖ ពួកយើងទាំងអស់គ្នាជាអ្នកឈ្នះ?

45. ពួកគេទាំងអស់នឹងត្រូវចាញ់ ហើយពួកគេនឹងរត់បកក្រោយ។

46. ផ្ទុយទៅវិញ ថ្ងៃបរលោក គឺជាពេលសន្យារបស់ពួកគេ ហើយថ្ងៃបរលោក គឺធំធេង និងល្វីងជូរចត់បំផុត។

47. ពិតប្រាកដណាស់ ពួកឧក្រិដ្ឋជនគឺស្ថិតនៅក្នុងភាពវង្វេង និងការលំបាកវេទនា។

48. នៅថ្ងៃដែលពួកគេត្រូវបានគេអូសផ្តាប់មុខនៅក្នុងភ្លើងនរក។ (ហើយមានគេនិយាយថា៖) ចូរពួកអ្នកភ្លក់ចុះនូវទណ្ឌកម្មនៃភ្លើងនរក។

49. ពិតប្រាកដណាស់ រាល់អ្វីៗទាំងអស់ គឺយើងបានបង្កើតវាទៅតាមការកំណត់(អំពីយើង)។

50. ហើយបទបញ្ជារបស់យើង គឺយើងគ្រាន់តែមានបន្ទូលនូវពាក្យមួយម៉ាត់ប៉ុណ្ណោះ (វានឹងកើតឡើងភ្លាម)ក្នុងមួយប៉ព្រិចភ្នែក។

51. ហើយជាការពិតណាស់ យើងបានបំផ្លាញអ្នកដែល(ប្រឆាំង)ដូចពួកអ្នក។ ដូច្នេះ តើមានអ្នកដែលយកជាមេរៀនដែរឬទេ?

52. ហើយរាល់អ្វីៗទាំងអស់ដែលពួកគេបានប្រព្រឹត្តវា គឺត្រូវបានកត់ត្រាទុកក្នុងសៀវភៅកំណត់ត្រា។

53. ហើយរាល់ទង្វើតូចធំ(របស់ពួកគេ) សុទ្ធតែត្រូវបានកត់ត្រាទុក។

54. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ពួកគេស្ថិតនៅក្នុងឋានសួគ៌ និងទន្លេជាច្រើន

55. ស្ថិតនៅកន្លែងដែលពិតប្រាកដនៅឯព្រះជាម្ចាស់ដែលជាស្តេច ជាអ្នកដែលមានអានុភាពបំផុត។

ជំពូក អាល់ក៉ោះម៉ាន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ព្រះជាម្ចាស់ដ៏មហាសប្បុរស។
2. ទ្រង់បានបង្រៀនគម្ពីរគួរអាន។
3. ទ្រង់បានបង្កើតមនុស្សលោក។
4. ទ្រង់បានបង្រៀនគេឱ្យចេះបរិយាយ។
5. ព្រះអាទិត្យនិងព្រះចន្ទធ្វើដំណើរតាមគន្លងរបស់វាយ៉ាងជាក់លាក់។
6. ហើយរុក្ខជាតិនិងដើមឈើទាំងឡាយពួកវាក្រាបស៊ូជោត(ចំពោះអល់ឡោះ)។
7. ហើយចំពោះមេឃ ទ្រង់បានលើកវាឡើង ហើយទ្រង់បានដាក់នូវភាពយុត្តិធម៌(នៅលើផែនដី)
8. ដើម្បីកុំឱ្យពួកអ្នក(ឱមនុស្សលោក)មានការបំពាននៅក្នុងការថ្លឹងថ្លែង។
9. ហើយចូរពួកអ្នកថ្លឹងដោយភាពយុត្តិធម៌ និងមិនត្រូវគៃបំបាត់នៅក្នុងការថ្លឹងឡើយ។
10. ហើយចំពោះផែនដី ទ្រង់បានសន្ធឹងវាដើម្បីឱ្យសត្វលោកទាំងឡាយ(រស់នៅ)។
11. នៅលើផែនដីនោះ មានផ្លែឈើ និងដើមល្មើដែលមានចង្កោមផ្លែជាច្រើន
12. ព្រមទាំងគ្រាប់ធញ្ញជាតិដែលមានសំបក និងរុក្ខជាតិដែលមានក្លិនក្រអូប។
13. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?
14. ទ្រង់បានបង្កើតមនុស្សលោក(ព្យាការីអាហ្សាំ)អំពីដីស្ងួត ប្រៀបដូចជាដីដែលគេដុត។
15. ហើយទ្រង់បានបង្កើតជិនពីអណ្តាតភ្លើង។

16. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

17. (ទ្រង់)ជាព្រះជាម្ចាស់នៃកន្លែងទាំងពីរដែលព្រះអាទិត្យរះ និងកន្លែងទាំងពីរដែលព្រះអាទិត្យលិច(ទាំងក្នុងរដូវក្តៅ និងរដូវរងា)។

18. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

19. ទ្រង់ធ្វើឱ្យសមុទ្រពីរ(ទឹកប្រៃនិងទឹកសាប)ជួបគ្នា។

20. នៅរវាងវាទាំងពីរ គឺមានរបាំងខណ្ឌមិនឱ្យវាទាំងពីរជ្រាបចូលគ្នាបានឡើយ។

21. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

22. គជ់ខ្យង ហើយនិងផ្កាថ្ម គឺចេញពីសមុទ្រទាំងពីរ។

23. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

24. ហើយ(ការសម្រួលឲ្យ)សំពៅដ៏ធំដែលធ្វើដំណើរលើផ្ទៃសមុទ្រប្រៀបដូចភ្នំនោះ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។

25. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

26. រាល់អ្វីៗទាំងអស់នៅលើវា(ផែនដី) គឺត្រូវតែវិនាសអន្តរាយ។

27. លើកលែងព្រះភ័ក្ត្រនៃព្រះជាម្ចាស់របស់អ្នកដែលពោរពេញទៅដោយភាពថ្កុំថ្កើង និងភាពសប្បុរសប៉ុណ្ណោះដែលគង់វង្ស(ជាអមតៈ)។

28. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

29. រាល់អ្នកដែលនៅលើមេឃជាច្រើនជាន់ និងអ្នកដែលនៅលើផែនដី គឺបួងសួងសុំពីទ្រង់។ ជារៀងរាល់ថ្ងៃ ទ្រង់ចាត់ចែងកិច្ចការ(របស់ទ្រង់)។

30. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

31. យើងនឹងធ្វើការទូទាត់ដល់ពួកអ្នក ឱពួកមនុស្ស និងជិនទាំងឡាយ!

32. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

33. ឱពួកជិន និងមនុស្សលោកទាំងឡាយ! ប្រសិនបើពួកអ្នកមានសមត្ថភាពអាចចេញផុតពីជ្រុងទាំងឡាយនៃមេឃជាច្រើនជាន់និងផែនដី ចូរពួកអ្នកចេញឲ្យផុតចុះ។ ពួកអ្នកមិនអាចចេញផុតបានឡើយ លើកលែងតែមានអំណាចណាមួយ។

34. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

35. គេបញ្ជូនអណ្តាតភ្លើង និងលោហធាតុទៅកាន់អ្នកទាំងពីរ(ឱមនុស្សលោកនិងជិន)។ ដូច្នេះ អ្នកទាំងពីរមិនអាចជួយគ្នាបាននោះឡើយ។

36. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

37. នៅពេលដែលមេឃបែកប្រេះ ពេលនោះ វាក្លាយជាពណ៌ក្រហមប្រៀបដូចប្រេងដែលកំពុងពុះ។

38. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

39. ហើយនៅក្នុងថ្ងៃនោះ មនុស្សលោកនិងជិននឹងមិនត្រូវបានគេសួរពីបាបកម្មរបស់ខ្លួននោះឡើយ។

40. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

41. គេស្គាល់ពួកឧក្រិដ្ឋជនទាំងឡាយតាមរយៈសញ្ញាសម្គាល់របស់ពួកគេ រួចគេបានចាប់សក់បង្ហើយ និងជើងរបស់ពួកគេ(បោះគ្រវែងទៅក្នុងនរក)។

42. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

43. (មានគេពោលទៅកាន់ពួកទាំងនោះថា៖) នេះហើយជានរកដើហាន់ណាំដែលពួកឧក្រិដ្ឋជនទាំងឡាយបានបដិសេធចំពោះវានោះ។

44. ពួកគេនៅវិលវល់រវាងវា(ភ្លើងនរក) និងរវាងទឹកដ៏សែនក្តៅបំផុត។

45. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ(ជិន និងមនុស្សលោក)ដែលអ្នកទាំងពីរបដិសេធនោះ?

46. រីឯសម្រាប់អ្នកដែលខ្លាចការឈរនៅចំពោះមុខព្រះជាម្ចាស់របស់គេ គឺទទួលបានឋានសួគ៌ពីរ។

47. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

48. ឋានសួគ៌ទាំងពីរនេះ គឺមានមែកឈើដែលពោរពេញទៅដោយផ្លែផ្កា។

49. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

50. នៅក្នុងវាទាំងពីរ គឺមានប្រភពទឹកចំនួនពីរដែលហូរ។

51. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

52. នៅក្នុងវាទាំងពីរផងដែរ រាល់ផ្លែឈើទាំងអស់ គឺមានជាគូៗ (ពីរប្រភេទ)។

53. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

54. ពួកគេទម្រេតខ្លួននៅលើពូកដែលកម្រាលរបស់វាធ្វើពីសូត្រក្រាស់។ ហើយរាល់ផ្លែឈើ (ក្នុងឋានសួគ៌នោះ) គឺស្ថិតនៅជិតបង្កើយពួកគេ។

55. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

56. នៅក្នុងនោះ មានស្ត្រីទេពអប្សរដ៏ច្រើនដែលមិនសម្លឹងទៅកាន់បុរសណាក្រៅពីស្វាមីរបស់ពួកនាងឡើយ ហើយក៏គ្មានមនុស្សឬជិនណាម្នាក់ធ្លាប់ប៉ះពាល់ពួកនាងមុនពួកគេនោះដែរ។

57. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

58. ពួកនាង (ស្រស់ស្អាត) ប្រៀបដូចជាត្បូងទទឹម និងផ្កាថ្ម។

59. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

60. តើពុំមែនទេឬដែលការតបស្នងចំពោះអ្នកដែលសាងអំពើល្អ គឺគ្មានអ្វីក្រៅពីប្រការល្អនោះ?

61. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

62. ហើយក្រៅពីឋានសួគ៌ទាំងពីរនោះ គឺមានឋានសួគ៌ពីរផ្សេងទៀត។

63. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

64. វាទាំងពីរនោះ គឺមានពណ៌បៃតងចាស់។

65. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

66. នៅក្នុងវាទាំងពីរ គឺមានប្រភពទឹកចំនួនពីរដែលបញ្ចេញទឹកយ៉ាងច្រើនឥតឈប់ឈរ។

67. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

68. នៅក្នុងវាទាំងពីរនេះដែរ គឺមានផ្លែឈើ ល្មើ និងផ្លែទទឹម។

69. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

70. នៅក្នុងនោះផងដែរ គឺមានស្ត្រីដ៏ល្អប្រពៃ និងស្រស់ស្អាតជាច្រើន។

71. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

72. បណ្តាស្ត្រីសូគ៌ាត្រូវបានបិទបាំងនៅក្នុងពន្លា។

73. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

74. គ្មានមនុស្សនិងជិនណាម្នាក់ធ្លាប់ប៉ះពាល់ពួកនាងមុនពួកគេនោះឡើយ។

75. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

76. ពួកគេទម្រេតខ្លួននៅលើខ្នើយដែលមានស្រោមពណ៌បៃតង និងកម្រាលព្រំដ៏ប្រណិត។

77. ដូច្នេះ តើមានឧបការគុណណាមួយនៃព្រះជាម្ចាស់របស់អ្នកទាំងពីរ (ជិន និងមនុស្សលោក) ដែលអ្នកទាំងពីរបដិសេធនោះ?

78. មហាពរជ័យព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដែលពោរពេញទៅដោយកាតព្តុំថ្កើង និងភាពសប្បុរស។

ជំពូក អាល់ខាគីរះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលថ្ងៃបរលោកកើតឡើង

2. ចំពោះការកើតឡើងរបស់វា គឺគ្មានអ្នកដែលបដិសេធទៀតឡើយ។

3. គេទម្លាក់(ពួកគ្មានជំនឿទៅក្នុងឋាននរក) និងលើកឋានៈ(បណ្តាអ្នកដែលមានជំនឿក្នុងឋានសួគ៌)។

4. នៅពេលដែលផែនដីត្រូវបានគេធ្វើឱ្យរង្គើយ៉ាងខ្លាំងបំផុត

5. ហើយភ្នំទាំងឡាយត្រូវបានគេបំបែកឱ្យបែកខ្ទេចខ្ទី

6. ពេលនោះ វាក៏ក្លាយជាធូលីដែលរសាត់តាមខ្យល់។

7. (នៅថ្ងៃនោះ) ពួកអ្នកត្រូវបានបែងចែកជាបីក្រុម។

8. ក្រុមខាងស្តាំ។ ខ្ពង់ខ្ពស់យ៉ាងណាទៅក្រុមខាងស្តាំនោះ!

9. និងក្រុមខាងឆ្វេង។ អាក្រក់យ៉ាងណាទៅក្រុមខាងឆ្វេងនោះ!

10. ហើយនិងក្រុមដែលរួសរាន់ក្នុងការសាងអំពើល្អ។

11. អ្នកទាំងនោះ គឺជាអ្នកដែល(មានឋានៈ)ជិតនឹងអល់ឡោះជាម្ចាស់

12. ដោយស្ថិតនៅក្នុងឋានសួគ៌ណាអ៊ីម។

13. មួយក្រុមធំ គឺមកពីប្រជាជាតិនេះ និងប្រជាជាតិជំនាន់មុនៗ។

14. ហើយភាគតិច គឺជាមនុស្សសម័យកាលចុងក្រោយ។

15. (ពួកគេ)នៅលើគ្រែធ្វើអំពីមាស

16. ដោយទម្រេតខ្លួននៅលើគ្រែទល់មុខគ្នា។

17. ហើយមានក្មេងៗដែលមានវ័យក្មេងជានិច្ចដើរជុំវិញ(ចាំបម្រើ)ពួកគេ

18. ដោយមានពែង កំសៀវ ហើយនិងកែវស្រាមកពីទន្លេដែលហូរ(ក្នុងឋានសួគ៌)។

19. វាមិនធ្វើឲ្យពួកគេឈឺក្បាល និងបាត់បង់សតិដោយសារវានោះឡើយ។

20. ហើយមានផ្លែឈើជាច្រើនដែលពួកគេអាចជ្រើសរើសបាន

21. និងសាច់បក្សីជាច្រើនតាមដែលពួកគេត្រូវការ

22. ព្រមទាំងស្ត្រីសួគ៌

23. ដែលប្រៀបដូចជាគជ់ខ្សងដែលត្រូវបានថែរក្សា(ទុកយ៉ាងល្អ)

24. ជាការតបស្នងចំពោះអ្វីដែលពួកគេធ្លាប់បានប្រព្រឹត្ត។

25. ពួកគេមិនឮនូវពាក្យសម្តីដែលអាក្រក់ និងពាក្យសម្តីដែលនាំឱ្យមានបាបកម្មនៅក្នុងវានោះឡើយ។

26. មានតែពាក្យឲ្យសាឡាមគ្នាប៉ុណ្ណោះ។

27. ហើយក្រុមខាងស្តាំ។ ខ្ពង់ខ្ពស់យ៉ាងណាទៅក្រុមខាងស្តាំនោះ!

28. (ពួកគេ)នៅក្រោមដើមពុទ្រាដែលពុំមានបន្លា

29. ក្រោមដើមចេកដែលមានផ្លែត្រួតលើគ្នា

30. នៅក្រោមម្លប់ជាប់ជានិច្ច

31. ហើយមានទឹកហូរជាប់រហូត

32. និងមានផ្លែឈើជាច្រើន

33. ដែលមិនចេះអស់ និងមិនអាចរារាំង(ពីពួកគេ)នោះដែរ

34. ហើយនិងពូកដែលត្រូវបានគេលើក(ដាក់លើគ្រែ)។

35. ពិតប្រាកដណាស់ យើងបានបង្កើតពួកនាង(ស្ត្រីសួគ៌)នូវការបង្កើតមួយ(ខុសពីការបង្កើតធម្មតា)

36. ដោយយើងបានឱ្យពួកនាងនៅក្រមុំព្រហ្មចារីយ៍ជានិច្ច

37. ដែលស្រលាញ់តែស្វាមីរបស់ខ្លួនប៉ុណ្ណោះ និងមានអាយុស្មើៗគ្នា

38. សម្រាប់ក្រុមខាងស្តាំ។

39. ពួកគេជាក្រុមជាច្រើននៃប្រជាជាតិជំនាន់មុនៗ។

40. និងក្រុមជាច្រើននៃប្រជាជាតិជំនាន់ក្រោយផងដែរ។

41. រីឯក្រុមខាងឆ្វេង។ អាក្រក់យ៉ាងណាទៅក្រុមខាងឆ្វេងនោះ!

42. (ពួកគេ)ស្ថិតនៅក្រោមខ្យល់ដ៏សែនក្តៅបំផុត និងក្រោមទឹកដ៏សែនក្តៅបំផុត។

43. និងនៅក្រោមម្លប់នៃផ្សែងដ៏ខ្មៅងងឹត

44. ដែលវាមិនត្រជាក់ ហើយក៏មិនសុខស្រួលនោះដែរ។

45. ប្រាកដណាស់ កាលពីមុននេះ ពួកគេធ្លាប់ជាពួកដែលសោយសុខ(ក្នុងលោកិយ)។

46. ហើយពួកគេធ្លាប់ស្ថិតនៅលើការប្រព្រឹត្តអំពើបាបដ៏ធំធេង។

47. ហើយពួកគេធ្លាប់បាននិយាយថាៈ នៅពេលដែលពួកយើងស្លាប់ ហើយបានក្លាយជាដី និងឆ្អឹងហើយនោះ ពួកយើងនឹងត្រូវបានគេបង្កើតឱ្យរស់ឡើងវិញឬ?

48. ចុះជីដូនជីតារបស់ពួកយើងជំនាន់មុនៗនោះ?

49. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថាៈ ពិតប្រាកដណាស់ ទាំងអ្នកជំនាន់មុន និងអ្នកជំនាន់ក្រោយ

50. ពិតជានឹងត្រូវបានគេប្រមូលផ្តុំទៅកាន់ទីណាត់មួយនាថ្ងៃដែលត្រូវបានកំណត់។

51. បន្ទាប់មក ប្រាកដណាស់ពួកអ្នក ឱពួកវង្វេងដែលបដិសេធ

52. ប្រាកដជានឹងបានទទួលទានអំពីដើមហ្ស៊ឹកគូម

53. ហើយពួកអ្នកនឹងបំពេញពោះ(របស់ពួកអ្នក)នឹងផ្លែនោះ។

54. រួចមក ពួកអ្នកនឹងផឹកទឹកដ៏សែនក្តៅបំផុត

55. ដោយពួកអ្នកផឹក(យ៉ាងច្រើន)ដូចសត្វអូដ្ឋដែលស្រេកទឹក។

56. នេះហើយជាអ្វីដែលគេត្រៀមទទួលពួកគេនៅថ្ងៃបរលោក។

57. យើងបានបង្កើតពួកអ្នក។ ដូចនេះ ហេតុអ្វីបានជាពួកអ្នកមិនជឿជាក់?

58. តើពួកអ្នកឃើញដែរឬទេនូវទឹកកាមដែលពួកអ្នកបញ្ចូលទៅក្នុងស្បូនស្ត្រី

59. តើពួកអ្នកជាអ្នកដែលបានបង្កើតវា ឬមួយយើងជាអ្នកបង្កើតវា?

60. យើងបានកំណត់សេចក្តីស្លាប់រវាងពួកអ្នក។ ហើយយើងមិនមែនជាអ្នកដែលអសមត្ថភាពនោះទេ

61. លើការផ្លាស់ប្តូរក្រុមមួយផ្សេងទៀតដែលដូចពួកអ្នក ហើយបង្កើតពួកអ្នកក្នុងលក្ខណៈមួយដែលពួកអ្នកមិនបានដឹងនោះ។

62. ហើយពិតប្រាកដណាស់ ពួកអ្នកបានដឹងពីការបង្កើត(ពួកអ្នក)លើកដំបូងហើយ។ ដូច្នេះ ហេតុអ្វីបានជាពួកអ្នកមិនយកជាមេរៀន?

63. តើពួកអ្នកបានឃើញដែរឬទេនូវអ្វីដែលពួកអ្នកបានសាបព្រួសនោះ?

64. តើពួកអ្នកជាអ្នកបណ្តុះវា ឬមួយយើងជាអ្នកដែលបណ្តុះវា(ឱ្យដុះឡើង)?

65. ប្រសិនបើយើងមានចេតនា យើងពិតជានឹងធ្វើឱ្យវាក្រៀមស្វិត ហើយពួកអ្នកនឹងមានការភ្ញាក់ផ្អើល(ចំពោះអ្វីដែលបានកើតឡើង)ជាមិនខាន។

66. (ពួកអ្នកនឹងនិយាយថា៖) ប្រាកដណាស់ ពួកយើងត្រូវបានគេជាក់ទណ្ឌកម្ម។

67. ផ្ទុយទៅវិញ ពួកយើងត្រូវបានគេរារាំង(ពីលាភសក្ការៈ)។

68. តើពួកអ្នកបានឃើញដែរឬទេចំពោះទឹកដែលពួកអ្នកផឹកនោះ

69. តើពួកអ្នកជាអ្នកបញ្ចុះវា(ទឹកភ្លៀង)ពីដុំពពក ឬមួយក៏យើងជាអ្នកដែលបញ្ចុះវា?

70. ប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងធ្វើឱ្យវាមានរសជាតិប្រៃខ្លាំងជាមិនខាន។ ដូច្នេះ ហេតុអ្វីបានជាពួកអ្នកមិនដឹងគុណ?

71. តើពួកអ្នកឃើញដែរឬទេចំពោះភ្លើងដែលពួកអ្នកបង្កាត់នោះ

72. តើពួកអ្នកជាអ្នកបង្កើតដើមឈើ(ដែលអាចយកមកបង្កាត់)វាបាន ឬមួយក៏យើងជាអ្នកដែលបង្កើតវា?

73. យើងបានបង្កើតវា(ភ្លើង)ជាការជាស់រំឭក និងជាប្រយោជន៍ដល់អ្នកដំណើរទាំងឡាយ។

74. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកតម្កើងនូវព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដ៏មហាធំធេងចុះ។

75. (អល់ឡោះទ្រង់)ស្បថនឹងទីគោចររបស់ហ្វូងតារាទាំងឡាយ។

76. ហើយពិតប្រាកដណាស់ វាជាការស្បថដ៏ធំធេងមួយ ប្រសិនបើពួកអ្នកបានដឹង។

77. ពិតប្រាកដណាស់ វាជាគម្ពីរគួរអានដ៏ឧត្តុង្គឧត្តម

78. ដែលត្រូវបានរក្សាទុកនៅក្នុងគម្ពីរកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)។

79. គ្មានអ្នកណាអាចប៉ះពាល់វាបានឡើយ លើកលែងតែអ្នកដែលស្អាតស្អំប៉ុណ្ណោះ។

80. ជាការបញ្ចុះមកពីព្រះជាម្ចាស់នៃពិភពទាំងឡាយ ។

81. តើពួកអ្នក(ឱពួកមុស្លីគីន)បដិសេធនឹងគម្ពីរគួរអាននេះ

82. ហើយពួកអ្នកចាត់ទុក(ការដឹងគុណ)លាភសក្ការៈរបស់ពួកអ្នកដោយពួកអ្នកប្រឆាំងបែបនេះឬ?

83. ដូច្នេះ ហេតុអ្វីបានជានៅពេលដែល(ព្រលឹង)បានទៅដល់បំពង់ក

84. ខណៈដែលពេលនោះ ពួកអ្នកកំពុងតែសម្លឹងមើល(អ្នកជិតស្លាប់)

85. ហើយយើង គឺនៅជិតរូបគេជាងពួកអ្នកទៅទៀត ប៉ុន្តែពួកអ្នកមិនបានឃើញនោះឡើយ

86. ដូច្នេះ តើពួកអ្នកមានសមត្ថភាពដែរឬទេ ប្រសិនបើពួកអ្នកមិនត្រូវបានគេជំនុំជម្រះទេនោះ

87. ចូរពួកអ្នកឱ្យព្រលឹងនោះត្រលប់មកវិញមក ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ។

88. រីឯប្រសិនបើរូបគេស្ថិតក្នុងចំណោមអ្នកដែលមានឋានៈជិត(ចំពោះអល់ឡោះ)

89. គេនឹងទទួលបានក្តីមេត្តាករុណា និងភាពរីករាយ ហើយនិងឋានសួគ៌ណាអ៊ីម។

90. រីឯប្រសិនបើរូបគេស្ថិតក្នុងចំណោមក្រុមខាងស្តាំវិញ

91. (មានគេនិយាយទៅកាន់រូបគេថា៖) សូមសន្តិភាពកើតមានដល់អ្នកដោយបានស្ថិតក្នុងចំណោមក្រុមខាងស្តាំ។

92. ចំណែកឯប្រសិនបើរូបគេស្ថិតក្នុងចំណោមពួកបដិសេធដែលវង្វេងវិញនោះ

93. ពិតណាស់ គេត្រៀមទទួលរូបគេដោយទឹកដ៏សែនក្តៅបំផុត

94. ហើយនិងត្រូវបានគេដុតដោយភ្លើងនរកជើហ៊ីម។

95. ពិតប្រាកដណាស់ នេះគឺជាការពិតយ៉ាងជាក់ច្បាស់។

96. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកតម្កើងនូវព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដ៏មហាធំធេងចុះ។

ជំពូក អាល់ហាឌីត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្វីៗដែលនៅលើមេឃជាច្រើនជាន់និងផែនដីបានលើកតម្កើងចំពោះអល់ឡោះជាម្ចាស់។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

2. ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ទ្រង់ផ្តល់ជីវិត និងដកយកជីវិត។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

3. ទ្រង់ជាអ្នកដំបូងគេបង្អស់ ជាអ្នកចុងក្រោយគេបង្អស់ ជាអ្នកខ្ពស់ជាងគេបង្អស់ ជាអ្នកជិតជាងគេបំផុត។ ហើយទ្រង់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

4. ទ្រង់គឺជាអ្នកដែលបានបង្កើតមេឃជាច្រើនជាន់និងផែនដីក្នុងរយៈពេលប្រាំមួយថ្ងៃ។ បន្ទាប់មក ទ្រង់នៅលើអារ៉ស្តេ។ ទ្រង់ដឹងនូវអ្វីដែលចូលទៅក្នុងដី និងអ្វីដែលចេញពីដី អ្វីដែលចុះមកពីលើមេឃ ហើយនិងអ្វីដែលឡើងទៅលើមេឃ។ ហើយទ្រង់នៅជាមួយពួកអ្នកទោះបីជាពួកអ្នកស្ថិតនៅទីណាក៏ដោយ។ ហើយទ្រង់មហាឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

5. ការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយកិច្ចការទាំងឡាយ នឹងត្រូវគេនាំត្រលប់ទៅកាន់ទ្រង់វិញ(តែមួយគត់)។

6. ទ្រង់បញ្ចូលពេលយប់ទៅក្នុងពេលថ្ងៃ និងបញ្ចូលពេលថ្ងៃទៅក្នុងពេលយប់។ ហើយទ្រង់មហាដឹងបំផុតនូវអ្វីដែលនៅក្នុងដួងចិត្ត។

7. ចូរពួកអ្នកមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយចូរពួកអ្នកបរិច្ចាគអំពីអ្វីដែលអល់ឡោះបានប្រទានឱ្យពួកអ្នកគ្រប់គ្រងវា។ ដូច្នេះ ជនណាដែលមានជំនឿក្នុងចំណោមពួកអ្នក និងបានបរិច្ចាគ(ទ្រព្យសម្បត្តិរបស់ខ្លួន) សម្រាប់ពួកគេនឹងទទួលបាននូវផលបុណ្យដ៏ធំធេង។

8. តើមានអ្វីដែលរារាំងពួកអ្នកមិនឱ្យមានជំនឿចំពោះអល់ឡោះជាម្ចាស់ ខណៈដែលអ្នកនាំសារ(របស់ទ្រង់)កំពុងតែអំពាវនាវពួកអ្នកដើម្បីឲ្យពួកអ្នកមានជំនឿចំពោះព្រះជាម្ចាស់របស់ពួកអ្នកនោះ? ហើយពិតប្រាកដណាស់ ទ្រង់បានទទួលយកនូវកិច្ចសន្យាពីពួកអ្នករួចទៅហើយ ប្រសិនបើពួកអ្នកជាអ្នកមានជំនឿមែននោះ។

9. ទ្រង់ជាអ្នកដែលបានបញ្ជូនមកឱ្យខ្ញុំបម្រើរបស់ទ្រង់(ព្យាការីមូហាំម៉ាត់)នូវសញ្ញាកស្តុតាងជាច្រើនដ៏ច្បាស់លាស់ដើម្បីបញ្ចេញពួកអ្នកពីភាពងងឹតទៅកាន់ពន្លឺ។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមេត្តាករុណា មហាអាណិតស្រលាញ់បំផុតចំពោះពួកអ្នក។

10. ហើយតើមានអ្វីដែលរារាំងពួកអ្នកមិនឱ្យបរិច្ចាគ(ទ្រព្យសម្បត្តិ)ក្នុងមាគ៌ារបស់អល់ឡោះ ខណៈដែលមរតកនៃមេឃជាច្រើនជាន់ និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះនោះ? មិនស្មើគ្នាឡើយចំពោះពួកអ្នក(ឱបណ្តាអ្នកដែលមានជំនឿ) អ្នកដែលបានបរិច្ចាគនិងបានប្រយុទ្ធមុនពេលរំដោះ(ទឹកដីម៉ាក្កះ)ហើយនិងអ្នកដែលបានបរិច្ចាគ និងបានប្រយុទ្ធបន្ទាប់ពីរំដោះ អ្នកទាំងនោះ មានឋានៈធំធេងជាងអ្នកដែលបានបរិច្ចាគ និងបានប្រយុទ្ធក្រោយពេលរំដោះ។ ហើយរាល់ក្រុមទាំងពីរ អល់ឡោះបានសន្យាផ្តល់នូវប្រការល្អ(ឋានសួគ៌)។ ហើយអល់ឡោះមហាដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

11. ជនណាហើយដែលបានឲ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ប្រសើរ ទ្រង់នឹងប្រទានទ្វេដងដល់រូបគេ ហើយសម្រាប់រូបគេនឹងទទួលបានផលបុណ្យដ៏ប្រពៃ(ឋានសួគ៌)។

12. នៅថ្ងៃដែលអ្នកនឹងឃើញបណ្តាអ្នកមានជំនឿប្រុសស្រី ពន្លឺរបស់ពួកគេភ្លឺចែងចាំងនៅខាងមុខពួកគេ និងនៅខាងស្តាំដៃពួកគេ។ (ហើយមានគេនិយាយទៅកាន់ពួកគេថា៖) ដំណឹងរីករាយរបស់ពួកអ្នកក្នុងថ្ងៃនេះ គឺ(ការចូល)ឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកអ្នកស្ថិតនៅក្នុងវាជាអមតៈ។ នោះហើយ គឺជាជោគជ័យដ៏ធំធេង។

13. នៅថ្ងៃដែលពួកពុតត្បុតប្រុសស្រីបាននិយាយទៅកាន់បណ្តាអ្នកមានជំនឿថា៖ សូមពួកអ្នករង់ចាំពួកយើងផង ដើម្បីពួកយើងអាចទទួលបានពន្លឺខ្លះពីពួកអ្នក។ មានគេនិយាយ(ចំអក)ថា៖ ចូរពួកអ្នកត្រលប់ក្រោយវិញ ហើយស្វែងរកពន្លឺ(ដោយខ្លួនឯង)ចុះ។ ហើយនៅពេលនោះ គេបានញែករវាងពួកគេ(និងបណ្តាអ្នកមានជំនឿ)ដោយរបងមួយដែលមានទ្វារ។ នៅខាងក្នុងវា(ប៉ែកខាងអ្នកមានជំនឿ) គឺមានក្តីមេត្តាករុណា។ ចំណែកឯផ្នែកខាងក្រៅវាដែលនៅខាងពួកពុតត្បុត គឺមានទណ្ឌកម្ម។

14. ពួកទាំងនោះបានស្រែកហៅពួកគេ(បណ្តាអ្នកមានជំនឿ)ថា៖ តើពួកយើងមិនធ្លាប់ស្ថិតនៅជាមួយពួកអ្នកទេឬ? ពួកគេបានតបវិញថា៖ ពិតមែនហើយ ក៏ប៉ុន្តែពួកអ្នកបានបំផ្លាញខ្លួនឯង ហើយពួកអ្នករង់ចាំ(ឱ្យបណ្តាអ្នកមានជំនឿទទួលបរាជ័យ) ព្រមទាំងពួកអ្នកមានការសង្ស័យ ហើយក្តីស្រមៃរបស់ពួកអ្នកបានបោកប្រាស់ពួកអ្នក រហូតដល់កិច្ចការរបស់អល់ឡោះបានមកដល់។ ហើយ(ស្មៃតន)បានបោកប្រាស់ពួកអ្នក(ឱ្យប្រាសចាកពី)អល់ឡោះ។

15. ដូច្នេះ នៅក្នុងថ្ងៃនេះ គេមិនទទួលយកការលោះពីពួកអ្នក និងពីពួកដែលប្រឆាំងនោះឡើយ។ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកអ្នក គឺឋាននរក។ វាគឺសក្តិសមបំផុតសម្រាប់ពួកអ្នក។ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

16. តើមិនទាន់ដល់ពេលទៀតឬសម្រាប់បណ្តាអ្នកដែលមានជំនឿដែលចិត្តរបស់ពួកគេទន់ភ្លន់ចំពោះការរំឭកទៅចំពោះអល់ឡោះ និងចំពោះសេចក្តីពិត(គម្ពីរគួរអាន)ដែលគេបានបញ្ចុះមក? ហើយកុំឱ្យពួកគេដូចទៅនឹងពួកដែលគេបានប្រទានគម្ពីរឲ្យកាលពីមុន(ពួកយូដានិងគ្រីស្ទាន)ដោយពេលវេលាដ៏យូរអង្វែងបានអូសបន្លាយលើពួកគេធ្វើឱ្យចិត្តរបស់ពួកគេប្រែជារឹងរូស។ ហើយភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស។

17. ចូរពួកអ្នកជ្រាបចុះថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ធ្វើឱ្យដីមានជីជាតិឡើងវិញ ក្រោយពីវាស្ងួតហួតហែង។ ប្រាកដណាស់ យើងបានបញ្ជាក់ដល់ពួកអ្នកនូវសញ្ញាកស្តុតាងជាច្រើន សង្ឃឹមថា ពួកអ្នកចេះគិតពិចារណា។

18. ប្រាកដណាស់ បណ្តាអ្នកដែលបរិច្ចាគទាន ទាំងប្រុសទាំងស្រី និងបានឲ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ប្រសើរ ទ្រង់នឹងប្រទានទ្វេដងដល់ពួកគេ ហើយសម្រាប់ពួកគេនឹងទទួលបានផលបុណ្យដ៏ប្រពៃ(ឋានសួគ៌)។

19. ហើយបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសារទាំងឡាយរបស់ទ្រង់ អ្នកទាំងនោះហើយគឺអ្នកសច្ចៈបំផុត។ ហើយបណ្តាអ្នកដែលពលីជីវិត(ក្នុងមាគ៌ាអល់ឡោះ) សម្រាប់ពួកគេនឹងទទួលបាននូវផលបុណ្យរបស់ពួកគេនៅឯព្រះជាម្ចាស់របស់ពួកគេ និងទទួលបានពន្លឺ(នៅថ្ងៃបរលោក)។ ហើយចំពោះពួកដែលគ្មានជំនឿ និងបានបដិសេធចំពោះសញ្ញាកស្តុតាងទាំងឡាយរបស់យើង ពួកទាំងនោះ គឺជាពួកនរកជើហ្មឹម។

20. ចូរពួកអ្នកជ្រាបចុះថា តាមពិត ឆាកជីវិតលោកិយ គ្រាន់តែជាលេងសើច ជាការកំសាន្ត និងជាការតុបតែងលម្អ ហើយនិងជាការអួតអាងគ្នារវាងពួកអ្នក ព្រមទាំងជាការបង្កើននូវទ្រព្យសម្បត្តិ និងកូនចៅប៉ុណ្ណោះ ប្រៀបដូចជាទឹកភ្លៀងដែលធ្វើឱ្យអ្នកដាំដុះទាំងឡាយមានក្តីរីករើបចំពោះដំណាំរបស់ខ្លួន។ ក្រោយមក វាក៏ប្រែទៅជាស្វិតស្រពោន ហើយអ្នកនឹងឃើញវាប្រែជាពណ៌លឿង។ រួចមកវាក៏ក្លាយជាកម្ទេចកម្ទីទៅវិញ។ ហើយនៅថ្ងៃបរលោក គឺមានទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត ហើយនិងមានការអភ័យទោស និងការពេញចិត្តពីអល់ឡោះ។ ហើយឆាកជីវិតលោកិយ គ្មានអ្វីក្រៅពីភាពត្រេកត្រអាលបោកបញ្ឆោតនោះឡើយ។

21. ចូរពួកអ្នកប្រណាំងប្រជែងគ្នាទៅកាន់ការអភ័យទោសពីព្រោះជាម្ចាស់របស់ពួកអ្នក និងទៅកាន់ឋានសួគ៌ដែលទទឹងរបស់វាប្រៀបដូចជាទទឹងមេឃនិងផែនដីដែលគេបានត្រៀមទុកសម្រាប់បណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសារទាំងឡាយរបស់ទ្រង់។ នោះគឺជាការប្រោសប្រទានរបស់អល់ឡោះដែលទ្រង់ប្រទានវាចំពោះជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាអ្នកដែលមានការប្រោសប្រទានដ៏ធំធេងបំផុត។

22. គ្មានគ្រោះណាមួយកើតមាននៅលើផែនដី ហើយក៏គ្មានគ្រោះណាមួយកើតមានក្នុងខ្លួនពួកអ្នកនោះឡើយ លើកលែងតែវាសុទ្ធតែ(ត្រូវបានគេកត់ត្រាទុក)នៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ះហ្វូស)មុនពេលដែលយើងបង្កើតវា។ ពិតប្រាកដណាស់ នោះគឺជារឿងងាយស្រួលបំផុតចំពោះអល់ឡោះ។

23. (ធ្វើដូច្នោះ) គឺដើម្បីកុំឱ្យពួកអ្នកមានទុក្ខព្រួយចំពោះអ្វីដែលបានបាត់បង់ពីពួកអ្នក និងដើម្បីកុំឱ្យពួកអ្នកសប្បាយហួសហេតុចំពោះអ្វីដែលទ្រង់បានប្រទានដល់ពួកអ្នក។ ហើយអល់ឡោះទ្រង់មិនស្រលាញ់រាល់ពួកដែលក្រអឺតក្រទម មានអំនួតក្អេងក្អាងឡើយ។

24. គឺពួកដែលកំណាញ់ និងបានប្រើមនុស្សលោកឱ្យកំណាញ់(ដូចខ្លួនដែរ)។ ជនណាហើយដែលងាកចេញ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ គឺជាម្ចាស់ដ៏មហាមានលើសលប់ ជាទីកោតសរសើរបំផុត។

25. ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នកនាំសារទាំងឡាយរបស់យើងដោយនាំមកនូវសញ្ញាកស្តុតាងយ៉ាងច្បាស់លាស់។ ហើយយើងបានបញ្ចុះមកជាមួយពួកគេនូវគម្ពីរ និងជញ្ជីងយុត្តិធម៌ដើម្បីឱ្យមនុស្សលោកមានទំនាក់ទំនងគ្នាដោយយុត្តិធម៌។ ហើយយើងបានបញ្ចុះដែកដែលវាមានភាពរឹងមាំបំផុត និងផ្តល់ជាប្រយោជន៍ជាច្រើនផងដែរសម្រាប់មនុស្ស។ ហើយនិងដើម្បីឱ្យអល់ឡោះដឹងថា តើជនណាដែលជួយដល់ទ្រង់ និងអ្នកនាំសារទាំងឡាយរបស់ទ្រង់ដោយកំបាំង។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងក្លា មហាខ្លាំងពូកែ។

26. ហើយពិតប្រាកដណាស់ យើងបានបញ្ជូនព្យាការីនូហ និងព្យាការីអ៊ីព្រហ៊ីម ហើយយើងបានប្រទាននូវភាពជាព្យាការី និងគម្ពីរដល់ពូជពង្សរបស់គេទាំងពីរ។ ក្នុងចំណោមពួកគេ គឺមានអ្នកដែលទទួលបានការចង្អុលបង្ហាញ។ តែភាគច្រើននៃពួកគេ ជាអ្នកដែលប្រព្រឹត្តល្មើស។

27. ក្រោយមក យើងបានបញ្ជូនអ្នកនាំសារជាច្រើនរបស់យើងជាបន្តបន្ទាប់នៅលើលំអានរបស់ពួកគេ។ ហើយយើងបានបញ្ជូនព្យាការីអ៊ីសា កូនប្រុសរបស់ម៉ារយ៉ាំ និងបានប្រទានដល់គេនូវគម្ពីរអ៊ិញជីល។ ហើយយើងបានដាក់ទៅក្នុងដួងចិត្តរបស់អ្នកដែលដើរតាមគេនូវក្តីអាណិតស្រលាញ់ និងក្តីមេត្តាករុណា។ តែពួកបុព្វជិត(របស់ពួកគេ)បានបង្កើតថ្មី(នូវភាពជ្រុលនិយមក្នុងការគោរពសក្ការៈ)នូវអ្វីដែលយើងមិនបានដាក់ជាកាតព្វកិច្ចលើពួកគេឡើយ ក្រៅតែពី(ពួកគេធ្វើដូច្នោះ)ដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះ។ ប៉ុន្តែពួកគេមិនបានអនុវត្តវាបានត្រឹមត្រូវនោះឡើយ។ ដូច្នេះ យើងក៏បានប្រទានឱ្យបណ្តាអ្នកដែលមានជំនឿក្នុងចំណោមពួកគេនូវផលបុណ្យរបស់ពួកគេ។ តែភាគច្រើននៃពួកគេ គឺជាពួកដែលប្រព្រឹត្តល្មើស។

28. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ ហើយចូរពួកអ្នកមានជំនឿចំពោះអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ចុះ នោះទ្រង់នឹងប្រទានឱ្យពួកអ្នកទ្វេដងដងអំពីក្តីមេត្តាករុណារបស់ទ្រង់ និងប្រទានឱ្យពួកអ្នកនូវពន្លឺដោយពួកអ្នកទទួលបានការចង្អុលបង្ហាញតាមរយៈវា ហើយទ្រង់នឹងអភ័យទោសដល់ពួកអ្នក។ ហើយអល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

29. (ធ្វើដូច្នោះ) គឺដើម្បីឱ្យពួកអះលីគីតាបបានដឹងថា ពិតប្រាកដណាស់ ពួកគេគ្មានសមត្ថភាពអ្វីបន្តិចណាឡើយទៅលើអ្វីមួយនៃការប្រោសប្រទានរបស់អល់ឡោះនោះ ហើយពិតប្រាកដណាស់ ការប្រោសប្រទាននោះ គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់អល់ឡោះជាម្ចាស់(តែមួយគត់)ដោយទ្រង់ប្រទានវាដល់ជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាអ្នកដែលមានការប្រោសប្រទានដ៏ធំធេងបំផុត។

ជំពូក អាល់មុជាឌីឡះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អល់ឡោះជាម្ចាស់ពិតបានស្តាប់ឮនូវសម្តីរបស់ស្ត្រីម្នាក់ដែលបានជជែកដេញដោលជាមួយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ក្នុងរឿងស្វាមីរបស់នាង ហើយនាងបានតួញត្អែរទៅកាន់អល់ឡោះ។ ហើយអល់ឡោះទ្រង់ឮបំផុតនូវការជជែកគ្នារវាងអ្នកទាំងពីរ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាឮ មហាឃើញបំផុត។

2. អ្នកដែលនិយាយ"ហ្សីហើរ"ចំពោះភរិយារបស់ខ្លួនក្នុងចំណោមពួកអ្នក គឺពួកនាង(ភរិយា) មិនមែនជាម្តាយរបស់ពួកគេឡើយ។ តាមពិតម្តាយរបស់ពួកគេ គឺអ្នកដែលបានប្រសូតពួកគេមក។ ពិតប្រាកដណាស់ ពួកគេពិតជានិយាយនូវពាក្យសម្តីដ៏អាក្រក់ និងកូតកុហកបំផុត។ ហើយពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ដែលមហាអធ្យាស្រ័យ មហាអភ័យទោសបំផុត។

3. អ្នកដែលនិយាយ"ហ្សីហើរ"ចំពោះភរិយារបស់ខ្លួន ក្រោយមក ពួកគេចង់លានូវពាក្យសម្តីដែលពួកគេបាននិយាយវិញ គឺគេត្រូវដោះលែងទាសីម្នាក់ឱ្យមានសេរីភាពមុនពេលដែលពួកគេចង់រួមដំណេកជាមួយគ្នា។ នោះជាអ្វីដែលគេផ្តល់ជំបូន្មាន ដល់ពួកអ្នក។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

4. ហើយជនណាដែលគ្មាន(ទាសីដោះលែង) គឺគេត្រូវបួសចំនួនពីរខែបន្តបន្ទាប់គ្នាមុនពេលដែលពួកគេចង់រួមដំណេកជាមួយគ្នា។ តែជនណាដែលគ្មានសមត្ថភាព គឺគេត្រូវផ្តល់អាហារដល់ជនក្រីក្រចំនួនហុកសិបនាក់។ នោះគឺដើម្បីឱ្យពួកអ្នកមានជំនឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ នោះហើយជាព្រំដែនច្បាប់របស់អល់ឡោះ។ ហើយសម្រាប់ពួកដែលប្រឆាំងនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

5. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ពួកគេនឹងត្រូវគេធ្វើឱ្យអាប់ឱន ដូចដែលអ្នកជំនាន់មុនពួកគេត្រូវបានគេធ្វើឲ្យអាប់ឱនដូច្នោះដែរ។ ហើយជាការពិតណាស់ យើងបានបញ្ចុះនូវសញ្ញាកស្តែងយ៉ាងច្បាស់លាស់ជាច្រើន។ ហើយសម្រាប់ពួកដែលប្រឆាំងនឹងទទួលនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

6. គឺនៅថ្ងៃដែលអល់ឡោះទ្រង់ឲ្យពួកគេរស់ឡើងវិញទាំងអស់គ្នា។ ពេលនោះ ទ្រង់នឹងប្រាប់ពួកគេពីអ្វីដែលពួកគេបានប្រព្រឹត្ត។ អល់ឡោះទ្រង់បានកត់ត្រាវាទុក តែពួកគេបានភ្លេចវា។ ហើយអល់ឡោះជាសាក្សីលើរាល់អ្វីៗទាំងអស់។

7. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬ ពិតប្រាកដណាស់ អល់ឡោះដឹងនូវអ្វីៗដែលមាននៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលមាននៅលើផែនដីនោះ? គ្មានការខ្សឹបខ្សៀវគ្នាស្ងាត់ៗណាមួយរបស់បុគ្គលបីនាក់ឡើយ លើកលែងតែមានទ្រង់ជាអ្នកទីបួននៃពួកគេ។ ហើយក៏គ្មានការខ្សឹបខ្សៀវគ្នាស្ងាត់ៗណាមួយរបស់បុគ្គលប្រាំនាក់នោះដែរ លើកលែងតែមានទ្រង់ជាអ្នកទីប្រាំមួយនៃពួកគេ។ ហើយទោះជា(ពួកគេ)មានគ្នាតិចជាងនេះ ឬច្រើនជាងនេះក៏ដោយ ក៏មានទ្រង់នៅជាមួយពួកគេជានិច្ច ទោះបីជាពួកគេស្ថិតនៅទីណាក៏ដោយ។ បន្ទាប់មក នៅថ្ងៃបរលោក ទ្រង់នឹងប្រាប់ពួកគេនូវអ្វីដែលពួកគេបានប្រព្រឹត្ត។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

8. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬចំពោះពួក(យូដា)ដែលត្រូវបានគេហាមឃាត់មិនឲ្យខ្សឹបខ្សៀវគ្នាក្រោយមក ពួកគេបែរជាត្រឡប់ទៅរកអ្វីដែលគេបានហាមឃាត់នោះទៅវិញ ហើយពួកគេបានខ្សឹបខ្សៀវគ្នាពីប្រការដែលនាំឲ្យមានបាប ភាពជាសត្រូវ និងការប្រឆាំងនឹងអ្នកនាំសារ។ ហើយនៅពេលពួកគេមកជួបអ្នក ពួកគេស្វាគមន៍អ្នកនឹងពាក្យដែលអល់ឡោះមិនបានស្វាគមន៍អ្នកនឹងវាឡើយ។ ហើយពួកគេបាននិយាយគ្នាថា៖ ហេតុអ្វីបានជាអល់ឡោះទ្រង់មិនដាក់ទណ្ឌកម្មពួកយើងចំពោះអ្វីដែលពួកយើងនិយាយ? គ្រប់គ្រាន់ហើយសម្រាប់ពួកគេនូវនរកដើហាន់ណាំដែលពួកគេត្រូវចូលនោះ។ ពិតណាស់ វាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

9. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលពួកអ្នកខ្សឹបខ្សៀវគ្នា ចូរពួកអ្នកកុំខ្សឹបខ្សៀវគ្នាពីប្រការដែលនាំឲ្យមានបាបភាពជាសត្រូវ និងការប្រឆាំងនឹងអ្នកនាំសារឱ្យសោះ។ តែពួកអ្នកត្រូវខ្សឹបខ្សៀវគ្នាពីប្រការល្អ និងការកោតខ្លាច។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះដែលពួកអ្នកនឹងត្រូវគេប្រមូលផ្តុំទៅកាន់ទ្រង់(នៅថ្ងៃបរលោក)។

10. តាមពិត ការខ្សឹបខ្សៀវគ្នាស្ងាត់ៗ គឺមកពីស្មែតនដើម្បីឱ្យអ្នកមានជំនឿទាំងឡាយមានទុក្ខព្រួយ។ តែវាមិនអាចបង្កគ្រោះថ្នាក់អ្វីបន្តិចដល់ពួកគេ(បណ្តាអ្នកដែលមានជំនឿ)បានឡើយ លើកលែងតែអ្វីដែលអល់ឡោះទ្រង់អនុញ្ញាតប៉ុណ្ណោះ។ ហើយចូរឱ្យបណ្តាអ្នកមានជំនឿទាំងឡាយប្រគល់ការទុកចិត្តលើអល់ឡោះ(តែមួយគត់)។

11. ឱបណ្តាអ្នកដែលមានជំនឿ! កាលណាមានគេនិយាយទៅកាន់ពួកអ្នកថា៖ "សូមពួកអ្នកសម្រួលកន្លែងអង្គុយឱ្យទូលាយ" ចូរពួកអ្នកសម្រួល(ឲ្យពួកគេ)ចុះ នោះអល់ឡោះជាម្ចាស់នឹងសម្រួលឱ្យទូលាយដល់ពួកអ្នកវិញ។ ហើយបើសិនជាមានគេនិយាយ(មកកាន់ពួកអ្នក)ថា៖ "សូមពួកអ្នកងើបចេញ" ចូរពួកអ្នកងើបចេញ(ពីកន្លែងនោះ)ចុះ។ អល់ឡោះទ្រង់លើកឋានៈបណ្តាអ្នកដែលមានជំនឿក្នុងចំណោមពួកអ្នក និងបណ្តាអ្នកដែលត្រូវបានគេផ្តល់ចំណេះដឹងឱ្យនូវឋានៈ(ដ៏ខ្ពង់ខ្ពស់)ជាច្រើន។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

12. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលណាដែលពួកអ្នកចង់ពិភាក្សារឿងសម្ងាត់ជាមួយអ្នកនាំសារ(មូហាំម៉ាត់)នោះ ចូរពួកអ្នកបរិច្ចាគទានជាមុនសិនមុននឹងពួកអ្នកពិភាក្សារឿងសម្ងាត់នោះ។ នោះគឺជាការប្រសើរ និងស្អាតស្អំបំផុតសម្រាប់ពួកអ្នក។ តែប្រសិនបើពួកអ្នកគ្មាន(អ្វីនឹងបរិច្ចាគ)ទេនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

13. តើពួកអ្នកខ្លាចក្រែងតែការបរិច្ចាគទានមុននឹងពួកអ្នកពិភាក្សារឿងសម្ងាត់(ជាមួយអ្នកនាំសារ)នោះឬ? ពិតប្រាកដណាស់ ប្រសិនបើពួកអ្នកមិនធ្វើ(ដូចនោះ) ហើយអល់ឡោះទ្រង់ទទួលយកការសារភាពកំហុសរបស់ពួកអ្នក ដូច្នេះចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ហើយនិងគោរពប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ចុះ។ ហើយអល់ឡោះជាម្ចាស់មហាដឹងបំផុតចំពោះអ្វីដែលពួកអ្នកប្រព្រឹត្ត។

14. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬ ពួក(ពុតត្បុត)ដែលបានចងសម្ព័ន្ធមិត្តជាមួយនឹងក្រុមមួយ(ពួកយូដា)ដែលអល់ឡោះខឹងសម្បាចំពោះពួកគេ? ពួកទាំងនោះ មិនស្ថិតក្នុងចំណោមពួកអ្នកឡើយ ហើយក៏មិនស្ថិតក្នុងចំណោមពួកគេ(ពួកយូដា)នោះដែរ។ ហើយពួកគេបានស្បថទាំងភូតកុហក ខណៈដែលពួកគេបានដឹង។

15. អល់ឡោះជាម្ចាស់ទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។ ជាការពិតណាស់ ទង្វើដែលពួកគេធ្លាប់បានប្រព្រឹត្ត គឺអាក្រក់បំផុត។

16. ពួកគេបានយកការស្បថកុហករបស់ពួកគេធ្វើជាខែលការពារ ហើយពួកគេបានរារាំងពីមាគ៌ារបស់អល់ឡោះ។ ដូចនេះសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏អាម៉ាស់បំផុត។

17. ទ្រព្យសម្បត្តិនិងកូនចៅរបស់ពួកគេមិនអាចការពារពួកគេពី(ទណ្ឌកម្ម)អល់ឡោះបន្តិចណាឡើយ។ ពួកទាំងនោះ គឺជាពួកឋាននរក។ ពួកគេស្ថិតនៅក្នុងវាជាអមតៈ។

18. នៅថ្ងៃដែលអល់ឡោះបង្កើតពួកគេឱ្យរស់ឡើងវិញទាំងអស់គ្នា ពេលនោះ ពួកគេស្បថចំពោះទ្រង់ ដូចដែលពួកគេបានស្បថ(កុហក)ចំពោះពួកអ្នកដូច្នោះដែរ។ ហើយពួកគេគិតស្មានថា ពិតប្រាកដណាស់ ពួកគេអាចនឹងទទួលបានផលប្រយោជន៍(ពីការស្បថនោះ)។ តើពុំមែនទេឬ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។

19. ស្មែតនបានគ្របដណ្តប់លើពួកគេដែលជាហេតុធ្វើឱ្យពួកគេភ្លេចពីការរំឭកចំពោះអល់ឡោះ។ ពួកទាំងនោះហើយ គឺជាក្រុមរបស់ស្មែតន។ តើពុំមែនទេឬ ក្រុមរបស់ស្មែតននោះ គឺជាពួកដែលខាតបង់បំផុត។

20. ពិតប្រាកដណាស់ ពួកដែលប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ពួកទាំងនោះ គឺស្ថិតក្នុងភាពអាប់ឱនបំផុត។

21. អល់ឡោះបានកត់ត្រារួចទៅហើយថា៖ យើង និងបណ្តាអ្នកនាំសាររបស់យើង ពិតជានឹងទទួលបានជ័យជម្នះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាខ្លាំងក្លា មហាខ្លាំងពូកែ។

22. អ្នកនឹងមិនជួបប្រទះនោះឡើយនូវក្រុមមួយដែលមានជំនឿលើអល់ឡោះនិងថ្ងៃបរលោកដែលស្រឡាញ់ពេញចិត្តពួកដែលប្រឆាំងនឹងអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់នោះ ទោះបីជាអ្នកទាំងនោះជាឪពុករបស់ពួកគេ ឬជាកូនរបស់ពួកគេ ឬជាបងប្អូនរបស់ពួកគេ ឬជាសាច់ញាតិរបស់ពួកគេក៏ដោយ។ អ្នកទាំងនោះហើយជាអ្នកដែលអល់ឡោះបានពង្រឹងនូវសេចក្តីជំនឿនៅក្នុងដួងចិត្តរបស់ពួកគេ និងធ្វើឱ្យពួកគេកាន់តែមានភាពរឹងមាំថែមទៀតតាមរយៈជំនួយពីទ្រង់។ ហើយទ្រង់នឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវាដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ អល់ឡោះទ្រង់ពេញចិត្តចំពោះពួកគេ ហើយពួកគេក៏ពេញចិត្តទ្រង់វិញដែរ។ អ្នកទាំងនោះហើយ គឺជាក្រុមរបស់អល់ឡោះ។ តើពុំមែនទេឬ ពិតប្រាកដណាស់ ក្រុមរបស់អល់ឡោះនោះ ពួកគេគឺជាអ្នកដែលទទួលជោគជ័យ។

ជំពូក អាល់ហាស្ហរ៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដីបានលើកតម្កើងចំពោះអល់ឡោះជាម្ចាស់។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

2. ទ្រង់ជាអ្នកដែលបានបណ្តេញពួកប្រឆាំងនៃពួកអះលីគីតាប(អម្បុរណាហ្ស៊ៀរ)ពីលំនៅឋានរបស់ពួកគេដែលជាការបណ្តេញចេញដំបូងគេបង្អស់។ ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)មិនធ្លាប់គិតទេថា ពួកគេនឹងចាកចេញនោះ។ ហើយពួកគេគិតថា៖ ពិតប្រាកដណាស់ បន្ទាយរបស់ពួកគេអាចការពារពួកគេពី(ទណ្ឌកម្ម)អល់ឡោះបាន។ ក៏ប៉ុន្តែ (កិច្ចការរបស់)អល់ឡោះបានមកដល់ពួកគេទាំងដែលពួកគេមិននឹកស្មានដល់។ ហើយទ្រង់បានបញ្ចូលនូវភាពភ័យរន្ធត់ទៅក្នុងដួងចិត្តរបស់ពួកគេ។ ពួកគេបានកម្ទេចលំនៅឋានរបស់ពួកគេដោយផ្ទាល់ដៃរបស់ពួកគេ និងដោយស្នាដៃបណ្តាអ្នកដែលមានជំនឿ។ ដូច្នេះ ចូរពួកអ្នកយកជាមេរៀនចុះ ឱអ្នកដែលមានការឈ្វេងយល់ទាំងឡាយ។

3. ហើយប្រសិនបើអល់ឡោះមិនកំណត់លើពួកគេឱ្យចាកចេញទេនោះ ទ្រង់ពិតជានឹងដាក់ទណ្ឌកម្មពួកគេក្នុងលោកិយជាមិនខាន។ ហើយនៅថ្ងៃបរលោកវិញ ពួកគេនឹងទទួលទណ្ឌកម្មនៃភ្លើងនរក។

4. នោះគឺដោយសារតែពួកគេបានប្រព្រឹត្តល្មើសនឹង(បទបញ្ជា)អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ ហើយជនណាដែលបានប្រព្រឹត្តល្មើសនឹងអល់ឡោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

5. ដើមល្មើដែលពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)បានកាប់រំលំ ឬក៏ពួកអ្នកទុកវាឱ្យឈរនៅនឹងគល់របស់វាដដែល គឺដោយការអនុញ្ញាតពីអល់ឡោះទាំងអស់ និងដើម្បីទ្រង់ធ្វើឱ្យពួកដែលប្រព្រឹត្តល្មើសទទួលនូវភាពអាម៉ាស់បំផុត។

6. ហើយអ្វីដែលអល់ឡោះបានប្រគល់ទៅឱ្យអ្នកនាំសាររបស់ទ្រង់អំពី(ទ្រព្យសម្បត្តិ)ពួកគេនោះ គឺពួកអ្នកមិនបានចំណាយសេះមួយក្បាល ឬសត្វអូដ្ឋមួយក្បាល(ទៅច្បាំងយកវា)នោះឡើយ។ ក៏ប៉ុន្តែអល់ឡោះទ្រង់ផ្តល់អំណាចដល់អ្នកនាំសារទាំងឡាយរបស់ទ្រង់ឱ្យយកឈ្នះទៅលើជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះជាម្ចាស់ទ្រង់មានមហាអានុភាពលើអ្វីៗទាំងអស់។

7. ហើយអ្វីដែលអល់ឡោះបានប្រគល់ទៅឱ្យអ្នកនាំសាររបស់ទ្រង់អំពី(ទ្រព្យសម្បត្តិ)អ្នកស្រុកភូមិនោះវា(ជាចំណែក)សម្រាប់អល់ឡោះ សម្រាប់អ្នកនាំសារ(មូហាំម៉ាត់) សម្រាប់សាច់ញាតិ(របស់អ្នកនាំសារ) សម្រាប់ក្មេងកំព្រា ជនក្រីក្រ និងអ្នកដំណើរជាច់ស្បៀង។ ហើយអ្វីដែលអ្នកនាំសារ(មូហាំម៉ាត់)បាននាំមក ចូរពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ទទួលយកវា។ ហើយអ្វីដែលគាត់ហាមឃាត់ពួកអ្នកអំពីវា ចូរពួកអ្នកបញ្ឈប់។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះគឺជាអ្នកដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

8. (ហើយទ្រព្យសម្បត្តិនោះផងដែរ) គឺសម្រាប់ជនក្រីក្រនៃពួកមូហាជីរីនដែលពួកគេត្រូវបានគេបណ្តេញចេញពីលំនៅឋានរបស់ពួកគេ និងទ្រព្យសម្បត្តិរបស់ពួកគេ ដោយស្វែងរកការប្រោសប្រទានពីអល់ឡោះ និងការពេញចិត្ត(ពីទ្រង់) ហើយពួកគេបានជួយដល់(សាសនារបស់)អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់។ អ្នកទាំងនោះហើយ គឺជាអ្នកដែលទៀងត្រង់។

9. ចំណែកឯអ្នកដែលរស់នៅក្នុងក្រុងម៉ាទីណៈ និងមានជំនឿមុននឹងពួកមូហាជីរីន(ភៀសខ្លួនមក) គឺពួកគេស្រលាញ់អ្នកដែលបានភៀសខ្លួនមកកាន់ពួកគេ ហើយនៅក្នុងដួងចិត្តរបស់ពួកគេពុំមានភាពច្រណែនឈ្នានីសចំពោះអ្វីដែលគេបានផ្តល់ឲ្យពួកមូហាជីរីននោះឡើយ ហើយពួកគេចែមទាំងគិតគូដល់ពួកមូហាជីរីនមុនខ្លួនឯងទៅទៀត ទោះបីជាពួកគេមានតម្រូវការក៏ដោយ។ ហើយជនណាដែលជម្រះភាពកំណាញ់ចេញពីខ្លួនរបស់គេ អ្នកទាំងនោះហើយ គឺជាអ្នកដែលទទួលបានជោគជ័យ។

10. ហើយអ្នក(ជំនាន់ក្រោយ)ដែលមកដល់បន្ទាប់ពីពួក(មូហាជីរីន និងពួកអាន់សារ៍)ទាំងនោះ ពួកគេបានបួងសួងថាៈ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំ និងបងប្អូនរបស់យើងខ្ញុំដែលមានជំនឿមុនយើងខ្ញុំផង ហើយសូមព្រះអង្គមេត្តាកុំធ្វើឱ្យចិត្តរបស់យើងខ្ញុំមានភាពច្រណែនឈ្នានីសចំពោះបណ្តាអ្នកដែលមានជំនឿ។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ ព្រះអង្គមហាមេត្តាករុណា មហាអាណិតស្រលាញ់។

11. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញពួកពុតត្បុតទេឬ ដែលពួកគេបាននិយាយទៅកាន់បងប្អូនរបស់ពួកគេដែលជាពួកប្រឆាំងក្នុងចំណោមពួកអះលីគីតាប(អម្ប្រាណាហ្ស៊ៀរ)ថាៈ ប្រសិនបើពួកអ្នកត្រូវបានគេបណ្តេញចេញ ពួកយើងប្រាកដជានឹងចាកចេញជាមួយពួកអ្នកដែរ។ ហើយពួកយើងមិនធ្វើតាមនរណាម្នាក់ជាដាច់ខាតក្នុងរឿងរបស់ពួកអ្នក។ ហើយប្រសិនបើមានគេប្រយុទ្ធនឹងពួកអ្នក ពួកយើងប្រាកដជានឹងជួយពួកអ្នកជាមិនខាន។ តែអល់ឡោះទ្រង់ធ្វើសាក្សីថាៈ ពិតប្រាកដណាស់ ពួកគេគឺជាពួកដែលភូតកុហក។

12. ប្រសិនបើគេបណ្តេញពួកទាំងនោះចេញ ពួកគេនឹងមិនចាកចេញជាមួយពួកទាំងនោះឡើយ។ ប្រសិនបើមានគេប្រយុទ្ធនឹងពួកទាំងនោះ ក៏ពួកគេមិនជួយពួកទាំងនោះដែរ។ ហើយបើទោះជាពួកគេទៅជួយពួកទាំងនោះក៏ដោយ ក៏ពួកគេពិតជានឹងត្រឡប់ក្រោយជាមិនខាន។ បន្ទាប់មក ពួកគេនឹងមិនត្រូវបានគេជួយឡើយ។

13. ពិតប្រាកដណាស់ នៅក្នុងចិត្តរបស់ពួកគេ(ពួកពុតត្បុតនិងពួកយូដា) គឺពួកគេខ្លាចពួកអ្នក(បណ្តាអ្នកមានជំនឿ)ខ្លាំងជាងខ្លាចអល់ឡោះជាម្ចាស់ទៅទៀត។ នោះគឺដោយសារពួកគេជាក្រុមមួយដែលពុំមានការឈ្វេងយល់ឡើយ។

14. ពួកគេ(ពួកយូដា)មិនហ៊ានប្រយុទ្ធនឹងពួកអ្នកទាំងអស់គ្នាឡើយ លើកលែងតែនៅក្នុងភូមិស្រុកដែលមានកំពែងការពារឬក៏ពីក្រោយជញ្ជាំងប៉ុណ្ណោះ។ ភាពជាសត្រូវរវាងពួកគេ គឺខ្លាំងក្លាបំផុត។ អ្នកគិតស្មានថា ពួកគេរួបរួមគ្នា។ តែ(តាមពិត)ដួងចិត្តរបស់ពួកគេ គឺផ្សេងៗពីគ្នា។ នោះគឺដោយសារតែពួកគេគឺជាក្រុមមួយដែលមិនចេះពិចារណាឡើយ។

15. (ពួកយូដាទាំងនោះ)គឺដូចជាពួក(មុស្ហរីគីន)មុនពួកគេបន្តិចនោះដែរ។ ពួកគេ(ពួកមុស្ហរីគីន)បានភ្លក់នូវលទ្ធផលចុងក្រោយរបស់ពួកគេដ៏អាក្រក់បំផុត។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏ឈឺចាប់បំផុត។

16. (ពួកពុតត្បុត)គឺដូចជាស្មៃតនដែរ ខណៈដែលវាបាននិយាយទៅកាន់មនុស្សលោកថាៈ ចូរអ្នកប្រឆាំងចុះ។ លុះពេលដែលគេបានប្រឆាំង វាបែរជានិយាយថាៈ ខ្ញុំមិនពាក់ព័ន្ធអ្វីនឹងអ្នកឡើយ។ ប្រាកដណាស់ ខ្ញុំខ្លាចអល់ឡោះដែលជាព្រះជាម្ចាស់នៃពិភពទាំងអស់។

17. លទ្ធផលចុងក្រោយរបស់គេទាំងពីរ(ស្មៃតននិងអ្នកដែលតាមវា) គឺគេទាំងពីរនឹងស្ថិតនៅក្នុងឋាននរក ដោយត្រូវស្ថិតនៅក្នុងវាជាអមតៈ។ នោះហើយជាការតបស្នងចំពោះពួកដែលបំពាន។

18. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកោតខ្លាចអល់ឡោះ ហើយចូរឱ្យបុគ្គលគ្រប់រូបពិនិត្យមើលចំពោះអ្វីដែលគេបានសាងទុកសម្រាប់ថ្ងៃស្អែក(ថ្ងៃបរលោក)។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

19. ហើយចូរពួកអ្នក(អ្នកមានជំនឿ)កុំធ្វើដូចពួកដែលបានភ្លេចអល់ឡោះ។ ពេលនោះ អល់ឡោះបានធ្វើឱ្យពួកគេភ្លេចខ្លួនឯងវិញ។ ពួកទាំងនោះហើយ គឺជាពួកដែលប្រព្រឹត្តល្មើស។

20. មិនស្មើគ្នាឡើយ(រវាង)ពួកឋានរកនិងបណ្តាអ្នកឋានសួគ៌នោះ។បណ្តាអ្នកឋានសួគ៌ពួកគេគឺជាអ្នកដែលទទួលជោគជ័យ។

21. ប្រសិនបើយើងបញ្ចុះគម្ពីរគួរអាននេះទៅលើភ្នំណាមួយ នោះអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពិតជានឹងឃើញវាឱនលំទោននិងបែកជាបំណែកដោយសារតែការខ្លាចអល់ឡោះ។ ទាំងនោះជាឧទាហរណ៍ដែលយើងបានលើកឡើងសម្រាប់មនុស្សលោក សង្ឃឹមថាពួកគេត្រិះរិះពិចារណា។

22. ទ្រង់គឺអល់ឡោះជាម្ចាស់ដែលគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ជាអ្នកដឹងបំផុតពីប្រការអោថ៌កំបាំង និងអ្វីដែលលាតត្រដាង។ ទ្រង់មហាសប្បុរស មហាអាណិតស្រលាញ់។

23. ទ្រង់គឺអល់ឡោះជាម្ចាស់ដែលគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ ជាស្តេចគ្រប់គ្រង ជាអ្នកមហាបរិសុទ្ធ មហាស្អាតស្អំ ជាអ្នកដែលបញ្ជាក់ពីសច្ចភាព ជាអ្នកឃ្លាំមើល មហាខ្លាំងពូកែ មានអំណាចផ្តាច់មុខ និងអំណាចមហិមា។ ទ្រង់មហាបរិសុទ្ធពីអ្វីដែលពួកគេធ្វើស្តីរិក។

24. ទ្រង់គឺអល់ឡោះជាម្ចាស់ដែលជាអ្នកបង្កើត ជាអ្នកធ្វើឱ្យអ្វីៗទាំងអស់មានវត្តមាន ជាអ្នកផ្តល់រូបរាង(ដល់សព្វភាវៈទាំងអស់)។ ទ្រង់មានព្រះនាមដ៏ល្អប្រពៃជាច្រើន។ អ្វីៗដែលនៅលើមេឃជាច្រើនជាន់និងផែនដីបានលើកតម្កើងទ្រង់។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

ជំពូក អាល់មុមតាហ៊ីណះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកសត្រូវរបស់យើងនិងសត្រូវរបស់ពួកអ្នក ធ្វើជាអ្នកគាំពារដោយពួកអ្នកផ្តល់ការស្រលាញ់ទៅកាន់ពួកគេឱ្យសោះ ខណៈដែលពួកគេបានប្រឆាំងនឹងសេចក្តីពិតដែលបានមកដល់ពួកអ្នក។ ពួកគេបានបណ្តេញអ្នកនាំសារ(មូហាំម៉ាត់) និងពួកអ្នក(ពីទឹកដីម៉ាក្កៈ) ដោយសារតែពួកអ្នកមានជំនឿចំពោះអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក ប្រសិនបើពួកអ្នកចាកចេញដើម្បីតស៊ូក្នុងមាគ៌ារបស់យើង និងស្វែងរកការពេញចិត្តពីយើងនោះ។ ពួកអ្នកបានផ្តល់ការស្រឡាញ់ទៅកាន់ពួកគេដោយលាក់បាំង ខណៈដែលយើងដឹងបំផុតនូវអ្វីដែលពួកអ្នកលាក់បាំងនិងអ្វីដែលពួកអ្នកលាតត្រដាង។ ជនណាហើយដែលបានធ្វើដូច្នោះក្នុងចំណោមពួកអ្នក ពិតប្រាកដណាស់ រូបគេពិតជាបានវង្វេងចេញពីមាគ៌ាដែលត្រឹមត្រូវហើយ។

2. ប្រសិនបើពួកគេមានអំណាចលើពួកអ្នកវិញ ពួកគេនឹងក្លាយជាសត្រូវសម្រាប់ពួកអ្នក ហើយពួកគេនឹងលើកដៃរបស់ពួកគេនិងអណ្តាតរបស់ពួកគេមករកពួកអ្នកដោយប្រការអាក្រក់ ហើយពួកគេប្រាថ្នាចង់ឱ្យពួកអ្នកប្រឆាំង(ដូចពួកគេដែរ)។

3. ញាតិសណ្តានរបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នក មិនអាចជួយជាប្រយោជន៍អ្វីដល់ពួកអ្នកឡើយ។ នៅថ្ងៃបរលោកទ្រង់នឹងបំបែកវាងពួកអ្នក។ ហើយអល់ឡោះមហាឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

4. ជាការពិតណាស់ ព្យាការីអ៊ីព្រហ៊ីម និងអ្នកដែលនៅជាមួយគាត់ គឺជាគំរូដ៏ល្អសម្រាប់ពួកអ្នក(ឱបណ្តាអ្នកមានជំនឿ) ខណៈពេលដែលពួកគេបានពោលទៅកាន់ក្រុមរបស់ពួកគេថា៖ ពិតប្រាកដណាស់ ពួកយើងមិនពាក់ព័ន្ធនឹងពួកអ្នក និងអ្វីដែលពួកអ្នកគោរពសក្ការៈផ្សេងពីអល់ឡោះឡើយ ដោយពួកយើងប្រឆាំងនឹងពួកអ្នក។ ហើយវាបង្ហាញឱ្យឃើញថាវាងពួកយើងនិងពួកអ្នក គឺជាសត្រូវនឹងគ្នា និងស្អប់ខ្ពើមគ្នាជាដរាប រហូតទាល់តែពួកអ្នកមានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់ លើកលែងតែពាក្យសម្តីរបស់ព្យាការីអ៊ីព្រហ៊ីមប៉ុណ្ណោះដែលគាត់បាននិយាយទៅកាន់ឪពុករបស់គាត់ថា៖ ខ្ញុំនឹងសុំការអភ័យទោស(ពីអល់ឡោះ)ជំនួសអ្នក។ ហើយខ្ញុំមិនមានអំណាចអ្វីអាចការពារអ្នកពី(ទណ្ឌកម្ម)អល់ឡោះបន្តិចណាឡើយ។ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ចំពោះព្រះអង្គ(តែមួយគត់)ដែលយើងខ្ញុំប្រគល់ការទុកចិត្ត ទៅកាន់ព្រះអង្គដែលយើងខ្ញុំសារភាពកំហុស ហើយកន្លែងវិលត្រឡប់(របស់យើងខ្ញុំ) គឺទៅកាន់ព្រះអង្គ(តែមួយគត់)។

5. បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាកុំធ្វើឱ្យយើងខ្ញុំក្លាយជាការសោកល្បងចំពោះពួកគ្មានជំនឿ។ ហើយសូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំផងចុះ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! ពិតប្រាកដណាស់ ព្រះអង្គមហាខ្លាំងពូកែមហាគតិបណ្ឌិត។

6. ពិតប្រាកដណាស់ នៅក្នុងរឿងរបស់ពួកគេ គឺជាគំរូដ៏ល្អមួយសម្រាប់ពួកអ្នក ចំពោះជនណាដែលរំពឹង(ផលបុណ្យពី)អល់ឡោះ និងថ្ងៃបរលោក។ រីឯជនណាហើយបែរចេញ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់ ជាទីកោតសរសើរបំផុត។

7. សង្ឃឹមថាអល់ឡោះជាម្ចាស់នឹងធ្វើឱ្យពួកអ្នក(បណ្តាអ្នកមានជំនឿ) ហើយនិងពួកដែលពួកអ្នកចងសត្រូវជាមួយក្នុងចំណោមពួកគេមានក្តីស្រលាញ់(ចំពោះគ្នាវិញ)។ ហើយអល់ឡោះមានមហាអានុភាពបំផុត។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

8. អល់ឡោះជាម្ចាស់មិនបានហាមឃាត់ពួកអ្នកនោះទេក្នុងការធ្វើល្អ និងផ្តល់ភាពយុត្តិធម៌ដល់ពួកដែលមិនបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកក្នុងសាសនា និងមិនបានបណ្តេញពួកអ្នកចេញពីលំនៅឋានរបស់ពួកអ្នកទេនោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់បណ្តាអ្នកដែលប្រកាន់នូវភាពយុត្តិធម៌។

9. តាមពិត អល់ឡោះទ្រង់ហាមឃាត់ពួកអ្នកមិនឱ្យចងសម្ព័ន្ធភាពតែជាមួយពួកដែលបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកក្នុងសាសនា និងបានបណ្តេញពួកអ្នកចេញពីលំនៅឋានរបស់ពួកអ្នក ហើយនិងគាំទ្រក្នុងការបណ្តេញពួកអ្នកប៉ុណ្ណោះ។ ជនណាហើយដែលបានចងសម្ព័ន្ធភាពជាមួយពួកទាំងនោះ ពិតប្រាកដណាស់ ពួកទាំងនោះហើយ គឺជាពួកដែលបំពាន។

10. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលមានបណ្តាស្ត្រីមានជំនឿដែលជាអ្នកភៀសខ្លួនបានមកដល់ពួកអ្នក ចូរពួកអ្នកសាកល្បងពួកនាងចុះ។ អល់ឡោះទ្រង់ដឹងបំផុតចំពោះសេចក្តីជំនឿរបស់ពួកនាង។ ប្រសិនបើពួកអ្នកបានដឹងថា ពួកនាងគឺជាអ្នកដែលមានជំនឿ ចូរពួកអ្នកកុំបញ្ជូនពួកនាងត្រឡប់ទៅកាន់(ស្វាមីពួកនាងដែលជា)ពួកគ្មានជំនឿវិញឱ្យសោះ។ ពួកនាងមិនត្រូវបានអនុញ្ញាតសម្រាប់ពួកគេនោះឡើយ ហើយពួកគេក៏មិនត្រូវបានអនុញ្ញាតសម្រាប់ពួកនាងនោះដែរ។ ហើយចូរពួកអ្នកផ្តល់ឱ្យពួកគេ(ស្វាមីរបស់ពួកនាងដែលគ្មានជំនឿ)នូវអ្វីដែលពួកគេបានចំណាយ(អំពីប្រាក់ខាន់ស្លា)។ ហើយគ្មានទោសពៃរ៍អ្វីឡើយចំពោះពួកអ្នក(ឱបណ្តាអ្នកមានជំនឿ)ដែលពួកអ្នករៀបការជាមួយនឹងពួកនាង នៅពេលណាដែលពួកអ្នកបានផ្តល់ប្រាក់ខាន់ស្លាដល់ពួកនាងហើយនោះ។ ហើយពួកអ្នកមិនត្រូវបន្តរួមរស់ជាមួយភរិយាដែលគ្មានជំនឿនោះឡើយ។ ហើយចូរពួកអ្នកទាមទារមកវិញនូវអ្វីដែលពួកអ្នកបានចំណាយ(ជាខាន់ស្លាចំពោះពួកនាង)។ ហើយចូរឱ្យពួកគេ(ពួកគ្មានជំនឿ)ទាមទារមកវិញដូចគ្នានូវអ្វីដែលពួកគេបានចំណាយ(អំពីខាន់ស្លា)។ នោះគឺជាក្បួនច្បាប់របស់អល់ឡោះដែលទ្រង់កាត់សេចក្តីរវាងពួកអ្នក។ ហើយអល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិត។

11. ហើយប្រសិនបើពួកអ្នកមិនទទួលបានអ្វីមួយ(ខាន់ស្លា)ពីភរិយារបស់ពួកអ្នកមួយចំនួនដែលបានរំលែកត្រលប់ទៅកាន់ភាពគ្មានជំនឿវិញ ដូច្នេះ នៅពេលដែលពួកអ្នកទទួលជ័យជម្នះ គឺពួកអ្នកត្រូវផ្តល់ឱ្យអ្នកដែលភរិយារបស់គេរំលែកទៅរកភាពគ្មានជំនឿនោះ(ពីទ្រព្យជ័យកណ្ឌ) ដូចទៅនឹងអ្វីដែលពួកគេបានចំណាយ(ជាខាន់ស្លាលើពួកនាង)។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះជាម្ចាស់ ក្នុងនាមជាអ្នកដែលមានជំនឿលើទ្រង់។

12. ឱព្យាការី(មូហាំម៉ាត់)! នៅពេលដែលបណ្តាស្ត្រីដែលមានជំនឿបានមកកាន់អ្នកដោយពួកនាងសច្ចាប្រណិធានឹងអ្នកថា ពួកនាងនឹងមិនធ្វើស្ថិកនឹងអល់ឡោះនូវអ្វីមួយជាដាច់ខាត ហើយពួកនាងនឹងមិនលួច មិនប្រព្រឹត្តអំពើហ្សីណា មិនសម្លាប់កូនៗខ្លួនឯង និងមិនក្លែងបន្លំកូនអ្នកដទៃ(ដែលកើតពីអំពើសហាយស្មន់របស់ខ្លួន) ថាជាកូន(ជាមួយ)ប្តី ហើយនិងមិនប្រព្រឹត្តល្មើសនឹងអ្នកចំពោះប្រការល្អទាំងឡាយ(ដែលអ្នកបង្គាប់ប្រើ) ចូរអ្នកទទួលយកការធ្វើសច្ចាប្រណិធានរបស់ពួកនាង ព្រមទាំងសុំការអភ័យទោសពីអល់ឡោះឱ្យពួកនាងចុះ បន្ទាប់ពីពួកនាងបានសច្ចាប្រណិធានឹងអ្នករួចហើយនោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

13. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំយកក្រុមមួយដែលអល់ឡោះទ្រង់ខឹងសម្បាចំពោះពួកគេធ្វើជាអ្នកគាំពារឱ្យសោះ។ ជាការពិតណាស់ ពួកគេអស់សង្ឃឹមចំពោះ(ផលបុណ្យ)ថ្ងៃបរលោក ដូចជាពួកគ្មានជំនឿអស់សង្ឃឹមចំពោះ(ការឲ្យ)អ្នកដែលនៅក្នុងផ្នូរ(រស់ឡើងវិញ)ដូច្នោះដែរ (ដោយសារតែពួកគេមិនជឿឡើយ)។

ជំពូក អាសស៊ីហ្យ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដីបានលើកតម្កើងចំពោះអល់ឡោះជាម្ចាស់។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

2. ឱបណ្តាអ្នកដែលមានជំនឿ! ហេតុអ្វីបានជាពួកអ្នកនិយាយនូវអ្វីដែលពួកអ្នកមិនបានធ្វើ?

3. អល់ឡោះទ្រង់ស្អប់ខ្ពើមបំផុតចំពោះការដែលពួកអ្នកនិយាយនូវអ្វីដែលពួកអ្នកមិនបានធ្វើបែបនេះ។

4. ពិតប្រាកដណាស់ អល់ឡោះទ្រង់ស្រលាញ់បណ្តាអ្នកដែលបានប្រយុទ្ធក្នុងមាគ៌ារបស់ទ្រង់ដែលតម្រៀបគ្នាជាជួរៗ ប្រៀបដូចជាសំណង់អគារដ៏រឹងមាំ។

5. ចូរអ្នករំលឹក(ឱអ្នកនាំសារមូហាំម៉ាត់) នៅពេលដែលព្យាការីមូសាបាននិយាយទៅកាន់ក្រុមរបស់គាត់ថា៖ ឱក្រុមរបស់ខ្ញុំ! ហេតុអ្វីបានជាពួកអ្នកធ្វើទុក្ខបុកម្នេញមកចំពោះខ្ញុំ ខណៈដែលពួកអ្នកដឹងហើយថា ជាការពិតណាស់ រូបខ្ញុំគឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នកនោះ? ហើយនៅពេលដែលពួកគេបែរចេញ អល់ឡោះក៏បានធ្វើឱ្យចិត្តរបស់ពួកគេកាន់តែឃ្លាតឆ្ងាយ(ពីការពិត)។ ហើយអល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលប្រព្រឹត្តល្មើសឡើយ។

6. ហើយចូរអ្នករំលឹក(ឱអ្នកនាំសារមូហាំម៉ាត់) នៅពេលដែលព្យាការីអ៊ីសា កូនប្រុសរបស់ ម៉ារយ៉ាំ បាននិយាយថា៖ ឱអម្បូរអ៊ីស្រាអែល! ពិតប្រាកដណាស់ រូបខ្ញុំជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នក ដើម្បីបញ្ជាក់នូវគម្ពីរតាវ៉ាត់ដែលទ្រង់បានបញ្ចុះមកមុនខ្ញុំ និងដើម្បីផ្តល់ដំណឹងរីករាយដល់ពួកអ្នកអំពីអ្នកនាំសារម្នាក់ទៀតដែលនឹងមកដល់បន្ទាប់ពីខ្ញុំ ដែលគាត់មានឈ្មោះថា អះម៉ាត់ (ព្យាការីមូហាំម៉ាត់)។ ក៏ប៉ុន្តែ នៅពេលដែលគាត់បានមកដល់ពួកគេដោយនាំមកនូវសញ្ញាកស្តុតាងដ៏ច្បាស់លាស់ជាច្រើន ពួកគេបែរជានិយាយថា៖ នេះជាមន្តអាគមយ៉ាងច្បាស់លាស់ទៅវិញ។

7. ហើយគ្មានអ្នកណាដែលបំពានជាងអ្នកដែលប្រឌិតកុហកលើអល់ឡោះជាម្ចាស់ ខណៈដែលរូបគេត្រូវបានគេអំពាវនាវទៅកាន់សាសនាអ៊ីស្លាមនោះឡើយ។ ហើយអល់ឡោះជាម្ចាស់ទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

8. ពួកគេមានបំណងចង់ពន្លត់នូវពន្លឺរបស់អល់ឡោះ(គម្ពីរគួរអាន)ដោយអណ្តាតរបស់ពួកគេ តែអល់ឡោះទ្រង់ជាអ្នកបំពេញនូវពន្លឺរបស់ទ្រង់ ទោះបីជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ។

9. អល់ឡោះទ្រង់ជាអ្នកដែលបញ្ជូនអ្នកនាំសាររបស់ទ្រង់(ព្យាការីមូហាំម៉ាត់)ដោយនាំមកនូវការចង្អុលបង្ហាញ(គម្ពីរគួរអាន) និងសាសនាពិត(សាសនាអ៊ីស្លាម)ដើម្បីឱ្យសាសនានេះខ្ពង់ខ្ពស់លើសសាសនាដទៃទាំងឡាយ បើទោះជាពួកមុស្លីគឺនមិនពេញចិត្តក៏ដោយ។

10. ឱបណ្តាអ្នកដែលមានជំនឿ! តើពួកអ្នកចង់ឱ្យយើងបង្ហាញប្រាប់ពួកអ្នកពីជំនួញមួយដែលអាចសង្គ្រោះពួកអ្នកពីទណ្ឌកម្មដ៏សែនឈឺចាប់ដែរឬទេ?

11. គឺពួកអ្នកត្រូវមានជំនឿលើអល់ឡោះជាម្ចាស់និងអ្នកនាំសាររបស់ទ្រង់ ហើយត្រូវតស៊ូ(ប្រយុទ្ធ)ក្នុងមាគ៌ារបស់ទ្រង់ដោយទ្រព្យសម្បត្តិនិងខ្លួនប្រាណរបស់ពួកអ្នក។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង។

12. ទ្រង់នឹងអភ័យទោសដល់ពួកអ្នកចំពោះបាបកម្មទាំងឡាយរបស់ពួកអ្នក ហើយទ្រង់នឹងបញ្ចូលពួកអ្នកទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ព្រមទាំងលំនៅឋានដ៏ល្អប្រណីតនៅក្នុងឋានសួគ៌អាត់និន។ នោះហើយគឺជាជោគជ័យដ៏ធំធេង។

13. ហើយ(និងឧបការគុណ)ផ្សេងទៀតដែលពួកអ្នកពេញចិត្តចំពោះវា គឺការជួយពីអល់ឡោះ និងការរំដោះ(ទឹកដី)ដ៏ឆាប់ខាងមុខ។ ហើយចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្តល់ដំណឹងរីករាយដល់បណ្តាអ្នកដែលមានជំនឿ។

14. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកធ្វើខ្លួនជាអ្នកជួយដល់(សាសនា)អល់ឡោះ ដូចដែលព្យាការីអ៊ីសាកូនប្រុសរបស់ម៉ារយ៉ាំ បានពោលទៅកាន់ក្រុមអាល់ហាវ៉ារីយីន(សាវ័ករបស់គាត់)ថា៖ តើអ្នកណាខ្លះដែលចូលរួមជាមួយខ្ញុំជួយដល់(សាសនា)អល់ឡោះនោះ? ពេលនោះ ក្រុមអាល់ហាវ៉ារីយីនបានឆ្លើយថា៖ ពួកយើង គឺជាអ្នកជួយដល់(សាសនា)អល់ឡោះ។ ហើយមួយក្រុមនៃអម្បូរអ៊ីស្រាអែលមានជំនឿ ហើយមួយក្រុមផ្សេងទៀតបានប្រឆាំង។ ហេតុនេះ យើងក៏បានពង្រឹងដល់បណ្តាអ្នកដែលមានជំនឿទៅលើសត្រូវរបស់ពួកគេ។ ដូច្នេះ ពួកគេក៏បានក្លាយជាអ្នកដែលទទួលបានជ័យជម្នះ។

ជំពូក អាល់ជុមុអះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដីបានលើកតម្កើងចំពោះអល់ឡោះ ជាស្តេចគ្រប់គ្រង ជាម្ចាស់មហាបរិសុទ្ធ មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

2. ទ្រង់ជាអ្នកដែលបានបញ្ជូនទៅកាន់ក្រុមដែលមិនចេះអក្សរ(ពួកអារ៉ាប់)នូវអ្នកនាំសារម្នាក់ពីក្នុងចំណោមពួកគេ ដោយសូត្រនូវវាក្យខណ្ឌទាំងឡាយរបស់ទ្រង់ឲ្យពួកគេស្តាប់ និងជម្រះសម្អាតពួកគេ ព្រមទាំងបង្រៀនដល់ពួកគេនូវគម្ពីរ(គួរអាន)និងគតិបណ្ឌិត(ស៊ុណ្ណះ)ខណៈដែលកាលពីមុន ពួកគេពិតជាស្ថិតនៅក្នុងភាពវង្វេងយ៉ាងច្បាស់លាស់។

3. ហើយ(បញ្ជូនទៅកាន់)ក្រុមផ្សេងទៀតក្នុងចំណោមពួកគេដែលអ្នកទាំងនោះមិនទាន់មកដល់នៅឡើយ។ ហើយទ្រង់មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

4. នោះគឺជាការប្រោសប្រទានរបស់អល់ឡោះដែលទ្រង់ប្រទានវាទៅឱ្យជនណាដែលទ្រង់មានចេតនា។ ហើយអល់ឡោះទ្រង់មានការប្រោសប្រទានដ៏ធំធេងបំផុត។

5. ការប្រៀបធៀបពួក(យូដា)ដែលគេជាក់កាតព្វកិច្ចឱ្យអនុវត្តន៍តាមគម្ពីរតាវ៉ាត ក្រោយមក ពួកគេបែរជាមិនអនុវត្តន៍តាមវាទៅវិញ គឺប្រៀបដូចជាសត្វលាដែលដឹកគម្ពីរជាច្រើន។ ការប្រៀបធៀបពួកដែលបដិសេធនឹងបណ្តាវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះ គឺអាក្រក់បំផុត។ ហើយអល់ឡោះទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលបំពានឡើយ។

6. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱពួកយូដាទាំងឡាយ! ប្រសិនបើពួកអ្នកអះអាងថា ពួកអ្នកពិតជាសំណព្វចិត្តរបស់អល់ឡោះជាម្ចាស់ក្រៅពីមនុស្សដទៃមែននោះ ចូរពួកអ្នកប្រាថ្នាចង់ស្លាប់មើល៍ ប្រសិនបើពួកអ្នក គឺជាអ្នកទៀងត្រង់មែននោះ។

7. ពួកគេនឹងមិនប្រាថ្នាចង់ស្លាប់ជាដាច់ខាតព្រោះតែអ្វីដែលពួកគេបានប្រព្រឹត្ត(កន្លងមក)។ ហើយអល់ឡោះមហាដឹងបំផុតចំពោះពួកដែលបំពាន។

8. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ពិតប្រាកដណាស់ សេចក្តីស្លាប់ដែលពួកអ្នកខំរត់គេចពីវានោះ គឺពិតជានឹងទៅជួបពួកអ្នកជាមិនខាន។ បន្ទាប់មក គេនឹងនាំពួកអ្នកត្រលប់ទៅកាន់អ្នកដែលមហាដឹងបំផុតពីប្រការអាថ៌កំបាំង និងប្រការលាតត្រដាង។ ពេលនោះ ទ្រង់នឹងប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។

9. ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលដែលគេ(អាហ្សាន)ប្រកាសហៅទៅកាន់ការប្រតិបត្តិសឡាតនៅថ្ងៃសុក្រ ចូរពួកអ្នករួសរាន់ទៅកាន់ការរំលឹកអល់ឡោះ(ស្តាប់ខុតប៊ះ និងសឡាតជុមអាត់)ហើយចូរពួកអ្នកបោះបង់នូវការលក់ដូរ។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង។

10. ហើយនៅពេលដែលគេបានបញ្ចប់ការសឡាត(ជុមអាត់)ចូរពួកអ្នកបំបែកគ្នានៅលើផែនដី ហើយស្វែងរកការប្រោសប្រទានពីអល់ឡោះ។ ហើយចូរពួកអ្នករំឭកចំពោះអល់ឡោះឲ្យបានច្រើន សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។

11. តែប្រសិនបើពួកគេឃើញការជួញដូរ ឬការកម្សាន្តសប្បាយ ពួកគេបំបែកគ្នាទៅរកវា ហើយបោះបង់អ្នកឱ្យនៅឈរ(សូត្រខុតប៊ះតែឯង) ចូរអ្នកពោលថា៖ អ្វីដែលនៅឯអល់ឡោះ គឺល្អប្រសើរជាងការកម្សាន្តសប្បាយ និងការជួញដូរនោះទៅទៀត។ ហើយអល់ឡោះជាអ្នកប្រទានលាភសក្ការៈដ៏ប្រសើរបំផុត។

ជំពូក អាល់មុណាហ្វីគូន

1. នៅពេលដែលពួកពុតត្បុតមកជួបអ្នក(ឱអ្នកនាំសារមូហាំម៉ាត់) ពួកគេនិយាយថា៖ ពួកយើងសូមធ្វើសាក្សីថា៖ ពិតប្រាកដណាស់ អ្នកពិតជាអ្នកនាំសាររបស់អល់ឡោះ។ ហើយអល់ឡោះទ្រង់ដឹងហើយថា អ្នកពិតជាអ្នកនាំសាររបស់ទ្រង់នោះ។ ហើយអល់ឡោះទ្រង់ធ្វើសាក្សីថា ពិតប្រាកដណាស់ ពួកពុតត្បុត គឺពិតជាពួកដែលកុហក។

2. ពួកគេបានយកការស្បថស្បែរបស់ខ្លួនធ្វើជាខែលបិទបាំង ហើយពួកគេបានរារាំង(មនុស្ស)ពីមាគ៌ារបស់អល់ឡោះ។ ពិតណាស់ អ្វីដែលពួកគេធ្លាប់បានប្រព្រឹត្តនោះ គឺអាក្រក់បំផុត។

3. នោះគឺដោយសារតែពួកគេមានជំនឿ ក្រោយមក ពួកគេបានប្រឆាំងទៅវិញ។ ដូច្នេះ គេក៏បានបោះត្រាភ្ជិតទៅលើដួងចិត្តរបស់ពួកគេ។ ហេតុនេះ ពួកគេមិនយល់អ្វីឡើយ។

4. ហើយនៅពេលដែលអ្នកឃើញពួកគេ លក្ខណៈខាងក្រៅរបស់ពួកគេធ្វើឱ្យអ្នកមានការចាប់អារម្មណ៍។ ហើយបើសិនជាពួកគេនិយាយ អ្នកនឹងស្តាប់សម្តីរបស់ពួកគេ។ ពួកគេប្រៀបដូចជាកំណាត់ឈើដែលគេផ្អែកចោលប៉ុណ្ណោះ។ ពួកគេគិតថាគ្រប់សំឡេងស្រែកទាំងឡាយ គឺសំដៅទៅរកពួកគេ។ ពួកគេជាសត្រូវ(យ៉ាងពិតប្រាកដ)។ ដូចនេះ ចូរអ្នកប្រុងប្រយ័ត្នចំពោះពួកគេ។ អល់ឡោះទ្រង់ដាក់បណ្តាសាពួកគេ។ តើពួកគេត្រូវបានគេបង្វែរចេញយ៉ាងដូចម្តេច?

5. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកគេថា៖ "ចូរពួកអ្នកនាំគ្នាមក នោះអ្នកនាំសាររបស់អល់ឡោះនឹងសុំការអភ័យទោសដល់ពួកអ្នក" ពួកគេបែរជាគ្រវីក្បាលរបស់ពួកគេ ហើយអ្នកនឹងឃើញពួកគេបដិសេធ ទាំងដែលពួកគេជាពួកក្រអឺតក្រទម។

6. វាដូចតែគ្នាទេចំពោះពួកគេ ទោះបីជាអ្នកសុំការអភ័យទោសឱ្យពួកគេ ឬមិនសុំការអភ័យទោសឱ្យពួកគេក៏ដោយ ក៏អល់ឡោះទ្រង់មិនអភ័យទោសឱ្យពួកគេជាដាច់ខាត។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនចង្អុលបង្ហាញដល់ក្រុមដែលប្រព្រឹត្តល្មើសឡើយ។

7. ពួកគេនេះឯងដែលនិយាយថា៖ ចូរពួកអ្នកកុំបរិច្ចាគឱ្យទៅអ្នកដែលនៅជាមួយអ្នកនាំសាររបស់អល់ឡោះឱ្យសោះ លុះត្រាតែពួកគេចាកចេញ(ពីគាត់)។ ហើយឃ្លាំង(ទ្រព្យ)នៃមេឃជាច្រើនជាន់ និងផែនដី គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ក៏ប៉ុន្តែពួកពុតត្បុតមិនយល់នោះឡើយ។

8. ពួកគេបាននិយាយថា៖ "ប្រសិនបើពួកយើងត្រលប់ទៅកាន់ក្រុងម៉ាទីណាវិញ នោះអ្នកខ្លាំងនឹងបណ្តេញពួកអ្នកទន់ខ្សោយចេញពីនោះជាមិនខាន" ខណៈដែលភាពខ្លាំងពូកែ គឺជាកម្មសិទ្ធិរបស់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងបណ្តាអ្នកដែលមានជំនឿសោះនោះ។ ក៏ប៉ុន្តែ ពួកពុតត្បុតមិនដឹងនោះឡើយ។

9. ឱបណ្តាអ្នកដែលមានជំនឿ! ចូរកុំឱ្យទ្រព្យសម្បត្តិរបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នករំខានពួកអ្នកពីការរំលឹកចំពោះអល់ឡោះឲ្យសោះ។ ជនណាហើយដែលធ្វើដូច្នោះ ពួកទាំងនោះហើយ គឺជាពួកដែលខាតបង់។

10. ហើយចូរពួកអ្នកបរិច្ចាគមួយចំនួនអំពីអ្វីដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកអ្នក មុននឹងសេចក្តីស្លាប់មកដល់អ្នកណាម្នាក់ក្នុងចំណោមពួកអ្នក។ ពេលនោះ គេនឹងនិយាយ៖ បពិត្រព្រះជាម្ចាស់! ប្រសិនបើព្រះអង្គពន្យារពេលឱ្យខ្ញុំបន្តិចទៀត ប្រាកដជាខ្ញុំនឹងធ្វើការបរិច្ចាគ ហើយខ្ញុំនឹងស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសលជាមិនខាន។

11. ហើយអល់ឡោះទ្រង់មិនពន្យារពេលឱ្យបុគ្គលណាម្នាក់ជាដាច់ខាតនៅពេលណាដែលកាលកំណត់នៃអាយុជីវិតរបស់គេបានមកដល់ហើយនោះ។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

ជំពូក អាត់តាហ្គីពុន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្វីៗដែលនៅលើមេឃជាច្រើនជាន់ និងអ្វីៗដែលនៅលើផែនដីបានលើកតម្កើងចំពោះអល់ឡោះ។ អំណាចគ្រប់គ្រង និងការកោតសរសើរទាំងឡាយ គឺជាកម្មសិទ្ធិរបស់ទ្រង់។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

2. ទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នក។ ក៏ប៉ុន្តែ មួយចំនួននៃពួកអ្នក ជាអ្នកដែលគ្មានជំនឿ។ ហើយមួយចំនួនទៀតនៃពួកអ្នក គឺជាអ្នកដែលមានជំនឿ។ ហើយអល់ឡោះមហាឃើញបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

3. ទ្រង់បានបង្កើតមេឃជាច្រើនជាន់និងផែនដីដោយពិតប្រាកដ។ ហើយទ្រង់បានបង្កើតរូបរាងពួកអ្នក និងបានធ្វើឱ្យរូបរាងរបស់ពួកអ្នកល្អស្អាត។ ហើយកន្លែងវិលត្រឡប់(នៅថ្ងៃបរលោក) គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

4. ទ្រង់ដឹងបំផុតនូវអ្វីដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី។ ហើយទ្រង់ក៏ដឹងបំផុតផងដែរចំពោះអ្វីដែលពួកអ្នកលាក់បាំង និងអ្វីដែលពួកអ្នកលាតត្រដាង។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលនៅក្នុងដួងចិត្ត។

5. តើដំណឹងរបស់ពួកដែលបានប្រឆាំងកាលពីមុនមិនបានមកដល់ពួកអ្នក(ពួកមុស្លីគីន)ទេឬ? ជាការពិតណាស់ ពួកគេបានភ្លក់នូវលទ្ធផលចុងក្រោយរបស់ពួកគេដ៏អាក្រក់បំផុត។ ហើយសម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

6. នោះគឺដោយសារតែបណ្តាអ្នកនាំសារទាំងឡាយរបស់ពួកគេបាននាំមកនូវភស្តុតាងដ៏ច្បាស់លាស់ជាច្រើនមកកាន់ពួកគេ តែពួកគេបែរជានិយាយថា៖ តើមនុស្សលោក(ធម្មតាដូចពួកយើង)អាចចង្អុលបង្ហាញដល់ពួកយើងឬ? ហេតុនេះ ពួកគេក៏បានប្រឆាំង និងបានបែរចេញ។ ហើយអល់ឡោះមិនត្រូវការពួកគេនោះឡើយ។ ហើយអល់ឡោះមហាមានលើសលុប ជាទីកោតសរសើរបំផុត។

7. ពួកដែលគ្មានជំនឿបានអះអាងថា៖ ជាការពិតណាស់ ពួកគេនឹងមិនត្រូវបានគេបង្កើតឱ្យរស់ឡើងវិញឡើយ។ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ មិនដូច្នោះឡើយ! សូមស្បថនឹងព្រះជាម្ចាស់របស់ខ្ញុំ! ទ្រង់ប្រាកដជានឹងបង្កើតពួកអ្នកឱ្យរស់ឡើងវិញជាមិនខាន។ បន្ទាប់មក គេពិតជានឹងប្រាប់ពួកអ្នកនូវអ្វីដែលពួកអ្នកធ្លាប់បានប្រព្រឹត្ត។ ហើយនោះ គឺជារឿងងាយស្រួលបំផុតចំពោះអល់ឡោះ។

8. ដូច្នេះ ចូរពួកអ្នកមានជំនឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ហើយនិងពន្លឺ(គម្ពីរគួរអាន)ដែលយើងបានបញ្ចុះមក។ ហើយអល់ឡោះមហាដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

9. (ចូរអ្នកនឹកឃើញ) នៅថ្ងៃដែលគេនឹងប្រមូលផ្តុំពួកអ្នកសម្រាប់ថ្ងៃប្រមូលផ្តុំ។ នោះគឺជាថ្ងៃដែលស្តែងចេញនូវភាពខាតបង់និងភាពខុសគ្នា)។ ហើយជនណាដែលមានជំនឿចំពោះអល់ឡោះ និងបានសាងទង្វើកុសល ទ្រង់នឹងលុបបំបាត់នូវអំពើអាក្រក់ទាំងឡាយរបស់គេ ហើយទ្រង់នឹងបញ្ចូលរូបគេទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ នោះហើយគឺជាជោគជ័យដ៏ធំធេងបំផុត។

10. រីឯពួកដែលបានប្រឆាំង ហើយបានបដិសេធនឹងសញ្ញាកសុតាងទាំងឡាយរបស់យើង ពួកទាំងនោះហើយគឺជាពួកឋាននរក ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

11. គ្មានអ្នកណាម្នាក់ទទួលរងនូវគ្រោះអ្វីមួយឡើយ លើកលែងតែដោយការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ។ ហើយជនណាដែលមានជំនឿចំពោះអល់ឡោះ នោះទ្រង់នឹងចង្អុលបង្ហាញដួងចិត្តរបស់គេ។ ហើយអល់ឡោះមហាដឹងបំផុតនូវរាល់អ្វីៗទាំងអស់។

12. ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ(មូហាំម៉ាត់)។ តែប្រសិនបើពួកអ្នកងាកចេញ តាមពិតកាតព្វកិច្ចលើអ្នកនាំសាររបស់យើង គឺគ្រាន់តែផ្សព្វផ្សាយ(សារ)យ៉ាងច្បាស់លាស់ប៉ុណ្ណោះ។

13. អល់ឡោះ(តែមួយគត់)គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ហេតុនេះ ចូរឱ្យបណ្តាអ្នកមានជំនឿទាំងឡាយប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់ចុះ។

14. ឱបណ្តាអ្នកដែលមានជំនឿ! ពិតប្រាកដណាស់ ភរិយារបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នកមួយចំនួន គឺជាសត្រូវចំពោះពួកអ្នក។ ហេតុនេះ ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះពួកគេ។ តែប្រសិនបើពួកអ្នកអធ្យាស្រ័យ សណ្តោសប្រណី និងអភ័យទោសដល់ពួកគេនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

15. តាមពិត ទ្រព្យសម្បត្តិរបស់ពួកអ្នក និងកូនចៅរបស់ពួកអ្នក គឺជាការសាកល្បង(ចំពោះពួកអ្នក)។ ហើយនៅឯអល់ឡោះគឺមានផលបុណ្យយ៉ាងធំធេងបំផុត។

16. ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះតាមលទ្ធភាពរបស់ពួកអ្នក។ ហើយចូរពួកអ្នកស្តាប់ និងប្រតិបត្តិតាម ព្រមទាំងបរិច្ចាគ(ទ្រព្យសម្បត្តិ) នោះវាជាការប្រសើរសម្រាប់ខ្លួនពួកអ្នក។ ហើយជនណាដែលត្រូវបានគេការពារខ្លួនរបស់គេពីភាពកំណាញ់ពិតប្រាកដណាស់ អ្នកទាំងនោះហើយគឺជាអ្នកដែលទទួលបានជោគជ័យ។

17. ប្រសិនបើពួកអ្នកឱ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ល្អប្រពៃ នោះទ្រង់នឹងបង្កើនវាទ្វេដងដល់ពួកអ្នក ហើយទ្រង់នឹងអភ័យទោសដល់ពួកអ្នក។ ហើយអល់ឡោះមហាដឹងគុណ មហាខន្តីបំផុត។

18. (ទ្រង់)ជាអ្នកដឹងបំផុតនូវប្រការអាថ៌កំបាំង និងប្រការដែលលាតត្រដាង មហាខ្លាំងពូកែ មហាគតិបណ្ឌិត។

ជំពូក អាត់តឆ្លាក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱព្យាការី(មូហាំម៉ាត់)! នៅពេលដែលពួកអ្នក(ចង់)លែងលះភរិយា គឺពួកអ្នកត្រូវលែងលះពួកនាងនៅក្នុងអ៊ិតហ្ទះរបស់ពួកនាង និងត្រូវចងចាំ(រយៈពេលនៃ)អ៊ិតហ្ទះនោះផង។ ហើយចូរពួកអ្នកកោតខ្លាចអល់ឡោះដែលជាព្រះជាម្ចាស់របស់ពួកអ្នក។ ពួកអ្នកមិនត្រូវបណ្តេញពួកនាងចេញពីផ្ទះរបស់ពួកនាងនោះឡើយ ហើយពួកនាងក៏មិនត្រូវចាកចេញ(ដោយចិត្តឯង)នោះដែរ លើកលែងតែពួកនាងបានប្រព្រឹត្តនូវទង្វើអសីលធម៌យ៉ាងច្បាស់លាស់ប៉ុណ្ណោះ។ នោះហើយជាព្រំដែន(ច្បាប់)របស់អល់ឡោះ។ ហើយជនណាដែលបានបំពានព្រំដែន(ច្បាប់)របស់អល់ឡោះ គឺគេពិតជាបានបំពានលើខ្លួនឯង។ អ្នកមិនដឹងឡើយ ជួនកាលអល់ឡោះអាចធ្វើឱ្យកិច្ចការអ្វីមួយកើតឡើងបន្ទាប់ពីនោះក៏ថាបាន។

2. ហើយនៅពេលដែលពួកនាងជិតផុតរយៈពេល(អ៊ិតហ្ទះ)របស់ពួកនាងហើយនោះ ចូរពួកអ្នករួមរស់ជាមួយនឹងពួកនាងវិញដោយសមរម្យ ឬបែកគ្នានឹងពួកនាងដោយសមរម្យ។ ហើយចូរពួកអ្នករកសាក្សីដ៏យុត្តិធម៌ចំនួនពីរនាក់ក្នុងចំណោមពួកអ្នក។ ហើយពួកអ្នក(ឱអ្នកដែលធ្វើសាក្សី)ត្រូវធ្វើសាក្សីដោយស្មោះសចំពោះអល់ឡោះ។ នោះហើយជាអ្វីដែលគេផ្តល់ដំបូន្មានចំពោះជនណាដែលមានជំនឿលើអល់ឡោះនិងថ្ងៃបរលោក។ ហើយជនណាដែលកោតខ្លាចអល់ឡោះ ទ្រង់នឹងធ្វើឱ្យគេមានច្រកចេញ

3. ហើយទ្រង់នឹងប្រទានលាភសក្ការៈដល់គេដោយនឹកស្មានមិនដល់។ ហើយជនណាដែលប្រគល់ការទុកចិត្តលើអល់ឡោះ គឺទ្រង់(តែមួយគត់)គ្រប់គ្រាន់ហើយសម្រាប់គេ។ ពិតប្រាកដណាស់ អល់ឡោះជាអ្នកសម្រេចនូវកិច្ចការរបស់ទ្រង់។ ពិតណាស់ អល់ឡោះទ្រង់បង្កើតសម្រាប់រាល់អ្វីៗទាំងអស់ គឺមានការកំណត់ជាក់លាក់។

4. ហើយចំពោះស្ត្រី(ចំណាស់)ដែលអស់រដូវក្នុងចំណោមភរិយាទាំងឡាយរបស់ពួកអ្នក ប្រសិនបើពួកអ្នកមានការសង្ស័យ គឺរយៈពេលអ៊ិតហ្ទះរបស់ពួកនាង បីខែ។ ហើយចំពោះក្មេងស្រីដែលមិនទាន់មានរដូវ(ក៏ដូចគ្នាដែរ)។ រីឯស្ត្រីដែលមានគភ៌វិញ រយៈពេល(អ៊ិតហ្ទះ)របស់ពួកនាង គឺរហូតដល់ពួកនាងសម្រាលកូនរួច។ ហើយជនណាដែលកោតខ្លាចអល់ឡោះ ទ្រង់នឹងផ្តល់ភាពងាយស្រួលនូវរាល់កិច្ចការទាំងឡាយរបស់គេ។

5. នោះគឺជាបទបញ្ជារបស់អល់ឡោះដែលទ្រង់បានបញ្ចុះវាមកកាន់ពួកអ្នក។ ហើយជនណាដែលកោតខ្លាចអល់ឡោះ ទ្រង់នឹងលុបបំបាត់ពីរូបគេនូវប្រការអាក្រក់ទាំងឡាយរបស់គេ ហើយទ្រង់នឹងប្រទានឱ្យគេនូវផលបុណ្យដ៏ធំធេង។

6. ចូរពួកអ្នកឲ្យពួកនាង(ភរិយាដែលស្ថិតក្នុងអ៊ិតហ្ទះ)ស្នាក់នៅកន្លែងណាដែលពួកអ្នករស់នៅតាមលទ្ធភាពរបស់ពួកអ្នក។ ហើយចូរពួកអ្នកកុំបង្កការលំបាកដល់ពួកនាងដែលជាហេតុធ្វើឱ្យពួកនាងមានភាពតានតឹងឱ្យសោះ។ ហើយប្រសិនបើពួកនាងមានគភ៌ ចូរពួកអ្នកផ្គត់ផ្គង់ជីវភាពដល់ពួកនាង រហូតដល់ពួកនាងសម្រាលកូនរួច។ ហើយប្រសិនបើពួកនាងបំបៅកូនឱ្យពួកអ្នក ចូរពួកអ្នកផ្តល់ឱ្យពួកនាងនូវថ្លៃឈ្នួល(នៃការបំបៅ)នោះផង ហើយចូរពិភាក្សាគ្នារវាងពួកអ្នក(ពីកម្រៃឈ្នួលនៃការបំបៅ)ដោយសមរម្យ។ តែប្រសិនបើពួកអ្នកមិនឯកភាពគ្នាទេនោះ ចូរឱ្យគេ(ឪពុក)រកអ្នកបំបៅផ្សេងទៀតចុះ។

7. ចូរឲ្យអ្នកដែលមានជីវភាពធូរធារផ្គត់ផ្គង់ទៅតាមជីវភាពធូរធាររបស់ខ្លួន។ រីឯជនណាដែលលាភសក្ការៈរបស់គេមានកម្រិត ចូរឱ្យគេផ្គត់ផ្គង់ទៅតាមអ្វីដែលអល់ឡោះបានផ្តល់ដល់គេ(តាមលទ្ធភាព)។ អល់ឡោះពុំដាក់បន្ទុកលើបុគ្គលណាម្នាក់លើសពីអ្វីដែលទ្រង់បានផ្តល់ដល់គេឡើយ។ ហើយអល់ឡោះនឹងធ្វើឱ្យមានភាពងាយស្រួលបន្ទាប់ពីមានការលំបាក។

8. ហើយមានអ្នកភូមិស្រុកជាច្រើនដែលបានប្រឆាំងនឹងបទបញ្ជានៃព្រះជាម្ចាស់របស់ពួកគេនិងអ្នកនាំសារទាំងឡាយរបស់ទ្រង់។ ដូច្នេះ យើងក៏បានទូទាត់ពួកគេនូវការទូទាត់មួយដ៏ធ្ងន់ធ្ងរ និងបានដាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្មមួយដ៏សែនរន្ធត់ជាទីបំផុត។

9. ហើយពួកគេបានភ្លក់នូវលទ្ធផលចុងក្រោយរបស់ពួកគេដ៏អាក្រក់បំផុត។ ហើយលទ្ធផលចុងក្រោយនៃកិច្ចការរបស់ពួកគេនោះ គឺមានតែការខាតបង់ប៉ុណ្ណោះ។

10. អល់ឡោះទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត។ ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះ ឱបញ្ញាជនទាំងឡាយដែលជាអ្នកមានជំនឿ។ ជាការពិតណាស់ អល់ឡោះបានបញ្ចុះនូវការរំឭកមួយមកកាន់ពួកអ្នក។

11. នោះគឺអ្នកនាំសារម្នាក់(ព្យាការីមូហាំម៉ាត់)ដោយគាត់សូត្រនូវវាក្យខណ្ឌទាំងឡាយរបស់អល់ឡោះដ៏ច្បាស់លាស់ឱ្យពួកអ្នកស្តាប់ដើម្បីបញ្ចេញបណ្តាអ្នកដែលមានជំនឿចំពោះអល់ឡោះ និងបានសាងទង្វើកុសលពីភាពងងឹតទៅកាន់ពន្លឺ។ ហើយជនណាដែលមានជំនឿលើអល់ឡោះ និងបានសាងទង្វើកុសលរូបគេនឹងត្រូវគេបញ្ចូលទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរកាត់ពីក្រោមវា ដោយពួកគេស្ថិតនៅក្នុងនោះជាអមតៈ។ ជាការពិតណាស់ អល់ឡោះទ្រង់ប្រទានដល់គេនូវលាភសក្ការៈដ៏ប្រសើរបំផុត(ក្នុងឋានសួគ៌)។

12. អល់ឡោះទ្រង់ជាអ្នកដែលបានបង្កើតមេឃប្រាំពីរជាន់ ហើយផែនដីក៏ដូចគ្នាដែរ។ បទបញ្ជារបស់អល់ឡោះត្រូវគេបញ្ចុះមកវាងពួកវា(មេឃនិងផែនដី) ដើម្បីឱ្យពួកអ្នកដឹងថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។ ហើយអល់ឡោះទ្រង់មហាដឹងជ្រួតជ្រាបលើរាល់អ្វីៗទាំងអស់។

ជំពូក អាត់តះរែម

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱព្យាការី(មូហាំម៉ាត់)! ហេតុអ្វីបានជាអ្នកដាក់បម្រាម(លើខ្លួនឯង)នូវអ្វីដែលអល់ឡោះទ្រង់អនុញ្ញាតដល់អ្នកព្រោះតែចង់បានការពេញចិត្តពីភរិយាទាំងឡាយរបស់អ្នក? ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់។

2. ពិតប្រាកដណាស់ អល់ឡោះទ្រង់បានដាក់កាតព្វកិច្ចលើពួកអ្នកក្នុងការដោះ(លុបលាង)ពាក្យសម្បថរបស់ពួកអ្នក។ ហើយអល់ឡោះជាអ្នកគាំពាររបស់ពួកអ្នក។ ហើយទ្រង់មហាដឹង មហាគតិបណ្ឌិត។

3. ហើយ(ចូរនឹកឃើញ)នៅពេលដែលព្យាការី(មូហាំម៉ាត់)បានប្រាប់រឿងសម្ងាត់មួយដល់ភរិយាមួយចំនួនរបស់គាត់(ហាហ្វសោះ)។ ដូច្នេះ នៅពេលដែលនាង(ហាហ្វសោះ)បានប្រាប់រឿងរ៉ាវនោះ(ដល់អាអ៊ីស្ហះ) ហើយអល់ឡោះទ្រង់បានលាតត្រដាងរឿងនោះឲ្យគាត់បានដឹង គាត់ក៏បានប្រាប់(ហាហ្វសោះ)ឱ្យដឹងនូវរឿងមួយចំនួន និងលាក់បាំងរឿងមួយចំនួន។ នៅពេលដែលគាត់បានប្រាប់នាងពីរឿងនោះ នាងក៏បានសួរថា៖ តើអ្នកណាប្រាប់រឿងនេះដល់អ្នក? គាត់បានឆ្លើយថា៖ គឺព្រះជាម្ចាស់ដ៏មហាដឹងជ្រួតជ្រាបបំផុតបានប្រាប់ខ្ញុំ។

4. ចូរអ្នកទាំងពីរ(ហាហ្វសោះនិងអាអ៊ីស្ហះ)សារភាពកំហុសចំពោះអល់ឡោះ ព្រោះដួងចិត្តរបស់អ្នកទាំងពីរ គឺលម្អៀង(ទៅរកការស្រឡាញ់ប្រការដែលព្យាការីមិនពេញចិត្ត)ហើយ។ តែប្រសិនបើអ្នកទាំងពីរនៅតែបន្តរួមគ្នាប្រឆាំងនឹងគាត់ ពិតប្រាកដណាស់អល់ឡោះទ្រង់ជាអ្នកគាំពារដល់គាត់ ហើយម៉ាឡាអ៊ីកាត់ជីព្រីលនិងអ្នកដែលសាងទង្វើកុសលនៃបណ្តាអ្នកមានជំនឿព្រមទាំងម៉ាឡាអ៊ីកាត់ទាំងឡាយ ក៏ជាអ្នកជួយ(ដល់គាត់)បន្ទាប់ពីនោះដែរ។

5. ប្រសិនបើគាត់លែងលះពួកនាង សង្ឃឹមថាព្រះជាម្ចាស់របស់គាត់នឹងផ្លាស់ប្តូរឱ្យគាត់នូវភរិយាជាច្រើនទៀតដែលល្អជាងពួកនាង ជាស្ត្រីមូស្លីម ជាស្ត្រីដែលមានជំនឿ ជាស្ត្រីដែលគោរពប្រតិបត្តិ(ចំពោះអល់ឡោះ) ជាស្ត្រីដែលសារភាពកំហុស ជាស្ត្រីដែលគោរពសក្ការៈ ជាស្ត្រីដែលកាន់អំណត់បួស(ដែលមួយចំនួន)ជាស្ត្រីមេម៉ាយ(និងមួយចំនួនទៀត)ជាស្ត្រីក្រមុំ។

6. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកការពារខ្លួនប្រាណពួកអ្នក និងក្រុមគ្រួសាររបស់ពួកអ្នកពីភ្លើងនរក ដែលវត្ថុសម្រាប់ដុត(បញ្ឆេះ)វា គឺមនុស្សនិងដុំថ្ម។ នៅពីលើឋានរកនោះ គឺមានម៉ាឡាអ៊ីកាត់ជាច្រើនដែលមានទឹកមុខមឺងម៉ាត់។ ពួកគេមិនល្មើសនឹងអល់ឡោះចំពោះអ្វីដែលទ្រង់ដាក់បទបញ្ជាដល់ពួកគេឡើយ ហើយពួកគេធ្វើនូវអ្វីដែលគេបង្គាប់ប្រើចំពោះពួកគេ។

7. ឱពួកដែលគ្មានជំនឿ! ពួកអ្នកមិនចាំបាច់ដោះសារអ្វីនោះទេនៅថ្ងៃនេះ។ តាមពិត គេតបស្នងដល់ពួកអ្នកចំពោះតែអ្វីដែលពួកអ្នកធ្លាប់បានសាងប៉ុណ្ណោះ។

8. ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកសារភាពកំហុសចំពោះអល់ឡោះនូវការសារភាពមួយដ៏ស្មោះសសង្ឃឹមថាព្រះជាម្ចាស់របស់ពួកអ្នកនឹងលុបបំបាត់ពីពួកអ្នកនូវប្រការអាក្រក់ទាំងឡាយរបស់ពួកអ្នក ហើយទ្រង់នឹងបញ្ចូលពួកអ្នកទៅក្នុងឋានសួគ៌ដែលមានទន្លេជាច្រើនហូរពីវា(នៅថ្ងៃបរលោក) គឺនៅថ្ងៃដែលអល់ឡោះនឹងមិនធ្វើឱ្យព្យាការី និងបណ្តាអ្នកដែលមានជំនឿជាមួយគាត់អាម៉ាស់ឡើយ។ ពន្លឺរបស់ពួកគេភ្លឺចែងចាំងពីខាងមុខ និងខាងស្តាំពួកគេ(ពេលឆ្លងស្ពានស៊ីរ៉ាត)។ ពួកគេបួងសួងថា៖ បពិត្រព្រះជាម្ចាស់នៃយើងខ្ញុំ! សូមព្រះអង្គមេត្តាបំពេញនូវពន្លឺសម្រាប់យើងខ្ញុំ (រហូតឆ្លងផុតស្ពានស៊ីរ៉ាត) និងសូមព្រះអង្គមេត្តាអភ័យទោសដល់យើងខ្ញុំផង។ ពិតប្រាកដណាស់ ព្រះអង្គមានអានុភាពលើអ្វីៗទាំងអស់។

9. ឱព្យាការី(មូហាំម៉ាត់)! ចូរអ្នកតស៊ូប្រឆាំងនឹងពួកគ្មានជំនឿ និងពួកពុតត្បុត និងត្រូវធ្វើឱ្យបានតឹងរ៉ឹងបំផុតចំពោះពួកគេ។ ហើយកន្លែងស្នាក់អាស្រ័យរបស់ពួកគេ គឺនរកជើហាន់ណាំ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

10. អល់ឡោះទ្រង់បានលើកយកភរិយារបស់ព្យាការីនួហ និងភរិយារបស់ព្យាការីលូតធ្វើជាឧទាហរណ៍មួយសម្រាប់ពួកដែលគ្មានជំនឿ។ នាងទាំងពីរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្ញុំបម្រើទាំងពីរក្នុងចំណោមខ្ញុំបម្រើទាំងឡាយរបស់យើងដែលជាអ្នកសាងទង្វើកុសល។ ប៉ុន្តែ នាងទាំងពីរបានក្បត់នឹងពួកគេទាំងពីរ(ស្វាមីពួកនាង)។ ដូច្នេះ គាត់ទាំងពីរមិនអាចជួយការពារពួកនាងទាំងពីរពី(ទណ្ឌកម្ម)អល់ឡោះបន្តិចណាឡើយ។ ហើយមានគេនិយាយទៅកាន់ពួកនាងទាំងពីរថា៖ ចូរអ្នកទាំងពីរចូលទៅក្នុងឋាននរកជាមួយនឹងពួកដែលបានចូលទាំងឡាយចុះ។

11. ហើយអល់ឡោះក៏បានលើកយកភរិយារបស់ហ្វៀរអោនធ្វើជាឧទាហរណ៍សម្រាប់បណ្តាអ្នកដែលមានជំនឿផងដែរ ខណៈដែលនាងបានបួងសួងថា៖ បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាសង់លំនៅឋានមួយសម្រាប់ខ្ញុំនៅក្បែរនឹងព្រះអង្គក្នុងឋានសួគ៌ផង។ ហើយសូមព្រះអង្គមេត្តាសង្គ្រោះរូបខ្ញុំពីហ្វៀរអោន និងទង្វើ(អាក្រក់)របស់គេ ព្រមទាំងសង្គ្រោះរូបខ្ញុំពីក្រុមដែលបំពានផងចុះ។

12. ហើយ(ទ្រង់ក៏បានលើកជាឧទាហរណ៍សម្រាប់បណ្តាអ្នកដែលមានជំនឿផងដែរ គឺ)ម៉ារយ៉ាំ កូនស្រីរបស់អ៊ិមរ៉ន ដែលនាងបានរក្សាភាពបរិសុទ្ធរបស់នាង(ពីប្រការហ្ស៊ីណា)។ ពេលនោះ យើងបានឲ្យជីព្រីលផ្លុំវិញ្ញាណទៅក្នុងស្បូនរបស់នាង។ ហើយនាងបានជឿជាក់ចំពោះពាក្យបន្ទូលនៃព្រះជាម្ចាស់របស់នាង និងបណ្តាគម្ពីររបស់ទ្រង់។ ហើយនាងគឺស្ថិតក្នុងចំណោមអ្នកដែលគោរពប្រតិបត្តិ(ចំពោះអល់ឡោះ)។

ជំពូក អាល់មុលក៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. មហាពរជ័យ(អល់ឡោះជាម្ចាស់)ដែលអំណាចគ្រប់គ្រងស្ថិតនៅក្នុងកណ្តាប់ដៃរបស់ទ្រង់(តែមួយគត់)។ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។

2. (ទ្រង់)ជាអ្នកដែលបានបង្កើតការស្លាប់ និងការរស់(មានជីវិត)ដើម្បីសាកល្បងពួកអ្នក ថាតើអ្នកណាក្នុងចំណោមពួកអ្នកដែលសាងទង្វើបានប្រសើរជាងគេ។ ហើយទ្រង់មហាខ្លាំងពូកែ មហាអភ័យទោស។

3. (ទ្រង់)ជាអ្នកដែលបានបង្កើតមេឃប្រាំពីរជាន់ត្រួតលើគ្នា។ អ្នកនឹងមិនឃើញថា នៅក្នុងការបង្កើតរបស់ព្រះជាម្ចាស់ដ៏មហាសប្បុរសនោះមានភាពឆ្គាំឆ្គងនោះឡើយ។ ហេតុនេះ ចូរអ្នកសម្លឹងមើល(ទៅកាន់មេឃ)ម្តងទៀត ថាតើ(អ្នកឃើញ)មានការប្រេះស្រាំដែរឬទេ?

4. បន្ទាប់មក ចូរអ្នកក្រឡេកមើលម្តងហើយម្តងទៀត ការសម្លឹងមើលនោះនឹងវិលត្រឡប់មកកាន់អ្នកវិញក្នុងសភាពអាម៉ាស់ហើយវាមានភាពនឿយហត់បំផុត។

5. ហើយជាការពិតណាស់ យើងបានតុបតែងលម្អមេឃលោកិយដោយហ្វូងតារាជាច្រើន ហើយយើងបានបង្កើតពួកវាសម្រាប់គប់ពពួកស្មៃតន(ដែលលួចស្តាប់ដំណឹងនៅលើមេឃ)។ ហើយយើងបានត្រៀមទុកសម្រាប់ពួកវានូវទណ្ឌកម្ម(ភ្លើងនរក)ដែលឆាបឆេះ។

6. ហើយសម្រាប់ពួកដែលប្រឆាំងនឹងព្រះជាម្ចាស់របស់ពួកគេ គឺនឹងទទួលទណ្ឌកម្មនៃនរកដ៏ហាន់ណាំ ហើយវាជាកន្លែងវិលត្រឡប់ដ៏អាក្រក់បំផុត។

7. នៅពេលដែលពួកគេត្រូវបានគេគ្រវែងចូលទៅក្នុងភ្លើងនរក ពួកគេបានឮសម្រែកមួយដ៏ខ្លាំងក្លាបំផុត ខណៈដែលវា(ភ្លើងនរក)កំពុងតែពុះកញ្ជ្រោលយ៉ាងខ្លាំង។

8. វា(ឋាននរក)ស្ទើរតែបែកខ្ចាត់ខ្ចាយព្រោះតែកំហឹង។ រាល់ពេលដែលក្រុមមួយត្រូវបានគេគ្រវែងចូលទៅក្នុងវា អ្នកដែលយាមឋាននរកបានសួរទៅកាន់ពួកគេថា៖ តើអ្នកជាស់តឿនព្រមានពុំបានមកដល់ពួកអ្នកទេឬ?

9. ពួកគេបានតបថា៖ ពិតមែនហើយ អ្នកជាស់តឿនព្រមានពិតជាបានមកដល់ពួកយើង តែពួកយើងបានបដិសេធ(ចំពោះគាត់)។ ហើយពួកយើងបាននិយាយថា៖ អល់ឡោះមិនបានបញ្ចុះអ្វីមួយនោះឡើយ។ ពួកអ្នកគ្មានអ្វីក្រៅពីស្ថិតក្នុងភាពវង្វេងដ៏ធ្ងន់ធ្ងរនោះឡើយ។

10. ហើយពួកគេបាននិយាយទៀតថា៖ បើសិនជាពួកយើងស្តាប់ ឬចេះគិតពិចារណា នោះពួកយើងក៏មិនស្ថិតក្នុងចំណោមពួកឋាននរកនោះដែរ។

11. ពេលនោះ ពួកគេបានទទួលស្គាល់ចំពោះបាបកម្មរបស់ខ្លួន។ ដូច្នេះ ការឃ្លាតឆ្ងាយ(ពីក្តីមេត្តាករុណារបស់អល់ឡោះ) គឺសម្រាប់ពួកឋាននរក។

12. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាចព្រះជាម្ចាស់របស់ពួកគេក្នុងពេលស្ងាត់កំបាំង សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស និងផលបុណ្យយ៉ាងធំធេងបំផុត(ឋានសួគ៌)។

13. ចូរពួកអ្នក(ឱមនុស្សលោក)លាក់បាំងសម្តីរបស់ពួកអ្នក ឬបើកចំហវាចុះ ពិតប្រាកដណាស់ ទ្រង់មហាដឹងបំផុតនូវអ្វីដែលមាននៅក្នុងដួងចិត្ត។

14. តើអ្នកដែលបានបង្កើតនោះមិនបានដឹង(ពីសព្វភាវៈរបស់ទ្រង់)ទេឬ? ហើយទ្រង់មហាទន់ភ្លន់ មហាដឹងបំផុត។

15. ទ្រង់ជាអ្នកដែលបានបង្កើតផែនដីឱ្យមានភាពងាយស្រួលសម្រាប់ពួកអ្នក។ ហេតុនេះ ចូរពួកអ្នកធ្វើដំណើរគ្រប់ទិសទីរបស់វា និងទទួលទានពីលាភសក្ការៈរបស់ទ្រង់ចុះ។ ហើយការបង្កើតឲ្យរស់ឡើងវិញ គឺឆ្ពោះទៅកាន់ទ្រង់(តែមួយគត់)។

16. តើពួកអ្នកគិតថាមានសុវត្ថិភាពពីអ្នកដែលនៅលើមេឃក្នុងករណីដែលទ្រង់ធ្វើឱ្យផែនដីស្រូបយកពួកអ្នក ខណៈដែលវាញ័ររញ្ជួយនោះឬ?

17. ឬមួយពួកអ្នកគិតថាមានសុវត្ថិភាពពីអ្នកដែលនៅលើមេឃ ក្នុងករណីដែលទ្រង់បញ្ជូនព្យុះដុំថ្មទៅលើពួកអ្នកនោះឬ? ពិតណាស់ ពួកអ្នកគង់តែនឹងដឹងថាតើការព្រមាននោះយ៉ាងដូចម្តេច។

18. ហើយជាការពិតណាស់ អ្នកជំនាន់មុនពួកគេ(ពួកមុស្លីគីន)បានបដិសេធ(នឹងអ្នកនាំសារទាំងឡាយរបស់ពួកគេ)។ ដូចនេះ តើការព្រមាន(របស់យើង)យ៉ាងដូចម្តេចដែរ?

19. តើពួកទាំងនោះមិនបានសម្លឹងមើលទៅកាន់សត្វបក្សីដែល(ហើរ)ត្រដាងស្លាប និងក្តោបស្លាប(របស់វា)នៅពីលើពួកគេទេឬ? គ្មានអ្វីដែលអាចទ្រពួកវា(មិនឱ្យធ្លាក់)ក្រៅពីព្រះជាម្ចាស់ដ៏មហាសប្បុរសនោះឡើយ។ ពិតប្រាកដណាស់ ទ្រង់មហាឃើញបំផុតនូវគ្រប់អ្វីៗទាំងអស់។

20. តើអ្នកណាជាកងទ័ពរបស់ពួកអ្នកដែលអាចជួយពួកអ្នកក្រៅពីព្រះជាម្ចាស់ដ៏មហាសប្បុរសនោះ? ពិតណាស់ ពួកគ្មានជំនឿគ្មានអ្វីក្រៅពីស្ថិតក្នុងការបោកបញ្ឆោត(របស់ស្តែតន)នោះឡើយ។

21. តើអ្នកណាដែលអាចផ្តល់លាភសក្ការៈដល់ពួកអ្នកបានទៅ ប្រសិនបើទ្រង់រារាំងលាភសក្ការៈរបស់ទ្រង់នោះ? ផ្ទុយទៅវិញ ពួកគេនៅតែបន្តស្ថិតនៅក្នុងភាពចចេសរឹងរូស និងក្រអឺតក្រទមដដែល។

22. ដូច្នេះ តើអ្នកដែលដើរឱនមុខរបស់ខ្លួនទទួលបានការចង្អុលបង្ហាញជាង ឬមួយអ្នកដែលដើរត្រង់លើមាគ៌ាដ៏ត្រឹមត្រូវនោះ(ទទួលបានការចង្អុលបង្ហាញជាង)?

23. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នក ហើយទ្រង់បានបង្កើតឱ្យពួកអ្នកនូវសោត ចក្ខុ និងដួងចិត្ត។ អ្វីដែលពួកអ្នកដឹងគុណ គឺតិចតួចបំផុត។

24. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ទ្រង់ជាអ្នកដែលបានបង្កើតពួកអ្នកឲ្យរីកសុសសាយនៅលើផែនដី។ ហើយពួកអ្នកនឹងត្រូវគេប្រមូលផ្តុំទៅកាន់ទ្រង់(តែមួយគត់)។

25. ហើយពួកគេ(ពួកគ្មានជំនឿ)បាននិយាយថា៖ តើការសន្យានេះនឹងកើតឡើងនៅពេលណា ប្រសិនបើពួកអ្នកជាអ្នកទៀងត្រង់មែននោះ?

26. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិត ចំណេះដឹង(ពីថ្ងៃបរលោក)គឺនៅឯអល់ឡោះ។ ហើយតាមពិត រូបខ្ញុំគ្រាន់តែជាអ្នកដាស់តឿនព្រមានដ៏ច្បាស់លាស់ម្នាក់ប៉ុណ្ណោះ។

27. ដូច្នេះ នៅពេលដែលពួកគេបានឃើញវា(ទណ្ឌកម្ម)នៅជិតពួកគេ គឺធ្វើឲ្យទឹកមុខរបស់ពួកគ្មានជំនឿប្រែជាអាក្រក់ ហើយមានគេនិយាយ(ទៅកាន់ពួកគេ)ថា៖ នេះហើយជាអ្វីដែលពួកអ្នកធ្លាប់បានទាមទារសុំឱ្យវាធាប់មកដល់នោះ។

28. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើអល់ឡោះទ្រង់ធ្វើឱ្យខ្ញុំនិងអ្នកដែលនៅជាមួយខ្ញុំស្លាប់ ឬក៏ទ្រង់អាណិតស្រលាញ់ពួកយើង ដូច្នេះ តើមានអ្នកណាដែលអាចការពារពួកគ្មានជំនឿពីទណ្ឌកម្មដ៏សែនឈឺចាប់បាននោះ?

29. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ទ្រង់ជាព្រះជាម្ចាស់ដ៏មហាសប្បុរស។ ពួកយើងមានជំនឿចំពោះទ្រង់ ហើយពួកយើងប្រគល់ការទុកចិត្តចំពោះទ្រង់(តែមួយគត់)។ ហើយពួកអ្នកគង់តែនឹងដឹងថា តើអ្នកណាដែលស្ថិតក្នុងភាពវង្វេងដ៏ច្បាស់លាស់នោះ?

30. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ចូរពួកអ្នកប្រាប់ខ្ញុំមក ប្រសិនបើទឹកធឹករបស់ពួកអ្នកប្រែជារីងស្ងួតអស់ ដូច្នេះ តើមានអ្នកណាដែលអាចនាំប្រភពទឹកមកឱ្យពួកអ្នកវិញបាននោះ?

ជំពូក អាល់កង្ហាំ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នូន (តួអក្សរទាំងនេះ គឺបានបកស្រាយរួចមកហើយនៅដើមស៊ូរ៉ោះមុន(ស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ)។ (អល់ឡោះ)ស្បថនឹងស្លាបប៉ាកកា និងអ្វីដែលពួកគេកត់ត្រា។

2. ដោយឧបការគុណនៃព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់) គឺអ្នកមិនមែនជាមនុស្សវិកលចរិតនោះឡើយ។

3. ពិតប្រាកដណាស់ សម្រាប់អ្នក គឺនឹងទទួលបានផលបុណ្យដោយគ្មានទីបញ្ចប់នោះឡើយ។

4. ហើយពិតប្រាកដណាស់ រូបអ្នកស្ថិតនៅលើសីលធម៌ដ៏ឧត្តុង្គឧត្តមបំផុត។

5. ពិតណាស់ អ្នកនឹងបានឃើញ ហើយពួកគេក៏នឹងបានឃើញដូចគ្នាដែរ

6. ថាតើនរណាក្នុងចំណោមពួកអ្នកជាមនុស្សវិកលចរិតនោះ?

7. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នកទ្រង់ដឹងបំផុតចំពោះជនដែលវង្វេងចេញពីមាគ៌ារបស់ទ្រង់ ហើយទ្រង់ក៏ដឹងបំផុតផងដែរចំពោះជនដែលទទួលបានការចង្អុលបង្ហាញទាំងឡាយ។

8. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំធ្វើតាមពួកដែលបដិសេធឱ្យសោះ។

9. ពួកគេប្រាថ្នាថា ប្រសិនបើអ្នកបន្ធន់ឥរិយាបថ(ចំពោះពួកគេ) នោះពួកគេនឹងបន្ធន់ឥរិយាបថ(ចំពោះអ្នកវិញ)។

10. ហើយចូរអ្នកកុំធ្វើតាមរាល់ពួកដែលចូលចិត្តស្បថបំពានដែលទាបថោកនោះឱ្យសោះ។

11. គឺអ្នកដែលចូលចិត្តនិយាយដើមគេ និងដើរនិយាយចាក់រុកគេ។

12. ជាអ្នកដែលចូលចិត្តកំណាញ់ក្នុងផ្លូវល្អ បំពានលើអ្នកដទៃ និងប្រព្រឹត្តអំពើបាបច្រើន។

13. ជាមនុស្សដែលអសីលធម៌ ថែមទាំងជាកូនឥតខាន់ស្លា។

14. នោះដោយសារតែគេជាអ្នកមានទ្រព្យសម្បត្តិ និងកូនចៅច្រើន។

15. នៅពេលដែលមានគេសូត្រវាក្យខណ្ឌទាំងឡាយរបស់យើងឱ្យគេស្តាប់ គេបែរជានិយាយថា៖ នេះជារឿងព្រេងនិទានរបស់អ្នកជំនាន់មុនប៉ុណ្ណោះ។

16. យើងនឹងដាក់សញ្ញាចំណាំនៅលើច្រមុះ(របស់គេ)។

17. ពិតប្រាកដណាស់ យើងបានសាកល្បងពួកគេ(ពួកមុស្តរីគីន)ដូចដែលយើងបានសាកល្បងចំពោះពួកម្ចាស់ចម្ការនោះដែរ ខណៈដែលពួកគេបានស្បថថា ពួកគេពិតជានឹងទៅប្រមូលផលវាទាំងព្រឹកព្រលឹម។

18. តែពួកគេមិនបាននិយាយថា អិនស្ហាអល់ឡោះ(ប្រសិនបើអល់ឡោះមានចេតនា)នោះឡើយ។

19. ដូច្នេះ ព្រះជាម្ចាស់របស់អ្នកក៏បានបញ្ជូនភ្លើងទៅកាន់ចម្ការនោះ(ទាំងយប់)ខណៈដែលពួកគេកំពុងតែគេងលង់លក់។

20. ពេលនោះ វា(បានឆេះខ្ទេច)ប្រៀបដូចជាពេលយប់ដែលងងឹតសូន្យសុង។

21. ហើយពួកគេបានស្រែកហៅគ្នានៅពេលព្រឹកព្រលឹមថា៖

22. ចូរនាំគ្នាចេញដំណើរពីព្រលឹមទៅកាន់ចម្ការរបស់ពួកអ្នក ប្រសិនបើពួកអ្នកចង់ប្រមូលផល(អំពីវា)មែននោះ។

23. ពេលនោះ ពួកគេក៏នាំគ្នាធ្វើដំណើរ(ឆ្ពោះទៅកាន់ចម្ការ)ហើយពួកគេនិយាយគ្នាតិចៗថា៖

24. ថ្ងៃនេះ មិនត្រូវឱ្យអ្នកក្រចូលមកក្នុងចម្ការរបស់ពួកអ្នកជាដាច់ខាត។

25. ហើយពួកគេស្រូតដំណើរទាំងព្រលឹមក្នុងបំណងរារាំងអ្នកក្រ ដោយគិតថា ខ្លួនមានលទ្ធភាពអាចធ្វើបាន។

26. នៅពេលដែលពួកគេបានឃើញចម្ការនោះ(ត្រូវភ្លើងឆេះខ្ទេច)ពួកគេនិយាយថា៖ ពួកយើងពិតជាវង្វេងផ្លូវហើយ។

27. (ទេ)ផ្ទុយទៅវិញ ពួកយើងត្រូវបានគេរារាំង(ពីការប្រមូលផលចម្ការ)នោះ។

28. អ្នកដែលល្អជាងគេក្នុងចំណោមពួកគេបាននិយាយថា៖ តើខ្ញុំមិនបានប្រាប់ពួកអ្នកទេឬថា៖ ហេតុអ្វីបានជាពួកអ្នកមិនពោលថា អិនស្ហាអល់ឡោះ?

29. ពួកគេបានពោលថា៖ ព្រះជាម្ចាស់របស់ពួកយើងដ៏មហាស្អាតស្អំ! ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាពួកដែលបំពាន។

30. បន្ទាប់មក ពួកគេបានសំដៅទៅរកគ្នាដោយស្តីបន្ទោសគ្នាទៅវិញទៅមក។

31. ពួកគេនិយាយថា៖ អនិច្ចាពួកយើង! ពិតប្រាកដណាស់ ពួកយើងធ្លាប់ជាពួកដែលបំពាន។

32. សង្ឃឹមថាព្រះជាម្ចាស់របស់ពួកយើងនឹងជំនួសឱ្យពួកយើងវិញនូវអ្វីដែលល្អប្រសើរជាងនោះទៅទៀត។ ពិតប្រាកដណាស់ ទៅកាន់ទ្រង់(តែមួយគត់)ដែលពួកយើងប្រាថ្នា(នូវប្រការល្អ)។

33. នោះហើយជាទណ្ឌកម្ម(ក្នុងលោកិយ)។ ហើយទណ្ឌកម្មនៅថ្ងៃបរលោក គឺធំធេងជាងនោះទៅទៀត ប្រសិនបើពួកគេបានដឹង។

34. ពិតប្រាកដណាស់ សម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) គឺទទួលបានឋានសួគ៌ណាអ៊ីមនៅឯព្រះជាម្ចាស់របស់ពួកគេ។

35. តើយើង(អល់ឡោះ)ចាត់ទុកជនមូស្លីមទាំងឡាយដូចគ្នានឹងពួកឧក្រិដ្ឋជនឬ?

36. តើមានអ្វីកើតឡើងចំពោះពួកអ្នក(ឱពួកមុស្រីគីន)ទើបបានជាពួកអ្នកហ៊ានកាត់សេចក្តីបែបនេះ?

37. ឬក៏ពួកអ្នកមានគម្ពីរមួយដែលពួកអ្នកសិក្សាអំពីវា?

38. (បើដូច្នោះមែននោះ) នៅក្នុងគម្ពីរនោះពិតជាបានចែងថា សម្រាប់ពួកអ្នក គឺអាចជ្រើសរើសបាន។

39. ឬមួយពួកអ្នកមានកិច្ចព្រមព្រៀងដ៏ច្បាស់លាស់មួយអំពីយើងរហូតដល់ថ្ងៃបរលោកដែលថា ពិតប្រាកដណាស់ ពួកអ្នកនឹងទទួលបានតាមអ្វីដែលពួកអ្នកចង់?

40. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សួរពួកគេថា៖ តើនរណាក្នុងចំណោមពួកគេជាអ្នកទទួលខុសត្រូវចំពោះរឿងនោះ?

41. ឬមួយពួកគេមានព្រះផ្សេងៗជាច្រើន? បើដូច្នេះមែន ចូរឱ្យពួកគេនាំព្រះទាំងឡាយរបស់ពួកគេមក ប្រសិនបើពួកគេជាអ្នកទៀងត្រង់មែននោះ។

42. នៅថ្ងៃដែលទ្រង់បញ្ចេញកំភួនជើង ហើយពួកគេត្រូវបានគេអំពាវនាវឱ្យស៊ូជោត តែពួកគេ(ពួកគ្មានជំនឿ)មិនអាចស៊ូជោតបាននោះឡើយ។

43. កែវភ្នែករបស់ពួកគេទម្លាក់ចុះ ខណៈដែលភាពអាម៉ាស់បានគ្របដណ្តប់លើពួកគេ។ ជាការពិតណាស់ ពួកគេធ្លាប់ត្រូវបានគេអំពាវនាវឱ្យស៊ូជោត ខណៈដែលពួកគេមានសុខភាពល្អ (តែពួកគេមិនស៊ូជោតឡើយ)។

44. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទុកឲ្យយើង និងអ្នកដែលបដិសេធនឹងពាក្យសម្តី(គម្ពីរគួរអាន)នេះ។ យើងនឹងល្បួងពួកគេ ដោយពួកគេមិនដឹងខ្លួនឡើយ។

45. ហើយយើងពន្យារពេលដល់ពួកគេ។ ជាពិតណាស់ គម្រោងការរបស់យើង គឺខ្លាំងក្លាបំផុត។

46. ឬមួយក៏អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទាមទារកម្រៃពីពួកគេ ដែលការបង់កម្រៃនោះជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះពួកគេ ?

47. ឬមួយពួកគេដឹងរឿងអាថ៌កំបាំង ហើយពួកគេកត់ត្រាវាទុក ?

48. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចំពោះការកំណត់របស់ព្រះជាម្ចាស់អ្នក ហើយចូរអ្នកកុំធ្វើដូចអ្នកដែលស្ថិតក្នុងពោះត្រីហ៊ូត(ព្យាការីយូនុស) ខណៈដែលគាត់បានបួងសួងនៅក្នុងពេលដែលគាត់ពោរពេញដោយទុក្ខព្រួយ។

49. ប្រសិនបើគ្មានឧបការគុណពីព្រះជាម្ចាស់របស់គាត់ទៅដល់គាត់ទេនោះ ច្បាស់ជារូបគាត់នឹងត្រូវត្រីនោះខ្ចាក់ចោលនៅទីវាលរហោស្ថានជាមិនខាន ខណៈដែលគាត់ជាអ្នកដែលត្រូវគេស្តីបន្ទោស។

50. តែព្រះជាម្ចាស់របស់គាត់បានជ្រើសរើសគាត់(ជាអ្នកនាំសារ)។ ដូច្នេះ ទ្រង់ក៏បានធ្វើឱ្យគាត់ស្ថិតក្នុងចំណោមអ្នកដែលសាងទង្វើកុសល។

51. ពិតប្រាកដណាស់ ពួកដែលគ្មានជំនឿ ស្ទើរតែធ្វើឱ្យអ្នកមានគ្រោះថ្នាក់ដោយសារតែក្រសែភ្នែករបស់ពួកគេ នៅពេលដែលពួកគេបានស្តាប់ឮគម្ពីរគួរអាន ហើយពួកគេនិយាយថា៖ ពិតណាស់ រូបគេ(ព្យាការីមូហាំម៉ាត់) គឺជាមនុស្សវិកលចរិត។

52. ហើយគម្ពីរនេះ(គម្ពីរគួរអាន) គឺគ្មានអ្វីក្រៅពីការដាស់រំឭកដល់ពិភពទាំងឡាយនោះឡើយ។

ជំពូក អាល់ហាកកោះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ថ្ងៃបរលោក(ជាថ្ងៃដែលនឹងកើតឡើងពិតប្រាកដ)។

2. អ្វីទៅជាថ្ងៃបរលោក?

3. ហើយតើអ្វីដែលធ្វើឱ្យអ្នកដឹងថា អ្វីទៅជាថ្ងៃបរលោកនោះ?

4. ពួកសាមូទ និងពួកអាទបានបដិសេធនឹងថ្ងៃបរលោក។

5. រីឯពួកសាមូទ ជាការពិតណាស់ គេបានបំផ្លាញពួកគេដោយសម្រែកមួយយ៉ាងខ្លាំងក្លា។

6. ចំណែកឯពួកអាទវិញ ជាការពិតណាស់ គេបានបំផ្លាញពួកគេដោយខ្យល់ត្រជាក់ដែលបក់បោកយ៉ាងខ្លាំងក្លា។

7. ទ្រង់បញ្ជូនវាមកលើពួកគេរយៈពេលប្រាំពីរយប់ប្រាំបីថ្ងៃជាប់ៗគ្នា។ ហើយអ្នកនឹងបានឃើញក្រុមនោះស្លាប់បាត់បង់ជីវិត ដែលពួកគេប្រៀបដូចជាដើមល្មើដែលដួលរលំ។

8. ដូច្នេះ តើអ្នកឃើញពួកគេនៅមានជីវិតសេសសល់ដែរឬទេ?

9. ហើយហ្វៀរអោន និងអ្នកជំនាន់មុនហ្វៀរអោន ហើយនិងស្រុកភូមិក្រុមរបស់ព្យាការីលូត គឺសុទ្ធតែបានប្រព្រឹត្តនូវអំពើខុសឆ្គង។

10. ហើយពួកគេបានបដិសេធនឹងអ្នកនាំសារនៃព្រះជាម្ចាស់របស់ពួកគេ។ ហេតុនេះ ទ្រង់ក៏បានដាក់ទណ្ឌកម្មពួកគេនូវទណ្ឌកម្ម ដ៏ខ្លាំងក្លាបំផុត។

11. ពិតណាស់ នៅពេលទឹកបានជន់លិចឡើងហួសកម្រិត យើងបានផ្ទុកពួកអ្នកក្នុងសំពៅ(ដែលព្យាការីនូហាបានសង់ឡើង)។

12. ដើម្បីយើងនឹងយករឿងនោះធ្វើជាការដាស់រំលឹកសម្រាប់ពួកអ្នក ហើយធ្វើឱ្យត្រចៀកចងចាំនូវអ្វីដែលបានស្តាប់ឮ។

13. ហើយនៅពេលដែលគេ(ម៉ាឡាអ៊ីកាត់)បានផ្លុំត្រែចំនួនមួយដង(ផ្លុំត្រែលើកទីមួយ)

14. ហើយផែនដី និងភ្នំទាំងឡាយត្រូវបានគេលើកចេញ(ពីកន្លែងរបស់វា) រួចវាទាំងពីរត្រូវបានបែកខ្ទេចខ្ទីនោះ

15. ថ្ងៃនោះហើយជាថ្ងៃដែលថ្ងៃបរលោកកើតឡើង។

16. ហើយមេឃបានប្រេះបែក។ ហើយនៅថ្ងៃនោះ វាប្រែជាទន់ខ្សោយ។

17. ពួកម៉ាឡាអ៊ីកាត់បិតនៅគ្រប់ជ្រុងនៃមេឃ។ ហើយនៅថ្ងៃនោះ មានម៉ាឡាអ៊ីកាត់ចំនួនប្រាំបីនាក់ទ្រអារ៉ស្ហ្សព្រះជាម្ចាស់របស់អ្នកពីលើពួកគេ។

18. នៅថ្ងៃនោះ ពួកអ្នកត្រូវបានគេនាំមកបង្ហាញខ្លួន។ គ្មានអាថ៌កំបាំងអ្វីមួយអំពីពួកអ្នកអាចលាក់បាំងបាននោះឡើយ។

19. រីឯជនណាដែលត្រូវបានគេ(ម៉ាឡាអ៊ីកាត់)ប្រគល់សៀវភៅកំណត់ត្រា(ទង្វើ)របស់គេពីខាងស្តាំ នោះគេនឹងនិយាយថា៖ ចូរពួកអ្នកយកសៀវភៅកំណត់ត្រា(ទង្វើ)របស់ខ្ញុំទៅអានចុះ។

20. ពិតប្រាកដណាស់ ខ្ញុំដឹងប្រាកដថា ខ្ញុំពិតជានឹងទទួលបាននូវការតបស្នងរបស់ខ្ញុំ។

21. ជាការពិតណាស់ គេនឹងទទួលបាននូវការរស់នៅមួយដែលជាទីគាប់ចិត្ត។

22. គឺស្ថិតនៅក្នុងឋានសួគ៌ដ៏ខ្ពង់ខ្ពស់បំផុត។

23. ផ្លែឈើរបស់វាបិតនៅជិតបង្គើយ(នឹងរូបគេ)។

24. (មានគេនិយាយថា៖) ចូរពួកអ្នកបរិភោគ និងផឹកដោយរីករាយចុះ ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានសាងក្នុងបណ្តាថ្ងៃកន្លងផុតទៅ(ក្នុងលោកិយ)។

25. រីឯជនណាដែលត្រូវបានគេ(ម៉ាឡាអ៊ីកាត់)ប្រគល់សៀវភៅកំណត់ត្រា(ទង្វើ)របស់គេពីខាងឆ្វេងវិញ នោះគេនឹងនិយាយថា៖ ឱអនិច្ចាខ្លួនខ្ញុំអើយ! មិនគួរណាខ្ញុំត្រូវបានគេប្រគល់សៀវភៅកំណត់ត្រា(ទង្វើ)របស់ខ្ញុំសោះ។

26. ហើយខ្ញុំក៏មិនដឹងដែរថា អ្វីទៅជាការតបស្នងរបស់ខ្ញុំនោះ។

27. ឱអនិច្ចា! គួរណាស់តែសេចក្តីស្លាប់(ក្នុងលោកិយ)ជាទីបញ្ចប់នៃអ្វីៗទាំងអស់។

28. ទ្រព្យសម្បត្តិរបស់ខ្ញុំមិនអាចជួយជាប្រយោជន៍អ្វីដល់ខ្ញុំឡើយ។

29. អំណះអំណាងរបស់ខ្ញុំ ក៏បានវិនាសបាត់បង់ពីខ្ញុំដែរ។

30. (មានគេនិយាយថា៖) ចូរពួកអ្នក(ឱម៉ាឡាអ៊ីកាត់)ចាប់ជននេះ រួចដាក់ខ្នោះគេចុះ។

31. បន្ទាប់មក ចូរពួកអ្នកបោះគេចូលក្នុងនរកជើហ៊ីម។

32. បន្ទាប់មកទៀត ចូរពួកអ្នកដោតគេនឹងច្រវាក់ដែលមានប្រវែងចិតសិបហត្ថចុះ។

33. ពិតប្រាកដណាស់ គេមិនធ្លាប់មានជំនឿលើអល់ឡោះដ៏មហាធំធេងឡើយ។

34. ហើយគេក៏មិនដែលជំរុញគ្នាឲ្យផ្តល់អាហារដល់អ្នកក្រីក្រនោះដែរ។

35. ដូចនេះ នៅក្នុងថ្ងៃនេះ គេគ្មានសាច់ញាតិណាដែលអាចការពាររូបគេ(ពីទណ្ឌកម្ម)នោះឡើយ។

36. ហើយគ្មានចំណីអាហារ(សម្រាប់គេ)ក្រៅពីខ្ទុះឈាមនោះឡើយ។

37. គ្មានអ្នកណាដែលទទួលទានវា ក្រៅតែពីពួកដែលប្រព្រឹត្តបាបកម្មប៉ុណ្ណោះ។

38. (អល់ឡោះ)ទ្រង់ស្បថនឹងអ្វីគ្រប់យ៉ាងដែលពួកអ្នកមើលឃើញ

39. ហើយនិងអ្វីគ្រប់យ៉ាងដែលពួកអ្នកមើលមិនឃើញ។

40. ជាការពិតណាស់ គម្ពីរនេះ(គម្ពីរគួរអាន) គឺជាបន្ទូល(របស់អល់ឡោះដែលសូត្រដោយ)អ្នកនាំសាររបស់ទ្រង់ដ៏មហាឧត្តុង្គឧត្តម។

41. ហើយគម្ពីរនេះមិនមែនជាពាក្យពេចន៍របស់អ្នកកវីឡើយ។ តិចតួចបំផុត អ្វីដែលពួកអ្នកមានជំនឿ។

42. ហើយគម្ពីរនេះក៏មិនមែនជាពាក្យពេចន៍របស់គ្រូទាយនោះដែរ។ តិចតួចបំផុតអ្វីដែលពួកអ្នកត្រិះរិះពិចារណា។

43. (តែគម្ពីរនេះ)ជាការបញ្ចុះមកពីព្រះជាម្ចាស់នៃពិភពទាំងឡាយ។

44. បើសិនជាគេ(ព្យាការីមូហាំម៉ាត់)និយាយប្រឌិតមកលើយើងនូវពាក្យពេចន៍មួយចំនួន(ដែលយើងមិនបានមានបន្ទូល)

45. យើងពិតជានឹងផ្តន្ទាទោសគេដោយអានុភាព(របស់យើង)។

46. បន្ទាប់មក យើងនឹងកាត់ផ្តាច់សរសៃឈាមបេះដូងរបស់គេ។

47. គ្មាននរណាម្នាក់ក្នុងចំណោមពួកអ្នកអាចរារាំងរូបគេឱ្យរួចផុត(ពីទណ្ឌកម្មយើង)បានឡើយ។

48. ពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន)គឺជាការដាស់រំឭកដល់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)។

49. ហើយពិតប្រាកដណាស់ យើងដឹងច្បាស់ថា ក្នុងចំណោមពួកអ្នក មានអ្នកដែលបដិសេធ(ចំពោះគម្ពីរគួរអាននេះ)។

50. ហើយជាការពិតណាស់វា(ការបដិសេធនឹងគម្ពីរគួរអាន)ពិតជាវិប្បដិសារីមួយចំពោះពួកគ្មានជំនឿ។

51. ហើយពិតប្រាកដណាស់គម្ពីរនេះ(គម្ពីរគួរអាន)គឺជាសេចក្តីពិតដ៏ច្បាស់លាស់បំផុត។

52. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)លើកតម្កើងព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដ៏មហាឧត្តុង្គឧត្តមចុះ។

ជំពូក អាល់ម៉ាអារិច

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អ្នកបួងសួងម្នាក់បានបួងសួងសុំឱ្យទណ្ឌកម្មកើតឡើង។
2. សម្រាប់ពួកគ្មានជំនឿ គឺគ្មានអ្នកការពាររូបគេ
3. ពីអល់ឡោះជាម្ចាស់ដែលមានភាពខ្ពង់ខ្ពស់នោះឡើយ។
4. ម៉ាឡាអ៊ីកាត់ទាំងឡាយ និងជីព្រីលឡើងទៅកាន់ទ្រង់នៅក្នុងថ្ងៃមួយដែលរយៈពេលរបស់វាស្មើនឹងហាសិបពាន់ឆ្នាំ (នៃលោកិយ)។
5. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចុះនូវការអត់ធ្មត់មួយដ៏ល្អប្រសើរ។
6. ពិតប្រាកដណាស់ ពួកគេមើលឃើញវា(ទណ្ឌកម្ម)នៅឆ្ងាយបំផុត។
7. តែយើងឃើញវានៅជិតបង្កើយ។
8. ថ្ងៃដែលមេឃប្រែក្លាយដូចជាលោហធាតុដែលត្រូវគេរំលាយ។
9. ហើយភ្នំទាំងឡាយប្រែក្លាយដូចជារោមសត្វ។
10. ហើយគ្មានសាច់ញាតិណាសួរសុខទុក្ខសាច់ញាតិ(របស់ខ្លួន)នោះឡើយ។
11. ពួកគេឃើញសាច់ញាតិរបស់ពួកគេ។ ជនគ្មានជំនឿមានបំណងលោះខ្លួនពីទណ្ឌកម្មនៅថ្ងៃនោះនឹងកូនចៅរបស់ខ្លួន
12. និងភរិយារបស់ខ្លួន បងប្អូនរបស់ខ្លួន
13. និងសាច់សាលោហិតរបស់ខ្លួនដែលធ្លាប់ពឹងពាក់គ្នា

14. ព្រមទាំងអ្នកនៅលើផែនដីទាំងអស់។ បន្ទាប់មក ឱ្យរូបគេរួចផុត(ពីទណ្ឌកម្មអល់ឡោះ)។

15. មិនដូច្នោះឡើយ។ ជាការពិតណាស់ វាគឺជាភ្លើងនរកដែលឆាបឆេះសន្ធោសន្ធៅ

16. ដែលវាឆេះរលេះរលួយស្បែកក្បាល(និងគ្រប់ស្បែកទាំងអស់)។

17. វាស្រែកហៅអ្នកដែលបែរក្រោយ និងងាកចេញ(ពីមាគ៌ាត្រឹមត្រូវ)

18. ហើយប្រមូល(ទ្រព្យសម្បត្តិ)រួចរក្សាទុក(មិនព្រមបរិច្ចាគ)។

19. ពិតប្រាកដណាស់ មនុស្សលោកត្រូវបានគេបង្កើតឡើងដោយមានចិត្តអន្ទះសា។

20. នៅពេលមានគ្រោះអាក្រក់កើតឡើងចំពោះរូបគេ គេគ្មានភាពអត់ធ្មត់ឡើយ។

21. តែនៅពេលដែលគេទទួលបានប្រការល្អ គេបែរជាកំណាញ់ទៅវិញ។

22. លើកលែងតែបណ្តាអ្នកដែលប្រតិបត្តិសឡាតប៉ុណ្ណោះ

23. ដែលពួកគេតែងប្រតិបត្តិសឡាតរបស់ខ្លួនជាប់ជានិច្ច។

24. និងបណ្តាអ្នកដែលដកយកមួយចំណែកអំពីទ្រព្យសម្បត្តិរបស់ពួកគេសម្រាប់បរិច្ចាគ

25. ដល់អ្នកសុំទាន និងអ្នកក្រដែលមិនហ៊ានសុំ។

26. និងបណ្តាអ្នកដែលជឿជាក់ចំពោះថ្ងៃបរលោក។

27. និងបណ្តាអ្នកដែលខ្លាចទណ្ឌកម្មនៃព្រះជាម្ចាស់របស់ពួកគេ។

28. ពិតប្រាកដណាស់ ទណ្ឌកម្មនៃព្រះជាម្ចាស់របស់ពួកគេគ្មាននរណាម្នាក់មានសុវត្ថិភាពឡើយ។

29. និងបណ្តាអ្នកដែលថែរក្សាប្រដាប់ភេទរបស់ពួកគេ

30. លើកលែងតែចំពោះភរិយារបស់ខ្លួន ឬខ្ញុំបម្រើស្រីដាច់ថ្លៃដែលនៅក្រោមការគ្រប់គ្រងរបស់ពួកគេប៉ុណ្ណោះ។ ពិតប្រាកដណាស់ ពួកគេមិនត្រូវបានគេយកទោសពៃរ៍ឡើយ។

31. តែជនណាដែលស្វែងរក(ការត្រេកត្រអាល)ផ្សេងពីនោះ ជាការពិតណាស់ ពួកទាំងនោះហើយគឺជាពួកដែលបំពាន។

32. និងបណ្តាអ្នកដែលបំពេញនូវទំនុកចិត្ត និងកិច្ចសន្យារបស់ខ្លួន។

33. និងបណ្តាអ្នកដែលធ្វើសាក្សីដោយត្រឹមត្រូវ។

34. ហើយនិងបណ្តាអ្នកដែលថែរក្សាលើការសឡាតរបស់ខ្លួន។

35. អ្នកទាំងនោះហើយដែលស្ថិតក្នុងឋានសួគ៌ដែលត្រូវបានគេលើកតម្កើង។

36. តើមានអ្វីដែលធ្វើឱ្យពួកគ្មានជំនឿបដិសេធចំពោះអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)យ៉ាងលឿនបែបនេះ?

37. (ពួកគេ)ស្ថិតនៅទាំងខាងស្តាំ និងខាងឆ្វេង ជាក្រុមផ្សេងៗ។

38. តើបុគ្គលម្នាក់ៗនៃពួកគេប្រាថ្នាថានឹងត្រូវបានគេបញ្ចូលទៅក្នុងឋានសួគ៌ណាអ៊ីមឬ?

39. មិនដូច្នោះឡើយ! ពិតប្រាកដណាស់ យើង(អល់ឡោះ)បានបង្កើតពួកគេពីអ្វីដែលពួកគេបានដឹង។

40. ទ្រង់ស្បថនឹង(ព្រះអង្គឯកឯងដែលជា)ព្រះជាម្ចាស់នៃទិសខាងកើត និងទិសខាងលិចថា៖ ពិតប្រាកដណាស់ យើងគឺជាអ្នកមានសមត្ថភាពបំផុត

41. លើការជំនួសពួកគេ(ពួកមុស្លីគីន)នឹងក្រុមមួយដែលល្អប្រសើរជាងពួកគេ។ ហើយយើងពុំមែនអសមត្ថភាព(ក្នុងការធ្វើដូច្នោះ)នោះឡើយ។

42. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទុកឱ្យពួកគេលិចលង់ និងលេងសើចចុះ រហូតដល់ពួកគេជួបនឹងថ្ងៃរបស់ពួកគេដែលត្រូវបានគេសន្យា។

43. គឺនៅថ្ងៃដែលពួកគេក្រោកចេញពីផ្នូរយ៉ាងលឿនហាក់ដូចជាពួកគេប្រជែងគ្នាទៅកាន់រូបបដិមា(របស់ពួកគេ)ដូច្នោះដែរ។

44. កែវភ្នែករបស់ពួកគេទម្លាក់ចុះ ខណៈដែលភាពអាម៉ាស់បានគ្របដណ្តប់លើពួកគេ។ នោះហើយជាថ្ងៃដែលពួកគេធ្លាប់ត្រូវបានគេសន្យា។

ជំពូក ន្ហូហ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពិតប្រាកដណាស់ យើងបានបញ្ជូនព្យាការីន្ហូហទៅកាន់ក្រុមរបស់គេ (ហើយយើងបានមានបន្ទូលថា៖) ចូរអ្នកដាស់តឿនព្រមានក្រុមរបស់អ្នកមុននឹងទណ្ឌកម្មដ៏ឈឺចាប់បានមកដល់ពួកគេ។

2. គាត់បាននិយាយថា៖ ឱក្រុមរបស់ខ្ញុំ! ពិតប្រាកដណាស់ ខ្ញុំជាអ្នកដាស់តឿនព្រមានយ៉ាងច្បាស់លាស់សម្រាប់ពួកអ្នក។

3. ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះ(តែមួយគត់) និងកោតខ្លាចទ្រង់ ហើយគោរពប្រតិបត្តិតាមខ្ញុំ

4. នោះទ្រង់នឹងអភ័យទោសដល់ពួកអ្នកនូវបាបកម្មទាំងឡាយរបស់ពួកអ្នក ហើយទ្រង់នឹងពន្យារអាយុជីវិតពួកអ្នករហូតដល់ពេលវេលាដែលត្រូវបានកំណត់។ ពិតប្រាកដណាស់ ពេលវេលាកំណត់របស់អល់ឡោះ កាលណាវាមកដល់ គឺគេមិនពន្យារពេលឡើយ ប្រសិនបើពួកអ្នកបានដឹង។

5. គាត់បានពោលថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំបានអំពាវនាវក្រុមរបស់ខ្ញុំទាំងយប់ទាំងថ្ងៃ។

6. តែការអំពាវនាវរបស់ខ្ញុំ គ្មានបន្ថែមអ្វីដល់ពួកគេក្រៅពីការគេចចេញនោះឡើយ។

7. ហើយពិតប្រាកដណាស់ រាល់ពេលដែលខ្ញុំអំពាវនាវពួកគេដើម្បីព្រះអង្គអភ័យទោសដល់ពួកគេ ពួកគេបែរជាយកម្រាមដៃញ៉ុកត្រចៀកខ្លួនឯង និងបានយកសម្លៀកបំពាក់គ្របមុខ ហើយពួកគេនៅតែបន្ត(ប្រឆាំង) និងក្អេងក្អាងជាខ្លាំង។

8. បន្ទាប់មក ខ្ញុំពិតជាបានអំពាវនាវពួកគេដោយបើកចំហ។

9. ក្រោយមកទៀត ខ្ញុំពិតជាបានអំពាវនាវពួកគេដោយសំឡេងខ្លាំងៗ ហើយក៏បានអំពាវនាវពួកគេដោយស្ងាត់ៗផងដែរ។

10. ហើយខ្ញុំបាននិយាយទៅកាន់ពួកគេថា៖ ចូរពួកអ្នកសុំការអភ័យទោសពីព្រះជាម្ចាស់របស់ពួកអ្នកចុះ។ ពិតប្រាកដណាស់ទ្រង់ជាអ្នកដែលមហាអភ័យទោសបំផុត។

11. ទ្រង់នឹងបញ្ចុះទឹកភ្លៀងយ៉ាងច្រើនសន្ធឹកសន្ធាប់មកកាន់ពួកអ្នក។

12. ហើយទ្រង់នឹងប្រទាននូវទ្រព្យសម្បត្តិនិងកូនចៅជាច្រើនដល់ពួកអ្នក និងបង្កើតសម្រាប់ពួកអ្នកនូវចម្ការដំណាំជាច្រើន ហើយនិងបង្កើតសម្រាប់ពួកអ្នកនូវទន្លេជាច្រើនផងដែរ។

13. ហេតុអ្វីបានជាពួកអ្នកមិនខ្លាចចំពោះភាពធំធេងរបស់អល់ឡោះជាម្ចាស់ដូចនេះ?

14. ជាការពិតណាស់ ទ្រង់បានបង្កើតពួកអ្នកជាដំណាក់កាលៗ។

15. តើពួកអ្នកមិនបានឃើញទេឬ ថាតើអល់ឡោះទ្រង់បង្កើតមេឃប្រាំពីរជាន់តម្រៀបលើគ្នា

16. ព្រមទាំងបង្កើតនូវព្រះចន្ទនៅលើមេឃជាពន្លឺ និងបង្កើតព្រះអាទិត្យជាដាចង្កៀងយ៉ាងដូចម្តេច?

17. ហើយអល់ឡោះទ្រង់បានបង្កើតពួកអ្នកអំពីដី។

18. បន្ទាប់មក ទ្រង់ត្រលប់ពួកអ្នកទៅក្នុងដីវិញ(បន្ទាប់ពីស្លាប់)។ បន្ទាប់មកទៀត ទ្រង់នឹងបញ្ចេញពួកអ្នក(ពីដីមកវិញនៅថ្ងៃបរលោក)។

19. ហើយអល់ឡោះទ្រង់បានបង្កើតផែនដីឱ្យលាតសន្ធឹងសម្រាប់ពួកអ្នក

20. ដើម្បីឲ្យពួកអ្នកអាចធ្វើដំណើរនៅលើវាតាមផ្លូវដែលធំទូលាយជាច្រើន។

21. ព្យាការីនួហបានពោលថា៖ បពិត្រព្រះជាម្ចាស់! ពិតប្រាកដណាស់ ពួកគេបានប្រឆាំងនឹងខ្ញុំ ហើយពួកគេបែរជាដើរតាមជនដែលទ្រព្យសម្បត្តិ និងកូនចៅរបស់គេមិនបានបន្ថែមអ្វីដល់គេក្រៅតែពីភាពខាតបង់ទៅវិញ។

22. ហើយពួកគេបានប្រើល្បិចកលមួយយ៉ាងធំ។

23. ហើយពួកគេ(ពួកមេដឹកនាំ)បាននិយាយថា៖ ចូរពួកអ្នកកុំបោះបង់ព្រះទាំងឡាយរបស់ពួកអ្នក និងកុំបោះបង់បដិមាវ៉ាតទិន, ស៊ូវ៉ាក, យ៉ាហ្គូស, យ៉ាអ៊ូក, និងណាស់រ៍ ឲ្យសោះ។

24. ហើយជាការពិតណាស់ ពួកវាបានធ្វើឱ្យមនុស្សជាច្រើនវង្វេង។ ហើយសូមព្រះអង្គកុំបន្ថែមអ្វីដល់ពួកដែលបំពានក្រៅពីភាពវង្វេងនោះឡើយ។

25. ដោយសារតែកំហុសឆ្គងរបស់ពួកគេ ពួកគេត្រូវបានគេពន្លិច(ដោយទឹកជំនន់)។ ក្រោយមក ពួកគេត្រូវបានគេបញ្ចូលទៅក្នុងឋាននរក។ ពិតណាស់ ពួកគេគ្មានអ្នកជួយណាក្រៅពីអល់ឡោះឡើយ។

26. ហើយព្យាការីនួហបានពោលថា៖ បពិតព្រះជាម្ចាស់! សូមព្រះអង្គមេត្តាកុំទុកឱ្យពួកគ្មានជំនឿណាម្នាក់មានជីវិតនៅលើផែនដីឱ្យសោះ។

27. ជាការពិតណាស់ ប្រសិនបើព្រះអង្គទុកឱ្យពួកគេនៅមានជីវិត នោះពួកគេនឹងធ្វើឱ្យខ្ញុំបម្រើរបស់ព្រះអង្គវង្វេងជាមិនខាន។ ហើយពួកគេក៏គ្មានបង្កើតកូនចៅណាក្រៅពីកូនចៅដែលអាក្រក់ និងប្រឆាំងប៉ុណ្ណោះ។

28. បពិត្រព្រះជាម្ចាស់! សូមព្រះអង្គមេត្តាអភ័យទោសដល់ខ្ញុំ និងឪពុកម្តាយរបស់ខ្ញុំ ព្រមទាំងបណ្តាអ្នកដែលបានចូលក្នុងផ្ទះរបស់ខ្ញុំក្នុងនាមជាអ្នកមានជំនឿ និងបណ្តាអ្នកមានជំនឿទាំងប្រុសទាំងស្រីផង។ ហើយសូមព្រះអង្គមេត្តាកុំបន្ថែមអ្វីដល់ពួកដែលបំពាន ក្រៅពីភាពវិនាសនោះឡើយ។

ជំពូក អាល់ជិន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ គេបានផ្តល់វ៉ាហ៊ីមកកាន់ខ្ញុំថា ជាការពិតណាស់ មានមួយក្រុមក្នុងចំណោមពួកជិនបានមកស្តាប់ខ្ញុំ(សូត្រគម្ពីរគួរអាន)។ ហើយពួកគេបាននិយាយថា៖ ពិតប្រាកដណាស់ ពួកយើងបានឮនូវគម្ពីរគួរអានមួយដ៏អស្ចារ្យ

2. ដែលចង្អុលបង្ហាញទៅកាន់ភាពត្រឹមត្រូវ។ ដូចនេះ ពួកយើងក៏មានជំនឿចំពោះគម្ពីរនេះ ហើយពួកយើងមិនយកអ្នកណាម្នាក់មកធ្វើស្ពឹរិកនឹងព្រះជាម្ចាស់របស់ពួកយើងឡើយ។

3. ហើយជាការពិតណាស់ ព្រះជាម្ចាស់របស់ពួកយើងដ៏មហាខ្ពង់ខ្ពស់ ទ្រង់គ្មានភរិយា និងគ្មានបុត្រនោះឡើយ។

4. ហើយពិតប្រាកដណាស់ អ្នកមានបញ្ញាខ្សោយនៃពួកយើង(អ៊ីព្លីស)ធ្លាប់បាននិយាយប្រឌិតទៅលើអល់ឡោះនូវសម្តីដ៏ជ្រុលហួសហេតុ។

5. ហើយពិតប្រាកដណាស់ ពួកយើងធ្លាប់បានគិតថា ជាការពិតណាស់ មនុស្ស និងជិនមិននិយាយប្រឌិតកុហកលើអល់ឡោះជាដាច់ខាត។

6. ហើយពិតប្រាកដណាស់ មានបុរសជាច្រើនក្នុងចំណោមមនុស្សលោកធ្លាប់បានសុំពីបុរសនៃពួកជិន(ឱ្យការពារពួកគេ)។ តែពួកជិនទាំងនោះរឹតតែបន្ថែមនូវការភ័យខ្លាចដល់ពួកគេថែមទៀត។

7. ហើយពិតប្រាកដណាស់ ពួកគេ(ពួកគ្មានជំនឿ)បានគិតស្មានដូចពួកអ្នក(ជិនគ្មានជំនឿ)ដែរថា ពិតណាស់ អល់ឡោះនឹងមិនបង្កើតអ្នកណាម្នាក់ឲ្យរស់ឡើងវិញឡើយ។

8. ហើយពិតណាស់ ពួកយើងបានទាមទារ(ចង់ដឹង)ដំណឹងនៅលើមេឃ តែពួកយើងបានប្រទះឃើញថា មេឃពោរពេញទៅដោយអ្នកការពារដ៏រឹងមាំ និងដុំភ្លើងជាច្រើន។

9. ហើយជាការពិតណាស់ ពួកយើងធ្លាប់បានឈរជើងនៅតាមទីតាំងមួយចំនួននៅលើមេឃដើម្បីលួចស្តាប់(ដំណឹងផ្សេងៗពីម៉ាឡាអ៊ីកាត់)។ តែឥឡូវនេះ(ក្រោយពីព្យាការីមូហាំម៉ាត់ក្លាយជាអ្នកនាំសារ) នរណាហើយដែលលួចស្តាប់(ដំណឹងពីម៉ាឡាអ៊ីកាត់)រូបគេនឹងត្រូវទទួលរងនូវការគប់ដោយដុំភ្លើងជាមិនខាន។

10. ហើយពិតប្រាកដណាស់ ពួកយើងមិនដឹងនោះឡើយថា តើគេចង់ឱ្យអ្នកនៅលើផែនដីបានអាក្រក់ ឬមួយក៏ព្រះជាម្ចាស់របស់ពួកគេចង់ឱ្យពួកគេទទួលបានការចង្អុលបង្ហាញ។

11. ហើយពិតប្រាកដណាស់ ក្នុងចំណោមពួកយើង មានអ្នកខ្លះជាអ្នកដែលសាងកុសល ហើយមានអ្នកខ្លះទៀត គឺមិនដូច្នោះឡើយ។ ពួកយើងមានច្រើនក្រុមខុសៗគ្នា។

12. ហើយពិតប្រាកដណាស់ ពួកយើងបានដឹងយ៉ាងប្រាកដថា៖ ពួកយើងមិនអាចគេចផុតពី(បទបញ្ជា)អល់ឡោះនៅលើផែនដីនោះឡើយ ហើយពួកយើងក៏មិនអាចរត់គេចពី(ទណ្ឌកម្ម)ទ្រង់បាននោះដែរ។

13. ហើយពិតប្រាកដណាស់ នៅពេលដែលពួកយើងបានឮការចង្អុលបង្ហាញ(គម្ពីរគួរអាន) ពួកយើងក៏មានជំនឿលើវា។ ហេតុនេះ ជនណាហើយដែលមានជំនឿលើព្រះជាម្ចាស់របស់គេនោះ គឺគេមិនខ្លាចបាត់បង់ផលបុណ្យ ហើយក៏មិនខ្លាចគេបំពាននោះដែរ។

14. ហើយពិតប្រាកដណាស់ ក្នុងចំណោមពួកយើង មានអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម) ហើយក្នុងចំណោមពួកយើងក៏មានអ្នកដែលល្មើសបំពានផងដែរ។ ដូច្នេះ ជនណាដែលប្រគល់ខ្លួន អ្នកទាំងនោះហើយគឺជាអ្នកដែលស្វែងរកការចង្អុលបង្ហាញ។

15. រីឯពួកដែលល្មើសបំពានវិញ ពួកគេនឹងក្លាយជាអុសសម្រាប់នរកដើហាន់ណាំ។

16. ហើយប្រសិនបើពួកគេ(ជិននិងមនុស្សលោក)ដើរតាមមាគ៌ា(អ៊ីស្លាម)យើងពិតជានឹងផ្តល់ឱ្យពួកគេនូវទឹកភ្លៀងយ៉ាងច្រើនជាមិនខាន

17. ដើម្បីយើងនឹងសាកល្បងពួកគេនឹងវា។ ហើយជនណាដែលងាកចេញពីការរំលឹកនៃព្រះជាម្ចាស់របស់ខ្លួន គេនឹងបញ្ចូលរូបគេទៅក្នុងទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

18. ហើយពិតប្រាកដណាស់ ម៉ាស្ជិទទាំងឡាយ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។ ហេតុនេះ ពួកអ្នកមិនត្រូវបួងសួងសុំពីអ្នកណាម្នាក់រួមជាមួយនឹងអល់ឡោះឡើយ។

19. ហើយពិតប្រាកដណាស់ នៅពេលដែលខ្ញុំបម្រើម្នាក់របស់អល់ឡោះ(ព្យាការីមូហាំម៉ាត់) បានក្រោកឈរគោរពសក្ការៈចំពោះទ្រង់ ពួកគេ(ជិន)ស្ទើរតែប្រជ្រៀតជាន់លើគ្នា(ដើម្បីស្តាប់ការសូត្រគម្ពីរគួរអាន)ទៅហើយ។

20. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ តាមពិតខ្ញុំបួងសួងសុំពីព្រះជាម្ចាស់របស់ខ្ញុំ(តែមួយគត់) ហើយខ្ញុំមិនយកអ្នកណាម្នាក់មកធ្វើស្ទើរីកជាមួយនឹងទ្រង់ជាដាច់ខាត។

21. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំគ្មានលទ្ធភាពការពារពួកអ្នកពីគ្រោះថ្នាក់នោះឡើយ ហើយខ្ញុំក៏គ្មានលទ្ធភាពផ្តល់ការចង្អុលបង្ហាញ(ដល់ពួកអ្នក)នោះដែរ។

22. ចូរអ្នកពោលទៀតថា៖ គ្មានអ្នកណាម្នាក់អាចជួយសង្គ្រោះរូបខ្ញុំពី(ទណ្ឌកម្ម)អល់ឡោះបានឡើយ ហើយខ្ញុំក៏គ្មានកន្លែងជ្រកកោនណាក្រៅពីទ្រង់នោះដែរ។

23. ប៉ុន្តែ ខ្ញុំអាចផ្សព្វផ្សាយពីអល់ឡោះ និងសាររបស់ទ្រង់។ ហើយជនណាដែលប្រឆាំងនឹងអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ពិតប្រាកដណាស់ សម្រាប់រូបគេ គឺនរកដើហាន់ណាំដោយរូបគេស្ថិតនៅក្នុងវាជាអមតៈ។

24. លុះដល់ពេលដែលពួកគេ(ពួកមុស្លរីគីន)បានឃើញនូវអ្វី(ទណ្ឌកម្ម)ដែលគេបានសន្យាចំពោះពួកគេ នៅពេលនោះ ពួកគេនឹងដឹងថា តើអ្នកណាជាអ្នកដែលមានអ្នកជួយដ៏ខ្សោយជាងគេ និងមានបក្សពួកតិចជាងគេ?

25. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ខ្ញុំមិនដឹងទេថា តើអ្វីដែលគេបានសន្យាចំពោះពួកអ្នកនោះនឹងកើតឡើងឆាប់ៗ ឬក៏ព្រះជាម្ចាស់របស់ខ្ញុំធ្វើឲ្យវានៅមានពេលវែង(ទៅមុខ)ទៀត?

26. (ទ្រង់)ជាអ្នកដឹងនូវប្រការអាថ៌កំបាំង។ ដូចនេះ ទ្រង់មិនលាតត្រដាងអាថ៌កំបាំងរបស់ទ្រង់ឱ្យនរណាម្នាក់ដឹងឡើយ

27. លើកលែងតែជនណាដែលទ្រង់ពេញចិត្តក្នុងចំណោមអ្នកនាំសារ(របស់ទ្រង់)ប៉ុណ្ណោះ។ ហើយទ្រង់បានចាត់តាំងអ្នកយាម(ម៉ាឡាអ៊ីកាត់)នៅពីខាងមុខនិងនៅពីក្រោយអ្នកនាំសារនោះ។

28. ដើម្បីឱ្យអ្នកនាំសារ(មូហាំម៉ាត់)ដឹងថា ជាការពិតណាស់ ពួកគេ(អ្នកនាំសារទាំងឡាយ)ពិតជាបានផ្សព្វផ្សាយសារនៃព្រះជាម្ចាស់របស់ពួកគេប្រាកដមែន។ ហើយទ្រង់ដឹងជ្រួតជ្រាបបំផុតចំពោះអ្វីដែលមាននៅនឹងពួកគេ។ ហើយទ្រង់ដឹងពីចំនួននៃគ្រប់អ្វីៗទាំងអស់។

ជំពូក អាល់មុសហ្សាំមិល

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱអ្នកដែលដណ្តប់ក្បួយ(ព្យាការីមូហាំម៉ាត់)!

2. ចូរអ្នកក្រោកប្រតិបត្តិសឡាតនៅពេលយប់ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ។

3. (ចូរក្រោកសឡាតឱ្យបាន)ពាក់កណ្តាលយប់ ឬតិចជាងពាក់កណ្តាលយប់បន្តិច។

4. ឬអាចបន្ថែមច្រើនជាងពាក់កណ្តាលយប់ក៏បាន។ ហើយចូរអ្នកសូត្រគម្ពីរគួរអានឱ្យច្បាស់ៗ មួយៗ។

5. ពិតប្រាកដណាស់ យើងនឹងបញ្ចុះឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវពាក្យពេចន៍ដ៏ធ្ងន់មួយ(គម្ពីរគួរអាន)។

6. ពិតប្រាកដណាស់ ការគោរពសក្ការៈនៅពេលយប់ គឺមានឥទ្ធិពលលើដួងចិត្តជាង និងសូត្របានត្រឹមត្រូវជាង។

7. ពិតប្រាកដណាស់ សម្រាប់អ្នក(ព្យាការីមូហាំម៉ាត់)នៅពេលថ្ងៃ គឺបានចំណាយពេលច្រើនលើកិច្ចការងារផ្សេងៗ។

8. ហើយចូរអ្នករំឭកព្រះនាមនៃព្រះជាម្ចាស់របស់អ្នក ហើយចូរអ្នកផ្តាច់ខ្លួនទៅកាន់ការគោរពសក្ការៈចំពោះទ្រង់ដោយពេញលេញ។

9. (ទ្រង់)ជាព្រះជាម្ចាស់នៃទិសខាងកើត និងទិសខាងលិច។ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ហេតុនេះ ចូរអ្នកយកទ្រង់ធ្វើជាអ្នកគាំពារចុះ។

10. ចូរអ្នក(ព្យាការីមូហាំម៉ាត់)អត់ធ្មត់ចំពោះអ្វីដែលពួកគេនិយាយ និងត្រូវចេញឱ្យឆ្ងាយពីពួកគេក្នុងលក្ខណៈមួយដ៏ល្អប្រពៃ។

11. ហើយចូរអ្នកទុកយើង និងពួកបដិសេធដែលទទួលបានឧបការគុណ ហើយនិងពន្យារពេលឱ្យពួកគេបន្តិចសិនចុះ។

12. ពិតប្រាកដណាស់ (នៅថ្ងៃបរលោក) យើងមានខ្សែច្រវាក់ដ៏ធ្ងន់ និងភ្លើងនរកដែលឆាបឆេះ

13. ព្រមទាំងចំណីអាហារដែលធ្វើឱ្យស្លាក់ ហើយនិងទណ្ឌកម្មដ៏សែនឈឺចាប់បំផុត(សម្រាប់ពួកគេ)។

14. គឺនៅថ្ងៃដែលផែនដីនិងភ្នំទាំងឡាយញ័ររញ្ជួយ ហើយភ្នំទាំងឡាយនឹងក្លាយទៅជាពំនូកខ្សាច់ដែលប៉ើងខ្ចាត់ខ្ចាយ។

15. ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នកនាំសារម្នាក់ទៅកាន់ពួកអ្នក(គឺព្យាការីមូហាំម៉ាត់)ដែលធ្វើជាសាក្សីលើពួកអ្នក ដូចដែលយើងបានបញ្ជូនអ្នកនាំសារម្នាក់(ព្យាការីមូសា)ទៅកាន់ហ្វៀរអោនដែរ។

16. តែហ្វៀរអោនបែរជាប្រឆាំងនឹងអ្នកនាំសារនោះ។ ហេតុនេះ យើងក៏បានដាក់ទណ្ឌកម្មគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

17. តើពួកអ្នកអាចការពារខ្លួនពួកអ្នកយ៉ាងដូចម្តេចនៅថ្ងៃមួយដែលធ្វើឱ្យក្មេងតូចឡើងស្កូវ ប្រសិនបើពួកអ្នកប្រឆាំងនោះ?

18. មេឃបានប្រេះបែកព្រោះតែភាពរន្ធត់របស់វា។ ការសន្យារបស់ទ្រង់នឹងកើតឡើងយ៉ាងពិតប្រាកដ។

19. ពិតប្រាកដណាស់នេះជាការដាស់រំឭកមួយ។ ហេតុនេះ ជនណាដែលមានបំណងទទួលយកការដាស់រំលឹក ចូរឲ្យគេជ្រើសយកមាគ៌ាទៅកាន់ព្រះជាម្ចាស់របស់គេចុះ។

20. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា ពិតណាស់ អ្នកបានក្រោកសឡាតតិចជាងពីរភាគបីនៃពេលយប់ ជួនកាលពាក់កណ្តាលយប់ និងជួនកាលមួយភាគបីនៃពេលយប់។ ហើយក្រុមមួយក្នុងចំណោមអ្នកដែលនៅជាមួយអ្នក (ក៏ពួកគេធ្វើដូច្នោះដែរ)។ ហើយអល់ឡោះទ្រង់បានកំណត់ពេលយប់និងពេលថ្ងៃ។ ទ្រង់ដឹងថាពួកអ្នកពុំមានសមត្ថភាព(សឡាតពេញមួយយប់)នោះឡើយ។ ហេតុនេះ ទ្រង់ក៏បានបន្ធូរបន្ថយដល់ពួកអ្នក។ ដូច្នេះ ចូរពួកអ្នកសូត្រនូវអ្វីដែលងាយស្រួលសម្រាប់ពួកអ្នកអំពីគម្ពីរគួរអាន។ ទ្រង់ក៏បានដឹងដែរថា ក្នុងចំណោមពួកអ្នក គឺនឹងមានអ្នកដែលមានជំងឺ ហើយមានអ្នកផ្សេងទៀតត្រូវធ្វើដំណើរលើផែនដីដើម្បីស្វែងរកការប្រោសប្រទានពីអល់ឡោះ ហើយក៏មានអ្នកផ្សេងទៀត ត្រូវចេញប្រយុទ្ធក្នុងមាគ៌ារបស់អល់ឡោះ។ ហេតុនេះ ចូរពួកអ្នកសូត្រនូវអ្វីដែលងាយស្រួលសម្រាប់ពួកអ្នកអំពីគម្ពីរគួរអានចុះ។ ហើយចូរពួកអ្នកប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់ ព្រមទាំងឲ្យអល់ឡោះខ្ចីនូវកម្ចីមួយដ៏ល្អប្រពៃ។ ហើយប្រការល្អណាមួយដែលពួកអ្នកបានសាងវាសម្រាប់ខ្លួនឯង នោះពួកអ្នកពិតជានឹងឃើញវានៅឯអល់ឡោះជាម្ចាស់ ហើយវាល្អប្រសើរជាង និងទទួលបានផលបុណ្យធំធេងជាង។ ហើយចូរពួកអ្នកសុំការអភ័យទោសពីអល់ឡោះចុះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រលាញ់។

ជំពូក អាល់មុទឍ្ហាសសៀរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ឱអ្នកដែលដណ្តប់ភួយ(ព្យាការីមូហាំម៉ាត់)!
2. ចូរក្រោកឡើង រួចដាស់តឿនព្រមាន(មនុស្សលោក)។
3. ហើយចំពោះព្រះជាម្ចាស់របស់អ្នក ចូរអ្នកលើកតម្កើង។
4. ហើយចំពោះសម្លៀកបំពាក់របស់អ្នក ចូរអ្នកសម្អាត។
5. ហើយចំពោះរូបបដិមា ចូរអ្នកចៀសឱ្យឆ្ងាយ។
6. ហើយចូរកុំឲ្យអ្វីមួយដល់អ្នកដទៃដោយប្រាថ្នាចង់បានការតបស្នងច្រើនមកវិញឲ្យសោះ។
7. ហើយចំពោះ(បទបញ្ជា)ព្រះជាម្ចាស់របស់អ្នក ចូរអ្នកអត់ធ្មត់។
8. នៅពេលដែលគេផ្លុំត្រែ(លើកទីពីរ)
9. ថ្ងៃនោះហើយគឺជាថ្ងៃដែលលំបាកបំផុត
10. ចំពោះពួកគ្មានជំនឿ ដោយគ្មានភាពងាយស្រួលឡើយ។
11. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ទុកយើង និងអ្នកដែលយើងបានបង្កើតគេមកតែឯង
12. ហើយយើងបានធ្វើឱ្យគេក្លាយជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ
13. និងមានកូនច្រើនរស់នៅជុំគ្នា
14. ព្រមទាំងបានប្រទានដល់គេនូវជីវិតរស់នៅដែលស្រណុកសុខស្រួល។

15. បន្ទាប់មក គេនៅតែមានភាពលោភលន់ចង់ឱ្យយើងបន្ថែម(ឱ្យគេ)ថែមទៀត។

16. មិនដូច្នោះទេ! ពិតប្រាកដណាស់ គេគឺជាអ្នកដែលប្រឆាំងរឹងរូសចំពោះវាក្យខណ្ឌទាំងឡាយរបស់យើង។

17. យើងនឹងដាក់ទណ្ឌកម្មលើគេកាន់តែខ្លាំង។

18. ជាការពិតណាស់ រូបគេបានរិះគិត និងបានរៀប(ពាក្យចោទប្រកាន់)។

19. ពិតណាស់ រូបគេត្រូវបានគេដាក់បណ្តាសា។ តើគេអាចរៀប(ពាក្យចោទប្រកាន់)បានយ៉ាងដូចម្តេច?

20. បន្ទាប់មក រូបគេត្រូវបានគេដាក់បណ្តាសា។ តើគេអាចរៀប(ពាក្យចោទប្រកាន់)បានយ៉ាងដូចម្តេច?

21. បន្ទាប់មកទៀត គេបានត្រិះរិះពិចារណា(សាជាថ្មី)។

22. ក្រោយមក គេធ្វើមុខក្រញូវ ហើយខឹងមួម៉ៅ។

23. ក្រោយមកទៀត គេបានបែរចេញ និងបានក្រអឺតក្រទម

24. រួចគេនិយាយថា៖ ពិតណាស់ (គម្ពីរគួរអាន)នេះ គ្មានអ្វីក្រៅពីមន្តអាគមដែលគេទទួលបាន(ពីអ្នកជំនាន់មុន)ប៉ុណ្ណោះ។

25. (គម្ពីរគួរអាន)នេះ គ្មានអ្វីក្រៅពីពាក្យសម្តីមនុស្សធម្មតាប៉ុណ្ណោះ។

26. យើង(អល់ឡោះ)នឹងបញ្ចូលរូបគេទៅក្នុងនរកសាកើរ។

27. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា តើនរកសាកើរជាអ្វីនោះ?

28. វាមិនបន្សល់ទុកអ្វី ហើយវាក៏មិនទុកអ្វីចោលដែរ(គឺបំផ្លាញទាំងអស់)។

29. វាធាបឆេះធ្វើឱ្យស្បែកប្រែ។

30. នៅលើនរកនោះ មាន(ម៉ាឡាអ៊ីកាត់)ដប់ប្រាំបួននាក់។

31. ហើយយើងមិនបានបង្កើតឆ្មាំនរកក្រៅពីម៉ាឡាអ៊ីកាត់ឡើយ។ ហើយយើងក៏មិនបានបង្កើតចំនួនរបស់ពួកគេ(ម៉ាឡាអ៊ីកាត់)នោះដែរ លើកលែងតែដើម្បីជាការសាកល្បងចំពោះពួកដែលគ្មានជំនឿប៉ុណ្ណោះ ដើម្បីឱ្យពួកដែលគេផ្តល់គម្ពីរឲ្យមានការជឿជាក់យ៉ាងច្បាស់ និងដើម្បីឲ្យបណ្តាអ្នកដែលមានជំនឿកាន់តែបន្ថែមនូវសេចក្តីជំនឿថែមទៀត និងដើម្បីកុំឱ្យពួកដែលគេផ្តល់គម្ពីរឲ្យ ព្រមទាំងបណ្តាអ្នកដែលមានជំនឿមានការសង្ស័យ ហើយនិងដើម្បីឱ្យពួកដែលក្នុងដួងចិត្តរបស់ពួកគេមានជំងឺ និងពួកប្រឆាំងនិយាយថា៖ តើអល់ឡោះមានបំណងអ្វីចំពោះការលើកឧទាហរណ៍នេះ។ ក៏ដូច្នោះដែរ អល់ឡោះធ្វើឱ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនា និងចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។ ហើយគ្មាននរណាម្នាក់ដឹងពីចំនួនកងទ័ពនៃព្រះជាម្ចាស់របស់អ្នកឡើយ។ ហើយវា(ហាននរក)គ្មានអ្វីក្រៅពីការដាស់រំឭកដល់មនុស្សលោកនោះឡើយ។

32. មិនដូច្នោះឡើយ។ (អល់ឡោះ)ទ្រង់ស្បថនឹងព្រះចន្ទ។

33. ហើយទ្រង់ស្បថនឹងពេលយប់នៅពេលដែលវាបានរំលងផុតទៅ។

34. ហើយទ្រង់ស្បថនឹងពេលព្រលឹមនៅពេលដែលវាបញ្ចោញរស្មី។

35. ជាការពិតណាស់វា(ហាននរក)ជាការសាកល្បងមួយដ៏ធំធេង

36. ដើម្បីជាការព្រមានបន្លាចដល់មនុស្សលោក។

37. សម្រាប់ជនណាក្នុងចំណោមពួកអ្នកដែលចង់ដើរទៅមុខ(មានជំនឿ)ឬចង់ដើរថយក្រោយ(ប្រឆាំង)។

38. រាល់បុគ្គលគ្រប់រូប គឺទទួលខុសត្រូវចំពោះអ្វីដែលរូបគេបានសាង។

39. លើកលែងតែក្រុមខាងស្តាំ(អ្នកមានជំនឿ)ប៉ុណ្ណោះ។

40. ពួកគេសួរនាំគ្នាទៅវិញទៅមកនៅក្នុងឋានសួគ៌

41. អំពីពួកឧក្រិដ្ឋជនទាំងឡាយថា៖

42. តើមូលហេតុអ្វីទៅទើបគេបញ្ចូលពួកអ្នកទៅក្នុងនរកសាកើរដូចនេះ?

43. ពួកគេឆ្លើយថា៖ (ដោយសារតែ)ពួកយើងមិនធ្លាប់ស្ថិតក្នុងចំណោមអ្នកដែលប្រតិបត្តិសឡាតឡើយ។

44. ហើយពួកយើងក៏មិនធ្លាប់បានផ្តល់អាហារដល់ជនក្រីក្រនោះដែរ។

45. ហើយពួកយើងធ្លាប់និយាយមិនត្រឹមត្រូវជាមួយពួកដែលវង្វេង។

46. ហើយពួកយើងធ្លាប់បានបដិសេធថ្ងៃបរលោក

47. រហូតដល់សេចក្តីស្លាប់បានមកដល់ពួកយើង។

48. ហើយការធ្វើអន្តរាគមន៍ពីបណ្តាអ្នកធ្វើអន្តរាយទាំងឡាយ គឺគ្មានផ្តល់ជាប្រយោជន៍អ្វីដល់ពួកគេឡើយ។

49. តើហេតុអ្វីទៅបានជាពួកគេ(ពួកមុស្តរីគីន)ងាកចេញពីការដាស់រំលឹក(គម្ពីរគួរអាន)

50. ពួកគេហាក់បីដូចជាសត្វលាដែលផ្អើលខ្លាំង

51. ដែលវារត់គេចពីសត្វតោ។

52. ផ្ទុយទៅវិញ បុគ្គលម្នាក់ៗក្នុងចំណោមពួកគេចង់ឱ្យគេផ្តល់ឲ្យនូវគម្ពីរមួយដែលល្អីសុសសាយ។

53. មិនដូច្នោះឡើយ។ ផ្ទុយទៅវិញ ពួកគេមិនខ្លាចថ្ងៃបរលោកឡើយ។

54. ពិតប្រាកដណាស់ វា(គម្ពីរគួរអាន)ជាការដាស់រឭក។

55. ដូចនេះ ជនណាដែលចង់ទទួលការដាស់រំលឹក គេនឹងយកវាជាការដាស់រំលឹក។

56. ហើយពួកគេមិនយកវាជាការដាស់រំលឹកនោះឡើយ លើកលែងតែអល់ឡោះមានចេតនាប៉ុណ្ណោះ។ ទ្រង់គឺជាអ្នកដែលគេត្រូវកោតខ្លាច និងជាអ្នកដែលអភ័យទោស។

ជំពូក អាល់គីយ៉ាម៉ះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ទ្រង់ស្បថនឹងថ្ងៃបរលោក។
2. ហើយទ្រង់ស្បថនឹងវិញ្ញាណដែលចេះស្តីបន្ទោស។
3. តើមនុស្សលោកគិតស្មានថា យើងមិនអាចប្រមូលធ្មុំឆ្អឹងរបស់គេឬ?
4. ពិតមែនហើយ យើងពិតជាមានសមត្ថភាពក្នុងការតម្រៀបម្រាមដៃរបស់គេ(ឱ្យដូចដើមវិញ)។
5. ផ្ទុយទៅវិញ មនុស្សលោកចង់បន្តប្រព្រឹត្តអំពើអាក្រក់តទៅមុខទៀត។
6. គេសួរថា៖ តើថ្ងៃបរលោកនឹងកើតឡើងនៅពេលណា?
7. នៅពេលដែលភ្នែកភ័យស្លន់ស្លោ
8. ហើយព្រះចន្ទបានបាត់ពន្លឺ
9. ហើយព្រះអាទិត្យនិងព្រះចន្ទត្រូវបានគេប្រមូល
10. នៅថ្ងៃនោះ មនុស្សលោកនឹងនិយាយថា៖ តើត្រូវរត់គេចទៅកន្លែងណា?
11. ទេ! គ្មានកន្លែងរត់គេចឡើយ។
12. កន្លែងវិលត្រឡប់នៅថ្ងៃនោះ គឺមានតែឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់អ្នកប៉ុណ្ណោះ។
13. នៅថ្ងៃនោះ គេនឹងប្រាប់មនុស្សលោកនូវអ្វីដែលរូបគេបានប្រព្រឹត្តកន្លងមក និងអ្វីដែលរូបគេមិនទាន់បានប្រព្រឹត្ត។
14. ផ្ទុយទៅវិញ មនុស្សលោកគឺជាសាក្សីប្រឆាំងនឹងខ្លួនឯង។

15. ទោះបីជាគេនាំមកនូវលេសដោះសារយ៉ាងច្រើនក៏ដោយ។

16. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)កុំកម្រើកអណ្តាតរបស់អ្នកសូត្រគម្ពីរគួរអាន(លឿនពេក) ព្រោះតែប្រញាប់ទន្ទេញគម្ពីរនេះឲ្យសោះ។

17. ពិតប្រាកដណាស់ យើងជាអ្នកទទួលខុសត្រូវប្រមូលផ្តុំគម្ពីរនេះ ហើយឱ្យអ្នកសូត្រគម្ពីរនេះ(បានត្រឹមត្រូវ)។

18. ដូច្នេះ នៅពេលណាដែលអ្នកនាំសាររបស់យើង(ម៉ាឡាអ៊ីកាត់ជីព្រីល)សូត្រគម្ពីរនេះ ចូរអ្នកស្តាប់និងសូត្រតាមការសូត្ររបស់គេ។

19. បន្ទាប់មក ពិតប្រាកដណាស់ យើងមានតួនាទីជាអ្នកបកស្រាយបញ្ជាក់គម្ពីរនេះ(ដល់អ្នក)។

20. មិនដូច្នោះឡើយ។ ផ្ទុយទៅវិញ ពួកអ្នកស្រលាញ់ពេញចិត្ត(ការរស់នៅក្នុង)លោកិយ

21. ហើយបោះបង់ថ្ងៃបរលោក។

22. ទឹកមុខ(អ្នកមានជំនឿ)នៅថ្ងៃនោះ គឺស្រស់ស្រាយ

23. ដោយសម្លឹងមើលទៅកាន់ព្រះជាម្ចាស់របស់គេ។

24. រីឯទឹកមុខ(ពួកគ្មានជំនឿ)នៅថ្ងៃនោះ គឺក្រញូវ

25. ដោយរូបគេដឹងច្បាស់ថា រូបគេពិតជានឹងត្រូវទទួលនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរជាមិនខាន។

26. មិនដូច្នោះឡើយ។ នៅពេលដែលព្រលឹងបានមកដល់បំពង់ក

27. គេនិយាយទៅកាន់គ្នាថា៖ តើមាននរណាអាចព្យាបាលគេបាន ?

28. ហើយគេដឹង(ខ្លួនឯង)យ៉ាងច្បាស់ថា ពិតណាស់ រូបគេនឹងត្រូវលាចាក(លោកិយ)ជាមិនខាន។

29. ស្ថានភាពដ៏លំបាកបំផុតបានប្រមូលផ្តុំគ្នានៅចុងក្រោយនៃជីវិតលោកិយ និងពេលចាប់ផ្តើមនៃជីវិតបរលោក។

30. នៅថ្ងៃនោះ គេនឹងនាំរូបគេទៅកាន់ព្រះជាម្ចាស់របស់គេ។

31. ពិតណាស់ គេមិនបានជឿជាក់ ហើយក៏មិនបានប្រតិបត្តិសឡាតនោះដែរ។

32. ក៏ប៉ុន្តែ គេបានបដិសេធ និងបែរចេញ។

33. ក្រោយមក គេបានដើរទៅជួបក្រុមគ្រួសាររបស់គេដោយភាពក្រអឺតក្រទម។

34. អន្តរាយហើយសម្រាប់ឯង ហើយក៏អន្តរាយទៀត។

35. ក្រោយមក អន្តរាយហើយសម្រាប់ឯង ហើយក៏អន្តរាយទៀត។

36. តើមនុស្សលោកគិតស្មានថា រូបគេត្រូវបានគេបោះបង់ចោលដោយមិនដំនុំជម្រះឬ?

37. តើមនុស្សមិនបានកើតមកពីតំណក់ទឹកកាមដែលចូលទៅក្នុងស្បូនទេឬ?

38. ក្រោយមក គេក៏ក្លាយទៅជាដុំឈាម ហើយទ្រង់បានបង្កើតរូបគេ រួចធ្វើឱ្យគេមានរូបរាងពេញលេញ។

39. ក្រោយមកទៀត ទ្រង់បានបង្កើតគេឱ្យមានជាគូៗ(ប្រុស ស្រី)។

40. តើអ្នកដែលអាចធ្វើដូច្នោះ ពុំមែនជាអ្នកដែលមានសមត្ថភាពក្នុងការធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញទេឬ?

ជំពូក អាល់អ៊ីនសាន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ជាការពិតណាស់ រយៈពេលដ៏យូរបានកន្លងផុតមុនពេលដែលមនុស្សមានវត្តមាន ខណៈដែលគេពុំទាន់ជាអ្វីមួយដែលត្រូវគេរំលឹកនៅឡើយ។

2. ជាការពិតណាស់ យើងបានបង្កើតមនុស្សពីតំណក់(ទឹកកាម)ដែលលាយចូលគ្នា ដើម្បីយើងនឹងសាកល្បងគេ។ បន្ទាប់មក យើងបានឱ្យគេស្តាប់ឮ និងមើលឃើញ។

3. ពិតប្រាកដណាស់ យើងបានបញ្ជាក់ដល់គេនូវមាគ៌ា(ចង្អុលបង្ហាញនិងមាគ៌ាដែលវង្វេង)។ (ក្រោយមក) រូបគេអាចជាអ្នកដឹងគុណ ឬជាអ្នកដែលប្រឆាំង។

4. ជាការពិតណាស់ យើងបានត្រៀមទុកសម្រាប់ពួកដែលប្រឆាំងនូវច្រវាក់ និងខ្នោះ ព្រមទាំងភ្លើងដែលឆេះសន្ធោសន្ធៅ។

5. ពិតប្រាកដណាស់ អ្នកសាងអំពើល្អទាំងឡាយ (នៅក្នុងថ្ងៃបរលោក) ពួកគេទទួលទានស្រាដែលលាយជាមួយទឹកក្រអូបកាហ្វូរ។

6. ជាប្រភពទឹកដែលខ្ញុំបម្រើអល់ឡោះទទួលទានដែលវាហូរទៅគ្រប់ទីកន្លែងដែលពួកគេត្រូវការ។

7. ពួកគេ(ជាអ្នកដែល)បានបំពេញតាមបំណន់ ហើយពួកគេខ្លាចថ្ងៃមួយដែលប្រការអាក្រក់របស់វារាលដាលគ្រប់ទីកន្លែង(ថ្ងៃបរលោក)។

8. ហើយពួកគេផ្តល់អាហារដែលពួកគេចូលចិត្តទៅឱ្យជនក្រីក្រ ក្មេងកំព្រា និងឈ្លើយសឹក។

9. (ពួកគេនិយាយថា៖) តាមពិត ពួកយើងផ្តល់អាហារដល់ពួកអ្នក គឺដើម្បីទទួលបានការពេញចិត្តពីអល់ឡោះប៉ុណ្ណោះ ដោយពួកយើងមិនចង់បានការតបស្នង និងការថ្លែងអំណរគុណអ្វីពីពួកអ្នកឡើយ។

10. ពិតណាស់ ពួកយើងខ្លាចព្រះជាម្ចាស់របស់ពួកយើងនៅថ្ងៃមួយដែល(ពួកគ្មានជំនឿ)មានទឹកមុខក្រញូវ ដោយសារតែក្តីរន្ធត់(ក្នុងថ្ងៃនោះ)។

11. ដូច្នេះ អល់ឡោះជាម្ចាស់ក៏បានការពារពួកគេពីគ្រោះអាក្រក់នៃថ្ងៃនោះ ហើយទ្រង់បានប្រទានឱ្យពួកគេនូវពន្លឺដ៏ត្រចះត្រចង់ និងក្តីរីករាយ។

12. ហើយទ្រង់បានតបស្នងដល់ពួកគេនូវឋានសួគ៌ និង(សម្លៀកបំពាក់អំពី)សូត្រដោយសារតែអ្វីដែលពួកគេបានអត់ធ្មត់។

13. ពួកគេទំរេតខ្លួនលើគ្រែក្នុងឋានសួគ៌នោះ។ នៅក្នុងឋានសួគ៌នោះដែរ ពួកគេមិនត្រូវកំដៅថ្ងៃ ហើយក៏មិនត្រជាក់ខ្លាំងដែរ។

14. ហើយម្លប់ដើមឈើរបស់វានៅជិតពួកគេ ហើយផ្លែឈើរបស់វាត្រូវបានគេធ្វើឱ្យងាយស្រួលសម្រាប់ពួកគេបេះបំផុត។

15. ហើយមានអ្នកបម្រើជុំវិញពួកគេដោយមានភាជន៍ធ្វើអំពីប្រាក់ និងពែងថ្មកែវ។

16. ថ្មកែវនោះធ្វើអំពីប្រាក់ដោយត្រូវបានកំណត់កម្រិត(ចំណុះ)យ៉ាងសមល្មម។

17. ហើយពួកគេត្រូវបានគេបម្រើស្រាដែលមានលាយជាមួយខ្ញី។

18. (ពួកគេទទួលទានពី)ប្រភពស្រានៅក្នុងឋានសួគ៌ដែលគេឱ្យឈ្មោះថា សាល់សាប៊ីល។

19. ហើយមានក្មេងៗដែលមានវ័យក្មេងជានិច្ចដើរជុំវិញ(ចាំបម្រើ)ពួកគេ។ នៅពេលដែលអ្នកឃើញពួកគេ អ្នកនឹងគិតថា ពួកគេជាគជ់ខ្សែដ៏ភ្លឺចែងចាំង។

20. ហើយនៅពេលដែលអ្នកមើល(គ្រប់ទីកន្លែង)ក្នុងឋានសួគ៌នោះ អ្នកនឹងឃើញនូវការប្រោសប្រទាន(គ្រប់បែបយ៉ាង)និងអំណាចដ៏ធំធេង។

21. នៅពីលើខ្លួនប្រាណរបស់ពួកគេ គឺ(គ្របដណ្តប់ដោយ)សម្លៀកបំពាក់ពណ៌បៃតងធ្វើអំពីសូត្រម៉ដ្ឋខៃ និងសូត្រក្រាស់ ព្រមទាំងត្រូវបានគេបំពាក់ដោយកងដៃធ្វើអំពីប្រាក់។ ហើយព្រះជាម្ចាស់បានប្រទានឱ្យពួកគេនូវភេសជ្ជៈដ៏បរិសុទ្ធ។

22. (ហើយមានគេនិយាយទៅកាន់ពួកគេថា៖) ពិតប្រាកដណាស់ ទាំងអស់នេះ គឺជាការតបស្នងសម្រាប់ពួកអ្នក។ ហើយការប្រឹងប្រែងរបស់ពួកអ្នកត្រូវបានគេទទួលយក។

23. ពិតប្រាកដណាស់ យើងបានបញ្ចុះគម្ពីរគួរអានឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ជាដំណាក់កាលៗ។

24. ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អត់ធ្មត់ចំពោះការកំណត់នៃព្រះជាម្ចាស់របស់អ្នក ហើយអ្នកមិនត្រូវប្រតិបត្តិតាមអ្នកដែលប្រព្រឹត្តបាបកម្ម ឬអ្នកដែលប្រឆាំងក្នុងចំណោមពួកគេឡើយ។

25. ហើយចូរអ្នករំឭកព្រះនាមនៃព្រះជាម្ចាស់របស់អ្នកទាំងព្រឹក ទាំងល្ងាច។

26. ហើយមួយផ្នែកនៃពេលយប់ ចូរអ្នកស៊ូជោតចំពោះទ្រង់ និងប្រតិបត្តិសឡាតចំពោះទ្រង់ឱ្យបានយូរ។

27. ពិតប្រាកដណាស់ ពួក(មុស្លីគីន)ទាំងនោះ ពួកគេស្រលាញ់(ការរស់នៅក្នុង)លោកិយ ហើយពួកគេបោះបង់ថ្ងៃដ៏សែនធ្ងន់ធ្ងរបំផុត(ថ្ងៃបរលោក)ដាក់ពីក្រោយខ្នងពួកគេ។

28. យើងជាអ្នកដែលបានបង្កើតពួកគេ និងបានធ្វើឱ្យរាងកាយពួកគេមានភាពរឹងមាំ។ ហើយប្រសិនបើយើងមានចេតនា យើងប្រាកដជានឹងផ្លាស់ប្តូរក្រុមផ្សេងទៀតមកជំនួសពួកគេជាមិនខាន។

29. ពិតប្រាកដណាស់ នេះជាការដាស់រំឭកមួយ។ ហេតុនេះ ជនណាដែលមានបំណងទទួលយកការដាស់រំលឹក ចូរឱ្យគេជ្រើសយកមាគ៌ាទៅកាន់ព្រះជាម្ចាស់របស់គេចុះ។

30. ហើយពួកអ្នកមិនអាចមានចេតនាអ្វីមួយនោះឡើយ លើកលែងតែអល់ឡោះទ្រង់មានចេតនាប៉ុណ្ណោះ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាគតិបណ្ឌិតបំផុត។

31. ទ្រង់បញ្ចូលជនណាដែលទ្រង់មានចេតនាទៅក្នុងក្តីមេត្តាករុណារបស់ទ្រង់។ ហើយចំពោះពួកដែលបំពាន ទ្រង់បានត្រៀមទុកសម្រាប់ពួកគេនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។

ជំពូក អាល់មួរស៊ីឡាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ទ្រង់ស្បថនឹងខ្យល់ដែលត្រូវគេបញ្ជូនមកជាបន្តបន្ទាប់។

2. ហើយទ្រង់ស្បថនឹងខ្យល់ព្យុះដែលបក់បោកយ៉ាងខ្លាំងក្លា។

3. ហើយទ្រង់ស្បថនឹងម៉ាឡាអ៊ីកាត់ដែលទទួលបន្ទុកពង្រាយទឹកភ្លៀង។

4. ហើយទ្រង់ស្បថនឹងម៉ាឡាអ៊ីកាត់ដែលចុះមកជាមួយនឹងការបែងចែករវាងប្រការពិតនិងប្រការមិនពិត។

5. ហើយទ្រង់ស្បថនឹងម៉ាឡាអ៊ីកាត់ដែលនាំវ៉ាហ៊ីចុះមក

6. ដើម្បីកុំឲ្យមានការដោះសាណាមួយ ឬជាការដាស់តឿនព្រមាន។

7. ពិតប្រាកដណាស់ អ្វីដែលគេសន្យាចំពោះពួកអ្នក ពិតជានឹងកើតឡើង។

8. នៅពេលដែលផ្កាយទាំងឡាយត្រូវបានគេបំបាត់ពន្លឺ(របស់វា)

9. ហើយនៅពេលដែលមេឃត្រូវប្រេះបែក

10. ហើយនៅពេលដែលភ្នំទាំងឡាយត្រូវគេបំបើង

11. ហើយនៅពេលដែលបណ្តាអ្នកនាំសារទាំងឡាយត្រូវបានគេកំណត់ពេល។

12. តើពួកគាត់ត្រូវបានគេពន្យារពេលរហូតដល់ថ្ងៃណា?

13. រហូតដល់ថ្ងៃកាត់សេចក្តី។

14. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា ថ្ងៃកាត់សេចក្តីជាអ្វីនោះ?

15. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

16. តើយើងមិនបានបំផ្លាញអ្នកជំនាន់មុនទេឬ?

17. បន្ទាប់មក យើងក៏បានបំផ្លាញអ្នកជំនាន់ក្រោយពួកគេទៀត។

18. ក៏ដូចគ្នាដែរ យើងបានធ្វើ(ដូចនោះ)ចំពោះពួកឧក្រិដ្ឋជនទាំងឡាយ។

19. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

20. តើយើងមិនបានបង្កើតពួកអ្នកពីទឹកកាមដ៏ទន់ខ្សោយទេឬ?

21. ហើយយើងបានដាក់វានៅក្នុងកន្លែងដែលត្រូវបានគេថែរក្សា(ស្បូនស្ត្រី)

22. រហូតដល់រយៈកាលកំណត់មួយ។

23. ហើយយើងបានកំណត់(នូវលក្ខណៈរបស់វា)។ ជាការពិតណាស់ យើងជាអ្នកកំណត់ដ៏ប្រសើរបំផុត។

24. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

25. តើយើងមិនបានបង្កើតផែនដីជាកន្លែងប្រមូលផ្តុំ

26. ទាំងអ្នករស់ ទាំងអ្នកស្លាប់ទេឬ?

27. ហើយយើងបានបង្កើតភ្នំខ្ពស់ៗទាំងឡាយនៅលើផែនដីដើម្បីទប់លំនឹង។ ហើយយើងបានផ្តល់ទឹកសាបដែលបរិសុទ្ធ ឱ្យពួកអ្នកផឹក។

28. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

29. (នៅថ្ងៃបរលោក មានគេនិយាយទៅកាន់ពួកដែលបដិសេធថា៖) ចូរពួកអ្នកធ្វើដំណើរទៅកាន់អ្វី(ទណ្ឌកម្ម)ដែលពួកអ្នកធ្លាប់បានបដិសេធនឹងវាចុះ។

30. ចូរពួកអ្នកធ្វើដំណើរទៅកាន់ម្លប់(នៃផ្សែងភ្លើងនរក)ដែលបែកជាបីផ្នែកនោះចុះ។

31. គ្មានម្លប់ត្រជាក់ឡើយ ហើយក៏គ្មានអ្វីអាចរារាំងពីអណ្តាតភ្លើង(នរក)នោះដែរ។

32. ពិតប្រាកដណាស់ វាជះផ្កាភ្លើងយ៉ាងខ្លាំងប្រៀបដូចជាវិមានដ៏ធំស្តឹមស្តែ

33. ដែលប្រៀបដូចជាសត្វអូដ្ឋលឿង។

34. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

35. នេះគឺជាថ្ងៃដែលពួកគេ(ពួកបដិសេធ)មិនអាចនិយាយអ្វីបានឡើយ។

36. ហើយពួកគេក៏មិនត្រូវបានគេអនុញ្ញាតឱ្យនិយាយដោះសានោះដែរ។

37. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

38. នេះគឺជាថ្ងៃកាត់សេចក្តី។ យើងបានប្រមូលផ្តុំពួកអ្នក និងអ្នកជំនាន់មុនទាំងអស់។

39. ដូចនេះ ប្រសិនបើពួកអ្នកមានកលល្បិចអ្វី(ដើម្បីរំដោះខ្លួនពីទណ្ឌកម្ម) ចូរពួកអ្នកប្រើកលល្បិចនោះចុះ។

40. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

41. ពិតប្រាកដណាស់ បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ) ពួកគេស្ថិតនៅក្រោមម្លប់ និងមានប្រភពទឹកជាច្រើន

42. ព្រមទាំងផ្លែឈើ(គ្រប់ប្រភេទ)តាមអ្វីដែលពួកគេប្រាថ្នា។

43. (ហើយមានគេនិយាយទៅកាន់ពួកគេថា៖) ចូរពួកអ្នកបរិភោគ និងផឹកដោយក្តីរីករាយចុះ ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានសាង។

44. ក៏ដូចគ្នាដែរ ពិតប្រាកដណាស់ យើងនឹងតបស្នងដល់បណ្តាអ្នកដែលសាងអំពើល្អ។

45. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

46. (ហើយមានគេនិយាយទៅកាន់ពួកទាំងនោះថា៖) ចូរពួកអ្នកបរិភោគ និងត្រេកត្រអាលមួយរយៈពេលខ្លីសិនចុះ ព្រោះពិតណាស់ ពួកអ្នកគឺជាពួកឧក្រិដ្ឋជន។

47. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

48. ហើយនៅពេលដែលមានគេនិយាយទៅកាន់ពួកទាំងនោះថា៖ ចូរពួកអ្នកប្រតិបត្តិសឡាត គឺពួកគេមិនសឡាតឡើយ។

49. ភាពវិនាសអន្តរាយនៅថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ។

50. ដូចនេះ តើមានពាក្យសម្តីអ្វីបន្ទាប់ពីវា(គម្ពីរគួរអាន)ដែលពួកគេមានជំនឿនោះ?

ជំពូក អាន់ណាហ្ពាក់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តើពួកគេ(មុស្លរីគីន)កំពុងតែសួរគ្នាពីរឿងអ្វី?

2. គឺអំពីដំណឹងដ៏សំខាន់

3. ដែលពួកគេខ្វែងគំនិតគ្នាចំពោះវា។

4. មិនដូច្នោះឡើយ ពួកគេគង់តែនឹងដឹង។

5. ក្រោយមក មិនដូច្នោះឡើយ ពួកគេគង់តែនឹងដឹង។

6. តើយើង(អល់ឡោះ)មិនបានបង្កើតផែនដីឱ្យមានសណ្ឋានលាតសន្ធឹង

7. និងភ្នំជាច្រើនជាបង្គោលស្នឹងទេឬ?

8. ហើយយើងបានបង្កើតពួកអ្នកមានគូ(ប្រុស និងស្ត្រី)។

9. ហើយយើងបានឱ្យការដេករបស់ពួកអ្នកជាការសម្រាក។

10. ហើយយើងបានបង្កើតពេលយប់ជាការបិទបាំង។

11. ហើយយើងបានបង្កើតពេលថ្ងៃជាពេលប្រកបរបរ(ចិញ្ចឹមជីវិត)។

12. យើងបានបង្កើតនៅពីលើពួកអ្នកនូវ(មេឃ)ប្រាំពីរជាន់ជាសំណង់ដ៏រឹងមាំ។

13. យើងបានបង្កើតព្រះអាទិត្យឱ្យមានស្មើចែងចាំង និងមានកម្តៅ។

14. ហើយយើងបានបញ្ចុះទឹកភ្លៀងដ៏ច្រើនសន្ធឹកសន្ធាប់ពីដុំពពក

15. ដើម្បីយើងបញ្ចេញតាមរយៈទឹកភ្លៀងនោះនូវគ្រាប់ធញ្ញជាតិ និងរុក្ខជាតិជាច្រើន

16. ព្រមទាំងចម្ការដំណាំដែលចាក់ស្រេះគ្នាត្រសុំត្រសាយ។

17. ពិតប្រាកដណាស់ ថ្ងៃកាត់សេចក្តី(រវាងភាវៈទាំងឡាយ) គឺជាពេលវេលាកំណត់។

18. គឺថ្ងៃដែលគេផ្តុំត្រែ(លើកទីពីរ)។ ពេលនោះ ពួកអ្នកនឹងមកជាក្រុមៗ។

19. ហើយមេឃត្រូវបានគេបើកចំហដោយវាមានទ្វារជាច្រើន។

20. ហើយភ្នំត្រូវបានគេបំបើង(ចេញពីកន្លែងរបស់វា) ដែលវាប្រៀបដូចជារូបបំភាន់ភ្នែក។

21. ពិតប្រាកដណាស់ នរកដើរហាន់ណាំគឺជាកន្លែងត្រៀម

22. ជាកន្លែងវិលត្រលប់សម្រាប់ពួកដែលបំពាន។

23. ពួកគេស្ថិតនៅទីនោះជាអមតៈ។

24. នៅក្នុងឋាននរកនោះ ពួកគេមិនស្គាល់រសជាតិត្រជាក់ ហើយក៏គ្មានគ្រឿងផឹកនោះដែរ

25. លើកលែងតែទឹកដ៏សែនក្តៅ និងខ្ទុះឈាមប៉ុណ្ណោះ

26. ជាការតបស្នងដ៏សក្តិសមបំផុត(សម្រាប់ពួកគេ)។

27. ជាការពិតណាស់ ពួកគេមិនធ្លាប់រំពឹងថាមានការជំនុំជម្រះឡើយ។

28. ហើយពួកគេថែមទាំងបានបដិសេធសញ្ញាកស្តុតាងទាំងឡាយរបស់យើងទៀតផង។

29. ហើយរាល់អ្វីៗទាំងអស់ យើងបានកត់ត្រាវាទុកនៅក្នុងសៀវភៅកំណត់ត្រា(ឡាវហ៊ុលម៉ៈហ្វូស)។

30. ដូច្នេះ ចូរពួកអ្នក(ឱពួកគ្មានជំនឿ)ភ្លក់ចុះ។ ហើយយើងមិនបន្ថែមអ្វីដល់ពួកអ្នកក្រៅតែពីទណ្ឌកម្មនោះឡើយ។

31. ពិតប្រាកដណាស់ សម្រាប់បណ្តាអ្នកដែលកោតខ្លាច(អល់ឡោះ)នឹងទទួលបានកន្លែងជោគជ័យ(ឋានសួគ៌)

32. ដែលមានសួនឧទ្យាន និងចម្ការទំពាំងបាយជូរ

33. និងស្ត្រីព្រហ្មចារីយ៍ជាច្រើនដែលមានវ័យស្មើៗគ្នា

34. ព្រមទាំងកែវដែលពេញដោយស្រា។

35. នៅក្នុងឋានសួគ៌នោះ ពួកគេមិនឮពាក្យសម្តីឥតបានការ ហើយពួកគេក៏មិននិយាយកុហកគ្នានោះដែរ។

36. (ទាំងនោះ)គឺជាការតបស្នងពីព្រះជាម្ចាស់របស់អ្នក ជាការប្រោសប្រទានដ៏ពេញលេញមួយ(អំពីទ្រង់)។

37. (ទ្រង់ជា)ព្រះជាម្ចាស់នៃមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរ ជាព្រះជាម្ចាស់ដ៏មហាសប្បុរស។ ពួកគេមិនអាចនិយាយអ្វីបានឡើយ (លុះត្រាតែមានការអនុញ្ញាតពីទ្រង់)។

38. នៅថ្ងៃដែលម៉ាឡាអ៊ីកាត់ដីព្រីល និងម៉ាឡាអ៊ីកាត់ទាំងឡាយតម្រៀបជាជួរៗ។ ពួកគេមិនអាចនិយាយអ្វីបានឡើយ លើកលែងតែអ្នកដែលព្រះជាម្ចាស់ដ៏មហាសប្បុរសអនុញ្ញាតដល់គេ ហើយគេនិយាយតែពាក្យសម្តីដែលត្រឹមត្រូវប៉ុណ្ណោះ។

39. នោះគឺជាថ្ងៃដែលនឹងកើតឡើងយ៉ាងពិតប្រាកដ។ ដូច្នេះ ជនណាដែលចង់ទទួលបានជោគជ័យ ចូរឱ្យគេជ្រើសយកកន្លែងវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់គេចុះ។

40. ពិតណាស់ យើងបានដាស់តឿនព្រមានពួកអ្នក(ឱមនុស្សលោកទាំងឡាយ)នូវទណ្ឌកម្មដែលនៅជិតបំផុត គឺនៅថ្ងៃដែលបុគ្គលម្នាក់ៗមើលទៅកាន់អ្វីដែលគេធ្លាប់បានសាងកន្លងមក។ ហើយអ្នកគ្មានជំនឿនឹងនិយាយថា៖ "ឱអនិច្ចាខ្ញុំអើយ! សូមឱ្យខ្ញុំក្លាយជាដី(ដូចសត្វទាំងឡាយ)ផងចុះ។

ជំពូក អាន់ណាហ្ស៊ីអាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលដកហូតព្រលឹងពួកគ្មានជំនឿដោយយោឃៅ។
2. (ទ្រង់)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលដកយកព្រលឹងបណ្តាអ្នកមានជំនឿដោយទន់ភ្លន់។
3. (ទ្រង់)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលចុះពីលើមេឃ និងឡើងទៅកាន់មេឃវិញយ៉ាងលឿន។
4. (ទ្រង់)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលប្រជែងគ្នាអនុវត្តបទបញ្ជារបស់អល់ឡោះ។
5. (ទ្រង់)ស្បថនឹងម៉ាឡាអ៊ីកាត់ដែលរៀបចំនូវបទបញ្ជារបស់អល់ឡោះ។
6. នៅថ្ងៃដែលផែនដីញ័ររញ្ជួយ(ដោយការផ្តុំត្រែលើកទីមួយ)
7. ហើយការផ្តុំត្រែលើកទីពីរក៏កើតមានឡើងបន្ទាប់ពីវា
8. នៅថ្ងៃនោះ ជួងចិត្ត(ពួកគ្មានជំនឿ)ភ័យញាប់ញ័រ។
9. កែវភ្នែករបស់ពួកគេបង្ហាញនូវភាពភ័យខ្លាច។
10. ពួកគេនិយាយថា៖ តើពួកយើងពិតជានឹងត្រូវគេត្រឡប់ឲ្យមានជីវិតម្តងទៀតឬ?
11. តើពួកយើងពិតជានឹងត្រូវគេត្រឡប់ឲ្យមានជីវិតឬ ខណៈដែលពួកយើងបានក្លាយជាឆ្អឹងដែលពុកផុយហើយនោះ?
12. ពួកគេនិយាយទៀតថា៖ ប្រសិនបើដូច្នោះមែន វាពិតជាការលិចត្រឡប់ដ៏ខាតបង់បំផុត។
13. តាមពិតវាគ្រាន់តែជាការផ្តុំត្រែ(លើកទីពីរ)តែមួយជងប៉ុណ្ណោះ។
14. ស្រាប់តែពេលនោះ ពួកគេក៏បានរស់ឡើងវិញ។

15. តើដំណឹងរបស់ព្យាការីមូសាបានមកដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ហើយឬនៅ?

16. នៅពេលដែលព្រះជាម្ចាស់របស់គាត់បានហៅគាត់នៅឯជ្រលងភ្នំទូវ៉ាដ៏ពិសិដ្ឋថា៖

17. ចូរអ្នកធ្វើដំណើរទៅកាន់ហ្វៀរអោនចុះ។ ពិតប្រាកដណាស់ គេជាអ្នកដែលបំពាន។

18. ហើយចូរអ្នកនិយាយ(ទៅកាន់គេ)ថា ៖ តើអ្នក(ឱហ្វៀរអោន)ចង់ជម្រះសម្អាតខ្លួន

19. និងឱ្យខ្ញុំណែនាំអ្នកទៅកាន់ព្រះជាម្ចាស់របស់អ្នក(អល់ឡោះ) រួចអ្នកនឹងកោតខ្លាចទ្រង់ដែរឬទេ?

20. ពេលនោះ គាត់ក៏បានបង្ហាញឱ្យគេ(ហ្វៀរអោន)ឃើញនូវសញ្ញាកស្តុតាងដ៏ធំមួយ។

21. តែគេបែរជាបដិសេធ និងប្រឆាំងទៅវិញ។

22. ក្រោយមក គេបែរក្រោយ(ងាកចេញពីការមានជំនឿ) និងព្យាយាមប្រឆាំង(នឹងព្យាការីមូសា)។

23. ហើយគេបានប្រមូល(ក្រុមរបស់គេ) រួចស្រែកប្រកាសថា៖

24. យើងគឺជាព្រះជាម្ចាស់របស់ពួកអ្នកដ៏មហាខ្ពង់ខ្ពស់។

25. ដូច្នេះ អល់ឡោះក៏បានដាក់ទណ្ឌកម្មរួបគេទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។

26. ពិតប្រាកដណាស់ នៅក្នុងរឿងនោះ គឺជាមេរៀនមួយសម្រាប់អ្នកដែលកោតខ្លាច(អល់ឡោះ)។

27. តើការបង្កើតពួកអ្នក(ឲ្យរស់ឡើងវិញម្តងទៀត)លំបាកជាង ឬមួយក៏ការបង្កើតមេឃដែលយើងបានបង្កើតវារួចនោះ (លំបាកជាង)?

28. ទ្រង់បានលើកវាខ្ពស់ប្រៀបដូចជាសំណង់មួយពីលើពួកអ្នក ហើយទ្រង់ធ្វើឱ្យវាមានផ្នែរាបស្មើ។

29. ទ្រង់បានធ្វើឱ្យពេលយប់របស់វាមានភាពងងឹត ហើយទ្រង់បានបញ្ចេញពន្លឺរបស់វា(ព្រះអាទិត្យ)មកវិញនៅពេលថ្ងៃរះ។

30. ហើយបន្ទាប់ពីនោះ ទ្រង់បានបង្កើតផែនដីឲ្យលាតសន្ធឹង។

31. ទ្រង់បានបញ្ចោញពីជីនូវទឹករបស់វា និងរុក្ខជាតិរបស់វា។

32. ហើយទ្រង់បានបង្កើតភ្នំជាស្នឹង(សម្រាប់ទប់លំនឹង)ផែនដី។

33. (ទាំងអស់នោះ) គឺដើម្បីជាប្រយោជន៍សម្រាប់ពួកអ្នក និងសត្វពាហនៈរបស់ពួកអ្នក។

34. នៅពេលដែលការផ្ទុំត្រៃលើកទីពីរត្រូវបានបន្លឺឡើង

35. នៅថ្ងៃនោះ មនុស្សលោកនឹងនឹកឃើញ(ទាំងអស់)នូវអ្វីដែលខ្លួនបានសាង

36. ហើយនរកជើហ៊ីមត្រូវបានគេនាំមកបង្ហាញឱ្យអ្នកដែលបានឃើញ បានឃើញច្បាស់។

37. ដូច្នេះ ចំពោះអ្នកដែលបានបំពាន

38. និងបានឲ្យតម្លៃឆាកជីវិតលោកិយ(ខ្លាំងជាងជីវិតបរលោក)

39. ពិតប្រាកដណាស់ នរកជើហ៊ីមគឺជាកន្លែងស្នាក់នៅរបស់គេ។

40. រីឯជនណាដែលខ្លាចការឈរនៅចំពោះមុខព្រះជាម្ចាស់របស់គេ ហើយបានទប់ស្កាត់ខ្លួនពីកិលេសតណ្ហា

41. ពិតប្រាកដណាស់ ឋានសួគ៌គឺជាកន្លែងស្នាក់នៅរបស់គេ។

42. ពួកគេ(ពួកមុស្លីគីន)នឹងសួរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពីថ្ងៃបរលោក ថាតើវានឹងកើតឡើងនៅពេលណា ?

43. រូបអ្នកមិនមែនជាអ្នកដែលដឹងពីពេលវេលារបស់វាឡើយ។

44. គឺមានតែព្រះជាម្ចាស់របស់អ្នក(តែមួយគត់)ដែលដឹង។

45. តាមពិត អ្នកគ្រាន់តែជាអ្នកដាស់តឿនព្រមានចំពោះជនដែលខ្លាចថ្ងៃនោះប៉ុណ្ណោះ។

46. នៅថ្ងៃដែលពួកគេបានឃើញថ្ងៃបរលោកនោះ ពួកគេមានអារម្មណ៍ហាក់បីដូចជាពួកគេមិនធ្លាប់បានរស់នៅក្នុងលោកិយនេះឡើយ លើកលែងតែមួយល្ងាច ឬមួយព្រឹកប៉ុណ្ណោះ។

ជំពូក អាល្ហាសា

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. គាត់(ព្យាការីមូហាំម៉ាត់)បានធ្វើមុខក្រញូវ ហើយងាកចេញ

2. ដោយសារមានជនពិការភ្នែកម្នាក់បានមកជួបគាត់។

3. តើអ្វីដែលធ្វើឲ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អាចដឹង(ពីរឿងនោះ)? ជួនកាលគេអាច(មក)សម្អាតខ្លួនរបស់គេ(ពីបាបកម្ម)ក៏ថាបាន។

4. ឬក៏គេអាចទទួលបានការដាស់រំលឹក(ពីអ្នក) ហើយការដាស់រំលឹកនោះអាចផ្តល់ជាប្រយោជន៍ដល់គេ។

5. រីឯអ្នកដែលមិនត្រូវការ(ការណែនាំពីអ្នក)

6. អ្នកបែរដោយយកចិត្តទុកដាក់ចំពោះគេទៅវិញ។

7. តើមានអ្វីកើតឡើងចំពោះអ្នក ប្រសិនបើគេមិនសម្អាតខ្លួន(ពីភាពគ្មានជំនឿ)ទេនោះ?

8. រីឯអ្នកដែលខំព្យាយាមមកជួបអ្នក

9. ហើយរូបគេក៏ខ្លាច(អល់ឡោះ)ផងនោះ

10. អ្នកបែរជាព្រងើយកន្តើយចំពោះគេទៅវិញ។

11. មិនដូច្នោះឡើយ! ពិតណាស់វា(ជំពូកនេះ)ជាការដាស់រំលឹកប៉ុណ្ណោះ។

12. ដូចនេះ ជនណាដែលចង់ទទួលការដាស់រំលឹក គេនឹងយកគម្ពីរនេះ(គម្ពីរគួរអាន)ជាការដាស់រំលឹក

13. (ដែលគម្ពីរនេះ)ស្ថិតនៅក្នុងគម្ពីរដែលត្រូវបានគេលើកតម្កើង

14. ដែលមានឋានៈខ្ពង់ខ្ពស់ និងជ្រះស្អាត។

15. គម្ពីរនេះ(គម្ពីរគួរអាន)នៅនឹងដៃម៉ាឡាអ៊ីកាត់។

16. ជាអ្នកដែលថ្កុំថ្កើង និងជាអ្នកដែលប្រព្រឹត្តតែអំពើល្អ។

17. គេបានដាក់បណ្តាសាលើមនុស្ស(ដែលប្រឆាំង)។ តើមានអ្វីដែលខ្លាំងជាងការប្រឆាំងនឹងទ្រង់ទៀតនោះ!

18. តើទ្រង់បានបង្កើតរូបគេពីអ្វី?

19. គឺទ្រង់បានបង្កើតរូបគេពីទឹកកាម ហើយទ្រង់បានកំណត់(ដំណាក់កាលរបស់)វា។

20. បន្ទាប់មក ទ្រង់បានសម្រួលនូវមាគ៌ា(ល្អ អាក្រក់)ដល់គេ។

21. ក្រោយមក ទ្រង់បានឱ្យគេស្លាប់ រួចឱ្យគេស្ថិតក្នុងផ្នូរ។

22. បន្ទាប់មក នៅពេលដែលទ្រង់មានចេតនា ទ្រង់នឹងឲ្យគេរស់ឡើងវិញ។

23. មិនដូច្នោះឡើយ! គេមិនបានបំពេញនូវអ្វីដែលទ្រង់បានដាក់បទបញ្ជាលើរូបគេឡើយ។

24. ដូច្នេះ ចូរឱ្យមនុស្សលោកមើលទៅកាន់ចំណីអាហាររបស់គេចុះ។

25. ពិតប្រាកដណាស់ យើងបានស្រោចស្រពនូវទឹកភ្លៀងយ៉ាងច្រើនសន្ធឹកសន្ធាប់។

26. បន្ទាប់មក យើងបានបំបែកដីជាបំណែកៗ។

27. ពេលនោះ យើងបានបណ្តុះនៅក្នុងវានូវគ្រាប់ធញ្ញជាតិជាច្រើន

28. និងទំពាំងបាយជូរ រុក្ខជាតិបៃតង(សម្រាប់ជាចំណីសត្វ)

29. និងដើមអូលីវ ដើមល្មើ

30. ហើយនិងចម្ការដោះច្រើនដែលមានដើមឈើធំៗ

31. ព្រមទាំងផលានុផល និងស្មៅ

32. ដើម្បីជាប្រយោជន៍សម្រាប់ពួកអ្នក និងសត្វពាហនៈរបស់ពួកអ្នក។

33. ហើយនៅពេលដែលសម្រែកយ៉ាងខ្លាំង(នៃការផ្លុំត្រែលើកទីពីរ)បានមកដល់

34. គឺនៅថ្ងៃដែលបុគ្គលម្នាក់ៗរត់គេចពីបងប្អូនរបស់ខ្លួន

35. និងពីម្តាយរបស់ខ្លួន ពីឪពុករបស់ខ្លួន

36. ហើយនិងពីភរិយារបស់ខ្លួន និងកូនចៅរបស់ខ្លួន។

37. នៅថ្ងៃនោះ បុគ្គលម្នាក់ៗក្នុងចំណោមពួកគេ គឺមានកិច្ចការដែលធ្វើឲ្យរូបគេវល់(ខ្វល់ខ្វាយរៀងៗខ្លួន)។

38. ទឹកមុខ(អ្នកមានជំនឿ)នៅថ្ងៃនោះ គឺភាពត្រចះត្រចង់

39. (ដោយពួកគេ)សើចសប្បាយ និងមានភាពរីករាយ។

40. ហើយទឹកមុខ(ពួកគ្មានជំនឿ)នៅថ្ងៃនោះ គឺប្រឡាក់ដោយធូលី។

41. ល្អងខ្មៅងងឹតបានគ្របដណ្តប់លើផ្ទៃមុខ(របស់ពួកគេ)។

42. ពួកទាំងនោះ គឺជាពួកដែលប្រឆាំង និងពួកដែលបំពាន។

ជំពូក អាត់តឹកឡៀរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលព្រះអាទិត្យត្រូវបានមូរ
2. និងនៅពេលដែលផ្កាយទាំងឡាយធ្លាក់បែកខ្ចាត់ខ្ចាយ
3. និងនៅពេលដែលភ្នំទាំងឡាយត្រូវបានគេបំប្រឹង
4. និងនៅពេលដែលមេអូដ្ឋផើម ត្រូវបានគេបោះបង់ចោល
5. និងនៅពេលដែលសត្វសាហាវត្រូវបានគេប្រមូលផ្តុំ
6. និងនៅពេលសមុទ្រទាំងឡាយត្រូវបានគេដុតឱ្យឆេះ
7. និងនៅពេលដែលជីវិតទាំងឡាយត្រូវបានផ្តុំ(ឱ្យនៅតាមក្រុមរៀងខ្លួន)
8. និងនៅពេលទារិកា(ដែលគេកប់ទាំងរស់)ត្រូវបានគេសួរថា៖
9. តើដោយសារបាបកម្មអ្វីបានជានាងត្រូវបានគេសម្លាប់បែបនេះ ?
10. និងនៅពេលដែលបញ្ជីកំណត់ត្រា(ទង្វើរបស់មនុស្ស)ត្រូវបានគេចែកចាយ
11. និងនៅពេលដែលមេឃាត្រូវបានគេយកចេញ
12. និងនៅពេលដែលភ្លើងនរកត្រូវបានដុតបញ្ឆេះឡើង
13. និងនៅពេលដែលឋានសួគ៌ត្រូវបានគេដាក់ឱ្យនៅជិត(អ្នកដែលកោតខ្លាចអល់ឡោះ)
14. (កាលណាហេតុការណ៍ទាំងនោះកើតឡើង) បុគ្គលគ្រប់រូបនឹងដឹងពីអ្វីដែលខ្លួនបានសាង។

15. (អល់ឡោះ)ស្បថនឹងហ្វូងតារាដែលបាត់ពន្លឺ។

16. (ទ្រង់)ស្បថនឹងហ្វូងតារាដែលដើរតាមគន្លងរបស់វា រួចក៏លិចបាត់ទៅវិញ។

17. (ទ្រង់)ស្បថនឹងពេលយប់នៅពេលដែលវាចាប់ផ្តើមងងឹត

18. (ទ្រង់)ស្បថនឹងពេលព្រលឹម នៅពេលដែលចាប់ផ្តើមបញ្ចោញពន្លឺ។

19. ពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន)ពិតជាបន្ទូល(របស់អល់ឡោះជាម្ចាស់)ដែលត្រូវបាននាំមកដោយម៉ាឡាអ៊ីកាត់ដ៏ឧត្តុង្គឧត្តម(ជីព្រីល)

20. ជាអ្នកមានអានុភាពខ្លាំងក្លា និងមានឋានៈខ្ពង់ខ្ពស់ចំពោះ(អល់ឡោះ)ព្រះជាម្ចាស់នៃអារ៉ស្ហ។

21. ជាអ្នកដែលត្រូវបានអ្នកដែលនៅទីនោះ(លើមេឃ)គោរពតាម ជាអ្នកដែលស្មោះត្រង់បំផុត។

22. ហើយមិត្តភក្តិរបស់ពួកអ្នក(គឺព្យាការីមូហាំម៉ាត់)ពុំមែនជាមនុស្សវិកលចរិតឡើយ។

23. ហើយជាការពិតណាស់ គាត់បានឃើញគេ(ជីព្រីល)យ៉ាងច្បាស់នៅឯជើងមេឃ។

24. ហើយគាត់ក៏មិនមែនជាអ្នកកំណាញ់ក្នុងការផ្សព្វផ្សាយសាររបស់អល់ឡោះនោះដែរ។

25. ហើយគម្ពីរនេះ(គម្ពីរគួរអាន)មិនមែនជាពាក្យពេចន៍របស់ស្ហៃតនដែលត្រូវគេដាក់បណ្តាសានោះឡើយ។

26. ដូចនេះ តើសតិបញ្ញារបស់ពួកអ្នកបាត់បង់ទៅណាហើយ?

27. គម្ពីរនេះ(គម្ពីរគួរអាន)គ្មានអ្វីក្រៅពីការដាស់រំឭកដល់ពិភពទាំងឡាយនោះឡើយ

28. សម្រាប់ជនណាក្នុងចំណោមពួកអ្នកដែលមានបំណងចង់ស្ថិតនៅលើមាគ៌ាត្រឹមត្រូវ។

29. ហើយពួកអ្នកមិនអាចមានចេតនា(ស្ថិតនៅមាគ៌ាត្រឹមត្រូវ)នោះឡើយ លើកលែងតែអល់ឡោះព្រះជាម្ចាស់នៃពិភពទាំងឡាយទ្រង់មានចេតនាប៉ុណ្ណោះ។

ជំពូក អាល់អ៊ីនហ្វឹតរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលមេឃប្រេះបែក

2. និងនៅពេលដែលកពទាំងឡាយត្រូវបានធ្លាក់បាក់បែក

3. និងនៅពេលដែលសមុទ្រទាំងឡាយត្រូវរលាយចូលគ្នា

4. និងនៅពេលដែលផ្នូរទាំងឡាយត្រូវបានគេក្រឡាប់។

5. (នៅពេលនោះ) បុគ្គលគ្រប់រូបនឹងដឹងនូវអ្វីដែលខ្លួនបានសាង និងអ្វីដែលខ្លួនមិនទាន់បានសាង។

6. ឱមនុស្ស(ដែលបដិសេធការបង្កើតឲ្យរស់ឡើងវិញ)! តើអ្វីដែលបោកប្រាស់អ្នកឲ្យប្រឆាំងនឹងព្រះជាម្ចាស់របស់អ្នក ដ៏មហាថ្កុំថ្កើង?

7. ជាអ្នកដែលបានបង្កើតរូបអ្នក និងបានធ្វើឱ្យអ្នកមានរូបរាងកាយសមសួន

8. ក្នុងរូបភាពណាមួយដែលទ្រង់មានចេតនា ទ្រង់នឹងបង្កើតអ្នក(ក្នុងរូបភាព)នោះ។

9. ពុំដូច្នោះឡើយ។ ផ្ទុយទៅវិញ ពួកអ្នកបានបដិសេធនឹងថ្ងៃបរលោក។

10. ហើយពិតប្រាកដណាស់ គឺពិតជាមានអ្នកឃ្លាំមើល(ម៉ាឡាអ៊ីកាត់)លើពួកអ្នក។

11. ជាអ្នកដែលថ្កុំថ្កើង និងជាអ្នកកត់ត្រា(រាល់ទង្វើរបស់ពួកអ្នក)។

12. ពួកគេដឹងនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។

13. ពិតប្រាកដណាស់ អ្នកដែលបានសាងអំពើល្អទាំងឡាយ ពិតជានឹងស្ថិតក្នុងឋានសួគ៌ណាអ៊ីម។

14. ហើយពិតប្រាកដណាស់ ពួកដែលប្រព្រឹត្តអំពើអាក្រក់ ពិតជាស្ថិតក្នុងភ្លើងនរកដែលឆាបឆេះ។

15. ពួកគេនឹងទទួលរងនូវកម្តៅរបស់វានៅថ្ងៃបរលោក។

16. ហើយពួកគេមិនអាចគេចវេះពីវាបានជាដាច់ខាត។

17. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា ថ្ងៃបរលោកជាអ្វីនោះ ?

18. បន្ទាប់មក តើអ្វីដែលធ្វើឱ្យអ្នកដឹងថា ថ្ងៃបរលោកជាអ្វីនោះ ?

19. គឺថ្ងៃដែលគ្មានបុគ្គលណាម្នាក់អាចផ្តល់ផលប្រយោជន៍អ្វីបន្តិចដល់អ្នកដទៃនោះឡើយ។ ហើយនៅក្នុងថ្ងៃនោះ កិច្ចការទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)។

ជំពូក អាល់មុតហ្សហ៊ីហ្ស៊ីន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ភាពវិនាសអន្តរាយ គឺសម្រាប់ពួកដែលគៃបន្លំ

2. គឺពួកដែលទាមទារចង់បានការវាល់គ្រប់ចំនួនពីអ្នកដទៃ នៅពេលខ្លួនទិញ។

3. តែនៅពេលដែលពួកគេវាល់ឬថ្លឹងឱ្យអ្នកដទៃវិញ គឺពួកគេវាល់ឬថ្លឹងមិនគ្រប់ឱ្យគេនោះឡើយ។

4. តើពួកទាំងនោះមិនដឹងថា ពិតប្រាកដណាស់ ពួកគេនឹងត្រូវគេបង្កើតឱ្យរស់ឡើងវិញ

5. នៅក្នុងថ្ងៃដ៏ធំធេង(ថ្ងៃបរលោក)ទេឬ?

6. គឺនៅថ្ងៃដែលមនុស្សលោកនឹងឈរនៅចំពោះមុខព្រះជាម្ចាស់នៃពិភពទាំងឡាយ។

7. ពុំដូច្នោះឡើយ! ពិតណាស់ បញ្ជី(កំណត់ត្រាទង្វើ)របស់ពួកដែលសាងអំពើអាក្រក់ គឺស្ថិតក្នុងសិជ្ជីន។

8. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា អ្វីទៅជា សិជ្ជីន នោះ?

9. គឺជាបញ្ជីដែលត្រូវបានគេកត់ត្រាយ៉ាងច្បាស់លាស់។

10. ភាពវិនាសអន្តរាយនៅក្នុងថ្ងៃនោះ គឺសម្រាប់ពួកដែលបដិសេធ

11. គឺពួកដែលបដិសេធនឹងថ្ងៃបរលោក។

12. ហើយគ្មានអ្នកដែលបដិសេធនឹងវាឡើយ លើកលែងតែពួកដែលបំពាន ពួកដែលសាងបាបកម្មច្រើនប៉ុណ្ណោះ។

13. នៅពេលមានគេសូត្របណ្តាវាក្យខណ្ឌរបស់យើងឱ្យគេស្តាប់ គេបែរជានិយាយថា៖ នេះជារឿងព្រេងនិទានរបស់មនុស្សជំនាន់មុនប៉ុណ្ណោះ។

14. ពុំដូច្នោះឡើយ! ផ្ទុយទៅវិញ អ្វីដែលពួកគេប្រព្រឹត្តបានដុះស្នឹមលើដួងចិត្តរបស់ពួកគេ។

15. ពុំដូច្នោះឡើយ! ពិតណាស់ នៅក្នុងថ្ងៃនោះ ពួកគេពិតជានឹងត្រូវបានគោរាំងមិនឱ្យឃើញព្រះជាម្ចាស់របស់ពួកគេឡើយ។

16. បន្ទាប់មក ពួកគេពិតជានឹងចូលក្នុងជើហ៊ីម។

17. ក្រោយមក មានគេនិយាយ(ទៅកាន់ពួកគេ)ថា៖ នេះហើយជាអ្វីដែលពួកអ្នកធ្លាប់បានបដិសេធចំពោះវា។

18. មិនដូច្នោះឡើយ! ពិតណាស់ បញ្ជី(កំណត់ត្រាទង្វើ)របស់អ្នកដែលបានសាងអំពើល្អទាំងឡាយ គឺស្ថិតក្នុង អ៊ិលលីយូន។

19. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា អ្វីទៅជា អ៊ិលលីយូន នោះ?

20. គឺជាបញ្ជីដែលត្រូវបានគេកត់ត្រាយ៉ាងច្បាស់លាស់។

21. ម៉ាឡាអ៊ីកាត់ដែលមានឋានៈជិតអល់ឡោះជាអ្នកនាំបញ្ជីនោះមក។

22. ពិតប្រាកដណាស់ អ្នកដែលសាងអំពើល្អទាំងឡាយ គឺស្ថិតនៅក្នុងឋានសួគ៌ណាអ៊ីម។

23. (ពួកគេ)ស្ថិតនៅលើគ្រែគយគន់មើល(ទៅកាន់ព្រះជាម្ចាស់របស់ពួកគេ)។

24. អ្នកនឹងឃើញភាពត្រេចត្រចង់ស្តែងចេញនៅលើផ្ទៃមុខរបស់ពួកគេ។

25. ពួកគេត្រូវបានគេបម្រើស្រាដ៏បរិសុទ្ធជាមួយនឹងពែងដ៏ប្រណីត។

26. តំណក់ចុងក្រោយរបស់វា មានក្លិនក្រអូប។ ដើម្បីទទួលបានបែបនេះ ចូរឲ្យអ្នកប្រកួតប្រជែងទាំងឡាយ ប្រកួតប្រជែងគ្នាចុះ។

27. វាត្រូវបានលាយជាមួយនឹង តាសនីម

28. ជាប្រភពទឹកមួយដែលអ្នកមានឋានៈខ្ពង់ខ្ពស់បំផុតទទួលទានវា។

29. ពិតប្រាកដណាស់ ពួកឧក្រិដ្ឋជនទាំងឡាយ ពួកគេធ្លាប់បានសើចចំអកឲ្យបណ្តាអ្នកដែលមានជំនឿ។

30. ហើយនៅពេលដែលពួកគេដើរកាត់បណ្តាអ្នកដែលមានជំនឿ គឺពួកគេចំអកឡកឡឺយដាក់។

31. ហើយនៅពេលដែលពួកទាំងនោះត្រឡប់ទៅកាន់ក្រុមគ្រួសាររបស់ខ្លួនវិញ គឺពួកគេត្រឡប់ទៅដោយភាពសប្បាយរីករាយ (ចំពោះអ្វីដែលពួកគេបានធ្វើ)។

32. ហើយនៅពេលដែលពួកគេបានឃើញបណ្តាអ្នកមានជំនឿ ពួកគេនិយាយថា៖ ពិតប្រាកដណាស់ ពួក(អ្នកមានជំនឿ) ទាំងនោះ គឺជាពួកដែលវង្វេង។

33. ហើយពួកគេមិនត្រូវបានគេបញ្ជូនឲ្យទៅឃ្លាំមើលអ្នកមានជំនឿទាំងឡាយនោះឡើយ។

34. ដូច្នេះ នៅក្នុងថ្ងៃនេះ បណ្តាអ្នកដែលមានជំនឿនឹងសើចចំអកឲ្យពួកគេវិញម្តង។

35. (ពួកគេ)ស្ថិតនៅលើគ្រែគយគន់មើល(ទៅកាន់អ្វីដែលអល់ឡោះបានប្រទានឲ្យពួកគេ)។

36. តើពួកគ្មានជំនឿត្រូវបានគេតបស្នងឲ្យចំពោះអ្វីដែលពួកគេបានប្រព្រឹត្តដែរឬទេ?!

ជំពូក អាល់អ៊ីនស្ទឹកក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលមេឃត្រូវប្រេះបែក

2. ហើយវាបានស្តាប់បង្គាប់ព្រះម្ចាស់របស់វា ហើយសក្តិសមបំផុតចំពោះវាក្នុងការធ្វើដូច្នោះ។

3. និងនៅពេលដែលផែនដីត្រូវបានគេលាតសន្ធឹង

4. ហើយវាបានបញ្ចោញនូវអ្វីមាននៅក្នុងខ្លួនវា និងធ្វើឱ្យខ្លួនវាទទេស្អាត។

5. ហើយវាបានស្តាប់បង្គាប់ព្រះជាម្ចាស់របស់វា ហើយសក្តិសមបំផុតចំពោះវាក្នុងការធ្វើដូច្នោះ។

6. ឱមនុស្សលោក!ពិតប្រាកដណាស់ រូបអ្នកគឺជាអ្នកដែលសាងទង្វើទាំងឡាយចំពោះព្រះជាម្ចាស់របស់អ្នក ហើយអ្នកនឹងជួបទ្រង់ជាមិនខាន។

7. ដូច្នេះ ចំពោះជនណាដែលត្រូវបានគេប្រគល់សៀវភៅកំណត់ត្រា(ទង្វើ)របស់គេពីខាងស្តាំ

8. រូបគេនឹងត្រូវគេជំនុំជម្រះនូវការជំនុំជម្រះមួយយ៉ាងងាយស្រួល។

9. ហើយគេនឹងត្រលប់ទៅជួបជុំគ្រួសាររបស់គេវិញដោយសប្បាយរីករាយ។

10. ចំណែកឯជនណាដែលត្រូវបានគេប្រគល់សៀវភៅកំណត់ត្រា(ទង្វើ)របស់គេពីក្រោយខ្នង

11. ពិតណាស់ គេនឹងស្រែកដង្ហោយថា៖ អន្តរាយហើយខ្ញុំ!

12. ហើយរូបគេនឹងត្រូវចូលឋាននរកដ៏សន្ធោសន្ធៅ។

13. ពិតប្រាកដណាស់ រូបគេធ្លាប់រស់នៅជាមួយនឹងក្រុមគ្រួសាររបស់គេយ៉ាងសប្បាយរីករាយ។

14. ពិតណាស់ រូបគេគិតស្មានថា រូបគេនឹងមិនត្រឡប់មកមានជីវិតជាថ្មីម្ដងទៀត(ដើម្បីជំនុំជម្រះ)នោះទេ។

15. មិនដូច្នោះឡើយ! ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់គេមហាឃើញបំផុតចំពោះគេ។

16. (អល់ឡោះ)ស្បថនឹងពន្លឺពណ៌ក្រហម(នៅឯជើងមេឃ)។

17. (ទ្រង់)ស្បថនឹងពេលយប់ និងអ្វីដែលគេប្រមូលផ្ដុំក្នុងពេលយប់។

18. (ទ្រង់)ស្បថនឹងព្រះចន្ទនៅពេលវារះពេញវង់។

19. ពួកអ្នក(ឱមនុស្សលោក)ពិតជានឹងវិវត្តន៍ពីមួយដំណាក់កាលទៅមួយដំណាក់កាល។

20. ដូច្នេះ តើអ្វីទៅដែលធ្វើឱ្យពួកទាំងនោះមិនព្រមមានជំនឿ?

21. ហើយនៅពេលដែលមានគេសូត្រគម្ពីរគួរអានឱ្យពួកគេស្ដាប់ គឺពួកគេមិនស៊ូជោតឡើយ។

22. ផ្ទុយទៅវិញ ពួកដែលប្រឆាំងថែមទាំងបដិសេធទៀតផង។

23. ហើយអល់ឡោះទ្រង់ដឹងបំផុតនូវអ្វីដែលពួកគេលាក់បាំង។

24. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ផ្ដល់ដំណឹងដល់ពួកគេពីទណ្ឌកម្មដ៏ឈឺចាប់បំផុតចុះ

25. លើកលែងតែបណ្ដាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសលប៉ុណ្ណោះ។ ពួកគេនឹងទទួលបានផលបុណ្យដោយគ្មានទីបញ្ចប់ឡើយ។

ជំពូក អាល់ពួរួច

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងមេឃដែលមានគន្លងគោចរជាច្រើន។

2. (ទ្រង់)ស្បថនឹងថ្ងៃ(បរលោក)ដែលគេបានសន្យា។

3. (ទ្រង់)ស្បថនឹងសាក្សី និងអ្នកដែលគេធ្វើសាក្សីឱ្យ។

4. គេបានដាក់បណ្តាសាចំពោះក្រុមអ៊ូខទូត(ដែលជីករណ្តៅធ្វើទារុណកម្មអ្នកមានជំនឿ)

5. នៅក្នុងរណ្តៅភ្លើងដែលមានកំណាត់អុស

6. ខណៈដែលពួកគេអង្គុយជុំវិញរណ្តៅភ្លើងនោះ។

7. ហើយពួកគេជាសាក្សីចំពោះអ្វីដែលពួកគេកំពុងតែប្រព្រឹត្តទៅលើបណ្តាអ្នកដែលមានជំនឿ។

8. ហើយការដែលពួកគេធ្វើទារុណកម្មលើបណ្តាអ្នកមានជំនឿនោះ គឺគ្មានអ្វីក្រៅពីដោយសារតែពួកគេមានជំនឿចំពោះអល់ឡោះដ៏មហាខ្លាំងពូកែ ជាទីកោតសរសើរនោះឡើយ។

9. ជាអ្នកដែលការគ្រប់គ្រងមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់(តែមួយគត់)។ ហើយទ្រង់មហាឃើញបំផុតនូវរាល់អ្វីៗទាំងអស់។

10. ពិតប្រាកដណាស់ ពួកដែលជុតសម្លាប់បណ្តាអ្នកមានជំនឿទាំងប្រុសទាំងស្រី ក្រោយមក ពួកគេមិនបានសារភាពកំហុស(ចំពោះអល់ឡោះ)ទេនោះ ពិតប្រាកដណាស់ សម្រាប់ពួកគេនឹងទទួលនូវទណ្ឌកម្មនៃនរកដើហាន់ណាំ ហើយនឹងទទួលនូវទណ្ឌកម្មដោយភ្លើងឆេះសន្ធោសន្ធៅ។

11. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសល សម្រាប់ពួកគេនឹងទទួលបានឋានសួគ៌ដែលមានទន្លេជាច្រើនហូរកោត់ពីក្រោមវា។ នោះហើយជាជោគជ័យដ៏ធំធេងបំផុត។

12. ពិតប្រាកដណាស់ ទណ្ឌកម្មនៃព្រះជាម្ចាស់របស់អ្នក គឺពិតជាខ្លាំងក្លាបំផុត។

13. ពិតប្រាកដណាស់ ទ្រង់ជាអ្នកដែលបានបង្កើត(ការៈទាំងអស់)ពីដំបូង ហើយទ្រង់ជាអ្នកត្រឡប់វាមកវិញ។

14. ហើយទ្រង់ជាអ្នកមហាអភ័យទោស មហាអាណិតស្រលាញ់បំផុត

15. ជាព្រះជាម្ចាស់នៃអារ៉ែស្តដ៏ថ្កុំថ្កើង

16. ជាអ្នកដែលធ្វើនូវអ្វីដែលទ្រង់មានចេតនា។

17. តើបានមកដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដែរឬទេនូវដំណឹងរបស់កងទ័ព

18. ហៀរអោន និងពួកសាមូដនោះ ?

19. ផ្ទុយទៅវិញ ពួកគ្មានជំនឿ គឺនៅតែបដិសេធ។

20. ហើយអល់ឡោះមហាដឹងជ្រួតជ្រាបអំពីពួកគេ។

21. ផ្ទុយទៅវិញ វាជាគម្ពីរគួរអានដ៏ថ្កុំថ្កើងបំផុត។

22. ដែលត្រូវបានថែរក្សានៅក្នុងបញ្ជីកំណត់ត្រា(ឡាវហុលម៉ះហ្វូស)។

ជំពូក អាត់តរិក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងមេឃ ហើយ(ទ្រង់)ស្បថនឹង អាត់តរិក។

2. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា អ្វីទៅជា អាត់តរិក នោះ?

3. គឺជាផ្កាយមួយដួងដែលបញ្ចេញរស្មីចិញ្ចែងចិញ្ចាច(នៅលើមេឃ)។

4. រាល់ជីវិតគ្រប់រូបសុទ្ធតែមានអ្នកឃ្លាំមើល(គ្រប់ទង្វើរបស់គេ)។

5. ដូច្នេះ ចូរឱ្យមនុស្សលោកពិចារណាមើលចុះ ថាតើរូបគេត្រូវបានគេបង្កើតពីអ្វី?

6. រូបគេត្រូវបានគេបង្កើតពីទឹក(កាម)ដែលបាញ់បញ្ចូលទៅក្នុងស្បូនស្ត្រី

7. ដែលចេញពីឆ្អឹងខ្នងបុរស និងឆ្អឹងជំនីស្ត្រី។

8. ពិតប្រាកដណាស់ ទ្រង់ពិតជាអ្នកដែលមានសមត្ថភាពបំផុតក្នុងការត្រឡប់គេ(ឲ្យមានជីវិតម្តងទៀត)។

9. នៅថ្ងៃដែលអាថ៌កំបាំងទាំងឡាយត្រូវបានគេលាតត្រដាង

10. ពិតណាស់ (នៅថ្ងៃនោះ) រូបគេគ្មានអានុភាពអ្វីឡើយ ហើយក៏គ្មានអ្នកជួយនោះដែរ។

11. (អល់ឡោះ)ស្បថនឹងមេឃដែលមានភ្លៀងធ្លាក់ម្តងហើយម្តងទៀត(មិនចេះអស់)។

12. (ទ្រង់)ស្បថនឹងផែនដីដែលប្រេះបែក។

13. ពិតប្រាកដណាស់ គម្ពីរនេះ(គម្ពីរគួរអាន) គឺពិតជាពាក្យបន្ទូលដែលវែកញែក(រវាងខុសនិងត្រូវ)។

14. ហើយវាមិនមែនជាការលេងសើចឡើយ។

15. ពិតប្រាកដណាស់ ពួកគេ(ពួកដែលបដិសេធ)បានប្រើល្បិចកល

16. ហើយយើង(អល់ឡោះ)ក៏មានផែនការតបតទៅវិញដែរ។

17. ដូច្នេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពន្យារពេលឱ្យពួកគ្មានជំនឿមួយរយៈពេលខ្លីសិនចុះ។

ជំពូក អាល់អាក់ឆ្បា

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ព្យាការីមូហាំម៉ាត់)លើកតម្កើងព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដ៏មហាខ្ពង់ខ្ពស់។

2. ទ្រង់ជាអ្នកដែលបានបង្កើត(សព្វភាវៈទាំងអស់)និងធ្វើឲ្យវាមានលក្ខណៈឥតខ្ចោះ។

3. ហើយទ្រង់ជាអ្នកដែលកំណត់(គ្រប់អ្វីៗទាំងអស់)ហើយផ្តល់ការចង្អុលបង្ហាញ។

4. ហើយទ្រង់ជាអ្នកដែលបណ្តុះរុក្ខជាតិបៃតង។

5. បន្ទាប់មក ទ្រង់បានធ្វើឱ្យវាទៅជាក្រៀមស្វិតក្លាយជាពណ៌ខ្មៅ។

6. យើងនឹងសូត្រវា(គម្ពីរគួរអាន)ឱ្យអ្នកស្តាប់។ ដូច្នេះ អ្នកនឹងមិនភ្លេចវាឡើយ

7. លើកលែងតែអ្វីដែលអល់ឡោះមានចេតនាប៉ុណ្ណោះ។ ពិតប្រាកដណាស់ ទ្រង់ដឹងបំផុតនូវអ្វីដែលលាតត្រដាង និងអ្វីដែលគេលាក់បាំង។

8. ហើយយើងនឹងសម្រួលដល់អ្នក(នូវគ្រប់កិច្ចការរបស់អ្នក)ឲ្យមានភាពងាយស្រួល។

9. ដូច្នេះ ចូរអ្នកដាស់តឿន(ក្រុមរបស់អ្នក)ដរាបណាការដាស់តឿននោះ(នៅតែ)មានប្រយោជន៍។

10. អ្នកដែលកោតខ្លាច(អល់ឡោះ)នឹងទទួលយកការដាស់តឿននោះ។

11. ចំណែកឯអ្នកដែលអពមង្គលនឹងចៀសឆ្ងាយពីការដាស់តឿននេះ។

12. គឺអ្នកដែលចូលឋាននរកដ៏មហិមា។

13. បន្ទាប់មក នៅក្នុងឋាននរកនោះ គេនឹងមិនស្លាប់ ហើយក៏មិនរស់(ដោយសុខស្រួល)នោះដែរ។

14. ពិតជាបានជោគជ័យហើយ អ្នកជម្រះសម្អាតខ្លួន

15. ហើយគេបានរំឭកព្រះនាមនៃព្រះជាម្ចាស់របស់គេ រួចបានប្រតិបត្តិសឡាត។

16. ផ្ទុយទៅវិញ ពួកអ្នកបែរជាឱ្យតម្លៃឆាកជីវិតរស់នៅក្នុងលោកិយទៅវិញ

17. ខណៈថ្ងៃបរលោក គឺវាល្អប្រសើរ និងបិតបៃជាង(លោកិយទៅទៀត)។

18. ពិតប្រាកដណាស់ រឿងរ៉ាវនេះក៏មានចែងនៅក្នុងគម្ពីរពីមុនៗផងដែរ

19. គឺនៅក្នុងគម្ពីររបស់ព្យាការីអ៊ីព្រហ៊ីម និងព្យាការីមូសា។

ជំពូក អាល់ហ្គាស៊ីយ៉ះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តើរឿងរ៉ាវនៃថ្ងៃបរលោក(ជាថ្ងៃដែលមនុស្សគ្របដណ្តប់ទៅដោយភាពភ័យរន្ធត់)បានមកដល់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ហើយឬនៅ?

2. នៅក្នុងថ្ងៃនោះ ទឹកមុខ(ពួកគ្មានជំនឿ)មានភាពអាប់ឱន។

3. ពួកគេទទួលនូវការងារដែលហត់នឿយបំផុត។

4. ពួកគេទទួលរងនូវកម្តៅភ្លើងនរកដ៏សែនក្តៅបំផុត។

5. គេបញ្ជ្រាកទឹកដ៏សែនក្តៅបំផុតឱ្យពួកគេផឹក។

6. គ្មានចំណីអាហារសម្រាប់ពួកគេឡើយ លើកលែងតែចំណីអាហារដ៏អាក្រក់បំផុតប៉ុណ្ណោះ។

7. វាមិនបានធ្វើឱ្យគេធំធាត់ ហើយក៏មិនធ្វើឱ្យគេបាត់ឃ្លាននោះដែរ។

8. នៅថ្ងៃនោះ ទឹកមុខ(អ្នកមានជំនឿ)ពោរពេញដោយភាពសប្បាយរីករាយ

9. ដោយសារពួកគេពេញចិត្តចំពោះការខិតខំប្រឹងប្រែង(របស់ខ្លួន)។

10. (ពួកគេ)ស្ថិតក្នុងឋានសួគ៌ដ៏ខ្ពង់ខ្ពស់។

11. នៅក្នុងឋានសួគ៌នោះ គេមិនឮនូវពាក្យសម្តីឥតបានការឡើយ។

12. នៅទីនោះ គឺមានប្រភពទឹកហូរជាច្រើន។

13. នៅទីនោះដែរ គឺមានគ្រែខ្ពស់ៗជាច្រើន

14. និងកែវដែលគេបានរៀបចំទុករួចជាស្រេច

15. ព្រមទាំងខ្នើយកើយដែលគេរៀបជាជួរៗ

16. ហើយនិងកម្រាលព្រំជាច្រើនដែលគេបានក្រាលរួចជាស្រេច។

17. ដូច្នេះ តើពួកគេមិនសង្កេតមើលទៅកាន់សត្វអូដ្ឋទេឬ ថាតើវាត្រូវបានគេបង្កើតយ៉ាងដូចម្តេច?

18. និងសង្កេតមើលទៅកាន់មេឃ ថាតើវាត្រូវបានគេលើកឱ្យខ្ពស់ឡើងយ៉ាងដូចម្តេច?

19. និងសង្កេតមើលទៅកាន់ភ្នំទាំងឡាយ ថាតើគេភ្ជាប់វាទៅនឹងដីយ៉ាងដូចម្តេច?

20. និងសង្កេតមើលទៅកាន់ផែនដី ថាតើគេលាតសន្ធឹងវាយ៉ាងដូចម្តេច?

21. ហេតុនេះ ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដាស់រំលឹកចុះ។ តាមពិត អ្នកគ្រាន់តែជាអ្នកដាស់រំលឹកប៉ុណ្ណោះ។

22. អ្នកពុំមែនជាអ្នកបង្ខំពួកគេ(ឱ្យមានជំនឿ)នោះឡើយ។

23. ក៏ប៉ុន្តែ ជនណាដែលបានងាកចេញ ហើយប្រឆាំង

24. អល់ឡោះនឹងដាក់ទណ្ឌកម្មគេនូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុត។

25. ពិតប្រាកដណាស់ ការវិលត្រឡប់របស់ពួកគេ គឺឆ្ពោះមកកាន់យើង(តែមួយគត់)។

26. បន្ទាប់មក ការជំនុំជម្រះរបស់ពួកគេ គឺជាតួនាទីរបស់យើង(តែមួយគត់)។

ជំពូក អាល់ហ្សាច់រ៉ែ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងពេលទៀបភ្លឺ(ពេលហ្វាជើរ)។

2. (ទ្រង់)ស្បថនឹងយប់ទាំងដប់(ដប់ថ្ងៃដំបូងនៃខែហ្ស៊ុលហិជ្ជៈ)។

3. (ទ្រង់)ស្បថនឹងចំនួនគូ និងចំនួនសេស។

4. (ទ្រង់)ស្បថនឹងពេលយប់នៅពេលដែលវាកន្លងផុតទៅ។

5. តើការស្បថទាំងអស់នោះមិនទាន់គ្រប់គ្រាន់សម្រាប់អ្នកដែលមានសតិបញ្ញាទេឬ?

6. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានឃើញទេឬ ថាតើព្រះជាម្ចាស់របស់អ្នកបានធ្វើដូចម្តេចចំពោះក្រុមអាទ

7. និងកុលសម្ព័ន្ធអ៊ីរ៉មដែលមានកម្លាំងខ្លាំងក្លា និងសំណង់ខ្ពស់ៗ

8. ដែលគេ(អល់ឡោះ)មិនដែលបានបង្កើតដូចវានោះទៀយនៅលើទឹកដីនេះ?

9. ហើយ(តើទ្រង់បានធ្វើដូចម្តេចចំពោះ)ក្រុមសាមូដដែលពួកគេបានចោះភ្នំធ្វើជាលំនៅឋាននោះ

10. និងចំពោះហ្វៀរអោនដែលមានពលទាហានជាច្រើន

11. ដែលពួកគេបានបំពាននៅក្នុងទឹកដី(របស់ពួកគេ)នោះ?

12. ពិតណាស់ ពួកគេបានបង្កវិនាសកម្មយ៉ាងច្រើននៅលើទឹកដីនោះ។

13. ដូច្នេះ ព្រះជាម្ចាស់របស់អ្នកក៏បានដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរបំផុតចំពោះពួកគេ។

14. ពិតប្រាកដណាស់ ព្រះជាម្ចាស់របស់អ្នក ទ្រង់ពិតជាអ្នកដែលឃ្លាំមើល។

15. រីឯមនុស្សលោក កាលណាព្រះជាម្ចាស់របស់គេបានសាកល្បងរូបគេដោយទ្រង់បានលើកតម្កើង និងប្រទាននូវឧបការគុណដល់គេ គេនិយាយថា៖ ព្រះជាម្ចាស់របស់ខ្ញុំបានលើកតម្កើងខ្ញុំ។

16. រីឯកាលណាទ្រង់សាកល្បងរូបគេដោយបានត្បិតត្បៀតនូវលោកសក្ការៈរបស់ទ្រង់ចំពោះរូបគេវិញ គេបែរជានិយាយថា៖ ព្រះជាម្ចាស់របស់ខ្ញុំធ្វើឱ្យខ្ញុំអាប់ឱន។

17. ពុំដូច្នោះឡើយ! ផ្ទុយទៅវិញ ពួកអ្នកគ្មានចិត្តសប្បុរសចំពោះក្មេងកំព្រាឡើយ។

18. ហើយពួកអ្នកក៏មិនជំរុញគ្នាឱ្យផ្តល់អាហារដល់ជនក្រីក្រនោះដែរ។

19. ហើយពួកអ្នកកេងប្រវ័ញ្ចសិទ្ធិរបស់អ្នកទន់ខ្សោយទាំងឡាយយ៉ាងខ្លាំង។

20. ហើយពួកអ្នកចែមទាំងស្រលាញ់ទ្រព្យសម្បត្តិខ្លាំងហួសហេតុ។

21. មិនដូច្នោះឡើយ! នៅពេលដែលផែនដីត្រូវបានគេធ្វើឱ្យញ័ររញ្ជួយ

22. ហើយព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)បានយាងមកដល់ និងម៉ាឡាអ៊ីកាត់ជាច្រើនបានតម្រៀបគ្នាជាជួរៗ។

23. ហើយនៅថ្ងៃនោះ គេបាននាំមកនូវនរកដើហាន់ណាំ។ នៅថ្ងៃនោះ មនុស្សលោកនឹងភ្ញាក់រលឹក។ តើការភ្ញាក់រលឹកនោះអាចផ្តល់ផលប្រយោជន៍ដល់គេយ៉ាងដូចម្តេច?

24. គេនិយាយថា៖ ឱអនិច្ចាខ្លួនខ្ញុំអើយ! គួរណាស់តែខ្ញុំបានសាងអំពើល្អសម្រាប់ឆាកជីវិតរបស់ខ្ញុំ(ក្នុងថ្ងៃនេះ)!

25. ដូច្នេះ នៅក្នុងថ្ងៃនោះ គ្មាននរណាម្នាក់អាចដាក់ទណ្ឌកម្មដូចទណ្ឌកម្មរបស់ទ្រង់នោះឡើយ។

26. ហើយក៏គ្មាននរណាម្នាក់អាចចងចំណង ដូចចំណងរបស់ទ្រង់នោះដែរ។

27. ឱព្រលឹងដែលមានភាពនឹងនរ!

28. ចូរអ្នកត្រលប់ទៅកាន់ព្រះជាម្ចាស់របស់អ្នកដោយការពេញចិត្តចំពោះទ្រង់ ហើយទ្រង់ក៏ពេញចិត្តចំពោះអ្នកដែរ។

29. ដូច្នេះ ចូរអ្នកចូលក្នុងចំណោមខ្ញុំបម្រើរបស់យើង(ដែលជាអ្នកសាងទង្វើកុសល)។

30. ហើយចូរអ្នកចូលឋានសួគ៌របស់យើងចុះ។

ជំពូក អាល់ហ្គាឆ្បាត់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងទឹកដីនេះ(ក្រុងម៉ាក្កៈ)។

2. ហើយអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ត្រូវបានគេអនុញ្ញាតនៅក្នុងទឹកដីនេះ។

3. (ទ្រង់)ស្បថនឹងបិតានៃមនុស្សជាតិ(ព្យាការីអាដាំ)ហើយនិងអ្វី(កូនចៅរបស់គាត់)ដែលកើតចេញអំពីគាត់។

4. ពិតប្រាកដណាស់ យើងបានបង្កើតមនុស្សលោកឱ្យស្ថិតក្នុងការលំបាក។

5. តើមនុស្សលោកគិតស្មានថា គ្មាននរណាម្នាក់អាចមានសមត្ថភាពធ្វើអ្វីចំពោះរូបគេឬ?

6. គេនិយាយថាៈ ខ្ញុំបានបរិច្ចាគនូវទ្រព្យសម្បត្តិយ៉ាងច្រើន។

7. តើគេគិតស្មានថា គ្មាននរណាម្នាក់ឃើញគេឬ?

8. តើយើងមិនបានបង្កើតឱ្យគេមានភ្នែកពីរ

9. និងអណ្តាតមួយ បបូរមាត់ពីរ

10. ព្រមទាំងចង្អុលបង្ហាញផ្លូវពីរដល់គេ(ផ្លូវល្អ និងផ្លូវអាក្រក់)ទេឬ?

11. ហេតុអ្វីបានជាគេមិនឆ្លងកាត់ការលំបាក(នៃថ្ងៃបរលោក)?

12. តើអ្វីដែលធ្វើឱ្យអ្នកដឹងថា អ្វីទៅជាការលំបាក(នៃថ្ងៃបរលោក)នោះ?

13. នោះគឺការដោះលែងទាសករម្នាក់ឱ្យមានសេរីភាព

14. ឬផ្តល់ចំណីអាហារ(ដល់មនុស្សលោក)នៅថ្ងៃដែលមានគ្រោះទុរភិក្ស

15. ឬ(ផ្តល់ចំណីអាហារដល់)ក្មេងកំព្រាដែលជាញាតិសន្តាននឹងគ្នា

16. ឬអ្នកក្រីក្រដែលគ្មានអ្វីសោះ។

17. បន្ទាប់មក គេក៏បានស្ថិតក្នុងចំណោមអ្នកដែលមានជំនឿ និងបានផ្តែផ្តាំគ្នាឱ្យមានការអត់ធ្មត់ ព្រមទាំងផ្តែផ្តាំគ្នាឱ្យមានក្តីមេត្តាករុណា។

18. អ្នកទាំងនោះហើយ គឺជាក្រុមខាងស្តាំ។

19. រីឯពួកដែលគ្មានជំនឿនឹងវាក្យខណ្ឌទាំងឡាយរបស់យើង ពួកគេគឺជាក្រុមខាងឆ្វេង។

20. ភ្លើងនរកនឹងគ្របដណ្តប់លើពួកគេយ៉ាងជិត(នៅថ្ងៃបរលោក)។

ជំពូក អាស្ហស្ហាំ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ទ្រង់ស្បថនឹងព្រះអាទិត្យ ហើយនិងពេលព្រឹក។

2. (ទ្រង់)ស្បថនឹងព្រះចន្ទនៅពេលដែលវារះ និងលិច។

3. (ទ្រង់)ស្បថនឹងពេលថ្ងៃនៅពេលដែលវាបានបញ្ចេញពន្លឺ។

4. (ទ្រង់)ស្បថនឹងពេលយប់នៅពេលដែលវាបានគ្របដណ្តប់។

5. (ទ្រង់)ស្បថនឹងមេឃ និងសំណង់ដ៏ឥតខ្ចោះរបស់វា។

6. (ទ្រង់)ស្បថនឹងផែនដី និងកាពលាតសន្ធឹងរបស់វា។

7. (ទ្រង់)ស្បថនឹងជីវិត និងលក្ខណៈសមសួនរបស់វា។

8. ហើយទ្រង់បានធ្វើគេស្គាល់(ដឹង)នូវអ្វីដែលជាអំពើអាក្រក់ និងអ្វីដែលជាអំពើល្អ។

9. ពិតជាបានទទួលជោគជ័យហើយ អ្នកដែលជម្រះសម្អាតខ្លួន(ដោយការសាងអំពើល្អ)។

10. ហើយពិតជាទទួលនូវការខាតបង់ហើយ អ្នកដែលធ្វើឱ្យខ្លួនមានភាពកខ្វក់(ដោយការសាងអំពើអាក្រក់)។

11. ក្រុមសាមូទបានបដិសេធ(នឹងអ្នកនាំសាររបស់ពួកគេ)ដោយការបំពាន

12. នៅពេលដែលអពមង្គលម្នាក់ក្នុងចំណោមពួកគេបានក្រោកឈរឡើង(ដើម្បីប្រឆាំង)។

13. ពេលនោះ អ្នកនាំសាររបស់អល់ឡោះ(ព្យាការីសែឡេះ)បាននិយាយទៅកាន់ពួកគេថា៖ (ចូរពួកអ្នកប្រយ័ត្នចំពោះ)សត្វអូដ្ឋញីរបស់អល់ឡោះ និងវេនផឹកទឹករបស់វា។

14. តែពួកគេបានប្រឆាំង ហើយក៏បានសម្លាប់សត្វអូដ្ឋញីនោះ។ ពេលនោះ ព្រះជាម្ចាស់ក៏បានដាក់ទណ្ឌកម្មលើពួកគេព្រោះតែបាបកម្មរបស់ពួកគេ។ ហើយទ្រង់បានធ្វើឱ្យពួកគេវិនាសអន្តរាយទាំងអស់គ្នា។

15. ហើយទ្រង់មិនខ្លាចលទ្ធផលចុងក្រោយរបស់វានោះឡើយ។

ជំពូក អាល់ឆ្បែល

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងពេលយប់ នៅពេលដែលផែនដីត្រូវបានគ្របដណ្តប់ដោយភាពងងឹតរបស់វា។

2. ហើយទ្រង់ស្បថនឹងពេលថ្ងៃ នៅពេលដែលវាបានបញ្ចោញពន្លឺ។

3. ហើយទ្រង់ស្បថនឹងអ្វីដែលទ្រង់បានបង្កើត មានប្រុស មានស្រី។

4. ជាការពិតណាស់ ទង្វើរបស់ពួកអ្នក(មនុស្សលោក) គឺខុសៗគ្នា។

5. រីឯអ្នកដែលបានបរិច្ចាគ និងកោតខ្លាច(អល់ឡោះ)

6. ហើយមានការជឿជាក់ចំពោះការសន្យារបស់អល់ឡោះ

7. យើងនឹងសម្រួលដល់គេនូវកិច្ចការទាំងឡាយរបស់គេ។

8. រីឯជនណាដែលកំណាញ់ និងមិនត្រូវការការតបស្នងរបស់អល់ឡោះ

9. ហើយគេបដិសេធ(មិនជឿ)ចំពោះការសន្យារបស់អល់ឡោះ

10. យើងនឹងសម្រួលដល់គេទៅកាន់ការលំបាក។

11. ហើយទ្រព្យសម្បត្តិរបស់គេមិនអាចផ្តល់ជាប្រយោជន៍អ្វីដល់គេនោះឡើយនៅពេលគេធ្លាក់ទៅក្នុងនរកនោះ។

12. ជាការពិតណាស់ តួនាទីរបស់យើង គឺការបកស្រាយបញ្ជាក់នូវមាគ៌ាដែលត្រឹមត្រូវ។

13. ហើយពិតប្រាកដណាស់ ឆាកជីវិតបរលោកនិងឆាកជីវិតលោកិយ គឺជាកម្មសិទ្ធិរបស់យើង។

14. ដូច្នេះ យើងបានដាស់តឿនព្រមានពួកអ្នក(ឱមនុស្សលោក)ឱ្យប្រុងប្រយ័ត្នអំពីភ្លើងនរកដែលឆាបឆេះសន្ធោសន្ធៅ។

15. គ្មាននរណាម្នាក់ចូលក្នុងវានោះទេ លើកលែងតែអ្នកដែលអពមង្គលប៉ុណ្ណោះ

16. គឺអ្នកដែលបដិសេធ និងងាកចេញ(ពីការមានជំនឿ)។

17. ហើយគេនឹងបញ្ចៀសអ្នកដែលកោតខ្លាចអល់ឡោះបំផុតអំពីវា(ឋាននរក)។

18. ជាអ្នកដែលបរិច្ចាគទ្រព្យសម្បត្តិរបស់គេដើម្បីជម្រះសម្អាតខ្លួន(ពីបាបកម្ម)។

19. គេមិនមែនបរិច្ចាគទ្រព្យសម្បត្តិដើម្បីសងគុណនរណាម្នាក់នោះឡើយ

20. ក្រៅតែពីដើម្បីស្វែងរកការពេញចិត្តពីម្ចាស់របស់គេដ៏មហាខ្ពង់ខ្ពស់ប៉ុណ្ណោះ។

21. ហើយគេពិតជានឹងពេញចិត្តជាមិនខាន។

ជំពូក អាត់ហ្សូហា

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងពេលព្រឹក។
2. (ទ្រង់)ស្បថនឹងពេលយប់នៅពេលដែលវាងងឹត។
3. ព្រះជាម្ចាស់របស់អ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានបោះបង់អ្នក និងមិនបានខឹងសម្បា(នឹងអ្នក)នោះឡើយ។
4. ហើយជាការពិតណាស់ ថ្ងៃបរលោក គឺល្អប្រសើរសម្រាប់អ្នកជាងលោកិយនេះទៅទៀត។
5. ហើយព្រះជាម្ចាស់របស់អ្នកពិតជានឹងប្រទានឱ្យអ្នក(នូវការប្រោសប្រទានគ្រប់បែបយ៉ាងនៅថ្ងៃបរលោក) ហើយអ្នកប្រាកដជានឹងពេញចិត្តជាមិនខាន។
6. តើទ្រង់មិនបានឃើញអ្នកជាក្មេងកំព្រា រួចទ្រង់បានផ្តល់ទីជម្រកដល់អ្នកទេឬ?
7. ហើយទ្រង់បានឃើញអ្នកជាមនុស្សដែលមិនដឹង(អ្វីទៅជាគម្ពីរគួរអាន និងអ្វីជាជំនឿ) រួចទ្រង់ក៏បង្រៀនដល់អ្នក។
8. ហើយទ្រង់បានឃើញអ្នកមានជីវភាពក្រីក្រ រួចទ្រង់ក៏បានធ្វើឱ្យអ្នកមានបាន។
9. ដូច្នេះ ចំពោះក្មេងកំព្រា ចូរអ្នកកុំគាបសង្កត់(ពួកគេ)ឱ្យសោះ។
10. ហើយចំពោះអ្នកសុំទាន ចូរអ្នកកុំគំហក(ដាក់ពួកគេ)។
11. ហើយចំណែកឯឧបការគុណនៃព្រះជាម្ចាស់របស់អ្នក ចូរអ្នករៀបរាប់(អំពីវា)ចុះ។

ជំពូក អាស្ហស្ហើរហ៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តើយើងមិនបានបើកទ្រូងរបស់អ្នក(បើកចិត្ត)ឲ្យមានភាពទូលាយសម្រាប់អ្នកទេឬ?

2. ហើយយើងបានដកចេញពីអ្នកនូវបន្ទុករបស់អ្នក

3. ដែលជាបន្ទុកដ៏ធ្ងន់លើខ្នងរបស់អ្នក។

4. ហើយយើងបានលើកតម្កើងឋានៈរបស់អ្នកឱ្យខ្ពង់ខ្ពស់។

5. ហើយពិតប្រាកដណាស់ ទន្ទឹមនឹងការលំបាក គឺមានភាពងាយស្រួល។

6. ពិតប្រាកដណាស់ ទន្ទឹមនឹងការលំបាក គឺមានភាពងាយស្រួល។

7. ដូច្នេះ នៅពេលដែលអ្នករួចរាល់(ពីកិច្ចការរបស់អ្នក) ចូរអ្នកប្រឹងប្រែងគោរពសក្ការៈ។

8. ហើយឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់អ្នក ចូរអ្នកប៉ងប្រាថ្នា។

ជំពូក អាត់ទីន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងផ្លែទីន(ផ្លែល្វាអារ៉ាប់) និងផ្លែហ្សៃទូន(ផ្លែអូលីវ)។

2. (ទ្រង់)ស្បថនឹងភ្នំទួរស៊ីណា(ភ្នំស៊ីណៃ)។

3. (ទ្រង់)ស្បថនឹងទីកដីនេះ(ក្រុងម៉ាក្កះ)ដែលមានសុវត្ថិភាព។

4. ជាការពិតណាស់ យើងបានបង្កើតមនុស្សលោកស្ថិតក្នុងទ្រង់ទ្រាយមួយដ៏ល្អប្រពៃបំផុត។

5. ក្រោយមក យើងបានត្រឡប់គេទៅកាន់កន្លែងដែលទាបបំផុត(ហាននរក)

6. លើកលែងតែបណ្តាអ្នកដែលមានជំនឿ និងបានសាងនូវទង្វើកុសលប៉ុណ្ណោះ។ ពិតប្រាកដណាស់ សម្រាប់ពួកគេនឹងទទួលបានផលបុណ្យគ្មានទីបញ្ចប់ឡើយ។

7. ដូច្នេះ បន្ទាប់ពីនោះ តើអ្វីមួយដែលធ្វើឱ្យអ្នក(ឱមនុស្សលោក)បដិសេធនឹងការបង្កើតឲ្យរស់ឡើងវិញ?

8. តើមិនមែនអល់ឡោះជាម្ចាស់ទេឬដែលជាអ្នកកាត់សេចក្តីដ៏សុក្រឹតបំផុតក្នុងចំណោមអ្នកកាត់សេចក្តីទាំងឡាយនោះ?

ជំពូក អាល់អាឡឺក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)សូត្រនូវព្រះនាមនៃព្រះជាម្ចាស់របស់អ្នកដែលបានបង្កើត(អ្វីៗទាំងអស់)ចុះ។
2. ទ្រង់បានបង្កើតមនុស្សលោកពីតំណក់ឈាមមួយដុំ។
3. ចូរអ្នក(មូហាំម៉ាត់)សូត្រចុះ ហើយព្រះជាម្ចាស់របស់អ្នកទ្រង់មហាសប្បុរសបំផុត។
4. ទ្រង់ជាអ្នកដែលបានបង្រៀន(ឱ្យចេះសរសេរ)ដោយស្លាបប៉ាកកា។
5. ទ្រង់បង្រៀនមនុស្សនូវអ្វីដែលគេមិនធ្លាប់បានដឹង។
6. ជាការពិតណាស់ មនុស្សលោកពិតជាអ្នកដែលបំពានបំផុត
7. ដោយសារតែគេយល់ឃើញថា រូបគេមានគ្រប់គ្រាន់ហើយ។
8. ពិតប្រាកដណាស់ កន្លែងវិលត្រឡប់(នៅថ្ងៃបរលោក) គឺឆ្ពោះទៅកាន់ព្រះជាម្ចាស់របស់អ្នក។
9. តើអ្នកឃើញដែរឬទេ អ្នកដែលបានហាមឃាត់
10. ខ្ញុំបម្រើរបស់យើង(ព្យាការីមូហាំម៉ាត់)នៅពេលដែលគេប្រតិបត្តិសឡាតនោះ?
11. តើអ្នកយល់ឃើញយ៉ាងណា ប្រសិនបើអ្នកដែលត្រូវបានគេហាមឃាត់នោះស្ថិតនៅលើការចង្អុលបង្ហាញ
12. ឬជាអ្នកដែលប្រើ(មនុស្ស)ឱ្យកោតខ្លាច(អល់ឡោះ)នោះ?
13. តើអ្នកយល់ឃើញយ៉ាងណាដែរ ប្រសិនបើអ្នកដែលហាមឃាត់គេនោះបានបដិសេធ និងងាកចេញ
14. តើគេមិនដឹងទេឬថា ពិតប្រាកដណាស់ អល់ឡោះទ្រង់ឃើញបំផុត(នូវអ្វីដែលគេបានធ្វើ)នោះ?

15. មិនដូច្នោះឡើយ! ប្រសិនបើគេមិនបញ្ឈប់ទង្វើនោះទេនោះ យើងនឹងចាប់ក្បាលរបស់គេទម្លាក់ទៅក្នុងនរកជាមិនខាន

16. គឺក្បាលអ្នកដែលកូតកុហក និងប្រព្រឹត្តអំពើខុសឆ្គង។

17. ដូច្នេះ ចូរទុកឱ្យគេស្រែកហៅក្រុមរបស់គេ(ឱ្យមកជួយគេ)ចុះ

18. យើងក៏នឹងហៅឆ្មាំនរកដូចគ្នា។

19. មិនដូច្នោះឡើយ។ ចូរអ្នក(ព្យាការីមូហាំម៉ាត់)កុំធ្វើតាមគេឱ្យសោះ។ ហើយចូរអ្នកស៊ូជូត និងបញ្ជិតខ្លួន(ទៅកាន់ទ្រង់)។

ជំពូក អាល់កន់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ជាការពិតណាស់ យើងបានបញ្ចុះគម្ពីរ(គម្ពីរគួរអាន)នៅក្នុងយប់ឡៃឡាតុលកទើរ។

2. ហើយតើអ្វីដែលធ្វើឲ្យអ្នក(ឱព្យាការីមូហាំម៉ាត់)ដឹងថា អ្វីទៅជាយប់ឡៃឡាទុលកទើរនោះ ?

3. យប់ឡៃឡាទុលកទើរ គឺល្អប្រសើរជាងមួយពាន់ខែ។

4. ម៉ាឡាអ៊ីកាត់ជាច្រើន និងជីព្រីលបានចុះមកក្នុងយប់នោះដោយមានការអនុញ្ញាតពីព្រះជាម្ចាស់របស់ពួកគេ ដើម្បីអនុវត្តរាល់បទបញ្ជាទាំងឡាយ។

5. យប់នោះពោរពេញសន្តិភាព រហូតដល់ពេលហ្វាជើរ(ទៀបភ្លឺ)។

ជំពូក អាល់ហ្គៃយីណាះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពួកគ្មានជំនឿនៃពួកអះលីគីតាប និងពួកមូស្លីគីន គឺមិនបោះបង់ភាពគ្មានជំនឿរបស់ពួកគេឡើយ រហូតទាល់តែសញ្ញាកស្តុតាងដ៏ច្បាស់លាស់បានមកដល់ពួកគេ។

2. គឺអ្នកនាំសារម្នាក់មកពីអល់ឡោះដែលនឹងសូត្រគម្ពីរ(គួរអាន)ដ៏ស្អាតស្អំ។

3. នៅក្នុងគម្ពីរនេះ(គម្ពីរគួរអាន) គឺមានដំណឹងពិត និងច្បាប់ដ៏យុត្តិធម៌។

4. ហើយពួកដែលគេផ្តល់គម្ពីរឱ្យមិនបានខ្វែងគំនិតគ្នានោះឡើយ លើកលែងតែក្រោយពីសញ្ញាកស្តុតាងដ៏ច្បាស់លាស់បានមកដល់ពួកគេប៉ុណ្ណោះ។

5. ហើយគេមិនបានប្រើពួកគេនោះឡើយ ក្រៅតែពីឲ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះដោយស្មោះសចំពោះសាសនា (របស់ទ្រង់) និងចៀសវាងពីប្រការស្តីរកៃ ព្រមទាំងប្រតិបត្តិសឡាត និងបរិច្ចាគហ្សាកាត់នោះឡើយ។ នោះហើយជាសាសនាដ៏ត្រឹមត្រូវ។

6. ពួកគ្មានជំនឿនៃពួកអះលីគីតាប និងពួកមូស្លីគីន នឹងស្ថិតក្នុងនរកដើហាន់ណាំដោយស្ថិតនៅក្នុងនោះជាអមតៈ។ ពួកទាំងនោះហើយជាភាវៈដែលអាក្រក់បំផុត។

7. ពិតប្រាកដណាស់ បណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល អ្នកទាំងនោះហើយជាភាវៈដែលល្អបំផុត។

8. ការតបស្នងរបស់ពួកគេនៅឯព្រះជាម្ចាស់របស់ពួកគេ គឺឋានសួគ៌អាត់និនដែលមានទន្លេជាច្រើនហូរពីក្រោមវាដោយពួកគេស្ថិតនៅទីនោះជាអមតៈ។ អល់ឡោះបានពេញចិត្តចំពោះពួកគេ ហើយពួកគេក៏ពេញចិត្តចំពោះទ្រង់វិញដែរ។ នោះគឺសម្រាប់តែជនណាដែលខ្លាចព្រះជាម្ចាស់របស់គេប៉ុណ្ណោះ។

ជំពូក អាល់ហ្សាល់ហ្សាឡះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលផែនដីត្រូវបានគេធ្វើឱ្យញ័ររញ្ជួយយ៉ាងខ្លាំង

2. ហើយផែនដីបានបញ្ចេញទាំងអស់នូវអ្វីដែលមាននៅក្នុងវា

3. ហើយមនុស្សលោកនិយាយថា៖ តើមានអ្វីកើតឡើងចំពោះផែនដី?

4. នៅក្នុងថ្ងៃនោះ ផែនដីនឹងប្រាប់ទាំងអស់នូវរឿងរ៉ាវរបស់វា

5. ពីព្រោះព្រះជាម្ចាស់របស់អ្នកបានបញ្ជាឱ្យវាធ្វើដូច្នោះ។

6. នៅក្នុងថ្ងៃនោះ មនុស្សលោកនឹងចេញ(ពីកន្លែងជំនុំជម្រះ)ជាក្រុមៗ ដើម្បីឲ្យគេបង្ហាញពីទង្វើទាំងឡាយរបស់ពួកគេ។

7. ដូច្នេះ ជនណាដែលសាងទង្វើល្អសូម្បីប៉ុនលំអងធូលីក៏ដោយ គេនឹងបានឃើញវា។

8. ហើយជនណាដែលសាងទង្វើអាក្រក់សូម្បីប៉ុនលំអងធូលីក៏ដោយ ក៏គេនឹងឃើញវាដូចគ្នាដែរ។

ជំពូក អាល់អាទីយ៉ាត

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. (អល់ឡោះ)ស្បថនឹងសត្វសេះទាំងឡាយដែលរត់ទាំងដង្ហក់នៅក្នុងសមរភូមិ

2. (ទ្រង់)ស្បថនឹងសត្វសេះដែលរត់យ៉ាងលឿនរហូតចេញផ្កាភ្លើង

3. (ទ្រង់)ស្បថនឹងសត្វសេះដែលវាបោលសម្រុកទៅរកខ្មាំងសត្រូវទាំងព្រឹកព្រលឹម

4. ដោយធ្វើឱ្យធូលីហុយទ្រលោម

5. ហើយពួកវាសម្រុកចូលទៅកណ្តាលហ្វូងសត្រូវ។

6. ពិតប្រាកដណាស់ មនុស្សលោក ពិតជារមិលគុណបំផុតចំពោះព្រះជាម្ចាស់របស់គេ។

7. ហើយពិតប្រាកដណាស់ រូបគេជាសាក្សីចំពោះការរមិលគុណនោះ។

8. ហើយពិតប្រាកដណាស់ គេពិតជាស្រលាញ់ទ្រព្យសម្បត្តិយ៉ាងងុបងល់។

9. តើគេមិនដឹងទេឬថា នៅពេលដែលគេ(អល់ឡោះ)បានឱ្យសាកសពនៅក្នុងផ្នូររស់ឡើងវិញ (តើអ្វីទៅដែលនៅរង់ចាំរូបគេនោះ)?

10. ហើយគេនឹងលាតត្រដាងនូវអ្វីដែលនៅក្នុងដួងចិត្ត។

11. ពិតប្រាកដណាស់នៅថ្ងៃនោះ ព្រះជាម្ចាស់របស់ពួកគេពិតជាដឹងបំផុតចំពោះពួកគេ។

ជំពូក អាល់ការីអះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ថ្ងៃបរលោក។
2. តើអ្វីទៅជាថ្ងៃបរលោក?
3. ហើយតើអ្វីដែលធ្វើឱ្យអ្នកដឹងថា អ្វីទៅជាថ្ងៃបរលោកនោះ?
4. គឺថ្ងៃដែលមនុស្សលោកប្រៀបដូចជាសត្វមេអំបៅដែលហើរប្រសេចប្រសាច។
5. ហើយភ្នំទាំងឡាយប្រៀបដូចជារោមសត្វដែលត្រូវគេធ្វើឱ្យប៉ើងរប៉ាត់រប៉ាយ។
6. រីឯអ្នកដែលជញ្ជឹង(ទង្វើល្អ)របស់គេធ្ងន់ជាង
7. រូបគេនឹងស្ថិតនៅក្នុងជីវិតរស់នៅមួយដ៏ជាទីគាប់ចិត្ត(ក្នុងឋានសួគ៌)។
8. ហើយចំណែកឯជនណាដែលជញ្ជឹង(ទង្វើល្អ)របស់គេស្រាលជាង
9. កន្លែងស្នាក់អាស្រ័យរបស់គេ គឺឋាននរក។
10. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា តើអ្វីទៅជាឋាននរកនោះ?
11. គឺជាភ្លើងដ៏សែនក្តៅបំផុត។

ជំពូក អត់តាកាស្ទូរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ការមានមោទនភាពនឹងទ្រព្យសម្បត្តិ និងរឿងកូនចៅច្រើនបានធ្វើឱ្យពួកអ្នកភ្លេចពីការគោរពប្រតិបត្តិចំពោះអល់ឡោះ

2. រហូតដល់ពួកអ្នកបានចូលទៅក្នុងផ្នូរ(ស្លាប់)។

3. មិនដូច្នោះឡើយ! ពួកអ្នកគង់តែនឹងដឹងជាមិនខាន។

4. ក្រោយមក មិនដូច្នោះឡើយ! ពួកអ្នកគង់តែនឹងដឹងជាមិនខាន។

5. មិនដូច្នោះឡើយ! ប្រសិនបើពួកអ្នកបានដឹងនូវការដឹងមួយយ៉ាងច្បាស់(ពួកនឹងមិនមានមោទនភាពនឹងរឿងនោះឡើយ)។

6. ពួកអ្នកពិតជានឹងឃើញនរកជើហ្មឹមជាមិនខាន។

7. បន្ទាប់មក ពួកអ្នកពិតជានឹងឃើញវាយ៉ាងច្បាស់ផ្ទាល់នឹងភ្នែក។

8. ក្រោយមក នៅថ្ងៃនោះ ពួកអ្នកពិតជានឹងត្រូវគេសួរពីឧបការគុណទាំងឡាយ(ដែលពួកអ្នកធ្លាប់ទទួលបាន)ជាមិនខាន។

ជំពូក អាល់អេសរ៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. អល់ឡោះទ្រង់ស្បថនឹងពេលវេលា។

2. ជាការពិតណាស់ មនុស្សលោកស្ថិតក្នុងភាពខាតបង់។

3. លើកលែងតែបណ្តាអ្នកដែលមានជំនឿ និងបានសាងទង្វើកុសល ហើយផ្តែផ្តាំគ្នាឱ្យប្រកាន់ខ្ជាប់នូវការពិត និងផ្តែផ្តាំគ្នាឱ្យមានការអត់ធ្មត់ប៉ុណ្ណោះ។

ជំពូក អាល់ហ៊ូម៉ាហ្សះ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ភាពវិនាសអន្តរាយ គឺចំពោះអ្នកដែលនិយាយដើមគេ និងមួលបង្កាច់អ្នកដទៃ។

2. ជាអ្នកដែលប្រមូលទ្រព្យសម្បត្តិ និងរាប់ចំនួនវាទុក

3. ដោយគេគិតស្មានថា ទ្រព្យសម្បត្តិរបស់គេអាចជួយឲ្យគេមានជីវិតអមតៈ(ក្នុងលោកិយ)បាន។

4. ពុំដូច្នោះឡើយ! តាមពិត រូបគេនឹងត្រូវគេបោះទៅក្នុងហាននរក។

5. តើអ្វីដែលធ្វើឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ដឹងថា អ្វីទៅជាហាននរកនោះ?

6. គឺជាភ្លើងរបស់អល់ឡោះដែលត្រូវបានគេបង្កាត់

7. ដែលវានឹងឆាបឆេះដល់បេះដូង(ពួកគេ)។

8. ជាការពិតណាស់ នៅលើពួកគេ គឺមានគម្របបិទជិត។

9. ពួកគេត្រូវបានគេចងភ្ជាប់នឹងសសរដ៏វែង។

ជំពូក អាល់ហ្វីល

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តើអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)មិនបានដឹងទេឬថា តើព្រះជាម្ចាស់របស់អ្នកបានធ្វើយ៉ាងដូចម្តេចទៅលើក្រុមទ័ពដំរី?
2. តើអល់ឡោះមិនបានធ្វើឱ្យឧបាយកល(ដ៏អាក្រក់)របស់ពួកគេបរាជ័យទេឬ?
3. ហើយទ្រង់បានបញ្ជូនបក្សីទាំងហ្វូងៗទៅកាន់ពួកគេ
4. ដោយពួកវាទម្លាក់ដុំថ្មពីដីឥដ្ឋដែលគេដុត(ក្នុងភ្លើងនរក)ទៅលើពួកគេ។
5. ពិតណាស់ អល់ឡោះបានធ្វើឱ្យពួកគេ(វិនាសអន្តរាយ)ដូចជាស្លឹកឈើដែលត្រូវសត្វស៊ី។

ជំពូក គូរ៉ស្ស

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ជាទម្លាប់របស់ពួកគូរ៉ស្ស

2. ទម្លាប់របស់ពួកគេ គឺការធ្វើដំណើរក្នុងរដូវរងារ(នៅកាន់ប្រទេសយេមែន) និងក្នុងរដូវក្តៅ(ទៅកាន់តំបន់ស្លាម)។

3. ដូច្នេះ ចូរឱ្យពួកគេគោរពសក្ការៈចំពោះព្រះជាម្ចាស់នៃកាក់ហ្គះនេះ(តែមួយគត់)

4. ដែលជាអ្នកផ្តល់ចំណីអាហារដល់ពួកគេដើម្បីបំបាត់ស្រេកឃ្លាន និងផ្តល់សុវត្ថិភាពដល់ពួកគេពីភាពភ័យខ្លាច។

ជំពូក អាល់ម៉ាអ៊ូន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. តើអ្នកឃើញ(ស្ថានភាព)អ្នកដែលបដិសេធនឹងថ្ងៃបរលោកដែរឬទេ?

2. នោះហើយជាបុគ្គលដែលរំលោកបំពានសិទ្ធិក្មេងកំព្រា

3. ហើយគេក៏មិនជំរុញឱ្យផ្តល់អាហារដល់ជនក្រីក្រឡើយ។

4. ដូច្នេះ ភាពវិនាសអន្តរាយ គឺសម្រាប់អ្នកសឡាតទាំងឡាយណា

5. ដែលពួកគេធ្វេសប្រហែសចំពោះការប្រតិបត្តិសឡាតរបស់ខ្លួន។

6. ពួកគេគឺជាពួកដែលធ្វើអ្វីដើម្បីបង្ហាញឱ្យគេឃើញប៉ុណ្ណោះ។

7. ហើយពួកគេមិនឲ្យអ្នកជទៃខ្ចីឡើយ បើទោះបីជាវាមិនប៉ះពាល់ដល់រូបគេក៏ដោយ។

ជំពូក អាល់កាវសើរ

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ពិតប្រាកដណាស់ យើងបានប្រទានឱ្យអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)នូវអាល់កាវសើរ(ឈ្មោះទន្លេមួយក្នុងឋានសួគ៌)។

2. ហេតុនេះ ចូរអ្នកប្រតិបត្តិសឡាតចំពោះព្រះជាម្ចាស់របស់អ្នក និងសំឡេះសត្វចុះ។

3. ពិតប្រាកដណាស់ អ្នកដែលខឹងសម្បានឹងអ្នក គឺជាបុគ្គលដែលត្រូវបានគេកាត់ផ្តាច់(ពីប្រការល្អទាំងឡាយ)។

ជំពូក អាល់កាហ្វីរូន

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ឱពួកដែលគ្មានជំនឿ!

2. ខ្ញុំមិនគោរពសក្ការៈចំពោះអ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈនោះឡើយ។

3. ហើយពួកអ្នកក៏មិនមែនជាអ្នកគោរពសក្ការៈចំពោះអ្វីដែលខ្ញុំកំពុងតែគោរពសក្ការៈនោះដែរ។

4. ហើយខ្ញុំមិនគោរពសក្ការៈចំពោះអ្វីដែលពួកអ្នកកំពុងតែគោរពសក្ការៈឡើយ។

5. ហើយពួកអ្នកក៏មិនមែនជាអ្នកគោរពសក្ការៈចំពោះអ្វីដែលខ្ញុំកំពុងតែគោរពសក្ការៈនោះដែរ។

6. សម្រាប់ពួកអ្នក គឺមានសាសនារបស់ពួកអ្នក។ ហើយសម្រាប់ខ្ញុំ គឺមានសាសនារបស់ខ្ញុំ។

ជំពូក អាន់ណោសរ៏

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. នៅពេលដែលជំនួយរបស់អល់ឡោះ និងការរំដោះ(ទីក្រុងម៉ាក្កះ)បានមកដល់

2. ហើយអ្នកបានឃើញមនុស្សលោកចូលសាសនារបស់អល់ឡោះទាំងក្រុម

3. ដូច្នេះ ចូរអ្នកលើកតម្កើងដោយការកោតសរសើរចំពោះព្រះជាម្ចាស់របស់អ្នក និងសុំការអភ័យទោសពីទ្រង់ចុះ។ ពិតណាស់ទ្រង់គឺជាអ្នកដែលទទួលយកការសារភាពកំហុសបំផុត។

ជំពូក អាល់ម៉ាសាត់

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ដៃទាំងពីររបស់អាពូឡាហាប់ គឺបានវិនាសអន្តរាយហើយ ហើយរូបគេក៏អន្តរាយដែរ។

2. ទ្រព្យសម្បត្តិ និងកូនចៅរបស់គេមិនអាចជួយជាប្រយោជន៍អ្វីដល់គេឡើយ។

3. គេនឹងចូលទៅក្នុងនរកដែលមានអណ្តាតភ្លើងដ៏សន្ធោសន្ធៅ។

4. ចំណែកឯប្រពន្ធរបស់គេដែលបានរាយបន្លា(លើផ្លូវដើររបស់ព្យាការីមូហាំម៉ាត់ ក៏ដូចគ្នាដែរ)។

5. នៅនឹងករបស់នាង មានខ្សែច្រវាក់សម្រាប់អូសនាងចូលទៅក្នុងឋាននរក។

ជំពូក អាល់អៀឡឺស

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ អល់ឡោះគឺជាព្រះជាម្ចាស់(ដែលគេត្រូវគោរពសក្ការៈ)តែមួយគត់។

2. អល់ឡោះទ្រង់ជាទីពឹងពាក់។

3. ទ្រង់មិនប្រសូតបុត្រ ហើយទ្រង់ក៏មិនត្រូវបានគេប្រសូតមកនោះដែរ។

4. ហើយគ្មាននរណាម្នាក់អាចប្រៀបប្រដូចនឹងទ្រង់បានឡើយ។

ជំពូក អាល់ហ្សាឡឹក

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំសុំពីព្រះជាម្ចាស់នៃពេលទៀបភ្លឺឱ្យបញ្ចៀស(រូបខ្ញុំ)

2. ពីប្រការអាក្រក់ទាំងឡាយដែលទ្រង់បានបង្កើតមក។

3. និងពីប្រការអាក្រក់នៃពេលយប់នៅពេលដែលភាពងងឹតបានមកដល់

4. និងពីប្រការអាក្រក់របស់ស្ត្រីមេធ្មប់ទាំងឡាយដែលបានសូត្រផ្លុំទៅក្នុងចំណងខ្សែគាថា(របស់ពួកគេ)

5. និងពីប្រការអាក្រក់នៃអ្នកដែលច្រណែនឈ្នានីសនៅពេលដែលគេច្រណែនឈ្នានីស។

ជំពូក អាន់ណាស

ក្នុងព្រះនាមអល់ឡោះ មហាសប្បុរស មហាអាណិតស្រលាញ់។

1. ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖ ខ្ញុំសុំពីព្រះជាម្ចាស់នៃមនុស្សលោក

2. ជាស្តេចគ្រប់គ្រងមនុស្សលោក

3. ជាព្រះជាម្ចាស់របស់មនុស្សលោក

4. (សូមទ្រង់មេត្តាបញ្ជៀស)ពីប្រការអាក្រក់នៃការញុះញង់របស់ស្តេតន

5. ដែលវាបញ្ចូលការញុះញង់ក្នុងដួងចិត្តមនុស្សលោក

6. (ដែលស្តេតននោះអាច)មកពីពួកជិន និងមនុស្សលោក។

មាតិកាជំពូក

ល.រ	ឈ្មោះសូរ៉ះ (ខ្មែរ)	ឈ្មោះជំពូក (អត្ថន័យ)	ទំព័រ		សូរ៉ះ(អារ៉ាប់)
1	អាល់ហ្វាទីហៈ	ការចាប់ផ្តើម	1	មកីយ៉ះ	الفاتحة
2	អាល់ប្ការ៉ក៏អ៊ោះ	សត្វគោ	2	មទីន៉ះ	البقرة
3	អាលីអ៊ិមរ៉ន	គ្រួសារអ៊ិមរ៉ន	35	មទីន៉ះ	آل عمران
4	អាន់នីសាក	ស្ត្រី	56	មទីន៉ះ	النساء
5	អាល់ម៉ាអ៊ីដៈ	តុអាហារ	76	មទីន៉ះ	المائدة
6	អាល់អាន់អាម	សត្វពាហនៈ	90	មកីយ៉ះ	الأنعام
7	អាល់អាក់រ៉ហ្វ	ក្រុមអាក់រ៉ហ្វ	108	មកីយ៉ះ	الأعراف
8	អាល់អាន់ហ្វាល	ទ្រព្យជ័យកណ្ដា	129	មទីន៉ះ	الأنفال
9	អាត់តាវ៉ះ	ការសារភាពកំហុស	137	មទីន៉ះ	التوبة
10	យូនុស	ព្យាការីយូនុស	151	មកីយ៉ះ	يونس
11	ហ៊ូទ	ព្យាការីហ៊ូទ	162	មកីយ៉ះ	هود
12	យូសុៈ	ព្យាការីយូសុៈ	174	មកីយ៉ះ	يوسف
13	អាល់រ៉ក់ទ៍	ផ្គរន្ទះ	185	មទីន៉ះ	الرعد
14	អ៊ីព្រហ៊ីម	ព្យាការីអ៊ីព្រហ៊ីម	190	មកីយ៉ះ	إبراهيم
15	អាល់ហ៊ិជ្ជរ៍	ក្រុមហ៊ុជ្ជរី	195	មកីយ៉ះ	الحجر
16	អាន់ណះល៍	សត្វឃ្មុំ	202	មកីយ៉ះ	النحل
17	អាល់អ៊ិសរ៉ក	ដំណើរអ៊ិសរ៉ក	214	មកីយ៉ះ	الإسراء
18	អាល់កៈហ្វឺ	គុហាភ្នំ	224	មកីយ៉ះ	الكهف
19	ម៉ារយ៉ំ	នាងម៉ារី	234	មកីយ៉ះ	مريم
20	តហា	តហា	242	មកីយ៉ះ	طه
21	អាល់អំពីយ៉ាក	បណ្ដាព្យាការី	253	មកីយ៉ះ	الأنبياء
22	អាល់ហាជ្ជ	ធម្មយាត្រាហាជ្ជ	262	មទីន៉ះ	الحج

23	អាល់មុមីនូន	បណ្តាអ្នកមានជំនឿ	270	مكية	المؤمنون
24	អាន់នួរ	ពន្លឺរស្មី	279	مدنية	النور
25	អាល់ហ្វួរកន	ការវិនិច្ឆ័យ	286	مكية	الفرقان
26	អាស់ស៊ូអារ៉ក	កវីកំណាព្យ	292	مكية	الشعراء
27	អាន់ណាំល៍	សត្វស្រមោច	307	مكية	النمل
28	អាល់ក៏សស្ស	និទានប្រវត្តិសាស្ត្រ	315	مكية	القصص
29	អាល់អាន់កាពូត	សត្វពីងពាង	323	مكية	العنكبوت
30	អាល់រ៉ូម	ពួករ៉ូម	329	مكية	الروم
31	លុកម៉ាន	លោកលុកម៉ាន	334	مكية	لقمان
32	អាសសាជ្ជហ្ទះ	ការក្រាបស៊ូជោត	337	مكية	السجدة
33	អាល់អះហ្សាប	ពួកពហុក្រុម	340	مدنية	الأحزاب
34	សាហ្ពាក់	ក្រុមសាហ្ពាក់	347	مكية	سبأ
35	ហ្វាតៀរ	អ្នកបង្កើត	352	مكية	فاطر
36	យ៉ាស៊ីន	យ៉ាស៊ីន	357	مكية	يس
37	អាសស៍ហ្វាហ្វាត	តម្រៀបជាជួរ	363	مكية	الصافات
38	សទ	សទ	374	مكية	ص
39	អាសហ៊្សូមើរ	ក្រុមពួក	380	مكية	الزمر
40	ហ្គហ្វៀរ	អ្នកដែលអភ័យទោស	387	مكية	غافر
41	ហ៊្វុសស៊ីឡាត់	ពណ៌នាយ៉ាងពិស្តារ	395	مكية	فصلت
42	អាសស៊ូរ៉	ការពិគ្រោះពិភាក្សា	400	مكية	الشورى
43	អាសហ៊្សុខរូហ្វ	គ្រឿងលម្អ	405	مكية	الزخرف
44	អាត់ទូខន	ផ្សែង	412	مكية	الدخان
45	អាល់ជើស៊ីយ៉ះ	លុតជង្គង់	416	مكية	الجاثية
46	អាល់អះក៏ហ្វ	តំបន់អះក៏ហ្វ	419	مكية	الأحقاف
47	មូហាំម៉ាត់	ព្យាការីមូហាំម៉ាត់	423	مدنية	محمد

48	អាល់ហ្វាត់ហ៏	ជ័យជម្នះ	427	مدنية	الفتح
49	អាល់ហ៊ូជូរ៉ាត	ជញ្ជាំងខណ្ឌ	430	مدنية	الحجرات
50	កហ្វ	កហ្វ	432	مكية	ق
51	អាល់ហ្សារីយ៉ាត	ខ្យល់ដែលបក់បោកល្អងធូលី	435	مكية	الذاريات
52	អាត់តួរ	ភ្នំតួរ	439	مكية	الطور
53	អាន់ណាច់ម៏	ផ្កាយ	443	مكية	النجم
54	អាល់កមើរ	ព្រះចន្ទ	447	مكية	القمر
55	អាល់រ៉ោះម៉ាន	ម្ចាស់មហាសប្បុរស	451	مدنية	الرحمن
56	អាល់វ៉ាគីអះ	ថ្ងៃបរលោក	456	مكية	الواقعة
57	អាល់ហាទីត	ដែក	462	مدنية	الحديد
58	អាល់មូជើទើឡះ	ការជជែកគ្នា	465	مدنية	المجادلة
59	អាល់ហាស្ហ៏	ការចាកចេញ	468	مدنية	الحشر
60	អាល់មុមតាហ៊ីណះ	ការសាកល្បង	471	مدنية	الممتحنة
61	អាសស៏ហ្វ	ជួរ	473	مدنية	الصف
62	អាល់ជូមូអះ	ថ្ងៃសុក្រ	475	مدنية	الجمعة
63	អាល់មូណាហ្វីគូន	ពួកពុតត្បុត	476	مدنية	المنافقون
64	អាត់តាហ្គ៊ាពុន	ការខាតបង់	477	مدنية	التغابن
65	អាត់តឡាក	ការលែងលះ	479	مدنية	الطلاق
66	អាត់តះរីម	ការដាក់បម្រាម	481	مدنية	التحريم
67	អាល់មុលក៏	អធិបតេយ្យភាព	483	مكية	الملك
68	អាល់កឡាំ	ស្លាបប៉ាកកា	486	مكية	القلم
69	អាល់ហាកកោះ	ថ្ងៃបរលោក	490	مكية	الحاقة
70	អាល់ម៉ាអារិច	ភាពខ្ពង់ខ្ពស់	494	مكية	المعارج
71	នួហ	ព្យាការីនួហ	497	مكية	نوح
72	អាល់ជិន	ពួកជិន	499	مكية	الجن

73	អាល់មុសហ្សាំមិល	អ្នកដែលដណ្តប់ក្បួយ	502	مكية	المزمل
74	អាល់មុទហ្ទាសសៀរ	អ្នកដែលដណ្តប់ក្បួយ	504	مكية	المدثر
75	អាល់គីយ៉ាម៉ះ	ថ្ងៃបរលោក	508	مكية	القيامة
76	អាល់អ៊ិនសាន	មនុស្សលោក	511	مدنية	الإنسان
77	អាល់មួរស៊ីឡាត	ខ្យល់ដែលគេបញ្ជូនមក	513	مكية	المرسلات
78	អាន់ណាហ្កាក់	ដំណឹង	516	مكية	النبأ
79	អាន់ណាហ្ស៊ីអាត	ពួកទេវតាដកព្រលឹង	519	مكية	النازعات
80	អាហ្កាសា	មុខក្រញូវ	522	مكية	عبس
81	អាត់តឹកវៀរ	ការមូរ	525	مكية	التكوير
82	អាល់អ៊ិនហ្វីតរ	ការបំបែក	527	مكية	الانفطار
83	អាល់មូតហ្វីហ្វីន	ពួកកេងបន្លំ	529	مكية	المطففين
84	អាល់អ៊ិនស្តីកក	ការប្រេះបែក	532	مكية	الانشقاق
85	អាល់ពួរច	គន្លង	534	مكية	البروج
86	អាត់តរិក	ផ្កាយតរិក	536	مكية	الطارق
87	អាល់អាក់ឡា	ម្ចាស់ដ៏មហាខ្ពង់ខ្ពស់	538	مكية	الأعلى
88	អាល់ហ្គស្ស៊ីយ៉ះ	ថ្ងៃបរលោក	540	مكية	الغاشية
89	អាល់ហ្វាច់រ៍	ពេលទៀបភ្លឺ	542	مكية	الفجر
90	អាល់ហ្គាឡាត់	ស្រុកទេស	544	مكية	البلد
91	អាសស្សាំ	ព្រះអាទិត្យ	546	مكية	الشمس
92	អាល់ឡៃល៍	ពេលរាត្រី	547	مكية	الليل
93	អាត់ហ្វូហា	ពេលព្រឹក	549	مكية	الضحى
94	អាសួរស្ហើរហ៍	បើកទូលាយ	550	مكية	الشرح
95	អាត់ទីន	ផ្លែទីន	551	مكية	التين
96	អាល់អាឡឹក	តំណក់ឈាម	552	مكية	العلق
97	អាល់កទរ៍	យប់អាល់កទើរ	554	مكية	القدر

98	អាល់ហ្គៃយីណៈ	កស្តុតាងដ៏ច្បាស់លាស់	555	مدنية	البينة
99	អាល់ហ្សាល់ហ្សាឡះ	ការរញ្ជួយដី	556	مدنية	الزلزلة
100	អាល់អាទីយ៉ាត	សេះចម្បាំង	557	مكية	العاديات
101	អាល់ករីអះ	ពេលវេលាដែលធ្វើឱ្យដួងចិត្តភ័យញាប់ញ័រ	558	مكية	القارعة
102	អាត់តាកាស៊ួរ	ការមានមោទនភាព	559	مكية	التكاثر
103	អាល់អោសរ៍	ពេលរសៀល	560	مكية	العصر
104	អាល់ហ៊ូម៉ាហ្សះ	ការនិយាយមូលបង្កាច់	561	مكية	الهمزة
105	អាល់ហ្វីល	សត្វដំរី	562	مكية	الفيل
106	គូរ៉ស្ត	ពួកគូរ៉ស្ត	563	مكية	قريش
107	អាល់ម៉ាអូន	ការមិនជួយអ្នកជិតខែ	564	مكية	الماعون
108	អាល់ការសើរ	ទន្លេអាល់ការសើរ	565	مكية	الكوثر
109	អាល់កាហ្វីរូន	ពួកគ្មានជំនឿ	566	مكية	الكافرون
110	អាន់ណោសរ៍	ជំនួយ	567	مدنية	النصر
111	អាល់ម៉ាសាត់	ខ្សែប្រវ៉ាក់	568	مكية	المسد
112	អាល់អៀខ្លីស	ភាពជ្រះថ្លា	569	مكية	الإخلاص
113	អាល់ហ្វាឡឹក	ពេលទៀបភ្លឺ	570	مكية	الفلق
114	អាន់ណាស	មនុស្សលោក	571	مكية	الناس



المحتوى الإسلامي
The Islamic content

جمعية الربوة
Rabwa Association

9 786038 474129